# បករណ៍វិសេស ឈ្មោះ វិសុទ្ធិមគ្គ
# និង
# បរមត្ថមញ្ជូសាមហាដីកា
# បញ្ញានិទ្ទេស
# ភាគទី ២

ដឹកនាំបកប្រែដោយ
ខ្ញុំព្រះករុណា
អាត្មាភាព យង់ សុជាត

ថ្ងៃ ៨ កើត ខែពិសាខ ពុទ្ធសករាជ ២៥៥៥

# បករណ៍វិសេស ឈ្មោះ វិសុទ្ធិមគ្គ

# និង

# បរមត្ថមញ្ជូសាមហាដីកា

# បញ្ញានិទ្ទេស

# ភាគទី ២

ដឹកនាំបកប្រែដោយ

ខ្ញុំព្រះករុណា

អាត្មាភាព យង់ សុជាត

ថ្ងៃ ៨ កើត ខែពិសាខ ពុទ្ធសករាជ ២៥៥៥

*ផ្សព្វផ្សាយដោយសមាគមធម្មទានអរិយវង្សយង់សុជាត*

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**ក្រសួងមហាផ្ទៃ**

លេខ : ២២៥ សជណ

រាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែ តុលា ឆ្នាំ២០១០

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
## ពិតថេរដីកា
## ព្រះតេជគុណ យង់ សុផាត ប្រធានសមាគមធម្មទានអរិយវង្ស យង់ សុផាត

**កម្មវត្ថុ** : អំពីការសុំចុះបញ្ជីរបស់***សមាគមធម្មទានអរិយវង្សយង់ សុផាត*** នៅក្រសួងមហាផ្ទៃ ។

**យោង** : លិខិតលេខ***០១/១០ស.ធ.អ.យ.ផ*** ចុះថ្ងៃទី***២៣*** ខែ***តុលា*** ឆ្នាំ***២០០៩*** ស្តីពីការសុំចុះបញ្ជីរបស់***សមាគមធម្មទានអរិយវង្ស យង់ សុផាត*** ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំព្រះករុណាសូមពិតថេរដីកាព្រះតេជគុណប្រធានថា ក្រសួងមហាផ្ទៃយល់ព្រមចុះបញ្ជី***សមាគមធម្មទានអរិយវង្សយង់ សុផាត*** ដែលមានអាសយដ្ឋាននៃទីស្នាក់ការកណ្ដាលនៅភូមិ***រំចេក៣*** សង្កាត់***រតនៈ*** ក្រុង***បាត់ដំបង*** ខេត្ត***បាត់ដំបង*** នោះហើយ ។ ***សមាគមធម្មទានអរិយវង្សយង់ សុផាត*** ត្រូវអនុវត្តតាមលក្ខន្តិកៈដូចបានតម្កល់ទុកនៅក្រសួងមហាផ្ទៃ និងធ្វើសកម្មភាពការងារក្នុងក្របខ័ណ្ឌជាសមាគមអព្យាក្រឹត មិនប្រកាន់ពូជសាសន៍ មិនប្រកាន់សាសនា មិនប្រកាន់និន្នាការនយោបាយ មិនធ្វើសកម្មភាពបម្រើឱ្យគណបក្សនយោបាយ និងមិនធ្វើជាឧបករណ៍គណបក្សនយោបាយ ។

ក្រោយពីច្បាប់ស្ដីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលចូលជាធរមាន សមាគមធម្មទានអរិយវង្ស យង់ សុផាត ត្រូវដាក់ពាក្យសុំចុះបញ្ជីសាជាថ្មីអោយបានត្រឹមត្រូវតាមច្បាប់ ។

អាស្រ័យហេតុនេះ សូមព្រះតេជគុណប្រធានជ្រាបជាព័ត៌មាន ។

សូមព្រះតេជគុណប្រធាន ទទួលនូវការគោរពអំពីខ្ញុំព្រះករុណា ។

ស ខេង

***ចម្លងជូន :***
- ទីស្ដីការគណៈរដ្ឋមន្ត្រី
  “ដើម្បីជូនជ្រាប”
- សាលាខេត្តបាត់ដំបង
  “ដើម្បីមុខការ”
- ឯកសារ-កាលប្បវត្តិ

# និទានវចនៈ

*វិសុទ្ធិមគ្គ* ជាបករណ៍វិសេស ដែលព្រះថេរៈ អ្នកស្រុកជម្ពូទ្វីប មានឈ្មោះ ប្រោះសំឡេងមួយរូប បានរចនាឡើង កាលព្រះពុទ្ធសាសនាកន្លងទៅហើយបាន ប្រមាណ ១.០០០ ឆ្នាំ **នៅកោះលង្កាទ្វីប** ព្រះថេរៈរូបនេះ គឺព្រះពុទ្ធឃោសៈ ឯលោកក៏បានរចនាគម្ពីរទុកជាច្រើន នៅក្នុងបវរនៃព្រះពុទ្ធសាសនា ជាការងារ ដ៏ធំ និងជាមរតក រហូតមកដល់សព្វថ្ងៃ ។ ការប្រែ **គម្ពីរព្រះត្រៃបិដក អដ្ឋកថា** ពី **ភាសាសីហឡៈ** មកជា **ភាសាមគធៈ** ឬ **ភាសាបាលី** ព្រះពុទ្ធឃោសៈបាន ប្រមូលធម៌នៅក្នុងព្រះត្រៃបិដក មកសម្តែងទុកជាពួកៗ តាំងពី **សីល សមាធិ** និង **បញ្ញា** តាមលំដាប់ ។

ឯការរៀបរៀងជាការតែងសំណួរ ឬលំដាប់នៃការឆ្លើយសំណួរធម៌ក្នុង បច្ចុប្បន្ន គឺអធិប្បាយសេចក្តីសង្ខេបឲ្យពិស្តារ បទសំណួររបស់ **វិសុទ្ធិមគ្គ** ពោលដោយត្រៃសិក្ខា ដែលជាមាតិកាធំក្នុងព្រះពុទ្ធសាសនា បទសំណួរទាំង អស់ គឺជាបេះដូងនៃការបដិបត្តិតែម្យ៉ាង ព្រោះព្រះពុទ្ធឃោសៈ បានអធិប្បាយ ដោយវិចិត្រពិស្តារ និងមានរបៀបរៀបរយ បានអាងព្រះពុទ្ធវចនៈជាអាគតដ្ឋាន ទុកក្នុងទីនោះៗ ទូទៅ នេះសម្តែងឲ្យដឹងថា លោកមានការបែកធ្លាយក្នុងព្រះ ត្រៃបិដក អាចលើកយកធម៌ ដែលពោលដោយសីល មករួបរួមទុកក្នុងពួក សីល លើកយកធម៌ដែលទាក់ទងជាមួយសមាធិ មករួបរួមទុកក្នុងពួកសមាធិ លើកយកធម៌ដែលទាក់ទងជាមួយបញ្ញា មករួមទុកជាមួយពួកបញ្ញា ដោយ

បែកជានិទ្ទេសៗ រួមទាំងអស់មាន **២៣ និទ្ទេស**, រីឯប្រវត្តិនៃការតែងវិសុទ្ធិមគ្គ ក៏បានក្លាយជាការប្រឡងដេញដោល, ព្រោះព្រះថេរៈ ជាអ្នកស្រុកសីហឡៈ បានផ្ដើមបញ្ហាឲ្យលោកតែងជាមុន កាលបើលោកធ្វើបានជាទីពេញចិត្ត នឹងលើក **គម្ពីរអដ្ឋកថាភាសាសីហឡៈ** ឲ្យលោកប្រែជាភាសាមគធៈតទៅ ព្រះពុទ្ធឃោសាចារ្យបានធ្វើយ៉ាងរហ័ស និងល្អក្រៃលែង ជាទីពេញចិត្តរបស់ព្រះថេរៈអ្នកស្រុកសីហឡៈទាំងពួង, ដូច្នោះ **គម្ពីរវិសុទ្ធិមគ្គនេះ** ជាវិជ្ជានិពន្ធ ដើម្បីសាកល្បងចំណេះដឹងរបស់ព្រះពុទ្ធឃោសៈ ។

ព្រះពុទ្ធឃោសៈ មានដើមកំណើតនៅ **ប្រទេសឥណ្ឌា នាតំបន់ពុទ្ធគយា** បានសិក្សាជំនាញនៅក្នុងព្រះពុទ្ធវចនៈ ទ្រទ្រង់ព្រះត្រៃបិដក មានបញ្ញាដ៏ក្រៃលែង លោកបានធ្វើដំណើរទៅ **លង្កាទ្វីប** ក្នុងរវាងពុទ្ធសករាជ ៩៥០-១០០០ ហើយបានរចនាគម្ពីរវិសុទ្ធិមគ្គនៅទីនោះ និងប្រែ **ព្រះបាលីអដ្ឋកថា** ពីភាសាសីហឡៈ មកជាភាសាមគធៈ ( ភាសាបាលី ) ។

ព្រះថេរៈ មានឈ្មោះដែលគ្រូទាំងឡាយកាន់យកហើយថា **ពុទ្ធឃោសៈ** ជាអ្នកមានភាពបរិសុទ្ធបរិបូណ៌ ប្រដាប់ដោយសទ្ធា វិជ្ជា និងសេចក្ដីព្យាយាម ដ៏បរិសុទ្ធយ៉ាងក្រៃលែង ជាបុគ្គលរុងរឿងដោយធម៌ ជាហេតុកើតនៃសេចក្ដីល្អ មានសីលាចារៈទៀងត្រង់ និងការឱនលំទោនជាដើម អាចឈោងចុះកាន់ជជៈ គឺលទ្ធិរបស់ខ្លួន និងលទ្ធិរបស់បុគ្គលដទៃ ប្រកបដោយការមុតស្រួចនៃបញ្ញា មានចំណេះដឹង មិនទើសទាក់ក្នុងសត្ថុសាសនៈ ដោយបរិយត្តិផ្សេងៗ គឺព្រះ

ត្រៃបិដក ព្រមទាំង **អដ្ឋកថា** ជា មហាវេយ្យាករណ៍ ប្រកបដោយភាពវិចិត្រនៃពាក្យសម្ពី ទាំងទន់ភ្លន់ទូលំទូលាយ បន្ទឹចេញបានស្អាត់ជំនាញ សន្សំឲ្យកើតករណសម្បត្តិ មានវាទៈប្រសើរត្រឹមត្រូវ បុគ្គលជនទៃយល់បានងាយ ជាមហាកវី ហែហមដោយបដិសម្ភិទាដែលបែកធ្លាយ ជាអលង្ការនៃវង្ស ព្រះថេរៈដែលនៅក្នុងមហាវិហារទាំងឡាយ ដែលជាប្រទីបនៃថេរវង្ស មានការដឹងតាំងមាំល្អហើយ ក្នុង **ឧត្តរិមនុស្សធម្ម** ដែលប្រដាប់ដោយគុណផ្សេងៗ មាន **អភិញ្ញា ៦** ជាដើម ហែហមដោយ **បដិសម្ភិទា** បានរចនាវិសុទ្ធិមគ្គនេះចប់ហើយ ។

វិសុទ្ធិមគ្គនេះ តាំងនៅក្នុងលោក សម្ដែងន័យដល់កុលបុត្រទាំងឡាយដែលស្វែងរកធម៌ ជាគ្រឿងដកចេញនូវលោក ដរាបប៉ុនដែលព្រះនាមថា **ពុទ្ធោ** របស់ព្រះលោកជេដ្ឋៈ ដែលស្វែងរកគុណដ៏ធំ មានព្រះទ័យដ៏បរិសុទ្ធ ជាតាទិបុគ្គលប្រព្រឹត្តទៅក្នុងលោក ។

គម្ពីរវិសុទ្ធិមគ្គនេះបានរចនាដោយ

ព្រះពុទ្ធឃោសាចារ្យ

# ព្រះធម្មបាលត្ថេរ

## ព្រះថេរៈជាអ្នករចនា

## ព្រះគម្ពីរបរមត្ថមញ្ជូសាមហាដីកាវិសុទ្ធិមគ្គ

ខ្ញុំម្ចាស់ ( ព្រះធម្មបាលត្ថេរ ) ដែលព្រះទាឋនាគត្ថេរ ជាអ្នកមានសីល និងអាចារៈដល់ព្រមហើយ មានបញ្ញាជាគ្រឿងទ្រទ្រង់ មានការប្រព្រឹត្តបរិសុទ្ធ មានចិត្តតាំងមាំ អារាធនាហើយ ។ សូមថ្វាយវន្ទា ព្រះពុទ្ធជាម្ចាស់ប្រៀបដូចជាព្រះអាទិត្យ ទ្រង់មានព្រះសទ្ធម្មដូចជាកួងរស្មី ទ្រង់កម្ចាត់ងងឹត គឺមោហៈធំអស់ហើយ ទ្រង់ញុំាងពួកវេនេយ្យសត្វ ដែលប្រៀបដូចជាផ្កាឈូកឲ្យដឹងវិសេស ទ្រង់មានព្រះបញ្ញាគុណដ៏វិសេស ដូចដួងព្រះអាទិត្យ មានព្រះវិសុទ្ធិគុណ និងព្រះករុណាគុណ ដូចជាពន្លឺអរុណដែលមិនមានភាពសៅហ្មងរះឡើងក្នុងលោក គួរដល់ការបូជា សូមថ្វាយវន្ទាព្រះធម៌ដែលបំភ្លឺដល់លោករុងរឿងដោយរស្មី គឺព្រះគុណ និងសូមនមស្ការព្រះអរិយសង្ឃ ដែលដូចជាផ្កាឈូកបរិសុទ្ធហើយ ដោយតេជះនៃបុណ្យ ចំពោះការថ្វាយវន្ទាព្រះរតនត្រ័យដែលកើតឡើងហើយ ដោយប្រការនោះៗ សូមប្រាសចាកអន្តរាយក្នុងទីគ្រប់ស្ថាន ខ្ញុំម្ចាស់នឹងអាស្រ័យបោរាណកថាមគ្គ ដើម្បីពណ៌នាខ្លឹមសារនៃបករណ៍វិសេស ឈ្មោះ **វិសុទ្ធិមគ្គ** ដែលប្រដាប់ដោយន័យដ៏បរិសុទ្ធ មានលំដាប់បទយ៉ាងប្រណីត ដែលព្រះអាចារ្យពុទ្ធឃោសៈបានពោលដើម្បីជាឧបាយក្នុងការសម្រេចភាពបរិសុទ្ធិដែលលោកជា **នាថ** មានព្រះចរិយាបរិសុទ្ធ មានហឫទ័យ

ដែលព្រះករុណាឲ្យឧស្សាហ៍ហើយ លោកបានសម្រេចហើយ សម្ដែងទុកមិនឲ្យខុសពីលទ្ធិរបស់ព្រះថេរៈឯសម្នាក់មហាវិហារ ឲ្យបរិសុទ្ធយ៉ាងល្អ មិនរាត់រាយ មានវិនិច្ឆ័យសេចក្ដីដ៏សុខុម ឲ្យបរិសុទ្ធ និងប្រកបដោយរបៀបរៀបរយ ។

សូមសាធុជនទាំងឡាយ តាំងចិត្តសិក្សានូវខ្លឹមសារនៃព្រះវិសុទ្ធិមគ្គនេះ ឲ្យបានល្អ ខ្ញុំប្រាថ្នាឲ្យព្រះសទ្ធម្មតាំងនៅអស់កាលយូរ ដោយប្រការដូច្នេះចុះ ។

**ព្រះធម្មបាលត្ថេរ** ជាជនជាតិស្រីលង្កា លោកបានសិក្សានៅក្នុងសំណាក់ **មហាវិហារ** នាក្រុង **អនុរាធបុរៈ** ក្នុង **លង្កាទ្វីប** បានចូលរួមរចនា **គម្ពីរអដ្ឋកថា** ជាមួយព្រះពុទ្ធឃោសាចារ្យដែរ, លោកបានរចនាអដ្ឋកថា និងមហាដីកា ទើបបានទទួលការលើកសរសើរថាជា **ព្រះអដ្ឋកថាចារ្យ** និង **ព្រះដីកាចារ្យ** នៅ**កោះលង្កាទ្វីប** ក្នុងរវាងពុទ្ធសករាជ ៩៥០-១០០០ ។

គម្ពីរបរមត្ថមញ្ជូសាមហាដីកានេះរចនាដោយ

**ព្រះធម្មបាលត្ថេរ**

# អារម្ភកថា

ការបកប្រែរៀបរៀងឡើងនូវ **គម្ពីរវិសុទ្ធិមគ្គ** និង **បរមត្ថមញ្ជូសាមហាដីកា បញ្ញានិទ្ទេស ភាគ ២ នេះ** យើងខ្ញុំបានរៀបរៀងដោយល្អមកជាខេមរភាសា និងរៀបរៀងទៅតាមលំដាប់នៃមាតិកានីមួយៗ យ៉ាងផ្ចិតផ្ចង់បំផុត មិនឲ្យឃ្លៀងឃ្លាតពីច្បាប់ដើម ដើម្បីជាប្រយោជន៍ដល់កុលបុត្តអ្នកជ្រះថ្លាក្នុងព្រះរតនត្រ័យ និងជាពិសេសដើម្បីជាប្រយោជន៍ដល់ការសិក្សាផងខ្លួន ។

សូមសាធុជនទាំងឡាយ ដែលមានចិត្តភក្តីចំពោះព្រះរតនត្រ័យនោះ **អនុមោទនា** នូវបុណ្យរបស់ខ្ញុំ ដែលសម្រេចហើយដោយប្រការយ៉ាងនេះ ។

ចំពោះបុណ្យធម្មទាននេះ និងបុណ្យកុសលដទៃៗ ទៀត ដូចជាបុណ្យថ្នាក់ការសម្ដែងព្រះធម៌ នៅក្នុងកម្មវិធីបុណ្យផ្សេងៗ ទៅតាម **ខេត្ត ក្រុង** ជាច្រើន នៅក្នុងប្រទេសកម្ពុជានេះ ដោយខ្ញុំព្រះករុណា អាត្មាភាពបានសម្ដែងព្រះធម៌ នៅកន្លែងណាៗ ក៏តែងតែបានទុកដាក់ប្រាក់បូជាព្រះធម៌ នៅកន្លែងនោះវិញ គ្រប់ៗកន្លែង ដោយសរុបប្រាក់នៅក្នុង **ព.ស. ២៥៥០** ប្រាក់ខ្មែរបាន ១៨.៤៩៥០០០ រៀល ( ១៨ លាន ៤ សែន ៩ ម៉ឺន ៥ ពាន់រៀល ) និងប្រាក់ដុល្លារ **៦៤៥ ដុល្លារសហរដ្ឋអាមេរិក** ។ នៅបុណ្យកុសលមួយផ្នែកទៀត គឺបុណ្យដែលខ្ញុំព្រះករុណា អាត្មាភាព បានទៅថ្វាយបង្គំនៅពុទ្ធស្ថាននានានៅក្នុង **ប្រទេសឥណ្ឌា** ដែលមានពុទ្ធបរិស័ទទៅ **ប្រមាណ ៦៥ នាក់** ក្នុងនោះ ក៏មាន **ព្រះសង្ឃ ១០** ព្រះអង្គផងដែរ ដែលមានលោកគ្រូអគ្គបណ្ឌិត **ប៊ុត សាវង្ស** ជាប្រធាន ក្នុង

ការដឹកនាំគណៈធម្មយាត្រានោះ ដោយទៅថ្វាយបង្គំបាន ៥១ កន្លែង បានការឧបត្ថម្ភមកអំពីឧបាសក ឡាយ សុខុម និងឧបាសិកា ឱម លក្ខណា នៅក្នុង ព.ស. ២៥៥០ ( ១០.០២.២០០៧ ) ។

## នឹកឃើញស្រុកព្រះ

នឹកឃើញស្រុកព្រះ បានក្រាបសំពះ អង្គព្រះសាស្តា
សិរសាលំទោន ទុកដូចឈូកផ្កា បូជាសាស្តា
ជ្រះថ្លាក្រៃលែង ។
៦៥ អង្គា គាល់ព្រះភគវា ៥១ កន្លែង
នៅស្រុកឥណ្ឌា ចងចាំមិនលែង សោមនស្សពន់ពេក
ក្នុង ព.ស. ២៥៥០ ។

នៅមានបុណ្យកុសលនៅក្នុង ព.ស. ២៥៥១ ផ្នែកខាងសម្តែងព្រះធម៌ដូចគ្នានឹង ព.ស. ២៥៥០ ផងដែរ ដោយសរុបប្រាក់នៅក្នុង ព.ស. ២៥៥១ ប្រាក់ខ្មែរបាន ១៥.៨៣១០០០ រៀល ( ១៥ លាន ៨ សែន ៣ ម៉ឺន ១ ពាន់រៀល ) និងប្រាក់ដុល្លារ ៤៥ ដុល្លារ ។ នៅបុណ្យកុសលមួយផ្នែកទៀត គឺបុណ្យកុសល ដែលខ្ញុំព្រះករុណា អាត្មាភាព បានទៅថ្វាយបង្គំនៅពុទ្ធស្ថាននានា នៅក្នុង ប្រទេសស្រីលង្កា ដែលមានលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ជាប្រធាន ក្នុងការដឹកនាំគណៈធម្មយាត្រានោះ ដែលមានពុទ្ធបរិស័ទទៅប្រមាណ

១២១ នាក់ ក្នុងនោះ ក៏មាន ព្រះសង្ឃ ៤ ព្រះអង្គផងដែរ ដោយទៅថ្វាយបង្គំបាន ១៩ កន្លែង បានការជួយជ្រោមជ្រែងឧបត្ថម្ភអំពីឧបាសក ឡាយ សុខុម និងឧបាសក សោម រតនៈ ឧបាសិកា ស៊ិប វណ្ណា នៅក្នុង ព.ស. ២៥៥១ ( ០៤.០៤.២០០៨ ) ។

## នឹកឃើញលង្កា

| | | |
|---|---|---|
| នឹកឃើញលង្កា | នឹកឃើញកាលណា | ជ្រះថ្លាក្រៃលែង |
| នៅពុទ្ធស្ថាន | ១៩ កន្លែង | ដែលខ្ញុំបានស្វែង |
| | ទៅថ្វាយបង្គំ ។ | |
| ១២១ អង្គា | គាល់ព្រះបាទា | នាស្ថានមនោរម |
| លើសុមនកូដ | ជេស្ឋាឧត្តម | ជាកំពូលភ្នំ |
| | ក្នុងប្រវត្តិពុទ្ធ ។ | |
| ទឹកដីលង្កា | ទឹកដីអស្ចារ្យ | ពេញពោរដោយឫទ្ធិ |
| នឹកឃើញកាលណា | ជ្រះថ្លាក្រៃពិត | ធម្មយាត្រាប្រណីត |
| | ក្នុង ព.ស. ២៥៥១ ។ | |

នៅមានបុណ្យកុសលនៅក្នុង ព.ស. ២៥៥២ ផ្នែកខាងសម្តែងព្រះធម៌ដូចគ្នានឹង ព.ស. ២៥៥១ ផងដែរ ដោយសរុបប្រាក់នៅក្នុង ព.ស. ២៥៥២ ប្រាក់ខ្មែរបាន ២៧.១២៨០០០ រៀល ( ២៧ លាន ១ សែន ២ ម៉ឺន ៨ ពាន់

វៀល ) និងប្រាក់ដុល្លារ ១៩៥ ដុល្លារ ។ នៅបុណ្យកុសលមួយផ្នែកទៀត គឺ បុណ្យកុសល ដែលខ្ញុំព្រះករុណា អាត្មាភាព បានទៅថ្វាយបង្គំនៅពុទ្ធស្ថាននានា នៅក្នុង ប្រទេសឥណ្ឌាជាលើកទីពីរ ដែលមានលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស មានលោកគ្រូធម្មបណ្ឌិត រស់ សុផាត និងលោកគ្រូធម្មាចារ្យ អឿ សៅ ជាប្រធាន ក្នុងការដឹកនាំគណៈធម្មយាត្រានោះ ដែលមានពុទ្ធបរិស័ទទៅប្រមាណ ៦៧ នាក់ ក្នុងនោះ ក៏មាន ព្រះសង្ឃ ៥ ព្រះអង្គផងដែរ បានការឧបត្ថម្ភមក អំពីឧបាសក យឹត សូណាត ឧបាសិកា ហ៊ុន ម៉ារ៉ានី M.SUSOKUNORAetMmeINN VISAL + NARITA et RAKSA. ក្រោមការជ្រោមជ្រែងរបស់ឧបាសិកា អ៊ុំង រិទ្ធារី ឧបាសិកា ស៊ួន កល្យាណ ឧបាសិកា ស៊ួន ចរណៃ នៅក្នុង ព.ស. ២៥៥២ ( ១៦.០២.២០០៩ ) ។

## ជ្រះថ្លាខ្លាំងណាស់

ជ្រះថ្លាខ្លាំងណាស់ ព្រះពុទ្ធជាម្ចាស់ គុណធំក្រៃលែង
ច្រើនពុទ្ធសកការជ សាសនាអង្វែង ល្អហួសការថ្លែង
ឱ ! ព្រះសាសនា ។
នៅស្រុកឥណ្ឌា ៦៧ អង្គា រួមគ្នាទមស្ការ
១០៩ ពុទ្ធស្ថាន ព្រមចិត្តផ្ចង់ថ្វា បីតិអស្ចារ្យ
ក្នុង ព.ស. ២៥៥២ ។

នៅមានបុណ្យកុសលមួយផ្នែកទៀត គឺបុណ្យកុសល ដែលខ្ញុំព្រះករុណា អាត្មាភាព បានទៅថ្វាយបង្គំនៅពុទ្ធស្ថានផ្សេងៗ នៅក្នុង **ប្រទេសស្រីលង្កាជាលើកទី ២** ដែលមានលោកគ្រូធម្មបណ្ឌិត **រស់ សុផាត** ជាប្រធាន ក្នុងការដឹកនាំគណៈធម្មយាត្រានោះ ដែលមានពុទ្ធបរិស័ទទៅប្រមាណ **៣៦ នាក់** នៅក្នុងនោះទៀត ក៏មាន **ព្រះសង្ឃ ៣** ព្រះអង្គផងដែរ បានការឧបត្ថម្ភមកអំពីឧបាសក **ឆាយ អ៊ីវស៊ាង** ឧបាសិកា **ហុង គឹមសែ** ក្រោមការជ្រោមជ្រែងរបស់ឧបាសក **យន្ត សួន** នៅក្នុង **ព.ស. ២៥៥២** ( ១១.០៣.២០០៩ ) ។

នៅមានបុណ្យកុសលនៅក្នុង **ព.ស. ២៥៥៣** ផ្នែកខាងសម្តែងព្រះធម៌ដូចគ្នានឹង **ព.ស. ២៥៥២** ដែរ ដោយសរុបប្រាក់នៅក្នុង **ព.ស. ២៥៥៣** ប្រាក់ខ្មែរបាន ១៣.០៨០០០០ រៀល ( **១៣ លាន ០ សែន ៨ ម៉ឺន** ) និងប្រាក់ដុល្លារ **២០៨ ដុល្លារ** ។ នៅបុណ្យកុសលមួយផ្នែកទៀត គឺបុណ្យកុសលដែលខ្ញុំព្រះករុណា អាត្មាភាព បានទៅថ្វាយបង្គំនៅពុទ្ធស្ថាននានានៅក្នុង **ប្រទេសឥណ្ឌាជាលើកទី ៣** ដែលមានលោកគ្រូអគ្គបណ្ឌិត **ប៊ុត សាវង្ស** ជាប្រធានក្នុងការដឹកនាំគណៈធម្មយាត្រានោះ ដែលមានពុទ្ធបរិស័ទទៅប្រមាណ **១១១ នាក់** ក្នុងនោះ ក៏មាន **ព្រះសង្ឃ ៦** ព្រះអង្គផងដែរ ដោយទៅថ្វាយបង្គំបាន **៩៦ កន្លែង** បានការជ្រោមជ្រែងអំពីឧបាសក **ឡាយ សុខុម** នៅក្នុង **ព.ស. ២៥៥៣** ( ២៥.០១.២០១០ ) ។

# ស្រណោះស្រុកព្រះ

ស្រណោះស្រុកព្រះ ធ្លាប់តែល្អល្អះ ឥឡូវអនិច្ចា !
យើងខ្ញុំទាំងឡាយ បានទៅនមស្ការ ស្ងប់ស្ងែងអស្ចារ្យ
ឱះ ឱ ! ពុទ្ធស្ថាន ។
នឹកឃើញកាលណា ចិត្តខ្ញុំជ្រះថ្លា គ្មានអ្វីប្រៀបបាន
១១១ អង្គា ៩៦ ពុទ្ធស្ថាន ព.ស.រាប់បាន
២៥៥៣ ។

នៅមានបុណ្យកុសលនៅក្នុង ព.ស. ២៥៥៤ ផ្នែកខាងសម្តេចព្រះធម៌ ដូចគ្នានឹង ព.ស. ២៥៥៣ ដែរ ដោយសរុបប្រាក់នៅក្នុង ព.ស. ២៥៥៤ ប្រាក់ខ្មែរបាន ៣១.៩៩០០០០ រៀល ( ៣១ លាន ៩ សែន ៩ ម៉ឺន ) និងប្រាក់ដុល្លារ ៧២០ ដុល្លារ ។ នៅបុណ្យកុសលមួយផ្នែកទៀត គឺបុណ្យកុសលដែលខ្ញុំព្រះករុណា អាត្មាភាព បានទៅថ្វាយបង្គំនៅពុទ្ធស្ថាននានានៅក្នុង ប្រទេសឥណ្ឌាជាលើកទី ៤ ដែលមានលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ជាប្រធានក្នុងការដឹកនាំគណៈធម្មយាត្រានោះ ដែលមានពុទ្ធបរិស័ទទៅប្រមាណ ១១១ នាក់ ក្នុងនោះ ក៏មាន ព្រះសង្ឃ ៥ ព្រះអង្គផងដែរ ដោយទៅថ្វាយបង្គំបាន ៩៦ កន្លែង បានការជ្រោមជ្រែងមកពីឧបាសក ឡាយ ស៊ុខុម នៅក្នុង ព.ស. ២៥៥៤ ( ២៧.០២.២០១១ ) ។

## គួរឲ្យសង្វេគ

គួរឲ្យសង្វេគ ស្រណោះពន់ពេក ពេលឃើញពុទ្ធស្ថាន
ធ្លាប់តែរុងរឿង ចម្រើនថ្កើងថ្កាន ឥឡូវប្រែប្រាន
ប្រៀបបានព្រៃស្ងាត់ ។

២៧៧ អង្គា ប្រណម្យវន្ទា បង្គំថ្វាយថ្វាត់
បូជនីយដ្ឋាន ១២ នាដែនពុទ្ធវត្ថុ ធម្មយាត្រាកំណត់
ក្នុងពុទ្ធសករាជ ២៥៥៤ ។

នៅមានបុណ្យកុសលនៅក្នុង ព.ស. ២៥៥៥ ផ្នែកខាងសម្តែងព្រះធម៌ដូចគ្នានឹង ព.ស. ២៥៥៤ ដែរ ដោយសរុបប្រាក់នៅក្នុង ព.ស. ២៥៥៥ ប្រាក់ខ្មែរបាន ៣៥,២៨២០០០ រៀល ( ៣៥ លាន ២ សែន ៨ ម៉ឺន ២ ពាន់រៀល ) និងប្រាក់ដុល្លារ ២៧៥៨ ដុល្លារ ។ នៅបុណ្យកុសលមួយផ្នែកទៀត គឺបុណ្យដែលខ្ញុំព្រះករុណា អាត្មាភាព បានទៅថ្វាយបង្គំនៅពុទ្ធស្ថាននានានៅក្នុងប្រទេសឥណ្ឌា ជាលើកទី ៥ ដែលមានលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ជាប្រធាន ក្នុងការដឹកនាំគណៈធម្មយាត្រានោះ ដែលមានពុទ្ធបរិស័ទទៅប្រមាណ ៦៨ នាក់ ក្នុងនោះ ក៏មាន ព្រះសង្ឃ ៥ ព្រះអង្គផងដែរ ដោយទៅថ្វាយបង្គំបាន ១៤ កន្លែងធំៗ បានការជ្រោមជ្រែងមកពីឧបាសិកា អ៊ឹង រិទ្ធារី នៅក្នុង ព.ស. ២៥៥៥ ( ០២.០២.២០១២ ) ។

នៅមានបុណ្យកុសលមួយផ្នែកទៀត គឺបុណ្យកុសល ដែលខ្ញុំព្រះករុណា អាត្មាភាព បានទៅថ្វាយបង្គំនៅពុទ្ធស្ថានផ្សេងៗ នៅក្នុង ប្រទេសស្រីលង្កាជា លើកទី ៣ ដែលមានលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ជាប្រធាន ក្នុងការ ដឹកនាំគណៈធម្មយាត្រានោះ ដែលមានពុទ្ធបរិស័ទទៅប្រមាណ ១៤០ នាក់ នៅក្នុងនោះទៀត ក៏មាន ព្រះសង្ឃ ៥ ព្រះអង្គផងដែរ ដោយទៅថ្វាយបង្គំ បាន ៩ កន្លែងធំៗ បានការឧបត្ថម្ភមកអំពីឧបាសិកា អ៊ឹង រិទ្ធារី នៅក្នុង ព.ស. ២៥៥៥ ( ២៧.០៣.២០១២ ) ។

## បានយល់ស្រុកព្រះ

| | | |
|---|---|---|
| ជ្រះថ្លាខ្លាំងណាស់ | បានយល់ស្រុកព្រះ | ជាតិភូមិសាស្តា |
| ១៤ កន្លែង | ៦៨ អង្គា | បានក្រាបវន្ទា |
| | បូជាគ្រប់ប្រាណ ។ | |
| សិរីលង្កា | ១៤០ អង្គា | ៩ ពុទ្ធស្ថាន |
| ជ្រះថ្លាខ្លាំងណាស់ | ដែលពួកខ្ញុំបាន | នមស្ការពុទ្ធស្ថាន |
| | ក្នុងពុទ្ធសករាជ ២៥៥៥ ។ | |

ហេតុដូច្នេះ ដោយបុណ្យកុសលនេះ ខ្ញុំព្រះករុណា សូមឧទ្ទិសមហា កុសលទាំងអស់នេះ ជូនចំពោះញោមប្រុស យង់ សុង ( ស្លាប់ ) និងញោម ស្រី ឈឹម ហយ ( ស្លាប់ ) មួយ៉ាងទៀត ញាតិកានៅក្នុងសង្សារវដ្ត ជាពិសេស

នោះ សូមលើកមហាកុសលទាំងអស់នេះ ជូនចំពោះលោកគ្រូអគ្គបណ្ឌិត **ប៊ុត សាវង្ស** លោកគ្រូធម្មបណ្ឌិត **រស់ សុផាត** និងលោកគ្រូធម្មាចារ្យ **គាំ អ៊ីវ** ជាដើម សូមឲ្យបានទួវចំណែកបុណ្យកុសលនេះស្មើនឹងអាត្មាភាពផងដែរ សូម**អនុមោទនា !!!** ក៏សូមឲ្យមិត្តអ្នកកំពុងតែកាន់សៀវភៅនេះអាន ឲ្យបានបុណ្យកុសលនៃធម្មទាននេះគ្រប់ៗគ្នា សូមអនុមោទនានូវចំណែកនៃបុណ្យកុសលនេះ ឲ្យបានស្មើនឹងខ្ញុំព្រះករុណា អាត្មាភាពផងដែរ ។

ម្យ៉ាងទៀត ដោយអំណាចបុណ្យកុសលទាំងអស់នេះ ក៏សូមឲ្យបានជាឧបនិស្ស័យ ក្នុងការអស់ទៅនៃអាសវក្កិលេស នាកាលជាអនាគត កុំបីអាក់ខានឡើយ ( **សូមឲ្យបានជាសាវកបារមីញាណ ក្នុងសាសនានៃព្រះសម្មាសម្ពុទ្ធអង្គណានីមួយ ដែលជាឯតទគ្គៈផ្នែកខាងពហូសូត ១ មានសតិ ១ មានគតិ ១ មានធិតិ ១ ជាពុទ្ធុបដ្ឋាក ១** ) សូមឲ្យព្រះពុទ្ធសាសនារុងរឿងចម្រើន សូមឲ្យព្រះពុទ្ធសាសនាផ្សាយទូទៅពេញសកលលោក សូមឲ្យលោកទាំងមូលបានប្រកបដោយសន្តិភាព ព្រះសក្យមុនីសម្ពុទ្ធទ្រង់ត្រាស់ថា **នត្ថិ សន្តិ បរំ សុខំ** ពុំមានសេចក្តីសុខដទៃ ក្រៅអំពីសេចក្តីស្ងប់ឡើយ ។

អាស្រមព្រះគន្ធកុដិ ថ្ងៃ ៨ កើត ខែពិសាខ ព.ស. ២៥៥៥
ផ្សព្វផ្សាយដោយសមាគមធម្មទានអរិយវង្សយង់សុផាត

# ឈ្មោះអ្នកជួយប្រែ និងពិនិត្យអក្ខរាវិរុទ្ធ

លោកអ្នកដ៏មានអាយុ ម៉ី សាលួន ជួយវាយកុំព្យូទ័រ

លោកអ្នកដ៏មានអាយុ សៀង កុសល ជួយវាយកុំព្យូទ័រ

លោកអ្នកដ៏មានអាយុ គឹម ម៉ានិត ជួយប្រែ

លោកអ្នកដ៏មានអាយុ ម៉ុន បូរ៉ា ជួយវាយកុំព្យូទ័រ

លោកអ្នកដ៏មានអាយុ អ៊ឹម សុជាន ជួយប្រែ

លោកអ្នកដ៏មានអាយុ មាន វណ្ណនា ជួយវាយកុំព្យូទ័រ

លោកអ្នកដ៏មានអាយុ ពេជ្រ ឧត្តម ជួយវាយកុំព្យូទ័រ

ឧបាសក អ៊ឹម រ៉ៃយ៉ា ជួយពិនិត្យអក្ខរាវិរុទ្ធ

ឧបាសក ឡាន សុខុម ជួយប្រែ

ឧបាសក ជិម ជំនិត ជួយពិនិត្យអក្ខរាវិរុទ្ធ

ឧបាសក បូ ស៊ីផូ ជួយពិនិត្យអក្ខរាវិរុទ្ធ

# សមាជិកសមាគមធម្មទានអរិយវង្សយង់សុផាត

សម្តេចព្រះសង្ឃរាជគណមហានិកាយ នន្ទ ង៉ែត ជាប្រធានកិត្តិយស

ភិក្ខុ អគ្គបណ្ឌិតោ យង់ សុផាត ជាប្រធានសមាគម

លោកអភិបាលស្រុក ស្រេង ស្រ៊ាង ជាទីប្រឹក្សាសមាគម

ឧបាសក អ៊ឹម វ៉ៃយ៉ា ជាអនុប្រធានសមាគម

ឧបាសិកា ង៉ែត យូអេង ជាអនុប្រធានសមាគម

សាមណេរ ម៉ី សាលួន ជាលេខាធិការ

ឧបាសក ឡាន សុខុម ជាលេខាធិការរង

ឧបាសិកា តាំង ប៉េងជីង ជាហេរញ្ញិក

ឧបាសិកា ជា នាង ជាបេឡា

លោកគ្រូធម្មបណ្ឌិត អឿ សៅ សមាជិកកិត្តិយស និងឧបការគុណ

ឧបាសក ឡាយ សុខុម សមាជិកកិត្តិយស និងឧបការគុណ

ឧបាសិកា អ៊ឹង រិទ្ធារី សមាជិកកិត្តិយស និងឧបការគុណ

ឧបាសិកា ហោ ភាព សមាជិកកិត្តិយស និងឧបការគុណ

ឧបាសិកា គួ ប៊ុនគាង សមាជិកកិត្តិយស និងឧបការគុណ

ឧបាសិកា ឈុំ គីមហួយ សមាជិកកិត្តិយស និងឧបការគុណ

| | |
|---|---|
| ឧបាសិកា ប៉ែន រមណីយ | សមាជិកកិត្តិយស និងឧបការគុណ |
| ឧបាសិកា ឱម លក្ខណា | សមាជិកកិត្តិយស និងឧបការគុណ |
| ឧបាសក អ៊ឹង ប៊ុនហួរ | សមាជិកកិត្តិយស និងឧបការគុណ |
| ឧបាសិកា ប៊ូ ម៉ាឡា | សមាជិកកិត្តិយស និងឧបការគុណ |
| ឧបាសក ប៊ុន ហេង | សមាជិកកិត្តិយស និងឧបការគុណ |
| ឧបាសិកា ជុំ សុខុម | សមាជិកកិត្តិយស និងឧបការគុណ |
| ឧបាសិកា មាស ម៉ូនីកា | សមាជិកកិត្តិយស និងឧបការគុណ |
| ឧបាសិកា ឡឹក ពេញចិត្ត | សមាជិកកិត្តិយស និងឧបការគុណ |
| ឧបាសិកា សៀក ឆាយគីម | សមាជិកកិត្តិយស និងឧបការគុណ |
| ឧបាសក បញ្ញា | សមាជិកកិត្តិយស និងឧបការគុណ |
| ឧបាសិកា កែវ កល្យាណ | ជាសមាជិកសកម្ម |
| ឧបាសិកា ឡេង ធីតា | ជាសមាជិកសកម្ម |
| ឧបាសិកា ម៉ៅ នី | ជាសមាជិកសកម្ម |
| ឧបាសិកា ហេង ចន្ទបុញ្ញាវតី | ជាសមាជិកសកម្ម |
| ឧបាសក ហុង សុវណ្ណារិទ្ធ | ជាសមាជិកសកម្ម |
| ឧបាសក ហុង សុវណ្ណារ៉េត | ជាសមាជិកសកម្ម |

# មាតិកាធម៌


| មាតិកា | លេខទំព័រ |
|---|---|
| បដិច្ចសមុប្បាទ ........................................................ | ១ |
| អធិប្បាយ បដិច្ចសមុប្បាទ .................................... | ៣០ |
| បទថា អវិជ្ជា ........................................................ | ៩១ |
| អធិប្បាយ បទថា អវិជ្ជា ........................................ | ៩៦ |
| បច្ច័យ ២៤ .......................................................... | ១១៤ |
| អធិប្បាយ បច្ច័យ ២៤ ............................................ | ១៣៤ |
| អវិជ្ជាជាបច្ច័យច្រើនប្រការ ...................................... | ១៧៩ |
| អធិប្បាយ អវិជ្ជាជាបច្ច័យច្រើនប្រការ ...................... | ១៨៩ |
| បទថា សង្ខារប្បច្ចយា វិញ្ញាណំ ................................ | ១៩៨ |
| អធិប្បាយ បទថា សង្ខារប្បច្ចយា វិញ្ញាណំ ............... | ២២៥ |
| បទថា វិញ្ញាណប្បច្ចយា នាមរូបំ ............................... | ២៦៩ |
| អធិប្បាយ បទថា វិញ្ញាណប្បច្ចយា នាមរូបំ .............. | ២៧៧ |
| បទថា នាមរូបប្បច្ចយា សឡាយតនំ ......................... | ២៨៣ |
| អធិប្បាយ បទថា នាមរូបប្បច្ចយា សឡាយតនំ ........ | ២៩០ |
| បទថា សឡាយតនប្បច្ចយា ផស្សោ ......................... | ២៩៥ |
| អធិប្បាយ បទថា សឡាយតនប្បច្ចយា ផស្សោ ........ | ២៩៩ |

បទថា ផស្សប្បច្ចយា វេទនា .................................... ៣០២

អធិប្បាយ បទថា ផស្សប្បច្ចយា វេទនា .................... ៣០៤

បទថា វេទនាបច្ចយា តណ្ហា .................................... ៣០៦

អធិប្បាយ បទថា វេទនាបច្ចយា តណ្ហា ..................... ៣០៩

បទថា តណ្ហាបច្ចយា ឧបាទានំ .................................. ៣១៣

អធិប្បាយ បទថា តណ្ហាបច្ចយា ឧបាទានំ ................. ៣២០

បទថា ឧបាទានប្បច្ចយា ភវោ .................................. ៣២៧

អធិប្បាយ បទថា ឧបាទានប្បច្ចយា ភវោ ................. ៣៣៨

បទថា ភវប្បច្ចយា ជាតិ .......................................... ៣៤៧

អធិប្បាយ បទថា ភវប្បច្ចយា ជាតិ .......................... ៣៤៩

ភវចក្រ ................................................................. ៣៥១

អធិប្បាយ ភវចក្រ .................................................. ៣៧៣

ទិដ្ឋិវិសុទ្ធិ ............................................................ ៤០១

អធិប្បាយ ទិដ្ឋិវិសុទ្ធិ .............................................. ៤០៩

អរូបធម៌ប្រាកដដោយអាការ ៣ ................................. ៤២១

អធិប្បាយ អរូបធម៌ប្រាកដដោយអាការ ៣ ................. ៤២៥

អរូបធម៌ប្រាកដដោយវិញ្ញាណ ( ត ) ........................ ៤៣៧

អធិប្បាយ អរូបធម៌ប្រាកដដោយវិញ្ញាណ ( ត ) ....... ៤៣៨

អរូបធម៌ប្រាកដដោយវិញ្ញាណ ( ត ) ...................... ៤៤០

អធិប្បាយ អរូបធម៌ប្រាកដដោយវិញ្ញាណ ( ត ) ....... ៤៤៧

កង្ខាវិតរណវិសុទ្ធិ ...................................................... ៤៥៧

អធិប្បាយកង្ខាវិតរណវិសុទ្ធិ ....................................... ៤៧១

# បករណ៍វិសេស ឈ្មោះ វិសុទ្ធិមគ្គ

## បញ្ញាភូមិនិទ្ទេស

## បដិច្ចសមុប្បាទ

ព្រោះហេតុក្នុងធម៌ទាំងឡាយ ដែលជាភូមិនៃបញ្ញានេះ លោកពោលទុកថា ធម៌ទាំងឡាយមានខន្ធ អាយតនៈ ធាតុ ឥន្ទ្រិយ និងបដិច្ចសមុប្បាទជាដើម ជាភូមិ (នៃបញ្ញា) ដូច្នេះ បដិច្ចសមុប្បាទ និងបដិច្ចសមុប្បន្នធម៌ទាំងឡាយ ដែលរួមចូលទុកដោយអាទិស័ព្ទ នៅសេសសល់ ( នៅមិនទាន់បានពណ៌នា ) ព្រោះហេតុនោះ ឥឡូវនេះទើបដល់លំដាប់នៃសំវណ្ណនាបដិច្ចសមុប្បាទ និងបដិច្ចសមុប្បន្នធម៌ទាំងឡាយនោះ ។

ក្នុងធម៌ទាំង ២ យ៉ាងនោះ ធម៌ទាំងឡាយ មានអវិជ្ជាជាដើម គប្បីជ្រាបថា ឈ្មោះថា បដិច្ចសមុប្បាទ ជាលំដាប់ដំបូង ។ ពិតណាស់ ពាក្យនេះព្រះមានព្រះភាគបានត្រាស់ទុកថា ម្នាលភិក្ខុទាំងឡាយ បដិច្ចសមុប្បាទ តើដូចម្តេច ? ម្នាលភិក្ខុទាំងឡាយសង្ខារទាំងឡាយមានព្រោះបច្ច័យគឺអវិជ្ជា វិញ្ញាណមានព្រោះបច្ច័យសង្ខារ នាមរូបមាន ព្រោះបច្ច័យ គឺវិញ្ញាណ សឡាយតនៈមាន ព្រោះបច្ច័យ គឺនាមរូប ផស្សៈមាន ព្រោះបច្ច័យ គឺសឡាយតនៈ វេទនាមាន ព្រោះបច្ច័យ គឺផស្សៈ តណ្ហាមាន ព្រោះបច្ច័យ គឺវេទនា ឧបាទានមាន ព្រោះបច្ច័យ គឺតណ្ហា ភពមាន ព្រោះបច្ច័យ គឺឧបាទាន ជាតិមាន ព្រោះបច្ច័យ គឺភព ជរាមរណៈ សោក បរិទេវៈ ទុក្ខ ទោមនស្ស ឧបាយាស មានព្រោះបច្ច័យ គឺជាតិ ការកើតឡើងនៃកងទុក្ខទាំងអម្បាលមាននោះរមែងមានដូច្នេះ ម្នាលភិក្ខុទាំងឡាយ នេះហៅថា បដិច្ចសមុប្បាទ ។

ចំណែកធម៌ទាំងឡាយ មានជរាមរណៈជាដើម គប្បីជ្រាបថា ឈ្មោះថា បដិច្ចសមុប្បន្នធម៌ ។ ពិតហើយ ពាក្យនេះ ព្រះសាស្តាក៏បានត្រាស់ទុកថា ម្នាលភិក្ខុ

ទាំងឡាយ បដិច្ចសមុប្បន្នធម៌ទាំងឡាយ តើដូចម្តេច ? ម្នាលភិក្ខុទាំងឡាយ ជរាមរណៈ ជាធម៌មិនទៀង ជាធម៌មានបច្ច័យតាក់តែងឡើង ជាបដិច្ចសមុប្បន្ន ( អាស្រ័យបច្ច័យកើតឡើង ) ជាធម៌មានការអស់ទៅជាធម្មតា មានការសាបសូន្យទៅជាធម្មតា មានការប្រែប្រួលទៅជាធម្មតា មានការរលត់ទៅជាធម្មតា ម្នាលភិក្ខុទាំងឡាយ ជាតិ... ភព... ឧបាទាន... តណ្ហា... វេទនា... ផស្សៈ... សឡាយតនៈ... នាមរូប... វិញ្ញាណ... សង្ខារ... អវិជ្ជា... ជាធម៌មិនទៀង ជាធម៌មានបច្ច័យតាក់តែងឡើង ជាបដិច្ចសមុប្បន្ន ( អាស្រ័យបច្ច័យកើតឡើង ) ជាធម៌មានការអស់ទៅជាធម្មតា មានការវិនាសទៅជាធម្មតា មានការប្រែប្រួលទៅជាធម្មតា មានការរលត់ទៅជាធម្មតា ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងនេះហៅថា បដិច្ចសមុប្បន្នធម៌ ដូច្នេះ ។

## អត្ថរបស់ពាក្យបដិច្ចសមុប្បាទ

ចំណែកសេចក្តី ( តទៅ ) នេះ ជាអត្ថសង្ខេបក្នុងបដិច្ចសមុប្បាទ និងបដិច្ចសមុប្បន្នធម៌នោះ

ធម៌ដែលជាបច្ច័យទាំងឡាយ គប្បីជ្រាបថា ឈ្មោះថា បដិច្ចសមុប្បាទ ធម៌ដែលកើតព្រោះបច្ច័យទាំងឡាយនោះៗ គប្បីជ្រាបថា ឈ្មោះថា បដិច្ចសមុប្បន្នធម៌ បើមានពាក្យសួរថា សេចក្តីនេះគប្បីជ្រាបបានដូចម្តេច ? គប្បីឆ្លើយថា ជ្រាបបានដោយព្រះតម្រាស់របស់ព្រះមានព្រះភាគ ។ ពិតហើយ ព្រះមានព្រះភាគ កាលទ្រង់សម្តែងបដិច្ចសមុប្បាទនៅក្នុងព្រះសូត្រ ដែលពោលដោយការសម្តែងបដិច្ចសមុប្បាទ និងបដិច្ចសមុប្បន្នធម៌ទុកដូច្នេះថា ម្នាលភិក្ខុទាំងឡាយ បដិច្ចសមុប្បាទ តើដូចម្តេច ? ម្នាលភិក្ខុទាំងឡាយ ជរាមរណៈ មានព្រោះបច្ច័យ គឺជាតិ ព្រោះការកើតឡើងនៃព្រះតថាគតក៏ដោយ ព្រោះការមិនកើតឡើងនៃព្រះតថាគតក៏ដោយ ធាតុនោះ **ធម្មដ្ឋិតតា**

(ការតាំងនៅជាធម្មតា) នោះ **ធម្មនិយាមតា** (ការប្រាកដជាធម្មតា) នោះ **ឥទប្បច្ចយតា** ( ការដែលវត្ថុនេះជាបច្ច័យរបស់វត្ថុនេះ ) នោះ ក៏គង់តាំងនៅនោះឯង តថាគតដឹងដល់ធាតុនោះ កាលដឹងដល់ហើយ ទើបសម្តែងប្រាប់ ទើបបញ្ញត្តតែងតាំង បើកបង្ហាញ ចែកចេញធ្វើឲ្យងាយឡើង អ្នកទាំងឡាយចូរមើលចុះ ដូច្នេះជាដើម និងត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ជរាមរណៈ មានព្រោះបច្ច័យ គឺជាតិ ជាតិមាន ព្រោះបច្ច័យ គឺភព ។បេ។ សង្ខារទាំងឡាយមាន ព្រោះបច្ច័យ គឺអវិជ្ជា ព្រោះការកើតឡើងនៃព្រះតថាគតក៏ដោយ ព្រោះការមិនកើតឡើងនៃព្រះតថាគតក៏ដោយ ។បេ។ ចែកចេញធ្វើឲ្យងាយឡើង អ្នកទាំងឡាយចូរមើលចុះ និងត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សង្ខារទាំងឡាយមាន ព្រោះបច្ច័យ គឺអវិជ្ជា **តថតា** ( ការមានព្រោះបច្ច័យយ៉ាងនោះ ) យ៉ាងនេះឯណា **អវិតថតា** ( ការមិនមាន ដែលនឹងមិនមានព្រោះបច្ច័យយ៉ាងនោះ ) យ៉ាងនេះឯងឯណា **អនញ្ញថតា** ( ការមិនមានធម៌ដទៃ ព្រោះបច្ច័យដទៃ ) យ៉ាងនេះឯងឯណា **ឥទប្បច្ចយតា** យ៉ាងនេះឯងឯណា ក្នុងធម៌នោះ នេះហៅថា **បដិច្ចសមុប្បាទ** ដូច្នេះជាដើម ជាការត្រាស់ធម៌ដែលជាបច្ច័យទាំងឡាយនោះឯង ថាជាបដិច្ចសមុប្បាទ ដោយពាក្យទាំងឡាយដែលជាវេវចនៈ ( របស់បដិច្ចសមុប្បាទ ) មាន **តថតា** ជាដើម ព្រោះហេតុនោះ បដិច្ចសមុប្បាទ បណ្ឌិតគប្បីជ្រាបថា មានភាពជាបច្ច័យនៃធម៌ទាំងឡាយ មានជរាមរណៈជាដើមជាលក្ខណៈ មានការចងភ្ជាប់នូវទុក្ខជារស មានភាពជាផ្លូវខុសជាបច្ចុប្បដ្ឋាន ឯបដិច្ចសមុប្បាទនោះ ព្រះមានព្រះភាគត្រាស់ហៅថា **តថតា** ព្រោះការមានឡើងនៃធម៌នោះៗ ក៏ព្រោះបច្ច័យទាំងឡាយនោះៗ ដែលមិនខ្វះមិនលើសនោះឯង ត្រាស់ហៅថា **អវិតថតា** ព្រោះកាលបច្ច័យទាំងឡាយដល់ព្រមគ្នាហើយ មិនលះបង់ធម៌ទាំងឡាយដែលកើតព្រោះបច្ច័យនោះមិនមាន សូម្បីតែមួយខណៈ ត្រាស់ហៅថា **អនញ្ញថតា** ក៏ព្រោះធម៌ ( ដែលជាផល ) តែម្យ៉ាង មិនកើតឡើងព្រោះ

បច្ច័យរបស់ធម៌ ( ដែលជាផល ) ម្យ៉ាងទៀត ត្រាស់ហៅថា **ឥទប្បច្ចយតា** ព្រោះជាបច្ច័យ ឬព្រោះជាប្រជុំនៃបច្ច័យរបស់ធម៌ ( ដែលជាផល ) ទាំងឡាយ មានជរាមរណៈជាអាទិ៍តាមដែលពោលហើយនោះ ។

## អធិប្បាយ ឥទប្បច្ចយតា

នេះជាអត្ថនៃពាក្យក្នុងពាក្យឥទប្បច្ចយតានោះ ធម៌ទាំងឡាយណាជាបច្ច័យរបស់ធម៌ទាំងនេះ ធម៌ទាំងឡាយនោះ ឈ្មោះថា **ឥទប្បច្ចយា ឥទប្បច្ចយតា** ក៏គឺ **ឥទប្បច្ចយា** នោះឯង ។ ន័យម្យ៉ាងទៀត ប្រជុំនៃ **ឥទប្បច្ចយា** ឈ្មោះថា **ឥទប្បច្ចយតា** ។ លក្ខណៈក្នុងពាក្យឥទប្បច្ចយតានេះ គប្បីរកមើលអំពីសព្ទសាស្ត្រចុះ ។

## ជំទាស់អត្ថបដិច្ចសមុប្បាទក្នុងលទ្ធិតិរ្ថិយ

មេលទ្ធិពួកខ្លះពោលកិរិយាត្រឹមតែការកើតឡើង ( ព្រងើយៗ មិនមានហេតុ ) ថាជាបដិច្ចសមុប្បាទ ដោយន័យដូច្នេះថា ការអាស្រ័យ ( វត្ថុផ្សេងៗ ) កើតឡើង និងកើតឡើងយ៉ាងត្រឹមត្រូវផង ( ដោយ ) មិនទាក់ទងជាមួយហេតុ ដូចការកើតនៃបកតិ ( ប្រក្រតី-មូលដើម ) និងបុរិស ( អាត្ម័ន ) ជាដើម ដែលតិរ្ថិយកំណត់ឡើង ឈ្មោះថា បដិច្ចសមុប្បាទ ។ ពាក្យរបស់មេលទ្ធិនោះមិនប្រពៃ ព្រោះហេតុអ្វី ព្រោះមិនមានព្រះសូត្រ ( អាង ) ព្រោះខុសចំពោះព្រះសូត្រ ព្រោះមិនកើតជម្រៅ និងន័យ និងព្រោះជាសទ្ទភេទ ( សព្ទបែក ) ប៉ុណ្ណោះ ។

## មិនមានព្រះសូត្រអាង និង ខុសចំពោះព្រះសូត្រ

ពិតណាស់ ព្រះសូត្រថា កិរិយាត្រឹមតែការកើតឡើង ( មិនមានហេតុ ) ឈ្មោះថា បដិច្ចសមុប្បាទ ដូច្នេះមិនមាន និងការខុសចំពោះបទេសវិហារសូត្រ ( ព្រះសូត្រ

ដែលពោលដល់បទេសវិហារធម៌ ) ក៏ត្រូវ ( មាន ) ដល់អ្នកដែលពោលថា កិរិយាត្រឹមតែការកើតឡើងនោះ ឈ្មោះថា បដិច្ចសមុប្បាទផង សួរថា ( ខុស ) ដូចម្តេច ? ឆ្លើយថា ក៏មនសិការបដិច្ចសមុប្បាទ ជាបឋមាភិសម្ពុទ្ធវិហារ ( វិហារធម៌កាលមុនត្រាស់ដឹង ) នៃព្រះមានព្រះភាគជាម្ចាស់ ដោយបាលីថា គ្រានោះឯង ព្រះសាស្តាទ្រង់បានមនសិការបដិច្ចសមុប្បាទ ទាំងអនុលោម និងបដិលោម អស់បឋមយាមនៃរាត្រី ដូច្នេះជាដើម ។ ម្យ៉ាងទៀត វិហារធម៌ជាចំណែកមួយនៃបដិច្ចសមុប្បាទនោះ ឈ្មោះថា បទេសវិហារធម៌ ដូចដែលត្រាស់ថា ( ម្នាលភិក្ខុទាំងឡាយ ) តថាគតនោះមុនត្រាស់ដឹង សម្រាកសម្រាន្តនៅដោយវិហារធម៌ណា តថាគតសម្រាកសម្រាន្តនៅដោយបទេស ( ចំណែកមួយ ) នៃវិហារធម៌នោះ ឯព្រះមានជោគទ្រង់សម្រាកសម្រាន្តនៅក្នុងបទេសវិហារធម៌នោះ ដោយទ្រង់ពិចារណាមើលបច្ចយាការ ( អាការនៃបច្ចយធម៌ ) ទ្រង់មិនមែន ( ពិចារណា ) មើលកិរិយាត្រឹមតែការកើតឡើងឡើយ ដូចដែលត្រាស់ថា តថាគតនោះដឹងទូទៅយ៉ាងនេះថា ការសោយអារម្មណ៍មានព្រោះបច្ច័យ គឺមិច្ឆាទិដ្ឋិក៏មាន ការសោយអារម្មណ៍មានព្រោះបច្ច័យ គឺសម្មាទិដ្ឋិក៏មាន ការសោយអារម្មណ៍មានព្រោះបច្ច័យ គឺមិច្ឆាសង្កប្បក៏មាន ដូច្នេះជាដើម ។ ពាក្យបាលីទាំងពួង បណ្ឌិតគប្បី (នាំមកពោល) ឲ្យពិស្តារចុះ កំហុសចំពោះបទេសវិហារសូត្រត្រូវ (មាន) ដល់អ្នកពោលថា កិរិយាត្រឹមតែការកើតឡើង ឈ្មោះថា បដិច្ចសមុប្បាទដោយប្រការដូច្នេះ ។

ន័យដូចគ្នា ខុសចំពោះកច្ចានសូត្រផង ពិតណាស់ សូម្បីក្នុង **កច្ចានសូត្រ** ក៏ពោលថា ម្នាលកច្ចានៈ ម្យ៉ាងទៀត កាលបុគ្គលឃើញលោកសមុទយៈ ( ហេតុកើតឡើងនៃលោក ) ដោយប្រាជ្ញាដ៏ប្រពៃតាមសេចក្តីពិត **នត្ថិតា** ( ការឃើញថាមិនមាន ឃើញថាដាច់សូន្យ ) ណាក្នុងលោក **នត្ថិតា** នោះរមែងមិនមាន ដូច្នេះ

បដិច្ចសមុប្បាទផ្នែកអនុលោម ឈ្មោះថា លោកសមុទយៈ ព្រោះជាបច្ច័យនៃលោក ព្រោះដូច្នោះ ទើបបដិច្ចសមុប្បាទផ្នែកអនុលោមនោះ ជាធម៌ដែលទ្រង់ប្រកាសដើម្បីដកឧច្ឆេទទិដ្ឋិ មិនមែនទ្រង់ប្រកាសកិរិយាត្រឹមតែការកើតឡើង ( ព្រងើយៗ ) ទេ ព្រោះថា ការដកឧច្ឆេទទិដ្ឋិ មិនមែនមានឡើងដោយការ ( ពិចារណា ) ឃើញត្រឹមតែការកើតឡើងបានទេ តែរមែងមានបានដោយការ ( ពិចារណា ) ឃើញការបន្តគ្នានៃបច្ច័យ ព្រោះការបន្តគ្នានៃផល រមែងមានព្រោះការបន្តគ្នានៃបច្ច័យ ដូច្នេះ សូម្បីការខុស ចំពោះកច្ចានសូត្រក៏ត្រូវ ( មាន ) ដល់អ្នកពោលថា កិរិយាត្រឹមតែការកើតឡើង ឈ្មោះថា បដិច្ចសមុប្បាទ ដោយប្រការដូច្នេះ ។

## មិនកើតជម្រៅ និង ន័យ

ពាក្យថា ព្រោះមិនកើតភាពជ្រាលជ្រៅ និងន័យ សេចក្តីថា ពាក្យនេះព្រះសាស្តាត្រាស់ទុកថា ម្នាលអានន្ទ បដិច្ចសមុប្បាទនេះ ជាធម៌ជ្រាលជ្រៅ ទាំងអាការដែលប្រាកដក៏ជ្រៅផង ដូច្នេះ សេចក្តីជ្រាលជ្រៅ ( នៃបដិច្ចសមុប្បាទនោះ ) មាន ៤ ប្រការ យើងទាំងឡាយនឹងពណ៌នាសេចក្តីជ្រាលជៅនោះខាងមុខ សេចក្តីជ្រាលជ្រៅនោះ មិនមែនមានក្នុងកិរិយាត្រឹមតែការកើតឡើងទេ ។

ម្យ៉ាងទៀត បណ្ឌិតទាំងឡាយពណ៌នាបដិច្ចស្សមុប្បាទនោះឲ្យប្រដាប់ដោយន័យ ៤ ប្រការ សូម្បីន័យទាំង ៤ នោះ ក៏មិនមែនមានក្នុងកិរិយាត្រឹមតែការកើតឡើងឡើយ ។

កិរិយាត្រឹមតែការកើតឡើង មិនជាបដិច្ចសមុប្បាទ ព្រោះមិនកើតជម្រៅ និងន័យដូចពណ៌នាមកដូច្នេះ ប្រការមួយ ។

## ជាសទ្ទភេទ

ពាក្យថា ព្រោះជាសទ្ទភេទ ( ស័ព្ទបែក ) សេចក្តីថា បដិច្ចស័ព្ទនេះ ព្រោះ

កត្តាស្មើគ្នា ( គឺបើមានកត្តាដូចគ្នានឹងឧប្បាទ ) ប្រកបទុកក្នុងបុព្វកាល ( គឺប្រើជាបុព្វកាលកិរិយា ) ទើបធ្វើសេចក្តីសម្រេចនៃអត្ថបាន (គឺបានសេចក្តីជាភាសា) ដូចពាក្យនេះថា **ចក្ខុញ្ច បដិច្ច រូបេ ច ឧប្បជ្ជតិ ចក្ខុវិញ្ញាណំ** ចក្ខុវិញ្ញាណ រមែងអាស្រ័យចក្ខុ និងរូបកើតឡើង តែក្នុងពាក្យរបស់កេចិអាចារ្យនេះ បដិច្ចស័ព្ទនោះប្រកបចូលជាមួយឧប្បាទស័ព្ទ ក៏ជាភាវសាធន ( គឺប្រែថា ការកើតឡើង ) ទើបដល់នូវភាពជាសទ្ទភេទ ព្រោះមិនមានកត្តាស្មើគ្នា និងមិនញ៉ាំងអត្ថណាមួយ ឲ្យសម្រេចផង ព្រោះដូច្នោះ ទើបកិរិយាត្រឹមតែការកើតឡើង មិនជាបដិច្ចសមុប្បាទ ព្រោះជាសទ្ទភេទប្រការមួយ ដូច្នេះ ។

ក្នុងពាក្យនោះ គប្បីមានពាក្យជំទាស់ថា ពួកខ្ញុំនឹងប្រកបចូលជាមួយ **ហោតិ** ស័ព្ទ ថា **បដិច្ចសមុប្បាទោ ហោតិ** ដូច្នេះក៏បាន គប្បីមានពាក្យឆ្លើយថា ពាក្យនោះក៏មិនប្រពៃ ព្រោះអ្វី ? ព្រោះមិនមានសេចក្តីដែលគួរប្រកបប្រការមួយ ព្រោះទោសគឺត្រូវ (ក្លាយជាសេចក្តីថា ) ការកើតឡើងនៃការកើតឡើងប្រការមួយ ព្រោះថា ក្នុងបទទាំងឡាយនេះ គឺ **បដិច្ចសមុប្បាទំ វោ ភិក្ខវេ ទេសិស្សាមិ កតមោ ច ភិក្ខវេ បដិច្ចសមុប្បាទោ ។បេ។ អយំ វុច្ចតិ ភិក្ខវេ បដិច្ចសមុប្បាទោ** ( ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងបដិច្ចសមុប្បាទដល់អ្នកទាំងឡាយ ម្នាលភិក្ខុទាំងឡាយ បដិច្ចសមុប្បាទ តើដូចម្តេច ។បេ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា បដិច្ចសមុប្បាទ ) **ហោតិ** ស័ព្ទ ក៏មិនដល់នូវសេចក្តីគួរប្រកបចូលជាមួយបទ ( ណា ) សូម្បីតែមួយបទ ទាំងមិនជាការកើតឡើងផង ( ព្រោះមិនប្រកបដោយលក្ខណៈនៃការកើត ) បើកើតក៏ត្រូវ ( ក្លាយជា ) ការកើតឡើងនៃការកើតឡើងទៅទៀត ប្រការមួយ ។

សូម្បីអាចារ្យពួកណាសម្គាល់ថា ភាវៈនៃឥទប្បច្ចយធម៌ទាំងឡាយ ឈ្មោះថាឥទប្បច្ចយតា ហើយភាវៈ ( នោះ ) ក៏បានដល់អាការដែលជាហេតុនៃបច្ចយធម៌

ទាំងឡាយ មានអវិជ្ជាជាអាទិ៍ ព្រោះការប្រាកដឡើងនៃសង្ខារ (វត្ថុដែលត្រូវតាក់តែងឡើង) ជាដើម និងឈ្មោះថា បដិច្ចសមុប្បាទ ( នោះសោកក៏មានឡើង ) ព្រោះមានការវិចិត្រនៃសង្ខារនោះឯង ដូច្នេះ ការសម្គាល់នៃអាចារ្យទាំងនោះ ក៏មិនប្រពៃ ព្រោះអ្វី ? ព្រោះពោលហេតុរបស់បច្ចយធម៌ទាំងឡាយ មានអវិជ្ជាជាដើម ដែលពិតបច្ចយធម៌ទាំងឡាយ មានអវិជ្ជាជាដើមនោះឯង ព្រះមានព្រះភាគត្រាស់ថា ជាតួហេតុដោយន័យព្រះសូត្រថា ព្រោះហេតុនោះឯង អានន្ទ វត្ថុនោះឯងជាហេតុ វត្ថុនោះជានិទាន វត្ថុនោះជាសមុទយៈ វត្ថុនោះ ជាបច្ច័យនៃជរាមរណៈ វត្ថុនេះ គឺអ្វី ? គឺជាតិ ។បេ។ វត្ថុនោះជាហេតុ...នៃសង្ខារទាំងឡាយ វត្ថុនេះ គឺអ្វី ? គឺអវិជ្ជា ដូច្នេះ មិនមែនមានការវិចិត្រនៃសង្ខារជាដើមនោះ ( ជាបដិច្ចសមុប្បាទ ) ឡើយ ព្រោះហេតុនោះគប្បីជ្រាបចុះថា បច្ចយធម៌ទាំងឡាយ ( នោះឯង ) ឈ្មោះថា បដិច្ចសមុប្បាទ ពាក្យនោះ ដែលខ្ញុំពោលទុកដូច្នេះ ពាក្យនោះគប្បីជ្រាបថា ជាពាក្យពោលប្រពៃហើយ ។

ចំណែកការយល់ប្រព្រឹត្តទៅឯណា កើតឡើងក្នុងបទបដិច្ចសមុប្បាទនោះថា ការកើតឡើងនេះឯង ហៅថា បដិច្ចសមុប្បាទ ( មិនមែនហេតុ ) ដោយស្រមោលនៃព្យញ្ជនៈថា បដិច្ចសមុប្បាទនេះ ការយល់នោះ អាចារ្យទាំងឡាយ គប្បីកាន់យកអត្ថនៃបទនេះដោយន័យដែលពោលហើយនោះ ហើយរម្ងាប់ចោលចុះ ព្រោះថា

ក្នុងក្រុម ( បច្ចុប្បន្ន ) ធម៌ដែលប្រព្រឹត្តទៅព្រោះក្រុមបច្ចយធម៌នោះ ពាក្យ ( បដិច្ចសមុប្បាទ ) នេះ ( លោកមានបំណង ) ដោយចំណែកពីរ ( គឺទាំងចំណែកផល និងចំណែកហេតុ ) ហេតុណា ព្រោះហេតុនោះ ( សូម្បី ) បច្ច័យនៃក្រុមធម៌នោះ ព្រះមានព្រះភាគក៏ត្រាស់ហៅថា បដិច្ចសមុប្បាទ ដោយឧបចារៈ ( គឺដោយវោហារ ) នៃផល ។

ពិតណាស់ ក្រុមធម៌ ( បច្ចុប្បន្ន គឺដែលជាផល ) ដែលប្រព្រឹត្តទៅ ( គឺ

កើតឡើង ) ព្រោះក្រុមបច្ច័យណា ក្នុងក្រុមធម៌នោះ បណ្ឌិតទាំងឡាយឃ្លាមានបំណង យកពាក្យថា បដិច្ចសមុប្បាទនេះជាពីរចំណែក ពង្រីកសេចក្តីដូចខាងក្រោមនេះ

## បដិច្ចសមុប្បាទចំណែកផល

ក្រុមធម៌នោះ គឺបណ្ឌិតអាស្រ័យ ( ដំណើរញាណ ) រមែងប្រព្រឹត្តទៅដើម្បីប្រយោជន៍ និងដើម្បីសេចក្តីសុខ ( ដែលជាលោកុត្តរ ) ហេតុណា ព្រោះហេតុនោះ ទើបក្រុមធម៌នោះ ឈ្មោះថា បដិច្ច ព្រោះដែលបណ្ឌិតគួរអាស្រ័យ និងក្រុមធម៌នោះ ឈ្មោះថា សមុប្បាទផង ព្រោះថា កាលកើតឡើង រមែងកើតឡើងដូចគ្នា និង ( កើតឡើង ) ដោយប្រពៃ ព្រោះមិនបានកើតឡើងតែម្យ៉ាង ទាំងមិនបានកើតឡើង ដោយមិនមានហេតុផង ហេតុដូច្នេះ ទើបក្រុមនោះ ឈ្មោះថា បដិច្ចសមុប្បាទ ព្រោះជាទីដែលបណ្ឌិតគួរអាស្រ័យផង កើតឡើងដូចគ្នា និងដោយប្រពៃផង ដោយន័យដូចពោលមកដូច្នេះ ។ ន័យម្យ៉ាងទៀត ក្រុមធម៌ ( ដែលជាផល ) ឈ្មោះថា សមុប្បាទ ព្រោះកើតឡើងដូចគ្នា ម្យ៉ាងទៀត ក្រុមធម៌នោះអាស្រ័យ គឺមិនបដិសេធ ការព្រមព្រៀងនៃបច្ច័យកើតឡើង ហេតុដូច្នេះ ទើបក្រុមធម៌នោះ ឈ្មោះថា បដិច្ចសមុប្បាទ ព្រោះក្រុមធម៌នោះ អាស្រ័យ ( បច្ច័យ ) ផង កើតឡើងដូចគ្នាផង ដូចពោលមកដូច្នេះ ។

## បដិសច្ចសមុប្បាទចំណែកហេតុ

ចំណែកក្រុមហេតុទាំងនេះ ក៏ជាបច្ច័យរបស់ក្រុមធម៌នោះ ហេតុនេះ ទើបក្រុមហេតុនោះបានឈ្មោះថា **តប្បច្ចយ** ព្រោះភាពដែលក្រុមហេតុជាតប្បច្ចយ ( នោះឯង ) សូម្បីក្រុមហេតុនេះ បណ្ឌិតគប្បីជ្រាបចុះថា ព្រះមានព្រះភាគជាម្ចាស់ត្រាស់ហៅថា បដិច្ចសមុប្បាទដូចគ្នា ដោយវោហារនៃផលដូចក្នុងផ្លូវលោក ដុំទឹកអំពៅ ដែលជា

បច្ច័យនៃសេម្ហ គេតែងហៅថា ស្ទេស្មទឹកអំពៅ និងដូចឧបមាក្នុងផ្លូវសាសនា ការកើតឡើងនៃព្រះពុទ្ធទាំងឡាយ ដែលជាបច្ច័យនៃសេចក្ដីសុខ លោកក៏ហៅថា ការកើតឡើងនៃព្រះពុទ្ធទាំងឡាយជាសុខ ដូច្នេះ ។

ក្រុមហេតុនេះ ហៅថា បដិច្ច ព្រោះអត្ថថា ដល់ចំពោះមុខគ្នា និងក្រុមហេតុនោះហៅថា សមុប្បាទផង ព្រោះអត្ថថា ញុំាងធម៌ទាំងឡាយដែលទៅផងគ្នាឲ្យកើត ។

ពិតហើយ ក្រុមហេតុរបស់ការប្រាកដ ( កើតឡើង ) នៃធម៌ទាំងឡាយ មានសង្ខារជាដើម ដែលទ្រង់សម្ដែងទុកដោយមាតិកា ហេតុជាវគ្គៗ មានអវិជ្ជាជាដើមនោះ ក្រុមហេតុនោះ ហៅថា បដិច្ច ព្រោះធ្វើអត្ថវិគ្រោះថា បណ្ដាបច្ចយធម៌ ដែលជាអង្គនៃការរួមក្រុមដល់ចំពោះមុខគ្នានឹងគ្នា គឺទៅប្រជួបមុខគ្នានឹងគ្នា ដោយអត្ថ ( រួមគ្នា ) ញុំាងផលទូទៅឲ្យសម្រេច និងដោយអត្ថថា មិនមាន ( ផលណា ) ដាច់ចុះខុសគ្នាទៅ ( និង ) ក្រុមហេតុនេះ ញុំាងធម៌ទាំងឡាយដែលទៅផងគ្នា គឺធម៌ដែលមានការប្រព្រឹត្តទៅមិនបែកគ្នានឹងគ្នានោះឯង ឲ្យកើតឡើង ព្រោះដូច្នេះ ទើបក្រុមហេតុនោះ ហៅថា សមុប្បាទផង ( ដូច្នេះ ) ទើបក្រុមហេតុ បានឈ្មោះថា បដិច្ច ព្រោះក្រុមហេតុនោះដល់ចំពោះមុខគ្នាផង ញុំាងធម៌ដែលទៅជាមួយគ្នាឲ្យកើតផង ដូចពោលមកដូច្នេះ ។

ន័យដទៃទៀតមានទៀត គឺ

ក្រុមបច្ច័យនេះ អាស្រ័យគ្នានឹងគ្នា ( ជាហេតុរួម ) ញុំាងធម៌ទាំងឡាយ ( ដែលជាផលរបស់ខ្លួន ) ឲ្យកើតឡើងស្មើគ្នានឹងគ្នា ហេតុណា សូម្បីព្រោះហេតុនោះ ទើបក្រុមបច្ច័យនេះ ព្រះមុនីត្រាស់ទុកក្នុងបទបដិច្ចសមុប្បាទនេះផងដូចគ្នា ។

ពិតហើយ ក្នុងបច្ច័យទាំងឡាយដែលទ្រង់សម្ដែងទុក ដោយមាតិកា មានអវិជ្ជាជាដើម បច្ច័យពួកណាញុំាងធម៌ មានសង្ខារជាដើមឲ្យកើតឡើង បច្ច័យទាំងនោះ នឹងពិតក៏ទេ អាស្រ័យគ្នានឹងគ្នា ( ជាហេតុរួម ) កាលដាច់គ្នានឹងគ្នាទៅ មិនអាចញុំាងធម៌

មានសង្ខារជាដើមនោះឲ្យកើតឡើងបានឡើយ ព្រោះដូច្នោះ ក្រុមបច្ច័យនេះ ព្រះសាស្តាដ៏ឈ្លាសក្នុងវោហារតាមទំនងសេចក្តីថា ក្រុមបច្ច័យនេះអាស្រ័យ ( គ្នានឹងគ្នាជាហេតុរួម ) ញ៉ាំងធម៌ទាំងឡាយឲ្យកើតឡើងដោយ ស្មើគ្នានឹងគ្នា គឺមិនមែន ( ឲ្យកើតឡើង ) ជាចំណែកៗ ទាំងមិនមែន ( ឲ្យកើតឡើង ) ដោយជាដុំ និងខ្នង ដូច្នេះ ទើបត្រាស់ទុកក្នុងបទបដិច្ចសមុប្បាទនេះផង ដូចគ្នា សេចក្តីថា ត្រាស់ថា ជាបដិច្ចសមុប្បាទផងនោះឯង ។

## បដិច្ចសមុប្បាទជាមជ្ឈិមប្បដិបទា

*ព្រះមហាមុនីនោះ កាលត្រាស់យ៉ាងនេះ*

***ក៏ជាការដែលទ្រង់សម្តែងភាពមិនជាសស្សតវាទជាដើម ដោយបទមុខ និងទ្រង់សម្តែងភាពជំទាស់ចំពោះឧច្ឆេទវាទជាដើមដោយបទក្រោយ ទ្រង់សម្តែងភាពត្រឹមត្រូវដោយបទទាំងពីរ ។***

*អត្ថាធិប្បាយនៃពាក្យប្រព័ន្ធនេះថា ពាក្យថា ដោយបទមុខ ជាដើម សេចក្តីថា ភាពជាសស្សតវាទជាដើម ដែលចែកចេញទៅជាសស្សតវាទ ( ពោលថា អត្តា និងលោកទៀង មិនសូន្យ ស្លាប់ហើយកើត ) អហេតុកវាទ ( ពោលថា ហេតុបច្ច័យនៃសេចក្តីសៅហ្មង និងភាពបរិសុទ្ធរបស់សត្វទាំងឡាយមិនមានស្រេច ហើយដោយជោគគ្រោះ ) វិសមហេតុវាទ ( ពោលថា លោកប្រព្រឹត្តទៅដោយអំណាចហេតុមិនស្មើគ្នា គឺដោយអំណាចបកតិ អណូ និងកាលជាដើម ) វសវត្តិវាទ ( ពោលថា មានព្រះឥស្សរ អាត្មន ឬព្រះបជាបតី គឺព្រហ្ម ជាអ្នកគ្របសង្កត់សត្វទុកក្នុងអំណាច គឺជាអ្នកបណ្តាល ) ជាការដែលទ្រង់សម្តែងដោយបទ បដិច្ច ដែលចុះបញ្ចាំងភាពដល់ព្រមនៃបច្ច័យ ព្រោះបវត្តិធម៌ ( ធម៌ចំណែកបវត្តិ-វិលទៅ ) មានការប្រព្រឹត្តទៅទាក់ទងនៅក្នុងភាពព្រមព្រៀងនៃបច្ច័យ ។ ពិតហើយ ប្រយោជន៍អ្វី ដោយការព្រម*

ព្រៀងនៃបច្ច័យនោះ សម្រាប់វត្ថុដែលជាសស្សតៈជាដើម ឬសម្រាប់វត្ថុដែលប្រព្រឹត្ត ទៅដោយអំណាចអហេតុជាដើម ។

ពាក្យថា និង... ដោយបទក្រោយជាដើម សេចក្ដីថា **ឧច្ឆេទវាទ** ( ពោលថា ស្លាប់ហើយសូន្យ ) **នត្ថិកវាទ** ( ពោលថា អ្វីៗ មិនមាន ផលរបស់បុណ្យបាប ក៏មិនមាន ) **អកិរិយវាទ** ( ពោលថា មិនជាការធ្វើ គឺធ្វើអ្វីៗ មិនជាកម្ម ) ឈ្មោះថា ត្រូវបដិសេធចេញទៅ ព្រោះការកើតឡើងនៃធម៌ទាំងឡាយ ក៏ព្រោះការព្រមព្រៀង នៃបច្ច័យ ហេតុនោះ ទើបជាការដែលទ្រង់សម្ដែងភាពជំទាស់ចំពោះឧច្ឆេទវាទជាដើម ដោយបទសមុប្បាទ ដែលចុះបញ្ចាំងការកើតឡើងនៃធម៌ទាំងឡាយ ពិតនៅក្នុងកាល ធម៌ទាំងឡាយកើតឡើងហើយកើតឡើងទៀត ដោយអំណាចនៃបច្ច័យមុនៗ ឧច្ឆេទវាទ នត្ថិកវាទ និងអកិរិយវាទ នឹងមានអំពីណា ពាក្យថា ដោយបទទាំងពីរជាដើម សេចក្ដី ថា ការត្រឹមត្រូវនេះ គឺមជ្ឈិមប្បដិបទា ការលះចេញនូវវាទៈថា អ្នកនោះធ្វើ អ្នកនោះ បានទទួលផល ( គឺអ្នកណាធ្វើ អ្នកណាបានរឿយៗ ទៅ មិនមានទីបំផុត ) ការលះបង់ នូវវាទៈថា អ្នកដទៃធ្វើ អ្នកដទៃបានទទួលផល ( គឺបុគ្គលណាធ្វើ បុគ្គលនោះបាន ) ការមិនប្រកាន់ក្នុងភាសារបស់ស្រុកតំបន់ ការមិនលះបង់នូវសមញ្ញា ( គឺឈ្មោះ មនុស្ស និងសត្វ វត្ថុដែលមនុស្សលោកសន្មត ) ជាការដែលទ្រង់សម្ដែងដោយពាក្យ ថា បដិច្ចសមុប្បាទគ្រប់ពាក្យទាំងអស់ ព្រោះធម៌នោះៗ កើតឡើងដោយមិនដាច់ ( គឺមិនវៀរ ) ការជាប់បន្តគ្នា ការព្រមព្រៀងនៃបច្ច័យនោះៗ ។

នេះជាការសំដៅត្រឹមតែពាក្យថា បដិច្ចសមុប្បាទប៉ុណ្ណោះ ។

ចំណែករបៀបដែលព្រះមានព្រះភាគ កាលទ្រង់សម្ដែងបដិច្ចសមុប្បាទ ទ្រង់ សម្ដែងដោយន័យថា **អវិជ្ជាបច្ចយា សង្ខារា**-សង្ខារទាំងឡាយមាន ព្រោះបច្ច័យ គឺអវិជ្ជាជាដើមនេះ បណ្ឌិតកាលនឹងធ្វើពណ៌នាសេចក្ដីនៃរបៀបដែលទ្រង់សម្ដែង

នោះចុះកាន់វង់វិកដវាទី ហើយពោលសន្តត់សន្តិន អាចារ្យទាំងឡាយ មិនធ្លាក់ចុះកាន់សកសម័យ ( គឺមិនប្រកាន់អំពីការដឹងចំណែកខ្លួន ) មិនឡើងកាន់បរសម័យ (គឺមិនសន្តត់សន្តិនការដឹងចំណែកអ្នកដទៃ) មិនជំទាស់ព្រះសូត្រ អនុលោមព្រះវិន័យ សម្លឹងមើលមហាបទេសទុក បង្ហាញគោលធម៌ ( គឺបាលី ) បាន ( ត្រឹមត្រូវ ) កាន់យកអត្ថ ( គឺសេចក្ដីអធិប្បាយនៃបាលីនោះ ) បាន ( មិនខុស ) និងបញ្ច្រាស់អត្ថនោះនុ៎ះឯង អធិប្បាយទៅដោយបរិយាយដទៃក៏បាន ( ដូច្នេះ ) ទើបគួរធ្វើការពណ៌នាបានយ៉ាងទៀតសោត ដោយប្រក្រតី អត្ថ គឺការពណ៌នានៃបដិច្ចសមុប្បាទ ក៏ធ្វើបានលំបាកដូចបោរាណាចារ្យទាំងឡាយពោលទុកថា

ធម៌ ៤ ប្រការ គឺសត្យ សត្វ បដិសន្ធិ និងបច្ចយាការ នេះឯងជាធម៌ឃើញបានលំបាក ទាំងលំបាកនឹងសម្ដែងផងដែរ ។

ដូច្នេះ ហេតុណា ព្រោះហេតុនោះ ការពណ៌នាសេចក្ដីនៃបដិច្ចសមុប្បាទដែលបុគ្គលណាម្នាក់ វៀរចាកអ្នកសម្រេចអាគម ( គឺព្រះបរិយត្តិ ) និងអធិគម ( គឺមគ្គផល ) មិនមែននឹងធ្វើបានងាយ ហេតុដូច្នេះ ខ្ញុំថ្លឹងថ្លែងមើលហើយ ។

ថ្ងៃនេះ បុគ្គលនឹងពោលពណ៌នាបច្ចយាការ ( ទាំងដែល ) មិនទាន់បាន ( ន័យដែលជា ) ទីតាំង ( ដែលអាស្រ័យដោយកម្លាំងបញ្ញាខ្លួន ) ដូចឈានចុះកាន់សាគរនៅមិនទាន់បានទីជាន់ ដូច្នោះ តែពាក្យប្រដៅខនេះ ជាពាក្យប្រៀនប្រដៅដែលប្រដាប់ទៅដោយន័យទេសនាជានានា ( វិធី ) ទាំងគន្លងផ្លូវ ( គឺអដ្ឋកថា ) របស់បុព្វាចារ្យសោត ក៏គង់មិនដាច់ខ្សែប្រព្រឹត្តទៅ ( រហូតដល់សព្វថ្ងៃនេះ ) ហេតុណា ព្រោះហេតុនោះ ខ្ញុំនឹងអាស្រ័យន័យទាំងពីរនោះ ចាប់ផ្ដើមពណ៌នាសេចក្ដីនៃបដិច្ចសមុប្បាទនោះសូមលោកទាំងឡាយ តាំងចិត្តស្ដាប់ពាក្យ ពណ៌នានោះចុះ ។

ដោយព្រះបុព្វាចារ្យទាំងឡាយពោលទុកថា

បើបុគ្គលណាម្នាក់តាំងចិត្តស្តាប់ខ្ញុំ នឹងគប្បីបានទទួលគុណវិសេស ដែលមានតាំងអំពីដើមទៅដល់ចុង លុះបានទទួលគុណវិសេស ដែលមានតាំងអំពីដើមទៅដល់ចុងហើយ ក៏នឹងគប្បីសម្រេចដល់ឋានៈ ដែលមច្ចុរាជមើលមិនឃើញ ដូច្នេះ ។

ក្នុងពាក្យបាលីបដិច្ចសមុប្បាទ មានពាក្យថា អវិជ្ជាបច្ចយា សង្ខារា ជាដើម។

បណ្ឌិតគប្បីជ្រាបវិនិច្ឆ័យដោយប្រភេទនៃទេសនា ដោយអត្ថ ដោយលក្ខណៈ (ជាដើម) ដោយប្រភេទផ្សេងៗ មានតែមួយ៉ាងជាដើម និងដោយកំណត់អង្គទាំងឡាយ ។

អំពីដើមទៅនោះ ដូច្នេះមុន ។

## វិនិច្ឆ័យដោយប្រភេទនៃទេសនា

ក្នុងបទទាំងនោះ បទថា ដោយប្រភេទនៃទេសនា មានវិនិច្ឆ័យថា ក៏ការសម្តែងបដិច្ចសមុប្បាទនៃព្រះមានព្រះភាគមាន ៤ យ៉ាង គឺទ្រង់សម្តែងតាំងអំពីដើម រហូតដល់ចុងខ្លះ តាំងអំពីកណ្តាលរហូតដល់ចុងខ្លះ ន័យដូចគ្នានោះ ទ្រង់សម្តែងអំពីចុងមកដល់ដើមខ្លះ អំពីកណ្តាលមកដល់ដើមខ្លះ ដូចការ ( ទាញ ) យកដើម វល្លិ៍នៃមនុស្សរកដើមវល្លិ៍ ៤ នាក់ ដូច្នោះ ។

## សម្តែងអំពីដើមដល់ចុង

ឧបមាដូចបុគ្គលស្វែងរកវល្លិ៍ ៤ នាក់នោះ ម្នាក់ជួបគល់វល្លិ៍មុន គេក៏កាត់ត្រង់គល់ ហើយទាញយកមករហូតអស់ នាំទៅប្រើការ យ៉ាងណា ព្រះមានព្រះភាគក៏ដូច្នោះ ទ្រង់សម្តែងបដិច្ចសមុប្បាទ តាំងអំពីដើមរហូតទៅដល់ចុងថា ដូច្នេះឯងម្នាលភិក្ខុទាំងឡាយ សង្ខារទាំងឡាយ មានព្រោះបច្ច័យ គឺអវិជ្ជា ។បេ។ ជរាមរណៈមាន ព្រោះបច្ច័យ គឺជាតិ ដូច្នេះក៏មាន ។

## សម្តែងអំពីកណ្តាលដល់ចុង

ម្យ៉ាងទៀត ក្នុងពួកមនុស្សនោះ មនុស្សម្នាក់ជួបផ្នែកកណ្តាលនៃវល្លិ៍នោះ គេក៏កាត់ត្រង់កណ្តាលទាញយកចំណែកលើប៉ុណ្ណោះ នាំទៅប្រើការ យ៉ាងណា ព្រះមានព្រះភាគក៏ដូច្នោះ ទ្រង់សម្តែង ( បដិច្ចសមុប្បាទ ) តាំងអំពីកណ្តាលទៅដល់ចុងថា កាលកុមារនោះតាំងចិត្តត្រេកអរនូវវេទនានោះ ពោលសរសើរនូវវេទនានោះ ប្រកាន់ស្អិតវេទនានោះនន្ទិ ( ការភ្ញើតភ្ញើន ) រមែងកើតឡើង នន្ទិក្នុងវេទនាទាំងឡាយណា ន៎ុះជាឧបាទាន ភពរមែងមានដល់បុគ្គល ព្រោះបច្ច័យ គឺឧបាទាន ជាតិ រមែងមានព្រោះបច្ច័យ គឺភព ដូច្នេះជាដើមក៏មាន ។

## សម្តែងអំពីចុងដល់ដើម

ម្យ៉ាងទៀត ក្នុងមនុស្សពួកនោះ មនុស្សម្នាក់ប្រទះចុងវល្លិ៍ គេក៏ចាប់វាត្រង់ចុង និងកន្ទ្រាក់យកមកអស់រហូតដល់គល់ ដោយស្រាវទៅអំពីចុងនោះឯង នាំទៅប្រើការ យ៉ាងណា ព្រះមានព្រះភាគក៏ដូច្នោះ ទ្រង់សម្តែងបដិច្ចសមុប្បាទ តាំងអំពីចុងទៅដល់ដើមថា ពាក្យដែលតថាគតពោលថា ជរាមរណៈ មានព្រោះបច្ច័យ គឺជាតិ ដូច្នេះនេះ ម្នាលភិក្ខុទាំងឡាយ ជរាមរណៈ មានព្រោះបច្ច័យ គឺជាតិ ឬថា មិនមែនទេ ឬថា ការសម្គាល់របស់ពួកអ្នកទាំងឡាយក្នុងសេចក្តីនេះ មានដូចម្តេច ? ( ភិក្ខុទាំងឡាយក្រាបទូលថា ) បពិត្រព្រះអង្គដ៏ចម្រើន ជរា មរណៈរមែងមានព្រោះបច្ច័យ គឺជាតិ ការសម្គាល់របស់ពួកខ្ញុំព្រះអង្គទាំងឡាយ ក្នុងសេចក្តីនេះ មានយ៉ាងនេះថា ជរាមរណៈ មានព្រោះបច្ច័យ គឺជាតិ ( ត្រាស់តទៅថា ) ពាក្យដែលតថាគតពោលថា ជាតិមាន ព្រោះបច្ច័យ គឺភព ។បេ។ សង្ខារទាំងឡាយមានព្រោះបច្ច័យ គឺអវិជ្ជាដូច្នេះនេះ ម្នាល ម្នាលភិក្ខុទាំងឡាយ... សង្ខារទាំងឡាយមាន ព្រោះបច្ច័យ គឺអវិជ្ជាមែនឬ ឬថា

មិនមែនទេ ឬថា ការសម្គាល់របស់អ្នកទាំងឡាយ ក្នុងសេចក្ដីនេះមានដូចម្ដេច ? ដូច្នេះជាដើម ក៏មាន ។

## សម្ដែងអំពីកណ្ដាលដល់ដើម

ម្យ៉ាងទៀត ក្នុងពួកមនុស្សនោះ មនុស្សម្នាក់ប្រទះផ្នែកកណ្ដាលនៃវល្លិ៍ គេក៏កាត់ត្រង់កណ្ដាល ហើយស្រាវចុះទៅ ចំណែកក្រោមរហូតដល់គល់ នាំទៅប្រើការយ៉ាងណា ព្រះមានព្រះភាគក៏ដូច្នោះ ទ្រង់សម្ដែងបដិច្ចសមុប្បាទផ្ដើមអំពីកណ្ដាលដល់ដើមថា ម្នាលភិក្ខុទាំងឡាយ អាហារ ៤ នេះ មានអ្វីជាដើមហេតុ មានអ្វីជាសមុទយៈ មានអ្វីជាកំណើត មានអ្វីជាដែនកើត ? អាហារ ៤ នេះ មានតណ្ហាជាដើមហេតុ មានតណ្ហាជាសមុទយៈ មានតណ្ហាជាកំណើត មានតណ្ហា ជាដែនកើត តណ្ហាមានអ្វីជាដើមហេតុ... វេទនា... ផស្សៈ... សឡាយតនៈ... នាមរូប... វិញ្ញាណ... សង្ខារមានអ្វីជាដើមហេតុ... សង្ខារមានអវិជ្ជាជាហេតុ ។បេ។ មានអវិជ្ជាជាដែនកើត ដូច្នេះក៏មាន ។

## ហេតុដែលទ្រង់សម្ដែងដូច្នេះ

សួរថា ព្រោះហេតុដូចម្ដេច ទើបទ្រង់សម្ដែងដូច្នេះ ? ឆ្លើយថា ព្រោះបដិច្ចសមុប្បាទជាធម៌ ( សមន្តភទ្រ ) មានការល្អដោយជុំវិញ និងព្រោះព្រះអង្គផ្ទាល់ក៏ទ្រង់ដល់នូវ ( ទេសនាវិលាស ) មានសេចក្ដីល្អក្នុង ( បែបបទ ) ទេសនាផងដែរ ។ ពិតហើយ បដិច្ចសមុប្បាទជាធម៌មានលម្អដោយជុំវិញ ទើបប្រព្រឹត្តទៅដើម្បីចាក់ធ្លុះនូវធម៌ដែលត្រឹមត្រូវ ព្រោះ ( បែបបទ ) ទេសនានោះៗ ដោយពិត ព្រះមានព្រះភាគក៏ទ្រង់ដល់នូវសេចក្ដីស្អាត ( បែបបទ ) ទេសនា ព្រោះទ្រង់ប្រកបដោយព្រះវេសារជ្ជញ្ញាណ ៤ និងព្រះបដិសម្ភិទាញាណ ៤ និងព្រោះទ្រង់ដល់នូវព្រះគម្ភីរភាព ៤ ប្រការផង

ព្រោះទ្រង់ដល់នូវសេចក្ដីល្អក្នុង (បែបបទ) ទេសនា ព្រះអង្គទ្រង់សម្ដែងធម៌បានដោយន័យផ្សេងៗ ពិត ។

តែ (កាលពោល) ដោយភាពប្លែកគ្នា (នៃទេសនាទាំង ៤) អនុលោមទេសនា (ការសម្ដែងបដិច្ចសមុប្បាទដោយអនុលោម) តាំងអំពីដើមទៅឯណា អនុលោមទេសនានោះ បណ្ឌិតគប្បីជ្រាបថា ប្រព្រឹត្តទៅដល់ព្រះអង្គ ដែលទ្រង់ពិចារណាឃើញវេនេយ្យជនដែលនៅល្ងង់ក្នុងការបែកហេតុនៃបវត្តិ (ការវិលទៅ) ដើម្បីទ្រង់បង្ហាញនូវបវត្តិ (ការវិលទៅ) តាមហេតុទាំងឡាយដែលជារបស់ខ្លួន និងដើម្បីទ្រង់បង្ហាញនូវលំដាប់នៃការកើតឡើងផង ។

បដិលោមទេសនាចំពោះ (ការសម្ដែងបដិច្ចសមុប្បាទដោយបដិលោម) តាំងអំពីចុងមកឯណា បដិលោមទេសនានោះ គប្បីជ្រាបថា ប្រព្រឹត្តទៅដល់ព្រះអង្គដែលទ្រង់សម្លឹងឃើញសត្វលោក ដែលត្រូវមានទុក្ខលំបាកដោយន័យ (ព្រះពុទ្ធដីកា) ថា សត្វលោកនេះត្រូវលំបាកហ្ន៎ នៅកើតផង ចាស់ផង ស្លាប់ផង ដូច្នេះជាដើម ដើម្បីទ្រង់បង្ហាញនូវហេតុរបស់ទុក្ខនោះៗ មានជរាមរណៈជាដើម ដែលព្រះអង្គទ្រង់បានជួបប្រទះតាមគន្លងនៃការត្រាស់ដឹងក្នុងបឋមពោធិកាល ។

ទេសនាដែលប្រព្រឹត្តទៅ តាំងអំពីកណ្ដាលដល់ដើមឯណា ទេសនានោះ គប្បីជ្រាបថា ប្រព្រឹត្តទៅដើម្បីទ្រង់បង្ហាញនូវលំដាប់នៃហេតុ និងផល ចាប់ផ្ដើមធ្លងតាំងអំពីអតីតអទ្ធាទៅរហូតដល់អតីតអទ្ធាទៀត តាមទំនងកំណត់ហេតុនៃអាហារ ។

ចំណែកទេសនាដែលប្រព្រឹត្តទៅ ផ្ដើមអំពីកណ្ដាលដល់ចុងឯណា ទេសនានោះគប្បីជ្រាបថា ប្រព្រឹត្តទៅដើម្បីទ្រង់បង្ហាញនូវធម៌ (ដែលនឹងមានក្នុង) អនាគតអទ្ធា (កាលអនាគត) ផ្ដើមអំពីការកើតឡើងនៃធម៌ ដែលជាហេតុនៃ (ផលដែលនឹងមានក្នុង) អនាគតអទ្ធាក្នុងកាលបច្ចុប្បន្ន (នេះឯង) ។

ក្នុងទេសនា ( ៤ ) នោះ អនុលោមទេសនាផ្ដើមអំពីដើមទៅ ដើម្បីទ្រង់បង្ហាញនូវបវត្តិ ( ការវិលទៅ ) តាមហេតុទាំងឡាយដែលជារបស់ខ្លួន និងដើម្បីទ្រង់សម្ដែងលំដាប់នៃការកើតឡើងដល់វេនេយ្យជនដែលនៅល្ងង់ក្នុង ( ការបែក ) ហេតុនៃបវត្តិឯណា អនុលោមទេសនានោះ បណ្ឌិតគប្បីជ្រាបថា ជាបែបដែលទ្រង់សម្ដែងទុកក្នុងទីនេះ ។

## អវិជ្ជាក៏មានហេតុ

សួរថា ព្រោះហេតុដូចម្ដេច ទើបក្នុងបច្ចយាការនេះ ព្រះមានព្រះភាគត្រាស់អវិជ្ជាទុក សូម្បីអវិជ្ជាក៏ជាវត្ថុមិនមានហេតុ (តែ) ជាតួមូលហេតុរបស់លោក ដូចបកតិរបស់ពួកបកតិវាទីដែរឬ ? ឆ្លើយថា អវិជ្ជាមិនមែនជាវត្ថុ មិនមានហេតុទេ ព្រោះថាហេតុរបស់អវិជ្ជាក៏បានត្រាស់ទុក ( ក្នុងបាលី ) ថា **អាសវសមុទយា អវិជ្ជាសមុទយោ** ការកើតឡើងនៃអវិជ្ជាមាន ព្រោះការកើតឡើងនៃអាសវៈ ដូច្នេះ តែបរិយាយ ( គឺហេតុដោយអម ) ដែលជាហេតុ ( ឲ្យពោលបានថា អវិជ្ជា ) ជាតួមូលហេតុក៏មាន សួរថា បរិយាយនោះ គឺអ្វី ? ឆ្លើយថា គឺការដែលអវិជ្ជាជាសីសៈ ( ជាកំពូលហេតុ ) ក្នុងវដ្ដកថា ( គឺព្រះធម៌ទេសនាពោលដោយវដ្ដៈ ) ។ ពិតហើយ ព្រះមានព្រះភាគកាលត្រាស់វដ្ដកថា រមែងត្រាស់ដោយទ្រង់លើកធម៌ ២ ប្រការជាសីសៈ គឺអវិជ្ជាខ្លះ ដូចដែលត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ខាងដើមខាងចុងនៃអវិជ្ជាមិនប្រាកដ បើបុគ្គលណាម្នាក់ ពោលថា មុននេះអវិជ្ជាមិនមាន វាទើបតែកើតខាងក្រោយ ដូច្នេះសោត តែដែលពិតអវិជ្ជាមាន វត្ថុនេះៗ ជាបច្ច័យក៏ប្រាកដ ដូច្នេះ ភវតណ្ហាខ្លះ ដូចដែលត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ខាងដើមខាងចុងនៃភវតណ្ហាមិនប្រាកដ បើបុគ្គលណាម្នាក់ពោលថា មុននេះ ភវតណ្ហាមិនមាន មកខាងក្រោយទើបកើត ដូច្នេះសោត តែដែលពិតភវតណ្ហា មាន វត្ថុនេះៗ ជាបច្ច័យក៏ប្រាកដ ដូច្នេះ ។

សួរថា ព្រោះហេតុអ្វី ទើបព្រះមានព្រះភាគត្រាស់វដ្តកថា ត្រាស់ដោយលើកធម៌ ២ ប្រការនេះជាសីសៈ ? ឆ្លើយថា ព្រោះធម៌ ២ ប្រការនេះ ជាហេតុពិសេសរបស់កម្ម ដែលជាសុគតិគាមី និងទុគ្គតិគាមី ។ ពិតហើយ អវិជ្ជាជាហេតុពិសេសរបស់កម្មដែលជាទុគ្គតិគាមី ព្រោះអ្វី ? ព្រោះបុថុជ្ជនអ្នកត្រូវអវិជ្ជាគ្របសង្កត់ហើយ រមែងធ្វើកម្មដែលជាទុគ្គតិគាមីជាអនេកប្រការ មានបាណាតិបាតជាដើម ទាំងដែលមិនមាន ( អ្វី ) ដែលគួរពេញចិត្ត ព្រោះដុតរោលដោយកិលេស ទាំងនាំមកនូវអនត្ថៈដល់ខ្លួនឯង ព្រោះធ្វើឲ្យធ្លាក់ចុះទៅកាន់ទុគ្គតិ ដូចគោដែលគេនឹងសម្លាប់ ដែលត្រូវការជន្លក់ ព្រោះត្រូវរោលដោយភ្លើង និងត្រូវវាយដោយដំបងគ្របសង្កត់ហើយ រមែងផឹកទឹកក្តៅ ( ដែលគេប្រកឲ្យ ) ទាំងមិនឆ្ងាញ់ ទាំងនាំមកនូវក្តីវិនាសដល់ខ្លួន ( ទាំងនេះក៏ ) ព្រោះអន្ទះអន្ទែងដោយការជន្លក់នោះ ដូច្នោះ ។

ចំណែកភវតណ្ហាជាហេតុពិសេសរបស់កម្ម ដែលជាសុគតិគាមី ព្រោះអ្វី ? ព្រោះបុថុជ្ជនដែលភវតណ្ហាគ្របសង្កត់ហើយ រមែងព្យាយាមធ្វើកម្មដែលជាសុគតិគាមីជាអនេកប្បការ មានវៀរចាកបាណាតិបាតជាដើម ដែលជាកម្មមានគុណគួរសប្បាយចិត្ត ព្រោះប្រាសចាកការក្តៅរោលរាលដោយកិលេស និងជាកម្មដែលបន្ទោបង់នូវការបម្រះនទៀលដោយទុក្ខក្នុងទុគ្គតិរបស់ខ្លួន ព្រោះញុំាងអ្នកធ្វើឲ្យដល់សុគតិ ដូចគោមានអាការដូចពោលហើយនោះ ( មិនព្រមផឹកទឹកក្តៅ ) ព្យាយាម ( រក ) ផឹកទឹកត្រជាក់ ដែលមានរសឆ្ងាញ់ និងបន្ទោបង់នូវការជន្លក់របស់ខ្លួនបានផង ( ទាំងនេះក៏ ) ព្រោះការស្រេកក្នុងទឹកត្រជាក់ ដូច្នោះ ។

តែក្នុងធម៌ ( ទាំងពីរ ) ដែលជាសីសៈក្នុងវដ្តកថានោះ ក្នុងព្រះសូត្រខ្លះ ព្រះមានព្រះភាគក៏ទ្រង់សម្តែង(បដិច្ចសមុប្បាទ)ទេសនាលើកធម៌មួយធម្មក្ខន្ធជាមូលនេះ ដូចម្តេច ? គឺទ្រង់សម្តែងថា ម្នាលភិក្ខុទាំងឡាយ សង្ខារទាំងឡាយមានអវិជ្ជាជា

ដើមហេតុ វិញ្ញាណមានសង្ខារជាដើមហេតុ ដូច្នេះជាដើម ន័យដូចគ្នានេះគឺ ម្នាលភិក្ខុទាំងឡាយ តណ្ហារមែងចម្រើនដល់បុគ្គលអ្នកឃើញ តែចំណែកដែលគួរពេញចិត្តក្នុងធម៌ទាំងឡាយ ដែលជាទីតាំងនៃឧបាទានៗ ក៏មានឡើងព្រោះបច្ច័យ គឺតណ្ហា ដូច្នេះជាដើម ក្នុងព្រះសូត្រខ្លះក៏ទ្រង់សម្តែង ( បដិច្ចសមុប្បាទ ) ទេសនា លើកធម៌ទាំងពីរប្រការនេះ ជាមូលក៏មាន នេះតើដូចម្តេច ? សេចក្តីនេះដូចម្តេច ? គឺទ្រង់សម្តែងថា ម្នាលភិក្ខុទាំងឡាយ កាយនេះ របស់មនុស្សល្ងង់ អ្នកមានអវិជ្ជាជាគ្រឿងរាំងប្រកបទៅដោយតណ្ហា ( ប្រព្រឹត្តទៅហើយ ) គឺកើតឡើងដោយហេតុ ដូច្នេះ កាយដូចពោលនេះផង នាមរូបខាងក្រៅផង ទាំងពីរនោះជាទ្វយ ( គឺជាគូគ្នា ) យ៉ាងនេះ ព្រោះអាស្រ័យទ្វយធម៌ គឺអាយតនៈ ៦ នោះឯង ផស្សៈក៏កើតឡើង បុគ្គលល្ងង់ខ្លៅត្រូវធម៌មានផស្សៈជាដើមណាប៉ះខ្ទប់ហើយ រមែងបានសោយសុខទុក្ខ ដូច្នេះជាដើម ។

ក្នុងទេសនាទាំងនោះ ទេសនាថា **អវិជ្ជាបច្ចយា សង្ខារា**-សង្ខារទាំងឡាយមានព្រោះបច្ច័យ គឺអវិជ្ជាជាដើមនេះ ចំពោះទីនេះគប្បីជ្រាបថា ជាទេសនាដែលមានប្រការតែមួយជាមូល ដោយ ( លើក ) អវិជ្ជាជា ( សីសៈ ) ។

វិនិច្ឆ័យដោយប្រភេទនៃទេសនា ក្នុងបាលីបដិច្ចសមុប្បាទនេះ បណ្ឌិតគប្បីជ្រាបដូចពោលមកដូច្នេះ ជាលំដាប់ដំបូង ។

## វិនិច្ឆ័យដោយអត្ថ

ពាក្យថា ដោយអត្ថ គឺដោយសេចក្តី ( ប្រែ ) នៃបទទាំងឡាយ មានបទថា **អវិជ្ជា** ជាដើម អត្ថនេះ តើដូចម្តេចខ្លះ ?

# អត្ថនៃបទអវិជ្ជាបច្ចយា

## អវិជ្ជា

អកុសលកម្ម មានកាយទុច្ចរិតជាដើម ឈ្មោះថា អវិន្ទិយៈ ប្រែថា មិនគួរបាន ព្រោះអត្ថថា មិនគួរបំពេញ ធម្មជាតិណា រមែងបាននូវអវិន្ទិយៈនោះ ហេតុនេះ ទើបធម្មជាតិនោះ ឈ្មោះថា អវិជ្ជា ( បានវត្ថុដែលមិនគួរបាន ) ១ ។

កុសលកម្ម មានកាយសុចរិតជាដើម ឈ្មោះថា វិន្ទិយៈ ( ប្រែថា គួរបាន ) ព្រោះអត្ថផុយគ្នា (គឺគួរបំពេញ) ធម្មជាតិណា រមែងមិនបាននូវវិន្ទិយៈនោះ ហេតុនេះ ទើបធម្មជាតិនោះ ឈ្មោះថា អវិជ្ជា ( មិនបានវត្ថុដែលគួរបាន ) ១ ។

ធម្មជាតិណា ធ្វើអត្ថ គឺភាពជាគំនរនៃខន្ធទាំងឡាយមិនឲ្យប្រាកដ ធ្វើអត្ថ គឺភាពជាគ្រឿងតនៃអាយតនៈទាំងឡាយមិនឲ្យប្រាកដ ធ្វើអត្ថ គឺការសូន្យទទេនៃធាតុទាំងឡាយមិនឲ្យប្រាកដ ធ្វើអត្ថ គឺភាពជាធំនៃឥន្ទ្រិយទាំងឡាយមិនឲ្យប្រាកដ ធ្វើអត្ថ គឺសេចក្តីពិតនៃសច្ចៈទាំងឡាយមិនឲ្យប្រាកដ ហេតុនេះ ទើបធម្មជាតិនោះ ឈ្មោះថា អវិជ្ជា ( ធ្វើអត្ថនៃខន្ធជាដើមមិនឲ្យប្រាកដ ) ១ ។

ធម្មជាតិណា ធ្វើអត្ថ ៤ យ៉ាង ( ក្នុងអរិយសច្ច ៤ ) ដែលពោល ដោយអត្ថ គឺបៀតបៀនជាដើមនៃសច្ចៈ មានទុក្ខសច្ចជាអាទិមិនឲ្យប្រាកដ ហេតុនេះ ទើបធម្មជាតិនោះ ឈ្មោះថា អវិជ្ជា ( ធ្វើអត្ថនៃអរិយសច្ចមិនឲ្យប្រាកដ ) ១ ។

ធម្មជាតិណា ញុំាងសត្វទាំងឡាយឲ្យស្ទុះទៅក្នុងកំណើត គតិ ភព វិញ្ញាណដ្ឋិតិ និងសត្តាវាសទាំងពួងក្នុងសង្សារ ដែលប្រាសចាកទីបំផុត ហេតុនេះ ទើបធម្មជាតិនោះ ឈ្មោះថា **អវិជ្ជា** ( ញុំាងសត្វឲ្យស្ទុះទៅក្នុងសង្សារ ដែលប្រាសចាកទីបំផុត ) ១។

ធម្មជាតិណា រមែងស្ទុះទៅក្នុងបញ្ញត្តិធម៌ទាំងឡាយ មានបុរស និងស្ត្រីជាដើម

ដែលមិនមានដោយបរមត្ថ មិនសុះទៅក្នុងបញ្ញត្តិធម៌ មានខន្ធជាដើម សូម្បីមានដោយបរមត្ថ ហេតុនេះ ទើបធម្មជាតិនោះ ឈ្មោះថា អវិជ្ជា ( សុះទៅក្នុងអវិជ្ជមានបញ្ញត្តិ ឬមិនសុះទៅក្នុងវិជ្ជមានបញ្ញត្តិ ) ១ ។

( ន័យម្យ៉ាងទៀត ) ធម្មជាតិនោះ ឈ្មោះថា អវិជ្ជា ព្រោះបិទបាំងនូវវត្ថុ និងអារម្មណ៍នៃវិញ្ញាណ មានចក្ខុវិញ្ញាណជាដើម និងនូវធម៌ទាំងឡាយ ទាំងដែលជាបដិច្ចសមុប្បាទ (គឺបច្ច័យ) និងដែលជាបដិច្ចសមុប្បន្ន ( គឺផល ) (ដូច្នេះ) ក៏បាន ( ដោយសការៈ ) ។

# បច្ច័យ

ផលអាស្រ័យធម៌ណាទៅ ធម៌នោះឈ្មោះថា បច្ច័យ ( ប្រែថា ធម៌ជាទីអាស្រ័យទៅនៃផល ) ស័ព្ទថា **បដិច្ច**-អាស្រ័យ សេចក្តីថា មិនវៀរ មិនបដិសេធ ស័ព្ទថា **ឯតិ**-ទៅ ដោយអត្ថថា កើតឡើង និងប្រព្រឹត្តទៅ ន័យម្យ៉ាងទៀត អត្ថថា **ឧបការក** អ្នកគាំទ្រ ជាអត្ថនៃបច្ចយស័ព្ទ ។

អវិជ្ជាផង អវិជ្ជានោះជាបច្ច័យផង ហេតុនោះ ទើបឈ្មោះថា **អវិជ្ជាបច្ចយ** ( ប្រែថា អវិជ្ជាជាបច្ច័យ ) ( បទថាអវិជ្ជាបច្ចយា ប្រែថា ) ព្រោះអវិជ្ជាជា បច្ច័យនោះ ។

# សង្ខារ

ធម៌ទាំងឡាយណា តាក់តែង ( វត្ថុផ្សេងៗ ) ឲ្យមាន ( បែប ) សង្ខតៈឡើង ហេតុនេះ ទើបធម៌ទាំងឡាយនោះ ឈ្មោះថា សង្ខារ ( ប្រែថា ធម៌អ្នកតាក់តែង ) តែសង្ខារមាន ២ គឺអវិជ្ជាបច្ចយសង្ខារ-សង្ខារដែលមានអវិជ្ជាជាបច្ច័យ ១ សង្ខារដែលបានមកដោយសង្ខារស័ព្ទ ១ ។

ក្នុងសង្ខារ ២ យ៉ាងនោះ សង្ខារទាំងនេះ គឺបុញ្ញាភិសង្ខារ អបុញ្ញាភិសង្ខារ

និងអនេញ្ជាភិសង្ខារ ជា ៣ ( និង ) កាយសង្ខារ វចីសង្ខារ និងចិត្តសង្ខារ ( ទៀត ) ៣ (រួម)ជា ៦ ចាត់ជាអវិជ្ជាបច្ចយាសង្ខារ សង្ខារទាំងអស់នោះ ក៏បានដល់កុសលចេតនា និងអកុសលចេតនាផ្នែកលោកិយនោះឯង ចំណែកសង្ខារ ៤ គឺសង្ខតសង្ខារ ( សង្ខារ គឺវត្ថុដែលបច្ច័យរបស់ខ្លួនតាក់តែងឡើង ) អភិសង្ខតសង្ខារ ( សង្ខារ គឺវត្ថុដែលកម្ម តាក់តែងឡើង ) អភិសង្ខរណកសង្ខារ ( សង្ខារ គឺតួកម្មដែលជាម្ចាស់នាទីតាក់តែង ) បយោគាភិសង្ខារ ( សង្ខារ គឺការព្យាយាម ) ចាត់ជាសង្ខារដែលបានមកដោយសង្ខារ ស័ព្ទក្នុងសង្ខារ ៤ នោះ ធម៌ដែលមានបច្ច័យទាំងពួង ដែលពោលទុកក្នុងបាលីទាំងឡាយ មានពាក្យថា **អនិច្ចា វត សង្ខារា**-សង្ខារទាំងឡាយមិនទៀងហ្ន៎ជាដើម ឈ្មោះថា សង្ខតសង្ខារ អភិសង្ខតសង្ខារពោលទុកក្នុងអដ្ឋកថាទាំងឡាយថា រូបធម៌ និងអរូបធម៌ ទាំងឡាយ ដែលកើតអំពីកម្ម ប្រព្រឹត្តទៅក្នុងត្រៃភូមិ ឈ្មោះថា អភិសង្ខតសង្ខារ ដូច្នេះ សូម្បីអភិសង្ខតសង្ខារនោះក៏ដល់ការសង្គ្រោះចុះ(ក្នុងសង្ខតសង្ខារដែលពោល ក្នុង ) បាលីថា **អនិច្ចា វត សង្ខារា** នេះដូចគ្នា តែអាគតដ្ឋាននៃអភិសង្ខតសង្ខារនោះ មិនបានប្រាកដ ( ក្នុងបាលី ) ដោយចំពោះចំណែកកុសលចេតនា និងអកុសលចេតនា ដែលប្រព្រឹត្តទៅក្នុងត្រៃភូមិ ហៅថា អភិសង្ខរណកសង្ខារ អាគតដ្ឋាននៃអភិសង្ខរណ-កសង្ខារនោះប្រាកដក្នុងបាលីទាំងឡាយ មានបាលីថា ម្នាលភិក្ខុទាំងឡាយ បុរសបុគ្គល នេះធ្លាក់នៅក្នុងអវិជ្ជា រមែងសាងសង្ខារដែលជាបុណ្យខ្លះ... ដូច្នេះជាដើម ចំណែក សេចក្តីព្យាយាមផ្លូវកាយ និងផ្លូវចិត្ត ហៅថា បយោគាភិសង្ខារ សង្ខារនោះ មកក្នុង បាលីទាំងឡាយ មានបាលីថា ការធ្វើដំណើរទៅ នៃអភិសង្ខារ ( គឺកម្លាំងនៃសេចក្តី ព្យាយាម) មានដរាបណា បុគ្គលនោះក៏ទៅបានដរាបនោះ ហើយក៏ឈប់ ដូចរទេះ ជាប់ភ្ជាប់ដូច្នោះ ដូច្នេះជាដើម ម្យ៉ាងទៀត សង្ខារដែលបានមក ដោយសង្ខារស័ព្ទ មិនមែនមានតែសង្ខារ ៤ នោះប៉ុណ្ណោះទេ សង្ខារដែលបានមក ដោយសង្ខារស័ព្ទដទៃៗ

*ទៀត ក៏មានជាអនេក ដោយន័យ ( ព្រះបាលី ) ថា នៃអាវុសោ វិសាខ កាលភិក្ខុចូលសញ្ញាវេទយិតនិរោធ វចីសង្ខាររលត់មុន បន្ទាប់អំពីនោះ កាយសង្ខាររលត់ បន្ទាប់អំពីនោះ ទើបចិត្តសង្ខាររលត់ ដូច្នេះជាដើម ក្នុងសង្ខារទាំងឡាយនោះ មិនមានសង្ខារដែលមិនគប្បីដល់ការសង្គ្រោះចុះក្នុងសង្ខតសង្ខារឡើយ ។*

## អត្ថនៃស័ព្ទ មានវិញ្ញាណជាដើម

*អធិប្បាយក្នុងបាលីទាំងឡាយ មានពាក្យថា **សង្ខារប្បច្ចយា វិញ្ញាណំ**-វិញ្ញាណមានព្រោះបច្ច័យ គឺសង្ខារជាដើម បន្ទាប់អំពីនេះទៅ គប្បីជ្រាបដោយន័យដែលពោលហើយចុះ ចំណែកក្នុងពាក្យដែលនៅមិនបានអធិប្បាយ គប្បីជ្រាបដូចតទៅនេះថា*

*ធម្មជាតិដែលឈ្មោះថា **វិញ្ញាណ** ព្រោះដឹង ( អារម្មណ៍ ) ផ្សេងៗ ឈ្មោះថា **នាម** ព្រោះបង្អោនទៅ ( កាន់អារម្មណ៍ ) ឈ្មោះថា **រូប** ព្រោះបែកធ្លាយ ឈ្មោះថា **អាយតនៈ** ព្រោះផ្សាយទៅក្នុងអាយៈ ( គឺពង្រីកខ្លួន ) និងព្រោះនាំឲ្យអាយតៈ ( គឺតចេញទៅ ) សភាវៈដែលឈ្មោះថា **ផស្សៈ** ព្រោះប៉ះខ្ទប់គ្នា ( នៃអាយតនៈខាងក្នុង និងអាយតនៈខាងក្រៅ ) ធម្មជាតិដែលឈ្មោះថា **វេទនា** ព្រោះដឹង ( រសអារម្មណ៍ ) ឈ្មោះថា **តណ្ហា** ព្រោះចង់បាន ( អារម្មណ៍ ) ឈ្មោះថា **ឧបាទាន** ព្រោះប្រកាន់មាំ សភាវៈដែលឈ្មោះថា **ភព** ព្រោះកើតឡើង ឬព្រោះធ្វើឲ្យកើតឡើង ការកើតឈ្មោះថា **ជាតិ** ការចាស់ ឈ្មោះថា **ជរា** ធម្មជាតិ ដែលឈ្មោះថា **មរណៈ** ព្រោះជាហេតុស្លាប់ ( នៃសត្វ ) សេចក្តីសោក ឈ្មោះថា **សោក** ការខ្សឹកខ្សួល ឈ្មោះថា **បរិទេវៈ** ធម្មជាតិដែលឈ្មោះថា **ទុក្ខ** ព្រោះធ្វើឲ្យលំបាក ឬឈ្មោះថា **ទុក្ខ** ព្រោះជីកពីរផ្នែកដោយ ( ជីកផ្នែក ) កើតឡើង និង ( ផ្នែក ) តាំងនៅក៏បានភាពជាអ្នកតូចចិត្ត ឈ្មោះថា **ទោមនស្ស** សេចក្តីក្រៀមក្រំយ៉ាងខ្លាំង ឈ្មោះថា **ឧបាយាស** ។*

ពាក្យថា **សម្ភវន្តិ**-មាន បានដល់ កើតឡើង ម្យ៉ាងទៀត បណ្ឌិតកុំគប្បីធ្វើយោជនា ( ប្រកប ) **សម្ភវន្តិ**-ស័ព្ទ ចូលជាមួយបទទាំងឡាយ មានសោកជាដើម ទៅត្រឹមតែប៉ុណ្ណោះឡើយ ដែលត្រឹមត្រូវគប្បីធ្វើយោជនា **សម្ភវន្តិ**-ស័ព្ទ ចូលជាមួយបទទាំងពួង ព្រោះថា កាលពោលដោយប្រការក្រៅអំពីនេះ ( គឺកាលមិនប្រកប សម្ភវន្តិស័ព្ទ ) ថា **អវិជ្ជាបច្ចយា សង្ខារ** ( ព្រងើយៗ ) សេចក្តីក៏នឹងមិនប្រាកដថា សង្ខារទាំងឡាយធ្វើអ្វី ( គឺមិនមានបទកិរិយា ) តែកាលមានប្រកបស័ព្ទថា សម្ភវន្តិ ចូល រមែងធ្វើសេចក្តីកំណត់បាន ទាំងបច្ចយធម៌ ទាំងបច្ចយុប្បន្នធម៌ថា **អវិជ្ជា ច សា បច្ចយោ ចាតិ អវិជ្ជាបច្ចយោ តស្មា អវិជ្ជាបច្ចយា សង្ខារា សម្ភវន្តិ**-អវិជ្ជាផង អវិជ្ជានោះជាបច្ច័យផង ហេតុនោះ ទើបឈ្មោះថា អវិជ្ជាបច្ចយ សង្ខារទាំងឡាយរមែងកើតឡើងព្រោះអវិជ្ជាបច្ចយនោះ ដូច្នេះ ក្នុងបទទាំងពួងក៏ដូចន័យនេះ ។

ពាក្យថា **ឯវំ** ជាពាក្យបង្ហាញន័យដែលសម្តែងមកហើយ ដោយពាក្យ ឯវំ នោះ សម្តែងថា បច្ចយុប្បន្នធម៌ទាំងឡាយកើតឡើងព្រោះបច្ច័យ មានអវិជ្ជាជាដើមនោះឯង ជាហេតុ មិនមែនកើតឡើងព្រោះព្រះឥស្សរបណ្តាលជាដើមទេ ពាក្យថា **ឯតស្ស**-នោះ គឺតាមដែលពោលមក ពាក្យថា **កេវលស្ស** ប្រែថា មិន ( មានសុខ ) លាយឡំ ឬទាំងមូល ។ ពាក្យថា **ទុក្ខក្ខន្ធស្ស** ប្រែថា កងទុក្ខ គឺមិនមែនសត្វ មិនមែនរបស់សុខ របស់ស្អាតជាដើម ពាក្យថា **សមុទយោ** ប្រែថា ការកើតឡើង ពាក្យថា **ហោតិ** ប្រែថា រមែងមាន ។

វិនិច្ឆ័យដោយអត្ថក្នុងបាលីបដិច្ចសមុប្បាទនេះ បណ្ឌិតគប្បីជ្រាបដូចពណ៌នាមក ដូច្នេះ ។

## វិនិច្ឆ័យដោយលក្ខណៈជាដើម

ពាក្យថា ដោយលក្ខណៈជាដើម គឺដោយលក្ខណៈជាដើមនៃបទ មានអវិជ្ជា

ជាអាទិ៍ លក្ខណៈជាដើមនេះដូចម្តេចខ្លះ ?

អវិជ្ជា មានការមិនដឹងជាលក្ខណៈ មានការធ្វើឲ្យវង្វេងជារស មានការបិទបាំង ( នូវសភាវៈ ) ជាបច្ចុប្បដ្ឋាន មានអាសវៈជាបទដ្ឋាន ។

សង្ខារ មានការតាក់តែងជាលក្ខណៈ មានការព្យាយាម ( ដើម្បីសាងបដិសន្ធិ ) ជារស មានចេតនាជាបច្ចុប្បដ្ឋាន មានអវិជ្ជាជាបទដ្ឋាន ។

វិញ្ញាណ មានការដឹងវិសេសជាលក្ខណៈ មានភាពជាប្រធាន ( នៃនាមរូប ) ជារស មានបដិសន្ធិជាបច្ចុប្បដ្ឋាន មានសង្ខារជាបទដ្ឋាន ឬមានវត្ថុ និងអារម្មណ៍ ជាបទដ្ឋាន ។

នាម មានការបង្អោនទៅ ( កាន់អារម្មណ៍ ) ជាលក្ខណៈ មានសម្បយោគ ( ការប្រកបគ្នានឹងគ្នាទុក ) ជារស មានការមិនបែកគ្នាជាបច្ចុប្បដ្ឋាន មានវិញ្ញាណ ជាបទដ្ឋាន ។

រូប មានការបែកធ្លាយជាលក្ខណៈ មានការខ្ចាត់ខ្ចាយជារស មានភាពជា អព្យាកតៈជាបច្ចុប្បដ្ឋាន មានវិញ្ញាណជាបទដ្ឋាន ។

សឡាយតនៈ មានការជាប់តជាលក្ខណៈ មានការឃើញជាដើមជារស មាន ភាពជាវត្ថុ និងទ្វារជាបច្ចុប្បដ្ឋាន មាននាមរូបជាបទដ្ឋាន ។

ផស្សៈ មានការពាល់ត្រូវជាលក្ខណៈ មានការប៉ះខ្ទប់ជារស មានការប្រជុំគ្នា ( នៃទ្វារ អារម្មណ៍ និងវិញ្ញាណ ) ជាបច្ចុប្បដ្ឋាន មានសឡាយតនៈ ជាបទដ្ឋាន ។

វេទនា មានការសោយ ( អារម្មណ៍ ) ជាលក្ខណៈ មានការប្រសព្វនឹងរស នៃអារម្មណ៍ជាកិច្ច មានសុខ និងទុក្ខជាបច្ចុប្បដ្ឋាន មានផស្សៈជាបទដ្ឋាន ។

តណ្ហា មានភាពជាហេតុ ( គឺជាទុក្ខសមុទយៈ ) ជាលក្ខណៈ មានការត្រេកអរ ( ក្នុងអារម្មណ៍នោះៗ ) ជារស មានការមិនឆ្អែត ( ក្នុងអារម្មណ៍ ) ជាបច្ចុប្បដ្ឋាន

មានវេទនាជាបទដ្ឋាន ។

ឧបាទាន មានការប្រកាន់ជាលក្ខណៈ មានការមិនលែងជារស មានការឃើញដោយអំណាចការហួងហែងនៃតណ្ហាជាបច្ចុប្បដ្ឋាន មានតណ្ហាជាបទដ្ឋាន ។

ភព មានកម្ម និងផលរបស់កម្មជាលក្ខណៈ មានការបានជួបនូវការបានកើតជារស មានកុសលអកុសល និងអព្យាកតៈជាបច្ចុប្បដ្ឋាន មានឧបាទានជាបទដ្ឋាន។

លក្ខណៈជាដើមនៃជាតិជាអាទិ៍ គប្បីជ្រាបដោយន័យដែលពោលហើយ ក្នុងសច្ចនិទ្ទេសឯណោះចុះ ។

វិនិច្ឆ័យដោយលក្ខណៈជាដើម ក្នុងបាលីបដិច្ចសមុប្បាទនេះ គប្បីជ្រាបដូចពោលមកដូច្នេះ ប្រការមួយ ។

## ដោយប្រភេទផ្សេងៗ មានតែម្យ៉ាងជាដើម

ក្នុងពាក្យថា ដោយប្រភេទផ្សេងៗ មានតែម្យ៉ាងជាដើមនេះ មានវិនិច្ឆ័យថា អវិជ្ជាមានតែម្យ៉ាងដោយភាវៈ គឺការមិនដឹង ឬការមិនឃើញ ឬការវង្វេងជាដើម មាន ២ យ៉ាង ដោយការមិនបដិបត្តិ និងការបដិបត្តិខុស ម្យ៉ាងទៀត មាន ២ ដោយសសង្ខារ និងអសង្ខារ មាន ៣ យ៉ាង ដោយសម្បយោគជាមួយវេទនា ៣ មាន ៤ យ៉ាង ដោយការមិនត្រាស់ដឹងសច្ចៈ ៤ មាន ៥ យ៉ាង ដោយបិទបាំងនូវទោស ក្នុងគតិ ៥ ចំណែកការដែលតណ្ហាមាន ៦ យ៉ាង ក្នុងអង្គបដិច្ចសមុប្បាទដែលជាអរូបធម៌ទាំងអស់ គប្បីជ្រាបដោយ ( ប្រព្រឹត្តទៅក្នុង ) ទ្វារ ( ៦ ) និងអារម្មណ៍ ( ៦ ) ។

សង្ខារមានតែម្យ៉ាង ដោយសាសវធម ជាវិបាកធម្មធម៌ ( ធម៌មានវិបាកជាធម្មតា ) ជាដើម មាន ២ យ៉ាង ដោយកុសល និងអកុសល ម្យ៉ាងទៀត មាន ២ ដោយភាពជាបរិត្ត មហគ្គតៈ ជាហីនៈ មជ្ឈិម ជាមិច្ឆត្តៈ សម្មត្តៈ ជានិយត អនិយត

មាន ៣ យ៉ាង ដោយភាពជាអភិសង្ខារ ៣ មានបុញ្ញាភិសង្ខារជាដើម មាន ៤ យ៉ាង ដោយឲ្យប្រព្រឹត្តទៅក្នុងកំណើត ៤ មាន ៥ យ៉ាង ដោយញ៉ាំងសត្វឲ្យទៅកាន់គតិ ៥ ។

វិញ្ញាណមានតែម្យ៉ាង ដោយភាពជាលោកិយវិបាកជាដើម មាន ២ យ៉ាង ដោយសហេតុកៈ និងអហេតុកៈជាដើម មាន ៣ យ៉ាង ដោយរាប់ទាក់ទងក្នុងភព ៣ ដោយសម្បយោគជាមួយនឹងវេទនា ៣ និងដោយអហេតុកៈ ទុកហេតុកៈ តិហេតុកៈ មាន ៤ យ៉ាង និង ៥ យ៉ាង ដោយកំណើត ( ៤ ) និងគតិ ( ៥ ) ។

នាមរូបមានតែម្យ៉ាង ដោយវិញ្ញាណសន្និស្សយ ( ទីអាស្រ័យនៃវិញ្ញាណ ) និងដោយកម្មប្បច្ច័យ ( បច្ច័យរបស់កម្ម ) មាន ២ យ៉ាង ដោយសារម្មណៈ ( មានអារម្មណ៍=នាម ) និងអនារម្មណៈ ( មិនមានអារម្មណ៍=រូប ) មាន ៣ យ៉ាង ដោយកាល មានអតីតជាដើម មាន ៤ និង ៥ យ៉ាង ដោយកំណើត និងគតិ ។

សឡាយតនៈមានតែម្យ៉ាង ដោយភាពជាទីកើត និងដោយភាពជាទីប្រជុំ ( នៃវិញ្ញាណ និងធម៌ដែលសម្បយុត្តជាមួយនឹងវិញ្ញាណនោះ ) មាន ២ យ៉ាង ដោយភាពជាភូតប្បសាទ ( ចំណែកដែលថ្លានៃភូតរូប ) និងជាគ្រឿងដឹងពិសេស មាន ៣ យ៉ាងដោយសម្បត្តគោចរ(ទទួលបានតែអារម្មណ៍ដែលមកដល់ខ្លួន) អសម្បត្តគោចរ ( ទទួលអារម្មណ៍ដែលមិនទាន់មកដល់ខ្លួនបាន ) និងដោយនោភយគោចរ ( ទទួលអារម្មណ៍មិនមែនទាំង ២ យ៉ាងនោះ ) មាន ៤ យ៉ាង និង ៥ យ៉ាង ដោយជាប់ដោយកំណើត និងគតិ ។

សូម្បីការមានប្រភេទផ្សេងៗ មានតែម្យ៉ាងជាដើមនៃអង្គដ៏សេស មានផស្សៈជាអាទិ៍ក៏គប្បីជ្រាបដោយន័យ ( ដែលពោល ) នេះចុះ ។

វិនិច្ឆ័យដោយប្រភេទផ្សេងៗ មានតែម្យ៉ាងជាដើម ក្នុងបាលីបដិច្ចសមុប្បាទនេះគប្បីជ្រាបដូចពោលមក ដូច្នេះ ប្រការមួយ ។

# ដោយកំណត់អង្គ

ពាក្យថា និងដោយកំណត់អង្គទាំងឡាយ មានវិនិច្ឆ័យថា ក្នុងបដិច្ចសមុប្បាទធម៌ទាំងឡាយនេះ ធម៌ មានសោកជាដើម ព្រះសាស្ដាត្រាស់ដើម្បីសម្ដែងការមិនដាច់នៃភវចក្រ ( កង់នៃភព ) ព្រោះធម៌ មានសោកជាដើមនោះ រមែងមានដល់បុគ្គលល្ងង់ខ្លៅ អ្នកត្រូវជរា និងមរណៈពាល់ត្រូវ ដូចដែលត្រាស់ទុកថា ម្នាលភិក្ខុទាំងឡាយ បុថុជ្ជនអ្នកមិនបានស្ដាប់ ជាអ្នកត្រូវទុក្ខវេទនាផ្លូវកាយពាល់ត្រូវហើយ រមែងសោយសោក ខ្សឹកខ្សួល គក់ទ្រូង ស្រែកយំ ដល់នូវការវង្វេងវង្វាយទៅជាដើម និងដោយព្រះពុទ្ធវចនៈថា ការរលត់ទៅនៃធម៌ទាំងឡាយ មានសោកជាដើមនោះនៅមានដរាបណា ការរលត់ទៅនៃអវិជ្ជាក៏នៅមានដរាបនោះ ដូច្នេះ ភវចក្រក៏ជាការភ្ជាប់ចូលជាបទថា **អវិជ្ជាបច្ចយា សង្ខារា** ទៀត ព្រោះហេតុនោះ ធម៌ ១២ ប៉ុណ្ណោះ ដោយនាំសង្ខេបធម៌ មានសោកជាដើមនោះឯងចូល ជាមួយគ្នានឹងជរាមរណៈ គប្បីជ្រាបថា ជាអង្គនៃបដិច្ចសមុប្បាទ ។

វិនិច្ឆ័យដោយកំណត់អង្គទាំងឡាយក្នុងបាលីបដិច្ចសមុប្បាទនេះ បណ្ឌិតគប្បីជ្រាបដូចពោលមកដូច្នេះ ប្រការមួយ ។

នេះត្រឹមតែជាសង្ខេបកថា ក្នុងបដិច្ចសមុប្បាទធម៌នេះ ចំណែកសេចក្ដី ( តទៅ ) នេះ ជាវិត្ថារន័យ ។

# មហាដីកា

## ពណ៌នាបញ្ញាភូមិនិទ្ទេស

## កថាពណ៌នាដោយបដិច្ចសមុប្បាទ

ពាក្យថា **នៃបញ្ញានេះ** បានដល់ នៃវិបស្សនានេះ តាមដែលបានត្រាស់ដឹងហើយ ។ ពាក្យថា **ដែលជាភូមិ** បានដល់ ដែលជាទីតាំងនៃការប្រព្រឹត្តទៅ ។ ឈ្មោះថា **បដិច្ចសមុប្បាទ** និង **បដិច្ចសមុប្បន្ន** នេះ សម្រេចដោយការសម្ព័ន្ធគ្នានឹងគ្នា ដូចឈ្មោះថា ឪពុក និងកូនក៏ពិត សូម្បីដូច្នោះ លោកអាចារ្យក៏បានញែកទុកតាមលំដាប់នោះឯង ក្នុងធម៌ដែលជាហេតុ និងជាផល ព្រោះដូច្នោះ ទើបលោកអាចារ្យពោលការចែកទុកដោយពាក្យថា **បដិច្ចសមុប្បាទ** ជាដើមនោះឯង ។ ពាក្យថា **ដោយអាទិស័ព្ទ** គឺដោយអាទិស័ព្ទដែលពោលទុកក្នុងពាក្យនេះថា **បដិច្ចសមុប្បាទាទិភេទា** ។ អធិប្បាយថា **ជាធម៌ដែលនៅសល់** ដោយអំណាចការពណ៌នា ដោយហេតុនោះ ទើបលោកអាចារ្យពោលថា **ទើបដល់លំដាប់ការពណ៌នាបដិច្ចសមុប្បាទ និងបដិច្ចសមុប្បន្នធម៌ទាំងឡាយនោះ** ។

ធម៌ទាំងឡាយ មានអវិជ្ជាជាដើម ឈ្មោះថា ជាបដិច្ចសមុប្បាទ ។ លោកកាលសម្តែងថា សេចក្តីនេះបណ្ឌិតគប្បីជ្រាបតាមបទព្រះសូត្រនេះ ទើបពោលពាក្យជាដើមថា **វុត្តញ្ហេតំ** ម្យ៉ាងទៀត ដើម្បីនឹងសម្តែងបដិច្ចសមុប្បន្នធម៌ទាំងឡាយ ទើបផ្តើមពាក្យជាដើមថា **ជរាមរណាទយោ បទ** ប្រែថា ចំណែកធម៌ទាំងឡាយ មានជរានិងមរណៈជាដើម ។ សួរថា ក្នុងអធិការនេះ ហេតុអ្វី ទើបព្រះមានព្រះភាគទ្រង់សម្តែងបដិច្ចសមុប្បាទធម៌ទុកដោយអនុលោម ទ្រង់សម្តែងបដិច្ចសមុប្បន្នធម៌ទុកដោយ

បដិលោម ? ឆ្លើយថា ព្រោះបដិច្ចសមុប្បន្នធម៌នោះ កើតឡើងអំពីបច្ច័យ ដើម្បីនឹងសម្តែងលំដាប់របស់បច្ច័យនោះ ។

ឈ្មោះថា **អនិច្ចំ** ព្រោះអត្ថថា មិនទៀង គឺមិនទៀងពិត ។ ឈ្មោះថា **សង្ខតំ** ព្រោះអត្ថថា ដែលបច្ច័យប្រជុំគ្នា គឺព្រមគ្នាតាក់តែងឡើង ។ ឈ្មោះថា **បដិច្ចសមុប្បន្នំ** ព្រោះអត្ថថា កើតឡើងដោយអាស្រ័យគ្នា គឺគួរដល់បច្ច័យ បានដល់ អាស្រ័យបច្ច័យប្រព្រឹត្តទៅរួមគ្នានោះឯង ។ មានការអស់ទៅជាសភាវៈ ឈ្មោះថា **ខយធម្មំ** ។ មានការអស់ទៅជាសភាវៈ ឈ្មោះថា **វយធម្មំ** ។ មានការប្រាសទៅជាសភាវៈ គឺមានការអស់ទៅជាសភាវៈ ឈ្មោះថា **វិរាគធម្មំ** ។ មានការរលត់ទៅជាសភាវៈ ឈ្មោះថា **និរោធធម្មំ** ។ ពាក្យណាដែលសល់ក្នុងអធិការនេះ ដែលគួរពោលទុក ពាក្យនោះនឹងមានជាក់ច្បាស់ខាងមុខ ។

បទថា **ឯត្ថ** ប៉ុនគ្នានឹង **ឯតេសុ យោគ យថាវុត្តេសុ សុត្តបទេសុ** ប្រែថា ក្នុងបទព្រះសូត្រដែលពោលហើយយ៉ាងនេះ ។ បទថា **សន្និដ្ឋោ** ប្រែថា ការបង្រួញ ។

បទថា **ជាតិប្បច្ចយា** ប្រែថា ព្រោះបច្ច័យ គឺជាតិ ។ បទនេះ ជាបញ្ចមីវិភត្តិចុះក្នុងអត្ថ គឺហេតុ ។ ពាក្យថា **ឋិតា វ សា ធាតុ** សេចក្តីថា ជរា និងមរណៈ មានវត្ថុនេះជាបច្ច័យថា **ព្រោះជាតិជាបច្ច័យ ទើបមានជរា និងមរណៈ** ដូច្នេះ ធាតុក៏ដូច្នេះ គឺសភាវៈក៏ដូច្នេះ ។ ធាតុនោះមុនព្រះតថាគតទ្រង់ឧប្បត្តិ និងផុតទៅមិនមាននរណាស្គាល់ តែមកស្គាល់ត្រង់កណ្តាល ព្រះតថាគតទ្រង់មិនបាន ធ្វើឲ្យកើតឡើង ដោយពិតនោះ ជរា និងមរណៈ ដែលមានក៏គង់មាន ព្រោះជាតិជាបច្ច័យសព្វកាល ព្រោះដូច្នោះទើបឈ្មោះថា តាំងនៅនោះឯង ។ តែព្រោះត្រាស់ដឹងបានដោយព្រះសយម្ភូញាណតែម្យ៉ាង និងព្រោះដឹងទូទៅថា **ព្រះធម៌នេះ ព្រះតថាគតទ្រង់ត្រាស់ដឹងហើយ** ទើបព្រះតថាគតបានទទួលព្រះនាមថា **ជាម្ចាស់របស់ព្រះធម៌** មិនមែនព្រោះទ្រង់ញុំាងព្រះ

ធម៌ដែលមិនធ្លាប់មានឲ្យកើតឡើង ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា **ធាតុនោះតាំងនៅហើយនោះឯង** ។ ធាតុនោះឯង ឈ្មោះថា **ធម្មដ្ឋិតតា** ព្រោះអត្ថថាជាការតាំងនៅរបស់សភាវៈ ឬហេតុ នេះដែលទឹងចុះកាន់បានយ៉ាងនេះ ព្រោះមិនមានវិបល្លាស ក្នុងសេចក្តីនេះថា **ព្រោះជាតិជាបច្ច័យ ទើបមានជរា និងមរណៈ** ។ ដោយភាវៈយ៉ាងនោះឯង ។ មួយ៉ាងទៀត ជាតិជាការតាំងនៅនៃការកើតឡើងរបស់ជរា និងមរណៈ ទើបជាការតាំងនៅនៃបវត្ត (ការកើត) **អាយូហន** (ការប្រមូលមក) **សំយោគ** (ការប្រកប) **បលិពោធ** (ការកង្វល់) **សមុទយៈ ហេតុ** និង **បច្ច័យ** ព្រោះដូច្នោះភាពដែលជាតិនោះជាធម្មជាតិតាំងនៅ ក៏ដោយភាវៈនៃហេតុ មានការកើតឡើងនៃជរា និងមរណៈនោះជាដើម ព្រះមានព្រះភាគ រមែងត្រាស់ដល់ហេតុម្យ៉ាង ដោយជាទីធ្វើឲ្យយល់ដល់ផលថា **ធម្មដ្ឋិតតា** ។ ន័យម្យ៉ាងទៀត សភាវៈឈ្មោះថា **ធម៌** ព្រោះអត្ថថា ដែលបច្ច័យទាំងឡាយទ្រទ្រង់ទុក ឈ្មោះថា **ឋិតិ** ព្រោះអត្ថថា ជាទីតាំងនៃផលដោយជាធម្មជាតិមានការប្រព្រឹត្តទៅទាក់ទងដោយផលនោះ ការតាំងនៅនៃធម៌ ឈ្មោះថា **ធម្មដ្ឋិតិ** ។ ម្យ៉ាងទៀត ហេតុ ឈ្មោះថា **ធម្មៈ** អធិប្បាយថា បានដល់ បច្ច័យ ។ សភាវៈ គឺការតាំងនៅនៃធម៌ និងសភាវៈដទៃក្រៅ អំពីធម៌មិនមាន ព្រោះដូច្នោះទើបឈ្មោះថា **ធម្មដ្ឋិតិ** បានដល់ បច្ច័យ ដោយហេតុនោះទើបព្រះធម្មសេនាបតីសារីបុត្រពោលទុកថា **បញ្ញាក្នុងការកំណត់បច្ច័យ** ឈ្មោះថា **ធម្មដ្ឋិតិញ្ញាណ** ធម្មដ្ឋិតិនោះឯងជា **ធម្មដ្ឋិតតា** ។ ធាតុនោះ ឈ្មោះថា **ធម្មនិយាមតា** ព្រោះអត្ថថា ជាភាពពិតប្រាកដ គឺជាការកំណត់បាន ព្រោះសភាវៈ ឬហេតុនេះថា **ព្រោះជាតិជាបច្ច័យ ទើបមានជរា និងមរណៈ** ដូច្នេះ និងមិនមានដោយប្រការដទៃ គឺព្រោះតែងយល់ថា **មិនមែនព្រោះជាតិជាបច្ច័យ ទើបមានជរា និងមរណៈ** ដូច្នេះ ទើបមិនដូច្នោះ ។ ន័យម្យ៉ាងទៀត កាលមានជាតិ ទើបមានជរា និងមរណៈជាផល ឈ្មោះថា ជាការតាំងនៅក្នុងធម៌ គឺ

ក្នុងហេតុ ព្រោះដូច្នោះ ទើបឈ្មោះថា **ធម្មដ្ឋិតតា** ។ កាលជាតិមិនមាន ជរា និងមរណៈ ដែលជាផលក៏មិនមាន ទើបជាការពិតប្រាកដក្នុងធម៌ ព្រោះដូច្នោះ ទើបឈ្មោះថា **ធម្មនិយាមតា** ព្រះមានព្រះភាគ ទ្រង់រមែងធ្វើហេតុ ឲ្យជាក់ច្បាស់ដោយហេតុ ឲ្យជាក់ច្បាស់ដោយផល ដោយប្រការ ដូចពោលមក ដូច្នេះ ។ **តំ យោគ បិតា វ សា ធាតូតិអាទិនា វុត្តំ ឥទប្បយតំ** ប្រែថា ជាធម៌ មានវត្ថុនេះជាបច្ច័យ ដែលត្រាស់ទុកដោយន័យជាដើមថា ធាតុនោះតាំងនៅនោះឯង ចូលជាមួយ **អភិសម្ពុជ្ឈតិ អភិសម្ពុជ្ឈតិ** ប្រែដោយព្យញ្ជនៈថា រមែងត្រាស់ដឹងចំពោះមុខ ដោយអាការធ្វើឲ្យប្រចក្ស ប្រែយកសេចក្តីថា រមែងចាក់ធ្លុះតាមសេចក្តីពិត ។ បទថា **អភិសមេតិ** ជាវេវចនៈរបស់ពាក្យថា **អភិសម្ពុជ្ឈតិ** នោះ ។ ត្រាស់អំពីខាងដើម ឈ្មោះថា **អាចិក្ខតិ** អធិប្បាយថា លើកឡើងសម្តែង ។ កាលធ្វើពាក្យដែលលើកឡើងសម្តែងនោះឯង ឲ្យចប់សព្វគ្រប់ ឈ្មោះថា **ទេសេតិ** ប្រែថា សម្តែង ។ កាលទ្រង់ឲ្យយល់ចូលចិត្តអត្ថតាមដែលលើកឡើងសម្តែងនោះ ដោយប្រការទាំងឡាយ ដោយអំណាចការសម្តែងលម្អិត ឈ្មោះថា **បញ្ញាបេតិ** ប្រែថា រមែងបញ្ញត្ត ។ កាលឲ្យតាំងទុកចំពោះដោយប្រការទាំងឡាយនោះឯង ឈ្មោះថា **បដ្ឋបេតិ** ប្រែថា រមែងតាំងទុកចំពោះ ។ ឈ្មោះថា **វិវរតិ វិភជតិ** ប្រែថា រមែងបើកផ្សាយ រមែងចែកនូវអត្ថតាមដែលសម្តែងលម្អិត ដោយអំណាចការសម្តែងលម្អិតគ្រប់ចំនួន កាលធ្វើអត្ថដែលបានបើកផ្សាយ និងដែលចែកឲ្យប្រាកដ ក៏ដោយការសម្តែងហេតុ និងឧទាហរណ៍ ឈ្មោះថា **ឧត្តានីករោតិ** ប្រែថា ធ្វើឲ្យរាក់ ។ ឈ្មោះថា **បស្សថាតិ ចាហ** ដោយអំណាចដែលទ្រង់ធ្វើឲ្យរាក់ ត្រាស់ដដែលធ្វើប្រចក្សយ៉ាងនោះ ។

បទថា **បច្ចយលក្ខណោ** ប្រែថា មានភាពជាបច្ច័យជាលក្ខណៈក៏បាន ឬប្រែថា គប្បីកំណត់ថា ជាបច្ច័យក៏បាន ឈ្មោះថា **មានការតាមចងភ្ជាក់ទុកនូវទុក្ខ ជារស**

ព្រោះមានការឲ្យតាមចងធ្លាក់ទុកក្នុងបវត្តិកាលជាកិច្ច ។ ឈ្មោះថា **មានភាពជាផ្លូវខុសជាបច្ចុប្បដ្ឋាន** ព្រោះភាពជាផ្លូវខុសចំពោះផ្លូវដែលឲ្យដល់នូវព្រះនិព្វាន ។

**សោ បនាយំ យោគ បដិច្ចសមុប្បាទោ** ប្រែថា បដិច្ចសមុប្បាទនេះ ។ ផលណាគួរកើតឡើងបាន ព្រោះបច្ច័យមានប្រមាណប៉ុនណា ការកើតឡើងរបស់ផលនោះ ក៏ដោយបច្ច័យទាំងនោះ ដែលមិនខ្វះខាតនោះឯង ហើយប្រយោជន៍របស់ផលនោះរមែងមិនមានដោយបច្ច័យដទៃអំពីបច្ច័យនោះ ព្រោះដូច្នោះ ទើបលោកអាចារ្យពោលថា **ដោយបច្ច័យដែលមិនតិចមិនច្រើននោះឯង** ។ លោកអាចារ្យសម្ដែងថា ប្រៀបដូចចក្ខុវិញ្ញាណសម្រេចបានក៏ដោយចក្ខុ ១ រូប ១ ពន្លឺ ១ មនសិការ ១ ដោយការធ្វើផលនោះៗ ឲ្យសម្រេច ទើបជាការដល់ព្រមនៃបច្ច័យនោះ មានការញ៉ាំងផលនោះៗ ឲ្យសម្រេចជាសំខាន់ ឈ្មោះថា **តថតា** ភាពជាយ៉ាងនោះ ពាក្យថា **សាមគ្គី** បានដល់ ការប្រជុំគ្នា អធិប្បាយថា បានដល់ ការព្រមព្រៀង ។ ពាក្យថា **ព្រោះការមិនកើតឡើងក៏ទេ** គឺព្រោះមិនមាននៃការមិនកើតឡើង ។ កាលការព្រមព្រៀងនៃបច្ច័យមាន ការព្រមព្រៀងនៃបច្ច័យនោះ ជាវត្ថុឃៀងឃាតក្នុងការដែលមិនកើតឡើង ក៏នឹងគប្បីមានបាន ។ ពាក្យថា **ដោយបច្ច័យនៃធម៌ដទៃ** បានដល់ ដោយបច្ច័យនៃធម៌ គឺផលដទៃ ។ ពាក្យថា **ព្រោះធម៌ដទៃមិនកើតឡើង** បានដល់ ព្រោះធម៌ គឺផលដទៃក្រៅអំពីធម៌នោះមិនកើតឡើង ។ ពិតហើយ សោតវិញ្ញាណមិនមានការកើតឡើងដោយចក្ខុ រូប ពន្លឺ មនសិការ ក្នុងកាលណាមួយឡើយ បើគប្បីមានសោតដែលបានឈ្មោះថា ជាភាពដទៃនៃការប្រជុំនោះ ក៏គប្បីមានបាន តែសេចក្ដីនេះមិនមែនដូច្នោះឡើយ ព្រោះដូច្នោះ ទើបព្រះមានព្រះភាគត្រាស់ថា ភាពមិនជាដទៃ ។ បទថា **បច្ចយតោ** ប្រែថា ព្រោះភាពជាបច្ច័យ ។ សូម្បីក្នុងបទថា **បច្ចយសមុបាតោ** នេះ ក៏មានន័យនេះដូចគ្នា ។

លោកបន្ថែមបទ **តា**-ស័ព្ទថា **ឥទប្បច្ចយា ឯវ ឥទប្បច្ចយតា** ដែលប្រែថា ឥទប្បច្ចយានោះឯង ជាឥទប្បច្ចយតា មិនមានអត្ថពិសេសណាមួយ ដូចពាក្យថា **ទេវោ ឯវ ទេវតា** ដែលប្រែថា ទេវោនោះឯងជាទេវតា ។ ពាក្យថា **ឥទប្បច្ចយានំ វា សមូហោ ឥទប្បច្ចយតា** ដែលប្រែថា ន័យម្យ៉ាងទៀត ប្រជុំនៃឥទប្បច្ចយា ឈ្មោះថា **ឥទប្បច្ចយតា** លោកពោលដល់ **តា**-ស័ព្ទ ដែលមានសមូហៈជាអត្ថ ដែលប្រែថា ប្រជុំ ដូចជាពាក្យថា **ជនានំ សមូហោ ជនតា** ប្រជុំនៃជនទាំងឡាយ ឈ្មោះថា **ជនតា** ។ **ឥទប្បច្ចយ**-ស័ព្ទ រមែងប្រាកដជាកម្មធារយសមាស ព្រោះសម្តែងដល់ភាព ដែល **ឥទំ**-ស័ព្ទ ជាសមានាធិករណៈជាមួយ **កឹ**-ស័ព្ទ ដែលជាសមានាធិករណៈ និងជាតិស័ព្ទ និងបច្ចយស័ព្ទថា **អត្ថិ ឥទប្បច្ចយា ជរាមរណន្តិ ឥតិ បុដ្ឋេន សតា អានន្ទ អត្ថីតិស្ស វចនីយំ ។ កឹ បច្ចយា ជរាមរណន្តិ ឥតិ ចេ វទេយ្យ ជាតិប្បច្ចយា ជរាមរណន្តិ ឥច្ចស្ស វចនីយំ** ប្រែថា ម្នាលអានន្ទ កាលអ្នកត្រូវសួរថា ជរាមរណៈមាន ព្រោះមានវត្ថុនេះជាបច្ច័យឬ អ្នកគប្បីឆ្លើយថា មាន ។ ប្រសិនបើគេសួរថា ជរាមរណៈមាន ព្រោះអ្វីជាបច្ច័យ អ្នកគប្បីឆ្លើយថា ជរាមរណៈមាន ព្រោះជាតិជាបច្ច័យ ដូច្នេះមិនមែនឬ ។ ព្រោះថា សេចក្តីនេះ មិនមានការសួរដល់ថា ជរាមរណៈមាន ព្រោះបច្ច័យនៃជរាមរណៈ ឬរបស់ធម៌ដទៃថា **ឥមស្ស បច្ចយា ឥទប្បច្ចយា** បច្ច័យនៃវត្ថុនេះ ឈ្មោះថា **ឥទប្បច្ចយា** ព្រោះជាប្រការដែលធ្លាប់ដឹងហើយ និងព្រោះជាការមិនមាន តែក៏គង់សម្រេចជាពាក្យសួរ ដល់បច្ច័យរបស់ជរា និងមរណៈផង ។ ការសួរដល់បច្ច័យនៃ **ឥទំ**-ស័ព្ទថា **ឥមស្មា បច្ចយា** ព្រោះបច្ច័យនេះរមែងគួរ ព្រោះជាសមានាធិករណៈ និងបច្ចយស័ព្ទ ។ ភាពដែល **ឥទំ**-ស័ព្ទ ជាសមានាធិករណៈនោះ រមែងបានក្នុងការបង្រួញ សេចក្តីខាងក្រៅ ។ ព្រោះហេតុនោះ កម្មធារិយសមាស គប្បីបានក្នុងការប្រាថ្នា ពាក្យដែលសម្តែងអត្ថនៃអញ្ញបទ ។ សួរថា ក្នុងការបង្រួញ

ឆដ្ឋីវិភត្តិរមែងមិនមានភាពជាសមានាធិករណៈ ព្រោះដូច្នោះ មិនជាកម្មធារយសមាស បានឬ ? ឆ្លើយថា សេចក្តីនេះមិនជាដូច្នោះឡើយ ព្រោះនៅមានសេចក្តីត្រូវការពាក្យដទៃទៀត ។ ពិតហើយ សេចក្តីត្រូវការពាក្យថាបដិច្ចសមុប្បាទនេះ ក្នុងពាក្យនេះថា **ឥទប្បច្ចយតា បដិច្ចសមុប្បាទោ** ប្រែថា ឥទប្បច្ចយតាក៏ជាបដិច្ចសមុប្បាទ ចំណែកក្នុងពាក្យ **អត្ថិ ឥទប្បច្ចយា ជរាមរណំ** ជរា និងមរណៈមាន ព្រោះធម៌នេះជាបច្ច័យ ព្រោះជាពាក្យសាកសួរត្រឹមតែជាបច្ច័យដល់ជរាមរណៈ ព្រោះដូច្នោះ ក្នុងពាក្យ **អត្ថិ ឥទប្បច្ចយា ជរាមរណំ** ទើបមានសមាសវិកប្ប ការចែកសមាស ហើយគួរធ្វើក្នុងពាក្យនោះ គឺ **ឥទប្បច្ចយតា បដិច្ចសមុប្បាទោ** ដូចគ្នានឹង **ឥទំ**-ស័ព្ទ ជាវិសេសនៈរបស់បដិច្ចសមុប្បាទ និងជាវិសេសនៈរបស់បច្ច័យដែលគប្បីសួរ ព្រោះដូច្នោះ ទើបមិនជាការសម្តែងសមាសដទៃ ដែលនឹងបៀតបៀនឆដ្ឋីតប្បុរិសសមាស ។ សួរថា ក្នុងពាក្យនេះលោកមិនមានបំណងយកកម្មធារយសមាស ព្រោះហេតុអ្វី ? ឆ្លើយថា ព្រោះអត្ថ **ហេតុប្បភវានំ ហេតុ បដិច្ចសមុប្បាទោ** នេះ ប្រែថា ហេតុនៃដែនកើតរបស់ហេតុទាំងឡាយ ឈ្មោះថា បដិច្ចសមុប្បាទមិនមានក្នុងកម្មធារយសមាស និងព្រោះលោកប្រាថ្នាសេចក្តីដូច្នេះថា **ឥមស្ស អត្ថនោ បច្ចយានុរូបស្ស អនុរូបោ បច្ចយោ ឥទប្បច្ចយោ** ប្រែថា បច្ច័យដែលសមគួរដល់ធម៌នេះ គឺដល់ធម៌ដែលគួរដល់បច្ច័យរបស់ខ្លួន ឈ្មោះថា **ឥទប្បច្ចយោ** ប្រែថា បច្ច័យដែលសមគួរដល់ធម៌ ។ ក្នុងពាក្យនេះ អត្ថណាលោកកាន់យក **ឥទំ**-ស័ព្ទអត្ថនោះ លោកក៏កាន់យកដោយ **ជរា**-ស័ព្ទនោះឯង ដូចក្នុងពាក្យថា **អត្ថិ ឥទប្បច្ចយា ជរាមរណំ** ដែលប្រែថា ជរា និងមរណៈមាន ព្រោះធម៌ដែលជាបច្ច័យ ព្រោះដូច្នោះ **ឥទំ**-ស័ព្ទ ទើបមិនឃ្លាតទៅអំពី **បដិច្ចសមុប្បន្ន**-ស័ព្ទ តាំងចុះក្នុងបច្ច័យ ព្រោះមិនមានធម៌ដទៃ ព្រោះដូច្នោះ ក្នុងពាក្យនោះ ( គឺក្នុងពាក្យថា **ឥទប្បច្ចយតា បដិច្ចសមុប្បាទោ** ) ទើបជាកម្មធារយ-

សមាសបាន ។ ចំណែកក្នុងពាក្យនេះ ( គឺពាក្យថា **អត្ថិ ឥទប្បច្ចយា ជរាមរណំ** ) មិនមានហេតុដែល **ឥទំ**-ស័ព្ទ នឹងលះបង់ទៅអំពីបច្ចយស័ព្ទនោះ ព្រោះដូច្នោះ ទើបជាឆដ្ឋីតប្បុរិសសមាសតែម្យ៉ាង ។ សួរថា កាលបើដូច្នេះ ក៏មិនគួរថា **ឥទប្បច្ចយោ** ឯវ **ឥទប្បច្ចយតាវោ** គឺ **ឥទប្បច្ចយោ** នោះឯង ជា **ឥទប្បច្ចយតាវោ** ព្រោះដូច្នោះ **ឥទប្បច្ចយតា** ទើបចូលដល់ភាពជាបដិច្ចសមុប្បាទ ? ឆ្លើយថា សេចក្តីនេះមិនខុសអ្វីឡើយ សេចក្តីនេះខ្ញុំបានពោលទុកហើយ ថា ព្រោះមិនមានអត្ថដទៃ ។

ប្រការមួយទៀត **ឥទប្បច្ចយតាវោ** ជា **ឥទប្បច្ចយតា** ចូរលើកទុកសិន ។ ក្នុងបទថា **តាវោ** នេះ បានដល់ ការមានហេតុ សំដៅដល់ ផល ដែលមានដោយមិនញែកគ្នា ។ ពិតយ៉ាងនោះ **ឥទប្បច្ចយ**-ស័ព្ទ ជាពាក្យជាប់មាត់ ក្នុងពាក្យថា ជាតិជាដើម ។ ការមាននៃ **ឥទប្បច្ចយ** នោះ នឹងជាដទៃទៅអំពី **ឥទប្បច្ចយ** ក៏រមែងមិនមាន ។ បើគប្បីជាដទៃទៅ ការមាននៃ **ឥទប្បច្ចយ** នោះ ក៏នឹងមិនមាន ។ ព្រោះដទៃទៅអំពីវត្ថុដែលមាន និងជាវត្ថុដែលមានក៏ទេ ។ បើការមានឈ្មោះថា **សំ** ប្រែថា ការមាន ភាវៈរបស់ការមានឯណានោះ ក៏គប្បីឈ្មោះថា **អសំ** ប្រែថា ការមិនមានបាន ។ ពិតហើយ ការមាននោះជាសភាវៈ ព្រោះដទៃទៅអំពីការមានក៏ទេ ព្រោះដូច្នោះ ភាវៈរបស់ការមាន ទើបឈ្មោះថា ការមាន ព្រោះដូច្នោះ ទើបការសម្តែងលម្អិតមិនត្រឹមត្រូវ ។ ម្យ៉ាងទៀត ភាពមិនមាន ឈ្មោះថា **សំ** ប្រែថា ការមានដោយភ្ជាប់ជាមួយ **សំ**-ស័ព្ទក៏ទេ នឹងចាំបាច់និយាយថ្វីដោយការភ្ជាប់ជាមួយ **អសំ** ស័ព្ទនោះ ។ ម្យ៉ាងទៀត ការប្រើស័ព្ទថា **សំ** ជាការប្រកាន់ខុសផ្ទុយគ្នា ព្រោះដូច្នោះ ទើបមិនសម្រេចដោយការកាន់យក ។ ឯការកំណត់វត្ថុដែលដូចគ្នានេះ ក៏ដូចគ្នានឹងការដែលបុគ្គលជាសីហៈ មិនមែនសភាវៈថា មានរបស់វត្ថុ ដែលមិនមាន ។ ភាពជា **ឥទប្បច្ចយ** ក៏បានដល់រូបរបស់ខ្លួននៃ **ឥទប្បច្ចយ** ដែលលោកពោលថា **ឥទប្បច្ចយតា**

ឲ្យផ្សេងទៅថា **ឥមស្សាយំ** ដើម្បីសម្ដែងការបដិសេធអំពីសភាវៈដទៃ ព្រោះដូច្នោះ ការមិនមាននៃបដិច្ចសមុប្បាទ ដោយ **ឥទប្បច្ចយតា** ក៏មិនមាន ក៏ព្រោះ **ឥទប្បច្ចយ** ជាការមានតាមដែលពោលហើយ មិនមែនជាការមិនមាន ។ ទាំងការមានដូច្នោះរបស់វត្ថុណា វត្ថុនោះឈ្មោះថា មិនមានក៏ទេ ។

ឈ្មោះថា **បដិច្ចសមុប្បាទ** ព្រោះអត្ថថា ជាដែនអាស្រ័យគ្នាកើតឡើង ព្រោះដូច្នោះ បណ្ឌិតគប្បីប្រកបសេចក្ដីនៃបដិច្ចសមុប្បាទនោះ មានហេតុជាប្រធាននៃបទថា **ជាតិ** ជាដើម ប្រាប់ដល់ភាពជាហេតុយ៉ាងនោះដូចគ្នា ដោយភាពជាអត្ថនៃហេតុ ព្រោះអធិប្បាយថា ហេតុនៃធម៌ជាដែនកើតនៃហេតុ ឈ្មោះថា បដិច្ចសមុប្បាទ ។ ពិតយ៉ាងនោះ សេចក្ដីនេះ ព្រះមានព្រះភាគទ្រង់ប្រកាសទុក ដោយ **សីហនាទសូត្រ** ថា ម្នាលភិក្ខុទាំងឡាយ ព្រះតថាគតដែលប្រកបដោយកម្លាំង ១០ ទ្រង់ប្រកបហើយដោយវេសារជ្ជញ្ញាណទាំង ៤ រមែងបញ្ជាក់ឋានៈដ៏អង់អាច បន្លឺសីហនាទក្នុងពពួកបរិស័ទ រមែងប្រកាសព្រហ្មចក្រថា កាលវត្ថុនេះមាន ទើបមានវត្ថុនេះ រហូតដល់ការរលត់នៃកងទុក្ខទាំងអម្បាលមាន រមែងមានដោយប្រការដូច្នេះ ។ **ព្រះអស្សជិត្ថេរ** ត្រូវឧបតិស្សបរិព្វាជកសួរថា ព្រះសាស្ដារបស់លោកម្ចាស់មានវាទៈដូចម្ដេច បានត្រាស់ប្រៀនប្រដៅដូចម្ដេច ? ព្រះថេរៈក៏បានឆ្លើយថា **ធម៌ណាកើតអំពីហេតុ ព្រះតថាគតត្រាស់ហេតុរបស់ធម៌ទាំងឡាយនោះ និងការរលត់របស់ធម៌ទាំងឡាយនោះ ព្រះមហាសមណៈមានវាទៈយ៉ាងនេះ** ។ ដោយពាក្យនោះរមែងធ្វើឲ្យយល់បានថា ហេតុនៃធម៌ដែលមានហេតុជាដែនកើត ឈ្មោះថា **បដិច្ចសមុប្បាទ** ។ ពាក្យដ៏សេសដែលគួរនឹងពោលក្នុងបដិច្ចសមុប្បាទនេះ នឹងមានច្បាស់ខាងមុខ ។

បទថា **បដិច្ច** ប្រែថា អាស្រ័យហេតុនោះៗ ។ បទថា **សម្មា** សេចក្ដីថា មិនមានវិបរិត អធិប្បាយថា វត្ថុដែលមិនទៀងក៏កើតឡើងអំពីវត្ថុដែលមិនទៀង ។

ព្រោះថា ការកើតឡើងរបស់ផលអំពីហេតុដែលទៀង ក៏ជាការវិបរិត ។ ដោយហេតុនោះ ទើបលោកអាចារ្យពោលថា **មិនបានសំដៅដល់ហេតុ មានបកតិហេតុ និងបុរស ជាដើមដែលត្រិរិយកំណត់ទុក** ។ អធិប្បាយរបស់កេចិអាចារ្យទាំងនោះថា អាការម្យ៉ាង ដែលមានបច្ច័យដូចបានពោលហើយ ក្នុងពាក្យនេះថា **ដោយបច្ច័យ ដោយលក្ខណៈ** ជាលក្ខណៈដទៃអំពីសង្ខតលក្ខណៈដែលត្រាស់ទុកយ៉ាងនេះថា **ការកើតឡើងរមែង ប្រាកដ** ឈ្មោះថា ជាការកើតឡើង ពាក្យណាដែលកេចិអាចារ្យទាំងនោះសំដៅដល់ ពោលទុកថា ហេតុរបស់ជាតិជាដើម ក៏គឺជាជាតិជាដើម ពាក្យនោះ ក៏ត្រឹមតែជាមតិ របស់កេចិអាចារ្យទាំងនោះ ព្រោះធម៌ណាមួយ ដូច្នោះ ដែលផុតទៅអំពីលក្ខណៈ គឺការកើតឡើងមិនមាន ។ ដោយហេតុនោះ ទើបលោកអាចារ្យពោលថា **ពាក្យនោះ មិនត្រឹមត្រូវ** ដូច្នេះជាដើម ។ បទថា **គម្ភីរនយាសម្ភវតោ** ប្រែថា ព្រោះមិនមាន សេចក្ដីជ្រាលជ្រៅដោយន័យ ។ បទថា **សទ្ទភេទតោ** គឺព្រោះខូចស័ព្ទ បានដល់ ព្រោះ មិនប្រកបដោយស័ព្ទ ។ **ព្រះសូត្រ** ឈ្មោះថា **មិនមាន** ព្រោះអាការត្រឹមតែការ កើតឡើង ព្រះសាស្ដាទ្រង់មិនបានប្រកាសទុកដោយបទព្រះសូត្រជាដើមថា ម្នាល ភិក្ខុទាំងឡាយ តថាគតនឹងសម្ដែងបដិច្ចសមុប្បាទដល់អ្នកទាំងឡាយ ។ ក៏អត្ថនេះឯង ដែលបានប្រកាសទុកហើយខាងដើម និងកំពុងសម្ដែងសូម្បីក្នុងកាលឥឡូវនេះ ។ **តំ យោគ អនុប្បាទមត្តំ** ប្រែថា អាការគ្រាន់តែការកើតឡើងនោះ ។ អធិប្បាយថា **វិហរាមិ** រមែងនៅក្នុងបឋមពោធិកាលនោះ ។ ម្យ៉ាងទៀត បទថា **វិហរាមិ** ព្រះមានព្រះភាគ ត្រាស់ទុកដោយ ជាកាលវិបល្លាស សេចក្ដីប៉ុនគ្នានឹង **វិហាសិ** ប្រែថា ប្រថាប់នៅ ហើយ ។ បទថា **តត្រ** សេចក្ដីប៉ុនគ្នានឹង **តស្មឹ យោគ បទេសវិហារេ** ប្រែថា ក្នុង បទេសវិហារធម៌នោះ ។ ពាក្យថា **ដោយទ្រង់មើលបច្ចយាការ** សេចក្ដីថា បច្ចយធម៌ រមែងជាបច្ច័យនៃបច្ចយុប្បន្នធម៌ ដោយអាការណា បច្ចយធម៌នោះ ឈ្មោះថា

បច្ចយាការ គឺភាពជាបច្ច័យ ដោយទ្រង់មើលបច្ចយាការនោះ ។ តែក្នុងទីនេះលោកមានបំណងយកបច្ច័យនៃវេទនាទាំងឡាយ ។ ដោយហេតុនោះ ទើបលោកពោលថា **ការសោយអារម្មណ៍ មានព្រោះមិច្ឆាទិដ្ឋិជាបច្ច័យក៏មាន** ដូច្នេះជាដើម ។ វិហារធម៌ដែលព្រះសាស្តាទ្រង់មើលបច្ច័យនៃវេទនាទាំងឡាយតែម្យ៉ាង ត្រាស់ទុក ឈ្មោះថា **ជាបទេសវិហារធម៌** ព្រោះអធិប្បាយថា ធម៌ជាគ្រឿងនៅនៃព្រះសាស្តា ដែលទ្រង់មើលត្រឹមតែឯកទេសនៃបដិច្ចសមុប្បាទប៉ុណ្ណោះ ការធ្វើមនសិការសមន្តប្បដ្ឋានអនន្តន័យ ឈ្មោះថា **វិហារធម៌** ក្នុងបឋមពោធិកាល ។ អាចារ្យមួយពួកពោលថា សេចក្តីនោះជាការដែលទ្រង់មើលបច្ចយាការទាំងអស់មិនមានសេសសល់ ។ ឈ្មោះថា **ត្រូវខុសចំពោះបទេសវិហារសូត្រ** ក៏ព្រោះពាក្យរបស់កេចិអាចារ្យនោះអធិប្បាយដល់ការធ្វើមនសិការ បច្ចយធម៌នៃវេទនាទាំងឡាយ ។ ឈ្មោះថា **លោកសមុទយៈ** ព្រោះអត្ថថាជាដែនកើតឡើងរបស់លោក បានដល់ ពពួកនៃបច្ច័យ មានអវិជ្ជាជាដើម មិនមែនត្រឹមតែការកើតឡើងនៃលោកប៉ុណ្ណោះទេ ។ ដោយហេតុនោះ ទើបអាចារ្យពោលថា **បដិច្ចសមុប្បាទ ផ្នែកអនុលោម** ។ បទថា **នត្ថិតា** គឺការមិនមានដោយប្រការទាំងពួង អធិប្បាយថា បានដល់ ការដាច់សូន្យ ដែលមានការអនុលោមតាម **នវិនាស** ទៅ ។ ម្យ៉ាងទៀត ឧច្ឆេទទិដ្ឋិរបស់បុគ្គលដែលមានបំណងថា ជា **នត្ថិតា** ព្រោះមានការប្រព្រឹត្តទៅរួមជាមួយ **នត្ថិតា** ។ **បច្ចយានុបរមោ** បានដល់ ការមិនដាច់ខ្សែនៃបច្ច័យទាំងឡាយ ។ ដូចជាហេតុទាំង ៥ រមែងមានបានដូចគ្នានឹងផលទាំងឡាយ ៥ ក្នុងបច្ចុប្បន្ន ដោយអាស្រ័យហេតុទាំង ៥ ក្នុងអតីត យ៉ាងណា ផលទាំង ៥ ក្នុងអនាគត នឹងមាន ដោយអាស្រ័យហេតុទាំង ៥ ក្នុងបច្ចុប្បន្ន ដូច្នេះ ។ ដោយហេតុនោះ ទើបលោកអាចារ្យពោលថា **ការបន្តនៃផល រមែងមានបាន ព្រោះការបន្តនៃបច្ច័យ** ។

**តំ យោគ គម្ភីរត្តំ** ប្រែថា សេចក្តីជ្រាលជ្រៅនោះ មិនមាននៅក្នុងអាការគ្រាន់

តែជាការកើតឡើង ព្រោះមិនមែនជាសភាវធម៌ ។ ន័យទាំងឡាយ មានឯកត្តន័យជាដើម ក៏មិនគប្បីបានសូម្បីដូចម្ដេចសោត ក្នុងអាការត្រឹមតែការកើតឡើង ព្រោះបាននៅក្នុងសភាវធម៌ទាំងឡាយ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **ន័យទាំង ៤ រមែងមិនមានក្នុងអាការគ្រាន់តែការកើតឡើង** ។ ពីរបទថា **សមានេ កត្តរិ** ប្រែថាក្នុងកត្តុដូចគ្នានោះឯង អធិប្បាយថា កត្តុណានៃកិរិយា គឺការកើតឡើងក្នុងកត្តុនោះឯងជាកត្តុនៃកិរិយា គឺការអាស្រ័យប្រព្រឹត្តទៅផង ដូចពាក្យថា **ន្ហាត្វា ភុញ្ជតិ** ងូតហើយក៏បរិភោគ **ភុត្វា សយតិ** បរិភោគហើយ ក៏ដេក ។ ចំណែកពាក្យថា **ក្នុងបុព្វកាល** នេះលោកពោលទុកព្រោះសម្ដែងកិរិយាដែលជាបុព្វកាល ដោយច្រើននៃបទទាំងឡាយដែលមាន **ត្វា**-ស័ព្ទជាទីបំផុត មិនមែនព្រោះ **បដិច្ច**-ស័ព្ទ មានអត្ថជាបុរិមកាលក្នុងទីនេះឡើយ ។ ពាក្យដែលជាគោលថា **ចក្ខុំ បដិច្ច** គប្បីប្រៀបធៀបបានជាមួយពាក្យដែលជាគោលដោយប្រការដូច្នេះ ។ ម្យ៉ាងទៀត ក្នុងទីនេះកិរិយាទាំង ២ មានកាលស្មើគ្នា ព្រោះកិរិយា គឺការអាស្រ័យគ្នាប្រព្រឹត្តទៅមុន មិនមានដល់កិរិយា គឺការកើតឡើងក៏ពិត សូម្បីដូច្នោះ កិរិយាដែលជាហេតុ នៃកិរិយាដែលជាផលក៏ត្រឹមត្រូវដែលនឹងពោលដូចបុរិមកាល ។ ការកំណត់ហេតុ និងផលនៃហេតុ រមែងជាក់ច្បាស់យ៉ាងល្អក្នុងទីនេះ ព្រោះដូច្នោះ ទើបលោកពោលថា **ក្នុងបុព្វកាល ដោយកាន់យកបុរិមកាល** ដែលសម្រេចដោយឧបចារវោហារ ។ ពាក្យថា **ធ្វើការសម្រេចអត្ថ** គឺធ្វើការទទួលដឹងអត្ថនៃពាក្យសម្ពី ។ ពិតហើយ ការយល់នៃពាក្យសម្ពីក្នុងបទថា **បដិច្ចសមុប្បាទ** នេះ លោកអាចារ្យបំណងថា កាលសម្រេចអត្ថក្នុងទីនេះ ។ បដិច្ចស័ព្ទប្រកបចូលជាមួយ ឧបាទស័ព្ទ គប្បីនាំយកបទថា **អភាវតោ** របស់កត្តុដែលស្មើគ្នាដែលកំពុងពោលមកប្រកបចូលផង ។ ក៏អត្ថក្នុងសេចក្ដីនេះ មានដូចតទៅ វិញ្ញាណនោះឯងជាកត្តានៃកិរិយា គឺការអាស្រ័យប្រព្រឹត្តទៅនៃកិរិយា គឺការកើតឡើង ដូច

ក្នុងពាក្យជាដើមថា **ចក្ខុញ្ច បដិច្ច រូបេ ច ឧប្បជ្ជតិ ចក្ខុវិញ្ញាណំ** ប្រែថា អាស្រ័យចក្ខុ និងរូប ទើបកើតចក្ខុវិញ្ញាណឡើង ព្រោះដូច្នោះ ទើបមានកត្តុ និងរូបស្មើគ្នា ។

ក្នុងពាក្យថា **បដិច្ចសមុប្បាទ** នេះ លោកពោលកិរិយាប៉ុណ្ណោះ ព្រោះឧបាទស័ព្ទ ជាភាវសាធន ព្រោះដូច្នោះ ការប្រែកបស័ព្ទ ដែលមានកត្តុស្មើគ្នាជាលក្ខណៈ ទើបមិនសម្រេចដូច្នេះ ។ ដោយហេតុនោះ ទើបលោកអាចារ្យពោលថា **ដល់នូវការខូចស័ព្ទ** ។ អធិប្បាយថា រមែងត្រូវប្រាសចាកការប្រែកបស័ព្ទ ។ ក្នុងពាក្យថា **បដិច្ច-សមុប្បាទ** នេះ មិនមានការប្រែកបអត្ថដែលឃាត់អត្ថដទៃ ដូចក្នុងពាក្យថា **អប្បត្វា នទី បព្វតោ** ប្រែថា មិនទាន់ដល់ស្ទឹងក៏មានភ្នំ **អតិក្កម្ម បព្វតំ នទី** ប្រែថា ហួសភ្នំក៏មានស្ទឹង ទាំងមិនមែនបយោគលក្ខណៈ និងបយោគហេតុជាដើម ដូចក្នុងពាក្យជាដើមថា **សីហំ ទិស្វា ភយំ ហោតិ** ប្រែថា ការខ្លាចរមែងមាន ព្រោះឃើញសីហៈ **ឃតំ បិវិត្វា ពលំ ជាយតេ** ប្រែថា កម្លាំងរមែងកើត ព្រោះផឹកទឹកដោះជូរ **ធន្ទិ កត្វា ទណ្ឌោ បតិតោ** ប្រែថា ដំបងធ្លាក់ទៅហើយ ព្រោះធ្វើសំឡេង **ធន្ទិ** ។ ក្នុងប្រយោគទាំងនេះ មិនជាការខូចស័ព្ទឡើយ ។ ក្នុងព្រះតម្រាស់របស់ព្រះសម្ពុទ្ធអ្នកស្វែងរកគុណដ៏ធំទាំងឡាយ ជាអ្នកធ្វើធម្មជាតិដែលគប្បី ដឹងទាំងពួងឲ្យប្រចក្ស តាំងនៅដូចកន្ទួតព្រៃលើបាតដៃ ពួកអ្នកគិតអក្ខរៈទាំងឡាយ មិនបានឱកាសនឹងពិពណ៌នាបាន បើនឹងបានក៏ព្រោះស័ព្ទសម្រេចដោយអត្ថរបស់ពាក្យពោល ដូចក្នុងពាក្យជាដើមថា **ន្ហាត្វា គមនំ** ប្រែថា ងូតស្រេចហើយ ក៏ទៅ **ភុត្វា សយនំ** ប្រែថា បរិភោគហើយក៏ដេក ។ សូម្បីយ៉ាងនេះ ក៏មិនសម្រេចអត្ថអ្វីឡើយ អធិប្បាយថា សូម្បីបានចំពោះបទជាបទៗ ទៅក៏ដោយ សូម្បីយ៉ាងនោះ អត្ថរបស់ពាក្យពោលក៏មិនសមគួរ ព្រោះដូច្នោះ ទើបជាពាក្យដែលឥតប្រយោជន៍ ព្រោះជាពាក្យដែលមានអត្ថមិនភ្ជាប់គ្នា ដូចពាក្យពោលរឿងទទឹម ១០ ផ្លែជាដើម ។

លោកអាចារ្យពោលថា **ពួកខ្ញុំនឹងប្រកបចូលជាមួយហោតិស័ព្ទ** ដូច្នេះ សំដៅយកន័យដែលគួរជ្រាបថា កាលពោលដល់បទនាមហើយ បទកិរិយាបែបនេះ គឺ **អត្ថិ ហោតិ វិជ្ជតិ** មិនបានប្រកបទុកក៏គួរនាំមកភ្ជាប់ចូលផង ។ បទថា **ឥមេសុ យោគបដិច្ចសមុប្បាទបទេសុ** ប្រែថា ក្នុងបណ្តាបទថា បដិច្ចសមុប្បាទ ដែលត្រាស់ទុកទាក់ទងនឹងពាក្យទេសនា ពាក្យបដិញ្ញា ពាក្យបុច្ឆា និងពាក្យនិគម តាមដែលត្រាស់ទុកហើយយ៉ាងនេះ ។ សេចក្តីនេះត្រឹមតែជាគំរូ សូម្បីក្នុងបទដទៃ មានអាទិ៍យ៉ាងនេះថា **បដិច្ចសមុប្បាទមេវ សាធុកំ យោនិសោ មនសិករោតិ ។ យទិទំ ឥទប្បច្ចយតា បដិច្ចសមុប្បាទោ ។ គម្ភីរោ ចាយំ អានន្ទ បដិច្ចសមុប្បាទោ ហោតិ** ស័ព្ទ ក៏មិនបានដល់ការភ្ជាប់ចូលជាមួយបទថា **បដិច្ចសមុប្បាទ** សូម្បីតែមួយបទ ។ ឈ្មោះថា **រមែងមិនដល់នូវការប្រកបចូល** ព្រោះមិនបានត្រាស់ទុក ទាក់ទងនឹងការភ្ជាប់គ្នាយ៉ាងនោះ ។ ពាក្យថា **ទាំងមិនជាការកើតឡើងផង** នេះ លោកអាចារ្យពោលទុកសំដៅយកការមិនប្រកបដោយលក្ខណៈ គឺការកើតឡើងរបស់ការកើតឡើង ព្រោះមិនមែនជាសភាវធម៌ ។ ដូចជាការវិនាសមិនមានដល់ការវិនាស យ៉ាងណា សូម្បីការកើតឡើងក៏មិនមានដល់ការកើតឡើង ដូចគ្នានឹងការវិនាស ដូច្នោះ ។ លោកពោលសេចក្តីនេះទុកហើយនោះឯងថា បើគប្បីមានសោត ការកើតឡើងក៏នឹងមានការកើតឡើង ដោយការកើតឡើងណា សូម្បីការកើតឡើងនោះ ក៏នឹងមានការកើតឡើង ព្រោះដូច្នោះ មិនគប្បីដល់នូវការឈប់នោះឯង ។ ដោយហេតុនោះ ទើបលោកអាចារ្យពោលថា **ប្រសិនបើគប្បីកើត** ដូច្នេះជាដើម ។ សួរថា បើយ៉ាងនោះ សមុទយៈនឹងមានបានដូចម្តេច ? សេចក្តីនេះមិនខុសអ្វីទេ ព្រោះមិនបានបំណងយកការកើតឡើង ។ សេចក្តីក្នុងប្រការនេះដូច្នេះថា សមុទយៈ គឺការប្រាកដរបស់កងទុក្ខ រមែងមានបានដោយប្រការដូច្នេះ តែក្នុងអធិការនេះមានបដិច្ចសមុប្បាទ ព្រោះដូច្នោះ ទើបលោកអាចារ្យ

ពោលថា **ទាំងមិនមានការកើតឡើង** ដូច្នេះ ដោយបំណងថា គប្បីធ្វើការចោទសួរដល់ការកើតថា **ហោតិ** ប្រែថា រមែងកើត ដោយធ្វើអធិប្បាយថា ជាការចោទសួរដល់អត្ថិភាវៈ ( ភាវៈដែលមាន ) របស់បដិច្ចសមុប្បាទនោះ ។ បច្ច័យនៃធម៌ទាំងឡាយមានសង្ខារជាដើមនេះ ឈ្មោះថា **ឥទប្បច្ចយ** បានដល់ ធម៌ទាំងឡាយ មានអវិជ្ជាជាដើម ភាវៈនៃឥទប្បច្ចយៈនោះ ឈ្មោះថា **ឥទប្បច្ចយតា** ។ លោកអាចារ្យពោលថា **ដែលឈ្មោះថា ភាវៈ** ដូច្នេះជាដើម ដើម្បីចៀសវាងនូវពាក្យសួរថា ឯភាវៈនោះបានដល់អ្វី ។ អត្ថរបស់ពាក្យនោះថា ធម៌មានអវិជ្ជាជាដើម រមែងជាហេតុនៃការប្រកបរបស់ធម៌ មានសង្ខារជាដើម ដោយអាការណា ឈ្មោះថា បដិច្ចសមុប្បាទនេះ ក៏នៅក្នុងអាការនោះដែលជាវិការផ្សេងគ្នានៃការប្រព្រឹត្តទៅរបស់ធម៌ មានអវិជ្ជាជាដើម ដូច្នេះ ។ **តេសំ យោគ វាទីនំ ។ តំ យោគ មញ្ញនំ** ប្រែថា ការសម្គាល់នោះរបស់អ្នកពោលទាំងនោះ ។ បទថា **ហេតុវចនតោ** ប្រែថា ព្រោះពោលភាវៈនៃហេតុ ។

បទថា **ឯត្ថ យោគ បដិច្ចសមុប្បាទបទេ** ប្រែថា ក្នុងបទថា បដិច្ចសមុប្បាទនេះ ។ ហេតុ ព្រមទាំងសមត្ថភាពដែលគប្បីយល់ ដោយពាក្យដែលមានសមុប្បាទជាប្រធាន ឈ្មោះថា បដិច្ចសមុប្បាទ ព្រោះដូច្នោះ សម្រាប់បុគ្គលដែលយល់អត្ថមិនឃៀងឃ្លាតនេះ ទើបលោកពោលតែ **ការកើតឡើងនេះប៉ុណ្ណោះ ដោយស្រមោលនៃព្យញ្ជនៈ** សូម្បីក្នុងទីនេះក៏យ៉ាងនោះ មិនពោលដល់ហេតុឡើយ ព្រោះក្នុងទីដទៃសម្ដែងសមុប្បាទសត្តុ ដែលជាភាវសាធន ព្រោះដូច្នោះ **ការយល់ឯណាកើតឡើងការយល់នោះ** គួរកាន់យកអត្ថនៃបទថា បដិច្ចសមុប្បាទនេះ យ៉ាងនេះ គឺដោយអាការដែលពោលក្នុងឥឡូវនេះ ហើយរម្ងាប់បង់ គឺបន្ទោបង់ ។

ក្នុងគាថាថា **ទ្វេធា** នេះ មានអត្ថសង្ខេបដូច្នេះ ពាក្យថា **បដិច្ចសមុប្បាទ** នេះ គួរប្រាថ្នាបានជា ២ ន័យ យ៉ាងនេះ គឺន័យម្យ៉ាងថា ក្រុមបច្ចយុប្បន្នធម៌ដែលប្រព្រឹត្ត

ទៅទាក់ទងនឹងបច្ច័យរបស់ខ្លួន ឈ្មោះថា បដិច្ច ព្រោះត្រូវអាស្រ័យគ្នាប្រព្រឹត្តទៅផង ក្រុមបច្ចយុប្បន្នធម៌នោះ ឈ្មោះថា សមុប្បាទ ព្រោះកើតឡើងរួមគ្នាផង ន័យមួយទៀត ព្រោះអាស្រ័យ គឺមិនបដិសេធការព្រមព្រៀងនៃហេតុកើតឡើងរួមគ្នាតែម្យ៉ាង ដូច្នោះ សូម្បីបច្ចយធម៌របស់ក្រុមបច្ចយុប្បន្នធម៌ លោកអាចារ្យពោលថា បដិច្ចសមុប្បាទ ដោយជាវោហារពោលអះអាងដល់ផលនោះឯង ។

បទថា **បច្ចយតាយ** សេចក្តីប៉ុនគ្នានឹង **បច្ចយសមូហតោ** ប្រែថា ព្រោះក្រុមនៃបច្ច័យ ។ បទថា **បវត្តតោ** ប្រែថា កើតឡើង ។ ពាក្យថា **ក្រុមនៃធម៌** បានដល់ក្រុមបច្ចយុប្បន្នធម៌ ។ បទថា **បតីយមានោ** សេចក្តីថា ចូលទៅអាស្រ័យប្រព្រឹត្តទៅចំពោះមុខ ចំពោះការប្រព្រឹត្តទៅនៃញាណ អធិប្បាយថា ត្រាស់ដឹង ។ ពីរបទថា **ហិតាយ សុខាយ ច** បានដល់ ដើម្បីលោកុត្តរប្រយោជន៍ និងដើម្បីលោកុត្តរសុខ ។ ឈ្មោះថា **រមែងកើតឡើងរួមគ្នា** ព្រោះមិនមានការកើតឡើងនៃធម៌ សូម្បីតែម្យ៉ាងក្នុងកាលណាមួយឡើយ ។ ឈ្មោះថា **រមែងកើតឡើងដោយប្រពៃ** ព្រោះមិនកើតឡើងដោយមិនមានហេតុ និងដោយហេតុដែលមិនស្មើគ្នា ។ ពាក្យថា **រមែងកើតឡើងរួមគ្នា** សេចក្តីថា កើតឡើងជាពួកតែមួយ ព្រោះដោយកំណត់យ៉ាងទាបបំផុត គឺកើតធម៌ទាំង ៨ ប្រការ ។ បទថា **ន បច្ចក្ខាយ** ប្រែថា មិនបដិសេធ អធិប្បាយថា មិនញែកអំពីការប្រជុំនៃធម៌ដែលជាបច្ច័យរបស់ខ្លួនប្រការណានីមួយ ។ បទថា **តស្ស** សេចក្តីថា ក្រុមនៃបច្ចយុប្បន្នធម៌ ដែលត្រាស់ថា **បដិច្ចសមុប្បាទ** នេះ ក្រុមនៃហេតុ មានអវិជ្ជាជាដើមនេះ នៃក្រុមបច្ចយុប្បន្នធម៌នោះ ។ ដោយបទថា **តប្បច្ចយត្តា** នេះ លោកអាចារ្យរមែងសម្តែងថា មានឈ្មោះថា បដិច្ចសមុប្បាទ ក៏ព្រោះអាស្រ័យបច្ច័យនៃបដិច្ចសមុប្បាទ ។ ដោយហេតុនោះ ទើបលោកអាចារ្យពោលពាក្យជាដើមថា **ដូចជាក្នុងផ្លូវលោក** ។ ដូចជាក្នុងផ្លូវលោក គេពោលដល់បច្ច័យដោយវោហារផលថា **បិត្តំ**

**មថិតំ** ប្រមាត់ គឺទឹកដោះស្រស់ **សុរា ទធិ** ស្រោ គឺទឹកដោះជូរ **តិបុសំ ជរោ** ត្រសក់ គឺដំណាប់ **សេម្ហោ គុឡោ** ស្ទេស្ម គឺទឹកអំពៅ និង **អាយុឃតំ** អាយុ គឺទឹកដោះថ្លា ដូច្នេះយ៉ាងណា បដិច្ចសមុប្បាទក៏គប្បីជ្រាបថា ត្រាស់ទុកដោយឧបចារវោហារដល់ផលដូចគ្នាដូច្នោះ ។

ដោយ **បដិច្ច**-ស័ព្ទ លោកអាចារ្យកាលសម្តែងសេចក្តីថា **បដិ**-ស័ព្ទ មានអត្ថថា ចំពោះមុខ **ឥច្ច**-ស័ព្ទ មានអត្ថថា ដល់ ទើបពោលថា **បដិមុខមិតោ** ប្រែថា ដល់ចំពោះមុខ លោកអាចារ្យកាលវិសជ្ជនាពាក្យចោទសួរប្រការក្រោយ ក្នុងបណ្តាពាក្យចោទសួរទាំង ៣ ប្រការ គឺចំពោះមុខរបស់បុគ្គលណា ឬដល់ដោយអ្វី ឬនរណាជាតួដល់ ទើបពោលថា **ហេតុសមូហោ** ប្រែថា ក្រុមហេតុ កាលដោះស្រាយបទក្រោយនោះ ក៏រមែងត្រូវដោះស្រាយអត្ថនេះឯងថា ដែលឈ្មោះថា ក្រុមនៃហេតុបានដល់ ការសាមគ្គីនៃបច្ច័យ ព្រោះដូច្នោះ ទើបជាការដល់ចំពោះមុខនៃគ្នានឹងគ្នាក្នុងក្រុមនៃហេតុនោះ និងដល់ហើយដោយគ្នានឹងគ្នានោះឯង ដូច្នេះ ។ បទថា **សហិតេ** បានដល់ ធម៌ដែលកើតឡើងជាមួយគ្នា គឺមិនបែកអំពីគ្នា ។ បទថា **សោ យោគហេតុសមូហោ** ប្រកបសេចក្តីបាលីថា **សមុប្បាទោ ឥតិ វុត្តោ** ។ បទថា **ធាតុកាវាយ** ប្រែថា នៃការកើតឡើង ។ អវិជ្ជាប៉ុណ្ណោះត្រាស់ទុក **ក្នុងព្រះបាលី** ដោយភាពជាបច្ច័យថា **អវិជ្ជាបច្ចយា សង្ខារា** ដូច្នេះក៏ពិត សូម្បីយ៉ាងនោះ មិនមែនអវិជ្ជាតែម្យ៉ាងប៉ុណ្ណោះជាបច្ច័យឡើយ ដោយពិត សហជាតធម៌ វត្ថុ និងអារម្មណ៍ជាដើម យោនិសោមនសិការ និងធម៌ទាំងឡាយ មានតណ្ហា និងឧបាទានជាដើម ក៏រមែងជាហេតុធ្វើរួមគ្នានៃអវិជ្ជាក្នុងការញុំាងសង្ខារឲ្យកើតឡើងតាមសមគួរនោះឯង ។សូម្បីសង្ខារជាដើមក៏ជាបច្ច័យដល់វិញ្ញាណជាដើមយ៉ាងនេះ ព្រោះដូច្នោះ ទើបលោកអាចារ្យពោលថា **ក្រុមនៃហេតុដែលទ្រង់បានសម្តែងទុកដោយមាតិកាហេតុជាតំណៗ មានអវិជ្ជាជាដើម** ។ដោយអត្ថ

ថា **ញុំាងផលទូទៅឲ្យសម្រេច** គឺដោយការៈដែលញុំាងផលទូទៅនៃធម៌ ដែលជាហេតុទាក់ទងដោយក្រុមហេតុនោះឲ្យកើតឡើង ។ ពាក្យថា **ដោយអត្ថថា មិនមានកំហុសខុសឆ្គង** គឺដោយការៈដែលមិនមានកំហុស ។ ពិតហើយ ក្នុងក្រុមហេតុនោះ គប្បីមានផលនេះ ដែលមិនទូទៅដល់ហេតុចំណែកខ្លះ និងគប្បីមានផល ដែលហេតុពួកខ្លះប៉ុណ្ណោះគប្បីឲ្យកើតឡើង ធម៌ដែលជាបច្ច័យទាំងឡាយនោះ ក៏មិនមានការស្មើងគ្នានឹងគ្នា ព្រោះដូច្នោះ អត្ថរបស់បដិច្ច ក៏មិនគប្បីគ្រប់ចំនួន ព្រោះមិនមានការដល់ចំពោះមុខ ដូច្នេះ ។ បទថា **សាមគ្គិអង្គានំ** ប្រែថា បណ្តាធម៌ដែលជាអង្គ អធិប្បាយថា ជាក្រុមនៃបច្ច័យសាមគ្គី ។ បទថា **សាមគ្គិអង្គានំ** ជាឆដ្ឋីវិភត្តិចុះក្នុងអត្ថថា **និទ្ធារណ** ។ ការមិនបែកគ្នា ឈ្មោះថា **ការប្រព្រឹត្តទៅរួមគ្នានៃធម៌ដែលជាផលទាំងឡាយ** មិនមែនស្មើងគ្នានឹងគ្នា ដូចជាធម៌ដែលជាហេតុ ព្រោះដូច្នោះ ទើបលោកអាចារ្យពោលថា **អញ្ញមញ្ញំ អវិនិព្ភោគវុត្តិធម្មេ** ប្រែថា ញុំាងធម៌ដែលមានការប្រព្រឹត្តទៅមិនបែកគ្នានឹងគ្នា ។ ស័ព្ទថា **វិនិព្ភោគ** ក្នុងពាក្យនេះ ដើម្បីរួមយករូបធម៌ទាំងឡាយផង ។ កាលកាន់យកដោយអត្ថប្រការដទៃ ក៏គួរពោលថា **សម្បយុត្តធម្មេ** ញុំាងសម្បយុត្តធម៌ទាំងឡាយ ។ បទថា **បច្ចយតា** សេចក្តីថា ក្រុមបច្ច័យនេះ គឺមានអវិជ្ជាជាដើម ។ បទថា **អញ្ញោញ្ញំ** សេចក្តីប៉ុនគ្នានឹង **អញ្ញមញ្ញំ** ប្រែថា នូវគ្នានឹងគ្នា ។ បទថា **បដិច្ច** ប្រែថា អាស្រ័យ គឺបានដល់ ហេតុដែលធ្វើរួមគ្នា ។ ពាក្យថា **ស្មើគ្នា** សេចក្តីថា មិនមែនមិនស្មើគ្នាដោយការមិនខ្វះខាត ។ ពាក្យថា **ជាមួយគ្នា** គឺរួមគ្នា ។ ពាក្យថា **ញុំាងធម៌ទាំងឡាយ** គឺញុំាងធម៌ដែលកើតអំពីបច្ច័យទាំងឡាយរបស់ខ្លួន ។ រមែងឲ្យកើតឡើងព្រោះហេតុណា **ព្រោះហេតុនោះ តតោបិ** សេចក្តីប៉ុនគ្នា **តស្មាបិ** ។ ប្រកបសេចក្តីថា ព្រះមុនី គឺព្រះមានព្រះភាគបានត្រាស់ទុកយ៉ាងនេះ គឺជាបដិច្ចសមុប្បាទ ។ លោកអាចារ្យកាលសម្តែងអត្ថនៃអវធារណៈថា **ន អបដិច្ច** សេចក្តីប៉ុនគ្នានឹង **បដិច្ចេវ**

ទើបសម្តែងថា **ឯវ** អក្ខរៈ ក្នុងគាថាសម្តែងថា ត្រូវបានលុបទៅ ។ បទថា **ឯកេកតោសំ** សេចក្តីថា ជាឯកទេសប្រជុំនៃផល អធិប្បាយថា ដោយជាចំណែកៗ ។ ពាក្យថា **ដោយមុន និងក្រោយ** គឺដោយលំដាប់ ។ ពាក្យនេះលោកពោលសំដៅយករូបកលាបៈ និងអរូបកលាបៈទាំងអស់នេះឲ្យកើតឡើង ។ ពាក្យថា **បុគ្គលឆ្លាតក្នុងវោហារតាមទំនងអត្ថ** គឺអ្នកឈ្លាសវៃ ក្នុងវោហារទៅតាមបរមត្ថធម៌ ។

មានពាក្យប្រកបសេចក្តីថា **បុរិមេន បទេន** គឺ **បុរមេន យោគ បទេន** ។ បទថា **សស្សតាទីនំ** សេចក្តីប៉ុនគ្នានឹង **សស្សតកាវាទីនំ** ប្រែថា នៃសស្សតៈជាដើម ឬសេចក្តីប៉ុនគ្នានឹង **សស្សតវាទាទីនំ** ប្រែថា នៃវាទៈទាំងឡាយ មានសស្សតវាទជាដើម ។ ពិតហើយ វាទៈទាំងឡាយដែលប្រព្រឹត្តទៅរួមគ្នាជាមួយ **សស្សត** លោកក៏ហៅថា **សស្សតាទយោ** ប្រែថា វាទៈ មានសស្សតៈជាដើម ដូចជាពាក្យថា **ទុក្ខទេសនា ទុក្ខំ** ប្រែថា ការសម្តែងរឿងទុក្ខ ហៅថា **ទុក្ខំ** ។ សូម្បីក្នុងបទថា **ឧច្ឆេទាទិ** ក៏មានន័យនេះដូចគ្នា ។ **ការពិឃាត** បានដល់ សេចក្តីវិនាស អធិប្បាយថា ការលះបង់ ។ បទថា **ញាយោ** បានដល់ គោលបដិបត្តិដែលជាខ្សែកណ្តាល វៀរចាកអន្តធម៌ទាំង ២ ។

ពាក្យថា **នៃបវត្តិធម៌** បានដល់ ធម៌ចំណែកបវត្តិ អធិប្បាយថា នៃធម៌ មានកិលេសវដ្តៈជាដើម ។ វាទៈដែលប្រព្រឹត្តទៅដោយន័យជាដើមថា **អត្តា និងលោកទៀង** ឈ្មោះថា **សស្សតវាទ** ។ វាទៈដែលប្រព្រឹត្តទៅដោយន័យជាដើមថា **ហេតុមិនមាន បច្ច័យមិនមាន ដើម្បីសេចក្តីសៅហ្មងរបស់សត្វទាំងឡាយ** ឈ្មោះថា **អហេតុកវាទ** ។ វាទៈដែលប្រព្រឹត្តទៅយ៉ាងនេះថា លោករមែងប្រព្រឹត្តទៅ ដោយអំណាចនៃបកតិ អណូ និងកាលជាដើម ឈ្មោះថា **វិសមហេតុវាទ** ។ វាទៈ ដែលពោលដល់ព្រះឥស្សរបុរស និងព្រះបជាបតី ឈ្មោះថា **វសវត្តិវាទ** ។ ក្នុងអធិការនេះដោយការកាន់យក

ស័ព្ទថា **អហេតុវាទ** នោះឯង គប្បីឃើញការរួមយក សូម្បី **សភាវវាទៈ និយតិវាទ** និង **យទិច្ឆាវាទ** ចូលផង ។ ចំណែកកេចិអាចារ្យពោលថា វាទៈមានអាទិ៍យ៉ាងនេះថា ចក្ខុនោះឯងជាហេតុរបស់ចក្ខុ ឈ្មោះថា **វិសមហេតុវាទ** ។ វាទៈដែលទាក់ទងនឹងព្រះឥស្សរជាដើម ក៏ឈោងចុះក្នុង **អហេតុវាទ** ។ វាទៈថា ធម៌ទាំងឡាយ រមែងប្រព្រឹត្តទៅដោយសភាវៈនោះឯង ឈ្មោះថា **វសវត្តិវាទ** ។អធិប្បាយថា ក៏ដោយការដល់ព្រមនៃបច្ច័យ នឹងមានប្រយោជន៍អ្វី ។ ប្រកបសេចក្ដីថា រមែងកំណត់ការសម្ដែងដោយបទថា **សមុប្បាទ** ។ ដើម្បីនឹងសម្ដែងហេតុដែលមិនវិបរិតនៃការកំណត់សម្ដែង ទើបលោកអាចារ្យពោលថា **ព្រោះធម៌ទាំងឡាយកើតឡើងព្រោះការដល់ព្រមនៃបច្ច័យ** ។ ពាក្យថា **ត្រូវផាត់ចេញទៅ** បានដល់ ត្រូវកម្ចាត់ចេញទៅ ដោយពាក្យថា **ដោយអំណាចបច្ច័យខាងដើម** លោកអាចារ្យសម្ដែងការទាក់ទងនៃហេតុ និងផលដែលហាមបង់នូវឧច្ឆេទទិដ្ឋិដែលប្រព្រឹត្តទៅដោយអំណាចការមិនដាច់ខ្សែ ។ ដោយហេតុនោះ ទើបលោកអាចារ្យពោលថា **ការដាច់សូន្យនឹងមានមកអំពីណា** ។ ក្នុងអធិការនេះគប្បីឃើញថា លោកសម្ដែងការមិនមាននៃឧច្ឆេទវាទ ដោយការពោលដល់ការដាច់សូន្យនោះឯង ។

ពាក្យថា **តស្សា តស្សា បច្ចយសាមគ្គិយា** សេចក្ដីប៉ុនគ្នានឹង **តស្មឹ តស្មឹ ហេតុប្បច្ចយសមវាយេ** ប្រែថា ក្នុងការព្រមព្រៀងនៃហេតុ និងបច្ច័យនោះៗ ។ ពីរបទថា **សន្តតី អវិច្ឆិន្ទិត្វា** សេចក្ដីថា ព្រោះនៅមិនទាន់កាត់ការបន្ត ពោល គឺការបន្តនៃហេតុ និងផលមិនបាន ។ ព្រោះបច្ចុប្បន្នធម៌ **នោះៗ** មាន គឺកើតឡើង កាលកើតឡើងនៃផលដែលសមគួរដោយបច្ច័យ តាមគួរដល់ខ្លួន មិនចូលទៅជាប់ក្នុងអន្តៈទាំង ២ ពោល គឺសស្សតៈ និងឧច្ឆេទ លោកមានបំណងយកថា មជ្ឈិមប្បដិបទាក្នុងទីនេះ ការលះបង់នូវវាទៈថា បុគ្គលនោះធ្វើ បុគ្គលនោះក៏បានសោយផល ព្រោះកម្មវដ្ដៈ

និងវិបាកវដ្ដៈ មានសភាវៈផ្សេងគ្នា និងព្រោះមានកាលផ្សេងគ្នា ។ ពិតហើយ ការបញ្ញត្តអ្នកធ្វើព្រោះការប្រព្រឹត្តទៅនៃកុសលក្ខន្ធ និងអកុសលក្ខន្ធ ការបញ្ញត្តអ្នកសោយផលព្រោះការប្រព្រឹត្តទៅនៃវិបាកក្ខន្ធ ដូច្នេះឯង ។ កម្មកើតឡើងក្នុងសន្តានណា ព្រោះផលនោះក៏កើតឡើងក្នុងសន្តាននោះឯង **ទើបលះវាទៈថា អ្នកដទៃធ្វើ អ្នកដទៃបានទទួលផល ដូច្នេះក៏បាន** ។ ពិតហើយ ការវិនាសទៅនៃវត្ថុដែលបានធ្វើទៅហើយ ឬការមកដល់ចំពោះមុខរបស់វត្ថុដែលមិនបានធ្វើមានក៏ទេ ។ ភាសាក្នុងជនបទដោយការបញ្ញត្តថា **ស្រី ប្រុស** ។ ក្នុងភាសាជនបទនោះ សូម្បីបណ្ឌិតទាំងឡាយក្នុងលោក ក៏មិនបានពោលថា **ចូរនាំខន្ធ ៥ មក នាមរូបចូរមក** ដូច្នេះ រមែងពោលថា ស្រី ប្រុស ដូច្នេះប៉ុណ្ណោះ ព្រោះដូច្នោះ ទើបមានការប្រកាន់មាំរបស់បុគ្គល ដែលមិនបានកំណត់ដឹងវត្ថុទាំងឡាយថា **នេះជាស្រីនោះឯង នេះជាប្រុសនោះឯង** ។ តែកាលបុគ្គលមានបញ្ញាដឹងបដិច្ចសមុប្បាទ ក៏មិនមានការប្រកាន់មាំដោយបរមត្ថក្នុងភាសាគមធៈនោះ ព្រោះត្រឹមតែជាបញ្ញត្តិអាស្រ័យធម៌ទាំងឡាយ ដែលប្រព្រឹត្តទៅដោយប្រការនោះៗ ព្រោះដូច្នោះ ទើបលោកអាចារ្យពោលថា **មិនបានប្រកាន់មាំក្នុងភាសាជនបទ** ។ ពាក្យថា **សមញ្ញា** បានដល់ ឈ្មោះផ្លូវលោក ។ ពាក្យថា **ការមិនកន្លងហួស** បានដល់ ការមិនឈានកន្លង ។ ពិតហើយ កាលពោលថា **សត្វ** ក៏នឹងមិនធ្វើការថែកថា **អ្វីជាសត្វក្នុងទីនេះ អ្វីជារូប ឬជាវេទនាជាដើម** មិនសំដៅដល់ឈ្មោះ គប្បីបញ្ញត្តតែអត្ថផ្លូវលោក ដូចគ្នានឹងពួកអ្នកស្រុកនិយាយគ្នា ទាក់ទងនឹងឈ្មោះផ្លូវលោកនោះឯង ។

ន័យម្យ៉ាងទៀត ធម៌ ឈ្មោះថា **បដិច្ច** ព្រោះអត្ថថា គួរយល់ដោយចំពោះ ។ ពិតហើយ បុគ្គលណារមែងយល់ដោយចំពោះ គឺរមែងត្រាស់ដឹងធម៌នោះ ធម៌នោះរមែងប្រព្រឹត្តទៅព្រម ដើម្បីការចូលទៅស្ងប់ទុក្ខយ៉ាងពិតប្រាកដនោះឯង ដល់បុគ្គលនោះ ។ ធម៌ ឈ្មោះថា **សមុប្បាទ** ព្រោះអត្ថថា ធ្វើឲ្យកើតឡើងដោយប្រពៃ និង

ព្រមគ្នា ។ ពិតហើយ **បច្ចយធម៌** កាលញុំាងផលរបស់ខ្លួនឲ្យកើតឡើង រមែងឲ្យកើតឡើងយ៉ាងសម្បូរនោះឯងមិនខ្វះខាត និងរមែងញុំាងធម៌ពួកណាឲ្យកើតឡើង ក៏ញុំាងធម៌ទាំងឡាយនោះឲ្យកើតឡើងព្រមគ្នានោះឯង មិនមែនម្យ៉ាងមួយបែបនោះឡើយ ។ **បច្ចយធម៌** នោះ គួរយល់ដោយចំពោះ និងធ្វើឲ្យកើតឡើងដោយប្រពៃ និងព្រមគ្នា ដូចពោលមកដូច្នេះ ព្រោះដូច្នោះ ទើបឈ្មោះថា **បដិច្ចសមុប្បាទ** ម្យ៉ាងទៀត ឈ្មោះថា **បដិច្ចសមុប្បាទ** ព្រោះអត្ថថា យល់ដោយចំពោះ គឺយល់ចំពោះមុខ មិនបានបដិសេធការដល់ព្រមនៃហេតុ ញុំាងធម៌ដែលប្រព្រឹត្តទៅរួមគ្នាឲ្យកើតឡើង ។ ឯការដល់ចំពោះមុខនៃបច្ច័យ ក៏គឺការញុំាងផលឲ្យកើតឡើងដោយភាព ជាអង្គនៃការដល់ព្រមរបស់ហេតុ និងពាក្យថា **មិនបដិសេធ** ក៏គឺវៀរទៅអំពីការដល់ព្រមនៃហេតុនោះក៏ទេ អធិប្បាយថា មិនទាន់ដល់នូវភាពជាអង្គ ក៏រមែងមិនធ្វើឲ្យកើតឡើងឯងនោះឯង ។ ដោយពាក្យនេះ លោកសម្ដែងភាពជាធម៌ដែលច្រើនទៅដោយហេតុ ដោយពាក្យថា **ញុំាងធម៌ដែលប្រព្រឹត្តទៅរួមគ្នា** នេះ លោកសម្ដែងភាពជាធម៌ដែលច្រើនទៅដោយបច្ចុប្បន្នធម៌ ។ ដោយពាក្យទាំង ២ រមែងជាការសម្ដែងន័យនៃព្រះសាសនាដែលពោលដល់ខាងមុខ ដោយពាក្យថា **មួយ តែមិនមែនរួមទីងមួយ** ជាដើម ។

ម្យ៉ាងទៀត ធម៌ដែលអាស្រ័យ គឺដល់ចំពោះបច្ច័យដែលគប្បីអាស្រ័យ មិនបានវៀរចាកបច្ច័យដែលគប្បីអាស្រ័យនោះ ក៏ញុំាងធម៌ដែលសម្ពន្ធគ្នាឲ្យកើតឡើង ទើបឈ្មោះថា **បដិច្ចសមុប្បាទ** ។ ក្នុងពាក្យថា បដិច្ចសមុប្បាទនេះ គប្បីជ្រាបថា បានដល់ហេតុ ព្រមទាំងសមត្ថភាព ដែលគប្បីដឹងច្បាស់ ដោយពាក្យដែលមានសមុប្បាទជាប្រធាន ក្នុងពាក្យនោះ កាលពោលថា **បដិច្ច** ប្រែថា អាស្រ័យ ក៏ត្រូវពោលថា អាស្រ័យអ្វី ព្រោះដូច្នោះ ទើបលោកអាចារ្យពោលថា **ធម៌ដែលអាស្រ័យ** ។ លោកអាចារ្យពោលថា **បច្ច័យ** ដូច្នេះ ព្រោះធ្វើអធិប្បាយថា ធម៌នោះ បានដល់ បច្ចយធម៌ ។

ឥឡូវនេះ លោកអាចារ្យពោលអត្ថរបស់ **បដិច្ច**-ស័ព្ទថា **បដិគន្ត្វា** ។ ដល់ហើយដោយការដល់ ដោយការបានចំពោះនូវធម៌នោះតាមសភាពរបស់ហេតុ ។ មិនបានវៀរចាកបច្ច័យដែលគប្បីអាស្រ័យនោះដូចម្ដេច ? គឺកាលមានបច្ច័យដែលគប្បីអាស្រ័យនោះឯង និងព្រោះធ្វើផលនោះឯងឲ្យកើតឡើង មិនមែនដោយប្រការដទៃ ។ កាលមិនមាន និងព្រោះរលត់ទៅផង ព្រោះដូច្នោះ ទើបការតាំងនៅនៃបច្ច័យនេះ ជាអត្ថរបស់បដិច្ចស័ព្ទ ។ ដោយហេតុនោះ ទើប **បដិច្ច**-ស័ព្ទនេះ ពោលដល់ហេតុនៃធម្មជាតិអាចដែលជាហេតុឲ្យធម៌នោះ ជាធម៌ដែលទាក់ទងជាមួយធម៌នោះដោយភាវៈដែលជាធម្មជាតិទាក់ទងជាមួយហេតុ ដែលសម្ដែងដល់កិរិយាដែលផុតពីការធ្វើឲ្យកើតឡើង ដោយប្រព្រឹត្តទៅអាស្រ័យនូវហេតុនៃពាក្យដែលមានហេតុនៃការធ្វើ និងអ្នកធ្វើដែលគប្បីដឹងច្បាស់នូវធម៌នោះឯង ដែលគប្បីពោលដោយស័ព្ទពិសេស គឺ **គន្ត្វា** ដែលប្រែថា ដល់ ដូចគ្នានឹងស័ព្ទទាំងនេះថា **ឥមស្មឹ សតិ ឥមស្ស ឧប្បាទោ** កាលវត្ថុនេះមាន ក៏ធ្វើវត្ថុនោះឲ្យកើត ដែលពោលដល់ហេតុនៃធម្មជាតិអាច ដែលជាហេតុឲ្យមានការទាក់ទងគ្នាជាមួយធម៌នោះដោយភាវៈដែលជាធម្មជាតិទាក់ទងជាមួយហេតុ ដែលសម្ដែងដល់កិរិយាខ្ពស់ជាង ដែលញ៉ាំងភាវៈឲ្យកើតឡើងរបស់ធម៌ដែលមានហេតុ ដែលគប្បីពោលដោយ **ឥទំ**-ស័ព្ទ ដែលចុះបញ្ចាំងដល់សត្តមីវិភត្តិ និងបញ្ចមីវិភត្តិ ដូច្នោះ ។ ព្រោះអធិប្បាយ យ៉ាងនេះ ទើបព្រះធម្មសេនាបតីសារីបុត្រពោលអំពីសង្ខារទុកក្នុងបិដកថា **អវិជ្ជា បដិច្ច សង្ខារា បដិច្ចសមុប្បន្នា** ជាដើម សេចក្ដីថា អាស្រ័យអវិជ្ជាទើបមានសង្ខារដែលជាធម៌អាស្រ័យគ្នាកើតឡើង ។ **ភាពជាធម្មជាតិអាច** ក្នុងទីនេះ បានដល់ ដើមហេតុជាដើម និងជាដើមហេតុនោះគឺមាននោះឯង ដោយសម្ដែងដល់ផលដែលមានដោយមិនបែកគ្នារបស់វត្ថុនោះ ។ ពាក្យថា **ធម៌ដែលជាសម្ពន្ធគ្នា** បានដល់ធម៌ដែលសម្ពន្ធគ្នាជាមួយជាតិជាដើម ទាក់ទងដោយភាពជាធម៌ ដែលសមគួរដល់ការ

ប្រកបទុក គឺធម៌ដែលកើតអំពីបច្ច័យ មានជរា និងមរណៈជាដើម ។ ពាក្យថា **ធ្វើឲ្យកើតឡើង** បានដល់ ការកើតឡើង សួរថា បើដូច្នោះ នឹងប្រកប **បដិច្ច**-ស័ព្ទបានដូចម្តេច ការប្រកបស័ព្ទដូច្នេះ ប្រើក្នុងបុព្វកាលរបស់ស័ព្ទដែលមានកត្តាស្មើគ្នាមិនមែនឬ ? ឆ្លើយថា សេចក្តីនេះ ពិត ដូចក្នុងពាក្យជាដើមថា **ភុត្វា គច្ឆតិ** ប្រែថា ស៊ីហើយក៏ទៅ **កសិត្វា វប្បតិ** ប្រែថា ភ្ជួរហើយ ក៏សាបព្រោះ តែសេចក្តីនោះ គប្បីឃើញទាក់ទងជាមួយរឿង ដែលមានជាចំណែកច្រើន ព្រោះជួបនៅក្នុងសមានកាល និងអបរកាល និងក្នុងរឿងដែលមានកត្តាមិនស្មើគ្នា ។ ខាងដើមក្នុងសមានកាល មានឧទាហរណ៍ថា **អន្ធការំ និហន្ត្វាន ឧទិតាយំ ទិវាករោ** ប្រែថា ព្រះអាទិត្យកាលរះឡើងកម្ចាត់ងងឹតបាន **វណ្ណបញ្ញាវភាសេតិ ឱភាសេត្វា សមុគ្គតោ** ប្រែថា ព្រះចន្ទរះឡើងរមែងភ្លឺ ។ ចំណែកអាចារ្យពួកខ្លះពោលឧទាហរណ៍ថា **មុខំ ព្យាទាយ សយតិ** ប្រែថា ដេកចងចិញ្ចើម **អក្ខីនិ បរិវត្តេត្វា បស្សតិ** ប្រែថា ក្រឡេកភ្នែកមើល ។ អាចារ្យមួយពួកទៀតពោលថា **និសជ្ជ អធីតេ** ប្រែថា អង្គុយរៀនគម្ពីរ **ឋត្វា កថេតិ** ប្រែថា ឈរនិយាយ ។

បណ្តាឧទាហរណ៍ទាំងនោះ កិរិយាដែលហួសខាងដើមទៅ ដែលសម្ព័ន្ធដល់កិរិយា គឺការដេក និងការមើល ដែលមានកាលហួស កាលចងចិញ្ចើម និងកាលក្រឡេកភ្នែកមាន ក៏ភាពជាកិរិយាមានកាលហួសខាងដើមទៅនោះ មិនបានចូលទៅកំណត់ភាពផ្សេងទុក បុគ្គលទាំងឡាយពួកខ្លះ ទើបកំណត់មិនបាន ។ ចំណែកការអង្គុយ និងការឈរ រមែងមានសួប្បក្នុងកិរិយាដែលជាសមានកាលថា **និសជ្ជ អធីតេ** បុគ្គលនោះអង្គុយរៀន **ឋត្វា កថេតិ** បុគ្គលនោះឈរនិយាយ សួប្បក្នុងកាលមុនអំពីការរៀន និងការនិយាយ ព្រោះដូច្នោះ ទើបអាចលើកតម្កើងកិរិយាដែលមានកាលខ្ពស់ជាងកាលខាងដើមបាន ព្រោះដូច្នោះ ទើបឧទាហរណ៍ខាងដើមប៉ុណ្ណោះសមគួរ ។

ការហាមអត្ថ ដែលគប្បីហាមនោះ មានកាលព្រមជាមួយនឹងការតាំងឡើងនោះឯង ដូច្នេះ ។ ក្នុងអបរកាលមានឧទាហរណ៍ថា **ទ្វារំ អាវរិត្វា បវិសតិ** បើកទ្វារហើយទើបចូលទៅ **អាវរិត្វា និក្ខមតិ** បើកទ្វារហើយទើបចេញ ។ ចំណែកអាចារ្យពួកខ្លះពោលឧទាហរណ៍ថា **ឧក្កុច្ច បតិតោ ទណ្ឌោ** ដំបងធ្លាក់ទៅសំឡេងលាន់ឧក្ក ។ សំឡេងកើតអំពីការប៉ះខ្ទប់ជាសមានកាលបានក្នុងទីនេះ ដោយជាសមានកាលដែលកើតព្រមគ្នាដែលជាការប៉ះខ្ទប់ ព្រោះដូច្នោះ ទើបឧទាហរណ៍ខាងដើមនោះឯង ក្នុងទីនេះត្រឹមត្រូវហើយ ។ ឯសេចក្តីប្រាថ្នាកិរិយាដែលជាលក្ខណៈ និងហេតុឲ្យជាលក្ខណៈ និងហេតុដោយអំណាចការប្រាថ្នាពាក្យសម្ពី គឺភាវៈដែលមានពីមុននោះឯង ព្រោះដូច្នោះ បុរិមកាលក៏ដោយភាវៈដែលជាលក្ខណៈ ព្រោះហេតុនោះឯង ទើបលោកប្រាថ្នាភាពសម្រេចនៃស័ព្ទថា **និហន្ត្វាន** ទុក ឯកិរិយា គឺការអាស្រ័យប្រព្រឹត្តទៅយ៉ាងនេះ គឺការអាស្រ័យប្រព្រឹត្តទៅយ៉ាងនេះ ជាកិរិយាដែលមានក្នុងកាលមុន ជាកិរិយាដែលកើតព្រមគ្នានោះឯង ព្រោះដូច្នោះ ទើបការសម្រេចនៃ **បដិច្ច**-ស័ព្ទមានបាន ។ សេចក្តីនោះ ត្រឹមត្រូវហើយដោយប្រចក្ស ក៏ព្រោះសម្តែងដល់កត្តុ ។ បើមានពាក្យសួរថា ក្នុងទីនេះមិនត្រឹមត្រូវ ព្រោះមិនមានការសម្តែងដល់កត្តុនោះ ? ឆ្លើយថា ប្រការនេះមិនជាអ្វី ។ សូម្បីក្នុងទីនេះក៏យល់បាន ដោយអនុមាន ។ កត្តុមានជរា និងមរណៈជាដើមក៏នៅមាននោះឯង នូវកត្តុបុគ្គលដែលអនុមានយក គប្បីប្រាថ្នាការប្រកបស័ព្ទដូច្នេះ យ៉ាងពិតប្រាកដ ។ ព្រោះសម្តែងប្រយោជន៍ជាដើម យ៉ាងនេះថា **ញត្វា កិរិយតោ វយំ** ដឹងការវិនាសទៅដោយកិរិយា ។ ចំណែកក្នុងកត្តុដែលមិនស្មើគ្នា គប្បីជ្រាបគំរូមានអាទិ៍យ៉ាងនេះថា **បិសាចំ ទិស្វា ភយំ ហោតិ** ការខ្លាចរមែងមានព្រោះឃើញបិសាច **បញ្ញាយ ចស្ស ទិស្វា អាសវា បរិក្ខីណា ហោន្តិ** ព្រោះឃើញដោយបញ្ញា ទើបអាសវៈរបស់លោកអស់ទៅ ។ ដូចជាការខ្វល់ខ្វាយរបស់បុគ្គល

មានការឃើញបិសាចជាដើម ក្នុងឧទាហរណ៍នោះ យ៉ាងណា ការអាស្រ័យគ្នាប្រព្រឹត្តទៅ គឺការខ្វល់ខ្វាយនៃបច្ច័យ បានដល់ ការញ៉ាំងផលរបស់ខ្លួនឲ្យកើតឡើង ក្នុងទីនេះក៏ដូច្នោះ ការមាននោះ បានដល់ ការកើតព្រមគ្នានោះឯង ព្រោះដូច្នោះ បុគ្គលដែលធ្វើឲ្យយល់ការ អាស្រ័យគ្នាប្រព្រឹត្តទៅ ជាហេតុនៃការកើតឡើងជាមួយគ្នាថា **កាលបច្ច័យមាន ក៏ព្រោះការកើតឡើងនៃបច្ច័យ** ដូច្នេះ គប្បីជ្រាបថា កាលមានកត្តដែលស្មើគ្នា **បដិច្ច-ស័ព្ទ**ក៏សម្រេចបាន ។ បើការកើតឡើងរបស់វត្ថុ ដែលអាស្រ័យការសមន្នគ្នាជាបដិច្ចសមុប្បាទ ។ សួរថា បច្ច័យជាបដិច្ចសមុប្បាទបានដូចម្តេច ? ឆ្លើយថា សេចក្តីនេះ ខ្ញុំព្រះករុណាបានពិចារណាទុកហើយនោះឯងខាងដើម ។ ប្រការមួយទៀតហេតុព្រមទាំងអំណាចនេះដែលអធិប្បាយដល់បដិច្ចស័ព្ទនៃបច្ចយុប្បន្នធម៌ទាំងឡាយ ដែលសម្តែងដល់សមុប្បាទស័ព្ទ លោកមានបំណងយកហើយ លោកពោលយ៉ាងនោះ ព្រោះពាក្យដែលជាប្រធាន មានសភាវៈដែលគប្បីយល់បាន ដោយភាពជាហេតុនោះប្រជួបមុខចំពោះការកើតឡើងព្រមគ្នា ។

ហេតុនៃការកើតឡើងព្រមគ្នា គប្បីជ្រាបដោយពាក្យសម្តីដែលមានសមុប្បាទជាប្រធាន មានហេតុដូចម្តេច មិនមែនសមុប្បាទមានហេតុនោះឯងឬ ? សេចក្តីនេះសូមឆ្លើយថា បច្ច័យណានៃទុក្ខដែលបានឃើញហើយ ក៏ព្រោះបានសម្តែងទុក្ខនោះដោយការសម្តែងលម្អិតបច្ច័យ ។ សេចក្តីនេះដូចម្តេច ? ដូចដែលត្រាស់ទុកក្នុង **បរិវីមង្សសូត្រ** ដែលដើមហេតុរបស់ទុក្ខបានឃើញហើយដោយន័យជាដើមថា

ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងធម្មវិន័យនេះ កាលពិចារណា រមែងពិចារណាថា ទុក្ខ គឺជរា និងមរណៈមានប្រការផ្សេងៗ សន្ទឹកសន្ធាប់កើតឡើងក្នុងលោក ទុក្ខនេះមានអ្វីជាហេតុ អ្វីជាសមុទយៈ មានអ្វីជាកំណើត មានអ្វីជាដែនកើតហ្ន៎ កាលអ្វីមានទើបជរា និងមរណៈមាន កាលអ្វីមិនមាន ទើបជរា និងមរណៈមិនមាន ? ភិក្ខុនោះ

កំពុងពិចារណា រមែងដឹងប្រចក្សយ៉ាងនេះថា ទុក្ខ គឺជរា និងមរណៈ មានប្រការផ្សេងៗនេះ ។បេ។ ទុក្ខនេះមានជាតិជាដែនកើត ។ ការដឹងច្បាស់នោះជាដើមហេតុ ក៏គួរយល់ដូច្នេះ ។ ដូចដែលត្រាស់ទុក គឺ

ត្រាស់ដល់ការពិចារណា និងដឹងបច្ច័យរបស់ទុក្ខដែលបានឃើញហើយ ដោយន័យជាដើមថា ម្នាលភិក្ខុទាំងឡាយ មុនអំពីកាលត្រាស់ដឹង កាលតថាគតនៅជាព្រះពោធិសត្វ មិនទាន់បានត្រាស់ដឹង តថាគតមានការគិតយ៉ាងនេះថា **លោកនេះដល់នូវសេចក្ដីលំបាកហ្ន៎ រមែងកើត ចាស់ ស្លាប់ ចុតិ និងឧប្បត្តិ កាលបើដូច្នោះនៅមានបុគ្គលណាជ្រាបច្បាស់ រលាស់ចេញនូវកងទុក្ខ គឺជរា និងមរណៈ កាលណាហ្ន៎ ការរលាស់ចេញនូវកងទុក្ខនេះ គឺជរា និងមរណៈនឹងប្រាកដសោត ។បេ។ ម្នាលភិក្ខុទាំងឡាយ ព្រោះការដាក់ចិត្តដោយឧបាយរបស់តថាគតនោះ ទើបដឹងបានដោយបញ្ញាថា កាលជាតិមាន ទើបជរា និងមរណៈមាន ព្រោះជាតិជាបច្ច័យ ទើបជរា និងមរណៈមាន** ។ ពិតហើយ បច្ច័យត្រូវដឹង ។ ការដឹងច្បាស់នូវធម៌ជាទីរលាស់ចេញនូវគំនរទុក្ខ ក៏ទាក់ទងមកអំពីការដឹងបច្ច័យនោះ ព្រោះដូច្នោះ បច្ច័យណា ដែលត្រូវដឹង បច្ច័យនោះនឹងត្រូវដឹងទូទៅ ព្រោះហេតុនោះ ទើបស័ព្ទថា **បដិច្ចសមុប្បាទ** នេះលោកពោលទុកដើម្បីសម្ដែងដល់បច្ច័យយ៉ាងនេះថា ទុក្ខដែលឃើញហើយ ដែលប្រាកដហើយ ដោយស័ព្ទថា **សមុប្បាទ** នេះ ទុក្ខនោះអាស្រ័យបច្ច័យនោះឯងមិនមែនដទៃ ។ពិតហើយ សូម្បីពាក្យដែលជាប្រធាន ដោយការៈដែលប្រាថ្នានឹងដឹង និងប្រកាសឲ្យដឹងទូទៅ ក៏នៅមានពាក្យពង្រីកសេចក្ដី ដោយជាពាក្យដែលមិនមែនជាប្រធាន ព្រោះជាពាក្យដែលគួរដឹង ដោយសេចក្ដីផ្សេងគ្នាខ្លះ ឧបមាដូចពាក្យថា **កោ សោតាបន្នោ យស្ស តីណិ សំយោជនានិ បហីនានិ** ប្រែថា បុគ្គលណាជាសោតាបន្នហ្ន៎ ? ឆ្លើយថា បុគ្គលដែលលះសំយោជនៈ ៣ បាន ។ **កោ ទេវទត្តោ យស្ស ឧច្ចតរានិ គេហានិ**

ប្រែថា បុគ្គលណាដែលទេវតាប្រទានឲ្យ គឺបុគ្គលដែលមានផ្ទះធំជាងគេ សេចក្តីនេះយ៉ាងណា សូម្បីក្នុងប្រការឧបមេយ្យនេះក៏ដូច្នោះ លោកពោលដល់បច្ច័យទុក ដោយពាក្យដែលជាបរិយាយថា **បដិច្ច** ដោយភាវៈដែលគួរដឹង ព្រោះដែលខ្លួនត្រូវអាស្រ័យប្រព្រឹត្តទៅដោយផលរបស់ខ្លួន ដោយសេចក្តីផ្សេងគ្នានៃសមត្ថភាពក្នុងពាក្យពង្រីកអត្ថ ដែលប្រកាសឲ្យដឹងដល់ការអាស្រ័យប្រព្រឹត្តទៅរបស់បច្ច័យ ។

ម្យ៉ាងទៀត ពាក្យពង្រីកសេចក្តីនេះ មានជាដើមថា **អវិជ្ជាបច្ចយា សង្ខារា** ព្រោះអវិជ្ជាជាបច្ច័យ ទើបមានសង្ខារ ពាក្យពង្រីកសេចក្តីនោះ ទ្រង់សម្តែងលម្អិតទុកដើម្បីការប្រកាសបច្ច័យខាងដើមរបស់កងទុក្ខទាំងឡាយ ព្រោះដូច្នោះ សូម្បីក្នុងទីបញ្ចប់នៃបច្ច័យទាំងឡាយ ទើបព្រះមានព្រះភាគទ្រង់សម្តែងទុក្ខ ដែលបានលើកឡើងដោយ **ឯវំ**-ស័ព្ទថា **ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតិ** ការកើតឡើងនៃកងទុក្ខទាំងឡាយនេះ រមែងមានដោយប្រការដូច្នេះ ហើយទ្រង់បញ្ជាក់បច្ច័យតាមដែលបានត្រាស់ទុកហើយរបស់កងទុក្ខនោះ ឲ្យជួបមុខចំពោះការកើតឡើងរបស់កងទុក្ខនោះ ។ **ក្នុងបដិបទាសូត្រ** ក៏បានត្រាស់ទុកថា ម្នាលភិក្ខុទាំងឡាយ ព្រោះអវិជ្ជាជាបច្ច័យ ទើបមានសង្ខារ ។បេ។ ការកើតឡើងនៃកងទុក្ខនេះ រមែងមានដោយប្រការដូច្នេះ និងត្រាស់ថា ម្នាលភិក្ខុទាំងឡាយ នេះហៅថា **មិច្ឆាបដិបទា** ។ តែទុក្ខដែលទ្រង់កាន់យកដោយបដិច្ចសមុប្បន្នធម៌ ជាមិច្ឆាបដិបទាក៏មិនមាន ។ ដោយពិតបច្ច័យដែលកើតឡើងរបស់ទុក្ខ ជាមិច្ឆាបដិបទាដូច្នេះឯង ។ ដូចជាព្រះមានព្រះភាគទ្រង់ធ្វើពាក្យប្រកាសអង្គ និងញាណ ដោយស័ព្ទ មានសម្មាសមាធិជាប្រធាន ព្រោះទេសនាមានអត្ថ ជាពាក្យប្រកាសអង្គ និងញាណថា **បញ្ចង្គិកោ សម្មាសមាធិ** សម្មាសមាធិមានអង្គ ៥ **បញ្ចញាណិកោ សម្មាសមាធិ** សម្មាសមាធិប្រកបដោយញាណ ៥ ដូច្នេះឯណា ក្នុងទីនេះពាក្យប្រកាសបច្ច័យគប្បីជ្រាបថា ទ្រង់ធ្វើដោយ

សត្វដែលមានសមុប្បាទជាប្រធាន ក៏ដូច្នោះ ។

ក្នុងសេចក្តីបាលីថា **យា បនាយំ តន្តិ** ។ បទថា **និក្ខិត្តា** ប្រែថា ទ្រង់តាំងទុក អធិប្បាយថា ទ្រង់សម្តែងទុក **គណ្ឋ** ( គម្ពីរ ) ឈ្មោះថា **តន្តិ** ព្រោះបន្តអត្ថ ដែលទ្រង់ព្រះបំណងហើយ ។ សាវករបស់ព្រះសម្មាសម្ពុទ្ធទាំងឡាយ ឈ្មោះថា **វិភជ្ជវាទី** ព្រោះជាសាវករបស់ព្រះសម្មាសម្ពុទ្ធទាំងឡាយ ព្រះមោគ្គលិបុត្តតិស្សត្ថេរ ដែលព្រះបាទអសោកមហារាជបានទូលសួរថា **លោកម្ចាស់ដ៏ចម្រើន ព្រះសម្មាសម្ពុទ្ធមានវាទៈដូចម្តេច** បានថ្វាយព្រះពរថា **បពិត្រព្រះរាជសម្ភារ ព្រះសម្មាសម្ពុទ្ធទ្រង់ជាវិភជ្ជវាទី** ។ ពិតហើយ សាវកនៃព្រះសម្មាសម្ពុទ្ធទាំងឡាយ រមែងពោលតាមពាក្យដែលព្រះសាស្តាត្រាស់ចែកកាត ដែលសត្វជាបុគ្គលគប្បីនាំទៅឲ្យវិសេសបានជាដើម រមែងពោលតាមពាក្យដែលព្រះសាស្តាត្រាស់ចែកធម៌ មានសោមនស្សជាដើម និងបច្ច័យ មានចីវរជាដើម គួរសេព និងមិនគួរសេព ។ ន័យម្យ៉ាងទៀត សាវកនៃព្រះសម្មាសម្ពុទ្ធរមែងពោលចែកសស្សតវាទ និងឧច្ឆេទវាទចេញទៅ ព្រោះបញ្ហាដែលត្រូវឆ្លើយជាដើមថា **អត្តា និងលោកទៀង ក៏ចូរលើកទុកសិន** សស្សតៈ គឺព្រះនិព្វានដែលជាទីអស់ទៅនៃកិលេស មានរាគៈជាដើម និងឧច្ឆេទ គឺការដាច់សូន្យនៃកិលេស មានរាគៈជាដើម និងទុច្ចរិត មានកាយទុច្ចរិតជាដើមក៏ដោយ តែនឹងនាំយកបញ្ហាទាំង ៣ មានបញ្ហាដែលនឹងត្រូវឆ្លើយចែកចេញទៅតែម្យ៉ាងមិនមាន ។ រង្វង់ គឺប្រជុំនៃវិភជ្ជវាទីទាំងឡាយ ឈ្មោះថា **វិភជ្ជវាទីមណ្ឌល** ប្រែថា រង្វង់នៃវិភជ្ជវាទី ។ អាចារ្យទាំងឡាយពោលថា ម្យ៉ាងទៀត បរិស័ទរបស់ព្រះមានព្រះភាគដែលជាវិភជ្ជវាទី ឈ្មោះថា **វិភជ្ជវាទីមណ្ឌល** ដូច្នេះក៏មាន ម្យ៉ាងទៀត ព្រះមានព្រះភាគ ឈ្មោះថា **វិភជ្ជវាទី** ព្រោះទ្រង់សម្តែងបដិច្ចសមុប្បាទ ដែលជាមជ្ឈិមប្បដិបទា ទ្រង់ចែកសស្សតៈ និងឧច្ឆេទចេញទៅ គឺមិនចូលទៅជាប់ជំពាក់ក្នុងអន្តធម៌ទាំង ២ ហើយសាវកទាំងឡាយនៃព្រះអង្គក៏ឈ្មោះថា

វិភជ្ជវាទី ព្រោះពោលតាមព្រះសាស្តាអង្គនោះឯង ។ ពាក្យដ៏សេសក៏ដូចពាក្យមុនៗ

ពាក្យថា **ចុះ** បានដល់ ឈោងចុះ អធិប្បាយថា ជាវិភជ្ជវាទី ។ ព្រោះថា ខ្លួនឯងជាបុគ្គលមិនមែនវិភជ្ជវាទី ជាបុគ្គលឈ្មោះថា ឈានចុះកាន់មណ្ឌលវិភជ្ជវាទី ដោយហេតុគ្រាន់តែឈរនៅក្នុងចន្លោះនៃវិភជ្ជវាទីទាំងឡាយក៏ទេ ។ **មិនពោលបន្ទាប់អាចារ្យទាំងនោះ** ដោយការសម្តែងអត្ថ ដែលវិបរិតអំពីអាចារ្យទាំងឡាយមិនបានពោលទុក ។ បុគ្គលដែលពោលថា អវិជ្ជាជាហេតុជាបច្ច័យដល់បុញ្ញាភិសង្ខារ និងអនេញ្ជាភិសង្ខារ ដូច្នេះ បុគ្គលដែលពោលវាទៈទាំងឡាយ មានបុគ្គលវាទៈជាដើម ដែលទ្រង់ហាមទុកក្នុងកថាវត្ថុ ឈ្មោះថា **រមៀលចុះកាន់សកសម័យ មិនរមៀលចុះយ៉ាងនោះ** ។ ឈ្មោះថា **មិនខ្វល់ខ្វាយកាន់បរសម័យ** ដោយវៀរចាកសេចក្តីព្យាយាមក្នុងការលើកទោស អាចារ្យទាំងឡាយពួកខ្លះពោលថា មិនប្រមូល **បរសម័យ** ថា **សូត្រនេះគួរកាន់យក** ។ បុគ្គលដែលពោលពាក្យទាំងឡាយជាដើមថា **ខ្ញុំរមែងដឹងទូទៅដល់ធម៌ ដែលព្រះមានព្រះភាគ ទ្រង់សម្តែងទុកហើយ ដោយប្រការថា វិញ្ញាណនេះប៉ុណ្ណោះ រមែងអន្ទោលទៅ រមែងស្ទុះទៅ មិនមែនអ្វីដទៃ** ឈ្មោះថា ជំទាស់ព្រះសូត្រ **មិនជំទាស់** យ៉ាងនោះ ។ បុគ្គលដែលពោលពាក្យជាដើមយ៉ាងនេះថា ខ្ញុំរមែងដឹងទូទៅដល់ធម៌ដែលព្រះមានព្រះភាគទ្រង់សម្តែងហើយ ដោយប្រការដែលធម៌ទាំងឡាយ ព្រះមានព្រះភាគបានត្រាស់ថា ជាធម៌ធ្វើអន្តរាយ ធម៌ទាំងនោះមិនអាចធ្វើអន្តរាយដល់បុគ្គលអ្នកសេពបានឡើយ និងថា ការប្រព្រឹត្តល្មើសដែលធ្វើទៅព្រោះយល់សប្តិ ក៏ជាការធ្វើឲ្យត្រូវអាបត្តិបាន ឈ្មោះថា **ជំទាស់ព្រះវិន័យ អនុលោមតាមព្រះវិន័យនោះ** ដោយបរិយាយដែលផ្សេងអំពីពាក្យដែលពោលនោះ ។ ពិតហើយ បុគ្គលដែលជំទាស់ គឺទម្លាយកម្មដទៃ បុគ្គលដែលប្រដែងធម្មតា និងអនុលោមព្រះវិន័យ គឺការកម្ចាត់កិលេសបានអំពីណា ។ **សម្លឹងមើល** មហាបទេសទាំង ៤ ដែល

*ត្រាស់ទុក ក្នុងព្រះសូត្រ និងមហាបទេស គឺព្រះសូត្រ សត្ថានុលោម អាចរិយវាទ អត្តនោមតិ ដែលពោលទុក ក្នុងអដ្ឋកថា ។ ដោយការសម្លឹងមើលមហាបទេសនោះ រមែងតាំងមាំនៅក្នុងព្រះសូត្រ និងក្នុងព្រះវិន័យ មិនជ្រុលហួសទៅ ។ ពាក្យថា **ធម្មៈ** បានដល់ព្រះបាលីពោលដោយបដិច្ចសមុប្បាទ ។ ពាក្យថា **អត្ថ** បានដល់ សេចក្តីនៃព្រះបាលីនោះ ។ ឬបានដល់ ហេតុ ផលនៃហេតុថា នេះជាហេតុក្នុងប្រការនេះ ឈ្មោះថា **ធម្មៈ** នេះ ជាផលនៃហេតុក្នុងប្រការនេះ ឈ្មោះថា **អត្ថ** ។ម្យ៉ាងទៀត ពាក្យថា **ធម្មៈ** បានដល់ ធម្មតា ។ គឺចន្លុលបង្ហាញសភាវៈដែលកំណត់ទុករបស់ហេតុដោយចំពោះនូវផលរបស់ខ្លួន តាមន័យដែលបានពោលទុកហើយក្នុងខាងដើម នោះឯង មិនបានចន្លុលបង្ហាញ ដូចជាអាចារ្យមួយពួក ចន្លុលបង្ហាញដោយខុសនូវធម៌ គឺបច្ចយាការថា **បដិច្ចសមុប្បាទទៀង** ធ្វើឲ្យកាន់យកដោយខុសនូវអត្ថរបស់បទព្រះសូត្រថា **ព្រះតថាគតទាំងឡាយ ទ្រង់ឧប្បត្តិឡើង ឬមិនឧប្បត្តិក៏ដោយ ធាតុនោះក៏គង់តាំងនៅនោះឯង** ។ និង **រួមយកអត្ថ** ដែលមិនវិបរិតតាមន័យដែលបានពោលទុកហើយនោះឯង មិនបានធ្វើឲ្យប្រកាន់ដូចអាចារ្យមួយពួក ធ្វើឲ្យប្រកាន់ខុសនូវអត្ថនៃបដិច្ចសមុប្បាទ ដោយន័យជាដើមថា **មិនរលត់ មិនកើតឡើង** ។ ឬរអត្ថដែលពោលទុកថា ការមិនដឹងក្នុងអរិយសច្ច មានទុក្ខជាដើម ឈ្មោះថា អវិជ្ជា ហើយ **អធិប្បាយដោយបរិយាយដទៃទៀត** ជាដើមថា ការមិនដឹងក្នុងចំណែកខាងដើមទៀត អាចារ្យទាំងឡាយរមែងពោលថា អធិប្បាយដោយន័យជាដើមថា សង្ខារទាំងឡាយ លោកហៅថា **ភព** ដោយបរិយាយនេះ **តណ្ហា** លោកហៅថា **ឧបាទាន** ដោយបរិយាយនេះ ។ ពាក្យថា **តាមប្រក្រតី** គឺសុទ្ធៗ នោះឯង មិនបានពឹងផ្អែកដល់វិធីតាមដែលបានពោលទុកហើយ ។*

*ពាក្យថា **សច្ចៈ** បានដល់ សច្ចៈ ៤ ។ លោកអាចារ្យទាំងឡាយពោលថា*

ពាក្យថា **សត្វ** បានដល់ **សត្តសុញ្ញតា** គឺការទទេអំពីសត្វ បានដល់ ការបញ្ញត្តថាសត្វក្នុងសង្ខារទាំងឡាយដែលទទេចាកសត្វ និងបានដល់ ការសម្រេចកិច្ចនៃអត្តថាសត្វ ។ បទថា **បច្ចយាការមេវ ច** សេចក្តីប៉ុនគ្នានឹង **បច្ចយាការោឯវ** ប្រែថា បច្ចយការនោះឯង **ម** អក្ខរៈ ធ្វើការភ្ជាប់បទ ។ សេចក្តីថា ផលរបស់ខ្លួននោះឯង ជាបច្ច័យដល់បច្ចយធម៌ទាំងឡាយ ឈ្មោះថា **បដិច្ចសមុប្បាទ** ។

ពាក្យថា **ព្រោះហេតុនោះ** គឺព្រោះការពណ៌នាសេចក្តីតាមន័យ ដែលបានពោលទុកហើយ ជារឿងដែលគួរធ្វើ និងព្រោះជារឿងដែលធ្វើបានដោយលំបាក ។ ពាក្យថា **ខ្ញុំមិនទាន់បានទីតាំងអាស្រ័យ** អធិប្បាយថា មិនទាន់បានន័យនោះ ដែលជាទីតាំងអាស្រ័យរបស់ការពណ៌នានោះ ដែលបុគ្គលតាំងនៅក្នុងទីតាំងអាស្រ័យបានហើយក៏ជារឿងដែលធ្វើបានងាយ ដោយកម្លាំងនៃញាណរបស់ខ្លួននោះឯង ។ លោកអាចារ្យកាលប្រាប់ដល់ទីអាស្រ័យ ទើបពោលពាក្យជាដើមថា **ពាក្យប្រៀនប្រដៅប្រការនេះ** ។ ក្នុងទីនេះលោកអាចារ្យពោលដល់ធម៌ គឺព្រះបាលី ឬពោលដល់បដិច្ចសមុប្បាទនោះឯងថា **ពាក្យប្រៀនប្រដៅ** ។ ពិតណាស់ បដិច្ចសមុប្បាទនោះ ប្រដាប់ទៅដោយទេសនាផ្សេងៗ និងន័យផ្សេងៗ មានអនុលោម និងបដិលោមជាដើម រមែងប្រព្រឹត្តទៅបាន សូម្បីរាល់ថ្ងៃនេះមិនដាច់ខ្សែ ព្រោះដូច្នោះ ទើបឈ្មោះថា ជាទីអាស្រ័យ ។ **ឯគន្លងនៃបុព្វាចារ្យ** បានដល់ អដ្ឋកថានៃបដិច្ចសមុប្បាទនោះ ។ បើមានអ្នកសង្ស័យសួរថា ក្នុងការធ្វើឲ្យកើតការអើពើ និងក្នុងការធ្វើឲ្យកើតឧស្សាហ៍ថា សូមលោកតាំងចិត្តស្តាប់ពាក្យពណ៌នានេះចុះ មានប្រយោជន៍ដូចម្តេច ? លោកអាចារ្យកាលនឹងសម្តែងប្រយោជន៍នោះ ទើបពោលថា **សេចក្តីនេះសមដូចពាក្យដែលបុព្វាចារ្យទាំងឡាយពោលទុក** ដូច្នេះជាដើម ។ បទថា **អដ្ឋិ កត្វា** សេចក្តីប៉ុនគ្នានឹង **អត្ថំ កត្វា** ប្រែថា ធ្វើឲ្យមានប្រយោជន៍ ។ម្យ៉ាងទៀត សេចក្តីប៉ុនគ្នានឹង **អដ្ឋី កត្វា** ប្រែថា ធ្វើឲ្យដល់ឆ្អឹង

ដោយប្រការដែលមិនវិនាសទៅ ឈ្មោះថា **អជ្ជិ កត្វា** ប្រែថា ធ្វើឲ្យដល់ផ្អឹង ។ ដែលមាននៅក្នុង កាលខាងចុងអំពីកាលខាងដើម ឈ្មោះថា **បុព្វាបរិយំ** ប្រែថា ដែលមាននៅអំពី ដើមទៅរហូតចុង ។ ពាក្យថា **គុណវិសេស** សេចក្តីថា រមែងបានញាណដ៏វិសេស និងគុណវិសេស គឺការអស់កិលេសគ្រប់ៗ ខណៈ ចាប់ផ្តើមអំពីដំបូងមក ។

ពាក្យថា **ដោយប្រភេទនៃទេសនា** គឺដោយការផ្សេងនៃទេសនា ។ ដោយអត្ថ ដោយលក្ខណៈជាដើម និងដោយបែបផ្សេងៗ មានតែម្យ៉ាងជាដើម ឈ្មោះថា **អត្ថលក្ខណេ កវិធាទិតោ** ។ ពាក្យថា **និងដោយកំណត់អង្គទាំងឡាយ** គឺដោយសម្តែងការកំណត់អង្គទាំង ១២ មានអវិជ្ជាជាដើម ។

អវិជ្ជាជាមូលនៃបដិច្ចសមុប្បាទ ព្រោះជាហេតុដើមនៃកម្មវដ្ដៈ វិបាកវដ្ដៈ និងកិលេសវដ្ដៈ និងព្រោះត្រាស់ទុកខាងដើម ។ ក្នុងសេចក្តីនោះ កាលបានឃើញមូលនៃបដិច្ចហើយ ការសម្តែងបដិច្ចសមុប្បាទចាប់ផ្តើមអំពីមូលនោះ ក៏ដូចគ្នានឹងកាលឃើញដោយគល់នៃវល្លិ៍ ហើយក៏ទាញវល្លិ៍អំពីគល់នោះទៅ ព្រោះដូច្នោះ ទើបគួរធ្វើការប្រៀបធៀបគ្នាដោយឧបមាថា វត្ថុដែលគប្បីចែកថា វត្ថុនេះទ្រង់បានឃើញហើយ វត្ថុនេះទ្រង់មិនបានឃើញហើយ ដូច្នេះ មិនមានដល់ព្រះមានព្រះភាគឡើយ ព្រោះព្រះអង្គទ្រង់ឃើញទាំងអស់ ។ តែលោកបំណងយកភាពស្មើគ្នាក្នុងប្រការនេះ ដូច្នេះថា ទ្រង់ធ្វើការសម្តែងបដិច្ចសមុប្បាទចាប់ផ្តើមអំពីមូល ដូចការទាញវល្លិ៍មក ចាប់ផ្តើមអំពីគល់ ម្យ៉ាងទៀត គប្បីប្រកបភាពស្មើគ្នាក្នុងការទ្រង់សម្តែងមូលជាដើម ដោយការៈដែលគប្បីឲ្យត្រាស់ដឹង ទាក់ទងនឹងអធ្យាស្រ័យរបស់សត្វដែលគប្បីឲ្យត្រាស់ដឹងបាន ។

បទថា **តស្ស** សេចក្តីថា កាលកុមារដែលព្រះមានព្រះភាគត្រាស់ទុកយ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ កុមារនោះឯង អាស្រ័យការចម្រើន និងការចំជាត់នៃឥន្ទ្រិយទាំងឡាយ ដល់ព្រមដោយកាមគុណ ៥ ។បេ។ ដែលជាទីតាំងនៃសេចក្តីតម្រេក ដែល

ជាទីតាំងនៃសេចក្តីត្រេកអរ ។ កុមារនោះឃើញរូប ដោយចក្ខុហើយ រមែងតម្រេកក្នុងរូបដែលគួរស្រឡាញ់ រមែងអាក់អន់ក្នុងរូបដែលគួរអាក់អន់ និងរមែងជាអ្នកមានសតិក្នុងកាយមិនតាំងមាំ និងមានចិត្តជាអកុសល រមែងមិនដឹងច្បាស់តាមសេចក្តីពិតនូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ដែលជាទីរលត់អស់នៃអកុសលធម៌ដ៏លាមកទាំងឡាយ ។ គេជាបុគ្គលដល់ព្រមនូវការត្រេកអរ មិនត្រេកអរយ៉ាងនេះ សោយវេទនាឯណានីមួយ ជាសុខក្តី ទុក្ខក្តី មិនសុខមិនទុក្ខក្តី រមែងតាំងមុខត្រេកអរ ពណ៌នាសរសើរប្រកាន់ជាប់ក្នុងវេទនានោះ ។ សូម្បីក្នុងសោតទ្វារជាដើមក៏យ៉ាងនេះ ។ ក្នុងបណ្តាពាក្យទាំងនោះ ពាក្យថា **តាំងមុខត្រេកអរ** គឺរីករាយដោយភាពជាបុគ្គលមានមុខចំពោះតណ្ហាដែលប្រកបដោយបីតិ ។ ពាក្យថា **ពោលសរសើរ** គឺពោលសរសើរថា **អញ របស់អញ** ដោយតណ្ហា មានកម្លាំង ដែលប្រព្រឹត្តទៅដោយធ្វើការបន្លឺវាចាថា **សុខ ពិតហ្ន៎ សុខពិតហ្ន៎** ។ ឈ្មោះថា **ប្រកាន់ជាប់** ព្រោះមិនគប្បីអាចនឹងដោះអំពីតណ្ហា ដែលមានកម្លាំងជាងនោះបាន ។ ម្យ៉ាងទៀត តណ្ហាដែលជាឧបាទានដែលមានកម្លាំងជាងនោះ ឈ្មោះថា **នន្ទិ** ។ ក្នុងអធិការនេះ គប្បីជ្រាបថា តណ្ហា លោកពោលទុកដោយពាក្យថា តាំងមុខចំពោះការត្រេកអរជាដើម ឧបាទានដែលមានតណ្ហានោះជាបច្ច័យ លោកពោលទុកដោយពាក្យថា នន្ទិ ឧបាទានទាំង ៤ គប្បីជ្រាបថា លោកពោលទុកដោយជាបុគ្គលមាននន្ទិ និងការមិនប្រាសចាកនន្ទិនោះ និងដោយជាអ្នកតាំងមុខត្រេកអរ ដោយតណ្ហា និងទិដ្ឋិ ។

ពាក្យថា **ព្រោះជាតិជាបច្ច័យ ទើបមានជរា និងមរណៈ** ជាដើម ព្រះសាស្តាត្រាស់ទុក **ក្នុងមហាតណ្ហាសង្ខយសូត្រនោះឯង** ។ ពាក្យថា **អាហារទាំង ៤ មានតណ្ហាជាដើមហេតុ** ជាដើម ព្រះមានព្រះភាគត្រាស់សំដៅដល់ធម៌ មានបដិសន្ធិ បវត្ត និងផស្សៈជាដើម ដែលជាវិបាកវដ្ដៈ និងខុជាដែលមានកម្មជាសមុដ្ឋាន ។ ចំណែកអាហារ

ដែលជាគ្រឿងឧបត្ថម្ភវដ្ដៈក្រៅអំពីនេះ មានតណ្ហាជាដែនកើត កាលតណ្ហាជាដែនកើតនោះមិនមាន ក៏រមែងមិនមាន ព្រោះដូច្នោះ ទើបគួរពោលបានថា មានតណ្ហាជាដើមហេតុ ។

ពីរបទថា **តតោ តតោ** សេចក្ដីថា ក្នុងបណ្ដាទេសនាទាំង ៤ ព្រោះទេសនានោះៗ ។ បទថា **ញាយោ** ក្នុងពីរបទថា **ញាយប្បដិវេធាយ សំវត្តតិ** ដូច្នេះ បានដល់មគ្គ ម្យ៉ាងទៀត **ញាយ** នោះឯង ឈ្មោះថា **បដិច្ចសមុប្បាទ** ព្រោះព្រះបាលីថា **អរិយោ ចស្ស ញាយោ បញ្ញាយ សុទិដ្ឋោ ហោតិ** ប្រែថា ញាយធម៌ដ៏ប្រសើររមែងជាធម៌ ដែលព្រះអរិយសាវកនោះឃើញល្អហើយ ដោយបញ្ញា ។ ពិតហើយ ហេតុថា ខ្លួនឯងនោះឯង ជាធម៌ដែលមានការស្អាតជុំវិញខ្លួន ទើបបដិច្ចសមុប្បាទនោះប្រព្រឹត្តទៅដើម្បីចាក់ធ្លុះនូវខ្លួនឯងដោយទេសនានោះៗ ព្រោះជាធម៌ដែលគប្បីចាក់ធ្លុះដោយប្រការនោះ ។ ពាក្យថា **ព្រោះទ្រង់ដល់នូវព្រះគម្ភីរភាព ៤ ប្រការ** សេចក្ដីថា ព្រោះទ្រង់តាំងនៅដោយការត្រាស់ដឹង ការតាំងនៅក្នុងធម៌គម្ភីរភាព អត្ថគម្ភីរភាព ទេសនាគម្ភីរភាព និងបដិវេធគម្ភីរភាព ។

ធម៌មានការស្អាតដោយជុំវិញ និងការដែលទ្រង់ដល់នូវភាពស្អាតក្នុងវិធីទេសនា ជាហេតុស្មើគ្នានៃទេសនាទាំង ៤ ព្រោះដូច្នោះ លោកអាចារ្យមានបំណងពោលហេតុដែលប្លែកគ្នា ទើបពោលថា **ដោយការប្លែកគ្នា** ដូច្នេះ ។ បទថា **អស្ស** គប្បីប្រកបបាលីថា **អស្ស ភគវតោ ទេសនា អស្ស ឃោគ ភគវតោ** ប្រែថា ទេសនារបស់ព្រះមានព្រះភាគនោះ ម្យ៉ាងទៀត គប្បីប្រកបបាលីថា **អស្ស បដិច្ចសមុប្បាទស្ស ទេសនា អស្ស ឃោគ បដិច្ចសមុប្បាទស្ស** ប្រែថា ទ្រង់សម្ដែងបដិច្ចសមុប្បាទនោះ **ពោលដល់ការចែកហេតុនៃបវត្តិតទៅ** ធម៌ទាំងឡាយ មានអវិជ្ជាជាដើមនោះឯង មានសភាវៈមិនទាន់បានចែក ម្យ៉ាងទៀត ភាវៈដែលធម៌មាន **បកតិ** ជាដើម និងធម៌ មានអវិជ្ជា

ជាដើម ដែលតែងប្រកាន់ថា ជាហេតុ មិនបានជាហេតុផង ជាហេតុផង ។ បុគ្គលពួកខ្លះដែលនៅល្ងង់ខ្លៅក្នុងការបែកហេតុប្បវត្តិនោះ រមែងប្រកាន់ថា មិនមែនជាហេតុថាជាហេតុ ពួកខ្លះក៏មិនស្គាល់សូម្បីហេតុត្រឹមតែមួយ ព្រោះដូច្នោះ **ដើម្បីទ្រង់ចង្អុលបង្ហាញបវត្តិ** នៃធម៌ មានសង្ខារជាដើម អធិប្បាយថា ដើម្បីទ្រង់ចង្អុលបង្ហាញការប្រព្រឹត្តទៅនៃសង្សារវដ្ត តាមហេតុ **ដែលសមគួរដល់ខ្លួន** គឺដែលសមគួរនៃធម៌ទាំងនោះ ។ **ដើម្បីទ្រង់ចង្អុលបង្ហាញនូវលំដាប់នៃការកើតឡើង** របស់បវត្តិយ៉ាងនេះថា អវិជ្ជាដែលជាគ្រឿងបិទបាំងទោសនៃបវត្តិជាខាងដើម តអំពីនោះ ទើបសង្ខារកើតឡើង តអំពីនោះ ទើបវិញ្ញាណកើតឡើង ម្យ៉ាងទៀត អនុលោមទេសនាប្រព្រឹត្តទៅហើយ ដើម្បីទ្រង់ចង្អុលបង្ហាញលំដាប់នៃការកើតឡើងនៃអត្តភាពក្នុងភពនោះៗ ដោយអំណាចសត្វ មានសត្វដែលនៅក្នុងគភ៌ជាដើមផងដែរ ។ ក្នុងពាក្យដែលទេសនាក្រៅអំពីនេះជាទេសនាដែលមានអត្ថ យ៉ាងនោះ ទេសនាក្រៅអំពីនេះក៏មិនមានការប្រព្រឹត្តទៅដើម្បីអត្ថនោះតែម្យ៉ាងឡើយ ព្រោះមានអត្ថដទៃ ។ ចំណែកអនុលោមទេសនានេះមានអត្ថដូច្នោះប៉ុណ្ណោះ ព្រោះដូច្នោះ ទើបលោកពោលអនុលោមទេសនានេះ មានអត្ថដូច្នោះ កាលព្រះមានព្រះភាគ ទ្រង់សម្លឹងឃើញបដិលោមទេសនានេះបានប្រព្រឹត្តទៅហើយ ដើម្បីទ្រង់ចង្អុលបង្ហាញហេតុ មានជាតិជាដើមនៃទុក្ខ មានជរាមរណៈជាដើមដែលព្រះអង្គទ្រង់បានជួបមកដោយការត្រាស់ដឹងធម៌ ដែលកើតអំពីបច្ច័យនោះៗ តាមគន្លងនៃការបាក់ធ្លុះ គ្រាដំបូង ពោល គឺការស្ទុង់ដឹងធម៌ដែលកើតអំពីបច្ច័យនោះ ដែលបានប្រព្រឹត្តទៅ ហើយក្នុងខាងដើមអំពីការត្រាស់ដឹងនោះ ។ ម្យ៉ាងទៀត ភ្ជាប់សេចក្តីថា បដិលោម ទេសនាបានប្រព្រឹត្តទៅហើយដល់ព្រះមានព្រះភាគ ដែលទ្រង់សម្លឹងឃើញ ។ ពិតហើយ ព្រះមានព្រះភាគសូម្បីទ្រង់កំពុងសម្តែងធម៌ ទ្រង់បានសម្លឹងឃើញសត្វ លោកដែលដល់នូវសេចក្តីលំបាក ទ្រង់រមែងសម្តែងដើម្បីចង្អុលបង្ហាញ

ហេតុនៃទុក្ខ មានជរា និងមរណៈជាដើមនោះៗ ដែលទ្រង់បានជួបតាមគន្លងដែលទ្រង់បានចាក់ធ្លុះ ក្នុងគ្រាដំបូងនោះឯង ។ លោកអាចារ្យពោលថា **ធ្វើទៅរហូតដល់អតីតអទ្ធា** ដូច្នេះ ដោយអធិប្បាយដូច្នេះថា ធម៌មានអាហារ និងតណ្ហាជាដើម ជាបច្ចុប្បន្នអទ្ធា សង្ខារ និងអវិជ្ជា ជាអតីតអទ្ធា ។ ម្យ៉ាងទៀត អាហារដែលតណ្ហាគប្បីឲ្យកើតមុន ជាអនាគតអទ្ធា កិលេស មានតណ្ហាជាដើម ជាបច្ចុប្បន្នអទ្ធា សង្ខារ និងអវិជ្ជាជាអតីតអទ្ធា ដូច្នេះ ។ ការសម្ដែងបន្តនៃហេតុ និងផល រមែងគួរដោយអំណាចការសម្ដែងដល់ផល ដោយប្រចក្សហើយ ទើបសម្ដែងដើមហេតុនៃផលនោះ ព្រោះដូច្នោះ ទើបលោកពោលអាហារដែលមូលតណ្ហាធ្វើឲ្យកើតឡើងថា ជាបច្ចុប្បន្នអទ្ធា កិលេស មានតណ្ហាជាដើម ថាជាអតីតអទ្ធា សង្ខារ និងអវិជ្ជា ថាជាអតីតអទ្ធា សូម្បីក្រៃលែងជាងកិលេស មានតណ្ហាជាដើមនោះ ដើម្បីសម្ដែងថា សង្សារមិនមានខាងដើម ។ ពាក្យថា **រហូតដល់អតីតអទ្ធា** សេចក្ដីថា រហូតអតីតអទ្ធាដែលក្រៃលែងជាងទើបសមគួរដូច្នេះ ម្យ៉ាងទៀត អាហារទាំង ៤ នាំមកនូវការកើតឡើងក្នុងភពថ្មីតទៅ ព្រោះផស្សៈ និងវេទនាសម្បយុត្តជាមួយវិញ្ញាណាហារ និងព្រោះកពឡិង្ការាហារជាហេតុឲ្យវិញ្ញាណ ផស្សៈ និងចេតនានោះប្រព្រឹត្តទៅ ព្រោះព្រះបាលីថា **តថាគតមិនបានពោលថា បរិភោគលេប វិញ្ញាណាហារ បើតថាគត ពោលថា ទំពាស៊ី ( វិញ្ញាណាហារ ) គួរតាំងបញ្ហាក្នុងប្រការនោះថា បពិត្រព្រះអង្គ បុគ្គលណាទំពាស៊ី តែតថាគតមិនបានពោលយ៉ាងនោះ បុគ្គលណាគប្បីសួរតថាគត ដែលមិនបានពោលយ៉ាងនោះ ដោយពាក្យនេះថា បពិត្រព្រះអង្គ វិញ្ញាណាហាររមែងមាន ដើម្បីអ្វីហ្ន៎នេះជាប្រស្នាគួរដោះស្រាយ គួរចន្លុលបង្ហាញឲ្យភ្លឺច្បាស់ក្នុងបញ្ហានោះថា វិញ្ញាណាហាររមែងមានដើម្បីការកើតឡើងក្នុងភពថ្មីតទៅ** ។

ពិតហើយ កពឡិង្ការាហារនោះ ឧបត្ថម្ភរូបកាយទុក ហើយកាលបុគ្គលត្រូវ

ការកពឡិង្គាភហារនោះ ក៏មានការប្រមូលមកនៃកាមវិញ្ញាណ ។ ពិតហើយ ភោជន លោកពោលថា ជាឧបនិស្សយប្បច្ច័យដល់ធម៌ មានសទ្ធាជាដើម និងដល់កិលេស មានរាគៈជាដើម ។ ព្រោះដូច្នោះ អាហារដែលលោករួមទុកដោយកម្មវដ្ដៈ ទាំងនោះ ទើបចាត់ជាបច្ចុប្បន្នអទ្ធា ព្រោះដូច្នោះ ក្នុងបរិយាយនេះ អត្ថខាងដើមប៉ុណ្ណោះសម គួរហើយ ។

សេចក្ដីថា ទេសនានេះប្រព្រឹត្តទៅហើយ **តាំងអំពីអតីតអទ្ធា** គឺក្នុងអតីត ដោយ ន័យជាដើមថា ម្នាលភិក្ខុទាំងឡាយ ព្រោះអវិជ្ជាជាបច្ច័យ ទើបមានសង្ខារដូច្នេះឯង និងលំដាប់ផលនៃហេតុតអំពីអតីតនោះ ដើម្បីទ្រង់សម្ដែងដល់លំដាប់នៃហេតុ និង ផលនោះដល់បុគ្គលដែលវៀរចាកការកើតកន្ទ្រាក់ឡើងទៅ ដោយការសម្ដែងហេតុ នៃអាហារ ដែលជាគ្រឿងប្រចក្សហើយត្រឡប់មកក៏មិនដឹង ។ ពាក្យថា **ចាប់ផ្ដើម អំពីការកើតឡើងនៃហេតុរបស់អនាគត** បានដល់ ចាប់ផ្ដើមអំពីការកើតឡើងរបស់ ធម៌ដែលជាហេតុនៃភពដែលមិនទាន់មកដល់ ។ ពាក្យថា **ដើម្បីទ្រង់ចង្អុលបង្ហាញ អនាគតអទ្ធា** សេចក្ដីថា ដើម្បីទ្រង់សម្ដែងហេតុដែលប្រចក្ស គឺចំពោះមុខនៃអនាគត-អទ្ធា ដល់បុគ្គលដែលមិនបានចាក់ធ្លុះ បុគ្គលដែលមិនឃើញ ហើយចង្អុលបង្ហាញ អនាគតអទ្ធានោះ ដោយការបន្តនៃហេតុ និងផល ។ ក្នុងអធិការនេះ ទេសនាប្រព្រឹត្ត ទៅចាប់ផ្ដើមអំពីដើម រហូតដល់ចុង និងចាប់ផ្ដើមអំពីចុងទៅរហូតដល់ដើម ក៏មានអង្គ ១២ ព្រោះហេតុនោះឯង ទើបមានសន្ធិ ៣ សង្ខេប ៤ ។ ទេសនាដែលប្រព្រឹត្តទៅ ចាប់ផ្ដើមអំពីកណ្ដាល រហូតដល់ដើម មានអង្គ ៨ មានសន្ធិ ២ មានសង្ខេប ៣ ។ ចំណែកទេសនាដែលប្រព្រឹត្តទៅចាប់ផ្ដើម អំពីកណ្ដាលរហូតដល់ចុង មានអង្គ ៦ មានសន្ធិ ២ មានសង្ខេប ៣ ។ ទេសនាដែលប្រព្រឹត្តទៅចាប់ផ្ដើមអំពីកណ្ដាល រហូត ដល់ចុង ដោយន័យ មានជាដើមថា ម្នាលភិក្ខុទាំងឡាយ កាលបុគ្គលតាមឃើញ

គុណក្នុងធម៌ទាំងឡាយដែលជាទីតាំងនៃសំយោជនៈ តណ្ហារមែងចម្រើនទូទៅ ព្រោះតណ្ហាជាបច្ច័យ ទើបមានឧបាទាន ដូច្នេះ ក៏មានសន្ធិ ១ មានសង្ខេប ២ ។ បដិច្ចសមុប្បាទទេសនា ដែលមានអង្គច្រើននេះ មានមកហើយដោយប្រការដូច្នេះ ។ ម្យ៉ាងទៀត បដិច្ចសមុប្បាទទេសនា សូម្បីទាក់ទងជាមួយអង្គ ១ ក៏បានដូចគ្នា ទើបត្រាស់ទុកថា

**ម្នាលភិក្ខុទាំងឡាយ ព្រះអរិយសាវកបានស្តាប់ហើយ រមែងធ្វើទុកក្នុងចិត្តដោយល្អ ដោយឧបាយដល់បដិច្ចសមុប្បាទ ក្នុងរាងកាយ និងចិត្ត ដែលតថាគតពោលមកនោះថា ព្រោះហេតុដូច្នេះ កាលវត្ថុនេះមាន ទើបវត្ថុនេះមាន ព្រោះវត្ថុនេះកើតឡើង ទើបវត្ថុនេះកើតឡើង ។ កាលវត្ថុនេះមិនមាន វត្ថុនេះក៏មិនមាន ព្រោះវត្ថុនេះរលត់ ទើបវត្ថុនេះរលត់ ម្នាលភិក្ខុទាំងឡាយ ព្រោះអាស្រ័យផស្សៈ ជាបច្ច័យនៃសុខវេទនា ទើបកើតសុខវេទនា ។**

ក្នុងអធិការនេះ ព្រះមានព្រះភាគ ត្រាស់បដិច្ចសមុប្បាទត្រឹមប៉ុណ្ណោះឯងថា ព្រោះផស្សៈជាបច្ច័យ ។ ដោយហេតុនោះ ទើបសេចក្តីនេះ ធ្វើឲ្យយល់ថា បដិច្ចសមុប្បាទមានអង្គ ១ ។ បណ្តាពាក្យទាំងនោះ ពាក្យថា **កាលវត្ថុនេះមាន ទើបវត្ថុនេះមាន** សេចក្តីថា កាលវត្ថុនេះ គឺកាលបច្ច័យ មានអវិជ្ជាជាដើមមាន ទើបវត្ថុនេះ គឺផលមានសង្ខារជាដើមមាន។ពាក្យថា**ព្រោះវត្ថុនេះកើតឡើងទើបវត្ថុនេះ កើតឡើង** សេចក្តីថា ព្រោះវត្ថុនេះ គឺបច្ច័យ មានអវិជ្ជាជាដើមកើតឡើង ទើបវត្ថុនេះ គឺផល មានសង្ខារជាដើម កើតឡើង ។ ពាក្យថា **កាលវត្ថុនេះមិនមាន ទើបវត្ថុនេះមិនមាន ព្រោះវត្ថុនេះរលត់ ទើបវត្ថុនេះរលត់** សេចក្តីថា ដោយការត្រាស់ដល់ការមិនមាននៃសង្ខារជាដើម ក្នុងកាលមិនមានអវិជ្ជាជាដើម និងការរលត់នៃសង្ខារជាដើម ព្រោះអវិជ្ជាជាដើមរលត់ទៅ រមែងត្រូវសម្តែងសេចក្តីពិតប្រាកដ ក្នុងលក្ខណៈ

នៃបច្ច័យដំបូងថា **កាលវត្ថុនេះមានប៉ុណ្ណោះ មិនមែនមិនមាន ព្រោះវត្ថុ នេះកើតឡើងប៉ុណ្ណោះ មិនមែនព្រោះរលត់** ដូច្នេះ ដោយហេតុនោះ លក្ខណៈនេះ មានការពិតប្រាកដឈោងចុះខាងក្នុង គប្បីឃើញថា ត្រាស់ទុកសម្រាប់បដិច្ចសមុប្បាទធម៌ **ក្នុងទីនេះ**។

ពាក្យថា **រលត់** បានដល់ ការមិនកើតតទៅ គឺការមិនប្រព្រឹត្តទៅ ព្រោះអវិជ្ជាជាដើម ដល់នូវការខ្ចាក់ទៅ ។ សមដូចព្រះពុទ្ធវចនៈដែលត្រាស់ទុក មានជាដើមថា **អវិជ្ជាយ ត្វេវ អសេសវិរាគនិរោធា** ព្រោះអវិជ្ជានោះឯងរលត់ទៅដោយការខ្ចាក់ចោលមិនមានសេសសល់ ។ ឯការកើតឡើងជាសត្រូវចំពោះការរលត់ដែលជាហេតុត្រាស់ហៅការរលត់នោះ ដោយការៈថា ជាសត្រូវចំពោះការកើតឡើងថា **ព្រោះវត្ថុនេះរលត់ ទើបវត្ថុនេះរលត់ទៅ** ដោយហេតុនោះ ទើបលោកអាចារ្យសម្ដែងទុកថា **ការមិនរលត់** ឈ្មោះថា **ការកើតឡើងក្នុងអធិការនេះ ការមិនរលត់នោះ លោកហៅថា អត្ថិភាវៈ** ដូច្នេះក៏មាន ។ ពិតហើយ លក្ខណៈនេះថា **កាលវត្ថុនេះមាន ទើបវត្ថុនេះមាន** ប៉ុណ្ណោះ រមែងជាពាក្យដែលអ្នកដទៃពោលថា **ព្រោះវត្ថុនេះកើតឡើង ទើបវត្ថុនេះកើតឡើង** ដោយបរិយាយដទៃធ្វើលក្ខណៈដំបូង ឲ្យផ្សេងចេញទៅ ព្រោះដូច្នោះ ព្រះមានព្រះភាគត្រាស់ថា **កាលវត្ថុនេះមាន** ដូច្នេះ ទ្រង់សំដៅដល់ភាវៈដែលកំពុងទ្រទ្រង់ប៉ុណ្ណោះក៏ទេ ដោយពិត រមែងធ្វើឲ្យយល់បានថា ជាភាវៈដែលមិនបានរំលត់ដោយមគ្គ ។ ម្យ៉ាងទៀត ព្រះមានព្រះភាគកាល ទ្រង់សម្ដែងពាក្យពន្រឹកនៃការរលត់ ដែលមានលក្ខណៈទ្រង់បានលើកឡើងសម្ដែងទុកទាំង ២ ប្រការថា **កាលវត្ថុនេះមិនមាន ទើបវត្ថុនេះមិនមាន ព្រោះវត្ថុនេះរលត់ ទើបវត្ថុនេះរលត់** ដូច្នេះ បានត្រាស់ដល់ការរលត់នោះឯង ដោយព្រះតម្រាស់ថា **ព្រោះអវិជ្ជានោះឯងរលត់ទៅដោយការខ្ចាក់ចោលមិនមានសេសសល់ ទើបសង្ខាររលត់** ព្រោះដូច្នោះ សូម្បីនត្ថិភាវៈក៏ត្រូវរលត់នោះឯង ព្រោះដូច្នោះ ទើបទ្រង់សម្ដែងបានថា អត្ថិភាវៈ ដែលខុស

ទៅអំពីនត្ថិភាវៈ ក៏មិនជាការរលត់ ដោយហេតុនោះ ទើបព្រះមានព្រះភាគទ្រង់ធ្វើការកើតឡើង ឲ្យផ្សេងចេញទៅដោយអត្ថិភាវៈ ពោល គឺការមិនរលត់ ។ ព្រោះដូច្នោះ ទើបលោកអធិប្បាយសេចក្ដីនេះទុកថា លោកមានបំណងយកថា ត្រឹមតែជាការបានអត្តាកើតឡើងក្នុងទីនេះក៏ទេ ដោយពិតនោះ លោកមានបំណងយកអត្ថិភាវៈ ពោល គឺការមិនរលត់ទុកផង ព្រោះដូច្នោះ ការពោលលក្ខណៈទាំង ២ នេះទុក គប្បីជ្រាបថា មានប្រយោជន៍ ដោយជាពាក្យដែលធ្វើឲ្យផ្សេងគ្នា និងប្រការដែលគប្បីធ្វើឲ្យផ្សេងគ្នានឹងគ្នា ដោយប្រការដូច្នេះ ។

សួរថា ដែលឈ្មោះថា **អនិរោធ** ការមិនរលត់ ដែលហៅថា **អត្ថិភាវ** ការមាន និងហៅថា **ឧប្បាទ** ការកើតឡើងនេះ ដូចម្ដេច ? ឆ្លើយថា បានដល់ ភាវៈដែលលះមិនទាន់បាន និងកិរិយាដែលអាចឲ្យកើតផលដោយសភាវៈ ដែលមានផលមិនទាន់កើតឡើង និងភាវៈដែលគួរដល់ភាពជាធម៌ដែលមិនទាន់លះបាន ។ ភាវៈដែលអកុសលធម៌ដែលធម៌ទាំងនោះ គប្បីលះនៅមិនទាន់ត្រូវអរិយមគ្គដកឡើង ម្យ៉ាងទៀត កុសលធម៌ និងអព្យាកតធម៌ពួកណា ដែលមិនមែនជាធម៌ គប្បីលះសំយោជនៈក្នុងកុសលធម៌ និងអព្យាកតធម៌ទាំងឡាយនោះរបស់លោកដែលមានអាសវៈមិនទាន់អស់ទៅ សំយោជនៈទាំងនោះនៅមិនទាន់អស់ទៅផង ។ ឯការប្រព្រឹត្តទៅនៃខន្ធ ព្រមទាំងសំយោជនៈ ឈ្មោះថា **បដិច្ចសមុប្បាទ** ព្រោះជាធម៌ដែលមានអនុស័យមិនទាន់ដកចេញ ។ សេចក្ដីនេះ សមដូចព្រះបាលីដែលត្រាស់ថា

ម្នាលភិក្ខុទាំងឡាយ កាយនេះរបស់បុគ្គលពាល ដែលត្រូវអវិជ្ជាណាបិទបាំងទុក បុគ្គលប្រកបដោយតណ្ហាណា កើតឡើង អវិជ្ជានោះ បុគ្គលពាលក៏នៅមិនទាន់លះបាន តណ្ហានោះក៏នៅមិនទាន់អស់ទៅផង ។ សេចក្ដីនោះព្រោះហេតុអ្វី? ម្នាលភិក្ខុទាំងឡាយ ព្រោះបុគ្គលពាលមិនបានប្រព្រឹត្តព្រហ្មចរិយៈដើម្បីការអស់ទុក្ខដោយ

*ប្រពៃ ។ ព្រោះដូច្នោះ បុគ្គលពាលកាលកាយបែកធ្លាយទៅ ទើបជាបុគ្គលចូលដល់កាយ បុគ្គលពាលនោះ កាលចូលដល់កាយ ទើបមិនរួចផុតអំពីជាតិ ជរា និងមរណៈដូច្នេះជាដើម ។*

*ម្យ៉ាងទៀត អវិជ្ជារបស់បុគ្គលដែលមានសំយោជនៈអស់ហើយ សង្ខារ តណ្ហា និងឧបាទានក៏មិនមាន ដូច្នោះ ទើបឧបាទាន និងភពមិនកើត ព្រោះហេតុនោះ ទើបការចូលទៅកាត់វដ្ដៈប្រាកដ ។ ដោយហេតុនោះឯង ទើបព្រះមានព្រះភាគត្រាស់ព្រះពុទ្ធវចនៈថា*

***ម្នាលផគ្គុន ព្រោះផស្សាយតនៈទាំង ៦ នោះឯងរលត់ទៅ ដោយខ្វាក់ចោលមិនមានសេសសល់ ទើបផស្សៈរលត់ ព្រោះផស្សៈរលត់ ទើបវេទនារលត់*** *ជាដើម ។*

*តអំពីការសម្រេចមគ្គដ៏លើសទៅរហូតដល់បរិនិព្វាន ធម៌ទាំងឡាយ មានសឡាយតនៈជាដើម មិនប្រព្រឹត្តទៅក៏ទេ ដោយពិត លោកក៏ហៅថា* ***និរោធ*** *ព្រោះជាការមិនមាន ដែលគប្បីពោលបានដោយនិរោធសព្ទ ឈ្មោះថា មានសំយោជនៈអស់ហើយ ។ ម្យ៉ាងទៀត កម្មដែលបានធ្វើទុកយូរហើយ ក៏រមែងឈ្មោះថា ជាធម្មជាតិដែលមាននោះឯង គួរដល់ការមានផល ព្រោះជាកម្មដែលមិនទាន់បានធ្វើផលឲ្យកើតឡើង និងព្រោះជាកម្មដែលអាចឈ្មោះថា មិនទាន់លះបាន ជាធម្មជាតិ មានផលកើតឡើងហើយក៏ទេ ទាំងជាធម្មជាតិគួរដល់ធម៌ ដែលលះបានហើយក៏ទេ ព្រោះដូច្នោះ គប្បីជ្រាបថា ធម៌ទាំងឡាយ មានអវិជ្ជា និងសង្ខារជាដើម ដែលជាបច្ច័យដល់ការកើតឡើងនៃផល ជាធម៌គួរដល់ការមានផល តាមន័យដែលបានពោលទុកហើយ ទើបឈ្មោះថា* ***អនិរោធ*** *ប្រែថា ការមិនរលត់ ។ ផលនឹងមិនមានដោយវៀរចាកហេតុណា ដោយការៈដែលជាហេតុនៅមិនទាន់រលត់នោះឯង យ៉ាងនេះ ហេតុនោះ*

ដែលជាអតីតជាដើមក៏មាន ។ ព្រះមានព្រះភាគបានត្រាស់ទុក ដោយពាក្យនេះថា **ឥមស្មឹ សតិ** ប្រែថា កាលវត្ថុនេះមាន ។ ក៏ព្រោះហេតុនោះឯង ការកើតឡើងនៃបច្ច័យ ដែលមិនទាន់ដល់នូវធម្មតា គឺការមិនប្រព្រឹត្តទៅរបស់បុគ្គល ដែលនៅមិនទាន់បាន នៅចប់ព្រហ្មចរិយៈ ព្រះមានព្រះភាគ ទើបមិនបានប្រារព្ធដល់ភាពផ្សេងគ្នានៃកាល ត្រាស់ទុកថា **ឥមស្សុប្បាទា** ប្រែថា ព្រោះវត្ថុនេះកើតឡើង ដូច្នេះ ព្រោះជាសភាវៈ មិនត្រឡប់ ។ម្យ៉ាងទៀត ធម៌សូម្បីនៅមិនទាន់មានក្នុងកាល ការប្រជុំនៃបច្ច័យដ៏សេស ក៏ដូចមាននៅ នឹងពោលទៅថ្វីដល់ធម៌ដែលមាននៅ ជាធម៌ដែលប្រឈមមុខចំពោះ ការកើតឡើងនៃផលឯណា ជាធម៌ប្រឈមមុខចំពោះការកើតឡើងនៃផលនោះ ត្រាស់ហៅថា **ឥមស្សុប្បាទា** ព្រោះវត្ថុនេះកើតឡើង ។ ព្រោះក្នុងវេលានោះ ផលរមែង កើតអំពីហេតុនោះ ព្រោះដូច្នោះ ហេតុដែលជាទីតាំង ចុះនៃផលនោះ ដែលប្រាកដ ដោយភាវៈ គឺការញ៉ាំងផលឲ្យកើតឡើង រមែងជាហេតុ ឈ្មោះថា កើតឡើងហើយ ហេតុដែលមាន តែមិនបានជាទីតាំងចុះនៃផលនោះ មិនឈ្មោះថាជាហេតុដែលកើតឡើង ហើយទេ ព្រោះដូច្នោះ ធម្មជាតិដែលជាទីតាំងចុះនៃផលនោះ គប្បីជ្រាបថា ឈ្មោះថា **ឧប្បាទ** ប្រែថា ការកើតឡើង ។

បណ្ដាបទទាំងនោះ ដោយបទថា **សតិ** នេះ ព្រះមានព្រះភាគ កាលត្រាស់ដល់ បច្ច័យដោយអាការគ្រាន់តែជាធម្មជាតិដែលមាន ទ្រង់រមែងសម្ដែងដល់បដិច្ចសមុប្បាទ ជាធម៌ដែលមិនមានការខ្វល់ខ្វាយ ។ ដោយបទថា **ឧប្បាទា** នេះ ព្រះមានព្រះភាគ កាលទ្រង់សម្ដែងជាធម៌ ដែលមានការកើតឡើងជាធម្មតា ជាធម៌ដែលមិនមែនមាន នៅក្នុងកាលទាំងពួង ជាធម៌ដែលប្រឈមមុខចំពោះការកើតឡើងនៃផល រមែងសម្ដែង ដល់ភាពដែលបដិច្ចសមុប្បាទជាធម៌មិនទៀង ។ ម្យ៉ាងទៀត ព្រះមានព្រះភាគទ្រង់ រមែងសម្ដែងភាពដែលបដិច្ចសមុប្បាទ ជាធម៌ដែលមានជាតិ ដែលមានដើមហេតុ

ជាសមុទយៈជាដែនកើតមុន ដែលធ្វើឲ្យយល់បានដោយសត្តមីវិភត្តិ និងបញ្ចមីវិភត្តិ មានអត្ថន័យថា ជាហេតុថា **សតិ ន អសតិ ឧប្បាទោ ន និរោធោ** ប្រែថា កាលមាន មិនមែនកាលមិនមានទេ កាលកើតឡើងមិនមែនកាលរលត់ទេ ។ក្នុងអធិការនេះដែល មានអត្ថថា ជាហេតុ បានដល់ ផលដែលគប្បីមាន ដោយមិនវៀរចាកហេតុនោះ លោករមែងកំណត់បានដោយភាវៈរបស់ធម៌ណា ក្នុងសត្តមីវិភត្តិ គប្បីជ្រាបបានដោយ ការប្រព្រឹត្តទៅក្នុងធម៌នោះ ដូចជាពាក្យថា **អធនានំ ធនេ អននុប្បទីយមានេ ទាលិទ្ទិយំ វេបុល្លមគមាសិ** ប្រែថា កាលព្រះមហាក្សត្រមិនព្រះរាជទានទ្រព្យដល់បុគ្គល ដែល មិនមានទ្រព្យ ភាពក្រីក្រក៏ផ្សាយចេញទៅ និងថា **និប្ផន្នេ សស្សេ សុភិក្ខំ ជាយតិ** ប្រែថា កាលស្រូវសម្រេចហើយ ទីឋាន ដែលមានភិក្ខាហាររកបានងាយក៏កើតឡើង ។ បញ្ចមីវិភត្តិមានអត្ថថា ហេតុព្រោះជាដែនកើតនៃផល និងព្រោះការប្រព្រឹត្តទៅក្នុង បកតិ ដូចជាពាក្យថា **កលលា ហោតិ អព្ពុទំ អព្ពុទា ជាយតេ បេសិ** ប្រែថា តអំពី កលលៈក៏ជាអព្ពុទៈ តអំពីអព្ពុទៈក៏កើតជាបេសិ និងពាក្យថា **ហិមវតា គង្គា បភវតិ សិង្គតោ សរោ ជាយតិ** ប្រែថា ស្ទឹងគង្គារមែងកើតអំពីភ្នំហិមពាន្ត សំឡេងរមែង កើតអំពីស្នែងសត្វ ។ ដោយធម៌ មានអវិជ្ជាជាដើម ទើបលោកកំណត់ថាជាធម៌ មានសង្ខារជាដើមដែលមានបាន ដោយមិនវៀរចាកអវិជ្ជាជាដើមនោះ និងព្រោះធម៌ ទាំងឡាយ មានអវិជ្ជាជាដើម ទើបកើតមានធម៌ទាំងឡាយ មានសង្ខារជាដើម និង តាក់តែងតទៅផង ព្រោះដូច្នោះ ទើបជាដែនកើតមុន និងជាប្រក្រតីនៃធម៌ទាំងនោះ ព្រោះដូច្នោះ កាលនឹងសម្តែងអត្ថនៃធម៌ទាំងនោះ ទើបព្រះមានព្រះភាគទ្រង់ធ្វើនិទ្ទេស ជាសត្តមីវិភត្តិ និងបញ្ចមីវិភត្តិ ដែលមានអត្ថថា ជាហេតុ ដូចពាក្យថា **ឥមស្មឹ សតិ ឥមស្ស ឧប្បាទា** ប្រែថា កាលមានវត្ថុនេះ ព្រោះវត្ថុនេះកើតឡើង ។ ព្រោះក្នុង អធិការបដិច្ចសមុប្បាទដែលទ្រង់លើកឡើងសម្តែងដោយសង្ខេបថា **ឥមស្មឹ សតិ ឥទំ**

**ហោតិ ឥមស្ស ឧប្បាទា ឥទំ ឧប្បជ្ជតិ** កាលមានវត្ថុនេះ ក៏រមែងមានវត្ថុនេះ ព្រោះវត្ថុនេះកើតឡើង វត្ថុនេះក៏រមែងកើតឡើង ដូច្នេះ មាននិទ្ទេសជាដើមថា **អវិជ្ជាបច្ចយា សង្ខារា** ព្រោះអវិជ្ជាជាបច្ច័យ ទើបមានសង្ខារ ដូច្នោះ អត្ថិភាវៈ គឺការមាន និង ឧប្បាទ គឺការកើតឡើងតាមដែលពោលហើយ រមែងធ្វើឲ្យយល់បានថា បច្ច័យរបស់ធម៌ដែលកើតអំពីបច្ច័យនោះៗ ។ ព្រោះថា លះអត្ថិភាវៈ ពោល គឺការមិនរលត់ និង ឧប្បាទ ពោល គឺជាសភាវៈដែលមិនត្រឡប់ ឬពោល គឺសភាវៈដែលកំណត់ចុះដោយការកើតឡើងដែលប្រកាសទុក ដោយពាក្យដែលមានការកំណត់ចុះកាន់ខាងក្នុងថា កាលមានប៉ុណ្ណោះ មិនមែនកាលមិនមាន ព្រោះការកើតឡើងប៉ុណ្ណោះ មិនមែនព្រោះការរលត់ ដែលបានឈ្មោះថា ជាបច្ច័យដទៃនឹងមានក៏ទេ ព្រោះដូច្នោះ អត្ថិភាវៈ និងឧប្បាទតាមដែលពោលហើយ គប្បីជ្រាបថា ជាបច្ច័យ ។ ព្រោះបច្ច័យ ២៤ មាន ហេតុប្បច្ច័យជាដើម ដែលមកហើយក្នុងគម្ពីរបដ្ឋានណា បច្ច័យនោះ គប្បីជ្រាបថា ជាសេចក្តីផ្សេងនៃបច្ច័យនេះនោះឯង ។ម្យ៉ាងទៀត អត្ថថា ហេតុ ដែលលោកប្រកាសទុកហើយ ដោយពាក្យបរិយាយជាដើមថា មូល ថាហេតុ ថានិទាន ថាសម្ភវៈ និងថា បភវៈ និងដោយពាក្យបរិយាយជាដើមថា **ឧប្បាទដ្ឋិតិ** ការតាំងនៅនៃការកើតឡើង **បវត្តដ្ឋិតិ** ការតាំងនៅនៃការប្រព្រឹត្តទៅ **និមិត្តដ្ឋិតិ** ការតាំងនៅនៃនិមិត្ត **អាយូហដ្ឋិតិ** ការតាំងនៅនៃការប្រមូលមក **សំយោគដ្ឋិតិ** ការតាំងនៅនៃការប្រកបទុក **បលិពោធដ្ឋិតិ** ការតាំងនៅនៃកង្វល់នេះ អត្ថថា ហេតុនោះ បណ្ឌិតគប្បីឃើញថា ឈោងចុះកាន់ខាងក្នុង ក្នុងអធិការនេះដូចគ្នា ។

លោកសម្តែងនបុំសកលិង្គទុកថា **ន អការណំ** ដោយសំដៅដល់ស័ព្ទថា **មូលការណ** សេចក្តីប៉ុនគ្នានឹង **អការណា** ។ លោកអាចារ្យកាលសម្តែងថា បើអវិជ្ជាគប្បីជាធម៌មិនមានហេតុសោត ព្រះសូត្រក៏គប្បីត្រូវជំទាស់ផង ទើបទាញយកព្រះ

*សូត្រមកថា **អាសវសមុទយា** ។ **បរិយាយោ** ប្រែថា ហេតុ ។ **អវិជ្ជាជាធម៌ កំពូល** ក្នុងកថាទាក់ទងនឹងវដ្ដៈ ក៏គឺកម្មដែលជាហេតុនៃវដ្ដៈ ក៏ជាតួហេតុ ។ ក្នុងវដ្ដកថានោះ អវិជ្ជាជាតួហេតុរបស់ភវតណ្ហាកើតឡើងក្នុងភព ដែលត្រូវអវិជ្ជានោះបិទបាំងទោសទុក ទើបអវិជ្ជាជាធម៌កំពូលដោយវិសេស ព្រោះហេតុនោះ ទើបលោកពោលថា **ជាមូលនៃហេតុ** ។*

*ព្រោះចំណុចខាងដើមមិនប្រាកដ វៀរចាកការកើតឡើង បុគ្គលក៏គប្បីកាន់យកថា ទៀង ព្រោះដូច្នោះ ទើបព្រះសាស្ដាត្រាស់ទុកថា **ម្នាលភិក្ខុទាំងឡាយ សេចក្ដីនេះតថាគតរមែងពោលទុកយ៉ាងនេះជាដើម** ។ ដោយហេតុនោះ ព្រោះមិនប្រាកដមុនអំពីនេះ អវិជ្ជាជាធម៌ធ្លាប់កើតឡើង រមែងមិនមាន ទើបលោកអាចារ្យសម្ដែងសេចក្ដីនេះទុកថា លោកបានពោលការមិនប្រាកដរបស់ចំណុចខាងដើមទុក ។*

*កាលគួរនឹងពោលដល់ផលតាមលំដាប់របស់ហេតុ គឺអវិជ្ជា និងតណ្ហា ការពោលថា **សុគតិទុគ្គតិគាមិនោ** ដូច្នេះ ដើម្បីមិនឲ្យជំទាស់ជាមួយសទ្ទលក្ខណៈ គឺវេយ្យាករណ៍ ។ ព្រោះថា ក្នុង **ទវន្ទវសមាស** ពាក្យដែលបានទទួលលើកតម្កើងលោកដាក់ទុកខាងដើម ។ បានឮថា ពួកអ្នកស្រុកព្រៃរមែងសម្លាប់គោ ធ្វើឲ្យមានសាច់របេះចេញពីឆ្អឹង រោលដោយគប់ភ្លើងឲ្យក្ដៅ វាយដំរឿយៗ ហើយបញ្ចុកទឹកក្ដៅដើម្បីមិនឲ្យសាច់ជាប់ឆ្អឹង ដោយហេតុនោះ ទើបលោកអាចារ្យពោលពាក្យជាដើមថា **រោលដោយភ្លើង** ។ ក្នុងពាក្យនោះ មានអធិប្បាយថា ឧបមាដូចគោដែលត្រូវសម្លាប់រមែងប្រាថ្នាការបញ្ចុកទឹកក្ដៅតាមដែលបានពោលទុកហើយ ព្រោះត្រូវអវិជ្ជាគ្របសង្កត់ យ៉ាងណា បុថុជ្ជនរមែងប្រាថ្នាកម្មដែលជាទុគ្គតិគាមីនេះ តាមដែលបានពោលទុកហើយ ដូច្នោះ ។ ម្យ៉ាងទៀត គោដែលកំពុងសម្លាប់នោះ ឃើញទោសក្នុងការផឹកទឹកក្ដៅ រមែងប្រាថ្នាការផឹកទឹកត្រជាក់ ដោយអំណាចនៃតណ្ហា យ៉ាងណា បុថុជ្ជន*

ក៏ដូច្នោះ ឃើញទោសក្នុងកម្មដែលជាទុគ្គតិគាមី ព្រោះអវិជ្ជាមិនមានកម្លាំង រមែងប្រារព្ធកម្ម ដែលជាសុគតិគាមី ដោយអំណាចនៃតណ្ហា ។ ពិតហើយ ក្នុងសេចក្តីទុក្ខ តណ្ហា រមែងអនុវត្តតាមអវិជ្ជា ក្នុងសេចក្តីសុខ អវិជ្ជារមែងអនុវត្តតាមតណ្ហា គឺការចង់បាន ។

*កត្ថចិ* *យោគ* *សុត្តេ* ប្រែថា ក្នុងព្រះសូត្រខ្លះ ។ ពីរបទថា **ឯកធម្មមូលិកំ** ***ទេសនំ*** សេចក្តីថា ទេសនា ឈ្មោះថា **ឯកធម្មមូលិកា** ដោយអត្ថថា ទេសនានេះមានធម៌ប្រការមួយប៉ុណ្ណោះ ក្នុងបណ្តាអវិជ្ជាតណ្ហាជាមូល, ទេសនាដែលមានធម៌ប្រការមួយជាមូលនោះ អធិប្បាយថា ព្រះមានព្រះភាគ ទ្រង់រមែងសម្តែងបដិច្ចសមុប្បាទទេសនា ដោយទ្រង់ធ្វើធម៌ប្រការមួយប៉ុណ្ណោះ ក្នុងបណ្តាអវិជ្ជា និងតណ្ហានោះឲ្យជាមូល ។ ហេតុ ឈ្មោះថា **ឧបនិសា** ដោយអត្ថថា ជាទីពឹងអាស្រ័យនៃផលសង្ខារ ឈ្មោះថា **អវិជ្ជូបនិសា** ដោយអត្ថថា មានអវិជ្ជាជាទីអាស្រ័យ ។ បទថា **អស្សាទានុបស្សិនោ** មានអត្ថថា បុគ្គលមានប្រក្រតីតាមឃើញសុខ និងសោមនស្សដែលតែងដឹងថា ជាទីគួរពេញចិត្ត ព្រោះជាធម្មជាតិគួរពេញចិត្តក្នុងធម៌ដែលប្រព្រឹត្តទៅក្នុងភូមិទាំង ៣ ដែលជាទីតាំងនៃឧបាទានជាវិស័យ ។ ឈ្មោះថា **របស់បុគ្គលពាល** ព្រោះការប្រកបដោយលក្ខណៈរបស់បុគ្គលពាល ដោយហេតុដែលជាបុគ្គលលះអវិជ្ជាមិនទាន់បាន ។ បទថា **ឯវំ** សេចក្តីថា ព្រោះជាបុគ្គលដែលមានអវិជ្ជារាំង និងព្រោះជាបុគ្គលប្រកបទៅដោយតណ្ហា ។ ពីរបទថា **អយំ កាយោ** សេចក្តីថា កាយដែលមានវិញ្ញាណនេះជាទីប្រចក្សដល់យើង និងដល់ពួកលោក បានដល់ ខន្ធ ៥ ឬបានដល់អាយតនៈ ៦ ព្រោះអាយតនៈ ៦ នេះ លោកពោលថា មានផស្សៈជាហេតុ ដោយមានព្រះបាលីថា **សាឡាយតនប្បច្ចយា ផស្សោ** ប្រែថា ព្រោះអាយតនៈ ៦ ជាបច្ច័យ ទើបមានផស្សៈ ។ បទថា **សមុទាគតោ** ប្រែថា កើតឡើងហើយ ។ ពីរបទ

ថា **ពហិទ្ធា ច នាមរូបំ** សេចក្តីថា បានដល់ កាយ ដែលមានវិញ្ញាណខាងក្រៅ បានដល់ ខន្ធ ៥ ឬអាយតនៈ ៦ ។ បទថា **ឥត្ថេតំ** កាត់បទជា **ឥត្ថំ ឯតំ** ប្រែថា នេះ ដោយប្រការដូច្នេះ ។ សេចក្តីថា ខន្ធ ៥ របស់ខ្លួន និងអ្នកដទៃ គឺអាយតនៈ ១២ ដែលកំណត់ដោយជាទ្វារ និងអារម្មណ៍ ឈ្មោះថា **ធម៌ ២ យ៉ាង** ។ ពាក្យថា **ព្រោះអាស្រ័យធម៌ ២ យ៉ាង ទើបមានផស្សៈ** សេចក្តីថា ក្នុងបាឋៈដទៃពោលដល់ធម៌ទាំងឡាយ មានចក្ខុសម្ផស្សជាដើម ព្រោះអាស្រ័យធម៌ ២ យ៉ាង មានចក្ខុ និងរូបជាដើម តែក្នុងទីនេះលោកពោលដល់ទាំងអាយតនៈក្នុង និងអាយតនៈខាងក្រៅ លោកពោលទុកថា បានឮថា នាមរូបនេះ ឈ្មោះថា ជាធម៌គូគ្នាយ៉ាងធំ ។ ក្នុងអធិការនេះ មានអធិប្បាយដូចតទៅនេះ ក្នុងបាឋៈដទៃ លោកពោលដល់ធម៌ មានចក្ខុសម្ផស្សជាដើម ដោយអាស្រ័យធម៌ដែលជាគូគ្នា ដែលព្រះមហាកច្ចាយនត្ថេរពោលទុកថា បានដល់ ចក្ខុ និងរូប ។បេ។ បានដល់ ចិត្ត និងធម៌ទាំងឡាយ ដោយន័យជាដើមថា **ព្រោះអាស្រ័យចក្ខុ និងរូប កើតចក្ខុវិញ្ញាណកើតឡើង ព្រោះធម៌ ៣ យ៉ាង ប្រជុំគ្នា ទើបកើតផស្សៈ** ដូច្នេះ តែក្នុងទីនេះ ព្រះមានព្រះភាគទ្រង់ត្រាស់ផស្សៈព្រោះអាស្រ័យអាយតនៈខាងក្នុង និងខាងក្រៅទាំងនោះ ដោយទ្រង់កាន់យកកាយមានចក្ខុជាដើម ដែលត្រាស់ទុកថា **កាយនេះផង** ទ្រង់ធ្វើធម៌ដ៏សេស មានចក្ខុជាដើម ជាទីអាស្រ័យឲ្យជាធម៌អាស្រ័យចក្ខុជាដើមតែម្យ៉ាងថា **ជាអាយតនៈខាងក្នុង** ដោយភាពតែមួយ និងដោយទ្រង់កាន់យកអារម្មណ៍ មានរូបជាដើម ដែលត្រាស់ទុកថា **នាមរូបខាងក្រៅ** ថា **ជាអាយតនៈ ខាងក្រៅ** តែម្យ៉ាងប៉ុណ្ណោះ ។ ព្រោះដូច្នោះ ទើបកាយ និងនាមរូបខាងក្រៅនេះ ឈ្មោះថា ជាធម៌គូគ្នាយ៉ាងធំ ។ ព្រោះអធិប្បាយយ៉ាងនេះ ទើបលោកអាចារ្យពោលថា គួរសម្តែងសេចក្តីក្នុងប្រការនេះថា ដោយខន្ធ ៥ ដោយអាយតនៈ ៦ របស់ខ្លួន និងរបស់បុគ្គលដទៃ ។ ពិតហើយ អាយតនៈ

មានចក្ខុជាដើម ព្រមទាំងទីអាស្រ័យដែលត្រាស់ទុកថា **កាយនេះ** ឈ្មោះថា **ខន្ធ ៥ របស់ខ្លួន** អាយតនៈ មានរូបជាដើម ដែលត្រាស់ទុកថា **នាមរូបខាងក្រៅ** ឈ្មោះថា **ខន្ធ ៥ របស់បុគ្គលដទៃ** ។ ម្យ៉ាងទៀត កាយនេះជាអាយតនៈខាងក្នុង ៦ របស់ខ្លួន នាមរូបខាងក្រៅ ជាអាយតនៈខាងក្រៅរបស់អ្នកដទៃ ដូច្នេះ ។ កាលកាន់យកអត្ថ ដោយប្រការដទៃ ដោយពាក្យដែលត្រាស់ទុកថា **កាយនេះ** ព្រោះធម៌គ្រាន់តែជា អាយតនៈខាងក្នុងប៉ុណ្ណោះ អាយតនៈខាងក្នុងនោះ រមែងជាខន្ធ ៥ របស់ខ្លួន ព្រោះដូច្នោះ ទើបមិនគប្បីមានការសម្តែងដោយខន្ធ ៥ របស់ខ្លួន និងរបស់បុគ្គល ដទៃ ។ បទថា **ឆឡេវាយតនានិ** សេចក្តីថា បុគ្គលពាលដែលត្រូវផស្សៈកើតអំពី អាយតនៈពួកណា ដែលជាហេតុ រមែងសោយសុខ និងទុក្ខ អាយតនៈទាំងនោះ ក៏មាន ៦ ប៉ុណ្ណោះ ជាហេតុរបស់ផស្សៈ ។ដោយ **អាទិ**-ស័ព្ទ បណ្ឌិតគប្បីប្រកបពាក្យ បាលីជាដើម ថា **ឯតេសំ វា អញ្ញតរេន ។ អវិជ្ជានីវរណស្ស ភិក្ខវេ បណ្ឌិតស្ស តណ្ហាយ សម្បយុត្តស្ស** ប្រែថា ឬត្រូវអាយតនៈទាំងឡាយ ៦ នេះ អាយតនៈ ណានីមួយ ពាល់ត្រូវហើយ ។ ម្នាលភិក្ខុទាំងឡាយ កាយនេះរបស់បណ្ឌិត ដែល មានអវិជ្ជាហ៊ុមព័ទ្ធប្រកបហើយដោយតណ្ហា ។ពិតហើយក្នុងព្រះសូត្រនេះព្រះសាស្តា ទ្រង់ធ្វើសង្ខារឲ្យជាធម៌អាស្រ័យអវិជ្ជា និងតណ្ហានោះឯង ហើយទ្រង់កាន់យកវិញ្ញាណ នាមរូប និងសឡាយតនៈ ដោយស័ព្ទថា ទ្រង់ធ្វើផស្សៈនៃសឡាយតនៈក្នុងកាយនោះ ឲ្យជាធម៌អាស្រ័យកាយនោះឯង ហើយទ្រង់សម្តែងវេទនាជាបច្ច័យពិសេស ទ្រង់បាន សម្តែងបដិច្ចសមុប្បាទ ដែលមានអវិជ្ជា និងតណ្ហា ដែលជាអតីតអទ្ធាជាមូល ដែល មានវេទនាជាទីបំផុតរបស់បុគ្គលពាល និងបណ្ឌិត ។ ម្យ៉ាងទៀត កាលទ្រង់សម្តែង សេចក្តីផ្សេងគ្នានៃបុគ្គលពាល និងបណ្ឌិតតទៅ ទ្រង់បានសម្តែងតណ្ហា ព្រមទាំងអវិជ្ជា ដែលជាប្រកពកើតរបស់វេទនាថា **ម្នាលភិក្ខុទាំងឡាយ ឯកាយនេះនៃបុគ្គលពាល**

ដែលត្រូវអវិជ្ជាណាបិទបាំងទុក បុគ្គលប្រកបដោយតណ្ហាណាកើតឡើង អវិជ្ជានោះ បុគ្គលពាលនៅមិនទាន់លះបាន ហើយតណ្ហានោះក៏នៅមិនទាន់អស់ទៅផង ។ សេចក្តីនេះព្រោះហេតុអ្វី ? ម្នាលភិក្ខុទាំងឡាយ ព្រោះបុគ្គលពាល មិនបានប្រព្រឹត្តព្រហ្មចរិយៈដើម្បីការអស់ទុក្ខដោយប្រពៃ ព្រោះដូច្នោះ បុគ្គលពាល កាលកាយបែកធ្លាយទៅ ទើបជាអ្នកចូលដល់កាយ តថាគតរមែងពោលថា បុគ្គលពាលនោះ កាលចូលដល់កាយ ទើបមិនរួចផុតអំពីជាតិ ។បេ។ អំពីទុក្ខ ។

ហើយទ្រង់ធ្វើឧបាទាន និងភពឲ្យជាធម៌អាស្រ័យតណ្ហា ព្រមទាំងអវិជ្ជានោះ សម្តែងធម៌ មានជាតិជាដើម ដោយពាក្យថា រមែងជាបុគ្គលចូលដល់កាយ ត្រាស់បដិច្ចសមុប្បាទដោយអំណាចមូលទាំង ២ ចាប់ផ្តើមអំពីការតាំងឡើងនៃបច្ចុប្បន្ន-ហេតុ ចំណែកបណ្ឌិតពោលដោយបរិយាយផ្សេងអំពីដែលពោលហើយនោះ ត្រាស់បដិច្ចសមុប្បាទដោយបដិលោម ដែលមានមូលទាំង ២ ចាប់ផ្តើមអំពីការអស់ទៅនៃបច្ចុប្បន្នហេតុ ដូច្នេះឯង ។

ពាក្យថា **ដើម្បីនឹងបំពេញ** គឺដើម្បីនឹងចម្រើន អធិប្បាយថា ដើម្បីនឹងចូលទៅសន្សំ ។ អវិជ្ជាលោកអាចារ្យពោលថា **អវិន្ទិយំ វិន្ទតិ** ប្រែថា រមែងបានវត្ថុដែលមិនគួរបាន ព្រោះជាបច្ច័យពិសេសដល់កម្ម ដែលធ្វើឲ្យទៅកាន់ទុគ្គតិ ហើយលោកពោលថា **វិន្ទិយំ ន វិន្ទតិ** ប្រែថា រមែងមិនបានវត្ថុដែលគួរបាន ព្រោះបច្ច័យពិសេសមិនមានដល់វត្ថុដែលគួរនឹងបានយ៉ាងនោះ ។ ការធ្វើឲ្យជាធម្មជាតិអាស្រ័យខន្ធ ហើយញុំាងវិញ្ញាណទាំងឡាយ មានចក្ខុវិញ្ញាណជាដើមឲ្យប្រព្រឹត្តទៅ គឺឲ្យកើតឡើង ឈ្មោះថា **អាយតនៈ** ។ រមែងធ្វើមិនឲ្យប្រាកដ គឺមិនឲ្យបុគ្គលណាដឹងបាន ព្រោះមិនត្រាស់ដឹងដោយភាវៈ គឺការវេង្វេងព្រមនោះឯង ។ ពីរបទថា **អន្តវិរហិតេ ជវាបេតិ** សេចក្តីថា លោកយក **អ** អក្ខរៈ **វិ** អក្ខរៈ និង **ជ** អក្ខរៈ ពោលថា **អវិជ្ជា** ព្រោះលុបអក្ខរៈដទៃ

និងចុះ ៨ អាគមអក្ខរៈទី ២ ដោយអំណាចនិរុត្តិលក្ខណៈ ៥ យ៉ាង គឺ **វណ្ណាគម** ចុះតួអក្ខរៈថ្មី **វិបរិយាយ** ផ្លាស់តួអក្ខរៈ **វិការ**ផ្លាស់តួអក្ខរៈ **វិនាស** លុបតួអក្ខរៈ និង **ធាតុអត្ថវិសេសយោគ** ប្រកបអត្ថ ពិសេសនៃធាតុ ។ លោកអាចារ្យកាល ពោលអត្ថរបស់ព្យញ្ជនៈ ហើយពោលថា ប្រការមួយទៀតជាដើម ដើម្បីនឹងសម្ដែង អត្ថនៃសភាវៈ ។

អវិជ្ជាលោកពោលថា បិទបាំងវត្ថុ និងអារម្មណ៍របស់វិញ្ញាណ មានចក្ខុវិញ្ញាណ ជាដើមនោះ ព្រោះអវិជ្ជាមិនអាចដឹងវត្ថុ និងអារម្មណ៍របស់វិញ្ញាណ មានចក្ខុវិញ្ញាណ ជាដើមថា នេះជាវត្ថុ នេះជាអារម្មណ៍ ។ ព្រោះបិទបាំងសភាវៈនៃវត្ថុ និងអារម្មណ៍ នោះឯង ទើបគប្បីជ្រាបការបិទបាំងបដិច្ចសមុប្បាទ និងបដិច្ចសមុប្បន្នធម៌ ព្រោះ បិទបាំងធម៌ មានអវិជ្ជាជាដើម ជាបដិច្ចសមុប្បាទ និងព្រោះធម៌ មានជរា និងមរណៈ ជាដើម ជាបដិច្ចសមុប្បន្នធម៌ ។

បទថា **អបច្ចក្ខិត្វា** សេចក្ដីថា មិនធ្វើឲ្យប្រចក្ស គឺមិនបដិសេធ ។ អត្ថថា **ឧបការៈដល់បុគ្គលអ្នកមានឧបការៈជាអត្ថរបស់បច្ច័យ** ដូចពាក្យថា **បិណ្ឌបាតាទិសរីរស្ស** ប្រែថា បច្ច័យ មានបិណ្ឌបាតជាដើម ជាឧបការៈដល់សរីរៈ ។ បទថា **អសង្ខតម-ភិសង្ខរោន្តិ** ប្រែថា ធម៌ទាំងឡាយ ប្រជុំតាក់តែងដោយប្រការដែលជាសង្ខតៈ ។ សង្ខារទាំងឡាយ ដែលមកដោយការកាន់យកសង្ខារស័ព្ទ ឈ្មោះថា **សង្ខារដែលមកដោយសង្ខារស័ព្ទ** ។ សូម្បីអវិជ្ជាជាបច្ច័យនៃសង្ខារ គឺសង្ខារដែលមានអវិជ្ជាជាបច្ច័យ មកដោយសង្ខារស័ព្ទដោយពិត សូម្បីដូច្នោះ អវិជ្ជាជាបច្ច័យ នៃសង្ខារទាំងឡាយនោះ ក៏ជាប្រធាននៃទេសនានេះ ព្រោះដូច្នោះ ទើបលោកពោលទុកមួយផ្នែក ព្រោះដូច្នោះ ក្នុងពាក្យថា **សង្ខារមាន ២ យ៉ាង** នេះ គប្បីវៀរអភិសង្ខរណកសង្ខារ ក្នុងបណ្ដា សង្ខារដែលមកដោយសង្ខារស័ព្ទចេញហើយ ប្រកបសង្ខារដែលមកដោយសង្ខារស័ព្ទ

ដទៃអំពីអភិសង្ខរណកសង្ខារនោះ ។ មួយ៉ាងទៀត លោកពោលរួមទុកថា **សង្ខារដែលមកដោយសង្ខារសព្ទ** ។ ចំណែកមួយដែលលោកកាន់របស់សង្ខារ ដែលមកដោយសង្ខារសព្ទនោះ លោកកាន់យកដោយសង្ខារដែលគប្បីពណ៌នាក្នុងទីនេះ ឈ្មោះថា **អវិជ្ជាជាបច្ច័យនៃសង្ខារ** ព្រោះដូច្នោះ គប្បីជ្រាបថា លោកពោលថា សង្ខារមាន ២ ទាក់ទងដោយសង្ខារដែល រួមគ្នាទាំងអស់ដែលគប្បីពណ៌នា ។ ដោយពាក្យថា **វចីសង្ខាររលត់មុន** ជាដើម ព្រះនាងធម្មទិន្នាភិក្ខុនីពោលដល់វិតក្ក វិចារៈ អស្សាសៈ បស្សាសៈ និងសញ្ញា វេទនា ថាជាវចីសង្ខារជាដើម មិនមែនពោលដល់កាយសញ្ចេតនាជាដើម ដែលបានពោលទុកក្នុងអវិជ្ជាជាបច្ច័យនៃសង្ខារ ។

ដែលឈ្មោះថា **សង្ខតសង្ខារ** ព្រោះត្រូវបច្ច័យប្រជុំតាក់តែងតាមសមគួរដល់សភាវៈរបស់ខ្លួន ។ **ក្នុងអដ្ឋកថា** លោកក៏ពោលរូបធម៌ អរូបធម៌ ដែលកើតអំពីកម្មជាអភិសង្ខតសង្ខារ ដោយអធិប្បាយថា សូម្បីកាលធម៌ទាំងពួងដែលកើតឡើងអំពីបច្ច័យជាសង្ខតធម៌មាន សង្ខតធម៌ដែលមានភាពពិសេសក្រៃលែង ក៏មាននៅក្នុងវិបាក និងកដត្តារូប ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ព្រោះត្រូវកម្ម ហាក់ដូចជាបែរមុខទៅក្នុងធម៌នោះថា **នេះជាផលរបស់យើង** ឲ្យកើតឡើង ។ តែព្រោះអាគតដ្ឋាន មិនមានក្នុង **ព្រះបាលី** ទើបលោកអាចារ្យពោលថា **សូម្បីអភិសង្ខតសង្ខារទាំងនោះ ក៏ដល់នូវការសង្គ្រោះនៅក្នុងព្រះបាលីនេះថា អនិច្ចា វត សង្ខារា** សង្ខារទាំងឡាយមិនទៀងហ្ន៎ ! ធម៌ទាំងឡាយ មានឧតុជាដើមជាសមុដ្ឋាន លោកក៏ពោលថា **អនិច្ចា វត សង្ខារា** សង្ខារទាំងឡាយមិនទៀងហ្ន៎ ! កុសលចេតនា និងអកុសលចេតនាដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ឈ្មោះថា **លោកហៅថា អភិសង្ខរណកសង្ខារ** ព្រោះតាក់តែងផលរបស់ខ្លួនឡើងមក ។ សេចក្តីព្យាយាមដែលញ៉ាំងកាយបយោគឲ្យតាំងឡើង ឈ្មោះថា **សេចក្តីព្យាយាមផ្លូវកាយ** ។ ពាក្យថា **នៃអភិសង្ខារ** បានដល់ កម្លាំងនៃបយោគ ។

ធម៌ ឈ្មោះថា **វចីសង្ខារ** ដោយអត្ថថា តាក់តែងវាចា ។ ធម៌ ឈ្មោះថា **កាយសង្ខារ** ដោយអត្ថថា ត្រូវកាយតាក់តែង ។ ធម៌ ឈ្មោះថា **ចិត្តសង្ខារ** ដោយអត្ថថា ត្រូវចិត្តតាក់តែង ឬដោយអត្ថថា តាក់តែងចិត្ត ។ តែដោយបង្រួញធម៌ទាំងឡាយគប្បីជ្រាបថា ឈ្មោះថា **សង្ខារ** ដោយអត្ថថា តាក់តែង និងដោយអត្ថថា ត្រូវតាក់តែងតាមសមគួរ ។ ពាក្យថា **ពាក្យដែលពោលហើយ** លោកអាចារ្យពោលដល់អត្ថនៃសង្ខារ និងអត្ថនៃបច្ច័យជាដើម ។

បទថា **នមតិ** ប្រែថា រមែងបង្អោនទៅចំពោះមុខទល់នឹងអារម្មណ៍ ព្រោះជាធម៌ដែលទទួលអារម្មណ៍បានដោយចំណែកមួយ ។ បទថា **បរិតស្សតិ** ប្រែថា រមែងស្រេក ឬប្រែថា រមែងញាប់ញ័រ ព្រោះជាធម្មជាតិក្តៅដោយតណ្ហា ។ បទថា **ឧបាទិយតិ** ប្រែថា រមែងប្រកាន់មាំ ។ បទថា **ភវតិ** ប្រែថា កើតឡើង លោកអាចារ្យពោលសំដៅដល់ឧបបត្តិភព ។ បទថា **ភាវយតិ** ប្រែថា ធ្វើឲ្យកើតឡើង លោកអាចារ្យពោលដំដៅដល់កម្មភព ។ ការឃ្លាតទៅនៃខន្ធទាំងឡាយ ឈ្មោះថា **មរណៈ** ព្រោះដូច្នោះ ទើបលោកអាចារ្យពោលថា **ជាហេតុនៃការស្លាប់** ។ លោកពោលថា **ដីក ២ កន្លែង** ព្រោះធ្វើអធិប្បាយថា ទុក្ខវេទនាជាទុក្ខពេលកើតឡើង និងជាទុក្ខពេលតាំងនៅ ។ បទថា **អាយាសោ** ប្រែថា គ្រាំចិត្ត គឺតានតឹងក្នុងចិត្ត។

ពាក្យថា **ជាពាក្យចង្អុលន័យដែលបានសម្តែងមកហើយ** គឺជាពាក្យចង្អុលដល់វិធីតាមដែលបានសម្តែងមកហើយ ។ **កេវល**-ស័ព្ទ ជាស័ព្ទប្រាប់អត្ថថា មិនលាយឡំ ដូចជាក្នុងពាក្យជាដើមថា **កេវលា សាលយោ** ប្រែថា ស្រូវសាលីទាំងឡាយសុទ្ធៗ និងជាស័ព្ទប្រាប់អត្ថថា មិនមានចំណែកសេសសល់ ដូចក្នុងពាក្យជាដើម **កេវលា អង្គមគធា** ប្រែថា អ្នកដែនអង្គៈ និងដែនមគធៈទាំងអស់ ព្រោះដូច្នោះ ទើបលោកអាចារ្យពោលអត្ថទាំង ២ ប្រការទុក ។ ក្នុងអត្ថទាំង ២ ប្រការនោះ បទថា **អសម្មិស្សស្ស**

ប្រែថា វៀរចាកសុខ ។ ពិតហើយ ធម្មជាតិដែលវៀរចាកការកើតឡើង និងការវិនាសទៅណាមួយ ក្នុងគំនរទុក្ខនេះ នឹងមានក៏ទេ ។ បទថា **សកលស្ស** សេចក្តីថា ទៅកាន់ភពទាំងឡាយជាដើម និងប្រព្រឹត្តទៅក្នុងកាលទាំងពួង ។

លោកអាចារ្យកាលសម្តែងថា **អាទិ-ស័ព្ទ** ក្នុងបទថា **លក្ខណេកវិធាទិតោ** នេះ បណ្ឌិតគប្បីធ្វើឲ្យចប់ចុះទៅជាមួយបទ ទើបពោលពាក្យថា **លក្ខណាទិតោ** ប្រែថា ពោលដោយលក្ខណៈជាដើម ។ ឈ្មោះថា **សម្មោហនរសា** មានការធ្វើឲ្យវង្វេងជារស ព្រោះអត្ថថា ញ៉ាំងសម្បយុត្តធម៌ទាំងឡាយ ឬញ៉ាំងបុគ្គលដែលមានការដល់ព្រមដោយអវិជ្ជានោះឲ្យវង្វេង ។ ឈ្មោះថា **ឆាទនបច្ចុប្បដ្ឋានា** មានការបិទបាំងជាបច្ចុប្បដ្ឋាន ព្រោះអត្ថថា ជាធម្មជាតិបិទបាំងសភាវៈនៃអារម្មណ៍ដែលបុគ្គល រមែងកាន់យកបាន ។ ឈ្មោះថា **អាសវបទដ្ឋានា** មានអាសវៈជាបទដ្ឋាន ព្រោះព្រះបាលីថា **អាសវសមុទយា អវិជ្ជាសមុទយោ** ប្រែថា អវិជ្ជាកើតព្រោះអាសវៈ ។ សង្ខារ ឈ្មោះថា **អាយូហនរសា** មានការព្យាយាមជារស ព្រោះអត្ថថា ព្យាយាម គឺធ្វើការខ្នះខ្នែងដើម្បីញ៉ាំងបដិសន្ធិឲ្យកើត ។ ម្យ៉ាងទៀត ការធ្វើឲ្យទៅជាគំនរឈ្មោះថា **អាយូហនំ** ប្រែថា ការប្រមូលមក ។ ឈ្មោះថា **ចេតនាបច្ចុប្បដ្ឋានា** មានចេតនាជាបច្ចុប្បដ្ឋាន ព្រោះអត្ថថា ជាចេតនាដែលបុគ្គលរមែងកាន់យកបាន ព្រោះមានចេតនាជាសភាវៈ ។ វិញ្ញាណ ឈ្មោះថា **បុព្វង្គមរសំ** មានភាពជាប្រធានជារស ព្រោះអត្ថថា ប្រព្រឹត្តទៅជាធម្មជាតិត្រាច់ទៅមុននៃនាមរូប ។ ឈ្មោះថា **បដិសន្ធិបច្ចុប្បដ្ឋានំ** មានបដិសន្ធិជាបច្ចុប្បដ្ឋាន ព្រោះអត្ថថា ជាធម្មជាតិបន្តជាមួយនឹងភពមុនដែលបុគ្គលរមែងកាន់យកបាន ។ នាម ឈ្មោះថា **សម្បយោគរសំ** មានសម្បយោគជារស ព្រោះអត្ថថា ប្រកបព្រមជាមួយនឹងវិញ្ញាណនិងប្រកបព្រមនូវគ្នានឹងគ្នា ។ ការប្រកបដោយប្រការទាំងឡាយជានិច្ច ឈ្មោះថា **សម្បយោគ** ។ ការមិនមានជាចំណែកមួយ ឈ្មោះថា **អវិនិព្ភោគោ** ប្រែថា

ការមិនបែកគ្នា ។ រូប ឈ្មោះថា **វិកិរណរសំ** ព្រោះអត្ថថា រូបរមែងខ្ចាត់ខ្ចាយខ្លួនឯង ព្រោះមិនមានសម្បយោគ ។ ពិតហើយ ព្រោះហេតុនោះឯង អង្គរជាដើមដែលត្រូវបុក រមែងខ្ចាត់ខ្ចាយ គឺជារបស់លាយឡំខ្ចាត់ខ្ចាយទៅ សូម្បីនាមក៏ជាកុសលជាដើមបាន ក្នុងកាលខ្លះ គ្រាខ្លះក៏នៅមាន ព្រោះដូច្នោះ ទើបរូបលោកពោលថា **អព្យាកត-បច្ចុប្បដ្ឋានំ** ប្រែថា មានភាពជាអព្យាកតៈជាបច្ចុប្បដ្ឋាន ដើម្បីឲ្យផ្សេងគ្នាអំពីនាម នោះ ។ ម្យ៉ាងទៀត ជាធម៌ដែលទទួលអារម្មណ៍មិនបាន គប្បីឃើញថា ជាអព្យាកតៈ ដូចជាក្នុងពាក្យថា **អចេតនោ អព្យាកតោ** កោដ្ឋាសចំពោះចំណែកមួយ ឈ្មោះថា **កេសា** ជាធម៌មិនមានចិត្ត ជាអព្យាកតៈ ។ បទថា **អាយតនលក្ខណំ** មានសេចក្តី ប៉ុនគ្នា នឹង **ឃដ្តនលក្ខណំ** ប្រែថា មានការបន្តជាលក្ខណៈ ឬមានសេចក្តីប៉ុនគ្នានឹង **អាយានំ តននលក្ខណំ** ប្រែថា មានការផ្សព្វផ្សាយទៅនៃអាយៈទាំងឡាយ ( គឺចិត្ត និងចេតសិកធម៌ ) ជាលក្ខណៈ ។ សឡាយតនៈ ឈ្មោះថា **ទស្សនរសំ** ប្រែថា មានការឃើញជារស ព្រោះធ្វើការឃើញដែលទទួលអារម្មណ៍តាមគួរដល់អារម្មណ៍ នៃខ្លួន ។ តែក្នុង **សម្មោហវិនោទនី** លោកពោលថា **ទស្សនាទិរសំ** ប្រែថា មានការ ឃើញជាដើមជារស ។ អធិប្បាយថា សឡាយតនៈ ឈ្មោះថា **មានភាពជាវត្ថុ និង ភាពជាទ្វារជាបច្ចុប្បដ្ឋាន** នៃវិញ្ញាណធាតុ និងមនោវិញ្ញាណធាតុតាមសមគួរ ។ ក្នុង សឡាយតនៈនេះ ស័ព្ទថា **វត្ថុ** សំដៅដល់វត្ថុទាំង ៥ មានចក្ខុជាដើម ។ លោកពោលថា **វេទនាមានសុខ និងទុក្ខជាបច្ចុប្បដ្ឋាន** ដូច្នេះ ព្រោះឧបេក្ខាដែលជាអកុសលវិបាក លោកសង្គ្រោះទុកដោយទុក្ខ ព្រោះជាអនិដ្ឋារម្មណ៍ ព្រោះឧបេក្ខាដែលជាកុសលវិបាក ក្រៅអំពីនេះ លោកសង្គ្រោះទុកដោយសុខ ព្រោះជាឥដ្ឋារម្មណ៍ ។ **តណ្ហា** ឈ្មោះថា **ហេតុលក្ខណា** មានភាពជាហេតុជាលក្ខណៈ ព្រោះជាហេតុកើតនៃទុក្ខ ។ តណ្ហា ឈ្មោះ ថា **អភិនន្ទនរសា** មានការត្រេកអរក្រៃលែងជារស ព្រោះព្រះបាលីថា **តត្រតត្រាភិនន្ទិនី**

ប្រែថា តណ្ហាមានការត្រេកអរក្រៃលែងក្នុងអារម្មណ៍នោះៗ ។ ឈ្មោះថា **អតិត្តិការ-បច្ចុប្បដ្ឋានា** មានការមិនឆ្អែតជាបច្ចុប្បដ្ឋាន ព្រោះអត្ថថា ជាការមិនឆ្អែតក្នុងអារម្មណ៍មានរូបជាដើមរបស់ចិត្ត ឬរបស់បុគ្គល ដែលបុគ្គលរមែងកាន់យកបាន ។ ឧបាទាន ឈ្មោះថា **អមុញ្ចនរសំ** មានការមិនលែងជារស ដោយអំណាចការប្រកាន់មាំដោយតណ្ហា និងទិដ្ឋិ ។ ឈ្មោះថា **តណ្ហាទឡ្ហត្តទិដ្ឋិបច្ចុប្បដ្ឋានំ** មានការស្អិតណែនដោយតណ្ហា និងទិដ្ឋិជាបច្ចុប្បដ្ឋាន ព្រោះអត្ថថា ជាការស្អិតណែនដោយតណ្ហា ដែលចាត់ជាកាមុបាទាន ឧបាទានដ៏សេស ជាទិដ្ឋិរមែងប្រាកដ ។ បណ្ឌិតគប្បីប្រកបបកិណ្ណកៈមានលក្ខណៈជាដើមនៃកព ទាក់ទងជាមួយកម្មភព និងឧបបត្តិភព ។

ដោយ **អាទិ**-ស័ព្ទ ក្នុងបទថា **មោហាទិការតោ** ប្រែថា ដោយភាពជាមោហៈជាដើមនេះ លោកសង្គ្រោះការមិនតាមត្រាស់ដឹងជាដើម ។ ឈ្មោះថា **ការមិនបដិបត្តិ** ដោយអំណាចការមិនដឹងក្នុងអរិយសច្ច មានទុក្ខជាដើម ឈ្មោះថា **ការបដិបត្តិខុស** ដោយអំណាចវិបល្លាសថា ស្អាតក្នុងរបស់ដែលមិនស្អាតជាដើម ។ម្យ៉ាងទៀត ឈ្មោះថា **ការមិនបដិបត្តិ** ដោយអំណាចទិដ្ឋិវិប្បយុត្ត ឈ្មោះថា **ការបដិបត្តិខុស** ដោយអំណាទិដ្ឋិសម្បយុត្ត ។ ពាក្យថា **ដោយទ្វារ និងអារម្មណ៍** សេចក្តីថា ព្រោះប្រព្រឹត្តទៅក្នុងទ្វារទាំង ៦ និងក្នុងអារម្មណ៍ទាំង ៦ ឈ្មោះថា ដោយទ្វារ និងដោយអារម្មណ៍ ។ ឯវិភាគនេះមិនមែនបានដល់អវិជ្ជាប៉ុណ្ណោះទេ រមែងបានដល់អរូបធម៌ ក្នុងអង្គបដិច្ច-សមុប្បាទដទៃផងដែរ ព្រោះដូច្នោះ ទើបលោកអាចារ្យពោលថា **សូម្បីទាំងអស់** ។

ដោយ **អាទិ**-ស័ព្ទ ក្នុងបទថា **វិបាកធម្មធម្មាទិការតោ** ប្រែថា ជាធម៌មានវិបាកធម្មតាជាដើមនេះ លោកអាចារ្យរមែងសង្គ្រោះដោយសង្ខារ ជា **នេវសេក្ខធម៌** ជា **អសេក្ខធម៌** និងជា **សំយោជនីយធម៌** ជាដើម ។ ពាក្យថា **ព្រោះឲ្យប្រព្រឹត្តទៅក្នុងកំណើត ៤** គឺព្រោះកើតឡើងក្នុងអត្តភាពដែលទាក់ទងក្នុងកំណើត ៤ ។ ដោយ

**អាទិ**-សព្ទ ក្នុងបទថា **លោកិយវិបាកាទិភាវតោ** ប្រែថា ដោយភាវៈ ជាលោកិយវិបាកជាដើមនេះ លោកអាចារ្យរមែងសង្គ្រោះវិញ្ញាណជាអព្យាកតៈ ជា **សប្បច្ចយ** និងជា **សង្ខត** ជាដើម ដោយ **អាទិ**-សព្ទ ក្នុងពាក្យថា **សហេតុកាហេតុកាទិតោ** ដោយជាសហេតុកៈ និងអហេតុកៈជាដើម លោកអាចារ្យរមែងសង្គ្រោះប្រភេទនៃវិញ្ញាណ មានវិញ្ញាណដែលជាសសង្ខារ និងអសង្ខារជាដើម ។

នាមរូបលោកពោលទុកទាក់ទងនឹងបច្ចុប្បន្នអទ្ធាក៏ពិត សូម្បីយ៉ាងនោះ នាមរូបប៉ុណ្ណោះជាបច្ចុប្បន្ន យ៉ាងណា សូម្បីជាអតីត និងអនាគតក៏ដូចគ្នាយ៉ាងនោះ ព្រោះដូច្នោះ ទើបលោកពោលថា **មាន ៣ យ៉ាង ដោយអតីតជាដើម** ព្រោះនាមរូប ដែលទាក់ទងក្នុងអទ្ធាទាំង ២ ក៏ជាធម្មជាតិដែលគប្បីកាន់យកបានដោយន័យ ។

ពាក្យថា **ដោយទីកើត និងជាទីប្រជុំ** ព្រោះជាប្រទេសដែលកើត និងប្រព្រឹត្តទៅនៃវិញ្ញាណ និងធម៌ដែលសម្បយុត្តដោយវិញ្ញាណនោះ ។ បាឋៈថា **ភូតប្បសាទវិញ្ញាណតោ** ដូច្នេះក៏ត្រឹមត្រូវ ។ ចំណែកអាចារ្យទាំងឡាយ រមែងស្វាធ្យាយថា **វិញ្ញាណាទិតោ** ។ កាលមានការរួមយកអាយតនៈខាងក្រៅតាមន័យនៃឯកសេសសមាស ក៏គប្បីឃើញថា អាយតនៈខាងក្រៅនោះ លោកសង្គ្រោះទុកដោយអាទិសព្ទ ។ លោកអាចារ្យពោលដល់មនាយតនៈថា **នោ ភយគោចរ** មិនមែនទទួលអារម្មណ៍ទាំង ២ យ៉ាងនោះ ព្រោះពួកអរូបធម៌ជាធម្មជាតិដែលនៅជិត ឬជាធម្មជាតិដែលនៅឆ្ងាយ មិនទាក់ទងដោយផែនដី ព្រោះវាមិនមានរូបរាង ព្រោះដូច្នោះ ទើបអារម្មណ៍នៃមនាយតនៈនិយាយមិនបានថា មកដល់ ឬមិនទាន់មកដល់អាយតនៈ ។ ក្នុងបទថា **ផស្សាទីនម្បិ** នេះ ផស្សៈខាងដើម ឈ្មោះថា **មានតែម្យ៉ាង** ដោយភាវៈ គឺការពាល់ត្រូវ និងដោយជាលោកិយ និងជាសាសវៈជាដើម ។ ឈ្មោះថា **មាន ២ យ៉ាង** គឺ បដិឃសម្ផស្ស សម្ផស្ស គឺការប៉ះខ្ទប់ និង **អធិវចនសម្ផស្ស** សម្ផស្សដែលជាឈ្មោះ

និងជាសហេតុកៈជាដើម ។ ឈ្មោះថា **មាន ៣ យ៉ាង** ដោយជាផស្សៈដែលទាក់ទង នៅក្នុងភព ៣ ដោយការប្រកបជាមួយនឹងវេទនា ៣ និងដោយជាអហេតុកៈ ទុហេតុកៈ តិហេតុកៈ ។ ឈ្មោះថា **មាន ៤ និងមាន ៥** ដោយអំណាចកំណើត និងគតិ ។

**វេទនា** ឈ្មោះថា **មានតែមួយ៉ាង** ដោយលក្ខណៈ គឺការសោយ និងដោយជា លោកិយ ជាសាសវៈជាដើម ។ ឈ្មោះថា **មាន ២ យ៉ាង** គឺដោយវេទនាដែលប្រព្រឹត្តទៅ ក្នុងបញ្ចទ្វារ និងវេទនាដែលប្រព្រឹត្តទៅក្នុងមនោទ្វារ ។ **មាន ៣ យ៉ាង** គឺដោយសុខ វេទនាជាដើម ។ **មាន ៤ និងមាន ៥ យ៉ាង** ដោយអំណាចកំណើត និងគតិ ។ **មាន ៦ យ៉ាង** គឺដោយអារម្មណ៍ ៦ ។

**តណ្ហា** ឈ្មោះថា **មានមួយ៉ាង** ដោយជាហេតុកើតរបស់លោក ។ **មាន ២ យ៉ាង** ដោយទិដ្ឋិសម្បយុត្ត និងទិដ្ឋិវិប្បយុត្ត ។ **មាន ៣ យ៉ាង** ដោយចែកជាកាមតណ្ហា ភវតណ្ហា និងវិភវតណ្ហា ។ **មាន ៤ យ៉ាង** ជាធម៌ដែលមគ្គទាំង ៤ គប្បីលះ ។ **មាន ៥ យ៉ាង** ជាភាពត្រេកអរក្រៃលែងក្នុងរូបជាដើម ។ **មាន ៦ យ៉ាង** ដោយពួកតណ្ហា ទាំង ៦ ។

**ឧបាទាន** ឈ្មោះថា **មានតែមួយ៉ាង** ដោយជាការប្រកាន់មាំ ។ **មាន ២ យ៉ាង** ដោយចែកជាតណ្ហា និងទិដ្ឋិ ។ **មាន ៣ យ៉ាង** ជាធម៌ដែលមានភពទាំង ៣ ជា ឧបនិស្ស័យ ។ **មាន ៤ យ៉ាង** ដោយចែកជាកាមុបាទានជាដើម ។ **មាន ៥ យ៉ាង** ដោយប្រព្រឹត្តទៅព្រមក្នុងគតិទាំង ៥ ។

**ភព** ឈ្មោះថា **មានតែមួយ៉ាង** ដោយជាលោកិយ និងជាសាសវៈជាដើម ។ **មាន ២ យ៉ាង** ដោយចែកជាកម្មភព និងឧបបត្តិភព ។ **មាន ៣ យ៉ាង** ដោយចែកជាកាមភព ជាដើម ។ **មាន ៤ យ៉ាង** ដោយមានឧបាទាន ៤ ជាបច្ច័យ ។ **មាន ៥ យ៉ាង** ដោយ ប្រព្រឹត្តទៅព្រមក្នុងគតិទាំង ៥ ។ **មាន ៦ យ៉ាង** ដោយជាកាមកម្មភពជាដើម ។ **មាន**

៧ យ៉ាង ដោយរួមនៅក្នុងវិញ្ញាណដ្ឋិតិ ៧ ។ **មាន ៨ យ៉ាង** ដោយចែកជាកម្មភព ដែលមានឧបាទាន ៤ ជាបច្ច័យជាដើម ។ **មាន ៩ យ៉ាង** ដោយជាកាមភពជាដើម ។

**ជាតិ** ឈ្មោះថា **មានតែម្យ៉ាង** ដោយកើតឡើងចំពោះក្នុងគ្រាដំបូងក្នុងភព នោះៗ ។ **មាន ២ យ៉ាង** ព្រោះជារូបក្ខន្ធ និងសង្ខារក្ខន្ធ ។ **មាន ៣ យ៉ាង** ព្រោះជាធម្មជាតិទាក់ទងនៅក្នុងភពទាំង ៣ ។ **មាន ៤ និង ៥ យ៉ាង** ចែកដោយកំណើត និងគតិ ។ គប្បីជ្រាបអង្គទាំងឡាយ មានជរា និងមរណៈជាដើម ជាធម្មជាតិមានតែម្យ៉ាងជាដើមដោយន័យនេះ ។

ព្រោះហេតុដែលលោកកាន់យកធម៌ មានសោកជាដើមទុកផង ទើបគប្បីជ្រាបការកំណត់អង្គថា **មាន ១២ ប៉ុណ្ណោះ** ក្នុងការទាក់ទងនឹងបដិច្ចសមុប្បាទ មានអង្គច្រើន ។ ព្រោះថា ធម៌ មានសោកជាដើម ព្រះមានព្រះភាគមិនត្រាស់ទុក ដោយជាអង្គនោះឡើយ តែធម៌ មានសោកជាដើមនោះ ទ្រង់ត្រាស់ទុកដើម្បីសម្តែងហេតុដោយផល គឺអវិជ្ជាជាអង្គដើម ។ ព្រោះធម៌ មានសោកជាដើមនោះ រមែងមានដល់បុគ្គលល្ងង់ខ្លៅ ដែលត្រូវជរា និងមរណៈគ្របសង្កត់ ព្រោះដូច្នោះ ទើបព្រះអង្គត្រាស់ធម៌ មានសោកជាដើម មានជរា និងមរណៈជាហេតុ ម្យ៉ាងទៀត ព្រះសាស្តាទ្រង់បានសង្គ្រោះទុកក្នុងព្រះសូត្រថា ជាបុគ្គលត្រូវទុក្ខវេទនាផ្លូវកាយពាល់ត្រូវហើយ និងទុក្ខដែលមានជរា និងមរណៈជានិមិត្តក៏ទេ ព្រោះហេតុនោះ ទើបទុក្ខនោះ ព្រះមុនីត្រាស់ជាធម៌ដែលមានសោកជាដើម ដែលមានជរា និងមរណៈជានិមិត្តនោះជាគ្រឿងសាធកៈ ព្រោះមានដល់បុគ្គលពាលដែលត្រូវជរា និងមរណៈគ្របសង្កត់ ។ ម្យ៉ាងទៀត ព្រះមានព្រះភាគទ្រង់ធ្វើសេចក្តីសង្ខេប មានសោកជាដើម ដូចគ្នានឹងជរា និងមរណៈនោះឯង ដូច្នោះធម៌ មានសោកជាដើមនោះ មានជាតិជាបច្ច័យក៏រមែងត្រឹមត្រូវ ម្យ៉ាងទៀត សេចក្តីសង្ខេបដែលដូចគ្នាជាមួយនឹងអវិជ្ជាដែលជាបច្ច័យនៃជរា និងមរណៈ

ក៏ជារឿងដែលគប្បីធ្វើបាន ។ ម្យ៉ាងទៀត ជរា មរណៈ និងធម៌ មានសោកជាដើម រមែងមាន ព្រោះមានជាតិជាបច្ច័យ ព្រោះដូច្នោះ ជរា មរណៈដែលប្រព្រឹត្តទៅ ដោយចំណែកមួយ ទើបព្រះមានព្រះភាគ ទ្រង់កាន់យកជាអង្គ ក្នុងអង្គនៃបដិច្ចសមុប្បាទនោះ ។ ម្យ៉ាងទៀត ធម៌ មានសោកជាដើម មិនបានប្រព្រឹត្តទៅដោយចំណែកមួយនោះឡើយ ព្រោះមិនមានក្នុងរូបកពជាដើម ទើបព្រះមានព្រះភាគទ្រង់កាន់យកដើម្បីសម្ដែងលម្អិតអវិជ្ជា ដោយផលដែលប្រាកដតែម្យ៉ាង ។ ដោយហេតុនោះ កាលមានជាតិក្នុងអនាគត ទើបព្រះមានព្រះភាគទ្រង់សម្ដែងអវិជ្ជាដែលជាហេតុនៃបដិសន្ធិបន្តអំពីជាតិនោះ ព្រោះដូច្នោះ ទើបទ្រង់សម្ដែងការមិនកាត់ផ្ដាច់នៃភវចក្រ ។ ម្យ៉ាងទៀត ព្រះសូត្រគប្បីឃើញថា ជាគ្រឿងសាធកៈដល់អត្ថនេះឯង ថា អវិជ្ជាជាហេតុនៃធម៌ មានសោកជាដើម មិនមែនជាគ្រឿងសាធកអត្ថ មិនត្រឹមតែជាធម៌ មានសោក ជាដើម មានជរា និងមរណៈ ជានិមិត្តដល់បុគ្គលល្ងង់ប៉ុណ្ណោះឡើយ ។ ពិតហើយ ដោយព្រះពុទ្ធត្រាស់ថា **បុថុជ្ជនដែលមិនបានស្ដាប់** ទ្រង់សម្ដែងដល់អវិជ្ជាថា ជាហេតុនៃធម៌ មានសោកជាដើម តែទ្រង់មិនសម្ដែងថា ទុក្ខ មានជរា មរណៈជានិមិត្តនោះឯងជាតួទុក្ខនោះឡើយ ។

ន័យម្យ៉ាងទៀត ជរា មរណៈ ក៏ជាបច្ច័យផងដែរ កាលកាន់យកអត្ថដោយប្រការដទៃ អង្គ ១២ ក៏មិនគ្រប់ បច្ច័យនោះរបស់ធម៌ណាហ្ន៎ ? របស់ធម៌ មានសោកជាដើម សួរថា បើយ៉ាងនោះ ព្រោះហេតុអ្វី ទើបទ្រង់មិនត្រាស់ថា **ធម៌ គឺសោកជាដើមមាន ព្រោះជរាមរណៈជាបច្ច័យ** ទ្រង់គ្រាន់តែត្រាស់ថា **ជរា មរណៈ និងធម៌ មានសោកជាដើមមាន ព្រោះជាតិជាបច្ច័យ** ? ព្រោះធម៌ មានសោកជាដើមនោះ រមែងមានដល់បុគ្គលដែលត្រូវធម៌ គឺសេចក្ដីទុក្ខដទៃអំពីជរា មរណៈនោះពាល់ត្រូវហើយ ព្រោះដូច្នោះ ធម៌ មានសោកជាដើមនោះ មានជរា មរណៈជាបច្ច័យ ទើប

មិនប្រព្រឹត្តទៅដោយចំណែកមួយ សូម្បីដល់បុគ្គលដែលមានសំយោជនៈនៅមិនទាន់លះបាន ព្រោះដូច្នោះ ទើបត្រាស់ធម៌ មានជាតិជាបច្ច័យប៉ុណ្ណោះ ។ ម្យ៉ាងទៀត ឧបបត្តិភព លោករួមទុកដោយសព្ទថា **ជរា មរណៈ** ។ ព្រោះថា ការចាស់របស់ខន្ធដែលមានវិញ្ញាណគ្រប់គ្រង ការវិនាសរបស់អាយុ និងការចាស់របស់ឥន្ទ្រិយទាំងឡាយ ឈ្មោះថា ជរា និងការបែកធ្លាយនៃធម៌ទាំងនោះ ឈ្មោះថា មរណៈ ដូច្នេះ ។ កាលមានឧបបត្តិភព កម្មដែលសត្វធ្វើទុក សន្សំទុក ក្នុងឧបបត្តិភពនោះ ឬកម្មចាស់ ចាត់ជា **កម្មភព** ក្នុងការប្រាកដនៃកម្មជាដើម រមែងឲ្យកើតបដិសន្ធិក្នុងលំដាប់នៃចុតិ ព្រោះដូច្នោះ ទើបចាត់ជា **ឧបបត្តិភព** ជាបច្ច័យដល់ជាតិ ព្រោះដូច្នោះ សូម្បីជរាមរណៈក៏ឈ្មោះថា ជាបដិច្ចសមុប្បាទ ព្រោះជាបច្ច័យដល់ជាតិ ។ ម្យ៉ាងទៀត ព្រោះទ្រង់រួមឧបបត្តិភពជាបច្ច័យដល់ជាតិទុក្ខ ក្នុងពាក្យនេះថា **ភវប្បច្ចយា ជាតិ** ជាតិមានព្រោះភពជាបច្ច័យ ដូច្នោះ មិនបានត្រាស់ថា **ជរាមរណប្បច្ចយា ជាតិ** ជាតិមានព្រោះជរាមរណៈជាបច្ច័យ ព្រោះទ្រង់រួមទុកដោយពាក្យបរិយាយដែលពោលទុកហើយនោះឯង ។ សូម្បីជរាមរណៈ ជាបដិច្ចសមុប្បាទ ក៏ព្រោះសម្រេចជាបច្ច័យយ៉ាងនេះ ព្រោះដូច្នោះ គប្បីជ្រាបថា លោកបានកំណត់បដិច្ចសមុប្បាទមានអង្គ ១២ ដោយហេតុនោះ ទើបលោកអាចារ្យពោលថា **បដិច្ចសមុប្បាទមានអង្គ ១២ ប៉ុណ្ណោះជាដើម** ។ បទថា **អយន្តាវ** លោកអាចារ្យពោលសំដៅដល់ការពណ៌នាសេចក្តីដែលលោកបានពោលទុកដោយពាក្យថា **ដោយប្រភេទនៃទេសនាជាដើម** ។

កថាពណ៌នាដោយបដិច្ចសមុប្បាទ ចប់ហើយ

ដោយប្រការដូច្នេះ ។

# វិសុទ្ធិមគ្គ

## អធិប្បាយ បទថា អវិជ្ជា

ដោយបរិយាយតាមព្រះសូត្រ ការមិនដឹងក្នុងឋានៈ ៤ មានទុក្ខជាដើម ឈ្មោះថា អវិជ្ជា ដោយបរិយាយតាមព្រះអភិធម្ម ការមិនដឹងក្នុងឋានៈ ៨ ព្រមទាំងឋានៈ មានបុព្វន្ត ( ចំណុចខាងដើម ) ជាដើម ឈ្មោះថា អវិជ្ជា សមនឹងព្រះបាលីថា ក្នុងធម៌ទាំងនោះ អវិជ្ជាតើដូចម្តេច ? ការមិនដឹងក្នុងទុក្ខ ។បេ។ មិនដឹងក្នុងទុក្ខនិរោធគាមិនីបដិបទា ការមិនដឹងក្នុងបុព្វន្ត ការមិនដឹងក្នុងអបរន្ត គឺចំណុចខាងចុង ការមិនដឹងក្នុងបុព្វន្តាបរន្ត ការមិនដឹងក្នុងធម៌ទាំងឡាយ ដែលជាឥទប្បច្ចយាតា គឺក្រុមហេតុ និងបដិច្ចសមុប្បន្ន គឺក្រុមផល នេះហៅថា អវិជ្ជា ដូច្នេះ ។

ក្នុងឋានៈទាំងនោះ វៀរសច្ចៈ ២ គឺនិរោធ និងមគ្គ ដែលជាលោកុត្តរចេញ អវិជ្ជា រមែងកើតឡើងក្នុងឋានៈដ៏សេស សូម្បីដោយធ្វើឲ្យជាអារម្មណ៍ក៏បាន មែនពិតតែទោះជាយ៉ាងនោះ ក្នុងបាលីនេះលោកក៏មានបំណងយកដោយពោលថា ជាគ្រឿងបិទបាំងប៉ុណ្ណោះឯង ។ ពិតហើយ អវិជ្ជានោះដែលកើតឡើងហើយ រមែងបិទបាំងទុក្ខសច្ចស្ថិតនៅ មិនឲ្យដឹងច្បាស់នូវលក្ខណៈដែលជារស ( គឺសភាវៈ ) ប្រចាំខ្លួនតាមសេចក្តីពិតបាន ដូចគ្នាដែរ រមែងបិទបាំងសមុទយសច្ច និរោធសច្ច មគ្គសច្ច ខន្ធបញ្ចកៈចំណែកអតីតដែលរាប់ថា ចំណែកដើម ខន្ធបញ្ចកៈចំណែកអនាគត ដែលរាប់ថា ចំណែកចុង ខន្ធបញ្ចកៈទាំង ២ ចំណែកនោះ ដែលរាប់ថា ទាំងចំណែកដើម និងចំណែកចុង ឥទប្បច្ចយតា និងបដិច្ចសមុប្បន្នធម៌ទាំងឡាយ ដែលរាប់ថា ឥទប្បច្ចយតា បដិច្ចសមុប្បន្នធម៌ ដោយតាំងនៅមិនឲ្យដឹងច្បាស់នូវលក្ខណៈដែលជារស គឺសភាវៈប្រចាំខ្លួនតាមសេចក្តីពិត ក្នុងទុក្ខជាដើមនោះថា នេះអវិជ្ជា នេះសង្ខារ ដូច្នេះជាដើម

ព្រោះហេតុនោះ ទើបលោកពោលថា អវិជ្ជា គឺមិនដឹងក្នុងទុក្ខ ។បេ។ មិនដឹងក្នុងឥទប្បច្ចយតា និងបដិច្ចសមុប្បន្នធម៌ទាំងឡាយ ។

# អធិប្បាយ បទថា សង្ខារ

បទថា *សង្ខារទាំងឡាយ* បានដល់ សង្ខារ ៦ ដែលពោលដោយសង្ខេបទុកក្នុងផ្នែកមុនដូច្នេះថា សង្ខារ ៣ មានបុញ្ញាភិសង្ខារជាដើម និងសង្ខារ ៣ មានកាយសង្ខារ ជាដើម ។

ចំណែកពោលដោយពិស្តារ ក្នុងសង្ខារទាំងនេះ សង្ខារទាំង ៣ បានដល់ ចេតនា ២៩ គឺបុញ្ញាភិសង្ខារ បានដល់ ចេតនា ១៣ គឺចេតនាជាកាមាវចរកុសល ៨ ដែលប្រព្រឹត្តទៅដោយអំណាចកុសល មានទាន សីលជាដើម និងចេតនាជារូបាវចរកុសល ៥ ដែលប្រព្រឹត្តទៅដោយអំណាចភាវនាតែម្យ៉ាង អបុញ្ញាភិសង្ខារ បានដល់ ចេតនាជាអកុសល ១២ ដែលប្រព្រឹត្តទៅដោយអំណាចអកុសល មានបាណាតិបាតជាដើម អានេញ្ជាភិសង្ខារ បានដល់ ចេតនាដែលជាអរូបាវចរកុសល ៤ ដែលប្រព្រឹត្តទៅដោយអំណាចភាវនាដូចគ្នា ។

ចំណែកក្នុងសង្ខារ ៣ ទៀត កាយសញ្ចេតនា គឺការតាំងចិត្តសម្តែងចេញតាមផ្លូវកាយ ជាកាយសង្ខារ វចីសញ្ចេតនា គឺការតាំងចិត្តសម្តែងចេញតាមវាចា ជាវចីសង្ខារ មនោសញ្ចេតនា គឺការតាំងចិត្តសម្តែងចេញតាមផ្លូវចិត្ត ជាចិត្តសង្ខារ ។ ត្រិកៈនេះ លោកពោលដើម្បីសម្តែងការប្រព្រឹត្តទៅនៃអភិសង្ខារ ៣ មានបុញ្ញាភិសង្ខារជាដើមតាមទ្វារ ក្នុងខណៈព្យាយាមធ្វើកម្ម ។ ពិតណាស់ ចេតនា ២០ គឺកាមាវចរកុសលចេតនា ៨ អកុសលចេតនា ១២ ដែលញ៉ាំងកាយវិញ្ញត្តិឲ្យតាំងឡើងប្រព្រឹត្តទៅតាមកាយទ្វារ បានឈ្មោះថា កាយសង្ខារ ចេតនាទាំងនោះឯងដែលញ៉ាំងវចីវិញ្ញត្តិឲ្យតាំងឡើងប្រព្រឹត្តទៅតាមវចីទ្វារ បានឈ្មោះថា វចីសង្ខារ ។

តែអភិញ្ញាចេតនា គឺចេតនាក្នុងអភិញ្ញា មិនជាបច្ច័យនៃវិញ្ញាណអង្គតទៅ ព្រោះដូច្នោះ ទើបលោកមិនកាន់យកក្នុងពាក្យថា កាយ...វចីសង្ខារនេះ និងអភិញ្ញា ចេតនាមិនជាបច្ច័យនៃវិញ្ញាណណា សូម្បីឧទ្ធច្ចចេតនាក៏មិនជាបច្ច័យដូច្នោះ ព្រោះហេតុនោះសូម្បីឧទ្ធច្ចចេតនានោះ ក៏ត្រូវកាត់ចេញក្នុងភាពជាបច្ច័យនៃវិញ្ញាណ តែចេតនាទាំងពួងនោះ ក៏គង់ជាធម៌មានអវិជ្ជាជាបច្ច័យដូចគ្នា ។

ចំណែកចេតនាទាំង ២៩ ដែលកើតឡើងក្នុងមនោទ្វារ ដោយមិនញុំាងវិញ្ញត្តិទាំង ២ ឲ្យតាំងឡើង ជាចិត្តសង្ខារ ។

ដោយប្រការដូច្នេះ តិកៈនេះក៏ចូលទៅកាន់តិកៈមុន ( គឺរួមបញ្ចូលជាមួយតិកៈមុន ) នោះឯង ព្រោះដូច្នោះ ពោលដោយសេចក្តីហើយ កាលដែលអវិជ្ជាជាបច្ច័យនៃសង្ខារ ក៏គប្បីជ្រាបដោយជាបច្ច័យនៃអភិសង្ខារ ៣ មានបុញ្ញាភិសង្ខារជាដើមនោះឯង ។

ក្នុងពាក្យនោះ បើមានបញ្ហាសួរថា ពាក្យនេះគប្បីជ្រាបបានដូចម្តេច ? ឬសួរថា សង្ខារទាំងឡាយនេះ ជាធម៌មានអវិជ្ជាជាបច្ច័យដូចម្តេច ? គប្បីមានពាក្យឆ្លើយថា ជ្រាបបាន ដោយកាលអវិជ្ជាមាន ទើបសង្ខារមាន ។ ពិតហើយ ការមិនដឹងក្នុងឋានៈទាំងឡាយ មានទុក្ខជាដើម ដែលហៅថា អវិជ្ជា បុគ្គលណានៅមិនទាន់លះបានមុនហើយ បុគ្គលនោះ ព្រោះការមិនដឹងក្នុងទុក្ខ និងឋានៈក្រៅអំពីនេះ មានបុព្វន្តជាដើម ទើបកាន់យកសង្សារទុក្ខដោយសម្គាល់ថាជាសុខ ហើយក៏សាងឡើងនូវសង្ខារទាំង ៣ យ៉ាង ដែលជាហេតុនៃសង្សារទុក្ខនោះឯង ព្រោះមិនដឹងក្នុងសមុទយៈ ទើបសម្គាល់ឃើញសង្ខារទាំងឡាយ ដែលមានតណ្ហាជាគ្រឿងប្រដាប់ ដែលសូម្បីជាហេតុនៃទុក្ខ ដោយយល់ថាជាហេតុនៃសុខទៅវិញ ក៏សាងសង្ខារទាំង ៣ យ៉ាងឡើង ម្យ៉ាងទៀត ព្រោះមិនដឹងក្នុងនិរោធ និងក្នុងមគ្គ ទើបជាអ្នកមានការសម្គាល់ក្នុងគតិវិសេស ( មាន

ព្រហ្មលោកជាដើម) ដែលសូម្បីមិនមែនជាទីរលត់ទុក្ខ ថាជាទីរលត់ទុក្ខទៅវិញ ជាអ្នកមានការសម្គាល់ក្នុងពាហិរមគ្គ មានការបូជាយញ្ញ និងបំពេញអមរតបៈជាដើម ដែលមិនមែនផ្លូវនៃការរលត់ទុក្ខ ថាជាផ្លូវរលត់ទុក្ខ ការប្រាថ្នាការរលត់ទុក្ខ ក៏សាងសង្ខារទាំង ៣ យ៉ាងឡើងតាមមុខពាហិរមគ្គ មានយញ្ញ និងអមរតបៈជាដើម ។ ប្រការមួយទៀត បុគ្គលនោះ ព្រោះការដែលលះអវិជ្ជាក្នុងសច្ចៈ ៤ មិនទាន់បាននោះ ក៏មិនដឹងទុក្ខពោល គឺផលនៃបុណ្យ ដែលសូម្បីពោរពេញដោយអាទីនវទោស ជាអនេក មានជាតិ ជរា រោគ និងមរណៈជាដើមយ៉ាងវិសេស ព្រោះថាជាទុក្ខបាន ទើបសាងបុញ្ញាភិសង្ខារ ដែលមានប្រភេទជាកាយសង្ខារក្តី វចីសង្ខារក្តី ចិត្តសង្ខារក្តី ដើម្បីបានផលនៃបុណ្យនោះ ដូចបុគ្គលអ្នកប្រាថ្នាទេពអប្សរ លោតចុះក្នុងប្រាំងចោតស្លាប់ បើមិនដូច្នោះ ក៏មិនឃើញការដែលបាននូវផលនៃបុណ្យនោះដែលសូម្បីសន្មតគ្នាថាជាសុខ ជាវិបរិណាមទុក្ខ ដែលញុំាងឲ្យកើតការក្តៅក្រហាយចិត្តធំក្នុងទីបំផុត (កាលអស់បុណ្យ) និង (មិនឃើញ) ការដែលបាននូវផលនៃបុណ្យនោះ (សូម្បីមានគុណគួរត្រេកអរក្តី) មានគុណគួរត្រេកអរជាចំណែកតិច ទើបសាងបុញ្ញាភិសង្ខារមានប្រការដូចពោលហើយនោះ ដែលជាបច្ច័យនៃវិបរិណាមទុក្ខនោះឯង ដូចសត្វមមាចហើរទំអណ្តាតភ្លើង និងដូចសត្វដែលជាប់ជំពាក់នឹងទឹកឃ្មុំ លិទ្ធមុខសស្ត្រា ដែលជាប់ទឹកឃ្មុំដូច្នោះ ។ ម្យ៉ាងទៀត មិនឃើញទោសក្នុងលោកិយវិស័យ មានការសេពកាមជាដើម ព្រមទាំងផលរបស់វា ព្រោះសម្គាល់ថាជាសុខ និងព្រោះត្រូវកិលេសគ្របសង្កត់ផង ទើបសាងអបុញ្ញាភិសង្ខារដែលប្រព្រឹត្តទៅក្នុងទ្វារទាំង ៣ ឡើងក៏បាន ដូចកូនក្មេងចង់លេងលាមក និងដូចមនុស្សចង់រស់ ឬចង់ស្លាប់ផឹកថ្នាំពិសដូច្នោះ ។ ម្យ៉ាងទៀត មិនដឹងការដែលសង្ខារសូម្បីក្នុងផ្នែកអរូបវិបាក ក៏ជាវិបរិណាមទុក្ខ ទើបសាងអនេញ្ជាភិសង្ខារដែលជាចិត្តសង្ខារឡើង ដោយវិបល្លាសទៅថា ជារបស់ទៀងជាដើម ដូចមនុស្សវង្វេង

ទិសផ្ដើម គិតដើរផ្លូវឈមមុខទៅកាន់ក្រុងបិសាច ដូច្នោះ ។

ព្រោះហេតុដែលសង្ខារមាន ព្រោះអវិជ្ជាមានប៉ុណ្ណោះ មិនមែនមានដោយមិនមានអវិជ្ជាឡើយ ដូចពោលមកដូច្នេះ បណ្ឌិតគប្បីដឹងសេចក្ដីថា សង្ខារទាំងឡាយនេះជាធម៌មានអវិជ្ជាជាបច្ច័យនោះបាន ។ ពិតហើយ ប្រការនេះ ព្រះមានព្រះភាគក៏បានត្រាស់ទុកថា ម្នាលភិក្ខុទាំងឡាយ បុគ្គលអ្នកមិនឈ្លាស ធ្លាក់នៅក្នុងអវិជ្ជា រមែងតាក់តែងបុញ្ញាភិសង្ខារខ្លះ រមែងតាក់តែងអបុញ្ញាភិសង្ខារខ្លះ រមែងតាក់តែងអនេញ្ជាភិសង្ខារខ្លះ ម្នាលភិក្ខុទាំងឡាយ លុះកាលណាអវិជ្ជា ភិក្ខុលះបានហើយ វិជ្ជាកើតឡើងហើយ កាលនោះ ភិក្ខុនោះ ព្រោះការប្រាសចាកទៅនៃអវិជ្ជា ព្រោះការកើតឡើងនៃវិជ្ជា រមែងមិនតាក់តែងបុញ្ញាភិសង្ខារឡើយ ដូច្នេះជាដើម ។

ក្នុងបទថា **អវិជ្ជា** នេះ យើងនឹងសួមផ្ទាកពាក្យថា អវិជ្ជាជាបច្ច័យនៃសង្ខារទាំងឡាយ នេះទុកសិន ព្រោះពាក្យនេះគួរនឹងពោលតទៅ គឺសួរថា អវិជ្ជាជាបច្ច័យនៃសង្ខារពួកណា ជាបច្ច័យដូចម្ដេច ? ក្នុងការដែលអវិជ្ជាជាបច្ច័យ ដូចម្ដេចខ្លះនោះ លោកពោលទុកដូចតទៅនេះ !

# មហាដីកា

## កថាពណ៌នាអំពីបទថា សង្ខារមាន

## ព្រោះអវិជ្ជាជាបច្ច័យ

*បទថា **អយំ បន** បានដល់ រឿងដែលនឹងពោលតទៅក្នុងឥឡូវនេះ ។ លោកអាចារ្យពោលថា **ដោយបរិយាយព្រះសូត្រ** ដូច្នេះ ។ ព្រោះព្រះមានព្រះភាគត្រាស់អវិជ្ជាដែលប្រព្រឹត្តទៅក្នុងឋានៈទាំង ៤ ក្នុងព្រះសូត្រទាំងឡាយ ដោយន័យជាដើមថា **ម្នាលភិក្ខុទាំងឡាយ អវិជ្ជាដូចម្តេច បានដល់ ការមិនដឹងក្នុងទុក្ខ** ។ ចំណែកក្នុងនិក្ខេបកណ្ឌ ព្រះមានព្រះភាគត្រាស់អវិជ្ជា ដែលព្រះអង្គបានត្រាស់ទុកក្នុងឋានៈទាំង ៤ ក្នុងព្រះសូត្រនោះឯង ដោយប្រភេទនៃកិច្ច ក្នុងឋានៈទាំង ៨ ដូច្នោះ លោកអាចារ្យមានបំណងធ្វើការអធិប្បាយទាក់ទងជាមួយនឹងការពណ៌នានៃអវិជ្ជានោះ ទើបផ្តើមពាក្យថា **ដោយបរិយាយនៃព្រះអភិធម្ម** ហើយពោលពាក្យជាដើមថា **សេចក្តីនេះសមដូចព្រះមានព្រះភាគត្រាស់ទុក** ដូច្នេះ ។ បណ្ឌិតគប្បីចែករឿងរ៉ាវកុំឲ្យដាច់ធ្លាក់ខុសគ្នា ។ ការចែកជាបរិយាយនៃព្រះអភិធម្ម ។ គប្បីនាំយកពាក្យថា **ការមិនដឹងក្នុងឋានៈទាំង ៨** មកភ្ជាប់ពាក្យនោះផង ។ ពាក្យថា **ក្នុងឋានៈដ៏សេស** គឺក្នុងទុក្ខ និងសមុទយៈ និងក្នុងឋានៈទាំងឡាយ មានបុព្វន្តចំណុចខាងដើម ។ បទថា **អារម្មណវសេន** ប្រែថា ដោយអំណាចធ្វើឲ្យជាអារម្មណ៍ ។ បទថា **ឥធ** សេចក្តីប៉ុនគ្នានឹង **ឥមស្មឹ យោគ ទុក្ខេ អញ្ញាណន្តិ អាទិកេ បាឋេ** ប្រែថា ក្នុងឋានៈនេះ គឺមានពាក្យជាដើមថា ទុក្ខេ **អញ្ញាណំ** ។ បទថា **សា យោគ អវិជ្ជា** ប្រែថា អវិជ្ជានោះ ។ ពាក្យថា **ដែលកើតឡើងហើយ** បានដល់ គឺនៅមិនទាន់បានផ្តាច់ផ្តិល គឺកើតឡើង ដែលកើតឡើងចំពោះមុខ មិនត្រូវពោលដល់ ។ លោកអាចារ្យពោលថា **រមែងមិនឲ្យចាក់ធ្លុះលក្ខណៈ***

**គឺរសរបស់ខ្លួនតាមសេចក្ដីពិតបាន** ដើម្បីសម្ដែងអាការ គឺការបិទបាំងដែលលោកបានពោលទុកក្នុងពាក្យថា **បិទបាំង** ។ សភាវៈដែលគប្បីត្រេកអរ គឺគប្បីចាក់ធ្លុះ ឈ្មោះថា **រស** រសរបស់ខ្លួន ឈ្មោះថា **សរសោ** ប្រែថា រសរបស់ខ្លួន រសរបស់ខ្លួនតាមសេចក្ដីពិត គឺមានពិត ឈ្មោះថា **យាថាវសរសោ** ប្រែថា រសរបស់ខ្លួនតាមសេចក្ដីពិត ដែលលោកបានពោលទុក ដោយពាក្យថា **បីឡូនត្ថោ** មានសភាវៈថា បៀតបៀនជាដើម និងធម៌ទាំងឡាយ មានបុព្វន្តជាដើមជាប្រភេទនៃទុក្ខសច្ចនោះឯងឯ រសនោះឯង ឈ្មោះថា **លក្ខណៈ គឺរសរបស់ខ្លួនតាមសេចក្ដីពិត** ព្រោះជារឿងដែលគប្បីកំណត់ ។ អវិជ្ជា **រមែងមិនឲ្យចាក់ធ្លុះ** លក្ខណៈ គឺរសរបស់ខ្លួនតាមសេចក្ដីពិតនោះ គឺដើម្បីដឹងដោយប្រចក្ស ។

ពាក្យថា **ខន្ធបញ្ចកៈទាំង ២** បានដល់ ខន្ធបញ្ចកៈខាងដើមដែលជាចំណែកអតីត និងខាងចុងដែលជាចំណែកអនាគត ។ ន័យម្យ៉ាងទៀត ចំណុចកណ្ដាល ដែលជាបច្ចុប្បន្នអទ្ធា ឈ្មោះថា **ចំណុចខាងដើម និងចំណុចខាងចុង** ព្រោះមានចំណែកនៃបុព្វន្ត និងអបរន្ត ។ ពាក្យថា **នេះអវិជ្ជា នេះសង្ខារ** ជាពាក្យសម្ដែងអាការ គឺការដឹងដោយប្រចក្សក្នុងឥទប្បច្ចយតា និងបដិច្ចសមុប្បន្នធម៌ ។ បទថា **ឯត្ថ** សេចក្ដីប៉ុនគ្នានឹង **ឯតេសុ យោគ ទុក្ខាទីសុ** ប្រែថា ក្នុងទុក្ខជាដើមនេះ គប្បីជ្រាបថា អវិជ្ជា រមែងប្រព្រឹត្តទៅទាក់ទងនឹងការធ្វើឲ្យជាអារម្មណ៍ក្នុងធម៌ មានទុក្ខជាដើមក៏ពិត សូម្បីដូច្នោះ អវិជ្ជាក៏មិនអាចធ្វើនិរោធ និងមគ្គឲ្យជាអារម្មណ៍បាន កាលប្រព្រឹត្តទៅទាក់ទងនឹងការបិទបាំងនិរោធ និងមគ្គនោះ ដល់បុគ្គលដែលប្រាថ្នាដឹងនិរោធ និងមគ្គទាំងនោះ និងដោយភាវៈដែលជាហេតុប្រកាន់មាំក្នុងធម៌ដែលមិនមែននិរោធ និងមគ្គថា ជានិរោធ និងមគ្គ រមែងមិនឲ្យចាក់ធ្លុះតាមសេចក្ដីពិតនូវនិរោធ និងមគ្គជាដើមនោះ យ៉ាងណា សូម្បីក្នុងសច្ចៈ មានទុក្ខជាដើម ក៏យ៉ាងនោះ ។ ពិតហើយ លោកអាចារ្យបានពោល

ថា ក្នុងបាលីនេះ លោកមានបំណងយកអវិជ្ជាដោយជាគ្រឿងបិទបាំងប៉ុណ្ណោះឯង ។ អាការ គឺការមិនឃើញដែលធ្វើកាពងងឹត ដែលមានសច្ចៈ មានទុក្ខជាដើមជាវិស័យ និងជា បច្ច័យដល់ធម៌ដែលធ្វើកាពងងឹត មានលោភៈជាដើម ឈ្មោះថា **អញ្ញាណំ** ប្រែថា ការមិនដឹង ។

ពាក្យថា **សង្ខារ មានបុញ្ញជាដើម** បានដល់ អភិសង្ខារ មានបុញ្ញាភិសង្ខារ ជាដើម ។ ក្នុងពាក្យថា **បុញ្ញាភិសង្ខារនោះ** មានវិគ្គហៈ ដូច្នេះ ធម្មជាតិឈ្មោះថា **បុញ្ញ** ព្រោះមានអត្ថថា **ជម្រះ** គឺធ្វើសន្តានរបស់ខ្លួនឲ្យបរិសុទ្ធអំពីផលនៃវត្ថុ ដែល មិនមែនជាបុញ្ញ និងអំពីការសៅហ្មង គឺទុក្ខ ។ ម្យ៉ាងទៀត បុគ្គលរមែងធ្វើបុណ្យ ដោយបំណងប្រយោជន៍ឧបការៈ និងសេចក្តីសុខ ព្រោះដូច្នោះ ធម្មជាតិឈ្មោះថា **បុញ្ញ** ក៏ព្រោះមានអត្ថថា **ធ្វើទិសដៅរបស់បុគ្គលដែលធ្វើឲ្យពេញ** ដោយការញ៉ាំង ប្រយោជន៍ និងសេចក្តីសុខនោះឲ្យសម្រេច ម្យ៉ាងទៀត ធម្មជាតិឈ្មោះថា **បុញ្ញ** ព្រោះមានអត្ថថា ញ៉ាំងភពដែលគួរបូជាឲ្យកើតឡើង ។ បុគ្គលដែលញ៉ាំងបំណងឲ្យ ពេញ និងដែលញ៉ាំងភពដែលគួរបូជាឲ្យកើត ដូច្នេះក៏គប្បីជ្រាបថា ឈ្មោះថា **បុញ្ញ** តាមន័យនៃនិរុត្តិ ។ សភាវៈឈ្មោះថា **អភិសង្ខារ** ដោយអត្ថថា **តាក់តែងផលរបស់ខ្លួន នោះផង** ជាបុញ្ញផង ព្រោះហេតុនោះ ទើបឈ្មោះថា **បុញ្ញាភិសង្ខារ** ប្រែថា សភាវៈ តាក់តែងដែលជាបុញ្ញ ។ ធម្មជាតិដែលឈ្មោះថា **អបុញ្ញ** ព្រោះជាបដិបក្ខ ចំពោះ ធម្មជាតិឈ្មោះថា **បុញ្ញ** ព្រោះដូច្នោះ គប្បីជ្រាបថា **អបុញ្ញាភិសង្ខារ** ដោយបរិយាយ ផ្ទុយអំពីពាក្យដែលបានពោលទុកហើយ ។ ភព ឈ្មោះថា **រមែងមិនញាប់ញ័រ** ព្រោះ នៅឆ្ងាយក្រៃលែងនៃធម៌ ដែលជាសត្រូវចំពោះសមាធិធម៌ណា រមែងតាក់តែងភព ដែលមិនញាប់ញ័រ ព្រោះដូច្នោះ ធម៌នោះ ឈ្មោះថា **អនេញ្ជាភិសង្ខារ** ។ ឈ្មោះថា **កាយសង្ខារ** ព្រោះអត្ថថា **ជាសង្ខារដែលកាយឲ្យប្រព្រឹត្តទៅហើយ** ឬព្រោះមាន

អត្ថថា **សង្ខារដែលប្រព្រឹត្តទៅតាមផ្លូវកាយ** ឬព្រោះមានអត្ថថា **តាក់តែងកាយ** ។ សូម្បីក្នុងវចីសង្ខារ និងចិត្តសង្ខារក៏ដូចន័យនេះ ។ ក្នុងសង្ខារ ៣ នោះ ត្រិកៈដំបូង លោកអាចារ្យកាន់យកដោយអំណាចនៃ **បរិវីមង្សនសូត្រ** ជាដើម ។

ពិតហើយ ក្នុងទីនោះមានព្រះបាលីមកហើយ ដោយន័យជាដើមថា **បុញ្ញញ្ចេ សង្ខារំ អភិសង្ខរោតិ បុញ្ញូបគំ ហោតិ វិញ្ញាណំ** ប្រែថា បើបុគ្គលតាក់តែងសង្ខារដែលជាបុញ្ញ វិញ្ញាណក៏ជាធម្មជាតិចូលដល់បុញ្ញ ។ ត្រិកៈទី ២ លោកអាចារ្យកាន់យកដោយអំណាច **វិភង្គសូត្រ** ។ ពិតហើយ ក្នុងទីនោះ ព្រះមានព្រះភាគត្រាស់ទុកថា **តយោមេ ភិក្ខវេ សង្ខារា ។ កតមេ តយោ ? កាយសង្ខារោ វចីសង្ខារោ ចិត្តសង្ខារោ** ប្រែថា ម្នាលភិក្ខុទាំងឡាយ សង្ខារ ៣ នេះ ។ សង្ខារ ៣ គឺអ្វី ? គឺ កាយសង្ខារ ១ វចីសង្ខារ ១ ចិត្តសង្ខារ ១ ។

ពាក្យថា **ពោលដោយពិស្តារ** ជាដើម ជាពាក្យអធិប្បាយសង្ខារទាំងឡាយមានបុញ្ញាភិសង្ខារជាដើម ដោយសរុប និងដោយប្រភេទ ។ **ដែលប្រព្រឹត្តទៅដោយអំណាចភាវនាប៉ុណ្ណោះ** គឺមិនប្រព្រឹត្តទៅដោយអំណាចទាន និងសីល ព្រោះដូច្នោះ ទើបលោកអាចារ្យសម្ដែងបុញ្ញកិរិយាវត្ថុដែលបាននៅក្នុងបុញ្ញាភិសង្ខារនោះ ។ ព្រោះអធិប្បាយយ៉ាងនេះ សូម្បីចេតនាដែលជាអរូបាវចរ ទើបលោកអាចារ្យពោលថា **ប្រព្រឹត្តទៅដោយអំណាចភាវនាប៉ុណ្ណោះ** ។ ចំណែកអាចារ្យពួកណារមែងពោលថា ដោយស័ព្ទដែលជា **អវធារណ** ថា **ភាវនាវសេនេវ** លោកអាចារ្យរមែងឃាត់ចេតនាក្នុងអភិញ្ញា ពាក្យនោះមិនត្រឹមត្រូវ ព្រោះលោកមានបំណងយកចេតនាទាំងនោះ ជាបុញ្ញាភិសង្ខារ ដូចជាក្នុងសង្ខារ មានអវិជ្ជាជាបច្ច័យ កាលកាន់យកអត្ថដោយប្រការដទៃ ការមិនរួមយកអភិញ្ញាចិត្តុប្បាទទុកក្នុងបុញ្ញកិរិយាវត្ថុនោះឯង ក៏គួរនឹងមាន និងពាក្យថា កុសល និងបុញ្ញកិរិយាវត្ថុ រមែងមិនមាន ដូច្នេះ ក៏មិនត្រឹមត្រូវ ។ ដោយ

**អាទិ-ស័ព្ទ**ថា **បាណាតិបាតាទិ** លោកកាន់យកអកុសលកម្មបថដ៏សេសអំពីកាមាវចរកុសលចេតនានោះប៉ុណ្ណោះក៏ទេ ដោយពិត គប្បីឃើញថា លោកកាន់យកអកុសលកម្ម មិនមានចំណែកសេសសល់ ។

ពាក្យថា **ក្នុងចំណែកសង្ខារក្រៅអំពីនេះ** បានដល់ ក្នុងសង្ខារ មានកាយសង្ខារជាដើម ។**ដើម្បីនឹងសម្តែងការប្រព្រឹត្តទៅតាមទ្វារ** ព្រោះអភិសង្ខារ មានបុញ្ញាភិសង្ខារជាដើម កាលប្រព្រឹត្តទៅ ក៏រមែងប្រព្រឹត្តទៅក្នុងទ្វារទាំងនេះ ។ លោកអាចារ្យពោលពាក្យថា **អភិញ្ញាចេតនា** ជាដើម សំដៅដល់ពាក្យសាកសួរថា ព្រោះហេតុអ្វី ទើបលោកពោលថា **ចេតនា ២០** កុសលចេតនា និងអកុសលចេតនា ដែលញុំាងកាយវិញ្ញត្តិ និងវចីវិញ្ញត្តិឲ្យតាំងឡើង លោកក៏ហៅថា កាយសង្ខារ និងវចីសង្ខារដោយពិត បើដូច្នេះ ក៏គួរពោលសូម្បីអភិញ្ញាចេតនាដែលជាកុសលប្រព្រឹត្តទៅហើយយ៉ាងនោះ ជាវចីសង្ខារ ។ បទថា **ឯត្ថ យោគ កាយវចីសង្ខារគ្គហនេ** ប្រែថា ក្នុងការកាន់យកកាយសង្ខារ និងវចីសង្ខារនេះ **យោគ កាយវចីសញ្ចេតនាគ្គហនេ** ប្រែថា ក្នុងការកាន់យកកាយសញ្ចេតនា និងវចីសញ្ចេតនានេះខ្វះ ។ ពាក្យថា **ទើបលោកមិនកាន់យក** គឺលោកមិនបានកាន់យកនៅក្នុងអដ្ឋកថាថា **អភិញ្ញាចេតនាមិនជាបច្ច័យដល់វិញ្ញាណ** សួរថា ព្រោះហេតុអ្វី អភិញ្ញាចេតនានោះជាកុសល និងវិបាកជាធម្មតាមិនមែនឬ ? ឆ្លើយថាសេចក្តីនេះពិតតែអភិញ្ញាចេតនានោះជាកុសលនិងជាវិបាកធម៌ លោកពោលទុកដោយសេចក្តីព្យាយាមរបស់ខ្លួន ក្នុងសន្តានដែលនៅមានតណ្ហាមិនទាន់លះ មិនមែនពោលទុកដោយប្រការដែលញុំាងវិបាកឲ្យកើតឡើងឡើយ ។ម្យ៉ាងទៀត អភិញ្ញាចេតនានោះ កាលញុំាងវិបាកឲ្យកើតឡើង ក៏គប្បីញុំាងវិបាកដែលជារូបាវចរប៉ុណ្ណោះឲ្យកើតឡើង ។ ព្រោះថា កម្មដែលប្រព្រឹត្តទៅក្នុងភូមិដទៃ រមែងញុំាងវិបាកដែលប្រព្រឹត្តទៅ ក្នុងភូមិដទៃឲ្យកើតឡើងក៏ទេ ដូច្នេះ ។ គប្បីញុំាងវិបាកដែល

មានអារម្មណ៍ដូចគ្នានឹងខ្លួន ឲ្យប្រព្រឹត្តទៅក្នុងឋានៈ ៣ ប៉ុណ្ណោះឲ្យកើតឡើង ព្រោះក្នុង **ចិត្តុប្បាទកណ្ឌ** ព្រះសាស្ដាត្រាស់រូបាវចរវិបាក ដែលមានអារម្មណ៍ដូចគ្នានឹងកម្មនោះឯង ។ មួយាំងទៀត រូបាវចរវិបាក មានអារម្មណ៍ ជាកាមាវចរជាដើម ឬក៏ទេ ។ ហើយអភិញ្ញាចេតនានឹងមានអារម្មណ៍ជាកាមាវចរជាដើមប៉ុណ្ណោះក៏ទេ ។ ព្រោះដូច្នោះ ទើបរមែងធ្វើឲ្យយល់ថា មិនធ្វើវិបាកឲ្យកើតឡើង និងអភិញ្ញាក៏ជាអានិសង្សនៃសមាធិក្នុងចតុត្ថជ្ឈាន ដែលព្រះយោគាវចរបុគ្គល ធ្វើឲ្យកើតឡើងក្នុងកសិណទាំងឡាយដូចដែលត្រាស់ថា **ភិក្ខុនោះ កាលចិត្តតាំងមាំ ហើយយ៉ាងនេះ** ជាដើម ។ ព្រោះដូច្នោះ ទើបអភិញ្ញាចេតនានោះ ដូចគ្នានឹងផលនៃសមាធិ និងរមែងមិនឲ្យផល ។ ដូចការបានបច្ច័យក្នុងភពនោះដែលជាអានិសង្សនៃទាន និងសីល ព្រោះដូច្នោះទើបអភិញ្ញាចេតនានោះមិនធ្វើវិបាកឲ្យកើតឡើង ដូច្នេះ ។

ពាក្យថា **អភិញ្ញាចេតនាមិនជាបច្ច័យ និងវិញ្ញាណ យ៉ាងណា សូម្បីឧទ្ធច្ចចេតនាក៏មិនជាបច្ច័យដូចគ្នាដូច្នោះ** នេះ គួរពិចារណា ព្រោះព្រះមានព្រះភាគទ្រង់លើកធម៌ដែលសហគតៈ ដោយឧទ្ធច្ចៈទុកមួយផ្នែក ដោយត្រាស់ទុកថា **ញាណក្នុងវិបាករបស់ធម៌ទាំងនោះ** ឈ្មោះថា **អត្ថប្បដិសម្ភិទា** ។ ឯគោលពិចារណានោះ ខ្ញុំបានពិចារណាទុកហើយនោះឯង ក្នុងកថាពោលដោយអកុសលក្នុងវណ្ណនានៃខន្ធនិទ្ទេសខាងដើម ព្រោះដូច្នោះ បណ្ឌិតគប្បីជ្រាបតាមន័យដែលបានពិចារណាទុកហើយ ក្នុងទីនោះឯង ។ ប្រការមួយទៀត ក្នុងអធិការនេះ អាចារ្យមួយពួករមែងពោលចែកពាក្យណាទុក ដោយសេចក្ដីថា ព្រោះការមិនមានទស្សនៈ (សោតាបត្តិមគ្គ) និងភាវនា (មគ្គ ៣ ខាងលើ) ទស្សនៈ និងភាវនាក៏នឹងត្រូវមានដល់បុថុជ្ជន និងសេក្ខបុគ្គល អកុសលដែលបុថុជ្ជន និងសេក្ខបុគ្គលទាំងនោះ គប្បីអាចលះបានក្នុង កាលដែលទស្សនៈ និងភាវនានោះកើតឡើងដល់បុថុជ្ជន និងសេក្ខបុគ្គលទាំងនោះ រមែងហៅបានថា ជាអកុសលដែល

ទស្សនៈគប្បីលះ និងថា ជាអកុសលដែលភាវនាគប្បីលះ ។ តែព្រោះភាវនាមិនមាន ដល់បុថុជ្ជនទាំងឡាយ ទើបមិនមានការត្រូវគិតដល់រឿងអកុសលធម៌ ដែលភាវនាគប្បីលះ ។ ដោយហេតុនោះ អកុសលទាំងឡាយ ដែលប្រព្រឹត្តទៅដល់បុថុជ្ជនទាំងនោះ ជាធម៌ដែលមិនគប្បីអាចលះបាន ដោយទស្សនៈ ក៏មិនហៅថា **ភាវនាយបហាតព្វធម៌** ធម៌ដែលភាវនាគប្បីលះ ។ បើគប្បីហៅសោត **ទស្សនេនបហាតព្វធម៌** ក៏គប្បីជាបច្ច័យដោយអារម្មណប្បច្ច័យ អារម្មណាធិប្បតិប្បច្ច័យ និងឧបនិស្សយប្បច្ច័យ ដល់ភាវនាយបហាតព្វធម៌ពួកខ្លះ ដោយបច្ច័យពួកខ្លះ ក្នុងកាលខ្លះបាន ក្នុងបដ្ឋាន **ទស្សនេនបហាតព្វធម៌** ព្រះមានព្រះភាគត្រាស់ថា មិនជាបច្ច័យដោយបច្ច័យណាមួយ ដល់ភាវនាយបហាតព្វធម៌នោះឡើយ ។ ចំណែកអកុសលដែលមានដល់សេក្ខបុគ្គល ដែលអាចលះបានដោយភាវនា ព្រោះដូច្នោះ ទើបឈ្មោះថា **ភាវនាយបហាតព្វធម៌** ។ ដោយហេតុនោះឯង ធម៌ដែលជាទស្សនៈរបស់សេក្ខបុគ្គលគប្បីលះបាន ក៏នៅមិនទាន់ជាធម៌ដែលគួររីករាយ និងគួរត្រេកអរក្រៃពេក ព្រោះជាធម៌ដែលលះបង់បានហើយ ព្រោះជាធម៌ដែលខ្ជាក់បានហើយ ព្រោះជាធម៌ដែលផុតបានហើយ ព្រោះជាធម៌ដែលលះបានហើយ ព្រោះជាធម៌ដែលលះបង់បានហើយ ។ ព្រោះជាធម៌ដែលលះបានហើយនោះឯង ធម៌ដែលជាហេតុនៃសោមនស្ស និងហេតុនៃការមិនរាយមាយ រមែងមិនញុំាងទោមនស្ស និងឧទ្ធច្ចៈឲ្យកើតឡើង ព្រោះហេតុនោះ ទើបបហាតព្វធម៌ទាំងនោះមិនចូលដល់នូវភាពជាអារម្មណប្បច្ច័យ អារម្មណាធិបតិប្បច្ច័យ និងបកតូបនិស្សយប្បច្ច័យ ដល់ភាវនាយបហាតព្វធម៌នោះ ។ ព្រះអរិយៈព្រោះអាស្រ័យកិលេស ដែលលះបានហើយ រមែងមិនញុំាងកិលេស មានរាគៈជាដើមឲ្យកើតឡើងទៀត ។

សេចក្ដីនេះ សមដូចពាក្យព្រះធម្មសេនាបតីសារីបុត្រពោលទុកថា កិលេសពួកណា ដែលព្រះអរិយៈលះបានហើយដោយសោតាបត្តិមគ្គ លោករមែងមិនមកទៀត

រមែងមិនបង្អោនមក រមែងមិនត្រឡប់មករកកិលេសទាំងនោះ ។បេ។ កិលេសណា ដែលលោកលះបានហើយដោយអរហត្តមគ្គ រមែងមិនមកទៀត រមែងមិនបង្អោនមក រមែងមិនត្រឡប់មករកកិលេសទាំងនោះឡើយ ។ ឯអកុសលទាំងឡាយ ដែលបុថុជ្ជន អាចលះបានដោយសោតាបត្តិមគ្គមិនមាន ទើបមិនអាចពោលបានថា ជាបច្ច័យដោយ បច្ច័យណាមួយ ដល់ព្រះអរិយបុគ្គលក្រៅអំពីនេះ ព្រោះព្រះមានព្រះភាគត្រាស់ទិដ្ឋិ និងវិចិកិច្ឆា មានឧទ្ធច្ចៈជាអារម្មណបច្ច័យទុកថា បុគ្គលរមែងត្រេកអររីករាយដោយ ទិដ្ឋិ ព្រោះប្រារព្ធទិដ្ឋិនោះ រមែងកើតរាគៈ រមែងកើតទិដ្ឋិ វិចិកិច្ឆា ឧទ្ធច្ចៈ ។ ព្រោះប្រារព្ធ វិចិកិច្ឆា រមែងកើតវិចិកិច្ឆា ឧទ្ធច្ចៈ ។ ឯក្នុងព្រះបាលីនេះ ពាក្យថា **ឧទ្ធច្ចៈ** ព្រះសាស្តា ត្រាស់សំដៅយកចិត្តុប្បាទដែលសហគតៈដោយឧទ្ធច្ចៈ ។ ព្រោះអធិប្បាយយ៉ាងនេះ ក្នុងនិទ្ទេសនៃអធិបតិប្បច្ច័យ ទើបព្រះមានជោគត្រាស់ពាក្យត្រឹមប៉ុណ្ណោះឯងថា បុគ្គល ព្រោះធ្វើទិដ្ឋិឲ្យជាអារម្មណ៍យ៉ាងធ្ងន់ រមែងត្រេកអររីករាយ ព្រោះធ្វើទិដ្ឋិនោះឲ្យជា អារម្មណ៍យ៉ាងធ្ងន់ រាគៈរមែងកើត ទិដ្ឋិរមែងកើត មិនបានត្រាស់ថា **ឧទ្ធច្ចៈរមែងកើត** ព្រោះដូច្នោះ សូម្បីក្នុងប្រការដែលធម៌ គឺទស្សនៈ និងភាវនាគប្បីលះ គប្បីជាធម៌ដែល ពោលមិនបាន ដោយជាអតីតជាដើម ធម៌ណាជាធម៌ដែលមិនបានកើតឡើង គប្បី ឲ្យដល់បានដោយទស្សនៈ និងភាវនាទាំងនោះ ធម៌ដែលប្រព្រឹត្តទៅក្នុងបុថុជ្ជននោះ សម្ទឹងដល់ទស្សនៈអាចលះបានដោយទស្សនៈនោះ ក៏ជា **ទស្សនេនបហាតព្វធម៌** ដែល ប្រព្រឹត្តទៅក្នុងសេក្ខបុគ្គលសម្ទឹងដល់ភាវនា គប្បីអាចលះបានដោយភាវនានោះ ក៏ជា **ភាវនាយបហាតព្វធម៌** ។

ក្នុងបណ្តាធម៌ទាំងនោះ **ភាវនាយបហាតព្វធម៌** វៀរចាកធម៌ដែលមានការ ប្រព្រឹត្តទៅរួមគ្នា រមែងមិនញុំាងវិបាកឲ្យកើត ព្រោះដូច្នោះ ទើបលោកមិនពោល ចេតនាក្នុង **ភាវនាយបហាតព្វធម៌** ជាកម្មប្បច្ច័យ ដែលមាននៅក្នុងខណៈផ្សេងគ្នា

តែព្រោះធម៌ មានឆន្ទរាគ:ជាដើម ក្នុងកណ្ឌ:របស់ខ្លួនដែលវៀរចាកទស្សន:និងភាវនា ដែលគប្បីសម្លឹងដល់ ដែលកើតឡើងក្នុងបុថុជ្ជនទាំងឡាយ និងកិលេស ដែលតាំងនៅជាមួយគ្នានឹងសំយោជន: ៣ នៃចិត្តុប្បាទដែលសហគត:ដោយឧទ្ធច្ច: ជាធម៌ដែលមិនទាន់ចូលទៅកាត់បាន ទើបបុគ្គលណាមួយមិនអាចបដិសេធការញុំាងវិបាកឲ្យកើតឡើងរបស់ធម៌ ដែលមានការប្រព្រឹត្តទៅរួមគ្នានៅមិនទាន់អស់ ព្រោះដូច្នោះ វិបាករបស់ធម៌ដែលសហគត:ដោយឧទ្ធច្ច: ទើបព្រះសាស្តាត្រាស់ក្នុងគម្ពីរវិភង្គ ។ សួរថា បើយ៉ាងនោះអកុសលទាំងឡាយដែលវៀរចាកទស្សន:និងភាវនាដែលគប្បីសម្លឹងដល់ ក៏ត្រូវជាធម៌ដែលគប្បីពោលមិនបាន ដោយជាធម៌ដែលទស្សន:ក៏មិនមែន ភាវនាក៏មិនមែននឹងគប្បីលះ ? ឆ្លើយថា មិនត្រឹមត្រូវ ព្រោះអប្បហាតព្វធម៌ ព្រះមានព្រះភាគក៏បានត្រាស់ថា **ជាធម៌ដែលទស្សន:ក៏មិនគប្បីលះ ភាវនាក៏មិនគប្បីលះ** ព្រោះអកុសលទាំងឡាយ ក៏មានសភាពខុសទៅអំពីអប្បហាតព្វធម៌ ។

សួរថា បើយ៉ាងនេះ ធម៌នោះនឹងត្រូវជាធម៌ដែលគប្បីពោលបានថា **នវត្តព្វធម៌** ធម៌ដែលមិនគប្បីពោលបានក្នុងតិក:នេះឬ ? ឆ្លើយថា មិនត្រឹមត្រូវ ព្រោះអកុសលចិត្តុប្បាទ ១២ ដួង ព្រះមានព្រះភាគទ្រង់សម្តែងទុកក្នុងចិត្តុប្បាទកណ្ឌ ទ្រង់ក៏សង្គ្រោះទុកដោយបទទាំង ២ ហើយ ។ ដូចជាសង្ខតធម៌ទាំងពួង ទ្រង់សង្គ្រោះទុកទាក់ទងនឹងធម៌ ព្រោះដូច្នោះ ក្នុងឧប្បន្នត្តិក: ធម៌ដែលមិនបានសង្គ្រោះជាមួយ កាលដែលជាអតីត លោកក៏មិនហៅថា **នវត្តព្វធម៌** ព្រោះមិនមានធម៌ដែលគប្បីពោលបាន ក្នុងធម៌ដែលលោកកាន់យកដោយជាចិត្តុប្បាទ និងរូបធម៌ យ៉ាងណា សូម្បីក្នុងអធិការនេះក៏ដូច្នោះ **នវត្តព្វធម៌** គប្បីជ្រាបថា លោកមិនបានពោលទុក ព្រោះមិនមានធម៌គប្បីពោលបាន សង្គ្រោះមិនបានក្នុងធម៌ដែលលោកកាន់យកដោយជាចិត្តុប្បាទ ។ ក្នុងទីណាមានចិត្តុប្បាទដួងខ្លះ ដែលគប្បីពោលមិនបានដោយការប្រកប ក្នុងទីនោះ ក៏មានចំណែក

ទី ៤ នៃធម៌ទាំងនោះ ព្រោះដូច្នោះ ទើបព្រះសាស្ដាទ្រង់ចែកចិត្តុប្បាទដែលទ្រង់ចែកក្នុងទីនោះ ហើយធ្វើឲ្យយល់ ដូចក្នុងបទតាមដែលបានពោលទុកហើយ ធ្វើឲ្យយល់ដោយពាក្យជាដើមថា **សិយា នវត្តព្វា បរិត្តារម្មណា** ប្រែថា ធម៌ដែលគប្បីពោលមិនបាន ថាជាបរិត្តារម្មណ៍ក៏មាន ។ ទ្រង់ត្រាស់ទុកក្នុងឧប្បន្នត្តិកៈ ព្រោះមិនមានធម៌នោះ តែក្នុងទីនេះមិនបានត្រាស់យ៉ាងនោះ ។

សួរថា ម្យ៉ាងទៀត មហាភូតរូប ៣ ក្នុងរូបធាតុ ទ្រង់ត្រាស់ហៅថា **សប្បដិឃធម៌** ធម៌ដែលមានការប៉ះខ្ទប់គ្នាបាន ព្រោះមានសភាពដូចសប្បដិឃធម៌ទាំងឡាយ ។ ដូចដែលត្រាស់ទុកថា **សម្រាប់ពួកអសញ្ញសត្ត មហាភូតរូប ២ អាស្រ័យមហាភូតរូប ១ ដែលមានការឃើញមិនបាន តែមានការប៉ះខ្ទប់បាន មហាភូតរូប ១ អាស្រ័យមហាភូតរូប ២ កើតឡើង** ធម៌ដែលប្រព្រឹត្តទៅដល់បុថុជ្ជនទាំងឡាយ ដែលមានសភាពដូចគ្នានឹងការនាយបហាតព្វធម៌ ក៏គួរនឹងហៅថា ការនាយបហាតព្វធម៌ ដូច្នោះឬ ? ឆ្លើយថា មិនមានទាក់ទងគ្នាដោយជានវត្តព្វធម៌ ។ កាលបើយ៉ាងនេះ ក៏រមែងបានអត្ថក្នុងសេចក្ដីនេះថា ធម៌ទាំងឡាយសូម្បីប្រព្រឹត្តទៅដល់បុថុជ្ជន ដែលការនាគប្បីលះជាដើមថា ធនុរាគៈក្នុងកណ្ឋៈរបស់ខ្លួន ជាឧបនិស្សយប្បច្ច័យដល់ធនុរាគៈជាដើមក្នុងកណ្ឋៈរបស់បុគ្គលដទៃ ម្យ៉ាងទៀត រាគៈក៏ជាអធិបតិប្បច្ច័យដល់រាគៈ និងទិដ្ឋិ ។ ម្យ៉ាងទៀត មហាភូតរូប ៣ ក្នុងរូបធាតុ ក៏មិនមែនជាសប្បដិឃធម៌ គឺធម៌ដែលប៉ះខ្ទប់បានដោយបរមត្ថ ព្រោះមិនមែនផោដ្ឋព្វៈ យ៉ាងណា ធម៌ទាំងឡាយដែលវៀរចាកការនា ដែលគប្បីសម្ព័ន្ធដល់ការប្រព្រឹត្តទៅក្នុងពួកបុថុជ្ជនជាដើម ដូចជាធនុរាគៈក្នុងកណ្ឋៈរបស់ខ្លួន ក៏មិនមែនជាការនាយបហាតព្វធម៌ដោយបរមត្ថ យ៉ាងនោះ ព្រោះដូច្នោះ ទើបមិនបានត្រាស់ការនាយបហាតព្វធម៌ជាកម្មប្បច្ច័យ ដែលប្រព្រឹត្តទៅក្នុងខណៈផ្សេងគ្នា ។ ម្យ៉ាងទៀត ទស្សនេនបហាតព្វធម៌ ត្រាស់ថា ជាបច្ច័យ ដោយបច្ច័យ

ណាមួយ ដល់ការនាំយបហាតពួធម៌មិនមាន ។ ពិតហើយ កិលេសទាំងឡាយណា ដែលមានធម៌ គឺសោតាបត្តិមគ្គគប្បីលះជាបច្ច័យ កិលេសទាំងឡាយនោះប្រព្រឹត្តទៅលើសោតាបត្តិមគ្គក៏ទេ ។ ឯធម៌ដែលសហគតៈដោយឧទ្ធច្ចៈ សូម្បីមានធម៌ដែលសោតាបត្តិមគ្គ គប្បីលះជាបច្ច័យ សោតាបត្តិមគ្គក៏ធ្វើកិច្ចត្រឹមតែតិចតួចនៃធម៌ដែលប្រព្រឹត្តទៅរួមគ្នាប៉ុណ្ណោះ ការៈណាមួយ ត្រូវសោតាបត្តិមគ្គឲ្យដល់នូវធម៌ដែលមានការមិនកើតឡើង ជាធម្មតាក៏ទេ ព្រោះដូច្នោះ ទើបត្រាស់ធម៌ដែលសហគតៈដោយឧទ្ធច្ចៈនោះជាការនាំយបហាតពួធម៌ដោយចំណែកមួយ ។ ព្រោះហេតុនោះ កាលមានធម៌ដែលប្រព្រឹត្តទៅរួមគ្នានៃសហគតធម៌ដោយឧទ្ធច្ចៈនោះ ដូច្នោះឯង ការពោលដល់ប្រការញុំាងវិបាកឲ្យកើតឡើងក៏មិនខុសនិងកាលមិនមានការពោលដល់ប្រការដែលមិនធ្វើវិបាកឲ្យកើតឡើងក៏មិនខុស ដូច្នេះ ។ អាចារ្យមួយពួកទៀតពោលថា ពាក្យទាំងអស់នេះគ្រាន់តែជាវាចារបស់អច្ចរិយបុរសនៃអាចារ្យទាំងនោះ ។ ព្រោះហេតុអ្វី ? ព្រោះធម៌ដែលសហគតៈដោយឧទ្ធច្ចៈ ជាការនាំយបហាតពួធម៌ដោយចំណែកមួយ ។ បើដូច្នេះ ទើបព្រះសាស្តាត្រាស់ថា ធម៌ដែលជាមគ្គខាងលើ ៣ គប្បីលះ គឺអ្វីខ្លះ ? គឺចិត្តុប្បាទដែលសហគតៈដោយឧទ្ធច្ចៈ ។ បើពាក្យនោះ ជាពាក្យគួរប្រាថ្នាសោត សូម្បីក្នុងអធិការនេះ ព្រះមានព្រះភាគត្រាស់ទុកថា ធម៌ដែលមគ្គខាងលើ ៣ គប្បីលះដោយចំពោះមិនមាន ដូច្នេះហើយ ក៏គួរត្រាស់ថា ធម៌ ដែលសហគតៈដោយឧទ្ធច្ចៈ ជាធម៌ដែលមគ្គ ៣ ខាងលើគប្បីលះក៏មាន ជាធម៌ គប្បីពោលមិនបានក៏មាន ដូចជាក្នុង **អតីតារម្មណត្តិក** បានត្រាស់ចែកទុក ដោយត្រាស់ថា **ធម៌ដែលមានអារម្មណ៍ ជាអនាគតដោយចំពោះមិនមាន** ។ យុត្តិណា ដែលលោកអាចារ្យធ្វើពាក្យនោះឲ្យសម្រេចប្រយោជន៍ បានពោលទុកដោយពាក្យជាដើមថា **បើអាចារ្យទាំងឡាយគប្បីពោលសោត** យុត្តិនោះ ក៏មិនជាយុត្តិ ។ ព្រោះហេតុអ្វី ? ព្រោះភគៈ ទិដ្ឋិ វិចិកិច្ឆា និង

ឧទ្ធច្ចៈ មានអារម្មណ៍ដែលសោតាបត្តិមគ្គគប្បីលះ ធម៌ដែលសោតាបត្តិមគ្គគប្បីលះ នោះឯង លោកធ្វើបំណងទុកហើយ ដូច្នេះ ។ ចំណែកពាក្យណាដែលលោកអាចារ្យ ពោលទុកថា ចិត្តុប្បាទដែលសហគតៈដោយឧទ្ធច្ចៈ ព្រះមានព្រះភាគត្រាស់ទុក **ក្នុងបាលី** ដោយស័ព្ទថា **ឧទ្ធច្ចៈ** លោកពោលជាមូលទុក មិនបានអធិប្បាយឧទ្ធច្ចៈក្នុងនិទ្ទេសនៃអធិបតិប្បច្ច័យ ដើម្បីញុំាងពាក្យនោះឲ្យជាទីយល់ ពាក្យនោះ មិនមែនជាពាក្យមូលដើម ព្រោះក្នុងបដ្ឋានទ្រង់សម្ដែងបាឋៈ ដែលនៅមានចំណែកសេសសល់ទុក ។ ពិតយ៉ាងនោះ ព្រះមានព្រះភាគ ទ្រង់ធ្វើការកាន់យកចេតោបរិយញ្ញាណ ក្នុងវិភង្គនៃបទទាំងឡាយថា ធម៌ដែលជាអតីត ជាអារម្មណប្បច្ច័យដល់ធម៌ដែលជាបច្ចុប្បន្ន ធម៌ដែលជាអនាគត ជាអារម្មណប្បច្ច័យដល់ធម៌ដែលជាបច្ចុប្បន្ន ទ្រង់មិនបានលើកធម៌ដែលមាន **ក្នុងវិភង្គ** នៃបទនេះថា **ធម៌ដែលជាបច្ចុប្បន្នជាអារម្មណប្បច្ច័យដល់ធម៌ដែលជាបច្ចុប្បន្ន** ។

កាលការនាយបហាតព្វធម៌ឲ្យវិបាក ក៏គួរពិចារណាការចូលដល់ធម៌ ដែលប្រព្រឹត្តទៅរួមគ្នាជាមួយទស្សនេនបហាតព្វធម៌ ។ មានពាក្យសួរថា ធម្មជាតិដែលសោតាបត្តិមគ្គគប្បីលះ រមែងចូលដល់ធម៌ដែលប្រព្រឹត្តទៅរួមគ្នារបស់ធម្មជាតិ ដែលមគ្គខាងលើ ៣ គប្បីលះទាក់ទងដោយឋានៈ ព្រោះទាន និងសីលជាដើម អាចឲ្យវិបាកដល់ការកើតឡើងនោះឯង ដូចជាអវិជ្ជាជាដើម ឬកាលកម្មឲ្យបដិសន្ធិដូចជាកិលេសទៅវិញ ? ឆ្លើយថា សេចក្ដីនេះ មានប្រការគួរពោលខ្លះដែរ គឺបើខាងដើម ចំណែកដំបូង ធម្មជាតិដែលមគ្គខាងលើ ៣គប្បីលះដែលប្រព្រឹត្តទៅក្នុងសន្ដាន នៃសេក្ខបុគ្គលក៏ត្រូវជាកិរិយា ព្រោះសោតាបត្តិមគ្គមានធម៌គប្បីលះ បានលះទៅហើយ ដូចជាទានប្រព្រឹត្តទៅក្នុងសន្ដានដែលមានអវិជ្ជា តណ្ហា និងមានះ លះបានហើយជាដើម ។ បើចំណែកទី ២ សូម្បីធម៌ដែលមគ្គខាងលើ ៣ គប្បីលះនោះ ក៏ត្រូវជាធម៌ ដែល

សោតាបត្តិមគ្គគប្បីលះ ព្រោះការមិនប្រព្រឹត្តទៅកន្លងសភាវៈ ដែលគប្បីទៅកាន់អបាយ ព្រោះដូច្នោះ កាលធម៌ដែលសហគតៈដោយឧទ្ធច្ចៈឲ្យវិបាកបាន តាមន័យដូចបាន ពិចារណាទុកហើយខាងដើមនោះឯង បណ្ឌិតក៏គួរជ្រាបសេចក្ដីវិនិច្ឆ័យក្នុងទីនេះ ដោយមិនប្រាសទៅអំពីព្រះបាលី និងអដ្ឋកថា ។

បទថា **សាបិ យោគ ឧទ្ធច្ចចេតនាបិ** ប្រែថា ដល់ឧទ្ធច្ចចេតនានោះ ។ ពាក្យថា **ក្នុងភាពជាបច្ច័យដល់វិញ្ញាណ** គឺក្នុងភាពជាបច្ច័យដល់វិបាកវិញ្ញាណ ដែលសម្បូរ ។ បើត្រូវជំទាស់ លោកអាចារ្យពោលទុកថា **ចេតនា ២០** ដូច្នេះ ព្រោះហេតុអ្វី ? ព្រោះដូច្នោះ លោកអាចារ្យកាលសម្ដែងហេតុរបស់ពាក្យនោះ ទើបពោលថា **តែចេតនាទាំងឡាយនោះក៏គង់ជាធម៌ មានអវិជ្ជាជាបច្ច័យ** លោកអាចារ្យរមែងសម្ដែងអភិញ្ញាចេតនាក៏ជាបច្ច័យផងដែរ ។ បើយ៉ាងនោះ ក៏គួរពោលថា ជា ២១ ដួង ទាំងអភិញ្ញាចេតនា តែលោកមិនបានពោលទុក ព្រោះមិនពោលយ៉ាងនោះ មានហេតុដែលបានពោលទុកហើយ ។ ឯការមិនបានពោលនោះជាហេតុនៃការមិនបានពោលក្រៅអំពីនេះ ព្រោះដូច្នោះ លោកសម្លឹងដល់ហេតុណាក្នុង ការមិនពោលចេតនាណានីមួយដែលមានរូបស្មើគ្នា ទើបមិនបានពោលចេតនាឯណានីមួយទុក លោកអាចារ្យរមែងសម្ដែងភាវៈដែលមិនគប្បីពោលនៃចេតនា ដែលបានពោលទុកហើយ ដោយហេតុនោះ ។ ពាក្យថា **តិកៈនេះ** បានដល់ តិកៈដែលកំណត់ដោយកាយសង្ខារជាដើម ។ ពាក្យថា **តិកៈមុន** បានដល់ តិកៈដែលកំណត់ ដោយបុញ្ញាភិសង្ខារជាប្រការដំបូង ។ ពាក្យថា **បន្ថែមចូល** គឺបន្ថែមពាក្យចូល ។ ពិតហើយ បុញ្ញាភិសង្ខារដែលចែកជាចេតនាខាងកាមាវចរ ៨ ដួង ជាកាយសង្ខារនៃបុគ្គលដែលវៀរចាកវចីទុច្ចរិតក៏មាន ចំណែកចេតនាទាំង ១៣ ដួង ដែលកើតឡើងក្នុងមនោទ្វារ រមែងជាបុញ្ញាភិសង្ខារ និងជាចិត្តសង្ខារ ។ សូម្បីបុញ្ញាភិសង្ខារ ជាកាយសង្ខារក៏មាន ក្នុងខណៈណាប្រព្រឹត្តទៅ

ដោយអំណាចកាយទុច្ចរិត ជាវចីសង្ខារក៏មាន ក្នុងខណៈប្រព្រឹត្តទៅដោយវចីទុច្ចរិត ជាចិត្តសង្ខារ និងអនេញ្ជាភិសង្ខារក៏មាន ក្នុងខណៈដែលទ្វារទាំង ២ ប្រព្រឹត្តទៅក្នុងមនោទ្វារ តិកៈទី ២ រមែងបន្ថែមចូលជាមួយតិកៈដំបូងនោះឯង ដោយប្រការដូចពោលមក ដូច្នេះ ។ ដោយហេតុនោះ ទើបលោកអាចារ្យពោលថា **ពោលដោយចិត្តហើយ អវិជ្ជាជាបច្ច័យក៏គប្បីជ្រាបដោយបច្ច័យនៃសង្ខារ មានបុញ្ញាភិសង្ខារជាដើមនោះឯង ។**

ពាក្យថា **ព្រោះកាលអវិជ្ជាមាន វាទើបមាន** សេចក្ដីថា កាលអវិជ្ជាមាន ទើបសង្ខារមាន ។ ព្រោះថា កាលអវិជ្ជាមិនមានសង្ខារមិនមានក្នុងកាលណាមួយឡើយ ។ ឥឡូវនេះ លោកអាចារ្យកាលសម្ដែងការមាននៃអវិជ្ជានោះ ទើបពោលថា **ការមិនដឹងរបស់បុគ្គលណាមិនទាន់លះបាន** ។ ដោយពាក្យនោះ លោករមែងសម្ដែងថា ការមិនរលត់ដោយមគ្គ ជាការមានអវិជ្ជាក្នុងទីនេះ មិនមែនជាការទ្រទ្រង់ប៉ុណ្ណោះទេ ។ សេចក្ដីនេះ ខ្ញុំបានអធិប្បាយទុកហើយខាងដើមនោះឯង ។ ដោយពាក្យថា **អវិជ្ជាសង្ខាតំ** ប្រែថា ដែលហៅថា អវិជ្ជានេះ លោកបដិសេធដល់ការមិនមាននៃញាណជាដើម ។ **អ** អក្ខរៈនេះ រមែងប្រាកដក្នុងអត្ថថា បដិសេធការប្រកបដោយវត្ថុនោះ ដូចក្នុងពាក្យជាដើមថា **អហេតុកា ធម្មា** ប្រែថា ធម៌ដែលមិនមានហេតុ **អភិក្ខុកោ អាវាសោ** វត្តដែលមិនមានភិក្ខុនៅ ។ ការមិនមាន លោកសម្ដែងទុកក្នុងមាតិកានេះ ។ រមែងប្រាកដក្នុងអត្ថថា បដិសេធ ការទាក់ទងជាមួយធម៌នោះ ដូចពាក្យថា **អបច្ចយា ធម្មា** ប្រែថា ធម៌ទាំងឡាយ មិនមានបច្ច័យ ។ ពិតហើយ ធម្មជាតិដែលកើតអំពីបច្ច័យមានការទាក់ទងជាមួយបច្ច័យ ព្រោះដូច្នោះ ទើបមាន ព្រោះជាធម៌កើតអំពីធម៌ដែលមិនមានបច្ច័យ ហេតុនោះ ធម៌ណាមានការទាក់ទងជាមួយបច្ច័យនោះ ទើបលោកធ្វើឲ្យជាក់ច្បាស់ក្នុងទីនេះ ។ រមែងប្រាកដក្នុងអត្ថថា បដិសេធសភាវៈដូច្នោះថា **អនិទស្សនា**

ធម្មា ប្រែថា ធម៌ដែលមិនគួរដល់ការឃើញ ។ ការឃើញបាន បានដល់ សភាវៈដែលគប្បីឃើញ ។ រមែងប្រាកដក្នុងអត្ថថា បដិសេធភាវៈណាដែលគប្បីប្រកាន់នោះ ដូចក្នុងពាក្យថា **អថ ចក្ខុវិញ្ញាណំ និទស្សនំ នបស្សតិ** ប្រែថា បើចក្ខុវិញ្ញាណមិនឃើញភាវៈ ដែលគប្បីឃើញ ។ ម្យ៉ាងទៀត រមែងប្រាកដក្នុងអត្ថថា បដិសេធកិច្ចនោះ ដូចក្នុងពាក្យថា **អនាសវា ធម្មា** ប្រែថា ធម៌ទាំងឡាយមិនមានអាសវៈ ។ ដូចក្នុងពាក្យថា **អប្បដិឃា ធម្មា** ប្រែថា ធម៌ទាំងឡាយប៉ះខ្ទប់មិនបាន ។ **អនារម្មណា ធម្មា** ប្រែថា ធម៌ទាំងឡាយដែលមិនទទួលអារម្មណ៍ ។ រមែងប្រាកដក្នុងអត្ថថា បដិសេធភាវៈនោះ ដូចក្នុងពាក្យថា **អរូបិនោ ធម្មា** ប្រែថា ធម៌ទាំងឡាយមិនមានរូប **អចេតសិកា ធម្មា** ប្រែថា ធម៌ទាំងឡាយដែលមិនមែនចេតសិក ។ កាលកាន់យកអត្ថដោយប្រការដទៃក្រៅអំពីនោះ លោកក៏បានប្រកាសអត្ថទុកក្នុងទីនេះ ។ រមែងប្រាកដក្នុងអត្ថថា ត្រឹមតែភាវៈដូច្នោះ ដូចក្នុងពាក្យថា **អមនុស្សោ** ប្រែថា បុគ្គលនេះមិនមែនមនុស្ស ។ ក្នុងពាក្យថា **អមនុស្សោ** នេះ លោកសំដៅដល់ការដូចគ្នាទុកថា មិនមានត្រឹមតែភាពជាមនុស្សដទៃដូចគ្នា ។ រមែងប្រាកដក្នុងអត្ថថា បុគ្គលដែលគួរលើកតម្កើង ដូច្នោះ ដូចក្នុងពាក្យថា **អស្សមនោ សមណបដិញ្ញោ** ប្រែថា បុគ្គលមិនមែនជាសមណៈតែប្តេជ្ញាថាជាសមណៈ **អបុត្តោ** ប្រែថា បុគ្គលមិនមែនជាបុត្រ ។ កិរិយាដែលនិន្ទារមែងដឹងបានក្នុងទីនេះ ។ រមែងប្រាកដក្នុងអត្ថថា បដិសេធដល់ភាពមិនតិចយ៉ាងនោះ ដូចក្នុងពាក្យថា **កច្ចិ ភោតោ អនាមយំ** ប្រែថា លោកមិនមានរោគភ័យឈឺចាប់ទេឬ **អនុទរា កញ្ញា** ប្រែថា ក្រមុំមានរាង រមែងប្រាកដក្នុងអត្ថថា បដិសេធភាវៈ ដែលដូចគ្នាយ៉ាងនោះ ដូចក្នុងពាក្យថា **អនុប្បន្នា ធម្មា** ប្រែថា ធម៌ដែលមិនកើតឡើង ។ ក៏ព្រោះធម៌ដែលកន្លងទៅហើយ ជាធម៌ដែលធ្លាប់កើតឡើង ព្រោះធម៌ដែលនឹងកើតឡើង ក៏ជាធម៌ដែលផ្តើមនឹងកើតឡើង ដោយការកើតឡើងចំណែកខ្លះនៃបច្ច័យ និង

ព្រោះធម៌ដែលផុតអំពីកាល ជាធម៌ដែលមាន ទើបជាធម៌ដែលអនុគោលដល់ធម៌ដែលកើតឡើងហើយ សម្រាប់ធម៌ដែលជាបច្ចុប្បន្ន មិនមានគោលដែលត្រូវពោលដល់ ព្រោះដូច្នោះ ក្នុងប្រការនេះ ទើបធ្វើឲ្យដឹងភាវៈដែលខុសទៅអំពីធម៌ជាបច្ចុប្បន្ន ។ រមែងប្រព្រឹត្តទៅក្នុងអត្ថថា បដិសេធធម៌ដែលមានធម៌នោះមិនជាទីបំផុត ដូចក្នុងពាក្យថា **អសេក្ខា ធម្មា** ប្រែថា ធម៌ដែលចម្រើនជាងសេក្ខធម៌ ។ ប្រការយល់ព្រមនោះ រមែងប្រាកដក្នុងទីនេះ ។ក៏ព្រោះអត្ថទាំងនេះមិនមាន ពោលដោយបរិសេសន័យ គប្បីជ្រាបថា ធម៌ដែលជាបដិបក្ខចំពោះ **ញាណ** ឈ្មោះថា **អញ្ញាណ** ព្រោះអធិប្បាយថា ធម៌ទាំងឡាយ ដែលជាបដិបក្ខចំពោះកុសល ឈ្មោះថា អកុសល យ៉ាងណា ធម៌ដែលជាបដិបក្ខចំពោះវិជ្ជាក៏ឈ្មោះថា អវិជ្ជា ដូច្នោះ ។

ពាក្យថា **កាន់យកដោយសម្គាល់ថា ជាសុខ** សេចក្តីថា ប្រកាន់មាំសង្ខារទុក្ខដែលវិញ្ញូជនទាំងឡាយ គប្បីកាន់យកថា ជាទុក្ខនោះឯង ព្រោះជាទុក្ខ ទុក្ខសែន ទុក្ខជាវិបរិណាមទុក្ខ ជាទុក្ខព្រោះប្រែប្រួល និងជាសង្ខារទុក្ខ ទុក្ខប្រចាំសង្ខារ ដោយសម្គាល់ថា ជាសុខ ដោយពាក្យនេះ លោកអាចារ្យរមែងសម្តែងដល់ការប្រព្រឹត្តទៅនៃតណ្ហាក្នុងទុក្ខនោះ ។ ពាក្យថា **កកើត** គឺធ្វើឲ្យកើតឡើង ។ បទថា **តណ្ហាបរិក្ខារេ** ប្រែថា ត្រូវតណ្ហាតាក់តែងឡើង អធិប្បាយថា ប្រដាប់ទៅដោយន័យ ដូចពាក្យថា **ជាសុខ ថាស្អាត** ជាដើម ។ ពិតហើយ តណ្ហាជាហេតុនៃទុក្ខ ព្រោះដូច្នោះ បុគ្គលពាលកាលមិនដឹង ទើបក្តៅក្រហាយទៅ ដោយន័យថា **ឱហ្ន៎ អាត្មាអញ កាលបែកកាយស្លាប់ទៅ ក៏គប្បីចូលដល់ការប្រព្រឹត្តទៅរួមគ្នារបស់ខត្តិយមហាសាលទាំងឡាយ** ដូច្នេះ ឈ្មោះថា តាក់តែងកាយសង្ខារឡើង ។ ន័យម្យ៉ាងទៀត បទថា **តណ្ហាបរិក្ខារេ** ប្រែថា ជាបរិវាររបស់តណ្ហា ពិតហើយ សង្ខារទាំងឡាយ កាលតាក់តែងចក្ខុ និងរូបជាដើម ដែលជាទីតាំងនៃតណ្ហា ហើយឲ្យដល់បុគ្គលដែលដល់ព្រមដោយតណ្ហានោះ កាល

នាំចូលទៅរកតណ្ហា រមែងដូចជាបរិវាររបស់តណ្ហានោះឯង ។ **ក្នុងគតិវិសេស** គឺក្នុងព្រហ្មលោកជាដើម ។ **យញ្ញ** មានរាជបេយ្យជាដើម ដែលធ្វើឲ្យសត្វចិញ្ចឹមច្រើនរយក្បាលក័យខ្ទាច ឈ្មោះថា **យញ្ញ** ។ **ទុក្ករកិរិយា** ដែលតែងដឹងថា មានប្រយោជន៍មិនឲ្យស្លាប់ ឈ្មោះថា **អមរតប** ។ ការប្រព្រឹត្តវត្តដែលឲ្យប្រព្រឹត្តទៅ ដោយគិតថា អញគប្បីជាអមតៈ គឺអ្នកមិនស្លាប់ ឬជាទេវៈ ឬជាទេវៈអង្គណាទីមួយ ក៏ឈ្មោះថា **អមរតប** ។ ម្យ៉ាងទៀត តបៈដែលធ្វើឲ្យស្លាប់ គឺជាអ្នកសម្លាប់ ព្រោះជាទុក្ខ ឈ្មោះថា **អមរតប** ។ គប្បីឃើញ **អមរ**-ស័ព្ទ ក្នុង **មរ** គឺស្លាប់ ដូច **អទិដ្ឋ**-ស័ព្ទ ប្រើក្នុង **ទិដ្ឋ** គឺឃើញក៏បាន ។ លោកពោលបុញ្ញាភិសង្ខារ ដូចជា **មរុប្បាត** គឺជ្រោះ ព្រោះធ្វើឲ្យកើតទុក្ខ គឺជ្រោះ មានជាតិជាដើម ។ ដោយពាក្យថា **ធ្វើឲ្យកើតការក្តៅក្រហាយធំ** នេះ លោកអាចារ្យរមែងសម្តែងផលនៃបុណ្យ ដូចជាគប់ភ្លើងស្មៅ ដោយអត្ថថា តាមដុត ។ ដោយ ច-ស័ព្ទ ក្នុងពាក្យថា **អប្បស្សាទតញ្ច** ប្រែថា មានភាពជាគុណមានការត្រេកអរតិចផង លោកអាចារ្យរមែងសង្គ្រោះវិធី មានការយកវត្ថុធ្ងន់សង្កត់ចាក់ទម្លុះរាងកាយ និងទម្លាយអវយវៈតូចធំជាដើម ។ បទថា **តប្បច្ចយំ** ប្រែថា ដែលជាបច្ច័យនៃផលរបស់សុគតិនោះ គឺដែលមានសេចក្តីទុក្ខ ព្រោះការប្រែប្រួលជាសភាវៈផលបុណ្យដែលកាន់យកដោយជាវត្ថុគួរត្រេកអរ និងដោយជាគុណ ដែលគួររីករាយក៏ដូចជាអណ្តាតប្រទីប និងមុខកាំបិតដែលលាបទុកដោយទឹកឃ្មុំ ។ បុញ្ញាភិសង្ខារដែលមានផលបុណ្យនោះជាប្រយោជន៍ លោកពោលថា ដូចការធ្លាក់ចុះទៅក្នុងអណ្តាតប្រទីបនោះ និងដូចការលិទ្ធមុខកាំបិត ដែលលាបដោយទឹកឃ្មុំនោះ ។ ឈ្មោះថា កូនអបុញ្ញាភិសង្ខារដែលគួរខ្ពើម និងជាទុក្ខ ទាំងក្នុងខណៈ ដែលធ្វើក្នុងបច្ចុប្បន្ន និងក្នុងខណៈដែលឲ្យផលក្នុងអនាគត ដូចជាក្មេងតូចលេងលាមក ព្រោះការបរិភោគកាមចំណែកខ្លះ ដោយការកំណត់មិនបានទូវភាពជារបស់មិនស្អាត ដោយសម្គាល់ថា ជាសុខ

ដោយន័យជាដើមថា **ការប៉ះត្រង់ដៃ មានរោមទន់របស់បរិញ្ជិកានេះជាសុខ** និងដូចបុគ្គលដែលត្រូវក្រោធ និងការមិនត្រេកអរគ្របសង្កត់ មិនមានអំណាចរបស់ខ្លួនឯងចង់ស្លាប់ គិតបរិភោគថ្នាំពុល ព្រោះជាបុគ្គលត្រូវកិលេសគ្របសង្កត់ហើយ ។ ម្យ៉ាងទៀត គប្បីប្រកបចិត្តុប្បាទ ដែលសហគតៈដោយលោភៈ ដូចជាការលេងលាមក គប្បីប្រកបចិត្តុប្បាទដែលសហគតៈដោយទោសៈ ដូចការបរិភោគថ្នាំពិស ។ អរូបាវចរវិបាកទាំងឡាយ ដែលមានការផ្លាស់ប្តូរ កាន់យកមិនបាន ព្រោះជាវិបាកដែលជានិរន្តរ ព្រោះការកើតឡើង និងការវិនាសទៅ ដែលចូលទៅកំណត់មិនបាន ជាវត្ថុដែលមានការបន្តគ្នាយូរ សូម្បីជាទុក្ខ ព្រោះការប្រែប្រួលនៃសង្ខារ ក៏ជាហេតុនៃវិបល្លាស គឺការយល់ខុសថា ជាវត្ថុដែលទៀងជាដើម ប្រៀបដូចក្រុងបិសាច សូម្បីប្រកបទៅដោយភ័យ ក៏ជាហេតុនៃវិបល្លាសថាជាសុខ ព្រោះការមាំទាំដោយកាមគុណ ព្រោះដូច្នោះបណ្ឌិតគប្បីប្រកបអរូបាវចរវិបាកទាំងឡាយនោះឲ្យដូចក្រុងបិសាច និងគប្បីប្រកបអនេញ្ជាភិសង្ខារ ដូចជាការបែរមុខទៅកាន់ក្រុងបិសាចនោះ ។

ព្រោះអវិជ្ជាមាននោះឯង ទើបសង្ខារមាន មិនមែនព្រោះមិនមាន ព្រោះហេតុនោះ ទើបលោកអាចារ្យនាំយកបទព្រះសូត្រមក ដោយពាក្យថា **សេចក្តីនេះសមដូចព្រះតម្រាស់ព្រះមានព្រះភាគត្រាស់ទុក** ជាដើម ដើម្បីញ៉ាំងអត្ថដែលលោកបានពោលទុកដោយអនុលោមតាមគ្នា និងដោយភាពពិសេសយ៉ាងសង្ខេប ក្នុងប្រការដែលសង្ខារ មានអវិជ្ជាជាបច្ច័យឲ្យសម្រេចដោយព្រះសូត្រ ។ ក្នុងបណ្តាពាក្យទាំងនេះ ពាក្យថា **បុគ្គលមិនឈ្លាស** គឺបុគ្គលមិនដឹង ។ ពាក្យថា **ធ្លាក់ក្នុងអវិជ្ជា** គឺប្រកបដោយអវិជ្ជា អធិប្បាយថា លះអវិជ្ជាមិនទាន់បាន ។

# វិសុទ្ធិមគ្គ

## បច្ច័យ ២៤

បច្ច័យ ២៤ ព្រះមានព្រះភាគត្រាស់ទុក គឺហេតុប្បច្ច័យ អារម្មណប្បច្ច័យ អធិបតិប្បច្ច័យ អនន្តរប្បច្ច័យ សមនន្តរប្បច្ច័យ សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ ឧបនិស្សយប្បច្ច័យ បុរេជាតប្បច្ច័យ បច្ឆាជាតប្បច្ច័យ អាសេវនៈប្បច្ច័យ កម្មប្បច្ច័យ វិបាកប្បច្ច័យ អាហារប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ ឈានប្បច្ច័យ មគ្គប្បច្ច័យ សម្បយុត្តប្បច្ច័យ វិប្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ នត្ថិប្បច្ច័យ វិគតប្បច្ច័យ អវិគតប្បច្ច័យ ។

## អធិប្បាយ ហេតុប្បច្ច័យ

ក្នុងឧទ្ទេសបទទាំងនោះ ធម៌ដែលបានឈ្មោះថា ហេតុប្បច្ច័យ ព្រោះធម៌នោះជាហេតុផង ជាបច្ច័យផង គឺជាបច្ច័យដោយជាហេតុ អធិប្បាយថា ជាបច្ច័យដោយភាពជាហេតុ ន័យសូម្បីក្នុងឧទ្ទេសបទដទៃ មានអារម្មណប្បច្ច័យជាដើមក៏ន័យដូចគ្នានេះ។

## អធិប្បាយ ហេតុ ស័ព្ទ

ក្នុងបទហេតុប្បច្ច័យនោះ ពាក្យថា ហេតុ ជាពាក្យហៅវចនាវយវៈ ( អវយវៈនៃពាក្យ គឺពាក្យដែលឲ្យដឹងសេចក្តីតែមួយពាក្យ ) និងការណៈ គឺវត្ថុដែលសាងផលមូល គឺវត្ថុដែលជាឫសគល់ ក៏វចនាវយវៈហៅថា ហេតុ ក្នុងផ្លូវលោក ដូចក្នុងពាក្យថា **បដិញ្ញាហេតុ**-ពាក្យប្តេជ្ញា តែក្នុងផ្លូវព្រះសាសនា ការណៈ ហៅថា ហេតុ ដូចក្នុងពាក្យថា **យេ ធម្មា ហេតុប្បភវា**-ធម៌ទាំងឡាយមាន ហេតុ គឺការណៈ ជាដែនកើតមូលក៏ហៅថា ហេតុ ដូចក្នុងពាក្យថា **តយោ កុសលហេតូ តយោ អកុសលហេតូ**

ហេតុ គឺមូលនៃកុសល ៣ ហេតុ គឺមូលនៃអកុសល ៣ មូលនោះឯង បំណងយក ( ហេតុ ) ក្នុងទីនេះ ។

## អធិប្បាយ បច្ច័យ ស័ព្ទ

ចំណែកសេចក្ដីតទៅនេះ ជាអត្ថនៃពាក្យក្នុងពាក្យថា បច្ច័យនេះ ។

ធម៌ ( ដែលជាផល ) ដែលជាផលអាស្រ័យទៅអំពីធម៌ ( ដែលជាហេតុ ) នោះ ដោយអត្ថថា មិនបដិសេធធម៌ ( ដែលជាហេតុ ) នោះឲ្យប្រព្រឹត្តទៅ ហេតុនេះ ទើបធម៌ ( ដែលជាហេតុ ) នោះ ឈ្មោះថា បច្ច័យ ។ មានពាក្យអធិប្បាយថា ក៏ធម៌ ( ដែលជាផល ) ណាអាស្រ័យ គឺមិនបដិសេធនូវធម៌ ( ដែលជាហេតុ ) ណា តាំងនៅ ឬកើតឡើងក្ដីធម៌(ដែលជាហេតុ)នោះឈ្មោះថាជាបច្ច័យនៃធម៌(ដែលជាផល) នោះ តែ ( កាលពោល ) ដោយលក្ខណៈ បច្ច័យ មានឧបការៈជាលក្ខណៈ ព្រោះថា ធម៌ ( ដែលជាហេតុ ) ណា ជាសភាពគាំទ្រ ដើម្បីការតាំងនៅ ឬដើម្បីការកើតឡើង នៃធម៌ ( ដែលជាផល ) ណា ធម៌ ( ដែលជាហេតុ ) នោះ លោកហៅថា ជាបច្ច័យ នៃធម៌ ( ដែលជាផល ) នោះ ។

ពាក្យថា បច្ច័យ ហេតុ ការណៈ និទាន សម្ភវៈ បភវៈជាដើម ដោយសេចក្ដី ក៏ដូចតែគ្នា ផ្សេងគ្នាតែដោយព្យញ្ជនៈ ។

ធម៌ ឈ្មោះថា ហេតុ ព្រោះអត្ថថា ជាមូល ឈ្មោះថា បច្ច័យ ព្រោះអត្ថថា ជាសភាពគាំទ្រ ដូចពោលមកដូច្នេះ ព្រោះហេតុនោះ ( កាលពោល ) ដោយសង្ខេប ធម៌ដែលគាំទ្រ ដោយអត្ថថា ជាមូល ឈ្មោះថា ហេតុប្បច្ច័យ ។

អធិប្បាយរបស់អាចារ្យទាំងឡាយថា ហេតុប្បច្ច័យនោះ ជាសភាពញុំាងភាព ជាកុសលជាដើមឲ្យសម្រេចដល់ ( សម្បយុត្ត ) ធម៌ទាំងឡាយ មានកុសលធម៌ ជាដើម ដូចពូជទាំងឡាយ មានពូជស្រូវសាលីជាដើម ញុំាង ( ភាពជា ) ធញ្ញជាតិ

មានស្រូវសាលីជាអាទិ៍ឲ្យសម្រេច និងដូចពណ៌របស់មណីជាដើម ញុំាងពន្លឺរបស់មណីជាដើមឲ្យសម្រេច ដូច្នោះ តែកាលបើយ៉ាងនោះ ភាពជាហេតុប្បច្ច័យ ក៏មិនសម្រេចទៅដល់ក្នុងរូបទាំងឡាយ ដែលមានហេតុនោះជាសមុដ្ឋាន ព្រោះថា ហេតុប្បច្ច័យនោះ មិនមែនញុំាងភាពជាកុសលជាដើមឲ្យសម្រេចដល់រូបទាំងនោះទេ តែក៏មិនមែនមិនជាបច្ច័យ សមដូចព្រះបាលីថា ហេតុជាបច្ច័យ ដោយហេតុប្បច្ច័យនៃធម៌ទាំងឡាយដែលសម្បយុត្តជាមួយហេតុ និងនៃរូបទាំងឡាយដែលមានហេតុនោះ ជាសមុដ្ឋានដូច្នេះ ។ មួយវិញទៀត សម្រាប់អហេតុកចិត្តទាំងឡាយ ភាពជាអព្យាកតៈ វៀរហេតុនោះចេញក៏សម្រេចបាន ( ព្រោះអព្យាកតៈជាអហេតុកៈ ) សម្រាប់សហេតុកចិត្តទាំងឡាយវិញ ភាពជាកុសលជាដើម ក៏ទាក់ទងដោយយោនិសោមនសិការជាដើម មិនមែនទាក់ទងដោយសម្បយុត្តហេតុ គឺហេតុដែលសម្បយុត្ត និងបើជាកុសលជាដើមមានដោយសភាវៈពិត ក្នុងសម្បយុត្តធម៌ទាំងឡាយសោត ក្នុងសម្បយុត្តធម៌ទាំងឡាយអលោភៈដែលទាក់ទងដោយហេតុ ក៏គប្បីជាកុសលខ្លះ អព្យាកតៈខ្លះបាន តែព្រោះហេតុដែលកើតបានទាំង ២ យ៉ាង ក្នុងសម្បយុត្តធម៌ទាំងឡាយ បើកុសលជាដើម ( ដែលជាប់ដោយហេតុ មិនមែនដោយសភាវៈ ) បានយ៉ាងណា សូម្បីក្នុងហេតុទាំងឡាយ ក៏គប្បីរកភាពជាកុសលជាដើម ( ដែលជាប់ដោយធម៌ដទៃ មិនមែនមានដោយសភាវៈ ) បាន ដូច្នោះ ។

តែសេចក្តីពិត កាលអត្ថថា ជាមូលនៃហេតុទាំងឡាយ បណ្ឌិតមិនកាន់យកថាជាហេតុ ញុំាងភាពជាកុសលជាដើមឲ្យសម្រេច ( តែ ) កាន់យកថាជាហេតុ ញុំាងការតាំងមាំដោយល្អ ( នៃធម៌ទាំងឡាយ ) ឲ្យសម្រេច ក៏មិនខុសអ្វីឡើយ ។ ពិតហើយ ធម៌ទាំងឡាយ ដែលបានហេតុប្បច្ច័យហើយ រមែងជាធម៌មាំទាំ តាំងចុះដោយល្អ ដូចដើមឈើទាំងឡាយដែលមានឫសដុះល្អ ហើយក៏តាំងនៅបានដោយល្អ ដូច្នោះ

(ចំណែក) អហេតុកធម៌ទាំងឡាយ ជាធម៌មិនតាំងមាំដោយល្អ ដូចសារាយទាំងឡាយ មានប្រភេទសារាយតិលពីជកៈ ( សារាយគ្រាប់ល្ង ) ជាដើម ដូច្នោះ ។

ហេតុប្បច្ច័យ ជាធម៌ឧបការៈ ដោយអត្ថថា ជាមូល ដូច្នេះ ព្រោះហេតុនោះ ធម៌ដែលឧបការៈ ដោយញុំាងការតាំងមាំដោយល្អ ( នៃសម្បយុត្តធម៌ ) ឲ្យសម្រេច បណ្ឌិតគប្បីជ្រាបថា ឈ្មោះថា ហេតុប្បច្ច័យ ។

## អធិប្បាយ អារម្មណប្បច្ច័យ

ក្នុងឧទ្ទេសបទបន្ទាំពីនោះទៅ ធម៌ដែលឧបការៈដោយភាពជាអារម្មណ៍ ឈ្មោះថា អារម្មណប្បច្ច័យ ធម៌ណាមួយ នឹងមិនជាអារម្មណប្បច្ច័យនោះមិនមាន ព្រោះពាក្យនិទ្ទេសដើមថា រូបាយតនៈជាបច្ច័យដោយអារម្មណប្បច្ច័យនៃចក្ខុវិញ្ញាណធាតុ ដូច្នេះ ជាដើម តែក៏ចុះក្រោយថា ធម៌ទាំងឡាយណាមួយ ជាចិត្តចេតសិកធម៌ ប្រារព្ធធម៌ណាមួយកើតឡើង ធម៌ទាំងឡាយ ( ដែលត្រូវប្រារព្ធ ) នោះៗ រមែងជាបច្ច័យ ដោយអារម្មណប្បច្ច័យនៃធម៌ ( ដែលកើតឡើង ) នោះៗ ដូច្នេះ ប្រៀបដូចមនុស្សខ្សោយកម្លាំង បានកាន់ឈើច្រត់ ឬខ្សែនោះឯង ទើបក្រោកឡើង និងឈរបាន យ៉ាងណា ចិត្ត និងចេតសិកទាំងឡាយក៏ដូច្នោះ ប្រារព្ធអារម្មណ៍ មានរូបជាដើមនោះឯង ទើបកើតឡើង និងតាំងនៅបាន ព្រោះហេតុនោះ ធម៌ទាំងឡាយ ដែលជាអារម្មណ៍នៃចិត្តចេតសិកទាំងឡាយទាំងពួង បណ្ឌិតគប្បីជ្រាបថា ឈ្មោះថា អារម្មណប្បច្ច័យ ។

## អធិប្បាយ អធិបតិប្បច្ច័យ

ធម៌ដែលឧបការៈដោយភាពជាធំ ឈ្មោះថា អធិបតិប្បច្ច័យៗ នោះ មាន ២ យ៉ាង ដោយអំណាចនៃសហជាតធម៌ និងអារម្មណ៍ ។ ក្នុង ២ យ៉ាងនោះ ធម៌ ៤ ប្រការ គឺ ឆន្ទៈ វីរិយៈ ចិត្ត វិមំសា គប្បីជ្រាបថា ឈ្មោះថា សហជាតាធិបតិ-

បច្ច័យ ( ជាអធិបតិប្បច្ច័យនៃសហជាតធម៌ ) ដោយបាលីថា ឆន្ទាធិបតី ជាបច្ច័យ ដោយអធិបតិប្បច្ច័យនៃធម៌ទាំងឡាយ ដែលសម្បយុត្តជាមួយឆន្ទៈនៃរូបទាំងឡាយ ដែលមានឆន្ទៈនោះជាសមុដ្ឋាន ដូច្នេះជាដើម តែធម៌ទាំង ៤ នោះ មិនបានជាអធិបតីរួមគ្នាទេ ។ ពិតហើយ ក្នុងខណៈណា ចិត្តធ្វើឆន្ទៈឲ្យជាធុរៈ ធ្វើឆន្ទៈឲ្យជាធំប្រព្រឹត្តទៅ ក្នុងខណៈនោះឆន្ទៈតែម្យ៉ាងជាអធិបតី ក្រៅអំពីនេះមិនជាអធិបតីឡើយ ក្នុងធម៌ដ៏សេស (៣ទៀត)ក៏ដូចន័យនេះ ។ចំណែកអរូបធម៌ទាំងឡាយធ្វើធម៌ណាឲ្យធ្ងន់(គឺជាទីគោរព) ប្រព្រឹត្តទៅ ធម៌នោះជាអារម្មណាធិបតីនៃអរូបធម៌ ទាំងឡាយនោះ ហេតុនោះ ទើបលោកពោលពាក្យនិទ្ទេសទុកថា ធម៌ទាំងឡាយណាមួយ ជាចិត្តចេតសិកធម៌ ធ្វើ ( អារម្មណ៍ ) ធម៌ណាមួយ ឲ្យធ្ងន់កើតឡើង ធម៌ ( អារម្មណ៍ ) ទាំងឡាយនោះៗ ជាបច្ច័យ ដោយអធិបតិប្បច្ច័យនៃធម៌ ( ចិត្ត ចេតសិក ) ទាំងឡាយនោះ ដូច្នេះ ។

## អធិប្បាយ អនន្តរប្បច្ច័យ សមនន្តរប្បច្ច័យ

ធម៌ដែលឧបការៈ ដោយភាពជាធម៌ មិនមានចន្លោះ ( ឃាំង ) ឈ្មោះថា អនន្តរប្បច្ច័យ ធម៌ដែលឧបការៈដោយភាពជាធម៌ជិតបំផុត ឈ្មោះថា សមនន្តរប្បច្ច័យ អាចារ្យទាំងឡាយអធិប្បាយបច្ច័យគូនេះទុកច្រើនប្រការ តែសេចក្តីតទៅនេះ ជាខ្លឹមសារក្នុងបច្ច័យគូនេះ ។

ចិត្តនិយាម ( ផ្លូវរបស់ចិត្ត ) ជាដើមថា មនោធាតុមានក្នុងលំដាប់នៃចក្ខុវិញ្ញាណ មនោវិញ្ញាណធាតុមានក្នុងលំដាប់នៃមនោធាតុ ដូច្នេះ ចិត្តនិយាមនោះ រមែងសម្រេចដោយអំណាចនៃចិត្តដូងមុនៗ ប៉ុណ្ណោះ មិនមែនសម្រេច ដោយប្រការដទៃឡើយ ហេតុណា ព្រោះហេតុនោះ ធម៌ដែលអាចក្នុងការញ៉ាំងចិត្តុប្បាទដែលគួគ្នាឲ្យកើតឡើង ក្នុងលំដាប់នៃខ្លួនរៀងៗ ខ្លួន ឈ្មោះថា អនន្តរប្បច្ច័យ ព្រោះដូច្នោះឯង ទើបលោកពោលថា បទថា **អនន្តរប្បច្ច័យ** សេចក្តីថា ចក្ខុវិញ្ញាណធាតុ និងធម៌ទាំងឡាយ ដែល

សម្បយុត្តជាមួយចក្ខុវិញ្ញាណធាតុនោះ ជាបច្ច័យដោយអនន្តរប្បច្ច័យនៃមនោធាតុ នៃធម៌ទាំងឡាយដែលសម្បយុត្តជាមួយមនោធាតុនោះ ដូច្នេះជាដើម អនន្តរប្បច្ច័យយ៉ាងណា សមនន្តរប្បច្ច័យក៏ដូច្នោះឯង ។ មែនហើយ សេចក្តីផ្សេងគ្នាក្នុងបច្ច័យគូនេះ មានត្រឹមតែព្យញ្ជនៈប៉ុណ្ណោះ ដូចសេចក្តីផ្សេងគ្នាត្រឹមតែព្យញ្ជនៈ ក្នុងស័ព្ទឧបចយ គឺចម្រើនឡើង និងសន្តតិ គឺជាប់បន្ត និងក្នុងស័ព្ទ គូ គឺអធិវចនៈ ( ពាក្យហៅ ) និង និរុត្តិ គឺពាក្យពោល ដូច្នោះ តែមិនមែនសេចក្តី ផ្សេងគ្នាដោយអត្ថឡើយ ។

ចំណែកមតិរបស់អាចារ្យទាំងឡាយថា ធម៌ដែលឈ្មោះថា អនន្តរប្បច្ច័យ ព្រោះជាធម៌មិនមានចន្លោះដោយអត្ថ ( គឺមិនមានអ្វីជាំងទៃរាំង ) ឈ្មោះថា សមនន្តរប្បច្ច័យ ព្រោះជាធម៌មិនមានចន្លោះដោយកាល ( គឺមិនមានកាលឃាំង ) ដូច្នេះ មតិនោះខុសចាកបាលីថា កាលព្រះយោគាវចរចេញចាកនិរោធ នេវសញ្ញានាសញ្ញាយតនកុសលរមែងជាបច្ច័យ ដោយសមនន្តរប្បច្ច័យនៃផលសមាបត្តិ ដូច្នេះជាដើម ។

ក្នុងការដែលជាសមនន្តរប្បច្ច័យ ព្រោះជាធម៌មិនមានចន្លោះនោះ អាចារ្យទាំងឡាយពោលពាក្យណាថា ការដែលធម៌នោះជាធម៌អាចក្នុងការញ៉ាំងធម៌ទាំងឡាយឲ្យតាំងឡើង មិនបានសាបសូន្យទៅ តែព្រោះកម្លាំងនៃភាវនានោះឃាំងទុកធម៌ទាំងឡាយដែលជាសមនន្តរ ទើបកើតឡើងមិនបាន ដូច្នេះ សូម្បីពាក្យនោះ ក៏នៅញ៉ាំងការមិនមាននៃភាពជាកាលានន្តរ គឺមិនមានរវាងដោយកាលនោះឯង ឲ្យសម្រេច ( គឺពិសោធឲ្យឃើញថា ភាពជាកាលានន្តរមិនមាននោះឯង ) ព្រោះភាពជាកាលានន្តរក្នុងធម៌នោះមិនមាន ដោយកម្លាំងនៃភាវនា ព្រោះហេតុនោះ ទើបខ្ញុំបញ្ជាក់ពាក្យនោះឯង ( គឺកាលានន្តរមិនមាន ) ហេតុណា ភាពជាកាលានន្តរមិនមាន ព្រោះហេតុនោះ ការដែលធម៌នោះជាសមនន្តរប្បច្ច័យ ក៏ប្រើមិនបានផង ព្រោះថា ការឃើញរបស់លោកទាំងឡាយថា ធម៌ ឈ្មោះថា ជាសមនន្តរប្បច្ច័យនៃធម៌ទាំងឡាយនោះ ព្រោះភាព

ជាធម៌មិនមានចន្លោះដោយកាល ( ដូច្នេះ ) ។

ព្រោះហេតុនោះ លោកទាំងឡាយកុំធ្វើការប្រកាន់មាំ (ការឃើញ) ទៅឡើយ គប្បីជឿចុះថា សេចក្តីផ្សេងគ្នានៃបច្ច័យគូនេះត្រឹមតែដោយព្យញ្ជនៈប៉ុណ្ណោះ មិនមែនផ្សេងគ្នាដោយអត្ថទេ ផ្សេងគ្នាដោយព្យញ្ជនៈដូចម្តេច ? ផ្សេងគ្នាប៉ុណ្ណោះ គឺ

ចន្លោះនៃធម៌ទាំងនោះមិនមាន ហេតុនេះ ទើបធម៌ទាំងនោះ ឈ្មោះថា អនន្តរ ( មិនមានចន្លោះ ) ។

ធម៌ទាំងនោះ ឈ្មោះថា អនន្តរយ៉ាងល្អ ព្រោះមិនមានឈប់ ឬផ្អាក ហេតុនេះ ទើបធម៌ទាំងនោះ ឈ្មោះថា សមនន្តរ ។

# អធិប្បាយ សហជាតបច្ច័យ

ធម៌ដែលឧបការៈ ដោយភាពជាធម៌ដែលកាលកើតឡើង ក៏ញុំាងធម៌ដទៃឲ្យកើតឡើងព្រមគ្នាផង ឈ្មោះថា សហជាតបច្ច័យ ដូចប្រទីបជាបច្ច័យដោយញុំាងពន្លឺឲ្យកើតឡើងព្រមគ្នា ដូច្នោះ សហជាតបច្ច័យនោះមាន ៦ យ៉ាង ដោយអំណាចនៃអរូបក្ខន្ធជាដើម ដូចបាលីថា ខន្ធ ៤ ដែលមិនមានរូប ជាបច្ច័យដោយសហជាតបច្ច័យនៃគ្នានឹងគ្នា មហាភូតរូប ៤ ជាបច្ច័យដោយសហជាតបច្ច័យនៃគ្នានឹងគ្នា នាម និងរូបក្នុងខណៈឈានចុះ ( កាន់គភ៌ ) ជាបច្ច័យដោយសហជាតបច្ច័យដល់គ្នានឹងគ្នា ចិត្ត និងចេតសិកធម៌ទាំងឡាយ ជាបច្ច័យដោយសហជាតបច្ច័យនៃរូបទាំងឡាយដែលមានចិត្តជាសមុដ្ឋាន មហាភូតទាំងឡាយជាបច្ច័យដោយសហជាតបច្ច័យនៃឧបាទាយរូបទាំងឡាយ ធម៌មានរូបទាំងឡាយពួកខ្លះជាបច្ច័យ ដោយសហជាតបច្ច័យ នៃធម៌មិនមានរូបទាំងឡាយក្នុងកាលខ្លះ គ្រាខ្លះ ជាបច្ច័យ មិនមែនដោយសហជាតបច្ច័យ ពាក្យក្រោយ ( គឺធម៌មានរូប ) នេះ លោកពោលសំដៅយកហទយវត្ថុតែម្យ៉ាង ។

## អធិប្បាយ អញ្ញមញ្ញប្បច្ច័យ

ធម៌ដែលឧបការៈ ដោយការដែលញ៉ាំងគ្នានឹងគ្នាឲ្យកើត និងគាំទ្រទ្រូវគ្នានឹងគ្នា ឈ្មោះថា អញ្ញមញ្ញប្បច្ច័យ ដូចឈើ ៣ កំណាត់ ( តាំងនៅអាស្រ័យគ្នា ) ទល់គ្នានឹងគ្នាទុក ដូច្នោះ អញ្ញមញ្ញប្បច្ច័យនោះ មាន ៣ យ៉ាង ដោយអំណាចអរូបក្ខន្ធជាដើម ដូចបាលីថា ខន្ធ ៤ ដែលមិនមានរូបជាបច្ច័យដោយអញ្ញមញ្ញប្បច្ច័យ មហាភូត ៤ ជាបច្ច័យ ដោយភាពជាអញ្ញមញ្ញប្បច្ច័យ នាម និងរូបក្នុងខណៈឈានចុះ ( កាន់គភ៌ ) ជាបច្ច័យដោយអញ្ញមញ្ញបច្ច័យ ។

## អធិប្បាយ និស្សយប្បច្ច័យ

ធម៌ដែលឧបការៈ ដោយអាការជាទីតាំង និងដោយអាការជាទីអាស្រ័យ ឈ្មោះថា និស្សយប្បច្ច័យ ដូចផែនដី និងផ្ទាំងសំពត់ជាដើម ជាទីតាំង និងជាទីអាស្រ័យនៃដើមឈើ និងចិត្រកម្មជាអាទិ៍ ដូច្នោះ និស្សយប្បច្ច័យនោះ គប្បីជ្រាបតាមន័យសេចក្តីដែលពោលក្នុងសហជាតប្បច្ច័យនោះឯងថា ខន្ធ ៤ ដែលមិនមានរូបជាបច្ច័យដោយនិស្សយប្បច្ច័យនៃគ្នានឹងគ្នា ដូច្នេះជាដើមចុះ តែកោដ្ឋាស ( ចំណែកទី ៦ ក្នុងបច្ច័យនេះ លោកចែកទុកដូច្នេះថា ចក្ខាយតនៈជាបច្ច័យ ដោយនិស្សយប្បច្ច័យនៃចក្ខុវិញ្ញាណធាតុ និងធម៌ទាំងឡាយដែលសម្បយុត្តជាមួយ ចក្ខុវិញ្ញាណធាតុនោះ សោតាយតនៈ... ឃានាយតនៈ... ជិវ្ហាយតនៈ... កាយាយតនៈ ជាបច្ច័យដោយនិស្សយប្បច្ច័យនៃកាយវិញ្ញាណធាតុ និងធម៌ទាំងឡាយដែលសម្បយុត្តជាមួយកាយវិញ្ញាណធាតុនោះ មនោធាតុ និងមនោវិញ្ញាណធាតុអាស្រ័យរូបណាប្រព្រឹត្តទៅ រូបនោះជាបច្ច័យ ដោយនិស្សយប្បច្ច័យនៃមនោធាតុ និងមនោវិញ្ញាណធាតុ និងធម៌ទាំងឡាយដែលសម្បយុត្តជាមួយមនោវិញ្ញាណធាតុនោះ... ។

# អធិប្បាយ ឧបនិស្សយប្បច្ច័យ

ចំណែកក្នុងបទថា ឧបនិស្សយប្បច្ច័យនេះ គប្បីជ្រាបអត្ថនៃពាក្យនេះមុន ធម៌ដែលផលនៃខ្លួនអាស្រ័យ គឺមិនបដិសេធ ដោយមានការប្រព្រឹត្តទៅជាប់ដោយធម៌ (ដែលជាហេតុ) នោះ ព្រោះហេតុនេះ ទើបធម៌ (ដែលជាហេតុ) នោះ ឈ្មោះថា និស្សយ (ជាទីដែលផលនៃខ្លួនអាស្រ័យ) ។ (ឧប-ស័ព្ទ ក្នុងបទឧបនិស្សយនោះមានអត្ថថា ក្រៃលែង ឬធ្ងន់) ដូចការចង្អៀតចិត្តខ្លាំង ឈ្មោះថា ឧបាយាស យ៉ាងណា ធម៌ជាទីដែលផលនៃខ្លួនអាស្រ័យយ៉ាងក្រៃលែង ក៏ឈ្មោះថា ឧបនិស្សយ ដូច្នោះ ពាក្យថា ឧបនិស្សយនោះ ជាឈ្មោះនៃហេតុដែលមានកម្លាំង (ហេតុដ៏ខ្លាំងក្លា) ព្រោះហេតុនោះ ធម៌ដែលឧបការៈ ដោយភាពជាហេតុមានកម្លាំង គប្បីជ្រាបថា ឈ្មោះថា ឧបនិស្សយប្បច្ច័យ ។

ឧបនិស្សយប្បច្ច័យនោះ មាន ៣ យ៉ាង គឺអារម្មណូបនិស្សយ អនន្តរូបនិស្សយ បកតូបនិស្សយ ។

# អារម្មណូបនិស្សយ

ក្នុងឧបនិស្សយប្បច្ច័យ ៣ នោះ លំដាប់ដំបូង អារម្មណូបនិស្សយ លោកចែកទុក (ដោយ) មិនធ្វើសេចក្ដីផ្សេងគ្នាជាមួយអារម្មណាធិបតី (ការមានអារម្មណ៍ជាធំ) ឡើយ ដោយន័យថា ការកបុគ្គលឲ្យទានហើយ សមាទានសីលហើយ ធ្វើឧបោសថកម្មហើយ បច្ចវេក្ខណៈដល់កុសលកម្មដែលពោលនោះ (ដោយ) ធ្វើ (កុសលកម្មនោះ) ឲ្យធ្ងន់ (គឺជាធំជាសំខាន់) បច្ចវេក្ខណៈដល់កុសលកម្មទាំងឡាយ ដែលបានប្រព្រឹត្តមកល្អ ហើយក្នុងកាលមុន ដោយធ្វើកុសលកម្មនោះឲ្យធ្ងន់ ចេញចាកឈានហើយ ពិចារណាអង្គឈាន ដោយធ្វើឈាននោះឲ្យធ្ងន់ ព្រះសេក្ខបុគ្គលទាំងឡាយ ពិចារណា

គោត្រភូ ដោយធ្វើគោត្រភូនោះឲ្យធ្ងន់ ពិចារណាវោទាន គឺការផូរផង់នៃចិត្ត ដោយធ្វើវោទាននោះឲ្យធ្ងន់ ព្រះសេក្ខបុគ្គលទាំងឡាយចេញអំពីមគ្គ ហើយពិចារណាមគ្គ ដោយធ្វើមគ្គនោះឲ្យធ្ងន់ ដូច្នេះជាដើម ។

ក្នុងអារម្មណ៍ទាំងនោះ ចិត្ត និងចេតសិកទាំងឡាយ ធ្វើអារម្មណ៍ណាឲ្យធ្ងន់ កើតឡើង អារម្មណ៍នោះ ដោយនិយមក៏រាប់ជាអារម្មណ៍មានកម្លាំងក្នុងអារម្មណ៍ទាំងនោះ ដោយប្រការដូចពោលមកនេះ សេចក្តីផ្សេងគ្នានៃអារម្មណ៍ទាំងនោះ គប្បីជ្រាប ដូច្នេះថា រាប់ថា ជាអារម្មណាធិបតី ដោយអត្ថថា ត្រឹមតែជាអារម្មណ៍ដែលគប្បីធ្វើឲ្យធ្ងន់ រាប់ថា ជាអារម្មណូបនិស្សយ ដោយអត្ថថា ជាអារម្មណ៍ដែលជាហេតុមានកម្លាំង ។

## អនន្តរូបនិស្សយ

សូម្បីអនន្តរូបនិស្សយ លោកចែកទុកដោយមិនធ្វើសេចក្តីផ្សេងគ្នាជាមួយអនន្តរប្បច្ច័យដូចគ្នា ដោយន័យថា ខន្ធទាំងឡាយដែលជាកុសលមុនៗ រមែងជាបច្ច័យដោយឧបនិស្សយប្បច្ច័យនៃខន្ធទាំងឡាយដែលជាកុសលក្រោយៗ ដូច្នេះជាដើម តែក្នុងមាតិកានិក្ខេប សេចក្តីប្លែកគ្នាក្នុងនិក្ខេបនៃចិត្ត និងចេតសិក (ដែលជាអនន្តរប្បច្ច័យ និងអនន្តរូបនិស្សយ ) ទាំងនោះមានព្រោះអនន្តរប្បច្ច័យ មកដោយន័យថា ចក្ខុវិញ្ញាណធាតុ និងធម៌ទាំងឡាយ ដែលសម្បយុត្តជាមួយចក្ខុវិញ្ញាណធាតុនោះជាបច្ច័យដោយអនន្តរប្បច្ច័យនៃមនោធាតុ និងធម៌ទាំងឡាយដែលសម្បយុត្តជាមួយមនោធាតុនោះ ដូច្នេះជាដើមចំណែកឧបនិស្សយមកដោយន័យថា ធម៌ទាំងឡាយដែលជាកុសលមុនៗ រមែងជាបច្ច័យដោយឧបនិស្សយប្បច្ច័យនៃ ធម៌ទាំងឡាយដែលជាកុសលក្រោយៗ ដូច្នេះជាដើម ។

សម្បីសេចក្ដីប្លែកគ្នាក្នុងនិក្ខេបនោះ ដោយអត្ថក៏ដល់ភាពដូចតែគ្នានោះឯង សម្បីយ៉ាងនោះ សេចក្ដីប្លែកគ្នាក៏នៅមាន គឺភាពជាអនន្តរប្បច្ច័យ គប្បីជ្រាបដោយភាពជាធម៌អាចក្នុងការញ៉ាំងចិត្តុប្បាទដែលគួរដល់លំដាប់របស់ខ្លួនឲ្យប្រព្រឹត្តទៅ ចំណែកភាពជាអនន្តរូបនិស្សយ គប្បីជ្រាបដោយការដែលចិត្តដួងមុនជាហេតុមានកម្លាំងក្នុងការញ៉ាំងចិត្តដួងក្រោយឲ្យកើតឡើង ព្រោះការកើតឡើងនៃចិត្ត វៀរចិត្តជាលំដាប់ចេញ មិនមែនមានដូចចិត្ត ដែលសម្បីវៀរធម៌ត្រឹមតែមួយចេញ ក្នុងធម៌ទាំងឡាយ មានហេតុប្បច្ចយធម៌ជាដើមក៏កើតឡើងបានដូច្នោះទេ ព្រោះហេតុនោះ ទើបអនន្តរូបនិស្សយជាបច្ច័យមានកម្លាំង ដោយប្រការដូចពោលមកនេះ សេចក្ដីផ្សេងគ្នានៃធម៌ ២ យ៉ាងនោះ បណ្ឌិតគប្បីជ្រាបដូច្នេះចុះថា ធម៌ដែលជាអនន្តរប្បច្ច័យដោយអំណាចនៃការអាចញ៉ាំងចិត្តដែលគួរដល់លំដាប់របស់ខ្លួនរៀងៗ ខ្លួន ឲ្យកើតឡើង ជាអនន្តរូបនិស្សយដោយអំណាចនៃភាពជាហេតុមានកម្លាំង ។

## បកតូបនិស្សយ

ចំណែកបកតូបនិស្សយ គប្បីជ្រាប ( ដូចតទៅនេះ ) ថា ឧបនិស្សយដែលធ្វើឡើងយ៉ាងល្អ ឈ្មោះថា បកតូបនិស្សយ ។

បច្ចយធម៌ដែលបុគ្គលសាងឡើងក្នុងសន្តានរបស់ខ្លួនក្ដី បច្ច័យខាងក្រៅមានរដូវនិងភោជនជាដើម ដែលបុគ្គលសេពដោយអំណាចសទ្ធា និងសីលជាដើមក្ដី ឈ្មោះថា បកត ( ធ្វើឡើងយ៉ាងល្អ ) ។

ន័យម្យ៉ាងទៀត ឧបនិស្សយ ដោយប្រក្រតី គឺដោយសភាវៈរបស់ខ្លួននោះឯង ឈ្មោះថា បកតូបនិស្សយ ដោយអត្ថថា មិនលាយឡំដោយអារម្មណូបនិស្សយ និងអនន្តរូបនិស្សយ ។

ប្រភេទដោយអនេកប្បការ នៃបកតូបនិស្សយនោះ គប្បីជ្រាបដោយន័យថា បកតូបនិស្សយ គឺបុគ្គលអាស្រ័យក្រៃលែងនូវសទ្ធាហើយ រមែងឲ្យទាន រមែងសមាទានសីល រមែងធ្វើឧបោសថកម្ម រមែងញ៉ាំងឈានឲ្យកើតឡើង រមែងញ៉ាំងវិបស្សនាឲ្យកើតឡើង រមែងញ៉ាំងមគ្គឲ្យកើតឡើង រមែងញ៉ាំងអភិញ្ញាឲ្យកើតឡើង រមែងញ៉ាំងសមាបត្តិឲ្យកើតឡើង អាស្រ័យក្រៃលែងនូវសីល...នូវសុតៈ...នូវចាគៈ... នូវបញ្ញាហើយ រមែងឲ្យទាន ។បេ។ រមែងញ៉ាំងសមាបត្តិឲ្យកើតឡើង សទ្ធា សីល សុតៈ ចាគៈ បញ្ញា ទើបជាបច្ច័យដោយឧបនិស្សយប្បច្ច័យនៃសទ្ធា សីល សុតៈ ចាគៈ បញ្ញា ដូច្នេះជាដើម ។

ធម៌ទាំងឡាយ មានសទ្ធាជាដើមនេះ ដែលបុគ្គលធ្វើឡើងយ៉ាងល្អផង ជាឧបនិស្សយ ដោយអត្ថថា ជាហេតុមានកម្លាំងផង ដូចពោលមកដូច្នេះ ហេតុនោះទើបបានឈ្មោះថា បកតូបនិស្សយ ។

## អធិប្បាយ បុរេជាតប្បច្ច័យ

ធម៌ដែលឧបការៈដោយសភាពកើតឡើងមុន ហើយប្រព្រឹត្តទៅ ឈ្មោះថា បុរេជាតប្បច្ច័យៗ នោះ មាន ១១ យ៉ាង ដោយភាពជាវត្ថុ និងអារម្មណ៍ក្នុងបញ្ចទ្វារ (ជា ១០) និងហទយវត្ថុ (រួមជា ១១) ដូចបាលីថា ចក្ខាយតនៈជាបច្ច័យដោយបុរេជាតប្បច្ច័យនៃចក្ខុវិញ្ញាណធាតុ និងធម៌ទាំងឡាយដែលសម្បយុត្ត ជាមួយចក្ខុវិញ្ញាណធាតុនោះ សោតាយតនៈ... ឃានាយតនៈ... ជិវ្ហាយតនៈ... កាយាយតនៈ ជាបច្ច័យដោយបុរេជាតប្បច្ច័យនៃកាយវិញ្ញាណធាតុនិងធម៌ទាំងឡាយដែលសម្បយុត្ត ជាមួយកាយវិញ្ញាណធាតុនោះ រូបាយតនៈជាបច្ច័យដោយបុរេជាតប្បច្ច័យនៃចក្ខុវិញ្ញាណធាតុ និងធម៌ទាំងឡាយដែលសម្បយុត្តជាមួយចក្ខុវិញ្ញាណធាតុនោះ សទ្ទាយតនៈ... គន្ធាយតនៈ... រសាយតនៈ... ផោដ្ឋព្វាយតនៈ ជាបច្ច័យ ដោយបុរេជាតប្បច្ច័យនៃ

កាយវិញ្ញាណធាតុ និងធម៌ទាំងឡាយដែលសម្បយុត្តជាមួយ កាយវិញ្ញាណធាតុនោះ រូបាយតនៈ សទ្ទាយតនៈ គន្ធាយតនៈ រសាយតនៈ ផោដ្ឋព្វាយតនៈ ជាបច្ច័យដោយបុរេជាតប្បច្ច័យនៃមនោធាតុ ។ មនោធាតុ និងមនោវិញ្ញាណធាតុ អាស្រ័យរូបណាប្រព្រឹត្តទៅ រូបនោះ គឺហទយវត្ថុជាបច្ច័យ ដោយបុរេជាតប្បច្ច័យនៃមនោធាតុ និងធម៌ទាំងឡាយដែលសម្បយុត្តជាមួយមនោធាតុនោះ ជាបច្ច័យដោយបុរេជាតប្បច្ច័យនៃមនោវិញ្ញាណធាតុ និងធម៌ទាំងឡាយ ដែលសម្បយុត្តជាមួយមនោវិញ្ញាណធាតុនោះក្នុងកាលខ្លះ គឺក្នុងបវត្តិកាល មិនជាបច្ច័យដោយបុរេជាតប្បច្ច័យក្នុងកាលខ្លះ គឺក្នុងចុតិកាល និងបដិសន្ធិកាល ។

## អធិប្បាយ បច្ឆាជាតប្បច្ច័យ

អរូបធម៌ដែលឧបការៈ ដោយភាពជាធម៌ឧបត្ថម្ភរូបធម៌ទាំងឡាយដែលកើតមុន ឈ្មោះថា បច្ឆាជាតប្បច្ច័យ ដូចចេតនា គឺការសង្ឃឹមក្នុងអាហារទំនុកបម្រុងសរីរៈរបស់កូនត្មាតទាំងឡាយ ដូច្នោះ ហេតុនោះ ទើបលោកពោលទុកថា ចិត្ត និងចេតសិកធម៌ទាំងឡាយដែលកើតខាងក្រោយ ជាបច្ច័យដោយបច្ឆាជាតប្បច្ច័យនៃកាយនេះដែលកើតមុន ។

## អធិប្បាយ អាសេវនប្បច្ច័យ

ធម៌ដែលឧបការៈ ដោយអត្ថ គឺអាសេវនៈ ( សេពច្រើន គឺប្រព្រឹត្តរហូតដល់ធ្លាប់ ) ដើម្បីការជំនាញ និងមានកម្លាំងនៃអនន្តរធម៌ ( ធម៌ជាលំដាប់ ) ទាំងឡាយ ឈ្មោះថា អាសេវនប្បច្ច័យ ដូចអភិយោគ (ការប្រកបក្រៃលែង គឺការប្រឹងប្រែង) ផ្នែកមុនៗ ក្នុងការរៀនគម្ពីរជាដើម ( ដើម្បីការស្ទាត់ ក្នុងការរៀនគម្ពីរក្រោយៗ ) ដូច្នោះ ។ អាសេវនប្បច្ច័យនោះចែកជា ៣ យ៉ាង ដោយអំណាចនៃជវនដែលជាកុសល

អកុសល និងកិរិយា ដូចបាលីថា កុសលធម៌ទាំងឡាយមុនៗ ជាបច្ច័យដោយអាសេវនប្បច្ច័យនៃកុសលធម៌ទាំងឡាយក្រោយៗ អកុសលធម៌ទាំងឡាយមុនៗ ជាបច្ច័យដោយអាសេវនប្បច្ច័យនៃអកុសលធម៌ទាំងឡាយក្រោយៗ កិរិយាអព្យាកតធម៌ទាំងឡាយមុនៗ ជាបច្ច័យដោយអាសេវនប្បច្ច័យ នៃកិរិយាអព្យាកតធម៌ទាំងឡាយក្រោយៗ ។

## អធិប្បាយ កម្មប្បច្ច័យ

ធម៌ដែលឧបការៈដោយភាពជាការធ្វើដែលបានដល់ចិត្តប្រយោគ (ការប្រកបផ្លូវចិត្ត គឺចេតនា) ឈ្មោះថា កម្មប្បច្ច័យៗ នោះ មាន ២ ដោយអំណាចនៃកុសលចេតនា និងអកុសលចេតនាដែលប្រព្រឹត្តទៅក្នុងខណៈផ្សេងៗ និងចេតនាទាំងពួងដែលជាសហជាត ដូចបាលីថា កុសលកម្ម និងអកុសលកម្មជាបច្ច័យ ដោយកម្មប្បច្ច័យនៃវិបាកក្ខន្ធទាំងឡាយ និងកដត្តារូប (រូបដែលកើតអំពីកម្ម) ទាំងឡាយផង សហជាតចេតនា ជាបច្ច័យដោយកម្មប្បច្ច័យនៃធម៌ទាំងឡាយ ដែលសម្បយុត្តជាមួយចេតនា និងធម៌ទាំងឡាយដែលមានចេតនានោះជាសមុដ្ឋានផង ។

## អធិប្បាយ វិបាកប្បច្ច័យ

វិបាកធម៌ដែលឧបការៈដោយភាពជាធម៌ស្ងប់ (គឺកម្មដែលធ្វើមកស្រេចហើយ ឬល្អិត ព្រោះដីងលំបាក) មិនមានឧស្សាហ៍ (គឺមិនត្រូវព្យាយាមធ្វើអ្វីទៀត) ដើម្បីជាសភាពស្ងប់ មិនមានឧស្សាហ៍ (គឺត្រូវមានយ៉ាងនោះ មិនមានផ្លូវប្រកែក) ឈ្មោះថា វិបាកប្បច្ច័យ វិបាកធម៌នោះរមែងជាបច្ច័យនៃរូបទាំងឡាយ ដែលមានចិត្តជាសមុដ្ឋានក្នុងបវត្តិកាល និងកដត្តារូបទាំងឡាយក្នុងបដិសន្ធិកាល និងសម្បយុត្តធម៌ទាំងឡាយក្នុងកាលទាំងពួងផង ដូចបាលីថា ខន្ធ ១ ដែលជាវិបាកអព្យាកតៈ ជាបច្ច័យដោយ

វិបាកប្បច្ច័យនៃខន្ធ ៣ និងរូបទាំងឡាយ ដែលមានចិត្តជាសមុដ្ឋាន ។បេ។ ខន្ធ ១ ដែលជាវិបាកអព្យាកតៈជាបច្ច័យ ដោយវិបាកប្បច្ច័យនៃខន្ធ ៣ និងកដត្តារូបទាំងឡាយក្នុងបដិសន្ធិក្ខណៈ ខន្ធ ៣ ជាបច្ច័យ ដោយវិបាកប្បច្ច័យនៃខន្ធ ១ ខន្ធ ២ ជាបច្ច័យដោយវិបាកប្បច្ច័យនៃខន្ធ ២ និងកដត្តារូបទាំងឡាយ ខន្ធទាំងឡាយជាបច្ច័យដោយវិបាកប្បច្ច័យនៃវត្ថុ ( គឺហទយវត្ថុ ) ។

## អធិប្បាយ អាហារប្បច្ច័យ

អាហារ ៤ ដែលឧបការៈ ដោយអត្ថ គឺជាអ្នកឧបត្ថម្ភរូប និងអរូបទាំងឡាយឈ្មោះថា អាហារប្បច្ច័យ ដូចបាលីថា កពឡិង្ការាហារជាបច្ច័យ ដោយអាហារប្បច្ច័យនៃកាយនេះ អាហារទាំងឡាយដែលជាអរូប ( គឺផស្សៈមនោសញ្ចេតនា និងវិញ្ញាណ ) ជាបច្ច័យដោយអាហារប្បច្ច័យនៃសម្បយុត្តធម៌ទាំងឡាយ និងរូបទាំងឡាយ ដែលមានអរូបាហារ ( ទាំង ៣ ) នោះជាសមុដ្ឋាន តែក្នុងបញ្ហាវារៈពោលទុកថា ក្នុងបដិសន្ធិក្ខណៈ អាហារទាំងឡាយ ដែលជាវិបាកអព្យាកតៈជាបច្ច័យដោយវិបាកប្បច្ច័យនៃខន្ធទាំងឡាយដែលសម្បយុត្តជាមួយអាហារនោះ និងកដត្តារូបទាំងឡាយផង ដូច្នេះទៀតផង ។

## អធិប្បាយ ឥន្ទ្រិយប្បច្ច័យ

ឥន្ទ្រិយ ២០ វៀរឥត្ថិន្ទ្រិយ និងបុរិសិន្ទ្រិយ ដែលឧបការៈដោយភាពជាធំ ឈ្មោះថា ឥន្ទ្រិយប្បច្ច័យ ។ ក្នុងឥន្ទ្រិយ ២០ នោះ ឥន្ទ្រិយ ៥ មានចក្ខុន្ទ្រិយជាដើម ជាបច្ច័យនៃអរូបធម៌ទាំងឡាយតែម្យ៉ាង ឥន្ទ្រិយដ៏សេស ( ១៥ ) ជាបច្ច័យនៃរូបធម៌ និងអរូបធម៌ ដូចបាលីថា ចក្ខុន្ទ្រិយជាបច្ច័យដោយឥន្ទ្រិយប្បច្ច័យនៃចក្ខុវិញ្ញាណធាតុ និងធម៌ទាំងឡាយ ដែលសម្បយុត្តជាមួយនឹងចក្ខុវិញ្ញាណធាតុនោះ សោតិន្ទ្រិយ.... ឃានិន្ទ្រិយ.... ជិវ្ហិន្ទ្រិយ.... កាយិន្ទ្រិយ ជាបច្ច័យដោយឥន្ទ្រិយប្បច្ច័យនៃកាយវិញ្ញាណធាតុ និងធម៌

ទាំងឡាយ ដែលសម្បយុត្តជាមួយកាយវិញ្ញាណធាតុនោះ រូបជីវិតិន្ទ្រិយជាបច្ច័យដោយឥន្ទ្រិយប្បច្ច័យនៃកដត្តារូបទាំងឡាយ ឥន្ទ្រិយទាំងឡាយដែលជាអរូប ( ១៤ ) ជាបច្ច័យដោយឥន្ទ្រិយប្បច្ច័យនៃសម្បយុត្តធម៌ទាំងឡាយ និងរូបទាំងឡាយ ដែលមានអរូបិន្ទ្រិយនោះជាសមុដ្ឋានផង តែក្នុងបញ្ហាវារៈពោលទុកថា ក្នុងបដិសន្ធិក្ខណៈ ឥន្ទ្រិយទាំងឡាយ ដែលជាវិបាកអព្យាកតៈ ជាបច្ច័យដោយឥន្ទ្រិយប្បច្ច័យនៃសម្បយុត្តកក្ខន្ធទាំងឡាយ និងកដត្តារូបទាំងឡាយ ដូច្នេះទៀតផង ។

## អធិប្បាយ ឈានប្បច្ច័យ

អង្គឈាន ៧ ( គឺវិតក្ក វិចារៈ បីតិ ឯកគ្គតា សោមនស្ស ទោមនស្ស ឧបេក្ខា ) ដែលផ្សេងគ្នាដោយកុសលឈានជាដើម វៀរលែងវេទនា ២ គឺសុខ ទុក្ខ ក្នុងទ្វិបញ្ចវិញ្ញាណដែលឧបការៈដោយអត្ថ គឺចូលទៅសម្ងឹង ( អារម្មណ៍ និងលក្ខណៈ ) ឈ្មោះថា ឈានប្បច្ច័យ ដូចបាលីថា អង្គឈានទាំងឡាយជាបច្ច័យ ដោយឈានប្បច្ច័យនៃធម៌ទាំងឡាយដែលសម្បយុត្តជាមួយឈាន និងរូបទាំងឡាយ ដែលមានឈាននោះជាសមុដ្ឋានផង តែក្នុងបញ្ហាវារៈពោលទុកថា ក្នុងបដិសន្ធិក្ខណៈ អង្គឈានទាំងឡាយដែលជាវិបាកអព្យាកតៈជាបច្ច័យ ដោយឈានប្បច្ច័យនៃសម្បយុត្តក្ខន្ធទាំងឡាយ និងកដត្តារូបទាំងឡាយផង ដូច្នេះក៏មាន ។

## អធិប្បាយ មគ្គប្បច្ច័យ

អង្គមគ្គ ១០ ( គឺសម្មាទិដ្ឋិ ។បេ។ សម្មាវិមុត្តិ ) ដែលផ្សេងដោយភាពជាកុសលមគ្គ ( គឺជាសម្មត្ត ) ជាដើម ដែលឧបត្ថម្ភ ដោយអត្ថ គឺនាំចេញទៅអំពីវត្ថុណា ក៏ស្រេចតែ ( គឺចាកខុស ឬប្រពៃ ក៏ស្រេចតែមគ្គ ឈ្មោះថា មគ្គប្បច្ច័យ ដូចបាលីថា អង្គមគ្គទាំងឡាយជាបច្ច័យដោយមគ្គប្បច្ច័យនៃធម៌ទាំងឡាយ ដែលសម្បយុត្តជាមួយមគ្គ

និងរូបទាំងឡាយដែលមានមគ្គនោះជាសមុដ្ឋានផង តែក្នុងបញ្ហាវារៈពោលទុកថា ក្នុងបដិសន្ធិក្ខណៈ អង្គមគ្គទាំងឡាយដែលជាវិបាកអព្យាកតៈជាបច្ច័យដោយមគ្គប្បច្ច័យនៃសម្បយុត្តក្ខន្ធទាំងឡាយ និងកដត្តារូបទាំងឡាយផង ដូច្នេះក៏មាន ។

តែឈានប្បច្ច័យ និងមគ្គប្បច្ច័យទាំង ២ នេះ គប្បីជ្រាបថា រមែងមិនមានក្នុងទ្វិបញ្ចវិញ្ញាណ និងអហេតុកចិត្តទាំងឡាយ ។

## អធិប្បាយ សម្បយុត្តប្បច្ច័យ

អរូបធម៌ទាំងឡាយ ដែលឧបការៈដោយភាពជាធម៌ប្រកបគ្នា ពោល គឺមានវត្ថុជាមួយគ្នា មានអារម្មណ៍ជាមួយគ្នា និងកើតជាមួយគ្នា រលត់ជាមួយគ្នា ឈ្មោះថាសម្បយុត្តប្បច្ច័យ ដូចបាលីថា ខន្ធ ៤ ដែលមិនមានរូបជាបច្ច័យ ដោយសម្បយុត្តប្បច្ច័យនៃគ្នានឹងគ្នា ។

## អធិប្បាយ វិប្បយុត្តប្បច្ច័យ

រូបធម៌ទាំងឡាយ ដែលឧបការៈដោយមិនចូលដល់ ( គឺមិនទាក់ទងជាមួយ ) ភាពជាធម៌មានវត្ថុដូចគ្នាជាដើម ជាវិប្បយុត្តប្បច្ច័យនៃអរូបធម៌ទាំងឡាយ សូម្បីអរូបធម៌ទាំងឡាយសោត ក៏ជាវិប្បយុត្តប្បច្ច័យនៃរូបធម៌ទាំងឡាយ ( ដូចគ្នា ) វិប្បយុត្តប្បច្ច័យនោះមាន ៣ ដោយចែកជាសហជាត ( កើតព្រមគ្នា ) បច្ឆាជាត ( កើតក្រោយ ) និងបុរេជាត ( កើតមុន ) សមដូចបាលីថា កុសលក្ខន្ធទាំងឡាយដែលជាសហជាតជាបច្ច័យដោយវិប្បយុត្តប្បច្ច័យនៃរូបទាំងឡាយ ដែលមានចិត្តជាសមុដ្ឋាន កុសលក្ខន្ធទាំងឡាយ ដែលជាបច្ឆាជាត ជាបច្ច័យដោយវិប្បយុត្តប្បច្ច័យនៃកាយនេះ ដែលជាបុរេជាត តែក្នុងសហជាតវិភង្គនៃបទអព្យាកតៈ ពោលទុកថា ក្នុងបដិសន្ធិក្ខណៈ ខន្ធទាំងឡាយ ដែលជាវិបាកអព្យាកតៈ ជាបច្ច័យដោយវិប្បយុត្តប្បច្ច័យ នៃកដត្តារូប

ទាំងឡាយ ខន្ធទាំងឡាយជាបច្ច័យដោយវិប្បយុត្តប្បច្ច័យនៃហទយវត្ថុ ។ ហទយវត្ថុជាបច្ច័យដោយវិប្បយុត្តប្បច្ច័យនៃខន្ធទាំងឡាយ ដូច្នេះខ្លះ ចំណែកដែលជាបុរេជាតគប្បីជ្រាបដោយអំណាចនៃវត្ថុ មានចក្ខុន្ទ្រិយជាដើមប៉ុណ្ណោះ ដូចបាលីថា ចក្ខាយតនៈដែលជាបុរេជាតជាបច្ច័យ ដោយវិប្បយុត្តប្បច្ច័យនៃចក្ខុវិញ្ញាណ ។បេ។ កាយាយតនៈដែលជាបុរេជាត ជាបច្ច័យដោយវិប្បយុត្តប្បច្ច័យនៃកាយវិញ្ញាណ ហទយវត្ថុជាបច្ច័យដោយវិប្បយុត្តប្បច្ច័យនៃខន្ធទាំងឡាយ ដែលជាវិបាកអព្យាកតៈ... ដែលជាកិរិយាអព្យាកតៈ ។បេ។ ហទយវត្ថុជាបច្ច័យ ដោយវិប្បយុត្តប្បច្ច័យនៃកុសលក្ខន្ធទាំងឡាយ ។បេ។ ហទយវត្ថុជាបច្ច័យ ដោយវិប្បយុត្តប្បច្ច័យនៃអកុសលក្ខន្ធទាំងឡាយ ។

# អធិប្បាយ អត្ថិប្បច្ច័យ

ធម៌ដែលឧបការៈ ដោយភាពជាធម៌គាំទ្រនូវធម៌ដូចគ្នា ដោយការដែលមានលក្ខណៈជាបច្ចុប្បន្ន ឈ្មោះថា អត្ថិប្បច្ច័យ មាតិកានៃអត្ថិប្បច្ច័យនោះលោកពោលទុក ៧ ប្រការ ដោយអំណាចនៃអរូបក្ខន្ធ មហាភូត នាមរូប ចិត្ត ចេតសិក មហាភូតរូប អាយតនៈ និងហទយវត្ថុ ដូចបាលីថា ខន្ធ ៤ ដែលមិនមានរូបជាបច្ច័យ ដោយអត្ថិប្បច្ច័យនៃគ្នានឹងគ្នា មហាភូត គឺធាតុ ៤ ជា... អត្ថិប្បច្ច័យនៃគ្នានឹងគ្នា នាមរូបជា... អត្ថិប្បច្ច័យនៃគ្នានឹងគ្នា ក្នុងឱក្កន្តិក្ខណៈ គឺខណៈចុះកាន់គភ៌ ចិត្ត និងចេតសិកធម៌ទាំងឡាយជា... អត្ថិប្បច្ច័យនៃរូបទាំងឡាយដែលមានចិត្តជាសមុដ្ឋាន មហាភូតរូបជា... អត្ថិប្បច្ច័យនៃឧបាទាយរូបទាំងឡាយ ចក្ខាយតនៈជា... អត្ថិប្បច្ច័យនៃចក្ខុវិញ្ញាណធាតុ ។បេ។ កាយាយតនៈជា... អត្ថិប្បច្ច័យនៃកាយវិញ្ញាណធាតុ រូបាយតនៈ ។បេ។ ផោដ្ឋព្វាយតនៈជា... អត្ថិប្បច្ច័យនៃកាយវិញ្ញាណធាតុ និងធម៌ទាំងឡាយដែលសម្បយុត្តជាមួយកាយវិញ្ញាណធាតុនោះ រូបាយតនៈ ។បេ។ ផោដ្ឋព្វាយតនៈជា... អត្ថិប្បច្ច័យនៃមនោធាតុ និងធម៌ទាំងឡាយដែលសម្បយុត្តជាមួយមនោធាតុនោះ មនោធាតុ និងមនោវិញ្ញាណ

ធាតុអាស្រ័យរូប គឺហទយវត្ថុណាប្រព្រឹត្តទៅ រូបនោះជា... អត្ថិប្បច្ច័យនៃមនោធាតុ និងមនោវិញ្ញាណធាតុ និងធម៌ទាំងឡាយ ដែលសម្បយុត្តជាមួយមនោវិញ្ញាណធាតុនោះ តែក្នុងបញ្ហាវារៈដាក់មាតិកាបន្ថែមទៀត គឺសហជាត បុរេជាត បច្ឆាជាត អាហារ ឥន្ទ្រិយ ហើយធ្វើនិទ្ទេស គឺអធិប្បាយក្នុងសហជាតមុន ដោយន័យថា ខន្ធ ១ ជា... អត្ថិប្បច្ច័យនៃខន្ធ ៣ និងរូបដែលមានខន្ធ ៣ នោះជាសមុដ្ឋាន ដូច្នេះជាដើម ។ ឯបុរេជាតធ្វើនិទ្ទេសដោយអំណាចនៃអាយតនៈ មានចក្ខុជាដើម ដែលជាបុរេជាតធម៌ ក្នុងបច្ឆាជាតធ្វើនិទ្ទេស ដោយអំណាចនៃកាយនេះ ដែលជាបុរេជាតជាបច្ច័យនៃចិត្ត និងចេតសិកទាំងឡាយដែលជាបច្ឆាជាត ក្នុងអាហារ និងឥន្ទ្រិយ ធ្វើនិទ្ទេសដូច្នេះថា កពឡិង្ការាហារជា...អត្ថិប្បច្ច័យនៃកាយនេះរូបជីវិតិន្ទ្រិយជា...អត្ថិប្បច្ច័យនៃកដត្តារូបទាំងឡាយ ដូច្នេះ ។

## អធិប្បាយ នត្ថិប្បច្ច័យ

អរូបធម៌ទាំងឡាយដែលរលត់ រលត់ទៅរហ័ស ដែលឧបការៈដោយឲ្យឱកាស ដើម្បីការប្រព្រឹត្តទៅ នៃអរូបធម៌ទាំងឡាយ ដែលកើតក្នុងលំដាប់នៃខ្លួន ឈ្មោះថា នត្ថិប្បច្ច័យ ។ ដូចបាលីថាចិត្ត និងចេតសិកធម៌ទាំងឡាយដែលរលត់ រលត់ទៅរហ័ស ជា... នត្ថិប្បច្ច័យនៃចិត្ត និងចេតសិកធម៌ទាំងឡាយដែលជាបច្ចុប្បន្ន ។

## អធិប្បាយ វិគតប្បច្ច័យ

នត្ថិប្បច្ចយធម៌ទាំងនោះឯង ឈ្មោះថា វិគតប្បច្ច័យ ព្រោះជាធម៌ដែលឧបការៈ ដោយភាពជាធម៌ដែលប្រាសទៅហើយ គឺមិនមាន ដូចបាលីថា ចិត្ត និងចេតសិកធម៌ទាំងឡាយដែលរលត់ រលត់ទៅរហ័សជា... វិគតប្បច្ច័យនៃចិត្ត និងចេតសិកធម៌

ទាំងឡាយដែលជាបច្ចុប្បន្ន ។

## អធិប្បាយ អវិគតប្បច្ច័យ

ម្យ៉ាងទៀត អត្ថិប្បច្ចយធម៌ទាំងឡាយនោះឯង គប្បីជ្រាបថា ឈ្មោះថា អវិគតប្បច្ច័យ ព្រោះជាធម៌ឧបការៈដោយភាពជាធម៌ដែលមិនទាន់ប្រាសទៅ គឺនៅមាន ។

ទុកៈនេះ គឺបច្ច័យគូនេះ ត្រាស់ដោយទេសនាវិលាស គឺការលម្អស្អាតនៃទេសនា ឬដោយអំណាចនៃវេនេយ្យដែលគប្បីទ្រង់ទូន្មានបានដោយទេសនាវិធីនោះ ដូចហេតុវិប្បយុត្តទុកៈ សូម្បីអហេតុកទុកៈ ហើយក៏នៅត្រាស់ទៀត ដូច្នេះឯង ។

# មហាដីកា

## កថាពណ៌នាដោយបច្ច័យក្នុងបដ្ឋាន

សព្ទថា **តាវ** ជានិបាត សម្ព័ន្ធដល់អត្ថដែលគប្បីពោលក្នុងចន្លោះ ដោយ **តាវ** សព្ទនោះ លោកអាចារ្យរមែងសម្តែងពាក្យថា **អវិជ្ជាជាបច្ច័យដល់សង្ខារ** នេះ សម្រេចហើយមុន ចំណែកពាក្យដទៃទៀត គប្បីពោលដូចតទៅនេះ ។ ពាក្យថា **ចំណែកពាក្យនេះ ដែលគប្បីពោល** មានដូច្នេះ លោកអាចារ្យពោលសំដៅដល់អត្ថណា ដើម្បីសម្តែងអត្ថនោះ លោកអាចារ្យកាលធ្វើសេចក្តីនោះនៃអវិជ្ជា ព្រោះឈ្មោះថាធម៌ដែលជាបច្ច័យទាំងឡាយ រមែងជាបច្ច័យដល់ធម៌ពួកណា ឬរមែងជាបច្ច័យដោយប្រការណា ក៏រមែងជាបច្ច័យដោយប្រការច្រើនយ៉ាង ព្រោះធម៌ ទាំង ២ ប្រការនោះមានច្រើន ទើបសួរថា **ជាបច្ច័យដល់សង្ខារពួកណា ដូចម្តេច** ដូច្នេះ លោកពោលសង្ខារទុកច្រើន មានបុញ្ញាភិសង្ខារជាដើម ។ អធិប្បាយថា គប្បីពោលដូច្នេះថា អវិជ្ជាជាបច្ច័យដល់សង្ខារទាំងនោះ មិនមែនដោយប្រការមួយ ដល់សង្ខារទាំងអស់ ព្រោះដូច្នោះ ទើបជាបច្ច័យយ៉ាងនេះដល់សង្ខារទាំងនេះ ។ បទថា **តត្រ** សេចក្តីប៉ុនគ្នានឹង **តស្មឹ យោគ បច្ចយការេ** ប្រែថា ក្នុងអវិជ្ជាជាបច្ច័យនោះ ។ លោកអាចារ្យបានផ្តើមពាក្យបុច្ឆាដោយមិនទូទៅថា **សង្ខារពួកណា** ដូច្នេះដោយពិត សូម្បីដូច្នោះ ពាក្យនេះក៏ជាការចូលទៅកំណត់អត្ថរួមទុកដោយឯកទេស ព្រោះដូច្នោះ គួរពោលអង្គបដិច្ចសមុប្បាទទាំង ១២ ដែលជាធម៌កើតអំពីបច្ច័យ តាមសមគួរដល់ខ្លួន ថាជាបច្ច័យ ព្រោះដូច្នោះ លោកអាចារ្យដើម្បីសម្តែងសេចក្តីនោះ ឬកាលត្រូវសួរអវិជ្ជាជាបច្ច័យប្រាថ្នានឹងវិសជ្ជនាធម៌ដែលជាបច្ច័យ ទាំងអស់ជាបច្ច័យ ដោយការទាក់ទងជាមួយបច្ច័យនោះ ទើបផ្តើមពាក្យថា **ពិតណាស់ ព្រះមានព្រះភាគ** ដូច្នេះជាដើម ដើម្បី

សម្ដែងបច្ច័យទាំងឡាយ តាមន័យរបស់ព្រះបាលីនោះឯងមុន ក្នុងព្រះបាលីនោះភ្ជាប់សេចក្ដីថា **ភគវតា ចតុវីសតិ បច្ចយា វុត្តា** ប្រែថា ព្រះមានព្រះភាគត្រាស់បច្ច័យ ២៤ ទុក ។ អធិប្បាយថា គប្បីជ្រាបអវិជ្ជាជាដើមជាបច្ច័យដោយអំណាចបច្ច័យទាំង ២៤ នោះ ។

ដោយពាក្យនេះថា **ពាក្យនោះ ជាហេតុផង ជាបច្ច័យផង** ក៏គួរមានការកាន់យកហេតុ និងធម៌ដែលជាអធិបតិប្បច្ច័យជាដើម ព្រោះដូច្នោះ លោកអាចារ្យកាលបដិសេធការកាន់យកនោះ ទើបពោលថា **ហេតុ ហុត្វា បច្ចយោ** ប្រែថា ជាបច្ច័យដោយភាពជាហេតុ ។ សូម្បីយ៉ាងនេះក៏ជាការខូចសេចក្ដី គឺហេតុប្បច្ច័យនោះ ព្រោះដូច្នោះ ទើបលោកអាចារ្យពោលទៀតថា **ហេតុភាវេន បច្ចយោតិ វុត្តំ ហោតិ** ប្រែថា មានអធិប្បាយថា ជាបច្ច័យដោយភាពជាហេតុ ។ ដោយពាក្យនោះ លោកអាចារ្យរមែងសម្ដែងថា ក្នុងទីនេះលោកធ្វើការកាន់យកធម៌ដោយស័ព្ទថា ហេតុក៏មិនមែនដោយពិតនោះ លោកកាន់យកភាពផ្សេងគ្នានៃសមត្ថភាពរបស់ធម៌ ។ លោកអាចារ្យសំដៅដល់ហេតុនោះ និងស័ព្ទថា **បច្ច័យ** ជាសមានាធិករណៈ ទើបពោលថា **ហេតុ ច សោ បច្ចយោ ច** ប្រែថា ធម៌នោះជាហេតុផង ជាបច្ច័យផង និងពោលថា **ហេតុ ហុត្វា បច្ចយោ** ប្រែថា ជាបច្ច័យដោយភាពជាហេតុ ។ ព្រោះអធិប្បាយ យ៉ាងនេះក្នុងព្រះបាលីតទៅ ទើបព្រះបរមសាស្ដាត្រាស់ធម៌នោះៗ ជាធម៌ឧបការៈ ដោយឧបការៈ មានហេតុជាដើមនោះៗ ដោយពាក្យមានជាដើមថា គឺហេតុ និងបច្ច័យ ដោយហេតុប្បច្ច័យដល់ធម៌ដែលសម្បយុត្តដោយហេតុ និងដល់រូបដែលមានធម៌សម្បយុត្តដោយហេតុនោះជាសមុដ្ឋាន ។ តែក្នុង **អដ្ឋកថាអភិធម្ម** គប្បីឃើញថា លោកអាចារ្យបានធ្វើការអធិប្បាយភាពអាចនៃធម៌ ដោយធម៌ទាំងឡាយនោះឯង ព្រោះដែលបានឈ្មោះថា សមត្ថភាពនៃធម៌ដទៃអំពីធម៌រមែងមិនមាន ដោយការអធិប្បាយធម្មប្បដ្ឋាន

មានជាដើមយ៉ាងនេះថា **ធម៌ណាមិនបដិសេធធម៌ណា រមែងតាំងនៅ ឬកើតឡើង ធម៌នោះក៏ជាបច្ច័យដល់ធម៌នោះ** និងថា **ធម៌ដែលជាគ្រឿងឧបការៈ ដោយអត្ថថាជាមូល ឈ្មោះថា ហេតុប្បច្ច័យ** ។ ម្យ៉ាងទៀត សូម្បីក្នុងទីនេះ លោកអាចារ្យក៏រមែងសម្ដែងសមត្ថភាពនៃធម៌ ដោយធម៌នោះឯង ថា **ធម៌នោះជាហេតុផង ជាបច្ច័យផង** ។ ព្រោះថា ឧទ្ទេសដែលផ្ដើមថា **ហេតុប្បច្ចយោ** មានធម៌ជាប្រធាន ដូចគ្នានឹងឧទ្ទេសដែលផ្ដើមថា កុសលក៏ទេ ដោយពិតជាធម៌ដែលឧបការៈដល់ធម៌ទាំងឡាយជាប្រធានដូច្នេះឯង ។

ដោយពាក្យថា **ក៏មានន័យនេះដូចគ្នា** នេះ លោកអាចារ្យរមែងសម្ដែងក្នុងមុខដល់បច្ច័យដោយការៈនោះ ក្នុងធម៌ទាំងឡាយ មានអារម្មណ៍ជាដើមថា **អារម្មណ៍នោះផង ជាបច្ច័យផង** ដូច្នោះ ទើបឈ្មោះថា អារម្មណប្បច្ច័យ គឺជាបច្ច័យដោយជាអារម្មណ៍ អធិប្បាយថា ជាបច្ច័យដោយភាពជាអារម្មណ៍ មិនមែនត្រឹមតែកម្មធារយសមាសប៉ុណ្ណោះឡើយ ។

លោកអាចារ្យពោលសំដៅដល់អវយវៈនៃសាធនៈថា **អវយវៈនៃពាក្យ** ពិតហើយ សាធនៈ មានពាក្យជាសភាវៈប្រាកដ គឺលោកបញ្ញត្តថា សាធនៈក្នុងលោក ព្រោះធ្វើឲ្យយល់អត្ថ ដែលមិនទាន់យល់ដល់បុគ្គលដទៃបាន ។ ពិតយ៉ាងនោះ អាចារ្យម្ចាស់លទ្ធិទាំងឡាយ ពោលដល់អវយវៈនៃពាក្យសម្ដីនោះថា មានអវយវៈ ជាលក្ខណៈថាជាសាធនៈ មានពាក្យសម្ដីជាសភាវៈ និងពាក្យសម្ដីទាំងឡាយដែលមានអវយវៈ និងបក្ខជាដើម ឈ្មោះថា សាធនៈ ដូច្នេះ ។ ពាក្យថា **ក្នុងពាក្យថា បដិញ្ញា និងហេតុជាដើម** សេចក្ដីថា បដិញ្ញា ១ ហេតុ ១ ឧទាហរណ៍ ១ ឧបនយ ១ និគមន ១ ។ ពាក្យសម្ដីដែលធ្វើសាធកៈឲ្យសម្រេចដោយវាចាដែលមានហេតុ ដោយឧទាហរណ៍ ឈ្មោះថា **ហេតុ** ។ ម្យ៉ាងទៀត ពាក្យសម្ដីដែលមានការណៈជាលក្ខណៈ ឬសូម្បីដែលមាន

ហេតុ ដែលធ្វើឲ្យដល់ព្រមជាលក្ខណៈឯណានីមួយ ឈ្មោះថា **ការណ** ដូចក្នុងពាក្យមានជាដើមយ៉ាងនេះថា **វិរូបា ហេតុ** ប្រែថា ហេតុដែលខុសរូប ។ ដោយ **អាទិ-**ស័ព្ទ សូម្បីការណៈនោះ ក៏ជាពាក្យដែលគួរទីងរូបរួមទុក ម្យ៉ាងទៀត ពាក្យដែលមានញាបកហេតុជាលក្ខណៈ លោកក៏កាន់យកដោយស័ព្ទថា **អវយវ** នៃពាក្យសម្ពី ។ សូម្បីមូលដែលមានការណៈជាលក្ខណៈ ក៏ជាការណៈដូចគ្នាដោយពិត សូម្បីយ៉ាងនោះ ក្នុងពាក្យថា **ការណ** នេះ លោកកាន់យកបច្ចយហេតុ គឺហេតុដែលជាបច្ច័យ ។ ពាក្យថា **មូល** បានដល់ហេតុហេតុ ព្រោះដូច្នោះ ទើបលោកកាន់យកមូលជាមួយផ្នែក ព្រោះមានសេចក្ដីផ្សេងនៃការណៈជាវិស័យ ។ បទថា **វត្តតិ** ជាពាក្យសម្ដែងអត្ថរបស់បទថា **ឯតិ** នេះ និងបទថា **វត្តតិ** នោះ ក៏ជាពាក្យដែលទូទៅដល់ការកើតឡើងនិងការតាំងនៅ ។ ដោយហេតុនោះឯង លោកអាចារ្យបានពោលថា **រមែងតាំងនៅ ឬរមែងកើតឡើង** ។ បច្ច័យខ្លះជាធម៌ឧបការៈដល់ការតាំងនៅតែម្យ៉ាង ដូចជា **បច្ឆាជាតប្បច្ច័យ** បច្ច័យខ្លះជាធម៌ឧបការៈដល់ការកើតឡើងតែម្យ៉ាង ដូចជា **អនន្តរប្បច្ច័យ** ជាដើម បច្ច័យខ្លះជាធម៌ឧបការៈទាំង ២ យ៉ាង ដូចជា **ហេតុប្បច្ច័យ** ជាដើម ។

ពាក្យថា **មានឧបការៈជាលក្ខណៈ** គប្បីឃើញថា លោកអាចារ្យរមែងសម្ដែងឧបការៈ គឺសមត្ថភាពនៃធម៌ដោយធម្មៈ ។ ឈ្មោះថា **ហេតុ** ព្រោះអត្ថថា ជាទីតាំង គឺឈរនៅចំពោះ ព្រោះហេតុដែលស័ព្ទនៃធាតុទាំងឡាយ មានអត្ថច្រើន **ហិ-**ស័ព្ទ ទើបបណ្ឌិតគប្បីជ្រាបថា មានអត្ថថា ជាទីតាំងចំពោះ ដូចជាស័ព្ទថា **ឫសគល់** ។ ម្យ៉ាងទៀត ធម៌ណារមែងទៅ គឺដល់នូវផលដែលមានធម៌នោះជាបច្ច័យ គឺប្រព្រឹត្តទៅដល់ភាពចម្រើនដុះលូតលាស់ដោយធម៌នេះ ជាធម៌ដែលមានកម្មជាដើមហេតុ ដូចជាដើមឈើដល់នូវការមានផ្លែដោយឫស ដែលនាំឱជាឡើងទៅខាងលើ ព្រោះហេតុនោះក៏ឈ្មោះថា **ហេតុ** ។ វត្ថុណារមែងធ្វើផលរបស់ខ្លួន ហេតុនោះ វត្ថុនោះ ឈ្មោះថា

ការណ ប្រែថា ជាអ្នកធ្វើផល ។ វត្ថុណារមែងប្រគល់ឲ្យ គឺដូចជាបង្ហាញហេតុនោះ វត្ថុនោះឈ្មោះថា **និទាន** ប្រែថា ប្រគល់ឲ្យ ។ វត្ថុនោះរមែងកើតព្រមអំពីធម៌នេះ ហេតុនោះ ធម៌នេះឈ្មោះថា **សម្ភវ** ប្រែថា ជាដែនកើតព្រម ។ ធម្មជាតិរមែងកើតមុនអំពីធម៌នេះ ហេតុនោះ ធម៌នេះឈ្មោះថា **បភវ** ប្រែថា ជាដែនកើតមុន បណ្ឌិតគប្បីជ្រាបសេចក្តីថា ស័ព្ទក្រៅអំពីនេះមានអត្ថ ដូច **បច្ចយ-ស័ព្ទ** និង **ហេតុ-ស័ព្ទ** ។ លោកអាចារ្យកាលសម្តែងថា សូម្បីបើយ៉ាងនេះ ហេតុស័ព្ទក៏មានសេចក្តីផ្សេងគ្នានៃការណៈជាវិស័យ បច្ចយស័ព្ទមានភាពស្មើគ្នានៃការណៈជាវិស័យ ទើបពោលពាក្យជាដើមថា **ដោយអត្ថថា ជាមូល** ។ លោកអាចារ្យកាលសម្តែងការបង្រួញនោះដោយអត្ថថា ហេតុ និងអត្ថថា បច្ច័យ លោកបានពោលទុកដោយអំណាចសេចក្តីពិស្តារខាងដើម ទើបពោលថា **ពោលដោយបង្រួញ ធម៌ដែលឧបការៈ ដោយអត្ថថា ជាមូល ឈ្មោះថា ហេតុប្បច្ច័យ** ។

ដោយពាក្យថា **ហេតុប្បច្ច័យ** នោះ ជាសភាវៈញ៉ាំងភាពជាកុសលជាដើមឲ្យសម្រេច ដូចជាពូជស្រូវសាលីជាដើម **ញ៉ាំងធញ្ញជាតិ មានស្រូវសាលីជាដើមឲ្យសម្រេច** ដូច្នេះជាដើម លោកអាចារ្យរមែងសម្តែងសេចក្តីនេះថា ពូជស្រូវសាលី និងពូជស្រូវធម្មតាជាដើម បណ្តាពូជនោះៗ ពូជស្រូវសាលី និងស្រូវធម្មតាជាដើម ញ៉ាំងភាពធញ្ញជាតិ មានស្រូវសាលី និងស្រូវធម្មតាឲ្យសម្រេច ហើយពណ៌ខៀវជាដើមដែលជាវត្ថុនៃរស្មីកែវមណីជាដើម ក៏ញ៉ាំងរស្មីពណ៌ខៀវជាដើមឲ្យសម្រេចសេចក្តីនេះយ៉ាងណា ហេតុប្បច្ច័យក៏ជាសភាវៈញ៉ាំងភាពជាកុសលជាដើមឲ្យសម្រេចដល់សម្បយុត្តធម៌ទាំងឡាយ ជាមួយខ្លួនតាមសមគួរ ។ ពាក្យថា **របស់អាចារ្យទាំងឡាយ** លោកអាចារ្យពោលសំដៅដល់អាចារ្យឈ្មោះ **រេវតៈ** ។ ពាក្យថា **កាលបើយ៉ាងនោះ** សេចក្តីថា ប្រសិនបើហេតុប្បច្ច័យ ញ៉ាំងភាពជាកុសលស័ព្ទជាដើម

ឲ្យសម្រេចសោត ដូច្នោះ ។ ន **សម្បជ្ជតិ** ប្រែថា មិនសម្រេច ។ ហេតុដែលជាកុសល និងអកុសលមិនគ្រប់គ្រាន់ដើម្បីភាពជាកុសលអកុសលដល់រូប ដែលមានហេតុនោះជាសមុដ្ឋាន សូម្បីហេតុដែលជាអព្យាកតៈ ក៏មិនគ្រប់គ្រាន់ដើម្បីភាពជាអព្យាកតៈដល់រូបដែលមានហេតុនោះជាសមុដ្ឋាន ។ ព្រោះថា សភាវៈនោះឯង រូបនោះក៏ជាអព្យាកតៈ ដូច្នោះ ទើបលោកអាចារ្យពោលថា **ព្រោះថា ហេតុប្បច្ច័យនោះ មិនញុំាងភាពជាកុសលជាដើមឲ្យសម្រេចដល់រូបទាំងនោះឡើយ** ។ ហេតុប្បច្ច័យរមែងជាហេតុនៃរូបទាំងឡាយនោះៗ ឯង ព្រោះដូច្នោះ ទើបលោកអាចារ្យពោលថា **តែមិនមែនមិនជាបច្ច័យ** ។ ឥឡូវនេះ លោកអាចារ្យមានបំណងញុំាងសេចក្តីនោះឲ្យសម្រេចដោយព្រះបាលី ទើបពោលពាក្យជាដើមថា **សមដូចព្រះបាលីដែលត្រាស់ទុក** ដូច្នេះ ។ ពាក្យថា **វៀរចាកហេតុនេះ** សេចក្តីថា វៀរចាកហេតុនេះ ដែលជាគ្រឿងឲ្យសម្រេចជាអព្យាកតៈ ព្រោះជាធម្មជាតិមិនមានហេតុ ជាអព្យាកតៈ ក៏សម្រេចហើយដោយសភាវៈនោះឯង ។

ដោយព្រះបាលីទាំងឡាយជាដើមថា ម្នាលភិក្ខុទាំងឡាយ កាលបុគ្គលធ្វើមនសិការ ដោយឧបាយប្រាជ្ញា កុសលធម៌ទាំងឡាយ ដែលមិនទាន់កើតឡើង ក៏រមែងកើតឡើង ហើយកុសលធម៌ទាំងឡាយ ដែលកើតឡើងហើយ ក៏រមែងចម្រើនក្រៃលែងឡើង ដូច្នេះ ។ ភាវៈដែលជាកុសល ជាវត្ថុដែលទាក់ទងដោយយោនិសោមនសិការទើបសម្រេច ហេតុនោះ ទើបលោកអាចារ្យពោលថា **ភាវៈជាកុសលទាក់ទងដោយយោនិសោមនសិការ** ដូច្នេះ ។ ដោយពាក្យនេះឯង រមែងត្រូវសម្តែងថា ភាវៈដែលជាអកុសល និងអព្យាកតៈ ក៏មិនមែនទាក់ទងដោយហេតុដូចគ្នានឹងសភាវៈ ដែលជាកុសល ។ ចំណែកពាក្យណាដែលអាចារ្យមួយពួក គប្បីសម្គាល់ថា សូម្បីភាវៈដែលហេតុជាសហេតុកៈ ជាកុសលជាដើម ដោយសភាពពិត ដែលដូចគ្នានឹងហេតុ

ជាអហេតុកៈ ជាអកុសល ក៏ជាភាវៈដែលទាក់ទង ដោយហេតុនៃធម៌ដែលសម្បយុត្ត ដោយហេតុនោះដទៃផង ។ ដើម្បីនឹងពោលពាក្យឆ្លើយរបស់ពាក្យនោះ ទើបលោកអាចារ្យពោលពាក្យជាដើម **តើបើ** ដូច្នេះ ។ ពាក្យថា **អលោភៈ ក៏គប្បីជាកុសលខ្លះ អព្យាកតៈខ្លះបាន** សេចក្តីថា បើអលោភៈ ជាកុសលដោយសភាវៈ អលោភៈនោះក៏មិនគប្បីជាអព្យាកតៈ ព្រោះមានកុសលជាសភាវៈ ។ បើអព្យាកតៈក៏មិនគប្បីជាកុសល ព្រោះមានអព្យាកតៈនោះជាសភាវៈ ដូចជាសភាវៈរបស់អលោភៈ មិនមានភាពជាអទោសៈ ។ តែព្រោះហេតុដែលកើត បានទាំង ២ យ៉ាង ដូច្នោះ ទើបគួរស្វែងរកកុសលជាដើម ដែលទាក់ទងដោយធម៌ដទៃ សូម្បីក្នុងហេតុទាំងឡាយ មិនមែនស្វែងរកដោយសភាវៈ ដូចជាគួរស្វែងរកកុសលជាដើម ដែលទាក់ទងដោយហេតុក្នុងសម្បយុត្តធម៌ទាំងឡាយ មានសទ្ធាជាដើមដែលកើតបានទាំង ២ យ៉ាង មិនមែនស្វែងរកដោយសភាវៈ ដូច្នោះ ព្រោះហេតុនោះ ពាក្យណាដែលលោកពោលថា **ជាកុសលជាដើម គប្បីមានបានដោយសភាវៈពិតក្នុងសម្បយុត្តហេតុទាំងឡាយ** ពាក្យនោះ ទើបមិនត្រឹមត្រូវ ។ ភាពជាកុសលជាដើមនោះដែលកំពុងស្វែងរក រមែងជាវត្ថុដែលទាក់ទងដោយយោនិសោមនសិការជាដើម ព្រោះដូច្នោះ ទើបអធិប្បាយថា រមែងត្រូវសម្រេចបានថា ជាកុសលជាដើម ទាក់ទងដោយយោនិសោមនសិការជាដើម ក្នុងសម្បយុត្តធម៌ទាំងឡាយ ដូចជាក្នុងហេតុទាំងឡាយ មិនមែនទាក់ទងដោយហេតុ។

ដោយពាក្យថា **ដូចដើមឈើទាំងឡាយ ដែលមានឫសដុះដាលហើយ** ដូច្នេះនេះ លោកអាចារ្យរមែងបង្ហាញថា ឈ្មោះថា ជាមូលដូចឫសឈើ ។ ដោយហេតុនោះឯង ទើបលោកអាចារ្យពោលថា **ជាហេតុញុំាងការតាំងមាំដោយល្អ ឲ្យសម្រេច** ដូច្នេះ ។ សេចក្តីនេះ ព្រះមានព្រះភាគទ្រង់បានសម្តែងលម្អិតទុក **ក្នុងបញ្ហាវារៈ ៧ ប្រការ** យ៉ាងនេះថា **កុសលធម៌ជាបច្ច័យដល់កុសលធម៌ ១ កុសលធម៌ជាបច្ច័យ**

ដល់អព្យាកតៈ ១ កុសលធម៌ជាបច្ច័យដល់កុសល និងអព្យាកតៈ ១ អកុសលធម៌ជាបច្ច័យដល់អកុសល ១ អកុសលធម៌ជាបច្ច័យដល់អព្យាកតៈ ១ អកុសលធម៌ជាបច្ច័យដល់អកុសល និងអព្យាកតៈ ១ អព្យាកតធម៌ជាបច្ច័យដល់អព្យាកតៈ ១ៗ ចំណែកពាក្យណា ដែលព្រះមានព្រះភាគ ទ្រង់សម្តែងកិច្ចនៃហេតុណាត្រាស់ទុកថា **ហេតូ ហេតុសម្បយុត្តកានំ ធម្មានំ តំ សមុដ្ឋានានញ្ច រូបានំ ហេតុប្បច្ចយេន បច្ចយោ** ប្រែថា ហេតុជាបច្ច័យដោយហេតុប្បច្ច័យដល់ធម៌ ដែលសម្បយុត្តដោយហេតុ និងដល់រូបទាំងឡាយ ដែលមានធម៌ដែលសម្បយុត្ត ដោយហេតុនោះជាសមុដ្ឋាន ដូច្នេះ ក្នុងពាក្យនោះ **ហេតុ**-ស័ព្ទដំបូង ជានិទ្ទេសនៃបច្ចយធម៌ដែលសម្តែងលម្អិតទុកដោយបឋមាវិភត្តិ ដោយហេតុស័ព្ទដំបូងនោះ ព្រះមានព្រះភាគទ្រង់រមែងសម្តែងថា ហេតុស័ព្ទនោះ ជាធម៌ឧបការៈដោយភាពជាហេតុ គឺភាពជាហេតុប្បច្ច័យ ៗ **ហេតុ**-ស័ព្ទទី ២ ជាវិសេសនៈរបស់បច្ចយុប្បន្នធម៌ ដោយហេតុស័ព្ទទី ២ នោះ ព្រះមានព្រះភាគទ្រង់រមែងសម្តែងថា មិនមែនជាហេតុជាបច្ច័យ ដោយហេតុប្បច្ច័យដល់សម្បយុត្តធម៌ពួកណានីមួយឡើយ ដោយពិត ជាហេតុជាបច្ច័យដល់ធម៌ ដែលសម្បយុត្តដោយហេតុប៉ុណ្ណោះ មានពាក្យសួរថា ព្រោះសម្បយុត្តស័ព្ទ ជាស័ព្ទដែលមានការសម្លឹងសូម្បីកាលមិនមានហេតុ ស័ព្ទទី ២ ក៏រមែងឲ្យយល់សេចក្តីនេះថា ជាហេតុជាបច្ច័យដល់ធម៌ដែលសម្បយុត្តជាមួយខ្លួនប៉ុណ្ណោះព្រោះមិនបានសម្តែងលម្អិតធម៌ដទៃ ដែលគប្បីសម្លឹងទុកមិនមែនឬ ? ឆ្លើយថា សេចក្តីនេះមិនមែនជាចំណែកមួយ ៗ ព្រោះហេតុស័ព្ទដែលលោកសម្តែងលម្អិតទុកដោយបឋមាវិភត្តិ ព្រះមានព្រះភាគ ទ្រង់សម្តែងដដែលទុកក្នុងពាក្យនេះថា **ហេតុប្បច្ចយេន បច្ចយោ** ជាបច្ច័យដោយហេតុប្បច្ច័យនោះឯង ទ្រង់កាន់យកក្នុងកាលណា ក៏ជាវិសេសនៈរបស់សម្បយុត្តធម៌ក្នុងកាលនោះក៏ទេ ព្រោះដូច្នោះ ក៏គប្បីជាការកាន់យកធម៌ពួកណានីមួយ ដែលមិនផ្សេងជាមួយ

សម្បយុត្តធម៌ ។ សួរថា កាលពោលថា **អរូបិនោ អាហារា សម្បយុត្តកានំ ធម្មានំ** អាហារ ដែលមិនមានរូបជាបច្ច័យដល់ធម៌ដែលសម្បយុត្តគ្នា និងថា **អរូបិនោ ឥន្ទ្រិយា សម្បយុត្តកានំ ធម្មានំ** ឥន្ទ្រិយដែលមិនមានរូប ជាបច្ច័យដល់ធម៌ទាំងឡាយ ដែលសម្បយុត្តគ្នា ដូច្នេះ សូម្បីវៀរចាកស័ព្ទថា **អាហារ** និងស័ព្ទថា **ឥន្ទ្រិយ** ទី ២ លោករមែងកាន់យកធម៌ ដែលសម្បយុត្តដោយអាហារ និងឥន្ទ្រិយនោះឯង សេចក្តីនេះយ៉ាងណា សូម្បីក្នុងទីនេះ ក៏គួរជាដូច្នោះ មិនមែនឬ ? ឆ្លើយថា មិនមែន ព្រោះមិនមានធម៌ដែលគួរវៀរ ដែលសម្បយុត្តដោយអាហារ និងឥន្ទ្រិយ ពិតហើយ ព្រោះមិនមានធម៌ដែលគួរវៀរ សូម្បីកាលមិនមានស័ព្ទថា **អាហារ** និង **ឥន្ទ្រិយ** ក្នុងពាក្យនោះលោករមែងកាន់យកធម៌ដែលសម្បយុត្តដោយអាហារនិងឥន្ទ្រិយនោះឯងព្រោះហេតុនោះ ទើបលោកមិនធ្វើស័ព្ទថា អាហារ និងឥន្ទ្រិយទី ២ នោះ តែក្នុងទីនេះមានវត្ថុដែលនឹងត្រូវវៀរ ព្រោះហេតុនោះ ទើបត្រូវធ្វើស័ព្ទថា ហេតុទី ២ ទុកផង ។ សួរតទៅថា សូម្បីបើយ៉ាងនេះ ក្នុងពាក្យថា **ហេតូ ហេតុសម្បយុត្តកានំ** ហេតុនោះឯងជាសម្បយុត្តកហេតុ ( ហេតុប្រកប ) ដល់ធម៌ដែលសម្បយុត្តដោយហេតុ ព្រោះដូច្នោះហេតុឯណានីមួយ ក៏ត្រូវជាបច្ច័យដោយហេតុប្បច្ច័យដល់ធម៌ ដែលសម្បយុត្តដោយហេតុឯណានីមួយព្រោះលោកមិនបានធ្វើវិសេសនៈទុកមិនមែនឬ?ឆ្លើយថាមិនត្រឹមត្រូវ ព្រោះលោកពោលហេតុដែលសម្តែងលម្អិតទុក ដោយបឋមាវិភត្តិនោះឯង ដោយជាវិសេសនៈរបស់សម្បយុត្តធម៌ទុកទៀត ។ដើម្បីប្រយោជន៍នេះឯងកាលធម៌សម្បយុត្តដោយហេតុសម្រេចហើយ សូម្បីវៀរចាកហេតុស័ព្ទទី ២ ទើបលោកធ្វើការកាន់យកហេតុស័ព្ទទី ១ នោះទុក ។

នយម្យ៉ាងទៀត កាលមិនមានហេតុស័ព្ទទី ២ ក៏ជាបច្ច័យដោយហេតុប្បច្ច័យដល់ធម៌ដែលសម្បយុត្តជាមួយហេតុបាន តែមិនជាបច្ច័យដល់ហេតុទាំងឡាយឡើយ

ព្រោះដូច្នោះ គួរមានការកាន់យកយ៉ាងនេះ ព្រោះដូច្នោះ ដើម្បីបដិសេធសេចក្ដីនោះ ទើបលោកពោលហេតុស័ព្ទដំបូងនោះទុក ។ ដោយហេតុនោះ រមែងសម្ដែងថា ធម៌ពួកណារមែងបានភាពជាធម៌ដែលសម្បយុត្តដោយហេតុក៏ជាហេតុ ជាបច្ច័យដោយហេតុប្បច្ច័យដល់ធម៌ទាំងឡាយនោះ ដែលជាហេតុដល់ធម៌ទាំងឡាយដទៃផងដែរ ។ តែព្រោះឈាន និងមគ្គដែលជាហេតុ មិនមានការសម្ទឹងដល់ធម៌ដទៃ ដោយត្រឹមតែជាទីតាំងអាស្រ័យ មិនមែនមានការសម្ទឹងដូចអាហារ និងឥន្ទ្រិយនោះឡើយ ដូច្នោះ ទើបលោកធ្វើស័ព្ទ មានហេតុជាដើមទី ២ ទុកក្នុងឈាន និងមគ្គ ដែលជាហេតុទាំងឡាយនេះប៉ុណ្ណោះ ។ ចំណែកអាហារ និងឥន្ទ្រិយ មានការសម្ទឹងដល់ធម៌ ដែលគប្បីនាំមក និងធម៌ដែលគប្បីឲ្យជាធំនោះឯង ព្រោះហេតុនោះ អាហារ និងឥន្ទ្រិយទាំងនោះ សូម្បីវៀរចាកស័ព្ទថា អាហារ និងឥន្ទ្រិយទី ២ ក៏រមែងកំណត់បាននូវធម៌ដែលជាអាហារ និងឥន្ទ្រិយ និងធម៌ដែលសម្បយុត្តគ្នាដទៃ ដែលខ្លួននោះឯង គប្បីនាំមក និងគប្បីជាធំ ព្រោះហេតុនោះ ទើបលោកមិនធ្វើស័ព្ទថា អាហារ និងឥន្ទ្រិយទី ២ នោះទុកក្នុងទីនោះ ។ តែក្នុងទីនេះ ព្រោះហេតុស័ព្ទ កំណត់បច្ចយុប្បន្នធម៌ កំណត់ហេតុដែលសម្បយុត្តជាមួយហេតុ និងជាមួយធម៌ ដែលជាបច្ច័យនោះឯង និងកំណត់ធម៌ពួកដទៃ ទើបមិនមានកិច្ចដោយពិសេសទៀត ព្រោះហេតុនោះ ក្នុងបញ្ហាវារៈ គប្បីឃើញថា លោកមិនបានធ្វើហេតុស័ព្ទទី ២ ទុក ដូចក្នុងពាក្យជាដើមថា **កុសលា ហេតូ សម្បយុត្តានំ ខន្ធានំ** ប្រែថា កុសលហេតុទាំងឡាយ ជាបច្ច័យដល់សម្បយុត្តក្ខន្ធ ។

ពាក្យថា **ដោយភាពជាអារម្មណ៍** គឺដោយជាវិស័យ អធិប្បាយថា ដោយការៈដែលគប្បីតោង ។ ដោយ **បិ**-ស័ព្ទ ក្នុងពាក្យថា **អារភិត្វាបិ** ប្រែថា សូម្បីផ្ដើម លោកអាចារ្យរមែងសម្ដែងអត្ថនោះថា សង្ខតធម៌ អសង្ខតធម៌ និងបញ្ញត្តិធម៌ ៦ យ៉ាង ដោយសេចក្ដីផ្សេងគ្នានៃធម៌ មានរូបជាដើម ធម៌ណាមួយ មិនតាំងនៅក្នុងធម៌មួយ

ឯណានីមួយ មានរូបាយតនៈជាដើម មិនជាអារម្មណប្បច្ច័យ រមែងមិនមាន ព្រោះលោកបានពោលភាពដែលរូបាយតនៈទាំងឡាយ ។បេ។ ធម្មាយតនៈទាំងឡាយ ជាអារម្មណប្បច្ច័យដោយមិននិយមថា **យំ យំ ធម្មំ អារព្ភ** ប្រែថា ប្រារព្ធធម៌ណាមួយដូច្នេះ ។ អារម្មណប្បច្ច័យនេះ ខ្ញុំបានអធិប្បាយហើយខាងដើមនោះឯង ។ បទថា **អាលម្ពិត្វា** ប្រែថា កាន់ ។ ការមិនប្រារព្ធហើយ ប្រព្រឹត្តទៅនោះឯងមិនមាន ព្រោះភាពជាសារម្មណៈ គឺទទួលអារម្មណ៍បាន ដោយចំណែកមួយ ព្រោះហេតុនោះ ទើបលោកពោលថា ប្រារព្ធនោះឯង ។ អារម្មណប្បច្ច័យនេះ គប្បីជ្រាបថា មាន ៩ ប្រការយ៉ាងនេះ គឺ កុសលធម៌ជាបច្ច័យដល់កុសលធម៌ ១ កុសលធម៌ជាបច្ច័យដល់អកុសលធម៌ ១ កុសលធម៌ជាបច្ច័យដល់អព្យាកតធម៌ ១ អកុសលធម៌ជាបច្ច័យដល់អកុសលធម៌ ១ អកុសលធម៌ជាបច្ច័យដល់កុសលធម៌ ១ អកុសលធម៌ជាបច្ច័យដល់អព្យាកតធម៌ ១ អព្យាកតធម៌ជាបច្ច័យដល់អព្យាកតធម៌ ១ អព្យាកតធម៌ជាបច្ច័យដល់កុសលធម៌ ១ អព្យាកតធម៌ជាបច្ច័យដល់អកុសលធម៌ ១ ។

ពាក្យថា **ដោយភាពជាធំ** គឺដោយភាពជាប្រមុខ ។ ពិតហើយ ធម៌ដែលជាធំនៃធម៌ដែលអាស្រ័យខ្លួនទាំងឡាយ ឈ្មោះថា អធិបតី ។ អធិបតីនោះ រមែងប្រព្រឹត្តទៅជាប្រមុខនៃធម៌ទាំងនោះ ។ ធម៌ទាំងឡាយ មានឆន្ទៈជាដើម ជាធុរៈ ជាធំក្នុងចិត្តុប្បាទដែលកើតឡើង ព្រោះបានឧបនិស្ស័យនៃអភិសង្ខារមុនជាដើមថា **អ្វីមិនសម្រេចដល់បុគ្គលដែលមានឆន្ទៈ** ដូច្នេះ ជាធម៌ដែលញ៉ាំងសម្បយុត្តធម៌ ទាំងឡាយឲ្យសម្រេចឲ្យប្រព្រឹត្តទៅក្នុងអំណាច និងសម្បយុត្តធម៌ទាំងឡាយ ក៏រមែងប្រព្រឹត្តទៅដោយអំណាចរបស់ធម៌ មានឆន្ទៈជាដើមនោះ ព្រោះប្រព្រឹត្តទៅតាមធម៌ទាំងនោះ ដោយជាធម៌ មានធម៌ថោកទាបជាដើម ដោយហេតុនោះ ទើបធម៌ទាំងនោះជាអធិបតិប្បច្ច័យ ។ អារម្មណ៍ដែលគប្បីធ្វើឲ្យធ្ងន់ ក៏រមែងជាបច្ច័យដល់ការត្រេកអរ ការពិចារណា និង

មគ្គផលដែលបង្អោនទៅ ទោរទន់ទៅ លំអៀងទៅក្នុងអារម្មណ៍នោះ ដូចឲ្យប្រព្រឹត្តទៅក្នុងអំណាចរបស់ខ្លួន ។ ព្រោះហេតុនោះ ធម៌នេះបណ្ឌិតគប្បីឃើញថា ជាអធិបតិប្បច្ច័យ ព្រោះជាធម៌ឧបការៈជាធំដល់ធម៌ទាំងឡាយដែលអាស្រ័យខ្លួន ។ ពាក្យថា ឆន្ទាធិបតី បានដល់ អធិបតី ពោល គឺឆន្ទៈ ពាក្យនេះជាឈ្មោះនៃកត្តុកម្យតាឆន្ទៈ ដែលកើតឡើងក្នុងកាលដែលចិត្តកើតឡើង ធ្វើឆន្ទៈឲ្យជាធុរៈ ធ្វើឆន្ទៈឲ្យជាធំ ។ ក្នុងអធិបតីធម៌ដ៏សេសក៏មានន័យនេះ ។ សួរថា ព្រោះហេតុអ្វី ក្នុងនិទ្ទេសនៃហេតុប្បច្ច័យ ព្រះមុនីបានត្រាស់ទុកថា **ហេតូ ហេតុសម្បយុត្តកានំ** ប្រែថា ធម៌ដែលជាហេតុ ជាបច្ច័យដល់សម្បយុត្តធម៌ ដោយហេតុយ៉ាងណា ក្នុងនិទ្ទេសនៃអធិបតិប្បច្ច័យ មិនបានត្រាស់ទុកថា **អធិបតី អធិបតិសម្បយុត្តកានំ** ប្រែថា ធម៌ដែលជាអធិបតីជាបច្ច័យដល់ធម៌ដែលសម្បយុត្តដោយអធិបតី ក៏ដូច្នោះ ត្រាស់ទុកដោយន័យ មានពាក្យជាដើមថា **ឆន្ទាធិបតិ ឆន្ទសម្បយុត្តកានំ** ប្រែថា ធម៌ដែលជាឆន្ទាធិបតីជាបច្ច័យដល់សម្បយុត្តធម៌ ដោយឆន្ទៈដូច្នេះវិញ ? ឆ្លើយថា ព្រោះមិនមាននៅក្នុងខណៈជាមួយគ្នា ។ ពិតហើយ ហេតុទាំងឡាយ រមែងជាហេតុប្បច្ច័យក្នុងខណៈជាមួយគ្នា ២ ហេតុខ្លះ ៣ ហេតុខ្លះ ព្រោះមិនបានលះភាពជាធម៌ឧបការៈ ដោយអត្ថថា ជាមូល ។ ចំណែកអធិបតី ជាធម៌ឧបការៈ ដោយអត្ថថា ជាធំ និងជាធំច្រើនជាមួយគ្នា ខណៈជាមួយគ្នាមិនបាន ។ ព្រោះហេតុនោះ ធម៌ មានឆន្ទៈជាដើមនោះ កើតឡើងព្រមគ្នាជាអធិបតិប្បច្ច័យក្នុងខណៈជាមួយគ្នា ទើបមិនមាន ព្រោះហេតុនោះ ទើបមិនត្រាស់ថា **អធបិតី អធិបតិសម្បយុត្តកានំ** ប្រែថា ធម៌ដែលជាអធិបតីជាបច្ច័យដល់សម្បយុត្តធម៌ ដោយអធិបតី ត្រាស់ទុកដោយន័យ មានពាក្យជាដើមថា **ឆន្ទាធិបតិ ឆន្ទសម្បយុត្តកានំ** ប្រែថា ធម៌ដែលជាឆន្ទាធិបតី ជាបច្ច័យដល់ធម៌ដែលសម្បយុត្តដោយឆន្ទៈ ។

ពាក្យថា **ធម៌ណាមួយ** បានដល់ធម៌ គឺអារម្មណ៍ណាមួយ ។ ពាក្យថា **ធ្វើឲ្យធ្ងន់**

គឺឲ្យជាទីធ្ងន់ គឺត្រូវបាន គប្បីលះមិនបាន មើលងាយមិនបាន ដោយអំណាចធ្វើឲ្យជាទីគោរព ធ្វើឲ្យជាទីកោតក្រែង ឬដោយអំណាចការត្រេកអរ ។ ពាក្យថា **ធម៌នោះៗ** គឺធម៌ដែលគប្បីធ្វើឲ្យធ្ងន់នោះៗ ។ ពាក្យថា **ដល់ធម៌នោះៗ** គឺដល់ធម៌ ដែលគប្បីធ្វើឲ្យធ្ងន់នោះៗ ។ ពាក្យថា **ដោយអធិបតិប្បច្ច័យ** គឺដោយអារម្មណាធិបតិប្បច្ច័យ ។ ដោយសង្ខេប អធិបតិប្បច្ច័យនេះ មាន ១០ ប្រការ គឺ

១- កុសលធម៌ ជាបច្ច័យដោយសហជាតប្បច្ច័យ និងអារម្មណប្បច្ច័យដល់កុសល ។

២- កុសលធម៌ ជាបច្ច័យដោយអារម្មណប្បច្ច័យតែម្យ៉ាងដល់អកុសល ។

៣- កុសលធម៌ ជាបច្ច័យដោយសហជាតប្បច្ច័យ និងអារម្មណប្បច្ច័យដល់អព្យាកតធម៌ ។

៤- កុសលធម៌ ជាបច្ច័យដោយសហជាតប្បច្ច័យតែម្យ៉ាង ដល់កុសលធម៌ និងអព្យាកតធម៌ រួមអធិបតិប្បច្ច័យមានកុសលធម៌ដែលធ្ងន់ ៤ ប្រការ ។

៥- អកុសលធម៌ ជាបច្ច័យដោយសហជាតប្បច្ច័យ និងអារម្មណប្បច្ច័យដល់អកុសលធម៌ ។

៦- អកុសលធម៌ ជាបច្ច័យដោយសហជាតប្បច្ច័យតែម្យ៉ាងដល់អព្យាកតធម៌ ។

៧- អកុសលធម៌ ជាបច្ច័យដោយជាសហជាតប្បច្ច័យតែម្យ៉ាងដូចគ្នាដល់អកុសលធម៌ និងអព្យាកតធម រួមអធិបតិប្បច្ច័យ ដែលមានអកុសលជាគោល ៣ ប្រការ ។

៨- អព្យាកតធម៌ ជាបច្ច័យដោយសហជាតប្បច្ច័យ និងអារម្មណប្បច្ច័យដល់អព្យាកតធម៌ ។

៩- អព្យាកតធម៌ ជាបច្ច័យដោយអារម្មណប្បច្ច័យតែម្យ៉ាងដល់កុសលធម៌ ។

១០- អព្យាកតធម៌ ជាបច្ច័យដោយអារម្មណប្បច្ច័យតែម្យ៉ាងដូចគ្នា ដល់អកុសលធម៌ ។

រួមអធិបតិប្បច្ច័យ ដែលមានអព្យាកតធម៌ជាគោល ៣ ប្រការ សូម្បីក្នុងទីនេះក៏គប្បីជ្រាបសហជាតាធិបតី ៧ ប្រការ អារម្មណាធិបតី ៧ ប្រការ ។

វត្ថុណារមែងខណ្ឌ ហេតុនោះ វត្ថុនោះ ឈ្មោះថា **អន្តរ** អធិប្បាយថា ជំទាស់ ។ វត្ថុដែលខណ្ឌមិនមានដល់ធម៌នេះ ហេតុនោះ ធម៌នេះឈ្មោះថា **អនន្តរ** ប្រែថា មិនមានអ្វីខណ្ឌ ធម៌នោះជាបច្ច័យផង មិនមានអ្វីខណ្ឌផង ហេតុនោះឈ្មោះថា **អនន្តរប្បច្ច័យ** ប្រែថា បច្ច័យមិនមានអ្វីរាំង ។ អាចារ្យទាំងឡាយ រមែងពណ៌នាទុកច្រើនប្រការ គឺរមែងធ្វើវិសាលភាពនៃព្រះគម្ពីរ ដែលមិនមានសារៈ ដោយន័យជាដើមថា ធម៌មិនមានអ្វីខណ្ឌ ដោយអត្ថឈ្មោះថា អនន្តរប្បច្ច័យ ធម៌មិនមានអ្វីខណ្ឌដោយកាលឈ្មោះថា **សមនន្តរប្បច្ច័យ** ដូច្នេះ ។ នត្ថិប្បច្ច័យ និងវិគតប្បច្ច័យ លោកពោលទុកថាជាធម៌ផ្សេងគ្នានៃការប្រព្រឹត្តទៅ និងការឲ្យឱកាស យ៉ាងណា លោកពោលអនន្តរប្បច្ច័យ និងសមនន្តរប្បច្ច័យដូច្នោះក៏ទេ ឯអនន្តរប្បច្ច័យ និងសមនន្តរប្បច្ច័យនេះ លោកពោលទុកថាជាធម៌មានចិត្តនិយមជាហេតុ ព្រោះហេតុនោះ លោកអាចារ្យបំណងសម្ដែងនូវធម៌ មានចិត្តនិយមជាហេតុនោះ ទើបផ្ដើមពាក្យជាដើមថា **ចិត្តនិយម** នោះឯណា ។

ដោយ **អាទិ**-សព្ទ ក្នុងបទថា **មនោវិញ្ញាណធាតុតិអាទិ ចិត្តនិយមោ** ប្រែថា ចិត្តនិយម មានមនោវិញ្ញាណធាតុជាដើម លោកអាចារ្យរមែងសម្ដែងថា វោដ្ឋព្វនៈមានក្នុងលំដាប់នៃសន្តីរណៈ បដិសន្ធិ មានក្នុងលំដាប់នៃចុតិ ព្រោះហេតុនោះ ចិត្តណាមួយកើតឡើងក្នុងលំដាប់នៃចិត្តណាមួយ ការកំណត់ការកើតឡើងក្នុងលំដាប់នៃចិត្តនោះៗ រមែងសម្រេចដោយអំណាចចិត្តដួងមុនៗ នោះឯង ដែលផ្សេងគ្នាដោយបច្ច័យ

ដែលផ្ទើរមគ្នានោះៗ ។

ពាក្យថា **ព្រោះជាធម៌មិនមានចន្លោះដោយអត្ថ** គឺជាធម៌មិនមានចន្លោះដោយអត្ថ គឺដោយធម៌ណាមួយ ។ ពាក្យថា **ជាធម៌មិនមានចន្លោះដោយកាល** គឺព្រោះជាធម៌មិនមានចន្លោះដោយភាពផ្សេងគ្នានៃកាល ។ ក្នុងពាក្យថា **របស់អាចារ្យទាំងឡាយ** នេះ លោកអាចារ្យក៏ពោលសំដៅដល់ **លោកអាចារ្យរេវតៈ** នោះឯង ។ បទថា **តត្ថ** សេចក្តីប៉ុនគ្នានឹង **តស្មឹ យោគ កាលានន្តរតាយ សមនន្តរប្បច្ចយភាវេ** ប្រែថា ក្នុងសមនន្តរប្បច្ច័យ ព្រោះជាធម៌មិនមានចន្លោះដោយកាល ឬប៉ុនគ្នានឹង **តស្មឹ យោគ យថាវុត្តវិរោធេ** ប្រែថា ក្នុងការខុសគ្នាតាមដែលពោលហើយ ។ ក្នុងពាក្យថា **ព្រោះកម្លាំងនៃភាវនាពាំងទុក** នេះ មានអធិប្បាយថា ឧបមាដូចកាលយកថ្នុំងចាក់ទម្លុះដើមឈើទុក ការចេញផ្កានៃដើមឈើ ដែលអាចចេញផ្កាបាននោះឯង រមែងមិនមាន តែកាលនាំយកថ្នុំងចាក់ទម្លុះចេញហើយ ការចេញផ្ការមែងមានបាន ព្រោះជាដើមហេតុដែលអាចចេញផ្កាបាននោះឯង សេចក្តីនេះយ៉ាងណា ក្នុងទីនេះក៏មានឧបមេយ្យដូច្នោះ ព្រោះត្រូវកម្លាំងនៃភាវនាពាំងទុក ធម៌ដែលអាចញ៉ាំងធម៌ដទៃឲ្យតាំងឡើងនោះឯង ទើបមិនញ៉ាំងធម៌ដទៃឲ្យកើតឡើង តែកាលកម្លាំងនៃភាវនានោះទៅប្រាសហើយ ការញ៉ាំងធម៌ដទៃតាំងឡើង រមែងមានបាន ព្រោះជាធម៌ដែលអាចនោះឯង ។ ពាក្យនោះ គឺ **កាលានន្តរ** មិនមាន ព្រោះជាធម៌ដែលកាល មានសប្តាហ៍ជាដើមខណ្ឌទុក **ខ្ញុំបានបញ្ជាក់សេចក្តីនេះប៉ុណ្ណោះថា** ជាធម៌ដែល ត្រូវខណ្ឌទុក នៅមានប៉ុណ្ណោះ ។ លោកអាចារ្យកាលញ៉ាំងចិត្តឲ្យប្រព្រឹត្តទៅថា បុគ្គលណាមួយ គប្បីពោលថា ឈ្មោះថា **កាលណាមួយ** ពោលដោយបរមត្ថមិនមានមិនមែនឬ ? ដូច្នេះ ទើបពោលថា **មានលទ្ធិថា អនន្តរប្បច្ច័យរមែងមាន ព្រោះធម៌ទាំងនោះជាកាលានន្តរ** ដូច្នេះ ។

ពាក្យថា **ក្នុងបច្ច័យមួយគូនេះ គប្បីភ្ជាប់សេចក្តីផ្សេងគ្នា ដោយត្រឹមតែព្យញ្ជនៈ**

ប៉ុណ្ណោះ មិនផ្សេងគ្នាដោយអត្ថឡើយ អធិប្បាយថា សេចក្តីផ្សេងគ្នាត្រឹមតែអត្ថនៃសព្ទ ដូចជាបទថា **ឧបចយ** និង **សន្តតិ** និងបទថា **អធិវចន** និង **និរុត្តិ** មិនផ្សេងគ្នាដោយអត្ថដែលគប្បីពោលឡើយ ។ ដោយហេតុនោះឯង ទើបលោកអាចារ្យពោលពាក្យជាដើមថា **សេចក្តីនេះដូចម្តេច** ដើម្បីសម្តែងសេចក្តីផ្សេងគ្នានៃអត្ថរបស់សព្ទ ។ ក្នុងពាក្យនោះ ធម៌ដែលមានសមត្ថភាពឲ្យកើតឡើង មិនមានចន្លោះ ព្រោះមិនមានចន្លោះនៃការរលត់ និងការកើតឡើងរបស់ធម៌ដែលមានមុន និងក្រោយ ឈ្មោះថា **ជាអនន្តរប្បច្ច័យ** ។ ធម៌ដែលអាចឲ្យកើតឡើង ជាធម៌មិនមានចន្លោះ ដោយល្អ ដោយបង្អួនចូលទៅ ហាក់ដូចភាពតែមួយជាមួយខ្លួន ព្រោះមិនមានការញែកគ្នាថា **វត្ថុនេះអំពីនេះទៅ ខាងក្រោម ខាងលើ ជាទទឹង** ហេតុដែលមិនមានសណ្ឋាន ដូចជារូបកលាបៈ និងហេតុដែលមិនមានការតាំងចុះរួមគ្នានៃបច្ចយធម៌ និងធម៌ដែលកើតអំពីបច្ច័យ ។ ពាក្យថា **ជាធម៌មានសមត្ថភាពដែលឲ្យកើតឡើង** សេចក្តីថា កាលអាការណាមួយ របស់ធម៌ទាំងឡាយរលត់ទៅ ព្រោះមិនមានការខ្វល់ខ្វាយ ឬនៅប្រព្រឹត្តទៅ ធម៌ទាំងឡាយដែលមានសេចក្តីផ្សេងគ្នានោះៗ រមែងមានអាការនោះឯងគប្បីឃើញថា លោកពោលទុកដល់អាការនោះ ។ ព្រោះអាស្រ័យត្រឹមតែការប្រព្រឹត្តទៅនៃធម៌ទាំងឡាយនោះឯង ទើបបញ្ញត្តថា កាលឡើងមក ព្រោះហេតុនោះ ចិត្តដែលចេញអំពីនិរោធ ចិត្តដែលចុតិអំពីអសញ្ញីកពនៃនេវសញ្ញានាសញ្ញាយតនៈ និងផលសមាបត្តិ និងចុតិចិត្តដួងមុន និងបដិសន្ធិចិត្តដួងក្រោយ ទើបមិនមានចន្លោះដោយកាល ព្រោះការមិនមានចន្លោះនៃការរលត់ និងការកើត ។ ការប្រព្រឹត្តទៅនៃអរូបធម៌ដែលអាស្រ័យហើយ គប្បីហៅថា ធម៌ជាចន្លោះ នឹងមាននៅក្នុងចន្លោះនៃធម៌ទាំងនោះក៏ទេ ការប្រព្រឹត្តទៅនៃរូបធម៌នឹងធ្វើចន្លោះនៃការប្រព្រឹត្តរបស់អរូបធម៌ ព្រោះមានការបន្តគ្នាដទៃក៏មិនមាន ។ ព្រោះថា រូបសន្តតិ និងអរូបសន្តតិទាំង ២ ប្រព្រឹត្តទៅជាធម៌ឧបការៈគ្នា

នឹងគ្នា ក៏រមែងជាធម៌ប្លែកគ្នានោះឯង ព្រោះជាធម៌មានសភាពមិនដូចគ្នា ។ ធម្មជាតិដែលប្រព្រឹត្តទៅក្នុងចំណោមនៃធម៌មាននៅមុន និងក្រោយក្នុងសន្តតិជាមួយគ្នា ក៏ជាធម្មជាតិធ្វើចន្លោះទុក ព្រោះជាធម្មជាតិទាក់ទងក្នុងសន្តតិនោះ ។ធម្មជាតិដូច្នោះបន្តិចបន្តួចរមែងមិនមានក្នុងចំណោមនៃនេវសញ្ញានាសញ្ញាយតនៈ និងផលសមាបត្តិ ឯសភាវៈជាវត្ថុដែលធ្វើចន្លោះមិនបាន ព្រោះជាការមិនមាននោះឯង ។ ព្រោះហេតុនោះ ព្រោះជាធម៌មិនមានចន្លោះ ក៏គ្រាន់តែជាធម៌ដែលមិនមានចន្លោះដោយល្អ ដូចជាជវនចំពោះជវន និងដូចភវង្គចំពោះភវង្គ ព្រោះហេតុនោះ ក៏គប្បីឃើញនេវសញ្ញានាសញ្ញាយតនៈ និងចុតិ ជាធម៌ដែលអាចញុំាងធម៌ដទៃឲ្យកើតឡើងបានយ៉ាងនោះ ។ ភាពជាបច្ច័យដល់ការកើតឡើងប្រាកដល់បច្ច័យទាំងឡាយ មានអនន្តរប្បច្ច័យជាដើមក្នុងទីនេះ ព្រោះហេតុនោះ ទើបលោកពោលដល់ធម៌ដែលអាចឲ្យកើតឡើងនោះឯង ។ ព្រះមានជោគបានត្រាស់ធម៌ ដែលជាបច្ចុប្បន្នទាំងឡាយ ដែលកាន់យកទីបំផុតខាងដើម និងទីបំផុតខាងចុង នៅមិនទាន់បានពាក្យថា កើតឡើងជាបច្ច័យ មានអនន្តរប្បច្ច័យជាដើម ដោយពាក្យជាដើមថា **ធម៌ជាអតីតជាបច្ច័យដោយអនន្តរប្បច្ច័យដល់ធម៌ ដែលជាបច្ចុប្បន្ន** ដូច្នេះ ព្រោះហេតុនោះ អនន្តរប្បច្ច័យជាដើមនោះ នឹងដឹងថា ព្រោះការកើតប៉ុណ្ណោះ ក៏ទេ ។ ស័ព្ទបច្ចុប្បន្នមិនមានដែនកំណត់ ដូចស័ព្ទថា **កុសល** ជាដើមមិនមាន ។ ដូចជាការកាន់យកធម៌ដែលមានការដល់ព្រម ដោយត្រឹមតែការកើតឡើងប៉ុណ្ណោះ គប្បីមាន ។ ដោយហេតុនោះឯង វារៈទាំងឡាយ មានបដិច្ចវារៈជាដើម ទើបមិនមានក្នុងអតីតត្តិកៈ ដូច្នេះ ។ គប្បីជ្រាបប្រភេទរបស់អនន្តរប្បច្ច័យជាដើមនោះ ៧ ប្រការ គឺ

១- កុសលធម៌ ជាបច្ច័យដល់កុសលធម៌ ។

២- កុសលធម៌ ជាបច្ច័យដល់អព្យាកតធម៌ ។

៣- អកុសលធម៌ ជាបច្ច័យដល់អកុសលធម៌ ។

៤- អកុសលធម៌ ជាបច្ច័យដល់អព្យាកតធម៌ ។

៥- អព្យាកតធម៌ ជាបច្ច័យដល់អព្យាកតធម៌ ។

៦- អព្យាកតធម៌ ជាបច្ច័យដល់កុសលធម៌ ។

៧- អព្យាកតធម៌ ជាបច្ច័យដល់អកុសលធម៌ ។

ក្នុងពាក្យនេះ **ធម៌ដែលកើតឡើង ក៏ញុំាងធម៌ដទៃឲ្យកើតឡើងព្រមគ្នាផង** នេះ បណ្ឌិតគប្បីឃើញថា លោកអាចារ្យរមែងសម្តែងលម្អិតបច្ច័យសូម្បីដល់ការតាំងនៅជាបច្ច័យដល់ការកើតឡើង ដែលប្រាកដហើយ កាលកាន់យកអត្ថដោយប្រការដទៃ ឧទាហរណ៍រឿងប្រទីប ក៏មិនគប្បីសមស្រប ។ ព្រោះថា ប្រទីបក៏នៅជាបច្ច័យដល់ការតាំងនៅនៃពន្លឺ មិនមែនជាបច្ច័យដល់ការកើតឡើងតែម្យ៉ាង ។ ធម៌ដែលឧបការៈដល់ធម៌ដែលកើតព្រមគ្នានៃធម៌ដែលកើតអំពីបច្ច័យទាំងឡាយ ឈ្មោះថា **សហជាតប្បច្ច័យ** ។ ពាក្យថា **ក្នុងខណៈដែលចុះកាន់គភ៌** បានដល់ ក្នុងបដិសន្ធិក្ខណៈ ។ ពិតហើយ នាមរូបក្នុងខណៈនោះរមែងកើតឡើង ដូចជាឈានចុះ គឺដូចជាមកអំពីលោកដទៃ ហើយឈានចុះកាន់គភ៌មាតាជាដើមក្នុងលោកនេះ ព្រោះហេតុនោះ ទើបខណៈនោះ ហៅថា ខណៈឈានចុះ ។ ពាក្យថា **រូប** ក្នុងទីនេះ លោកមានបំណងយកហទយវត្ថុនោះឯង ។ ពិតហើយ ហទយវត្ថុនោះជាបច្ច័យដល់នាម ហើយនាមក៏ជាសហជាតប្បច្ច័យដល់ហទយវត្ថុនោះ ។ ពាក្យថា **ចិត្ត** និង **ចេតសិក** បានដល់ ខន្ធ ៤ ក្នុងបវត្តិកាល ព្រោះរូបដែលមានចិត្តជាសមុដ្ឋាន មិនមានក្នុងបដិសន្ធិក្ខណៈ ។ ពាក្យថា **ធម៌មានរូបទាំងឡាយ** លោកអាចារ្យពោលសំដៅដល់ហទយវត្ថុ ។ ក្នុងពាក្យនោះ លោកអាចារ្យបានពោលទុកថា **នាម រូបក្នុងខណៈឈានចុះកាន់គភ៌** ក៏ពិត សូម្បីយ៉ាងនោះ ដោយពាក្យនោះ លោកក៏មិនបានបដិសេធរូបធម៌ទាំងឡាយ ជាសហជាតប្បច្ច័យក្នុងខណៈដទៃ ព្រោះហេតុនោះ គប្បីកាន់យកថា ពាក្យនេះលោកពោលទុកដើម្បី

បដិសេធរូបធម៌នោះ ។ បទថា **កិញ្ចិ កាលេ** សេចក្តីប៉ុនគ្នានឹង **កេចិ កិស្មិញ្ចិ កាលេ** ប្រែថា ក្នុងកាលខ្លះ ដោយពាក្យនោះ លោកអាចារ្យរមែងបដិសេធអរូបធម៌ទាំងឡាយ ក្នុងបវត្តិកាល ជាសហជាតប្បច្ច័យដល់រូបធម៌ដទៃ និងដល់វត្ថុដែលមិនបានបដិសេធ អំពីមុនថា ធម៌ដែលមានរូបទាំងឡាយខ្លះ ជាវត្ថុក្នុងកាលខ្លះ គឺក្នុងបដិសន្ធិកាល ព្រោះអធិប្បាយ យ៉ាងនេះ គួរនឹងពោលថា **កិញ្ចិ កាលំ** ឬគួរពោលថា **កិស្មិញ្ចិ កាលេ** លោកអាចារ្យក៏មិនបានពោលយ៉ាងនោះបានពោលទុកដោយធ្វើឲ្យជាវិភត្តិវិបល្លាស ។ ដោយហេតុនោះ ទើបបទថា **កិញ្ចិ** ជាទុតិយាវិភត្តិឯកវចនៈ កាលភ្ជាប់ចូលគ្នាជាមួយ បទថា **រូបិនោ ធម្មា** នេះ ទើបកើតជាបឋមាវិភត្តិពហុវចនៈ ។ កាលភ្ជាប់ចូលជាមួយ បទថា **កាលេ** នេះ ក៏គប្បីជ្រាបថា ជាសត្តមីវិភត្តិឯកវចនៈ ។ ដោយពាក្យជាដើមថា **ខន្ធ ១ និងវត្ថុ ជាបច្ច័យដល់ខន្ធ ៣** ដែលមានអំពីមុន គួរនឹងពោលថា វត្ថុដែលប្រកបជាមួយនាមប៉ុណ្ណោះជាបច្ច័យដល់នាម ដូច្នេះ លោកអាចារ្យក៏រមែងសម្តែងដល់វត្ថុសុទ្ធៗ ប៉ុណ្ណោះ ជាវត្ថុដែលគប្បីពោលយ៉ាងនោះ ដោយពាក្យក្រៅអំពីនេះ។ សហជាតប្បច្ច័យនេះ គប្បីជ្រាបថា មាន ៩ យ៉ាង គឺ

១- កុសលធម៌ ជាបច្ច័យដល់កុសល ។

២- កុសលធម៌ ជាបច្ច័យដល់អព្យាកតៈ ។

៣- កុសលធម៌ ជាបច្ច័យដល់កុសល និងអព្យាកតៈ ។

៤- អកុសលធម៌ ជាបច្ច័យដល់អកុសល ។

៥- អកុសលធម៌ ជាបច្ច័យដល់អព្យាកតៈ ។

៦- អកុសលធម៌ ជាបច្ច័យដល់អកុសល និងអព្យាកតៈ ។

៧- អព្យាកតធម៌ ជាបច្ច័យដល់អព្យាកតៈ ។

៨- កុសល និងអព្យាកតធម៌ ជាបច្ច័យដល់អព្យាកតៈ ។

៩- អកុសល និងអព្យាកតធម៌ ជាបច្ច័យដល់អព្យាកតៈ ។

ធម៌ដែលឧបការៈដល់ធម៌ដែលឧបការៈខ្លួន ឈ្មោះថា **អញ្ញមញ្ញប្បច្ច័យ** ។ពិតយ៉ាងនោះ លោកសម្ដែងឧបមាឈើ ៣ កំណាត់ទុក ដល់អញ្ញមញ្ញប្បច្ច័យដូច្នោះ ។ ធម៌ដែលឧបការៈ បណ្ឌិតគប្បីឃើញទាក់ទងដោយបច្ច័យដល់គ្នានឹងគ្នានោះឯង មិនមែនទាក់ទង ដោយជាសហជាតប្បច្ច័យជាដើម ព្រោះថា បច្ច័យ មានសហជាតប្បច្ច័យជាដើម កាលមាននោះឯង គ្រាខ្លះ ក៏មិនបានជាអញ្ញមញ្ញប្បច្ច័យ និងវៀរចាកធម៌ដែលជាបច្ច័យ មានសហជាតប្បច្ច័យជាដើម អញ្ញមញ្ញប្បច្ច័យនេះ មិនមានការប្រព្រឹត្តទៅបានឡើយ ។ ពិតយ៉ាងនោះ បច្ច័យខ្លះ មានសហជាតប្បច្ច័យជាដើមនោះឯង ក៏ជាអញ្ញមញ្ញប្បច្ច័យបាន ។បើត្រឹមតែខ្លួនជាធម៌ឧបការៈដល់ធម៌ដែលឧបការៈខ្លួន ក៏គប្បីជាអញ្ញមញ្ញប្បច្ច័យសោត វត្ថុ និងខន្ធដែលឧបការៈដល់ធម៌ដែលឧបការៈ ក៏គប្បីជាអញ្ញមញ្ញប្បច្ច័យបាន ជាធម៌ដែលកើតមុន និងជាធម៌ដែលកើតក្រោយ តែសេចក្ដីនោះលោកមិនមានបំណងនោះឡើយ ។ ដោយហេតុនោះ ទើបខ្ញុំពោលថា **ជាធម៌ដែលឧបការៈ បណ្ឌិតគប្បីឃើញការទាក់ទងជាបច្ច័យដល់គ្នានឹងគ្នានោះឯង** ។ អញ្ញមញ្ញប្បច្ច័យនេះ គប្បីជ្រាបថា ជាធម៌ឧបការៈដល់ការកើតឡើង និងដល់ការតាំងនៅ ។ ម្យ៉ាងទៀត អញ្ញមញ្ញប្បច្ច័យនេះ គប្បីជ្រាបថា មាន ៣ យ៉ាង គឺ

១- កុសលធម៌ ជាបច្ច័យដល់កុសល ។

២- អកុសលធម៌ ជាបច្ច័យដល់អកុសល ។

៣- អព្យាកតធម៌ ជាបច្ច័យដល់អព្យាកតៈ ។

បបរិធម៌ ជាធម៌ឧបការៈដល់ធាតុដ៏សេស សការធម៌ទាំងឡាយ មានចក្ខុជាដើម ជាធម៌ឧបការៈដល់សការធម៌ មានចក្ខុវិញ្ញាណជាដើម ដោយអាការជាទីតាំងដូចផែនដីជាទីតាំងនៃដើមឈើជាដើម សការធម៌មានខន្ធជាដើម ក៏ជាធម៌ឧបការៈដល់សការធម៌

មានខន្ធជាដើម ដែលមានសភាវធម៌ មានខន្ធជាដើមនោះៗ ជាទីអាស្រ័យដោយអាការជាទីអាស្រ័យ ដូចវត្ថុ មានផ្ទាំងសំពត់ជាដើម ដែលជាទីអាស្រ័យនៃគំនូរ ដូច្នោះ ។ ពិតហើយ ធាតុដ៏សេសតាំងនៅក្នុងបឋវីធាតុប៉ុណ្ណោះ រមែងធ្វើកិច្ចតាមគួរដល់កិច្ចរបស់ខ្លួន ដូចឧបាទាយរូបទាំងឡាយ ។

ពាក្យថា **ដោយអាការជាទីតាំង** គឺដោយអាការជាទីទទួលទ្រ ។ អាការដែលទទួលទ្រក្នុងទីនេះ បណ្ឌិតគប្បីជ្រាបដោយភាវៈដែលធម៌ទាំងនោះ មានការប្រព្រឹត្តទៅអាស្រ័យធម៌នោះជាវិសេសក្រៃលែង ។ ព្រោះភូតរូបទាំងឡាយ លោកពោលថា មានទីតាំងដែលគប្បីសម្តែងចេញមិនបាន ក៏ព្រោះធ្វើការអធិប្បាយយ៉ាងនេះ ភូតរូបទាំងឡាយ ជាធម៌ឧបការៈដោយអាការជាទីទ្រទ្រង់នៃវត្ថុ មានចក្ខុជាដើម ក៏រមែងពាល់ត្រូវដោយល្អ ។ ព្រោះថា អាការជាទីតាំងនៃអរូបធម៌ទាំងឡាយ ដែលមិនមានទីកន្លែងក្នុងវត្ថុ មានចក្ខុជាដើមដទៃ វៀរភាពផ្សេងនៃធម៌ដែលមានការប្រព្រឹត្តទៅអាស្រ័យធម៌នោះតាមដែលពោលហើយ នឹងមាននៅក៏ទេ ។ បើធម៌ពួកណាមួយអាស្រ័យធម៌ណាមួយកើតឡើង ធម៌ទាំងនោះក៏មានការប្រព្រឹត្តទៅអាស្រ័យធម៌នោះ ។ ម្យ៉ាងទៀតធម៌ទាំងឡាយ មានចក្ខុវិញ្ញាណជាដើម រមែងប្រព្រឹត្តទៅដោយអាការដែលធ្វើតាមធម៌នោះ ព្រោះវត្ថុ មានចក្ខុជាដើម ជាវត្ថុដែលជាក់ច្បាស់ និងទន់ ដោយភាពផ្សេងនៃបច្ច័យណា ភាពផ្សេងគ្នានេះសម្រេចដោយធម៌ទាំងនោះ មានការប្រព្រឹត្តទៅអាស្រ័យធម៌នោះក្នុងទីនេះ ។ សូម្បីកាលបច្ច័យស្មើគ្នាយ៉ាងនេះមានសេចក្តីផ្សេងនៃនិស្សយប្បច្ច័យ ក៏រមែងជាក់ច្បាស់បានដោយអារម្មណប្បច្ច័យ ន័យនេះ ខ្ញុំបានប្រកាសហើយខាងដើម ។ ក្នុងពាក្យថា **ចំណែកកោដ្ឋាសទី ៦** នេះ មិនទាន់បានពាក្យនេះថា **ធម៌ដែលមានរូបទាំងឡាយ ជាបច្ច័យក្នុងគ្រាខ្លះ ដល់ធម៌ដែលមិនមានរូបទាំងឡាយ ។** ចំណែកពាក្យណាដែលបាននៅក្នុងបច្ច័យនេះថា **ធម៌ដែលមានរូបទាំងឡាយពួកខ្លះ**

លោកអាចារ្យសម្ដែងលម្អិតពាក្យថា **ចក្ខាយតនៈ** ជាដើម ដើម្បីសម្ដែងធម៌ទាំងនោះឯង ក្នុងពាក្យនោះ ។ ពាក្យថា រូបណា លោកពោលសំដៅយកហទយវត្ថុ ។ និស្សយប្បច្ច័យ មាន ១៣ យ៉ាង អ្វីខ្លះ គឺ

កុសលមូល ៣ ដោយសហជាតនិស្សយប្បច្ច័យ ។

អកុសលមូល ៣ ដោយសហជាតនិស្សយប្បច្ច័យដូចគ្នា ចំណែកក្នុងបណ្ដាអព្យាកតមូលបានបុរេជាតនិស្សយប្បច្ច័យ ១ ។

ឯអព្យាកតៈ ជាសហជាតប្បច្ច័យដល់អព្យាកតៈក៏មាន ១ សូម្បីធម្មជាតិដែលកើតមុនជាបុរេជាតនិស្សយប្បច្ច័យតែម្យ៉ាងដល់កុសល ១ជាបុរេជាតនិស្សយប្បច្ច័យដល់អកុសលយ៉ាងនោះ ១ ។ កុសល និងអព្យាកតៈជានិស្សយប្បច្ច័យ ដល់កុសលដោយសហជាតប្បច្ច័យ និងបុរេជាតប្បច្ច័យ ១ កុសល និងអព្យាកតៈ ជានិស្សយ-ប្បច្ច័យដល់អព្យាកតៈដោយសហជាតប្បច្ច័យតែម្យ៉ាង ១ អកុសល និងអព្យាកតៈជានិស្សយប្បច្ច័យដល់អព្យាកតៈ ដោយសហជាតប្បច្ច័យតែម្យ៉ាងដូចគ្នា ១ ។

ពាក្យថា **ធម៌ដែលផលរបស់ខ្លួនអាស្រ័យ ដោយមានការប្រព្រឹត្តទៅ អាស្រ័យធម៌ជាហេតុនោះ** ដូច្នេះ មានអធិប្បាយថា លោកអាចារ្យពោលថា ហេតុឯណានីមួយឈ្មោះថា និស្ស័យ ដូច្នេះហើយ ពង្រីកសេចក្ដីថា និស្ស័យដ៏មានកម្លាំងឯណាក្នុងបច្ច័យនោះ នោះឈ្មោះថា **ឧបនិស្សយ** ។ ពាក្យថា **ធម៌ដែលឧបការៈដោយភាពជាហេតុមានកម្លាំង** សេចក្ដីថា ធម៌ដែលឧបការៈដែលជាហេតុមានកម្លាំងសុទ្ធ ដោយអំណាចជាអារម្មណ៍ ដោយអំណាចជាធម្មជាតិ មានសមត្ថភាពក្នុងការឲ្យកើតចិត្តដែលសមគួរក្នុងលំដាប់គ្នា ។ ដោយហេតុនោះ លោកអាចារ្យពោលថា **ឧបនិស្សយ-ប្បច្ច័យនោះ** ដូច្នេះជាដើម ។

ក្នុងពាក្យនោះ មានវិនិច្ឆ័យដូច្នេះ ពាក្យថា **ឲ្យទាន** បានដល់ លះទេយ្យធម៌ ។

ម្យ៉ាងទៀត ទេយ្យធម៌នោះ គេឲ្យដោយចេតនាណា ចេតនានោះឈ្មោះថា **ទាន** ។ពាក្យថា **ឲ្យហើយ** បានដល់ ញុំាងចេតនាឲ្យផូរផង់ គឺធ្វើឲ្យបរិសុទ្ធ ។ ពាក្យថា **សមាទានសីល** បានដល់ ទទួលនិច្ចសីល ដោយអំណាចសីលមានអង្គ ៥ និងសីលមានអង្គ ១០ ជាដើម ។ ដោយពាក្យនេះលោកពោលដល់សមាទានវិរតិតែម្យ៉ាង ចំណែកសម្បត្តវិរតិ និងសមុច្ឆេទវិរតិ លោកមិនបានពោលទុក ព្រោះក្នុងផ្លូវលោក មិនប្រាកដថា **ជាសីល** ។ លោកមិនបានពោលទុកក៏ពិត សូម្បីយ៉ាងនោះ វិរតិទាំង ២ នោះ ក៏គង់ជាអារម្មណប្បច្ច័យនោះឯង ។ បណ្តាវិរតិទាំង ២ នោះ សមុច្ឆេទវិរតិជាអារម្មណ៍ដល់កុសលរបស់សេក្ខបុគ្គលប៉ុណ្ណោះ មិនជាអារម្មណ៍ដល់បុគ្គលក្រៅអំពីនេះឡើយ ។ ពាក្យថា **ឧបោសថកម្ម** បានដល់ ឧបោសថសីលដែលលោកពោលទុកយ៉ាងនេះថា **មិនសម្លាប់សត្វ មិនកាន់យករបស់ដែលគេមិនបានឲ្យ** ។ ពាក្យថា **បច្ចវេក្ខណៈ ធ្វើកុសលកម្មនោះឲ្យជាសំខាន់** សេចក្តីថា សេក្ខបុគ្គល និងបុថុជ្ជន ក៏ពិចារណាកុសលកម្មនោះ តាមដែលបានពោលហើយ សូម្បីព្រះអរហន្តក៏បច្ចវេក្ខណៈកុសលកម្មនោះដូចគ្នា ។ ព្រោះថា កុសលដែលបានធ្វើទុកមុនរបស់ព្រះអរហន្ត ក៏ជាកុសលនោះឯង ។តែព្រះអរហន្តបច្ចវេក្ខណៈគឺពិចារណាដោយចិត្តណាចិត្តនោះឈ្មោះថាកិរិយាចិត្ត ដោយហេតុនោះ ទើបមិនបានក្នុងអធិការនេះថា **កុសលជាបច្ច័យដល់កុសល** ។ ពាក្យថា **កុសលកម្មទាំងឡាយដែលប្រព្រឹត្តមកល្អហើយក្នុងកាលមុន** កុសលកម្មដែលធ្វើក្នុងវេលាជិត លោកពោលថា **ឲ្យហើយ ធ្វើហើយ** ដោយពាក្យនេះ គប្បីជ្រាបថា មិនមែនកុសលកម្មដែលធ្វើក្នុងវេលាជិត ម្យ៉ាងទៀត ពាក្យនេះ លោកពោលទុកដើម្បីសម្តែងកាមាវចរកុសលដ៏សេសអំពីទានជាដើម ។ ពីរបទថា **ឈានា វុដ្ឋហិត្វា** សេចក្តីថា បុគ្គលចូលឈានហើយ ចេញអំពីឈាន ។ បាលីថា **ឈានំ វុដ្ឋហិត្វា** ដូច្នេះ ក៏មាន ។ ពីរបទថា **សេក្ខា គោត្រភុំ** លោកពោលសំដៅដល់ព្រះសោតាបន្ន ។

ពិតហើយ ព្រះសោតាបន្នទោះ រមែងបច្ចវេក្ខណៈគោត្រភូ ។ ចំណែកពាក្យថា **វោទាន** នេះ លោកពោលសំដៅដល់ព្រះសកទាគាមី និងព្រះអនាគាមី ។ ពិតហើយ ចិត្តរបស់ព្រះសកទាគាមី និងព្រះអនាគាមីទាំងនោះ ជាចិត្ត ឈ្មោះថា វោទាន គឺផូវផង់ ។ ម្យ៉ាងទៀត ពាក្យថា **ព្រះសេក្ខបុគ្គលទាំងឡាយ** បានដល់ ព្រះសោតាបន្ន ព្រះសកទាគាមី និងព្រះអនាគាមី ។ ពាក្យថា **ចេញអំពីមគ្គ** គឺចេញអំពីមគ្គដែលខ្លួនបានដោយអំណាចឈានកន្ទងកវេគ្គក្នុងមគ្គចិត្ត និងផលចិត្ត ឈ្មោះថា ការចេញអំពីមគ្គសុទ្ធនោះឯង ហើយបច្ចវេក្ខណៈ រមែងមិនមាន ។ ដោយ **អាទិ-ស័ព្ទ** លោកអាចារ្យរមែងរួមដល់ពាក្យជាដើមយ៉ាងនេះថា **ចេញអំពីឈានហើយ រមែងពិចារណាឃើញកុសលកម្ម ដោយជារបស់មិនទៀង ជាទុក្ខ ជាអនត្តា** ។ លោកចែកទុកដោយមិនបានធ្វើសេចក្តីផ្សេងគ្នាទុកក៏ពិត សូម្បីយ៉ាងនោះ លោកអាចារ្យពោលពាក្យថា **ក្នុងបណ្តាអារម្មណ៍ទាំងនោះ** ដូច្នេះជាដើម ក៏ដើម្បីសម្តែងថា សេចក្តីនេះក៏ជាសេចក្តីផ្សេងគ្នារបស់អារម្មណាធិបតី និងអារម្មណូបនិស្សយៈ ។

សេចក្តីផ្សេងគ្នានៃការតាំងចិត្ត និងចេតសិកទាំងនោះ ដែលជាអនន្តរប្បច្ច័យ និងជាអនន្តរូបនិស្សយមាន ។ ព្រោះការផ្សេងគ្នានៃការតាំងគ្រាដំបូង ប្រព្រឹត្តទៅដោយអំណាចអព្យាកតធម៌ ការផ្សេងគ្នានៃការតាំងក្រៅអំពីនេះ ប្រព្រឹត្តទៅដោយអំណាចកុសលធម៌ជាដើម ព្រោះហេតុនោះ សេចក្តីផ្សេងគ្នានៃការតាំងនោះ **ដោយអត្ថ ទើបដល់នូវភាពដូចគ្នានោះឯង** ព្រោះការផ្សេងគ្នានៃការតាំងទាំង ២ យ៉ាងនោះ លោកមានបំណងយកក្នុងចិត្តុប្បាទទាំងឡាយ ។ ពាក្យថា **សូម្បីកាលបើដូច្នេះ** ជាដើម ជាពាក្យសម្តែងការផ្សេងគ្នានៃអនន្តរប្បច្ច័យ និងអនន្តរូបនិស្សយៈ ។ បទថា **យថា ហិ** ជាដើម ជាពាក្យសម្តែងការមាននៃអនន្តរូបនិស្សយៈ ។

ប អក្ខរៈ ក្នុងបទថា **បកតោ** នេះ ជាឧបសគ្គ ប អក្ខរៈនោះ រមែងសម្តែង

ដល់បច្ច័យដែលធ្វើទុកយ៉ាងល្អ ដោយការៈដែលអាចឲ្យកើតផលដល់ខ្លួនបាន ។កម្ម ដែលធ្វើទុកយ៉ាងនោះ រមែងធ្វើទុកក្នុងសន្តានរបស់ខ្លួន ព្រោះដូច្នោះ ទើបលោកអាចារ្យ ពោលពាក្យជាដើមថា **ក្នុងសន្តានរបស់ខ្លួន** ។ ការធ្វើមាន ២ យ៉ាង គឺការសាងឡើង ឲ្យសម្រេច ១ ការចូលទៅសេព ១ ដោយហេតុនោះ ទើបលោកអាចារ្យពោលពាក្យ ជាដើមថា **ដែលបុគ្គលសាងឡើងឲ្យសម្រេច** ដើម្បីសម្តែងដល់ការធ្វើនោះ ។ ក្នុងការ ធ្វើទាំង ២ យ៉ាងនោះ **ការសាងឡើងឲ្យសម្រេច** បានដល់ ការញុំាងផលឲ្យកើតឡើង ដោយការប្រជុំនៃហេតុបច្ច័យ ។ ចំណែក **ការចូលទៅសេព** បានដល់ ការចូលទៅសេព ដោយការប្រើប្រាស់ ដោយអំណាចធ្វើឲ្យជាប់នៅក្នុងកាយ និងបានដល់ ការចូលទៅ សេពអារម្មណ៍ ដោយអំណាចការដឹងច្បាស់ និងការកំណត់ដឹងជាដើម ។ ដោយហេតុ នោះឯង រមែងពោលដល់ឧតុសម្បទាជាដើម មិនបានមកដល់បានចូលទៅសេពទុក ដោយការចូលទៅសេពអារម្មណ៍ ក៏ជាបកតូបនិស្សយបាន ឧតុសម្បទាជាដើម ដែល ជាអតីត និងបច្ចុប្បន្ន មិនចាំបាច់ពោលដល់ឡើយ ។ ពិតហើយ វត្ថុដែលជាបច្ចុប្បន្ន ក៏ជាបកតូបនិស្សយបាន ព្រោះមានព្រះបាលីថា **បុគ្គលចូលទៅអាស្រ័យឧតុ ភោជន សេនាសនៈដែលជាបច្ចុប្បន្ន រមែងញុំាងឈានឲ្យកើតឡើងបាន** ដូច្នេះ ។ ពាក្យថា **ដោយបកតិនោះឯង** គឺដោយការៈរបស់ខ្លួនដែលវៀរចាកការលាយឡំ ដោយបច្ច័យ ដទៃនោះឯង ។ ពាក្យថា **ឧបនិស្សយ** គឺធ្វើហេតុមានកម្លាំង ។ **គប្បីជ្រាបប្រភេទ ដោយអនេកប្រការ** ដោយន័យរបស់ពាក្យដែលមកក្នុងបញ្ហាវារៈ ។ ក្នុងបញ្ហាវារៈ មានពាក្យថា

កុសលធម៌ទាំងឡាយដែលកើតមុនៗ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យដល់ កុសលធម៌ទាំងឡាយដែលកើតក្រោយៗកុសលធម៌ទាំងឡាយដែលកើតមុនៗជាបច្ច័យ ដោយឧបនិស្សយប្បច្ច័យដល់អកុសលធម៌ទាំងឡាយ ដែលកើតក្រោយៗ ជំពូកខ្លះ

កុសលធម៌ទាំងឡាយ ជាបច្ច័យដល់អព្យាកតធម៌ទាំងឡាយ អកុសលធម៌ទាំងឡាយ ជាបច្ច័យដល់អកុសលធម៌ទាំងឡាយ អកុសលធម៌ទាំងឡាយ ជាបច្ច័យដល់កុសលធម៌ទាំងឡាយពួកខ្លះ អកុសលធម៌ទាំងឡាយ ជាបច្ច័យដល់អព្យាកតធម៌ អព្យាកតធម៌ទាំងឡាយ ជាបច្ច័យដល់អព្យាកតធម៌ អព្យាកតធម៌ទាំងឡាយ ជាបច្ច័យដល់កុសលធម៌ អព្យាកតធម៌ទាំងឡាយ ជាបច្ច័យដល់អកុសលធម៌ បុគ្គលក្តី សេនាសនៈក្តី ក៏ជាបច្ច័យដោយឧបនិស្សយបច្ច័យ ដូច្នេះ ។

ក្នុងបណ្តាធម៌ទាំងនោះ ធម៌ពួកណាដែលកើតមុនៗ ជាអនន្តរូបនិស្សយបច្ច័យ ដល់ធម៌ពួកណា ដែលកើតខាងក្រោយ ធម៌ទាំងនោះ រមែងជាអនន្តរូបនិស្សយដោយចំណែកមួយប៉ុណ្ណោះ ដល់ធម៌ទាំងអស់នោះ មិនមែនជាអនន្តរូបនិស្សយបច្ច័យ ដល់ធម៌ពួកខ្លះ ក្នុងកាលខ្លះ ។ ព្រោះហេតុនោះ បានអនន្តរូបនិស្សយក្នុងបទណា បទនោះមិនអាចពោលថា **ដល់ធម៌ពួកខ្លះ** បានទេ ហេតុនោះ ទើបលោកមិនបានពោលទុក ។ ចំណែកធម៌ពួកណាកើតមុន ជាអារម្មណូបនិស្សយ ឬបកតូបនិស្សយ ដល់ធម៌ទាំងឡាយដែលកើតក្រោយ ធម៌ទាំងឡាយនោះក៏ជាបច្ច័យដល់ធម៌ទាំងឡាយនោះមិនមែនជាបច្ច័យដោយចំណែកមួយដល់ធម៌ទាំងអស់ ។ ធម៌ទាំងឡាយណា មានបច្ច័យរាំងការកើតឡើងជាបច្ច័យមានកម្លាំង ក៏មិនជាបច្ច័យដល់ធម៌ទាំងនោះ តែជាបច្ច័យដល់ធម៌ក្រៅអំពីនេះ ព្រោះដូច្នោះ អនន្តរបច្ច័យមិនបានក្នុងបទទាំងឡាយណា ក្នុងបទទាំងឡាយនោះ លោកពោលថា **ដល់ធម៌ពួកខ្លះ** ។ បច្ចយុប្បន្នធម៌ទាំងឡាយណា គប្បីមានដល់បច្ចយធម៌ ដែលសម្រេចហើយ បច្ចយុប្បន្នធម៌ទាំងនោះ ក៏មានអត្ថដូច្នេះថា **ដល់ធម៌ពួកខ្លះ ក្នុងឧបនិស្សយបច្ច័យនេះ** ។

ក្នុងឧបនិស្សយបច្ច័យនេះ មានការបង្រួញដូច្នេះថា ធម៌ទាំងពួង និងបញ្ញត្តិខ្លះ ជាអារម្មណូបនិស្សយ ព្រោះកសិណបញ្ញត្តិ ជាអារម្មណូបនិស្សយ គំនរចិត្ត និង

ចេតសិកដែលកន្លងទៅ មិនមានចន្លោះ ជាអនន្តរូបនិស្សយ បកតូបនិស្សយ មាន ៥ យ៉ាង គឺកុសល អកុសល វិបាក កិរិយា និងអរូប ។ ឯសេចក្ដីពិស្ដារគប្បីជ្រាបក្នុងអដ្ឋកថានៃបដ្ឋាន ។

ពាក្យថា **មុនជាង** គឺមុនជាងបច្ចយុប្បន្នធម៌ ។ បុរេជាតប្បច្ច័យនេះ រមែងបានដោយជារូបធម៌តែម្យ៉ាង ។ ចំណែកបច្ចយុប្បន្នធម៌ជាអរូបធម៌តែម្យ៉ាង ។ ដោយហេតុនោះ ទើបលោកអាចារ្យពោលថា **ធម៌ដែលឧបការៈជាសភាវៈប្រព្រឹត្តទៅ** ។ ធម៌ឧបការៈដោយអាការដែលកើតមុននៃវត្ថុ និងអារម្មណ៍ ដែលមិនដល់នូវភាពជាធម៌ដែលឧបការៈ វៀរតែភាវៈដែលជាធម៌កើតមុន ដែលផ្សេងទៅអំពីអាការនៃវត្ថុ និងអារម្មណ៍ជាទីអាស្រ័យ ឈ្មោះថា ជាបុរេជាតប្បច្ច័យ ។ ក្នុងបណ្ដាបុរេជាតប្បច្ច័យ ២ យ៉ាង ដោយជាវត្ថុ និងអារម្មណ៍យ៉ាងនេះ ពាក្យថា **ចក្ខាយតន** ជាដើម លោកពោលអំណាចវត្ថុ ពាក្យថា **រូបាយតន** ជាដើម លោកពោលដោយអំណាចអារម្មណ៍ ។

ពាក្យថា **រូបណា** លោកពោលសំដៅយកហទយវត្ថុ ក្នុងពាក្យនោះ ពាក្យថា **ក្នុងកាលខ្លះ** លោកពោលដោយអំណាចបវត្តិកាល ។ ពាក្យថា **ក្នុងកាលខ្លះ** លោកពោលដោយអំណាចបដិសន្ធិកាល ។ ធម្មជាតិទាំងឡាយណា វៀរបុរេជាតប្បច្ច័យដែលជាអារម្មណបុរេជាត រមែងមិនប្រព្រឹត្តទៅ ធម្មជាតិណាមួយ រមែងប្រព្រឹត្តទៅដោយអារម្មណបុរេជាតប្បច្ច័យ ក្នុងមនោទ្វារដោយការសម្ដែងការកើតមុន ដោយអារម្មណ៍ នៃធម្មជាតិទាំងឡាយនោះ មានចក្ខុវិញ្ញាណជាដើម រូបរូប ទាំងអស់ជាអារម្មណប្បច្ច័យនៃធម្មជាតិនោះៗ រមែងត្រូវសម្ដែងបានថា ជាអារម្មណបុរេជាតនោះឯង ។ សេចក្ដីនេះ នឹងឃើញបានដូចព្រះមានព្រះភាគត្រាស់ទុកក្នុងបញ្ហាវារៈថា ដែលជាអារម្មណបុរេជាត បានដល់ សេក្ខបុគ្គល ឬបុថុជ្ជនទាំងឡាយរមែងពិចារណាឃើញចក្ខុជារបស់មិនទៀង ជាទុក្ខ ជាអនត្តា ដូច្នេះជាដើម ។ មាន ៣ វារៈ មាន

អព្យាកតធម៌ជាគោល គឺ **អព្យាកតធម៌ជាបច្ច័យដោយបុរេជាតប្បច្ច័យដល់អព្យាកតធម៌ ១ អព្យាកតធម៌ជាបច្ច័យដោយបុរេជាតប្បច្ច័យដល់កុសលធម៌ ១ អព្យាកតធម៌ជាបច្ច័យដោយបុរេជាតប្បច្ច័យដល់អកុសលធម៌ ១** ។ ទាំង ៣ វារៈនោះ ១ វារៈចែកជា ២ យ៉ាង គឺវត្ថុបុរេជាត ១ អារម្មណបុរេជាត ១ ។

កាលបច្ចយុប្បន្នធម៌ ជាធម៌សម្រេចមុនមាន បច្ចយធម៌ដែលជាធម៌កើតខាងក្រោយរមែងមាន ហេតុនោះ ទើបលោកអាចារ្យពោលថា **ដែលកើតមុន** ។ ន័យនេះបានក្នុងរូបធម៌ប៉ុណ្ណោះ មិនបានក្នុងអរូបធម៌ទាំងឡាយឡើយ ហេតុនោះ ទើបលោកអាចារ្យពោលថា **រូបធម៌ទាំងឡាយ** ។ លោកអាចារ្យពោលថា ជាធម៌ឧបការៈ ដូច្នេះ ដើម្បីចៀសវាងពាក្យសួរថា បើបច្ចយុប្បន្នធម៌ទាំងឡាយកើតមុនប៉ុណ្ណោះ បច្ច័យមានអ្វីខ្លះ ។ ពិតហើយ ធម៌ទាំងឡាយណា ជាធម៌ឧបការៈដោយអាការដែលកើតខាងក្រោយនៃធម៌ទាំងឡាយ ដែលមិនដល់នូវភាពជាហេតុ ដែលមិនដាច់ទៅអំពីការបន្តគ្នា ដោយវៀរចាកធម៌ដែលកើតខាងក្រោយ ធម៌ឧបការៈដែលផ្សេងទៅអំពីអាការមិនប្រកបគ្នាជាដើមនៃធម៌ទាំងនោះ ឈ្មោះថា បច្ឆាជាតប្បច្ច័យ ។ បណ្ឌិតគប្បីប្រកបធម៌ ដែលឧបការៈដែលផ្សេងទៅអំពីអាការបច្ច័យដទៃ នៃបច្ច័យទាំងឡាយយ៉ាងនេះ ដោយពាក្យថា **ដូចចេតនា គឺការសង្ឃឹមក្នុងអាហារឧបការៈ សរីរៈរបស់កូនត្មាតទុកដូច្នោះ** នេះ លោកអាចារ្យរមែងសម្តែងដល់អរូបធម៌ទាំងឡាយដែលប្រព្រឹត្តទៅដោយអំណាចមនោសញ្ចេតនាហារ ជាធម៌ដែលឧបត្ថម្ភរូបកាយ ដោយហេតុនោះឯង ទើបលោកធ្វើស័ព្ទចេតនា មិនបានពោលថា **ដូចការសង្ឃឹមក្នុងអាហារ** ។ ពាក្យថា **កាយ** បានដល់ រូបកាយ ពោល គឺភូតរូប និងឧបាទាយ រូបដែលមានសមុដ្ឋាន ៤ ។ ដោយបង្រួញអរូបក្ខន្ធដ៏សេស វៀររូបធម៌ទាំងឡាយ ឈ្មោះថា បច្ឆាជាតប្បច្ច័យ គប្បីជ្រាបថា បច្ឆាជាតប្បច្ច័យនោះ ទាក់ទងជាតិ មាន ៤ យ៉ាង គឺកុសល អកុសល

វិបាក កិរិយា ។

ការធ្វើ បានដល់ ការប្រព្រឹត្តរឿយៗ នូវកិច្ចដែលគប្បីធ្វើដោយប្រយោគដូចគ្នា នឹងខ្លួន ជាកុសលជាដើម ឬការអប់រំដែលឲ្យដល់នូវភាពជាធម៌ដូចខ្លួន ឈ្មោះថា **អាសេវនត្ថោ** ដោយអត្ថ គឺអាសេវន ការសេព ។ ពាក្យថា **ដូចការខ្វល់ខ្វាយមុនៗ** គឺដូចការសេពមុនៗ ក្នុងការរៀន ការស្ដាប់ ការទ្រទ្រង់ទុកជាដើម ។ ពាក្យថា **មុនៗ** ក្នុងអាសេវនប្បច្ច័យទាំង ៣ នេះ គប្បីឃើញថា បានដល់ ធម៌ដែលកន្លងទៅហើយ ក្នុងលំដាប់ ។ សួរថា ព្រោះហេតុអ្វី ទើបក្នុងអធិការនេះ លោកមិនធ្វើនិទ្ទេសរួមជាមួយធម៌ ដែលមានជាតិផ្សេងគ្នា ដោយន័យជាដើមថា កុសលធម៌មុនៗ ជាបច្ច័យដល់អព្យាកតធម៌ក្រោយៗ **ដូចជាក្នុងអនន្តរប្បច្ច័យទៅវិញ** ? ឆ្លើយថា ព្រោះមិនអាចឲ្យកាន់យកគតិរបស់ខ្លួនបាន ។ ពិតហើយ ធម៌ដែលមានជាតិផ្សេងគ្នា កាលនឹងឲ្យសម្រេចការស្ទាត់ជំនាញ មានកម្លាំងដោយគុណ គឺការសេពដល់ធម៌ មានជាតិផ្សេងគ្នា រមែងមិនអាចឲ្យកាន់យកគតិ ពោល គឺជាកុសលជាដើមរបស់ខ្លួននោះឯងបាន ។ ព្រោះហេតុនោះ គប្បីឃើញថា លោកមិនបានធ្វើនិទ្ទេសជាមួយធម៌ដែលមានជាតិផ្សេងគ្នានោះ ធម៌ទាំងឡាយណាអាចឲ្យកាន់យកគតិ ពោល គឺជាកុសលជាដើមរបស់ខ្លួនដែលពិសេសដោយការស្ទាត់ជំនាញ និងមានកម្លាំងដោយគុណ គឺការសេពរឿយៗ ពោល គឺការអប់រំរបស់ធម៌ទាំងឡាយណា ក៏ធ្វើនិទ្ទេសរួមជាមួយធម៌ទាំងនោះ ដែលមានជាតិស្មើគ្នាប៉ុណ្ណោះ ដើម្បីធម៌ទាំងនោះ ។

បើដូច្នោះ ព្រោះហេតុអ្វី ទើបលោកមិនកាន់យកវិបាកដែលជាអព្យាកតៈទៅវិញ? ព្រោះមិនមានការសេពរឿយៗ ស្និទ្ធស្នាល ។ ពិតហើយ វិបាកដែលជាអព្យាកតៈដល់នូវភាពជាវិបាក ក៏ដោយអំណាចនៃកម្ម ជាធម្មជាតិត្រូវកម្មឲ្យប្រែប្រួលទៅ ប្រព្រឹត្តទៅមិនមានវត្ថុដឹកនាំ ជាធម្មជាតិទុព្វលស្ងប់ ឲ្យកាន់យកសភាវៈរបស់ខ្លួនហើយ ឲ្យអប់រំ

ហើយដោយគុណ គឺការសេពរហូតស្ទិទ្ធស្នាល ក៏មិនញ៉ាំងវិបាកដទៃឲ្យប្រព្រឹត្តទៅ និងមិនកាន់យកអានុភាពនៃវិបាកចាស់កើតឡើង ដោយពិត ត្រូវកម្លាំងកម្មបន្សាត់ទៅដូចជាធ្លាក់ទៅហើយ កើតឡើង ។ ព្រោះដូច្នោះ ការសេពរហូតស្ទិទ្ធស្នាលមិនមាននៅក្នុងវិបាក សូម្បីដោយប្រការទាំងពួង ព្រោះហេតុនោះទើបលោកមិនកាន់យកវិបាកដែលជាអព្យាកតៈ ។ វិបាកដែលជាអព្យាកតៈសូម្បីកើតឡើង ក្នុងលំដាប់នៃកុសល អកុសល និងកិរិយា រមែងមិនកាន់យកគុណ គឺការសេព ព្រោះមានការប្រព្រឹត្តទៅទាក់ទងដោយកម្មរបស់ខ្លួន ព្រោះហេតុនោះ សូម្បីធម៌ មានកុសលជាដើម ក៏រមែងមិនជាអាសេវនប្បច្ច័យដល់វិបាកដែលជាអព្យាកតៈនោះ ម្យ៉ាងទៀត ធម៌មានកុសលជាដើមនេះ ក៏រមែងមិនធ្វើការទទួលការសេពដល់វិបាក ដែលជាអព្យាកតៈនោះឡើយ ។ តែពោលដោយភូមិ ឬដោយអារម្មណ៍ ឈ្មោះថា ជាធម៌មានជាតិផ្សេងគ្នារមែងមិនមាន ព្រោះហេតុនោះ កុសល និងកិរិយាដែលជាកាមាវចរ ទើបជាអាសេវនប្បច្ច័យដល់កុសល និងកិរិយាដែលជាមហគ្គតៈ និងកុសលដែលមានសង្ខារជាអារម្មណ៍ ក៏ជាអាសេវនប្បច្ច័យដល់ធម៌ ដែលមាននិព្វានជាអារម្មណ៍ដូចគ្នា ។ អាសេវនប្បច្ច័យនេះលោកពោលទុក ៣ យ៉ាង គឺធម៌ដែលជាកុសលជាអាសេវនប្បច្ច័យដល់ធម៌ដែលជាកុសល ធម៌ដែលជាអកុសលជាអាសេវនប្បច្ច័យដល់ធម៌ដែលជាអកុសល ធម៌ដែលជាអព្យាកតៈជាអាសេវនប្បច្ច័យដល់ធម៌ដែលជាអព្យាកតៈ ។ ធម៌ដែលជាកិរិយាវៀរអាវជ្ជនៈ លោកកាន់យកដោយស័ព្ទថា អព្យាកតៈ ។

ចិត្តប្បយោគ បានដល់ ការធ្វើរបស់ចិត្ត អធិប្បាយថា ការខ្នះខ្នែងនៃចិត្ត ចិត្តប្បយោគ បានដល់ ចេតនា ដូចគ្នានឹងកាយបយោគ និងវចីបយោគ បានដល់វិញ្ញត្តិ ។ ដោយហេតុនោះឯង ទើបចេតនានោះ ជាឧបការៈ ដោយជាការធ្វើដែលផ្សេងគ្នា ក្នុងសន្តាននោះឯង សូម្បីដល់កដត្តារូបដែលជាវិបាកដែលប្រព្រឹត្តទៅ ក្នុង

កាលបច្ច័យដ៏សេសប្រជុំគ្នា ក្នុងសន្តានដែលផ្សេងគ្នា ដោយជាការធ្វើដែលកើតឡើង ។ ព្រោះហេតុដែលការធ្វើនោះប្រព្រឹត្តទៅហើយ កដត្តារូបដែលជាវិបាកទាំងនោះ ទើបប្រព្រឹត្តទៅ មិនមែនដោយប្រការដទៃ ។ ធម៌ទាំងឡាយដែលប្រព្រឹត្តទៅ ដោយការធ្វើ គឺការប្រមូលមករបស់ធម៌ទាំងឡាយដែលកើតរួមគ្នា ជាធម៌ដែលមានឧបការៈ ព្រោះហេតុនោះ នឹងពោលទៅថា ។ ពាក្យថា **កម្ម** លោកបំណងយកកម្ម គឺចេតនាប៉ុណ្ណោះ ។ ព្រោះថា កម្មដែលជាចេតនាសម្បយុត្ត មានអភិជ្ឈាជាដើម មិនជាកម្មប្បច្ច័យឡើយ សូម្បីវិបាកធម៌មានចេតនាដែលជាវិបាក ក៏ជាសហជាតកម្មប្បច្ច័យប៉ុណ្ណោះ ព្រោះធម៌ដែលវៀរចាកចេតនា មិនជាធម៌ដែលមានសភាពជាចេតនានោះឡើយ ។ កម្មប្បច្ច័យនេះ មាន ៤ យ៉ាង ទាក់ទងដោយជាតិ ព្រោះដូច្នោះ គួរពោលទាំងអស់ ដោយពាក្យថា **ជាធម៌ស្ងប់ មិនមានឧស្សាហ៍** នេះ លោកអាចារ្យរមែងសម្ដែងដល់វិបាក ដែលមិនដូចគ្នាដល់ធម៌ដែលដូចគ្នា ដោយជាធម៌ទទួលអារម្មណ៍បានជាដើម ជាមួយកុសល និងអកុសលដែលជាធម៌ មានវិបាកជាសភាវធម៌ដែលមានឧស្សាហ៍ ។ វិបាកនោះជាការស្ងប់ដែលមិនមានឧស្សាហ៍ ព្រោះបយោគនៃធម៌ដែលមិនគប្បីឲ្យសម្រេច ដោយប្រយោគនៃវិបាកទាំងឡាយ ឬព្រោះកាលបច្ច័យដ៏សេសសម្រេចហើយ ដោយប្រការដទៃ ក៏សម្រេចបាន ព្រោះធ្វើកម្មស្រេចមកហើយ មិនមែនជាការចូលទៅស្ងប់កិលេស ។ ពិតហើយ ធម៌ទាំងឡាយ មានភវង្គជាដើម ក៏គប្បីដឹងបានលំបាក ព្រោះជាការស្ងប់យ៉ាងនោះឯង ។ តែរមែងដឹងរូបធម៌ជាដើមជាសភាវៈ ដែលកាន់យកបានដោយការប្រព្រឹត្តទៅនៃជវនក្នុងបញ្ចទ្វារ ។ ចំណែកវិបាកត្រឹមតែជាសម្បដិច្ឆន្នៈ និងសន្តីរណៈដែលយល់ព្រមចំពោះ ជាធម៌ដែលដឹងបានដោយលំបាកនោះឯង ។ ពាក្យថា **ដើម្បីជាសភាវៈស្ងប់ មិនមានឧស្សាហ៍** គឺដើម្បីប្រយោជន៍ដល់សភាពស្ងប់ មិនមានឧស្សាហ៍ ។ ដោយពាក្យនេះ លោកអាចារ្យរមែងសម្ដែងការប្រព្រឹត្តទៅដែលសមដល់វិបាករបស់

រូបធម៌ ដែលមិនមានវិបាក ដែលមានសភាវៈនោះជាបច្ច័យ ។ ពាក្យថា **ក្នុងបវត្តិកាល** ជាដើម លោកពោលយកន័យក្នុងបញ្ហាវារៈ ។ ចំណែកក្នុងបដិច្ចវារៈមកហើយដោយន័យជាដើមថា **ខន្ធ ៤ ដែលមិនមានរូបជាវិបាក ជាបច្ច័យ ដោយវិបាកប្បច្ច័យដល់គ្នានឹងគ្នា** ។ ក្នុងអធិការនេះ វិបាកដោយចំណែកមួយនៃធម៌ពួកណា ជាវិបាកប្បច្ច័យគប្បីឃើញថា លោកធ្វើការសម្ដែងន័យដោយអំណាចនៃធម៌ទាំងនោះ ។ ពិតហើយ វិបាករមែងជាបច្ច័យដល់រូប ដូចក្នុងអរូប ក្នុងកាមភូមិ និងរូបភូមិក៏ទេ ។

សូម្បីកាលមានភាពជាធម៌ឲ្យកើតមាន ការឧបត្ថម្ភក៏ជាកិច្ច ជាប្រធានរបស់អាហារទាំងឡាយ ព្រោះដូច្នោះ ទើបលោកអាចារ្យពោលថា **ដោយភាវៈ គឺធម៌ ដែលឧបត្ថម្ភរូប និងអរូបទាំងឡាយ** ។ ពិតហើយ ការដែលឧបត្ថម្ភសូម្បីមានភាពជាធម៌ដែលឲ្យកើតមាន ក៏រមែងជាកិច្ចដែលជាប្រធាននៃអាហារទាំងឡាយដែលមិនមានរូប និងរបស់រូបាហារដែលញ៉ាំងអាហារជរូបឲ្យកើតឡើង ។ កាលមិនមានភាពជាធម៌ដែលឲ្យកើត ក៏នៅជាប្រធាននៃរូបាហារដែលឧបត្ថម្ភរូប ដែលមានសមុដ្ឋាន ៤ តែកាលមិនមានធម៌ ដែលឧបត្ថម្ភធម៌ដែលធ្វើឲ្យកើត រមែងមិនមានដល់អាហារទាំងឡាយ ព្រោះហេតុនោះ ទើបធម៌ដែលឧបត្ថម្ភជាប្រធាន ។ ម្យ៉ាងទៀត អាហារសូម្បីធ្វើឲ្យកើត ក៏ឧបត្ថម្ភដោយមិនដាច់ខ្សែធ្វើឲ្យកើត ព្រោះហេតុនោះ ភាវៈនៃអាហារ ក៏គឺភាវៈដែលឧបត្ថម្ភនោះឯង ព្រោះដូច្នោះ ទើបលោកអាចារ្យពោលថា **ដោយអត្ថ ក៏គឺជាធម៌ដែលឧបត្ថម្ភ** ។ ចំណែកអាចារ្យពួកខ្លះ រមែងពោលថា **អាហារមិនជាអាហារប្បច្ច័យដល់រូបដែលខ្លួនធ្វើឲ្យកើត តែជាបច្ច័យដល់ធម៌ ដែលធម៌ដទៃធ្វើឲ្យកើត ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា ដោយអត្ថ ក៏គឺជាធម៌ដែលជាឧបត្ថម្ភ** ។ ពាក្យរបស់អាចារ្យពួកខ្លះនោះ អាចារ្យមួយពួកទៀត មិនព្រមទទួលថា **ពាក្យថា អាហារកាលជាបច្ច័យដល់រូប រមែងមិនជាអាហារប្បច្ច័យ** នេះខុស ។ ក្នុងអធិការនេះ

អាហារ គឺរូប រមែងជាអាហារប្បច្ច័យដល់រូបធម៌តែម្យ៉ាង ។ ចំណែកអាហារ គឺអរូប រមែងជាអាហារប្បច្ច័យដល់រូបធម៌ទាំងឡាយ ។ លោកអាចារ្យពោលពាក្យជាដើមថា **តែក្នុងបញ្ហាវារៈ** ដើម្បីសម្តែងថា សេចក្តីនោះឯង មិនមែនមានដល់រូបទាំងឡាយ ដែលមានចិត្តជាសមុដ្ឋានតែម្យ៉ាងប៉ុណ្ណោះទេ ដោយពិតនោះ រមែងមានដល់កដត្តារូបទាំងឡាយក្នុងគ្រាខ្លះដែរ ។

ក្នុងពាក្យថា **ដោយអត្ថ គឺភាពជាធំ** នេះជាភាពសំខាន់ដោយការគ្របសង្កត់ធម៌ ដែលបដិសេធការប្រព្រឹត្តទៅ ហើយធ្វើឲ្យប្រព្រឹត្តទៅ ដូចជាធម៌ គឺអធិបតិប្បច្ច័យ ទើបឈ្មោះថា អត្ថ គឺភាពជាធំ ក៏មិនមាន ដោយពិតនោះ បានដល់ ធម៌ដែលអនុវត្តតាមធម៌មានចក្ខុជាដើម ដោយធម៌ដែលជាបច្ច័យដល់ចក្ខុជាដើមក្នុងកិច្ចនោះៗ យ៉ាងនេះ គឺដោយចក្ខុវិញ្ញាណជាដើមក្នុងកិច្ច គឺការឃើញជាដើម ដោយកម្មជរូប និងអរូបធម៌ទាំងឡាយដែលកើតនៅក្នុងការរស់នៅ ដោយសម្បយុត្តធម៌ទាំងឡាយក្នុងការនឹកគិត ដោយសត្វទាំងឡាយដែលបានទទួលសេចក្តីសុខជាដើម ក្នុងភាពជាបុគ្គលបានទទួលសេចក្តីសុខជាដើម ដោយធម៌ដែលកើតរួមគ្នា មានសទ្ធាជាដើមក្នុងការបង្អោនចិត្តជឿ ការផ្គងទុក ការចូលទៅប្រាកដ ការមិនរាយមាយ និងការដឹងទូទៅ ក្នុងការដឹងទូទៅ ព្រោះប្រព្រឹត្តទៅថា **យើងនឹងដឹងធម៌ដែលមិនទាន់ដឹង** ដូច្នេះ និងក្នុងធម៌ដែលដឹងទូទៅដល់ហើយ ។ ភាពជាធំនៃធម៌ មានចក្ខុជាដើមក្នុងកិច្ចទាំងនោះ ក៏គឺការប្រព្រឹត្តទៅក្នុងកិច្ចទាំងនោះ ដោយប្រព្រឹត្តទៅតាមកិច្ចទាំងនោះនៃធម៌ដែលជាបច្ច័យដល់ធម៌ មានចក្ខុជាដើមនោះ ។ សួរថា ក្នុងអធិការនេះ ព្រោះហេតុអ្វី ទើបលោកមិនកាន់យកឥត្ថិន្ទ្រិយ និងបុរិសិន្ទ្រិយទាំង ២ ក៏ឥត្ថិន្ទ្រិយ និងបុរិសិន្ទ្រិយទាំង ២ នេះ ដែលធម៌មានភេទជាដើមប្រព្រឹត្តទៅតាមមិនមែនឬ ? ឆ្លើយថា ពិត ធម៌មានភេទជាដើម ប្រព្រឹត្តទៅតាម តែមិនមែនជាបច្ច័យ ។ ដូចជាជីវិត និងអាហារ ជាបច្ច័យដល់ធម៌ណា រមែង

ជាធម៌តាមរក្សា និងឧបត្ថម្ភដល់ធម៌ទាំងនោះ និងជាអត្ថិប្បច្ច័យអវិគតប្បច្ច័យផងដែរ ដល់ធម៌ទាំងនោះ សេចក្តីនេះយ៉ាងណា ឥត្ថិភាវៈ និងបុរិសភាវៈ មិនជាឧបការៈដោយប្រការណាមួយដល់ធម៌ មានភេទជាដើមដូច្នោះឡើយ ព្រោះគប្បីមានបច្ច័យ និងធម៌មានភេទជាដើម ដែលប្រព្រឹត្តទៅដោយបច្ច័យតាមសមគួរដល់ខ្លួននោះឯង ជាបច្ច័យដល់ការកាន់យកភាពជាស្រីជាដើម ដោយប្រការណា ដូច្នោះ ទើបលោកពោលធម៌ទាំងនោះ មានភេទជាដើមប្រព្រឹត្តទៅតាម និងជាឥន្ទ្រិយដល់ធម៌ទាំងនោះ ព្រោះការមិនប្រព្រឹត្តទៅក្នុងសន្តាន ដែលប្រកបដោយធម៌នោះ ដោយប្រការដទៃ ។ ព្រោះហេតុនោះ ទើបលោកមិនពោលធម៌ទាំងនោះ ជាឥន្ទ្រិយប្បច្ច័យ ។ ក្នុងពាក្យថា **ឥន្ទ្រិយ ៥ មានចក្ខុន្ទ្រិយជាដើម ជាបច្ច័យដល់អរូបធម៌ទាំងឡាយតែម្យ៉ាង** នេះ បណ្ឌិតគប្បីឃើញថា លោកកាន់យកសុខិន្ទ្រិយ និងទុក្ខិន្ទ្រិយ ដោយស័ព្ទថា **ចក្ខុ** ជាដើម ។

ការចូលទៅកាន់អារម្មណ៍ ដោយអំណាចនៃការត្រិះរិះជាដើមនៃធម៌ មានវិតក្កជាដើមដែលជាលក្ខណូបនិជ្ឈាន និងអារម្មណូបនិជ្ឈាន សម្លឹង គឺមើល ឬគិត បានដល់ការប្រមូលមកដោយពិសេសនៃធម៌ មានវិតក្កជាដើមនោះឯង ឈ្មោះថា **ការចូលទៅសម្លឹង** ។ គប្បីឃើញថា លោកអាចារ្យសូម្បីពោលថា **វៀរវេទនាទាំង ២ គឺសុខ និងទុក្ខក្នុងទ្វិបញ្ចវិញ្ញាណ** ដូច្នេះហើយ ក៏បានធ្វើការបដិសេធឧបេក្ខា និងឯកគ្គតានៃចិត្តដែលមិនជាអង្គឈាន ដោយពាក្យថា **អង្គឈាន ៧** ដូច្នេះ ។ បើយ៉ាងនោះ កាលអត្ថសម្រេចហើយ ដោយពាក្យនេះថា អង្គឈាន ៧ នោះឯង ព្រោះហេតុអ្វី ទើបពោលថា **វៀរវេទនា ២ គឺសុខ និងទុក្ខទៅវិញ** ? ឆ្លើយថា ព្រោះក្នុងបណ្តាប្រភេទនៃវេទនាទាំង ៥ សុខ ទុក្ខ ទាំង ២ លោកបានសម្តែងលម្អិតទុកហើយក្នុងឋានៈជាអង្គឈាន ដើម្បីសម្តែងថា មិនមែនជាអង្គឈានដោយចំណែកមួយ ឬថា កាលមានវោហារថា ជាអង្គឈាន ក៏ដើម្បីសម្តែងការមិនមាន ដែលប្រភេទនៃវេទនាទាំង

២ ជាឈានប្បច្ច័យដោយចំណែកមួយ ។ ម្យ៉ាងទៀត ការមិនមានភាពជាឈានប្បច្ច័យ មានដល់ឧបេក្ខា និងឯកគ្គតានៃចិត្តក៏ពិត សូម្បីដូច្នោះ ការមិនជាឈានប្បច្ច័យក៏រមែង មិនមាន ព្រោះដូច្នោះ ទើបលោកអាចារ្យបានធ្វើការកាន់យកក្នុងពាក្យនេះថា **អង្គឈាន ទាំងអស់ ៧** ។ ក្នុងពាក្យនោះ ពាក្យថា **ទាំងអស់** គប្បីឃើញថា ដើម្បីនឹងរួមយកធម៌ មានកុសលទាំងអស់ជាដើម តែមិនមែនប្រើដើម្បីរួមធម៌ដែលជាចិត្តុប្បាទទាំងអស់ ។ ចំណែកបាឋៈរបស់អាចារ្យពួកណាថា **ឋបេត្វា ទ្វិបញ្ចវិញ្ញាណេ វេទនាត្តយំ** ប្រែថា វៀរវេទនាទាំង ៣ ក្នុងទ្វិបញ្ចវិញ្ញាណ ការពិចារណាតាមដែលពោលហើយរបស់ អាចារ្យទាំងនោះ ក៏គប្បីជ្រាបទាក់ទងនឹងឯកគ្គតានៃចិត្តនោះឯង ។

ពីរបទថា **យតោ តតោ វា** ( អំពីវត្ថុណាក៏ស្រេចតែ ) ដោយអត្ថ បានដល់ អំពីប្រពៃ ឬខុស ។ ពាក្យថា **តែក្នុងបញ្ហាវារៈ** ជាដើម លោកពោលទុកដើម្បីសម្តែង ថា អត្ថនោះធ្វើឲ្យយល់ហើយនោះឯង ដោយស័ព្ទថា មានមគ្គនោះជាសមុដ្ឋាន ក្នុង និទ្ទេសនៃបច្ច័យក៏ពិត សូម្បីយ៉ាងនោះ ក្នុងបញ្ហាវារៈលោកបានកាន់យកដោយសរុប នោះឯង ។ គប្បីជ្រាបពាក្យដ៏សេសថា **ឈានប្បច្ច័យ និង មគ្គប្បច្ច័យទាំង ២ នេះ មិនមានក្នុងទ្វិបញ្ចវិញ្ញាណតាមចំនួន** ។ តែ **ក្នុងអដ្ឋកថាបដ្ឋាន** លោកពោលទុកថា **ឈានប្បច្ច័យ និង មគ្គប្បច្ច័យទាំង ២ មិនមានក្នុងអហេតុកចិត្តទាំងឡាយ** ។ សួរថា ដោយហេតុនោះ ពាក្យក្នុងអដ្ឋកថាបដ្ឋាននោះ មិនជំទាស់គ្នាបានដូចម្តេច ? ឆ្លើយថា មិនជំទាស់គ្នាដោយអំណាចការអធិប្បាយ ។ ពិតហើយ ក្នុងអដ្ឋកថាបដ្ឋាននោះ មាន អធិប្បាយដូច្នេះ ឈានប្បច្ច័យ និងមគ្គប្បច្ច័យ មិនបាននៅក្នុងអហេតុកចិត្តតែម្យ៉ាង និងមិនបានក្នុងសហេតុកចិត្តក៏ទេ ព្រោះដូច្នោះ ទើបលោកពោលទុកដើម្បីសម្តែងការ មិនមានការមិនបានក្នុងសហេតុកចិត្តទាំងឡាយ មិនមែនពោលទុកដើម្បីសម្តែងការ មិនមានការបាន ក្នុងអហេតុកចិត្តឡើយ ។ ដើម្បីកាន់យកភាវៈយ៉ាងនេះ រមែងធ្វើឲ្យ

យល់ថា លោកមិនបានបដិសេធការបានរបស់ណាមួយ ក្នុងទី ១៦ នៃអហេតុកចិត្តទាំងឡាយឡើយ ។ ដោយហេតុនោះ ទើបលោកព្រមទទួលយកការមាននៃឈានបច្ច័យក្នុងអហេតុកចិត្ត ដែលមានវិតក្កទាំងឡាយ ។ ក្នុងការមាននៃឈានបច្ច័យនោះ ក្នុង **គម្ពីរធម្មសង្គណី** លោកមិនបានលើកឈានឡើងក្នុងសង្គហសុញ្ញតទ្វារនៃមនោធាតុជាដើម ដោយការមិនបាន លោកសំដៅដល់ការមិនបាននោះ ទើបពោលការមិនបានក្នុងអហេតុកចិត្តទាំងឡាយនៃឈានបច្ច័យ ។ ដូចជាការទាញយកសហជាតធម៌ទាំងឡាយនៃធម៌ មានវិតក្កជាដើមក្នុងចិត្តុប្បាទ ដែលជាសហេតុកៈមកធ្វើការៈ ដែលដល់នូវឯកកាពជាការប្រមូលគឺការចូលទៅសម្ងឹងដែលមានកម្លាំងយ៉ាងណា ក្នុងចិត្តុប្បាទដែលជាអហេតុកៈ ក៏ដូច្នោះមិនមាន ដូច្នេះ ។ ក្នុងទីនេះ ការចូលទៅសម្ងឹងសូម្បីមានកម្លាំង និងមានសូម្បីត្រឹមតែបន្តិចបន្តួចក៏ពិត សូម្បីដូច្នោះ មិនមានភាពជាឧបការៈដោយការចូលទៅសម្ងឹងនោះក៏ទេ ព្រោះហេតុនោះ លោកអាចារ្យកាលព្រមទទួលឈានបច្ច័យក្នុងអហេតុកចិត្ត ដែលមានវិតក្ក ទើបពោលថា **ឈានបច្ច័យ និងមគ្គបច្ច័យទាំង ២ នេះ មិនបាននៅក្នុងទ្វិបញ្ចវិញ្ញាណ និងអហេតុកចិត្តទាំងឡាយ ។** ធម្មតាកថាពោលដោយបច្ច័យ ពីងផ្អែកសមន្តប្បដ្ឋាន មិនមែនពីងផ្អែកធម្មសង្គណីនោះឡើយ ។

ធម៌ឧបការៈ ដូចក្នុងការចូលដល់ភាពតែមួយ ព្រោះជាធម៌ប្រកបគ្នាដោយប្រការទាំងឡាយជានិច្ច គឺមិនមែនប្រាសចាកភាពជានិច្ច ដោយប្រពៃ ឬរួមគ្នា ឈ្មោះថា សម្បយុត្តបច្ច័យ លោកអាចារ្យពោលថា **ពោល គឺមានវត្ថុជាមួយគ្នា មានអារម្មណ៍ជាមួយគ្នា កើតព្រមគ្នា រលត់ព្រមគ្នា** ដូច្នោះ ដើម្បីចៀសវាងពាក្យសួរថា ធម៌ប្រកបគ្នាដោយប្រការទាំងឡាយ គឺអ្វី ។ ក្នុងពាក្យថា កាលពោលត្រឹមប៉ុណ្ណោះថា ធម៌ពួកណាមានវត្ថុជាមួយគ្នា ធម៌ទាំងនោះក៏សម្បយុត្តគ្នា គឺប្រកបគ្នា ហើយដូច្នេះ

ក្នុងបណ្តាអវិនិព្ភោគរូបទាំងឡាយ មហាភូតរូប ១ រមែងជានិស្សយប្បច្ច័យដល់មហាភូតរូបដ៏សេស និងឧបាទាយរូបទាំងឡាយ មហាភូតរូបដ៏សេស និងឧបាទាយរូបប៉ុណ្ណោះមានវត្ថុជាមួយនឹងមហាភូតរូបមួយនោះ ម្យ៉ាងទៀត ភូតរូបទាំងឡាយដែលជាទីអាស្រ័យនៃចក្ខុជាដើម ក៏ជាវត្ថុមួយអាស្រ័យនៅក្នុងភូតរូបទាំងនេះ ហេតុនោះកាលគិតថា មានវត្ថុជាមួយគ្នា រូបទាំងនោះក៏គប្បីដល់នូវភាពជាសម្បយុត្តធម៌ផងដែរ ព្រោះដូច្នោះ ទើបលោកប្រើស័ព្ទថា មានអារម្មណ៍ជាមួយគ្នា ដើម្បីបដិសេធគំនិតនោះចោល ។ ម្យ៉ាងទៀត បើបុគ្គលគិតយ៉ាងនេះថា ធម៌ពួកណាមានវត្ថុដូចគ្នា និងមានអារម្មណ៍ដូចគ្នា ធម៌ទាំងនោះជាសម្បយុត្តធម៌ គឺប្រកបគ្នាដូច្នេះ ធម៌ទាំងឡាយមានសម្បដិច្ឆន្នៈ និងសន្តីរណៈជាដើមដែលជិត ចំពោះចុតិក៏គប្បីត្រូវជាសម្បយុត្តធម៌ គឺប្រកបគ្នាផងដែរ ព្រោះដូច្នោះ ទើបលោកប្រើស័ព្ទថា កើតព្រមគ្នា ។ កាលមានការពិចារណាថា ធម៌ពួកណាមានវត្ថុជាមួយគ្នា មានអារម្មណ៍ជាមួយគ្នា កើតព្រមគ្នា ធម៌ទាំងនោះជាសម្បយុត្តធម៌ គឺប្រកបគ្នា ព្រោះដូច្នោះ ធម៌ដែលមានការរលត់ផ្សេងគ្នា ក៏រមែងជាសភាវៈមានលក្ខណៈ ៣ យ៉ាង យ៉ាងនេះឬ ឬធម៌ដែលមានការរលត់ព្រមគ្នាប៉ុណ្ណោះទេ ទើបលោកអាចារ្យពោលថា **មានការរលត់ព្រមគ្នា** ដូច្នេះ ដើម្បីសម្តែងថា ធម៌ដែលមានការរលត់ ព្រមគ្នាប៉ុណ្ណោះ ទើបជាសភាវៈមានលក្ខណៈយ៉ាងនេះ ។

ម្យ៉ាងទៀត ដោយបដិលោមន័យ កាលពោលថា ធម៌ដែលមានការរលត់ព្រមគ្នាជាសម្បយុត្តធម៌ គឺប្រកបគ្នា ដូច្នេះ ទាំងរូបធម៌ និងអរូបធម៌ទាំងឡាយ ដែលរលត់ទៅក្នុងខណៈជាមួយគ្នា ក៏ត្រូវជាសម្បយុត្តធម៌ គឺប្រកបគ្នាទៅ ព្រោះដូច្នោះ ទើបលោកអាចារ្យពោលថា **កើតព្រមគ្នា** សូម្បីយ៉ាងនេះ អវិនិព្ភោគរូបទាំងឡាយក៏ជាធម៌កើតព្រមគ្នា និងរលត់ព្រមគ្នា ព្រោះដូច្នោះ សូម្បីអវិនិព្ភោគរូបទាំងនោះ ក៏ត្រូវជាសម្បយុត្តធម៌ទៅដែរ ព្រោះដូច្នោះ ដើម្បីបដិសេធគំនិតនោះ ទើបលោកប្រើស័ព្ទថា មាន

អារម្មណ៍ជាមួយគ្នា ធម៌ពួកណា ជាសភាវៈមានអារម្មណ៍ជាមួយគ្នា ជាធម៌ដែលកើតព្រមគ្នា រលត់ព្រមគ្នា ធម៌ទាំងនោះ ឈ្មោះថា **ជាសម្បយុត្តធម៌** ព្រោះដូច្នោះ ទើបលោកប្រើសព្ទថា មានវត្ថុជាមួយគ្នា ដើម្បីសម្ដែងថា ន័យនេះ រមែងបានក្នុងធម៌ដែលមានវត្ថុជាមួយគ្នាប៉ុណ្ណោះ មិនមែនបានក្នុងធម៌ ដែលមានវត្ថុផ្សេងគ្នាឡើយ ។លោកប្រើសព្ទថា មានវត្ថុជាមួយគ្នានេះ ដោយសម្ព័ន្ធដល់បញ្ចវោការភពថា ធម៌ពួកណាមានវត្ថុជាមួយគ្នា មានអារម្មណ៍ជាមួយគ្នា កើតព្រមគ្នា រលត់ព្រមគ្នា ធម៌ទាំងនោះជាសម្បយុត្តធម៌ ។ ចំណែកក្នុងអរូបភពមិនមានវត្ថុឡើយ ព្រោះដូច្នោះ ឱកាសដែលប្រើសព្ទថា មានវត្ថុជាមួយគ្នា នឹងមានមកពីណា ។

សភាវធម៌ទាំងឡាយសូម្បីជាធម៌ប្រកបគ្នាដោយសម្ពន្ធគ្នានឹងគ្នាដែលឧបការៈគ្នាដោយការចូលដល់ភាពបែកគ្នា ព្រោះការមិនច្រឡំគ្នា ដោយការមិនប្រកបគ្នា ឈ្មោះថា វិប្បយុត្តប្បច្ច័យ ។ វិប្បយុត្តប្បច្ច័យនេះ គួរកាន់យកដោយជាធម៌ដែលជាបច្ច័យនិងដែលកើតអំពីបច្ច័យ ដូចជាក្នុងសម្បយុត្តប្បច្ច័យក៏ទេ ដោយពិត គប្បីកាន់យកដោយបែកគ្នាតែម្យ៉ាង ។ ក៏ក្នុងបណ្ដាធម៌ទាំងនោះ អរូបធម៌ទាំងឡាយ មានការរួមគ្នាព្រោះមានជាតិស្មើគ្នា ក្នុងទីនេះរូបធម៌ និងអរូបធម៌ មានការបែកគ្នា ព្រោះមានជាតិផ្សេងគ្នា ។ ដោយហេតុនោះ ទើបពោលថា **សភាវធម៌ទាំងឡាយ ជាធម៌ប្រកបគ្នាដោយសម្ពន្ធគ្នានឹងគ្នា ជាធម៌ដែលឧបការៈគ្នា ដោយការចូលដល់ភាពបែកគ្នា ឈ្មោះថាជាវិប្បយុត្តប្បច្ច័យ** ។ធម៌ទាំងឡាយ មានរូបជាដើម មិនប្រកបគ្នាដោយវត្ថុ និងអំណាចភាពជាសហជាត និងបច្ឆាជាតឧបការៈគ្នាដោយជាអារម្មណ៍ជាដើម សូម្បីបែកគ្នាជាវិប្បយុត្តប្បច្ច័យ មានក៏ទេ ។ ដូចជាធម៌ដែលប្រកបគ្នាដោយវត្ថុ និងទាក់ទងជាសហជាត និងបច្ឆាជាត រមែងជាវិប្បយុត្តប្បច្ច័យ ដោយព្រះបាលីជាដើមថា **វត្ថុជាបច្ច័យដោយវិប្បយុត្តប្បច្ច័យដល់ខន្ធទាំងឡាយ កុសលក្ខន្ធដែលជាសហជាត ជា**

បច្ច័យដោយវិប្បយុត្តប្បច្ច័យដល់រូបដែលមានចិត្តជាសមុដ្ឋានទាំងឡាយ កុសលក្ខន្ធ ដែលជាបច្ឆាជាតជាបច្ច័យ ដោយវិប្បយុត្តប្បច្ច័យដល់កាយនេះ ដែលកើតមុន យ៉ាងណា ធម៌ដែលមិនប្រកបគ្នាយ៉ាងនេះ មិនមានភាពជាវិប្បយុត្តប្បច្ច័យដូច្នោះឡើយ ដូច្នេះ ។ សួរថា បើយ៉ាងនោះ ហេតុអ្វី ទើបលោកមិនពោលរូបទាំងឡាយជាវិប្បយុត្ត-ប្បច្ច័យដល់រូបទាំងឡាយ ? ឆ្លើយថា ព្រោះរូប និងរូប សូម្បីមិនមានការបែកគ្នា ក៏មិនមានការបែកគ្នា ដូចការប្រកបគ្នា ព្រោះដូច្នោះ រូប និងរូបទាំងនោះ ទើបលោក មិនបានពោលថា ជាវិប្បយុត្តប្បច្ច័យ ។ សេចក្ដីនេះ សមដូចព្រះបាលីត្រាស់ទុកថា **ការប្រកបបានដោយធម៌ ៤ ការប្រកបមិនបានដោយធម៌ ៤** ។ ពិតហើយ អាចមាន ការសង្ស័យបានថា អរូបទាំងឡាយដែលប្រកបគ្នា និងប្រកបចូលជាមួយរូបទាំងឡាយ ហើយរូបទាំងឡាយនឹងប្រកបចូលជាមួយអរូបទាំងឡាយនោះ ដូច្នោះ ទើបលោក ពោលថា អរូប និងរូបទាំងនោះ ជាវិប្បយុត្តប្បច្ច័យដល់គ្នានឹងគ្នា ។ ចំណែករូប និង រូបទាំងឡាយប្រកបគ្នា មិនមាន ព្រោះដូច្នោះ ទើបលោកមិនពោលថា រូប និងរូបទាំង នោះជាវិប្បយុត្តប្បច្ច័យ ។

សព្ទថា អរូប ក្នុងពាក្យថា **រូបធម៌ទាំងឡាយជាវិប្បយុត្តប្បច្ច័យដល់អរូបធម៌ ទាំងឡាយ សូម្បីអរូបធម៌ទាំងឡាយ** ក៏ជាវិប្បយុត្តប្បច្ច័យដល់រូបធម៌ទាំងឡាយ គប្បីជ្រាបទាក់ទងនឹងខន្ធ ៤ ។ ពិតហើយ ក្នុងបណ្ដាអរូបធម៌ទាំងឡាយ ខន្ធ ៤ ប៉ុណ្ណោះ ជាវិប្បយុត្តប្បច្ច័យដល់រូបធម៌ទាំងឡាយដែលជាសហជាត និងបុរេជាត ។ ចំណែក និព្វាន រមែងមិនជាវិប្បយុត្តប្បច្ច័យដល់រូបធម៌ទាំងឡាយ ដូចជាមិនសម្បយុត្តប្បច្ច័យ ដល់អរូបធម៌ទាំងឡាយ ។ សេចក្ដីនេះ សមដូចព្រះបាលីត្រាស់ទុកថា **ការប្រកបបាន ដោយធម៌ ៤ ការប្រកបមិនបានដោយធម៌ ៤** ព្រោះដូច្នោះ បណ្ដាអរូបធម៌ទាំងឡាយ ខន្ធ ៤ ប៉ុណ្ណោះ ទើបជាវិប្បយុត្តប្បច្ច័យ ។ មួយវិញទៀត **ក្នុងបញ្ហាវារៈ** បានត្រាស់ទុកថា

កុសលក្ខន្ធដែលជាសហជាត ជាវិប្បយុត្តប្បច្ច័យដល់រូបទាំងឡាយ ដែលមានចិត្តជាសមុដ្ឋាន ។ ពាក្យថា *រូបធម៌ទាំងឡាយ* នេះ គប្បីជ្រាបទាក់ទងនឹងហទយវត្ថុ និងវត្ថុ មានចក្ខុជាដើម ។ ព្រោះថា ក្នុងបណ្តារូបធម៌ទាំងឡាយ វត្ថុ ៦ ប៉ុណ្ណោះ ជាវិប្បយុត្តប្បច្ច័យដល់អរូបក្ខន្ធទាំងឡាយ ។ ចំណែកធម៌ដែលជាអារម្មណ៍ទាំងឡាយ មានរូបាយតនៈជាដើម ជាធម៌ដែលមិនប្រកបគ្នាក៏ពិត សូម្បីយ៉ាងនោះ ក៏មិនជាវិប្បយុត្តប្បច្ច័យ ។ ព្រោះហេតុអ្វី ? ព្រោះមិនមានប្រការ ដែលត្រូវសង្ស័យថា ប្រកបគ្នា ។ ពិតហើយ អរូបក្ខន្ធទាំងឡាយ រមែងកើតឡើង ដូចជាកំពុងចេញអំពីខាងក្នុងនៃវត្ថុទាំងឡាយ មានចក្ខុជាដើម ព្រោះហេតុនោះ ទើបគួរមានសេចក្តីសង្ស័យក្នុងអរូបធម៌ទាំងនោះថា **អរូបធម៌ទាំងនេះប្រកបជាមួយ រូបធម៌ទាំងនេះឬហ្ន៎ ឬមិនប្រកបគ្នាទេ ។** ចំណែកធម៌ដែលជាអារម្មណ៍ រមែងត្រឹមតែអារម្មណ៍នៃធម៌ទាំងឡាយដែលកំពុងកើតឡើង ដោយទីអាស្រ័យ គឺវត្ថុ ព្រោះហេតុនោះ ក្នុងធម៌ដែលជាអារម្មណ៍ទាំងនោះ ទើបមិនមានប្រការដែលគួរសង្ស័យថា ប្រកបគ្នា ព្រោះហេតុនោះ ទើបធម៌ដែលជាអារម្មណ៍ទាំងនោះ មិនប្រកបគ្នា ។ វត្ថុប៉ុណ្ណោះឯង រមែងជាវិប្បយុត្តប្បច្ច័យ ព្រោះមិនមានប្រការដែលគួរសង្ស័យថា ប្រកបគ្នា ។ សេចក្តីនេះ សមដូចព្រះបាលីត្រាស់ទុកក្នុង **បញ្ហាវារៈ** ជាដើមថា វត្ថុជាវិប្បយុត្តប្បច្ច័យដល់កុសលក្ខន្ធទាំងឡាយ វត្ថុជាវិប្បយុត្តប្បច្ច័យដល់អកុសលក្ខន្ធទាំងឡាយ ចក្ខាយតនៈជាវិប្បយុត្តប្បច្ច័យដល់ចក្ខុវិញ្ញាណធាតុ ។ វិប្បយុត្តប្បច្ច័យនេះ គប្បីជ្រាបថា មាន ៥ យ៉ាង គឺជាអព្យាកតៈដោយកុសលជាសហជាត និងបច្ឆាជាត ជាអព្យាកតៈ ដោយអកុសលជាសហជាត និងបច្ឆាជាតដូចគ្នា ជាអព្យាកតៈ ដោយអព្យាកតៈ ជាសហជាត បុរេជាត និងបច្ឆាជាត ជាកុសល ដោយអព្យាកតៈ ជាវត្ថុបុរេជាត ជាអកុសល ដោយអព្យាកតៈ ជាវត្ថុបុរេជាតដូចគ្នា រួមជាកុសលមូល ១ អកុសលមូល ១ អព្យាកតមូល ៣ ។

ពាក្យថា **មានលក្ខណៈជាបច្ចុប្បន្ន** គឺមានសភាពជាបច្ចុប្បន្ន ។ ដោយពាក្យនោះ លោកអាចារ្យរមែងបដិសេធភាវៈដែលមាន មានលក្ខណៈ គឺការឲ្យកើតឡើងហើយ និងដែលកំពុងបាន ដូចព្រះមានព្រះភាគបានត្រាស់ទុកក្នុងពាក្យជាដើមយ៉ាងនេះថា **បាបកម្មដែលយើងធ្វើហើយមាន** និងថា **បុគ្គលអ្នកបដិបត្តិដើម្បីប្រយោជន៍ដល់ខ្លួនមាន** ។ សូម្បីជាធម៌ដែលឲ្យកើតមានភាវៈដែលជាធម៌ឧបត្ថម្ភ ដោយភាវៈដែលមាន ដែលមានភាពជាធម៌ឧបការៈជាប្រធាន ក៏រមែងមាន ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **ជាធម៌ឧបត្ថម្ភ** ។ ឯធម៌ឧបត្ថម្ភនេះ គប្បីឃើញថា បានដល់ធម៌ឧបការៈដោយភាវៈដែលមាន ដែលទូទៅដល់ធម៌ មានវត្ថុ អារម្មណ៍ និងសហជាតជាដើម ។ លោកអាចារ្យពោលពាក្យថា **យថាហ** ដូចដែលត្រាស់ទុកដូច្នេះជាដើម ដើម្បីសម្តែងអត្ថដែលលោកបានពោលទុកថា **ដាក់មាតិកាទុក ៧ យ៉ាង** ដោយព្រះបាលីនោះឯង ។ ក្នុងបណ្តាពាក្យទាំងនោះ ពាក្យថា **អរូបក្ខន្ធ ៤** ជាដើម លោកសម្តែងអត្ថិប្បច្ច័យ ដោយជាសហជាត ដោយពាក្យថា **ចក្ខាយតនៈ** ជាដើម លោកសម្តែងអត្ថិប្បច្ច័យ ដោយជាបុរេជាត ដោយពាក្យថា **អាស្រ័យរូបណា** ជាដើម លោកសម្តែងអត្ថិប្បច្ច័យ ដោយជាសហជាត និងបុរេជាត ។ បាឋៈនេះមកហើយ ដោយជាអត្ថិប្បច្ច័យដែលជាសហជាត និងបុរេជាតនោះឯង ដោយប្រការដូច្នេះ ។

លោកអាចារ្យពោលពាក្យជាដើមថា **តែក្នុងបញ្ហាវារៈ** ដូច្នេះ ដើម្បីសម្តែងថា ចំណែកក្នុងទីដទៃ អត្ថិប្បច្ច័យ មកហើយដោយប្រការដទៃអំពីនោះ ។ ពាក្យនោះ រមែងសម្តែងដល់អត្ថិប្បច្ច័យ ដោយជាបច្ឆាជាត អាហារ និងឥន្ទ្រិយនោះ ។ ចំណែកក្នុងបាឋៈដំបូង គប្បីជ្រាបថា លោកធ្វើទេសនា មានចំណែកសល់ទុក ។ ម្យ៉ាងទៀត ធម៌ទាំងឡាយជាបច្ច័យដល់ធម៌ពួកណា កាលមានភាវៈដែលកើតឡើង ព្រមគ្នាមុន និងខាងក្រោយធម៌ទាំងនោះ អាហារ និងឥន្ទ្រិយ ក៏រមែងមិនបានភាពផ្សេង មាន

សហជាតជាដើម ព្រោះមិនមានភាពជាបច្ច័យ មានសហជាតប្បច្ច័យជាដើម និងការមិនមាននៃសហជាតជាដើមនោះ ក៏គប្បីឃើញទាក់ទងដោយសភាវៈនៃធម៌របស់ធម៌ទាំងនោះ ។ អត្ថិប្បច្ច័យនេះមាន ១៣ យ៉ាង គឺជាកុសល ដោយកុសល ជាសហជាត ១ ជាអព្យាកតៈដោយកុសល ជាសហជាត និងបច្ឆាជាត ១ ជាកុសលអព្យាកតៈដោយកុសល ជាសហជាតតែម្យ៉ាង ១ រួមជាកុសលមូល ៣ ជាអកុសលមូល ៣ ដូចគ្នា ។ ចំណែកអព្យាកតៈដោយអព្យាកតៈ ជាសហជាត បុរេជាត បច្ឆាជាត អាហារ និងឥន្ទ្រិយ ១ ជាកុសលដោយអព្យាកតៈ ជាវត្ថារម្មណៈ និងបុរេជាត ១ ជាអកុសលក៏ដូចគ្នា ១ ។ ជាកុសល និងអព្យាកតៈនៃកុសល ជាសហជាត និងបុរេជាត ១ ជាកុសល និងអព្យាកតៈនៃអព្យាកតៈជាសហជាត បុរេជាត បច្ឆាជាត អាហារ និងឥន្ទ្រិយ ១ ជាអកុសល និងអព្យាកតៈ នៃអព្យាកតៈ ជាសហជាត និងបុរេជាត ១ ជាអកុសល និងអព្យាកតៈនៃអព្យាកតៈ ជាសហជាត បុរេជាត បច្ឆាជាត អាហារ និងឥន្ទ្រិយ ១ ។ ដោយបង្រួញអត្ថិប្បច្ច័យ មាន ៥ គឺជាកុសល អកុសល វិបាក កិរិយា និងរូប ។ និព្វានមិនជាអត្ថិប្បច្ច័យ ។ ពិតហើយ ធម៌ណាមិនឧបការៈ ព្រោះមិនមានភាវៈដែលមាន បានភាវៈដែលមានហើយ ក៏ជាធម៌ដែលឧបត្ថម្ភធម៌នោះ រមែងឈ្មោះថាជាអត្ថិប្បច្ច័យ ។ ឯនិព្វានសម្រាប់ធម៌ដែលមាននិព្វានជាអារម្មណ៍ជាធម្មជាតិមិនជាធម៌ដែលឧបការៈ ព្រោះមិនមានភាវៈដែលមានដល់ខ្លួន និងជាធម្មជាតិដែលឧបការៈ ក៏ព្រោះការបានភាវៈដែលមានក៏ទេ ដូច្នេះ ប្រការមួយទៀត ភាវៈដែលជាធម៌ឧបការៈ ដែលខុសទៅអំពីភាពជាធម៌ដែលឧបការៈ គឺភាវៈដែលមិនមាននៃធម៌ដែលប្រកប និងការកើតឡើងជាដើម ក៏ជាអត្ថិប្បច្ច័យ ព្រោះដូច្នោះ ទើបនិព្វានមិនជាអត្ថិប្បច្ច័យ ។

ធម៌ដ៏ច្រើន មានផស្សៈជាដើម ដែលប្រព្រឹត្តទៅទាក់ទងនឹងការពាល់ត្រូវជាដើម

ក្នុងអារម្មណ៍ មិនមានភាវៈរួមគ្នា ព្រោះដូច្នោះ កាលមានការប្រជុំនៃធម៌ មានផស្សៈជាដើមឯណានីមួយ ក៏មិនមានការប្រជុំនៃធម៌ មានផស្សៈជាដើមជាទី ២ តែកាលមិនមាន រមែងមានការប្រជុំជាទី ២ បាន ព្រោះដូច្នោះ កិច្ចឧបការៈដោយភាវៈ ដែលមិនមាននោះ ទើបជា **នត្ថិប្បច្ច័យ** ។ សូម្បីមានភាវៈដែលមិនមាននៃចិត្តដែលកើតឡើងមុន ចិត្តដែលកើតឡើងមុនទាំងនោះ មិនជាធម៌ឧបការៈដោយភាវៈដែលមិនមាននោះឡើយ តែធម្មជាតិដែលមិនបានឱកាសនៃការប្រព្រឹត្តទៅដោយភាវៈ ដែលមាននៃខ្លួនក្នុងលំដាប់នោះឯង រមែងជាធម៌ឧបការៈ ដូចជាឲ្យឱកាស ដោយភាវៈដែលមិនមាន ព្រោះដូច្នោះ ទើបលោកអាចារ្យពោលថា **ជាធម៌ឧបការៈដោយការឲ្យឱកាសនៃការប្រព្រឹត្តទៅ** ។ បទថា **បដុប្បន្នានំ** សេចក្តីប៉ុនគ្នានឹង **បច្ចុប្បន្នានំ** ប្រែថា ដែលជាបច្ចុប្បន្ន ។

ដោយបទថា **តេ ឯវ** នេះ លោកអាចារ្យពោលដល់ភាពមិនមានសេចក្តីផ្សេងគ្នាដោយធម៌នៃនត្ថិប្បច្ច័យ និងវិគតប្បច្ច័យ ។ កាលបើយ៉ាងនេះការឲ្យឱកាស គឺជាធម៌ឧបការៈដោយត្រឹមតែការមិនមាន ជានត្ថិប្បច្ច័យ ជាធម៌ដែលឧបការៈដោយប្រាសចាកសភាវៈនៃធម៌ទាំងឡាយ ដែលមិនប្រព្រឹត្តទៅ ដោយមិនទាន់ប្រាសចាកសភាវៈក៏ជាវិគតប្បច្ច័យ ។ **ភាវៈដែលមិនមាន** បានដល់ ភាពទទេក្នុងលំដាប់នៃការរលត់ **ភាវៈដែលប្រាសទៅ** បានដល់ ភាវៈដែលធ្លុះបញ្ចាំងការរលត់នត្ថិប្បច្ច័យ និងវិគតប្បច្ច័យនេះមានភាពផ្សេងគ្នាដូចពោលមកនេះ ។

ច-ស័ព្ទ ក្នុងបទថា **អត្ថិប្បច្ចយា ធម្មា ឯវ ច** ជាសម្បិណ្ឌនត្ថ ។ ដោយ ច ស័ព្ទនោះ លោកអាចារ្យរមែងសម្តែងសេចក្តីប្រការនេះថា មិនមែនតែអត្ថិប្បច្ច័យ និងវិគតប្បច្ច័យតែម្យ៉ាងប៉ុណ្ណោះទេ ដែលមិនផ្សេងគ្នាដោយធម៌ ដោយពិតនោះ សូម្បីអត្ថិប្បច្ច័យ និងអវិគតប្បច្ច័យក៏មិនផ្សេងគ្នា ។ បច្ច័យទាំងនេះមិនផ្សេងគ្នាដោយធម៌

ដោយពិត សូម្បីយ៉ាងនោះ ភាពជាធម៌ឧបការៈដែលមានសភាវៈ ព្រោះជាការមាន ជាអត្ថិប្បច្ច័យ ធម៌ឧបការៈដើម្បីការមិនប្រព្រឹត្តទៅនៃការរលត់ ដោយការមិនទៅប្រាសនៃសភាវៈ ឈ្មោះថា ជាវិគតប្បច្ច័យ ព្រោះដូច្នោះ បណ្ឌិតគប្បីជ្រាបសេចក្ដីផ្សេងគ្នានៃបច្ច័យក្នុងការមិនផ្សេងគ្នានៃធម៌ ។ ពិតហើយ ព្រះមានព្រះភាគត្រាស់ដឹងការផ្សេងគ្នានៃសមត្ថភាពទាំងពួង នៃធម៌ទាំងឡាយតាមសេចក្ដីពិត ហើយបានត្រាស់ការផ្សេងគ្នានៃបច្ច័យ ២៤ ព្រោះដូច្នោះ កុលបុត្រគប្បីធ្វើសុតមយញ្ញាណថា **ធម៌ទាំងនេះមានការផ្សេងគ្នាយ៉ាងនេះ** ដោយសទ្ធាក្នុងព្រះមានព្រះភាគជាម្ចាស់នៃធម៌ ហើយគប្បីធ្វើសេចក្ដីខ្នះខ្នែង ដើម្បីការដឹងដ៏ក្រៃលែងនូវការផ្សេងគ្នានៃធម៌ទាំងនោះ ដោយចិន្តាមយញ្ញាណ និងភាវនាមយញ្ញាណ ។

ក្នុងអធិការនេះ អារម្មណប្បច្ច័យ អនន្តរប្បច្ច័យ សមនន្តរប្បច្ច័យ ឧបនិស្សយប្បច្ច័យ បុរេជាតប្បច្ច័យ អាសេវនប្បច្ច័យ សម្បយុត្តប្បច្ច័យ នត្ថិប្បច្ច័យ និងវិគតប្បច្ច័យ មានដល់អរូបធម៌ប៉ុណ្ណោះ បច្ឆាជាតប្បច្ច័យ មានដល់រូបធម៌តែម្យ៉ាង បច្ច័យ ១៤ ក្រៅអំពីនេះ មានដល់រូបធម៌ និងអរូបធម៌ទាំងឡាយ ។

ហេតុប្បច្ច័យ អនន្តរប្បច្ច័យ សមនន្តរប្បច្ច័យ អាសេវនប្បច្ច័យ បច្ឆាជាតប្បច្ច័យ កម្មប្បច្ច័យ វិបាកប្បច្ច័យ ឈានប្បច្ច័យ មគ្គប្បច្ច័យ សម្បយុត្តប្បច្ច័យ នត្ថិប្បច្ច័យ និងវិគតប្បច្ច័យ ជាអរូបធម៌តែម្យ៉ាង, បុរេជាតប្បច្ច័យ ជារូបតែម្យ៉ាង, បច្ច័យដ៏សេស វៀរអារម្មណប្បច្ច័យ និងឧបនិស្សយប្បច្ច័យកើតបាន ទាំង ២ យ៉ាង បច្ច័យទាំង ២ នោះមានសភាពជាបញ្ញត្តិក៏មាន ។

អនន្តរប្បច្ច័យ សមនន្តរប្បច្ច័យ អាសេវនប្បច្ច័យ នត្ថិប្បច្ច័យ និងវិគតប្បច្ច័យ ជាអតីតតែម្យ៉ាង ។ អារម្មណប្បច្ច័យ អារម្មណាធិបតិប្បច្ច័យ និងអារម្មណូបនិស្សយប្បច្ច័យប្រព្រឹត្តទៅក្នុងកាលទាំង ៣ និងជាកាលវិមុត្តិ ។ កម្មប្បច្ច័យប្រព្រឹត្តទៅ

ក្នុងកាលទាំង ២ គឺអតីត និងបច្ចុប្បន្ន ។ បច្ច័យដ៏សេស ១៥ ជាបច្ចុប្បន្នតែម្យ៉ាង ។

ម្យ៉ាងទៀត បច្ច័យទាំងនេះ គឺអនន្តរប្បច្ច័យ សមនន្តរប្បច្ច័យ អនន្តរូបនិស្សយប្បច្ច័យ បកតូបនិស្សយប្បច្ច័យ អាសេវនប្បច្ច័យ នានក្ខណិកកម្មប្បច្ច័យ និងនត្ថិប្បច្ច័យ វិគតប្បច្ច័យ ជាបច្ច័យដែលធ្វើឲ្យកើតតែម្យ៉ាង មិនមែនជាបច្ច័យ ឧបត្ថម្ភឡើយ ។ បច្ឆាជាតប្បច្ច័យ ជាបច្ច័យដែលឧបត្ថម្ភតែម្យ៉ាង មិនមែនជាបច្ច័យធ្វើឲ្យកើតឡើយ ។ បច្ច័យដ៏សេស ជាបច្ច័យធ្វើឲ្យកើត និងឧបការៈ បណ្ឌិតគប្បីជ្រាបការផ្សេងគ្នានេះ ដោយប្រការដូច្នេះ ។

# វិសុទ្ធិមគ្គ

## អធិប្បាយ បទថា អវិជ្ជាបច្ចយា សង្ខារា

## អវិជ្ជាជាបច្ច័យច្រើនប្រការ

ក្នុងបច្ច័យ ២៤ ដែលពោលមកនេះ អវិជ្ជានេះ

រាប់ជាបច្ច័យនៃអភិសង្ខារ គឺបុណ្យទាំងឡាយដោយ ២ ប្រការ តែជាបច្ច័យនៃអភិសង្ខារបន្ទាប់ទៅ ( គឺអបុញ្ញាភិសង្ខារ ) ដោយច្រើនប្រការ ជាបច្ច័យនៃអភិសង្ខារចុងក្រោយ ( គឺអនេញ្ជាភិសង្ខារ ) ដោយប្រការ ១ ដូច្នេះ ។

ក្នុងពាក្យទាំងនោះ ពាក្យថា ជាបច្ច័យនៃអភិសង្ខារ គឺបុណ្យទាំងឡាយ ដោយ ២ ប្រការ សេចក្តីថា អវិជ្ជាជាបច្ច័យ ( នៃបុញ្ញាភិសង្ខារ ) ដោយ ២ ប្រការ គឺដោយអារម្មណប្បច្ច័យ ១ ដោយឧបនិស្សយប្បច្ច័យ ១ អធិប្បាយថា អវិជ្ជានោះជាបច្ច័យដោយអារម្មណប្បច្ច័យ នៃបុញ្ញាភិសង្ខារទាំងឡាយ ផ្នែកកាមាវចរក្នុងកាលដែលពិចារណាអវិជ្ជាដោយការអស់ទៅ ការវិនាសទៅជា...អារម្មណប្បច្ច័យនៃបុញ្ញាភិសង្ខារផ្នែករូបាវចរៈ ក្នុងកាលដែលដឹងចិត្តដែលប្រព្រឹត្តទៅជាមួយមោហៈ ( ទាំងរបស់ខ្លួននិងអ្នកដទៃ ) ដោយអភិញ្ញាចិត្ត ( មានចេតោបរិយញ្ញាណជាដើម ) តែកាលបុគ្គលបំពេញបុញ្ញកិរិយាវត្ថុផ្នែកកាមាវចរៈទាំងឡាយ មានទានជាដើមក្តី ញុំាងរូបាវចរជ្ឈានទាំងឡាយឲ្យកើតឡើងក្តី ដើម្បីប្រយោជន៍ដល់ការឈានកន្លងនូវអវិជ្ជា ក៏ជាបច្ច័យដោយឧបនិស្សយប្បច្ច័យនៃបុញ្ញាភិសង្ខារទាំង ២ នោះ កាលបុគ្គលប្រាថ្នាសម្បត្តិក្នុងកាមភព និងរូបភព ហើយធ្វើបុណ្យ ( ទាំង ២ ) នោះឯង ព្រោះវង្វេងទៅដោយការមិនដឹងក៏យ៉ាងនោះ ( គឺអវិជ្ជានោះជា... ឧបនិស្សយប្បច្ច័យនៃបុញ្ញាភិសង្ខារទាំង ២ នោះដូចគ្នា ) ។

ពាក្យថា តែជាបច្ច័យនៃអភិសង្ខារបន្ទាប់ទៅដោយច្រើនប្រការ សេចក្តីថា អវិជ្ជារមែងជាបច្ច័យនៃអបុញ្ញាភិសង្ខារទាំងឡាយដោយច្រើនប្រការ បុច្ឆាថា តើដូចម្តេច ? វិសជ្ជនាថា អវិជ្ជានោះរមែងជាបច្ច័យ ( នៃអបុញ្ញាភិសង្ខារ ) ដោយច្រើនប្រការ គឺក្នុងកាលដែលចេតសិក មានរាគៈជាដើមប្រារព្ធអវិជ្ជាកើតឡើង ក៏ជាបច្ច័យដោយអារម្មណប្បច្ច័យ ក្នុងកាលដែលធ្វើអវិជ្ជាឲ្យធ្ងន់ (គឺទម្ងន់ដែលនៅក្នុងអវិជ្ជា) កើតការពេញចិត្តឡើង ក៏ជាបច្ច័យដោយអារម្មណាធិបតី និងអារម្មណូបនិស្សយ កាលបុគ្គលអ្នកវង្វេងដោយការមិនដឹង មិនឃើញទោស ( ក្នុងបាប ) ធ្វើបាបទាំងឡាយ មានបាណាតិបាតជាដើម អវិជ្ជាក៏ជា... ឧបនិស្សយប្បច្ច័យជា... អនន្តរ... សមនន្តរ... អនន្តរូបនិស្សយ... អាសេវន... នត្ថិ... និងវិគតប្បច្ច័យនៃជវនចិត្ត មានជវនដួងទី ២ ជាដើមទៅ កាលបុគ្គលធ្វើអកុសលគ្រប់យ៉ាង អវិជ្ជាជា... ហេតុ... សហជាត... អញ្ញមញ្ញ... និស្សយ... សម្បយុត្ត... អត្ថិ... និងអវិគតប្បច្ច័យ ។

ពាក្យថា រាប់ថា ជាបច្ច័យនៃអភិសង្ខារចុងក្រោយដោយប្រការតែមួយ គឺអវិជ្ជារាប់ថា ជាបច្ច័យដោយប្រការមួយ គឺដោយឧបនិស្សយប្បច្ច័យប៉ុណ្ណោះនៃអនេញ្ជាភិសង្ខារទាំងឡាយ ការដែលជាឧបនិស្សយប្បច្ច័យនោះ គប្បីជ្រាបដោយន័យដែលពោលហើយ ក្នុងបុញ្ញាភិសង្ខារនោះចុះ ។

# ឆ្លើយបញ្ហាថា អវិជ្ជាតែម្យ៉ាងជាបច្ច័យនៃសង្ខារឬ

ក្នុងបទថា សង្ខារទាំងឡាយរមែងមានព្រោះបច្ច័យ គឺអវិជ្ជានេះ ចោទកាចារ្យពោលសួរថា អវិជ្ជានេះតែម្យ៉ាងប៉ុណ្ណោះ ជាបច្ច័យនៃសង្ខារទាំងឡាយឬ ឬបច្ច័យដទៃទៀតក៏មាន ? អាចារ្យពោលឆ្លើយថា ក្នុងពាក្យនេះគប្បីពោលដូចម្តេចល្អទៅ បើអវិជ្ជាតែម្យ៉ាង ( ជាបច្ច័យ ) សោត ក៏ត្រូវជាពួកឯកការណវាទ ( ពោលថាមានហេតុតែមួយដែលមិនត្រឹមត្រូវ ) បើពោលថា បច្ច័យដទៃៗ ទៀតក៏មានសោត ឯកការណនិទ្ទេស

( ពាក្យបាលីដែលសម្ដែងហេតុទុកតែមួយ ) ថា **អវិជ្ជាបច្ចយា សង្ខារា**-សង្ខារទាំងឡាយមាន ព្រោះបច្ច័យ គឺអវិជ្ជា ក៏មិនកើតប្រយោជន៍ អាចារ្យពោលតទៅថា ( តែការដែលពិត ) ឯកការណនិទ្ទេសនោះ នឹងមិនកើតប្រយោជន៍មិនមែនឡើយ ព្រោះអ្វី ?

ព្រោះ **ឯកផល ( កើត ) អំពីឯកហេតុមិនមាន សូម្បីអនេកផល ( កើត ) អំពីឯកហេតុក៏មិនមាន ឯកផលសោត ( កើត ) អំពីអនេកហេតុក៏មិនមាន តែអត្ថ ( គឺប្រយោជន៍ ) ក្នុងការសម្ដែងឯកហេតុ ឯកផល មាន ។**

ពិតណាស់ ផលតែមួយ ( កើត ) អំពីហេតុតែមួយមិនមាន ក្នុងបច្ចយាការនេះ ផលច្រើនយ៉ាង ( កើត ) អំពីហេតុតែមួយក៏មិនមាន ផលតែមួយ ( កើត ) អំពីហេតុច្រើនក៏មិនមាន តែផលច្រើនយ៉ាង ( កើត ) អំពីហេតុទាំងឡាយនោះមាន ។ ពិតហើយ ផលច្រើនយ៉ាង បានដល់ រូប ក្លិន រសជាដើម និងពន្លកឈើនោះកើតឡើងអំពីហេតុច្រើន ពោល គឺរដូវ ដី ពូជ និងទឹកប្រាកដ តែការសម្ដែងហេតុតែមួយ និងផលតែមួយ ព្រះមានព្រះភាគត្រាស់ទុកថា **អវិជ្ជាបច្ចយា សង្ខារា សង្ខារប្បច្ចយា វិញ្ញាណំ** នោះ ក្នុងការសម្ដែងហេតុតែមួយ និងផលតែមួយនោះ អត្ថមាន គឺមានប្រយោជន៍ ។ ពិតហើយ ព្រះមានព្រះភាគទ្រង់សម្ដែងឯកហេតុខ្លះ ឯកផលខ្លះដូចគ្នាដោយគួរដល់ព្រះទេសនាវិលាសនិង(អធ្យាស្រ័យរបស់)វេនេយ្យសត្វទាំងឡាយខ្លះក្នុងបទខ្លះព្រោះជាហេតុនិងផលប្រធានបទខ្លះព្រោះជាហេតុប្រាកដ(ឃើញជាក់ច្បាស់)បទខ្លះព្រោះជាហេតុអសាធារណៈ ( ចំពោះ ) ពង្រីកសេចក្ដីថា ព្រះមានព្រះភាគជាម្ចាស់ត្រាស់ ឯកហេតុ និងឯកផលផង ព្រោះភាពជាហេតុប្រធាន និងផលប្រធានដូចក្នុងបទថា **ផស្សប្បច្ចយា វេទនា** ហេតុថា ផស្សៈជាប្រធានហេតុនៃវេទនា ព្រោះកំណត់វេទនាតាមគួរដល់ផស្សៈ វេទនាសោតក៏ជាប្រធានផលនៃផស្សៈ ព្រោះកំណត់ផស្សៈតាមគួរដល់វេទនា ត្រាស់ឯកហេតុ ព្រោះការប្រាកដ ដូចក្នុងពាក្យថា **សេម្ហ**-

សមុដ្ឋានា អាពាធា-អាពាធទាំងឡាយមានស្លេស្មជាសមុដ្ឋាន ព្រោះថា ក្នុងអាពាធនេះ ស្លេស្មជាហេតុដែលប្រាកដ ហេតុដទៃមានកម្មជាដើមមិនប្រាកដ ត្រាស់ឯកហេតុ ព្រោះជាហេតុអសាធារណៈ ដូចក្នុងប្រការថា **យេកេចិ ភិក្ខវេ អកុសលា ធម្មា សព្វេ តេ អយោនិសោមនសិការមូលកា** ម្នាលភិក្ខុទាំងឡាយ បណ្ដាអកុសលធម៌ទាំងឡាយណាមួយ អកុសលធម៌ទាំងឡាយនោះ សុទ្ធតែមានអយោនិសោមនសិការជាមូល ព្រោះអយោនិសោមនសិការជាហេតុអសាធារណៈ ហេតុដទៃៗ មានវត្ថុ និងអារម្មណ៍ជាដើម ជាហេតុសាធារណៈដល់អកុសលទាំងឡាយ ។

ព្រោះហេតុនោះ ក្នុងបច្ចយាការនេះ អវិជ្ជានេះ សូម្បីកាលហេតុនៃសង្ខារទាំងឡាយដទៃ មានវត្ថុ អារម្មណ៍ និងសហជាតធម៌ជាដើមមាន ក៏គប្បីជ្រាបចុះថា ព្រះមានព្រះភាគជាម្ចាស់ ទ្រង់សម្ដែងដោយភាពជាហេតុនៃសង្ខារទាំងឡាយ ព្រោះការដែលអវិជ្ជានោះជាសង្ខារហេតុដែលជាប្រធាន នៃសង្ខារហេតុដទៃៗ មានតណ្ហាជាដើម ដោយព្រះបាលីថា តណ្ហារមែងចម្រើនដល់បុគ្គលអ្នកចាំមើលតែចំណែកដែលគួរត្រេកអរ ( ក្នុងសំយោជនិយធម៌ )... ជាដើម និងដោយព្រះបាលីថា ការកើតឡើងនៃអាសវៈរមែងមាន ព្រោះការកើតឡើងនៃអវិជ្ជា ព្រោះជាហេតុប្រាកដ និងព្រោះជាហេតុអសាធារណៈ ដោយព្រះបាលីថា ម្នាលភិក្ខុទាំងឡាយ បុគ្គលអ្នកល្ងង់ធ្លាក់នៅក្នុងអវិជ្ជា រមែងសាងបុញ្ញាភិសង្ខារឡើងខ្លះ... ជាដើម ប្រយោជន៍ក្នុងការសម្ដែងឯកហេតុ ឯកផលក្នុងបទទាំងពួង គប្បីជ្រាបដោយពាក្យឆ្លើយការសម្ដែងឯកហេតុឯកផល ( ដែលពោលមក ) នោះចុះ ។

## អធិប្បាយ អវិជ្ជាជាហេតុនៃសង្ខារផ្ទែកល្អអាក្រក់

ក្នុងបទ **អវិជ្ជាបច្ចយា សង្ខារា** នេះ ចោទកាចារ្យពោលសួរ ( ចំណុចសំខាន់មួយទៀត ) ថា សូម្បីដូចពោលមកនោះ ( តែ ) ការដែលអវិជ្ជាដែលជាវត្ថុមានទោស

មានផល ដែលមិនគួរប្រាថ្នាដោយចំណែកមួយ មកជាបច្ច័យនៃបុញ្ញាភិសង្ខារ និង អនេញ្ជាភិសង្ខារ ( ដែលមានផលគួរប្រាថ្នា ) នឹងប្រើបានដូចម្តេច ? ព្រោះថា អំពៅ មិនមែនកើតអំពីពូជស្តៅទេគប្បីឆ្លើយថា ដូចម្តេចនឹងប្រើមិនបានទៅ ព្រោះក្នុងលោក

**បច្ច័យនៃ ( សភាវៈ ) ធម៌ទាំងឡាយដែលខុសគ្នា ( ជាមួយផល ) ក្តី មិនខុសគ្នាក្តី ដែលដូចគ្នា និងមិនដូចគ្នា ( ជាមួយផល ) ក៏ដូចគ្នា រមែងជាហេតុ សម្រេច ( គឺឲ្យកើតផល ) បានអំពីធម៌ទាំងនោះ មិនបានជាវិបាក ( នៃបច្ច័យ ទាំងនោះ ) ឡើយ ។**

ពិតណាស់ បច្ច័យដែលខុសគ្នាដោយឋាន ( ទីកន្លែង និងវេលា ) សភាវៈ និង កិច្ចជាដើមនៃ ( សភាវៈ ) ធម៌ទាំងឡាយក្តី មិនខុសគ្នាក្តី រមែងជាហេតុសម្រេចបាន ក្នុងលោក ដោយចិត្តដួងមុនរមែងជាបច្ច័យ ដែលខុសគ្នាដោយឋានៈនៃចិត្តដួងក្រោយ បាន និងការសិក្សា មានសិក្សាសិប្បៈជាដើមមុន រមែងជាបច្ច័យ ដែលខុសគ្នា ដោយ ឋាននៃការធ្វើការងារ មានប្រកបសិប្បៈជាដើមដែលប្រព្រឹត្តទៅក្នុងខាងក្រោយក៏បាន កម្មជាបច្ច័យដែលខុសគ្នាដោយសភាវៈនៃរូបបាន និងទឹកដោះស្រស់ជាដើម ជាបច្ច័យ ដែលខុសគ្នាដោយសភាវៈនៃទឹកដោះជូរក៏បាន ពន្លឺជាបច្ច័យដែលខុសគ្នាដោយកិច្ចនៃ ចក្ខុវិញ្ញាណបាន និងទឹកអំពៅជាដើម រមែងជាបច្ច័យដែលខុសគ្នានៃទឹកត្នោត ( មេរ័យ ) ជាដើមក៏បាន ចំណែកចក្ខុ និងរូបជាដើម ជាបច្ច័យដែលមិនខុសគ្នាដោយឋាននៃ ចក្ខុវិញ្ញាណជាដើម ជវនចិត្តដួងមុនជាដើម ជាបច្ច័យដែលមិនខុសគ្នាដោយសភាវៈ និងមិនខុសគ្នា ដោយកិច្ចនៃជវនចិត្តដួងក្រោយជាដើម ។

ម្យ៉ាងទៀត បច្ច័យដែលខុសគ្នា និងមិនខុសគ្នា ( ជាមួយផល ) ជាហេតុសម្រេច បានយ៉ាងណា សូម្បីបច្ច័យដែលដូចគ្នា និងមិនដូចគ្នា ( ជាមួយផល ) ក៏ជាហេតុ សម្រេចបានដូច្នោះ ពិតណាស់ រូប ពោល គឺឧតុ និងអាហារដែលដូចគ្នានោះឯង

ជាបច្ច័យនៃរូប ពូជស្រូវសាលីជាដើម ដែលដូចគ្នានោះឯង ជាបច្ច័យនៃគ្រាប់ស្រូវសាលីជាដើម រូបដែលមិនដូចគ្នា តែជាបច្ច័យនៃអរូបបាន អរូបសោត ក៏ជាបច្ច័យនៃរូបបាន និងរោមគោ រោមចៀម ស្នែងសត្វ ទឹកដោះជូរ ល្ង មេ្សៅ ជាដើមដែលមិនដូចគ្នា ក៏ជាបច្ច័យនៃស្បូវក្លាំង និងស្លឹកគ្រៃជាដើមបាន តែបច្ចយធម៌ទាំងនោះជាបច្ច័យដែលខុសគ្នា មិនខុសគ្នា និងដូចគ្នា មិនដូចគ្នា ( ក្តី ) នៃធម៌ពួកណា ធម៌ពួកនោះ ក៏មិនបានជាវិបាកនៃ ( បច្ច័យ ) ធម៌ទាំងនោះឡើយ ។

ដោយប្រការដូច្នេះ អវិជ្ជានេះ សូម្បីដោយវិបាកក៏ជាវត្ថុដែលមានផលមិនគួរប្រាថ្នាដោយចំណែកមួយ និងពោលដោយសភាវៈក៏ជាវត្ថុមានទោស ( តែក៏ ) គប្បីជ្រាបចុះថា អវិជ្ជាជាបច្ច័យនៃសង្ខារ មានបុញ្ញាភិសង្ខារជាដើមទាំងអស់នោះបាន ដោយអំណាចនៃបច្ច័យដែលខុសគ្នា និងមិនខុសគ្នា ដោយឋាន កិច្ច សភាវៈ និងដោយអំណាចជាបច្ច័យដែលដូចគ្នា និងមិនដូចគ្នាតាមគួរ ឯការដែលជាបច្ច័យនោះ បានពោលហើយដោយន័យថា ការមិនដឹងដែលរាប់ថា អវិជ្ជាក្នុងទុក្ខជាដើម បុគ្គលណានៅមិនទាន់លះបាន បុគ្គលនោះ ព្រោះការមិនដឹងក្នុងទុក្ខ និងក្នុងវត្ថុនៃអវិជ្ជាទាំងឡាយមានខន្ធបញ្ចកៈចំណែកអតីតជាដើម ទើបប្រកាន់សង្សារទុក្ខ ដោយសម្គាល់ជាសុខហើយរមែងធ្វើសង្ខារទាំង ៣ យ៉ាងដែលជាហេតុនៃសង្សារទុក្ខនោះឡើង ដូច្នេះជាដើមនោះឯង ។

តទៅនេះជាបរិយាយមួយដទៃទៀត

បុគ្គលណាវង្វេងក្នុងរឿងចុតិ បដិសន្ធិ ក្នុងរឿងសង្សារ និងក្នុងលក្ខណៈនៃសង្ខារទាំងឡាយ និងក្នុងបដិច្ចសមុប្បន្នធម៌ទាំងឡាយ បុគ្គលនោះ រមែងសាងសង្ខារទាំង ៣ នោះឡើង ទាំងនេះក៏ព្រោះហេតុដែលអវិជ្ជានេះជាបច្ច័យនៃសង្ខារទាំង ៣ នោះ ។

បើមានពាក្យសួរថា ហេតុអ្វី ទើបបុគ្គលវង្វេងក្នុងធម៌ទាំងនោះ បុគ្គលនោះធ្វើសង្ខារទាំង ៣ នោះឡើង ? ដូច្នេះសោត គប្បីមានពាក្យឆ្លើយថា លំដាប់ដំបូងបុគ្គលអ្នកវង្វេងក្នុងរឿងចុតិ មិនកាន់យកចុតិ ( ដោយសេចក្តីពិត ) ថា ការបែកធ្លាយនៃខន្ធទាំងឡាយក្នុងភពទាំងពួង ឈ្មោះថា មរណៈ (តែ) កំណត់ចិត្តទៅថា សត្វស្លាប់ការស្លាប់ ក៏គឺការឈានទៅ ( គឺឃ្លាតទៅ ) កាន់សរីរៈដទៃនៃសត្វ ដូច្នេះជាដើម ។

អ្នកវង្វេងក្នុងបដិសន្ធិ មិនកាន់យកបដិសន្ធិ (ដោយសេចក្តីពិត) ថា ការប្រាកដឡើងនៃខន្ធទាំងឡាយក្នុងភពទាំងពួង ឈ្មោះថា ជាតិ ( តែ ) កំណត់ចិត្តទៅថា សត្វកើតឡើង ការកើតក៏គឺការប្រាកដឡើងនៃសរីរៈថ្មីរបស់សត្វ ដូច្នេះជាដើម ។

អ្នកវង្វេងក្នុងសង្សារ មិនកាន់យកសង្សារ ដូចដែលលោកពណ៌នាទុកដូច្នេះថា

**ការជាប់បន្តគ្នានៃខន្ធ ធាតុ អាយតនៈទាំងឡាយ ប្រព្រឹត្តទៅមិនដាច់ខ្សែ ហៅថា សង្សារ ។**

( តែ ) កំណត់ចិត្តទៅថា សត្វនេះទៅកាន់លោកដទៃអំពីលោកនេះ មកកាន់លោកនេះអំពីលោកដទៃ ដូច្នេះជាដើម ។

អ្នកវង្វេងក្នុងលក្ខណៈនៃសង្ខារទាំងឡាយ មិនកាន់យកសភាវលក្ខណៈ (មានសាបសូន្យជាដើម) និងសាមញ្ញលក្ខណៈ (មានមិនទៀងជាដើម) នៃសង្ខារទាំងឡាយ ( តែ ) កំណត់យកសង្ខារទាំងឡាយដោយភាពជាខ្លួន ដោយភាពជារបស់ខ្លួន ដោយភាពជារបស់ស្ថិតស្ថេរ ដោយភាពជារបស់ស្អាត និងដោយភាពជាសុខ ។

អ្នកវង្វេងក្នុងបដិច្ចសមុប្បន្នធម៌ទាំងឡាយ មិនកាន់យកការវិលទៅនៃបច្ចយុប្បន្នធម៌ទាំងឡាយ មានសង្ខារជាដើម ព្រោះបច្ចយធម៌ មានអវិជ្ជាជាអាទិ៍ ( តែ ) កំណត់ចិត្តទៅថា អត្តារមែងដឹងខ្លះ មិនដឹងខ្លះ អត្តានោះឯងធ្វើ ( ខ្លួនឯង ) និងប្រើ ( អ្នកដទៃ ) ឲ្យធ្វើផង ក្នុងបដិសន្ធិអត្តានោះឯងកើតឡើង អ្នកបណ្តាល មានអណូ

និងល្បស្វរជាដើម ចាត់ចែងសរីរៈឲ្យអត្តានោះ ដោយ (តាក់តែងឲ្យ) ជាកលលៈជាដើម (រហូត) ធ្វើឥន្ទ្រិយទាំងឡាយឲ្យគ្រប់គ្រាន់ អត្តានោះ មានឥន្ទ្រិយគ្រប់គ្រាន់ហើយ ទើបប៉ះពាល់បាន ដឹង (អារម្មណ៍) បាន ចង់កើត ប្រកាន់កើត ព្យាយាមកើត អត្តានោះរមែងមានក្នុងភពដទៃទៀត ដូច្នេះខ្លះថា សត្វទាំងពួង ប្រែប្រួលទៅតាមសភាវៈ គឺការប្រព្រឹត្តទៅ តាមជោគជតាភាសីដូច្នេះខ្លះ ។

បុគ្គលនោះគឺអវិជ្ជាធ្វើឲ្យជាមនុស្សខ្វាក់ ហើយកំណត់ចិត្តទៅយ៉ាងនោះក៏រមែងសាងសង្ខារជាបុណ្យខ្លះ មិនជាបុណ្យខ្លះ ជាអនេញ្ជាខ្លះឡើង ប្រៀបដូចមនុស្សខ្វាក់ភ្នែកត្រាច់ទៅលើផែនដីក៏រមែងដើរទៅត្រូវផ្លូវខ្លះខុសផ្លូវខ្លះត្រង់ទួលខ្លះត្រង់រណ្តៅខ្លះត្រង់ទីរាបខ្លះ ទីរដិបរដុបខ្លះដូច្នោះ ព្រោះហេតុនោះ ទើបព្រះអាចារ្យពោលពាក្យជាគាថានេះទុកថា

ប្រៀបដូចមនុស្សខ្វាក់ភ្នែកអំពីកំណើត មិនមានមនុស្សដឹកនាំ គ្រាខ្លះ ក៏ដើរទៅតាមផ្លូវ គ្រាខ្លះ ក៏ដើរខុសផ្លូវ យ៉ាងណាក្តី មនុស្សល្ងង់ដែលត្រាច់រង្គាត់នៅក្នុងសង្សារ មិនមានអ្នកដឹកនាំ គ្រាខ្លះ ក៏ធ្វើបុណ្យ គ្រាខ្លះ ក៏ធ្វើកម្មមិនមែនបុណ្យ ដូច្នោះលុះកាលណាគេដឹងធម៌ ហើយត្រាស់ដឹងសច្ចៈបាន កាលនោះ ព្រោះអវិជ្ជាស្ងប់ទៅទើបគេជាឧបសន្តបុគ្គលទៅបាន ។

នេះជាវិត្ថារកថា ក្នុងបទថា អវិជ្ជាបច្ចយា សង្ខារ ។

# មហាដីកា

## កថាពណ៌នាដោយពិស្តារនៃបទថា

## សង្ខារមាន ព្រោះអវិជ្ជាជាបច្ច័យ

*បទថា **បច្ចយេសុ** ជាសត្តមីវិភត្តិ ចុះក្នុងនិទ្ធារណៈ ។ បទថា **ទុវិធា** ប្រែថា ដោយប្រការពីរ ។ បទថា **អនេកធា** សេចក្តីថា ដោយប្រការ ១៧ យ៉ាង ទាក់ទង នឹងអារម្មណប្បច្ច័យជាដើម ។*

*ពាក្យថា **ដោយអភិញ្ញាចិត្ត** គឺចិត្តសហគតៈដោយអភិញ្ញា ពោល គឺចេតោ-បរិយញ្ញាណ បុព្វេនិវាសញ្ញាណ និងអនាគតំសញ្ញាណ ។ ពាក្យថា **ក្នុងកាលដឹង មោហចិត្ត** គឺក្នុងកាលដឹងចិត្តដែលមានមោហៈរបស់បុគ្គលដទៃ និងរបស់ខ្លួន ។ **ដើម្បី ប្រយោជន៍ដល់ការឈានកន្លងនូវអវិជ្ជា** អធិប្បាយថា ដើម្បីប្រាថ្នាក្រៃលែងនូវវិវដ្តៈ ដោយការឃើញទោសនៃអវិជ្ជាថា វិបត្តិឯណានីមួយ ដែលប្រព្រឹត្តទៅដោយអកុសល មានអវិជ្ជាជាប្រធាន វិបត្តិការណ៍ទាំងនោះ មានមោហៈជាមូល នៃបុញ្ញាភិសង្ខារ **ទាំង ២ នោះ** ។ បទថា **អវិជ្ជា សម្មុឡ្ហត្តា** ប្រែថា ព្រោះជាបុគ្គល វង្វេងដោយអវិជ្ជា ដែលមានការបិទបាំងទោសនៃភពជាដើម ។ ពាក្យថា **បុញ្ញនោះឯង** បានដល់ បុណ្យ ដែលជាកាមាវចរ និងរូបាវចរនោះឯង គឺតាមដែលពោលហើយ ។ ភ្ជាប់សេចក្តីថា ( អវិជ្ជា ) រមែងជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ។*

*ពាក្យថា **រាគៈជាដើម** បានដល់ រាគៈ ទិដ្ឋិ វិចិកិច្ឆា ឧទ្ធច្ចៈ និងទោមនស្ស ។ បណ្ឌិតគប្បីជ្រាបការកើតឡើងប្រាកដអវិជ្ជានៃរាគៈជាដើម ក្នុងកាលដែលត្រេកអរ ដោយរាគៈជាដើម ព្រោះប្រកបដោយអវិជ្ជា ។ តម្រេកធ្វើឲ្យធ្ងន់ បណ្ឌិតគប្បីប្រកប ដោយអវិជ្ជាដែលប្រកបដោយរាគៈ ទិដ្ឋិនោះឯង ។ ឯការត្រេកអរ បានដល់ រាគៈ និង*

ទិដ្ឋិ ក៏មិនបានញែកទៅអំពីរាគៈនោះ ព្រោះហេតុនោះ គប្បីជ្រាបថា លោកពោល ដល់ទិដ្ឋិដែលធ្វើអវិជ្ជា តាមដែលបានពោលទុកហើយឲ្យធ្ងន់ ដោយពោលថា ត្រេកអរ នោះឯងទុកផង ។ លោករមែងសម្ដែងសង្ខារដែលសម្បយុត្តដោយទិដ្ឋិនោះ ថាមាន អវិជ្ជាជាអារម្មណ៍ជាដើម ដោយកិលេស មានរាគៈជាដើម ដែលលោកពោលទុក ដោយសរុបក្នុងព្រះបាលី ។ ពាក្យថា **មិនឃើញទោស** គឺមិនឃើញទោសក្នុងបាប មានបាណាតិបាតជាដើម ។ លោកអាចារ្យពោលថា **អកុសលឯណានីមួយ** ដើម្បី រួមយកអកុសលទាំងអស់ដែលមិនបានជាអារម្មណ៍នៃអវិជ្ជា និងដែលជាជវនដំបូង ដែលមិនបានពោលទុក និងដែលពោលទុកក្នុងពាក្យថា បច្ច័យ មានអារម្មណប្បច្ច័យ អធិបតិប្បច្ច័យ និងអនន្តរប្បច្ច័យជាដើម ។

ពាក្យថា **តាមន័យដែលពោលហើយ** គឺតាមន័យដែលពោលហើយក្នុងបុញ្ញា កិសង្ខារ ដោយអំណាចការឈានកន្ទង និងការប្រាថ្នាកត ។

ដោយបទថា **កឹ បនាយំ** ជាដើម លោកអាចារ្យអ្នកចោទមានអធិប្បាយដូច តទៅនេះ ក្នុងប្រការថា **អវិជ្ជាបច្ចយា សង្ខារា សម្ភវន្តិ** នេះ លោកមិនប្រកបពាក្យ អវធារណៈថា **សម្ភវន្តិ ឯវ** ព្រោះកាលមិនមានការប្រជុំនៃបច្ច័យដ៏សេស សង្ខារ ក៏មិនមានប្រាកដ ។ ម្យ៉ាងទៀត លោកក៏មិនប្រកបសូម្បីពាក្យអវធារណៈថា **សង្ខារា ឯវ** ។ ព្រោះហេតុអ្វី ? ព្រោះការមាននៃបច្ចយុប្បន្នធម៌ដទៃ លោកប្រាថ្នា ហើយអំពី សង្ខារនោះ ។សូម្បីកាលកាន់យកពាក្យដែលជាអវធារណៈថា សង្ខារ រមែងមានព្រោះ អវិជ្ជាជាបច្ច័យប៉ុណ្ណោះ ដូច្នេះ ។ ព្រោះពាក្យពោល មានពាក្យដែលជាអវធារណៈ ជាផលក៏នឹងមានប្រការខូចបង់ ដូច្នេះ ។ ព្រោះហេតុអ្វី ? ព្រោះរមែងបានបច្ច័យ ពួកដទៃ មានលោភៈជាដើម និងមានកម្មដែលជាដើមហេតុ ឧបាទាន វត្ថុ អារម្មណ៍ និងមនសិការជាដើមនោះឯង ដូច្នេះ ។ បណ្ដាពាក្យទាំងនោះ ពាក្យថា **តែម្យ៉ាង** គឺ

មិនមានដទៃ អធិប្បាយថា មិនសម្ពឹងដល់ហេតុដទៃ ។ **បច្ច័យពួកដទៃ** ដែលជាហេតុធ្វើរួមគ្នា ។ លោកអាចារ្យដឹងថា អាចារ្យអ្នកចោទមានបំណងលើកទោសក្នុងសេចក្ដីនេះ ទើបបានសួរឡើង ទើបពោលថា **ក្នុងប្រការនេះគប្បីពោល ដូចម្ដេចល្អហ្ន៎** ។ ក្នុងសេចក្ដីនេះ គឺក្នុងប្រការដែលវៀរចាកបច្ច័យដទៃ គឺអវិជ្ជា និងក្នុងប្រការដែលប្រកបជាមួយបច្ច័យដទៃ គឺអវិជ្ជា ក៏នឹងមានពាក្យអ្វីហ្ន៎ ដែលគួរនឹងពោល មានអធិប្បាយពាក្យចោទរបស់លោកមិនសម្បូរ ហើយសូមលោកពោលពាក្យដ៏សេសមុន ។ ពាក្យថា **ក៏នឹងត្រូវជាពួកឯកការណវាទ** លោកពោលដល់ការទាក់ទងជាមួយការខូចបង់ ។ សេចក្ដីពិត ឯកការណវាទដ៏សេស នឹងត្រូវមានគ្រប់កាល គ្រប់កន្លែង ហើយត្រូវមិនមានសភាវៈដូចគ្នា ។

កាលមិនមានប្រការទាំង ៣ មានជាដើមថា **ព្រោះផលតែម្យ៉ាង កើតអំពីហេតុម្យ៉ាងមិនមាន** កាលមានប្រការទី ៤ ប៉ុណ្ណោះនេះថា ផលច្រើនយ៉ាងកើតអំពីហេតុច្រើនយ៉ាង ក៏មានប្រយោជន៍ក្នុងការសម្ដែងហេតុតែម្យ៉ាង និងផលតែម្យ៉ាង ព្រោះដូច្នោះ នឹងមិនកើតប្រយោជន៍ក៏ទេ រមែងកើតប្រយោជន៍នោះឯង ។ ក្ជាប់សេចក្ដីថា ផលតែម្យ៉ាង មិនមានអំពីហេតុតែម្យ៉ាង សូម្បីផលច្រើនយ៉ាង ក៏មិនមានអំពីហេតុម្យ៉ាង ។ ផលម្យ៉ាងមានអំពីហេតុច្រើនយ៉ាងក៏មិនមាន ។

ពាក្យថា **ការសម្ដែងហេតុតែម្យ៉ាង និងផលតែម្យ៉ាង** សេចក្ដីថា ព្រះសាស្ដាទ្រង់ធ្វើការសម្ដែងហេតុតែម្យ៉ាង និងផលតែម្យ៉ាងក្នុងបាឋៈនោះៗ យ៉ាងនេះ គឺសម្ដែងហេតុតែម្យ៉ាងថា **អវិជ្ជាបច្ចយា សង្ខារា** សម្ដែងផលតែម្យ៉ាងថា **សង្ខារបច្ចយា វិញ្ញាណំ** ។

ពាក្យថា **ដោយគួរដល់វេនេយ្យសត្វ** គឺដោយគួរដល់អធ្យាស្រ័យនៃវេនេយ្យសត្វ ។ សេចក្ដីដែលទ្រង់សម្ដែងហេតុតែម្យ៉ាង និងផលតែម្យ៉ាងប៉ុណ្ណោះ ក៏ដោយ

ទេសនា វិលាសរបស់ព្រះសាស្តាខ្លះ ដោយអជ្ឈាស្រ័យរបស់វេនេយ្យបុគ្គលខ្លះ ផល ដែលទ្រង់សម្តែងក្នុងបទទាំងនោះ ជាប្រធាន ជាផលប្រាកដ និងជាផលដែលមិនទូទៅ ជាហេតុក្នុងការសម្តែងនេះនៃហេតុ និងផលទាំង ២ នោះ ។ ម្យ៉ាងទៀត ព្រះសាស្តាទាំងឡាយ ទ្រង់រមែងកាន់យកអត្ថដែលទ្រង់សម្តែងទាំងនោះ តាមដែលទ្រង់ពេញព្រះទ័យក្នុងកាលទ្រង់បានបរិយាយសូម្បីច្រើនហើយ ។ ទ្រង់សម្តែងធម៌នោះ **ជាសេចក្តីសមគួរដល់ទេសនាវិលាស** ។ ម្យ៉ាងទៀត ក្នុងទេសនាវិលាសនោះ វេនេយ្យសត្វពួកណារមែងត្រាស់ដឹងបានដោយបរិយាយណា ការញុំាងវេនេយ្យសត្វទាំងនោះឲ្យត្រាស់ដឹងដោយបរិយាយនោះឯង នេះ **ជាការសមគួរដោយអជ្ឈាស្រ័យរបស់វេនេយ្យសត្វ** ។

ពាក្យថា **ព្រោះកំណត់វេទនាតាមគួរដល់ផស្សៈ** សេចក្តីថា ព្រោះកំណត់វេទនាមានសុខវេទនាជាដើម និងវេទនា មានចក្ខុសម្ផស្សជាវេទនាជាដើមបាន ដោយសមគួរដល់ផស្សៈ មានផស្សៈដែលគប្បីសោយជាសុខ និងផស្សៈ មានចក្ខុសម្ផស្សជាដើម ដោយព្រះបាលីថា ម្នាលភិក្ខុទាំងឡាយ ព្រោះអាស្រ័យផស្សៈដែលសោយជាសុខ រមែងកើតសុខវេទនាជាដើម និងព្រោះព្រះបាលីថា អាស្រ័យចក្ខុ និងរូប រមែងកើតចក្ខុវិញ្ញាណ ធម៌ ៣ ប្រការប្រជុំគ្នា ទើបជាផស្សៈ ព្រោះផស្សៈជាបច្ច័យ ទើបមានវេទនា ដូច្នេះជាដើម ។ អធិប្បាយថា ព្រោះមិនមានការយល់ខុសក្នុងវេទនា មានសុខវេទនាជាដើម ដោយអំណាចផស្សៈ ក្នុងចក្ខុ និងរូបជាដើម ដែលស្មើគ្នា ព្រោះមិនមានការយល់ខុសក្នុងវេទនា មានចក្ខុសម្ផស្សជាវេទនាជាដើម ដោយអំណាចការប៉ះខ្ទប់របស់ចក្ខុជាដើម ក្នុងការធ្វើមនសិការរូបជាដើមដែលស្មើគ្នា និងព្រោះមិនមានការលាយឡំគ្នានៃភាពគ្រោតគ្រាត និងល្អិតជាដើមរបស់វេទនា មានសុខវេទនាជាដើម និងវេទនា មានចក្ខុសម្ផស្សជាវេទនាជាដើម ដោយអំណាចចក្ខុសម្ផស្ស ព្រោះភាព

ដែលមានបច្ច័យដទៃស្មើគ្នា ។ **ការកំណត់ផស្សៈតាមវេទនា** គឺការៈដែលផស្សៈ តាមដែលពោលហើយជាបច្ច័យ ដែលមិនវិបរិតដល់វេទនា មានសុខជាដើមនោះឯង ។ ម្យ៉ាងទៀត បានដល់ការវិនិច្ឆ័យភាពផ្សេងគ្នានៃហេតុរបស់ផល ដោយភាពផ្សេងគ្នានៃផលរបស់ហេតុ ព្រោះហេតុនោះ ការវិនិច្ឆ័យក្នុងហេតុ និងផលទាំង ២ លោកក៏ហៅថា ការកំណត់ ។

ពាក្យថា **ហេតុដទៃ មានកម្មជាដើម** បានដល់ ហេតុដទៃ មានកម្ម អាហារ និងឧតុជាដើមមិនប្រាកដ ព្រោះរោគជាសះស្បើយបានដោយការកម្ចាត់នូវសេម្ហ ។ ហើយសេម្ហប៉ុណ្ណោះជាហេតុប្រាកដដោយការៈ ដែលសេម្ហស្រាលស្តើងចុះជាដើម ។ ក្នុងសេចក្តីថា ក្នុងបច្ចយាការនេះ អវិជ្ជាទ្រង់សម្តែងដោយជាហេតុនៃសង្ខារ ។ ពាក្យថា **ដោយព្រះបាលីថា តណ្ហារមែងចម្រើនដល់បុគ្គល ដែលតាមឃើញតែចំណែកដែលគួរត្រេកអរ** សេចក្តីថា ព្រោះត្រាស់ការៈដែលតណ្ហាជាហេតុនៃសង្ខារ ដោយសូត្រនេះថា ម្នាលភិក្ខុទាំងឡាយ តណ្ហារមែងចម្រើនដល់បុគ្គលដែលតាមឃើញតែចំណែកដែលគួរត្រេកអរក្នុងធម៌ទាំងឡាយ ដែលជាទីតាំងនៃសំយោជនៈ ព្រោះតណ្ហាជាបច្ច័យ ទើបមានឧបាទាន ព្រោះឧបាទានជាបច្ច័យ ទើបមានភព ដូច្នេះ ។ លោកអាចារ្យពោលថា **ព្រោះព្រះបាលីថា ព្រោះអវិជ្ជាកើត ទើបអាសវៈកើត** ដូច្នេះដើម្បីសម្តែងថា ហេតុនៃអវិជ្ជារបស់តណ្ហានោះតទៅ ។ ម្យ៉ាងទៀត តណ្ហា និងកាមាសវៈ ទិដ្ឋាសវៈ ដែលជាឧបាទានទាំង ៤ ក៏ជាហេតុនៃសង្ខារ ព្រោះហេតុនោះ ទើបសង្ខារដែលមានអវិជ្ជាជាហេតុប្រាកដ ព្រោះហេតុនោះ ទើបលោកអាចារ្យសម្តែការៈដែលអវិជ្ជាជាហេតុនៃសង្ខារដែលប្រាកដប៉ុណ្ណោះ ។ ដោយពាក្យថា **អ្នកតាមឃើញតែចំណែកដែលល្អ** ដូច្នេះនេះ ទ្រង់រមែងសម្តែងអវិជ្ជា ដែលមានកិច្ចបិទបាំងទោសនៃភពជាដើមថា ជាហេតុនៃតណ្ហា ។ ព្រោះអវិជ្ជាជាធាតុមិនដឹង ដូច្នោះ ទើបតាក់

តែងសង្ខារ មានបុញ្ញាភិសង្ខារជាដើម ដូច្នោះ ទើបលោកពោលអវិជ្ជាដែលជាធាតុមិនដឹងប៉ុណ្ណោះ ដោយជាហេតុនៃសង្ខារ ព្រោះភាវៈដែលជាហេតុនៃសង្ខារប្រាកដ ។ ម្យ៉ាងទៀត គប្បីឃើញអត្ថថា ហេតុដទៃៗ មានវត្ថុ និងអារម្មណ៍ជាដើម ជាហេតុទូទៅនៃសង្ខារ មានបុញ្ញាភិសង្ខារជាដើម ព្រោះព្រះវិញ្ញាណស្រេចមិនមានសង្ខារ និងព្រោះមិនទូទៅ ព្រោះដូច្នោះ អវិជ្ជាដែលបិទបាំងទោសរបស់បុញ្ញកពជាដើម ទើបជាហេតុមិនទូទៅរបស់បុញ្ញាភិសង្ខារជាដើម ។ ដោយហេតុនេះឯង ក្នុងពាក្យថា **ព្រោះអវិជ្ជាជាបច្ច័យ ទើបមានសង្ខារ ព្រោះសង្ខារជាបច្ច័យ ទើបមានវិញ្ញាណ** ព្រោះជាហេតុ និងផល ព្រោះជាហេតុប្រាកដ ព្រោះជាហេតុមិនទូទៅ ដូច្នោះ បណ្ឌិតគប្បីជ្រាបប្រយោជន៍ ពោល គឺការឲ្យយល់ក្នុងធម៌ ដោយអំណាចអធ្យាស្រ័យរបស់ពោធនេយ្យបុគ្គល ដូចក្នុងព្រះបាលីថា **ព្រោះផស្សៈជាបច្ច័យ ទើបមានវេទនា ព្រោះវេទនាជាបច្ច័យ ទើបមានតណ្ហា** ដូច្នេះ គ្រប់កន្លែង ដោយការពោលពាក្យឆ្លើយក្នុងការសម្តែងហេតុ និងផលតែម្យ៉ាង ។

ដោយពាក្យថា **មានផលដែលមិនគួរប្រាថ្នាដោយចំណែកមួយ** នេះ លោកអាចារ្យរមែងញ៉ាំងភាពជាបច្ច័យដែលខុសគ្នាឲ្យក្លឹច្បាស់ ដោយអវិជ្ជា ដោយពាក្យថា **ដែលមានទោស** នេះ លោកអាចារ្យរមែងញ៉ាំងបច្ច័យដែលផ្សេងគ្នាដោយជាតិឲ្យក្លឹច្បាស់ដោយអវិជ្ជា ។ ពិតហើយ បុញ្ញាភិសង្ខារ និងអនេញ្ជាភិសង្ខារខុសគ្នានិងផ្សេងជាតិគ្នាចំពោះអវិជ្ជានោះ ព្រោះអភិសង្ខារទាំង ២ នោះ មានវិបាកគួរប្រាថ្នា និងព្រោះជាធម៌មានសភាវៈដែលមិនមានទោស ។ ពាក្យថា **មិនសមគួរ ដូចម្តេច** ជាដើម ជាពាក្យប្រមូលទុក ដោយពាក្យនោះលោកអាចារ្យរមែងសម្តែងដល់ចំណែកខ្លះរបស់ហេតុ មានហេតុ មានផល ដែលមិនគួរប្រាថ្នាដោយចំណែកមួយជាដើមនេះ ជារឿងដែលមានចំណែកមិនមែនតិច ។ ក្នុងអធិការនេះ មានអធិប្បាយទុកដូច្នេះ ពាក្យ

ចោទនេះ លោកបានធ្វើទុកដោយពាក្យថា **កាលបើយ៉ាងនោះ** ពាក្យចោទនោះសមគួរហើយ បើពោលដល់ផល ។ ព្រោះហេតុដែលធ្មិនមិនគួរប្រាថ្នា និងបង្កើតផលដែលគួរប្រាថ្នា ឬហេតុដែលធ្មិនគួរប្រាថ្នា នឹងបង្កើតផលដែលគួរប្រាថ្នាក៏ទេ ។ មួយ៉ាងទៀត ព្រោះក្នុងអធិការនេះ លោកមានបំណងយកលក្ខណៈធម្មតារបស់បច្ចយុប្បន្នធម៌ដែលមានលក្ខណៈ ជាបច្ច័យជាធម៌ និងក្នុងភាពធម្មតានោះ មិនមានការកំណត់សេចក្តីនេះទុក ព្រោះភាពធម្មតានោះ មានច្រើនសន្ទឹកសន្ធាប់ ។ ដោយហេតុនោះ ទើបលោកអាចារ្យពោលថា **បច្ច័យ នៃធម៌ទាំងឡាយដែលខុសគ្នា** ដូច្នេះជាដើម ។

ក្នុងបទទាំងនោះ ពាក្យថា **នៃធម៌ទាំងឡាយ** គឺនៃសភាវធម៌ទាំងឡាយ ។ ពាក្យថា **ឋាន** បានដល់ ដែលតាំងចុះ ។ ព្រោះហេតុនោះ ពាក្យថា **ខុសគ្នាដោយឋាន** បានដល់ ខុសគ្នាដោយភាវៈដែលមាន ។ ចំណែកអាចារ្យពួកខ្លះពោលថា **បដិសន្ធិជាដើម ឈ្មោះថា ឋាន** ។ កាលបើដូច្នោះ ពាក្យថា **ចិត្តដួងមុនជាបច្ច័យដែលខុសគ្នាដោយឋាននៃចិត្តដួងក្រោយ** ដូច្នេះ ក៏មិនគប្បីប្រព្រឹត្តទៅដោយចំណែកមួយ ។ ពិតហើយ សុម្បីកវគ្គ ក៏ជាអនន្តរប្បច្ច័យដល់កវគ្គ ជវន ក៏ជាអនន្តរប្បច្ច័យដល់ជវនឯសិប្បៈជាដើម មិនមានឋាន មានបដិសន្ធិជាដើមនោះឡើយ ព្រោះដូច្នោះ ទើបលោកមិនបំណងយកឋាន គឺបដិសន្ធិជាដើមទុកក្នុងទីនេះផង ។ **កម្មជាបច្ច័យដែលខុសគ្នាដោយសភាវៈដល់រូបណា** ព្រោះការបង្អោនទៅជាមួយការប្រែប្រួលខុសគ្នា និងព្រោះធម៌ដែលទទួលអារម្មណ៍បានជាមួយធម៌ដែលទទួលអារម្មណ៍ មិនបានជាដើមខុសគ្នា ។ **ទឹកដោះស្រស់ជាដើម ជាបច្ច័យដែលខុសគ្នា ដោយសភាវៈដល់ទឹកដោះជូរជាដើម** បាន ព្រោះសភាវៈ មានរសផ្អែម និងរសជូរជាដើមខុសគ្នា ។ **ពន្លឺ** ដែលមានការមិនដឹងជាកិច្ច ជាបច្ច័យដែលខុសគ្នាដោយកិច្ច **ដល់វិញ្ញាណ** ដែលមានការដឹងច្បាស់ជាកិច្ច ។ ទឹកអំពៅធ្មិនជាដើម ដែលមានការមិនស្រវឹងជាកិច្ច ជាបច្ច័យដែលខុសគ្នា

ដល់មេរ័យ ដែលមានការស្រវឹងជាកិច្ច ។

ក្នុងបទថា **គោលោមាវិលោមាទិ** ជាដើម មានវិនិច្ឆ័យថា រោមគោ និងរោមចៀម ជាបច្ច័យដែលខុសគ្នាដល់ស្បូវក្លាំង ឯចៀមពណ៌ក្រហមគប្បីជ្រាបថា ឈ្មោះ **អវិ** ។ **ស្នែងសត្វ** ជាបច្ច័យដល់សំឡេង **ទឹកដោះជូរ ល្ង មេ្សា និងទឹកអំពៅឆ្អិន** ជាបច្ច័យដល់ស្ទឹកគ្រៃ ។ ពាក្យជាដើមយ៉ាងនេះថា សារាយ ជាបច្ច័យដល់ម្រះព្រៅ លា និងមេសេះ ជាបច្ច័យដល់សេះអស្សតរ លោកអាចារ្យរួមទុក ដោយ **អាទិ-ស័ព្ទ** ។ អធិប្បាយថា ព្រោះហេតុដែលធម៌ទាំងនោះមិនបានជាវិបាកឡើយ ដូច្នោះ អវិជ្ជា មានវិបាកជាទុក្ខ ជាបច្ច័យដល់បុញ្ញាភិសង្ខារ និងអនេញ្ជាភិសង្ខារដែលមានវិបាកមិនជាទុក្ខ នឹងមិនសមគួរក៏ទេ ។

ពាក្យថា បច្ច័យនៃធម៌ទាំងឡាយ ដែលខុសគ្នានឹងផលក្តី មិនខុសគ្នាក្តី និងដែលដូចគ្នា ឬមិនដូចគ្នាជាមួយផល រមែងសម្រេចជាបច្ច័យបាន ដូច្នេះ លោកអាចារ្យពោលទុកដើម្បីបដិសេធនូវការទាក់ទងគ្នាក្នុងសេចក្តីនេះថា សូម្បីធម៌ទាំងនោះ មិនបានជាវិបាក អវិជ្ជាក៏ជាបច្ច័យដល់អបុញ្ញាភិសង្ខារប៉ុណ្ណោះ ដែលជាធម៌ខុសគ្នានឹងអភិសង្ខារទាំង ២ នោះ និងដូចគ្នាជាមួយអវិជ្ជានោះ ព្រោះជាធម៌ដែលមានទោស ។ ព្រោះដូច្នោះ លោកអាចារ្យកាលនឹងធ្វើអត្ថនោះឲ្យប្រាកដ ទើបពោលពាក្យជាដើមថា **ដោយប្រការដូច្នេះ អវិជ្ជានេះ** ។

ពាក្យថា **មិនកាន់យកចុតិថា ការបែកនៃខន្ធទាំងឡាយក្នុងភពទាំងពួង ឈ្មោះមរណៈ** សេចក្តីថា មិនដឹងតាមសេចក្តីពិតថា ដែលឈ្មោះថា **ចុតិ** ក្នុងទីនេះ បានដល់ការបែកគ្រាចុងក្រោយដែលតែងហៅថា ស្លាប់នៃខន្ធ មានរូបជាដើម ក្នុងភពជាដើមនោះៗ ។ **សត្តស្ស** ប្រែថា មាននៅ គឺប្រាកដនៅ ។ **ការឈានទៅកាន់សរីរៈដទៃ** បានដល់ ការមកប្រមូលជាមួយកាយដទៃ ។

ពាក្យថា **ការប្រាកដនៃខន្ធទាំងឡាយក្នុងភពទាំងពួង** បានដល់ ការកើតឡើងដំបូងនៃខន្ធក្នុងភពជាដើមនោះៗ ។ ពាក្យថា **ការប្រាកដនៃសរីរៈថ្មី** បានដល់ ការកើតឡើងនៃកាយថ្មីដែលទាក់ទងនៅក្នុងបរលោក ក្នុងកាលសរីរៈចាស់ចោលនៅក្នុងលោកនេះ ។ ដូចអាចារ្យមួយពួកពោលថា

ប្រៀបដូចនរជនចោលផ្ទាំងសំពត់ចាស់ហើយ រមែងកាន់យកផ្ទាំងសំពត់ថ្មីដទៃយ៉ាងណា សត្វដែលស្វែងរកសេចក្តីសុខ ក៏ចោលរាងកាយដែលចាស់ទុកក្នុងលោកនេះ ហើយកាន់យកអត្តាដែលថ្មី ក៏ដូច្នោះដែរ ។

ពាក្យថា **សត្វនេះ** បានដល់ អត្តាដែលលោកមានបំណងយកថាជាម្ចាស់របស់ជាអ្នកនៅប្រចាំជាមេការ និងជាអ្នកសោយនេះ ។សូម្បីក្នុងពាក្យថា **សត្វស្លាប់ សត្វកើត** នេះ ក៏មានន័យនេះ ។ ដោយ **អាទិ-ស័ព្ទក្នុងឋានៈទាំង ៣** លោកអាចារ្យរមែងសង្គ្រោះយកការគិតដល់កិរិយារបស់ព្រះឥស្សរ និងកិរិយារបស់ព្រះព្រហ្មជាដើម ។

ពាក្យថា **សភាវលក្ខណៈ** បានដល់ លក្ខណៈមានការបែកធ្លាយ និងការសោយអារម្មណ៍ជាដើម ឬបានដល់ មានការគ្រោតគ្រាត និងការពាល់ត្រូវជាដើមជាសភាវៈនោះឯង ។ ពាក្យថា **សាមញ្ញលក្ខណៈ** បានដល់ ការមិនទៀងជាដើម ។ ពាក្យថា **កំណត់ចិត្តយកសង្ខារទាំងឡាយ ដោយភាពជាខ្លួន ដោយភាពជារបស់ខ្លួន** សេចក្តីថា កំណត់ចិត្តយកចំណែកខ្លះក្នុងរូបជាដើម ដោយភាពជាខ្លួន កំណត់ចិត្តយកវត្ថុដទៃអំពីរូបជាដើមនោះ ដោយភាពជារបស់ខ្លួន ។

រមែងកំណត់ថា **អត្តារមែងដឹងខ្លះ** ដូចជាលទ្ធិទាំងឡាយ មានលទ្ធិរបស់កបិលជាដើម ។ រមែងកំណត់ថា **អត្តារមែងមិនដឹងខ្លះ** ដូចជាលទ្ធិទាំងឡាយ មានលទ្ធិរបស់កណាទៈ និងលទ្ធិអាជីវកជាដើម ។ ពិតហើយ អត្តាសូម្បីរបស់កណាទៈ រមែងមិនដឹងដោយសភាវៈ ។ កាលណារួមជាមួយគុណ គឺពុទ្ធិ កាលនោះលោករមែងប្រាថ្នា

ថា រមែងដឹង ។ ពាក្យថា **អត្តានោះឯង ធ្វើខ្លួនឯង និងប្រើឲ្យអ្នកដទៃធ្វើ** អធិប្បាយថា អត្តាណា រមែងសោយសុខ ទុក្ខ ក្នុងលោកខាងមុខ អត្តានោះឯង រមែងធ្វើបុណ្យ និងបាបខ្លួនឯង មិនមែនអ្នកដទៃធ្វើឲ្យ ឬប្រើអ្នកដទៃធ្វើឲ្យនោះឡើយ ។ ពាក្យថា **ចាត់ចែង** បានដល់ ធ្វើឲ្យដល់ព្រមដោយអំណាចធ្វើឲ្យកើតវត្ថុផ្សេងៗ មានអណ្ឌ ២ ជាដើម ដោយអំណាចការចង់បាន ។ បទថា **សោ យោគ អត្តសញ្ញិតោ សត្តោ** ប្រែថា សត្វដែលសម្គាល់គ្នាថា អត្តានោះ ។ ពាក្យថា **មានឥន្ទ្រិយដល់ព្រមហើយ** គឺ ដែលប្រកបដោយឥន្ទ្រិយ មានចក្ខុជាដើម ដោយពាក្យនោះលោករមែងសម្តែងការ ប្រព្រឹត្តទៅនៃសឡាយតនៈ ។ ពាក្យទាំងអស់នេះលោក ពោលទុកដោយអំណាចការ សម្តែងថា បុគ្គលម្ចាស់ទិដ្ឋិរមែងវង្វេងទៅផ្សេងៗ ព្រោះធ្វើកិច្ចនៃអវិជ្ជាជាដើម ដែល ប្រព្រឹត្តទៅតាមបច្ច័យឲ្យជាសេចក្តីខ្ទះខ្ទែងរបស់ខ្លួន ។ការកំណត់ចុះដែលប្រព្រឹត្តទៅ ខាងដើម និងខាងចុង ដូចជាកែវមណីមិនបែក គេដោតទុកដោយអំបោះដែលមិនដាច់ ឈ្មោះថា **និយតិ** ប្រែថា ជោគល្អ ជោគអាក្រក់ ការប្រជុំ គឺការមកព្រមគ្នា ដោយ ជោគល្អ ជោគអាក្រក់ ឬគឺជោគល្អ ជោគអាក្រក់ ឈ្មោះថា **និយតិ សង្គតិ** ប្រែថា ការប្រជុំដោយជោគល្អ ជោគអាក្រក់ ឬគឺជោគល្អ ជោគអាក្រក់ សត្វទាំងឡាយ ផ្លាស់ប្តូរទៅក្នុងភាវៈទាំងឡាយ ដោយការប្រជុំ គឺជោគល្អ ជោគអាក្រក់នោះ គឺដល់ នូវភាវៈជាមនុស្ស ជាទេវតា និងជាបក្សីជាដើម ឈ្មោះថា **និយតិ សង្គតិ ភាវបរិណតា** បុគ្គលផ្លាស់ប្តូរទៅក្នុងភាវៈដោយការប្រជុំ គឺជោគល្អ ជោគអាក្រក់ ។ អាចារ្យទាំង ឡាយរមែងពោលអត្ថថា សត្វទាំងឡាយប្រែប្រួលទៅ គឺដល់នូវភាពជាប្រការផ្សេងៗ ដោយជោគល្អ ជោគអាក្រក់ ដោយការប្រជុំ និងដោយសភាវៈដែលហៅថា **និយ-តិសង្គតិភាវបរិណតា** បុគ្គលប្រែប្រួលទៅដោយជោគល្អ ជោគអាក្រក់ ការប្រជុំ និងភាវៈ ដូច្នេះ ។ លោកអាចារ្យកាលសម្តែងអត្ថប្រការនេះថា ក៏ដោយការកំណត់ចិត្ត

ទាំងនេះ អវិជ្ជាធ្វើអកុសលចិត្តហើយ រមែងញុំាងសត្វទាំងឡាយឲ្យប្រព្រឹត្តទៅក្នុងសង្ខារ ឯណានីមួយក្នុងបណ្តាសង្ខារទាំងឡាយ មានបុញ្ញាភិសង្ខារជាដើម ទើបពោលពាក្យជាដើមថា **បុគ្គលនោះដែលអវិជ្ជាធ្វើឲ្យងងឹតហើយ** ដូច្នេះ ។ ពាក្យថា **រមែងដើរទៅ** គឺរមែងចូលទៅ ។

បទថា **អបរិណាយកោ** សេចក្តីថា វៀរចាកកល្យាណមិត្តដែលញុំាងអរហត្តមគ្គឲ្យសម្រេច ម្យ៉ាងទៀត ញាណដែលមានអរហត្តមគ្គញ្ញាណជាទីបំផុត បង្ហាញទីរាបស្មើនិងទីរដិបរដុប នាំសត្វទាំងឡាយទៅកាន់ព្រះនិព្វាន ព្រោះហេតុនោះ ទើបឈ្មោះថា **បរិណាយកំ** អ្នកនាំទៅ វៀរហើយអំពីញាណដែលនាំទៅនោះ ទើបឈ្មោះថា **អបរិណាយកោ** បុគ្គលមិនមានញាណនាំទៅ ។ ពាក្យថា **ដឹងធម៌ហើយ** គឺដឹងព្រះសូត្រនិងព្រះអភិធម្មដែលប្រកាសសច្ចៈទាំង ៤ ដោយអំណាចការសេពគប់សប្បុរស ឬដឹងធម៌ គឺព្រះនិព្វានដ៏ប្រសើរជាងធម៌ទាំងឡាយដោយមគ្គញ្ញាណនោះឯង ។ ឯការត្រាស់ដឹងសច្ចៈ ៣ ដ៏សេស ដែលទាក់ទងដោយការដឹងធម៌ គឺព្រះនិព្វាននោះ សូម្បីជាសមានកាល គឺមានកាលស្មើគ្នា លោកក៏ពោលទុកដោយធ្វើការត្រាស់ដឹងសច្ចៈ ៣ ដ៏សេសនោះ ឲ្យដូចជាបុរិមកាល ។ ពីរបទថា **ឧបសន្តោ ចរិស្សតិ** សេចក្តីថា ចូលទៅស្ងប់ហើយ គឺតាំងនៅក្នុងសឧបាទិសេសនិព្វានធាតុ ព្រោះអវិជ្ជាស្ងប់ដោយប្រការទាំងឡាយ ដោយការត្រាស់ដឹងមគ្គដ៏លើស និងញុំាងអត្តភាពឲ្យប្រព្រឹត្តទៅតាំងនៅ គឺដោយការនៅជាសុខក្នុងទិដ្ឋធម៌ ដើម្បីប្រព្រឹត្តប្រយោជន៍ដល់សត្វទាំងឡាយ ដរាបដល់ត្រាស់ដឹងអនុបាទិសេសនិព្វានធាតុ ។

# វិសុទ្ធិមគ្គ

## អធិប្បាយ បទថា សង្ខារប្បច្ចយា វិញ្ញាណំ

តទៅនេះជាវិត្ថារកថាក្នុងបទ សង្ខារប្បច្ចយា វិញ្ញាណំ

ពាក្យថា វិញ្ញាណ បានដល់ វិញ្ញាណ ៦ មានចក្ខុវិញ្ញាណជាដើម ក្នុងវិញ្ញាណ ៦ នោះ ចក្ខុវិញ្ញាណមាន ២ យ៉ាង គឺចក្ខុវិញ្ញាណជាកុសលវិបាក ១ ជាអកុសលវិបាក ១ សោតវិញ្ញាណ ឃានវិញ្ញាណ ជិវ្ហាវិញ្ញាណ កាយវិញ្ញាណក៏យ៉ាងនោះ ។ មនោវិញ្ញាណមាន ២២ គឺមនោធាតុ ២ ជាកុសលវិបាក និងអកុសលវិបាក មនោ-វិញ្ញាណធាតុជាអហេតុកៈ ៣ កាមាវចរវិបាកចិត្តជាសហេតុកៈ ៨ រូបាវចរចិត្ត ៥ អរូបាវចរចិត្ត ៤ ទើបទាំងនេះជាការរួមវិបាកវិញ្ញាណផ្នែកលោកិយ តាមវិញ្ញាណ ៦ នេះ ទាំងអស់ដូចគ្នាបាន ៣២ ចំណែកវិញ្ញាណផ្នែកលោកុត្តរទាំងឡាយ ប្រើមិនបានក្នុងការពោលដោយវដ្តៈ ព្រោះដូច្នោះ ទើបមិនកាន់យក ។

ក្នុងបទថា វិញ្ញាណមានព្រោះបច្ច័យ គឺសង្ខារនោះ បើមានពាក្យសួរថា សេចក្តីនេះគប្បីជ្រាបបានថា វិញ្ញាណមានប្រការដូចពោលមកនេះ មានឡើងព្រោះបច្ច័យគឺសង្ខារដូចម្តេច ? ឆ្លើយថា ជ្រាបបានព្រោះការដែលកាលកម្មដែលសាងទុកមិនមានវិបាកក៏មិនមាន ។ ពិតហើយ វិញ្ញាណនោះជាវិបាក វិបាកក្នុងកាលកម្មដែលសាងទុកមិនមាន រមែងមិនកើតឡើង បើគប្បីកើតឡើងបាន ( ដោយមិនអាស្រ័យកម្ម ) សោត វិបាកវិញ្ញាណគ្រប់យ៉ាង ក៏នឹងគប្បីកើតឡើង ដល់សត្វគ្រប់ជំពូកបាន តែមិនកើតទេ ( ក្នុងកាលមិនមានកម្មដែលសាងទុក ) ព្រោះហេតុនោះ គប្បីជ្រាបថា វិញ្ញាណនេះរមែងមានព្រោះបច្ច័យ គឺសង្ខារនោះបាន ។

បើសួរថា វិញ្ញាណណារមែងមានព្រោះបច្ច័យគឺសង្ខារណា ? ដូច្នេះសោត

គប្បីឆ្លើយថា លំដាប់ដំបូង វិញ្ញាណ ១៦ ដួង គឺវិញ្ញាណ មានចក្ខុវិញ្ញាណជាដើម ដែលជាកុសលវិបាក ៥ ក្នុងមនោវិញ្ញាណ មនោធាតុ ១ មនោវិញ្ញាណធាតុ ២ កាមាវចរវិបាកវិញ្ញាណ ៨ រមែងមានព្រោះបច្ច័យ គឺបុញ្ញាភិសង្ខារ ផ្នែកកាមាវចរ ដូចបាលីថា ព្រោះកម្មដែលជាកុសលកាមាវចរដែលបុគ្គលធ្វើទុកហើយ សាងទុកហើយ ចក្ខុវិញ្ញាណ... សោតវិញ្ញាណ... ឃានវិញ្ញាណ... ជិវ្ហាវិញ្ញាណ... ទើបកាយវិញ្ញាណ ដែលជាវិបាកកើតឡើង ទើបមនោធាតុដែលជាវិបាកកើតឡើង មនោវិញ្ញាណធាតុ ដែលជាសោមនស្សសហគតៈ... ទើបឧបេក្ខាសហគតៈកើតឡើង ដែលជាសោមនស្ស សហគតញាណសម្បយុត្ត...សោមនស្សសហគតញាណសម្បយុត្តជាមួយសសង្ខារ... សោមនស្សសហគតញាណវិប្បយុត្ត... សោមនស្សសហគតញាណវិប្បយុត្តជាមួយ សសង្ខារ... ឧបេក្ខាសហគតញាណសម្បយុត្ត... ឧបេក្ខាសហគតញាណសម្បយុត្ត ជាមួយសសង្ខារ... ឧបេក្ខាសហគតញាណវិប្បយុត្ត... ទើបឧបេក្ខាសហគតញាណ វិប្បយុត្តជាមួយសសង្ខារកើតឡើង ដូច្នេះ ។

ចំណែករូបាវចរវិបាកវិញ្ញាណ ៥ ដួង មានព្រោះបច្ច័យ គឺបុញ្ញាភិសង្ខារផ្នែក រូបាវចរ ដូចបាលីថា ព្រោះកម្មដែលជាកុសលផ្នែករូបាវចរនោះឯង ដែលបុគ្គលធ្វើ ទុកហើយ សាងទុកហើយ ទើបស្ងាត់ចាកកាមទាំងឡាយ ។បេ។ ចូលដល់បឋមជ្ឈាន ។បេ។ បញ្ចមជ្ឈានដែលជាវិបាក ដូច្នេះ ។

រួមវិញ្ញាណ ២១ ដួង រមែងមានព្រោះបច្ច័យ គឺបុញ្ញាភិសង្ខារដូច្នេះខ្លះ

ចំណែកវិញ្ញាណ ៧ ដួង ដូច្នេះ គឺវិញ្ញាណ មានចក្ខុវិញ្ញាណជាដើម ដែល ជាអកុសលវិបាក ៥ មនោធាតុ ១ មនោវិញ្ញាណធាតុ ១ រមែងមានព្រោះបច្ច័យ គឺ អបុញ្ញាភិសង្ខារ ដូចបាលីថា ព្រោះកម្មជាអកុសលដែលបុគ្គលធ្វើទុកហើយ សាង ទុកហើយ ចក្ខុវិញ្ញាណ... សោតវិញ្ញាណ... ឃានវិញ្ញាណ... ជិវ្ហាវិញ្ញាណ... ទើប

កាយវិញ្ញាណដែលជាវិបាកកើតឡើង មនោធាតុដែលជាវិបាក... ទើបមនោវិញ្ញាណធាតុ ដែលជាវិបាកកើតឡើង ដូច្នេះ ។

ចំណែកវិញ្ញាណ ៤ ដួង ដូច្នេះ គឺវិញ្ញាណដែលជាអរូបវិបាក ៤ រមែងមានព្រោះបច្ច័យ គឺអនេញ្ជាភិសង្ខារ ដូចបាលីថា ហេតុកម្មដែលជាកុសលផ្នែកអរូបាវចរនោះឯង ដែលបុគ្គលធ្វើទុកហើយ សាងទុកហើយ ព្រោះឈានកន្លងរូបសញ្ញាទាំងឡាយបានដោយប្រការទាំងពួង ទើបចូលដល់វិញ្ញាណដែលសហគតៈ ដោយអាកាសានញ្ចាយតនសញ្ញា... វិញ្ញាណញ្ចាយតនសញ្ញា... អាកិញ្ចញ្ញាយតនសញ្ញា... នេវសញ្ញានាសញ្ញាយតនសញ្ញាដែលជាវិបាក ដូច្នេះ ។

## ការប្រព្រឹត្តទៅនៃវិញ្ញាណ

វិញ្ញាណណាមួយ រមែងមានព្រោះបច្ច័យ គឺសង្ខារណាមួយហើយ ឥឡូវនេះគប្បីជ្រាបបវត្តិ ( ការប្រព្រឹត្តទៅនៃរឿងរ៉ាវ ) នៃវិញ្ញាណនោះៗ ដូចតទៅនេះ ។

វិញ្ញាណទាំងពួងនេះឯង រមែងប្រព្រឹត្តទៅដោយចំណែក ២ ដោយអំណាចនៃបវត្តិ ( ការប្រព្រឹត្តទៅចំណែកតអំពីបដិសន្ធិទៅ ) និង ( ចំណែក ) បដិសន្ធិ ក្នុង ២ ចំណែកនោះ វិញ្ញាណ ១៣ ដួង គឺបញ្ចវិញ្ញាណ ២ ( ជា ១០ ) មនោធាតុ ២ អហេតុកមនោវិញ្ញាណធាតុ ដែលជាសោមនស្សសហគតៈ ១ រមែងប្រព្រឹត្តទៅក្នុងចំណែកបវត្តិក្នុងបញ្ចវោការភពប៉ុណ្ណោះ វិញ្ញាណដ៏សេស ១៩ ដួង ប្រព្រឹត្តទៅទាំងក្នុងចំណែកបវត្តិ ទាំងក្នុងចំណែកបដិសន្ធិតាមគួរក្នុងភព ៣ ( គឺបញ្ចវោការ ចតុវោការ និងឯកវោការ ) ។

## ការចែកបវត្តិ

បុច្ឆាថា ប្រព្រឹត្តទៅយ៉ាងដូចម្តេច ?

វិសជ្ជនាថា ក្នុងអដ្ឋកថាមជ្ឈិមនិកាយពោលទុកថា លំដាប់ដំបូងវិញ្ញាណ ៥ មានចក្ខុវិញ្ញាណជាដើមផ្នែកកុសលវិបាក ប្រារព្ធអារម្មណ៍ មានរូបជាដើមដែលមកកាន់គន្លងនៃទ្វារ មានចក្ខុទ្វារជាដើមរបស់បុគ្គលអ្នកកើតមកដោយកុសលវិបាក ឬដោយអកុសលវិបាកក៏ដោយ ដែលមានឥន្ទ្រិយចូលដល់ការចាស់ក្លាហើយតាមលំដាប់ជាឥដ្ឋារម្មណ៍ក៏ដោយ ឥដ្ឋមជ្ឈត្តារម្មណ៍ក៏ដោយ អាស្រ័យបសាទ មានចក្ខុបសាទជាអាទិ៍ ក៏ញ៉ាំងកិច្ច គឺការឃើញ ការឮ ការធុំក្លិន ការដឹងរស ការប៉ះពាល់ឲ្យប្រព្រឹត្តទៅ វិញ្ញាណ ៥ ផ្នែកអកុសលវិបាកក៏ប្រព្រឹត្តទៅយ៉ាងនោះ តែអារម្មណ៍របស់អកុសលវិបាកវិញ្ញាណទាំងនោះជាអនិដ្ឋារម្មណ៍ ឬអនិដ្ឋមជ្ឈត្តារម្មណ៍ប៉ុណ្ណោះឯងជាការប្លែកគ្នា ។ ពិតហើយ វិញ្ញាណទាំង ១០ នោះ ក៏មានទ្វារ អារម្មណ៍ វត្ថុនិងឋានផ្ទាល់ខ្លួន និងមានកិច្ចសម្រាប់ខ្លួនប៉ុណ្ណោះឯង តពីនោះ មនោធាតុ ដែលជាកុសលវិបាកក្នុងលំដាប់នៃវិញ្ញាណទាំងឡាយ មានចក្ខុវិញ្ញាណជាដើមដែលជាកុសលវិបាក ប្រារព្ធអារម្មណ៍របស់វិញ្ញាណនោះឯង អាស្រ័យហទយវត្ថុ ក៏ញ៉ាំងសម្បដិច្ឆន្នកិច្ចឲ្យសម្រេចប្រព្រឹត្តទៅ មនោធាតុផ្នែកអកុសលវិបាកក្នុង លំដាប់នៃអកុសលវិបាកវិញ្ញាណទាំងឡាយ ក៏ប្រព្រឹត្តទៅយ៉ាងនោះ តែមនោធាតុមួយគូនេះ មានទ្វារ និងអារម្មណ៍មិនពិតប្រាកដ តែមានវត្ថុ និងឋានផ្ទាល់ខ្លួន និងកិច្ចក៏ចំពោះតែខ្លួន ឯអហេតុកមនោវិញ្ញាណធាតុដែលជាសោមនស្សសហគតៈ ក្នុងលំដាប់នៃកុសលវិបាកមនោធាតុក៏ប្រារព្ធអារម្មណ៍នៃកុសលវិបាកមនោធាតុនោះឯងអាស្រ័យហទយវត្ថុ ញ៉ាំងសន្តីរណកិច្ចឲ្យសម្រេចកាត់វិថីកវង្គក្នុងទីបំផុត នៃជវនដែលសម្បយុត្តជាមួយលោភៈដោយច្រើននៃពួកសត្វកាមាវចរ ក្នុងកាលអារម្មណ៍នោះជាអារម្មណ៍មានកម្លាំងក្នុងទ្វារទាំង ៦ ប្រព្រឹត្តទៅ ១ វារៈខ្លះ ២ វារៈខ្លះ ដោយអំណាចនៃតទាលម្ពណៈក្នុងអារម្មណ៍ដែលជវនតោងទុក ដូច្នេះ តែក្នុងអដ្ឋកថាអភិធម្ម វារៈចិត្តក្នុងតទាលម្ពណៈមកជា ២

( ១ ភវៈមិនមាន ) ឯចិត្តដួងនេះមានឈ្មោះ ២ គឺតទាលម្ពណៈ ១ បិដ្ឋិភវង្គ ( មានភវង្គអែបខ្នង ) ១ ជាចិត្ត មានទ្វារ និងអារម្មណ៍មិនពិតប្រាកដ តែមានវត្ថុផ្ទាល់ខ្លួន ឋាន និងកិច្ចក៏មិនចំពោះខ្លួន ។

វិញ្ញាណ ១៣ ដួង គប្បីជ្រាបថា រមែងប្រព្រឹត្តទៅក្នុងចំណែកបវត្តិក្នុងបញ្ច-វោការភពប៉ុណ្ណោះដូចពោលមកដូច្នេះមុន ។

ក្នុងវិញ្ញាណ ១៩ ដ៏សេស វិញ្ញាណណាមួយ មិនប្រព្រឹត្តទៅដោយបដិសន្ធិកិច្ច ដែលគួរដល់ខ្លួនក៏មិនមាន តែក្នុងចំណែកបវត្តិ លំដាប់ដំបូង អហេតុកមនោវិញ្ញាណធាតុដែលជាកុសលវិបាក និងអកុសលវិបាកទាំង ២ ញ៉ាំងកិច្ច ៤ ឲ្យសម្រេច គឺញ៉ាំងសន្តីរណកិច្ច ក្នុងលំដាប់នៃកុសលាកុសលវិបាកមនោធាតុ ក្នុងបញ្ចទ្វារឲ្យសម្រេច ញ៉ាំងតទាលម្ពណកិច្ចក្នុងទ្វារ ៦ ដោយន័យដែលពោលក្នុងផ្នែកមុននោះឯងឲ្យសម្រេច កាលចិត្តុប្បាទដែលចូលទៅកាត់ភវង្គមិនមាន ញ៉ាំងភវង្គកិច្ចខាងមុខអំពីបដិសន្ធិដែលខ្លួនឲ្យហើយឲ្យសម្រេចនិងញ៉ាំងចុតិកិច្ចក្នុងលំដាប់ចុងក្រោយឲ្យសម្រេចជាវិញ្ញាណធាតុដែលមានវត្ថុផ្ទាល់ខ្លួន តែមានទ្វារ អារម្មណ៍ ឋាន និងកិច្ចមិនផ្ទាល់ខ្លួនប្រព្រឹត្តទៅ សហេតុកចិត្តផ្នែកកាមាវចរ ៨ ញ៉ាំងកិច្ច ៣ ឲ្យសម្រេច គឺញ៉ាំងតទាលម្ពណកិច្ចក្នុងទ្វារ ៦ ដោយន័យដែលពោលហើយនោះឯងឲ្យសម្រេច កាលចិត្តុប្បាទដែលចូលទៅកាត់ភវង្គមិនមាន ក៏ញ៉ាំងភវង្គកិច្ចខាងមុខអំពីបដិសន្ធិ ដែលខ្លួនឲ្យហើយឲ្យសម្រេច និងញ៉ាំងចុតិកិច្ចក្នុងលំដាប់ចុងក្រោយឲ្យសម្រេច ជាចិត្តមានវត្ថុផ្ទាល់ខ្លួន តែទ្វារ អារម្មណ៍ ឋាន និងកិច្ចមិនផ្ទាល់ខ្លួនប្រព្រឹត្តទៅ រូបាវចរវិញ្ញាណ ៥ និងអរូបាវចរ-វិញ្ញាណ ៤ ញ៉ាំងកិច្ច ២ ឲ្យសម្រេច គឺកាលចិត្តុប្បាទដែលចូលទៅកាត់ភវង្គមិនមាន ក៏ញ៉ាំងភវង្គកិច្ចខាងមុខអំពីបដិសន្ធិដែលខ្លួនឲ្យហើយឲ្យសម្រេច និងញ៉ាំងចុតិកិច្ចក្នុងលំដាប់ចុងក្រោយ ឲ្យសម្រេចប្រព្រឹត្តទៅក្នុងចិត្ត ២ ប្រភេទនោះ រូបាវចរចិត្ត

ទាំងឡាយ មានវត្ថុ ទ្វារ និងអារម្មណ៍ផ្លាស់ប្តូរ តែឋាន និងកិច្ចមិនផ្លាស់ប្តូរ ចំណែកអរូបាវចរចិត្តទាំងឡាយមានវត្ថុផ្លាស់ប្តូរ អារម្មណ៍ផ្លាស់ប្តូរ តែឋាន និងកិច្ចមិនផ្លាស់ប្តូរប្រព្រឹត្តទៅ ។

វិញ្ញាណទាំង ៣២ ដួង រមែងប្រព្រឹត្តទៅ ព្រោះសង្ខារប្បច្ច័យក្នុងបវត្តិ ដូចពោលមកដូច្នេះ ។

សង្ខារនោះៗ ជាបច្ច័យដោយកម្មប្បច្ច័យ និងឧបនិស្សយប្បច្ច័យនៃវិបាកវិញ្ញាណ ៣២ នោះ ក្នុងបវត្តិនោះ ។

# ការចែកបដិសន្ធិ

ចំណែកពាក្យណាដែលខ្ញុំពោលទុកថា ក្នុងវិញ្ញាណ ១៩ ដ៏សេស វិញ្ញាណណាមួយ មិនប្រព្រឹត្តទៅដោយបដិសន្ធិកិច្ច ដែលគួរដល់ខ្លួនក៏មិនមាន ពាក្យនោះដឹងបានលំបាក ព្រោះជាពាក្យសង្ខេបពេក ព្រោះហេតុនោះ ខ្ញុំពោលដើម្បីសម្តែងវិត្ថារន័យនៃបដិសន្ធិវិញ្ញាណនោះតទៅ ដោយតាំងបញ្ហាថា

១- បដិសន្ធិមានប៉ុន្មានយ៉ាង ?

២- បដិសន្ធិចិត្តមានប៉ុន្មាន ?

៣- បដិសន្ធិរមែងមានក្នុងភពណា ដោយចិត្តអ្វី ?

៤- អ្វីជាអារម្មណ៍របស់បដិសន្ធិ ?

មានពាក្យឆ្លើយថា

១- បដិសន្ធិមាន ២០ ទាំងបដិសន្ធិរបស់អសញ្ញីសត្វ ( គឺដោយបដិសន្ធិចិត្តក៏មានត្រឹមតែ ១៩ តែរាប់បដិសន្ធិរបស់ពួកអសញ្ញីចូលផង ទើបជា ២០ ) ។

២- បដិសន្ធិចិត្តមាន ១៩ ប្រការដូចពោលហើយនោះឯង ។

៣- ក្នុងបដិសន្ធិចិត្ត ១៩ នោះ បដិសន្ធិក្នុងអបាយទាំងឡាយ រមែងមានដោយអហេតុកមនោវិញ្ញាណធាតុដែលជាអកុសលវិបាក បដិសន្ធិនៃពួកមនុស្សខ្វាក់អំពីកំណើត មនុស្សថ្លង់អំពីកំណើត មនុស្សឆ្កួតអំពីកំណើត មនុស្ស.គអំពីកំណើត និងពួកខ្ទើយទាំងឡាយក្នុងមនុស្សលោក រមែងមានដោយអហេតុកមនោវិញ្ញាណធាតុដែលជាកុសលវិបាក បដិសន្ធិនៃលោកអ្នកមានបុណ្យក្នុងពួកទេវតាជាន់កាមាវចរក្តី ក្នុងពពួកមនុស្សក្តី រមែងមានដោយសហេតុកកាមាវចរវិបាកចិត្ត ៨ បដិសន្ធិក្នុងរូបព្រហ្ម រមែងមានដោយរូបាវចរវិបាកចិត្ត ៥ បដិសន្ធិក្នុងអរូបព្រហ្ម រមែងមានដោយអរូបាវចរវិបាកចិត្ត ៤ ឯបដិសន្ធិរមែងមានក្នុងកពណា ដោយចិត្តអ្វី ដូចពោលមកដូច្នេះ បដិសន្ធិនោះឯងឈ្មោះថា បដិសន្ធិដ៏គួរដល់វិញ្ញាណនោះ ។

៤- ចំណែកអារម្មណ៍របស់បដិសន្ធិដោយសង្ខេបមាន ៣ គឺអតីតារម្មណ៍ បច្ចុប្បន្នារម្មណ៍ និងនវត្តព្វារម្មណ៍ ( គឺអារម្មណ៍ដែលមិនគួរនឹងពោលបានថា ជាអតីត ឬបច្ចុប្បន្ន ) តែបដិសន្ធិរបស់ពួកអសញ្ញីជាអនារម្មណ៍ គឺមិនមានអារម្មណ៍ ។

ក្នុងអារម្មណ៍ ៣ នោះ អារម្មណ៍របស់បដិសន្ធិនៃសត្វជាន់វិញ្ញាណញ្ចាយតនៈ និងជាន់នេវសញ្ញានាសញ្ញាយតនៈ ជាអតីតារម្មណ៍តែម្យ៉ាង នៃសត្វជាន់កាមាវចរ ១០ ជាអតីតារម្មណ៍ខ្លះ បច្ចុប្បន្នារម្មណ៍ខ្លះនៃសត្វដ៏សេស ជានវត្តព្វារម្មណ៍ពិត ។

ម្យ៉ាងទៀត បដិសន្ធិដែលប្រព្រឹត្តទៅក្នុងអារម្មណ៍ ៣ ដូច្នេះ ក៏រមែងប្រព្រឹត្តទៅក្នុងលំដាប់នៃចុតិចិត្ត ដែលមានអារម្មណ៍ជាអតីតារម្មណ៍ខ្លះ នវត្តព្វារម្មណ៍ខ្លះប៉ុណ្ណោះ ព្រោះធម្មតាថា ចុតិចិត្តមិនមែនជាបច្ចុប្បន្នារម្មណ៍ទេ ហេតុណា ព្រោះហេតុនោះ ទើបបណ្ឌិតគួរជ្រាបអាការប្រព្រឹត្តទៅនៃបដិសន្ធិ ដែលមានអារម្មណ៍ឯណាមួយក្នុងអារម្មណ៍ ៣ ក្នុងលំដាប់នៃចុតិមានអារម្មណ៍ណាមួយក្នុងអារម្មណ៍ ២ ដោយអំណាចនៃសុគតិ និងទុគ្គតិ ( តទៅ ) សេចក្តីនេះដូចម្តេច ?

លំដាប់ដំបូង បាបកម្មតាមដែលខ្លួនសន្សំទុកខ្លះ កម្មនិមិត្តខ្លះ រមែងមកកាន់គន្លង ក្នុងមនោទ្វារ របស់បុគ្គលអ្នកតាំងនៅក្នុងសុគតិជាន់កាមាវចរ ( តែ ) ជាមនុស្សមាន បាបកម្ម ដែល (ឈឺធ្ងន់) ដេកនៅលើគ្រែសម្រាប់ស្លាប់ (ទាំងនេះ) ដោយបាលី ពោលទុកថា ក្នុងសម័យនោះ កម្មទាំងឡាយ ( ដែលខ្លួនធ្វើទុកមុន ) នោះ រមែងតោង ( ក្នុងចិត្ត ) របស់បុគ្គល ( អ្នកជិតស្លាប់ ) នោះ ដូច្នេះជាដើម ចុតិចិត្តធ្វើអារម្មណ៍ នៃភវង្គឲ្យជាអារម្មណ៍កើតឡើងក្នុងលំដាប់នៃជវនវិថីដែលប្រារព្ធកម្ម ឬកម្មនិមិត្តនោះ កើតឡើង មានតទាលម្ពណៈជាទីបំផុត គ្រាចុតិចិត្តនោះ រលត់ហើយ បដិសន្ធិចិត្តដែល កម្លាំងនៃកិលេសដែលនៅកាត់មិនបានដឹកនាំចូលទៅផ្លូវទុគ្គតិក៏ប្រារព្ធកម្ម ឬកម្មនិមិត្ត ដែលមកកាន់គន្លង ( មនោទ្វារ ) នោះឯងកើតឡើង នេះជាបដិសន្ធិមានអារម្មណ៍ ជាអតីត ( កើត ) ក្នុងលំដាប់នៃចុតិដែលមានអារម្មណ៍ជាអតីត ( ដូចគ្នា ) ។

ក្នុងមរណសម័យ ( វេលាជិតស្លាប់ ) ទុគ្គតិនិមិត្ត មានវណ្ណរូបនៃអណ្ដាតភ្លើង ជាដើម ក្នុងទុគ្គតិទាំងឡាយ មាននរកជាអាទិ៍ រមែងមកកាន់គន្លងក្នុងមនោទ្វារ របស់ បុគ្គលអ្នកមានបាបកម្មម្នាក់ទៀត ដោយអំណាចនៃកម្មមានប្រការ ដូចពោលហើយ គ្រាភវង្គចិត្តកើតឡើងហើយរលត់ទៅ ២ វារៈ វិថីចិត្ត ៣ ដួង គឺអាវជ្ជនៈ ១ ជវន ( ត្រឹមតែ ) ៥ ព្រោះជាចិត្តមានកម្លាំងខ្សោយ ដោយការដែលមរណៈ ជិតចូលមក តទាលម្ពណៈ ២ ប្រារព្ធអារម្មណ៍នោះកើតឡើងដល់បុគ្គលនោះ តអំពីនោះ ចុតិចិត្ត ១ ដួង ធ្វើអារម្មណ៍របស់ភវង្គឲ្យជាអារម្មណ៍កើតឡើង ខណៈចិត្ត ១១ ( គឺភវង្គ ២ អាវជ្ជនៈ ១ ជវន ៥ តទាលម្ពណៈ ២ ចុតិ ១ ) ត្រឹមនេះរាប់ជាអតីត លំដាប់នោះ បដិសន្ធិចិត្តកើតឡើងដល់បុគ្គលនោះក្នុងអារម្មណ៍នោះៗ ឯង ដែលមានអាយុគ្រប់ ៥ ខណៈចិត្តដ៏សេស នេះជាបដិសន្ធិមានអារម្មណ៍ ជាបច្ចុប្បន្ន ( កើត ) ក្នុងលំដាប់ នៃចុតិដែលមានអារម្មណ៍ជាអតីត ។

ក្នុងមរណសម័យ អារម្មណ៍ដែលជាហេតុនៃកិលេស មានរាគៈជាដើម មកកាន់គន្លងតាមទ្វារ ៥ ទ្វារណាមួយរបស់បុគ្គលម្នាក់ទៀត ជវន ( ត្រឹមតែ ) ៥ ព្រោះជាចិត្តមានកម្លាំងខ្សោយ ដោយការដែលមរណៈជិតចូលមក និងតទាលម្ពណៈ ២ កើតឡើងក្នុងទីបំផុតនៃវោដ្ឋពូនៈ ដែលកើតឡើងតាមលំដាប់ដល់បុគ្គលនោះតពីនោះ ចុតិចិត្ត ១ ដួង ធ្វើអារម្មណ៍របស់ភវង្គឲ្យជាអារម្មណ៍កើតឡើង ឯខណៈចិត្ត ១៥ គឺភវង្គ ២ អាវជ្ជនៈ ១ ទស្សនៈ ១ សម្បដិច្ឆន្នៈ ១ សន្តីរណៈ ១ វោដ្ឋពូនៈ ១ ជវន ៥ តទាលម្ពណៈ ២ ចុតិចិត្ត ១ ត្រឹមនេះរាប់ថាជាអតីត លំដាប់នោះ បដិសន្ធិចិត្តកើតឡើង ក្នុងអារម្មណ៍នោះៗ ឯង ដែលមានអាយុគ្រប់ ១ ខណៈចិត្តដ៏សេស សូម្បីបដិសន្ធិនេះ ក៏ជាបដិសន្ធិមានអារម្មណ៍ជាបច្ចុប្បន្ន ( កើត ) ក្នុងលំដាប់នៃចុតិដែលមានអារម្មណ៍ជាអតីត ។

នេះជាអាការប្រព្រឹត្តទៅរបស់ទុគ្គតិបដិសន្ធិ ដែលមានអារម្មណ៍ជាអតីតខ្លះ បច្ចុប្បន្នខ្លះ កើតក្នុងលំដាប់នៃសុគតិចុតិដែលមានអារម្មណ៍ជាអតីតប៉ុណ្ណោះ ។

សម្រាប់អ្នកតាំងនៅក្នុងទុគ្គតិ តែមានកម្មដែលមិនមានទោសបានសន្សំទុកពាក្យទាំងពួងបណ្ឌិតគប្បីជ្រាបដោយន័យមុននោះឯង ដោយបញ្ចុះពាក្យផ្នែក.សចុះ (ជំនួស) ក្នុងពាក្យចំណែកខ្មៅ ដូចពាក្យថា កម្មមិនមានទោសនោះខ្លះ កម្មនិមិត្តខ្លះ រមែងមកកាន់គន្លងក្នុងមនោទ្វារជាដើម តាមន័យដែលពោលហើយចុះ នេះជាអាការប្រព្រឹត្តទៅ នៃសុគតិបដិសន្ធិ ដែលមានអារម្មណ៍ជាអតីតខ្លះ បច្ចុប្បន្នខ្លះ កើតក្នុងលំដាប់នៃទុគ្គតិ ចុតិដែលមានអារម្មណ៍ជាអតីត ។

ខាងផ្នែកអ្នកតាំងនៅក្នុងសុគតិ មានកម្មដែលមិនមានទោស បានសន្សំទុក ( ឈឺធ្ងន់ ) ដេកលើគ្រែសម្រាប់ស្លាប់ កម្មមិនមានទោសតាមដែលបានសន្សំទុកខ្លះ កម្មនិមិត្តខ្លះ រមែងមកកាន់គន្លងក្នុងមនោទ្វារ ( ទាំងនេះ ) ដោយព្រះបាលី ( ពោល

ទុក ) ថា ក្នុងសម័យនោះ អនវជ្ជកម្មទាំងឡាយ ( ដែលខ្លួនសន្សំទុកមុន ) នោះ រមែង តោង ( ក្នុងចិត្ត ) របស់បុគ្គល ( អ្នកជិតស្លាប់ ) នោះ ដូច្នេះជាដើម ក៏ប៉ុន្តែប្រការ ដែលមិនកំណត់ប្រាកដថា អនវជ្ជកម្ម ឬកម្មនិមិត្ត នឹងមកកាន់គន្លងមនោទ្វារនោះ សម្រាប់អ្នកសន្សំអនវជ្ជកម្មផ្នែកកាមាវចរទុកប៉ុណ្ណោះ ចំណែកអ្នកសន្សំមហគ្គតកម្ម ទុក មានតែកម្មនិមិត្តតែម្យ៉ាងមកកាន់គន្លង ( មនោទ្វារ ) ចុតិ ចិត្តធ្វើអារម្មណ៍នៃកវគ្គ ឲ្យជាអារម្មណ៍កើតឡើងក្នុងលំដាប់នៃជវនវិថី មានតទាលម្ពណៈជាទីបំផុត ឬជវនសុទ្ធ ( មិនមានតទាលម្ពណៈ ) ដែលប្រារព្ធកម្ម ឬកម្មនិមិត្តនោះកើតឡើង កាលចុតិចិត្ត នោះរលត់ទៅហើយ បដិសន្ធិចិត្តដែលកម្លាំងនៃកិលេស ដែលនៅកាត់មិនទាន់បាន ដឹកនាំចូលទៅផ្លូវសុគតិ ក៏ប្រារព្ធកម្ម ឬកម្មនិមិត្ត ដែលមកកាន់គន្លង ( មនោទ្វារ ) នោះឯងកើតឡើង នេះជាបដិសន្ធិជាអតីតារម្មណ៍ ជានវត្តព្វារម្មណ៍ខ្លះ ( កើត ) ក្នុង លំដាប់នៃចុតិដែលជាអតីតារម្មណ៍ ។

បុគ្គលអ្នកមានអនវជ្ជកម្ម បានសន្សំទុកក្នុងមរណសម័យ មានសុគតិនិមិត្ត បានដល់ វណ្ណរូបនៃផ្ទៃមាតាក្នុងមនុស្សលោកខ្លះ បានដល់ វណ្ណរូបនៃឧទ្យាន វិមាន និងកប្បព្រឹក្សជាដើមក្នុងទេវលោកខ្លះ មកកាន់គន្លងនៃមនោទ្វារ ដោយអំណាចនៃ អនវជ្ជកម្មកាមាវចរ បដិសន្ធិចិត្តកើតឡើងដល់បុគ្គលនោះក្នុងលំដាប់នៃចុតិចិត្ត តាម លំដាប់ចិត្តដែលសម្តែងមកហើយក្នុង ( វគ្គពោលដោយ ) ទុគ្គតិនិមិត្តនោះឯង នេះជា បដិសន្ធិជាបច្ចុប្បន្នារម្មណ៍ ( កើតក្នុង ) លំដាប់នៃចុតិដែលជាអតីតារម្មណ៍ ។

ម្នាក់ទៀត ក្នុងមរណសម័យ ពួកញាតិប្រាប់ថា នេះនែ កូន ពុទ្ធបូជាយើង ធ្វើដើម្បីប្រយោជន៍ដល់អ្នក អ្នកចូរញ៉ាំងចិត្តឲ្យជ្រះថ្លាចុះ ហើយនាំរូបារម្មណ៍ ដោយ ភាពជាគ្រឿងបូជា មានបាច់ផ្កាឈើ និងទង់វែង ទង់ផ្ទាំងសំពត់ជាដើមខ្លះ សទ្ទារម្មណ៍ ដោយការស្តាប់ធម៌ និងការបូជាដោយសំឡេងតន្ត្រីជាដើមខ្លះ គន្ធារម្មណ៍ ដោយ

ក្លិនធូប និងគ្រឿងអប់ជាដើមខ្លះ រសារម្មណ៍ដោយគ្រឿងលិទ្ធភ្លក្ស មានទឹកឃ្មុំ និងទឹកអំពៅជាដើម ដោយប្រាប់ថា នែកូន ចូរកូនភ្លក្សនេះមើល ជាទេយ្យធម៌ដែលយើងនឹងគប្បីឲ្យដើម្បីជាប្រយោជន៍ដល់អ្នក ដូច្នេះខ្លះ ផោដ្ឋព្វារម្មណ៍ ដោយសំពត់ មានសំពត់ចិន និងសំពត់សោមារជាដើម ដោយប្រាប់ថា នែបា ចូរប៉ះរបស់នេះមើលជាទេយ្យធម៌ ដែលយើងនឹងគប្បីឲ្យដើម្បីប្រយោជន៍ដល់អ្នក ដូច្នេះខ្លះ បង្អោនចូលទៅឲ្យប្រចក្សក្នុងទ្វារ ៥ ជវន ត្រឹមតែ ៥ ព្រោះជាចិត្តមានកម្លាំងខ្សោយ ព្រោះការដែលមរណៈ ជិតចូលមក និងតទាលម្ពណៈ ២ កើតឡើងដល់បុគ្គល នោះក្នុងទីបំផុតនៃវោដ្ឋព្វនៈ ដែលកើតឡើងតាមលំដាប់ក្នុងអារម្មណ៍មានរូបជាដើម ដែលមកកាន់គន្លងទ្វារនោះ តពីនោះ ចុតិចិត្ត ១ ដួង ធ្វើអារម្មណ៍នៃភវង្គឲ្យជាអារម្មណ៍កើតឡើងក្នុងទីបំផុត នៃចុតិចិត្តនោះ បដិសន្ធិចិត្តក៏កើតឡើងក្នុងអារម្មណ៍នោះឯង ដែលតាំងនៅគ្រប់ខណៈចិត្តមួយ សូម្បីបដិសន្ធិនេះក៏ជាបដិសន្ធិជាបច្ចុប្បន្នារម្មណ៍ កើតក្នុងលំដាប់នៃចុតិដែលជាអតីតារម្មណ៍ ។

ចំណែកម្នាក់ទៀត ស្ថិតនៅក្នុងសុគតិ សម្រាប់បុគ្គលអ្នកបានមហគ្គតវិបាកដោយអំណាចឈាន មានបឋវីកសិណជាដើម ក្នុងមរណសម័យ កាមាវចរកុសលកម្មកម្មនិមិត្ត ឬគតិនិមិត្ត ឯណានីមួយ កសិណនិមិត្ត មាននិមិត្តនៃបឋវីកសិណជាដើមខ្លះ មហគ្គតចិត្តខ្លះ មកកាន់គន្លងក្នុងមនោទ្វារ ឬមិនដូច្នោះ អារម្មណ៍ប្រណីត ដែលជាហេតុកើតកុសលមកកាន់គន្លងក្នុងចក្ខុទ្វារ ឬសោតទ្វារណាមួយ ជវនត្រឹមតែ ៥ ព្រោះជាចិត្តមានកម្លាំងខ្សោយដោយមរណៈជិតចូលមក កើតឡើងដល់បុគ្គលនោះ ក្នុងទីបំផុតនៃវោដ្ឋព្វនៈដែលកើតឡើងតាមលំដាប់ ព្រោះតទាលម្ពណៈ រមែងមិនមានដល់បុគ្គលអ្នកចូលដល់គតិមហគ្គតៈទាំងឡាយ ហេតុនោះ ទើបចុតិចិត្ត ១ ដួងធ្វើអារម្មណ៍នៃភវង្គឲ្យជាអារម្មណ៍កើតឡើងក្នុងលំដាប់នៃជវននោះឯង ក្នុងទីបំផុតនៃចុតិចិត្តនោះ

បដិសន្ធិចិត្តមានអារម្មណ៍ តាមដែលចូលមកប្រាកដយ៉ាងណាមួយជាអារម្មណ៍ឈោងចុះក្នុងសុគតិជាកាមាវចរ ឬមហគ្គតៈ ស្ថានណាមួយហើយក៏កើតឡើង នេះជាបដិសន្ធិដែលជាអតីតារម្មណ៍ បច្ចុប្បន្នារម្មណ៍ និងនវត្តព្វារម្មណ៍ កើតក្នុងលំដាប់នៃសុគតិចុតិដែលជានវត្តព្វារម្មណ៍ សូម្បីបដិសន្ធិក្នុងលំដាប់នៃអរូបចុតិ ក៏គប្បីជ្រាបដោយទំនងនេះ ។

នេះជាអាការប្រព្រឹត្តទៅ របស់បដិសន្ធិដែលជាអតីតារម្មណ៍ នវត្តព្វារម្មណ៍ បច្ចុប្បន្នារម្មណ៍ កើតក្នុងលំដាប់នៃសុគតិចុតិដែលជាអតីតារម្មណ៍ នវត្តព្វារម្មណ៍ ។

ចំណែកអ្នកមានបាបកម្មនៅក្នុងទុគ្គតិ ( ក្នុងមរណសម័យ ) រមែងមានកម្ម ( ដែលធ្វើទុក ) នោះខ្លះ កម្មនិមិត្តខ្លះ គតិនិមិត្តខ្លះ មកកាន់គន្លងក្នុងមនោទ្វារ ឬមិនដូច្នោះ អារម្មណ៍ដែលជាហេតុកើតអកុសលមកកាន់គន្លងក្នុងបញ្ចទ្វារ ដោយន័យដែលពោលហើយនោះឯង តពីនោះ ក្នុងទីបំផុតនៃចុតិចិត្តតាមលំដាប់ បដិសន្ធិចិត្ត មានអារម្មណ៍ទាំងនោះឯណាមួយជាអារម្មណ៍ ធ្លាក់ទៅក្នុងផ្លូវទុគ្គតិក៏កើតឡើងដល់បុគ្គលនោះ នេះជាអាការប្រព្រឹត្តទៅនៃបដិសន្ធិដែលជាអតីតារម្មណ៍ បច្ចុប្បន្នារម្មណ៍ កើតក្នុងលំដាប់នៃទុគ្គតិចុតិ ដែលជាអតីតារម្មណ៍ ។

ការប្រព្រឹត្តទៅដោយអំណាចបដិសន្ធិនៃវិញ្ញាណទាំង ១៩ ដួង ជាការសម្តែងហើយត្រឹមប៉ុណ្ណោះ ។

## គាថាសង្ខេបបដិសន្ធិវិញ្ញាណ

វិញ្ញាណទាំងអស់នេះ កាលប្រព្រឹត្តទៅក្នុងបដិសន្ធិដូចពោលមកនោះ រមែងប្រព្រឹត្តទៅ ដោយកម្ម ២ ផ្នែក និងមានប្រភេទផ្សេងៗ ដូចប្រភេទ ២ ជាដើម ដោយប្រភេទទាំងឡាយ មានប្រភេទផ្សំជាដើម ។

## ពន្យល់សេចក្តី

មែនពិត វិបាកវិញ្ញាណ ២៩ ដូងនេះ កាលប្រព្រឹត្តទៅក្នុងបដិសន្ធិ រមែងប្រព្រឹត្តទៅដោយកម្មពីរផ្នែកដូចគ្នា ព្រោះថា ជនកកម្មរមែងជាបច្ច័យដោយកម្មប្បច្ច័យ ដែលប្រព្រឹត្តទៅក្នុងខណៈផ្សេងៗ គ្នា ១ ដោយឧបនិស្សយប្បច្ច័យ ១ នៃវិបាកវិញ្ញាណនោះតាមដែលជារបស់ខ្លួន សមដូចពាក្យបាលីថា កុសលកម្ម និងអកុសលកម្មជាបច្ច័យដោយឧបនិស្សយប្បច្ច័យនៃវិបាក ដូច្នេះ ។

ម្យ៉ាងទៀត គប្បីជ្រាបប្រភេទមាន ២ ប្រភេទជាដើម ដោយប្រភេទទាំងឡាយមានប្រភេទផ្សំគ្នាជាដើមនៃវិបាកវិញ្ញាណដែលប្រព្រឹត្តទៅយ៉ាងនេះតទៅ សេចក្តីនេះយ៉ាងណា ? វិបាកវិញ្ញាណនេះ សូម្បីប្រព្រឹត្តទៅតែម្យ៉ាងដោយអំណាចបដិសន្ធិ តែជា ២ ដោយចែកជាប្រភេទផ្សំជាមួយរូប និងប្រភេទមិនផ្សំជាមួយរូប ជា ៣ ដោយចែកជាកាមភព រូបភព និងអរូបភព ជា ៤ ដោយកំណើតអណ្ឌជៈ ជលាពុជៈ សំសេទជៈ ឱបបាតិកៈ ជា ៥ ដោយគតិ ជា ៧ ដោយវិញ្ញាណដ្ឋិតិ ជា ៨ ដោយសត្តាវាស (វៀរអសញ្ញី ១) ។

## គាថាសង្ខេបវិញ្ញាណផ្សំ

ក្នុងវិញ្ញាណផ្សំ និងមិនផ្សំនោះ វិញ្ញាណផ្សំមាន ២ ដោយផ្សេងគ្នានៃភាវៈ និងក្នុងភាវៈប្រភេទនោះសោត វិញ្ញាណដែលមានភាវៈក៏មាន ២ ( រូបកលាបៈ ) ទសកៈ ២ ឬ ៣ ខ្ទះ យ៉ាងទាប រមែងកើតព្រមជាមួយវិញ្ញាណប្រភេទដើម គឺវិញ្ញាណផ្សំ ។

## ពន្យល់សេចក្តី

ពាក្យថា វិញ្ញាណមាន ២ ដោយផ្សេងគ្នានៃភាវៈនោះ សេចក្តីថា ក្នុងវិញ្ញាណផ្សំ និងមិនផ្សំនោះ បដិសន្ធិវិញ្ញាណដែលផ្សំជាមួយរូបនោះ ណាកើតឡើងក្នុងភព វៀរតែ

អរូបភព បដិសន្ធិវិញ្ញាណផ្សំនោះរមែងមាន ២ គឺមានភាវៈ ១ មិនមានភាវៈ ១ ព្រោះកើតឡើងវៀរចាកភាវៈ ពោល គឺឥត្ថិន្ទ្រិយ និងបុរិសិន្ទ្រិយក្នុងរូបភព និងកើតឡើងព្រមជាមួយភាវៈក្នុងកាមភព វៀរតែបដិសន្ធិរបស់មនុស្សខ្ទើយអំពីកំណើត ។

ពាក្យថា និងក្នុងភាវៈប្រភេទនោះសោត វិញ្ញាណដែលមានភាវៈក៏មាន ២ អធិប្បាយថា សូម្បីក្នុងភាវៈប្រភេទនោះសោត បដិសន្ធិវិញ្ញាណណាមានភាវៈ បដិសន្ធិវិញ្ញាណនោះក៏មាន ២ ដូចគ្នា ព្រោះកើតឡើងព្រមជាមួយឥត្ថីភាវៈ ឬបុរិសភាវៈណាមួយ ។

ពាក្យថា ( រូបកលាបៈ ) ទសកៈ ២ ឬ ៣ យ៉ាងទាប រមែងកើតព្រមជាមួយវិញ្ញាណប្រភេទដើម មានអធិប្បាយថា ( រូបកលាបៈ ) ទសកៈ ២ ដោយវត្ថុទសកៈ និងកាយទសកៈ ឬទសកៈ ៣ ដោយវត្ថុទសកៈ កាយទសកៈ និងភាវទសកៈខ្វះយ៉ាងតិច រមែងកើតឡើងព្រមជាមួយបដិសន្ធិវិញ្ញាណដែលផ្សំជាមួយរូប ដែលជាប្រភេទដើមក្នុង ២ ប្រភេទ គឺផ្សំ និងមិនផ្សំនោះ រូប ( កលាបៈ ) ថយចុះទៅក្រៃលែងជាងនេះមិនមាន ។

ឯបដិសន្ធិវិញ្ញាណ ដែលមានបរិមាណរូបកលាបៈ យ៉ាងតិចដូចពោលនេះ កាលកើតឡើងរមែងកើតជាវត្ថុដែលបានឈ្មោះថា កលលៈ ប្រមាណប៉ុនតំណក់ទឹកដោះថ្លាដែលប្រើរោមចៀមមួយសរសៃជ្រលក់លើកឡើង ក្នុងកំណើត ២ ដែលមានឈ្មោះថា អណ្ឌជៈ និងជលាពុជៈ ក្នុងកំណើត និងគតិទាំងនោះ បណ្ឌិតគប្បីជ្រាបការ មានឡើងនៃកំណើតទាំងឡាយ ដែលផ្សេងគ្នាដោយអំណាចគតិដូចតទៅនេះ ក្នុងកំណើតទាំងឡាយនោះ ។

## គាថាសង្ខេបកំណើត

កំណើត ៣ ខាងដើម រមែងមិនមានក្នុងនរក និងក្នុងពួកទេព វៀរភុម្មទេព

កំណើតទាំង ៤ រមែងមានក្នុងគតិ ៣ ។

## ពន្យល់ការសេចក្តី

ក្នុងបទទាំងនោះ ដោយ ច-ស័ព្ទ ក្នុងបទថា ទេវេសុ ច កំណើត ៣ ខាងដើម គប្បីជ្រាបថា មិនមានក្នុងនរក និងក្នុងពួកទេវតា វៀរភុម្មទេវតា យ៉ាងណា ក៏រមែង មិនមានក្នុងពួកនិជ្ឈាមតណ្ហិកប្រេតផងដូច្នោះ ព្រោះពួកនិជ្ឈាមតណ្ហិកប្រេត ទាំងនោះ ក៏ជាឱបបាតិកៈដូចគ្នា ចំណែកក្នុងគតិ ៣ ដ៏សេស ដែលបានដល់តិរច្ឆាន បេតវិស័យ មនុស្ស និងក្នុងពួកភុម្មទេវតាដែលវៀរទុកមុនផង រមែងមានកំណើត គ្រប់ទាំង ៤។

## គាថាសង្ខេបរូបកលាបៈ

ក្នុងគតិ និងកំណើតទាំងនោះ រូប ៣០ និង ៩ រមែងកើតក្នុងពួករូបព្រហ្ម ម្យ៉ាងទៀត ដោយកំណត់យ៉ាងច្រើន រូប ៧០ រមែងកើតក្នុងសត្វពួកដែលកើត ក្នុងកំណើតសំសេទជៈ និងឱបបាតិកៈ ម្យ៉ាងទៀត ដោយកំណត់យ៉ាងតិច រូប ៣០ រមែងកើត ។

## ពន្យល់ការសេចក្តី

លំដាប់ដំបូង រូប ៣០ និង ៩ ដោយអំណាចនៃកលាបៈ ៤ គឺចក្ខុទសកៈ សោតទសកៈ វត្ថុទសកៈ និងជីវិតនវកៈ រមែងកើតឡើងព្រមជាមួយបដិសន្ធិវិញ្ញាណ ក្នុងពួកសត្វដែលកើតក្នុងកំណើតឱបបាតិកៈ ក្នុងជំពូករូបព្រហ្ម ចំណែកដោយកំណត់ យ៉ាងច្រើន រូប ៧០ ដោយអំណាចនៃ ( កលាបៈ ៧ គឺ ) ចក្ខុទសកៈ សោតទសកៈ ឃានទសកៈ ជិវ្ហាទសកៈ កាយទសកៈ វត្ថុទសកៈ និងភាវទសកៈ រមែងកើតឡើង ព្រមដោយបដិសន្ធិវិញ្ញាណក្នុងពួកសត្វដែលកើតក្នុងកំណើតសំសេទជៈ និងឱបបាតិកៈ ពួកដទៃ វៀរពួករូបព្រហ្ម ម្យ៉ាងទៀត រូបទាំង ៧០ នោះ រមែងកើតឡើងក្នុងពពួក

ទេវតាជានិច្ច ។

ក្នុងទសកៈទាំងនោះ សំណុំរូប មានបរិមាណរូប ១០ នេះ គឺពណ៌ ក្លិន រស ឱជា ធាតុ ៤ ទៀត គឺចក្ខុបសាទ និងជីវិត ឈ្មោះចក្ខុទសកៈ ( មានចក្ខុជាគម្រប់ ១០ ) ទសកៈដ៏សេសក៏គប្បីជ្រាប ដូច្នេះ ។

ចំណែកពោលដោយយ៉ាងតិច រូប ៣០ ដោយអំណាចនៃកលាបៈ ៣គឺជិវ្ហាទសកៈ កាយទសកៈ វត្ថុទសកៈ រមែងកើតឡើងដល់មនុស្សខ្វាក់ភ្នែកអំពីកំណើត មនុស្សត្រចៀកថ្លង់អំពីកំណើត មនុស្សច្រមុះកង្អួត ( មិនមានឃានបសាទ ) អំពីកំណើត មនុស្សខ្ទើយអំពីកំណើត មា្យ៉ាងទៀត គប្បីជ្រាបការកំណត់ ( រូបកលាបៈ ) ក្នុងរវាងបរិមាណរូបយ៉ាងច្រើន និងយ៉ាងតិច ( ក្នុងរវាងរូប ៧០ និង ៣០ ) តាមគួរចុះ។

## គាថាសង្ខេបចុតិបដិសន្ធិប្លែកៗ

កាលជ្រាបយ៉ាងនេះហើយ គប្បីកំណត់ដឹងភាពប្លែកគ្នានៃការខុសគ្នា និងមិនខុសគ្នានៃចុតិបដិសន្ធិដោយខន្ធ អារម្មណ៍ គតិ ហេតុ វេទនា បីតិ វិតក្ក និងវិចារៈតទៅទៀត ។

## ពន្យល់សេចក្តី

សេចក្តីនៃគាថានោះថា បដិសន្ធិ ២ យ៉ាង ដោយបដិសន្ធិផ្សំ និងបដិសន្ធិមិនផ្សំនោះ និងចុតិដែលមានក្នុងលំដាប់ដែលជាអតីតនៃបដិសន្ធិនោះ គប្បីជ្រាបភាពប្លែកនៃការខុសគ្នា និងមិនខុសគ្នានៃចុតិ និងបដិសន្ធិនោះដោយខន្ធជាដើម ទាំងនេះប្លែកគ្នាដូចម្តេច ? បដិសន្ធិខ្លះ ដែលមានខន្ធ ៤ មិនផ្សេងគ្នា (ជាមួយចុតិ)សូម្បីដោយអារម្មណ៍ មានឡើងក្នុងលំដាប់នៃអរូបចុតិដែលមានខន្ធ ៤ ( ដូចគ្នា) ក៏មានបដិសន្ធិខ្លះមានអារម្មណ៍ជាមហគ្គតៈ និងជាខាងក្នុងមានឡើង ក្នុងលំដាប់នៃចុតិដែលមានអារម្មណ៍

មិនជាមហគ្គតៈ និងជាខាងក្រៅក៏មាន នេះជាន័យក្នុងពួកអរូបភូមិ ប៉ុណ្ណោះ ។

ម្យ៉ាងទៀត កាមាវចរបដិសន្ធិខ្លះដែលមានខន្ធ ( គ្រប់ ) ៥ មានក្នុងលំដាប់នៃអរូបចុតិដែលមានខន្ធ ៤ ( គឺចុតិចាកអរូបភូមិមកបដិសន្ធិក្នុងកាមាវចរភូមិ ) ក៏មាន អរូបបដិសន្ធិខ្លះដែលមានខន្ធ ៤ មានក្នុងលំដាប់នៃកាមាវចរចុតិដែលមានខន្ធ ៥ ខ្លះ នៃរូបាវចរចុតិខ្លះ (គឺចុតិចាកកាមាវចរភូមិខ្លះ រូបាវចរភូមិខ្លះ ទៅបដិសន្ធិក្នុងអរូបភូមិ) ក៏មាន យ៉ាងនេះជាបដិសន្ធិមានអារម្មណ៍ជាបច្ចុប្បន្ន មានក្នុងលំដាប់នៃចុតិមាន អារម្មណ៍ជាអតីត ។

ទុគ្គតិបដិសន្ធិខ្លះ មានក្នុងលំដាប់នៃសុគតិចុតិខ្លះ ( ដូចមនុស្សខ្លះស្លាប់ទៅកើតជាសត្វប្រេតទខ្លះ ) ក៏មាន សហេតុកបដិសន្ធិមានក្នុងលំដាប់នៃអហេតុកចុតិ តិហេតុកបដិសន្ធិមានក្នុងលំដាប់នៃទុហេតុកចុតិក៏មាន បដិសន្ធិជាសោមនស្សសហគតៈ មានក្នុងលំដាប់នៃចុតិ ជាឧបេក្ខាសហគតៈក៏មាន បដិសន្ធិប្រកបដោយបីតិ មានក្នុងលំដាប់នៃចុតិមិនប្រកបដោយបីតិក៏មាន បដិសន្ធិមានវិតក្កៈ មានក្នុងលំដាប់នៃចុតិមិនមានវិតក្កៈ បដិសន្ធិមានវិចារៈ មានក្នុងលំដាប់នៃចុតិមិនមានវិចារៈ បដិសន្ធិ មានទាំងវិតក្កៈ វិចារៈ មានក្នុងលំដាប់នៃចុតិ មិនមានទាំងវិតក្កៈ វិចារៈក៏មាន ។

ម្យ៉ាងទៀត គប្បីប្រកប ( ពាក្យ ) ចូលតាមដែលគួរប្រកបបានដោយពាក្យផ្ទុយគ្នានៃបទនោះៗ ចុះ ។

## គាថាសង្ខេបដោយបរមត្ថ

ឯវិញ្ញាណដែលបានបច្ច័យដូចពោលមកដូច្នេះនោះ ក៏មានតែធម៌ដែលចូលដល់ភពដទៃ កាលឃ្លាតមកអំពីភពនោះក៏មិនមាន ( ប៉ុន្តែថា ) វៀរហេតុអំពីភពនោះចេញក៏មិនមាន ។

# ពង្រីកសេចក្តី

វិញ្ញាណ ដែលបានបច្ច័យដូចពោលមកដូច្នេះនោះ ក៏ត្រឹមតែរូបធម៌ អរូបធម៌ កាលកើតឡើងក៏ ( មានវោហារ ) ហៅថា ចូលដល់ភពដទៃ មិនមែនសត្វមិនមែនជីវៈ ទាំងការឃ្លាតអំពីភពអតីតមកក្នុងភពនេះក៏មិនមាន តែថា វៀរហេតុអំពីអតីតនោះចេញ ការប្រាកដឡើងក្នុងភពក៏មិនមាន ។

ខ្ញុំនឹងប្រកាសការប្រព្រឹត្តទៅនៃវិញ្ញាណដូចពោលនេះ ដោយការបន្តបដិសន្ធិអំពីចុតិនៃមនុស្សដែលឃើញបានជាក់ច្បាស់ ។

ក្នុងអតីតភព កាលបុគ្គលដែលគាប់ជួននឹងស្លាប់ ព្រោះការអស់ទៅដោយខ្លួនឯង ឬព្រោះការធ្វើ ( បាប ) ក៏ដោយ មិនអាចធន់នឹងការមុតត្រូវសស្ត្រា គឺមរណន្តិកវេទនា (ការឈឺប្រកេទដល់ស្លាប់) ទាំងឡាយ ដែលអារពន្ធះសរសៃឆ្អឹងគ្រប់អវយវៈធំតូច ដែលហួសនឹងទ្រាំ លុះរាងកាយស្ងោកស្ងាំងទៅដោយលំដាប់ ដូចស្លឹកត្នោតស្រស់ ដែលគេដាក់ទុកក្នុងកម្តៅថ្ងៃ ស្វិតស្រពោនទៅតាមលំដាប់ដូច្នោះ លុះឥន្ទ្រិយទាំងឡាយ មានចក្ខុជាដើមរលត់ កាយិន្ទ្រិយ មនិន្ទ្រិយ និងជីវិតិន្ទ្រិយគង់ (សល់) នៅតែក្នុងហទយវត្ថុ វិញ្ញាណដែលអាស្រ័យហទយវត្ថុដ៏សេសនៅក្នុងខណៈនោះ ក៏ប្រារព្ធយក គរុកម្ម (កម្មធ្ងន់) សមាសេវិតកម្ម (កម្មដែលធ្វើរឿយៗ) អាសន្នកម្ម (កម្មដែលធ្វើកាលជិតស្លាប់ ) បុព្វកតកម្ម ( កម្មដែលធ្វើទុកអំពីមុន ) ឯណាមួយ បានដល់សង្ខារដែលបានបច្ច័យដ៏សេស ( មានអវិជ្ជាជាដើម ) ហើយ ឬ ( ប្រារព្ធយក ) វិស័យ ( គឺវណ្ណរូបារម្មណ៍ ) ដែលបានដល់ កម្មនិមិត្ត គតិនិមិត្ត ដែលចូលទៅប្រាកដដល់វិញ្ញាណនោះប្រព្រឹត្តទៅ តណ្ហាក្នុងវិស័យនោះមានទោសត្រូវអវិជ្ជាបិទបាំង ព្រោះមិនទាន់លះតណ្ហា អវិជ្ជាបាន ក៏ទាញយកវិញ្ញាណដែលប្រព្រឹត្តទៅយ៉ាងនេះទៅ សង្ខារ គឺចេតនាដែលកើតរួមគ្នាក៏ជួយបន្សាត់វិញ្ញាណនោះទៅ វិញ្ញាណដែលត្រូវតណ្ហា

បន្សាត់ទៅ ត្រូវសង្ខារទាំងឡាយបន្សាត់ទៅដោយអំណាចនៃសន្តតិនោះ ក៏លះបង់ទីអាស្រ័យ គឺហទយវត្ថុដើមផងដែរ បានទីអាស្រ័យថ្មីដែលកម្មសាងឡើងខ្លះ មិនបានសាងឡើងខ្លះ ប្រព្រឹត្តទៅដោយបច្ច័យទាំងឡាយ មានអារម្មណ៍ជាដើមប៉ុណ្ណោះផង ដូចបុគ្គលតោងខ្សែដែលចងដើមឈើ ត្រង់ត្រើយនាយ យោលឆ្លងអូរទៅដូច្នោះឯង ។

ឯវិញ្ញាណដែលប្រព្រឹត្តទៅនេះ វិញ្ញាណដួងមុន ហៅថា ចុតិវិញ្ញាណ ព្រោះឃ្លាតទៅ ដួងក្រោយហៅថា បដិសន្ធិវិញ្ញាណ ព្រោះជាប់បន្តមកអំពីខាងដើម នៃភពដទៃ ។ វិញ្ញាណនេះ បណ្ឌិតគប្បីជ្រាបចុះថា មកត្រង់ភពនេះអំពីភពមុនក៏មិនមែន វៀរហេតុ មានកម្ម សង្ខារ តណ្ហា អ្នកអូសទាញ និងវិស័យជាដើមអំពីភពមុននោះចេញ ក៏ប្រាកដមានឡើងមិនបាន ។

## គាថាសង្ខេបនិទស្សនៈ ចុតិ បដិសន្ធិ

ធម៌ទាំងឡាយ មានសំឡេងខ្ទរជាដើម គប្បីជានិទស្សនៈក្នុងសេចក្តីនេះបាន ម្យ៉ាងទៀត ព្រោះការទាក់ទងគ្នាក្នុងសន្តាន ( គឺការបន្ត ) ទើបការប្រព្រឹត្តទៅ ដែលដូចគ្នាមិនមាន ទាំងការផ្សេងគ្នាក៏មិនមានផង ។

## ពង្រីកសេចក្តី

ពិតហើយ ធម៌ទាំងឡាយមានប្រការ គឺសំឡេងខ្ទរ ប្រទីប ត្រា និងរូបចាំង ( គឺស្រមោល ) គប្បីជានិទស្សនៈក្នុងសេចក្តីនេះ គឺក្នុងការមិនបានមកត្រង់ភពនេះអំពីភពមុន និងក្នុងការកើតឡើងដោយហេតុ ដែលជាប់មកអំពីភពអតីត នៃវិញ្ញាណនោះ ដូចសំឡេងខ្ទរ ប្រទីប ត្រា និងស្រមោល រមែងមានសំឡេងជាដើម ជាហេតុទើបមាន វៀរសំឡេងជាដើមចេញ ក៏មានទៅមិនបាន យ៉ាងណា ចិត្តនេះ ក៏ដូច្នោះដូចគ្នា ។ ម្យ៉ាងទៀត ក្នុងសេចក្តីនេះ ព្រោះការជាប់គ្នាក្នុងសន្តាន (គឺការជាប់បន្ត)

ទើបភាពជាការដូចគ្នាមិនមាន ទាំងការផ្សេងគ្នាក៏មិនមានផង ។ ពិតណាស់ ប្រសិនបើកាលការជាប់គ្នាក្នុងសន្តាន ( គឺការជាប់បន្ត ) មានភាពជាការដូចគ្នា យ៉ាងដាច់ខាតនឹងគប្បីមានសោត ទឹកដោះជូរក៏មិនមែនជាវត្ថុកើតមកអំពីទឹកដោះស្រស់សូម្បីការផ្សេងគ្នាយ៉ាងដាច់ខាតនឹងគប្បីមានសោត ទឹកដោះជូរក៏មិនមែនជាវត្ថុអាស្រ័យទឹកដោះស្រស់ៗ

( ន័យការប្រកបសេចក្តី ) ក្នុងវត្ថុដែលជាហេតុ និងដែលកើតអំពីហេតុ ( គឺផល ) ទាំងពួងក៏មានន័យនេះ ព្រោះកាលបើយ៉ាងនោះ ( គឺកាលប្រកាន់ថា ហេតុ និងផលជាការដូចគ្នា ឬផ្សេងគ្នាម្ខាងមួយបែប ដែលដាច់ខាតទៅយ៉ាងណាមួយដូច្នោះ ) ការបដិសេធវោហាររបស់លោកទាំងពួងក៏មានឡើង តែការបដិសេធវោហាររបស់លោកនោះ បណ្ឌិតមិនគួរប្រាថ្នា ព្រោះហេតុនោះ ភាពតែមួយ ឬផ្សេងគ្នាដាច់ខាតក្នុងវត្ថុដែលជាហេតុ និងផលដែលជាប់គ្នាក្នុងសន្តានទាំងឡាយនេះ ទើបបណ្ឌិតមិនគួរជាប់នៅ ( គឺកុំជាក់ចិត្ត ) ។

## ពាក្យចោទសួរ

ក្នុងសេចក្តីនេះ មានចោទកាចារ្យពោលថា កាលមានការប្រាកដ ( កើតឡើងនៃវិញ្ញាណ ) ដោយមិនបានឃ្លាតមក ( អំពីភពមុន ) យ៉ាងនោះ ព្រោះខន្ធទាំងឡាយដែលមានក្នុងអត្តភាពមនុស្សនេះរលត់ទៅ និងព្រោះកម្មដែលជាបច្ច័យនៃផលមិនទៅក្នុងទីកើតឡើងនៃផលនោះៗ ក៏មិន ( ទៅ ) មានដល់អ្នកដទៃ និងអំពីកម្មដទៃ ឬម្យ៉ាងទៀត កាលអ្នកសោយ ( ផល ) មិនមាន ផលនោះនឹងគប្បីមានដល់នរណាទៅ ព្រោះហេតុនោះ វិធាន ( គឺបទបញ្ញា ) ការ នេះមិនល្អទេ ។

ក្នុងពាក្យចោទសួរនោះ ខ្ញុំនឹងឆ្លើយតទៅនេះ

## គាថាសង្ខេបរឿងសន្តាន

ផល ( នៃកម្ម ) ដែលមានក្នុងសន្តាន ( គឺការជាប់បន្តតែមួយ ) មិនមានដល់អ្នកដទៃទេ និងមិនមែនមានតែកម្មដទៃឡើយ អភិសង្ខារ ( សភាពដែលតាក់តែង ) នៃពូជទាំងឡាយ ជាសាធកៈនៃសេចក្ដីនេះបាន ។

## ពង្រីកសេចក្ដី

ពិតហើយ ផល ( នៃកម្ម ) កាលកើតឡើងក្នុងសន្តានតែមួយ ( សូម្បី ) ព្រោះភាពជាការដូចគ្នា និងការផ្សេងគ្នាដាច់ខាតក្នុងសន្តានតែមួយនោះត្រូវបដិសេធ ក៏មិនមែនក្លាយទៅកើតដល់អ្នកដទៃ គឺកើតអំពីកម្មដទៃ ឬកើតអំពីអ្នកដទៃឡើយ ក៏អភិសង្ខារនៃពូជទាំងឡាយ ជាសាធកៈនៃពាក្យនេះបាន ។ ពិតណាស់ កាលអភិសង្ខារទាំងឡាយ នៃពូជទាំងឡាយ មានពូជស្វាយជាដើមដែលធម្មជាតិធ្វើឲ្យហើយ ផលផ្សេងៗ កាលកើតឡើងក្នុងកាលដទៃ ( ខាងក្រោយ ) ព្រោះបានបច្ច័យក្នុងសន្តាននៃពូជនោះក៏មិនមែនកើតឡើងដល់ពូជដទៃៗទេ ទាំងមិនមែនកើតព្រោះបច្ច័យ គឺអភិសង្ខារដទៃទេ តែពូជទាំងនោះ ឬអភិសង្ខារទាំងឡាយ ក៏មិនមែន ( ទៅ ) ដល់ទីកើតផលទេ សេចក្ដីឧបមេយ្យនេះ បណ្ឌិតក៏គប្បីជ្រាបដូច្នោះ ។

ម្យ៉ាងទៀត សេចក្ដីនេះគប្បីជ្រាបសូម្បីដោយវិជ្ជា សិល្បៈ និងឱសថជាដើម ដែលបុគ្គលប្រកបចូលក្នុងខ្លួនក្មេងហើយ ( ទៅ ) ឲ្យផលក្នុងខ្លួន ( មនុស្សនោះ ) ដែលធំធាត់ឡើងជាដើមក្នុងកាលដទៃ ( ខាងក្រោយ ) ក៏បាន ។

សូម្បីពាក្យណាដែលចោទកាចារ្យពោលថា ម្យ៉ាងទៀត កាលអ្នកសោយ ( ផល ) មិនមាន ផលនោះនឹងគប្បីមានដល់នរណាទៅ ដូច្នេះ ខ្ញុំនឹងឆ្លើយ ក្នុងពាក្យនោះ ( តទៅ ) ។

## គាថាសង្ខេបរឿងអ្នកសោយ

ការសន្មតិថា (មាន) អ្នកសោយ រមែងជាការសម្រេចបានដោយការកើតឡើង នៃផល ប្រៀបដូចការសន្មតិថា មានផ្លែ ជាការសម្រេចបានដោយការកើតឡើង នៃផ្លែ របស់ដើមឈើ ដូច្នោះ ។

## ពន្យល់ការសេចក្តី

ឧបមាដូចដើមឈើនឹងហៅថាមានផ្លែ ឬបញ្ចេញផ្លែក៏ដោយ ការកើតឡើងនៃ ផ្លែឈើដែលជាចំណែកមួយនៃធម៌ទាំងឡាយដែលហៅថា ដើមឈើនោះឯង យ៉ាងណា ទេវតា ឬមនុស្សក្តី នឹងហៅថាបានសោយ ( ផល ) ឬនឹងហៅថាអ្នកបានទទួលសេចក្តី សុខ អ្នកបានទទួលសេចក្តីទុក្ខក៏ដោយ ក៏ដោយការកើតឡើងនៃផល គឺសុខទុក្ខដែល រាប់ជាឧបភោគ ( របស់សោយ ) ជាចំណែកមួយនៃខន្ធទាំងឡាយដែលហៅថា ទេវតា និងមនុស្សដូច្នោះ ដូចគ្នា ព្រោះហេតុនោះ អត្តណាមួយ ដោយអ្នកសោយដទៃ ( ក្រៅ អំពីខន្ធ ) ក្នុងសេចក្តីថា ដោយអ្នកសោយផលនេះ ក៏មិនមាន ។

សូម្បីចោទកាចារ្យណាគប្បីពោលថា បើយ៉ាងនោះ សង្ខារទាំងនោះកាលមាន ទើបជាបច្ច័យនៃផលឬ ឬថា មិនមានក៏ជាបច្ច័យនៃផលបាន បើមានទើបជាបច្ច័យ បានសោត វិបាករបស់កម្មក៏នឹងគប្បីមានតែក្នុងបវត្តិក្ខណៈ ( គឺក្នុងខណៈដែលសង្ខារ ប្រព្រឹត្តទៅ) ប៉ុណ្ណោះ បើសូម្បីមិនមានក៏ជាបច្ច័យបានសោត ក៏នឹងគប្បីនាំមកឲ្យបាន ជានិច្ចទៅ ទាំងក្នុងខណៈមុនបវត្តិ ( គឺក្នុងខណៈធ្វើកម្ម ) ទាំងខាងក្រោយបវត្តិ ( គឺ កាលឲ្យផលស្រេចហើយ ) ដូច្នេះ ចោទកាចារ្យនោះ គប្បីបានទទួលចម្លើយ ដូច្នេះ។

## គាថាសង្ខេបព្រំដែនភាពជាបច្ច័យនៃសង្ខារ

សង្ខារទាំងឡាយនោះ ជាបច្ច័យ ( នៃផល ) ព្រោះធ្វើ ( ផល ) ឡើង តែនាំ

ផលមកឲ្យជានិច្ចមិនបានទេ កិរិយា មានការធានាជាដើម គប្បីជ្រាបថា ជានិទស្សនៈ ក្នុងសេចក្តីនោះបាន ។

## ពន្យល់ការសេចក្តី

ពិតហើយ សង្ខារទាំងឡាយ រមែងជាបច្ច័យនៃផលរបស់ខ្លួន ព្រោះធ្វើ (ផល) ឡើងប៉ុណ្ណោះ មិនមែនព្រោះមាន ឬមិនមាន ដូចបាលីថា ចក្ខុវិញ្ញាណ ដែលជាវិបាក រមែងជាវត្ថុកើតឡើងព្រោះកុសលកម្មផ្នែកកាមាវចរធ្វើឡើង សាងឡើង ដូច្នេះជាដើម និងជាបច្ច័យនៃផលរបស់ខ្លួនតាមដែលគួរហើយ ក៏មិនជាបច្ច័យនាំផលមកឲ្យទៀត ព្រោះមានវិបាកឆ្អិនហើយ ( គឺឲ្យផលស្រេចហើយ ) កិរិយា មានការធានាជាដើម ( ដូចនឹងពោលតទៅ ) នេះ គប្បីជ្រាបថាជានិទស្សនៈ ក្នុងការអធិប្បាយសេចក្តីនោះបាន ដូចក្នុងផ្លូវលោក អ្នកណាជានាយធានាដើម្បីបញ្ជូនផលប្រយោជន៍ណាមួយ ( ឲ្យម្ចាស់ទ្រព្យ ) ឬទិញរបស់ក៏ដោយ កូនបំណុលក៏ដោយ ក៏ត្រឹមតែការធ្វើកិរិយាប៉ុណ្ណោះ ( គឺធានា ឬទិញ ឬចងការ ) នៃបុគ្គលនោះប៉ុណ្ណោះ ជាបច្ច័យក្នុងការបញ្ជូនផលប្រយោជន៍នោះជាដើម មិនមែនការមាន ឬមិនមាននៃកិរិយា ( ជាបច្ច័យ ) ទេ និងខាងមុខអំពីបញ្ជូនផលប្រយោជន៍ឲ្យ ( ហើយ ) ជាដើមទៅ គេក៏មិនជាកូនបំណុលទៀតឡើយ ព្រោះអ្វី ? ព្រោះការបញ្ជូន ( ផលប្រយោជន៍ ) ឲ្យជាដើម គេបានធ្វើហើយ យ៉ាងណា សូម្បីសង្ខារទាំងឡាយ ក៏ជាបច្ច័យរបស់ខ្លួន ព្រោះធ្វើ ( ផល ) ឡើងប៉ុណ្ណោះ និងខាងមុខអំពីឲ្យផលតាមដែលគួរហើយទៅ ក៏មិនជាបច្ច័យនាំផលមកឲ្យតទៅទៀត ដូច្នោះឯង ។

ការប្រព្រឹត្តទៅនៃបដិសន្ធិវិញ្ញាណ ដែលប្រព្រឹត្តទៅទាំងពីរចំណែក ដោយវិញ្ញាណផ្សំ និងមិនផ្សំ ព្រោះបច្ច័យ គឺសង្ខារ ជាការសម្តែងហើយដោយនិទ្ទេសកថាត្រឹមប៉ុណ្ណោះ ។

ឥឡូវនេះ ដើម្បីកម្ចាត់ចោលនូវការសង្ស័យក្នុងវិបាកវិញ្ញាណ ៣២ ទាំងអស់នោះ

## គាថាសង្ខេបសង្ខារជាបច្ច័យនៃវិញ្ញាណដូចម្ដេច

បណ្ឌិតគប្បីយល់សង្ខារទាំងឡាយនោះ ( ថា ) ជាបច្ច័យនៃវិបាកវិញ្ញាណពួកណា និងដូចម្ដេច ក្នុងកន្លែងកើតទាំងឡាយ មានភពជាដើមដោយអំណាច ( គឺការបន្ដាប់ ) នៃបដិសន្ធិ និងបវត្តិ ។

## ពន្យល់សេចក្ដី

សេចក្ដីក្នុងគាថានោះថា ប្រភពកើតទាំងនេះ គឺភព ៣ កំណើត ៤ គតិ ៥ វិញ្ញាណដ្ឋិតិ ៧ សត្តាវាស ៩ ឈ្មោះថា ប្រភពកើត មានភពជាដើម សង្ខារទាំងឡាយនោះរមែងជាបច្ច័យនៃវិបាកវិញ្ញាណពួកណា ក្នុង (ផ្នែក) បដិសន្ធិ និងក្នុងបវត្តិកាលក្នុងប្រភពកើតទាំងឡាយ មានភពជាដើមទាំងនោះឯង ជាបច្ច័យដោយប្រការណា បណ្ឌិតគប្បីជ្រាបដោយប្រការនោះចុះ ។

## ពណ៌នាសេចក្ដី

ក្នុងសង្ខារទាំងឡាយនោះ ពណ៌នាក្នុងបុញ្ញាភិសង្ខារមុន

បុញ្ញាភិសង្ខារប្រភេទ ( កុសល ) ចេតនា ៨ ផ្នែកកាមាវចរ ( ពោល ) ដោយមិនចែក ( ប្រភេទ ) គ្នា រមែងជាបច្ច័យដោយចំណែក ២ គឺដោយកម្មប្បច្ច័យក្នុងខណៈផ្សេងៗ ផង ដោយឧបនិស្សយប្បច្ច័យផង នៃវិបាកវិញ្ញាណ ៩ ក្នុងសុគតិកាមភព ក្នុង **បដិសន្ធិ** ( កាល ) បុញ្ញាភិសង្ខារប្រភេទកុសលចេតនា ៥ ផ្នែករូបាវចរជាបច្ច័យនៃវិបាកវិញ្ញាណ ៥ សូម្បីក្នុងរូបភព ក្នុង **បដិសន្ធិ** យ៉ាងទៀត បុញ្ញាភិសង្ខារផ្នែកកាមាវចរ មានប្រភេទដូចពោលជាបច្ច័យដោយចំណែក ២ តាមន័យដូចពោលនោះឯង នៃវិបាកវិញ្ញាណកាមភូមិ ៧ វៀរអហេតុកមនោវិញ្ញាណធាតុ

ដែលសហគតៈជាមួយឧបេក្ខាក្នុងសុគតិកាមភព ក្នុង **បវត្តិកាល** មិនជាបច្ច័យក្នុងបដិសន្ធិ បុញ្ញាភិសង្ខារប្រភេទដូចពោលហើយនោះឯង ជាបច្ច័យដោយចំណែក ២ យ៉ាងនោះ ដូចគ្នានៃវិបាកវិញ្ញាណ ៥ ក្នុងរូបភព ក្នុង **បវត្តិកាល** មិនជាបច្ច័យ ក្នុងបដិសន្ធិ ។

ចំណែកក្នុងទុគ្គតិកាមភព បុញ្ញាភិសង្ខារកាមាវចរដែលពោលនោះជាបច្ច័យដោយចំណែក ២ យ៉ាងនោះដូចគ្នានៃវិបាកវិញ្ញាណកាមភូមិទាំង ៨ ក្នុង **បវត្តិកាល** បាន ( តែ ) មិនជាបច្ច័យក្នុងបដិសន្ធិ ក្នុងទុគ្គតិកាមភពនោះ ក្នុងនរក បុញ្ញាភិសង្ខារកាមាវចរនោះ ក៏ជាបច្ច័យក្នុងការប្រសព្វឥដ្ឋារម្មណ៍បាន ក្នុងគ្រាផ្សេងៗ ដូចគ្រាចារិកទៅ ( សួរសុខទុក្ខ ) នរកនៃព្រះមហាមោគ្គល្លានត្ថេរជាដើម ។ ម្យ៉ាងទៀត ឥដ្ឋារម្មណ៍ រមែងមានក្នុងពួកសត្វតិរច្ឆាន និងក្នុងពួកប្រេតដែលមានឫទ្ធិច្រើន ដូចគ្នា បុញ្ញាភិសង្ខារកាមាវចរនោះឯង ជាបច្ច័យដោយចំណែក ២ យ៉ាងនោះដូចគ្នា នៃវិញ្ញាណដែលជាកុសលវិបាកទាំង ១៦ ក្នុងសុគតិកាមភព ទាំងក្នុង **បវត្តិកាល** ទាំងក្នុង **បដិសន្ធិ** តែ ( ពោល ) ដោយមិនញែកគ្នា ( គឺរួមកាមាវចរ និងរូបាវចរបួលជាមួយគ្នា ) បុញ្ញាភិសង្ខារជាបច្ច័យដោយចំណែក ២ យ៉ាងនោះដូចគ្នា នៃវិបាកវិញ្ញាណ ១០ ក្នុងរូបភព ទាំងក្នុង **បវត្តិកាល** និងក្នុង **បដិសន្ធិ** ផង ។

អបុញ្ញាភិសង្ខារប្រភេទអកុសលចេតនា ១២ ជាបច្ច័យដោយចំណែក ២ យ៉ាងនោះៗ ឯង នៃវិញ្ញាណ ១ ដួង ( គឺបដិសន្ធិវិញ្ញាណ ) ក្នុងទុគ្គតិកាមភព ក្នុងបដិសន្ធិ មិនកើតក្នុងបវត្តិកាល ជាបច្ច័យនៃអកុសលវិបាកវិញ្ញាណ ៦ ក្នុងបវត្តិកាល មិនកើតក្នុងបដិសន្ធិ ជាបច្ច័យនៃអកុសលវិបាកវិញ្ញាណទាំង ៧ ទាំងក្នុងបវត្តិកាល និងក្នុងបដិសន្ធិ ចំណែកក្នុងសុគតិកាមភព អបុញ្ញាភិសង្ខារក៏ជាបច្ច័យ ដោយចំណែក ២ យ៉ាងនោះៗ ឯង ដល់អកុសលវិបាកវិញ្ញាណទាំង ៧ នោះ ក្នុងបវត្តិកាលបាន

ដូចគ្នា (តែ) មិនមានក្នុងបដិសន្ធិ ក្នុងរូបភពក៏ជាបច្ច័យ ដោយចំណែក ២ យ៉ាង នោះឯងនៃវិបាកវិញ្ញាណ ៤ ក្នុងបវត្តិកាល (តែ) មិនមានក្នុងបដិសន្ធិក៏ប៉ុន្តែការដែល អបុញ្ញាភិសង្ខារជាបច្ច័យក្នុងរូបភពនោះ មានដោយបានឃើញរូបដែលមិនគួរប្រាថ្នា និងបានឮសំឡេងដែលមិនគួរប្រាថ្នាក្នុងកាមាវចរភព ព្រោះថា ក្នុងព្រហ្មលោកក៏វត្ថុ ដែលមិនគួរប្រាថ្នាទាំងឡាយ មានរូបដែលមិនគួរប្រាថ្នាជាដើមមិនមាន សូម្បីកាមាវចរ ក៏យ៉ាងនោះ ។

ចំណែកអនេញ្ជាភិសង្ខារជាបច្ច័យដោយចំណែក ២ យ៉ាងនោះដូចគ្នានៃវិបាក វិញ្ញាណ ៤ ក្នុងអរូបភព ទាំងក្នុងបវត្តិកាល និងបដិសន្ធិ ។

សង្ខារទាំងនោះជាបច្ច័យ នៃវិបាកវិញ្ញាណពួកណា ដោយអំណាចនៃបដិសន្ធិ និងបវត្តិក្នុងភពទាំងឡាយ និងជាបច្ច័យដោយប្រការណា គប្បីជ្រាបដោយប្រការនោះ ដូចពោលមកដូច្នេះ ។

សូម្បីក្នុងកំណើតជាដើម ក៏គប្បីជ្រាបដោយន័យនោះដូចគ្នា ( តទៅ ) នេះ ជាពាក្យបង្ហាញសេចក្ដីសំខាន់ក្នុងកំណើតជាដើមនោះតាំងអំពីដើមទៅ ។

ព្រោះថា ក្នុងសង្ខារទាំងឡាយនេះ លំដាប់ដំបូង បុញ្ញាភិសង្ខារឲ្យបដិសន្ធិ ក្នុងភព ២ ( គឺកាមភព និងរូបភព ) ហើយញុំាងវិបាករបស់ខ្លួនទាំងពួងឲ្យកើត ( យ៉ាងណា ) ក៏ឲ្យបដិសន្ធិក្នុងកំណើត ៤ មានអណ្ឌជៈជាដើម ក្នុងគតិ ២ ពោល គឺទេវតា និងមនុស្ស ក្នុងវិញ្ញាណដ្ឋិតិ ៤ បានដល់ នានត្តកាយនានត្តសញ្ញី ( សត្វ ពួកមួយមានកាយផ្សេងគ្នាមានសញ្ញាផ្សេងគ្នា ) នានត្តកាយឯកត្តសញ្ញី ( សត្វពួក មួយមានកាយផ្សេងគ្នា តែមានសញ្ញាដូចគ្នា ) ឯកត្តកាយនានត្តសញ្ញី ( សត្វពួក មួយមានកាយដូចគ្នា តែមានសញ្ញាផ្សេងគ្នា ) ឯកត្តកាយឯកត្តសញ្ញី ( សត្វពួកមួយ មានកាយដូចគ្នា មានសញ្ញាដូចគ្នា ) និងក្នុងសត្តាវាសត្រឹម ៤ ព្រោះថា ក្នុងអសញ្ញី

សត្តាវាស បុញ្ញាភិសង្ខារនោះតាក់តែងតែរូបម្យ៉ាងប៉ុណ្ណោះ ហើយញុំាងវិបាករបស់ខ្លួនទាំងពួងឲ្យកើតដូចគ្នានោះ ព្រោះហេតុនោះ ទើបបុញ្ញាភិសង្ខារនោះ ជាបច្ច័យដោយន័យដូចពោលហើយ (គឺជានានាខណិកកម្មប្បច្ច័យ និងឧបនិស្សយប្បច្ច័យ) នោះឯងនៃវិបាកវិញ្ញាណ ២១ ក្នុងភព ២ កំណើត ៤ គតិ ២ វិញ្ញាណដ្ឋិតិ ៤ និងសត្តាវាស ៤ ទាំងនោះ ទាំងក្នុងបដិសន្ធិ និងបវត្តិកាល តាមដែលកើត ។

ចំណែកអបុញ្ញាភិសង្ខាររមែងឲ្យផល ដោយឲ្យបដិសន្ធិក្នុងកាមភពតែមួយប៉ុណ្ណោះ ក្នុងកំណើត ៤ ក្រៅពីនោះ ក្នុងគតិ ៣ ក្នុងវិញ្ញាណដ្ឋិតិ ១ ( គឺនានត្តកាយឯកត្តសញ្ញី ) និងសត្តាវាសក៏ ១ដូច្នោះដូចគ្នា ហេតុណា ព្រោះហេតុនោះ ទើបអបុញ្ញាភិសង្ខារនោះ ជាបច្ច័យដោយន័យដែលពោលហើយនោះដូចគ្នានៃវិបាកវិញ្ញាណ ៧ ក្នុងភព ១ ក្នុងកំណើត ៤ ក្នុងគតិ ៣ ក្នុងវិញ្ញាណដ្ឋិតិ ១ និងក្នុងសត្តាវាស ១ ទាំងក្នុងបដិសន្ធិ និងក្នុងបវត្តិកាល ។

ចំណែកអនេញ្ជាភិសង្ខារ ឲ្យផលដោយឲ្យបដិសន្ធិក្នុងអរូបភពតែ ១ ប៉ុណ្ណោះ ក្នុងកំណើតឱបបាតិកកំណើត ១ ក្នុងទេវគតិ ១ ក្នុងវិញ្ញាណដ្ឋិតិ ៣ មានជាន់អាកាសានញ្ចាយតនៈជាដើម ហេតុណា ព្រោះហេតុនោះ ទើបអនេញ្ជាភិសង្ខារនោះជាបច្ច័យ ដោយន័យដែលពោលហើយដូចគ្នានៃវិញ្ញាណ ៤ ក្នុងភព ១ កំណើត ១ គតិ ១ វិញ្ញាណដ្ឋិតិ ៣ សត្តាវាស ៤ ទាំងក្នុងបដិសន្ធិ និងក្នុងបវត្តិកាល ដូច្នេះ។

បណ្ឌិតគប្បីជ្រាបសង្ខារទាំងឡាយនោះថា ជាបច្ច័យនៃវិបាកវិញ្ញាណ នៃវិញ្ញាណពួកណា និងដូចម្ដេចក្នុងកន្លែងកើតទាំងឡាយ មានភពជាដើម ដោយអំណាច ( គឺគោលបង្គាប់ ) នៃបដិសន្ធិ និងបវត្តិ ។

ដោយន័យដូចពោលមកដូច្នេះចុះ ។

នេះជាកថាយ៉ាងពិស្ដារ ក្នុងបទថា សង្ខារប្បច្ចយា វិញ្ញាណំ ។

# មហាដីកា

## កថាពិស្ដារនៃបទថា

## ព្រោះសង្ខារជាបច្ច័យ ទើបមានវិញ្ញាណ

វិញ្ញាណនោះកើតឡើង ព្រោះសង្ខារតាមដែលពោលហើយជាបច្ច័យ រមែងគួរជាធម្មជាតិដែលកើតអំពីកម្មតែម្យ៉ាង ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **ទើបត្រូវរួមវិបាកវិញ្ញាណចំណែកលោកិយបាន ៣២** ដូច្នេះ ចំណែកក្នុងនិទ្ទេស បទថា **ដោយធម៌ដែលសង្គ្រោះបាន និងសង្គ្រោះមិនបាន ជាមួយធម៌ដែលប្រកបមិនបាន ក្នុងធាតុកថា** ព្រះសាស្ដាទ្រង់កំណត់កាន់យកវិញ្ញាណ ផស្សៈ និងវេទនាទាំងអស់ ដោយព្រះបាលីថា ធម៌ទាំងឡាយណា ប្រកបមិនបានដោយវិញ្ញាណ ព្រោះសង្ខារជាបច្ច័យ, ធម៌ទាំងឡាយណា ប្រកបមិនបានដោយផស្សៈ ព្រោះសឡាយតនៈ ជាបច្ច័យ, ធម៌ទាំងឡាយណាប្រកបមិនបានដោយវេទនា ព្រោះផស្សៈជាបច្ច័យ, ធម៌ទាំងឡាយនោះ សង្គ្រោះដោយខន្ធប៉ុន្មាន ។បេ។ ? ធម៌ទាំងឡាយនោះ វៀរអសង្ខតៈចេញអំពីខន្ធ សង្គ្រោះដោយខន្ធ ១ ដោយអាយតនៈ ១១ ដោយធាតុ ១១ ។ សង្គ្រោះមិនបានដោយខន្ធ អាយតនៈ ធាតុប៉ុន្មាន ? សង្គ្រោះមិនបានដោយខន្ធ ៤ ដោយអាយតនៈ ១ ដោយធាតុ ៧ ។ បើក្នុងអធិការនេះ វិញ្ញាណ ផស្សៈ និងវេទនា គួរជាធម៌មានការសម្ដែងអាងបានសោត ក៏គួរឆ្លើយដូចវិសជ្ជនាបទនេះថា **ធម៌ដែលជាវិបាកទាំងឡាយ** ។ ព្រោះដូច្នោះ គប្បីជ្រាបអធិប្បាយថា លោកកាន់យកធម៌ទាំងឡាយមានវិញ្ញាណជាដើម ព្រោះសង្ខារជាបច្ច័យដោយអំណាចអភិធម្មភាជនីយ៍ក្នុងទីនោះ។ ឯសង្ខារ ព្រោះអវិជ្ជាជាបច្ច័យដែលលោកពោលទុក បានដល់ សង្ខារដែលជាកុសលប្រព្រឹត្តទៅក្នុងភូមិ ៤ ក្នុងអភិធម្មភាជនីយ៍ និងបានដល់សង្ខារដែលជាអកុសល ព្រោះ

ដូច្នោះ សង្ខារ ព្រោះអវិជ្ជាជាបច្ច័យនេះឯង គប្បីឃើញថា ទ្រង់កាន់យកហើយក្នុងធាតុកថា ។ ចំណែកភព ទ្រង់មិនបានកាន់យកដោយអំណាចអភិធម្មភាជនីយ៍ ដើម្បីទ្រង់សម្ដែងភាពផ្សេងគ្នានៃកម្មភព និងឧបបត្តិភព **ក្នុងធាតុកថា** ។ ព្រោះអធិប្បាយយ៉ាងនេះ ក្នុងធាតុកថានោះ ទ្រង់មិនបានលើកឡើងថា **ភពមានព្រោះឧបាទានជាបច្ច័យ** ទ្រង់លើកភពឡើងដោយន័យជាដើមថា **កម្មភព** ។

លោកអាចារ្យពោលថា **មនោវិញ្ញាណមាន ២២** ដូច្នេះ សំដៅយកមនោវិញ្ញាណដែលជាលោកិយវិបាកប៉ុណ្ណោះ ។ ពាក្យថា **ដោយវិញ្ញាណ ៦** គឺដោយវិញ្ញាណ ៦ មានចក្ខុវិញ្ញាណជាដើម តាមដែលបានធ្វើជាគោលទុក ។ លោកអាចារ្យពោលថា **ចំណែកលោកុត្តរវិញ្ញាណ មិនសមគួរក្នុងកថាពោលដោយវដ្ដៈ** ដូច្នេះ ដើម្បីចៀសវាងនូវពាក្យសួរថា ឯក្នុងទីនេះ លោកធ្វើការកាន់យកចំពោះលោកិយវិបាកវិញ្ញាណប៉ុណ្ណោះ ព្រោះហេតុអ្វី សួរថា បើយ៉ាងនោះ ព្រោះហេតុអ្វី ក្នុងធាតុកថា ទើបព្រះសាស្ដា ទ្រង់ធ្វើការកាន់យកលោកុត្តរវិបាកទុកដែរ ដូចក្នុងពាក្យជាដើមថា **ធម៌ណាមិនប្រកបដោយវិញ្ញាណ ព្រោះសង្ខារជាបច្ច័យ ?** ឆ្លើយថា សេចក្ដីនោះ ព្រះសាស្ដាត្រាស់ទុកដោយអំណាចការសង្គ្រោះធម៌ ដែលជាវិបាកមិនមានចំណែកសល់ ដូច **ក្នុងវិបាកត្តិកៈ** ដោយអភិធម្មទេសនា ព្រោះជាការទូន្មានតាមធម៌ ។ ចំណែកសុត្តន្តទេសនាជាទេសនាតាមអនុលោម ព្រោះដូច្នោះ ទើបការបដិសេធការប្រព្រឹត្តទៅក្នុងសុត្តន្ត-ទេសនា គួរសម្ដែងដោយមិនលាយឡំគ្នា ។ ព្រោះដូច្នោះ ទើបលោកកាន់យកចំពោះលោកិយវិបាកវិញ្ញាណប៉ុណ្ណោះ ក្នុងកថាពោលដោយការប្រព្រឹត្តទៅ ព្រោះអធិប្បាយថា ជាការពណ៌នាអត្ថនោះ ។ ដោយហេតុនោះឯង ទើបលោកពោលថា **មិនសមគួរក្នុងកថាពោលដោយវដ្ដៈ ព្រោះដូច្នោះ ទើបលោក មិនកាន់យក** ។

កម្មដែលធ្វើទុកដោយប្រការដែលកម្មនោះ អាចឲ្យផល លោកហៅថា ដែល

**បុគ្គលសាងទុកហើយ** ព្រោះដូច្នោះ លោកអាចារ្យកាលកាន់យកសង្ខារដែលគួរដល់ការឲ្យវិបាកតែម្យ៉ាង ទើបពោលថា **កាលមិនមានកម្មដែលសាងទុកហើយ** ។ ឈ្មោះថា **ហេតុ** ជាប្រធានពិសេស ព្រោះដូច្នោះ ទើបលោក **ប្រើស័ព្ទថា មិនមាន** ដោយហេតុនោះ ទើបក្នុងទីនេះមានអធិប្បាយដូច្នេះថា ព្រោះកម្មមាន ទើបមាន ព្រោះកម្មមិនមាន ក៏មិនមាន ។ ឯវិញ្ញាណនោះ មានសង្ខារជាបច្ច័យមិនសម្រេចហើយ យ៉ាងណា វិញ្ញាណជាវិបាកដូច្នោះក៏ទេ លោកអាចារ្យពោលថា **ពិតហើយ វិញ្ញាណនោះជាវិបាក** ដូច្នេះ ព្រោះអធិប្បាយថា វិញ្ញាណនោះជាវិបាកសម្រេចហើយ ។ វិបាករមែងញុំាងសង្ខារជាបច្ច័យឲ្យសម្រេចបាន ដោយជាវិបាកនៃវិញ្ញាណនោះ ។ លោកអាចារ្យកាលនឹងបើកផ្សារសេចក្ដីនោះថា លោកពោលទុកថា **ព្រោះកាលកម្មដែលសាងទុកមិនមាន វិបាកក៏មិនមាន** ដូច្នេះ ដើម្បីនឹងញុំាងវិញ្ញាណ មានសង្ខារជាបច្ច័យនោះឲ្យសម្រេច ទើបពោលពាក្យជាដើមថា **ដែលវិបាក** ដូច្នេះ ។ ពាក្យថា **ឧបមាគប្បីកើតឡើងបាន** សេចក្ដីថា ឧបមាគប្បីកើត វិបាកឡើងបាន មិនបានសម្ងឹងដល់កម្មសោត ។ ដល់សត្វ**គ្រប់ជំពូក** គឺដល់ពួកសត្វសូម្បីតាំងនៅក្នុងភព ដែលមិនមានឱកាសដល់វិបាកនោះៗ គឺវិញ្ញាណ មានយានវិញ្ញាណជាដើម នៃសត្វដែលចូលដល់ភាពជាព្រហ្ម ដែលជាមហាវិបាកវិញ្ញាណ ។ បទថា **វិបាកានិ** សម្ដែងដល់ទបុំសកលិង្គ ដោយសម្ងឹងដល់**វិញ្ញាណ-ស័ព្ទ** អធិប្បាយថា បានដល់ វិបាកវិញ្ញាណគ្រប់យ៉ាង ។ លោកអាចារ្យពោលថា **វិញ្ញាណណា មានព្រោះសង្ខារណាជាបច្ច័យ** ដូច្នេះ ដើម្បីចៀសវាងពាក្យសួរថា សង្ខារមានច្រើន ព្រោះចែកចេតនាចេញទៅដល់ ២៩ និងវិញ្ញាណក៏មានច្រើន ព្រោះមានដល់ទៅ ៣២ ដួង តែមិនឈ្មោះថា វិញ្ញាណទាំងអស់មាន ព្រោះសង្ខារទាំងអស់ឡើយ ។ ឯពាក្យថា **វិញ្ញាណ** នេះ លោកពោលដោយកាន់យកជាវិញ្ញាណស្មើគ្នា ។ វិញ្ញាណទាំងនេះលោកសម្ដែងលម្អិតទុក **សូម្បីក្នុងខន្ធនិទ្ទេសក៏ពិត សូម្បី**

យ៉ាងនោះ វិញ្ញាណនោះក៏សង្ខេបពន់ពេក ហើយវិញ្ញាណទាំងនោះ មានសង្ខារជាបច្ច័យ លោកមិនបានសម្ដែងទុកច្បាស់លាស់ ក្នុងខន្ធនិទ្ទេសនោះឡើយ ព្រោះហេតុនោះ ទើបលោកអាចារ្យផ្ដើមពាក្យជាដើមថា **ព្រោះមានបុញ្ញាភិសង្ខារ ចំណែកកាមាវចរជាបច្ច័យ** ដើម្បីសម្ដែងវិញ្ញាណនោះដោយពិស្ដារ ទាក់ទងនឹងអាការដែលប្រព្រឹត្តទៅក្នុងភពជាដើម ទាំងក្នុងបវត្តិកាល និងក្នុងបដិសន្ធិកាល ។ បទថា **មនោ-វិញ្ញាណេ** ជាសត្តមីវិភត្តិ ប្រើក្នុងនិទ្ធារណៈ ។ បទថា **មហាវិបាកានិ** សម្ដែងនបុំសកលិង្គ ដោយសម្ព័ន្ធដល់ **វិញ្ញាណ-ស័ព្ទ** ។ គួរនាំបទថា **មនោវិញ្ញាណធាតុយោ** មកភ្ជាប់ទុកក្នុងបាឋៈថា **មហាវិបាកា** ។

បណ្ឌិតគប្បីឃើញការលុបពាក្យជាន់គ្នា ក្នុងបទទាំងពីរយ៉ាងនេះថា បទថា **យំសង្ខារប្បច្ចយា** សេចក្ដីប៉ុនគ្នានឹង **យស្ស យស្ស សង្ខារស្ស បច្ចយភាវេន** ប្រែថា ព្រោះសង្ខារណាមួយជាបច្ច័យ ។ បទថា **យំ វិញ្ញាណំ** សេចក្ដីប៉ុនគ្នានឹង **យំ យំ វិញ្ញាណំ** ប្រែថា វិញ្ញាណណាមួយ ។ ដោយបទថា **ហោតិ** នេះ លោកធ្វើឲ្យយល់ត្រឹមតែ កាលហេតុមាន វិញ្ញាណក៏មាន មិនមែនធ្វើឲ្យយល់ដោយការផ្សេងគ្នានៃការប្រព្រឹត្តទៅ ព្រោះហេតុនោះ ទើបលោកអាចារ្យកាលសម្ដែងអត្ថនោះ ដោយពោលថា **គប្បីជ្រាបការប្រព្រឹត្តទៅយ៉ាងនេះ** ។ ចក្ខុវិញ្ញាណដែលជាអកុសលវិបាកជាដើម រមែងកើតឡើងបានក្នុងគ្រាខ្លះ ព្រោះរូបដែលមិនគួរប្រាថ្នាជាដើមមកកាន់គន្លងសម្បជល់ពួកព្រហ្ម ព្រោះហេតុនោះ ទើបលោកអាចារ្យពោលទុកថា **វិញ្ញាណ ១៣ ដូងនេះ រមែងប្រព្រឹត្តទៅក្នុងបវត្តិកាល ក្នុងបញ្ចវោការភពប៉ុណ្ណោះ** ។ ក្នុងពាក្យនោះ ការធ្វើផ្សេងៗ គឺសេចក្ដីពិស្ដាររបស់ខន្ធ ៥ មាននៅក្នុងភពនេះ ហេតុនោះ ទើបភពនេះឈ្មោះថា **បញ្ចវោការ** ប្រែថា មានអាការធ្វើផ្សេងៗ របស់ខន្ធ ៥ ភព គឺភពមានការធ្វើផ្សេងៗ របស់ខន្ធ ៥ នោះឯង **ក្នុងបញ្ចវោការភព** នោះ ។ ឯការសង្ខេប

អត្ថនៃបទដទៃរបស់ស័ព្ទ ដែលមានអធិករណៈផ្សេងគ្នា រមែងមានបានដូចពាក្យថា **ឧរសិលោមោ** ប្រែថា មានរោមត្រង់ទ្រូង ។ ម្យ៉ាងទៀត វិគ្គហៈថា **ភពណាខន្ធ ៥ ដែលប្រព្រឹត្តទៅតាមបច្ច័យ** រមែងធ្វើឲ្យថោកទាប ហេតុនោះ ភពនោះឈ្មោះថា **បញ្ចវោការភព** គឺភពដែល ៥ ខន្ធ ធ្វើឲ្យថោកទាបនោះ ព្រោះហេតុនោះ ពាក្យទាំងឡាយក៏ដូចគ្នាក្នុងកាលមុន ។

លោកអាចារ្យផ្តើមពាក្យថា **សេចក្តីនេះដូចម្តេច** ជាដើម ដើម្បីបើកផ្សារអត្ថដែលលោកពោលទុកដោយសង្ខេបថា **រមែងប្រព្រឹត្តទៅក្នុងបវត្តិកាលប៉ុណ្ណោះ** ។

អាចារ្យពួកខ្លះពោលថា ពាក្យថា **ក្នុងទីបំផុតនៃជវនដែលសម្បយុត្តដោយលោភៈដោយច្រើន** នេះ ព្រោះចិត្តដែលសហគតៈដោយសោមនស្ស មិនកើតក្នុងលំដាប់នៃចិត្តដែលសម្បយុត្តដោយបដិឃៈ វិចិកិច្ឆា និងឧទ្ធច្ចៈ ពាក្យរបស់អាចារ្យពួកខ្លះនោះ មិនគួរកាន់យក ព្រោះព្រះបាលីថា **បុគ្គលត្រេកអររីករាយក្នុងចក្ខុ រមែងកើតរាគៈ ទិដ្ឋិ ។បេ។ វិចិកិច្ឆា ឧទ្ធច្ចៈ ប្រារព្ធចក្ខុនោះ កាលអកុសលរលត់ហើយ រមែងកើតវិបាក ជាតទាលម្ពណៈ** ។ សួរថា បើជាឥដ្ឋារម្មណ៍នឹងមិនកើតតទាលម្ពណៈដែលជាសោមនស្សមិនបានឬ ? អាចារ្យមួយពួកទៀតពោលថា ក្នុងការកំណត់តទាលម្ពណៈដោយជវន លោកពោលសំដៅយកចិត្ត ដែលសហគតៈដោយសោមនស្សក្នុងលំដាប់នៃចិត្តសហគតៈដោយសោមនស្សប៉ុណ្ណោះ ពាក្យរបស់លោកអាចារ្យមួយពួកទៀតនោះ គួរពិចារណា ព្រោះបំណងយកតទាលម្ពណៈ ដែលជាសោមនស្សសូម្បីក្នុងលំដាប់នៃជវនដែលជាកុសល និងអកុសល ដែលសហគតៈដោយឧបេក្ខា ។ ព្រោះថា អាចារ្យទាំងឡាយមិនបំណងយកតទាលម្ពណៈ ដែលជាសោមនស្ស ក្នុងលំដាប់នៃជវនដែលជាកិរិយា ដែលសហគតៈដោយឧបេក្ខាតែម្យ៉ាង ។

ព្រោះតទាលម្ពណៈដែលជាអហេតុកៈ រមែងមានបានក្នុងគ្រាខ្លះ ក្នុងទីបំផុត

នៃជវនដែលជាតិហេតុកៈផង ដូច្នោះ ទើបលោកពោលថា **ដោយច្រើន** ។ ព្រោះហេតុដែលអាចារ្យពួកខ្លះពោលថា អារម្មណ៍នៃជវនដែលមានអាយុ ខណៈចិត្តមួយមានលោកពោលថា **វារៈមួយខ្លះ** ដូច្នេះ ព្រោះអធិប្បាយថា ជាតទាលម្ពណៈមួយប៉ុណ្ណោះ ក្នុងអារម្មណ៍នៃជវននោះ ក្នុងវេលានោះ ។ ចំណែកអាចារ្យមួយពួកទៀត ពោលថា ឈ្មោះថា **តទាលម្ពណៈ** មានកិច្ចសោយអារម្មណ៍របស់ជវន តទាលម្ពណៈនោះ រមែងមិនកើតក្នុងអារម្មណ៍ ដែលមានក្នុងខណៈចិត្តមួយ ដែលមានការផ្សេងគ្នា ជិតគ្នាយ៉ាងនោះ ដូច្នោះ ពាក្យថា **វារៈមួយខ្លះ** នេះ គប្បីជ្រាបថា លោកពោលទុកដោយអំណាចជាពាក្យងាយស្រួល ដូចពាក្យថា **ទិរត្តតិរត្ត** ប្រែថា ២ យប់ ៣ យប់ជាដើម តែរមែងកើតឡើង ២ វារៈនោះឯង ។ ក្នុងពាក្យថា **ទិរត្តតិរត្តំ** នេះ លោកធ្វើស័ព្ទថា **ទិរត្ត** ទុកដោយត្រឹមតែជាពាក្យងាយស្តាប់ ព្រោះមិនមាន **វា**-ស័ព្ទ ព្រោះដូច្នោះ ទើបត្រឹមត្រូវ ។ ចំណែកក្នុងបាឋៈនេះថា **ទិរត្តំ តិរត្តទស្សនដ្ឋំ វា** ដើម្បីសម្តែង ៣ យប់ជាប់គ្នា ដូច្នេះ លោកពោល **វា**-ស័ព្ទ ដែលមានអត្ថជាវិកប្ប ព្រោះហេតុនោះ គប្បីឃើញថា លោកអាចារ្យពោលថា **សកឹ វា** វារៈមួយខ្លះ ដូច្នេះ សំដៅយកការប្រព្រឹត្តទៅគ្រាខ្លះ វារៈមួយប៉ុណ្ណោះផង ។ ដោយហេតុនោះឯង **ក្នុងសម្មោហវិនោទនី** លោកអាចារ្យកាលនឹងសម្តែងការប្រព្រឹត្តទៅនៃតទាលម្ពណៈមួយដង ជារឿងដែលគួរពិចារណា ទើបបានពោលថា **ក្នុងការរាប់ការប្រព្រឹត្តទៅនៃចិត្ត វារៈនៃចិត្ត ២ វារៈប៉ុណ្ណោះមកហើយ ក្នុងតទាលម្ពណៈក្នុងទ្វារទាំងឡាយ** ដូច្នេះ ។

ក្នុងពាក្យនោះ ពាក្យថា **ក្នុងការរាប់ការប្រព្រឹត្តទៅនៃចិត្ត** លោកអាចារ្យពោលសំដៅយកការរាប់ការប្រព្រឹត្តទៅនៃចិត្ត ដែលលោកពោលទុកក្នុងរូបារម្មណ៍ជាដើម ដែលមានកម្លាំងក្នុងវិបាកកថា ។ ក្នុងវិបាកកថានោះ លោកពោលវារៈការកើតឡើងនៃតទាលម្ពណៈ ២ វារៈប៉ុណ្ណោះ លោកអាចារ្យសំដៅយកសេចក្តីនោះឯង

ទើបពោលទុកក្នុងវិសុទ្ធិមគ្គនេះថា **តែក្នុងអដ្ឋកថាព្រះអភិធម្ម វារៈចិត្តក្នុងតទាលម្ពណៈមកជា ២ វារៈ** ដូច្នេះ ។ ក្នុងអដ្ឋកថាព្រះអភិធម្មលោកពោលទុក ដោយមិនបានកំណត់ដល់ទ្វារយ៉ាងនេះថា អហេតុកមនោវិញ្ញាណធាតុជាធម៌ដែលមានទ្វារ អារម្មណ៍ឋាន និងកិច្ចមិនទៀងទាត់ប្រព្រឹត្តទៅ ។ ពាក្យក្នុងអដ្ឋកថាព្រះអភិធម្មនោះ លោកពោលដោយមានគោលបំណងគឺជាបុគ្គលប្រាថ្នាធ្វើការពណ៌នា ដែលដូចគ្នានៃវិបាកវិញ្ញាណដែលជាសហេតុកៈ ដែលលោកពោលទុកខាងមុខជាលំដាប់ទៅ ។ ពិតហើយ បុគ្គលណាម្នាក់ មិនអាចពោលបានថា អហេតុកមនោវិញ្ញាណធាតុទាំងនេះ មានទ្វារដែលទៀងទាត់ ព្រោះខ្លួនឯងនោះឯងជាទ្វារនៃចិត្ត មានអហេតុកៈទាំងពីរជាដើមដែលជាកវគ្គ ឬមិនអាចពោលថា មានទ្វារមិនទៀងទាត់ ព្រោះមិនកើតឡើងដោយទ្វារដទៃ ដែលហៅថា ជាកវគ្គនៃចិត្តដែលធ្វើចុតិកិច្ច និងបដិសន្ធិកិច្ច ដូច្នេះឯង ។

ឯអហេតុកចិត្តទាំង ២ ដែលជាសន្តីរណៈ និងតទាលម្ពណៈ រមែងបានទ្វារ ហើយអហេតុកចិត្តទាំង ២ នោះ ក៏មិនទៀងទាត់ ព្រោះហេតុនោះ លោកអាចារ្យកាលនឹងកាន់យកអហេតុកចិត្តទាំង ២ នោះ ទើបពោលថា **អហេតុកមនោវិញ្ញាណធាតុដែលជាកុសលវិបាក និងអកុសលវិបាក មានទ្វារ អារម្មណ៍ ឋាន និងកិច្ច មិនទៀងទាត់ប្រព្រឹត្តទៅ** ។ ដោយហេតុនោះឯង ក្នុងទីនេះសូម្បីមហាវិបាកទាំងឡាយដែលជាតទាលម្ពណៈ ទើបបានទ្វារ ព្រោះហេតុនោះ ទើបលោកធ្វើស័ព្ទថា ទ្វារ សូម្បីក្នុងមហាវិបាកនោះ ។

រូបាវចរវិបាក ប្រព្រឹត្តទៅដល់សត្វមួយ ប្រព្រឹត្តទៅហើយក្នុងអារម្មណ៍ណាក្នុងបណ្តាអារម្មណ៍ មានបឋវីកសិណជាដើម ការប្រព្រឹត្តទៅរបស់រូបាវចរវិបាកនោះ រមែងមិនមានក្នុងអារម្មណ៍ដទៃក្រៅអំពីអារម្មណ៍នោះព្រោះហេតុនោះទើបលោកពោលរូបាវចរមានអារម្មណ៍ទៀងទាត់ ។ ពាក្យថា **ចិត្តក្រៅអំពីនេះ** បានដល់ អរូបាវចរ

វិបាកវិញ្ញាណ ។ អរូបាវចរវិបាកវិញ្ញាណក្រៅអំពីនេះ មិនមានវត្ថុទៀងទាត់ ហេតុនោះទើបឈ្មោះថា **និយតាវត្ថុកានិ** ប្រែថា មិនមានវត្ថុទៀងទាត់ ។ ឈ្មោះថា **និយតា-រម្មណានិ** ប្រែថា មានអារម្មណ៍ពិតប្រាកដ ព្រោះប្រព្រឹត្តទៅក្នុងអារម្មណ៍ទាំងឡាយមានកសិណុគ្ឃាដិមាកាសជាដើមនោះឯង ។ បទថា **តត្រ យោគ បវត្តិយំ** ប្រែថា ក្នុងបវត្តិកាលនោះ ។ បទថា **អស្ស យោគ ពត្តឹសវិធស្ស វិបាកវិញ្ញាណស្ស** ប្រែថា ដល់វិបាកវិញ្ញាណ ៣២ ដួងនោះ ។ ពាក្យថា **សង្ខារនោះៗ** សេចក្តីថា **សង្ខារ** មានបុញ្ញាភិសង្ខារជាដើមតាមដែលពោលហើយ ។ ពាក្យថា **ព្រោះកម្មជាបច្ច័យ** គឺព្រោះកម្មប្បច្ច័យដែលប្រព្រឹត្តទៅក្នុងខណៈផ្សេងៗគ្នា ។ ពាក្យថា **ព្រោះឧបនិស្សយប្បច្ច័យ** គឺព្រោះបកតូបនិស្សយប្បច្ច័យ ។

លោកអាចារ្យកាលសម្តែងការប្រព្រឹត្តទៅនៃវិញ្ញាណ ក្នុងបវត្តិកាលយ៉ាងនេះហើយ មានបំណងនឹងសម្តែងក្នុងបដិសន្ធិកាល ទើបពោលពាក្យថា ចំណែកពាក្យណាដែលខ្ញុំពោលទុក ដូច្នេះជាដើម ។ ក្នុងពាក្យនេះ ពាក្យថា **ដោយបដិសន្ធិដែលសមគួរ** បានដល់ ដោយបដិសន្ធិកិច្ចដែលសមគួរ ។ ឯភាពដែលបដិសន្ធិជាកិច្ចដែលសមគួរនោះ លោកអាចារ្យនឹងពោលតទៅនោះឯង ។ លោកអាចារ្យសូម្បីធ្វើពាក្យបុច្ឆាថា **បដិសន្ធិមានប៉ុន្មានយ៉ាង** ដូច្នេះ ហើយនៅធ្វើបុច្ឆាថា **បដិសន្ធិចិត្ត មានប៉ុន្មានយ៉ាង** ព្រោះធ្វើពាក្យអធិប្បាយទុកថា ការបន្តភពដទៃដោយភពដទៃ ឈ្មោះថា **បដិសន្ធិក្នុងទីនេះ** ព្រោះហេតុនោះ ការបន្តនោះសូម្បីមិនមានចិត្តក៏មាន ដូចគ្នា ។ ពីរបទថា **កេន តត្ថ** ប្រែថា ក្នុងភពណាដោយចិត្តណា ។

បទថា **តត្ថ** សេចក្តីប៉ុនគ្នានឹង **តេសុ យោគ ឯកូនវីសតិយា បដិសន្ធិចិត្តេសុ** ប្រែថា ក្នុងបណ្តាបដិសន្ធិចិត្ត ១៩ ដួងនោះ ។ ភ្ជាប់ជាមួយពាក្យថា ដោយអហេតុកមនោវិញ្ញាណធាតុដែលជាកុសលវិបាក ។ ពាក្យថា **ក្នុងមនុស្សលោក** ជាពាក្យធ្វើ

ឲ្យផ្សេងអំពីពពួកទេវតាមិនមានហេតុកបដិសន្ធិ ។ ដោយ **អាទិ-ស័ព្ទថា នបុំសកាទីនំ** ប្រែថា មានខ្ទើយជាដើម លោករួមយកមនុស្សនិយាយត្រដិតជាដើមទុកផង ។ចំណែក អាចារ្យពួកខ្លះពោលថា មនុស្សខ្លះមានបដិសន្ធិជាអហេតុកៈ ជាបុគ្គលមានឥន្ទ្រិយ មិនវិកល រមែងជាអ្នកគួរពិចារណាបន្តិចបន្តួចជាប្រក្រតីខ្លះដែរដូចគ្នា ព្រោះហេតុនោះ សូម្បីមនុស្សពួកខ្លះនោះ ក៏រួមទុកដោយ **អាទិ-ស័ព្ទក្នុងទីនេះ** ។ បទថា **សង្ខេបតោ** ប្រែថា ដោយសង្ខេប សេចក្តីថា មិនបានធ្វើការចែកថា បដិសន្ធិឈ្មោះនោះ មាន អារម្មណ៍ឈ្មោះនោះ ។

បទថា **សេសានំ** ប្រែថា នៃបដិសន្ធិ ៧ ដ៏សេសអំពីដែលពោលហើយនេះ គឺរូបាវចរបដិសន្ធិ ៥ អរូបាវចរបដិសន្ធិទី ១ និងទី ៣ រួមជា ២ ។ **ឈ្មោះថា ចុតិចិត្ត ជាបច្ចុប្បន្នារម្មណ៍មិនមាន ព្រោះប្រព្រឹត្តទៅក្នុងអារម្មណ៍របស់បដិសន្ធិនោះឯង** ។ ពាក្យថា **ក្នុងបណ្តាអារម្មណ៍ ២ យ៉ាង** បានដល់ ក្នុងបណ្តាអារម្មណ៍ ២ យ៉ាង គឺអតីតារម្មណ៍ និងនវត្តព្វារម្មណ៍ ។

បទថា **តានិ យោគ បុព្វេ កតានិ កម្មានិ** ប្រែថា កម្មទាំងឡាយដែលធ្វើទុក មុននោះ ។ បទថា **អស្ស យោគ អាសន្នមរណស្ស បុគ្គលស្ស** ប្រែថា របស់ បុគ្គលដែលជិតស្លាប់នោះ ។ បទថា **ឱលម្ពន្តិ** ប្រែថា ស្មាត់ជំនាញ គឺចូលទៅតាំង នៅក្នុងចិត្តរបស់បុគ្គលនោះដូចស្រមោលនៃភ្នំធំចោលលើផែនដីក្នុងវេលាល្ងាចដូច្នោះ។ ពីរបទថា **តស្មឹ និរុទ្ធេ** ប្រែថា កាលចុតិចិត្តនោះរលត់ហើយ គឺក្នុងលំដាប់នៃការ រលត់នៃចុតិចិត្តនោះឯង ។ បទថា **តទេវ** សេចក្តីថា កម្ម ឬកម្មនិមិត្តនោះឯង ដែល ជាអារម្មណ៍របស់ជវនវិថីតាមដែលពោលហើយ ។ កម្មជាដើមប្រាកដបានក្នុងកាល កិលេស មានអវិជ្ជា និងតណ្ហាជាដើម ដែលមិនទាន់កាត់បាន និងរមែងមានដោយ ចិត្តសន្តានបង្អោនទៅ ឱនទៅ ទោរទន់ទៅកាន់ភពដទៃ ដោយប្រារព្ធកម្ម ឬកម្មនិមិត្ត

នោះ ដូច្នោះ ទើបលោកអាចារ្យពោលថា **បដិសន្ធិចិត្ត ដែលកម្លាំងកិលេសមិនទាន់កាត់បាន ទាញនាំទម្លាក់ទៅ** ។ កាលសន្តានត្រូវទាញនាំអិលទៅ បដិសន្ធិចិត្តដែលជាចំណែកមួយរបស់សន្តាននោះ រមែងត្រូវបន្សាត់នាំទៅផង ភាវៈដែលសន្តានត្រូវទាញនាំទម្លាក់ទៅ វៀរចាកភាវៈដែលត្រូវទាញ នាំទម្លាក់ទៅមួយចំណែកហើយ មិនមានឡើយក្នុងទីទាំងឡាយអាចារ្យទាំងឡាយរមែងវិនិច្ឆ័យថាចុតិចិត្តដែលបង្អោនទៅក្នុងទុគ្គតិបដិសន្ធិ មានជវនដំបូងៗ ជាអកុសល ចុតិចិត្តក្រៅអំពីនេះមានជវនដំបូងៗជាកុសល ។ សេចក្តីនេះ សមដូចព្រះបាលីដែលត្រាស់ទុកថា **ម្នាលភិក្ខុទាំងឡាយ វិញ្ញាណដែលទាក់ទងដោយសេចក្តីត្រេកអរក្នុងនិមិត្ត ឬដែលទាក់ទងដោយសេចក្តីត្រេកអរ ក្នុងអនុព្យញ្ជនៈ កាលតាំងនៅ រមែងតាំងនៅ, បើបុគ្គលធ្វើកាលកិរិយាក្នុងសម័យនោះ ប្រការដែលបុគ្គលគប្បីចូលដល់គតិ ២ យ៉ាងឯណានីមួយ គឺនរក ឬកំណើតសត្វតិរច្ឆាន ជាឋានៈដែលនឹងមានបាន** ។ ព្រោះហេតុនោះ អកុសលរមែងជាឧបនិស្ស័យដល់បដិសន្ធិក្នុងទុគ្គតិ តែកុសល រមែងជាឧបនិស្ស័យដល់បដិសន្ធិក្នុងសុគតិ ។ ចំណែកព្រះអរហន្តកាត់កិលេសបានជាសមុច្ឆេទហើយ និមិត្ត មានកម្មជាដើម ទើបមិនប្រាកដ ព្រោះជាបុគ្គលមានការឈានទៅកាន់កពទាំងពួងស្ងប់រម្ងាប់ហើយ ។ ដូច្នោះ កម្មសូម្បីនៅមាន ក៏រមែងមិនញ៉ាំងបដិសន្ធិឲ្យកើត ព្រោះមិនបានធម៌ដែលជាសម្ងាញ់ ។

ពាក្យថា **ដោយអំណាចកម្ម មានប្រការដូចពោលហើយ** គឺដោយអំណាចបាបកម្ម អធិប្បាយថា ដែលបាបកម្មនោះឲ្យប្រាកដ ។ ពាក្យថា **មានវណ្ណរូបនៃអណ្តាតភ្លើងជាដើម ក្នុងទុគ្គតិ មាននរកជាដើម** នេះ លោកអាចារ្យពោលទុកដោយអំណាចភាវៈដែលដូចគ្នានឹងវណ្ណរូបនោះ ។ ព្រោះថា វណ្ណរូប មានអណ្តាតភ្លើងជាដើមនោះឯងមិនមកកាន់គន្លងទ្វាររបស់បុគ្គលនោះក្នុងវេលានោះឡើយ ។ បណ្តាបទទាំងនោះ ដោយ

**អាទិ** សព្ទថា **អគ្គិជាល វណ្ណាទិកំ** លោកអាចារ្យរមែងរួមដល់វណ្ណរូបនៃវេត្តរណីនរក សិម្ពលីនរក អសិបត្តនរក (នរកជាវល្លិ៍ឈើ) និងនរកព្រៃឈើជាដើម ។ម្យ៉ាងទៀត ដោយ **អាទិ-សព្ទថា នរកាទីសុ** លោកអាចារ្យក៏រួបរួមយកវណ្ណរូប ដែលទាក់ទង ក្នុងទីកន្លែងសញ្ចរទៅជានិច្ចរបស់ប្រេត និងសត្វតិរច្ឆាន ។ ពាក្យថា **មកកាន់គន្លង ក្នុងមនោទ្វារ** សេចក្តីថា វណ្ណាយតនៈ ដែលត្រូវកម្លាំងកម្មឲ្យតាំងឡើង រមែងដល់ នូវភាពជាអារម្មណ៍ក្នុងមនោទ្វារតែម្យ៉ាង ដូចបុគ្គលដែលយល់សប្តិឃើញហាក់ដូចខ្លួន បានទិព្វចក្ខុ ។ មានវិថីចិត្ត ៣ គឺអាវជ្ជនៈ ១ ជវន ៥ តទាលម្ពណៈ ២ ។ ពាក្យថា **អារម្មណ៍ថោកទាប ដែលជាហេតុនៃកិលេស មានរាគៈជាដើម** លោកអាចារ្យពោល ដល់អនិដ្ឋារម្មណ៍ ដែលគួរជាអារម្មណ៍របស់អកុសលវិបាក ព្រោះអនិដ្ឋារម្មណ៍នោះ រមែងជាហេតុនៃរាគៈ ដោយអំណាចការត្រេកអរ ។ ម្យ៉ាងទៀត អារម្មណ៍ដែលជាហេតុ នៃកិលេស មានរាគៈជាដើម ដែលកើតរួមនឹងកម្ម ដែលញុំាងអកុសលវិបាកឲ្យកើត និងដែលកើត រួមជាមួយចេតនាក្នុងជវនវិថីជិតចុតិ ដែលដូចគ្នានឹងកម្មនោះៗ ឯង ឈ្មោះថា ជាអារម្មណ៍ថោកទាប ។ ព្រោះថា អារម្មណ៍នោះ ជាអារម្មណ៍របស់កម្ម ដែលធ្វើទុកឲ្យកើតការក្តៅក្រហាយតាមជាខាងក្រោយជាអារម្មណ៍ ដែលមិនគួរប្រាថ្នា ដោយអំណាចកម្មគួរជាអារម្មណ៍នៃអកុសលវិបាក ។ ចំណែកវិបាកនៃអកុសលកម្ម ដែលប្រព្រឹត្តទៅក្នុងឥដ្ឋារម្មណ៍ដោយប្រការដទៃ មិនគួរនឹងមាននិមិត្តនៃអកុសលកម្ម ជាអារម្មណ៍ ព្រោះថា អកុសលវិបាក មិនគួរជាឥដ្ឋារម្មណ៍ឡើយ ដូច្នេះ ។

ឯកម្មនិមិត្តដែលជាបច្ចុប្បន្នមកកាន់គន្លងក្នុងបញ្ចទ្វារ គប្បីឃើញថា កើតឡើង ក្នុងការបន្តគ្នានៃអារម្មណ៍របស់កម្ម ដែលធ្វើទុកក្នុងកាលជិតស្លាប់ ហើយដូចគ្នានឹង អារម្មណ៍នោះ ។ពោលដោយប្រការដទៃ កម្មនិមិត្តនោះគប្បីជាធម្មជាតិញុំាងអារម្មណ៍ បដិសន្ធិឲ្យប្រាកដ ហើយកម្មនិមិត្តនោះឯង គប្បីជាធម្មជាតិញុំាងបដិសន្ធិឲ្យកើត ។

ជវនដែលជិតចំពោះចុតិ ដែលប្រព្រឹត្តទៅ ដូចជាឧបចារៈនៃបដិសន្ធិ និងដូចជាមិនធ្វើអារម្មណ៍របស់បដិសន្ធិឲ្យកើតឡើងថា អ្នកគប្បីបដិបត្តិនៅក្នុងទីដូច្នេះ មិនគប្បីជាធម្មជាតិញ៉ាំងបដិសន្ធិឲ្យកើតឡើងនោះឡើយ ។ សេចក្តីនេះ សមដូចព្រះបាលីដែលត្រាស់ទុកថា **ព្រោះជាកម្មដែលបានធ្វើហើយ បានសន្សំទុកហើយ** ។ សួរថា ជវនដែលប្រព្រឹត្តទៅ ដូចនៅក្នុងវិថីដែលស្មើគ្នានឹងជវននោះ ក្នុងវេលានោះ នឹងគប្បីជាកម្មដែលបានធ្វើហើយ បានសន្សំទុកហើយដូចម្តេច ? ឆ្លើយថា ជវនទាំងនោះមិនឲ្យផលក្នុងវេលានោះឡើយ និងមិនជាធម្មជាតិដែលជាផលរបស់វិថីស្មើគ្នា ដូចជាលោកិយ លោកុត្តរនោះឡើយ ។ ព្រះមានជោគបានត្រាស់ការឲ្យបដិសន្ធិក្នុងចេតនាដែលកើតរួមដោយមិច្ឆាទិដ្ឋិ និងសម្មាទិដ្ឋិដែលបានសមាទានដល់ព្រមក្នុងវេលាជិតស្លាប់ទុកក្នុងព្រះសូត្រ ដោយន័យជាដើមថា កម្មអាក្រក់ មានផលជាទុក្ខ រមែងត្រូវគេធ្វើទុកមុននោះឯង ឬត្រូវគេធ្វើទុកក្នុងកាលខាងក្រោយ ឬមានមិច្ឆាទិដ្ឋិដែលគេបានសមាទានដល់ព្រមហើយ ក្នុងវេលាជិតស្លាប់ ។ ដោយហេតុនោះ ខាងមុខអំពីសេចក្តីស្លាប់ ព្រោះកាយបែកធ្លាយ ទើបបុគ្គលនោះចូលដល់អបាយទុគ្គតិ វិនិបាត នរកម្យ៉ាងទៀត មិច្ឆាទិដ្ឋិ ឬសម្មាទិដ្ឋិ មិនមែនបុគ្គលនោះសមាទានដល់ព្រមដោយជវនដែលប្រព្រឹត្តទៅក្នុងទ្វារ ៥ យ៉ាងទុព្វលឡើយ ។ សេចក្តីនេះ សមដូចពាក្យដែលលោកអាចារ្យពោលទុកក្នុង **សម្មោហវិនោទនីថា** កិច្ចដែលជាទីបំផុតនៃចុតិ មានការទទួលដឹងកុសលធម៌ និងអកុសលធម៌ជាដើមទាំងអស់នេះ រមែងមានបានដោយចិត្តក្នុងមនោទ្វារប៉ុណ្ណោះ មិនមានបានដោយចិត្តក្នុងបញ្ចទ្វារឡើយ ព្រោះហេតុនោះ ទើបលោកបដិសេធវិថីចិត្ត ដែលស៊ុះទៅរួមគ្នាក្នុងការធ្វើកិច្ចទាំងអស់នោះ ។

ពាក្យថា **មិនទទួលដឹងធម៌ណាមួយ** ដូច្នេះ ក្នុងកិច្ចនៃចុតិចិត្តនោះ លោកពោលទុកយ៉ាងនេះថា **ធម៌ទាំងឡាយ មានចិត្តជាប្រធាន** និងពោលទុកថា មិនទទួលដឹង

កុសល ឬអកុសលតែម្យ៉ាងនោះឡើយ ។ សុខ ឬទុក្ខ ទៅតាមដោយការប្រព្រឹត្តទៅនៃការជាក់ច្បាស់ចំពោះរបស់ចិត្តទាំងឡាយណា ការប្រព្រឹត្តទៅនៃចិត្តទាំងនោះ លោកបដិសេធទុកក្នុងបញ្ចទ្វារ ការប្រកាន់មាំក្នុងកុសលកម្ម និងអកុសលធម៌ ក៏ដូច្នោះដូចគ្នា ។ ដោយការអធិប្បាយនេះថា ចុតិមានក្នុងលំដាប់នៃតទាលម្ពណៈ និងឧប្បត្តិមានក្នុងលំដាប់នៃចុតិនោះ រមែងជាធម្មជាតិប្រព្រឹត្តទៅតាមមនោទ្វារប៉ុណ្ណោះ មិនបានទាក់ទងក្នុងវិថីចិត្តដែលស្មុះទៅរួមគ្នា ដូច្នេះ ក្នុងទីនេះ គប្បីឃើញថា លោកពោលចុតិទុកក្នុងលំដាប់នៃតទាលម្ពណៈដែលមានក្នុងបញ្ចទ្វារ និងបដិសន្ធិទុកក្នុងលំដាប់នៃចុតិនោះ ។ ក្នុងសេចក្តីនោះ គប្បីជ្រាបថា ទ្រង់សំដៅដល់បដិសន្ធិដែលកើតឡើងក្នុងរូបជាដើម ដែលមានអាយុនៅសល់ ៥ ខណៈចិត្ត ទើបត្រាស់ទុកថា ចិត្តដែលជាឧប្បត្តិ មានអារម្មណ៍ជាបច្ចុប្បន្នជាបច្ច័យ ដោយអនន្តរប្បច្ច័យដល់កវគ្គ ដែលមានអារម្មណ៍ជាបច្ចុប្បន្ន និងទ្រង់សំដៅដល់បដិសន្ធិដែលកើតឡើងក្នុង រូបដែលមានអាយុនៅសល់ខណៈចិត្ត ១ ត្រាស់ទុកថា ចិត្តដែលជាឧប្បត្តិដែលមានអារម្មណ៍ជាបច្ច័យ ដោយអនន្តរប្បច្ច័យដល់កវគ្គ ដែលមានអារម្មណ៍ជាអតីត ដូច្នេះ ។

ក្នុងពាក្យថា បន្ថែមពាក្យចំណែក.សជំនួសក្នុងពាក្យចំណែកខ្មៅនេះ មានសេចក្តីថា បណ្ឌិតគប្បីជ្រាបពាក្យទាំងពួងដ៏សេស ដោយបន្ថែមពាក្យចំណែក.សយ៉ាងនេះថា បដិសន្ធិចិត្តដែលទាក់ទងក្នុងសុគតិភូមិ មាននិមិត្តនៃសុគតិភូមិ ពោល គឺវណ្ណរូបជាផ្ទៃមាតា ដូចសំពត់កម្ពលក្រហមក្នុងមនុស្សលោក ឬមាននិមិត្តនៃសុគតិភូមិ ពោល គឺវណ្ណរូប ជាឧទ្យាន វិមាន ដើមកប្បព្រឹក្សជាដើមក្នុងទេវលោក ដូច្នេះជំនួសពាក្យក្នុងចំណែកខ្មៅដែលលោកពោលទុកថា ម្យ៉ាងទៀត បដិសន្ធិចិត្តទាក់ទងក្នុងទុគ្គតិ មាននិមិត្តនៃទុគ្គតិ ជាវណ្ណរូបរបស់អណ្តាតភ្លើងក្នុងនរកជាដើម ដូចដែលលោកពោលចំណែក.សថា កម្មមិនមានទោសខ្វះ កម្មនិមិត្តខ្វះ ដូច្នេះ ជំនួសក្នុង

ចំណែកពាក្យដែលលោកពោលទុកថា **បាបកម្មខ្លះ កម្មនិមិត្តខ្លះ** ដូច្នេះ ដូច្នោះ ។ ពាក្យថា **សុគតិបដិសន្ធិដែលមានអារម្មណ៍ជាអតីតខ្លះ បច្ចុប្បន្នខ្លះ** សេចក្តីថា មានអារម្មណ៍ជាអតីតដោយអំណាចកម្ម និងកម្មនិមិត្ត មានអារម្មណ៍ជាបច្ចុប្បន្ន ដោយអំណាចនិមិត្តក្នុងសុគតិភូមិ មានវណ្ណរូបជាគភ៌មាតាជាដើម ។

បទថា **តញ្ចខោ** សេចក្តីថា សេចក្តីដែលធ្វើការមិនកំណត់ទុកថា **អនវជ្ជកម្ម ឬកម្មនិមិត្ត** ដូច្នេះ ។ **កម្មនិមិត្តតែម្យ៉ាងរមែងមកកាន់គន្លង** សម្រាប់បុគ្គលដែលមានមហគ្គតវិបាក ព្រោះខ្លួនមានកម្មជាអារម្មណ៍តែម្យ៉ាង ។ ពាក្យថា **ឬនៃជវនវិថីសុទ្ធ** បានដល់ **នៃជវនវិថី** ដែលមានកម្មនិមិត្តនៃមហគ្គតៈជាអារម្មណ៍ អធិប្បាយថា ដែលវៀរចាកតទាលម្ពណៈ ។ ឯជវនវិថីនោះ គប្បីឃើញដូចជាឧបចារៈនៃមហគ្គតវិបាក ។ ចំណែកអាចារ្យពួកខ្លះពោលវិថីនោះឯងថា មានមហគ្គតៈ ជាទីបំផុត ។ ពាក្យថា **បដិសន្ធិជានវត្តព្វារម្មណ៍** នេះ លោកអាចារ្យពោលសំដៅដល់បដិសន្ធិក្នុងរូបាវចរ និងបដិសន្ធិទី ១ បដិសន្ធិទី ៣ ក្នុងអរូបាវចរ ។ ចំណែកបដិសន្ធិទី ២ និងទី ៤ លោកកាន់យកដោយពាក្យថា បដិសន្ធិជាអតីតារម្មណ៍នោះឯង ។

ពាក្យថា **ពោល គឺវណ្ណរូប ជាឧទរមាតា** ជាដើម វណ្ណរូបប៉ុណ្ណោះមកហើយដោយភាពជាគតិនិមិត្ត ។ ក្នុងពាក្យទាំងនោះ សទ្ទរូប មិនបានមកហើយក្នុងអដ្ឋកថាទាំងឡាយដោយភាពជាគតិនិមិត្ត ព្រោះជាធម៌ដែលទាក់ទងនៅក្នុងសុគតិភូមិ ដោយភាពជាអនុបាទិន្នរូប ព្រោះដូច្នោះ ទើបសេចក្តីនេះប្រពៃហើយ ចំណែកហេតុក្នុងការមិនមកនៃគន្ធរូបជាដើម បណ្ឌិតគួរពិចារណា ។

ក្នុងពាក្យថា **នៃបា ពុទ្ធបូជានេះ ខ្ញុំធ្វើដើម្បីប្រយោជន៍ដល់អ្នក** ជាដើម វិនិច្ឆ័យថា បុណ្យរមែងសម្រេចដោយអំណាចបុព្វចេតនា ។ អាចារ្យទាំងឡាយ ពោលថា សម្រាប់បុគ្គលកំពុងប្រព្រឹត្តទៅក្នុងជវនចិត្តជួនទីបំផុតទាំងអស់ ។

សួរថា ពាក្យថា បដិសន្ធិក្នុងលំដាប់នៃអរូបចុតិ ក៏គប្បីជ្រាបដោយទំនងនោះនេះ លោកអាចារ្យពោលទុកព្រោះហេតុណា បដិសន្ធិនេះក៏ចូលគ្នាបានក្នុងន័យជាដើមយ៉ាងនេះថា **សម្រាប់បុគ្គលម្នាក់ដែលនៅក្នុងសុគតិភូមិ បានមហគ្គតវិបាកដោយអំណាចឈាន មានបឋវីកសិណជាអារម្មណ៍ជាដើម** ដូច្នេះនោះឯង មិនមែនឬ ? ឆ្លើយថា មិនមែន ព្រោះក្នុងទីនោះ លោកពោលបដិសន្ធិ ដែលជាលំដាប់នៃរូបាវចរចុតិប៉ុណ្ណោះ ។ ពិតហើយ ក្នុងទីនោះ រមែងដឹងបដិសន្ធិថា លោកពោលទុកក្នុងលំដាប់នៃរូបាវចរចុតិប៉ុណ្ណោះ ដោយពាក្យជាដើមថា **កសិណនិមិត្ត មាននិមិត្តនៃបឋវីកសិណជាដើមខ្លះ មហគ្គតចិត្តខ្លះ មកកាន់គន្លងក្នុងមនោទ្វារ ម្យ៉ាងទៀត អារម្មណ៍ដែលប្រណីតដែលជាហេតុកើតកុសលមកកាន់គន្លងក្នុងចក្ខុទ្វារ ឬសោតទ្វារឯណានីមួយ** ។ សូម្បីកាលបើដូច្នេះ បដិសន្ធិចិត្តនេះក៏ចូលគ្នាមិនបានក្នុងទីនោះដូចគ្នា ដោយការប្រកបតាមគួរតែរូបាវចរបដិសន្ធិមិនមានក្នុងលំដាប់នៃអរូបាវចរចុតិចិត្តឡើយ ។ ហើយក្នុងអរូបាវចរបដិសន្ធិជាន់ទាបៗ ក្នុងលំដាប់នៃចុតិជាន់ខ្ពស់ៗ ក៏មិនមាន ព្រោះហេតុនោះ ក្នុងអរូបាវចរចុតិទី ៤ ទើបមិនមានបដិសន្ធិដែលជានវត្តព្វារម្មណ៍ ។ ដោយហេតុនោះទើបគួរប្រកបបដិសន្ធិ ដែលមានអារម្មណ៍ជាអតីតក្នុងអរូបាវចរចុតិទី ៤ នោះប៉ុណ្ណោះ ដោយប្រការនោះ និងគួរប្រកបបដិសន្ធិដែលមានអារម្មណ៍ជាអតីត និងបច្ចុប្បន្នក្នុងកាមាវចរ ។ និងអំពីបដិសន្ធិក្រៅអំពីនេះ ក៏គួរប្រកបអរូបាវចរបដិសន្ធិ ដែលមានអារម្មណ៍ជាអតីត និងជានវត្តព្វារម្មណ៍ និងគួរប្រកបកាមាវចរបដិសន្ធិដែលមានអារម្មណ៍ជាអតីត និងជាបច្ចុប្បន្នតាមសមគួរ ព្រោះហេតុនោះ ទើបលោកធ្វើការពង្រីកទៅមួយផ្នែក ដើម្បីសម្តែងការផ្សេងគ្នាក្នុងសេចក្តីនេះ ។

លោកអាចារ្យបានសម្តែងទុគ្គតិបដិសន្ធិ ២ យ៉ាងនៃចុតិក្នុងសុគតិកាមាវចរភូមិតែម្យ៉ាង ដោយអំណាចអារម្មណ៍ សម្តែងសុគតិបដិសន្ធិ ២ យ៉ាងនៃចុតិក្នុងទុគ្គតិ

សម្តែងសុគតិបដិសន្ធិ ៥ យ៉ាង គឺកាមភូមិ ២ ប្រការ រូបភូមិ ១ ប្រការ អរូបភូមិ ២ ប្រការ នៃចុតិក្នុងសុគតិកាមាវចរភូមិ សម្តែងសុគតិបដិសន្ធិ ៥ យ៉ាងនោះ ដូចគ្នា នៃចុតិរូបាវចរភូមិ និងបានសម្តែងបដិសន្ធិ ៨ យ៉ាង គឺកាមភូមិ និងអរូបភូមិចំពោះ តែម្យ៉ាងៗ ២ នៃអរូបចុតិ ២ យ៉ាង ដោយប្រការដូច្នេះ ។ តែលោកមិនបានសម្តែង ទុគ្គតិបដិសន្ធិ ២ យ៉ាង នៃទុគ្គតិចុតិតែម្យ៉ាងទុក ដើម្បីសម្តែងទុគ្គតិបដិសន្ធិ ២ យ៉ាង នោះ ទើបលោកអាចារ្យបានពោលទុកថា **ចំណែកបុគ្គល មានបាបកម្មនៅក្នុងទុគ្គតិ** ដូច្នេះជាដើមទុក ។ ដូចដែលបុរាណាចារ្យបានពោលថា

បដិសន្ធិទាំងនេះនៃចុតិ ដូច្នោះ ដោយគព និងអារម្មណ៍ទុក ២៤ ប្រការ គឺ ២ ប្រភេទ, ២ ប្រភេទ, ៥ ប្រភេទ, ៥ ប្រភេទ, ៨ ប្រភេទ, ២ ប្រភេទ ភាពជាកម្មប្បច្ច័យ ដែលប្រព្រឹត្តទៅក្នុងខណៈផ្សេងៗ គ្នា មានប្រការដែលបានសម្តែងមកហើយខាងដើម ដោយពាក្យជាដើមថា **ព្រោះបានធ្វើកុសលកម្ម ដែលជាកាមាវចរហើយ** ដូច្នេះ ព្រោះ ដូច្នោះ លោកអាចារ្យកាលសម្តែងឧបនិស្សយប្បច្ច័យតែម្យ៉ាង ទើបបានពោលពាក្យ ថា **សេចក្តីនេះសមដូចពាក្យដែលព្រះមានព្រះភាគត្រាស់ទុកហើយ** ដូច្នេះជាដើម ។

ការប្រព្រឹត្តទៅរួមជាមួយរូប ដែលជានិស្សយប្បច្ច័យ ឈ្មោះថា **ការផ្សំ** ជាមួយ រូបនោះនៃវិញ្ញាណក្នុងទីនេះ, ការមិនមាននៃការទៅរួមនោះ ឈ្មោះថា **ការមិនផ្សំ** ។ ឈ្មោះ **យោនិ** ដោយអត្ថថា ជាទីទៅរបស់សត្វទាំងឡាយ គឺផ្សំគ្នានឹងគ្នា ដោយការ ប្រកបដោយការកើតម្តង ។ ឈ្មោះថា **គតិ** ដោយអត្ថថា ដែលសត្វគប្បីដល់ គឺគប្បី សម្រេចដោយអំណាចសុចរិត និងទុច្ចរិត ។ ឈ្មោះថា **ឋិតិ** ដោយអត្ថថា ជាទីតាំង, ទីតាំងនៃវិញ្ញាណ ឈ្មោះថា **វិញ្ញាណដ្ឋិតិ** ។ លំនៅរបស់សត្វ មាននានត្តកាយនា- នត្តសញ្ញី គឺសត្វដែលមានកាយផ្សេងគ្នា មានសញ្ញាផ្សេងគ្នាជាដើមនោះឯង ឈ្មោះថា **សត្តាវាស** ព្រោះសត្វទាំងឡាយ គប្បីអាស្រ័យនៅ ។ លោកអាចារ្យពោលថា **ប្រភេទ**

មាន ៨ យ៉ាង ដោយអំណាចសត្តាវាស ដូច្នេះ ព្រោះអសញ្ញីសត្តាវាសមិនមានក្នុងទីនេះ ។

ក្នុងពាក្យថា **វៀរតែបដិសន្ធិ មនុស្សខ្វើយដោយកំណើត** នេះ គួរពោលដល់ថា វៀរតែបដិសន្ធិរបស់មនុស្សក្នុងបឋមកប្បផង ។ ព្រោះបដិសន្ធិរបស់មនុស្សក្នុងបឋមកប្បនោះ ក៏វៀរចាកភាវៈនោះឯងកើតឡើង ។

បទថា **ឱមតោ** ប្រែថា យ៉ាងទាប អធិប្បាយថា ជាន់យ៉ាងទាប ។ ពាក្យថា **ជាមួយវិញ្ញាណប្រភេទខាងដើម** គឺជាមួយវិញ្ញាណផ្សំដែលលោកពោលទុកក្នុងវិញ្ញាណប្រភេទដើម ក្នុងបណ្ដាវិញ្ញាណពួក ២ នោះថា **វិញ្ញាណផ្សំគ្នា ( និង ) មិនផ្សំគ្នា** ។ ពាក្យថា ( រូបកលាបៈ ) **ទសកៈ ២ ឬ ៣ យ៉ាងទាប រមែងកើតឡើង** លោកពោលទុកដោយអំណាចគព្ភសេយ្យកសត្វ ។ ចំណែកក្នុងកំណើតដទៃ រូបកលាបៈសន្ទឹកសន្ទាប់រមែងកើតឡើងរួមគ្នា ពិតហើយ សូម្បីក្នុងអត្តភាពនៃព្រហ្ម រមែងកើតរូបកលាបៈរួមគ្នាសន្ទឹកសន្ទាប់ ដោយប្រមាណច្រើនតាវ៉ត ព្រោះហេតុនោះ ទើបមានរូបជាង ៣០ រូបកលាបៈ ។ អាចារ្យពួកខ្លះពោលថា ពេមចៀម ដែលកើតក្នុងថ្ងៃនោះ ឈ្មោះថា **ជាតិឧណ្ណា** ។ អាចារ្យមួយពួកទៀត ពោលថា ពេមចៀមដែលកើតក្នុងហេមវន្តប្រទេស ឈ្មោះថា **ជាតិឧណ្ណា** ។ អាចារ្យពួកដទៃ ពោលថា ពេមចៀមដែលវះពោះយកមកឈ្មោះថា **ជាតិឧណ្ណា** ។ បណ្ឌិតគប្បីជ្រាប **សេចក្ដីផ្សេងគ្នានៃការមានឡើងរបស់កំណើត ដោយអំណាចគតិ** យ៉ាងនេះ គឺកំណើតទាំងនេះ រមែងមានឡើងក្នុងគតិទាំងនេះ មិនមានឡើងក្នុងគតិទាំងនេះ ។

បទថា **កុម្មវេជ្ជេសុ** សេចក្ដីថា ការវៀរពួកកុម្មទេវតា ព្រោះកុម្មទេវតាទាំងនោះដូចគ្នានឹងមនុស្សក្រាលចែកដោយកំណើត ។ ពាក្យថា **កំណើត ៣ ខាងដើម មិនមាន** សេចក្ដីថា លោកអនុញ្ញាតកំណើតខាងក្រោយទុក ដោយបដិសេធទុក ៣ កំណើត

ព្រោះហេតុនោះ ទើបជាការត្រឹមត្រូវហើយនោះឯង ដោយអត្ថ ។ ពាក្យថា **ក្នុងគតិ ៣** បានដល់ ក្នុងគតិទាំង ៣ ដែលឈ្មោះថា **មនុស្ស ប្រេត តិរច្ឆាន**។ ឯគតិទាំង ៣ នោះ មិនបានកំណត់ទុកមុនក្នុងទីនេះ ។

ដើម្បីសម្ដែងថា ច-ស័ព្ទ មានអត្ថរួបរួមសេចក្ដីដែលមិនបានពោលទុក ទើបលោកអាចារ្យពោលពាក្យជាដើមថា **ដោយ ច-ស័ព្ទ** សួរថា ព្រោះហេតុអ្វី ក្នុងពួកនិជ្ឈាមតណ្ហិកប្រេត ទើបមិនមានកំណើត ៣ ខាងដើម ? ឆ្លើយថា ព្រោះមិនមានទឹកសម្ភវៈ ។ ព្រោះថា មិនមានការសេពកាម ព្រោះនិជ្ឈាមតណ្ហិកប្រេតទាំងនេះមានការសោប់សេល់ជានិច្ច ព្រោះហេតុនោះ ទើបអណ្ឌជកំណើតទាំងនោះ មិនមាន ។ អាចារ្យពួកខ្លះពោលថា សត្វដែលកើតក្នុងគភ៌របស់នាងនិជ្ឈាមតណ្ហិកប្រេតទាំងនោះ មិនតាំងចុះក្នុងពោះ ព្រោះមានតែអណ្ដាតភ្លើង ។ អាចារ្យទាំងឡាយ ពោលថា នាងនិជ្ឈាមតណ្ហិកប្រេតទាំងនោះរមែងកើតឡើងមានសរីរៈសន្ទោសន្ទៅដោយអណ្ដាតភ្លើង ព្រោះដូច្នោះ សូម្បីជាសំសេទជកំណើតក៏មិនមានដល់នាងប្រេតទាំងនោះឡើយ ព្រោះមិនមានទឹកសម្ភវៈក្នុងទីដែលសើម និងរដូវជាដើម ។ ដោយហេតុនោះ ទើបលោកអាចារ្យពោលថា **ព្រោះពួកនិជ្ឈាមតណ្ហិកប្រេតនោះជាឱបបាតិកៈ** ដូចគ្នា ។

លោកអាចារ្យពង្រីកសេចក្ដីដល់ពួករូបព្រហ្ម ដោយពួកសត្វដែលកើតក្នុងកំណើតឱបបាតិកៈថា **រូបីព្រហ្មេសុ តាវ ឱបបាតិកយោនិកេសុ** ប្រែថា លំដាប់ដំបូងក្នុងពួកសត្វដែលកើតក្នុងកំណើតឱបបាតិកៈក្នុងជំពូករូបព្រហ្ម ។ បទថា **រូបីព្រហ្មេសុ** ជាសត្តមីវិភត្ត ចុះក្នុងអធិករណៈ ។ បទថា **ឱបបាតិកេសុ** ជាសត្តមីវិភត្តិ ចុះក្នុងនិទ្ធារណៈ ។ ដោយហេតុនោះ ទើបលោកអាចារ្យពង្រីកសេចក្ដីមួយចំណែករបស់ឱបបាតិកៈនោះ ដោយពិសេសថា **ក្នុងជំពូករូបព្រហ្ម** អំពីក្រុមរបស់សត្វដែលលោកពោលទុកដោយភាពស្មើគ្នាថា **ក្នុងពពួកសត្វដែលកើតក្នុងកំណើតឱបបាតិកៈ** ។ ក្នុង

ពាក្យថា ចក្ខុទសកៈ សោតទសកៈ វត្ថុទសកៈ និងជីវិតនវកៈ នេះ អាចារ្យពួកខ្លះ ពោលហេតុទុកថា រូប ២៧ ព្រមជាមួយបដិសន្ធិវិញ្ញាណ រមែងកើតក្នុងរូបភពដោយ អំណាចកលាបៈទាំង ៤ គឺចក្ខុសត្តកៈ សោតសត្តកៈ វត្ថុសត្តកៈ និងជីវិតឆក្កៈ ព្រោះក្នុងរូបភពនោះ លោកបដិសេធគន្ធៈ រស និងអាហារ ដូច្នេះហើយ កាលនឹង ចងហេតុនោះឲ្យជាប់ ទើបពោលថា សេចក្តីពិតក្នុងព្រះបាលី ព្រះមានព្រះភាគត្រាស់ ថា ក្នុងខណៈកើតឡើងនៃរូបធាតុ វៀរទេវតាជំពូក អសញ្ញីសត្វ អាយតនៈ ៥ រមែងប្រាកដ ធាតុទាំង ៥ រមែងប្រាកដ ម្យ៉ាងទៀត មិនបានត្រាស់ទុកថា ដើម្បីទ្រង់ សម្តែងដល់អាយតនៈ និងធាតុដែលមាននៅក្នុងរូបភពនោះ ដោយអំណាចពាក្យដែល រួមទុកទាំងអស់ថា រូបធាតុ មានអាយតនៈ ៦ ធាតុទាំង ៩ ។ ក្នុងកថាវត្ថុបករណ៍ លោកក៏បានបដិសេធភាពមាននៃគន្ធាយតនៈជាដើមក្នុងរូបធាតុនោះ ដូចគ្នានឹងបដិសេធ ភាពមាននៃឃានាយតនៈជាដើមទុក ដោយពាក្យជាដើមថា សកវាទីសួរថា ក្នុងរូបធាតុ នោះ មានឃានាយតនៈឬ ? បរវាទីឆ្លើយថា ត្រូវហើយ ។ សកវាទីសួរថា ក្នុង រូបធាតុនោះ មានគន្ធាយតនៈឬ ? បរវាទីឆ្លើយថា មិនគប្បីពោលយ៉ាងនោះ ។

បុគ្គលណាម្នាក់ មិនអាចពោលការមាននៃគន្ធៈ រស ដែលមិនមែនជាគន្ធាយតនៈ និងរសាយតនៈទុកក្នុងរូបធាតុនោះឡើយ ដូចជាការមាននៃបឋវីធាតុជាដើម ដែលជា អាយតនៈ ដែលមិនមែនជាផោដ្ឋព្វៈ ព្រោះភាវៈនៃគន្ធៈ រស ដែលផុតអំពីភាវៈ ជា គន្ធាយតនៈ និងរសាយតនៈមិនមាន ដូចជាសភាវៈនៃបឋវីជាដើម ដែលផុតអំពីភាព ជាធម្មជាតិដែលមិនគប្បីអាចពាល់ត្រូវបានមិនមាន ដូច្នោះ ។ បើឃានសម្ពស្សជាដើម ជាហេតុមិនមានសោត ព្រោះហេតុនោះ សភាវធម៌ទាំងនោះ ក៏មិនគួរពោលថា អាយតនៈ ម្យ៉ាងទៀត ធាតុ-ស័ព្ទ ប្រាប់អត្ថដល់និស្សត្តធម៌ និងនិជ្ជីវធម៌ ព្រោះហេតុ នោះ ហេតុក្នុងការមិនពោលថា គន្ធធាតុ រសធាតុ ដូច្នេះ ទើបមិនមាន ម្យ៉ាងទៀត

សភាវធម៌ទាំងនោះ ជាធម៌ដែលបណ្ឌិតគួរប្រាជ្ញាដោយចំណែកមួយ ព្រោះមិនមានកិច្ចដទៃអំពីលក្ខណៈ មានការទ្រទ្រង់ទុកនូវភាវៈរបស់ខ្លួនជាដើម ។ និងភាពដែលសភាវធម៌ទាំងឡាយជាអាយតនៈ ក៏ប្រព្រឹត្តទៅដោយចំណែកមួយ ដែលបានត្រាស់ទុកក្នុង **គម្ពីរយមកៈថា សួរថា ធម៌ជាអាយតនៈឬ ? ឆ្លើយថា ពិត** ។ ព្រោះហេតុនោះ គួរពោលអាយតនៈខ្វះទុកក្នុងការកើត និងមិនជាគន្ធាយតនៈ និងរសាយតនៈនៃគន្ធៈ រសទាំងនោះ ។ ឧបមាថា គប្បីមានសភាវៈខ្វះរបស់សភាវធម៌ទាំងនោះដទៃទៅអំពីគន្ធៈ រស ដូចជាបឋវីដទៃទៅអំពីផោដ្ឋព្វៈសោត សភាវធម៌ទាំងនោះ ក៏រួមគ្នាជាធម្មាយតនៈ ។ ម្យ៉ាងទៀត កាលគន្ធៈ រស និងកាលអាយតនៈមាន ក៏នឹងត្រូវកើតដូច្នេះនោះឯង គឺគន្ធៈនោះផង ជាអាយតនៈផង ឈ្មោះថា គន្ធាយតនៈ រសនោះផងជាអាយតនៈផង ឈ្មោះថា រសាយតនៈ ព្រោះហេតុនោះ មិនអាចបដិសេធគន្ធាយតនៈនិងរសាយតនៈនោះឯង ។ ឯកពឡិង្គាកាហារមិនមានក្នុងរូបភូមិនោះ រមែងដឹងបានដោយព្រះបាលីថា **អាហារ ៣** ។ ព្រោះហេតុនោះ ទើបអាចារ្យទាំងឡាយពោលថា ការរាប់រូបគួរធ្វើដោយមិនខុសអំពីព្រះបាលី ។ កាលបើយ៉ាងនេះ ធម៌រមែងមិនជំទាស់គ្នា ។

ក្នុងអធិការនេះ ខ្ញុំនឹងពោលពាក្យឆ្លើយទុកដូច្នេះ ព្រោះរូបាវចរសត្វ មិនមានឃានាយតនៈ និងជិវ្ហាយតនៈ គន្ធៈ រស សូម្បីមាន ក៏មិនធ្វើកិច្ចរបស់អាយតនៈ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគទ្រង់មិនបានប្រារព្ធដល់គន្ធៈ រសទាំងនោះ ត្រាស់ទុកក្នុងព្រះបាលីជាដើមថា **អាយតនៈ ៥ រមែងប្រាកដ** ថា **អាយតនៈ ៦ រមែងប្រាកដ** ដូច្នេះ ហើយពាក្យថា **អាហារ ៣** ត្រាស់ទុកព្រោះមិនបានធ្វើកិច្ចរបស់អាហារ ពោលគឺការញ៉ាំងរូបដែលមានឱជាជាគម្រប់ ៨ ឲ្យតាំងឡើង ដោយមិនមានអាហារដែលគប្បីទំពាស៊ី ព្រោះមិនមានគន្ធៈ រស និងឱជា ទាំងអស់ ។ មិនបានត្រាស់សភាវធម៌ដែលជាអារម្មណ៍ និងសភាវធម៌ដែលមានកិច្ច ដោយការមិនមានសភាវធម៌ ដែល

ទទួលអារម្មណ៍បាន និងដោយការមិនមានកិច្ច ដោយប្រការដូច្នេះ ។ ពិតហើយ ក្នុងភពណា មិនមានសភាវធម៌ទទួលអារម្មណ៍បាន ក្នុងភពនោះ ក៏រមែងមិនមានភាវៈដែលសភាវធម៌ជាអារម្មណ៍ ជាអាយតនៈដោយត្រង់ ដែលមានសភាវធម៌ទទួលអារម្មណ៍បាននោះជាហេតុ ព្រោះហេតុនោះ សភាវធម៌ដែលមាន លោកក៏មិនបានពោលទុកដូចជាដោយភាវៈដែលបឋវីធាតុ តេជោធាតុ វាយោធាតុ ជាផោដ្ឋព្វាយតនៈនៅក្នុងរូបភពនោះឯង ។ ម្យ៉ាងទៀត សភាវធម៌ណា ដែលលោកបានពោលទុកក្នុងភពណា សភាវធម៌នោះជាអាយតនៈដោយត្រង់ ដែលមានសភាវធម៌ទទួលអារម្មណ៍បានជាហេតុ លោកពោលទុកក្នុងភពនោះ ដូចពោលភាវៈនៃរូបាយតនៈទុកក្នុងរូបភពនោះឯង ។

សេចក្តីនេះបើមានបុគ្គលសង្ស័យសួរចូលមកថា បើសភាវធម៌ដែលជាអារម្មណ៍ជាអាយតនៈដោយត្រង់ ដែលមានសភាវធម៌ទទួលអារម្មណ៍បានជាហេតុសោតអាយតនៈ ២ នឹងប្រាកដដល់ពួកអសញ្ញីសត្វ បានដូចម្តេចហ្ន៎ ព្រោះថា អសញ្ញីសត្វមិនមានចក្ខាយតនៈ និងរូបាយតនៈរបស់អសញ្ញីសត្វទាំងនោះ ក៏មិនជាវិស័យរបស់សត្វដទៃ ដោយភាវៈដែលមិនមានចក្ខាយតនៈ ? ឆ្លើយថា សេចក្តីនេះមិនខុសអ្វីឡើយ ។ គន្ធាយតនៈជាដើមរបស់ពួកសត្វដែលមានសញ្ញាក្នុងរូបធាតុ លោកមិនបានពោលទុកដោយបំណងឯណា សូម្បីរូបាយតនៈ លោកក៏មិនបាន ពោលទុកដោយបំណងនោះ ព្រោះហេតុនោះ ទើបពួកអសញ្ញីសត្វគួរពោលទុកអាយតនៈ ១ ។ សេចក្តីពិត ភាវៈដែលសភាវធម៌ពួកណាជាអាយតនៈដោយត្រង់ មានក៏ដោយការសម្ព័ន្ធដល់ភាពជាឥន្ទ្រិយរូប និងគោចររូបតាមសមគួរដល់ខ្លួន ។ កាលលម្អិតសភាវធម៌ទាំងនោះ សភាវធម៌ទាំងនោះក៏មិនមាន ដូច្នោះ ទើបលោកមិនពោលសភាវធម៌ មានគន្ធៈជាដើមរបស់ពួកសត្វ ដែលមានសញ្ញាក្នុងរូបធាតុ ដោយជាអាយតនៈមួយផ្នែក បានពោលទុកក្នុងព្រះបាលីថា អាយតនៈ ៥ ធ្វើឲ្យឈោងចុះក្នុងធម្មាយតនៈ ព្រោះមិនប្រព្រឹត្តទៅ

កន្លងសភាវៈនៃធម៌ និងព្រោះចូលដល់ភាពជាអារម្មណ៍របស់មនោវិញ្ញាណ ។ ក៏ដើម្បីប្រយោជន៍នេះ ទើបលោកធ្វើការតាំងឈ្មោះទុក ដោយសទ្ទតថា **ធម្មាយតនៈ** ម្យ៉ាងទៀត លោកពោលថា **អាយតនៈ ៥** ធ្វើអាយតនៈទាំងនោះឲ្យវិលមកខាងក្រោយ ។

លោកពោលរូបាយតនៈរបស់ពួកអសញ្ញីសត្វ ដោយបំណងណា ក៏គួរធ្វើការកាន់យកអាយតនៈមានគន្ធៈជាដើមសូម្បីរបស់ពួកសត្វដែលមានសញ្ញាទុកមួយផ្នែកដោយបំណងនោះ ព្រោះហេតុនោះ ទើបព្រះសាស្តាត្រាស់ថា **អាយតនៈ ២ រមែងប្រាកដដល់ទេវតាពួកអសញ្ញីសត្វ** ដូច្នេះ ដើម្បីសម្ដែងន័យនេះ ។ កាលឥន្ទ្រិយរបស់ខ្លួនក្នុងពួកអសញ្ញីសត្វនោះ សូម្បីមិនមានការឈានកន្លងសភាវៈនៃវណ្ណាយតនៈនៃរូបក៏មិនមានដូចគ្នាដូច្នោះ ទើបវណ្ណាយតនៈនោះ លោកហៅថា រូបាយតនៈនោះឯង ។ និងដោយការសម្ដែងន័យនេះ លោកបន្ថែមអាយតនៈ ៣ មានគន្ធៈជាដើមចូលទៅ ទើបជាការសម្ដែងអត្ថនេះថា របស់ពួកសត្វដែលមានសញ្ញា មានអាយតនៈ ៨ របស់ពួកអសញ្ញីសត្វ មានអាយតនៈ ៥ ។ និងគួរទទួលសេចក្ដីនេះទុកយ៉ាងនេះ កាលនឹងកាន់យកអត្ថដោយប្រការដទៃ កាលលាន់ឮនូវវាចារបស់ពួកព្រហ្មនោះឯងក៏មិនគប្បីមាន ព្រោះភាពដែលធាតុទាំងឡាយ មានបឋវីជាដើមជាធម្មជាតិ មិនគប្បីអាចពាល់ត្រូវបានក្នុងរូបាវចរលោក ។ ពិតហើយ ការប្រព្រឹត្តទៅនៃសំឡេងនឹងមានដោយចន្លោះនៃការប៉ះខ្ទប់ និងការពាល់ត្រូវក៏មិនមាន ហើយនឹងអាចដឹងបាន ព្រោះភាវៈគឺសម្ពស្សមិនបានក្នុងធម៌ណាមួយនៃធម៌ទាំងឡាយ ដែលមានសម្ពស្សជាសភាវៈក៏មិនមាន ។ មួយទៀត សោត កាលមិនមានកូតរូបទាំង ៣ ពោល គឺផោដ្ឋព្វាយតនៈក៏មិនគប្បីមានការកើតនៃអាយតនៈទាំងឡាយ មានរូបាយតនៈជាដើមក្នុងរូបភពនោះឯង ។ ព្រោះដូច្នោះ ទើបលោកមិនពោលភាវៈនៃអាយតនៈទាំងឡាយ មានរូបាយតនៈជាដើម ទាំងនោះជាផោដ្ឋព្វៈ ដោយការមិនមានកាយិន្ទ្រិយក្នុងរូបភពនោះ ព្រោះបឋវី

ធាតុជាដើម ជាធម្មជាតិដែលអាចពាល់ត្រូវបាន និងព្រោះធ្វើអធិប្បាយយ៉ាងនេះ រមែងជាការយល់ព្រម ការពោលអាយតនៈទាំងឡាយ មានរូបាយតនៈជាដើមនោះ មានការប៉ះខ្ទប់បានក្នុងរូបធាតុ សេចក្តីនេះ សមដូចព្រះបាលីដែលត្រាស់ទុកថា **មហាភូតរូប ២ អាស្រ័យមហាភូតរូប ១ ដែលមិនមានការឃើញបាន តែមានការប៉ះខ្ទប់បាននៃពួកអសញ្ញីសត្វ** ដូច្នេះជាដើម ។

ដែលឈ្មោះថា **ការប៉ះខ្ទប់** បានដល់ ភាវៈដែលមហាភូតរូបទាំង ៣ ជួបគ្នាតាមទ្វារដែលប៉ះខ្ទប់ភូតរូប ដែលមានមហាភូតរូបទាំង ៣ នោះជាទីអាស្រ័យ កាលមានកាយបសាទ ក្នុងទីនេះ បានដល់ភាវៈដែលមានសភាពដូច្នោះ ។ ឯការប៉ះខ្ទប់នោះឈ្មោះថា **មិនមាន** ព្រោះមិនមានការប៉ះខ្ទប់សភាវៈដែលមិនអាចពាល់ត្រូវ បានសួរថា បើកាលសភាវធម៌ដែលទទួលអារម្មណ៍បាន សូម្បីមិនមាននៅក្នុងអសញ្ញីសត្វនោះ ព្រះមានព្រះភាគទ្រង់កាន់យករូបាយតនៈ ត្រាស់ថា **អាយតនៈ ២** ដូច្នេះ កាលបើដូច្នេះ ព្រោះហេតុអ្វី ទើបព្រះអង្គទ្រង់មិនកាន់យកអាយតនៈ មានគន្ធាយតនៈជាដើម ហើយត្រាស់ថា **អាយតនៈ ៥** ដូច្នេះទៅវិញ ? ឆ្លើយថា ទេសនាប្រព្រឹត្តទៅដោយអំណាចការសម្តែងជាន័យទុក ព្រោះហេតុនោះ ទើបអត្ថនេះត្រូវបានពោលទុកហើយនោះឯង ។ ប្រការមួយទៀត ការពោលរូបាយតនៈតែម្យ៉ាងក្នុងពួកអសញ្ញីសត្វនោះ សំដៅយកភាពជាអារម្មណ៍ នៃបសាទរបស់ព្រហ្មដែលនៅក្នុងភូមិដទៃក្នុងគ្រាខ្លះ តែមិនមែនអាយតនៈក្រៅអំពីនេះឡើយ ទាំងមិនមែនការមាន និងការមិនមាននៃអាយតនៈ សូម្បីដោយបរិយាយ ។ ព្រោះថា រូបាយតនៈ របស់ពួកអសញ្ញីសត្វ រមែងដល់នូវភាពជាអារម្មណ៍នៃបសាទរបស់ពួកព្រហ្មជាន់វេហប្ផលាដែលនៅក្នុងជាន់ស្មើគ្នា និងរបស់ពួកព្រហ្មជាន់សុទ្ធាវាស ដែលនៅក្នុងភូមិដែលខ្ពស់ជាង តែគន្ធៈនិងរស មិនដល់នូវភាពជាអារម្មណ៍ឡើយ ព្រោះហេតុនោះ ការដែលលោកមិនពោលគន្ធាយតនៈ

ជាដើមនោះឯងទុកក្នុងពួកអសញ្ញីសត្វនោះ ប្រពៃហើយ ។ ក្នុងកថាវត្ថុបករណ៍ ព្រះមោគ្គលីបុត្តតិស្សត្ថេរ បានធ្វើការបដិសេធទុក សំដៅដល់បុគ្គលទទួលដឹងភាវៈដែលមាននៃគន្ធាយតនៈជាដើម ដោយនិប្បរិយាយ ។

សួរថា ការពោលនេះមិនជាការសម្តែងដល់ការមិនមាននៃគន្ធាយតនៈជាដើមក្នុងពួកអសញ្ញីសត្វនោះដោយពិត សូម្បីយ៉ាងនោះ ការពោលរឿងដទៃសូម្បីដល់ភាវៈដែលមាន ក៏មិនមានដូចគ្នាមែនឬ ? ឆ្លើយថា សេចក្តីនេះ លោកមិនគួរឃើញយ៉ាងនោះ ព្រោះក្នុងអដ្ឋកថាទាំងឡាយ លោកបានពោលពន្លឹកគន្ធាយតនៈជាដើមទាំងនោះមានក្នុងពួកអសញ្ញីសត្វនោះ ។ ឯក្នុងពាក្យអដ្ឋកថា មិនខុសអំពីព្រះបាលីពាក្យក្នុងអដ្ឋកថានោះ ក៏ជាប្រមាណដូចព្រះបាលី ព្រោះបន្តអំពីអាចារ្យដែលមិនគួរតិះដៀលមករហូតដរាបដល់សព្វថ្ងៃនេះ ក្នុងសេចក្តីនោះ គប្បីមានបុគ្គលសង្ស័យ សួរថា ពាក្យក្នុងអដ្ឋកថាមិនខុសអំពីព្រះបាលី ពាក្យក្នុងអដ្ឋកថានោះ ជាប្រមាណ តែពាក្យក្នុងអដ្ឋកថានេះខុសមិនមែនឬ ? សេចក្តីនេះ មិនគួរឃើញយ៉ាងនោះ ព្រោះលោកធ្វើឲ្យប្រព្រឹត្តទៅដោយមិនខុស ព្រះសាស្តាទ្រង់សម្តែងធាតុទេសនា ក៏ដើម្បីទ្រង់បង្អួលភាពទទេចាកសត្វនៃអាយតនៈ មានចក្ខុជាដើម និងនៃវិញ្ញាណ ដែលមានអាយតនៈនោះជាទីអាស្រ័យ ព្រោះហេតុនោះ ការដែលមិនត្រាស់អាយតនៈទាំងនោះទុក រមែងត្រឹមត្រូវនោះឯង ព្រោះទ្រង់សម្តែងភាវៈនៃធាតុរបស់អាយតនៈទាំងឡាយ ដែលត្រាស់ទុកដោយជាអាយតនៈនោះឯង ។ ព្រោះដូច្នោះ កាលរាប់របក្នុងទីនេះ ទើបលោកធ្វើដោយអំណាចចក្ខុទសកៈជាដើម ដោយមិនខុសអំពីព្រះបាលី ព្រោះហេតុនោះ គប្បីជ្រាបថា មិនមែនជាឱកាសក្នុងការសង្ស័យ ដែលមកជំទាស់ចំពោះធម្មតាក្នុងទីនេះ ។

ពាក្យថា **ក្នុងពួកសត្វដែលកើតក្នុងកំណើតសំសេទជៈ និងឱបបាតិកៈជំពូកដទៃ** បណ្ឌិតគប្បីជ្ជាប់សេចក្តីក្នុងពាក្យនេះយ៉ាងនេះថា ក្នុងពួកសត្វជំពូកឱបបាតិកៈ

ពួកដទៃ វៀរពួករូបព្រហ្ម និងក្នុងពួកសត្វសំសេទជៈ ។ ព្រោះថា ស័ព្ទដទៃក្នុងទីនេះ ធ្វើឲ្យសត្វពួកឱបបាតិកៈផ្សេងចេញទៅ មិនមែនធ្វើឲ្យសត្វពួកសំសេទជៈផ្សេងចេញទៅ ព្រោះមិនមានការកើត ។ កាលការកើតមាន រមែងមានភាវៈនៃការធ្វើឲ្យផ្សេងចេញទៅ និងវត្ថុដែលគប្បីធ្វើឲ្យផ្សេងចេញទៅ ព្រោះការប្រព្រឹត្តទៅផ្សេងគ្នាផង ។ លោកអាចារ្យ ពោលថា **រូប ៧០ នោះ រមែងកើតឡើងក្នុងជំពូកទេវតាជានិច្ច** ដូច្នេះ ។ ព្រោះ សន្តតិតាមដែលពោលហើយ ក្នុងបដិសន្ធិកាល និងបវត្តិកាល បានដល់ រូបសព្វកាល ទាំងពួងក្នុងជំពូកទេវតាជាន់កាមាវចរ ព្រោះថា ទេវតាទាំងនោះជាអ្នកមានឥន្ទ្រិយមិន បរិបូណ៌ និងមិនមានភាវៈក្នុងកាលខ្លះនោះឡើយ ។ ក្រុមរូប ឈ្មោះថា **ចក្ខុទសកៈ** ព្រោះធ្វើអធិប្បាយថា មានចក្ខុពេញត្រឹមរូបទាំង ១០ នោះ ម្យ៉ាងទៀត ទសកៈដែល កំណត់ដោយចក្ខុមិនទូទៅ ឈ្មោះថា **ចក្ខុទសកៈ** ។ ពាក្យថា **ទសកៈដ៏សេសគប្បី ជ្រាបដោយន័យយ៉ាងនេះ** សេចក្តីថា ទសកៈដ៏សេសក៏គប្បីជ្រាបដោយប្រកបដូច ចក្ខុទសកៈ ។ លោកអាចារ្យកាលនឹងបើកផ្សារអត្ថដែលលោកពោលទុកដោយសង្ខេប ថា **ក្នុងពួកសត្វដែលកើតក្នុងសំសេទជកំណើត និងឱបបាតិកៈ ពោលយ៉ាងទាប រូប ៣០** ដូច្នេះ ទើបពោលពាក្យថា **ចំណែកពោលយ៉ាងទាប** ដូច្នេះជាដើម ។ ឯពាក្យ នោះមិនសមជាមួយព្រះបាលី ព្រោះថា ក្នុងព្រះបាលីមិនបានត្រាស់ការកើតឡើងរបស់ ពួកសត្វ ដែលមិនមានឃានៈ ក្នុងកំណើតសំសេទជៈ និងឱបបាតិកៈជាន់កាមាវចរ ពិតហើយ ក្នុងធម្មហទយវិភង្គ ត្រាស់ទុកថា **ក្នុងខណៈកើតឡើងក្នុងកាមធាតុ សត្វខ្លះប្រាកដអាយតនៈ ១១ សត្វខ្លះប្រាកដ អាយតនៈ ១០ សត្វខ្លះប្រាកដអាយតនៈ ១០ ដទៃទៀត សត្វខ្លះប្រាកដអាយតនៈ ៩ សត្វខ្លះប្រាកដអាយតនៈ ៧** មិនបាន ត្រាស់ថា **ប្រាកដអាយតនៈ ៨** នោះឡើយ ។ ព្រោះប្រសិនបើសត្វដែលមិនមានឃានៈ គប្បីមានការកើតឡើង ក៏ប្រពៃ ដែលគប្បីត្រាស់ថា **ប្រាកដអាយតនៈ ១០** ដូច្នេះ ៣

ការៈ និងថា **ប្រាកដអាយតនៈ ៩** ដូច្នេះ ៣ ការៈ តែមិនបានត្រាស់ដូច្នោះឡើយ ។

ក្នុងបណ្តាពាក្យទាំងនោះ ពាក្យថា **ក្នុងខណៈកើតឡើង** បានដល់ ក្នុងខណៈបដិសន្ធិ ។ ពាក្យថា **អាយតនៈ ១១** បានដល់ អាយតនៈ ១១ វៀរសទ្ទាយតនៈរបស់សត្វដែលមានអាយតនៈគ្រប់ចំនួន ។ ពាក្យថា **សត្វខ្លះប្រាកដអាយតនៈ ១០** គឺសត្វខ្វាក់ប្រាកដអាយតនៈ ១០ វៀរចក្ខាយតនៈ ។ ពាក្យថា **សត្វខ្លះប្រាកដ អាយតនៈ ១០ ដទៃទៀត** គឺសត្វថ្លង់ប្រាកដអាយតនៈ ១០ វៀរសោតាយតនៈ ។ ពាក្យថា **ប្រាកដអាយតនៈ ៩** បានដល់ សត្វទាំងខ្វាក់ទាំងថ្លង់ ប្រាកដអាយតនៈ ៩ វៀរចក្ខាយតនៈនិងសោតាយតនៈ ។ ពាក្យថា **ប្រាកដអាយតនៈ ៧** ត្រាស់ទុកដោយអំណាចរូបាយតនៈគន្ធាយតនៈ រសាយតនៈ កាយាយតនៈ ផោដ្ឋព្វាយតនៈ មនាយតនៈ និងធម្មាយតនៈនៃសត្វដែលជាគព្ភសេយ្យក ។ បើការវិកលនៃចក្ខុ សោតៈ ហើយឃានៈគប្បីកើតឡើងគព្ភសេយ្យកសត្វនោះ ក៏គប្បីមាន អាយតនៈ ៨ ប៉ុណ្ណោះ តែមិនត្រាស់ថា **ប្រាកដអាយតនៈ ៨** ដូច្នេះឡើយ ។ ព្រោះហេតុនោះ ទើបការវិកលចក្ខុ សោតៈ និងឃានៈមិនមាននោះឯង ។ ម្យ៉ាងទៀត កាលការកើតឡើងនៃសត្វដែលមិនមានឃានៈ មានក៏ប្រពៃ ដែលនឹងត្រាស់ដដែលទៀតថា **សត្វពួកខ្លះប្រាកដអាយតនៈ ១០ ដទៃទៀត** ដូច្នេះ ។ អធិប្បាយថា ម្យ៉ាងទៀត កាលបើយ៉ាងនោះ ក៏ប្រពៃ ដែលនឹងពោលថា **បើយ៉ាងនោះ សត្វខ្លះក៏ប្រាកដអាយតនៈ ៩ ដទៃទៀត សត្វខ្លះក៏ប្រាកដអាយតនៈ ៩ ដទៃទៀត** ដូច្នេះ ដោយអំណាចសត្វទាំងខ្វាក់ទាំងដែលមិនមានឃានៈ និងសត្វទាំងថ្លង់ ទាំងដែលមិនមានឃានៈ ដូចដែលត្រាស់ទុកគ្រាមួយថា **សត្វខ្លះ រមែងប្រាកដអាយតនៈ ៦ យ៉ាង** ដូច្នេះ ដោយអំណាចសត្វទាំងខ្វាក់ទាំងថ្លង់ អាចារ្យទាំងឡាយរមែងពោលថា គួរពោលបញ្ហារឿងការប្រាកដនៃធាតុជាដើមយ៉ាងនេះ ។ ក្នុងអធិការនេះ បទថា **ដោយចំណែកខ្ពស់ រូប ៧០** ដូច្នេះ លោកប្រកបទុកដោយអំណាច

កំណើតទាំង ២ ក្នុងពាក្យនេះថា ក្នុងកំណើតសត្វដែលជាសំសេទជៈ និងឱបបាតិកៈ យ៉ាងណា ពាក្យថា ដោយចំណែកយ៉ាងទាប រូប ៣០ នេះ មិនប្រកបដូច្នោះឡើយ ។ ឯពាក្យនេះគួរប្រកបដោយអំណាចសំសេទជកំណើតតែម្យ៉ាង ។ ចំណែកមួយសូម្បីរបស់ពាក្យដែលសម្ដែងហើយដោយការប្រកបតែមួយ រមែងបានការភ្ជាប់គ្នា ព្រោះហេតុនោះ ទើបក្នុងពាក្យនេះ មានអធិប្បាយក្នុងអដ្ឋកថាដូច្នេះថា លោកពោលថា រូប ៣០ រមែងកើតដោយអំណាចជិវ្ហាទសកៈ កាយទសកៈ និងវត្ថុទសកៈរបស់សត្វដែលខ្វាក់អំពីកំណើត ថ្លង់អំពីកំណើត និងមិនមានឃានៈ និងខ្ទើយអំពីកំណើត ដែលជាសំសេទជៈ មិនមែនជាឱបបាតិកៈ ។

ចំណែកលោកអាចារ្យពួកណា រមែងពោលថា ក្នុងមហាអដ្ឋកថា លោកពោលទុកថា រូប ៣០ រមែងកើតដោយអំណាចជិវ្ហាទសកៈ កាយទសកៈ និងវត្ថុទសកៈរបស់សត្វដែលជាខ្ទើយ ដែលខ្វាក់អំពីកំណើត ថ្លង់អំពីកំណើត និងមិនមានឃានៈអំពីកំណើត ជាឱបបាតិកៈ ពាក្យនោះ មិនគួរកាន់យក ។ ព្រោះបាឋៈនោះ ជាបាឋៈដែលសរសេរដោយការភាំងភាត់ ។ ព្រោះធ្វើអធិប្បាយយ៉ាងនេះ ក្នុងវណ្ណនាអាយតនយមកៈ ទើបលោកពោលទុកថា ក្នុងកាមធាតុ ឱបបាតិកសត្វដែលមិនមានឃានៈ រមែងមិនមាន ។ បើគប្បីមាន ព្រះមានព្រះភាគក៏គប្បីត្រាស់ថា សត្វខ្លះរមែងប្រាកដអាយតនៈ ៨ ដូច្នេះ ។ ចំណែកអាចារ្យមួយពួកពោលទុកថា ព្រះបាលីថា សត្វខ្លះរមែងប្រាកដអាយតនៈ ១១ ទៅរហូតដល់ថា សត្វខ្លះរមែងប្រាកដអាយតនៈ ៩ ដូច្នេះ ត្រាស់សំដៅយកសត្វពួកឱបបាតិកៈ ។ ព្រោះហេតុនោះ ក្នុងអដ្ឋកថា ទើបយល់សេចក្ដីមិនជំទាស់ទាំងពាក្យដើម និងពាក្យចុង ។ ហើយការពណ៌នានៃព្រះបាលីតាមដែលពោលហើយនេះ រមែងប្រៀបធៀបគ្នាបាន សមគ្នាបានដោយពិត ។ ចំណែកពាក្យណា ដែលអាចារ្យមួយពួកពោលថា សូម្បីសត្វពពួកសំសេទជៈ ក៏

**សង្គ្រោះចូលដោយសព្ទថា ឱបបាតិកៈ** ។ ពិតយ៉ាងនោះ ក្នុងធម្មហទយវិភង្គ ទ្រង់ក៏ធ្វើសព្ទថា ឱបបាតិកៈនោះឯង ដោយពាក្យថា **ឱបបាតិកានំ បេតានំ** ជាដើម ប្រែថា ប្រេតដែលជាឱបបាតិកៈ **ទុកក្នុងនិទ្ទេស** នៃពាក្យជាដើមថា **ក្នុងខណៈកើតឡើងក្នុងកាមធាតុ សត្វខ្លះរមែងប្រាកដអាយតនៈ ១១** ទ្រង់មិនបានធ្វើសព្ទថា សំសេទជៈនោះឡើយ ដូច្នេះ ពាក្យនោះ គប្បីជ្រាបថា លោកពោលទុកដោយអំណាចការរួបរួមសត្វ ជំពូកសំសេទជៈ ដែលមានអាយតនៈគ្រប់ចំនួននោះឯង ទុកក្នុងសត្វជំពូកឱបបាតិកៈ ។ ពិតយ៉ាងនោះ ក្នុងអដ្ឋកថា លោកពោលទុកថា **សត្វជំពូកសំសេទជកំណើត លោកពោលធ្វើការរួមទុកដោយឱបបាតិកៈ ដោយភាវៈដែលមានអាយតនៈគ្រប់ចំនួន និងមានអាយតនៈមិនគ្រប់ចំនួន** និងម្យ៉ាងទៀតថា **លោកពោលថា ឱបបាតិកៈ** ដូច្នេះ ដើម្បីនឹងសម្តែងកំណើតសត្វ ដែលមានអាយតនៈគ្រប់ចំនួនទាំងអស់ ដោយកំណើតជាប្រធាន តែពោលក្នុងទីនេះថា **ក្នុងកំណើតសត្វជំពូកសំសេទជៈ និងឱបបាតិកៈ** ដូច្នេះ មិនបានរួមកំណើត ក្រៅអំពីនេះទុកដោយឱបបាតិកកំណើត ក៏ដើម្បីប្រកាសកំណើតទាំង ២ ទុកដោយសរុបនោះឯង និងដើម្បីសម្តែងការប្រព្រឹត្តទៅនៃរូបដោយកំណើតយ៉ាងទាប ដោយអំណាចកំណើតសំសេទជៈនោះឯង ។ ពាក្យទាំងអស់នោះគួរពិចារណាហើយកាន់យកចុះ ។

ពាក្យថា **ម្យ៉ាងទៀត ក្នុងចន្លោះរូបយ៉ាងច្រើន និងរូបយ៉ាងតិច** គឺក្នុងកណ្តាលការកំណត់យ៉ាងច្រើន និងយ៉ាងតិច នៃរូបដែលលោកពោលទុកយ៉ាងនេះថា **រូប ៧០, ៣០** ដូច្នេះ ។ ពាក្យថា **គប្បីជ្រាបការកំណត់តាមសមគួរ** គឺគប្បីជ្រាបការកំណត់តាមន័យជាដើមយ៉ាងនេះ គឺក្នុងអបាយសម្រាប់បុគ្គលខ្វាក់ មាន ៦ ព្រោះមិនមានចក្ខុទសកៈ សម្រាប់បុគ្គលថ្លង់ក៏មាន ៦ ដូចគ្នា ព្រោះមិនមានសោតទសកៈ ។ ម្យ៉ាងទៀត សម្រាប់បុគ្គលទាំងខ្វាក់ទាំងថ្លង់មាន ៥ ព្រោះមិនមានចក្ខុទសកៈ និង

សោតទសកៈ ។ ឯពាក្យណាដែលគួរពោលក្នុងទីនេះ ពាក្យនោះ ខ្ញុំបានពោលទុកហើយ ដូច្នេះ ។

ចុតិ និងបដិសន្ធិ ជាធម្មជាតិដូចគ្នានឹងគ្នា ដោយខន្ធជាដើម ឈ្មោះថា **ការមិនបែកផ្សេងគ្នា** ។ ភាពជាធម្មជាតិមិនដូចគ្នា ឈ្មោះថា **ការបែកផ្សេងគ្នា** ។

ពាក្យថា **មិនបែកផ្សេងគ្នា សូម្បីដោយអារម្មណ៍** លោកអាចារ្យពោលដោយអំណាចសត្វដែលចុតិចាកភូមិនោះៗ ក្នុងអរូប ៤ ហើយកើតក្នុងភូមិនោះៗ ឯង ។ ម្យ៉ាងទៀត លោកពោលទុកដោយអំណាចសត្វដែលកើតក្នុងភូមិដែលទាបជាងយ៉ាងនោះៗ ឯង ម្យ៉ាងទៀត ការកើតក្នុងរូបភព រមែងមិនមាន ។ ធម្មតាការចុតិអំពីអរូបភូមិហើយ កើតក្នុងភូមិដែលទាបជាង គឺកើតក្នុងកាមភពនោះឯង សូម្បីក្នុងកាមភពនោះ ក៏ជាបដិសន្ធិដែលជាតិហេតុកៈនោះឯង ។ អាចារ្យទាំងឡាយ រមែងពោលថា **សត្វដែលចុតិអំពីរូបភព ជាទុហេតុកៈក៏មាន ។ បដិសន្ធិដែលមានអារម្មណ៍ជាមហគ្គតៈ និងជាខាងក្នុង** បានដល់ អរូបបដិសន្ធិទី ២ និងទី ៤ មានឡើងក្នុងលំដាប់នៃ **ចុតិដែលមានអារម្មណ៍មិនជាមហគ្គតៈ និងជាខាងក្រៅ** លោកអាចារ្យបានរួមយកពាក្យទាំងអស់ដែលបានពោលទុក និងមិនបានពោលទុក ពោលថា **នេះជាន័យក្នុងពួកអរូបភូមិប៉ុណ្ណោះសិន** ដូច្នេះ ព្រោះលោកបានសម្ដែងត្រឹមន័យទុកដោយប្រការដូច្នេះ ។ ព្រោះឧបចារៈនៃរូបាវចរជ្ឈាន និងអរូបាវចរជ្ឈានមានកម្លាំង ការចុតិអំពីភូមិនោះហើយកើតក្នុងទុគ្គតិរមែងមិនមាន ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **នៃសុគតិចុតិខ្វះ ។** ក្នុងពាក្យថា **ទុគ្គតិបដិសន្ធិខ្វះ** នេះ គួរស្វែងរកការប្រកបស័ព្ទថា **ខ្វះ** ។ ក្នុងសេចក្ដីនេះ គប្បីមានអធិប្បាយដូច្នេះ ពួកវិនិបាតិកពួកខ្វះដែលលោកពោលទុកក្នុងពួកសត្វដែលមានកាយផ្សេងគ្នា មានសញ្ញាផ្សេងគ្នា មានបដិសន្ធិជាដើមថា តិហេតុកបដិសន្ធិ ហើយបដិសន្ធិនោះ រមែងមានក្នុងលំដាប់នៃសុគតិចុតិទាំងអស់ ព្រោះកាន់

យកបដិសន្ធិរបស់ពួកវិនិបាតិកៈទាំងនោះថា **ជាទុគ្គតិបដិសន្ធិ** ដោយភាពជាវិនិបាតិកៈ មិនមែនមានក្នុងលំដាប់នៃសុគតិចុតិខ្លះប៉ុណ្ណោះ ព្រោះហេតុនោះ ទើបលោកធ្វើស័ព្ទថា **ទុគ្គតិខ្លះ** ដើម្បីបដិសេធនូវអត្ថនោះ ។ ពិតហើយ អបាយបដិសន្ធិប៉ុណ្ណោះ រមែងមានក្នុងលំដាប់នៃសុគតិចុតិខ្លះ មិនមែនមានក្នុងលំដាប់នៃសុគតិចុតិគ្រប់យ៉ាងនោះឡើយ ។ ម្យ៉ាងទៀត ទុគ្គតិបដិសន្ធិមាន ២ យ៉ាង គឺមានក្នុងលំដាប់នៃសុគតិចុតិ ១ មានក្នុងលំដាប់នៃទុគ្គតិចុតិ ១ ។ ក្នុងទុគ្គតិបដិសន្ធិទាំង ២ នោះ លោកអាចារ្យវៀរបដិសន្ធិខាងក្រោយចេញហើយ ពោលថា **ទុគ្គតិបដិសន្ធិខ្លះ** ដើម្បីកាន់យកបដិសន្ធិដំបូងនោះប៉ុណ្ណោះ ។ ពាក្យថា **សហេតុកបដិសន្ធិមានក្នុងលំដាប់នៃអហេតុកចុតិ** បណ្ឌិតគប្បីប្រកបទុហេតុកបដិសន្ធិ និងតិហេតុកបដិសន្ធិ ។ ព្រោះថា តិហេតុកបដិសន្ធិក៏រមែងមានក្នុងលំដាប់នៃអហេតុកចុតិ ដូចការបដិសន្ធិរបស់មណ្ឌូកទេវបុត្រជាដើម ដូច្នេះ ។

ពាក្យថា **ម្យ៉ាងទៀត** គប្បីប្រកបពាក្យចូលតាមដែលគួរប្រកបបាន ដោយពាក្យផ្ទុយគ្នានៃបទនោះៗ ចុះ សេចក្តីថា ក្នុងសេចក្តីប្លែកគ្នានៃការបែកផ្សេងគ្នាទាំងឡាយមានជាដើមថា **ទុគ្គតិបដិសន្ធិខ្លះ មានក្នុងលំដាប់នៃសុគតិចុតិខ្លះ** ដូច្នេះ ពាក្យណាមួយ ដែលលោកប្រកបទុកដោយពាក្យជាដើមថា **សុគតិបដិសន្ធិខ្លះ មានក្នុងលំដាប់នៃទុគ្គតិចុតិខ្លះ** ដូច្នេះ គួរប្រកបពាក្យនោះៗ ។ លោកធ្វើនិទ្ទេសជានបុំសកលិង្គទុកដោយអំណាចការសម្លឹងត្រឹមពាក្យដែលប្រកបទុក ។ ម្យ៉ាងទៀត អត្ថនៃភាវៈ បណ្ឌិតគប្បីឃើញដោយបទថា **យោជេតព្វំ** ។ តែមិនគួរធ្វើការប្រកបពាក្យដែលផ្ទុយគ្នាក្នុងពាក្យជាដើមថា **បដិសន្ធិដែលជាមហគ្គតៈ មានអារម្មណ៍ជាខាងក្នុង មានក្នុងលំដាប់នៃចុតិ ដែលមិនមែនជាមហគ្គតៈ មានអារម្មណ៍ជាខាងក្រៅ** ។ ព្រោះថា បដិសន្ធិដែលមិនមែនជាមហគ្គតៈមានអារម្មណ៍ជាខាងក្រៅ និងមាននៅក្នុងអរូបភូមិក្នុងលំដាប់

នៃចុតិដែលជាមហគ្គតៈ មិនមានអារម្មណ៍ជាខាងក្នុងទេ ។ ការផ្ទុយគ្នារបស់ពាក្យនេះថា **កាមាវចរបដិសន្ធិដែលមានខន្ធ ៥ មានក្នុងលំដាប់នៃអរូបចុតិ ដែលមានខន្ធ ៤ លោកប្រកបហើយនោះឯង** ។ ចំណែកការផ្ទុយគ្នារបស់ពាក្យនេះថា **បដិសន្ធិមានអារម្មណ៍ជាបច្ចុប្បន្ន មានក្នុងលំដាប់នៃចុតិ ដែលមានអារម្មណ៍ជាអតីត** ដូច្នេះមិនមាននោះឯង ។ ឯការបែកផ្សេងគ្នានោះឯង លោកបានសម្ដែងហើយ ដោយពិស្ដារយ៉ាងនេះ ចំណែកការបែកដែលមិនផ្សេងគ្នា បណ្ឌិតគប្បីជ្រាបដោយអំណាចពាក្យប្រកបចុតិ និងបដិសន្ធិក្នុងភូមិនោះៗ ឯង ក្នុងការបែកផ្សេងគ្នាតែម្យ៉ាងថា **កាមាវចរបដិសន្ធិដែលមានខន្ធ ៥ មានក្នុងលំដាប់នៃកាមាវចរចុតិដែលមានខន្ធ ៥ ។បេ។ បដិសន្ធិដែលមិនមានវិតក្ក មិនមានវិចារៈ មានក្នុងលំដាប់នៃចុតិ ដែលមិនមានវិតក្កមិនមានវិចារៈ** ។ ឯបដិសន្ធិដែលមានខន្ធ ៤ មានក្នុងលំដាប់នៃចុតិដែលមានខន្ធ ៤ លោកប្រកបហើយនោះឯង សេចក្ដីបែកផ្សេងគ្នា ការបែកគ្នានៃការមិនបែកផ្សេងគ្នាក្នុងបដិសន្ធិដែលមានខន្ធ ៥ ជាដើម លោកមិនបានសម្ដែងទុក ព្រោះអាចយល់បានដោយន័យនេះឯង ដូច្នេះឯង ។

បទថា **ឥតិ** សេចក្ដីប៉ុនគ្នានឹង **ឯវំ** ប្រែថា ដោយប្រការដូចពោលមកយ៉ាងនេះ ។ វិញ្ញាណនេះឈ្មោះថា **បានបច្ច័យ** ដោយអំណាចសង្ខារដែលប្រកបដោយហេតុដែលមានការផ្ញើរួមគ្នា មានអវិជ្ជាជាដើម ។ ឈ្មោះថា **ត្រឹមតែជារូបធម៌ អរូបធម៌** ព្រោះមិនមានធម៌ដែលតាំងជាអធិបតី ដែលលទ្ធិខាងក្រៅគិតគ្នាហើយ ។ ដោយហេតុនោះទើបអាចារ្យពោលថា **មិនមែនសត្វ មិនមែនជីវៈ** ។ អធិប្បាយថា **ហៅថា ចូលដល់** ត្រឹមតែជាវោហារយ៉ាងនោះ តែដោយអត្ថ ក៏ត្រឹមតែជាការកើតឡើងដោយជាភពដទៃព្រោះការដល់ព្រមនៃបច្ច័យ ។ ដោយហេតុនោះ ទើបអាចារ្យពោលពាក្យជាដើមថា **តែរបស់វា** ដូច្នេះ ។ ពាក្យថា **វៀរហេតុក្រៅអំពីអតីតភពនោះ** គឺវៀរហេតុក្នុង

អតីតភពនោះ ។ បទថា **មនុស្សចុតិបដិសន្ធិក្កមេន** សេចក្ដីថា ដោយតាមបន្ទុបដិសន្ធិនៃមនុស្សអំពីចុតិនៃមនុស្ស ។ ឯសព្ទថា **ប្បាកដ** ( ដែលឃើញបានច្បាស់ ) ជាពាក្យធ្វើឲ្យការចុតិ និងបដិសន្ធិទាំង ២ ផ្សេងគ្នា ដោយប្រការដូច្នេះ ។ ក្នុងសេចក្ដីនេះ ការៈដែលឃើញបានច្បាស់ក៏គប្បីជ្រាបដោយអំណាចខន្ធដែលជិតនឹងចុតិ និងបដិសន្ធិនោះ ដូចក្នុងពាក្យថា **ចវមានេឧប្បជ្ជមានេ** ជាដើម ដែលប្រែថា កាលកំពុងចុតិកំពុងឧប្បត្តិ ។ ម្យ៉ាងទៀត បទថា **មនុស្សចុតិបដិសន្ធិក្កមេន** ប្រែថា ដោយផ្លូវបន្តបដិសន្ធិនៃសត្វណានីមួយអំពីចុតិនៃមនុស្ស ។ ពិតយ៉ាងនោះ លោកអាចារ្យពោលតទៅថា **បានទីអាស្រ័យខ្វះ មិនបានខ្វះ** ដូច្នេះ ។

បទថា **សរសេន** ប្រែថា ដោយសភាវៈ អធិប្បាយថា ដោយមានអាយុសង្ខារអស់ទៅជុំវិញហើយ ។ បទថា **ឧបក្កមេន** សេចក្ដីថា ដោយសេចក្ដីព្យាយាមមានការកាត់ក្បាលជាដើមដែលខ្លួន ឬអ្នកដទៃធ្វើ ។ សរសៃដែលជាគ្រឿងចងទី.តនៃអវយវៈតូចធំទាំងពួង ឈ្មោះថា **សព្វង្គបច្ចង្គសន្ធិពន្ធនានិ** ដែលកាត់ផ្ដាច់នូវសរសៃដែលជាគ្រឿងចងនៃអវយវៈតូចធំទាំងពួងនោះ ។ បទថា **សន្និបាតំ** សេចក្ដីថា ការធ្លាក់ទៅ គឺការប្រព្រឹត្តទៅ ។ សូម្បីហទយបទេសក៏ស្ងួតស្វាំងទៅដោយលំដាប់សល់នៅតិចតួចនឹងពោលទៅថ្វីដល់កាយនោះ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **កាលសរីរៈស្ពាំងស្គមទៅដោយលំដាប់** ដូច្នេះ ។ ដោយហេតុនោះឯង ទើបលោកអាចារ្យពោលថា **អាស្រ័យហទយវត្ថុដ៏សេសចុះក្នុងខណៈនោះ** ។ ពាក្យថា **កាលឥន្ទ្រិយទាំងឡាយ មានចក្ខុជាដើមរលត់** នេះ លោកអាចារ្យពោលទុកដោយអធិប្បាយថា សូម្បីការរលត់នៃអាយតនៈទាំងឡាយរបស់គព្ភសេយ្យកសត្វទាំងឡាយក៏រមែងមានដោយលំដាប់ ដូចគ្នានឹងការកើតឡើងដោយលំដាប់ ម្យ៉ាងទៀត ពាក្យថា **រលត់** លោកពោលសំដៅយកការៈដែលចូលដល់ធម្មជាតិទន់យ៉ាងក្រៃលែង មិនមែន

ពោលសំដៅដល់ការរលត់ជាសមុច្ឆេទនោះឡើយ ។ព្រោះថាលោកសម្តែងចុតិទុកមុនក្នុងលំដាប់នៃវិញ្ញាណ ដែលប្រព្រឹត្តទៅក្នុងទ្វារទាំង ៥ ។ ពិតហើយ **ក្នុងយមកប្បករណ៍** ព្រះមានជោគបានត្រាស់ការរលត់នៃអាយតនៈ មានចក្ខាយតនៈជាដើមព្រមជាមួយចុតិចិត្តទុក ដោយព្រះតម្រាស់ជាដើមថា **ចក្ខាយតនៈរបស់សត្វណារមែងរលត់ទៅ មនាយតនៈរបស់សត្វនោះរមែងរលត់ទៅឬ** ? ត្រូវហើយ ។ ឬថា មនាយតនៈរបស់សត្វណារមែងរលត់ទៅ ចក្ខាយតនៈរបស់សត្វនោះក៏រមែងរលត់ទៅឬ ? មនាយតនៈរបស់សត្វទាំងនោះ ដែលមានចិត្តមិនមានចក្ខុ ដែលកំពុងចុតិរមែងរលត់ទៅ តែចក្ខាយតនៈរបស់សត្វ ទាំងនោះរមែងរលត់ទៅក៏មិនមែន ។ មនាយតនៈរបស់សត្វទាំងនោះ ដែលមានចក្ខុកំពុងចុតិរមែងរលត់ទៅ និងចក្ខាយតនៈក៏រមែងរលត់ទៅដូច្នេះ ។

ពាក្យថា **តែក្នុងហទយវត្ថុ** គឺតែក្នុងហទយវត្ថុបទេស ។ ឯកាយិន្ទ្រិយរមែងមិនអាស្រ័យហទយវត្ថុប្រព្រឹត្តទៅឡើយ ។ អាចារ្យទាំងឡាយរមែងពោលថា សូម្បីហទយវត្ថុ ក៏រមែងជាធម្មជាតិដែលនៅសល់តិច ដូចនៅក្នុងស្លឹកត្នោតខៀវ ដែលហាលកណ្តាលក្តៅ ដូច្នោះ ព្រោះដូច្នោះ ទើបលោកអាចារ្យពោលថា **វិញ្ញាណដែលអាស្រ័យហទយវត្ថុដ៏សេសនៅក្នុងខណៈនោះ** តែព្រោះវត្ថុក្រៅអំពីនេះជាធម្មជាតិមិនអាចក្នុងកិច្ចរបស់ខ្លួន ទើបមានវិញ្ញាណក្នុងវេលានោះ ដែលអាស្រ័យហទយវត្ថុតែមយ៉ាងប៉ុណ្ណោះ ព្រោះហេតុនោះ ទើបអាចារ្យពោលថា **វិញ្ញាណដែលអាស្រ័យហទយវត្ថុដ៏សេសក្នុងខណៈនោះ** ។ កម្ម មានមាតុឃាតជាដើម ឬមហគ្គតកម្មដទៃដូច្នោះ ឈ្មោះថា **គរុកម្ម** ។ **សមាសេវិតកម្ម** ប្រែថា កម្មដែលធ្វើរឿយៗ ។ **អាសន្នកម្ម** បានដល់ កម្មដែលធ្វើក្នុងពេលជិតស្លាប់ ឬកម្មដែលធ្វើក្នុងពេលណានីមួយ ជាកម្មដែលរឭកបានយ៉ាងជាក់ច្បាស់ក្នុងពេលជិតស្លាប់ ។ **បុព្វកតកម្ម** បានដល់ កម្មដែល

មានវិបាកគប្បីសោយតៗ មក ។ បច្ច័យនៃវិញ្ញាណ មានអវិជ្ជាជាដើមដ៏សេសចុះក្នុងសង្ខារនេះបានហើយ ហេតុនោះ សង្ខារនេះ ឈ្មោះថា **លទ្ធាវសេសបច្ចយោ** សង្ខារមានបច្ច័យដ៏សេសចុះបានហើយ ។ ដោយពាក្យនេះ លោកអាចារ្យពោលដល់កុសលចេតនា និងអកុសលចេតនា តាមដែលចូលទៅសន្សំទុក ដែលមានឱកាសធ្វើដើម្បីឲ្យផល ដែលឈ្មោះថា **កម្មនិមិត្ត** បានដល់ វត្ថុដែលធ្វើឲ្យជាអារម្មណ៍ ប្រមូលកម្មមកក្នុងវេលាដែលបានធ្វើទុក កាលបានធ្វើកម្មទុកក្នុងអតីត សូម្បីយូរដល់ទៅសែនកោដិកប្ប កម្ម ឬកម្មនិមិត្ត ក៏នឹងមកប្រាកដ ក្នុងវេលាឲ្យផល ។ ដែលឈ្មោះថា **គតិនិមិត្ត** បានដល់ វណ្ណរូបម្យ៉ាងក្នុងឱកាស ដែលកើតឡើង ។ ឯវណ្ណរូបនោះ ខ្ញុំបានពោលទុកហើយខាងដើមនោះឯង ដោយពាក្យថា **វណ្ណរូប មានពណ៌ជាអណ្តាតភ្លើងជាដើម** សម្រាប់សត្វ ដែលគួរកើតឡើងក្នុងនរក ។ ក្នុងវិស័យដែលកម្មជាដើមនោះ **ដែលមានទោស ព្រោះអវិជ្ជាបិទបាំងទុក** ជាទីតាំងនៃការកើត ដោយភាពជាអារម្មណ៍របស់បដិសន្ធិវិញ្ញាណ ។

លោកអាចារ្យពោលថា **តណ្ហារមែងញ៉ាំងវិញ្ញាណឲ្យបង្អោនទៅ** ដូច្នេះ ព្រោះវិញ្ញាណដែលបែរមុខចំពោះបដិសន្ធិស្ថាន រមែងជាធម្មជាតិបង្អោនទៅ ទោរទន់ទៅទេរទៅ ប្រព្រឹត្តទៅ ព្រោះហេតុថា លះតណ្ហាមិនទាន់បាននោះឯង និងព្រោះសន្តតិដែលកើតមកមុន ជាធម្មជាតិប្រែប្រួលទៅយ៉ាងនោះ ។ ពាក្យថា **សង្ខារដែលកើតរួមគ្នា** បានដល់ ចេតនាដែលកើតរួមជាមួយជវនចិត្តជិតចុតិ ឬបានដល់ សភាវធម៌ទាំងអស់ មានផស្សៈជាដើម ។ **រមែងបន្សាត់** វិញ្ញាណទៅក្នុងវិស័យ មានកម្មជាដើម ក្នុងបដិសន្ធិស្ថាននោះ ។ អធិប្បាយថា រមែងប្រព្រឹត្តទៅដោយភាពជាហេតុនៃការតាំងនៅរបស់វិញ្ញាណ ដោយអំណាចបដិសន្ធិក្នុងវិស័យនោះ ដូចបន្សាត់ទៅ ។ បទថា **តំ** សេចក្តីថា **តំ យោគ វិញ្ញាណំ** ប្រែថា វិញ្ញាណនោះ លោកអាចារ្យ

នាំភាពជាឯកវចនៈចូលមកទុក ព្រោះវិញ្ញាណ **មានដោយអំណាចការបន្ត** របស់ចុតិ បដិសន្ធិ និងវិញ្ញាណដែលជិតចុតិបដិសន្ធិនោះ ។ ពាក្យថា **វិញ្ញាណត្រូវតណ្ហាបង្អោនទៅ ត្រូវសង្ខារបន្សាត់ទៅ ក៏លះទីអាស្រ័យដើម ។បេ។ ប្រព្រឹត្តទៅ** ដូច្នេះ លោកអាចារ្យរមែងសម្ដែងថា ការប្រព្រឹត្តទៅដោយការបង្អោនទៅ បន្សាត់ទៅ ការបោលទីអាស្រ័យដើម ការបានទីអាស្រ័យដទៃ និងការវៀរទីអាស្រ័យ រមែងមានដល់វិញ្ញាណ ១ ដួងប៉ុណ្ណោះ ដោយអំណាចការបន្ត មិនមានដល់វិញ្ញាណដទៃនោះទេ ។ ឯលោកអាចារ្យ កាលពោលថា **ដោយអំណាចសន្តតិ** ដូច្នេះ រមែងបដិសេធការកាន់យកខុសសេចក្ដីនេះថា **វិញ្ញាណនោះប៉ុណ្ណោះ រមែងស្ទុះទៅ រមែងអន្ទោលទៅ មិនមែនវិញ្ញាណដទៃ** ដូច្នេះ ។ ព្រោះកាលមានន័យផ្សេងគ្នា ក៏មានន័យដូចគ្នាដោយអំណាចសន្តតិ ដូច្នេះឯង ។ ឯក្នុងអធិការនេះ អារម្មណ៍មានកម្មជាដើម ដែលចងទុកដោយជាភពចាស់ គប្បីឃើញថា លោកប្រៀបដូចខ្សែដែលចងទុក ត្រង់ដើមឈើនាប្រាំងអាយ វិញ្ញាណគប្បីឃើញប្រៀប ដូចបុរស ។ តណ្ហាគប្បីឃើញប្រៀបដូចការប្រាថ្នានឹងឆ្លងអូររបស់បុរសនោះ សង្ខារដែលបន្សាត់ទៅ គប្បីឃើញប្រៀបដូចបយោគដែលឆ្លង ឧបមាដូចជាបុរសនោះ ឈរនៅត្រង់មាត់ប្រាំងខាងនាយ កាលបានឬមិនបានវត្ថុណា ដែលត្រូវចងដើមឈើប្រាំងនាយ ក៏រមែងឈរដោយបយោគនៃកម្លាំងរបស់ខ្លួន លើផែនដីតែម្យ៉ាងប៉ុណ្ណោះ យ៉ាងណា សូម្បីវិញ្ញាណនេះក៏ដូច្នោះកាលបានទីអាស្រ័យ ពោល គឺហទយវត្ថុ ដែលចងដោយអត្តភាពក្នុងភពដទៃ ក្នុងបញ្ច-វោការភព ឬកាលមិនបាននៅក្នុងចតុវោការភព ក៏រមែងប្រព្រឹត្តទៅដោយកម្ម ដែលសម្បយុត្តដោយអារម្មណ៍តែម្យ៉ាងប៉ុណ្ណោះ ។បណ្ដាបទទាំងនោះ បទថា **អស្សាទយមានំ** ប្រែថា ដល់ សេចក្ដីថា បាន ។

បទថា **ភវន្តរាទិបដិសន្ធានតោ** ប្រែថា ព្រោះបន្តមកអំពីខាងដើមនៃភវន្តរ គឺភព

ដទៃ ៗ ម្យ៉ាងទៀត ខាងដើមនៃភពដទៃជាដើម បានដល់ ភព កំណើត គតិ វិញ្ញាណដ្ឋិតិ និងសត្តាវាសដទៃ សេចក្តីថា ព្រោះបន្ទភព កំណើត គតិ វិញ្ញាណដ្ឋិតិ និងសត្តាវាសដទៃទាំងនោះ ៗ វិញ្ញាណនេះមិនបានមកហើយក្នុងភពនេះ ព្រោះកើតឡើង ក្នុងភពនេះនោះឯង ៗ ពាក្យថា **កម្ម** បានដល់ កម្មដែលឲ្យកើតបដិសន្ធិ ៗ ពាក្យថា **សង្ខារ** បានដល់ សង្ខារដែលបន្សាត់ទៅ សហគតៈដោយជវនចិត្តជិតចុតិ ៗ បទថា **នតិ** បានដល់ តណ្ហាដែលប្រព្រឹត្តទៅដោយអំណាចការបង្អោនទៅ ៗ **វិសយ** បានដល់ កម្មជាដើម ៗ

កាលភាវៈដែលធម្មជាតិ មានសំឡេងពិត និងសំឡេងខ្ទររជាដើម ជាបច្ច័យ និងជាធម៌ដែលកើតអំពីបច្ច័យមាន ការទាក់ទងគ្នាក្នុងការបន្ត ក៏មិនប្រាកដ ព្រោះហេតុនោះ ទើបលោកអាចារ្យមិនប្រារព្ធដល់ភាវៈដែលធម្មជាតិមានសំឡេងពិត និងសំឡេងរំពងជាដើមនោះដូចគ្នា និងដែលផ្សេងគ្នាសម្តែងចំពោះតែការមិនបានមក និងការកើតឡើងដោយហេតុដែលទាក់ទងមកអំពីអតីតភពប៉ុណ្ណោះ ទើបពោលពាក្យជាដើមថា **ឯត្ថ ច** ក្នុងពាក្យថា **មានសំឡេងពិតជាដើមជាហេតុ** នេះ មានវិនិច្ឆ័យថា **សំឡេងខ្ទរ** មានសំឡេងពិតជាហេតុ ៗ **ប្រទីប** មានប្រទីបដទៃជាដើមជាហេតុ ៗ **ត្រា** មានខ្លួនត្រាជាហេតុ ៗ **ស្រមោល** មានអវយវៈ មានមុខជាដើម ដែលផ្ចុះត្រង់កញ្ចក់ជាដើមជាហេតុ ៗ ពាក្យថា **ហោន្តិ អញ្ញត្រ អគន្ត្វា** សេចក្តីថា មិនចូលទៅអាស្រ័យចំណែកខ្លះនៃបច្ច័យ មានសំឡេងពិតជាដើម ក៏ជាធម្មជាតិមានសំឡេង ពិតជាដើម ជាហេតុ ព្រោះមុននោះ ក៏មិនមាន ៗ សូម្បីបដិសន្ធិវិញ្ញាណក៏ដូច្នោះ មិនបានដល់ចំណែកខ្លះរបស់ហេតុ ហើយមានចំណែកខ្លះរបស់ហេតុនោះជាហេតុ ព្រោះកាលមុន អំពីនោះក៏មិនមាន ៗ អធិប្បាយថា ព្រោះហេតុនោះ ទើបបដិសន្ធិវិញ្ញាណនេះ មិនបានមកក្នុងភពនេះអំពីភពមុន ព្រោះចំណែកខ្លះរបស់ហេតុ ឧបមាដូចសំឡេងខ្ទរជាដើមមកអំពីសំឡេងពិតជាដើម ទាំងមិនមែនវៀរចាកហេតុ ក្នុងភពនោះហើយក៏កើតឡើង

ដូចសំឡេងរំពងជាដើម វៀរចាកសំឡេងពិតជាដើម ក៏មិនបានកើតឡើង ដូច្នោះ ។ ន័យម្យ៉ាងទៀត បណ្ឌិតគប្បីប្រកបសេចក្តីតាមន័យ ដែលពោលហើយនោះឯងថា ពាក្យថា **ហោន្តិ អញ្ញត្រ អគន្ត្វា** សេចក្តីថា ផ្តើមឧបមា មានសំឡេងរំពងជាដើម ទាំងនោះ ជាធម្មជាតិតាំងចុះក្នុងចំណែកខ្លះនៃបច្ច័យ តអំពីនោះទៅក្នុងទីដទៃ មិនបាន មានចំណែកខ្លះនៃបច្ច័យជាបច្ច័យ ព្រោះមុនកើតឡើងក៏មិនមាន ទាំងមិនបានមានសំឡេង ពិតជាដើមជាបច្ច័យផងដែរ សូម្បីបដិសន្ធិវិញ្ញាណនេះ ក៏ប្រៀបដូច្នោះដែរ ។

ឈ្មោះថា **ការប្រដូចគ្នាមិនមាន** ព្រោះវិញ្ញាណដទៃប៉ុណ្ណោះកំពុងប្រាកដ សូម្បី ក្នុងកាលដែលដូចគ្នាក្នុងការបន្តដែលដូចគ្នា ។ **ទាំងសេចក្តីផ្សេងគ្នាក៏ឈ្មោះថា មិនមាន ព្រោះការទាក់ទងគ្នាក្នុងការបន្ត ដូចជាប្រទីប** ។ សេចក្តីពិត អណ្តាតប្រទីបដែល មាននៅគ្រប់ខណៈ លោកហៅថា អណ្តាតប្រទីបនោះៗ ឯង ដោយអាស្រ័យការធ្វើ ក្នុងការបន្ត និងរមែងឲ្យសម្រេចកិច្ចនៃសេចក្តីត្រូវការបាន សូម្បីក្នុងរឿងនៃចុតិវិញ្ញាណ និងបដិសន្ធិវិញ្ញាណនេះ គប្បីឃើញសេចក្តីឧបមេយ្យ ដូច្នោះ ។ ដោយពាក្យថា **ពិត ហើយ ឧបមា** ជាដើម លោកអាចារ្យរមែងសម្តែងការៈដែលមិនគួរប្រកាន់ក្នុងកាល ដែលដូចគ្នាយ៉ាងដាច់ខាត និងក្នុងកាលផ្សេងគ្នាយ៉ាងដាច់ខាត ក្នុងការទាក់ទងគ្នានៃការ បន្ត និងរមែងសម្តែងទោសក្នុងការប្រកាន់ផងដែរ ។ ដោយការសម្តែងតទៅថា **ន័យនេះ** លោកអាចារ្យរមែងសម្តែងថា គួរប្រកបពាក្យ ដែលប្រកបបានតាមសមគួរ ក្នុងធម៌ ដែលជាហេតុ និងធម៌ដែលកើតអំពីហេតុទាំងអស់ មានពូជ និងពន្លកជាដើម ។ ក្នុង ទីនេះ កាលមានប្រការដែលវិញ្ញាណជាហេតុ និងវិញ្ញាណដែលកើតអំពីហេតុ ដូចគ្នា ដាច់ខាត គតិរបស់ទេវតាដែលនឹងកើតមកអំពីគតិរបស់មនុស្ស ក៏មិនគប្បីមាន ។ កាលមានសេចក្តីផ្សេងគ្នាដោយសព្វអន្ទើ ផលរបស់បុគ្គលដែលធ្វើកម្មក៏មិនគប្បីមាន ព្រោះហេតុនោះ គប្បីជាការលុបលាងវោហារជាដើមថា **បពិត្រព្រះអង្គដ៏ចម្រើន**

**អំពីមុន ខ្ញុំជាឥសីឈ្មោះរោហិតស្ស** ដូចជាពាក្យជាដើមថា **ពូជរបស់កេសរពណ៌ក្រហម ផលរបស់កេសរពណ៌ក្រហម** ដូច្នេះ ព្រោះហេតុនោះ ទើបមិនគួរជាប់ជំពាក់ភាពដូចគ្នាយ៉ាងដាច់ខាត ឬភាពផ្សេងគ្នាយ៉ាងដាច់ខាត មិនគួរកាន់យកក្នុងការទាក់ទងគ្នា ក្នុងការបន្តនេះ ដែលជាហេតុ និងកើតអំពីហេតុ ។ ក្នុងអធិការនេះ ដោយការបដិសេធភាពដូចគ្នាឥតខ្ចោះ លោកអាចារ្យរមែងបដិសេធការឃើញសេចក្ដីនេះថា **សុខទុក្ខជាវត្ថុដែលខ្លួនឯងធ្វើ** ដោយការបដិសេធភាពផ្សេងគ្នាយ៉ាងដាច់ខាត លោកអាចារ្យរមែងបដិសេធការឃើញសេចក្ដីនេះថា **សុខទុក្ខអ្នកដទៃធ្វើឲ្យ** ដោយការពោលដល់ហេតុ និងកើតអំពីហេតុ លោកអាចារ្យរមែងបដិសេធការយល់ឃើញនេះថា **សុខទុក្ខកើតឡើងឯងៗ** ។

បទថា **តត្ថ យោគ ផលុប្បត្តិដ្ឋានេ** ប្រែថា ក្នុងទីដែលកើតឡើងនៃផលនោះ ។ បទថា **អញ្ញស្ស** សេចក្ដីថា កម្មនោះ បុគ្គលណាធ្វើទុកដល់បុគ្គលដទៃក្រៅអំពីបុគ្គលនោះ ។ បទថា **អញ្ញតោ** សេចក្ដីថា កម្មនោះដែលធ្វើឲ្យកើតឡើងអំពីកម្មដទៃអំពីកម្មនោះ ។ ព្រោះលោកអាចារ្យបានពោលទុកថា **វិញ្ញាណត្រឹមតែជាធម៌ ចូលដល់ភពដទៃ** ដូច្នេះ លោករមែងចោទថា **កាលអ្នកសោយផលមិនមាន ផលនោះគប្បីមានដល់នរណា** ។ បទថា **តត្រ** សេចក្ដីប៉ុនគ្នានឹង **តស្មិ យោគ អនុយោគេ** ប្រែថា ក្នុងពាក្យចោទនោះ គឺតាមដែលពោលហើយនោះ ។

បទថា **តត្ថ យោគ ឯកសន្តានេ** ប្រែថា ក្នុងការបន្តដែលដូចគ្នា ។ អធិប្បាយថា កម្មកើតឡើងក្នុងគំនរធម៌ណា ក្នុងការបន្តនៃគំនរធម៌នោះ ពីរបទថា **ឯតស្ស ឯត្ថស្ស** សេចក្ដីថា នៃសេចក្ដីប្រការនេះ សូម្បីកាលហេតុ និងផល ពោលដោយអត្ថដទៃផលនោះក៏មិនគួរពោលថា **កើតដល់អ្នកដទៃ ឬកើតអំពីកម្មដទៃ** ព្រោះជាធម្មជាតិដែលទាក់ទងដោយហេតុផលគ្នានោះឯង ។ បណ្ឌិតគប្បីប្រកបសេចក្ដីថា កាលដែល

ធ្វើឲ្យមានចតុមធុរស គឺរសផ្អែម ៤ យ៉ាង និងរស ប្រហាតជាដើម ឈ្មោះថា **អភិសង្ខារ** ភាពដែលតាក់តែងរបស់ពូជ មានស្វាយ និងក្រូចព្រៃជាដើម ។ ក្នុងទីនេះសត្វដែលធ្វើកម្ម ប្រៀបដូចពូជដែលតាក់តែងឡើង កម្មប្រៀបដូចស្ថានទីតាក់តែងការសម្ពន្ធនៃបដិសន្ធិវិញ្ញាណជាដើម របស់សត្វប្រៀបដូចការទាក់ទងនៃពន្លកជាដើមរបស់ពូជ ។ គប្បីជ្រាបភាវៈនៃសត្វដែលធ្វើកម្ម និងផល ព្រោះកម្មរបស់សត្វនោះប្រៀបដូចភាវៈនៃកេសរពណ៌ក្រហម ឬផ្លែឈើដែលមានរសឆ្ងាញ់ ដែលកើតឡើងក្នុងទីនោះ និងភាវៈនៃពូជនោះឯង ព្រោះការតាក់តែងអំពីពូជនោះឯង ដូច្នោះ ។ ការរៀនវិជ្ជា ការសិក្សាសិប្បៈ និងការប្រកបឱសថដែលបានធ្វើទុកក្នុងរាងកាយកុមារមិនទៅកាន់រាងកាយកាលកុមារនោះធំឡើយ ។ និងកាលបើដូច្នោះ ការជំនាញរបស់វិជ្ជា ការចេះសិប្បៈ និងភាពជាអ្នកមានអនាម័យក៏រមែងមាននៅក្នុងរាងកាយ កាលបុគ្គលនោះធំបាន ព្រោះមានរាងកាយកាលនៅជាកុមារនោះជាហេតុ ឯរឿងទាំងនោះមិនមានដល់បុគ្គលដទៃឡើយ ព្រោះកើតឡើងក្នុងរាងកាយកាលធំចម្រើនឡើង ដែលទាក់ទងក្នុងសន្តតិនោះឯង បើវៀរចាកការទន្ទេញវិជ្ជាជាដើមតាមដែលបានប្រកបទុកហើយ វត្ថុទាំងនោះមិនមានមកអំពីទីដទៃឡើយ ព្រោះកាលវាមិនមានក៏ទេ សូម្បីក្នុងចុតិវិញ្ញាណ និងបដិសន្ធិវិញ្ញាណនេះ ក៏មានឧបមេយ្យដូច្នោះ ក្នុងការបន្តគ្នា ផលឯណាផលនេះ មិនមែនរបស់បុគ្គលដទៃ ។ និងមិនមែនកើតអំពីកម្មដទៃដែរ ។ ដោយពាក្យនេះ លោករមែងសម្តែងការមិនមានផល ក្នុងកាលមិនមានការតាក់តែងនោះឯង រមែងធ្វើការបដិសេធបច្ច័យដទៃ ។

**យម្បិ វុត្តំ តត្ថ** មានពាក្យដ៏សេសថា **វទាម** ប្រែថា ពាក្យដែលអាចារ្យអ្នកចោទពោលទុក ខ្ញុំនឹងពោលក្នុងពាក្យនោះ ។ ម្យ៉ាងទៀត ភ្ជាប់សេចក្តីបាលីថា **តត្ថ វា ឧបកុញ្ចកេ អសតិ សិទ្ធា កុញ្ចកសម្មុតិ** ប្រែថា កាលមិនមានអ្នកសោយការ

សន្និដ្ឋានថា មានអ្នកសោយ ក៏សម្រេចក្នុងពាក្យនោះ ដូច្នេះក៏បាន ។ ការសន្និដ្ឋានថា មានផល ឈ្មោះថា **ផលតិសម្មុតិ** ។

ពាក្យថា **នៃធម៌ទាំងឡាយដែលហៅថា ដើមឈើ** បានដល់ នៃធម៌ គឺរូបក្ខន្ធ និងឧបាទាយរូបទាំងឡាយ ដែលជាឧបាទាននៃការបញ្ញត្តថា ដើមឈើ ។ ពាក្យថា **ព្រោះហេតុនោះ** សេចក្តីថា ព្រោះឧបមាដូចវោហារថា អ្នកធ្វើ ដូចពាក្យថា **ធ្វើបុណ្យ ធ្វើបាប** ដូច្នេះ ក៏ព្រោះការកើតឡើងនៃកុសលចេតនា និងអកុសលចេតនាក្នុងខន្ធសន្តានឯណា វោហារថា អ្នកសោយ ដូចពាក្យថា **សោយសុខ សោយទុក្ខ** ដូច្នេះ ក៏ព្រោះការកើតឡើងនៃផលរបស់សុខ និងទុក្ខនោះ ក៏ដូច្នោះ ដូច្នោះ អត្តណាមួយ ដោយឈ្មោះថា អ្នកសោយដទៃដែលផុតទៅ អំពីខន្ធក្នុងរឿងអ្នកសោយផលនេះ មិនមាន ដូច្នេះ ។

ពាក្យថា **សូម្បីកាលបើយ៉ាងនោះ** សេចក្តីថា កាលការប្រាកដនៃការមិនឃ្លាត និងកាលការលុបលាងទោសតាម ដែលពោលក្នុងការប្រាកដនៃការមិនឃ្លាតនោះមាន សេចក្តីថា សម្រេចហើយ ។ ពាក្យថា **ក្នុងបវត្តិក្ខណៈនោះ** គឺក្នុងខណៈ ដែលសង្ខារប្រព្រឹត្តទៅប៉ុណ្ណោះ ។ ពាក្យថា **ក្នុងខណៈមុនបវត្តិ** គឺក្នុងខណៈមុន ដែលធ្វើកម្ម លោកពោលទុកយ៉ាងនេះ ព្រោះភាពជារឿងស្មើដោយការៈដែលមិនមាន ។ ពាក្យថា **និងក្នុងកាលខាងក្រោយបវត្តិ** សេចក្តីថា និងក្នុងខាងក្រោយការដល់នូវភាពឲ្យផល ។

លោកអាចារ្យពោលថា **តែវានាំផលមកឲ្យជានិច្ចក៏ទេ** ដូច្នេះ ដើម្បីបដិសេធចោលនូវសេចក្តីសង្ស័យថា បើសង្ខារទាំងឡាយមានវិបាកមិនទាន់ផ្អិនជាបច្ច័យ ( នៃផល ) ព្រោះធ្វើផលឡើងមក សង្ខារទាំងឡាយសូម្បីមានវិបាកផ្អិនហើយ ជាវត្ថុដែលធ្វើផលឡើងមកក៏ប៉ុនគ្នា ព្រោះហេតុនោះ សង្ខារទាំងនោះនាំផលមកក៏គប្បីមាន ដូច្នេះ ។

ដោយពាក្យនេះថា **មិនមែនព្រោះវាមាន ឬវាមិនមាន** លោកអាចារ្យរមែង
ចៀសវាងនូវទោសដែលពោលទុក ព្រោះអាស្រ័យការមាន ឬការមិនមាន ។ ក៏ត្រឹមតែ
ធ្វើកិរិយា គឺការទទួលយក កិរិយា គឺការទិញដូរ ឬកិរិយា គឺការខ្ចីបុល ឈ្មោះថា
**តំកិរិយាករណមត្តំ** ត្រឹមតែធ្វើកិរិយានោះៗ ត្រឹមតែធ្វើកិរិយានោះៗ រមែងជាបច្ច័យ
**ក្នុងការបញ្ជូនផលប្រយោជន៍នោះ** គឺក្នុងការប្រើទ្រព្យសងត្រឡប់ និងក្នុងការខ្ចីបុល
អធិប្បាយថា មានការបញ្ជូនផលដែលមិនឲ្យផលជាដើមជាផល ។

ពាក្យថា **ដើម្បីកម្ចាត់ការវង្វេង** សេចក្ដីថា ដើម្បីនាំទៅអំពីការវង្វេងដែល
ប្រព្រឹត្តទៅក្នុងវិញ្ញាណ ៣២ គឺក្នុងបដិសន្ធិកាល និងក្នុងភាពជាបច្ច័យក្នុងបវត្តិកាល
នៃសង្ខារតាមដែលពោលហើយ ដែលលោកមិនបានចែកឲ្យជាក់ច្បាស់ទុក ។

បទថា **បុញ្ញាភិសង្ខារេ** ជាសត្តមីវិភត្តិ ចុះក្នុងអត្ថនិទ្ធារណៈ ។ ពាក្យថា **ដោយ
មិនផ្សេងគ្នា** គឺដោយស្មើគ្នា មិនបានធ្វើការចែកគ្នាជាដើមថា **ធម៌ដែលជាតិហេតុកៈ
ជាបច្ច័យដល់ធម៌ដែលជាតិហេតុកៈ** អធិប្បាយថា ដោយអំណាចការរួមគ្នា ។ ឧប-
និស្សយប្បច្ច័យគ្រប់កន្លែង បណ្ឌិតគប្បីប្រកបដោយកម្មដែលមានកម្លាំង ។ **ក្នុងការ
ពណ៌នាគម្ពីរបដ្ឋាន លោកបានសម្ដែងទុកថា កម្មដែលទុព្វលរមែងមិនជាឧបនិស្ស-
យប្បច្ច័យ** ។ ពាក្យថា **បុញ្ញាភិសង្ខារប្រភេទកុសលចេតនា ៥ ខាងរូបាវចរ** គួរនឹង
ពោលឲ្យផ្សេងទៅថា **វៀរប្រភេទដែលដល់អភិញ្ញា** ឬមិនគួរពោលព្រោះវិបាកដែល
មិនគួរជាវិបាក ក្នុងកថាពោលដោយភាពជាបច្ច័យមិនមានការទាក់ទងគ្នា ។ ឯចេតនា
ក្នុងអភិញ្ញាមិនជាវិបាក លោកបានអធិប្បាយទុកហើយខាងដើមនោះឯង ។ ក្នុងពាក្យ
ថា **ដោយមិនផ្សេងគ្នា** នេះ ក៏ន័យនេះ ។ គប្បីនាំពាក្យថា **បញ្ចន្នំ វិបាកវិញ្ញាណានំ**
ដល់វិបាកវិញ្ញាណទាំង ៥ មកភ្ជាប់ចូលជាមួយគ្នា ។ ពាក្យថា **ដល់វិបាកវិញ្ញាណ
ទាំង ៥ បានដល់** វិបាកវិញ្ញាណទាំង ៥ នេះ គឺចក្ខុវិញ្ញាណ សោតវិញ្ញាណ

*សម្បដិច្ឆន្នមនោធាតុ និងសន្តីរណមនោវិញ្ញាណធាតុ ទាំង ២ ។ ពាក្យថា* ***យ៉ាងនោះដូចគ្នា*** *គឺដោយចំណែក ២ នោះឯង ។ លោកអាចារ្យពោលពាក្យថា* ***នៃព្រះមហាមោគ្គល្លានត្ថេរក្នុងនរក*** *ដូច្នេះជាដើម ដើម្បីនឹងឆ្លើយបញ្ហាថា វិញ្ញាណដែលជាកុសលវិបាក ប្រព្រឹត្តទៅក្នុងឥដ្ឋារម្មណ៍ប៉ុណ្ណោះ រមែងប្រព្រឹត្តទៅក្នុងទុគ្គតិ បានដូចម្តេច ។ សេចក្តីពិត ព្រះថេរៈនិម្មិតភ្លៀងដោយឫទ្ធិក្នុងនរកនោះ រំលត់ភ្លើងនរកអស់វេលាតិចតួច ហើយសម្តែងធម៌ដល់សត្វនរកទាំងនោះ ។*

***ឯវំ យោគ កាមាវចរោ បុញ្ញាភិសង្ខារោ*** *ប្រែថា បុញ្ញាភិសង្ខារខាងកាមាវចរនោះឯង ។ ដោយពាក្យថា* ***តែដោយមិនផ្សេងគ្នា បុញ្ញាភិសង្ខារ*** *ដូច្នេះ លោកអាចារ្យរមែងសរុបយកបុញ្ញាភិសង្ខារទាំង ២ យ៉ាង គឺកាមាវចរ និងរូបាវចរចូលគ្នា ។*

*ក្នុងពាក្យថា* ***អបុញ្ញាភិសង្ខារប្រភេទអកុសលចេតនា ១២ នេះ*** *ហេតុក្នុងការកាន់យកចេតនាសហគតៈដោយឧទ្ធច្ចៈ នឹងមិនប្រាកដ សេចក្តីនេះគួរពិចារណា ។ អធិប្បាយថា ជាបច្ច័យដល់វិញ្ញាណ ១ ដួងយ៉ាងនោះ ក្នុងបដិសន្ធិកាល មិនប្រព្រឹត្តទៅក្នុងបវត្តិកាល ព្រោះហេតុនោះ ទើបលោកកំណត់បច្ច័យដល់វិញ្ញាណ ១ ដួងប៉ុណ្ណោះក្នុងបដិសន្ធិកាល មិនប្រព្រឹត្តទៅក្នុងបវត្តិកាល ។ ព្រោះថា ក្នុងបវត្តិកាលជាបច្ច័យដល់វិញ្ញាណទាំង ៧ ដួង ។*

*ពាក្យថា* ***ក្នុងរូបភព ជាបច្ច័យដល់វិបាកវិញ្ញាណទាំង ៤*** *សេចក្តីថា ជាបច្ច័យដល់ចក្ខុវិញ្ញាណ សោតវិញ្ញាណ សម្បដិច្ឆន្នៈ និងសន្តីរណៈ ដែលជាអកុសលវិបាក ។ លោកអាចារ្យពោលពាក្យជាដើម* ***ឯបុញ្ញាភិសង្ខារជាបច្ច័យក្នុងរូបភពនោះឯង*** *ដើម្បីឆ្លើយសំណួរថា អកុសលវិបាកនោះជាអនិដ្ឋារម្មណ៍ដោយចំណែកមួយ ក្នុងរូបភព និងប្រកបដោយអនិដ្ឋារម្មណ៍បានដូចម្តេច ។ ពាក្យថា* ***វត្ថុដែលមិនគួរប្រាថ្នា មានរូបដែលមិនគួរប្រាថ្នាជាដើមក៏មិនមានក្នុងទេវលោកកាមាវចរដូចយ៉ាងនោះ*** *នេះ*

លោកពោលទុកដោយជារឿងរ៉ាវចំណែកច្រើន ។ ព្រោះរូបជាដើម ដែលគួរប្រាថ្នា ប៉ុណ្ណោះ រមែងប្រាកដដល់ទេវតាទាំងនោះដោយច្រើន គ្រាខ្លះ ក៏ប្រាកដវត្ថុដែលមិនគួរប្រាថ្នា ពិតហើយ ការជួបដោយអនិដ្ឋារម្មណ៍ មានផ្កាស្រពោនជាដើម រមែងមានដល់ទេវតាពួកខ្លះ ក្នុងពេលដែលបុព្វនិមិត្តប្រាកដជាដើម ។

ពាក្យប្រកាសសេចក្តីពិស្តារ លោកអាចារ្យបានធ្វើហើយក្នុងភពណា លោកអាចារ្យមានបំណងធ្វើពាក្យប្រកាសសេចក្តីសំខាន់ តាំងអំពីភពនោះទៅ ទើបពោលថា **តាំងអំពីដើម** ។ ដោយហេតុនោះឯង ទើបលោកអាចារ្យពោលពាក្យថា **ក្នុងភព ២** ដូច្នេះជាដើម សូម្បីមនុស្សទាំងឡាយពួកខ្លះក៏កើតក្នុងស៊ុត ពួកខ្លះក៏កើតក្នុងញើសក្អែល ព្រោះហេតុនោះ ទើបលោកអាចារ្យពោលពាក្យថា **ក្នុងកំណើត ៤** ដោយសំដៅដល់សេចក្តីនោះ ។ សត្វសូម្បីនៅក្នុងចតុត្ថជ្ឈានភូមិ វៀរអសញ្ញភូមិ និងអរូបភូមិ រមែងរួមចូលវិញ្ញាណដ្ឋិតិទី ៤ តែម្យ៉ាង ព្រោះជាឯកត្តកាយឯកត្តសញ្ញីស្មើគ្នា ។ ឯស**យោគ បុញ្ញាភិសង្ខារោ** ប្រែថា បុញ្ញាភិសង្ខារនេះ ។ ពាក្យថា **ដោយន័យដែលពោលហើយនោះឯង** គឺដោយន័យដែលពោលហើយថា **ដោយនានាក្ខណិកកម្មប្បច្ច័យ និងដោយឧបនិស្សយប្បច្ច័យ** នោះឯង ។ ពាក្យថា **តាមដែលមាន** សេចក្តីថា តាមដែលមានដូច្នេះ ក្នុងបណ្តាកាមាវចរកុសលវិបាក និងរូបាវចរកុសលវិបាក ២១ ដួង បុញ្ញាភិសង្ខារជាបច្ច័យដល់វិបាកវិញ្ញាណ ១៤ ដួង ក្នុងបដិសន្ធិកាល និងក្នុងបវត្តិកាល ជាបច្ច័យដល់វិបាកវិញ្ញាណ ៧ ដួងក្នុងបវត្តិកាល តែម្យ៉ាង ។

ពាក្យថា **ក្នុងសត្តាវាស ១ ដូច្នោះដូចគ្នា** បានដល់ ក្នុងសត្តាវាស ពោលគឺនានត្តកាយឯកត្តសញ្ញីនោះឯង ។

ពាក្យថា **ដល់វិញ្ញាណ ៤** លោកពោលសំដៅដល់ភពជាដើម ។ បណ្ឌិតគប្បីប្រកបសេចក្តីដែលវិញ្ញាណទាំង ៣ ដែលចុះកាន់ក្នុងវិញ្ញាណទាំង ៤ ជាបច្ច័យ ក្នុង

វិញ្ញាណដ្ឋិតិទាំង ៣ ។ សូម្បីកាលមិនបានវិញ្ញាណ ព្រោះសង្ខារជាបច្ច័យក្នុងសត្តាវាស ដែលមិនមានវិញ្ញាណក៏គង់បាន ភាពដែលសត្តាវាសដែលមិនមានវិញ្ញាណនោះ មាន សង្ខារជាហេតុនោះឯង ។ ពិតយ៉ាងនោះ បុញ្ញាភិសង្ខារក្នុងសត្តាវាស ដែលមិនមាន វិញ្ញាណនោះ ជាបច្ច័យដោយនានាក្ខណិកកម្មប្បច្ច័យដល់កដត្តារូបទាំងឡាយ ក្នុងការ ប្រកាសសេចក្តីសំខាន់នេះ ដែលបុញ្ញាភិសង្ខារជាដើមជាបច្ច័យដល់វិញ្ញាណ មាន កុសលវិបាកជាដើមក្នុងបវត្តិកាល ក្នុងទុគ្គតិភូមិជាដើម រមែងដឹងបានតាមន័យដែល ពោលហើយ ក្នុងភពទាំងឡាយនោះឯង ព្រោះហេតុនោះ គប្បីជ្រាបថា លោកមិន បានពោលទុក ។

# វិសុទ្ធិមគ្គ

## អធិប្បាយ បទថា វិញ្ញាណប្បច្ចយា នាមរូបំ

ក្នុងបទថា វិញ្ញាណប្បច្ចយា នាមរូបំ

បណ្ឌិតគប្បីជ្រាបវិនិច្ឆ័យដោយវិភាគនៃនាមរូបទាំងឡាយ ដោយការប្រព្រឹត្តទៅ ( នៃនាមរូប ) ក្នុងទីទាំងឡាយ មានភពជាដើម ដោយសង្គ្រោះ ( សង្ខេបចូល ) ដោយបច្ចយន័យ ។

## វិនិច្ឆ័យដោយវិភាគ

ក្នុងពាក្យថា ដោយវិភាគនៃនាមរូបទាំងឡាយនោះ មានវិនិច្ឆ័យថា ខន្ធ ៣ មានវេទនាជាដើម ឈ្មោះថា នាម ព្រោះបង្អោនទៅឈមមុខចំពោះអារម្មណ៍ មហាភូតរូប ៤ និងឧបាទាយរូប ( រូបអាស្រ័យ ) នៃមហាភូត ៤ ឈ្មោះថា រូបវិភាគ ( គឺ ប្រភេទ ) នៃនាមរូបទាំងឡាយនោះ បានពោលទុកក្នុងខន្ធនិទ្ទេសហើយ ។

វិនិច្ឆ័យក្នុងបទថា **វិញ្ញាណប្បច្ចយា នាមរូបំ** នោះ ដោយវិភាគនៃនាមរូបទាំងឡាយ គប្បីជ្រាបដូចពោលមកដូច្នេះ ជាលំដាប់ដំបូង ។

## វិនិច្ឆ័យដោយការប្រព្រឹត្តទៅ

ឯក្នុងពាក្យថា ដោយការប្រព្រឹត្តទៅ ( នៃនាមរូប ) ក្នុងទីទាំងឡាយ មានភពជាដើមនោះ មានវិនិច្ឆ័យថា នាម រមែងប្រព្រឹត្តទៅក្នុងភព កំណើត គតិ វិញ្ញាណដ្ឋិតិទាំងពួង និងក្នុងសត្តាវាសដ៏សេស វៀរសត្តាវាស ១ ( គឺអសញ្ញសត្តាវាស ) រូបរមែងប្រព្រឹត្តទៅក្នុងភព ២ កំណើត ៤ ក្នុងគតិ ៥ ក្នុងវិញ្ញាណដ្ឋិតិ ៤ ខាងដើម ក្នុងសត្តាវាស ៥ ខាងដើម ( រួមអសញ្ញសត្តាវាសផង ) កាលនាមរូបនោះប្រព្រឹត្តទៅ

យ៉ាងនោះ ហេតុដែលក្នុងបដិសន្ធិក្ខណៈនៃពួកសត្វគព្ភសេយ្យកកំណើត ដែលនៅមិនទាន់សម្តែងភាវៈ ( ភេទ ) និងពួកសត្វអណ្ឌជកំណើតដែលមិនទាន់សម្តែងភាវៈ សន្តតិសីសៈ ( គឺរូបកលាបៈជាដើម ជាមូលនៃការជាប់បន្ត ) ២ ដោយភាពជារូបដោយអំណាចនៃវត្ថុទសកៈ ( ពួករូប ១០ ទាំងហទយៈ ) និងកាយទសកៈ ( ពួករូបមានកាយទសកៈជាគម្រប់ ១០) ជាមួយអរូបក្ខន្ធ ៣ រមែងកើតប្រាកដឡើង ហេតុនោះដោយបែករូបទាំងនោះចេញទៅ ( ក៏ ) ធម៌ ២៣ គឺ ( រូប ) ធម៌ ២០ ជារូបរូប ( គឺរូបដែលសម្រេចហើយ ) និងអរូបក្ខន្ធ ៣ នោះឯង បណ្ឌិតគប្បីជ្រាបថា ឈ្មោះថា នាមរូប ដែលមានព្រោះបច្ច័យ គឺវិញ្ញាណ តែដោយកាន់យកតែរូបដែលនៅមិនបានកាន់យក ( គឺកាន់យកតែដែលមិនជាន់គ្នា ) ទាញរូបធម៌ ៩ ចាកសន្តតិសីសៈ ១ ចេញ ក៏ ( សល់ ) ១៤ បន្ថែមភាវទសកៈ ( ពួករូប ១០ ទាំងភាវៈ ) សម្រាប់សត្វដែលមានភាវៈ ( ហើយ ) ចូលក៏ជា ៣៣ ម្យ៉ាងទៀត ដោយកាន់យកតែដែលនៅមិនទាន់កាន់យក ទាញរូបធម៌ ១៣ ចាកសន្តតិសីសៈ ២ ពួកចេញទៀត ( សល់ ) ១៥ ( ឈ្មោះថា **វិញ្ញាណប្បច្ចយា នាមរូបំ** សម្រាប់សត្វ ២ កំណើតនោះ ) ។

ចំណែកក្នុងពួកសត្វឱបបាតិកកំណើត ហេតុដែលក្នុងបដិសន្ធិក្ខណៈនៃរូបព្រហ្មមានចំពូក **ព្រហ្មកាយិក** ជាដើម សន្តតិសីសៈ ៤ ជារូបដោយអំណាចនៃចក្ខុទសកៈ សោតទសកៈ វត្ថុទសកៈ និងជីវិតិន្ទ្រិយនវកៈ និងអរូបក្ខន្ធ ៣ រមែងប្រាកដ ហេតុនោះដោយបែករូបរបស់រូបព្រហ្មទាំងនោះចេញទៅ ( ក៏ ) ធម៌ ៤២ គឺរូបធម៌ ៣៩ ជារូបរូប និងអរូបក្ខន្ធ ៣ នោះ បណ្ឌិតគប្បីជ្រាបថា ឈ្មោះថា នាមរូប ដែលមានព្រោះបច្ច័យ គឺវិញ្ញាណ តែដោយកាន់យក តែដែលនៅមិនបានកាន់យក ទាញរូបធម៌ ២៧ ( ដែលជាន់គ្នា ) ចាកសន្តតិសីសៈ ៣ ពួកចេញ ក៏ ( សល់ ) ១៥ ។

ចំណែកក្នុងកាមភព ហេតុដែលក្នុងបដិសន្ធិក្ខណៈនៃពួកសត្វឱបបាតិកកំណើត

ដ៏សេសក្តី និងពួកសត្វសំសេទជកំណើតក្តី ដែលមានភាវៈ និងមានអាយតនៈគ្រប់ សន្តតិសីសៈ ៧ ដោយជារូប និងអរូបក្ខន្ធ ៣ រមែងប្រាកដ ហេតុនោះ ដោយចែក រូបទាំងនោះចេញទៅ ក៏ធម៌ ៧៣ គឺរូបធម៌ ៧០ ដោយភាពជារូបរូប និងអរូបក្ខន្ធ ៣ នោះ បណ្ឌិតគប្បីជ្រាបថា ឈ្មោះថា នាមរូប ដែលមានព្រោះបច្ច័យ គឺវិញ្ញាណ តែ ដោយកាន់យក តែនៅមិនបានកាន់យក ទាញរូបធម៌ ៥៤ ( ដែលជាន់គ្នា ) ចាករូប សន្តតិសីសៈ ៦ ពួកចេញ ក៏សល់ ១៩ នេះជាការរាប់យ៉ាងច្រើន ចំណែកយ៉ាងតិច ការរាប់នាមរូបដែលមានព្រោះបច្ច័យ គឺវិញ្ញាណក្នុងបដិសន្ធិនៃពួកសត្វដែលមានរូប សន្តតិសីសៈនោះៗ វិកល ( ខ្វះខាត ) ក៏គប្បីជ្រាបដោយបន្ថយៗ ចុះខ្វះ បន្ថែមឡើងខ្វះ តាមកេណ្ឌនៃសន្តតិសីសៈនោះៗ ចុះ ។

ចំណែកក្នុងបដិសន្ធិនៃអរូបព្រហ្មទាំងឡាយ ក៏ប្រាកដតែអរូបក្ខន្ធ ៣ ( មិនមាន រូប ) ក្នុងបដិសន្ធិនៃពួកអសញ្ញីព្រហ្ម ប្រាកដតែជីវិតិន្ទ្រិយនវកៈជារូបប៉ុណ្ណោះឯង នេះ ជានយ័ក្នុងបដិសន្ធិមុន ។

ចំណែកក្នុងបវត្តិកាល សុទ្ធដ្ឋករូប ( សំណុំរូប ៨ សុទ្ធ គឺអវិនិព្ភោគរូប ) ដែលមានឧតុជាសមុដ្ឋានដោយរដូវ ( គឺតេជោធាតុ ) ដែលប្រព្រឹត្តទៅព្រមជាមួយ បដិសន្ធិចិត្ត រមែងប្រាកដឡើងក្នុងឋិតិក្ខណៈនៃបដិសន្ធិចិត្តក្នុងគ្រប់កន្លែងប្រព្រឹត្តទៅ នៃរូប តែ ( តួ ) បដិសន្ធិចិត្ត មិនមែនញុំាងរូបឲ្យតាំងឡើងបានទេ ពិតហើយ បដិសន្ធិចិត្តនោះ មិនអាចញុំាងរូបឲ្យតាំងឡើងបាន ព្រោះជាចិត្តមានកម្លាំងតិច ហេតុ ដែល ( ហទយ ) វត្ថុ ( ទើបតែកើត ) នៅមានកម្លាំងខ្សោយ ប្រៀបដូចមនុស្ស ធ្លាក់ជ្រោះ មិនអាចជាទីអាស្រ័យនៃមនុស្សដទៃបាន ដូច្នោះ ចាប់ផ្តើមអំពីភវង្គចិត្ត ដួងដំបូងតអំពីបដិសន្ធិចិត្តទៅ ទើបសុទ្ធដ្ឋករូបដែលមានចិត្តជាសមុដ្ឋានប្រាកដឡើង ដល់កាលដែលសំឡេងប្រាកដ ( គឺដល់គ្រានឹងកើតសំឡេងបាន ) សទ្ទនវកៈ ( សំណុំរូប

៩ ទាំងសំឡេង ) ទើបប្រាកដឡើងអំពីរដូវដែលប្រព្រឹត្តទៅតអំពីបដិសន្ធិក្ខណៈនោះឯង និងអំពីចិត្តផង ចំណែកសត្វពួកណាជាគព្ភសេយ្យកសត្វ អាស្រ័យកពឡិង្ការាហារ រស់នៅ សុទ្ធដ្ឋករូបដែលមានអាហារជាសមុដ្ឋាន រមែងប្រាកដក្នុងសរីរៈរបស់សត្វទាំងនោះ ដែលអាហារមាតាលេបចុះទៅជ្រួតជ្រាបចូលទៅ តាមបាលីថា

*សត្វអ្នកកំបាំងខ្លួននៅក្នុងផ្ទៃរបស់មាតាៗ របស់សត្វនោះបរិភោគភោជនណាជាបាយក្ដី ទឹកក្ដី ( ចូលទៅ ) សត្វនោះញ៉ាំងជីពឲ្យប្រព្រឹត្តទៅក្នុងផ្ទៃមាតានោះដោយភោជននោះ ។*

ដូច្នេះសម្រាប់ឱបបាតិកសត្វទាំងឡាយ សុទ្ធដ្ឋករូបដែលមានអាហារជាសមុដ្ឋាន រមែងប្រាកដក្នុងកាលដែលលេបទឹកមាត់ ដែលនៅក្នុងមាត់របស់ខ្លួនចូលទៅជាគ្រាដំបូង ព្រោះដូច្នោះ ដោយរួមចូលគ្នា ធម៌ ៩៩ គឺរូប ៩៦ បានដល់ រូប ២៦ ដោយអំណាចនៃសុទ្ធដ្ឋករូបមានអាហារជាសមុដ្ឋាន ៨ និងនវករូប ២ យ៉ាងច្រើន ដែលមានឧតុ និងចិត្តជាសមុដ្ឋាន ១៨ និងរូប ៧០ ដែលមានកម្មជាសមុដ្ឋាន ដែលកើតឡើង ៣ វារៈក្នុងខណៈចិត្តមួយៗ ដែលពោលមកមុនហើយជាមួយអរូបក្ខន្ធ ៣ ( រួមជា ៩៩ ) ឬថា ហេតុដែលសំឡេងជាវត្ថុ មិនប្រាកដ ព្រោះប្រាកដក្នុងគ្រាខ្លះប៉ុណ្ណោះ ហេតុនោះ ដកសំឡេងទាំង ២ យ៉ាង ( គឺដែលជាឧតុសមុដ្ឋាន និងចិត្តសមុដ្ឋាន ) នោះចេញ ធម៌ចំនួននេះក៏ជា ៩៧ បណ្ឌិតគប្បីជ្រាបថា ឈ្មោះថា នាមរូប ដែលមានព្រោះបច្ច័យ គឺវិញ្ញាណនៃសត្វ ទាំងពួងតាមដែលវាកើត ព្រោះថា កាលសត្វទាំងពួងនោះ សូម្បីដេកលក់ទៅ សូម្បីស្រវឹង សូម្បីស៊ី សូម្បីផឹក ធម៌ដែលមានវិញ្ញាណជាបច្ច័យទាំងនោះ ក៏គង់ប្រព្រឹត្តទៅទាំងយប់ទាំងថ្ងៃ ការដែលធម៌ទាំងនោះមានវិញ្ញាណជាបច្ច័យនោះ ខ្ញុំនឹងពណ៌នាខាងមុខ ។

ចំណែកក្នុងរូបទាំងនោះ កម្មជរូបណា កម្មជរូបនោះសូម្បីតាំងឡើងមុនក្នុងកត

កំណើត គតិ ឋិតិ និងសត្តាវាសទាំងឡាយ ( តែបើ ) រូប ៣ សមុដ្ឋាន ( គឺឧតុ ចិត្ត អាហារ ) មិនជួយឧបត្ថម្ភហើយ ក៏មិនអាចតាំងនៅបាន សូម្បីរូប ៣ សមុដ្ឋាន ( បើ ) កម្មជរូបនោះមិនឧបត្ថម្ភ ក៏មិនអាចតាំងនៅបានយូរ ( ដូចគ្នា ) ។ ដែលពិតនោះ រូបទាំង ៤ សមុដ្ឋាននោះឧបត្ថម្ភគ្នានឹងគ្នាទុកនោះឯង ទើបមិនធ្លាក់ទៅ តាំងនៅបាន មួយឆ្នាំក៏មាន ពីរឆ្នាំក៏មាន ។បេ។ ដល់ ១០០ ឆ្នាំក៏មាន ប្រព្រឹត្តទៅដល់អស់អាយុ ឬអស់បុណ្យនៃសត្វទាំងនោះ ដូចបាច់នៃដើមបបុសដែលឫសទាញទុកទាំង ៤ ទិស សូម្បីត្រូវខ្យល់វាយក៏តាំងនៅបាន និងដូចពួកមនុស្សបែកទូកដែលបានទីពឹងណា ត្រឹមតែមួយកន្លែងក្នុងមហាសមុទ្រហើយ សូម្បីត្រូវកម្លាំងរលកវាយក៏ទប់ខ្លួននៅបាន ដូច្នោះឯង ។

ការវិនិច្ឆ័យក្នុងបទថា **វិញ្ញាណប្បច្ចយា នាមរូបំ** នេះ ដោយការប្រព្រឹត្តទៅ ក្នុងទីទាំងឡាយ មានភពជាដើម បណ្ឌិតគប្បីជ្រាបដូចពោលមកដូច្នេះ ប្រការមួយ។

## វិនិច្ឆ័យដោយសង្គ្រោះ

ចំណែកក្នុងពាក្យថា ដោយសង្គហៈនោះ មានវិនិច្ឆ័យថា នាមដែលមានព្រោះ បច្ច័យ គឺវិញ្ញាណតែម្យ៉ាងទាំងក្នុងបវត្តិកាល និងបដិសន្ធិកាល ក្នុងអរូបភព និង (ចំពោះ) ក្នុងបវត្តិកាលក្នុងបញ្ចវោការភពណាក្តី រូបដែលមានព្រោះបច្ច័យ គឺវិញ្ញាណ តែម្យ៉ាងក្នុងគ្រប់កាល ក្នុងពួកអសញ្ញីសត្វ និង ( ចំពោះ ) ក្នុងបវត្តិកាលក្នុងបញ្ចវោការភពណាក្តី ទាំងនាម ទាំងរូបដែលមានព្រោះបច្ច័យ គឺវិញ្ញាណគ្រប់កាលក្នុង បញ្ចវោការភពណាក្តី នាម និងរូបទាំងពួងនោះ បណ្ឌិតគប្បីសង្គ្រោះចូលដោយ ឯកទេសសរូបេកសេសន័យ ( វិធីរួមសព្ទដែលមានរូបស្មើគ្នា តែមួយចំណែកចូល ឲ្យសល់តែមួយ ) ដូច្នេះថា នាមផង រូបផង ទាំងនាម និងរូបផង ឈ្មោះថា នាមរូប

ហើយគប្បីជ្រាបចុះថា នាមរូបនោះ ឈ្មោះថា នាម រូប ដែលមានព្រោះបច្ច័យ គឺ វិញ្ញាណ ។

បើមានពាក្យសួរថា ពាក្យវិនិច្ឆ័យនេះមិនប្រពៃ ព្រោះក្នុងពួកអសញ្ញីសត្វ មិនមានវិញ្ញាណ ដូច្នេះសោត គប្បីមានពាក្យឆ្លើយថា មិនមែនមិនប្រពៃទេ ព្រោះ

**វិញ្ញាណដែលជាហេតុនៃនាមរូបណា វិញ្ញាណនោះ អ្នកប្រាជ្ញដឹងថា មាន ២ ចំណែក គឺវិបាកវិញ្ញាណ ១ អវិបាកវិញ្ញាណ ១ ព្រោះហេតុដែលវិញ្ញាណមាន ២ ចំណែក ( ដូច្នេះ ) ពាក្យវិនិច្ឆ័យនេះ ទើបប្រពៃពិត ។**

## ពន្យល់សេចក្តី

ពិតណាស់ វិញ្ញាណណា ជាហេតុនៃនាមរូប វិញ្ញាណនោះអ្នកប្រាជ្ញជ្រាបថា មាន ២ ចំណែក ដោយចែកចេញជាវិបាកវិញ្ញាណ និងអវិបាកវិញ្ញាណ ក្នុងពួកអសញ្ញីសត្វ ក៏វិញ្ញាណនេះឯងជារូប ដែលមានព្រោះបច្ច័យ គឺអភិសង្ខារវិញ្ញាណ ដែលប្រព្រឹត្តទៅក្នុងបញ្ចវោការភព ព្រោះជារូបដែលមានកម្មជាសមុដ្ឋាន ក្នុងបវត្តិ-កាល ក្នុងបញ្ចវោការភពក៏យ៉ាងនោះ គឺក្នុងខណៈចិត្ត មានកុសលចិត្តជាដើម រូបក៏មានកម្មជាសមុដ្ឋាន ( ដូចគ្នា ) ព្រោះដូច្នោះ ទើបពាក្យវិនិច្ឆ័យប្រពៃ ។

វិនិច្ឆ័យក្នុងបទថា **វិញ្ញាណប្បច្ចយា នាមរូបំ** នេះ ដោយសង្ខេបចូល បណ្ឌិតគប្បីជ្រាបដូចពោលមកដូច្នេះ ប្រការ ១ ។

## ដោយបច្ចយន័យ

ក្នុងពាក្យថា ដោយបច្ចយន័យនោះ មានវិនិច្ឆ័យថា

**វិបាកវិញ្ញាណដែលជាបច្ច័យនៃនាម ៩ យ៉ាង នៃវត្ថុរូប ( គឺហទយ ) ក៏ ៩ យ៉ាង នៃរូបដ៏សេស ៨ យ៉ាង អភិសង្ខារវិញ្ញាណជាបច្ច័យនៃរូបតែម្យ៉ាង ចំណែក**

វិញ្ញាណក្រៅនោះជាបច្ច័យនៃនាមរូបនោះៗ តាមគួរ ។

## ពង្រីកសេចក្ដី

ពិតណាស់ នាមដែលរាប់ថាជាវិបាក ក្នុងបដិសន្ធិកាល ឬក្នុងបវត្តិកាលក្ដី វិបាកវិញ្ញាណដែលប្រព្រឹត្តទៅក្នុងបដិសន្ធិកាលខ្លះ កាលដទៃខ្លះ រមែងជាបច្ច័យ ៩ យ៉ាង ដោយសហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ សម្បយុត្តប្បច្ច័យ វិបាកប្បច្ច័យ អាហារប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ អត្ថិប្បច្ច័យ និងអវិគតប្បច្ច័យនៃនាមនោះ ដែលផ្សំជាមួយរូប ឬមិនបានផ្សំក៏ដោយ ជាបច្ច័យ ៩ យ៉ាង ដោយសហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ វិបាកប្បច្ច័យ អាហារប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ វិប្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ និងអវិគតប្បច្ច័យ នៃវត្ថុរូបក្នុងបដិសន្ធិកាល តែជាបច្ច័យដោយបច្ច័យ ៩ នេះ ដកអញ្ញមញ្ញប្បច្ច័យចេញ សល់ ៨ នៃរូបដ៏សេស វៀរវត្ថុរូប ចំណែកអភិសង្ខារវិញ្ញាណ ជាបច្ច័យតែម្យ៉ាង ដោយឧបនិស្សយប្បច្ច័យប៉ុណ្ណោះ នៃរូបអសញ្ញីសត្វខ្លះ នៃកម្មជរូបក្នុងបញ្ចវោការភពខ្លះ (ទាំងនេះ) ដោយបរិយាយតាមព្រះសូត្រ វិញ្ញាណដ៏សេសទាំងអស់រាប់អំពីភវង្គដួងដំបូង គប្បីជ្រាបថា រមែងជាបច្ច័យនៃនាមរូបនោះៗ តាមគួរដែលនឹងសម្ដែងបច្ចយន័យ នៃនាមរូបនោះដោយពិស្ដារ ក៏ចាំបាច់ត្រូវអធិប្បាយបង្ហាញកថាទាំងអស់ ព្រោះហេតុនេះ ទើបខ្ញុំមិនផ្ដើមវិត្ថារន័យ នោះ ។

ក្នុងការដែលវិញ្ញាណជាបច្ច័យនៃនាមរូបនោះ បើមានពាក្យសួរថា បើនាមរូបក្នុងបដិសន្ធិ រមែងមានព្រោះបច្ច័យ គឺវិញ្ញាណនោះនឹងគប្បីជ្រាបបានដូចម្ដេច ? ដូច្នេះ គប្បីឆ្លើយថា ជ្រាបបានដោយព្រះសូត្រ និងដោយយុត្តិ ( គឺសេចក្ដីអនុមានដែលប្រពៃដោយហេតុ ) ។

ពិតហើយ ក្នុងព្រះសូត្រ កាលដែលនាមធម៌ទាំងឡាយ មានវេទនាជាដើម មានវិញ្ញាណជាបច្ច័យជាចំណែកច្រើន ជាការសម្រេចបាន ដោយន័យក្នុងព្រះសូត្រ ដូចពាក្យថា **ចិត្តានុបរិវត្តិនោ ធម្មា**-ធម៌ទាំងឡាយ រមែងវិលវល់ទៅតាមចិត្ត ដូច្នេះ ជាអាទិ៍ ចំណែកពោលដោយយុត្តិដូច្នេះថា

## គាថាសង្ខេប

ពាក្យថា វិញ្ញាណជាបច្ច័យនៃរូបសូម្បីដែលមើលមិនឃើញ រមែងសម្រេចបាន ដោយចិត្តជរូបដែលមើលឃើញបានក្នុងលោកនេះ ។

## ពង្រីកសេចក្តី

ពាក្យថា កាលចិត្តផូរផង់ ឬមិនផូរផង់ រូបដែលប្រព្រឹត្តទៅតាមចិត្តនោះ កាលកើតឡើងជារូបដែលមើលឃើញបាន និងការអនុមាន ដល់រូបដែលមិនឃើញ ក៏មានបានដោយរូបដែលមើលឃើញ ដូច្នេះ ពាក្យថា វិញ្ញាណជាបច្ច័យនៃបដិសន្ធិ រូបដែលមើលមិនឃើញនោះ គប្បីជ្រាបបានដោយចិត្តជរូប ដែលមើលឃើញបាន ក្នុងលោកនេះ ។ ពិតណាស់ រូបដែលមានកម្មជាសមុដ្ឋាន ក៏មានវិញ្ញាណជាបច្ច័យបាន ដូចរូបដែលមានចិត្តជាសមុដ្ឋាន មានមកក្នុង **គម្ពីរបដ្ឋាន** ។

វិនិច្ឆ័យក្នុងបទថា **វិញ្ញាណប្បច្ចយា នាមរូបំ** នេះ ដោយបច្ចយន័យ បណ្ឌិតគប្បីជ្រាបដូចពោលមកដូច្នេះ ប្រការមួយ ។

នេះជាកថាយ៉ាងពិស្តារ ក្នុងបទថា **វិញ្ញាណប្បច្ចយា នាមរូបំ** ។

# មហាដីកា

## អធិប្បាយកថាពណ៌នាដោយពិស្តារនៃបទថា ព្រោះវិញ្ញាណជាបច្ច័យ ទើបមាននាមរូប

ពាក្យថា **ដោយវិភាគនៃនាមរូប** គឺដោយប្រភេទនៃនាម និងរូប ។

ក្នុងពាក្យនោះ លោកអាចារ្យកាលសម្តែងប្រភេទនៃនាមមុន សូម្បីវិញ្ញាណក៏ជានាមដូចគ្នា សូម្បីយ៉ាងនោះក៏ពោលថា **ខន្ធ ៣ មានវេទនាខន្ធជាដើម ឈ្មោះថា នាម ព្រោះបង្អោនទៅចំពោះមុខចំពោះអារម្មណ៍** ដើម្បីសម្តែងធម៌ដែលជាបច្ច័យ និងធម៌ដែលកើតអំពីបច្ច័យ ដោយមិនលាយឡំគ្នា តែក្នុងទីនេះ ព្រោះនិព្វានជាធម៌ដែលមិនមានបច្ច័យ ក្នុងកថាពោលដោយការប្រព្រឹត្តទៅ និងព្រោះមិនមានអត្ថថាបង្អោនទៅ ទើបមិនមានការទាក់ទងគ្នាឡើយ ។ ក៏និព្វាននោះ ឈ្មោះថា **នាម** ដោយអត្ថថា ធ្វើឲ្យឱនទៅ មិនមែនដោយអត្ថថា ការបង្អោនទៅ ។ **តេសំ យោគ នាមរូបានំ** ប្រែថា នៃនាមរូបទាំងនោះ **វិភាគ** នៃនាមរូបទាំងនោះ ដោយជាសុខ វេទនាជាដើម និងដោយជាបឋវីធាតុជាដើមនោះឯង ។

ពាក្យថា **សត្តាវាសមួយ** បានដល់ អសញ្ញសត្តាវាស ។ ក្នុងសត្តាវាស ទាំង ៥ គឺក្នុងសត្តាវាស ៤ ខាងដើម និងក្នុងអសញ្ញសត្តាវាស ។

លោកអាចារ្យពោលថា **និងនៃពួកសត្វអណ្ឌជកំណើត** ដូច្នេះ ព្រោះលោកកាន់យកពួកសត្វជលាពុជកំណើត ដោយស័ព្ទថា **គព្ភសេយ្យក** ។ គប្បីប្រកបសេចក្តីថា និងនៃពួកសត្វអណ្ឌជកំណើតដែលមិនទាន់មានភាវរូប ។ ពាក្យថា **សន្តតិសីសៈ** គឺរូបកលាបៈដែលមានមូលនៃការបន្ត ។ម្យ៉ាងទៀត ភាវរូបមិនមាននៅក្នុងបដិសន្ធិក្ខណៈក៏ពិត សូម្បីដូច្នោះ លក្ខណរូប និងបរិច្ឆេទរូបក៏នៅមាន ព្រោះហេតុនោះ លក្ខណរូប

និងបរិច្ឆេទរូបទាំងនោះ ពោលដោយបរមត្ថ ក៏ជាអបរិផន្នរូប ព្រោះហេតុនោះ លោកអាចារ្យកាលនឹងវៀរចេញ ទើបពោលថា **ដោយជារូបរូប** ។ លោកអាចារ្យនាំយកនាមធម៌ មានផស្សៈជាដើមចូលតែមួយ ជាសង្គហៈរក្ខន្ធ ។ ទើបពោលថា **ធម៌ ២៣** ។ ពាក្យថា **ទាញចេញ** គឺមិនកាន់យករូបធម៌ មានបឋវីធាតុជាដើម ដែលនៅក្នុងកលាបៈដទៃជាសភាវៈមានលក្ខណៈស្មើគ្នា ។

បទថា **តេសំ យោគ ព្រហ្មកាយិកាទីនំ** ប្រែថា នៃរូបព្រហ្ម មានពួកព្រហ្មកាយិកជាដើមនោះ ។ ពាក្យថា **ដោយពិស្តារ** គឺដោយមិនសង្ខេបរូបទាំងឡាយចុះក្នុងសន្តតិសីសៈទាំង ៤ ។

ក្នុងពាក្យថា **ចំណែកក្នុងកាមភព ហេតុដែលក្នុងបដិសន្ធិក្ខណៈនៃពួកសត្វឱបបាតិកកំណើតដ៏សេសក្តី** នេះ ពួកសត្វឱបបាតិកៈក្នុងកាមភពដែលជាហេតុក្នុងស័ព្ទឱបបាតិកកំណើតដ៏សេស គប្បីជាពាក្យដែលមានប្រយោជន៍ក៏ពិត សូម្បីដូច្នោះក៏គប្បីជ្រាបថា លោកធ្វើស័ព្ទថា **ឱបបាតិកកំណើតដ៏សេស** ព្រោះពួកសត្វឱបបាតិកៈនិងសំសេទជៈ ជាពួកដ៏សេសអំពីពួកសត្វ ដែលជាអណ្ឌជកំណើត និងគព្ភសេយ្យកកំណើត ។ ន័យម្យ៉ាងទៀត លោកអាចារ្យពោលថា **នៃពួកសត្វឱបបាតិកកំណើតដ៏សេស** ដូច្នេះ សំដៅយកពួកដ៏សេសអំពីពួកសត្វឱបបាតិកៈ មានព្រហ្មកាយិកៈជាដើមដែលបានពោលទុកហើយ ។ ឯឱបបាតិកៈទាំងនោះ សូម្បីជាពួកអរូបព្រហ្មក៏មាន ព្រោះហេតុនោះ ទើបពោលថា **ក្នុងកាមភព** ។ ចំណែកនាមរូបរបស់ពួកសត្វដែលមានអាយតនៈមិនគ្រប់ គប្បីឃើញថា លោកមិនបានពោលទុក ព្រោះអាចនឹងដឹងបានដោយការកំណត់ធម៌តាមន័យដែលពោលហើយ ក្នុងនិទ្ទេសនៃវិញ្ញាណផ្សំជាមួយរូបតាមគួរ ។

ពាក្យថា **ដោយឧតុដែលប្រព្រឹត្តទៅព្រមជាមួយបដិសន្ធិចិត្ត** គឺដោយតេជោ

ធាតុក្នុងរូបដែលកើតឡើងព្រមជាមួយបដិសន្ធិចិត្ត ។ បដិសន្ធិចិត្ត **ជាធម្មជាតិ មានកម្លាំងទន់ខ្សោយ** ព្រោះហទយវត្ថុដែលកើតក្នុងខណៈនោះ ។ ក្ណាប់សេចក្តីថា សុទ្ធដ្ឋករូបដែលមានអាហារជាសមុដ្ឋាន រមែងប្រាកដក្នុងសរីរៈរបស់សត្វទាំងនោះ ដែលអាហារមាតាលេបចូលទៅជ្រួតជ្រាប ។ បទថា **តិរោ** សេចក្តីប៉ុនគ្នានឹង **តិរោក្ខា** ប្រែថា ឃើញបានខាងក្រៅ ដោយការៈដែលនៅក្នុងផ្ទៃរបស់មាតានោះឯង ។ អដ្ឋករូប ២ ប៉ុណ្ណោះយ៉ាងតិច ជារូប មានឧតុ និងចិត្តជាសមុដ្ឋាន ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **យ៉ាងច្រើននវករូប ២** ដូច្នេះ សំដៅដល់វេលាដែលមានសំឡេងបាន ។ ពាក្យថា **បុព្វេតិ** សេចក្តីថា លោកអាចារ្យពោលថា **រូប ៧០ ដែលមានកម្មជាសមុដ្ឋាន ដែលកើត ៣ ដង ក្នុងខណៈចិត្តនីមួយៗ ដែលពោលមកអំពីមុនហើយ** ព្រោះធ្វើអធិប្បាយណាថា រូបណាមានសន្តតិរូប ២ ជាដើម មានសត្តករូបជាទីបំផុត ដែលពោលទុកក្នុងទីនេះអំពីមុន រូបនោះកើតឡើងនៅក្នុងខណៈទាំង ៣ នៃចិត្ត ១ ដួងៗ នោះឯង ដែលបានពោលទុកហើយ ។ បទថា **ទុវិធម្បិ តំ** ប្រែថា សំឡេងទាំង ២ យ៉ាងនោះ គឺសំឡេងដែលមានឧតុជាសមុដ្ឋាន និងសំឡេងដែលមានចិត្តជាសមុដ្ឋាន ។

បទថា **សណ្ឋាតុំ** ប្រែថា ដើម្បីតាំងនៅដោយជាធម្មជាតិតាំងនៅយូរ តែរមែងតាំងនៅត្រឹមមួយខណៈនៃខ្ទួនប៉ុណ្ណោះ ។ បទថា **ចតុទ្ទិសវវដ្ឋាបិតា** សេចក្តីថា មានត្រួយព័ទ្ធព័ន្ធគ្នានឹងគ្នាដែលឫសទាញទុកក្នុងទិសទាំង ៤ ។ **និងដូចពួកអ្នកទូក** ឈរឱបគ្នានឹងគ្នា ។

លោកអាចារ្យពោលសំដៅយកបវត្តិកាលនៃកម្មជរូប ដែលញ៉ាំងរូបឲ្យកើត និងបញ្ចវិញ្ញាណ និងបច្ច័យ គឺវិញ្ញាណដែលកើតរួមគ្នា **និងក្នុងបវត្តិកាលក្នុងបញ្ចវោការភព** ។ ក្នុងកាលនោះ រមែងមានតែនាមប៉ុណ្ណោះ ព្រោះបច្ច័យ គឺវិញ្ញាណ

នោះ ។ តែព្រោះកម្ម និងវិញ្ញាណជាបច្ច័យ ទើបអាចពោលបានថា មានទាំង ២ យ៉ាង ក្នុងកាលនោះ និងព្រោះវិញ្ញាណដែលកើតខាងក្រោយជាបច្ច័យ ទើបរូបជាធម្មជាតិដែលបានទទួលឧបត្ថម្ភ ។ ពាក្យថា **ក្នុងពួកអសញ្ញីសត្វ** ជាដើម លោកអាចារ្យពោលសំដៅដល់បច្ច័យ គឺកម្ម និងវិញ្ញាណ ។ ពាក្យថា **ក្នុងបវត្តិកាល ក្នុងបញ្ចវោការភព** លោកអាចារ្យពោលសំដៅដល់កាលកើតឡើងនៃរូបដោយកម្មដទៃអំពីកម្ម ដែលធ្វើឲ្យភវង្គជាដើមកើត កាលនៃនិរោធសមាបត្តិ និងកាលដទៃ អំពីកាលកើតឡើងនៃភវង្គជាដើម ព្រោះហេតុនោះ ទើបប្រពៃហើយ ។ អាចពោលបានថា រូបដែលកើតឡើងដោយកម្មដែលធ្វើឲ្យកើតភវង្គជាដើមនោះ ក្នុងកាលកើតឡើង ភវង្គជាដើម និងវិបាកនោះ ក៏រមែងមានកម្ម និងវិញ្ញាណជាបច្ច័យ ។ ពិតហើយ រូបសូម្បីមិនសំដៅដល់បច្ច័យ គឺវិញ្ញាណដែលកើតរួមគ្នា ក៏ប្រព្រឹត្តទៅដោយកម្មក្នុងបវត្តិកាល ចំណែកនាមជាធម្មជាតិ សម្ព័ន្ធកម្ម និងវិញ្ញាណបាន ដូច្នេះឯង ។ ពាក្យថា **សព្វកាល** គឺក្នុងបដិសន្ធិកាល និងក្នុងបវត្តិកាល ។ បណ្ឌិតគប្បីប្រកបនាមរូប ព្រោះវិញ្ញាណដែលកើតរួមគ្នាជាបច្ច័យ និងនាមរូប ព្រោះកម្ម និងវិញ្ញាណជាបច្ច័យតាមគួរ ។ នាមរូបស័ព្ទ ក្នុងពាក្យថា **នាមផង រូបផង ទាំងនាម និងរូបផង** ជាសរូបនាមស័ព្ទ ដោយនាមស័ព្ទ និងជាសរូបរូបស័ព្ទ ដោយរូបស័ព្ទដែលជាចំណែកមួយរបស់ខ្លួន ព្រោះហេតុនោះ ទើបជាឯកសេសនៃសរូបទាំងឡាយ ព្រោះដូច្នោះ ទើបឈ្មោះថា **ឯកទេសសរូបេកសេស** អធិប្បាយថា ទីតាំងនៃនាមរូបស័ព្ទ នឹងមិនសម្តែងនាមរូបស័ព្ទក្រៅអំពីនេះ ។

វិញ្ញាណដទៃអំពីវិបាក ឈ្មោះថា **អវិបាក** ។ គប្បីប្រកបសេចក្តីថា ព្រោះវិញ្ញាណ អ្នកប្រាជ្ញតែងជ្រាបថា មាន ២ ចំណែក ទើបវិញ្ញាណនេះប្រពៃពិត ។

ដោយ **អាទិ**-ស័ព្ទថា **កុសលាទីចិត្តក្ខណេ** ក្នុងខណៈចិត្ត មានកុសលចិត្ត

ជាដើម គប្បីជ្រាបថា លោកសង្គ្រោះរូបដែលមានកម្ម ដែលមិនឲ្យកើតវិបាកជាសមុដ្ឋាន ក្នុងខណៈវិបាកចិត្ត ដូចក្នុងខណៈអកុសលចិត្ត និងកិរិយាចិត្ត ។ តែក្នុងខណៈវិបាកចិត្ត រមែងបានទាំង ២ យ៉ាងតាមន័យដែលពោលហើយអំពីមុន ព្រោះអភិសង្ខារវិញ្ញាណ ជាបច្ច័យ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **ក្នុងខណៈចិត្ត** មានកុសលចិត្តជាដើម ដើម្បីវៀរខណៈវិបាកចិត្តដូច្នោះ ។

ពាក្យថា **ដោយបរិយាយតាមព្រះសូត្រ** លោកអាចារ្យពោលទុក ព្រោះលោកមិនបានពោលឧបនិស្សយប្បច្ច័យនៃរូបទាំងឡាយ ទុកក្នុងគម្ពីរបដ្ឋាន ។ ឯក្នុងព្រះសូត្រ ព្រះមានព្រះភាគបានត្រាស់ថា **នាមរូបពឹងអាស្រ័យវិញ្ញាណ** និងត្រាស់រូបដែលមានវិញ្ញាណជាឧបនិស្ស័យ ព្រោះធ្វើអធិប្បាយថា កាលធម្មជាតិ មានធម្មជាតិនេះក៏មាន និងកាលមិនមាន វាក៏មិនមាន ធម៌នោះជាឧបនិស្ស័យ ជាមូល ជាហេតុ ជាដែនកើតមុនរបស់ធម៌នោះ ដូច្នេះ ។ និងក្នុង **វនបត្ថបរិយាយ** ( ហេតុរបស់ការនៅព្រៃស្ងាត់ ) ព្រះមានព្រះភាគបានត្រាស់ការនៅដោយឥរិយាបថ ដែលមានព្រៃស្ងាត់ ស្រុក និគម នគរ ជនបទ និងបុគ្គលជាឧបនិស្ស័យ តអំពីនោះ ក៏បានត្រាស់ការកើតឡើងដោយលំបាក និងមិនលំបាកនៃបច្ច័យគ្រឿងឧបការៈជីវិត មានចីវរជាដើម និងព្រៃស្ងាត់ជាដើមក៏មិនបានប្រមូលយកឥរិយាបថនិងការកើតឡើងនៃបច្ច័យឧបការៈជីវិត មានចីវរជាដើម ជាអារម្មណប្បច្ច័យ និងជាឧបនិស្សយប្បច្ច័យជាដើម ព្រោះហេតុនោះ ការវៀរចាក គឺការមិនមាននោះឯង បណ្ឌិតគប្បីឃើញថា ជាឧបនិស្ស-យប្បច្ច័យដោយបរិយាយតាមព្រះសូត្រ ។ លោកអាចារ្យពោលនាមដែលជាបច្ច័យដោយចំណែកមួយប៉ុណ្ណោះ ដោយបរិយាយតាមព្រះសូត្រដល់រូបប៉ុណ្ណោះ ព្រោះមិនមានពាក្យដែលគួរនឹងពោលថា **អភិសង្ខារវិញ្ញាណ** ជាអារម្មណប្បច្ច័យក្នុងបដិសន្ធិកាល មានកម្មជាអារម្មណ៍ជាដើមនោះឯង ។ កាលពោលថា អភិសង្ខារវិញ្ញាណនេះ

ជាបច្ច័យដល់រូប ដែលមានសេចក្តីគួរឲ្យសង្ស័យ ពាក្យដែលគួរពោលថា ជាបច្ច័យដល់នាមនោះឯង រមែងមិនមាន ដូច្នេះ ។

ព្រោះបវត្តិកាលដែលជាក់ច្បាស់ ទើបលោកអាចារ្យកាន់យកបដិសន្ធិកាលដែលមិនជាក់ច្បាស់ ដោយពាក្យថា **ប្រការដែលនាមរូបក្នុងបដិសន្ធិមាន ព្រោះវិញ្ញាណជាបច្ច័យនេះ គប្បីជ្រាបបានដូចម្តេច** ដូច្នេះជាដើម ។ នាមគប្បីជ្រាបថា មានព្រោះវិញ្ញាណជាបច្ច័យដោយព្រះសូត្រ រូបគប្បីជ្រាបថា មានព្រោះវិញ្ញាណជាបច្ច័យដោយយុត្តិ ។

លោកអាចារ្យកាលញ៉ាំងអត្ថឲ្យសម្រេចដោយយុត្តិហើយ កាលធ្វើសេចក្តីនោះឲ្យមាំទាំដោយព្រះសូត្រ ទើបពោលពាក្យជាដើមថា **ពិតហើយ រូបដែលមានកម្មជាសមុដ្ឋាន** ដូច្នេះជាដើម ។ បទថា **ចិត្តសមុដ្ឋានស្សេវ** ប្រែថា ដូចគ្នានឹងរូប ដែលមានចិត្តជាសមុដ្ឋាន ។ ក្នុងសេចក្តីនេះ ព្រះមានព្រះភាគត្រាស់ទុកថា **នាមរូប មានព្រោះវិញ្ញាណជាបច្ច័យ** ដូច្នេះ គឺទ្រង់ប្រកាសព្រះធម្មចក្រដ៏កំពូលដែលបុគ្គលណាម្នាក់ បង្វិលមិនបាន ព្រោះថា ដោយបរមត្ថត្រឹមតែនាមរូបប៉ុណ្ណោះ ដែលប្រព្រឹត្តទៅរមែងប្រាកដដល់បណ្ឌិតទាំងឡាយ ដែលពិចារណាឃើញសត្វ ឬជីវៈប្រាកដមិនមាន ។ ពិតហើយ ការប្រកាសធម្មចក្រ ក៏ជាគ្រឿងប្រកាសសុញ្ញតា ( ធម្មជាតិទទេ ) ដូច្នេះឯង ។ ម្យ៉ាងទៀត ព្រះមានព្រះភាគត្រាស់បវត្តិដែលត្រឹមតែជាទុក្ខសច្ច ដោយការត្រាស់ត្រឹមតែនាមរូប ។ និងដោយការប្រកាសទុក្ខសច្ច ទ្រង់ប្រកាសហេតុកើតរបស់ទុក្ខនោះ ការរលត់ទុក្ខនោះ និងបដិបទាដែលជាគ្រឿងឲ្យដល់នូវការរលត់ផងនោះឯង ។ បណ្ឌិតគប្បីពង្រីកការប្រកាសព្រះធម្មចក្រ ជាគ្រឿងប្រកាសសច្ចៈ ៤ គឺព្រោះហេតុមិនមាន ទុក្ខក៏មិនមាន ព្រោះហេតុរលត់ទុក្ខ បុគ្គលរលត់ក៏មិនមាន និងព្រោះនិរោធវៀរចាកឧបាយក៏សម្រេចមិនបាន ។

# វិសុទ្ធិមគ្គ

## អធិប្បាយបទថា នាមរូបប្បច្ចយា សឡាយតនំ

## គាថាសង្ខេប

ក្នុងបទថា នាមរូបប្បច្ចយា សឡាយតនំ

នាម បានដល់ ខន្ធ ៣ រូប បានដល់ រូប មានភូតរូប និងវត្ថុរូបជាដើម នាមរូបនោះដែលធ្វើឲ្យជាឯកសេស ជាបច្ច័យនៃសឡាយតនៈនោះដែលធ្វើឲ្យជាឯកសេសដូច្នោះដូចគ្នា ។

## អធិប្បាយសេចក្តី

សេចក្តីថា នាមរូបដែលជាបច្ច័យនៃសឡាយតនៈនោះ ក្នុងនាមរូបនោះ គប្បីជ្រាបថា ខន្ធ ៣ មានវេទនាជាដើម ឈ្មោះថា នាម ចំណែករូបដែលទាក់ទងដោយវត្ថុដែលមានសន្តតិ ដោយចំពោះបានដល់រូប មានភូតរូប និងវត្ថុ ( ទ្វារ ) រូបជាដើមយ៉ាងនេះ គឺភូតរូប ៤ វត្ថុរូប ៦ ជីវិតិន្ទ្រិយរូប ១ ឯនាមរូបនោះដែលធ្វើឲ្យជាឯកសេសថា នាមផង រូបផង ទាំងនាម និងរូបផង ឈ្មោះថា នាមរូប ដូច្នេះ គប្បីជ្រាបថា រមែងជាបច្ច័យនៃសឡាយតនៈដែលធ្វើ ឲ្យជាឯកសេសដូចគ្នាដូច្នេះថា **ឆដ្ឋាយតនៈ** សួរថា ព្រោះហេតុអ្វី ( ទើបធ្វើឯកសេសយ៉ាងនោះ ) ? ឆ្លើយថា ព្រោះក្នុងអរូបភព នាមតែម្យ៉ាងជាបច្ច័យ និងនាមនោះក៏ជាបច្ច័យនៃអាយតនៈទី ៦ ប៉ុណ្ណោះ មិនជាបច្ច័យនៃអាយតនៈដទៃឡើយ សមដូចពាក្យក្នុងវិភង្គថា **នាមរូបប្បច្ចយា ឆដ្ឋាយតនំ** អាយតនៈទី ៦ រមែងមានចំពោះបច្ច័យ គឺនាម ដូច្នេះ ។

ក្នុងបទនេះ ប្រសិនបើមានពាក្យសួរថា ពាក្យថា នាមរូបជាបច្ច័យនៃសឡាយតនៈនោះ គប្បីជ្រាបបានដូចម្តេច ? ចម្លើយមានដូច្នេះថា ជ្រាបបានដោយសឡាយតនៈ

នោះមានក្នុងកាលនាមរូបមាន ។ ពិតណាស់ ព្រោះមាននាម និងរូបនោះៗ ទើបអាយតនៈនោះៗ មាន មិនមែនមានដោយប្រការដទៃឡើយ ។ ឯភាពដែលអាយតនៈមាន ព្រោះនាមរូបនោះមាន នឹងមានច្បាស់ ក្នុងបច្ចយន័យនោះឯង ( តទៅនេះ ) ព្រោះដូច្នោះ ក្នុងបដិសន្ធិកាល ឬក្នុងបវត្តិកាលក្តី នាមណា និងរូបណា ជាបច្ច័យនៃអាយតនៈណា និងជាបច្ច័យដោយប្រការណា អ្នកប្រាជ្ញគប្បីនាំមកដោយប្រការនោះ ហោង ។

( តទៅ ) នេះជាពាក្យពង្រីកសេចក្តីក្នុងគាថា ( បច្ចយន័យ ) នោះ

## នាមជាបច្ច័យក្នុងអរូបភព

សេចក្តីថា ក្នុងអរូបភព នាមតែម្យ៉ាងជាបច្ច័យ ៧ យ៉ាង ( និង ) ៦ យ៉ាង ក្នុងបដិសន្ធិកាល និងបវត្តិកាលនោះ ( ថា ) ដោយយ៉ាងតិច ។

សេចក្តីនេះដូចម្តេច ? យើងនឹងពោលក្នុងបដិសន្ធិកាលមុន ដោយយ៉ាងតិច នាមរមែងជាបច្ច័យ នៃឆដ្ឋាយតនៈ ៧ យ៉ាង ដោយជាសហជាតប្បច្ច័យ អញ្ញមញ្ញ-ប្បច្ច័យ និស្សយប្បច្ច័យ សម្បយុត្តប្បច្ច័យ វិបាកប្បច្ច័យ អត្ថិប្បច្ច័យ និងអវិគតប្បច្ច័យ ។ ម្យ៉ាងទៀត ក្នុងបដិសន្ធិកាល នាមជាបច្ច័យ ដោយប្រការដទៃខ្លះក៏មានដូច្នេះ គឺនាមខ្លះកើតដោយហេតុប្បច្ច័យ ខ្លះទៀតកើត ដោយអាហារប្បច្ច័យ យ៉ាងច្រើននិងយ៉ាងតិច គប្បីជ្រាបដោយអំណាចហេតុប្បច្ច័យជាដើមនោះ សូម្បីក្នុងបវត្តិកាល នាមដែលជាវិបាកក៏ជាបច្ច័យដោយន័យដែលពោលហើយដូចគ្នា តែក្នុងបច្ច័យមានប្រការដូចពោលដោយយ៉ាងតិច ( នោះ ) នាមក្រៅអំពីនេះ ( គឺនាមដែលមិនមែនវិបាក ) រមែងជាបច្ច័យដោយបច្ច័យ ៦ វៀរវិបាកប្បច្ច័យ ។ ម្យ៉ាងទៀត ក្នុងបវត្តិកាលនេះ អវិបាកនាមជាបច្ច័យដោយប្រការដទៃខ្លះក៏មានដូច្នេះ គឺនាមពួកខ្លះកើតដោយហេតុប្បច្ច័យ ពួកខ្លះកើតដោយអាហារប្បច្ច័យ ចំណែកយ៉ាងច្រើន និងយ៉ាង

តិច គប្បីជ្រាបដោយអំណាចនៃហេតុប្បច្ច័យជាដើមនោះ ។

## គាថាសង្ខេបនាមជាបច្ច័យក្នុងភពឯទៀតក្នុងបដិសន្ធិ

សូម្បីក្នុងភពដទៃ នាមក៏ជាបច្ច័យនៃអាយតនៈទី ៦ ក្នុងបដិសន្ធិយ៉ាងនោះ ( គឺ ៧ យ៉ាង ) ដូចគ្នា តែនាមនោះជាបច្ច័យនៃអាយតនៈក្រៅអំពីនេះ ដោយអាការ ៦ ។

## ពន្យល់សេចក្តី

សេចក្តីថា សូម្បីក្នុងភពដទៃក្រៅអំពីអរូបភព គឺក្នុងបញ្ចវោការភព វិបាកនាមនោះ ជាសម្ពាញ់ ( គឺរួមជាមួយ ) ហទយវត្ថុ ជាបច្ច័យនៃអាយតនៈទី ៦ គឺមនាយតនៈ យ៉ាងតិចក៏ ៧ យ៉ាងដូចដែលពោលក្នុង ( វគ្គ ) អរូបភពដូចគ្នា តែនាមជាសម្ពាញ់ ( គឺរួមជាមួយ ) មហាភូត ៤ ជាបច្ច័យនៃអាយតនៈ ៥ ក្រៅអំពីនេះ មានចក្ខាយតនៈជាដើម ដោយអាការ ៦ ដោយជាសហជាតប្បច្ច័យ និស្សយប្បច្ច័យ វិបាកប្បច្ច័យ វិប្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ និងអវិគតប្បច្ច័យ ។ម្យ៉ាងទៀត ក្នុងបដិសន្ធិកាលនេះ វិបាកនាមជាបច្ច័យដោយប្រការដទៃខ្លះក៏មានដូច្នេះ គឺនាមពួកខ្លះកើតដោយហេតុប្បច្ច័យ ពួកខ្លះកើតដោយអាហារប្បច្ច័យ ចំណែកយ៉ាងច្រើន និងយ៉ាងតិច គប្បីជ្រាបដោយអំណាចនៃហេតុប្បច្ច័យជាដើមនោះ ។

## គាថាសង្ខេបនាមជាបច្ច័យនៃឆដ្ឋាយតនៈក្នុងបវត្តិកាល

សូម្បីក្នុងបវត្តិកាល វិបាកនាមក៏ជាបច្ច័យនៃអាយតនៈទី ៦ ដែលជាវិបាកយ៉ាងនោះ ( គឺ ៧ យ៉ាង ) ចំណែកអវិបាកនាមជាបច្ច័យនៃអាយតនៈទី ៦ ដែលមិនមែនវិបាក ៦ យ៉ាង ។

## ពន្យល់ដីកាសេចក្តី

*សេចក្តីថា សូម្បីក្នុងបវត្តិកាលក្នុងបញ្ចវោការភព វិបាកនាមក៏ជាបច្ច័យនៃអាយតនៈទី ៦ ដែលជាវិបាក យ៉ាងតិចក៏ ៧ យ៉ាង ដូចក្នុងបដិសន្ធិកាលដូចគ្នា ចំណែកអវិបាកនាមជាបច្ច័យនៃអាយតនៈទី ៦ ដែលមិនមែនវិបាក យ៉ាងតិច ៦ យ៉ាងប៉ុណ្ណោះ ដោយទាញវិបាកប្បច្ច័យចេញអំពីបច្ច័យ ៧ នោះ ចំណែកយ៉ាងច្រើន និងយ៉ាងតិចក្នុងបច្ច័យពេលនេះ ក៏គប្បីជ្រាបដោយន័យដែលពោលហើយនោះឯង ។*

## គាថាសង្ខេបនាមជាបច្ច័យនៃអាយតនៈដ៏សេស

***ក្នុងបវត្តិកាលនោះឯង វិបាកនាមជាបច្ច័យនៃអាយតនៈ ៥ ដ៏សេស ៤ យ៉ាង សូម្បីអវិបាកនាម លោកក៏ប្រកាសទុកដូចគ្នាយ៉ាងនោះ ។***

## ពន្យល់ដីកាសេចក្តី

*សេចក្តីថា ក្នុងបវត្តិកាលនោះៗ ឯង វិបាកនាមដែលជាវត្ថុនៃបសាទ មានចក្ខុបសាទជាដើមក្តី ក្រៅអំពីនោះក្តី រមែងជាបច្ច័យ ៤ យ៉ាង នៃអាយតនៈដ៏សេស ៥ មានចក្ខាយតនៈជាដើម ដោយជាបច្ឆាជាតប្បច្ច័យ វិប្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ និងអវិគតប្បច្ច័យ ។ ឯវិបាកនាមជាបច្ច័យ យ៉ាងណា សូម្បីអវិបាកនាម លោកក៏ប្រកាសទុក ( ថាជាបច្ច័យ ) យ៉ាងនោះដូចគ្នា ព្រោះហេតុនោះ គប្បីជ្រាបថា នាម សូម្បីបែកផ្សេងគ្នា ដោយជាកុសលជាដើម ក៏ជាបច្ច័យនៃអាយតនៈ ៥ នោះ ៤ យ៉ាង ។*

*នាមតែម្យ៉ាងជាបច្ច័យនៃអាយតនៈណាមួយ និងជាបច្ច័យដោយប្រការណាមួយ ក្នុងបដិសន្ធិកាល ឬក្នុងបវត្តិកាលក្តី បណ្ឌិតគប្បីជ្រាបដោយប្រការនោះ ដូចពោលមកដូច្នេះ ជាលំដាប់ដំបូង ។*

# រូបជាបច្ច័យ

## គាថាសង្ខេប

ចំណែករូបមិនជាបច្ច័យនៃអាយតនៈសូម្បីតែមួយ៉ាងក្នុងអរូបភពនោះ តែក្នុងបញ្ចវោការភព ក្នុងបដិសន្ធិដោយរូប វត្ថុរូបជាបច្ច័យនៃឆដ្ឋាយតនៈ ៦ យ៉ាង ភូតរូបទាំងឡាយជាបច្ច័យនៃអាយតនៈ ៥ ដោយមិនប្លែកគ្នា ៤ យ៉ាង ។

## ពង្រីកសេចក្តី

សេចក្តីថា ក្នុងបដិសន្ធិដោយរូប វត្ថុរូបរមែងជាបច្ច័យនៃអាយតនៈទី ៦ គឺមនាយតនៈ ៦ យ៉ាង ដោយជាសហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ វិប្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ និងអវិគតប្បច្ច័យ ។ ចំណែកភូតរូប ៤ ជាបច្ច័យ ៤ យ៉ាងនៃអាយតនៈទាំង ៥ មានចក្ខាយតនៈជាដើម ស្រេចតែអាយតនៈណានឹងកើតឡើងដោយជាសហជាតប្បច្ច័យ និស្សយប្បច្ច័យ អត្ថិប្បច្ច័យ និងអវិគតប្បច្ច័យ ទាំងក្នុងបដិសន្ធិកាល និងក្នុងបវត្តិកាលដោយ មិនប្លែកគ្នា ។

## គាថាសង្ខេបជីវិតរូបជាដើមជាបច្ច័យ

ជីវិតរូប និងអាហាររូបជាបច្ច័យនៃអាយតនៈ ៥ នោះ ( មួយចំណែក ) ៣ យ៉ាង ក្នុងបវត្តិកាល អាយតនៈ ៥ នោះសោត ក៏ជាបច្ច័យនៃឆដ្ឋាយតនៈ ៦ យ៉ាង វត្ថុរូបក៏ជាបច្ច័យនៃឆដ្ឋាយតនៈនោះដូចគ្នា ៥ យ៉ាង ។

## ពង្រីកសេចក្ដី

ចំណែករូបជីវិតជាបច្ច័យ ៣ យ៉ាង ដោយជាអត្ថិប្បច្ច័យ អវិគតប្បច្ច័យ និងឥន្ទ្រិយប្បច្ច័យនៃអាយតនៈ ៥ នោះ មានចក្ខាយតនៈជាដើម ក្នុងបដិសន្ធិកាល និងក្នុងបវត្តិកាលផង និងអាហារក៏ជាបច្ច័យ ៣ យ៉ាង ដោយជាអត្ថិប្បច្ច័យ អវិគតប្បច្ច័យ និងអាហារប្បច្ច័យ ។ តែអាហារនោះ រមែងជាបច្ច័យតែក្នុងកាយដែលជ្រាប ( រស ) អាហារបានរបស់សត្វពួកដែលអាស្រ័យអាហាររស់នៅក្នុងបវត្តិកាលប៉ុណ្ណោះមិនជាបច្ច័យ ក្នុងបដិសន្ធិកាលឡើយ ចំណែកអាយតនៈ ៥ មានចក្ខាយតនៈជាដើមនោះជាបច្ច័យ នៃឆដ្ឋាយតនៈ គឺមនាយតនៈដែលបានដល់ចក្ខុវិញ្ញាណ សោតវិញ្ញាណ ឃានវិញ្ញាណ ជិវ្ហាវិញ្ញាណ កាយវិញ្ញាណ ៦ យ៉ាង ដោយជានិស្សយប្បច្ច័យ បុរេជាតប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ វិប្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ និងអវិគតប្បច្ច័យ ក្នុងបវត្តិកាល មិនកើតក្នុងបដិសន្ធិកាល ។ម្យ៉ាងទៀត វត្ថុរូបជាបច្ច័យនៃមនាយតនៈនោះឯង វៀរវិញ្ញាណ ៥ គឺមនាយតនៈដ៏សេស ( បានដល់ មនោវិញ្ញាណ ?) ៥ យ៉ាង ដោយជានិស្សយប្បច្ច័យ បុរេជាតប្បច្ច័យ វិប្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ និងអវិគតប្បច្ច័យ ចំពោះក្នុងបវត្តិកាល មិនកើតក្នុងបដិសន្ធិកាលឡើយ ។

រូបតែម្យ៉ាងជាបច្ច័យនៃអាយតនៈណាមួយ ក្នុងបដិសន្ធិកាល ឬក្នុងបវត្តិកាលក្ដី ហើយរូបនោះ ជាបច្ច័យដោយប្រការណា បណ្ឌិតគប្បីជ្រាបដោយប្រការនោះ ដូចពោលមកដូច្នេះ ។

## គាថាសរុបបច្ច័យនាមរូប

នាម និងរូបទាំង ២ ណា ជាបច្ច័យនៃអាយតនៈណា និងកើតដោយប្រការណា

សូម្បីនាម និងរូបនោះ អ្នកប្រាជ្ញគប្បីជ្រាបក្នុងប្រការទាំងពួងចុះ ។

សេចក្ដីនេះដូចម្ដេច ? ដូចជា ( ដំបូង ) ក្នុងបដិសន្ធិមុន នាម និងរូប ពោលគឺខន្ធ ៣ និងវត្ថុរូប រមែងជាបច្ច័យដោយជាសហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ វិបាកប្បច្ច័យ សម្បយុត្តប្បច្ច័យ វិប្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ និងអវិគតប្បច្ច័យជាដើម នៃឆដ្ឋាយតនៈក្នុងបញ្ចវោការភព ដូច្នេះជាដើម ។ នេះជាកថាមុខ ( ម្យ៉ាង ) ក្នុងសេចក្ដីនេះ តែអ្នកប្រាជ្ញអាចប្រកបសេចក្ដីបានគ្រប់យ៉ាងតាមទំនងន័យដែលពោលមកហើយ ព្រោះដូច្នោះ ទើបខ្ញុំមិនសម្ដែងសេចក្ដីពិស្ដារក្នុងប្រការនេះឡើយ ។

នេះជាកថាយ៉ាងពិស្ដារ ក្នុងបទថា **នាមរូបប្បច្ចយា សឡាយតនំ** ។

# មហាដីកា

## កថាពណ៌នាដោយពិស្តារនៃបទថា ព្រោះនាមរូបជាបច្ច័យ ទើបមានសឡាយតនៈ

បទថា **តំ** យោគ **នាមរូបំ** ប្រែថា នាមរូបនោះ ។ បទថា **តស្ស** យោគ **សឡាយតនស្ស** ប្រែថា នៃសឡាយតនៈនោះ ។ បទថា **តាទិស្សស្សេវ** យោគ **កទេកសេសស្សេវ** ប្រែថា ដែលធ្វើឲ្យជាឯកសេស ដូច្នោះដូចគ្នា ។

ហេតុក្នុងការកាន់យកខន្ធ ៣ នោះឯងថា **នាម** ក្នុងទីនេះ មានន័យដូចបានពោលហើយនោះឯង ។ ពាក្យថា **ដោយពិតប្រាកដ** នេះ លោកអាចារ្យពោលសំដៅដល់ ភូតរូប ៤ វត្ថុរូប ៦ និងជីវិតរូប ១ ជាបច្ច័យដោយចំណែក ១ ដល់សឡាយតនៈដែលប្រព្រឹត្តទៅដោយសហជាតប្បច្ច័យ និស្សយប្បច្ច័យ បុរេជាតប្បច្ច័យ និងឥន្ទ្រិយប្បច្ច័យជាដើមតាមសមគួរ ។ ចំណែករូបាយតនៈជាដើម គប្បីជ្រាបថា លោកមិនកាន់យក ព្រោះមិនមានភាពជាសហជាតប្បច្ច័យ និស្សយប្បច្ច័យ និងការតាមរក្សា ។ រូបាយតនៈជាដើមនោះ ជាអារម្មណប្បច្ច័យ និងអារម្មណបុរេជាតប្បច្ច័យជាដើម មិនមែនទាក់ទងដោយវត្ថុដែលមានសន្តតិ តែក៏មិនមែនជាបច្ច័យ ដោយតែម្តងប៉ុណ្ណោះ ដូចចក្ខុរូបជាដើម ព្រោះហេតុនោះ ទើបជាបច្ច័យដោយមិនពិតប្រាកដ ។ ម្យ៉ាងទៀត ដោយ **ឯវំ**-ស័ព្ទ ក្នុងពាក្យថា **និយមតោ ។បេ។ ជីវិតិន្ទ្រិយន្តិ ឯវំ** នេះ បណ្ឌិតគប្បីឃើញការរួមរូបាយតនៈជាដើមផង ។ ក្នុងពាក្យថា **ឆដ្ឋាយតន (អាយតនៈទី ៦ ) ផង** ឈ្មោះថា **សឡាយតនៈ** នេះ ឆដ្ឋាយតន-ស័ព្ទ និង **សឡាយតន** ស័ព្ទ ជាសរូបគ្នាដោយស័ព្ទមិនមានដោយពិត សូម្បីយ៉ាងនោះ ដោយអត្ថចំណែក

មួយនៃសឡាយតនៈនោះឯង ជា **ឆដ្ឋាយតន** ព្រោះហេតុនោះ ទើបភាពជាសរូបគ្នាដោយឯកទេសមាន ព្រោះហេតុនោះ បណ្ឌិតគប្បីជ្រាបថា លោកធ្វើ **សរូបេកសេស** ដោយឯកទេស ។ ពិតហើយ ដោយអត្ថ បណ្ឌិតទាំងឡាយ រមែងប្រាថ្នា **សរូបេក-សេស** ដោយឯកទេសនៃសត្វដែលមានរូបស្មើគ្នាទាំងឡាយ ដូចពាក្យថា **វង្កោ ច កុដិលោ ច កុដិលា** ប្រែថា បុគ្គល វៀចផង បុគ្គលកោងផង ឈ្មោះថា **កុដិលា** ប្រែថា បុគ្គលវៀចផង កោងផង ។ ព្រោះហេតុនោះ ពោលដោយអត្ថ ទើបគួរជាឯកសេសនៃសរូបដោយឯកទេសផង ដូច្នេះ ។

ម្យ៉ាងទៀត លោកធ្វើ **ឆដ្ឋាយតន** ផង **មនាយតន** ផង ឲ្យជាឯកសេសថា **ឆដ្ឋាយតន ១ៈ មនាយតន ១ៈ**, ធ្វើ **ឆដ្ឋាយតន** ផង **ឆដ្ឋាយតន** ដោយឲ្យជាឯកសេសថា **ឆដ្ឋាយតន**, ធ្វើ **មនាយតន** ផង **មនាយតន** ដោយឲ្យជាឯកសេសថា **មនាយតន**, ហើយពោលថា **សឡាយតនៈ** ព្រមជាមួយចក្ខុជាដើម ព្រោះហេតុនោះ លោកអាចារ្យកាលនឹងសម្តែងសឡាយតនៈនោះៗ ឯង ដែលជាឯកសេស ដែលធ្វើដោយអំណាចមនាយតនៈ ដែលមានត្រឹមតែនាមជាបច្ច័យ និងដែលមាននាមរូបជាបច្ច័យ ដោយអត្ថ ទើបពោលថា **ដល់សឡាយតនៈ ដែលធ្វើឲ្យជាឯកសេសយ៉ាងនេះថា ឆដ្ឋាយតនផង សឡាយតនផង** ឈ្មោះថា **សឡាយតនៈ** ដូច្នេះ ។ ឯកសេសតាមដែលពោលហើយ ដោយអត្ថ **រមែង** ឈ្មោះថា ត្រូវលោកធ្វើទុកយ៉ាងនេះថា **ឆដ្ឋាយតន** ផង **សឡាយតន** ផងដូច្នេះ ។ កាលបានធ្វើឯកសេសគ្រប់បទហើយ ការនិទ្ទេសជាឯកវចនៈ គប្បីឃើញថា លោកធ្វើដោយអំណាចការស្មើគ្នា ដោយជាពាក្យដែលគប្បីពោលដោយសត្វ មានសឡាយតនៈជាដើម ដែលធ្វើជាឯកសេសទុក ។

ដោយពាក្យថា **វាមិនមានដោយប្រការដទៃឡើយ** នេះ លោកអាចារ្យរមែងអធិប្បាយអត្ថពិសេសក្រៃលែងឡើងថា កាលនាម និងរូបនោះៗ មិនមានអាយតនៈ

នោះៗ ក៏មិនមាន ដូច្នេះ ។

បទថា **យំ** សេចក្តីប៉ុនគ្នានឹង **យំ យំ យោគ នាមំ រូបញ្ច** ប្រែថា នាម និង រូបណាមួយ ។ បទថា **យស្ស** សេចក្តីប៉ុនគ្នានឹង **យស្ស យស្ស យោគ អាយតនស្ស** ប្រែថា ដល់អាយតនៈណាមួយ ។ បទថា **យថា** ប្រែថា ដោយប្រការណាមួយ មានកើតរួមគ្នាជាដើម ។ បទថា **នេយ្យំ** ប្រែថា គប្បីដឹង ។

ពីរបទថា **តស្ស វសេន** ប្រែថា ដោយអំណាចនៃហេតុប្បច្ច័យជាដើមនោះៗ ក្នុងពាក្យថា **យ៉ាងឧក្រិដ្ឋ និងយ៉ាងឧក្កដ្ឋ** នេះ ចំណែកយ៉ាងច្រើន ដូច្នេះ ចំណែកយ៉ាងច្រើនដោយភាពជាបច្ច័យ ៧ យ៉ាង គឺជាបច្ច័យ ៨ យ៉ាង តអំពីនោះ ជាបច្ច័យ ៩ យ៉ាង តអំពីនោះ ជាបច្ច័យ ១០ យ៉ាង ចំណែកយ៉ាងតិច គប្បីជ្រាបយ៉ាងនេះ គឺអំពីភាពជាបច្ច័យ ១០ យ៉ាង មកជាបច្ច័យ ៩ យ៉ាង ពីបច្ច័យ ៩ យ៉ាងនោះ មកជាបច្ច័យ ៨ យ៉ាង ពីបច្ច័យ ៨ យ៉ាងនោះ មកជាបច្ច័យ ៧ យ៉ាង ចំណែកយ៉ាងច្រើន និងយ៉ាងតិច សូម្បី ២ យ៉ាង មិនគួរប្រកបអំពីបច្ច័យ ៧ យ៉ាងនោះឯង ព្រោះមិនមានចំណែកទាបជាងនោះ ដូច្នេះ ។

ក្នុងសេចក្តីថា នាមដែលជាវិបាក ។ ពាក្យថា **ដោយន័យដែលពោលហើយដូចគ្នា** គឺដោយ ៧ យ៉ាង ដោយអំណាចជាសហជាតប្បច្ច័យជាដើម និងដោយអំណាចជាហេតុប្បច្ច័យជាដើម ។ ពាក្យថា **នាមក្រៅអំពីនេះ** គឺនាមដែលមិនមែនវិបាក ។

ដោយពាក្យថា **ជាសម្ពាញ់របស់ហទយវត្ថុ** នេះ លោកអាចារ្យសម្តែងត្រឹមតែប៉ុណ្ណោះថា នាមដែលមិនមែនជាសម្ពាញ់មិនមាន ដូចក្នុងអរូបភព និងហទយវត្ថុក៏ជាបច្ច័យដល់ធម្មាយតនៈ រួមជាមួយនាមដូច្នេះប៉ុណ្ណោះ តែមិនមានបំណងយកអត្ថនេះថា សូម្បីនាមក៏ជាបច្ច័យដូចហទយវត្ថុជាបច្ច័យ ដូច្នោះ ។ ព្រោះថា វត្ថុជាវិប្បយុត្តប្បច្ច័យដល់នាម មិនមែននាមជាវិប្បយុត្តប្បច្ច័យដល់នាមឡើយ ។ ហើយ

នាមក៏ជាបច្ច័យ មានវិបាកប្បច្ច័យ និងហេតុប្បច្ច័យជាដើម វត្ថុមិនមែនដូច្នោះឡើយ ។ ដូច្នេះ អរូបធម៌ក្នុងបវត្តិកាលជាបច្ច័យដល់កម្មជរូប ដែលដល់នូវឋិតិក្ខណៈប៉ុណ្ណោះ មិនកើតដល់កម្មជរូបដែលកំពុងកើត ព្រោះហេតុនោះ ទើបគួរប្រកបវិប្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ និងអវិគតប្បច្ច័យ មានវិប្បយុត្តប្បច្ច័យដែលកើត ខាងក្រោយជាដើម ប៉ុណ្ណោះ ដល់វត្ថុ មានចក្ខុជាដើម ។

បទថា **បវត្តេ** នេះ លោកប្រារព្ធទុកដោយបទថា **តត្ថេវ** នេះ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **តត្ថេវ ហិ បវត្តេ** ក្នុងបវត្តិកាលនោះៗ ឯង ចំណែកពាក្យថា **ក្នុងបញ្ចវោការភព** នេះ លោកសម្តែងទុកដោយពាក្យថា **ដល់អាយតនៈ ៥** នេះ ដូច្នេះឯង ។ ក្នុងបវត្តិកាល នាម មិនជាវិបាកប្បច្ច័យដល់អាយតនៈ មានចក្ខុជាដើម រមែងកើតដល់រូបដែលខ្លួនឲ្យកើតហើយប៉ុណ្ណោះ ។ តែក្នុងបដិសន្ធិកាល រូបដែលមានកម្មជាសមុដ្ឋាន ក៏ដូចគ្នានឹងរូបដែលមានចិត្តជាសមុដ្ឋាន ព្រោះហេតុនោះ ទើបជាវិបាកប្បច្ច័យដល់វត្ថុនោះឯង ។

បទថា **រូបតោ** សេចក្តីប៉ុនគ្នានឹង **រូបេសុ** ប្រែថា ក្នុងរូបទាំងឡាយ ។ ពាក្យថា **អាយតនៈណាមួយ នឹងកើតឡើង** សេចក្តីថា ក្នុងបដិសន្ធិកាល បណ្តាអាយតនៈទាំង ៥ កាយាយតនៈប៉ុណ្ណោះ រមែងកើតឡើងដល់សត្វជំពូកអណ្ឌជកំណើត និងជំពូកជលាពុជកំណើត ។ សូម្បីអាយតនៈក្រៅអំពីនេះ ក៏រមែងកើតឡើងដល់សត្វក្រៅអំពីនេះតាមសមគួរ ។

ក្នុងពាក្យថា **គឺដល់មនាយតនៈដ៏សេស** នេះ បណ្ឌិតគប្បីឃើញថា លោកពោលដល់មនាយតនៈដ៏សេសអំពីបញ្ចវិញ្ញាណ ដែលប្រព្រឹត្តទៅក្នុងបញ្ចវោការភពប៉ុណ្ណោះ ព្រោះស្របតាមពាក្យនេះថា **ក្នុងភពដែលមានខន្ធ ៥** ដូច្នេះ ។ កាលដែល

នាមរូបជាបច្ច័យទូទៅ មានសហជាតប្បច្ច័យជាដើម និងជាបច្ច័យមិនទូទៅ មានសម្បយុត្តប្បច្ច័យជាដើម បណ្ឌិតគប្បីប្រកបតាមសមគួរ ។ បណ្ឌិតគប្បីជ្រាបន័យនេះថា **ព្រោះរូបជាបច្ច័យ ទើបមានអាយតនៈ ៥** ដូច្នេះ លោកបានដោយអំណាចបុគ្គលដែលចូលនិរោធសមាបត្តិទាំងឡាយ ម្យ៉ាងទៀត នាមរូបដែលជាបច្ច័យក្នុងបដិសន្ធិកាលតែម្យ៉ាងមកជាបច្ច័យក្នុងបវត្តិកាល លោកបានអធិប្បាយទុកដោយការៈដែលមិនធ្ងន់ និងដោយច្រើន ព្រោះហេតុនោះ ទើបលោកបានសម្តែងទុក ។

# វិសុទ្ធិមគ្គ

## អធិប្បាយ បទថា សឡាយតនប្បច្ចយា ផស្សោ

ក្នុងបទថា សឡាយតនប្បច្ចយា ផស្សោ មានគាថាសង្ខេបដូច្នេះថា

ដោយសង្ខេប ផស្សៈក៏មាន ៦ ប៉ុណ្ណោះ មានចក្ខុសម្ផស្សជាដើម ( តែ ) ដោយពិស្តារ មានដល់ ៣២ ដូចវិញ្ញាណដែរ ។

## ពន្យល់សេចក្តី

សេចក្តីថា ដោយសង្ខេប ផស្សៈ ក្នុងបទថា សឡាយតនប្បច្ចយា ផស្សោ ក៏មាន ៦ ប៉ុណ្ណោះ មានចក្ខុសម្ផស្សជាដើមទាំងនេះ គឺចក្ខុសម្ផស្ស សោតសម្ផស្ស ឃានសម្ផស្ស ជិវ្ហាសម្ផស្ស កាយសម្ផស្ស មនោសម្ផស្ស តែបើពោលដោយពិស្តារ ផស្សៈ មានចក្ខុសម្ផស្សជាដើមទាំងអស់ មានដល់ ៣២ ដូចវិញ្ញាណដែលពោលហើយ ដែលមានព្រោះសង្ខារប្បច្ច័យ ដូច្នេះ គឺផស្សៈ ១០ គឺជាកុសលវិបាក ៥ អកុសលវិបាក ៥ និងផស្សៈ ២២ ដែលសម្បយុត្តជាវិបាកវិញ្ញាណចំណែកលោកិយ ២២ ដ៏សេស ។

ឯសឡាយតនៈដែលជាបច្ច័យនៃផស្សៈទាំង ៣២ យ៉ាងនោះ ក្នុងសឡាយ-តនៈនោះ ។

## គាថាសង្ខេបវាទៈរបស់អាចារ្យ

អាចារ្យដែលមានបញ្ញាទាំងឡាយ ប្រាថ្នាយកសឡាយតនៈខាងក្នុង មានចក្ខុជាដើមជាមួយឆដ្ឋាយតនៈខ្លះ ប្រាថ្នាយកសឡាយតនៈជាមួយអាយតនៈខាងក្រៅ ៦ ខ្លះ ។

## ពង្រីកសេចក្តី

ក្នុងអាចារ្យទាំងឡាយនោះ លំដាប់ដំបូង អាចារ្យពួកណាចង់លបង្ហាញយកធម៌ដែលទាក់ទងដោយវត្ថុ ដែលមានសន្តតិប្រចាំខ្លួនដែលកើតទាំងបច្ចយធម៌ និងបច្ចយុប្បន្នធម៌ផងនោះឯង ដោយសេចក្តីថា នេះជាការពោលដល់ការប្រព្រឹត្តទៅនៃវត្ថុដែលជាឧបាទិន្នក អាចារ្យទាំងនោះរមែងប្រាថ្នាយកថា សឡាយតនៈខាងក្នុងមានចក្ខុជាដើម និងឆដ្ឋាយតនៈ ដោយធ្វើឯកទេសសរូបេកសេសថា ឆដ្ឋាយតនៈក្នុងអរូបកពដោយទំនងបាលីថា **ឆដ្ឋាយតនប្បច្ចយា ផស្សោ** ផស្សៈមានព្រោះបច្ច័យគឺឆដ្ឋាយតនៈនេះផង សឡាយតនៈក្នុងកពដទៃ ដោយសព្វសង្គហៈ ( រួមចូលគ្នាទាំងអស់ ) ផង ជាបច្ច័យនៃផស្សៈ ដូច្នេះ ។ ដែលពិត ពាក្យដូចពោលនោះ ក៏ប៉ុន្តែនឹង ( វិគ្រោះឯកសេស ) ថា **ឆដ្ឋាយតនញ្ច សឡាយតនញ្ច សឡាយតនំ** ឆដ្ឋាយតនៈ ( អាយតនៈទី ៦ ) ផង សឡាយតនៈ ( អាយតនៈ ៦ ) ផង ឈ្មោះថា សឡាយតនៈនោះឯង ។

ចំណែកអាចារ្យពួកណា ចង់លសំដៅយកធម៌ដែលទាក់ទងដោយវត្ថុ ដែលជាឯកសន្តតិ ( សន្តតិមួយ ) ដែលជាបច្ចយុប្បន្នធម៌ប៉ុណ្ណោះ តែសម្តែងបច្ចយធម៌ជាពួកកិន្នសន្តាន ( គឺមានសន្តតិបែកផ្សេងគ្នាមិនទាក់ទងគ្នា ) អាចារ្យទាំងនោះ អាយតនៈណាមួយ ជាបច្ច័យនៃផស្សៈបាន លោកសម្តែងយកអាយតនៈ ទាំងអស់នោះ ទើបកំណត់យកអាយតនៈខាងក្រៅផង បំណងយកអាយតនៈខាងក្នុង និងឆដ្ឋាយតនៈនោះឯង ព្រមទាំងអាយតនៈខាងក្រៅ មានរូបាយតនៈជាដើមផង ឈ្មោះថា សឡាយតនៈ ដូច្នេះ ។ ដែលពិត សូម្បីពាក្យដែលពោលនោះ កាលធ្វើវាឲ្យជាឯកទេសហើយថា **ឆដ្ឋាយតនញ្ច សឡាយតនញ្ច សឡាយតនំ**, ឆដ្ឋាយតនៈផង សឡាយតនៈផង ឈ្មោះថា សឡាយតនៈ ដូច្នេះ ហើយក៏ហៅបានថា **សឡាយតនៈ** ដូចគ្នា ។

ក្នុងសេចក្តីនេះ ( មាន ) អ្នកចោទសួរពោលថា ផស្សៈតែមួយនឹងកើតអំពីអាយតនៈគ្រប់យ៉ាងបានឬទេ ទាំងផស្សៈគ្រប់យ៉ាងក៏នឹងកើតអំពីអាយតនៈតែមួយបានឬទេ តែផស្សៈក្នុងបាឋៈថា **សឡាយតនប្បច្ចយា ផស្សោ** នេះ ត្រាស់ទុកតែមួយទើបត្រាស់ផស្សៈនោះតែមួយទៅវិញ ?

នេះជាពាក្យដោះស្រាយក្នុងបញ្ហានោះ គឺដែលពោលផស្សៈមួយកើតអំពីអាយតនៈគ្រប់យ៉ាងមិនបាន ឬថា ផស្សៈគ្រប់យ៉ាងកើតអំពីអាយតនៈតែមួយក៏មិនបាននោះពិត តែផស្សៈតែមួយ រមែងកើតអំពីអាយតនៈច្រើនយ៉ាងបាន ដូចចក្ខុសម្ផស្ស រមែងកើតអំពីចក្ខាយតនៈ និងអំពីរូបាយតនៈ អំពីមនាយតនៈ ពោលគឺចក្ខុវិញ្ញាណ និងអំពីធម្មាយតនៈដែលជាសម្បយុត្តធម៌ដ៏សេស ( រួមគ្នា ) ជាដើម បណ្ឌិតគប្បីប្រកបសេចក្តីតាមសមគួរក្នុងផស្សៈ ( ប្រការដទៃ ) គ្រប់ប្រការ ដូចនិទស្សនៈដែលពោលនេះចុះ ។

ក៏ព្រោះហេតុនោះឯង ផស្សៈនេះក្នុងបទថា **សឡាយតនប្បច្ចយា ផស្សោ** ទើបព្រះតាទិជាម្ចាស់ ទ្រង់សម្តែងដោយឯកវចននិទ្ទេស ដើម្បីឆ្លុះបញ្ចាំងអត្ថថា **ផស្សៈសូម្បីតែមួយ មានអាយតនៈច្រើនយ៉ាងជាដែនកើតបាន ។**

ពាក្យថា ដោយឯកវចននិទ្ទេសជាដើម សេចក្តីថា ព្រះតាទិជាម្ចាស់ ទ្រង់សម្តែងព្រះពុទ្ធាធិប្បាយថា ផស្សៈតែ ១ រមែងមានព្រោះអាយតនៈច្រើនយ៉ាងបាន ដោយសម្តែងចេញ ដោយពាក្យជាឯកវចនៈនេះថា **សឡាយតនប្បច្ចយា ផស្សោ** ។

ចំណែកក្នុងអាយតនៈទាំងឡាយ **បណ្ឌិតគប្បីចង្អុលបង្ហាញអាយតនៈ ៥ ក្នុងភាពជាបច្ច័យនៃផស្សៈនោះ ៦ យ៉ាង គប្បីចង្អុលបង្ហាញអាយតនៈ ១ បន្ទាប់អំពីអាយតនៈ ៥ នោះទៅ ក្នុងភាពជាបច្ច័យនៃផស្សៈនោះ ៩ យ៉ាង គប្បីចង្អុលបង្ហាញអាយតនៈខាងក្រៅ ៦ ក្នុងភាពជាបច្ច័យនៃផស្សៈនោះ តាមដែលវាកើត ។**

តទៅនេះ ជាពាក្យចង្អុលបង្ហាញក្នុងភាពដែលអាយតនៈជាបច្ច័យនៃផស្សៈនោះលំដាប់ដំបូង អាយតនៈ ( ខាងក្នុង ) ៥ មានចក្ខាយតនៈជាដើមជាបច្ច័យ ៦ យ៉ាង ដោយជានិស្សយប្បច្ច័យ បុរេជាតប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ វិប្បយុត្តប្បច្ច័យ អត្ថិ-ប្បច្ច័យ និងអវិគតប្បច្ច័យនៃផស្សៈ ៥ យ៉ាង ដោយចែកជាចក្ខុសម្ផស្សជាដើម អាយតនៈ ១ បន្ទាប់អំពីអាយតនៈ ៥ នោះទៅ គឺមនាយតនៈដែលជាវិបាក ជាបច្ច័យ ៩ យ៉ាង ដោយជាសហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ វិបាកប្បច្ច័យ អាហារប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ សម្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ និងអវិគតប្បច្ច័យ នៃមនោសម្ផស្ស ដែលជាវិបាកច្រើនប្រភេទ ។ ចំណែកក្នុងអាយតនៈខាងក្រៅទាំងឡាយ រូបាយតនៈជាបច្ច័យ ៤ យ៉ាង ដោយជាអារម្មណប្បច្ច័យ បុរេជាតប្បច្ច័យ អត្ថិប្បច្ច័យ និងអវិគតប្បច្ច័យនៃចក្ខុសម្ផស្ស អាយតនៈដ៏សេស មានសទ្ទាយតនៈជាដើម ក៏ជាបច្ច័យនៃផស្សៈដ៏សេស មានសោតសម្ផស្សជាដើមដោយន័យដូចគ្នានោះដែរ តែសម្រាប់មនោសម្ផស្ស មានអាយតនៈទាំងនោះផង ធម្មារម្មណ៍ផង ជាបច្ច័យ ដោយជាបច្ចយន័យដូចគ្នានោះ និងដោយត្រឹមតែជាអារម្មណប្បច្ច័យប៉ុណ្ណោះផង បណ្ឌិតគប្បីចង្អុលបង្ហាញអាយតនៈខាងក្រៅ ៦ ក្នុងភាពជាបច្ច័យនៃផស្សៈនោះតាមដែលវាកើត ( មានជាអារម្មណប្បច្ច័យជាដើម ) ដោយន័យ ដូចពោលមកដូច្នេះឯង ។

នេះជាកថាយ៉ាងពិស្តារក្នុងបទថា **សឡាយតនប្បច្ចយា ផស្សោ** ។

# មហាដីកា

## កថាពណ៌នាដោយពិស្តារ នៃបទថា

## ព្រោះសឡាយតនៈជាបច្ច័យ ទើបមានផស្សៈ

ផស្សៈដែលសម្បយុត្តនឹងវិបាកវិញ្ញាណចំណែកលោកិយ ២២ ឈ្មោះថា **ពាវីសតិលោកិយវិញ្ញាណសម្បយុត្តា** ផស្សៈដែលសម្បយុត្តនឹងវិបាកវិញ្ញាណ ២២ ។ ព្រោះហេតុនោះឯង ទើបឈ្មោះថា **ពាវីសតិ** ប្រែថា ផស្សៈ ២២ ។

បទថា **តត្ថ** សេចក្តីប៉ុនគ្នានឹង **តស្មឹ យោគ សឡាយតនេ** ប្រែថា ក្នុងសឡាយតនៈនោះ សេចក្តីថា ក្នុងអាយតនៈ ៦ នោះ ។ លោកអាចារ្យរមែងកាន់យកវត្ថុដែលទាក់ទងដោយវត្ថុ មានសន្តតិតែម្យ៉ាងថា **សឡាយតនៈខាងក្នុង** ។ ពិតហើយ សឡាយតនៈខាងក្នុងនោះ ដែលកើតឡើងអំពីកម្ម ដែលទាក់ទងដោយវត្ថុដែលមានសន្តតិ រមែងជាបច្ច័យដល់ផស្សៈ ដូច្នោះ ។ ចំណែកអាយតនៈទាំងឡាយ មានរូបាយតនៈជាដើម និងអនុបាទិន្នរូបទាំងឡាយខាងក្រៅ ជាអារម្មណ៍ដល់ផស្សៈ អាយតនៈ មានរូបជាដើម និងអនុបាទិន្នរូបខាងក្រៅទាំងនោះ មិនបានជាបច្ច័យដល់ផស្សៈ ដោយភាវៈដែលប្រព្រឹត្តទៅព្រោះហេតុ គឺកម្មក្កិលេស ដែលទាក់ទងដោយវត្ថុ ដែលមានសន្តតិ ដូចជាអាយតនៈខាងក្នុង មានចក្ខុជាដើមនោះឡើយ ព្រោះហេតុនោះ ទើបលោកមិនបានកាន់យកទុកក្នុងវាទៈរបស់លោកអាចារ្យពួកដំបូង តែក្នុងវាទៈរបស់អាចារ្យពួកទី ២ លោកកាន់យក ព្រោះកាលមានភាព ជាបច្ច័យឯណានីមួយបាន ក៏មិនអាចនឹងវៀរបាន ។

បទថា **តត្ថ យោគ សឡាយតនបច្ចយា ផស្សបទេ** ប្រែថា ក្នុងបទថា ព្រោះមានសឡាយតនៈជាបច្ច័យ ទើបមានផស្សៈនោះ ។ ខាងដើម អាចារ្យទាំងឡាយ

ពួកណា គឺអាចារ្យទាំងឡាយដែលនៅក្នុងសម្នាក់មហាវិហារនោះឯង កាលសម្តែងនាមរូប សឡាយតនៈ ផស្សៈ និងវេទនា ដែលជាបច្ចយធម៌ និងបច្ចយុប្បន្នធម៌ ដែលទាក់ទងដោយវត្ថុដែលមានសន្តតិ រមែងប្រាថ្នា ព្រោះជាវិបាក ដូចគ្នានឹងវិញ្ញាណ ។ ព្រះបាលី ក្នុងអភិធម្មភាជនីយ៍ថា **ឆដ្ឋាយតនបច្ចយា ផស្សោ** ព្រោះមានអាយតនៈទី ៦ ជាបច្ច័យ ទើបមានផស្សៈ ដូច្នេះ ព្រះមានព្រះភាគត្រាស់សំដៅយកអរូបភព ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **តាមគន្ធព្រះបាលីថា ព្រោះមានអាយតនៈទី ៦ ជាបច្ច័យ ទើបមានផស្សៈ** ដូច្នេះ ។

ពាក្យប្រកបបាលីថា **សព្វេ ផស្សា ន សម្ភោន្តិ** ទាំងផស្សៈគ្រប់យ៉ាង ក៏មិនកើត ។ បើផស្សៈតែ ១ គប្បីកើតអំពីអាយតនៈគ្រប់យ៉ាងបាន ការពោលផស្សៈតែ ១ ថា **សឡាយតនបច្ចយា ផស្សោ** ដូច្នេះ គួរតែត្រឹមត្រូវ កាលបើយ៉ាងនោះ ផស្សៈគ្រប់យ៉ាងក៏គប្បីកើតអំពីអាយតនៈតែមួយបាន សូម្បីយ៉ាងនោះ ព្រោះផស្សៈគ្រប់យ៉ាងកើតអំពីអាយតនៈគ្រប់យ៉ាង ទើបការផ្សេងនៃផស្សៈមិនមាន ការផ្សេងនៃអាយតនៈ ព្រោះហេតុនោះ ទើបការពោលផស្សៈតែ ១ ដោយអំណាចការផ្សេងនៃអាយតនៈ និងផស្សៈនោះ គួរត្រឹមត្រូវ តែព្រោះមិនកើតយ៉ាងនោះ ទើបមិនគួរ ព្រោះហេតុនោះ ទើបលោកអាចារ្យសួរដោយពាក្យថា **ផស្សៈតែ ១ មិនកើតអំពីអាយតនៈគ្រប់យ៉ាងបានឡើយ** ដូច្នេះ ។ ម្យ៉ាងទៀត ពាក្យថា **ផស្សៈ គ្រប់យ៉ាងមិនកើតអំពីអាយតនៈតែ ១ បានឡើយ** នេះ លោកពោលទុកដើម្បីឲ្យយល់វិធីដែលមិនមានដទៃ ចំណែកពាក្យថា **ផស្សៈតែ ១ មិនកើតអំពីអាយតនៈគ្រប់យ៉ាងបានឡើយ** នេះប៉ុណ្ណោះ បណ្ឌិតគប្បីជ្រាបថា ជាហេតុដែលសម្តែងពាក្យមិនសមគួរដល់ការពោលផស្សៈតែ ១ ។ ម្យ៉ាងទៀត ពាក្យនេះ ពោលទុកទាក់ទងជាគំរូ ។ ទាំងផស្សៈគ្រប់យ៉ាងមិនកើតអំពីអាយតនៈតែ ១ នោះឡើយ ផស្សៈតែ ១ មិនកើតអំពី

អាយតនៈគ្រប់យ៉ាងនោះឡើយ ដូចគ្នាយ៉ាងនោះ ។ ព្រោះហេតុនោះ ទើបការពោល ផស្សៈតែ ១ មិនសមគួរ ។ តែលោកអាចារ្យកាលនឹងសម្តែងពាក្យឆ្លើយថា ព្រោះ ផស្សៈតែ ១ មានអំពីអាយតនៈច្រើនយ៉ាងបាន ទើបពោលពាក្យជាដើមថា **ពាក្យ ដោះស្រាយក្នុងសេចក្តីនោះ មានដូច្នេះ ។ ធម្មាយតនៈដែលសម្បយុត្តធម៌ដ៏សេស** បានដល់ ធម៌ គឺចេតសិកដែលសម្បយុត្តជាមួយចក្ខុវិញ្ញាណនោះ ដែលវៀរផស្សៈ ។

ផស្សៈសូម្បីតែ ១ មានអាយតនៈច្រើនយ៉ាងជាដែនកើតបាន ឈ្មោះថា **ឯកោបនេកាយតនប្បភវោ** ប្រែថា ផស្សៈតែម្យ៉ាង មានអាយតនៈច្រើនយ៉ាងជាដែនកើតបាន ។

ក្លាប់សេចក្តីថា បណ្ឌិតគប្បីសម្តែងអាយតនៈ ៥ ក្នុងភាពជាបច្ច័យ ៦ យ៉ាង គប្បីសម្តែងអាយតនៈ ១ ក្នុងភាពជាបច្ច័យ ៩ យ៉ាង គប្បីសម្តែងអាយតនៈ ៦ ខាងក្រៅក្នុងភាពជាបច្ច័យបានតាមសមគួរ ដោយជាអារម្មណប្បច្ច័យជាដើម ។

ពាក្យថា **ច្រើនប្រភេទ** បានដល់ ផស្សៈដែលជាវិបាកច្រើនប្រភេទ ដោយជាអកុសលវិបាកជាដើម និងជាបញ្ចទ្វារជាដើម ដែលវៀរផស្សៈ ដែលសម្បយុត្តនឹងទ្វិបញ្ចវិញ្ញាណ ។ បទថា **តានិ ច យោគ រូបាយតនាទីនិ** ប្រែថា អាយតនៈ មានរូបាយតនៈជាដើមនោះ ។ សេចក្តីនេះ សមដូចពាក្យដែលព្រះសារីបុត្រពោលទុកថា **មនោ ច នេសំ គោចរវិសយំ បច្ចនុភវតិ** ចិត្តរមែងទទួលដឹងវិស័យដែលជាគោចររបស់ឥន្ទ្រិយទាំងនោះ ។ បទថា **តថា ច** លោកពោលសំដៅយករូបាយតនៈជាដើម ដែលជាបច្ចុប្បន្ន និងរូបរូបដែលទាក់ទងដោយធម្មាយតនៈ ដែលជាបច្ចុប្បន្ន ។ ពាក្យថា **ដោយត្រឹមតែជាអារម្មណប្បច្ច័យ** លោកពោលសំដៅយកអាយតនៈទាំងអស់នោះ ដែលមិនមែនជាបច្ចុប្បន្ន និងធម្មាយតនៈដទៃផង ។

# វិសុទ្ធិមគ្គ

## អធិប្បាយ បទថា ផស្សប្បច្ចយា វេទនា

*ក្នុងបទថា ផស្សប្បច្ចយា វេទនា មានគាថាសង្ខេបដូច្នេះថា*

*វេទនាពោលដោយទ្វារក៏មាន ៦ មានចក្ខុសម្ផស្សជាវេទនាជាដើមប៉ុណ្ណោះ តែដោយប្រភេទ មានដល់ទៅ ៨៩ ។*

## ពង្រីកសេចក្តី

*ពិតណាស់ ក្នុងវិភង្គនៃបទនេះ ពោលវេទនាទុក ៦ តាមទ្វារប៉ុណ្ណោះ ដូច្នេះ គឺចក្ខុសម្ផស្សជាវេទនា សោតសម្ផស្សជាវេទនា ឃានសម្ផស្សជាវេទនា ជិវ្ហាសម្ផស្ស ជាវេទនា កាយសម្ផស្សជាវេទនា មនោសម្ផស្សជាវេទនា តែដោយប្រភេទ មាន ដល់ទៅ ៨៩ ព្រោះវេទនានោះ សម្បយុត្តជាមួយចិត្ត ៨៩ ដួង ។*

*តែក្នុងវេទនាទាំងនោះ វេទនា ៣២ ដែលប្រកបជាមួយវិបាកចិត្តប៉ុណ្ណោះ លោកពោលថា ជាវេទនាដែលបំណងយកក្នុងបទនេះ ។*

## គាថាសង្ខេបបច្ចយន័យ

*ក្នុងវេទនា ( ដែលបំណងយក ) ទាំងនោះ ផស្សៈជាបច្ច័យនៃវេទនា ៥ ក្នុង បញ្ចទ្វារ ៨ យ៉ាង ជាបច្ច័យនៃវេទនាដ៏សេសតែមួយ៉ាង សូម្បីក្នុងមនោទ្វារ ក៏យ៉ាង នោះ ។*

## ពង្រីកសេចក្តី

*សេចក្តីថា ក្នុងវេទនាទាំងនោះ ផស្សៈ មានចក្ខុសម្ផស្សជាដើមជាបច្ច័យ ៨ យ៉ាង ដោយជាសហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ វិបាកប្បច្ច័យ*

អាហារប្បច្ច័យ សម្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ និងអវិគតប្បច្ច័យនៃវេទនា ៥ ដែលមានចក្ខុបសាទជាដើមជាវត្ថុ គឺទីតាំងក្នុងបញ្ចទ្វារ តែផស្សៈ មានចក្ខុសម្ផស្សជាដើមនោះ ជាបច្ច័យតែម្យ៉ាង ដោយជាឧបនិស្សយប្បច្ច័យប៉ុណ្ណោះ នៃវេទនាដ៏សេស គឺវេទនាដែលជាកាមាវចរវិបាកដែលប្រព្រឹត្តទៅ ដោយអំណាចសម្បដិច្ឆន្នចិត្ត សន្តីរណចិត្ត និងតទាលម្ពណចិត្ត ក្នុងទ្វារនីមួយៗ ។

ពាក្យថា **សូម្បីមនោទ្វារក៏កើតយ៉ាងនោះ** សេចក្តីថា សូម្បីក្នុងមនោទ្វារ ផស្សៈពោល គឺមនោសម្ផស្សដែលកើតរួមគ្នានោះ ក៏ជាបច្ច័យ ៨ យ៉ាងដូច្នោះ ដូចគ្នានៃវេទនាដែលជាកាមាវចរវិបាក ដែលប្រព្រឹត្តទៅដោយអំណាចតទាលម្ពណចិត្ត និងនៃវេទនាតេភូមិកវិបាកដែលប្រព្រឹត្តទៅ ដោយអំណាចបដិសន្ធិចិត្ត និងភវង្គចុតិចិត្ត ចំណែកកាមាវចរវេទនាទាំងឡាយ ដែលប្រព្រឹត្តទៅដោយអំណាចតទាលម្ពណចិត្តក្នុងមនោទ្វារនោះ មនោសម្ផស្សដែលសម្បយុត្តជាមួយមនោទ្វារាវជ្ជនចិត្ត ជាបច្ច័យនៃវេទនាទាំងនោះតែម្យ៉ាង ដោយជាឧបនិស្សយប្បច្ច័យប៉ុណ្ណោះ ។

នេះជាកថាយ៉ាងពិស្តារ ក្នុងបទថា **ផស្សប្បច្ចយា វេទនា** ។

# មហាដីកា

## កថាពណ៌នាដោយពិស្តារនៃបទថា

## ព្រោះផស្សៈជាបច្ច័យ ទើបមានវេទនា

*ពាក្យថា **វេទនា ៦ តាមទ្វារប៉ុណ្ណោះ** សេចក្តីថា វេទនាសូម្បីមានតែមួយ៉ាង ដោយភាពស្មើគ្នា គឺដែនកើតក៏មាន ៦ យ៉ាងប៉ុណ្ណោះ ដោយទ្វារនៃការកើត ព្រោះហេតុនោះ ទើបពោលវេទនាទុក ៦ ប៉ុណ្ណោះ ។*

*វេទនាសូម្បីមាន ៨៩ យ៉ាង ដោយប្រភេទនៃចិត្ត លោកអាចារ្យមានបំណងសម្តែងវេទនា ដែលបំណងយកក្នុងបទនេះប៉ុណ្ណោះ ទើបពោលពាក្យជាដើមថា **ក្នុងបណ្តាវេទនាទាំងឡាយ** ដូច្នេះ ។ ក្នុងពាក្យថា **ដល់វេទនាដ៏សេស** នេះ ផស្សៈទាំង ៥ មានចក្ខុសម្ផស្សជាដើមជាបច្ច័យ ដោយអនន្តរប្បច្ច័យជាដើម ដល់វេទនាដែលសម្បយុត្តនឹងសម្បដិច្ឆនចិត្តក៏ពិត សូម្បីយ៉ាងនោះ លោកអាចារ្យពោលថា **ជាបច្ច័យតែមួយ៉ាង** ដូច្នេះ ដោយអំណាចផស្សៈដែលជាបច្ច័យនោះ ដែលទូទៅដល់អនន្តរប្បច្ច័យជាដើម និងសន្តីរណចិត្ត តទាលម្ពណចិត្ត ព្រោះជាសភាវៈឈោងចុះខាងក្នុង ក្នុងឧបនិស្សយប្បច្ច័យ ។ គប្បីប្រកបសេចក្តីថា ផស្សៈទាំងឡាយដែលកើតរួមជាមួយចក្ខុវិញ្ញាណជាដើម ដែលកើតក្នុងចក្ខុទ្វារជាដើម ក្នុងទ្វារតែមួយទ្វារ រមែងជាបច្ច័យដល់វេទនាដែលសម្បយុត្តជាមួយសម្បដិច្ឆនចិត្តជាដើម ក្នុងវិថីរបស់ខ្លួនរៀងៗខ្លួន ផស្សៈនោះ ពោល គឺមនោសម្ផស្សដែលកើតរួមគ្នា រមែងជាបច្ច័យ ៨ យ៉ាងដល់វេទនាដែលជាវិបាក ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ដែលប្រព្រឹត្តទៅ ដោយអំណាចតទាលម្ពណៈក្នុងមនោទ្វារនោះឯង ។*

វិបាកវេទនាផ្នែករូបាវចរ និងចំណែកអរូបាវចរ រមែងប្រព្រឹត្តទៅដោយអំណាចបដិសន្ធិចិត្តជាដើមប៉ុណ្ណោះ សូម្បីខាងកាមាវចរក៏មានវេទនាខ្លះ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **សូម្បីដល់វិបាកវេទនាដែលប្រព្រឹត្តទៅក្នុងភូមិទាំង ៣** ដូច្នេះ ។ មនោសម្ផស្សដែលកើតរួមគ្នា រមែងជាបច្ច័យ ៨ យ៉ាង ដល់វិបាកវេទនាដែលប្រព្រឹត្តទៅក្នុងភូមិទាំង ៣ នោះ ។ អាចារ្យពួកខ្លះ រមែងប្រាថ្នាបច្ច័យដែលជាអនុបាទិន្ន ព្រោះហេតុនោះ ទើបលោកពោលផស្សៈ ដែលសម្បយុត្តដោយមនោទ្វារាវជ្ជនៈជាបច្ច័យ ដោយពាក្យថា **ចំណែកវេទនាខាងកាមាវចរទាំងឡាយ ដែលប្រព្រឹត្តទៅដោយអំណាចតទាលម្ពណចិត្តក្នុងមនោទ្វារនេះបាន** ដូច្នេះ ។ ពាក្យនោះ បណ្ឌិតគប្បីឃើញថាជាការសម្តែងត្រឹមតែមាតិកា ។ ដោយន័យនេះ បណ្ឌិតគប្បីប្រកបផស្សៈទាំងឡាយដែលមិនមានអ្វីភាំង និងដែលមិនមានអ្វីភាំងបានឡើយ ជាឧបនិស្សយបច្ច័យដល់វិបាកវេទនានោះៗ ដូច្នេះឯង ។

# វិសុទ្ធិមគ្គ

## អធិប្បាយ បទថា វេទនាបច្ចយា តណ្ហា

## គាថាសង្ខេបតណ្ហា

តណ្ហា ៦ ដោយចែកជារូបតណ្ហាជាដើម ទ្រង់សម្តែងក្នុងបទនេះ ក្នុងតណ្ហាទាំងនោះ តណ្ហាប្រការនីមួយៗ គប្បីជ្រាបថា មានបីៗ យ៉ាង តាមការដែលប្រព្រឹត្តទៅ ។

## ពង្រីកសេចក្តី

ពិតណាស់ ក្នុងបទនេះ ក្នុងវិភង្គលោកសម្តែងតណ្ហា ៦ ដោយឲ្យឈ្មោះតាមអារម្មណ៍ថា រូបតណ្ហា សទ្ទតណ្ហា គន្ធតណ្ហា រសតណ្ហា ផោដ្ឋព្វតណ្ហា ធម្មតណ្ហា ដូចកូនដែលត្រូវសម្តែងដោយឲ្យឈ្មោះតាមបិតាថា សេដ្ឋីបុត្រ ព្រាហ្មណបុត្រជាដើម ដូច្នោះ ។ ម្យ៉ាងទៀត ក្នុងតណ្ហាទាំងនោះ តណ្ហានីមួយៗ គប្បីជ្រាបថា ចែកជាបីៗ យ៉ាង តាមអាការដែលប្រព្រឹត្តទៅដូច្នេះ គឺកាមតណ្ហា ភវតណ្ហា វិភវតណ្ហា ។

រូបតណ្ហានោះឯង កាលណា ( វា ) ត្រេកអរក្នុងរូបារម្មណ៍ដែលមកកាន់គន្លងចក្ខុដោយអំណាចសេចក្តីពេញចិត្តផ្លូវកាមប្រព្រឹត្តទៅ កាលនោះ តណ្ហានោះក៏បានឈ្មោះថា ជាកាមតណ្ហា កាលណាតណ្ហាប្រព្រឹត្តទៅជាមួយសស្សតទិដ្ឋិដែលប្រព្រឹត្តទៅដោយឃើញថា អារម្មណ៍នោះឯងជារបស់ទៀងស្ថិតស្ថេរ កាលនោះ តណ្ហានោះក៏បានឈ្មោះថា ជាភវតណ្ហា ព្រោះថា រាគៈដែលសហគតៈជាមួយសស្សតទិដ្ឋិ លោកហៅថា ភវតណ្ហា បើក្នុងកាលណា តណ្ហាប្រព្រឹត្តទៅជាមួយឧច្ឆេទទិដ្ឋិដែលប្រព្រឹត្តទៅដោយឃើញថា អារម្មណ៍នោះឯងដាច់សូន្យទៅ កាលនោះ តណ្ហានោះ ក៏បានឈ្មោះថា ជាវិភវតណ្ហា ព្រោះថា រាគៈដែលសហគតៈជាមួយឧច្ឆេទទិដ្ឋិ លោកហៅថា វិភវតណ្ហា

សូម្បីក្នុងតណ្ហាដ៏សេស មានសទ្ទតណ្ហាជាដើមក៏ន័យនេះ ព្រោះហេតុនោះ ទើបតណ្ហានោះ ជាតណ្ហា ១៨ ។ តណ្ហាប្រព្រឹត្តទៅក្នុងរូបារម្មណ៍ជាដើមដែលជាខាងក្នុង ១៨ ដែលជាខាងក្រៅ ១៨ ព្រោះដូច្នោះ ទើបជាតណ្ហា ៣៦ ដោយប្រការដូច្នេះ ដោយជាអតីត ៣៦ ជាអនាគត ៣៦ ជាបច្ចុប្បន្ន ៣៦ ដូច្នោះ ទើបជាតណ្ហា ១០៨ ។ តណ្ហាទាំងនោះ បណ្ឌិតគប្បីជ្រាបថា កាលបង្រួញក៏នៅសល់តណ្ហា ៦ ដោយអំណាចនៃអារម្មណ៍ មានរូបជាដើម ឬជាតណ្ហា ៣ ដោយជាប្រភេទកាមតណ្ហាជាដើមប៉ុណ្ណោះឯង ។

ព្រោះសត្វទាំងឡាយនេះ ពេញចិត្តវេទនាដែលកើតឡើង ដោយអំណាចអារម្មណ៍ មានរូបជាដើម ទើបធ្វើសក្ការៈធំដល់ចិត្រការ ( ជាងគូរ ) **គណ្ឌព្វ** ( អ្នកតន្ត្រីច្រៀងរាំ ) **គន្ធិក** ( ជាងធ្វើគ្រឿងក្រអូប ) **សូទ** ( ចុងភៅ ) **តន្តវាយ** ( ជាងតម្បាញ ) និងរសាយនវិធាយកវេជ្ជ ( ពេទ្យផ្សំថ្នាំតាមតម្រារសាយតនវេទ ) ជាដើម ដែលជាអ្នកឲ្យអារម្មណ៍ មានរូបជាដើម ក៏ដោយការស្រឡាញ់ក្នុងវេទនា ដូចបិតាពេញចិត្តបុត្រ ( របស់ខ្លួន ) ហើយធ្វើសក្ការៈធំដល់មេដោះ ក៏ដោយការស្រឡាញ់ក្នុងបុត្រដូច្នោះ ហេតុដូច្នោះ តណ្ហាទាំងពួងនោះ បណ្ឌិតគប្បីជ្រាបចុះថា ជាតណ្ហាមានព្រោះបច្ច័យ គឺវេទនា ។

ព្រោះសុខវេទនាដែលជាវិបាកតែម្យ៉ាងប៉ុណ្ណោះ លោកមានបំណងយកក្នុងបទនេះ ហេតុនោះ ទើបសុខវេទនានោះ ជាបច្ច័យនៃតណ្ហា ប្រការមួយដូចគ្នា ។

ពាក្យថា ( ជាបច្ច័យ ) ប្រការមួយ គឺជាបច្ច័យដោយជាឧបនិស្សយប្បច្ច័យប៉ុណ្ណោះ ឬព្រោះថា

បុគ្គលមានទុក្ខ រមែងប្រាថ្នាសេចក្តីសុខ បុគ្គលមានសេចក្តីសុខសោត ក៏ប្រាថ្នាសេចក្តីសុខក្រៃលែងឡើងទៅ ចំណែកឧបេក្ខាវេទនា ព្រោះជាវេទនាល្អិត លោក

ក៏ពោលថា ជាសុខដូចគ្នា ហេតុនោះ ទើបវេទនាជាបច្ច័យនៃតណ្ហាបានទាំង ៣ តែព្រោះថា តណ្ហា ដែលព្រះមហាឫស្សីត្រាស់ទុកក្នុងបទថា វេទនាបច្ចយា តណ្ហា នោះ សូម្បីមានវេទនាជាបច្ច័យ ( តែ ) វៀរអនុស័យចេញ តណ្ហាក៏មិនមាន ព្រោះដូច្នោះ ទើបតណ្ហាមិនមានដល់ព្រាហ្មណ៍ ( គឺសមណៈ ) អ្នកមានព្រហ្មចរិយៈចប់ហើយ ។

នេះជាកថាយ៉ាងពិស្តារ ក្នុងបទថា វេទនាបច្ចយា តណ្ហា ។

# មហាដីកា

## កថាពណ៌នាដោយពិស្តារនៃបទថា ព្រោះវេទនាជាបច្ច័យ ទើបមានតណ្ហា

បទថា **ឥធ** សេចក្តីប៉ុនគ្នានឹង **ឥមស្មឹ យោគ លោកេ** ប្រែថា ទ្រង់សម្តែងតណ្ហា ៦ យ៉ាង ក្នុងលោកនេះ ម្យ៉ាងទៀត សេចក្តីប៉ុនគ្នានឹង **ឥមស្មឹ យោគ សាសនេ** ប្រែថា ទ្រង់សម្តែងតណ្ហា ៦ យ៉ាង ក្នុងព្រះសាសនានេះ ។ ម្យ៉ាងទៀត បទថា **ឥធ** សេចក្តីប៉ុនគ្នានឹង **ឥមស្មឹ យោគ វេទនាបច្ចយា តណ្ហាបទេ** ប្រែថា ក្នុងបទថា ព្រោះវេទនាជាបច្ច័យ ទើបមានតណ្ហានេះ ។ បទថា **តត្ថ** សេចក្តីប៉ុនគ្នានឹង **តាសុ យោគ ឆសុ តណ្ហាសុ** ក្នុងតណ្ហា ៦ នោះ ។

អាការដែលតណ្ហាតែម្យ៉ាង ដែលសហគតៈដោយសស្សតទិដ្ឋិនិងដែលសហគតៈដោយឧច្ឆេទទិដ្ឋិប្រព្រឹត្តទៅក្នុងអារម្មណ៍ មានរូបជាដើម ដែលសមគួរដល់ការរីករាយដោយតណ្ហានោះ តណ្ហាមាន ៣ យ៉ាង ក៏ដោយអាការប្រព្រឹត្តទៅ ដែលពោលហើយព្រោះការប្រព្រឹត្តទៅ ដោយអំណាចសេចក្តីត្រេកអរក្នុងកាម មានអាការពិសេសតែម្យ៉ាង ។

បទថា **មមត្តេន** ប្រែថា ដោយការស្រឡាញ់ អធិប្បាយថា ដោយតណ្ហា គឺការត្រេកអរនោះឯង ។ ក្នុងពាក្យនោះ បណ្ឌិតគប្បីឃើញវេទនាប្រៀបដូចកូនគប្បីឃើញធម៌មានរូបជាដើម ដែលជាបច្ច័យដល់វេទនា ប្រៀបដូចទឹកដោះជាដើម គប្បីឃើញបុគ្គលទាំង ៦ មានជាងគំនូរជាដើម ដែលឲ្យអារម្មណ៍ ៦ មានរូបជាដើម ប្រៀប

ដូចមេដោះដែលឲ្យទឹកដោះជាដើម ។ ក្នុងបណ្តាបុគ្គលទាំង ៦ នោះ បុគ្គលដែលឲ្យសំពត់ ដែលសម្ផស្សជាសុខ គប្បីឃើញថា ឈ្មោះថា **ជាងតម្បាញ** ពេទ្យគប្បីឃើញថា ជាអ្នកឲ្យធម្មារម្មណ៍ ទាក់ទងដោយរសាយតនៈ និងឱជា និងទាក់ទងដោយជីវិតដែលរសាយតនៈ និងឱជានោះឧបត្ថម្ភហើយ ។ **តណ្ហាទាំងឡាយនោះ** បានដល់តណ្ហា មាន ១០៨ ប្រភេទ ។

សុខវេទនា រមែងត្រឹមតែជាអារម្មណ៍របស់តណ្ហាដែលកើតឡើង ព្រោះអារម្មណប្បច្ច័យមិនមែនជាបច្ច័យដែលធ្វើឲ្យកើតឡើង ដូចឧបនិស្សយប្បច្ច័យ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **ប្រការ ១** ដោយអំណាចឧបនិស្សយប្បច្ច័យដែលធ្វើឲ្យកើតឡើងនោះឯង ។ ម្យ៉ាងទៀត លោករួមយកអារម្មណូបនិស្សយ ដោយឧបនិស្សយប្បច្ច័យ និងដោយឧបនិស្សយប្បច្ច័យនោះ រមែងត្រូវលោកសម្តែងភាពជាអារម្មណប្បច្ច័យសូម្បីដទៃ ដែលជាសភាគគ្នានឹងឧបនិស្សយនោះ ដោយភាពជាអារម្មណ៍ ព្រោះហេតុនោះ បណ្ឌិតគប្បីជ្រាបថា លោកពោលភាពជាបច្ច័យដោយអំណាចឧបនិស្សយប្បច្ច័យប៉ុណ្ណោះ ។

ពាក្យថា **ម្យ៉ាងទៀត ព្រោះហេតុដែល** ដូច្នេះជាដើម លោកអាចារ្យរមែងសម្តែងថា មិនមែនសុខវេទនាដែលជាវិបាកតែម្យ៉ាងប៉ុណ្ណោះឡើយ សូម្បីវេទនា ទាំង ៣ដែលជាវិបាកក៏ជាឧបនិស្សយប្បច្ច័យដល់តណ្ហាដោយពិសេស និងវេទនា ក្រៅអំពីនេះក៏ជាឧបនិស្សយប្បច្ច័យដោយមិនពិសេស ។ពាក្យថា **ចំណែកឧបេក្ខាវេទនា ព្រោះជាវេទនាល្អិត ទើបលោកពោលថា ជាសុខដូចគ្នា** អធិប្បាយថា ព្រោះហេតុនោះ សូម្បីសុខវេទនានោះក៏ជាឧបនិស្ស័យដល់តណ្ហា ដោយអំណាចការប្រាថ្នាក្រៃលែង

ឡើងទៅ ។ ចំណែកឧបេក្ខាដែលជាអកុសលវិបាក គួរចាត់ចូលទុកក្នុងទុក្ខ ព្រោះជាវត្ថុដែលមិនគួរប្រាថ្នា ឧបេក្ខាក្រៅអំពីនេះគួរចាត់ចូលក្នុងសុខ ព្រោះជាវត្ថុដែលគួរប្រាថ្នា ព្រោះហេតុនោះ ទើបឧបេក្ខានោះអាចពោលបានថា ជាឧបនិស្សយប្បច្ច័យ ( ដល់តណ្ហា ) ដូចសុខ និងទុក្ខ ។ ព្រោះបច្ច័យដែលមានវេទនាទាំងអស់មាន កាលមានការទាក់ទងគ្នានឹងការកើតឡើងនៃតណ្ហា ដោយពាក្យថា **វេទនាបច្ចយា តណ្ហា** ប្រែថា ព្រោះវេទនាជាបច្ច័យ ទើបមានតណ្ហា ដូច្នេះ លោកអាចារ្យពោលពាក្យជាដើមថា **សូម្បីមានវេទនាជាបច្ច័យ** ដើម្បីបដិសេធការទាក់ទងគ្នានោះ ។

មានពាក្យសួរថា ព្រោះមិនមានព្រះពុទ្ធវចនៈថា **អនុសយសហាយា វេទនា តណ្ហាបច្ចយា** ប្រែថា វេទនា មានអនុស័យជាសម្លាញ់ជាបច្ច័យដល់តណ្ហា ដូច្នេះ ទើបមិនអាចធ្វើការបដិសេធភាពដែលទាក់ទងគ្នាយ៉ាងក្រៃលែងបាន មិនមែនឬ ?

ឆ្លើយថាមិនមែនយ៉ាងនោះព្រោះជារឿងប្រព្រឹត្តទៅដោយការពោលដល់វដ្តៈ។ ព្រោះកាលវៀរចាកអនុស័យហើយ វដ្តៈក៏មិនមានសេចក្ដីនេះ ទើបលោកពោលទុកដោយអត្ថថា វេទនាដែលប្រកបដោយអនុស័យប៉ុណ្ណោះ ទើបជាបច្ច័យ ដូច្នេះ ។ ម្យ៉ាងទៀត វេទនាដែលប្រកបដោយអនុស័យប៉ុណ្ណោះ រមែងដឹងថា ជាបច្ច័យ ព្រោះស្របតាមព្រះបាលីថា **អវិជ្ជាបច្ចយា** ព្រោះអវិជ្ជាជាបច្ច័យ ដូច្នេះ ។ ក្នុងបទថា **វេទនាបច្ចយា តណ្ហា** ព្រោះវេទនាជាបច្ច័យទើបមានតណ្ហានេះលោកមានបំណងយកភាពពិតប្រាកដនេះថា ព្រោះវេទនាជាបច្ច័យប៉ុណ្ណោះ ទើបមានតណ្ហា មិនមែនវៀរចាកវេទនាក៏មាននោះទេ ព្រោះវេទនាជាបច្ច័យ ទើបមានតណ្ហាប៉ុណ្ណោះ ក៏មិនមែនដូច្នេះ ព្រោះហេតុនោះ ទើបការទាក់ទងគ្នាយ៉ាងក្រៃលែង ក្នុងបទនេះ មិនមាននោះឯង ដូច្នេះឯង ។

បទថា **វុសីមតោ** សេចក្ដីប៉ុនគ្នានឹង **វុសិតវតោ** អត្ថថា អ្នកមានការនៅចប់ព្រហ្មចរិយៈហើយ ។ ម្យ៉ាងទៀត **មគ្គ** លោកហៅថា **វុសី** ព្រោះអត្ថថា ដែលព្រះអរិយបុគ្គលនៅ មគ្គនោះដែលព្រះអរិយបុគ្គលនៅហើយ ក៏មានដល់ព្រាហ្មណ៍នេះ ហេតុនោះព្រាហ្មណ៍នេះ ឈ្មោះថា **វុសីមា** ដែលមានមគ្គនៅហើយ ដោយនិទ្ទេសយ៉ាងឧក្រិដ្ឋបានដល់ ព្រះអរហន្ត ។ ម្យ៉ាងទៀត ផលដ៏លើស លោកហៅថា **វុសី** ព្រោះជាផលដែលមានការនៅសម្រេចហើយ ផលដ៏លើសឈ្មោះ **វុសី** នោះ មានដល់ព្រាហ្មណ៍នេះហេតុនោះ ព្រាហ្មណ៍នេះឈ្មោះថា **វុសីមា** អ្នកមានផលដ៏លើសសម្រេចហើយ ។

# វិសុទ្ធិមគ្គ

## អធិប្បាយ បទថា តណ្ហាបច្ចយា ឧបាទានំ

ក្នុងបទថា តណ្ហាបច្ចយា ឧបាទានំ

ឧបាទានមាន ៤ បណ្ឌិតគប្បីអធិប្បាយឧបាទាន ៤ នោះ ដោយអត្ថវិភាគ ( ចែកសេចក្ដី ) ដោយសង្ខេប និងដោយពិស្ដារនៃធម៌ និងដោយលំដាប់ ។

នេះជាអធិប្បាយក្នុងឧបាទាននោះ គឺក្នុងគាថានេះ ដំបូង ( ពោលដោយ ) ឧបាទានមាន ៤ គឺកាមុបាទាន ទិដ្ឋុបាទាន សីលព្វតុបាទាន អត្តវាទុបាទាន ។

តទៅនេះ ជាអត្ថវិភាគនៃឧបាទានទាំងនោះ

## អត្ថនៃកាមុបាទាន

( អត្ថថា ) បុគ្គលរមែងប្រកាន់មាំនូវកាមដែលបានដល់វត្ថុ ហេតុនេះ ទើបឈ្មោះថា កាមុបាទាន ( ប្រែថា សេចក្ដីប្រកាន់មាំក្នុងកាមនៃបុគ្គល ) ដូច្នេះខ្លះ ។

( អត្ថថា ) កាម ( គឺកិលេស ) ដោយកាម ( គឺកិលេស ) នោះ ជាធម្មជាតិដែលប្រកាន់មាំផង ហេតុនេះទើបឈ្មោះថា កាមុបាទាន ( ប្រែថា កាមដែលប្រកាន់មាំ ) ដូច្នេះខ្លះ ។

## អត្ថនៃឧបាទានសព្ទ

ពាក្យថា ឧបាទាន ប្រែថា ប្រកាន់មាំ ព្រោះ **ឧប**-សព្ទ ក្នុងទីនេះមាន ទឡ្ហ សព្ទ ( មាំ រឹងមាំ ក្ដៀវក្ដាក្រៃពេក ) ជាអត្ថ ដូច **ឧប**-សព្ទ ក្នុងពាក្យថា ឧបាយាស ( លំបាកចិត្តក្រៃពេក គឺតានតឹង ) និងពាក្យថា **ឧបក្កដ្ឋ** ( ទាញមកជិតពេក គឺរហ័ស ) ជាដើម ។

## អត្ថនៃទិដ្ឋុបាទាន

ន័យដូចគ្នានោះ ( គឺឧបាទានស័ព្ទ មានអត្ថថា ប្រកាន់មាំ ទាញទុកដូចគ្នា ) គឺ ( អត្ថថា ) ទិដ្ឋិផង ទិដ្ឋិនោះជាធម្មជាតិប្រកាន់មាំផង ហេតុនោះ ទើបឈ្មោះថា ទិដ្ឋុបាទាន ( ប្រែថា ទិដ្ឋិដែលប្រកាន់ទុក ) អត្ថមួយទៀតថា ទិដ្ឋិរមែងប្រកាន់មាំ ក្នុងទិដ្ឋិ ហេតុនោះ ទើបឈ្មោះទិដ្ឋុបាទាន ( ប្រែថា ទិដ្ឋិប្រកាន់ទិដ្ឋិ ) ព្រោះថា ឧត្តរទិដ្ឋិ ( ការឃើញខាងក្រោយ ) រមែងប្រកាន់បរិមទិដ្ឋិ ( ការឃើញមុនៗ ) ក្នុងការឃើញខុសទាំងឡាយ មានឃើញថា អត្តាទៀង និងលោកទៀងជាដើម ។

## អត្ថនៃសីលព្វតុបាទាន

ន័យដូចគ្នានោះ គឺ ( អត្ថថា ) បុគ្គលរមែងប្រកាន់មាំសីល និងវត្ត ហេតុនេះ ទើបឈ្មោះសីលព្វតុបាទាន ដូច្នេះខ្លះ អត្ថថា សីលព្វតផង សីលព្វតនោះជាធម្មជាតិប្រកាន់មាំផង ហេតុនោះ ទើបឈ្មោះថា សីលព្វតុបាទាន ( ប្រែថា សីលព្វតដែលប្រកាន់មាំ ) ដូច្នេះខ្លះ ព្រោះថា សីលព្វតផ្សេងៗ មានគោសីល និងគោវត្តជាដើម ជាឧបាទានក្នុងខ្លួនឯង ព្រោះប្រកាន់មាំថា សេចក្ដីបរិសុទ្ធនឹងមានដោយសីលវត្ត យ៉ាងនោះ ។

## អត្ថនៃអត្តវាទុបាទាន

ន័យដូចគ្នានោះ បុគ្គលទាំងឡាយរមែងពោលព្រោះវត្ថុនោះ ( ជាហេតុ ) ហេតុនេះ ទើបវត្ថុនោះឈ្មោះ វាទៈ ( ប្រែថា វត្ថុជាហេតុពោល ) ។

សត្វទាំងឡាយរមែងប្រកាន់មាំ ព្រោះវត្ថុនោះ ( ជាហេតុ ) ហេតុនេះ ទើបវត្ថុនោះឈ្មោះថា ឧបាទាន ( ប្រែថា វត្ថុជាហេតុប្រកាន់មាំ ) ។

សួរថា បុគ្គលទាំងឡាយរមែងពោលក្ដី រមែងប្រកាន់មាំក្ដី នូវអ្វី ? ឆ្លើយថា

បុគ្គលទាំងឡាយ រមែងពោលក្តី ប្រកាន់មាំក្តី នូវអត្តា ។

វត្ថុជាហេតុពោល ជាហេតុប្រកាន់មាំនូវអត្តា ឈ្មោះថា អត្តវាទុបាទាន ។ អត្ត ម្យ៉ាងទៀត បុគ្គលទាំងឡាយរមែងប្រកាន់មាំយកត្រឹមពាក្យថា អត្តាប៉ុណ្ណោះឯង ថា ជាអត្តា ព្រោះវត្ថុនោះ ( ជាហេតុ ) ហេតុនេះ ទើបវត្ថុនោះឈ្មោះថា អត្តវាទុបាទាន ( ប្រែថា វត្ថុជាហេតុប្រកាន់មាំត្រឹមពាក្យថា អត្តា ) ។

នេះជាអត្ថវិភាគនៃឧបាទានទាំងនោះ ជាលំដាប់ដំបូង ។

## ដោយសង្ខេប និង ដោយពិស្តារ

ចំណែកក្នុងប្រការសង្ខេប និងពិស្តារនៃធម៌ ( នោះ ) ដោយសង្ខេបលំដាប់ ដំបូង **តណ្ហាទឡ្ហត្ត** គឺការប្រកាន់ស្អិតនៃតណ្ហា ហៅថា **កាមុបាទាន** ព្រោះមកក្នុង បាលីថា ក្នុងឧបាទាន ៤ នោះ កាមុបាទានដូចម្តេច ? **កាមច្ឆន្ទៈ** សេចក្តីពេញចិត្ត ដោយអំណាចកិលេសកាម ក្នុងកាម ( គុណ ) ទាំងឡាយឯណា **កាមរាគៈ** គឺសេចក្តី តម្រេកដោយអំណាចកិលេសកាម ក្នុងកាម ( គុណ ) ទាំងឡាយឯណា **កាមនន្ទិ** គឺសេចក្តីត្រេកអរដោយអំណាចកិលេសកាម ក្នុងកាម ( គុណ ) ទាំងឡាយឯណា **កាមតណ្ហា** គឺការចង់បានដោយអំណាចកិលេសកាម ក្នុងកាម ( គុណ ) ទាំងឡាយ ឯណា **កាមស្នេហ** គឺសេចក្តីស្រឡាញ់ដោយអំណាចកិលេសកាម ក្នុងកាម ( គុណ ) ទាំងឡាយឯណា **កាមបរិឡាហ** គឺសេចក្តីអន្ទះអន្ទែងដោយអំណាចកិលេសកាម ក្នុង កាម ( គុណ ) ទាំងឡាយឯណា **កាមមុច្ឆា** គឺការងប់ជ្រប់ដោយអំណាចកិលេសកាម ក្នុងកាម ( គុណ ) ទាំងឡាយឯណា **កាមជ្ឈោសាន** គឺការសំចតចិត្តដោយអំណាច កិលេសកាម ក្នុងកាម ( គុណ ) ទាំងឡាយឯណា នេះហៅថា **កាមុបាទាន** ។

ឧតរតណ្ហា គឺតណ្ហាដែលកើតក្រោយៗ តមក ដែលកើតជាទោសច្រើនឡើងៗ

ព្រោះមានបុរិមតណ្ហា គឺតណ្ហាដែលកើតមុនៗ ជាឧបនិស្សយប្បច្ច័យនោះឯង ឈ្មោះថា តណ្ហាទឡ្ហត្ត ។

តែអាចារ្យពួកខ្លះពោលថា សេចក្តីប្រាថ្នាអារម្មណ៍ដែលនៅមិនទាន់មកដល់ជាតណ្ហា ឧបមាដូចការលាដៃរបស់ចោរ ( ស្រវារកវត្ថុរបស់របរ ) ក្នុងទីងងឹត ដូច្នោះការតោងយកអារម្មណ៍ដែលមិនទាន់មកដល់ទុកជាឧបាទាន ឧបមាដូចការស្រវាយកទ្រព្យ ( ដែលរាវប៉ះ ) របស់ចោរនោះៗ ឯង ឯធម៌ ( ទាំងពីរ ) នោះជាបដិបក្ខចំពោះអប្បិច្ឆតា និងសន្តុដ្ឋិតា ។ មួយវិញទៀត ជាមូលនៃបរិយេសនទុក្ខ គឺទុក្ខព្រោះការស្វែងរក និងអារក្ខទុក្ខ គឺទុក្ខព្រោះការរក្សា ។

ចំណែកឧបាទាន ៣ ដ៏សេសដោយសង្ខេបក៏ត្រឹមជាទិដ្ឋិប៉ុណ្ណោះ ។

ចំណែកពោលដោយពិស្តារ ការហួងហែងនៃតណ្ហាក្នុងអារម្មណ៍ទាំងឡាយមានរូបជាដើម ដែលមានប្រភេទដល់ទៅ ១០៨ ដែលពោលមកអំពីមុន ( នោះ ) ជាកាមុបាទាន មិច្ឆាទិដ្ឋិមានវត្ថុ ១០ ជាទិដ្ឋុបាទាន ដូចបាលីថា ក្នុងឧបាទាន ទាំងនោះទិដ្ឋុបាទានដូចម្តេច ? ការយល់ឃើញ ។បេ។ ការប្រកាន់វិបល្លាសដូច្នេះថា ការឲ្យ ( ជាទាន ) មិនមាន ( ផលវិបាក ) ការ ( ឲ្យជាការ ) បូជាមិនមាន ( ផលវិបាក ) ។បេ។ សមណព្រាហ្មណ៍ទាំងឡាយដែលដំណើរប្រពៃ បដិបត្តិប្រពៃ បុគ្គលដែលធ្វើឲ្យជាក់ច្បាស់នូវលោកនេះ និងលោកដទៃ ដោយអភិញ្ញាខ្លួនឯង ហើយ ( ប្រកាស ) ឲ្យដឹងទូទៅ មិនមានក្នុងលោក ដូច្នេះឯណា នេះហៅថា ទិដ្ឋុបាទាន ។

ចំណែកការប្រកាន់មាំថា ភាពបរិសុទ្ធមានបានដោយសីល និងវត្តទាំងឡាយជាសីលព្វតុបាទាន ដូចបាលីថា ក្នុងឧបាទានទាំងនោះ សីលព្វតុបាទានដូចម្តេច ? ការឃើញ ។បេ។ ការប្រកាន់វិបល្លាសដូច្នេះថា ភាពបរិសុទ្ធមានបានដោយសីល ភាពបរិសុទ្ធមានបានដោយវត្ត ភាពបរិសុទ្ធមានបានដោយសីល និងវត្ត ដូច្នេះឯណា

នេះហៅថា **សីលព្វតុបាទាន** ។

សក្កាយទិដ្ឋិមានវត្ថុ ២០ ជាអត្តវាទុបាទាន ដូចបាលីថា ក្នុងឧបាទានទាំងនោះ អត្តវាទុបាទានដូចម្តេច ? បុថុជ្ជនដែលមិនបានស្តាប់ក្នុងលោកនេះ ។បេ។ មិនបានហ្វឹកហាត់ក្នុងធម៌របស់សប្បុរស រមែងឃើញរូបដោយភាពជាខ្លួន ។បេ។ ការឃើញ ។បេ។ ការប្រកាន់វិបល្លាសដូច្នេះឯណា នេះហៅថា **អត្តវាទុបាទាន** ។

នេះជាសេចក្តីសង្ខេប និងសេចក្តីពិស្តារនៃធម៌ក្នុងឧបាទាននោះ ។

## ដោយលំដាប់

ចំណែកក្នុងពាក្យថា **ដោយលំដាប់** នោះ មានពណ៌នាថា លំដាប់មាន ៣យ៉ាង គឺលំដាប់ការកើតឡើង ១ លំដាប់ការលះ ១ លំដាប់ការសម្តែង ១ ។

ក្នុងលំដាប់ ៣ យ៉ាងនោះ ព្រោះមិនមានថា ការកើតឡើងនៃវត្ថុនេះមានមុន ក្នុងសង្សារដែលមិនមានទរណាដឹងខាងដើម-ខាងចុង ដូច្នេះ លំដាប់ការកើតឡើងនៃកិលេសទាំងឡាយ ទើបលោកមិនពោលទុកដោយត្រង់ តែដោយអមគប្បីពោលបានថា អត្តវាទុបាទានកើតមុនគេ តអំពីនោះ ទើបទិដ្ឋុបាទាន សីលព្វតុបាទាន និងកាមុបាទានកើត (ដោយលំដាប់) ដោយអធិប្បាយដូច្នេះគឺដោយច្រើនក្នុងភពនីមួយៗ ( អត្តវាទុបាទាន គឺ ) ការប្រកាន់មាំថាទៀង ឬថា ដាច់សូន្យ ដែលមានការប្រកាន់អត្តាទៅខាងមុខ ( កើតឡើងមុន ) តអំពីនោះ សីលព្វតុបាទាន ដែលមានភាពបរិសុទ្ធនៃអត្តាជាគោលដៅ ( ទើបកើតឡើង ) ដល់បុគ្គលដែលប្រកាន់ថា អត្តានេះទៀង ( ហើយ ) កាមុបាទាន ( ទើបកើតឡើង ) ដល់បុគ្គលដែលប្រកាន់ថា អត្តានេះដាច់សូន្យ មិនជាប់តចំពោះបរលោក នេះជាលំដាប់នៃការកើតឡើងរបស់ឧបាទាន ៤ នោះ ក្នុងភពនីមួយៗ ។

ចំណែកលំដាប់ការលះគប្បីជ្រាបថា ក្នុងឧបាទាន ៤ នោះ ឧបាទាន ៣ មានទិដ្ឋុបាទានជាដើម លះបានមុន ព្រោះឧបាទាន ៣ នោះ ជាទោសដែលសោតាបត្តិមគ្គគប្បីលះកាមុបាទានលះបានខាងក្រោយ ព្រោះកាមុបាទានជាទោសដែលអរហត្តមគ្គគប្បីលះ នេះជាលំដាប់ការលះនៃឧបាទានទាំងឡាយនោះ ។

ចំណែកលំដាប់ការសម្ដែង គប្បីជ្រាបថា ក្នុងឧបាទាន ៤ នោះ កាមុបាទានសម្ដែងមុន ព្រោះជាទោសមានវិស័យធំ និងព្រោះជាទោសប្រាកដ ( ឃើញច្បាស់ ) ផង ។ ពិតណាស់ កាមុបាទាននោះ រាប់ជាទោសមានវិស័យធំ ព្រោះសម្បយោគជាមួយចិត្តទាំង ៨ ដួង ឧបាទានក្រៅអំពីនេះ រាប់ជាទោសមានវិស័យតូច ព្រោះសម្បយោគជាមួយចិត្ត ( ត្រឹមតែ ) ៤ ដួង ។ម្យ៉ាងទៀត កាមុបាទាន រាប់ថា ជាទោសប្រាកដដល់ពពួកសត្វ ព្រោះភាពដែលពពួកសត្វជាអ្នកត្រេកអរ ក្នុងអាល័យដោយច្រើន ឧបាទានក្រៅអំពីនេះមិនប្រាកដ អ្នកមានកាមុបាទាន រមែងជាអ្នកច្រើនទៅដោយការធ្វើមង្គល មានកោតុហលមង្គល ( មង្គលដែលធ្វើឲ្យជាការគគ្រឹកគគ្រេង ) ជាដើម ដើម្បី ( ឲ្យ ) បាន ( វត្ថុ ) កាមទាំងឡាយ ដោយងាយ ភាពជាអ្នកច្រើនដោយការធ្វើមង្គល មានកោតុហលមង្គលជាដើម របស់បុគ្គលដែលមានកាមុបាទាននោះ ជាសស្សតទិដ្ឋិ ព្រោះដូច្នោះ ទើបទិដ្ឋុបាទានសម្ដែងក្នុងលំដាប់កាមុបាទាននោះ ទិដ្ឋុបាទាននោះកាលបំបែកចេញ ក៏បាន ២ យ៉ាង ដោយជាសីលព្វតុបាទាន និងអត្តវាទុបាទាន ក្នុង ២ យ៉ាងនោះ សីលព្វតុបាទានសម្ដែងមុន ព្រោះថា ជាទោសគ្រោតគ្រាត ព្រោះសូម្បីឃើញកិរិយាគោ ឬកិរិយាឆ្កែក៏ដោយ ( ដែលបុគ្គលមានសីលព្វតុបាទានបង្ហាញ ) ក៏គប្បីជ្រាបបាន **អត្តវាទុបាទាន** សម្ដែងទុកចុងក្រោយ ព្រោះជាទោសល្អិត នេះជាលំដាប់ការសម្ដែងនៃឧបាទាន ៤ នោះ

## គាថាសង្ខេបបច្ចយន័យ

ក្នុងឧបាទានទាំងឡាយនេះ តណ្ហាជាបច្ច័យតែម្យ៉ាងនៃឧបាទានប្រការមុនគេ រាប់ជាបច្ច័យ ៧ យ៉ាងខ្លះ ៨ យ៉ាងខ្លះក៏មាន នៃឧបាទាន ៣ ដ៏សេស ។

## ពន្យល់ពាក្យសេចក្តី

ឯក្នុងឧបាទានទាំងឡាយនេះ គឺក្នុងឧបាទាន ៤ ដែលសម្តែងមកដូច្នេះ កាមតណ្ហា ជាបច្ច័យតែម្យ៉ាង ដោយជាឧបនិស្សយប្បច្ច័យប៉ុណ្ណោះនៃឧបាទានទី ១ គឺកាមុបាទាន ព្រោះកើតឡើងក្នុងអារម្មណ៍ទាំងឡាយ ដែលតណ្ហាត្រេកអរដោយចំពោះតែតណ្ហា ជាបច្ច័យ ៧ យ៉ាង ដោយសហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ សម្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ និងហេតុប្បច្ច័យក៏មាន ជា ៨ យ៉ាង ទាំងឧបនិស្សយប្បច្ច័យខ្លះក៏មាន នៃឧបាទាន ៣ ដ៏សេស តែថា កាលណាតណ្ហា ជាបច្ច័យដោយជាឧបនិស្សយ កាលនោះ តណ្ហាក៏ជាអសហជាត ( គឺមិនជាសហជាត ផងដូច្នេះ ) ។

នេះជាកថាយ៉ាងពិស្តារ ក្នុងបទថា តណ្ហាបច្ចយា ឧបាទានំ ។

# មហាដីកា

## កថាពណ៌នាដោយពិស្តារនៃបទថា

## ព្រោះមានតណ្ហាជាបច្ច័យ ទើបមានឧបាទាន

*__អត្ថវិភាគ__ បានដល់ ការចែកអត្ថ ។ លោកអាចារ្យពោលអារម្មណ៍ មានរូបជាដើម ដែលតែងហៅថា កាមគុណថា __វត្ថុសង្ខាតំ កាមំ__ កាម ពោល គឺវត្ថុ ។ បទថា __ឧបាទិយតិ__ បានដល់ កាន់យកដោយអំណាចកាម អធិប្បាយថា ត្រេកអរយ៉ាងក្រៃលែង ។ __កាម-ស័ព្ទ__ ក្នុងបទថា __កាមំ ឧបាទិយតិ__ ប្រកាន់មាំក្នុងកាម នេះជាកម្មសាធនៈ ។ ក្នុងបទថា __កាមោ ច សោ__ កាមនោះផង នេះជាកត្តុសាធនៈ ព្រោះលោកមានបំណងយកកិលេសកាម ។ ចំណែក __ឧបាទាន-ស័ព្ទ__ សូម្បីក្នុងបទទាំង ២ ជាកត្តុសាធនៈតែម្យ៉ាង ។ __អត្ថថា ទឡ្ហ__ ( មាំទាំ ) ប៉ុន្តែគ្នានឹងអត្ថថា __កុស__ ( ខ្លាំងក្លា ) ។ __កុសោ អាយាសោ__ ( លំបាកចិត្តយ៉ាងខ្លាំងក្លា ) ឈ្មោះថា __ឧបាយាសោ__ ប្រែថាតានតឹងចិត្ត __កុសំ កុដ្ឋំ__ ភេគយូងយ៉ាងខ្លាំងក្លា ឈ្មោះថា __ឧបកុដ្ឋំ__ យ៉ាងណា សូម្បីក្នុងបទថា __ឧបាទាន__ នេះ ក៏ដូចគ្នាដូច្នោះ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា ដូចក្នុងពាក្យថា __ឧបាយាស ឧបកុដ្ឋ__ ជាដើម ។ ច្រើនបទថា __បុរិមទិដ្ឋិ ឧត្តរទិដ្ឋិ ឧបាទិយតិ__ ឧត្តរទិដ្ឋិ គឺការយល់ខុសខាងក្រោយ រមែងប្រកាន់មាំក្នុងបុរិមទិដ្ឋិ គឺការយល់ខុសអំពីដំបូង សេចក្តីថា ការប្រកាន់បុរិមទិដ្ឋិដោយភាពជារបស់ទៀង ឈ្មោះថា រមែងប្រកាន់មាំ ម្យ៉ាងទៀត ឧត្តរទិដ្ឋិ កើតឡើងដោយអាការនៃបុរិមទិដ្ឋិ កាលធ្វើបុរិមទិដ្ឋិឲ្យមាំដោយអាការនោះៗ ឯង លោកហៅថា ប្រកាន់មាំក្នុងបុរិមទិដ្ឋិនោះ ។ ន័យម្យ៉ាងទៀត ពាក្យថា __ឧត្តរទិដ្ឋិ រមែងប្រកាន់មាំបុរិមទិដ្ឋិ__ នេះ លោកពោលទុកដើម្បីសម្តែងលម្អិតឧត្តរទិដ្ឋិ ដែលប្រកាន់មាំក្នុងបុរិមទិដ្ឋិថា __ខ្លួនទៀង__ ។ ដូចជាឧត្តរទិដ្ឋិ*

នេះប្រកាន់មាំបុរិមទិដ្ឋិដោយអំណាចធ្វើឲ្យមាំ យ៉ាងណា សូម្បីទិដ្ឋិជាដើមថា **នត្ថិ ទិន្នំ** ទានដែលឲ្យហើយមិនមានផល ដូច្នេះ ក៏ដូច្នោះនោះឯង ។ ចំណែកការប្រកាន់ **អត្តា** ជាអត្តវាទុបាទាន ព្រោះហេតុនោះ គប្បីឃើញថា ការប្រកាន់អត្តានេះ មិនមែនជាការសម្តែងទិដ្ឋុបាទាន ម្យ៉ាងទៀត ការប្រកាន់ដែលផុតទៅអំពីការប្រកាន់អត្តាថា **លោកទៀង** ដូច្នេះ ជាទិដ្ឋុបាទាន បណ្ឌិតគប្បីជ្រាបថា លោកពោលទុកដោយពាក្យថា **បុរិមទិដ្ឋិ** និង **ឧត្តរទិដ្ឋិ** ក្នុងទីនេះ ។

ក្នុងពាក្យថា **បុគ្គលរមែងប្រកាន់សីលព្វត** នេះ អធិប្បាយថា ឈ្មោះថា **សីល** ដោយអំណាចការសមាទានសីលរបស់គោ ដែលមិនមែនជាផ្លូវនៃសេចក្តីបរិសុទ្ធជាដើម ឈ្មោះថា **វត្ត** ដោយអំណាចការមិនកន្លងល្មើស ។ ម្យ៉ាងទៀត ទាំង ២ ប្រការ ឈ្មោះថា **សីល** ឈ្មោះថា **វត្ត** ព្រោះជាការកាន់យកដោយភាពជាកម្ម គឺតប: បានដល់ការធ្វើប្រក្រតីរបស់គោជាដើមឲ្យមាន ។ ម្យ៉ាងទៀត ការដែលខ្ជួនអធិដ្ឋានភាពជាគោជាដើម ឈ្មោះថា **សីល** ការធ្វើកិរិយារបស់គោជាដើម ដោយន័យជាដើមថា **ដើរស៊ីឈរបន្ទោបង់បស្សាវៈ** ឈ្មោះថា **វត្ត** ។ ម្យ៉ាងទៀត ការបដិសេធអំពីសម្មតិវត្តដែលមិនមែនជារឿងគួរធ្វើនោះ ឈ្មោះថា **សីល** ការបដិបត្តិដែលផ្សេងគ្នា មានការធ្វើកិច្ចក្នុងការបរិភោគជាដើមរបស់បុគ្គល អ្នកសមាទានសីលនោះ ឈ្មោះថា **វត្ត** បុគ្គលកាលប្រកាន់ខុសវត្តដែលមិនមែនផ្លូវនៃសេចក្តីបរិសុទ្ធថា **ជាផ្លូវបរិសុទ្ធ** កាលប្រកាន់មាំយ៉ាងនោះ ឈ្មោះថា **រមែងប្រកាន់មាំនូវសីលវត្តនោះ** អធិប្បាយថា រមែងកាន់យកការប្រកាន់នោះឲ្យមាំពិត ។ លោកអាចារ្យកាន់យកការប្រកាន់ខុស ដែលប្រព្រឹត្តទៅរួមជាមួយសីលវត្តថា ជាសីលព្វត ទើបពោលថា **សីលវត្តនោះផង ជាការប្រកាន់មាំផង** ដូច្នេះ ។ ម្យ៉ាងទៀត លោកពោលទិដ្ឋិយ៉ាងនោះថា **សីលវត្តផ្សេងៗ មានគោសីល និងគោវត្ត** ជាដើម ។ ដោយហេតុនោះឯង ទើបលោកពោលថា **ជា**

**ឧបាទានក្ខន្ធនិទ្ទេស** ។ បទថា **អភិនិវេសតោ** សេចក្ដីប៉ុនគ្នានឹង **អភិនិវេសកាវតោ** ប្រែថា ព្រោះការៈដែលប្រកាន់មាំ ឬប៉ុនគ្នានឹង **អភិនិវិសនតោ** ព្រោះការប្រកាន់មាំ ។ ពាក្យថា **អត្តវាទុបាទាន** សេចក្ដីថា បានដល់ ទិដ្ឋិដែលជាហេតុនៃវាទៈ គឺបញ្ញត្តិ និងនៃការប្រកាន់ថា **អត្តា** ។ ពាក្យថា **ត្រឹមតែវាទៈថាអត្តាប៉ុណ្ណោះឯង** គឺត្រឹមតែពាក្យថា **អត្តា** ប៉ុណ្ណោះ ព្រោះមិនមានអត្តាទេ ។ បទថា **ឧបាទិយន្តិ** ប្រែថា រមែងប្រកាន់មាំ ។ ប្រកាន់មាំដូចម្ដេច ? ប្រកាន់មាំថា **ជាអត្តា** ។ អធិប្បាយថា ពិតហើយ សត្វទាំងឡាយ ដែលប្រកាន់មាំថា **អត្តា** រមែងប្រកាន់ការធ្វើត្រឹមតែពាក្យសម្ដីប៉ុណ្ណោះឲ្យមាំ ដូច្នេះ ។ លោកពោលទុកថា **សត្វទាំងឡាយ រមែងប្រកាន់មាំត្រឹមតែជាវាទៈថា អត្តាប៉ុណ្ណោះ** ដោយប្រការដូច្នេះ ។ ម្យ៉ាងទៀត លោកអាចារ្យពោលដល់ត្រឹមតែទីតាំងនៃវាចាប៉ុណ្ណោះថា **ត្រឹមតែវាទៈថា អត្តា** ។ ពិតហើយ សត្វទាំងឡាយ រមែងប្រកាន់មាំត្រឹមតែទីតាំងនៃវាចាប៉ុណ្ណោះថា **ជាអត្តា** ព្រោះមិនមានតួអត្តា ។

លោកអាចារ្យរមែងពង្រីកសេចក្ដីសង្ខេប និងសេចក្ដីពិស្ដារដែលជាចំណែកបន្តិចបន្តួចនោះអំពីការរួមនៃការសង្ខេប និងការពិស្ដារនៃធម៌យ៉ាងនេះថា **ក្នុងសេចក្ដីសង្ខេប និងសេចក្ដីពិស្ដារនៃធម៌ កាមុបាទានពោលដោយសង្ខេប បានដល់ ការមាំទាំនៃតណ្ហា ឧបាទានដ៏សេស ៣ ត្រឹមតែជាទិដ្ឋិប៉ុណ្ណោះ តែដោយពិស្ដារ** ដូច្នេះឯង ។ បទថា **ធម្មសង្ខេបវិត្ថារេ** គប្បីឃើញជាសត្តមីវិភត្តិចុះក្នុងនិទ្ធារណៈ ។ បទថា **កាមេសុ** បានដល់ ក្នុងកាមគុណទាំង ៥ ។ ពាក្យថា **កាមច្ឆន្ទៈ** បានដល់ សេចក្ដីពេញចិត្ត គឺកាម មិនមែន **កត្តុកម្យតាឆន្ទៈ** និងមិនមែន **ធម្មច្ឆន្ទៈ** សេចក្ដីតម្រេក គឺកាម ដោយអំណាចធ្វើឲ្យប្រាថ្នា និងដោយអំណាចសេចក្ដីត្រេកអរ ឈ្មោះថា **កាមរាគៈ** បណ្ឌិតកាលជ្រាបអត្ថរបស់កាមក្នុងទីនេះទាំងឡាយយ៉ាងនេះគប្បីជ្រាបថា កាមនោះឯង ឈ្មោះថា **កាមនន្ទី** ដោយអត្ថថា ត្រេកអរ កាមនោះឯង ឈ្មោះថា **កាមតណ្ហា**

ដោយអត្ថថា ធ្វើឲ្យចង់បាន កាមនោះឯង ឈ្មោះថា **កាមស្នេហា** ដោយអត្ថថា ជាស្នេហា ឈ្មោះថា **កាមបរិឡាហ** ដោយអត្ថថា ក្តៅអន្ទះអន្ទែង ឈ្មោះថា **កាមមុច្ឆា** ដោយអត្ថថា ងប់ជ្រប់ ឈ្មោះថា **កាមជ្ឈោសាន** ដោយអត្ថថា លេបចូលទៅហើយធ្វើឲ្យចត់ ។ ដែលឈ្មោះថា **ការប្រាថ្នាអារម្មណ៍ដែលមិនទាន់មកដល់ជាតណ្ហា** ព្រោះជាការបង្រេះនទៀលនៅក្នុងអារម្មណ៍ ដែលឈ្មោះថា **ការទាញយកអារម្មណ៍ដែលមកដល់ជាឧបាទាន** ព្រោះជាភាពប្រកាន់មាំនៅក្នុងអារម្មណ៍ ។ **តណ្ហា** ឈ្មោះថា **ជាបដិបក្ខចំពោះអប្បិច្ឆតា** ព្រោះជាការបែរមុខទៅកាន់អារម្មណ៍ **ឧបាទាន** ឈ្មោះថា **ជាបដិបក្ខចំពោះសន្តុដ្ឋិ** ព្រោះជាការមាំទាំនៃតណ្ហា ជាការប្រាថ្នាក្រៃលែង ។ **តណ្ហា** ឈ្មោះថា **មានទុក្ខ ព្រោះការស្វែងរកជាមូល** ព្រោះជាការប្រាថ្នាអារម្មណ៍ដែលនៅមិនទាន់មកដល់ **ឧបាទាន** ឈ្មោះថា **មានទុក្ខ ព្រោះការរក្សាជាមូល** ព្រោះជាការកាន់យកអារម្មណ៍ដែលមកដល់ហើយ ។

ក្នុងពាក្យថា **នត្ថិ ទិន្នំ** ទានដែលបុគ្គលឲ្យហើយមិនមានផលជាដើម មានវិនិច្ឆ័យដូច្នេះ លោកពោលទានថា **ទិន្នំ** លោកបដិសេធថា ទានទាំងនោះមិនឈ្មោះជាទានដូចគ្នានឹងរូប ព្រោះជាវត្ថុមិនមានផល ។ ការបូជាធំ ដូចគ្នានឹងយញ្ញរបស់ព្រះបាទមហាវិជិតរាជ ហៅថា **យិដ្ឋំ** ការបូជា ។ **អាហុន** ការនាំមកបូជា **បាហុន** ការក្រោកទទួល និង **មង្គលកិរិយា** ការធ្វើមង្គល ឈ្មោះថា **ហុតំ** ការបូជា ។ ក្នុងប្រការ ៣ នោះ ការអញ្ជើញមកហើយបូជា គឺឲ្យទាន ឈ្មោះថា **អាហុនំ** ការនាំមកបូជា ការក្រោកទទួលភ្ញៀវទាំងឡាយដែលគួរទទួល ឈ្មោះថា **បាហុនំ** ការក្រោកទទួល ការឲ្យដើម្បីជាមង្គល ដូចក្នុងគ្រាអាវាហមង្គលជាដើម ឈ្មោះថា **មង្គលកិរិយា** ការធ្វើមង្គល កុសលកម្មបថ ១០ ឈ្មោះថា **កម្មល្អ** អកុសលកម្មបថ ១០ ឈ្មោះថា **កម្មដែលធ្វើអាក្រក់** ពាក្យថា **ផលវិបាក** ប្រកបសេចក្តីថា **ផល** មានផលដែលបញ្ជូន

មកជាដើម និងវិបាកដោយត្រង់រមែងមិនមាន ។ គប្បីឃើញការបដិសេធផលនៃវិបាក ក្នុងពាក្យថា **ទានដែលបុគ្គលឲ្យហើយមិនមានផល** ជាដើម ដូចនៅក្នុងទីនេះឯង ។ ពាក្យថា **លោកនេះមិនមាន** សេចក្ដីថា បុគ្គលដែលនៅក្នុងលោកដទៃ រមែងប្រកាន់លោកនេះថា **មិនមាន** ។ អធិប្បាយថា លោកដទៃមាន ក៏ដោយសួន់ឃើញលោកនេះ ព្រោះត្រូវទៅ ហើយលោកនេះមានក៏ដោយ ពិចារណាឃើញលោកដទៃ ព្រោះត្រូវមក ព្រោះហេតុនោះ បុគ្គលដែលនៅក្នុងលោកដទៃ រមែងប្រកាន់លោកនេះថា **មិនមាន** ដោយចិត្ត ព្រោះដាច់សូន្យទៅក្នុងលោកដទៃនោះឯង ហេតុដែលមិនមានការមកកាន់លោកនេះអំពីលោកដទៃ ។ សេចក្ដីពិត ទិដ្ឋិនេះ រមែងមិនមានដល់បុគ្គលនៅក្នុងលោកដទៃប៉ុណ្ណោះទេ ។ ពាក្យថា **លោកដទៃមិនមាន** សេចក្ដីថា បុគ្គលដែលនៅក្នុងលោកនេះរមែងប្រកាន់លោកដទៃថា **មិនមាន** ។ សូម្បីក្នុងទីនេះ ក៏គប្បីជ្រាបអត្ថតាមន័យដែលពោលហើយនោះឯង ។ម្យ៉ាងទៀត ក្នុងអធិការនេះ មានអត្ថដូច្នេះ ប្រទេសដែលអន្ទោលទៅ ឈ្មោះថា **លោកនេះ** ហើយលោកដទៃមិនមាន ព្រោះដាច់សូន្យទៅក្នុងទីនោះៗ ឯង ហេតុដែលមិនមានការអន្ទោលទៅ ដូច្នេះ ។

ការកើតឡើងក្នុងភពខាងក្រោយអំពីភពមុន ឈ្មោះថា **ឧបបាតោ** ប្រែថា ការកើតឡើង ។ ការកើតឡើងនោះជាប្រក្រតីរបស់សត្វពួកណា សត្វទាំងនោះ ឈ្មោះថា **ឱបបាតិក** បុគ្គលកើតឡើង ។ ព្រះមានព្រះភាគកាលទ្រង់សម្ដែងថា សត្វដែលចុតិនិងឧប្បត្តិទាំងនោះមិនមាន ទើបត្រាស់ថា **ពួកឱបបាតិកសត្វមិនមាន** ។ ពាក្យថា **សមណព្រាហ្មណ៍ទាំងឡាយ ។បេ។ ប្រកាសឲ្យដឹងទូទៅមិនមានក្នុងលោក** សេចក្ដីថា លោករមែងសម្ដែងថា សមណព្រាហ្មណ៍ដែលប្រកបដោយធម៌ទាំងឡាយ ដែលមានដំណើរប្រពៃ បដិបត្តិប្រពៃ ព្រោះជាអ្នកបដិបត្តិអនុលោមប្បដិបទាមិនមានក្នុងលោក ។ សមណព្រាហ្មណ៍ពួកណា ដែលអាចដឹងដោយប្រចក្សនូវលោកនេះ និង

លោកដទៃ ដោយញាណដ៏វិសេសក្រៃលែងដោយខ្លួនឯង ហើយប្រកាសឲ្យអ្នកដទៃដឹងផង ឈ្មោះថា **សព្វញ្ញុពុទ្ធទាំងឡាយមិនមាន** ។ ពាក្យដែលគួរពោលក្នុងពាក្យជាដើមថា **រមែងពិចារណាឃើញរូប ថាជាអត្តា** ដូច្នេះ ខ្ញុំបានពោលហើយខាងដើមនោះឯង ។

ការប្រកាន់ មានការប្រកាន់ **បកតិ** និង **អណុ** ជាដើម ថាទៀងជាប្រធាន និងការប្រកាន់ដែលមានការប្រកាន់សរីរៈ ថាដាច់សូន្យជាប្រធាន ការប្រកាន់អត្តាថា **ខ្លះទៀង** ឬថា **អត្តាដែលដាច់សូន្យមាន** ដែលជាធំជាងការប្រកាន់ទាំងនោះ រមែងមានបានដោយគ្រាខ្លះ ព្រោះហេតុនោះ ទើបលោកពោលថា **ដោយច្រើន** ។ ការប្រកាន់អត្តានេះ ដោយអត្ថ គប្បីឃើញថា **មានខន្ធជាអារម្មណ៍តែម្យ៉ាង** ។ ភ្ជាប់សេចក្តីថា **យេភុយ្យេន បឋមំ អត្តវាទុបាទានំ** ដោយច្រើន អត្តវាទុបាទានកើតមុន ។ លោកអាចារ្យសម្គាល់ថា ជវនវិថីនៃភវរាគៈ រមែងប្រព្រឹត្តទៅមុនគេ ព្រោះការជាប់ចិត្តនៅក្នុងភពរបស់សត្វដែលបដិសន្ធិនឹងត្រូវប្រព្រឹត្តទៅក៏ពិត សូម្បីយ៉ាងនោះ ភវរាគៈក៏មិនបានជាការប្រកាន់មាំនៃតណ្ហា ទើបមិនបានពោលការកើតឡើងមុននៃកាមុបាទាន ។

ក្នុងការដែលមិនបានធ្វើការបែកទុកថា តណ្ហាជាកាមុបាទាន តណ្ហាទាំងអស់ទើបចាត់ជា **កាមុបាទាន** ម្យ៉ាងទៀត សូម្បីក្នុងការធ្វើតណ្ហាដទៃអំពីកាមរាគៈដែលដល់នូវការមាំទាំ ចាត់ជាកាមុបាទាន ព្រោះហេតុនោះ ទើបលោកអាចារ្យបានពោលកាមុបាទាននោះ ជាធម្មជាតិដែលអរហត្តមគ្គគប្បីលះ ។

ចិត្តុប្បាទដែលជាឋានៈនៃការកើតឡើង ឈ្មោះថា **វិសយ** ។ ឧបាទានក្ខន្ធ ៥ ឈ្មោះថា **អាលយ** ។ ពពួកសត្វ ឈ្មោះថា **អាលយរាមា** ព្រោះអត្ថថា ត្រេកអរនៅក្នុងអាល័យនោះ ។ ដោយហេតុនោះឯង សេចក្តីត្រេកអរក្នុងអាល័យនោះ រមែងជាការៈប្រាកដក្នុងសន្តានរបស់ខ្លួន និងក្នុងសន្តានរបស់បុគ្គលដទៃ ។ ពាក្យថា **កាម**

**ទាំងឡាយ** បានដល់ វត្ថុកាមទាំងឡាយ ។ បុគ្គលមានកាមុបាទាន ឈ្មោះថា **រមែង** ជាបុគ្គលច្រើនទៅដោយមង្គល មានកោតុហលមង្គលជាដើម ព្រោះមិនបានកាន់ យកថា **សុខទុក្ខ** មានដោយអំណាចកម្ម ។ **សា យោគ** **កោតុហលមង្គលាទិ-ពហុលតា** ប្រែថា ភាពជាបុគ្គលច្រើនទៅដោយមង្គល មានកោតុហលមង្គលជាដើម។ **អស្ស យោគ** **កាមុបាទានវតោ** ប្រែថា នៃបុគ្គលដែលមានកាមុបាទាននោះ ។ **តំ យោគ** **ទិដ្ឋុបាទានំ** ប្រែថា ទិដ្ឋុបាទាននោះ លោកអាចារ្យពោលការប្រកាន់មាំខុសក្នុងរបស់ ដែលមិនមែនជាអត្តា ដែលត្រឹមតែជាធម៌ថា **ជាអត្តា** ជារឿងដែលល្អិតល្អន់ ព្រោះ ជាការប្រកាន់មាំនូវធម៌ដែលល្អិតក្រៃលែង ។ ដោយពាក្យថា **ឧបនិស្សយ** លោក ពោលដល់ **អារម្មណូបនិស្សយ** **អនន្តរូបនិស្សយ** និង **បកតូបនិស្សយ** ព្រោះហេតុ នោះ ទើបធ្វើការសង្គ្រោះយកបច្ច័យ មានអនន្តរបច្ច័យជាដើមផងដែរ ។

# វិសុទ្ធិមគ្គ

## អធិប្បាយ បទថា ឧបាទានប្បច្ចយា ភវោ

ក្នុងបទថា ឧបាទានប្បច្ចយា ភវោ គប្បីជ្រាបវិនិច្ឆ័យដោយអត្ថ ( គឺសេចក្តីនៃពាក្យ ១ ដោយធម៌ គឺអត្ថ របស់មាតិកាធម៌ ) ១ ដោយសាត្ថ ( គឺគោលដែលនៅមានប្រយោជន៍ដែលនឹងពោលដដែល ) ១ ដោយភេទ ( គឺចែកចេញ ) និងដោយសង្គហៈ ( គឺបង្រួបបង្រួម ) ១ ដោយវត្ថុណាជាបច្ច័យរបស់វត្ថុណា ១ ។

## វិនិច្ឆ័យដោយអត្ថ

វិនិច្ឆ័យដោយអត្ថក្នុងបទទាំងនោះ ធម៌ណារមែងកើត ហេតុនេះ ទើបធម៌នោះឈ្មោះថា ភព ( ប្រែថា ធម៌ដែលកើតឡើង ) ភពនោះមាន ២ ប្រភេទ គឺកម្មភព ១ ឧបបត្តិភព ១ ដូចបាលីថា ភពមានដោយចំណែក ២ គឺកម្មភពក៏មាន ឧបបត្តិភពក៏មាន ដូច្នេះ ។

ក្នុងភព ២ នោះ ភព គឺកម្ម ឈ្មោះថា កម្មភព ន័យដូចគ្នានោះដែរ ភព គឺការចូលដល់ ឈ្មោះថា ឧបបត្តិភព ឯក្នុងកម្ម និងឧបបត្តិនេះ ឧបបត្តិចាត់ជាភពព្រោះកើត ( គឺកើត ) ឡើង ចំណែកកម្មគប្បីជ្រាបថា ចាត់ជាភពដោយផល វោហារ ( គឺពោលសំដៅដល់ផល ) ព្រោះកម្មនោះជាហេតុនៃភព ដូចការកើតឡើងនៃព្រះសម្ពុទ្ធទាំងឡាយ ត្រាស់ថា ជាសុខ ព្រោះជាហេតុនៃសេចក្តីសុខ ដូច្នោះ ។

វិនិច្ឆ័យដោយអត្ថក្នុងបទនេះ គប្បីជ្រាបដោយប្រការដែលពោលមកដូច្នេះជាលំដាប់ដំបូង ។

# វិនិច្ឆ័យដោយធម៌

## កម្មភព

ចំណែកវិនិច្ឆ័យដោយធម៌ គប្បីជ្រាបថា លំដាប់ដំបូង កម្មភពដោយសង្ខេប ក៏បានដល់ចេតនា និងធម៌ទាំងឡាយដែលរាប់ជាកម្ម មានអភិជ្ឈាជាដើម ដែលសម្បយុត្ត ជាមួយចេតនានោះឯង ដូចបាលីថា ក្នុងភព ២ នោះ កម្មភពដូចម្តេច បុញ្ញាភិសង្ខារ អបុញ្ញាភិសង្ខារ អនេញ្ជាភិសង្ខារ ជាបរិត្តភូមិ ( គឺភូមិកាម ) ក្តី ជាមហាភូមិ ( គឺភូមិមហគ្គតៈ ) ក្តី នេះហៅថា កម្មភព ម្យ៉ាងទៀត កម្មដែលជាភវគាមី ( ញុំាងសត្វឲ្យទៅកាន់ភព ) ទាំងពួង ក៏ហៅថា កម្មភព ឯក្នុងកម្មភពនេះ ចេតនា ១៣ ដួង ឈ្មោះថា បុញ្ញាភិសង្ខារ ចេតនា ១២ ដួង ឈ្មោះថា អបុញ្ញាភិសង្ខារ ចេតនា ៤ ដួង ឈ្មោះថា អនេញ្ជាភិសង្ខារដោយប្រការដូច្នេះ ការដែលចេតនាទាំងនោះឯងមានវិបាកតិច និងច្រើន ជាការដែលពោលដោយពាក្យថា ជាបរិត្តភូមិក្តី ជាមហាភូមិក្តីនោះ ចំណែកធម៌ទាំងឡាយ មានអភិជ្ឈាជាដើម ដែលសម្បយុត្តជាមួយចេតនា ជាការដែលពោលដោយពាក្យថា ម្យ៉ាងទៀត កម្ម ដែលជាភវគាមីទាំងពួង នេះ ។

## ឧបបត្តិភព

ចំណែកឧបបត្តិភព ដោយសង្ខេប ក៏បានដល់ខន្ធទាំងឡាយដែលកើតព្រោះកម្មដោយចំពោះ ( ពោល ) ដោយប្រភេទមាន ៩ យ៉ាង ដូចបាលីថា ក្នុងភព ២ នោះ ឧបបត្តិភពដូចម្តេច កាមភព រូបភព អរូបភព សញ្ញាភព អសញ្ញាភព នេវសញ្ញានាសញ្ញាភព ឯកវោការភព ចតុវោការភព បញ្ចវោការភព នេះហៅថា ឧបបត្តិភព ។

ក្នុងភពទាំងនោះ ភពដែលរាប់ថាកាម ឈ្មោះកាមភព ក្នុងរូបភព និង

អរូបភពក៏ន័យនេះ ( គឺថា រូបភព ក៏ប្រែថា ភពដែលរាប់ថា រូប អរូបភព ប្រែថា ភពដែលរាប់ថា អរូប ) ។

ភពរបស់សត្វទាំងឡាយដែលមានសញ្ញា ឈ្មោះសញ្ញាភព ន័យម្យ៉ាងទៀត សញ្ញាមាននៅក្នុងភពនោះ ហេតុនោះ ទើបភពនោះ ឈ្មោះថា សញ្ញាភព អសញ្ញាភព គប្បីជ្រាបដោយន័យផ្ទុយគ្នា ( អំពីនេះ ) ។

ធម្មជាតិដែលជានេវសញ្ញានាសញ្ញា ( មានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែន ) ព្រោះមិនមានសញ្ញាគ្រោតគ្រាត និងព្រោះមានតែសញ្ញាល្អិត មាននៅក្នុងភពនេះ ហេតុនេះ ទើបភពនោះ ឈ្មោះថា នេវសញ្ញានាសញ្ញាភព ។

ភពដែលពេញទៅដោយរូបក្ខន្ធតែម្យ៉ាង ឈ្មោះថា ឯកវោការភព ន័យម្យ៉ាងទៀត វោការ ( គឺខន្ធ ) របស់ភពនោះមានតែម្យ៉ាង ហេតុនេះ ទើបភពនោះ ឈ្មោះថា ឯកវោការភព ។ ( អត្ថន័យ ) ក្នុងចតុវោការភព និងបញ្ចវោការភព ក៏ន័យនេះ ( គឺចតុវោការភព ក៏ប្រែថា ភពមានវោការ ៤ បញ្ចវោការភព ប្រែថា ភពមានវោការ ៥ ) ។

ក្នុងភពទាំងនោះ កាមភព បានដល់ ឧបាទិន្នក្ខន្ធ ( ខន្ធមានចិត្តគ្រប់គ្រង ) ៥ រូបភពក៏យ៉ាងនោះ អរូបភព បានដល់ ឧបាទិន្នក្ខន្ធ ៤ សញ្ញាភព បានដល់ ឧបាទិន្នក្ខន្ធ ៥ អសញ្ញាភព បានដល់ ឧបាទិន្នក្ខន្ធ ១ នេវសញ្ញានាសញ្ញាភព បានដល់ ឧបាទិន្នក្ខន្ធ ៤ ភព ៣ មានឯកវោការភពជាដើម ក៏បានដល់ ខន្ធ ១ ខន្ធ ៤ និងខន្ធ ៥ ដោយជាឧបាទិន្នក្ខន្ធ ។

វិនិច្ឆ័យដោយធម៌ក្នុងបទនេះ គប្បីជ្រាបដោយន័យដូចពោលមក ដូច្នេះ

ប្រការ ១ ។

# វិនិច្ឆ័យដោយសាត្ថ

ប្រការថា ដោយសាត្ថ មានវិនិច្ឆ័យថា ឯអភិសង្ខារទាំងឡាយ មានបុញ្ញាភិសង្ខារជាដើមនោះឯង សូម្បីពោលមកហើយក្នុងវគ្គអធិប្បាយអំពីសង្ខារ ដូចដែលពោលក្នុងវគ្គអធិប្បាយអំពីភព ( នេះ ) ដូចគ្នាក៏ពិត សូម្បីកាលបើដូច្នោះ អភិសង្ខារវគ្គមុនលោកពោលដោយជាអតីតកម្ម ព្រោះជាបច្ច័យនៃបដិសន្ធិក្នុងភពនេះ(តែ) អភិសង្ខារវគ្គនេះ ពោលដោយជាបច្ចុប្បន្នកម្ម ព្រោះជាបច្ច័យនៃបដិសន្ធិក្នុងភពតទៅ ព្រោះដូច្នោះ ការពោល ( ដល់អភិសង្ខារ ) ដដែលទៀត ទើបគង់មានប្រយោជន៍ ដោយពិត ឬ ( ឧបមាម្យ៉ាងទៀត ) ក្នុងវគ្គមុន ចេតនាប៉ុណ្ណោះ លោកពោលថា ជាសង្ខារ ដោយន័យថា ក្នុងអភិសង្ខារ ៣ នោះ បុញ្ញាភិសង្ខារដូចម្តេច ? ចេតនា ជាកុសលកាមាវចរ... ( នេះហៅថា បុញ្ញាភិសង្ខារ ) ដូច្នេះជាដើម តែក្នុងវគ្គនេះ សូម្បីធម៌ទាំងឡាយដែលសម្បយុត្តជាមួយចេតនា លោកក៏ពោលដែរ ដោយពាក្យថា សូម្បីកម្មដែលជាភវគាមីទាំងពួង ( ក៏ឈ្មោះថា កម្មភព ) ដូច្នេះ ។ ម្យ៉ាងទៀត ពីកាលមុន កម្មដែលជាបច្ច័យនៃវិញ្ញាណប៉ុណ្ណោះ លោកពោលថាជាសង្ខារ ឯក្នុងទីនេះ សូម្បីកម្មដែលញុំាងសត្វឲ្យកើតក្នុងអសញ្ញាភព លោកក៏ពោលដែរ នឹងពោលច្រើនទៅថ្វីក្នុងបទថា **អវិជ្ជាបច្ចយា សង្ខារា** នោះ បុញ្ញាភិសង្ខារជាដើមនោះឯង លោកពោលតែធម៌ដែលជាកុសល និងអកុសល ចំណែកក្នុងបទថា **ឧបាទានបច្ចយា ភវោ** នេះ លោកពោលធម៌ទាំងដែលជាកុសល ទាំងដែលជាអកុសល ទាំងដែលជាអព្យាកតៈ ក៏ព្រោះ ( ក្នុងវគ្គនេះ ) សង្គ្រោះយកឧបបត្តិភពចូលផង ព្រោះដូច្នោះ ការពោលដដែលនេះទើបគង់មានប្រយោជន៍ពិត ។

វិនិច្ឆ័យដោយសាត្ថក្នុងបទនេះ គប្បីជ្រាបដោយន័យដូចពោលមក ដូច្នេះ ប្រការមួយ ។

## វិនិច្ឆ័យដោយបែងចែក និង រួមចូល

ពាក្យថា ដោយភេទ និងសង្គហៈ គឺដោយបែងចេញ និងដោយរួមចូលនូវភព ដែលមានព្រោះបច្ច័យ គឺឧបាទាន ។

## ដោយពន្រីកចេញ

សេចក្តីថា កម្មដែលញុំាងសត្វឲ្យកើតក្នុងកាមភព ដែលមានព្រោះបច្ច័យ គឺឧបាទានណា ដែលសត្វកំពុងធ្វើ ធម៌ គឺកម្មនោះ ឈ្មោះកម្មភព ខន្ធទាំងឡាយ ដែលកើតឡើងព្រោះកម្មនោះដោយចំពោះ ឈ្មោះឧបបត្តិភព ក្នុងរូបភព និងអរូបភព ក៏ន័យនេះ ។

ដោយន័យដូច្នេះ កាមភព ទាំងសញ្ញាភព និងបញ្ចវោការភពដែលនៅខាងក្នុង ( គឺរួមនៅក្នុងកាមភព ) ជា ២ រូបភពទាំងសញ្ញាភព អសញ្ញាភព ឯកវោការភព និងបញ្ចវោការភពដែលនៅខាងក្នុង ជា ២ អរូបភពទាំងសញ្ញាភព នេវសញ្ញានា-សញ្ញាភព និងចតុវោការភពដែលនៅខាងក្នុង ជា ២ ដូច្នេះ ទើបភពជា ៦ ព្រមទាំងភពដែលនៅខាងក្នុង ដែលមានព្រោះបច្ច័យ គឺកាមុបាទាន ឯភពដែលមានព្រោះបច្ច័យ គឺកាមុបាទាន ជា ៦ ព្រមទាំងភពដែលនៅខាងក្នុង យ៉ាងណា សូម្បីភពដែលមាន ព្រោះបច្ច័យ គឺឧបាទានដ៏សេសក៏ជាប្រាំមួយៗ ដូច្នោះឯង ។

ដោយប្រការដូច្នេះ ដោយពន្រីកចេញ ភពដែលមានព្រោះបច្ច័យ គឺឧបាទាន ទើបជា ២៤ ព្រមទាំងភពដែលមាននៅខាងក្នុង ។

## ដោយបង្រួមចូល

ចំណែកពោលដោយការរួមចូល មានវិនិច្ឆ័យថា រួមកាមភព និងឧបបត្តិភព ចូលជាមួយគ្នា កាមភពក៏ជា ១ ព្រមទាំងភពដែលមាននៅខាងក្នុង រូបភព និងអរូបភព ក៏បង្រួមចូលយ៉ាងនោះ ដូច្នេះ ទើបជាភព ៣ ដែលមានព្រោះបច្ច័យ គឺឧបាទាន សូម្បីភពដែលមានព្រោះបច្ច័យ គឺឧបាទានដ៏សេសក៏យ៉ាងនោះ ( គឺគង់នៅជាបីៗ ) ដោយប្រការដូច្នេះ ដោយរួមចូល ភពដែលមានព្រោះបច្ច័យ គឺឧបាទាន ទើបជា ១២ ព្រមទាំងភពដែលមាននៅខាងក្នុង ។

ន័យម្យ៉ាងទៀត កម្មដែលមានផលជាកាមភព ចាត់ជាកម្មដែលមានព្រោះបច្ច័យ គឺឧបាទាន ដោយមិនប្លែកគ្នា ( គឺមិនចែកប្រភេទឧបាទាន ) ខន្ធទាំងឡាយ ដែលកើតព្រោះកម្មនោះដោយចំពោះ ចាត់ជាឧបបត្តិភព ក្នុងរូបភព និងអរូបភព ក៏ន័យនេះ ដោយប្រការនេះ ដោយរួមចូលបរិយាយដទៃទៀត... ភពដែលមានព្រោះបច្ច័យ គឺឧបាទាន ទើបជា ៦ គឺកាមភព ២ រូបភព ២ អរូបភព ២ ព្រមទាំងភពដែលមាននៅខាងក្នុង ។

ឬថា មិនពោលដល់ការចែកជាកម្មភព និងឧបបត្តិភពឡើយ ភពក៏គង់ជា ៣ ដោយជាកាមភពជាដើម ព្រមទាំងភពដែលមាននៅខាងក្នុង ។

មួយទៀតសោត មិនពោលដល់ការចែកជាភព ៣ មានកាមភពជាដើម ភពក៏ជា ២ ដោយជាកម្មភព និងឧបបត្តិភព ។

មិនពោលដល់ការចែកជាកម្មភព និងឧបបត្តិភពហើយ ភពក៏ជា ១ ប៉ុណ្ណោះ ដោយជាភព ( ឯកវចនៈ ) តាមបទថា **ឧបាទានប្បច្ចយា ភវោ** ដូច្នេះ ។

វិនិច្ឆ័យដោយពង្រីកចេញ និងរួមចូលនូវភពដែលមានឧបាទានជាបច្ច័យ ក្នុងបទនេះ គប្បីជ្រាបដូចពោលមកដូច្នេះ ប្រការមួយ ។

## វិនិច្ឆ័យដោយវត្ថុណាជាបច្ច័យនៃវត្ថុណា

ពាក្យថា យំ យស្ស បច្ចយោ ច សេចក្ដីថា ម្យ៉ាងទៀត ក្នុងបទ ឧបាទានប្បច្ចយា ភវោ នេះ ឧបាទានណា ជាបច្ច័យរបស់ភពណា ? បណ្ឌិតគប្បីជ្រាបវិនិច្ឆ័យដោយប្រការដែលវត្ថុណាជាបច្ច័យរបស់វត្ថុណានោះផង ។

សួរថា ក្នុងបទនេះ វត្ថុណាជាបច្ច័យរបស់វត្ថុណា ?

ឆ្លើយថា គ្រប់វត្ថុជាបច្ច័យរបស់គ្រប់វត្ថុនោះឯង ។

ពិតណាស់ បុថុជ្ជនប្រៀបដូចមនុស្សឆ្កួត គេមិនអាចពិចារណាថា វត្ថុនេះគួរ វត្ថុនេះមិនគួរបានទេ ប្រាថ្នាភពគ្រប់ភពដោយអំណាចឧបាទានគ្រប់ប្រការ ហើយក៏ធ្វើកម្មគ្រប់យ៉ាងនោះឯង ព្រោះដូច្នោះ អាចារ្យពួកខ្លះពោលពាក្យណាថា រូបភព អរូបភពរមែងមិនមានព្រោះសីលព្វតុបាទាន ដូច្នេះ ទើបពាក្យនោះមិនគួរកាន់យក តែគួរកាន់យកថា ភពទាំងពួងរមែងមានបានព្រោះឧបាទានទាំងពួង ។

## កាមុបាទានជាបច្ច័យនៃកាមភព

សេចក្ដីនេះ មានដូចម្ដេច ?

បុគ្គលពួកខ្លះក្នុងលោកនេះ គិតដោយអំណាចការបានឮតគ្នាមកខ្លះ តាមបែបផែនដែលបានឃើញខ្លះថា កាមទាំងឡាយនោះ សម្បូរតែក្នុងត្រកូលមហាសាល មានត្រកូលខត្តិយមហាសាលជាដើម ក្នុងមនុស្សលោក និងក្នុងកាមាវចរ ទេវលោក ៦ ជាន់ប៉ុណ្ណោះ ដូច្នេះហើយ ត្រូវអសប្បុរិសធម៌ មានការស្ដាប់រឿងអសទ្ធម្មជាដើម បិទបាំងចិត្តបុគ្គលនោះៗ សម្គាល់ថា កាមទាំងឡាយ នឹងសម្រេចបានដោយការធ្វើ ( យ៉ាង ) នេះ ( គឺដូចដែលបានឮ ) ហើយជ្រុលធ្វើទុច្ចរិត មានកាយទុច្ចរិតជាដើមទៅតាមអំណាចនៃកាមុបាទាន បុគ្គលនោះក៏បានធ្វើដើម្បី ( ឲ្យ ) បានកាមទាំងឡាយនោះ

ព្រោះទុច្ចរិតពេញទី បុគ្គលនោះក៏ទៅកើតក្នុងអបាយ ឬបើមិនដូច្នោះ កាលប្រាថ្នាកាមទាំងឡាយដែលជួបចំពោះមុខ ឬនឹងឃុំគ្រងកាមទាំងឡាយដែលបានមក ហើយក៏ដោយ ធ្វើទុច្ចរិត មានកាយទុច្ចរិតជាដើម ដោយអំណាចនៃកាមុបាទាន ( ក៏បាន ) ព្រោះទុច្ចរិតពេញទី បុគ្គលនោះក៏ទៅកើតក្នុងអបាយ ។

កម្មដែលជាហេតុនៃការឧប្បត្តិក្នុងអបាយនោះ ជាកម្មភព ខន្ធទាំងឡាយដែលកើតព្រោះកម្មនោះ ក៏ជាឧបបត្តិភពរបស់បុគ្គលនោះ ចំណែកសញ្ញាភព និងបញ្ចវោការភពក៏រួមនៅក្នុងនោះឯង ។

ចំណែកបុគ្គលមួយពួកទៀត ជាអ្នកមានការដឹងសម្បូរឡើងដោយសប្បុរិសធម៌ទាំងឡាយ មានការបានស្តាប់ព្រះសទ្ធម្មជាដើមហើយ សម្គាល់ថា កាមទាំងឡាយនឹងសម្រេចបានដោយការធ្វើយ៉ាងនេះ ការធ្វើសុចរិត មានកាយសុចរិតជាដើម ដោយអំណាចកាមុបាទាន ព្រោះសុចរិតបរិបូណ៌ បុគ្គលនោះក៏ទៅកើតក្នុងពពួកទេវតាខ្លះ ក្នុងពពួកមនុស្សខ្លះ ។

កម្មដែលជាហេតុនៃការឧប្បត្តិក្នុងពពួកទេវតា និងមនុស្សនោះ ជាកម្មភព ខន្ធទាំងឡាយដែលកើតព្រោះកម្មនោះ ជាឧបបត្តិភពរបស់បុគ្គលនោះ ចំណែកសញ្ញាភព និងបញ្ចវោការភពក៏រួមនៅក្នុងនោះដូចគ្នា ។

កាមុបាទានជាបច្ច័យនៃកាមភព ដែលមានការបែកគ្នា ( ច្រើនប្រភេទ ដូចជា សុគតិ ទុគ្គតិ ) ព្រមទាំងភពដែលនៅខាងក្នុង ដូច្នេះ ។

## កាមុបាទានជាបច្ច័យនៃរូបភព-អរូបភព

បុគ្គលមួយពួកទៀត បានស្តាប់ ឬគិតគ្មាន់គ្នេរក៏ដោយ ថាកាមទាំងឡាយ ក្នុងរូបភព និងអរូបភពសម្បូរជាងកាមក្នុងកាមភពនោះ ក៏ធ្វើរូបសមាបត្តិ និងអរូបសមាបត្តិ

ឲ្យកើតឡើងដោយអំណាចកាមុបាទាននោះឯង ហើយក៏ទៅកើតក្នុងព្រហ្មលោក និង អរូបព្រហ្ម ដោយកម្លាំងនៃសមាបត្តិ ។

កម្មដែលជាហេតុនៃការឧប្បត្តិក្នុងព្រហ្មលោកនោះ ជាកម្មភព ខន្ធទាំងឡាយ ដែលកើតព្រោះកម្មនោះជាឧបបត្តិភពរបស់បុគ្គលនោះចំណែកសញ្ញាភព អសញ្ញាភព នេវសញ្ញានាសញ្ញាភព និងឯកវោការភព ចតុវោការភព បញ្ចវោការភពក៏រួមនៅក្នុង នោះឯង ។

កាមុបាទានជាបច្ច័យនៃរូបភព អរូបភព ដែលមានការបែកគ្នា ( ច្រើនប្រភេទ ) ព្រមទាំងភពដែលនៅខាងក្នុងក៏បាន ដូច្នេះ ។

## ទិដ្ឋុបាទានជាបច្ច័យនៃភពទាំង ៣

បុគ្គលពួកមួយទៀត យល់ឃើញថា អត្តានេះ កាលភពនៃកាមាវចរសម្បត្តិ ឬរូបភព អរូបភពឯណានីមួយក៏ដោយ ដាច់ហើយ ក៏ឈ្មោះថា ដាច់សូន្យ ដូច្នេះ ហើយ ប្រកាន់ឧច្ឆេទទិដ្ឋិ ហើយក៏ធ្វើកម្មដែលទៅជាមួយគ្នាបាន ជាមួយទិដ្ឋិនោះ ។

កម្មនោះជាកម្មភព ខន្ធទាំងឡាយដែលកើតព្រោះកម្មនោះ ក៏ជាឧបបត្តិភពរបស់ បុគ្គលនោះ ចំណែកភពទាំងឡាយ មានសញ្ញាភពជាដើម ក៏រួមនៅក្នុងនោះឯង ។

ទិដ្ឋុបាទានជាបច្ច័យនៃភពទាំង ៣ គឺទាំងកាមភព និងរូបភព អរូបភពដែល មានការបែកផ្សេងគ្នា ( ច្រើនប្រភេទ ) ព្រមទាំងភពដែលនៅខាងក្នុងក៏បានដូច្នេះ។

## អត្តវាទុបាទានជាបច្ច័យនៃភពទាំង ៣

បុគ្គលមួយពួកទៀត យល់ឃើញថា អត្តានេះ រមែងនឹងមានសេចក្តីសុខ ប្រាសចាកភាពក្តៅក្រហាយនៅក្នុងភពនៃកាមាវចរសម្បត្តិ ឬក្នុងរូបភព និងអរូបភព កន្លែងណានីមួយក៏បាន ដូច្នេះហើយ ក៏ធ្វើកម្មដែលទៅជាមួយការយល់ឃើញនោះ

ដោយ ( អំណាច ) អត្តវាទុបាទាន ។

កម្មនោះជាកម្មភព ខន្ធទាំងឡាយដែលកើតព្រោះកម្មនោះ ក៏ជាឧបបត្តិភពរបស់បុគ្គលនោះ ចំណែកសញ្ញាភពជាដើម ក៏រួមនៅក្នុងនោះឯង ។

អត្តវាទុបាទានជាបច្ច័យនៃភពទាំង ៣ដែលមានការបែកផ្សេងគ្នា ( ច្រើនប្រភេទ ) ព្រមទាំងភពដែលនៅខាងក្នុង ដូច្នេះ ។

## សីលព្វតុបាទានជាបច្ច័យនៃភពទាំង ៣

បុគ្គលមួយពួកទៀតយល់ឃើញថា សេចក្ដីសុខរមែងដល់នូវភាពពេញបរិបូណ៌ ដល់បុគ្គលដែលធ្វើសីលវត្តនេះឲ្យបរិបូណ៌ ក្នុងភពនៃកាមាវចរសម្បត្តិក៏ដោយ ក្នុងរូបភព និងអរូបភពកន្លែងណាមួយក៏ដោយ ដូច្នេះហើយ ក៏ធ្វើកម្មដែលទៅបានជាមួយការយល់ឃើញនោះ ដោយអំណាចសីលព្វតុបាទាន ។

កម្មនោះជាកម្មភព ខន្ធទាំងឡាយដែលកើតព្រោះកម្មនោះ ក៏ជាឧបបត្តិភពរបស់បុគ្គលនោះ ចំណែកសញ្ញាភពជាដើមក៏រួមនៅក្នុងនោះដូចគ្នា ។

សូម្បីសីលព្វតុបាទាន ក៏ជាបច្ច័យនៃភពទាំង ៣ ដែលបែកផ្សេងគ្នា ព្រមទាំងភពដែលនៅខាងក្នុងបានដូច្នេះឯង ។

វិនិច្ឆ័យដោយប្រការដែលវត្ថុណាជាបច្ច័យរបស់វត្ថុណា ក្នុងបទនេះ គប្បីជ្រាបដូចពោលមក ដូច្នេះ ។

## អ្វីជាបច្ច័យរបស់អ្វី ដូចម្ដេច

ប្រសិនបើសួរថា ក្នុងបទនេះ ឧបាទានណាជាបច្ច័យរបស់ភពណា ដូចម្ដេច ? ដូច្នេះសោត ពាក្យដោះស្រាយគប្បីមានដូចគាថាសង្ខេបនេះថា

បណ្ឌិតគប្បីជ្រាបចុះថា ឧបាទានជាឧបនិស្សយប្បច្ច័យនៃរូបភព និងអរូបភព

ម្យ៉ាង វាជាបច្ច័យនៃកាមភព ដោយបច្ច័យទាំងឡាយ មានសហជាតប្បច្ច័យជាដើម

## ពន្លឹកសេចក្តីបច្ច័យន័យ

ពន្លឺកសេចក្តីថា ឧបាទានទាំង ៤ យ៉ាងនោះ ជាបច្ច័យប្រភេទ ១ ដោយជាឧបនិស្សយប្បច្ច័យប៉ុណ្ណោះ របស់រូបភព អរូបភព គឺរបស់កម្ម ចំពោះដែលជាកុសលក្នុងកម្មភព ដែលទាក់ទងក្នុងកាមភព និងរបស់ឧបបត្តិភពដោយ (ចំណែក) ក្នុងកាមភព វាជាបច្ច័យដោយសហជាតប្បច្ច័យជាដើម ដែលចែកចេញជាសហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ សម្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ និងហេតុប្បច្ច័យរបស់អកុសលកម្មភព ដែលសម្បយុត្តជាមួយខ្លួន តែជាបច្ច័យដោយឧបនិស្សយប្បច្ច័យតែម្យ៉ាង របស់កម្មភពដែលជាវិប្បយុត្ត ។

នេះជាកថាយ៉ាងពិស្តារ ក្នុងបទថា ឧបាទានប្បច្ចយា ភវោ ។

# មហាដីកា

## កថាពណ៌នាដោយពិស្តារនៃបទថា ព្រោះឧបាទានជាបច្ច័យ ទើបមានភព

*បទថា **អត្ថតោ** ប្រែថា ដោយអត្ថនៃពាក្យ ។ បទថា **ធម្មតោ** ប្រែថា ដោយសភាវធម៌ ។ បទថា **សាត្ថតោ** សេចក្ដីប៉ុនគ្នានឹង **សាត្ថកតោ** ប្រែថា ដោយមាតិកាដែលនៅមានប្រយោជន៍ គឺដោយពាក្យដែលនៅមានប្រយោជន៍ នៃពាក្យដដែលៗដែលបានពោលមកហើយអំពីមុន ។ បទថា **ភេទសង្គហា** ប្រែថា ដោយការបែងចេញដោយការសង្គ្រោះចូល អធិប្បាយថា ដោយការចែកចេញ និងដោយការបង្រួញមាតិកាដែលចែកចេញហើយ ។ ពាក្យថា **យំ យស្ស បច្ចយោ** សេចក្ដីថា ឧបាទានណាមួយ ជាបច្ច័យដល់ភពណាមួយ ដោយឧបាទាន និងភពនោះៗ ។*

***ភវតីតិ ភវោ*** *លោកអាចារ្យពោលកម្មភព ដោយការបញ្ញត្តផលថា ធម៌ណារមែងកើត ហេតុនោះ ធម៌នោះ ឈ្មោះថា **ភព** ប្រែថា ធម៌ដែលកើតឡើង ។ សេចក្ដីពិត ពាក្យលម្អិតនៃឧបបត្តិភពនោះឯង លោកពោលទុកធ្វើឲ្យទូទៅដល់ភពទាំង ២ ដោយវិគ្គហៈថា ឈ្មោះថា **ភព** ព្រោះអត្ថថា ជាដែនមានឡើងនៃឧបបត្តិភពដូច្នេះក៏មាន ។ ម្យ៉ាងទៀត កម្មភពទី ២ ឈ្មោះថា **ភព** ព្រោះអត្ថថា មានឡើងដោយពិសេស ដោយភាពជាភពថ្មីរបស់សត្វ ។ ព្រោះហេតុនោះឯង ទើបមិនមានការទាក់ទងជាមួយភពរបស់ភវន្តរៈ គឺចន្លោះភពទាំងអស់ ឬរបស់ភវន្តរៈ ដែលមានភពនោះជាហេតុ ។ បទថា **ទុវិធេន** សេចក្ដីថា ព្រោះប្រព្រឹត្តទៅដោយអាការ ២ យ៉ាង ។ ម្យ៉ាងទៀត បទថា **ទុវិធេន** ជាតតិយាវិភត្តិ ចុះក្នុងអត្ថនៃបឋមាវិភត្តិ មាន*

អធិប្បាយថា សេចក្ដីប៉ុនគ្នានឹង **ទុវិធោ** ប្រែថា មាន ២ យ៉ាង ។ បទថា **អត្ថិ** ប្រែថា មាន ។

វត្ថុដែលឈ្មោះថា **កម្ម** ព្រោះមានអត្ថថា ត្រូវបច្ច័យរបស់ខ្លួនធ្វើ អាចារ្យពួកខ្លះពោលថា វត្ថុដែលឈ្មោះថា កម្ម ព្រោះមានអត្ថថា ធ្វើផលរបស់ខ្លួន ធម៌ទាំងឡាយដែលគប្បីពោលយ៉ាងនេះថា **កម្ម** ឈ្មោះថា **ដែលរាប់ជាកម្ម** ។ ពាក្យថា **បរិត្តភូមិ** បានដល់ កាមភូមិ ។ ពាក្យថា **មហាភូមិ** បានដល់ មហគ្គតភូមិ ។ ពាក្យថា **ទាំងពួង** គឺមិនមានចំណែកសេសសល់ ។ កម្ម ឈ្មោះថា **ភវគាមី** ព្រោះមានអត្ថថា ទៅកាន់ភព និងញ៉ាំងសត្វឲ្យទៅកាន់ភព ។ ពាក្យថា **ទៅ** ទាក់ទងនឹងវត្ថុដែលអាចធ្វើឲ្យសម្រេច អធិប្បាយថា ជាវត្ថុដែលបែរមុខទៅកាន់ភព ប្រព្រឹត្តទៅក្នុងបវត្តិកាលរបស់ខ្លួន ម្យ៉ាងទៀត ការកើតឡើងនោះឯង លោកមានបំណងថា **ទៅ** ។ ដោយពាក្យថា **ភវគាមី** នេះ លោកបដិសេធកម្មដែលធ្វើការអស់ទៅនៃកម្ម ។ រឿងនេះជារឿងវដ្ដៈ ចំណែកកម្មដែលធ្វើការអស់ទៅនៃកម្មនោះ ទាក់ទងនឹងវិវដ្ដៈ ។ ពាក្យថា **ចេតនា ១២ ដួង** ឈ្មោះថា **អបុញ្ញាភិសង្ខារ** លោកកាន់យកចេតនាដែលសហគតៈដោយឧទ្ធច្ចៈ បណ្ឌិតគប្បីជ្រាប ដូចជាក្នុងពាក្យថា **អវិជ្ជាបច្ចយា សង្ខារា** ព្រោះអវិជ្ជាជាបច្ច័យ ទើបមានសង្ខារ ។ ចំណែកក្នុងពាក្យថា **ភវប្បច្ចយា ជាតិ** ព្រោះភពជាបច្ច័យ ទើបមានជាតិ ដូច្នេះ ។ សូម្បីចេតនា ដែលសហគតៈដោយឧទ្ធច្ចៈនោះ ក៏គួរនាំចេញទៅ ដូចក្នុងពាក្យថា **សង្ខារប្បច្ចយា វិញ្ញាណំ** ព្រោះសង្ខារជាបច្ច័យ ទើបមានវិញ្ញាណ ដូច្នេះ ។ បទថា **មន្ទពហុវិបាកតា** ប្រែថា ចេតនាទាំងនោះ មានវិបាកតិច និងច្រើន ។

ដោយពាក្យថា ចំណែកធម៌ទាំងឡាយ មានអភិជ្ឈាជាដើម ដែលសម្បយុត្តជាមួយចេតនា ជាការពោលហើយដោយពាក្យនេះថា ម្យ៉ាងទៀត កម្មដែលជាភវគាមីទាំងពួង ដូច្នេះ លោកពោលដល់ធម៌ មានអភិជ្ឈាជាដើមនោះ រាប់ជាកម្ម ព្រោះជា

អាចយកគាមី ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **ជាធម៌ដែលទាក់ទងដោយកម្មភព** ទុកដោយបរិយាយ តែដោយនិប្បរិយាយចេតនានោះឯង ជាកម្មភព ។ សមដូចព្រះបាលីដែលទ្រង់ត្រាស់ទុកថា **កម្មភពដែលសម្បយុត្តដោយខន្ធ ៣ ដោយអាយតនៈ ១ ដោយធាតុ ១ សម្បយុត្តដោយធម៌ខ្លះទៀត គឺដោយខន្ធ ១ ដោយអាយតនៈ ១ ដោយធាតុ ១** ដូច្នេះ ។ **ឧបបត្តិភព** បានដល់ ឧបាទិន្នក្ខន្ធ ដែលលោកពោលទុកដោយតិកៈទាំង ៣ ។ ដូចដែលត្រាស់ទុកថា **ឧបបត្តិភព កាមភព សញ្ញាភព ។ បញ្ចវោការភព លោកសង្គ្រោះដោយខន្ធ ៥ ដោយអាយតនៈ ១១ ដោយធាតុ ១៧** ដូច្នេះជាដើម ។ សួរថា ឧបមាថា ទីឯគប្បីមានការកាន់យកធម៌ដែលជាអនុបាទិន្នកសោតក៏ប្រពៃ ដែលគប្បីពោលថា **ដោយអាយតនៈ ១២ ដោយធាតុ ១៨** ដូច្នេះ ។ ឆ្លើយថា ឧបាទិន្នក្ខន្ធទាំងឡាយ ដែលកំណត់ដោយអវិចី និងបរនិម្មិតវសវត្តី លោកហៅថា **កាម** ព្រោះជាខន្ធដែលកាមតណ្ហាគប្បីឲ្យសត្វប្រាថ្នា គឺព្រោះមានកាមជាទីអាស្រ័យ ដូចជាភោគៈទាំងឡាយ ព្រោះជាខន្ធដែលមានការប្រព្រឹត្តទៅរួមជាមួយកាម ដូចពាក្យថា **កុន្តា បចរន្តិ** ប្រែថា លំពែងទាំងឡាយរមែងត្រាច់ទៅ ( សេចក្តីថា មនុស្សកាន់លំពែងត្រាច់ទៅ ) ព្រោះមានកាមជាអារម្មណ៍ ដូចពាក្យថា **សុខំ រូបំ** រូបជាសុខ ព្រោះមានកាមជាបច្ច័យ និងជាទីតាំង ដូចពាក្យថា **សុខោ សគ្គោ** ស្ថានសួគ៌ជាសុខ ដូច្នេះ ។ ឧបាទិន្នក្ខន្ធទាំងឡាយ ដែលកំណត់ដោយព្រហ្មជាន់ព្រហ្មកាយិក និងជាន់អកនិដ្ឋក លោកហៅថា **រូប** ព្រោះដែលមិនប្រាសទៅអំពីរូប គឺពឹងអាស្រ័យដល់រូបដែលបានអាស្រ័យនៅ ដូចពាក្យថា **មញ្ចា ឃោសន្តិ** គ្រែប្រកាស ( សំដៅដល់បុគ្គលនៅលើគ្រែស្រែកប្រកាស ) និងដូចពាក្យថា **ផន្ទន ទេវតា** ប្រែថា ទេវតាដែលបម្រះនទៀល ។

ភព គឺរូប ឈ្មោះថា **រូបភព** ឧបាទិន្នក្ខន្ធ ៤ ដែលកំណត់ដោយភពដ៏លើស

គឺអាកាសានញ្ចាយតនៈ លោកហៅថា **អរូប** ដូចគ្នា ។ ភព គឺអរូប ឈ្មោះថា **អរូបភព** ។ ភព គឺកាម ព្រោះហេតុនោះ ទើបឈ្មោះថា **កាមភព** ។ កាមភពនោះ ព្រោះហេតុដែលប្រពៃ ដែលគប្បីពោលថា **កាម** ដោយអត្ថតាមដែលពោលហើយ ដូច្នោះ ទើបលោកអាចារ្យពោលថា **ភពដែលរាប់ថា ជាកាម** ។ ម្យ៉ាងទៀត ភព ដែលតែងសម្គាល់ថា ជាកាមាវចរលោកហៅថា **ភពដែលរាប់ថា កាម** ។ រូបភព និងអរូបភពក៏ដូចគ្នា ហេតុនោះ ទើបលោកអាចារ្យពោលថា **ក្នុងរូបភព និងអរូបភព ក៏ន័យនេះ** ។ ក្នុងពាក្យថា **សញ្ញាវ តំ ភវោ សញ្ញាភវោ** នេះ គប្បីឃើញការលុប **វន្តុ-ស័ព្ទ** ។ ម្យ៉ាងទៀត បាឋៈ **សញ្ញាភវោ** ដូច្នេះក៏មាន ព្រោះលុប **អ** អក្ខរៈ ក្នុងអត្ថរបស់ **វន្តុ-ស័ព្ទ**នោះ ។ ដោយហេតុនោះ ទើបលោកអាចារ្យពោលថា **សញ្ញា វា** ដូច្នេះជាដើម ។ លោកអាចារ្យពោល **វោការ-ស័ព្ទ** ជាកម្មសាធនៈ ដោយបទថា **វោកិន្នោ** ។ **វោកិរិយតិ បសារិយតិ វិត្ថារិយតីតិ វោការោ** សភាវៈណាដែលធម៌រមែងលាយឡំ គឺផ្សាយទៅ ពង្រីកទៅ ហេតុនោះ សភាវៈនោះ ឈ្មោះថា **វោការោ** ត្រូវលាយឡំ ម្យ៉ាងទៀត វិគ្គហៈថា **វោកិរណំ វោការោ** ការលាយឡំ ឈ្មោះថា **វោការោ** ភពនោះ លោកពោលថា **ឯកវោការោ** ព្រោះប្រព្រឹត្តទៅដោយអំណាចខន្ធ ១ ប៉ុណ្ណោះ អធិប្បាយថា មានការកើតឡើងផ្សាយទៅហើយ ។

លោកពោលធម៌ដែលសម្បយុត្តជាមួយចេតនាទុកដោយពាក្យថា **កម្មដែលជាភវគាមីទាំងពួង ឈ្មោះថា កម្មភព** ដូច្នេះ ក្នុងភវនិទ្ទេសក៏ពិត ។ សូម្បីយ៉ាងនោះ អវធារណៈថា **បុញ្ញាភិសង្ខារាទយោវ** អភិសង្ខារទាំងឡាយ មានបុញ្ញាភិសង្ខារនោះឯង ដូច្នេះ លោកអាចារ្យបានធ្វើទុកដើម្បីសម្តែងក្នុងស័ព្ទថា **សង្ខារ** និង **ភព** មានភាពផ្សេងគ្នានោះឯង ព្រោះផ្សេងគ្នាដោយអត្ថ ព្រោះផ្សេងគ្នា នៃធម៌ដែលជាបច្ច័យ ។ ដោយហេតុនោះ ទើបលោកអាចារ្យពោលថា **សូម្បីកាលបើយ៉ាងនោះ**

ដូច្នេះជាដើម ។ បើមានអ្នកចោទសួរថា ព្រោះសង្ខារ និងភពផ្សេងគ្នាដោយធម៌ ទើបលោកមិនបានពោលដដែលទៀតនូវសង្ខារនោះឯង ហេតុនោះ ពាក្យថា **ការពោលអភិសង្ខារដដែលនេះ ទើបមានប្រយោជន៍ពិត** នេះ ទើបមិនសមគួរ មិនមែនឬ ? សេចក្ដីនេះឆ្លើយថា មិនមែនដូច្នោះទេ ព្រោះសង្ខារទាំងឡាយ លោកពោលដដែលថាភព ដោយភាពជាចំណែកមួយរបស់ភព ។ ប្រការ ១ ទៀត បុគ្គលដទៃចោទសួរការពោលដដែល ក៏ព្រោះមិនបានកាន់យកភាពផ្សេងនៃធម៌ ហេតុនោះ ពាក្យថា **ការពោលអភិសង្ខារដដែលនេះ ទើបមានប្រយោជន៍ពិត** លោកអាចារ្យពោលទុកដោយការពេញចិត្តរបស់អ្នកសួរ ។

ការៈដែលកម្មញ៉ាំងសត្វឲ្យកើតឡើងក្នុងភព មានកាមភពជាដើម ចាត់ជាកាមភពជាដើម លោកពោលទុកក្នុងអដ្ឋកថា ដោយវោហារពោលដល់ផល ។ កម្មឯណានីមួយដែលពោលទុកក្នុងខាងដើម ដោយស័ព្ទថា **សង្ខារ** មានអវិជ្ជាជាហេតុ ដែលជាបច្ច័យដល់វិញ្ញាណដែលកើតរួមគ្នា តែក្នុងទីនេះលោកមានបំណងយកកម្មដែលធ្វើឱកាសដើម្បីឲ្យផល ដែលមានឧបាទានជាហេតុ ញ៉ាំងភពថ្មីឲ្យកើតឡើងនោះឯង ឈ្មោះថា **ភព** ដោយព្រះបាលីថា **កម្មដែលជាភវគាមីទាំងពួង** ដូច្នេះ សេចក្ដីនេះ កម្មណាដែលញ៉ាំងរូបភពឲ្យកើតឡើង និងញ៉ាំងអរូបភពឲ្យកើត មានព្រោះកាមុបាទានជាបច្ច័យដែលសត្វធ្វើទុក សេចក្ដីនោះ ឈ្មោះថា **កម្មភព** ខន្ធទាំងឡាយដែលកើតឡើងអំពីកម្មនោះ ឈ្មោះថា **ឧបបត្តិភព** ដូច្នេះ លោកអាចារ្យសម្ដែងទុកជាមុនថា **ក្នុងរូបភព និងអរូបភពក៏មានន័យនេះ** ។ ពាក្យថា **កាមភព ២** បានដល់ កាមភព ២ គឺកាមភព ១ កាមុបបត្តិភព ១ សូម្បីក្នុងពាក្យថា **រូបភព ២ អរូបភព ២** នេះក៏យ៉ាងនេះ ។ លោកអាចារ្យពោលថា **ភពមាន ៦** ដូច្នេះ មិនបានកាន់យកភពដែលនៅខាងក្នុងជាមួយផ្នែក ចាត់ឲ្យជាភព នៅក្នុងតែម្យ៉ាង ហើយបន្ថែមភព មាន

កាមភពជាដើមជា ២ ជាន់ គឺកម្មភព និងឧបបត្តិភព ។

ពាក្យថា **ដោយមិនប្លែកគ្នា** គឺមិនធ្វើការញែកគ្នាជាមួយឧបាទាន ។ម្យ៉ាងទៀត លោកពោលថា **ភពមាន ៦ ព្រោះរួមយកដោយអំណាចការសង្គ្រោះភព ទាំង ១២ ប្រភេទ ដោយមិនធ្វើការញែកឧបាទាន** ។ ពាក្យថា **មិនប៉ះពាល់** គឺមិនអាស្រ័យ អធិប្បាយថា មិនពឹងផ្អែក ។

លោកពោលថា ពួកគោ និងពួកសុនខ ជាអ្នកកើតរួមគ្នាដោយគោសីល គឺ ទំនៀមគោ និងកុក្កុរសីល ទំនៀមឆ្កែ ដែលបុគ្គលនោះប្រកាន់ហើយ ប្រកាន់មាំហើយ ព្រោះហេតុនោះ អាចារ្យពួកខ្លះសម្គាល់ថា **ការចម្រើនឈានរមែងមិនសម្រេចដល់ បុគ្គលដែលមានសីលព្វតុបាទាន** ទើបពោលថា រូបភព និងអរូបភព រមែងមិនមាន ដោយសីលព្វតុបាទាននោះ ។ លោកអាចារ្យពោលថា **ពាក្យនោះមិនគួរកាន់យក ព្រោះបច្ច័យដោយប្រការដែលនឹងពោលដល់តទៅ** ។ ឯការប្រកាន់ខុសក្នុងវត្ថុដែល មិនមែនផ្លូវនៃសេចក្ដីបរិសុទ្ធថា ជាផ្លូវនៃសេចក្ដីបរិសុទ្ធ ចាត់ជាសីលព្វតុបាទាន ព្រោះ ហេតុនោះ ការញុំាងរូបាវចរជ្ឈាន និងអរូបាវចរជ្ឈានឲ្យកើតឡើង ដោយការប្រកាន់ ខុសថា ជាផ្លូវនៃសេចក្ដីបរិសុទ្ធ និងមិនគួរក៏មិនមែនដូច្នេះ។

ពាក្យថា **ដោយអំណាចការបានឮតគ្នាមក** បានដល់ ដោយអំណាចការបាន ឮតគ្នាមក ដែលប្រកាន់ថា **បុគ្គលស្រឡាញ់សេចក្ដីចម្រើន រមែងប្រកាន់យកការ សម្លាប់សត្វ និងការបួងសួង** ឬតាមបែបផែនដែលបានឃើញថា កាមទាំងឡាយ ក្នុងមនុស្សលោកនេះសម្បូរ យ៉ាងណា កាមទាំងឡាយ ក្នុងទេវលោកសម្បូរជាង មនុស្សលោកនេះ ដូច្នោះដែរ ។ ការស្ដាប់រឿងបុរាណ រឿងការតៈ រឿងនាងសិតា

និងរឿងវិធីចងបសុសត្វជាដើម ឈ្មោះថា **ការស្តាប់រឿងអសទ្ធម្ម** ។ ដោយ **អាទិស័ព្ទ** លោកអាចារ្យរមែងសង្គ្រោះរឿងដែលពឹងអាស្រ័យអសប្បុរស បុគ្គលដែលមិនកតញ្ញូក្នុងកាលមុន និងការតាំងខ្លួនទុកខុសក្នុងកាលមុន ។ ពាក្យថា **សូម្បីទុច្ចរិតមានកាយទុច្ចរិតជាដើម** សេចក្តីថា **រមែងធ្វើ** ទុច្ចរិត មានកាយទុច្ចរិតជាដើម មិនមែនជាឧបាយនៃកាមដែលជាបំណងរបស់ខ្លួន អធិប្បាយថា ដោយអំណាចការច្បាំងជាដើម ដើម្បីសេចក្តីសុខ មានស្ថានសួគ៌ជាដើមអស់កាលយូរ ។ ឬ ( ប្រាថ្នា ) **កាមទាំងឡាយ ដែលជាបច្ចុប្បន្ន** គឺរួមទាំងរាជសម្បត្តិ និងតំណែងសេនាបតីជាដើម ។ បទថា **តទន្តោគធា ឯវ** សេចក្តីថា ដែលរួមនៅខាងក្នុង ក្នុងកាមភពនោះ គឺដែលកើតឡើងដល់ទុច្ចរិត និងកើតអំពីសុចរិតនោះឯង ។ ម្យ៉ាងទៀត បទថា **អន្តោគធា** លោកពោលទុកដោយរួមនៅខាងក្នុងដោយចំណែកមួយនៃសញ្ញាភព និងបញ្ចវោការភព ។ ព្រោះថា សញ្ញាភព និងបញ្ចវោការភពនោះ មិនរួមនៅខាងក្នុង ក្នុងកាមភពដោយមិនមានសេសសល់ឡើយ ។

ពាក្យថា **ព្រមទាំងប្រភេទ** គឺដែលមានប្រភេទមានសុគតិ ទុគ្គតិ និងមនុស្សជាដើម ។

អត្ថានេះ រមែងដាច់សូន្យ ទាក់ទងដោយឧច្ឆេទវាទទី ១ ទី ២ ក្នុងភពនៃកាមាវចរសម្បត្តិ ទាក់ទងនឹងឧច្ឆេទវាទទី ៣ ក្នុងរូបភព ទាក់ទងនឹងឧច្ឆេទវាទដ៏សេសក្នុងអរូបភព ព្រោះហេតុនោះ ទើបធ្វើកម្មដែលចូលគ្នាបានជាមួយឧច្ឆេទទិដ្ឋិនោះ ព្រោះហេតុនោះ ទើបលោកពោលពាក្យថា **ឈ្មោះថា អត្តានេះ** ដូច្នេះជាដើម ។ ក្នុងពាក្យនោះ ពាក្យថា **ដាច់សូន្យ** សេចក្តីថា ដាច់សូន្យដោយការកាត់វដ្តទុក្ខទាំងអស់ជា

សមុច្ឆេទ អធិប្បាយថា រមែងមានការមិនកើតឡើងក្នុងភពថ្មី ។

ពាក្យថា **ក្នុងភពនៃកាមាវចរសម្បត្តិ** នេះ លោកពោលទាក់ទងនឹងទិដ្ឋធម្មនិព្វានប្រការទី ១ ពាក្យដ៏សេសលោកពោលទាក់ទងនឹងទិដ្ឋធម្មនិព្វានក្រៅអំពីនេះ ។ ក្នុងពាក្យនោះ ទិដ្ឋធម្មនិព្វានរាំទ ៤ ប្រការខាងមុខមកហើយ ទាក់ទងនឹងរូបាវចរជ្ឈាននោះឯង **ក្នុងព្រះបាលីសូម្បីក៏ពិតយ៉ាងនោះ** បុគ្គលម្ចាស់លទ្ធិប្រកាន់ណាមួយ ហើយប្រកាន់ទៅតាមតែបាន ព្រោះហេតុនោះ ទើបលោកកាន់យកអរូបភព ម្យ៉ាងទៀតលោកកាន់យកអរូបភព ក៏ព្រោះអរូបជ្ឈាន ក៏សង្គ្រោះនៅក្នុងចតុត្ថជ្ឈាន ម្យ៉ាងទៀតលោកកាន់យកអរូបភព ក៏ព្រោះអរូបជ្ឈានមានការស្មើគ្នាដោយបុគ្គលដែលមានការដល់ព្រម ដោយចតុត្ថជ្ឈាននោះ ជាបុគ្គលដល់នូវសេចក្ដីសុខ ព្រោះអរូបជ្ឈានជាសុខដ៏ល្អិត ។ ពាក្យថា **ប្រាសចាកការក្ដៅក្រហាយ** សេចក្ដីថា ជាអ្នកមានការក្ដៅក្រហាយ គឺកាមរាគៈស្ងប់ហើយ អធិប្បាយថា ជាអ្នកសម្រេចនិព្វានក្នុងបច្ចុប្បន្ននោះឯង ដោយការនាំចូលទៅនូវអារម្មណ៍បានតាមប្រាថ្នា និងដោយការលះ ។

សីល និងឈាន ដែលជាលោកិយឯណានីមួយ ដែលបុគ្គលឲ្យប្រព្រឹត្តទៅហើយ ទាក់ទងនឹងការប្រកាន់ខុស ថាជាផ្លូវនៃសេចក្ដីបរិសុទ្ធ លោកមានបំណងយកសីលព្វតក្នុងទីនេះ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលពាក្យជាដើមថា **ឈ្មោះថាសីលព្វត** នេះ ដូច្នេះ ។ លោកមិនបានពោលទុកដោយលំដាប់ថា ជាបច្ច័យដល់កតក្នុងទីបំផុតនៃសីលព្វតុបាទាន ព្រោះមិនបានប្រាកដរឿយៗ ដូចអត្តវាទុបាទាន និងព្រោះសីលព្វតុបាទាន មានអត្តវាទុបាទានជានិមិត្ត ។

បទថា **កាមភវេ** ជាសត្តមីវិភត្តិ ចុះក្នុងនិទ្ធារណៈ ។ ឯក្នុងបទថា **ហេតុប្បច្ចយ**-

ប្បភេទេហិ នេះ គួរពោលដល់មគ្គប្បច្ច័យផងដែរ ។ ពិតហើយ ឧបាទានទាំងឡាយ មានទិដ្ឋុបាទានជាដើម រមែងជាមគ្គប្បច្ច័យដល់កម្មភពដែលកើតរួមគ្នា ដូច្នេះ ។ ព្រោះហេតុនោះ ឧបាទានទាំងឡាយ មានទិដ្ឋុបាទានជាដើមនោះ គប្បីជ្រាបថា បណ្តាបច្ច័យមានសហជាតប្បច្ច័យជាដើម ទាញយកហេតុប្បច្ច័យចេញ បន្ថែមមគ្គប្បច្ច័យចូល ក៏ជាបច្ច័យបាន ៧ យ៉ាង ។ មួយ៉ាងទៀត ឧបាទានទាំងអស់ ជាបច្ច័យដោយអនន្តរប្បច្ច័យ សមនន្តរប្បច្ច័យ អនន្តរូបនិស្សយប្បច្ច័យ នត្ថិប្បច្ច័យ វិគតប្បច្ច័យ និងអាសេវនប្បច្ច័យ ។ ជាបច្ច័យ ដោយឧបនិស្សយប្បច្ច័យដល់កត ដែលមិនមែនជាលំដាប់ ។ គ្រាខ្លះក៏ជាអារម្មណប្បច្ច័យជាដើមក៏មាន លោករួមកតដែលមិនមែនជាលំដាប់ដោយឧបនិស្សយប្បច្ច័យប៉ុណ្ណោះ ពោលទុកថា **តែជាបច្ច័យដោយឧបនិស្សយប្បច្ច័យប៉ុណ្ណោះដល់កតដែលជាវិប្បយុត្ត** ដូច្នេះ ។

# វិសុទ្ធិមគ្គ

## អធិប្បាយ បទថា ភវប្បច្ចយា ជាតិ

*ក្នុងបទទាំងឡាយ មានបទថា **ភវប្បច្ចយា ជាតិ** ជាដើម កាលវិនិច្ឆ័យពាក្យមានពាក្យថា ជាតិជាដើម គប្បីជ្រាបដោយន័យដែលពោលហើយ ក្នុងសច្ចនិទ្ទេសចុះ ចំណែកពាក្យថា **ភវោ** ក្នុងបទនេះ សំដៅយកកម្មភពតែម្យ៉ាង ព្រោះកម្មភពនោះជាបច្ច័យនៃជាតិ ឧបបត្តិភពមិនជាបច្ច័យឡើយ ឯកម្មភពនោះជាបច្ច័យ ២ យ៉ាងដោយជាកម្មប្បច្ច័យ និងឧបនិស្សយប្បច្ច័យប៉ុណ្ណោះឯង ។*

*ប្រសិនបើពាក្យសួរនឹងគប្បីមានថា ពាក្យថា ភពជាបច្ច័យរបស់ជាតិនោះនឹងគប្បីជ្រាបបានដូចម្តេច ? ដូច្នេះសោត ចម្លើយគប្បីមានដូច្នេះថា គប្បីជ្រាបបានក្នុងកាលបច្ច័យខាងក្រៅមានស្មើគ្នា ប្រាកដសេចក្តីប្លែកគ្នា មានភាពជាបុគ្គលថោកទាប និងជាបុគ្គលប្រណីតជាដើមបាន ។ ពិតណាស់ សូម្បីភាពស្មើគ្នានៃបច្ច័យខាងក្រៅទាំងឡាយ មាន **សុក្កសោណិត** ( ឈាម.ស ) របស់ជនកជននី និងអាហារជាដើម មានសេចក្តីប្លែកគ្នាមានភាពជាបុគ្គលថោកទាប និងជាបុគ្គលប្រណីតជាដើមរបស់សត្វទាំងឡាយ សូម្បីជាកូនភ្លោះក៏ឃើញបានពិត ឯការប្លែកគ្នានៃសត្វទាំងឡាយនោះមិនមែនមិនមានហេតុ ព្រោះមិនមានទៅគ្រប់កាល និងគ្រប់គ្នា មិនមែនមានហេតុដទៃទៅអំពីកម្មភព ព្រោះមិនមានហេតុ ដទៃក្នុងសន្តានចំពោះខន្ធរបស់សត្វទាំងឡាយដែលកើតមកព្រោះកម្មភពនោះ ហេតុដូច្នោះ ទើបមានកម្មភពជាហេតុពិត ព្រោះកម្មជាហេតុនៃសេចក្តីប្លែកគ្នា មានភាពជាបុគ្គលថោកទាប និងជាបុគ្គលប្រណីតជាដើម ព្រោះដូច្នោះ ទើបព្រះមានព្រះភាគត្រាស់ថា កម្មរមែងចែកសត្វទាំងឡាយ នេះដូចម្តេច គឺរមែងចែកដោយភាពជាបុគ្គលថោកទាប និងជាបុគ្គលប្រណីត ដូច្នេះ ហេតុនោះ*

ពាក្យថា ភពជាបច្ច័យរបស់ជាតិ នោះ ទើបគួរជ្រាបបាន ( ដោយន័យដូចពោលមកដូច្នេះ ) ។

## អធិប្បាយ បទថា ជាតិប្បច្ចយា ជរាមរណំ ។បេ។

ឯហេតុណា កាលជាតិមិនមាន ដែលបានឈ្មោះថា ជរា និងមរណៈ ឬធម៌ទាំងឡាយ មានសោកជាដើម ក៏រមែងមិនមាន តែកាលជាតិមាន ជរាមរណៈ និងធម៌ទាំងឡាយ មានសោកជាដើម ដែលទាក់ទងជាមួយការចាស់ ការស្លាប់ ( របស់ខ្លួន) រមែងមានដល់បុគ្គលល្ងង់ខ្លៅ ដែលត្រូវទុក្ខធម៌ ពោល គឺជរាមរណៈពាល់ត្រូវខ្លះ ដែលមិនទាក់ទង (ជាមួយការចាស់ ការស្លាប់របស់ខ្លួន) ក៏រមែងមានដល់បុគ្គលល្ងង់ខ្លៅនោះដែលត្រូវទុក្ខធម៌នោះៗ ( មានញាតិស្លាប់ជាដើម ) ពាល់ត្រូវខ្លះ ព្រោះហេតុនោះ សូម្បីជាតិនេះ ក៏គប្បីជ្រាបថា ជាបច្ច័យនៃជរាមរណៈ និងនៃធម៌ទាំងឡាយមានសោកជាដើមផងដែរ ឯជាតិនោះ ជាបច្ច័យតែម្យ៉ាង ដោយជាបច្ច័យកំពូល គឺឧបនិស្សយប្បច្ច័យប៉ុណ្ណោះឯង ។

នេះជាកថាយ៉ាងពិស្តារ ក្នុងបទទាំងឡាយ មានបទថា ភវប្បច្ចយា ជាតិ ជាដើម ។

# មហាដីកា

## កថាពណ៌នាដោយពិស្តារនៃបទថា ព្រោះភពជាបច្ច័យ ទើបមានជាតិ

*អាទិ-ស័ព្ទថា **ជាតីតិអាទីសុ** ក្នុងពាក្យទាំងឡាយ មានជាតិជាដើម លោកអាចារ្យ រមែងសង្គ្រោះពាក្យទាំងពួងថា **ជាតិប្បច្ចយា ជរាមរណំ សោកបរិទេវទុក្ខទោមនស្សុបាយាសា សម្ភវន្តិ** ព្រោះជាតិជាបច្ច័យ ទើបមានជរា មរណៈ សោកបរិទេវៈ ទុក្ខ ទោមនស្ស ឧបាយាស ។ ដោយហេតុនោះ ទើបលោកអាចារ្យពោលពាក្យជាដើមថា **ជាតិអាទីនំ** ពាក្យមានជាតិជាដើម ។ ការកើតឡើងក្នុងឧបបត្តិភពនោះឯង ឈ្មោះថា **ជាតិ** ព្រោះហេតុនោះ ទើបលោកពោលថា **ឧបបត្តិភពមិនជាបច្ច័យឡើយ** ។ កាលសត្វកើត ទើបមានជាតិ សូម្បីឧបបត្តិភពក៏ឈ្មោះថា ជាតិ អាចពោលបានថា ជាបច្ច័យដល់ជាតិ ព្រោះកាលឧបបត្តិភពមិនមាន ជាតិក៏មិនមាន ។ ពិតហើយ លោកពោលសូម្បីភាវៈ ដែលជាតិរូបជាធម្មជាតិមាន រូបដែលកើតមានជាបទដ្ឋានទុកថា **ឧបចយរូប មានរូបដែលកកើតឡើងជាបទដ្ឋាន សន្តតិរូប មានរូបដែលទាក់ទងគ្នាដោយលំដាប់ជាបទដ្ឋាន** ដូច្នេះ ។*

*ខន្ធទាំងឡាយដែលកើតហើយ ជាសភាវៈដែលគេមើលងាយ និងជាសភាវៈដែលគេសរសើរ ឈ្មោះថា **បុគ្គលថោកទាប** និង **បុគ្គលប្រណីត** ។ ពិតហើយ វត្ថុដែលមិនគួរប្រាថ្នាជារបស់ថោកទាប វត្ថុដែលគួរប្រាថ្នាជារបស់ប្រណីត ។ ដោយ **អាទិ**-ស័ព្ទ លោកអាចារ្យរមែងសង្គ្រោះវត្ថុដែលមានពណ៌សម្បុរល្អ វត្ថុដែលមានពណ៌សម្បុរអាក្រក់ វត្ថុដែលថោកទាប និងវត្ថុដែលឧត្តម ។ ពាក្យថា **សូម្បីជាកូនក្មេង** សេចក្តីថា សូម្បីកើតហើយ ដោយភាពជាកូនក្មេង ។ **សោ ច យោគ***

**សត្តានំ វិសេសោ** ប្រែថា ឯការប្លែកគ្នានៃសត្វទាំងឡាយនោះឯង ។ លោកពោលថា **ក្នុងសន្តានខាងក្នុង** ព្រោះហេតុនៃការប្លែកគ្នាដែលមានសន្តានផ្សេងគ្នា មិនមានវត្ថុគ្រប់យ៉ាង ។ ពាក្យថា **ព្រោះមិនមានហេតុដទៃ** សេចក្ដីថា ព្រោះមិនបានហេតុនៃការប្លែកគ្នាដទៃអំពីសន្តានរបស់ខ្លួន និងកាលមានហេតុនៃការប្លែកគ្នានោះ ក៏ព្រោះមិនមានទៅគ្រប់កាល និងគ្រប់គ្នា ព្រោះហេតុនោះ កាលមិនសល់ហេតុ ដោយបដិសេធបានលំបាកនូវការទាក់ទងគ្នា ក៏ព្រោះមិនប្រកបដោយភាពប្លែកគ្នានៃផល ។ ដោយហេតុនោះ ទើបលោកអាចារ្យពោលថា **មានកម្មជាហេតុនោះឯង** ។

ពីរបទថា **តេន តេន** សេចក្ដីថា ត្រូវទុក្ខធម៌ដទៃអំពីជរា និងមរណៈ មានការវិនាសញាតិជាដើម ។ ពិតហើយ ធម៌ទាំងឡាយ មានសោកជាដើម ក៏ទាក់ទងជាមួយជរា និងមរណៈកើតឡើង ព្រោះមានជរា និងមរណៈជាហេតុ ធម៌ទាំងឡាយមិនទាក់ទង ( ជាមួយជរា និងមរណៈ ) ដទៃទៅអំពីជរា និងមរណៈនោះ ។ ពាក្យថា **ដោយជាបច្ច័យកំពូល គឺ ឧបនិស្សយប្បច្ច័យ** បានដល់ ដោយចំណែកនៃឧបនិស្សយប្បច្ច័យ អធិប្បាយថា ដោយអាងដល់ឧបនិស្សយប្បច្ច័យ ។ បច្ច័យណាមិនបានមកក្នុងគម្ពីរបដ្ឋានជាបច្ច័យដែលចូលទៅអាស្រ័យដោយបរិយាយនៃព្រះសូត្រព្រោះកាលមានបច្ច័យ ១ ទើបវាមាន និងព្រោះកាលមិនមានបច្ច័យ ១ វាក៏មិនមាន បច្ច័យនោះហៅថា **បច្ច័យកំពូល គឺឧបនិស្សយប្បច្ច័យ** ។ បានឮថា បច្ច័យនេះជាបច្ច័យមហាបទេស គឺជាបច្ច័យសម្រាប់អាងធំ ដែលបានដល់ឧបនិស្សយប្បច្ច័យ ។

# វិសុទ្ធិមគ្គ

## ភវចក្រ

ក្នុងបដិច្ចសមុប្បាទទេសនានេះ បកិណ្ណកធម៌ មានសោកជាដើម ព្រះសាស្តាត្រាស់ទុកក្នុងខាងចុង ហេតុនោះ អវិជ្ជាដែលត្រាស់ទុកក្នុងខាងដើម នៃភវចក្រនោះថា *អវិជ្ជាបច្ចយា សង្ខារា* ដូច្នេះ អវិជ្ជានោះ ក៏ប្រព្រឹត្តទៅ ( គឺមានបាន ) ព្រោះសោកជាដើម ( នោះឯង ) ។

ឯភវចក្រនេះ បណ្ឌិតគប្បីជ្រាបចុះថា មានខាងដើមមិនប្រាកដ ប្រាសចាកបុគ្គលអ្នកសាង និងបុគ្គលអ្នកសោយ ( ផល ) ទទេ ដោយសុញ្ញតា ១២ ប្រការ រមែងវិលទៅស្មើជានិច្ច ( រហូតដល់សម្រេចព្រះអរហត្ត ) ។

ប្រសិនបើមានពាក្យសួរថា ក្នុងបដិច្ចសមុប្បាទទេសនានេះ អវិជ្ជាមានបានព្រោះសោកជាដើមដូចម្តេច ភវចក្រនេះ មានខាងដើមមិនប្រាកដដូចម្តេច ប្រាសចាកបុគ្គលអ្នកសាង និងបុគ្គលអ្នកសោយ ( ផល ) ដូចម្តេច ទទេដោយសុញ្ញតា ១២ ប្រការដូចម្តេច ដូច្នេះសោត ។

## អវិជ្ជាមានព្រោះសោកជាដើមមាន

ពាក្យវិសជ្ជនាក៏គប្បីមានថា ក្នុងបដិច្ចសមុប្បាទធម៌ទាំងឡាយនេះ សោក ទុក្ខ ទោមនស្ស ឧបាយាស រមែងមានដល់បុគ្គលដែលនៅមិនទាន់ប្រាសចាកអវិជ្ជា ឯបរិទេវៈសោត ក៏រមែងមានដល់បុគ្គលដែលល្ងង់ ព្រោះហេតុនោះ ប្រការដំបូង កាលធម៌មានសោកជាដើមទាំងនោះប្រព្រឹត្តទៅហើយ អវិជ្ជាក៏ត្រូវមានប្រាកដ ប្រការមួយទៀតព្រះមានព្រះភាគត្រាស់ទុកថា ការកើតឡើងនៃអវិជ្ជា រមែងមានព្រោះការកើតឡើងនៃអាសវៈ ដូច្នេះ ឯធម៌ទាំងឡាយ មានសោកជាដើមនោះ ក៏រមែងមានព្រោះការកើត

ឡើងនៃអាសវៈ សេចក្តីនេះមានដូចម្តេច ? លំដាប់ដំបូង ក្នុងករណីដែលព្រាត់ប្រាសចាកវត្ថុកាម សោកជាដើមដែលកើតឡើង ព្រោះកាមាសវៈ ដូចព្រះបាលីថា

**តស្ស ចេ កាមយានស្ស ។បេ។ សល្លវិទ្ធោវ រុប្បតិ** ប្រសិនបើកាលជននោះកើតសេចក្តីពេញចិត្ត ប្រាថ្នាកាមពួកណា កាមទាំងនោះព្រាត់ប្រាសទៅសោត គេរមែងសោកា ប្រាកដដូចព្រួញចាក់ទម្លុះ ។

និងដូចព្រះបាលីថា **កាមតោ ជាយតី សោកោ** សេចក្តីសោក រមែងកើតអំពីកាមដូច្នេះ ។ ធម៌ទាំងឡាយ មានសោកជាដើមទាំងពួងនោះ រមែងជាធម៌កើតឡើងព្រោះទិដ្ឋាសវៈផង ដូចបាលីថា **តស្ស អហំ រូបំ ។បេ។... ទោមនស្សុបាយាសា** សោកបរិទេវទុក្ខទោមនស្ស និងឧបាយាស រមែងកើតឡើងដល់បុគ្គលនោះដែលប្រកាន់ ( ដោយទិដ្ឋិ ) ថា អញជារូប រូបជារបស់អញ ព្រោះភាពដែលរូបប្រែប្រួល និងផ្លាស់ប្តូរទៅ ដូច្នេះជាដើម ។

ម្យ៉ាងទៀត ធម៌ទាំងនោះកើតឡើង ព្រោះការកើតឡើងនៃទិដ្ឋាសវៈបានយ៉ាងណា ក៏រមែងកើតឡើង ព្រោះការកើតឡើងនៃភវាសវៈក៏បានដូច្នោះ ដូចព្រះបាលីថា សូម្បីទេវតាទាំងនោះដែលមានអាយុវែង ពណ៌សម្បុរល្អ ច្រើនទៅដោយសេចក្តីសុខ ស្ថិតនៅក្នុងវិមានដ៏ខ្ពស់អស់កាលដ៏យូរ សូម្បីទេវតាទាំងនោះ បានស្តាប់ធម្មទេសនារបស់តថាគតហើយ ពាល់ត្រូវ ( គឺដឹង ) ខ្វាចស្លុតចិត្ត ( ធម៌ទាំងនោះកើតដល់ទេវតាទាំងឡាយ ព្រោះការកើតឡើងនៃភវាសវៈ ) ដូចសេចក្តីសោកជាដើម កើតដល់ទេវតាទាំងឡាយដែលត្រូវមរណភ័យគំរាម ព្រោះឃើញបុព្វនិមិត្ត ៥ ដូច្នោះ ។

ម្យ៉ាងទៀត ធម៌ទាំងនោះ កើតព្រោះការកើតឡើងនៃភវាសវៈបាន យ៉ាងណា ក៏រមែងកើតព្រោះការកើតឡើង នៃអវិជ្ជាសវៈក៏បានដូច្នោះ ដូចព្រះបាលីថា ម្នាលភិក្ខុទាំងឡាយ បុគ្គលល្ងង់ខ្លៅនោះឯង រមែងបានសោយទុក្ខទោមនស្ស ៣ ប្រការ ក្នុង

ទិដ្ឋធម៌នេះឯង ដូច្នេះជាដើម ។

ព្រោះហេតុដែលធម៌ទាំងនោះ រមែងមានព្រោះការកើតឡើងនៃអាសវៈ ដូចពោលមកដូច្នេះ ធម៌ទាំងនោះ កាលមានឡើង ទើបញុំាងអាសវៈដែលជាហេតុនៃអវិជ្ជាឲ្យមានផង កាលអាសវៈទាំងឡាយមានហើយ សូម្បីអវិជ្ជាក៏មានដោយពិត ព្រោះកាលបច្ច័យមាន ធម៌ដែលកើតអំពីបច្ច័យក៏ត្រូវមាន ដូច្នេះ ។

ក្នុងបដិច្ចសមុប្បាទទេសនានេះ អវិជ្ជា បណ្ឌិតគប្បីជ្រាបថា រមែងមានបាន ព្រោះធម៌ទាំងឡាយ មានសោកជាដើម តាមន័យដូចពោលមកដូច្នេះ ជាប្រការដំបូង ។

## ភវចក្រមានខាងដើមមិនប្រាកដ

ប្រការតទៅ ព្រោះកាលបច្ច័យមាន ធម៌ដែលកើតអំពីបច្ច័យ ក៏ត្រូវមាន ដូច្នេះ កាលអវិជ្ជាមានឡើងហើយ ចុងបញ្ចប់ក៏មិនមាន ព្រោះការបន្តគ្នានៃហេតុ និងផល គឺសង្ខារទាំងឡាយក៏មានឡើង ព្រោះបច្ច័យ គឺអវិជ្ជាទៀត វិញ្ញាណក៏មានឡើង ព្រោះបច្ច័យ គឺសង្ខារទៀត យ៉ាងនេះជាដើម ហេតុណា ហេតុនោះ ភវចក្រមានអង្គ ១២ ដែលវិលទៅដោយអំណាចការសម្ពន្ធគ្នានៃហេតុ និងផលនោះ ទើបត្រូវសម្រេច គឺកើតបានថា មានខាងដើមមិនប្រាកដ ។

ប្រសិនបើពាក្យសួរគប្បីមានថា បើដូច្នោះ ( គឺកាលមិនមានអ្វីជាដើម ដូច្នោះ ) ការពោលភវចក្រមានខាងដើមថា **អវិជ្ជាបច្ចយា សង្ខារា** នេះ ក៏ខុស ដូច្នេះសោតគប្បីដោះស្រាយថា នេះមិនមែនជាការពោលភវចក្រមានខាងដើមនោះទេ តែទុំះជាការពោលធម៌ដែលជាតួប្រធាន ដោយអវិជ្ជាថា ជាប្រធាននៃវដ្តៈ ៣ ។ ពិតណាស់ ព្រោះប្រកាន់អវិជ្ជាទុក កិលេសវដ្តៈដ៏សេស និងវដ្តៈ ២ ទៀត មានកម្មវដ្តៈជាដើម ក៏ព័ទ្ធព័ន្ធយកបុគ្គលល្ងង់ខ្លៅទៅផង ដូចចាប់ក្បាលពស់ទុក ជនខ្លួនពស់ដែលសល់ក៏រុំព័ទ្ធដៃអ្នកចាប់ ដូច្នោះ តែកាលលះបង់អវិជ្ជាដាច់ជាសមុច្ឆេទហើយ ការផុតចាកធម៌ទាំង

នោះក៏មានឡើង ដូចកាលកាត់ក្បាលពស់ហើយ ការផុតចាកភាពជាដៃដែលត្រូវពស់រុំព័ទ្ធ ក៏មានឡើងដូច្នោះ ដូចព្រះបាលីថា ចំណែកការរលត់នៃសង្ខាររមែងមានព្រោះការរលត់ដោយខ្ជាក់ចោលមិនមានសេសសល់នៃអវិជ្ជានោះឯង ដូច្នេះជាដើម ។

នេះជាការពោលធម៌ដែលជាប្រធាន ដែលកាលបុគ្គលកំពុងប្រកាន់ រមែងជាអ្នកត្រូវចងប្រទាក់ កាលបន្សាត់ចោលហើយ ការរួចផុតរមែងមាន មិនមែនពោលភវចក្រមានខាងដើម ដូច្នេះឡើយ ។

ភវចក្រនេះ បណ្ឌិតគប្បីជ្រាបថា មានខាងដើមមិនប្រាកដ ដូចពោលមកដូច្នេះ ។

## ភវចក្រប្រាសចាកអ្នកសាងអ្នកសោយ

ភវចក្រនេះ ព្រោះហេតុដែលការវិលទៅនៃធម៌ទាំងឡាយ មានសង្ខារជាដើម រមែងមានព្រោះហេតុទាំងឡាយ មានអវិជ្ជាជាដើម ទើបវៀរចាកអ្នកសាងសង្សារ គឺព្រហ្មជាដើម ទើបកំណត់គ្នាយ៉ាងនេះថា **ព្រហ្មា** ព្រះព្រហ្ម **មហាព្រហ្មា** ទេវមហាព្រហ្ម **សេដ្ឋោ** អ្នកដ៏ជាធំ **សជ្ជិតា** លោកអ្នកបណ្ដាលជទៃទៅអំពីហេតុ មានអវិជ្ជាជាដើមនោះក្ដី ចាកអ្នកសោយសុខ និងទុក្ខ គឺអត្តា ដែលកំណត់គ្នាយ៉ាងនេះថា ឯអត្តារបស់អញនេះឯងជា **វទោ** អ្នកពោល **វេទេយ្យោ** អ្នកសោយ ដូច្នេះក្ដី ។

ភវចក្រ បណ្ឌិតគប្បីជ្រាបថា ប្រាសចាកអ្នកសាង និងអ្នកសោយដូចពោលមកនេះ ។

## ភវចក្រទទេដោយសុញ្ញតា ១២ ប្រការ

ប្រការមួយទៀត ក្នុងបដិច្ចសមុប្បាទធម៌នេះ អវិជ្ជា ឈ្មោះថា ទទេចាកភាពស្ថិតស្ថេរ ព្រោះមានការកើតឡើង និងការវិនាសទៅជាធម្មតា ១ ( ទទេ ) ចាកភាព

ស្អាត ព្រោះជាសង្កិលេសិកធម៌ ហេតុជាធម៌សៅហ្មង ១ ( ទទេ ) ចាកភាពជាសុខ ព្រោះត្រូវការកើតឡើង និងវិនាសទៅគ្រប់សង្កត់ ១ ( ទទេ ) ចាកភាពជាអត្តា គឺ ( ដោយអត្ថថា ) ជាវត្ថុដែលបង្គាប់មិនបាន ព្រោះមានការប្រព្រឹត្តទៅទាក់ទងដោយបច្ច័យ ១ សូម្បីអង្គទាំងឡាយ មានសង្ខារជាដើមក៏យ៉ាងនោះ ។ ម្យ៉ាងទៀត អវិជ្ជា មិនមែនខ្លួន មិនមែនរបស់ខ្លួន មិនមាននៅក្នុងខ្លួន មិនមានខ្លួន សូម្បីអង្គទាំងឡាយ មានសង្ខារ ជាដើមក៏យ៉ាងនោះ ហេតុណា ហេតុនោះ ភវចក្រនោះ បណ្ឌិតគប្បីជ្រាបចុះថា ទទេ ដោយសុញ្ញតា ១២ ប្រការ ដោយន័យដូចពោលមក ។

## មូល និង កាលនៃភវចក្រ

កាលជ្រាបយ៉ាងនេះហើយ គប្បីជ្រាបទៀតថា

## គាថាសង្ខេប មូល និង កាល

អវិជ្ជា និងតណ្ហា ជាមូលនៃភវចក្រនោះ កាលរបស់បដិច្ចសមុប្បាទមាន ៣ មានអតីតកាលជាដើម អង្គក្នុងកាល ៣ នោះ ដោយសរុបក៏មាន ២ និង ៨ និង ២ ប៉ុណ្ណោះឯង ។

## ពន្យល់សេចក្តី

សេចក្តីថា ធម៌ ២ គឺអវិជ្ជា និងតណ្ហា គប្បីជ្រាបថា ជាមូលនៃភវចក្រនោះៗ ឯងភវចក្រនោះសោត ក៏ចាត់ជា ២ ចំណែក គឺដែលមានអវិជ្ជាជាមូល មានវេទនាជាទីបំផុត ( ជាភវចក្រ ១ ) ព្រោះនាំ ( បច្ចុប្បន្នផល ) មកអំពីចំណែកខាងដើម ( គឺចំណែកអតីត ) ។ ដែលមានតណ្ហាជាមូល មានជរាមរណៈជាទីបំផុត (ជាភវចក្រ ១) ព្រោះតជាមួយ ( ផល ) ចំណែកខាងចុង ( គឺអនាគត ) ក្នុងភវចក្រ ២ ចំណែកនោះ ភវចក្រចំណែកដំបូង ពោលដោយអំណាចបុគ្គលទិដ្ឋិចរិត ចំណែកខាងក្រោយ ពោល

ដោយអំណាចបុគ្គលតណ្ហាចរិត ព្រោះថា អវិជ្ជាជាសង្សារនាយិកា ( អ្នកនាំទៅក្នុងសង្សារ ) សម្រាប់បុគ្គលទិដ្ឋិចរិតទាំងឡាយ តណ្ហាជាសង្សារនាយិកាសម្រាប់បុគ្គលតណ្ហាចរិតទាំងឡាយ ។ ន័យម្យ៉ាងទៀត ភវចក្រទី ១ ពោលដើម្បីដកឧច្ឆេទទិដ្ឋិ ព្រោះប្រកាសភាពមិនដាច់សូន្យនៃហេតុទាំងឡាយ ដោយការកើតឡើងនៃផល ( បច្ចុប្បន្នកំពុងប្រាកដ ) ភវចក្រទី ២ ពោលដើម្បីដកសស្សតទិដ្ឋិ ព្រោះប្រកាសជរាមរណៈនៃសត្វដែលកើតមកហើយទាំងឡាយ ។ ន័យម្យ៉ាងទៀត ភវចក្រដំបូង ពោលដោយអំណាចគព្ភសេយ្យកសត្វ ព្រោះសម្ដែងការវិលទៅនៃធម៌តាមលំដាប់ ភវចក្រក្រោយ ពោលដោយអំណាចឱបបាតិកសត្វ ព្រោះសម្ដែងការកើតឡើងព្រមគ្នា ( នៃឧបបត្តិភព និងខន្ធ ) ។

ចំណែកកាលរបស់ភវចក្រនោះមាន ៣ គឺអតីត បច្ចុប្បន្ន និងអនាគត ក្នុងកាល ៣ នោះ ពោលដោយទីមកក្នុងបាលីដោយសរុបអង្គ ២ គឺអវិជ្ជា និងសង្ខារ គប្បីជ្រាបថា ជាអតីតកាល អង្គ ៨ មានវិញ្ញាណជាដើម មានភពជាទីបំផុត គប្បីជ្រាបថា ជាបច្ចុប្បន្នកាល អង្គ ២ គឺជាតិ និងជរាមរណៈ គប្បីជ្រាបថា ជាអនាគតកាល ។

## សន្ធិ ៣ សង្ខេបៈ ៤ អាការ ២០ វដ្ដៈ ៣ នៃភវចក្រ

គប្បីជ្រាបគាថាសង្ខេបដូច្នេះថា

ភវចក្រនោះ មានសន្ធិ ( ទី.ត ) ៣ មានពាក្យថា ហេតុផល និងផលហេតុជាបទមុខ និងមានសង្គហៈ ( គឺសង្ខេប ) ៤ ប្រភេទ ដែលមានកាំ គឺអាការ ២០ មានវដ្ដៈ ( វង្វង់មូល ) ៣ រមែងវិលទៅមិនឈប់ ( រហូតទាល់តែដល់អរហត្តមគ្គ)ៗ

# ពន្យល់សេចក្តី

## សន្ធិ ៣

ក្នុងសន្ធិ ៣ នោះ ចំណុចទី ១ ក្នុងរវាងសង្ខារ និងបដិសន្ធិវិញ្ញាណ ឈ្មោះថា ហេតុផលសន្ធិ ( តភ្ជាប់ហេតុ និងផល ) សន្ធិ ១ ទៀត ក្នុងរវាងវេទនា និងតណ្ហា ឈ្មោះថា ផលហេតុសន្ធិ ( តផលភ្ជាប់នឹងហេតុ ) សន្ធិ ១ ទៀត ក្នុងរវាងភព និងជាតិ ឈ្មោះថា ហេតុផលសន្ធិ ( តភ្ជាប់ហេតុនឹងផល ) ភវចក្រនេះ បណ្ឌិតគប្បីជ្រាបថា មានសន្ធិ ៣ មានពាក្យថា ហេតុផល និងផលហេតុ ជាបទមុខយ៉ាងនេះឯង ។

## សង្គហៈ ៤

ចំណែកសង្គហៈនៃភវចក្រនោះ កំណត់ដោយអន្តខាងដើមជាមួយខាងចុងនៃសន្ធិទាំងឡាយជា ៤ គឺអ្វីខ្លះ ? គឺអវិជ្ជា និងសង្ខារ ជាសង្គហៈ ១ វិញ្ញាណ នាមរូប សឡាយតនៈ ផស្សៈ វេទនា ជាសង្គហៈទី ២ តណ្ហា ឧបាទាន ភព ជាសង្គហៈទី ៣ ជាតិ ជរាមរណៈ ជាសង្គហៈទី ៤ ភវចក្រនេះ បណ្ឌិតគប្បីជ្រាបថា មានសង្គហៈ ៤ ប្រភេទ ដូច្នេះឯង ។

## អាការ ២០

ម្យ៉ាងទៀត ភវចក្រនេះ បណ្ឌិតគប្បីជ្រាបថា មានអាការ ២០ ដោយកាំ ពោលគឺអាការ ២០ នោះ គឺ

## គាថាសង្ខេបអាការ ២០

ហេតុក្នុងកាលកន្លងហើយ ៥ ផលក្នុងកាលឥឡូវនេះ ៥ ហេតុក្នុងកាលឥឡូវនេះ ៥ ផលក្នុងកាលតទៅ ៥ ។

# ពង្រីកសេចក្តី

## អតីតហេតុ ៥

ក្នុង ៤ ប្រការនោះ ពាក្យថា **ហេតុក្នុងកាលកន្លងហើយ ៥** ពង្រីកសេចក្តីថា ដំបូង ( អតីតហេតុនោះ ) ក៏ពោលយកធម៌ ២ ប្រការ គឺអវិជ្ជា និងសង្ខារនេះប៉ុណ្ណោះ តែព្រោះបុគ្គលមិនបានដឹង រមែងប្រាថ្នា បុគ្គលប្រាថ្នា រមែងប្រកាន់មាំ ព្រោះការប្រកាន់មាំរបស់បុគ្គលនោះជាបច្ច័យ ភពក៏មានឡើង ព្រោះដូច្នោះ សូម្បីតណ្ហា ឧបាទាន និងភព ទើបត្រូវរួមចូលផង ហេតុនោះ ទើបព្រះធម្មសេនាបតីសារីបុត្រពោលទុកថា ការវង្វេងក្នុងបុរិមកម្មភព ជាអវិជ្ជា ចេតនាដែលប្រមូលទុកក្នុងបុរិមកម្មភព ជាសង្ខារ សេចក្តីប្រាថ្នាក្នុងបុរិមកម្មភពជាតណ្ហា កាលជាប់ជំពាក់ក្នុងបុរិមកម្មភពជាឧបាទាន ចេតនាក្នុងបុរិមកម្មភពជាភព ធម៌ ៥ ប្រការ ដូចពោលមកនេះ ក្នុងបុរិមកម្មភព រមែងជាបច្ច័យនៃបដិសន្ធិក្នុងភពនេះ ។

អត្ថ ( នៃព្រះបាលីនោះ ) គប្បីជ្រាបដូច្នេះថា ក្នុងបទទាំងនោះ បទថា **ក្នុងបុរិមកម្មភព** គឺក្នុងកម្មភពដែលមានមកអំពីមុន សេចក្តីថា ក្នុងកម្មភពដែលបានធ្វើមកក្នុងជាតិដែលកន្លងហើយ ។

ពាក្យថា ការវង្វេងជាអវិជ្ជា សេចក្តីថា បុគ្គលវង្វេងក្នុងធម៌ជាទីតាំងនៃសេចក្តីវង្វេងទាំងឡាយ មានទុក្ខជាដើម ក្នុងកាលនោះឯណា បុគ្គលអ្នកវង្វេង ហើយធ្វើកម្មដោយការវង្វេងឯណា ការវង្វេងនោះ ជាអវិជ្ជា ។

ពាក្យថា **ចេតនាដែលប្រមូលទុកជាសង្ខារ** បានដល់ ចេតនាដួងមុនៗ របស់បុគ្គលដែលធ្វើកម្មនោះ ដូចជាចេតនាដួងដំបូងៗ ដែលកើតឡើងដល់ទាយក ដែលញុំាងចិត្តឲ្យកើតឡើងថា យើងនឹងឲ្យទាន ហើយត្រៀមរៀបចំគ្រឿងឧបភោគបរិភោគ

ក្នុងការឲ្យទានទាំងឡាយ អស់មួយខែក្តី មួយឆ្នាំក្តី ចំណែកចេតនារបស់ទាយកនោះ ដែលដាក់ទក្ខិណាទានចុះក្នុងដៃរបស់បដិគ្គាហកៈទាំងឡាយ ហៅថា កព ។ ន័យម្យ៉ាងទៀត ចេតនាក្នុងជវន ៦ ដែលជាចិត្តមានអាវជ្ជនៈ ១ ឈ្មោះថា ចេតនាដែលប្រមូលទុករាប់ជាសង្ខារ ចេតនាក្នុងជវនទី ៧ ជាកព ឬបើមិនដូច្នោះ ចេតនាគ្រប់ដួងជាកព ធម៌ទាំងឡាយដែលសម្បយុត្ត ( ជាមួយចេតនាទាំងនោះ ) ឈ្មោះថា ចេតនាដែលប្រមូលទុក ជាសង្ខារ ។

ពាក្យថា **ការប្រាថ្នាជាតណ្ហា** សេចក្តីថា កាលបុគ្គលកំពុងធ្វើកម្ម ការពេញចិត្ត គឺសេចក្តីប្រាថ្នាក្នុងឧបបត្តិកព ដែលជាផលរបស់កម្មនោះឯណា ការពេញចិត្តនោះ ឈ្មោះថា តណ្ហា ។

ពាក្យថា **ការជាប់ជំពាក់ ជាឧបាទាន** សេចក្តីថា ការដែលធ្វើកម្មជាបច្ច័យនៃកម្មកពនេះហើយ កាលជាប់ជំពាក់ គឺប្រកាន់មាំ ដែលប្រព្រឹត្តទៅដោយន័យថា អញនឹង ( ទៅកើត ) សេពកាមទាំងឡាយ ក្នុងទីឈ្មោះនោះ ឬអញ នឹងដាច់សូន្យ ( គឺមិនកើត ) ដូច្នេះជាដើមឯណា ការជាប់ជំពាក់នេះ ឈ្មោះថា ឧបាទាន ។

ពាក្យថា **ចេតនាជាកព** គឺចេតនាដែលពោលហើយក្នុងទីបំផុតនៃចេតនាដែលប្រមូលទុកជាកព ។

## បច្ចុប្បន្នផល ៥

ពាក្យថា **ផលក្នុងកាលឥឡូវនេះ ៥** បានដល់ អគ្គ មានវិញ្ញាណជាដើម មានវេទនាជាទីបំផុត ដែលមកក្នុងបាលីនោះឯង ដូច្នេះថា បដិសន្ធិក្នុងបច្ចុប្បន្នកពនេះជាវិញ្ញាណ ការឈានចុះ ( ក្នុងគក៌ ) ក្នុងបច្ចុប្បន្នកពនេះ ជានាមរូប បសាទ

ក្នុងបច្ចុប្បន្នភពនេះ ជាអាយតនៈ ការៈដែលប៉ះខ្ទប់ ( អារម្មណ៍ ) ក្នុងបច្ចុប្បន្នភពនេះ ជាផស្សៈ ការសោយ ( វិបាក ) ក្នុងបច្ចុប្បន្នភពនេះ ជាវេទនា ធម៌ ៥ ប្រការដូចពោលមកនេះ មានក្នុងឧបបត្តិភពនេះ ព្រោះកម្មដែលធ្វើទុកក្នុងភពមុនជាបច្ច័យ ។

អត្ថ ( នៃបាលីនោះ ) គប្បីជ្រាបដូច្នេះថា ក្នុងពាក្យទាំងនោះ ពាក្យថា **បដិសន្ធិជាវិញ្ញាណ** សេចក្ដីថា វត្ថុណាលោកហៅថាបដិសន្ធិ ព្រោះកើតឡើងដោយអំណាចការភ្ជាប់ភពដទៃ ( ជាមួយបច្ចុប្បន្នភពនេះ ) វត្ថុនោះ ជាវិញ្ញាណ ។

ពាក្យថា **ការឈានចុះ ជានាមរូប** សេចក្ដីថា ការឈានចុះនៃរូបធម៌ និងអរូបធម៌ក្នុងគភ៌ ហាក់បីដូចជាមក ( អំពីទីដទៃ ) ហើយចូលទៅ ( ក្នុងគភ៌ ) ឯណានេះជានាមរូប ។

ពាក្យថា **បសាទជាអាយតនៈ** នេះ លោកពោលដោយអំណាចអាយតនៈ ៥ មានចក្ខាយតនៈជាដើម ។

ពាក្យថា **ការៈដែលប៉ះខ្ទប់ជាផស្សៈ** សេចក្ដីថា ការៈណាប៉ះខ្ទប់ គឺពាល់ត្រូវអារម្មណ៍កើតឡើង ការៈនេះជាផស្សៈ ។

ពាក្យថា **ការសោយជាវេទនា** សេចក្ដីថា ការសោយវិបាកដែលកើតឡើងរួមជាមួយបដិសន្ធិវិញ្ញាណក្ដី ជាមួយផស្សៈដែលមានសឡាយតនៈជាបច្ច័យក្ដី ការសោយ វិបាកនោះជាវេទនា ។

## បច្ចុប្បន្នហេតុ ៥

ពាក្យថា **ហេតុក្នុងកាលឥឡូវនេះ ៥** បានដល់ បច្ចយធម៌ មានតណ្ហាជាដើមដែលមកក្នុងបាលី ក៏តណ្ហា ឧបាទាន និងភព តែកាលភពត្រូវកាន់យកហើយ សង្ខារដែលជាបុព្វភាគរបស់ភពនោះ ឬដែលសម្បយុត្តជាមួយភពនោះត្រូវកាន់យកផង និងដោយការកាន់យកតណ្ហា ឧបាទាន អវិជ្ជា ដែលសម្បយុត្តជាមួយតណ្ហា ឧបាទាននោះ

ឬដែលជាហេតុធ្វើកម្មនៃបុគ្គលល្ងង់ខ្លៅ ក៏ត្រូវកាន់យកផង ដូច្នេះឯង ទើបបច្ចុប្បន្ន ហេតុជា ៥ ហេតុនោះ ទើបព្រះសារីបុត្រពោល ព្រោះភាពដែលអាយតនៈទាំងឡាយ ឆ្អិនហើយក្នុងភពនេះ ការវង្វេងជាអវិជ្ជា ចេតនាដែលព្យាយាមជាសង្ខារ ការប្រាថ្នា ជាតណ្ហា ការជាប់ជំពាក់ ជាឧបាទាន ចេតនាជាភព ធម៌ ៥ ប្រការដូចពោលក្នុង កម្មភពនេះ រមែងជាបច្ច័យនៃបដិសន្ធិក្នុងភពតទៅ ។

ក្នុងពាក្យទាំងនោះ ពាក្យថា **ព្រោះភាពដែលអាយតនៈទាំងឡាយឆ្អិនហើយក្នុងភពនេះ** លោកសម្ដែងសេចក្ដីវង្វេងក្នុងវេលាធ្វើកម្មនៃបុគ្គលដែលមានអាយតនៈ ឆ្អិនហើយ ពាក្យដ៏សេសមានអត្ថពាក់ហើយ ។

## អនាគតផល ៥

ពាក្យថា **ផលក្នុងកាលតទៅ ៥** បានដល់ អង្គ ៥ មានវិញ្ញាណជាដើម ធម៌ ៥ នោះ លោកពោលដោយប្រកាន់ថាជាជាតិ ចំណែកជរាមរណៈ គឺជរាមរណៈ នៃធម៌ពួកនោះៗ ឯង ហេតុនោះ ទើបព្រះសារីបុត្រពោលថា បដិសន្ធិក្នុងភពតទៅ ជាវិញ្ញាណ ការឈានចុះ ( ក្នុងគភ៌ ) ក្នុងភពតទៅជានាមរូប បសាទក្នុងភពតទៅ ជាអាយតនៈ ភាវៈដែលប៉ះខ្ទប់ ( អារម្មណ៍ ) ក្នុងភពតទៅជាផស្សៈ ការសោយ ( ផល ) ក្នុងភពតទៅជាវេទនា ធម៌ ៥ ប្រការដូចពោលមកនេះ មានក្នុងឧបបត្តិភព តទៅ ព្រោះកម្មដែលធ្វើក្នុងភពនេះជាបច្ច័យ ។

ភវចក្រនេះ មានកាំ គឺអាការ ២០ ដូចពោលមកដូច្នេះ ។

## វដ្ដៈ ៣

ចំណែកក្នុងពាក្យថា **ភវចក្រមានវដ្ដៈ ៣ វិលទៅមិនឈប់** មានអធិប្បាយ ថា ភវចក្រនេះមានវដ្ដៈ ៣ ដោយវដ្ដៈ ៣ នេះ គឺសង្ខារ និងភព ជាកម្មវដ្ដៈ អវិជ្ជា

តណ្ហា ឧបាទាន ជាកិលេសវដ្ដៈ វិញ្ញាណ នាមរូប សឡាយតនៈ ផស្សៈ វេទនា ជាវិបាកវដ្ដៈ គប្បីជ្រាបចុះថា កិលេសវដ្ដៈនៅមិនទាន់ដាច់ដរាបណា ក៏ឈ្មោះថា វិល ព្រោះប្រព្រឹត្តទៅជុំវិញហើយ ជុំវិញទៀត ឈ្មោះថា មិនឈប់ ព្រោះមានបច្ច័យនៅមិនទាន់ដាច់ដរាបនោះៗ ឯង ។

## គួរដឹងបកិណ្ណកៈក្នុងភវចក្រ

ភវចក្រនោះដែលកំពុងវិលយ៉ាងនេះ ដូចមាន គាថាសង្ខេបមាតិកាបកិណ្ណកៈ ដូចតទៅនេះ

**បណ្ឌិតគប្បីជ្រាបថា ( អង្គណា ) កើតអំពីសច្ចៈ ១ ដោយកិច្ច ១ ដោយជាគ្រឿងការពារ ១ ដោយឧបមាទាំងឡាយ ១ ដោយជម្រៅ ១ ដោយន័យ ១ តាមសមគួរ ។**

## ពន្យល់ការសេចក្ដី

## ពោលដោយអង្គណាកើតអំពីសច្ចៈណា

ក្នុងមាតិកាទាំងនោះ ព្រោះហេតុដែលកម្មដែលជាកុសល និងអកុសល លោកពោលទុកក្នុងសច្ចវិភង្គថា ជាសមុទយសច្ច ដោយមិនប្លែកគ្នា ក្នុងធម៌ទាំងឡាយ ក្នុងបទថា **អវិជ្ជាបច្ចយា សង្ខារា** ជាដើម សង្ខារដែលមានព្រោះអវិជ្ជា ទើបជាទុតិយសច្ចៈ កើតអំពីទុតិយសច្ចៈ ( ផងគ្នា ) វិញ្ញាណដែលមានព្រោះសង្ខារជាបឋមសច្ចៈ កើតអំពីទុតិយសច្ចៈ អង្គ មាននាមរូបជាដើម មានវិបាកវេទនាជាទីបំផុតដែលមានព្រោះវិញ្ញាណជាដើមជាបឋមសច្ចៈ កើតអំពីបឋមសច្ចៈ ( ផងគ្នា ) តណ្ហាដែលមានព្រោះវេទនាជាទុតិយសច្ចៈ កើតអំពីបឋមសច្ចៈ ឧបាទានដែលមានព្រោះតណ្ហា ជាទុតិយសច្ចៈ កើតអំពីទុតិយសច្ចៈ ( ផងគ្នា ) ភពដែលមាន ព្រោះឧបាទាន ជាបឋមសច្ចៈ និង

ទុតិយសច្ចៈទាំងពីរ កើតអំពីទុតិយសច្ចៈ ជាតិ ដែលមានព្រោះភព ជាបឋមសច្ចៈ កើតអំពីទុតិយសច្ចៈ ជរាមរណៈដែលមានព្រោះជាតិ ជាបឋមសច្ចៈ កើតអំពីបឋមសច្ចៈ ( ជាមួយគ្នា ) ។

ភវចក្រនេះ បណ្ឌិតគប្បីជ្រាបដោយ ( អន្តណា ) កើតអំពីសច្ចៈណាតាមសមគួរ ដោយន័យដូចពោលមកដូច្នេះ ជាលំដាប់ដំបូង ។

## ដោយកិច្ច

ប្រការមួយទៀត ហេតុណា ក្នុងអង្គទាំងនេះ អវិជ្ជា រមែងញុំាងសត្វទាំងឡាយឲ្យវង្វេងក្នុងវត្ថុ (គឺអារម្មណ៍) ទាំងឡាយ និងជាបច្ច័យដើម្បីការប្រាកដឡើងនៃសង្ខារទាំងឡាយផង ន័យដូចគ្នានោះ សង្ខារក៏តាក់តែងសង្ខតធម៌ និងជាបច្ច័យនៃវិញ្ញាណផង ចំណែកវិញ្ញាណក៏ទទួលដឹងវត្ថុ ( គឺអារម្មណ៍ ) និងជាបច្ច័យនៃនាមរូបផងដែរ ខាងនាមរូបក៏ឧបការៈគ្នានឹងគ្នា និងជាបច្ច័យនៃសឡាយតនៈផង សឡាយតនៈសោតក៏ប្រព្រឹត្តទៅក្នុងវិស័យរបស់ខ្លួនរៀងៗខ្លួន ( មានរូបជាដើម ) និងជាបច្ច័យនៃផស្សៈផង ផស្សៈសោត ក៏ប៉ះពាល់អារម្មណ៍ និងជាបច្ច័យនៃវេទនាផង វេទនាសោតក៏សោយរសអារម្មណ៍ និងជាបច្ច័យនៃតណ្ហាផង តណ្ហាសោតក៏ត្រេកអរក្នុងធម៌ដែលជាទីតាំងនៃតម្រេក និងជាបច្ច័យនៃឧបាទានផង ឧបាទានសោតក៏ប្រកាន់មាំក្នុងធម៌ដែលជាទីតាំងនៃសេចក្តីប្រកាន់មាំ និងជាបច្ច័យនៃភពផង ភពសោត ក៏អន្ទោលទៅក្នុងគតិផ្សេងៗ និងជាបច្ច័យនៃជាតិផង ជាតិសោតក៏ញុំាងខន្ធទាំងឡាយឲ្យកើត និងព្រោះប្រព្រឹត្តទៅដោយជាអាការកើតឡើង នៃខន្ធទាំងឡាយនោះ ទើបជាបច្ច័យនៃជរាមរណៈផង ជរាមរណៈសោត ក៏គ្របសង្កត់យកភាពចាស់ និងភាពបែកធ្លាយនៃខន្ធទាំងឡាយទុក និងជាបច្ច័យដើម្បីការប្រាកដឡើងក្នុងភពដទៃ ព្រោះជាទីតាំង ( គឺជាហេតុ )

នៃបកិណ្ណកទុក្ខ មានសោកជាដើម ហេតុនោះ ភវចក្រនេះ បណ្ឌិតគប្បីជ្រាបសូម្បី ដោយកិច្ច សូម្បីប្រព្រឹត្តទៅដោយកិច្ចពីរៗ ក្នុងបទទាំងពួងតាមសមគួរ ។

## ដោយជាគ្រឿងការពារ

ប្រការមួយទៀត ហេតុណា ក្នុងបទទាំងនេះ បទថា **សង្ខារមានព្រោះបច្ច័យ គឺអវិជ្ជា** នេះជាគ្រឿងការពារ ( គឺបដិសេធ ) ការឃើញថា មានអ្នកសាង ។ បទថា **វិញ្ញាណមានព្រោះបច្ច័យ គឺសង្ខារ** ជាគ្រឿងរាំងការយល់ឃើញថា អត្តាឃ្លាតចាកទីបាន បទថា **នាមរូបមានព្រោះវិញ្ញាណ** ជាគ្រឿងរាំងឃនសញ្ញា ( ការសម្គាល់ថាជាដុំ ) ព្រោះសម្តែងការបែកបាននៃវត្ថុដែលបុគ្គលល្ងង់ខ្លៅកំណត់យក ( ខ្លួនឯង) ថាជាអត្តា បទថា **សឡាយតនៈមានព្រោះបច្ច័យ គឺនាមរូប** ជាដើម ជាគ្រឿងរាំងការយល់ឃើញ ( ខុសផ្សេងៗ ) មានឃើញថា អត្តាឃើញ ។បេ។ អត្តាចាំអារម្មណ៍ អត្តាប៉ះពាល់ អត្តាសោយ ( វេទនា ) អត្តាចង់បាន អត្តាប្រកាន់មាំ អត្តាឧប្បត្តិ អត្តាកើត អត្តាចាស់ អត្តាស្លាប់ ដូច្នេះជាដើម ហេតុនោះ ភវចក្រនោះ បណ្ឌិតគប្បីជ្រាបសូម្បីដោយជាគ្រឿងរាំងការយល់ឃើញខុសតាមសមគួរ ។

## ដោយឧបមា

ប្រការមួយទៀត ហេតុណា ក្នុងអង្គទាំងនេះ អវិជ្ជាឧបមាដូចបុគ្គលខ្វាក់ ព្រោះមិនឃើញធម៌ទាំងឡាយ ទាំងដោយលក្ខណៈប្រចាំខ្លួន ( របស់ធម៌នោះៗ ) ទាំងដោយសាមញ្ញលក្ខណៈ សង្ខារដែលមានព្រោះបច្ច័យ គឺអវិជ្ជា ដូចការឈានភ្លាត់របស់បុគ្គលខ្វាក់ វិញ្ញាណដែលមានព្រោះបច្ច័យ គឺសង្ខារ ដូចការដួលចុះរបស់បុគ្គលឈានភ្លាត់ នាមរូបដែលមានព្រោះបច្ច័យ គឺវិញ្ញាណ ដូចការកើតឡើងនៃស្នាមរបួស ដែលកើតឡើងព្រោះបុគ្គលដួលចុះ សឡាយតនៈដែលមានព្រោះបច្ច័យ គឺនាមរូប ដូចខ្ទុះ

ដែលបែក ផស្សៈដែលមានព្រោះបច្ច័យ គឺសឡាយតនៈ ដូច ( វត្ថុណាមួយ ) ដែលប៉ះខ្ទប់មុខដំបៅនោះ វេទនាដែលមានព្រោះបច្ច័យ គឺផស្សៈ ដូចសេចក្តីទុក្ខ ដែលកើតអំពីការប៉ះខ្ទប់ តណ្ហាដែលមានព្រោះបច្ច័យ គឺវេទនា ដូចសេចក្តីប្រាថ្នានឹងបំបាត់ទុក្ខ ឧបាទានដែលមានព្រោះបច្ច័យ គឺតណ្ហា ដូចការស្រវាយកថ្នាំស្ងួន ដោយបំណងនឹងបំបាត់ ( ទុក្ខ ) ភពដែលមានព្រោះបច្ច័យ គឺឧបាទាន ដូចការលាបថ្នាំស្ងួនដែលខ្លួនប្រកាន់ ជាតិដែលមានព្រោះបច្ច័យ គឺភព ដូចការកើតជាដំបៅក្លាយ ព្រោះលាបថ្នាំស្ងួន ជរាមរណៈដែលមានព្រោះជាតិ ដូចការបែកនៃដំបៅក្លាយ ។

ឬន័យម្យ៉ាងទៀត ហេតុណា ក្នុងអង្គទាំងនេះ អវិជ្ជារមែងគ្របសង្កត់សត្វទាំងឡាយទុក ដោយធ្វើឲ្យមិនបដិបត្តិ ឬបដិបត្តិខុស ដូចជញ្ជាំងបាំងភ្នែក ( ទាំងសងខាង ) ទុក បុគ្គលល្ងង់ខ្លៅដែលត្រូវអវិជ្ជានោះបិទបាំងទុកហើយ រមែងចងរុំខ្លួនទុកដោយសង្ខារទាំងឡាយ ដែលនាំទៅកាន់ភពថ្មី ដូចដង្កូវនាងរុំខ្លួនទុកដោយសរសៃសូត្រ វិញ្ញាណដែលសង្ខារគ្រប់គ្រងហើយ រមែងបានទីអាស្រ័យក្នុងគតិទាំងឡាយ ដូចព្រះរាជកុមារដែលបរិនាយកការពារហើយ រមែងបានភាពកក់ក្តៅក្នុងរាជសម្បត្តិ វិញ្ញាណរមែងញុំាងនាមរូបច្រើនប្រការឲ្យកើតក្នុងបដិសន្ធិ ព្រោះត្រាច់ទៅក្នុងអារម្មណ៍ដែលជានិមិត្តនៃឧបបត្តិ ( មានកម្មនិមិត្តជាដើម ) ដូចអ្នកលេងរហ័សធ្វើកលឲ្យកើតបានច្រើនប្រការ សឡាយតនៈដែលតាំងមាំនៅក្នុងនាមរូបហើយ រមែងដល់នូវការចម្រើនដុះដាលបរិបូណ៌ ដូចគុម្ពឈើក្នុងព្រៃដែលតាំងនៅក្នុងផែនដីដែលល្អ រមែងដល់នូវការធំលូតលាស់វិសាល ផស្សៈរមែងកើត ព្រោះការប៉ះខ្ទប់គ្នានៃអាយតនៈ ដូចភ្លើងកើតព្រោះការក្អួតនៃឈើពំនួត វេទនាកើតដល់បុគ្គលដែលត្រូវផស្សៈប៉ះខ្ទប់ ដូចកម្តៅកើតដល់បុគ្គលដែលភ្លើងឆេះ តណ្ហារមែងចម្រើនច្រើនដល់បុគ្គល ដែលកំពុងសោយវេទនា ដូចការស្រេក កើតខ្លាំងឡើងដល់បុគ្គលដែលផឹកទឹកអំបិលចូលទៅ បុគ្គលដែលប្រាថ្នា

( ដោយតណ្ហា ) ហើយ រមែងធ្វើសេចក្តីប្រាថ្នាក្នុងភពទាំងឡាយ ដូចបុគ្គលស្រេកប្រាថ្នាដើម្បីផឹកទឹក ការធ្វើភាពប្រាថ្នានោះ រាប់ជាឧបាទានរបស់បុគ្គលៗ រមែងប្រកាន់យកភពទុកយ៉ាងមាំដោយឧបាទាន ដូចត្រីទាញផ្លែសន្ទូចទុកដោយសេចក្តីល្មោភក្នុងនុយ កាលភពមាន ជាតិក៏រមែងមាន ដូចកាលគ្រាប់ពូជមាន ពន្លកក៏រមែងមាន ជរាមរណៈរមែងមាន ដល់បុគ្គលដែលកើតមកហើយដោយពិត ដូចការជួល រមែងមានដល់ដើមឈើ ដែលកើតឡើងហើយដោយពិត ហេតុនោះ ភវចក្រនោះ បណ្ឌិតគប្បីជ្រាបដោយឧបមាទាំងឡាយដូចពោលមកដូច្នេះតាមសមគួរ ។

## ដោយជម្រៅ

ប្រការមួយទៀត ហេតុណា ពាក្យបាលីថា ម្នាលអានន្ទ ឯបដិច្ចសមុប្បាទនេះជាធម៌ជ្រាលជ្រៅផង មូល ( ស្រមោលដែលប្រាកដចេញមក ) ក៏ជ្រៅផង ដូច្នេះ ។ ព្រះមានដោគត្រាស់សំដៅយកភាព ដែលបដិច្ចសមុប្បាទនោះជាធម៌ជ្រាលជ្រៅទាំងដោយអត្ថ ( គឺផល ) ទាំងដោយធម៌ ( គឺហេតុ ) ទាំងដោយការសម្តែង ទាំងដោយបដិវេធ ហេតុនោះ ភវចក្រនោះ បណ្ឌិតគប្បីជ្រាប សូម្បីដោយជម្រៅតាមសមគួរ ។

## ជ្រៅដោយផល

ក្នុងជម្រៅទាំងនោះ ហេតុណា អត្ថ គឺភាពដែលជរាមរណៈកើតឡើងប្រព្រឹត្តទៅព្រមព្រោះបច្ច័យ គឺជាតិ ឈ្មោះថា ជាជម្រៅធម៌ ព្រោះអត្ថ គឺភាពដែលជរាមរណៈប្រព្រឹត្តទៅព្រម ព្រោះបច្ច័យ គឺជាតិយ៉ាងនេះថា ជរាមរណៈ រមែងមានដល់ជាតិ វៀរជាតិចេញហើយ ជរាមរណៈ មិនមានអំពីហេតុដទៃឡើយ ហើយជរាមរណៈរមែងប្រព្រឹត្តទៅព្រមទឹងជាតិដោយប្រការយ៉ាងនេះ ន័យដូចគ្នានោះដែរ អត្ថ គឺការដែលជាតិកើតឡើងប្រព្រឹត្តទៅព្រម ព្រោះបច្ច័យ គឺភព ។បេ។ អត្ថ គឺភាពដែល

សង្ខារកើតឡើង ប្រព្រឹត្តទៅព្រម ព្រោះបច្ច័យ គឺអវិជ្ជា ( សុទ្ធៗ ) ជាជម្រៅធម៌... ហេតុនោះ ទើបភវចក្រនេះ ឈ្មោះថា ជ្រាលជ្រៅដោយអត្ថដូច្នេះ នេះជាជម្រៅដោយអត្ថ ( គឺផល ) ក្នុងភវចក្រនេះ ជាលំដាប់ដំបូង មែនពិត ផលដែលកើតអំពីហេតុ លោកហៅថា អត្ថ ដូចបាលីថា **ការដឹងក្នុងផលដែលកើតអំពីហេតុ ឈ្មោះថា អត្ថប្បដិសម្ភិទា** ។

## ជ្រៅដោយហេតុ

ប្រការមួយទៀត ហេតុណា អត្ថ គឺភាពដែលអវិជ្ជាជាបច្ច័យនៃសង្ខារទាំងឡាយ ឈ្មោះថា ជាជម្រៅធម៌ ព្រោះអវិជ្ជាជាបច្ច័យនៃសង្ខារនោះៗ ដោយអាការណា និងឋានៈណា អាការនោះ និងឋានៈនោះ ជាករណីដែលដឹងបានលំបាក ។ ន័យដូចគ្នានោះដែរ អត្ថ គឺភាពដែលសង្ខារជាបច្ច័យនៃវិញ្ញាណ ។បេ។ អត្ថ គឺភាពដែលជាតិជាបច្ច័យនៃជរាមរណៈ ( សុទ្ធៗ ) ជាធម៌ជ្រៅ... ហេតុនោះ ទើបភវចក្រនេះ ឈ្មោះថា ជ្រៅដោយធម៌ដូច្នេះ នេះជាជម្រៅដោយធម៌ ( គឺហេតុ ) ក្នុងភវចក្រនេះ សមដូចពាក្យថា ធម៌ ជាឈ្មោះនៃហេតុ ដូចបាលីថា **ការដឹងក្នុងហេតុ ឈ្មោះថា ធម្មប្បដិសម្ភិទា** ។

## ជ្រៅដោយការសម្តែង

ប្រការមួយទៀត ហេតុណា សូម្បីការសម្តែងបដិច្ចសមុប្បាទនោះក៏ជ្រៅ ព្រោះជាការសម្តែងដែលគប្បីឲ្យប្រព្រឹត្តទៅដោយហេតុនោះៗ ដោយប្រការនោះៗ ញាណដទៃផ្សេងអំពីសព្វញ្ញុតញ្ញាណ រមែងមិនបានទីតាំងក្នុងបដិច្ចសមុប្បាទនោះ ពិតដូច្នោះ ភវចក្រនោះ ក្នុងសូត្រខ្លះ ទ្រង់សម្តែងដោយអនុលោម សូត្រខ្លះទ្រង់សម្តែងដោយបដិលោម សូត្រខ្លះទ្រង់សម្តែងដោយអនុលោមផង និងបដិលោមផង សូត្រខ្លះទ្រង់សម្តែងចាប់ពីពាក់កណ្តាលទៅ ដោយអនុលោមខ្លះ ដោយបដិលោមខ្លះ សូត្រខ្លះទ្រង់

សម្តែងទាំង ៣ សន្ធិ ៤ សង្ខេប សូត្រខ្លះទ្រង់សម្តែង ២ សន្ធិ ៣ សង្ខេប សូត្រខ្លះទ្រង់សម្តែងតែសន្ធិ ១ សង្ខេប ២ ហេតុនោះ ទើបកវចក្រនេះ ឈ្មោះថា ជ្រៅដោយការសម្តែងដូច្នេះ នេះជាជម្រៅដោយការសម្តែង ។

## ជ្រៅដោយបដិវេធ

ប្រការមួយទៀត ហេតុណា ក្នុងបដិច្ចសមុប្បាទធម៌នេះ សភាវៈនៃធម៌ មានអវិជ្ជាជាដើមនោះឯណា ម្យ៉ាងទៀត ព្រោះសភាវៈណាដែលព្រះយោគាវចរចាក់ធ្លុះហើយនូវធម៌ទាំងឡាយ មានអវិជ្ជាជាដើម ក៏ត្រូវបានចាក់ធ្លុះដោយលក្ខណៈប្រចាំខ្លួន ( របស់ធម៌នោះៗ ) យ៉ាងត្រឹមត្រូវ ដោយសភាវៈនោះ ចាត់ថា ជាជម្រៅ ព្រោះពិចារណាបានលំបាក ហេតុនោះ ទើបកវចក្រនេះ ឈ្មោះថា ជ្រៅដោយបដិវេធ ។

ន័យដូចគ្នានោះឯង ហេតុណា ក្នុងបដិច្ចសមុប្បាទធម៌នេះ មានអត្ថ គឺការមិនដឹង ការមិនឃើញ ការមិនចាក់ធ្លុះដោយល្អនូវសច្ចៈនៃអវិជ្ជាក៏ជ្រៅ អត្ថ គឺការតាក់តែង ការកពូនឡើង ការប្រព្រឹត្តទៅជាមួយរាគៈ ការប្រជែងចំពោះរាគៈនៃសង្ខារទាំងឡាយក៏ជ្រៅ អត្ថ គឺភាពទទេ ភាពមិនក្រវល់ក្រវាយ ( គឺមិនមានការគិត ) ការមិនឃ្លាតចាកទីទៅ ( តែ ) ប្រាកដដោយបដិសន្ធិបាននៃវិញ្ញាណក៏ជ្រាលជ្រៅ អត្ថ គឺការកើតឡើងព្រមគ្នា ការបែកគ្នា ការបែកគ្នាមិនបាន ការបង្អោនទៅបាន ការបែកធ្លាយបាននៃនាមរូបក៏ជ្រៅ អត្ថ គឺភាពជាអធិបតី ភាពជាលោក ភាពជាទ្វារ ភាពជាដែនកំណត់ ភាពជាវិសយី គឺឥន្ទ្រិយ នៃសឡាយតនៈក៏ជ្រៅ អត្ថ គឺភាពត្រូវគ្នា ការបៀតបៀនគ្នា ការជល់គ្នា ការប្រជុំគ្នានៃផស្សៈក៏ជ្រាលជ្រៅ អត្ថ គឺការសោយអារម្មណ៍ជាសុខ ជាទុក្ខ និងកណ្តាលៗ ការសោយដូចនិជ្ជីវៈ គឺមិនមានអត្តាអ្នកសោយ នៃវេទនាក៏ជ្រាលជ្រៅ អត្ថ គឺការភ្ញើតភ្ញើន ការ **សំបតចិត្ត** ការប្រាថ្នា ( ដែលហូរទៅ ) ដូចជ្រោះ ដូចរងើកភ្លើង ដូចស្ទឹងទឹងមិនស្គាល់ការពេញ ដូចសមុទ្រនៃតណ្ហាក៏ជ្រៅ

អត្ថ គឺសេចក្តីទង់ទាញ ការប្រកាន់ ការជោតចិត្ត ការចាប់ទុក ការឈានកន្ទងលំបាក នៃឧបាទានក៏ជ្រៅ អត្ថ គឺការប្រមូលទុក ការតាក់តែងទុក និងការបន្សាត់ទៅក្នុងកំណើត ក្នុងគតិ ក្នុង ( វិញ្ញាណ ) ឋិតិ និងក្នុង ( សត្វ ) និវាស នៃភពក៏ជ្រៅ អត្ថ គឺការកើត ការបានកំណើត ការឈោងចុះ ( ក្នុងគភ៌ ) ការផុសឡើង ការប្រាកដឡើង នៃជាតិក៏ជ្រៅ អត្ថ គឺការអស់ទៅ ការវិនាសទៅ ការបែកទៅ ការប្រែប្រួលទៅ នៃមរណៈក៏ជ្រៅ ហេតុនោះ ទើបភវចក្រនេះ ឈ្មោះថា ជ្រៅដោយបដិវេធ ដូច្នេះ ។

នេះជាជម្រៅដោយបដិវេធក្នុងបដិច្ចសមុប្បាទធម៌នេះ ។

## ដោយន័យផ្សេងៗ

ប្រការមួយទៀត ហេតុណា ក្នុងបដិច្ចសមុប្បាទធម៌នេះ មានន័យនៃអត្ថ ៤ គឺ ឯកត្តន័យ (ន័យ ១) នានត្តន័យ ( ន័យផ្សេងៗ ) អព្យាបារន័យ ( ន័យមិនមានសេចក្តីខ្វល់ខ្វាយ ) ឯវំធម្មតាន័យ ( ន័យធម្មតា ) ហេតុនោះ ភវចក្រនោះ បណ្ឌិតគប្បីជ្រាបសូម្បីដោយន័យផ្សេងៗ ទៀត តាមសមគួរ ។

## ឯកត្តន័យ

ក្នុងន័យ ៤ នោះ ការមិនដាច់ខ្សែនៃការបន្តដូច្នេះ គឺសង្ខារមានព្រោះបច្ច័យ គឺអវិជ្ជា វិញ្ញាណមានព្រោះបច្ច័យ គឺសង្ខារជាដើម ដូចការដែលគ្រាប់ពូជ ដល់នូវភាពជាដើមឈើ ព្រោះការមានឡើងនៃអវយវៈរបស់ដើមឈើ មានពន្លកជាដើម ( បន្តគ្នាមក ) ដូច្នោះ ឈ្មោះថា ឯកត្តន័យដែលជាន័យ កាលព្រះយោគាវចរឃើញដោយត្រឹមត្រូវ រមែងលះឧច្ឆេទទិដ្ឋិបាន ព្រោះពិចារណាដឹងការមិនដាច់ខ្សែនៃការបន្តដែលប្រព្រឹត្តទៅដោយការសម្ពន្ធគ្នានៃហេតុ និងផល កាលយល់ឃើញខុសទៅ រមែងប្រកាន់មាំក្នុងសស្សតទិដ្ឋិ ព្រោះកាន់យកការមិនដាច់ខ្សែនៃការបន្តគ្នាដែលប្រព្រឹត្តទៅ

ដោយការសម្ពន្ធគ្នានៃហេតុ និងផលថា ភាពតែមួយ ។

## នានត្តន័យ

ចំណែកការកំណត់លក្ខណៈណាមួយរបស់បដិច្ចសមុប្បាទ នៃធម៌ទាំងឡាយមានអវិជ្ជាជាដើម ឈ្មោះថា នានត្តន័យ ដែលជាន័យកាលឃើញដោយត្រឹមត្រូវ រមែងលះសស្សតទិដ្ឋិបាន ព្រោះឃើញការកើតឡើងនៃវត្ថុថ្មីៗ កាលយល់ឃើញខុសទៅ រមែងប្រកាន់មាំក្នុងឧច្ឆេទទិដ្ឋិ ព្រោះការប្រកាន់យកហេតុផលដែលធ្លាក់នៅក្នុងសន្តានមួយជាមួយគ្នា ( គឺមានសន្តតិមួយជាមួយគ្នាដូចពោលហើយ ) សន្តានមកបែកចុះ ( គឺស្លាប់ ) នោះឯង ថាផ្សេងគ្នា ( គឺជាបុគ្គលមួយដែលមិនបន្តគ្នា ) ទៅ ។

## អព្យាបារន័យ

ភាពដែលអវិជ្ជា មិនមានសេចក្តីខ្វល់ខ្វាយ ( គឺមិនមានការគិត ) ថា សង្ខារទាំងឡាយអញធ្វើឲ្យកើតឡើង ឬសង្ខារមិនមានសេចក្តីខ្វល់ខ្វាយថា វិញ្ញាណអញធ្វើឲ្យកើតឡើង ដូច្នេះជាដើម ឈ្មោះថា អព្យាបារន័យ ដែលជាន័យកាលឃើញដោយត្រឹមត្រូវ រមែងលះអត្តទិដ្ឋិ ( ការឃើញថាមានខ្លួន ) បាន ព្រោះពិចារណាដឹងភាពមិនមានអ្នកសាង កាលឃើញខុសទៅ រមែងប្រកាន់យកអកិរិយទិដ្ឋិ ព្រោះមិនកាន់យកភាពជាហេតុនៃធម៌ទាំងឡាយ មានអវិជ្ជាជាដើម កាលការខ្វល់ខ្វាយមិនមាន ក៏មានបានដោយសភាវនិយម ។

## ឯវំធម្មតាន័យ

ចំណែកន័យថា ការកើតឡើងនៃផល មានសង្ខារជាដើម រមែងមានអំពីហេតុមានអវិជ្ជាជាដើមប៉ុណ្ណោះ ដូចការកើតឡើងនៃទឹកដោះជូរជាដើម រមែងមានអំពីទឹកដោះស្រស់ជាដើម ដូច្នោះ មិនមែនដទៃ នេះឈ្មោះថា ឯវំធម្មតាន័យ ដែលជាន័យ

កាលយល់ឃើញដោយត្រឹមត្រូវ រមែងលះអហេតុកទិដ្ឋិនិងអកិរិយទិដ្ឋិបាន ព្រោះពិចារណាដឹងផល ដោយសមគួរដល់បច្ច័យ កាលយល់ឃើញខុសទៅ រមែងប្រកាន់ក្នុងអហេតុកទិដ្ឋិ និងនិយតិវាទ ព្រោះមិនកាន់យកការប្រព្រឹត្តទៅនៃផល តាមគួរដល់បច្ច័យហើយ នៅប្រកាន់ថា វត្ថុណាមួយ មិនបានកើតអំពីវត្ថុណាមួយ ( គឺប្រកាន់ថា កើតអំពីជោគគ្រោះ ) ដូច្នេះ ។

**ភវចក្រនេះ បណ្ឌិតគប្បីជ្រាបថា ( អង្គណា ) កើតអំពីសច្ចៈណា ១ ដោយកិច្ច ១ ដោយជាគ្រឿងរារាំង ១ ដោយឧបមាទាំងឡាយ ១ ដោយជម្រៅ ១ ដោយន័យផ្សេងៗ ១ តាមសមគួរ** ដោយប្រការដូច្នេះ ។

ព្រោះហេតុដែលបុគ្គល មិនទាន់បានទម្លាយភវចក្រ ដែលពិចារណាមិនដល់ព្រោះជាធម៌ជ្រាលជ្រៅ ដែលតទល់លំបាក ព្រោះកាន់យកបានដោយន័យផ្សេងៗនេះដោយដាវ គឺញាណ ដែលសំលៀងល្អត្រង់ថ្មយ៉ាងប្រសើរ គឺសមាធិ ហើយកាត់ក្របែលសង្សារភ័យ ដែលគ្របសង្កត់ជានិច្ច ដូចអសនីវិចក្រ ( គឺរន្ទះ ) ទៅបានមិនមានបុគ្គលត្រឹមតែម្នាក់ សូម្បីក្នុងយល់សប្តិ ។ ពិតណាស់ សេចក្តីនេះសូម្បីមានព្រះមានព្រះភាគក៏បានត្រាស់ទុកថា ម្នាលអានន្ទ បដិច្ចសមុប្បាទនេះ ជាធម៌ជ្រៅផងស្រមោល ( ដែលប្រាកដចេញមក ) ក៏ជ្រៅផង ម្នាលអានន្ទ ក៏ព្រោះមិនយល់មិនដឹងតាមនូវធម៌នោះ ពពួកសត្វនេះ ទើបកើតជាអ្នក ( ជាប់ជំពាក់ ) ដូចអំបោះជំពាក់ កើតជាបុគ្គល ( រសាប់រសល់ ) ដូចសម្បុកគុណ្ឋិ កើតជាបុគ្គល ( ចាក់ស្រេះ ) ដូចស្មៅជំណោកទទ្រាយ និងស្មៅឃាប្លង មិនកន្លងអបាយ ទុគ្គតិ វិនិបាត

សង្ខារទៅបាន ដូច្នេះ ព្រោះហេតុនោះ បណ្ឌិតដែលបដិបត្តិដើម្បីជាប្រយោជន៍ និងដើម្បីសេចក្តីសុខដល់ខ្លួនក្តី ដល់អ្នកដទៃក្តី គប្បីលះកិច្ចដែលសេសសល់ចេញហើយ នឹងបាននូវការឈោងចុះដ៏មាំ ក្នុងប្រភេទនៃបច្ចយាការដ៏ជ្រាលជ្រៅនេះ ដោយប្រការណា ក៏គប្បីជាអ្នកមានសតិប្រកបរឿយៗ ដោយប្រការនោះឯង ។

បរិច្ឆេទទី ១៧ ឈ្មោះបញ្ញាភូមិនិទ្ទេស

ក្នុងអធិការនៃបញ្ញាភាវនា

ក្នុងបករណ៍វិសុទ្ធិមគ្គ

ដែលធ្វើដើម្បីប្រយោជន៍ដល់បាមោជ្ជនៃសាធុជន

ដូច្នេះ ។

# មហាដីកា

## កថាពណ៌នាដោយភវចក្រ

លោកអាចារ្យផ្តើមពាក្យថា **ឯហេតុណា** ជាដើម ដើម្បីសម្តែងថា ជាតិជាបច្ច័យដល់ធម៌ទាំងឡាយ មានសោកជាដើមប៉ុណ្ណោះ នៅមិនទាន់អស់សេចក្តី តែព្រោះជាបច្ច័យដល់ធម៌ទាំងឡាយ មានសោកជាដើម ទើបជាបច្ច័យដល់អវិជ្ជាដែរនោះឯង ។ បទថា **ឯត្ថ យោគ បដិច្ចសមុប្បាទទេសនាយំ** ប្រែថា ក្នុងបដិច្ចសមុប្បាទទេសនានេះ ។ **ម** អក្ខរៈ ក្នុងបទថា **អវិទិតាទិមិទំ** ធ្វើការត.បទ ។ ពាក្យថា **ជានិច្ច** គឺសព្វកាលទាំងពួង រហូតដល់សម្រេចអរហត្តមគ្គ ។ ពាក្យថា **ជានិច្ចកាល** គឺរួមគ្នា អធិប្បាយថា មិនដាច់ខ្សែ ។

បទថា **តេសុ យោគ សោកាទីសុ** ប្រែថា កាលធម៌ មានសោកជាដើមនោះ ។ បទថា **សិទ្ធេសុ** សេចក្តីថា ដែលបាន ។ ឈ្មោះថា អវិជ្ជា រមែងជាការសម្រេច ព្រោះជាធម្មជាតិដែលមិនប្រាសគ្នា ។

បទថា **កាមយានស្ស** សេចក្តីប៉ុនគ្នានឹង **កាមយមានស្ស** ប្រែថា ប្រាថ្នា ម្យ៉ាងទៀត មានវិគ្គហៈថា កាម ជាយានរបស់ជននេះ ហេតុនោះ ជននេះ ឈ្មោះថា **កាមយានោ** ប្រែថា មានកាមជាយាន អធិប្បាយថា កាលជននោះប្រព្រឹត្តទៅ ដោយអំណាចកាម ។បទថា **ឆន្ទជាតស្ស** សេចក្តីថា មានឆន្ទៈ គឺតណ្ហាកើតហើយ ។ ពាក្យថា **រមែងវិនាសទៅ** គឺរមែងប្រាសទៅ ។បទថា **រុប្បតិ** សេចក្តីថា រមែង កម្រើកដោយធម៌មានសោកជាដើម ។

បុគ្គលអ្នកមានប្រក្រតីតាំងនៅ ដោយជាបុគ្គលចោមរោម ឈ្មោះថា **បរិយុដ្ឋានដ្ឋាយី** ប្រែថា អ្នកមានប្រក្រតីតាំងនៅដោយភាពជាអ្នកចោមរោម ។ ម្យ៉ាងទៀត

បាឋៈថា **បរិយុដ្ឋដ្ឋាយិនោ** ដូច្នេះក៏មាន ។ ក្នុងបាឋៈនោះ គប្បីឃើញថា វត្ថុណា រមែងចោមរោម ហេតុនោះ វត្ថុនោះ ឈ្មោះថា **បរិយុដ្ឋំ** ចោមរោម បានដល់ វត្ថុដែលចោមរោម គឺ ទិដ្ឋិ បុគ្គលណារមែងតាំងនៅដោយវត្ថុដែលចោមរោម គឺទិដ្ឋិនោះ ហេតុនោះ បុគ្គលនោះ ឈ្មោះថា **បរិយុដ្ឋដ្ឋាយី** អ្នកតាំងនៅដោយវត្ថុ ដែលចោមរោម ។

ពាក្យថា **បុព្វនិមិត្ត ៥ ប្រការ** បានដល់ បុព្វនិមិត្តនៃការស្លាប់ ៥ ប្រការ ដែលត្រាស់ទុកថា **ផ្ការមែងស្វិតស្រពោន ១ សំពត់រមែងសៅហ្មង ១ ញើសរមែងហូរចេញអំពីក្លៀក ១ ពណ៌សម្បុរសៅហ្មងរមែងប្រាកដត្រង់កាយ ១ ទេវតារមែងមិនត្រេកអរក្នុងទិព្វអាសនៈរបស់ខ្លួន ១** ។ ព្រោះឃើញបុព្វនិមិត្តទាំងនោះ ទើបពួកទេវតាកើតសេចក្ដីសោកដ៏មានកម្លាំង ដោយកម្លាំងនៃកវចទុះក្នុងឧបបត្តិកព ពោល គឺខន្ធដែលកើតឡើងអំពីកម្ម ដូច្នេះឯង ។

ពាក្យថា **បុគ្គលពាល** បានដល់ បុគ្គលដែលមិនដឹង ។ ដោយពាក្យនោះ ព្រះមានព្រះភាគទ្រង់រមែងសម្ដែងភាពដែលអវិជ្ជាជាហេតុ ។ ពាក្យថា **ទុក្ខ ៣ ប្រការ** បានដល់ ទុក្ខ មានសោកជាដើមដែលមានដើមហេតុមកអំពីការស្ដាប់រឿង ដែលសមគួរដល់រឿងនោះ ការឃើញការដាក់ទោសផ្សេងៗ និងការប្រាកដនៃកម្ម ក្នុងវេលាជិតនឹងស្លាប់ ។

ពាក្យថា **ញុំាងអាសវៈឲ្យសម្រេច** សេចក្ដីថា ធ្វើឲ្យដល់ គឺធ្វើឲ្យយល់អាសវៈទាំងឡាយ ។

បទថា **ឯវំ សតិ** សេចក្ដីថា កាលបើយ៉ាងនោះ គឺកាលភាវៈដែលកវចក្រមិនមានខាងដើម ដោយភាវៈដែលខាងដើមមិនប្រាកដ ។ បទថា **អាទិមត្តកថនំ** ប្រែថា ការពោលភាពមានខាងដើម ដោយអំណាចអវិជ្ជា ឯកវចក្រ ឈ្មោះថា **អាទិមំ** ( មានខាងដើម ) ព្រោះអត្ថថា ខាងដើមកវចក្រនេះមាន ។ ភាវៈនៃកវចក្រដែលមានខាង

ដើមនោះ ឈ្មោះថា **អាទិមត្តំ** ( ភាពដែលកវចក្រមានខាងដើម ) ការពោលកវចក្រ មានខាងដើមនោះ ឈ្មោះថា **អាទិមត្តកថនំ** ( ការពោលកវចក្រមានខាងដើម ) ។ ម្យ៉ាងទៀត អធិប្បាយថា **មត្ត**-ស័ព្ទ មានអត្ថបដិសេធ អត្ថដែលផ្សេងចេញទៅ កាល កវចក្រមិនមានខាងដើម អវិជ្ជាក៏គួរមាននៅក្នុងខាងដើម ក្នុងកណ្តាល និងក្នុង ទីបំផុតគ្រប់ៗ កន្លែង ព្រោះហេតុនោះ ការពោលអវិជ្ជាត្រឹមតែជាខាងដើមក៏ខុស ។ លោកអាចារ្យពោលថា **អវិជ្ជាជាប្រធាន** ដូច្នេះ ហើយផ្តើមពាក្យថា **ព្រោះអវិជ្ជា ប្រកាន់ទុក** ដូច្នេះ ដើម្បីសម្តែងអវិជ្ជានោះជាប្រធាន ។ ក្នុងពាក្យនោះ ពាក្យថា **ព្រោះ អវិជ្ជាប្រកាន់ទុក** គឺព្រោះធ្វើអវិជ្ជាឲ្យកើតឡើង ឬព្រោះមិនលះអវិជ្ជា អធិប្បាយថា ព្រោះធ្វើអវិជ្ជាជាធម្មជាតិតាំងចុះក្នុងសន្តានរបស់ខ្លួន ។ បទថា **កម្មាទីនិ** សេចក្តីថា កម្មវដ្ដៈ និងវិបាកវដ្ដៈ ។ បទថា **បលិពោធេន្តិ** សេចក្តីថា រមែងញ៉ាំងពួកសត្វដែល ត្រាច់ទៅក្នុងសង្សារ ដែលក្តៅក្រហាយដោយទុក្ខផ្សេងៗ ឲ្យរលត់ទៅ ។ បទថា **តេហិ យោគ កិលេសកម្មវិបាកវដ្ដេហិ** ប្រែថា អំពីកិលេសវដ្ដៈ កម្មវដ្ដៈ និងវិបាកវដ្ដៈ ទាំងនោះ ។ លោកពោលអវិជ្ជាថា **ធម៌ដែលជាប្រធាន** ព្រោះជាប្រធានដោយការៈ ដែលជាហេតុនៃវដ្ដៈ ។

**តតោ យោគ អវិជ្ជាទិតោ** ប្រែថា អំពីហេតុ មានអវិជ្ជាជាដើមនោះ ។ ដោយ **អាទិ**-ស័ព្ទ ក្នុងបទថា **ព្រហ្មាទិនា** លោករមែងសង្គ្រោះព្រះបជាបតី ព្រះឥស្សរ និង បុរសជាដើម ។ បុគ្គលណារមែងពោលអធិប្បាយថា រមែងពោលប្រយោជន៍ និង មិនមែនប្រយោជន៍ ហេតុនោះ បុគ្គលនោះ ឈ្មោះថា **វទោ** អ្នកពោល ។ បុគ្គលណា រមែងសោយ អធិប្បាយថា រមែងសោយវេទនា មានសុខជាដើម ហេតុនោះបុគ្គលនោះ ឈ្មោះថា **វេទេយ្យោ** អ្នកសោយ ម្យ៉ាងទៀត បុគ្គលណារមែងដឹងអធិប្បាយថា រមែង ដឹងអារម្មណ៍ទាំងពួង គឺរមែងដឹងដោយខ្លួន និងដោយបុគ្គលដទៃ ឯខ្លួន និងបុគ្គលដទៃ

ក៏រមែងជីង ដោយន័យជាដើមថា **ជាបុគ្គលដល់នូវសុខ ជាបុគ្គលដល់នូវទុក្ខ** ហេតុនោះ បុគ្គលនោះ ឈ្មោះថា **វេទេយ្យោ** ប្រែថា បុគ្គលជីង ឬបុគ្គលត្រូវជីង ។ **វា**-ស័ព្ទ ក្នុងពាក្យថា **ព្រហ្មាទិនា វា អត្តនា វា** សេចក្ដីប៉ុនគ្នានឹង **ច**-ស័ព្ទ ។ ដោយហេតុនោះ ទើបលោកអាចារ្យពោលសេចក្ដីសង្ខេបនៃ **ច**-ស័ព្ទទុកថា **ការកវេទករហិតំ** ប្រែថា វៀរចាកអ្នកសាង និងអ្នកសោយ ដូច្នេះ ។

បទថា **ទ្វាទសវិធសុញ្ញតាសុញ្ញំ** មានអត្ថថា ទទេ ដោយសុញ្ញតានៃសភាវៈទទេ ១២ ប្រការ មានអវិជ្ជាជាដើម ទើបឈ្មោះថា **ទ្វាទសវិធសុញ្ញតាសុញ្ញំ** ទទេ ដោយសុញ្ញតានៃធម៌ ១២ ប្រការ ម្យ៉ាងទៀត អធិប្បាយថា **សុញ្ញតា** ឈ្មោះថា មាន ១២ យ៉ាង ព្រោះភាវៈជារបស់ទទេចាកការស្ថិតស្ថេរជាដើម បានអង្គ ១២ ដោយសង្គ្រោះសុញ្ញតាទាំង ៤ យ៉ាងជា ១ យ៉ាង ហេតុនោះ ទើបឈ្មោះថា **ទទេ ដោយសុញ្ញតា ១២ យ៉ាងនោះ** ។

បទថា **បុព្វន្តាហរណតោ** ប្រែថា ព្រោះនាំបច្ចុប្បន្នផលមកអំពីចំណែកខាងដើម គឺអំពីចំណែកអតីត ។ ដែលកំណត់មានវេទនាជាទីបំផុត ក៏ចាត់ជាភវចក្រ ១ ។ ពិតហើយ សូម្បីចំណែកមួយនៃភវចក្រ លោកក៏ហៅថា **ភវចក្រ** ។ ម្យ៉ាងទៀត វេទនារមែងជាបច្ច័យដល់អវិជ្ជាដែលមានតណ្ហាជាសម្មាញ់ ព្រោះហេតុនោះ ភវចក្រដែលមានវេទនាជាទីបំផុត បណ្ឌិតគប្បីឃើញថា គ្រប់ចំនួននោះឯង ព្រោះទាក់ទងគ្នា គឺព្រោះវេទនា ទើបមានអវិជ្ជា ព្រោះអវិជ្ជា ទើបមានសង្ខារ ។ ម្យ៉ាងទៀត ដោយការកាន់យកអវិជ្ជា លោកក៏កាន់យកតណ្ហា និងឧបាទាន ព្រោះអវិជ្ជា តណ្ហា និងឧបាទាននោះមិនបែកគ្នា ។ ដោយការកាន់យកសង្ខារ លោកក៏កាន់យកភពដែរ ការកាន់យកវិញ្ញាណជាដើម លោកក៏កាន់យកជាតិ ជរា មរណៈ និងធម៌ មានសោកជាដើមផងដែរ ភវចក្រ មានវេទនាជាទីបំផុត មានន័យដូចពណ៌នា ដោយប្រការដូច្នេះ ព្រោះ

ហេតុនោះ ភវចក្រ មានវេទនាជាទីបំផុតនេះ ជាការសមគួរហើយ ។ ក្នុងភវចក្រដែលមានតណ្ហាជាមូល បណ្ឌិតក៏គប្បីប្រកបយ៉ាងនេះ ។ ឯភវចក្រទាំង ២ បន្ថែមចូលគ្នានឹងគ្នាបាន ដូច្នេះ ។ អវិជ្ជាបិទបាំងសភាវៈនៃធម៌ ធ្វើឲ្យប្រកាន់ខុសយ៉ាងមាំ រមែងនាំបុគ្គលពួកទិដ្ឋិចរិតទៅក្នុងសង្សារ ឬរមែងនាំសង្សារ គឺការប្រព្រឹត្តទៅនៃធម៌ មានសង្ខារជាដើម គឺធ្វើឲ្យប្រព្រឹត្តទៅដល់ពួក បុគ្គលទិដ្ឋិចរិតនោះ ព្រោះហេតុនោះ ទើបលោកហៅថា **សង្សារនាយិកា** ( អ្នកនាំទៅក្នុងសង្សារ ឬនាំសង្សារទៅ ) ។ ក្នុងប្រការដែលតណ្ហាជាសង្សារនាយិកា សម្រាប់ពួកបុគ្គលតណ្ហាចរិត មិនមានពាក្យដែលនឹងពោលដល់ឡើយនោះឯង ។

**បឋមំ** ជាវិសេសនៈរបស់ **ភវចក្កំ** ប្រែថា ភវចក្រទី ១ ។ បទថា **ផលុប្បត្តិយា** ជាតតិយាវិភត្តិ ចុះក្នុងអត្ថនៃកត្តុ ម្យ៉ាងទៀត ចុះក្នុងអត្ថនៃករណៈនោះឯង ។ ម្យ៉ាងទៀត ការកើតឡើងនៃបច្ចុប្បន្នផល មានវិញ្ញាណជាដើមឃើញបាន ហើយក្នុងភពនេះ រមែងប្រកាស ឬរមែងធ្វើការប្រកាសការមិនដាច់សូន្យ ដោយមិនញ៉ាំងផលនៃអវិជ្ជា និងសង្ខារ ដែលជាហេតុរបស់ខ្លួនក្នុងភពមុន ដែលមិនបានឃើញឲ្យកើតឡើង ដូច្នេះ ។ ម្យ៉ាងទៀត អធិប្បាយថា **បុព្វន្តភវចក្រ** លោកពោលថា សម្ពន្ធគ្នានឹង **អបរន្តភវចក្រ** ព្រោះហេតុនោះ ទើបរមែងប្រកាសការមិនដាច់សូន្យនៃហេតុ មានតណ្ហាជាដើម ដោយការកើតឡើងនៃផល ពោល គឺវេទនា ព្រោះហេតុនោះ ទើបលោកពោល ព្រោះប្រកាសការមិនដាច់សូន្យនៃហេតុរបស់បុព្វន្តភវចក្រ ដោយការកើតឡើងនៃផល ដែលជាតួហេតុ ។ ម្យ៉ាងទៀត ការមិនញ៉ាំងផលនៃហេតុទាំងឡាយ មានអវិជ្ជាជាដើមឲ្យកើត ក៏មិនដាច់ខ្សែដូចគ្នា ដោយការកើតឡើងនៃផលទាំងឡាយ មានសង្ខារជាដើម នោះឯង ម្យ៉ាងទៀត **បុព្វន្តភវចក្រ** រមែងប្រកាសការទាក់ទងគ្នាដោយលំដាប់នៃធម៌ មានសង្ខារជាដើម ដែលជាហេតុនៃវិញ្ញាណជាដើម រមែងប្រកាសទីបំផុត ដូចជា

*អបរន្តកវចក្រក៏ទេ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា ព្រោះប្រកាសការ* ***មិនដាច់សូន្យនៃហេតុ ដោយការកើតឡើងនៃផល*** *ដូច្នេះ ។ ពាក្យថា* ***ព្រោះសម្តែង*** ***ការប្រព្រឹត្តទៅដោយលំដាប់*** *គឺព្រោះសម្តែងការប្រព្រឹត្តទៅដោយលំដាប់នៃធម៌ទាំង ឡាយ ដោយពាក្យជាដើមថា* ***ព្រោះសង្ខារជាបច្ច័យ ទើបមានវិញ្ញាណ ព្រោះ*** ***វិញ្ញាណជាបច្ច័យ ទើបមាននាមរូប*** *។ ក្នុងពាក្យថា* ***ព្រោះវិញ្ញាណជាបច្ច័យ ទើប*** ***មាននាមរូប*** *នេះ លោកពោលកលលរូបដែលមានអាយតនៈមិនគ្រប់ ហើយផុតអំពី នោះ ទើបពោលការប្រព្រឹត្តទៅនៃសឡាយតនៈថា* ***ព្រោះនាមរូបជាបច្ច័យ ទើប*** ***មានសឡាយតនៈ*** *។ ពាក្យថា* ***ព្រោះសម្តែងការកើតឡើងព្រមគ្នា*** *សេចក្តីថា ព្រោះ សម្តែងការកើតឡើង ព្រមគ្នានៃឧបបត្តិភព និងខន្ធថា* ***ព្រោះឧបាទានជាបច្ច័យ ទើប*** ***មានភព ( ខ្វះ ) ព្រោះភពជាបច្ច័យ ទើបមានជាតិ ខ្វះ*** *។ ក្នុងអធិការនេះ លោកពោលការ កើតឡើងដោយលំដាប់នៃអាយតនៈទាំងឡាយ ដូចក្នុងភវចក្រទី ១ ក៏ទេ ។*

***សន្ធិ*** *( គឺតំណ ) ៣ មានពាក្យថា* ***ហេតុ*** *ជាដើម ជាបទមុខ មានដល់ភវចក្រនេះ ហេតុនោះ ភវចក្រនេះ ឈ្មោះថា* ***ហេតុផល ហេតុបុព្វកតិសន្ធិ*** *ប្រែថា មានសន្ធិ ៣ មានពាក្យថា* ***ហេតុផល*** *និង* ***ផលហេតុ*** *ជាបទមុខ* ***ភវចក្កំ*** *ជា* ***អញ្ញបទ*** *។ សង្គហៈ គឺការសង្គ្រោះអង្គ មាន ៤ ប្រភេទ គឺហេតុ ១ ផល ១ ហេតុ ១ ផល ១ មានដល់ ភវចក្រនេះ ហេតុនោះ ភវចក្រនេះ ឈ្មោះថា* ***ចតុភេទសង្គហំ*** *មានសង្គហៈ ៤ ប្រភេទ ។ សភាវៈឈ្មោះថា* ***អាការ*** *ព្រោះមានអត្ថថា សូម្បីលោកមិនបានពោលទុក ដោយសរុប ក៏ជម្រាលទៅក្នុងសង្គហៈនោះៗ គឺលោកប្រកាសទុកដោយសព្ទ មាន អវិជ្ជា និងសង្ខារជាដើម ។ម្យ៉ាងទៀត ប្រការនៃធម៌ទាំងឡាយ មានអតីតហេតុជាដើម ក៏ឈ្មោះថា* ***អាការ*** *។ កិលេស កម្ម និងវិបាក ជាធម៌ដែលសម្ពន្ធជាមួយនឹងវិបាក កិលេស និងកម្ម រមែងវិលវល់ទៅរឿយៗ ព្រោះហេតុនោះ ទើបលោកពោលថា*

មានវដ្ដៈ ៣ ព្រោះលើកឈ្មោះថា វដ្ដៈឡើងទុកក្នុងកិលេស កម្ម និងវិបាកនោះ ម្យ៉ាងទៀត លោកហៅថា **វដ្ដៈ** ក៏ ព្រោះជាចំណែកមួយនៃវដ្ដៈ ។

ពីរបទថា **សន្ធីនំ អាទិបរិយោសានវវត្ថិតា** ប្រែថា កំណត់ដោយអន្តដើម និងអន្តចុងនៃសន្ធិទាំងឡាយ ។

ពាក្យថា **រមែងចង់បាន** សេចក្ដីថា រមែងបម្រុះនទៀល អធិប្បាយថា រមែងចង់បានវត្ថុនោះៗ ដោយអំណាចការធ្វើការកំណត់កាន់យក ។ ពាក្យថា **រមែងប្រកាន់មាំ** គឺរមែងហួងហែង ។ ពាក្យថា **ក្នុងបុរិមកម្មភព** គឺក្នុងបុរិមកម្មភពដែលមាន ។

ឯការមាននៃបុរិមកម្មភពនោះ បានដល់ **បុរិមកម្មភព** ដែលបានធ្វើមកនោះឯង ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **អធិប្បាយថា ក្នុងបុរិមកម្មភព ដែលបានធ្វើមកនោះឯង** ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **អធិប្បាយថា ក្នុងបុរិមកម្មភពដែលបានធ្វើមក** ។ ពាក្យថា **ការវង្វេងក្នុងធម៌ដែលជាទីតាំងនៃការវង្វេងទាំងឡាយ មានទុក្ខជាដើម** បានដល់ ការវង្វេងដែលលះមិនទាន់បានដែលបិទបាំងទោសនៃធម៌ជាទីតាំងនៃការវង្វេងទាំងឡាយ មានទុក្ខជាដើម ។ បទថា **អាយូហនា** ប្រែថា ប្រមូលទុក គឺធ្វើឲ្យប្រព្រឹត្តទៅក្នុងការធ្វើកម្ម មានទានជាដើម ។ អាវជ្ជនៈ ១ របស់សការធម៌ទាំងនេះ ហេតុនោះ សការធម៌ទាំងនេះ ឈ្មោះថា **ឯកាវជ្ជនា** មានអាវជ្ជនៈ ១ ក្នុងសការធម៌ ដែល**មានអាវជ្ជនៈ ១ ទាំងនោះ** ។ ចេតនា **ក្នុងជវនទី ៧ ជាភព** ។ ពាក្យថា **ឬចេតនាដួងណានីមួយជាភព ធម៌ទាំងឡាយដែលសម្បយុត្ត ឈ្មោះថា ចេតនាដែលប្រមូលទុកជាសង្ខារ** នេះ លោកពោលទុក ដោយអំណាចព្រះបាលីបដិសម្ភិទាមគ្គ ដែលព្រះធម្មសេនាបតីសារីបុត្រពោលទុកក្នុងធម្មដ្ឋិតិញ្ញាណភាជនីយ៍ តាមដែលបានសម្ដែងទុកហើយ ។ ក្នុងព្រះបាលីបដិសម្ភិទាមគ្គនោះមកហើយថា **ចេតនា ជាភព** ។ តែក្នុងកវនិទ្ទេស ក្នុងពាក្យថា **សត្តោ** នេះ លោក

បានសម្ដែងទាក់ទងជាមួយនឹង **ព្រះបាលីក្នុងវិភង្គប្បករណ៍** ថា **ចេតនានោះឯង ជាសង្ខារ ចំណែកភព បានដល់ ធម៌ទាំងឡាយដែលសម្បយុត្ត ជាមួយនឹងចេតនា ។** ឯភាពដែលជាសង្ខារ ជាចេតនា ព្រះមុនីបានត្រាស់ទុក **ក្នុងព្រះបាលីវិភង្គប្បករណ៍** ដោយពាក្យជាដើមថា **ក្នុងអភិសង្ខារទាំង ៣ នោះ បុញ្ញាភិសង្ខារដូចម្ដេច បានដល់កុសលចេតនាចំណែកកាមាវចរ ។** ក្នុងសេចក្ដីនោះ លោកពោលទុក **ក្នុងព្រះបាលីបដិសម្ភិទាមគ្គ** ថា ធម៌ទាំងឡាយដែលសម្បយុត្តជាមួយនឹងចេតនា ឈ្មោះថា **ជាសង្ខារ** ដោយកិច្ច គឺការតាក់តែងសង្ខតធម៌ ពោល គឺការប្រមូលមកព្រមទាំងវិបាក ព្រោះមានវិបាកជាធម្មតា ។ **ក្នុងព្រះបាលីវិភង្គប្បករណ៍** លោកពោលថា **ភព** ដោយអត្ថថា ញុំាងឧបបត្តិភពឲ្យមាន ព្រោះជាធម្មជាតិដែលធ្វើឲ្យទៅកាន់ភព គឺដោយជាបច្ច័យដល់ភពថា **កម្ម ដែលធ្វើឲ្យទៅកាន់ភពទាំងពួង ឈ្មោះថា កម្មភព** និងព្រោះជាកម្មដោយភាវៈ ដែលជាសម្ភារៈ ដែលប្រឡូកប្រឡំជាមួយកម្ម ។ ឯកិច្ច គឺការញុំាងឧបបត្តិភពឲ្យមាន ជាកិច្ចពិសេសក្រៃលែងនៃចេតនា ព្រោះហេតុនោះ ក្នុងព្រះបាលីបដិសម្ភិទាមគ្គ ទើបព្រះសារីបុត្រពោលចេតនាថា **ភព** ។ កិច្ច គឺការតាក់តែងភព ជាកិច្ចដ៏ពិសេសក្រៃលែងនៃចេតនា ព្រោះហេតុនោះ ទើបក្នុងព្រះបាលីវិភង្គប្បករណ៍ ត្រាស់ចេតនាថា **សង្ខារ** ដោយពាក្យជាដើមថា **ចេតនាជាកុសល** ដូច្នេះ ។ ព្រោះហេតុនោះ ការពោលធម៌ទាំង ២ ក្នុងទីទាំង ២ កន្លែង ដោយបរិយាយនោះៗ ទើបប្រពៃហើយ ព្រោះហេតុនោះ ក្នុងសេចក្ដីនេះមិនខុស ។ ពាក្យថា **ការប្រាថ្នា ក្នុងឧបបត្តិភពដែលជាផលរបស់កម្មនោះ** សេចក្ដីថា ការសង្ឃឹមចំពោះក្នុងឧបបត្តិភពដែលមានដោយទំនងដូចបានស្ដាប់មក មានពាក្យជាដើមថា **បុគ្គលនោះ រមែងមានការបានស្ដាប់មកថា ពួកទេវតាជាន់ចាតុម្មហារាជិកាមានអាយុវែង មានពណ៌ សម្បូរណ៍ច្រើនទៅដោយសេចក្ដីសុខ** ដូច្នេះ ។ លោកអាចារ្យពោលកាមុបាទាន ដោយកិច្ចថា

**ការកាន់យក** ។ លោកពោលឧបាទានក្រៅអំពីនេះ ដោយកិច្ចថា **ការកាន់យក** ។ ពាក្យថា **ក្នុងទីបំផុតនៃចេតនាដែលប្រមូលទុកក្នុងភព** បានដល់ ក្នុងទីបំផុតនៃការប្រមូលទុកដែលលោកពោលទុកក្នុងអត្ថវិកប្បទាំង ៣ ។

បទថា **ឥធ** សេចក្តីប៉ុនគ្នានឹង **ឥមស្មឹ យោគ បច្ចុប្បន្នភវេ** ប្រែថា ក្នុងបច្ចុប្បន្នភពនេះ ។ ការភ្ជាប់ភពដទៃ គឺអតីតភព និងបច្ចុប្បន្នភពនេះ ឈ្មោះថា **ភវន្តរបដិសន្ធានំ** ប្រែថា ការភ្ជាប់ភពដទៃ ម្យ៉ាងទៀត ការភ្ជាប់ដោយភាពជាចន្លោះ ភព ឈ្មោះថា **ភវន្តរបដិសន្ធានំ** ការភ្ជាប់ដោយភាពជាចន្លោះភព ដោយអំណាចនៃការភ្ជាប់ចំពោះភពដទៃនោះ ឬនៃការភ្ជាប់ដោយភាពជាចន្លោះភពនោះ ។ សម្ពន្ធបាលីថា **យំ បដិសន្ធីតិ វុច្ចតិ តំ វិញ្ញាណំ** ប្រែថា វត្ថុណា ហៅថាបដិសន្ធិ វត្ថុនោះ ជាវិញ្ញាណ ។ ពិតហើយ វិញ្ញាណ លោកពោលថា **មានការតភ្ជាប់ជាបច្ចុប្បដ្ឋាន** ។ ពាក្យថា **ក្នុងគភ៌** គឺក្នុងពោះម្តាយ ឬក្នុងកិរិយាដែលកំណត់ថា គភ៌ ។

លោកអាចារ្យពោលសង្ខារដែលប្រមូលមក ដូចបានពោលទុកក្នុងអត្ថវិកប្បទាំង ២ ថា **ឯបុព្វភាគនៃភពនោះ** ពោលសង្ខារដែលប្រមូលមក ដែលបានពោលទុកក្នុងអត្ថវិកប្បទី ៣ ថា **ដែលសម្បយុត្តជាមួយភពនោះ** ។ ភ្ជាប់សេចក្តីថា អវិជ្ជាដែលសម្បយុត្តជាមួយភពនោះ ក៏រមែងកាន់យកផងនោះឯង ។ ការប្រព្រឹត្តទៅនៃចិត្តរបស់យុវជនច្រើនទៅដោយភវង្គ មិនអាចប្រមូលជនកកម្មក្នុងភពដទៃ ដោយច្រើន ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **ព្រោះអាយតនៈទាំងឡាយឆ្អិនហើយក្នុងភពនេះ** ។ ដោយពាក្យថា **លោកសម្តែងការវង្វេងក្លេច ក្នុងពេលធ្វើកម្មនៃបុគ្គលដែលមានអាយតនៈឆ្អិនហើយ** នោះ លោកអាចារ្យរមែងសម្តែងការវង្វេងក្លេច ដែលជាបច្ច័យដល់កម្ម មិនមែនសម្តែងការវង្វេងដែលសម្បយុត្តជាមួយកម្មនោះឡើយ ។

ក្នុងបណ្តាបច្ចយាការធម៌ទាំងនោះ កម្មសម្ភារៈ អង្គនៃកម្ម ៥ យ៉ាង ក្នុងភព

អំពីមុន ធម៌ គឺវិបាក ៥ យ៉ាង ក្នុងកាលឥឡូវនេះ កម្មសម្ភារៈ អង្គនៃកម្ម ៥ ក្នុងកាលឥឡូវនេះ ធម៌ គឺវិបាក ៥ ក្នុងកាលតទៅ ទើបរួមជាធម៌ ១០ យ៉ាង ចាត់ជាកម្មធម៌ ១០ យ៉ាង ចាត់ជាវិបាក កម្មក្នុងឋានៈ ២ ដូច្នេះ ចាត់ជាកម្មវដ្តៈ វិបាកក្នុងឋានៈ ២ ដូច្នេះ ចាត់ជាវិបាកវដ្តៈ ដូច្នេះ ដូច្នោះ ទើបជាកម្មសង្ខេប ១ វិបាកសង្ខេប ១ ចាត់ជាកម្មភព ១ វិបាកភព ១ កម្មវដ្តៈ ១ វិបាកវដ្តៈ ១ កម្មប្បវត្ត ការប្រព្រឹត្តទៅនៃកម្ម ១ វិបាកប្បវត្ត ការប្រព្រឹត្តទៅនៃវិបាក ១ កម្មសន្តតិ ការបន្តនៃកម្ម ១ វិបាកសន្តតិ ការបន្តនៃវិបាក ១ ចាត់ជាកិរិយា ១ ជាផលនៃកិរិយា ១ ដូច្នេះ ។

ភវចក្រនេះ កើតឡើងយ៉ាងនេះ ប្រកបដោយហេតុ ជាទុក្ខ មិនទៀង ញាប់ញ័រ មានការមិនស្ថិតស្ថេរ ធម៌ទាំងឡាយរមែងកើតឡើងដោយហេតុ តែធម៌ទាំងឡាយក្នុងភវចក្រនេះ មិនមានអត្តាឡើយ ជារបស់ដទៃតែម្យ៉ាង ។ ធម៌ទាំងឡាយ រមែងញុំាងធម៌ទាំងឡាយឲ្យកើត ព្រោះសម្ភារៈ គឺហេតុជាបច្ច័យ ឯព្រះសម្ពុទ្ធត្រាស់ព្រះធម៌ទុក ដើម្បីការរំលត់ហេតុទាំងឡាយ ។ កាលហេតុទាំងឡាយរលត់ហើយ វដ្តៈដាច់ហើយ រមែងមិនវិល មានព្រហ្មចរិយៈក្នុងសាសនានេះ ដើម្បីធ្វើទីបំផុតនៃទុក្ខយ៉ាងនេះ និងកាលមិនមានសត្វ ក៏មិនមានការដាច់សូន្យ មិនមានការទៀង ដូច្នេះឯង ។

ក្នុងបណ្តាពាក្យទាំងនោះ ដែលឈ្មោះថា **កម្មសម្ភារ** ដោយអត្ថថា កម្មនោះឯងរមែងតាក់តែងវិបាក គឺធ្វើឲ្យចម្រើន ម្យ៉ាងទៀត កម្មចាត់ជាសង្ខារភព អវិជ្ជា តណ្ហា និងឧបាទាន ដែលជាអ្នកឧបការៈដល់កម្មនោះ ចាត់ជា **កម្មសម្ភារ** ។ ម្យ៉ាងទៀត ភពដែលឲ្យបដិសន្ធិ ឈ្មោះថា **កម្ម** សង្ខារដែលប្រមូលមកតាមដែលពោលហើយ ដែលជាអ្នកឧបការៈដល់កម្មនោះ និងធម៌ទាំងឡាយ មានអវិជ្ជាជាដើម ឈ្មោះថា **កម្មសម្ភារ** ព្រោះហេតុនោះ កម្មផង កម្មសម្ភារៈផង ឈ្មោះថា **កម្មសម្ភារ** ព្រោះហេតុនោះ គប្បីជ្រាបស័ព្ទថា **កម្មសម្ភារ** ដោយអំណាចជាឯកសេស ។ ពាក្យថា

ធម៌ ១០ យ៉ាង ចាត់ជាកម្ម សេចក្តីថា សូម្បីធម៌ មានអវិជ្ជាជាដើមដែលគប្បីឃើញស្មើនឹងកម្ម និងជាអ្នកឧបការៈដល់កម្មនោះ ព្រោះមានកម្មជាសម្ងាញ់ ហេតុនោះទើបពោលថា **ចាត់ជាកម្ម** ។ ធម៌ទាំងឡាយ មានអវិជ្ជា និងមានវិញ្ញាណជាដើម រមែងសង្គ្រោះចូលក្នុងធម៌ ហេតុនោះ ធម៌នេះ ឈ្មោះថា **សង្ខេប** បានដល់ កម្ម និងវិបាក ។ម្យ៉ាងទៀត ឈ្មោះថា **សង្ខេប** ព្រោះអត្ថថា លោកសង្គ្រោះចូលយ៉ាងនេះថា **កម្ម វិបាក** បានដល់ ធម៌ទាំងឡាយ មានអវិជ្ជា និងវិញ្ញាណជាដើម ។ គប្បីឃើញថា លោកធ្វើជាឯកវចនៈ ដោយភាពជាសង្ខេបស្មើគ្នា ម្យ៉ាងទៀត សង្ខេបសព្ទជាឈ្មោះនៃចំណែក ព្រោះហេតុនោះ ទើបចំណែកនៃកម្ម ឈ្មោះថា **កម្មសង្ខេប** ។

ពាក្យថា **កើតឡើងយ៉ាងនេះ** គឺវិបាកកើតឡើងព្រោះកម្ម ។ ក្នុងសេចក្តីនោះក៏មានអត្ថថា ភវចក្រនេះ កើតឡើងយ៉ាងនេះថា សង្ខារកើតឡើង ព្រោះអវិជ្ជា ឬកើតឡើងដោយអំណាចសន្ធិ ៣ ជាដើម អធិប្បាយថា បានដល់ ភវចក្រ ។ ពាក្យថា **មានការទៅ** គឺមានការទៅជាធម្មតា អធិប្បាយថា មានការវិនាសទៅជាធម្មតា ។ ដោយហេតុនោះ ទើបលោកសម្តែងការៈ គឺជាធម្មជាតិមិនតាំងនៅក្នុងកាលដទៃ ដោយសព្ទថា មិនទៀង ដែលសម្តែងដល់ធម្មជាតិ មានការកើតឡើង និងវិនាសទៅជាទីបំផុត និងដោយសព្ទថា **ញាប់ញ័រ** ដែលសម្តែងដល់ការប្រែប្រួល ។ ដោយពាក្យថា **មិនស្ថិតស្ថេរ** នេះ លោករមែងសម្តែងដល់ធម្មជាតិមិនមានសារៈ គឺការមាំមួន ។ សម្ភារៈ គឺហេតុ ឈ្មោះថា **ហេតុសម្ភារ** ប្រែថា សម្ភារៈ គឺហេតុ ។ ម្យ៉ាងទៀត ឋានៈដែលលោកពោលទុកយ៉ាងនេះ ក្នុងពាក្យនេះថា **ដោយឋានៈ ដោយហេតុ** ឈ្មោះថា **សម្ភារៈ** ហេតុទូទៅនៃឋានៈនោះៗ សូម្បីដទៃ ក៏ឈ្មោះថា **សម្ភារៈ** ហេតុដែលមិនទូទៅ ឈ្មោះថា **ហេតុ** ។ ពាក្យថា **យ៉ាងនេះ** សេចក្តីថា ញាណត្រឹមតែធម៌ដោយហេតុយ៉ាងនេះ អធិប្បាយថា កាល មានការកាត់វដ្តៈ ព្រោះរលត់ហេតុ និងកាល បាន

សម្តែងធម៌ដើម្បីរំលត់ហេតុនោះ ។ **ព្រហ្មចរិយំ** ឥធ សម្រេចរូបជា **ព្រហ្មចរិយមិធ** ប្រែថា ព្រហ្មចរិយៈក្នុងសាសនានេះ ។ ច-ស័ព្ទ ក្នុងពាក្យថា **ព្រហ្មចរិយមិធ សត្តេ ច** នេះ មានអត្ថថា **មានព្រហ្មចរិយៈនៅយ៉ាងនេះ ដោយមិនមានការទៀង និងមិនមានការដាច់សូន្យផង** ។ មានអធិប្បាយថា កាលមានត្រឹមតែធម៌ដែលទាក់ទងដោយហេតុយ៉ាងនេះ ទើបសត្វមិនមាន និងកាលសត្វនោះមាន ក៏គប្បីមានការទៀង ឬការដាច់សូន្យ ព្រោះហេតុនោះ កាលសត្វមិនមាន ទើបមិនមានការដាច់សូន្យ មិនមានការទៀង ។

បទថា **សច្ចប្បភវតោ** ប្រែថា ដោយកើតអំពីសច្ចៈ ឬប្រែថា ដោយកើតនៃសច្ចៈទាំងឡាយក៏បាន ។

ពាក្យថា **កម្មទាំងកុសល និងអកុសល** ធ្វើឲ្យយល់ថា កម្មដែលនៅមានអាសវៈ ព្រោះប្រព្រឹត្តទៅក្នុងកថាដោយវដ្តៈ ។ ពាក្យថា **ដោយមិនផ្សេងគ្នា** សេចក្តីថា មិនបានធ្វើភាពផ្សេងគ្នាថា **ចេតនាធម៌ទាំងឡាយ ដែលសម្បយុត្តជាមួយចេតនា** កម្មទាំងដែលជាកុសល និងអកុសលទាំងអស់នោះ លោកពោលថា ជាសមុទយសច្ច ។ អធិប្បាយថា លោកពោលទុកមិនបានធ្វើភាពផ្សេងគ្នាថា ជាចេតនា និងធម៌ដែលសម្បយុត្តជាមួយចេតនាថា **តណ្ហា កិលេសដ៏សេស អកុសលធម៌ដ៏សេស កុសលមូល ៣ ដែលជាអារម្មណ៍របស់អាសវៈ កុសលធម៌ដែលជាអារម្មណ៍នៃអាសវៈដ៏សេស** ដូច្នេះ ម្យ៉ាងទៀត លោកពោលថា ជាសមុទយសច្ច ដោយមិនបានធ្វើការផ្សេងគ្នាថា ជាអរិយសច្ច ។ **ក្នុងសច្ចវិភង្គ** កិលេសទាំងអស់ កម្មដែលធ្វើឲ្យទៅកាន់ភពទាំងអស់ ត្រាស់ថា **ជាសមុទយសច្ច** ។ ឈ្មោះថា **ទុតិយ សច្ចប្បភវំ** ដោយអត្ថថា មានទុតិយសច្ចជាដែនកើត ។ លោកពោលថា **ជាបឋមសច្ចៈ និងទុតិយសច្ចៈទាំងពីរ** ព្រោះលោកមានបំណងយកឧបបត្តិភព និងកម្មភពថា ព្រោះឧបាទានជាបច្ច័យ ទើបមានភព ដូច្នេះ ។

ពាក្យថា **ក្នុងវត្ថុទាំងឡាយ** បានដល់ ក្នុងវត្ថុទាំងឡាយដែលជាអារម្មណ៍ ឬដែលគប្បីបិទបាំងក្នុងសច្ចៈ មានទុក្ខជាដើម ។ ពាក្យថា **រមែងឲ្យវង្វេង** សេចក្ដីថា កាលមិនឲ្យដឹង គឺដើម្បីចាក់ចុះសភាវៈនៃធម៌ ឈ្មោះថា រមែងធ្វើឲ្យវង្វេងដោយអំណាចបិទបាំងភាវៈនៃធម៌នោះ អារម្មណ៍លោកបំណងយកក្នុងពាក្យថា **វត្ថុ** នេះ ។ ឈ្មោះថា **រមែងឧបត្ថម្ភគ្នានឹងគ្នា** ដូចបុរស ២ កំណាត់ វៀរចាកទីអាស្រ័យគ្នានឹងគ្នា មិនអាចតាំងនៅបាន ។ ពាក្យថា **ក្នុងវិស័យរបស់ខ្លួន** គឺក្នុងអាយតនៈ មានរូបាយតនៈជាដើម ដែលជាវិស័យតាមគួរដល់ខ្លួន ។ ជាតិដែលបានដោយការផ្លាស់ប្ដូរនៃខន្ធទាំងឡាយដែលកើត រមែងហាក់ដូចញ៉ាំងខន្ធទាំងនោះឲ្យកើត ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **រមែងញ៉ាំងខន្ធទាំងឡាយឲ្យកើត** ។ ដោយហេតុនោះ ទើបលោកអាចារ្យពោលថា **ព្រោះប្រព្រឹត្តទៅដោយជាអាការកើតឡើងនៃខន្ធទាំងឡាយនោះ** ។ សូម្បីក្នុងពាក្យថា **គ្របយកភាវៈ គឺការឆ្អិន និងការបែកធ្លាយ** នេះ បណ្ឌិតគប្បីកាន់យកអត្ថតាមន័យដែលពោលហើយ ក្នុងពាក្យថា **រមែងញ៉ាំងខន្ធទាំងឡាយឲ្យកើតនោះឯង** អធិប្បាយថា រមែងប្រព្រឹត្តទៅដោយអំណាចការឆ្អិន និងការបែកធ្លាយនោះឯង ។ ឈ្មោះថា **ឆ្អិន** ព្រោះមានអត្ថថា ទុំ ឈ្មោះថា **បែកធ្លាយ** ព្រោះមានអត្ថថា ធ្លាយ ការឆ្អិនផង ការបែកធ្លាយផង ឈ្មោះថា **ការឆ្អិន និងការបែកធ្លាយ** អធិប្បាយថា ភាវៈនៃការឆ្អិន និងការបែកនោះ ក៏គឺការឆ្អិន និងការបែកធ្លាយ ។ ពាក្យថា **ព្រោះជាទីតាំងនៃបកិណ្ណកទុក្ខ មានសោកជាដើម** អធិប្បាយថា ព្រោះជាហេតុនៃបកិណ្ណកទុក្ខ មានសោកជាដើមនោះ និងរមែងជាបច្ច័យ ដើម្បីការប្រាកដក្នុងភពដទៃ ដោយសង្ខារដែលប្រកបជាមួយអវិជ្ជាដែលសម្រេចមកអំពីបកិណ្ណកទុក្ខ មានសោកជាដើមនោះ ។ ម្យ៉ាងទៀត ចុតិចិត្ត រមែងជាអនន្តរប្បច្ច័យដល់បដិសន្ធិវិញ្ញាណ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **និងរមែងជាបច្ច័យដើម្បីការប្រាកដក្នុងភពដទៃ** ។

លោកអាចារ្យពោលថា **ព្រោះជាទីតាំងនៃបកិណ្ណកទុក្ខ មានសោកជាដើម** ដើម្បីសម្តែងភាវៈដែលមានសម្ភាញ់ថា ចុតិចិត្តនោះ វៀរអវិជ្ជា និងសង្ខារ រមែងមិនជាបច្ច័យដល់ភពដទៃ ។ បទថា **ទ្វេធា** ប្រែថា ពីរចំណែក ពីរចំណែក គឺដោយសភាវៈជារបស់ខ្លួន និងដោយភាពជាបច្ច័យដល់ធម៌ដទៃ ។ ជាការសម្តែងដោយ **ព្យាបន្និច្ឆាលោបវិធី** គឺការលុប អត្ថដែលត្រូវការដោយការយល់ដ៏ជ្រួតជ្រាប ។

ដោយពាក្យថា **ព្រោះអវិជ្ជាជាបច្ច័យ ទើបមានសង្ខារ** នេះ លោកអាចារ្យរមែងសម្តែងថា មានពាក្យសួរថា **នរណាហ្ន៎ រមែងតាក់តែង ដូច្នេះ ? ចម្លើយថា បញ្ហានេះ មិនគួរដោះស្រាយ** ដូច្នេះ ដោយការសម្តែងសង្ខារ ជាធម៌កើតអំពីបច្ច័យ ដោយហេតុនោះ ពាក្យថា **ព្រោះអវិជ្ជាជាបច្ច័យ ទើបមានសង្ខារនេះ ទើបជាគ្រឿងរារាំង ការយល់ឃើញថា មានអ្នកសាង** ។ ការឃើញថា **អត្តា** រមែងរំកិលចាកភពទៅកាន់ភពដទៃ ឈ្មោះថា **អត្តសង្កន្តិទស្សនំ** ការឃើញថា អត្តារំកិល ការឃើញថា អត្តារំកិលនោះ រមែងត្រូវបដិសេធហើយ ដោយការពោលដល់ការកើតឡើងនៃវិញ្ញាណ ព្រោះសង្ខារជាបច្ច័យ ។ ការប្រកាន់ថា អត្តាជារបស់មួយ ព្រោះការមិនបែកគ្នានៃខន្ធ ៥ ឈ្មោះថា **ឃនសញ្ញា** ការសម្គាល់ថា **ជាដុំ** ។ ការប្រកាន់នោះរមែងត្រូវបដិសេធហើយ ដោយការពោលថា **នេះត្រឹមតែ ព្រោះមានវិញ្ញាណជាបច្ច័យ ទើបមាននាមរូប** ដូច្នេះ ដូចដែលទម្លាយកំពីងត្នោតទាំងគូ ដូច្នោះ ។ ដោយពាក្យនេះថា **ជាគ្រឿងរារាំងការឃើញជាដើមយ៉ាងនេះ** លោកអាចារ្យពោលថា គ្រឿងរារាំងការឃើញជាដើមថា **បុគ្គលមានទុក្ខ រមែងសោយសោក រមែងកន្ទក់កន្ទេញ** ដូច្នេះ។ សូម្បីធម៌ទាំងឡាយ មានសោកជាដើម ក៏ទាក់ទងដោយបច្ច័យ មិនមានបុគ្គលណាឲ្យប្រព្រឹត្តទៅក្នុងអំណាច ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ទុកដោយពាក្យនេះថា **ព្រោះជាតិជាបច្ច័យ ទើបមានជរា មរណៈ សោក ។បេ។** នោះឯង ដូច្នេះ ។

ពាក្យថា **សូម្បីដោយជាគ្រឿងរាំងការយល់ខុស** គឺដោយជាគ្រឿងរាំងសេចក្តីប្រកាន់ខុស មានប្រការផ្សេងៗ ថា មានអ្នកសាងជាដើម ។

ដោយពាក្យថា **ដោយអំណាចលក្ខណៈរបស់ខ្លួន និងសាមញ្ញលក្ខណៈ** នេះ លោកអាចារ្យពោលការមិនឃើញតាមសេចក្តីពិតនូវធម៌ទាំងឡាយ ព្រោះភាវៈដែលគប្បីឃើញដោយបរមត្ថ ក្នុងធម៌ទាំងឡាយ ដែលផុតចាកលក្ខណៈទាំងពីរនោះមិនមានដោយប្រការទាំងពួង ។ ឈ្មោះថា **ដូចការរអិលជើង** ព្រោះជាហេតុឲ្យកើតទុក្ខ ។ ឈ្មោះថា **ដូចការដួល** ព្រោះធ្វើឲ្យធ្លាក់ទៅក្នុងភពដទៃ ។ ឈ្មោះថា **ដូចការកើតជាមុខដំបៅ** ព្រោះប្រកបដោយការពើតផ្សា គឺសេចក្តីទុក្ខ និងព្រោះហូរចេញនូវវត្ថុដែលមិនស្អាត គឺកិលេស ។ ពាក្យថា **ដូចបូសដែលបែក** គឺដូចពកតូចដែលកើតលើបូសនោះ ក្នុងកាលបូសហើម ដើម្បីការបែក ឬដូចពកក្នុងបូសផ្សេងគ្នាច្រើនយ៉ាង ។ **ផស្សៈ** ព្រោះជាធម៌មានកិច្ចប៉ះខ្ទប់ **ទើបប្រៀបដូចការប៉ះខ្ទប់** ។ម្យ៉ាងទៀតបទថា **យដ្ឋនទុក្ខំ វិយ** ប្រែថា កាលសេចក្តីទុក្ខកើតអំពីការប៉ះខ្ទប់ ព្រោះវេទនាទាំង ៣ ជាសេចក្តីទុក្ខ ទាក់ទងជាមួយទុក្ខ ៣ យ៉ាង ។ ពាក្យថា **ដូចការប្រាថ្នានឹងដោះស្រាយទុក្ខ** លោកអាចារ្យពោលដោយភាវៈជាគំរូមួយ ចំណែកនៃការសង្គ្រោះ។ ឈ្មោះថា **ដូចការស្រវាយកថ្នាំស្ងែង ( ចំណីទាស់ )** ព្រោះជានិមិត្តនៃការកើតឡើងនៃអនត្ថៈច្រើនយ៉ាង ។ ឈ្មោះថា **ដូចការលាបថ្នាំទាស់** ព្រោះញ៉ាំងហេតុនៃសេចក្តីទុក្ខឲ្យតាំងចុះក្នុងសន្តានរបស់ខ្លួន ឈ្មោះថា **ដូចកើតដំបៅក្លាយ** ព្រោះភាពដែលបូស គឺអត្តភាពជាការពិការ គឺការកើតឡើង និងព្រោះបូស គឺអត្តភាពនោះ មានការប៉ោងឡើងជាដើម ព្រោះភាពពិការ គឺការកើតឡើងនោះ ជានិមិត្ត ។ ឯការគុំជាខ្ទុះ គឺមានឫសជាដើម គឺការហើមឡើង ឈ្មោះថា បូសក្លាយ ។ ការបែកនៃបូសដោយសភាវៈវៀរការទុំ រមែងមិនមាន ព្រោះហេតុនោះ ទើបលោកកាន់យកសូម្បីការទុំនៃបូសនោះ

ដោយសព្ទថា **បែក** ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **ជរា និងមរណៈ** ប្រៀបដូចការបែកនៃបូស ។ម្យ៉ាងទៀត គប្បីជ្រាបថា ការដែលបូសដល់នូវការប្រែប្រួលទៅ និងបែកទៅ ឈ្មោះថា **ការបែកនៃបូស** ការដល់នូវភាពប្រែប្រួលក្នុងការបែកធ្លាយនៃបូសនោះ ក៏ជាការទុំនៃបូស ។

លោកអាចារ្យកាលនឹងធ្វើឲ្យយល់ភវចក្រ ដោយឧបមាទាំងឡាយ កាលធ្វើឲ្យយល់ភវចក្រនោះ ដោយឧបមាផ្សេងៗ ដែលមានការទទួលទ្រ តែម្យ៉ាងហើយ ឥឡូវនេះ មានបំណងធ្វើឲ្យយល់ដោយឧបមា ដែលមានទីទទួលទ្រផ្សេងៗ ទើបពោលពាក្យជាដើមថា **ន័យម្យ៉ាងទៀត ហេតុណា** ដូច្នេះ ។

អធិប្បាយក្នុងពាក្យទាំងនោះតទៅ បុគ្គលដែលមានភ្នែក ត្រូវជញ្ជាំងបិទបាំងហើយ រមែងមិនឃើញរូបទាំងឡាយ សូម្បីឃើញខ្លះ ក៏ឃើញខុសទៅ បុគ្គលដែលត្រូវអវិជ្ជាបិទបាំង ក៏ប្រៀបដូច្នោះ រមែងមិនបដិបត្តិ គឺមិនឃើញទុក្ខសច្ចជាដើម ឬបដិបត្តិខុសទៅ ព្រោះហេតុនោះ ទើប **អវិជ្ជា** ប្រៀបដូចជញ្ជាំង ។ **សង្ខារទាំងឡាយ** ឈ្មោះថា **ប្រៀបដូចចំណែកមួយនៃសម្បុកជន្លួនទាង** ព្រោះអត្តា **ប្រៀបដូចជន្លួនទាង** សាងឡើងមក និងព្រោះជាហេតុវិលវល់ទៅនៃវដ្ដៈ គឺនៃអត្តានោះឯង ។ **វិញ្ញាណ** វៀរការគ្រប់គ្រងនៃសង្ខារ ក៏មិនបានទីអាស្រ័យ **ប្រៀបដូចព្រះរាជកុមារវៀរចាកការការពារនៃរេហ៍ពល ក៏មិនបានទីអាស្រ័យ** ព្រោះហេតុនោះ ការវៀរចាកការគ្រប់គ្រងមិនបានទីអាស្រ័យ ទើបជាការស្មើគ្នានៃពាក្យឧបមាឧបមេយ្យក្នុងទីនេះ ។ លោកអាចារ្យពោលដល់អារម្មណ៍ មានកម្មជាដើមថា **និមិត្តនៃឧបបត្តិ** ។ បទថា **បរិកប្បនតោ** ប្រែថា ព្រោះធ្វើឲ្យជាអារម្មណ៍ ឬប្រែថា ព្រោះត្រាច់ទៅដោយវិតក្កដែលសម្បយុត្តគ្នា ។ **នាមរូបប្រៀបដូចកលមាយា** ព្រោះមានច្រើនប្រការជាដើមថា ជាទេវតា ជាមនុស្ស ជាម្រឹគ និងជាបក្សី ។ **សឡាយតនៈ** ឈ្មោះថា **ប្រៀបដូច**

គុម្ពឈើក្នុងព្រៃ ព្រោះដល់នូវការផ្សេងគ្នានៃការចម្រើន ដោយភាពផ្សេងៗ នៃទីតាំងអាស្រ័យ ។ អាយតនៈទាំងឡាយដែលជាធម៌ទទួលអារម្មណ៍បាន និងជាធម៌ដែលជាអារម្មណ៍ មកជួបគ្នានឹងគ្នា ឈ្មោះថា **ការប៉ះខ្ទប់នៃអាយតនៈ** ។ ព្រោះហេតុនោះទើប **ផស្សៈ** ឈ្មោះថា **ប្រៀបដូចភ្នែង** ព្រោះការប៉ះខ្ទប់គ្នានៃអាយតនៈ ព្រោះទាំងពីរចំណែកកើតពីការកួតគ្នា និងព្រោះជាហេតុនៃទុក្ខ គឺវេទនា ។ **វេទនាប្រៀបដូចកម្តៅ** ព្រោះមានការក្តៅ ។ ការសោយអារម្មណ៍ ប្រៀបដូចការផឹកទឹកអំបិល ព្រោះការចម្រើនច្រើននៃតណ្ហា ។ **តណ្ហាប្រៀបដូចការស្រេក** ព្រោះត្រូវការផឹកក្នុងអារម្មណ៍ ។ បទថា **តទស្សុបាទានំ** កាត់បទជា **តំ អស្ស ឧបាទានំ តំ យោគ អភិលាសករណំ** លម្អិតចេញជា **តណ្ហាទិដ្ឋាភិនន្ទនំ** ការធ្វើសេចក្តីប្រាថ្នានោះ គឺការត្រេកអរក្នុងវត្ថុដែលតណ្ហាបានឃើញជាឧបាទានរបស់បុគ្គល ដែលមានសេចក្តីដល់ព្រមដោយតណ្ហានោះម្យ៉ាងទៀត កាត់ចេញជា **តទស្ស ឧបាទានំ** ប្រែថា ការធ្វើសេចក្តីប្រាថ្នានោះគប្បីជាឧបាទាន **អស្ស** ខែជា **ភវេយ្យ** ។ ការប្រកាន់កពុកប្រៀបដូចត្រីទាញផ្ទៃសន្ទូចទុក ព្រោះការមិនដឹងភាវៈ គឺការនាំមកនូវសេចក្តីវិនាស ។ ក្នុងអធិការនេះ ឧបមាម្យ៉ាងពីរគប្បីជ្រាបថា លោកពោលទុក ព្រោះធម៌ទាំងឡាយ មានសន្ទារជាដើមជាសភាវៈដែលដូចគ្នានឹងឧបមាម្យ៉ាងពីរ មានចំណែកមួយនៃសម្បុកដង្កូវនាង និងពលរេហ៍ជាដើម ។

វត្ថុខ្លះមិនជ្រៅឡើយ តែប្រាកដដូចជ្រៅ ដូចជាថ្លុកទឹកលើភ្នំដែលពេញទៅដោយស្មៅ និងស្លឹកឈើចាស់ៗ ជាដើម បដិច្ចសមុប្បាទមិនដូច្នោះឡើយ ។ បដិច្ចសមុប្បាទធម៌នេះ រមែងប្រាកដ គឺបង្ហាញច្បាស់ សម្លឹងឃើញបានថា ជាធម៌ ជ្រៅតែម្យ៉ាង ព្រោះហេតុនោះ ទើបឈ្មោះថា **គម្ភីរាវភាសោ** ប្រែថា ប្រាកដជាធម៌ ជ្រាលជ្រៅ ។ បទថា **យថារហំ** ប្រែថា តាមសមគួរទាក់ទងជាមួយអត្ថជាដើម ។

កាលចុះស័ព្ទ អវធារណៈថា **ជាតិតោ ជរាមរណំ ន ន ហោតិ ហោតិ ឯវ** ប្រែថា ជរាមរណៈ នឹងមិនមានមកអំពីជាតិ ក៏ទេ ដូច្នេះ កាលមានសេចក្តីសង្ស័យថា **ជរាមរណៈ មានមកអំពីជាតិ ឬហ្ន៎ ! ឬមានមកអំពីហេតុដទៃក៏បាន** ដើម្បីបដិសេធសេចក្តីសង្ស័យដូច្នោះ ទើបលោកអាចារ្យពោលថា **វៀរជាតិចេញជរាមរណៈមិនមានមកអំពីហេតុដទៃឡើយ** ដូច្នេះ ។ ក្នុងពាក្យនោះ ស័ព្ទថា **ហេតុដទៃ** ជាពាក្យមានការប្រកបចំពោះជាតិជាវិស័យ មិនមែនជាពាក្យមានត្រឹមតែហេតុដទៃជាវិស័យឡើយ ព្រោះពោលទុកថា **វៀរជាតិចេញ** ដូច្នេះ ។ ដោយពាក្យនោះ រមែងមិនបដិសេធហេតុដទៃរបស់ជរាមរណៈនោះ ដែលជាហេតុ មានការជ្រើសរើសគ្នាជាមួយជាតិនោះឡើយ ។ សូម្បីក្នុងបទដទៃក្រៅអំពីនេះ ក៏មានន័យនេះ ។ បទថា **ឥត្ថំ** ប្រែថា ប្រការនេះ អធិប្បាយថា ដោយប្រការដូច្នេះ ។ បទថា **ជាតិប្បច្ចយសម្ភូតសមុទាគតដ្ឋោ** សេចក្តីថា ភាវៈដែលជរាមរណៈ ជាធម្មជាតិមាន ព្រោះជាតិ ជាបច្ច័យប្រព្រឹត្តទៅរួមគ្នា សមគួរដល់បច្ច័យរបស់ខ្លួន មកហើយក្រែលែងឡើងៗ អធិប្បាយថា អត្ថថា **ជរាមរណៈ** ប្រព្រឹត្តទៅដោយលំដាប់ ។ ម្យ៉ាងទៀត អត្ថថា **ជរាមរណៈ** មានឡើងដោយអត្ថថា **ជរាមរណៈ** កើតឡើងដោយឈ្មោះថា **សម្ភូតសមុទាគតដ្ឋោ** អត្ថថា **ជរាមរណៈ** មានឡើង និងកើតឡើង ។ លោកអាចារ្យពោលអត្ថថា **ជរាមរណៈ** មានឡើង ព្រោះជាតិជាបច្ច័យថា **ជរាមរណៈរមែងមានអំពីជាតិ វៀរជាតិចេញហើយ ជរាមរណៈមិនមានហេតុដទៃឡើយ** ដូច្នេះ ។ ពាក្យថា **ជរាមរណៈរមែងកើតឡើងអំពីជាតិដោយប្រការដូច្នេះ** សេចក្តីថា បានដល់ អត្ថថា **កើតឡើង** ព្រោះជាតិជាបច្ច័យ គឺជាតិណាមួយមាន និងជាបច្ច័យ ដោយប្រការណាមួយ ភាវៈដែលប្រាកដសមគួរដល់ជាតិ និងប្រការនោះ ។ ក្នុងបណ្តាពាក្យទាំងនោះ ដោយពាក្យថា **ជរាមរណៈមានមកអំពីជាតិ** នេះ លោកអាចារ្យរមែងសម្តែងជរាមរណៈមិនប្រែប្រួល ព្រោះជាធម្មជាតិ

មានជាតិជាបច្ច័យ ដោយពាក្យថា **វៀរជាតិចេញជរាមរណៈ មិនមានមកអំពីហេតុដទៃឡើយ** នេះ លោកអាចារ្យរមែងសម្តែងដល់ភាពជាធម្មជាតិមិនជាដទៃ ដោយពាក្យថា **ហើយជរាមរណៈ រមែងកើតឡើងអំពីជាតិ ដោយប្រការដូច្នេះ** នេះ លោកអាចារ្យរមែងសម្តែងដល់ធម្មជាតិពិត ។ ហើយដោយពាក្យនោះ លោកអាចារ្យរមែងសម្តែងថា បច្ចយធម៌ទាំងឡាយ ព្រោះជាបច្ច័យដល់បច្ចយុប្បន្នធម៌ទាំងឡាយរបស់ខ្លួន ដោយប្រការណា ភាពជាធម្មជាតិមិនប្រែប្រួលទៅជាដទៃ ក៏រមែងមានដោយប្រការនោះ សូម្បីបច្ចយុប្បន្នធម៌ទាំងឡាយក្នុងភាវៈនោះ ក៏មានយ៉ាងនោះ ។ សូម្បីក្នុងបទដ៏សេស ក៏មានន័យនេះ ។ សួរថា ពាក្យថា **ការដឹងក្នុងផល ដែលកើតអំពីហេតុ ឈ្មោះថា អត្ថប្បដិសម្ភិទា** នេះ គប្បីដឹងអត្ថជាផលដែលកើតអំពីហេតុបានដូចម្តេច ? ឆ្លើយថា គប្បីដឹងបាន ព្រោះជាអត្ថដែលលោកអាចារ្យ កាលសម្តែងអត្ថចំពោះបទជាចំណែកបន្ទិចបន្តួចនៃបទសមាសនេះថា **អត្ថប្បដិសម្ភិទា** បានពោលទុកថា **ហេតុផលេញាណំ** ការដឹងក្នុងផលដែលកើតអំពីហេតុ ។ ព្រោះថា ក្នុងពាក្យថា **ការបែកធ្លាយក្នុងអត្ថ ឈ្មោះថា អត្ថប្បដិសម្ភិទា** នេះ លោកអាចារ្យកាលសម្តែងអត្ថរបស់ពាក្យនេះថា **ក្នុងអត្ថ** បានពោលថា **ក្នុងផលនៃហេតុ** កាលសម្តែងអត្ថរបស់បទថា **បដិសម្ភិទា** ប្រែថា ការបែកធ្លាយនេះ ក៏បានពោលថា **ញាណំ** ប្រែថា ការដឹង ព្រោះហេតុនោះ ស័ព្ទថា **ផលដែលកើតអំពីហេតុ និងអត្ថ ទើបមានអត្ថតែមួយ** លោកអាចារ្យកាលពោលអត្ថថា **ញាណប្បដិសម្ភិទា** ក៏បានឲ្យសម្រេចភាពដែលអត្ថជាផល ដែលកើតអំពីហេតុ ។

ពាក្យថា **ដោយអាការណា** គឺដោយអាការនៃការប្រព្រឹត្តទៅទាំងឡាយណា ។ ឯសភាវធម៌ទាំងឡាយ រមែងជាអាការពិសេស ដោយអាការនៃការប្រព្រឹត្តទៅដែលសម្រេចដោយការផ្សេងគ្នានៃបច្ច័យ ។ ដោយហេតុនោះ ទើបព្រះធម្មសេនាបតីសារីបុត្រ

ពោលថា ធម៌ទាំងឡាយរមែងមកកាន់គន្លងក្នុងមុខ គឺញាណរបស់ព្រះសម្មាសម្ពុទ្ធដោយអាការទាំងពួង ។ បទថា **យទវត្ថា** សេចក្តីថា ដែលកំណត់ចុះដោយស្ថានឯណា ។ ឯធម៌ទាំងឡាយ ដែលមានការផ្សេងគ្នានៃស្ថាន រមែងជាធម៌អាចញុំាងកិច្ចនៃប្រយោជន៍នោះឲ្យសម្រេចដោយការផ្សេងគ្នានៃស្ថាននោះៗ ។អាការនៃការប្រព្រឹត្តទៅនិងការផ្សេងគ្នានៃស្ថាននេះជាសភាវៈដែលមានទីអាស្រ័យ ដែលញាណមិនគប្បីបាន ព្រោះជាធម៌ដែលបុគ្គលអ្នកមិនមាន កុសលសម្ភារៈដែលបានសន្សំទុក សូម្បីព្រោះអវិជ្ជាគប្បីស្ទង់ដឹងបានលំបាកនោះឯង ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **អត្ថ គឺអវិជ្ជាជាបច្ច័យដល់សង្ខារ** ឈ្មោះថា ជាធម៌ជ្រាលជ្រៅ **ព្រោះអវិជ្ជាជាបច្ច័យដល់សង្ខារនោះ ដោយអាការណា និងស្ថានណា អាការនោះ និងស្ថាននោះ ដឹងបានលំបាក** ដូច្នេះ ។ **តស្ស យោគ អាការស្ស** និង **អវត្ថាយ** នៃអាការនោះ នៃស្ថាននោះ ។ ក្នុងពាក្យថា **ហេតុម្ហិ ញាណំ** ការដឹងក្នុងហេតុនេះ បណ្ឌិតគប្បីជ្រាបហេតុជាពាក្យបរិយាយនៃធម៌តាមន័យ ដែលបានពោលហើយនោះឯង ។

បទថា **អស្ស យោគ បដិច្ចសមុប្បាទស្ស** ប្រែថា នៃបដិច្ចសមុប្បាទនោះ ។ ពាក្យថា **ដោយហេតុនោះ** សេចក្តីថា ដោយហេតុ ពោល គឺភាវៈដែលមានគុណសមគួរដល់ការត្រាស់ដឹងរបស់វេនេយ្យសត្វនោះៗ ។ បទថា **តត្ថ** សេចក្តីប៉ុនគ្នា នឹង **តស្មឹ យោគ តេសនប្បការេ** ប្រែថា ក្នុងប្រការនៃការសម្តែងនោះ ។ ពាក្យថា **ទាំងដោយអនុលោម និង បដិលោម** សេចក្តីថា ក្នុងទីនេះ ព្រះមានព្រះភាគទ្រង់ត្រាស់បដិច្ចសមុប្បាទដែលជាអនុលោម ពោល គឺការកើតឡើងនៃបច្ចយុប្បន្នធម៌ ព្រោះការកើតឡើងនៃបច្ចយធម៌ និងត្រាស់បដិច្ចសមុប្បាទដែលជាបដិលោម ពោល គឺការរលត់នៃបច្ចយុប្បន្នធម៌ ព្រោះការរលត់នៃបច្ចយធម៌ក៏ទេ ។ តែទ្រង់បានត្រាស់បដិច្ចសមុប្បាទ ដែលជាអនុលោមអំពីខាងដើមទៅដល់ទីបំផុត និងបដិច្ចសមុប្បាទ

ដែលជាបដិលោមអំពីទីបំផុតទៅដល់ខាងដើម ។ ឈ្មោះថា ទ្រង់សម្ដែងទាំងសន្ធិ ៣ សង្ខេប ៤ ព្រោះទ្រង់សម្ដែងជាអនុលោមតាំងអំពីដើមទៅ និងព្រោះទ្រង់សម្ដែងជាបដិលោមតាំងអំពីទីបំផុតទៅ ។ ឈ្មោះថា **ទ្រង់សម្ដែងសន្ធិ ២ សង្ខេប ៣** ព្រោះទ្រង់សម្ដែងជាបដិលោម តាំងអំពីពាក់កណ្ដាលទៅជាដើមថា **អាហារ ៤ នេះ មានអ្វីជាហេតុ** ដូច្នេះ និងព្រោះទ្រង់សម្ដែងជាអនុលោមជាដើមថា **ព្រោះអាស្រ័យចក្ខុនិងរូប ទើបកើតចក្ខុវិញ្ញាណ ធម៌ ៣ យ៉ាងប្រជុំគ្នា ទើបកើតផស្សៈ ព្រោះសម្ផស្សជាបច្ច័យ ទើបមានវេទនា** ដូច្នេះ ។ ឈ្មោះថា **ទ្រង់សម្ដែងសន្ធិ ១ សង្ខេប ២** ដូចក្នុងពាក្យជាដើមថា ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុឃើញការពេញចិត្តរឿយៗ ក្នុងធម៌ទាំងឡាយ ដែលជាបច្ច័យនៃសំយោជនៈ តណ្ហារមែងចម្រើន ព្រោះតណ្ហាជាបច្ច័យទើបមានឧបាទាន ដូច្នេះ ។ ក្នុងព្រះសូត្រខ្លះ ទ្រង់សម្ដែងបដិច្ចសមុប្បាទមានអង្គ ១ ក៏មាន បដិច្ចសមុប្បាទមានអង្គ ១ នោះ ទ្រង់សម្ដែងទុកដោយន័យជាដើមថា **ម្នាលភិក្ខុទាំងឡាយ អរិយសាវកដែលបានស្ដាប់ រមែងដាក់ចិត្តដោយឧបាយដល់បដិច្ចសមុប្បាទក្នុងរាងកាយ និងចិត្តដែលតថាគតពោលមកនោះ** ដូច្នេះ ។

សភាវៈនៃធម៌ មានអវិជ្ជាជាដើម ដែលយោគាវចររមែងចាក់ធ្លុះ ហេតុនោះទើបសភាវៈនោះ ឈ្មោះថា **បដិវេធ** ប្រែថា ដែលយោគាវចរចាក់ធ្លុះ ។ សេចក្ដីនេះសមដូចពាក្យដែលលោកពោលទុកក្នុង **អដ្ឋកថា** ដូច្នេះថា **ម្យ៉ាងទៀត សភាវៈដែលមិនវិបរិត ពោល គឺលក្ខណៈរបស់ខ្លួន ដែលគប្បីចាក់ធ្លុះនៃធម៌ដែលលោកពោលទុកក្នុងទីនោះៗ ឈ្មោះថា បដិវេធ ។ អត្ថ គឺការមិនដឹង** នៃអវិជ្ជាជា បដិបក្ខចំពោះញាណដែលមានការដឹងជាលក្ខណៈ ។ **អត្ថ គឺការមិនឃើញ** ជាបដិបក្ខចំពោះញាណដែលជាគ្រឿងឃើញ ដោយការធ្វើអារម្មណ៍ឲ្យប្រចក្ស ។ អវិជ្ជានេះ រមែងមិនឲ្យចាក់ធ្លុះសភាវៈតាមសេចក្ដីពិតនៃធម៌ មានទុក្ខជាដើម គឺរមែងបិទបាំង ចងរឹត តាំងនៅ

ដោយអត្ថណា អត្ថនោះ ក៏បានដល់ **អត្ថ គឺការមិនចាក់ចុះដោយល្អនូវសច្ចៈ** ។ ចំណែកមួយនៃអបុញ្ញាភិសង្ខារ ជា **សភាគៈ** អភិសង្ខារដទៃជា **វិភាគៈ** ។ ម្យ៉ាងទៀត អបុញ្ញាភិសង្ខារដែលញ៉ាំងរាគៈឲ្យចម្រើន ព្រោះមិនជាបដិបក្ខចំពោះរាគៈទាំងអស់ ចាត់ជា **សភាគៈ** អភិសង្ខារក្រៅអំពីនេះ ចាត់ជា **វិភាគៈ** ព្រោះជាបដិបក្ខចំពោះរាគៈនោះ ។ វិញ្ញាណ ត្រាស់ទុកថាជាទីតាំង ដោយពិសេសនៃការប្រកាន់ខុសយ៉ាងមាំថា ពោលជាអត្តាថា ម្នាលភិក្ខុទាំងឡាយ ព្រោះថា ចិត្តជាដើមនេះ ដែលបុថុជ្ជនមិនបានស្តាប់ចងរឹត ប្រកាន់ទុកដោយតណ្ហា ប្រកាន់ដោយទិដ្ឋិថា **នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាតួខ្លួនរបស់អញ ដូច្នេះ អស់កាលដ៏យូរ** ដូច្នេះ ព្រោះហេតុនោះ **អត្ថ** គឺ **ភាពទទេ** នៃវិញ្ញាណ ទើបជ្រាលជ្រៅ ដូច្នេះ **អត្ថ គឺការមិនមានការខ្នះខ្នែង អត្ថ គឺការមិនវិកិលទៅ អត្ថ គឺប្រាកដដោយបដិសន្ធិ** ក៏ឈ្មោះថា ជ្រាលជ្រៅ ព្រោះភាវៈដែលមានកម្លាំង ដោយភាវៈដែលមានការខ្នះខ្នែង ការវិកិលទៅ និងការប្រកាន់មាំថា រមែងដឹងច្បាស់ រមែងត្រាច់ទៅ ដូច្នេះ ។ **នាមរូប** ឈ្មោះថា **កើតព្រមគ្នា** ក្នុងបដិសន្ធិក្ខណៈ ឈ្មោះថា **កើតព្រមគ្នា** តាមសមគួរជាចំណែកៗ ក្នុងបវត្តិកាល នាម និងរូប រូបនិងនាម ឈ្មោះថា **បែកគ្នាបាន** ព្រោះមិនលាយឡំគ្នា គប្បីប្រកប **ការមិនបែកគ្នា** នៃនាមជាមួយនាម និងរបស់រូបជាមួយរូបខ្លះៗ ប៉ុណ្ណោះ ។ ព្រោះថា បើបំណងយកការមិនបែកគ្នា គឺកើតក៏ព្រមគ្នា រលត់ក៏ព្រមគ្នា ការមិនបែកគ្នានោះ ទើបមានដល់រូបដែលប្រព្រឹត្តទៅក្នុងកលាបៈជាមួយគ្នា ។ ម្យ៉ាងទៀត បណ្ឌិតគប្បីជ្រាបការបែកគ្នានឹងគ្នា ព្រោះនាមរូបក្នុងឯកវោការភព និងចតុវោការភពមិនប្រព្រឹត្តទៅរួមគ្នា និងគប្បីជ្រាបការមិនបែកគ្នា ព្រោះនាមរូបក្នុងបញ្ចវោការភពប្រព្រឹត្តទៅរួមគ្នា ។

ឥន្ទ្រិយប្បច្ច័យក្នុងទីនេះ ឈ្មោះថា **អត្ថ គឺភាពជាអធិបតី** ។ **អត្ថ គឺភាពជាលោកជាដើម** បានត្រាស់ទុកថា **នេះជាលោកខ្លះ នេះជាទ្វារខ្លះ នេះជាខេត្តខ្លះ**

ដូច្នេះ គប្បីប្រកបក្នុងអាយតនៈទាំង ៥ មានចក្ខុជាដើម ។ អត្ថទាំងនេះរមែងមានដូចគ្នាដល់មនាយតនៈ ព្រោះជាការវិនាស និងរមែងមានដល់ផស្សៈ មានមនោសម្ផស្សជាដើម ព្រោះកើតបានទាំងទ្វារ និងបានទាំងខេត្ត ។ ការពិចារណាដែលមានការសមគួរដល់សេចក្តីប្រាកដរបស់អារម្មណ៍ មានរូបជាដើម រហូតដល់ស្មាត់ជំនាញជាលក្ខណៈ ឈ្មោះថា **ភាវៈដែលទទួលអារម្មណ៍បាន** របស់អាយតនៈ មានចក្ខុជាដើមបានដល់ ការដឹងច្បាស់របស់មនាយតនៈ ។ **អត្ថ គឺការប៉ះខ្ទប់** គប្បីប្រកបដល់ផស្សៈ ៥ មានចក្ខុសម្ផស្សជាដើមដោយពិសេស អត្ថក្រៅអំពីនេះ គប្បីប្រកបដល់ផស្សៈទាំង ៦ ។ ឯការពាល់ត្រូវជាសភាវៈរបស់ផស្សៈ ការប៉ះខ្ទប់គ្នាជារស អត្ថក្រៅអំពីនេះជាអាការប្រាកដ ។ **អត្ថ គឺការសោយរសអារម្មណ៍** លោកពោលទាក់ទងនឹងរស **អត្ថ គឺការសោយ** លោកពោលទាក់ទងជាមួយនឹងលក្ខណៈ ។ សេចក្តីសុខទុក្ខ និងភាពជាកណ្តាល លោកពោលទាក់ទងនឹងសភាវៈរបស់វេទនាទាំង ៣ តាមលំដាប់ **អត្ថ គឺការមិនមានជីវៈ** របស់វេទនាក៏ឈ្មោះថា **ជ្រៅ** ព្រោះការប្រកាន់មាំថា **អត្តារមែងសោយ** ជាសភាវៈមានកម្លាំង ។ ម្យ៉ាងទៀត ការសោយរបស់វេទនាដែលមិនមានជីវៈ ឈ្មោះថា **និជ្ជីវវេទយិតំ** ប្រែថា ការសោយរបស់វេទនាដែលមិនមានជីវៈ អត្ថ គឺការសោយរបស់វេទនា ដែលមិនមានជីវៈ ឈ្មោះថា **និជ្ជីវវេទយិតដ្ឋោ** ប្រែថា អត្ថ គឺការសោយរបស់វេទនា ដែលមិនមានជីវៈ ។ តណ្ហាដែលមានបីតិឈ្មោះថា **មានអត្ថ គឺការត្រេកអរ** តណ្ហាដែលមានកម្លាំងក្រៃលែងគ្របសង្កត់ហើយធ្វើឲ្យសម្រេចចុះ ឈ្មោះថា **អត្ថ គឺការចងចិត្តមាំ** ។ អត្ថក្រៅអំពីនេះ បណ្ឌិតគប្បីជ្រាបទាក់ទងនឹងអត្ថទូទៅ ។ **អត្ថ គឺការប្រកាន់ ការប្រកាន់មាំ និងការជោតចិត្តស្មើគ្នានឹងឧបាទានទាំង ៤ អត្ថ គឺការចាប់ទុក** លោកពោលដល់ឧបាទាន មានទិដ្ឋុបាទានប៉ុណ្ណោះ **អត្ថ គឺការឈានកន្លងបានលំបាក** ក៏ដូចគ្នា ។ ពិតហើយ ទិដ្ឋិទាំងឡាយ

ជាធម្មជាតិ ដែលឈានកន្លងបានលំបាក ព្រោះមានបាលីថា **កន្តា គឺទិដ្ឋិ** ម្យ៉ាងទៀត បណ្ឌិតគប្បីប្រកបអត្ថនៃឧបាទានទាំង ៤ **ជាអត្ថ គឺការឈានកន្លងបានលំបាក** ព្រោះជាការប្រកាន់មាំ ។ ដែលលោកពោល **អត្ថនៃតណ្ហាថា ដូចសមុទ្រ** ព្រោះជាធម្មជាតិឈានកន្លងបានលំបាកក៏មាន ។ បទថា **យោនិគតិឋិតិនិវាសេសុខិបនំ** គប្បីឃើញការមិនលុបសត្តមីវិភត្តិក្នុងសមាស ។ មានការសង្ខេបបទថា **អាយូហនាភិសង្ខរណ** ចូលជាមួយបទថា **យោនិគតិឋិតិនិវាសេសុខិបនំ** ដោយប្រការដូច្នេះ ។ **អត្ថទាំងឡាយមានការអស់ទៅជាដើម** ជាអត្ថរបស់មរណៈតែម្យ៉ាង ព្រោះអង្គនៃជរា និងមរណៈ មានមរណៈជាប្រធាន លោកសម្តែងថា ជ្រាលជ្រៅ ។ ការប្រព្រឹត្តទៅនៃការធ្មេញ មានធ្មេញបាក់ជាដើម ក៏ព្រោះការអស់ទៅនៃរបស់ថ្មីៗ គប្បីឃើញថា ឈ្មោះថា **ជរា** ម្យ៉ាងទៀត ដោយអត្ថ គឺការអស់ទៅ គប្បីឃើញថា លោកពោលដល់ជរា ។ ពិតហើយ ការប្រាសចាកភាពថ្មី គួរពោលថា **ជាការអស់ទៅ** ដូច្នេះ ។ **អត្ថ គឺការប្រែប្រួលទៅ** លោកពោលទុកដល់ជរា និងមរណៈ ទាំង ២ ។ ម្យ៉ាងទៀត ការអស់ទៅ និងការវិនាសទៅ គប្បីប្រកបដល់ជរាដោយអំណាចសន្តតិ ការបែកធ្លាយទៅ និងការប្រែប្រួលទៅ គប្បីប្រកបដល់មរណៈ ដោយអំណាចសម្មុតិមរណៈ និងខណិកមរណៈ ។

បទថា **អត្ថនយា** ប្រែថា ន័យរបស់អត្ថទាំងឡាយ ភាវៈទាំងឡាយ មានឯកត្តភាវៈជាដើម រមែងដឹកនាំ គឺធ្វើឲ្យយល់ដោយភាវៈរបស់ខ្លួន ដោយអត្ថ មានអវិជ្ជាជាដើម ព្រោះហេតុនោះ ទើបឈ្មោះថា **ឯកត្តភាវ** ជាដើម លោកពោលថា ជាន័យរបស់អត្ថទាំងនោះ ។ ព្រោះថា ឈ្មោះថា **នយ** ក៏ព្រោះអត្ថថា ដឹកនាំ ដូច្នេះ ។ ម្យ៉ាងទៀត អត្ថទាំងឡាយនោះឯង ត្រូវដឹកនាំ គឺធ្វើឲ្យយល់ដោយភាវៈ មាន **ឯកត្តភាវ** ជាដើម លោកពោលហៅថា **អត្ថនយា** ប្រែថា អត្ថដែលត្រូវដឹកនាំ ។ ម្យ៉ាងទៀត

ឈ្មោះថា **នយ** ព្រោះមានអត្ថថា ជាគ្រឿងដឹកនាំ ឯអត្ថទាំងឡាយ លោកណែនាំដោយពាក្យថា **ដោយចំណែកមួយ** ជាដើម ដោយភាវៈទាំងឡាយ មាន ឯកត្ត ជាដើម ព្រោះហេតុនោះ **ឯកត្តភាវ** ជាដើម ទើបឈ្មោះថា **អត្ថនយា** ព្រោះអត្ថថា ជាន័យនៃអត្ថទាំងឡាយ ។

ពាក្យថា **ព្រោះមានឡើងនៃអវយវៈរបស់ដើមឈើ មានពន្លកជាដើម** លោកអាចារ្យរមែងសម្តែងថា ការមិនដាច់ខ្សែនៃការបន្ត គឺការជ្ញាក់ទៅក្នុងសន្តតិដូចគ្នានៃធម៌ដែលជាហេតុ និងធម៌ដែលកើតអំពីហេតុ មានអវិជ្ជា និងសង្ខារជាដើម សូម្បីក្នុងបដិច្ចសមុប្បាទធម៌នេះ ឈ្មោះថា **ឯកត្តន័យ** ប្រៀបដូចការមិនដាច់ខ្សែនៃការបន្តដែលឈ្មោះថា **ភាពតែមួយ** ព្រោះហេតុដែលពូជដល់នូវភាពជាដើមឈើ គឺប្រព្រឹត្តទៅដោយភាពជាដើមឈើ ដោយការមិនដាច់ខ្សែនៃការបន្ត ព្រោះសង្គ្រោះយកអវយវៈ ( របស់ដើមឈើ ) ដែលប្រព្រឹត្តទៅ ព្រោះការមាននៃអវយវៈរបស់ដើមឈើ មានពន្លកស្លឹក ជាង ដើម មែក ស្លឹកខ្ចី និងស្លឹកចាស់ជាដើម និងពូជនោះលោកក៏ពោលទុកដោយភាពតែមួយដូចគ្នា ។ ដោយពាក្យថា **ដោយការសម្ពន្ធគ្នានៃហេតុ និងផល** នេះ លោកអាចារ្យក៏រមែងអធិប្បាយដល់ការមិនដាច់ខ្សែនៃការបន្ត ។ ពិតហើយ សូម្បីកាលមានការបែងចែកដោយបរមត្ថនៃហេតុ និងផល ការសម្ពន្ធគ្នានៃហេតុ និងផលនោះ ដោយភាពជាហេតុ និងជាផលនោះឯង ឈ្មោះថា **ការមិនដាច់ខ្សែនៃការបន្ត** ក្នុងទីនេះ ព្រោះថា កម្មកើតឡើងហើយក្នុងសន្តានណា ការកើតផលក៏នៅក្នុងសន្តាននោះឯង ព្រោះហេតុនោះ កម្មដែលបានធ្វើហើយ នឹងវិនាស ឯកម្មដែលមិនបានធ្វើនឹងមកចំពោះមុខ រមែងមិនមាន ដូច្នេះ ។ ពាក្យថា **ព្រោះប្រកាន់ថា ជាភាពតែមួយ** សេចក្តីថា ព្រោះមិនបានពិចារណាដោយការបែកគ្នានៃហេតុនិងផល ហើយកាន់យកភាពតែមួយ គឺការមិនបែកគ្នានៃហេតុ និងផល ទាំង ២ ដោយធ្វើហេតុ និងផល

មិនឲ្យបែកគ្នា ។ ឈ្មោះថា **រមែងប្រកាន់មាំដោយសស្សតទិដ្ឋិ** ដោយពាក្យជាដើមថា **វិញ្ញាណនោះឯងរមែងត្រាច់ទៅ រមែងស្ទុះទៅ** ដូច្នេះ ។

ពាក្យថា **ការកំណត់លក្ខណៈ** បានដល់ ការកំណត់សភាវៈ គឺការស្ទង់ដឹងតាមដែលហេតុ និងផលមានសភាវៈបែកគ្នា ។ ពាក្យថា **សន្តានមកបែកគ្នានោះឯង** សេចក្តីថា ព្រោះកាន់យកការផ្សេងគ្នាដែលវៀរការសម្ពន្ធគ្នា ទើបឈ្មោះថា **អ្នកដទៃស្លាប់ អ្នកដទៃកើត** ព្រោះហេតុនោះ បុគ្គលប្រកាន់ថា **សត្វដទៃដាច់សូន្យ សត្វដទៃកើតឡើង** ដូច្នេះ ឈ្មោះថា **រមែងប្រកាន់ដោយឧច្ឆេទទិដ្ឋិ** ។

នាំមកភ្ជាប់គ្នាថា **អម្ហេហិ ឧប្បាទេតព្វំ** ខ្ញុំធ្វើឲ្យកើតឡើង ។ **ភាពដែលមិនមានការខ្នះខ្នែង** បានដល់ ការមិនខ្នះខ្នែង ព្រោះការមិនមានការបន្តចំពោះ ។ ពាក្យថា **កាលឃើញដោយត្រឹមត្រូវ** គឺកាលឃើញថា **មិនមានសេចក្តីប្រឹងប្រែង មិនមានជីវៈត្រឹមតែជាធម៌** ។ ការកំណត់ គឺភាវៈនោះឯង ឈ្មោះថា **សភាវនិយម** ដូចពាក្យជាដើមយ៉ាងនេះថា **ភ្លើង ព្រមទាំងសម្ភារៈ ជាសភាវៈហុយឡើងទៅលើភាពដែលខ្យល់ព្រមទាំងសម្ភារៈជាសភាពទៅតាមទទឹង** ។ ធម៌ដែលកើតអំពីបច្ច័យ **ជាហេតុ** តាមគួរដល់ខ្លួនសម្រេចហើយ ដោយសភាវៈនិយមនោះ ។ ឈ្មោះថា **រមែងប្រកាន់មាំដោយអកិរិយទិដ្ឋិ** ព្រោះ **កិរិយាខ្វះមិនទាក់ទងជាមួយផលឡើយ ហេតុដែលមិនមានកត្តុខ្វះ** ។

កាលឃើញផល ដែលសមគួរដល់ហេតុនោះឯង **រមែងលះអហេតុកទិដ្ឋិ** បានដោយការឃើញភាវៈមិនមាននៃការកើតទាំងពួងថា ទឹកដោះជូរក៏កើតអំពីទឹកដោះស្រស់ មិនមែនកើតអំពីទឹកជម្ពូតាឡើយ ប្រេងកើតអំពីល្ង មិនមែនកើតអំពីដីខ្សាច់ឡើយ ដូច្នេះ ឈ្មោះថា **រមែងលះអកិរិយទិដ្ឋិ** ។ ពាក្យថា **អំពីហេតុណាមួយ** សេចក្តីថា បណ្ឌិតគប្បីជ្រាបតាមសមគួរថា **រមែងប្រកាន់មាំដោយអហេតុកទិដ្ឋិ** ថា បើវត្ថុនេះគប្បីកើតឡើងអំពីវត្ថុមួយបានសោត ហេតុអ្វី ប្រេងគប្បីកើតអំពីដីខ្សាច់មិនបាន ឬ

ទឹកដោះស្រស់ គប្បីកើតអំពីទឹកអំពៅមិនបាន ព្រោះហេតុនោះ វត្ថុណាមួយមិនជាហេតុនៃវត្ថុណាមួយឡើយ និងសូម្បីកាលមិនមានហេតុ **ក៏រមែងប្រកាន់មាំនិយតវាទ**ថា វត្ថុផ្សេងៗ មានប្រេង ទឹកដោះស្រស់ និងសរីរៈជាដើម រមែងកើតអំពីហេតុ មានល្ងមេគោ និងទឹកសុក្កលោហិតជាដើម ។

ក្នុងសេចក្តីថា ព្រោះហេតុអ្វី ? ព្រោះហេតុដែលបុគ្គលមិនទាន់បានទម្លាយភវចក្រនេះឯង កន្លងសង្សារភ័យទៅមិនមានត្រឹមតែម្នាក់ ដោយហោចសូម្បីយល់សប្តិ ។ **សុបិនមិនដល់** គឺមិនមានទីពឹង ។ **តទល់បានលំបាក** គឺឈានកន្លងបានលំបាក ។ **អសនីវិចក្រ** គឺដូចរន្ទះ ។ ពិតហើយ អសនីវិចក្រនោះ គ្រប់សង្កត់តែម្យ៉ាង មិនមែនមិនគ្រប់សង្កត់ប្រព្រឹត្តទៅ សូម្បីភវចក្រនេះ ក៏ដូច្នោះ លោកអាចារ្យពោលថា **គ្រប់សង្កត់ជានិច្ច** ព្រោះញុំាងទុក្ខឲ្យកើតឡើងដោយចំណែកមួយប៉ុណ្ណោះ ។

លោកអាចារ្យ កាលសម្តែងព្រះសូត្រ ដែលជាគ្រឿងសាធកៈនៃពាក្យនេះថា បុគ្គលមិនទាន់បានទម្លាយដោយដាវ គឺញាណ កន្លងសង្សារភ័យទៅមិនមានសូម្បីតែម្នាក់ ទើបពោលពាក្យជាដើមថា **សេចក្តីនេះ សមដូចពាក្យដែលព្រះមានព្រះភាគត្រាស់ទុក** ដូច្នេះ ។ ការជាប់ជំពាក់របស់អំបោះទាំងឡាយ ឈ្មោះថា **តន្តាកុលកំ** ប្រែថា អំបោះជំពាក់ ពួកសត្វកើតហើយ ដូចអំបោះជំពាក់ ឈ្មោះថា **តន្តាកុលកជាតា** ប្រែថា កើតដូចសូត្រជំពាក់ អធិប្បាយថា ជាប់ជំពាក់ក្រៃពេកដោយកិលេស កម្ម និងវិបាក ។ សម្បុកបក្សី ឈ្មោះថា **កុលិ** ឈ្មោះថា **កុលិកំ** ប្រែថា សម្បុកបក្សីកុលិកើតហើយ គឺកើតហើយដូចស្មៅជំណេកទន្សាយ និងដូចស្មៅយាប្លង ។ ឈ្មោះថា **មុញ្ជបព្វជភូតា** ដូចគ្នានឹងស្មៅជំណេកទន្សាយ និងស្មៅយាប្លង ។ បានឮថា ស្មៅទាំង ២ ប្រភេទនោះ ដុះដាលជារបស់ជំពាក់ គឺចាក់ស្រែះ ព្រោះមិនមានការបម្រើន ទើបឈ្មោះថា **អបាយ** ព្រោះជាភូមិដែលដល់នូវសេចក្តីលំបាក ឈ្មោះថា **ទុគ្គតិ** ព្រោះ

ជាធម្មជាតិធ្លាក់ទៅអំពីគំនរនៃសេចក្ដីសុខ ទើបឈ្មោះថា **វិនិបាត** រមែងមិនកន្លង អបាយភូមិ ៤ យ៉ាង **និងសង្សារ** ដែលពោលទុកដោយពាក្យជាដើមថា **និងលំដាប់នៃខន្ធទាំងឡាយ** ដូច្នេះ ។ ម្យ៉ាងទៀត សង្សារទាំងពួងនោះ មានឈ្មោះថា **អបាយ** ជាដើម ដោយអត្ថ មានការប្រាសចាកសេចក្ដីចម្រើនជាដើម លោកពោលហើយ ព្រោះជាគំនរទុក្ខតែម្យ៉ាង ។

ពណ៌នាបដិច្ចសមុប្បាទនិទ្ទេស ចប់

ពណ៌នាបរិច្ឆេទទី ១៧ ចប់ហើយ

ដោយប្រការ ដូច្នេះ ។

# វិសុទ្ធិមគ្គ

## ក្បាលចប់

## ទិដ្ឋិវិសុទ្ធិនិទ្ទេស

ឥឡូវនេះ វិសុទ្ធិទាំងឡាយណា ដែលខ្ញុំពោលទុកថា វិសុទ្ធិ ដែលជាមូល ២ គឺសីលវិសុទ្ធិ ១ ចិត្តវិសុទ្ធិ ១ ដែលព្រះយោគាវចរធ្វើការចម្រើនចំណេះដឹង ដោយការស្វាធ្យាយ និងសាកសួរក្នុងធម៌ទាំងឡាយ ដែលជាភូមិ ( នៃវិបស្សនា មានខន្ធជាដើម ) នេះហើយ គប្បីធ្វើឲ្យដល់ព្រមចុះ ដូច្នេះ ក្នុងវិសុទ្ធិ ២ នោះ សីល ៤ យ៉ាង មានបាតិមោក្ខសំវរសីលជាដើម ដែលបរិសុទ្ធល ឈ្មោះថា **សីលវិសុទ្ធិ** ឯសីល ៤ យ៉ាងនោះ ខ្ញុំបានពោលឲ្យពិស្តារក្នុងសីលនិទ្ទេសនោះហើយ ។ សមាបត្តិ ៨ ព្រមទាំងឧបចារៈ ឈ្មោះថា **ចិត្តវិសុទ្ធិ** សមាបត្តិនោះសោត ខ្ញុំក៏បានពោលឲ្យពិស្តារ ដោយអាការទាំងឡាយក្នុងសមាធិនិទ្ទេស ដែលពោលដោយមាតិកា គឺចិត្តហើយដូចគ្នា ព្រោះហេតុនោះ វិសុទ្ធិ ២ នោះ បណ្ឌិតគប្បីជ្រាបតាមន័យដែលខ្ញុំធ្វើឲ្យពិស្តារហើយ ក្នុងនិទ្ទេសទាំង ២ នោះចុះ ។ ចំណែកពាក្យណាដែលខ្ញុំបានពោលទុកថា **វិសុទ្ធិ ៥ នេះ គឺទិដ្ឋិវិសុទ្ធិ កង្ខាវិតរណវិសុទ្ធិ មគ្គាមគ្គញាណទស្សនវិសុទ្ធិ បដិបទាញាណទស្សនវិសុទ្ធិ ញាណទស្សនវិសុទ្ធិ ជាសរីរៈ** ( គឺជាតួបញ្ញា ) ដូច្នេះ ការឃើញនាម និងរូបដោយពិត ឈ្មោះថា **ទិដ្ឋិវិសុទ្ធិ** ក្នុងពាក្យនោះ ។

## វិបស្សនាវិធីនៃសមថយានិក

ព្រះយោគាវចរប្រាថ្នានឹងធ្វើទិដ្ឋិវិសុទ្ធិនោះ ឲ្យដល់ព្រម ( ពោលដោយ ) បុគ្គលដែលជាសមថយានិកមុន ចេញអំពីរូបាវចរជ្ឈាន និងអរូបាវចរជ្ឈានដ៏សេស

ឯណាទីមួយ វៀរនេវសញ្ញានាសញ្ញាយតនៈហើយ គប្បីកំណត់យកអង្គឈានទាំងឡាយ មានវិតក្កជាដើម និងធម៌ទាំងឡាយ ដែលសម្បយុត្តជាមួយអង្គឈាននោះ ដោយលក្ខណៈ និងរសជាដើម ។ កាលកំណត់បានហើយ គប្បីកំណត់ចុះថា ទាំងអស់នោះជានាម ដោយអត្ថថា ជាវត្ថុដែលបង្អោនទៅបាន ព្រោះទោរទន់ មានមុខទៅកាន់អារម្មណ៍ លំដាប់នោះ ឧបមាដូចបុរសឃើញពស់នៅក្នុងផ្ទះ ហើយដេញតាមទៅក៏ជួបទីលំនៅរបស់វា យ៉ាងណាក្តី សូម្បីព្រះយោគាវចរនេះក៏ដូច្នោះដូចគ្នា កាលពិនិត្យនាមនោះរកមើលទៅថា នាមនេះអាស្រ័យអ្វីប្រព្រឹត្តទៅ ក៏នឹងជួបហទយរូបដែលជាទីអាស្រ័យរបស់ញាណនោះ តអំពីនោះ ទើបកំណត់រូប គឺភូតរូបទាំងឡាយដែលជាទីអាស្រ័យនៃហទយរូប និងឧបាទាយរូបដ៏សេស ដែលអាស្រ័យភូតរូបនោះ ( កាលកំណត់បានហើយ ) ទើបលោកកំណត់ថា វត្ថុទាំងពួងនោះ ជារូប ព្រោះបែកធ្លាយបាន តអំពីនោះ ទើបកំណត់នាមរូបដោយសង្ខេបថា វត្ថុដែលមានការបង្អោនទៅបានជាលក្ខណៈ ជានាម វត្ថុដែលមានការបែកធ្លាយបានជាលក្ខណៈ ជារូប ។

## វិបស្សនាវិធីនៃវិបស្សនាយានិក

## កំណត់នាមរូបដោយចតុធាតុវវដ្ឋាន

ចំណែកព្រះយោគាវចរដែលជាវិបស្សនាយានិកសុទ្ធ ឬបុគ្គលដែលជាសមថយានិកនេះឯងក៏ដោយ កំណត់ធាតុ ៤ យ៉ាងដោយសង្ខេប ឬពិស្តារ ដោយធាតុបរិគ្គហមុខ ( ផ្លូវកំណត់ធាតុ ) នោះៗ ដែលពោលហើយក្នុងចតុធាតុវវដ្ឋានមុខណាទីមួយ ។ លំដាប់នោះ ក្នុងធាតុទាំងឡាយដែលប្រាកដច្បាស់ដោយរស និងលក្ខណៈរបស់ខ្លួនតាមសេចក្តីពិតហើយ ក្នុងសក់ ដែលមានកម្មជាសមុដ្ឋានមុនរូប ១០ ( ក្នុងសក់នោះ ) ដោយកលាបៈនៃកាយទសកៈ ដូច្នេះ គឺធាតុ ៤ ពណ៌ ក្លិន រស ឱជា

ជីវិត កាយបសាទរូប ១០ ដោយកលាបៈនៃការទសកៈ ( ក្រុមរូប ១០ ទាំងការៈគឺភេទ ) ព្រោះក្នុងសក់ដែលមានកម្មជាសមុដ្ឋាននោះឯង មានការៈដោយរូប ២៤ ដទៃទៀត ក្នុងក្រុមរូបដែលមានឈ្មោះថា សក់នោះដូចគ្នា គឺ **ឱជដ្ឋមករូប** ( ក្រុមរូបមានឱជាជាគម្រប់ ៨ ) ដែលមានអាហារជាសមុដ្ឋាន ឱជដ្ឋមករូបមានឧតុជាសមុដ្ឋាន ឱជដ្ឋមករូប មានចិត្តជាសមុដ្ឋាន ( មួយក្រុម ៨ រូបជា ២៤ ខាងដើម ២០ ទៀត រូបជា ៤៤ ) រមែងប្រាកដដល់ព្រះយោគាវចរនោះឯង ។

( ក្នុងសក់ មានរូប ៤៤ យ៉ាងណា ) ក្នុងកោដ្ឋាស ២៤ ដែលជាចតុសមុដ្ឋាន ក៏មានរូប ( នីមួយៗ ) ៤៤ ៗ ដូច្នោះ ។ ចំណែកក្នុងកោដ្ឋាសដែលមានឧតុ និងចិត្តជាសមុដ្ឋាន ៤ នេះ គឺញើស ទឹកភ្នែក ទឹកមាត់ ទឹកសំបោរ មានរូប ( នីមួយៗ ) ១៦ ៗ ដោយកលាបៈនៃឱជដ្ឋមករូប ២ កលាបៈ ក្នុងកោដ្ឋាសដែលមានឧតុជាសមុដ្ឋាន ( តែម្យ៉ាង ) ៤ នេះ គឺអាហារថ្មី អាហារចាស់ ខ្ទុះ ទឹកនោម ក៏មានរូប ( នីមួយៗ ) ៨ ៗ ដោយកលាបៈនៃឱជដ្ឋមករូបដែលមានឧតុជាសមុដ្ឋាន តែម្យ៉ាង ប្រាកដដល់ព្រះយោគាវចរនោះឯង នេះជាន័យក្នុងអាការ ៣២ ជាលំដាប់ដំបូង ។

ម្យ៉ាងទៀត កាលអាការ ៣២ នេះ ប្រាកដច្បាស់ហើយ អាការ ១០ ដទៃទៀត ( គឺតេជោកោដ្ឋាស ៤ និងវាយោកោដ្ឋាស ៦ ) ពួកណារមែងប្រាកដច្បាស់ក្នុងអាការទាំងនោះ ដំបូងក្នុងតេជោកោដ្ឋាស ដែលកើតអំពីកម្មដែលញ៉ាំងអាហារដែលបរិភោគចូលទៅជាដើមឲ្យរលាយ មានរូប ៩ គឺឱជដ្ឋមករូប ៨ និងជីវិតរូប ១ ។ ន័យដូចគ្នាក្នុងកោដ្ឋាស គឺខ្យល់ដង្ហើមដែលកើតអំពីចិត្ត ក៏មានរូប ៩ គឺឱជដ្ឋមករូប ៨ និងសទ្ទរូប ១ ។ ក្នុងកោដ្ឋាសដ៏សេស ៨ ទៀត ( គឺតេជោ ៣ វាយោ ៥ ) ដែលជាចតុសមុដ្ឋាន មានរូប ៣៣ ៗ គឺជីវិតនវករូប ៩ និងឱជដ្ឋមករូប ៣ ( ស្មើ ២៤ ) ប្រាកដ ( ដល់ព្រះយោគាវចរនោះ ) ។

កាលភូតរូប និងឧបាទាយរូបទាំងនេះ កើតប្រាកដដល់ព្រះយោគាវចរនោះ ដោយជាអាការ ៤២ យ៉ាង ដោយពិស្តារដូច្នេះហើយ រូបដទៃទៀត ៦០ គឺរូបកលាបៈ ៥ មានចក្ខុទសកៈជាដើម និងហទយវត្ថុទសកៈ ដោយជាវត្ថុ និងទ្វារ ក៏រមែងប្រាកដ ។

ព្រះយោគាវចរ រួមរូបទាំងឡាយនោះចូលគ្នាដោយលក្ខណៈ គឺការបែកធ្លាយ ក៏ឃើញថា **នុ៎ះជារូប** ។ អរូបធម៌ទាំងឡាយក៏រមែងប្រាកដជាទ្វារដល់ព្រះយោគាវចរនោះ ដែលកំណត់រូបបានហើយ អរូបធម៌នេះ បានដល់អ្វីខ្លះ ? បានដល់ លោកិយចិត្ត ៨១ គឺទ្វិបញ្ចវិញ្ញាណ ១០ មនោធាតុ ៣ មនោវិញ្ញាណធាតុ ៦៨ ។ ម្យ៉ាងទៀត ពោលដោយមិនប្លែកគ្នា គឺជាសាធារណៈ បានដល់ ចេតសិក ៧ គឺផស្សៈ វេទនា សញ្ញា ចេតនា ជីវិត ចិត្តដ្ឋិតិ គឺការឈប់នៃចិត្ត គឺសមាធិយ៉ាងទន់ មនសិការដែលកើតរួមជាមួយចិត្តនោះឯង ។

ចំណែកលោកុត្តរចិត្តទាំងឡាយ មិនដល់នូវការកំណត់យកបានដល់ព្រះយោគាវចរសុទ្ធវិបស្សកៈនោះឡើយ មិនមានដល់ព្រះយោគាវចរសមថយានិកនោះឡើយ ព្រោះមិនទាន់បានសម្រេច ។

ព្រះយោគាវចរនោះ រួមអរូបធម៌ទាំងពួងនោះចូលគ្នាដោយលក្ខណៈ គឺការបង្អោនទៅបាន ក៏ឃើញថា **នុ៎ះជានាម** ។

ព្រះយោគាវចរណាមួយ កំណត់នាមរូបយ៉ាងពិស្តារដោយមុខចតុធាតុវវដ្ឋាន ដូចពណ៌នាមកដូច្នេះ ។

## កំណត់នាមរូបដោយធាតុ ១៨

ព្រះយោគាវចរណានីមួយ កំណត់នាមរូបតាមធាតុ ១៨ កំណត់ដូចម្ដេច ? គឺភិក្ខុក្នុងសាសនានេះ អាវជ្ជនាការដល់ធាតុទាំងឡាយថា **មានក្នុងអត្តភាពនេះ គឺ ចក្ខុធាតុ រូបធាតុ ចក្ខុវិញ្ញាណធាតុ ។ល។ មនោធាតុ ធម្មធាតុ មនោវិញ្ញាណធាតុ**

ដូច្នេះហើយ មិនកាន់យកដុំសាច់ដែលសរសៃចងទុកក្នុងរង្វង់ភ្នែក មានសណ្ឋានវែទៅវែមក ស្រស់ស្អាត ( ប៉ែកៗ ) ដោយប្រសីពណ៌ប្រផេះ ( ក៏មាន ) និងពណ៌ខ្មៅស្និទ្ធ ក៏មាន ដែលសត្វលោកតែងហៅថា ចក្ខុកំណត់យកចក្ខុបសាទ មានប្រការដូចពោលទុកក្នុងពពួកឧបាទាយរូប ក្នុងខន្ធនិទ្ទេសថា ជាចក្ខុធាតុ ។ ម្យ៉ាងទៀត រូបដ៏សេស ៥៣ មានដូច្នេះ គឺសហជាតរូប ( របស់ចក្ខុបសាទ ) ៩ បានដល់ ធាតុ ៤ ដែលជាទីអាស្រ័យនៃចក្ខុបសាទនោះ រូប ៤ គឺពណ៌ ក្លិន រស ឱជា ដែលជារូបចោមរោម ជីវិតិន្ទ្រិយដែលជារូប ( មាននាទី ) អនុបាលកម្មជរូប ២០ ដោយជាកាយទសករូប ១០ និងភាវទសករូប ១០ ដែលតាំងនៅក្នុងចក្ខុបសាទនោះឯង អនុបាទិន្នករូប ២៤ ដោយជាឱជដ្ឋមករូប ៣ នៃរូបដែលជាអាហារសមុដ្ឋានជាដើម ( ៩ + ២០ + ២៤ = ៥៣ ) ក៏មិនកំណត់យករូប ៥៣ នោះ ថាជាចក្ខុធាតុ សូម្បីក្នុងធាតុទាំងឡាយ មានសោតធាតុជាដើមក៏ន័យនេះ តែក្នុងកាយធាតុ រូបដ៏សេស ៤៣ ចំណែកអាចារ្យពួកខ្លះ ពោលថាមាន ៤៥ ដោយធ្វើ រូបដែលជាឧតុសមុដ្ឋាន និងចិត្តសមុដ្ឋានមួយក្រុមជា ៩ និងសទ្ទរូប ។ ព្រះយោគាវចរនោះកំណត់ថា រូប ១០ គឺបសាទរូប ៥ ដូចពោលមកនេះ និងវិស័យនៃបសាទទាំងនោះ ៥ គឺរូប សំឡេង ក្លិន រស ផោដ្ឋព្វៈ ជាធាតុ ១០ រូបដ៏សេស រាប់ជាធម្មធាតុតែម្យ៉ាង ចំណែកទ្វិបញ្ចវិញ្ញាណ ដោយន័យថា **ចិត្តអាស្រ័យចក្ខុប្រាសាទ្ធរូបប្រព្រឹត្តទៅ ឈ្មោះថា ចក្ខុវិញ្ញាណធាតុ** ដូច្នេះជាដើម ជាវិញ្ញាណធាតុ ៥ មនោធាតុចិត្ត ៣ ដួង ជាមនោធាតុ ១ មនោវិញ្ញាណធាតុចិត្ត ៦៨ ដួង ជាមនោ-វិញ្ញាណធាតុ ១ ( រួមជាធាតុ ១៨ ) ។

កំណត់ថា **លោកិយចិត្តទាំងអស់ ៨១ ដួង វិញ្ញាណធាតុ ៧ ធម៌ទាំងឡាយមានផស្សៈជាដើម ដែលសម្បយុត្តជាមួយវិញ្ញាណធាតុនោះ ក៏ជាធម្មធាតុ** ។

ក្នុងធាតុ ១៨ នេះ ធាតុ ១០ កន្លះ ជារូប ធាតុ ៧ កន្លះជានាម ដូច្នេះឯង ។

ព្រះយោគាវចរកំណត់នាមរូប តាមធាតុ ១៨ ដោយន័យដូចពោលមកដូច្នេះ ។

## កំណត់នាមរូបដោយអាយតនៈ ១២

ព្រះយោគាវចរអង្គខ្លះ កំណត់នាមរូបតាមអាយតនៈ ១២ កំណត់ដូចម្តេច ? កំណត់អំពីចក្ខុបសាទ វៀររូប ៥៣ តាមន័យដែលពោលក្នុងចក្ខុធាតុចេញ ថាជាចក្ខាយតនៈ និងកំណត់សោតធាតុ ឃានធាតុ ជិវ្ហាធាតុ កាយធាតុ តាមន័យដែលពោលក្នុងចក្ខុធាតុនោះដូចគ្នា ថាជាសោតាយតនៈ ឃានាយតនៈ ជិវ្ហាយតនៈ កាយាយតនៈ កំណត់ធម៌ ៥ ដែលជាវិស័យនៃអាយតនៈ ៥ នោះ ថាជារូបាយតនៈ សទ្ទាយតនៈ គន្ធាយតនៈ រសាយតនៈ ផោដ្ឋព្វាយតនៈ កំណត់ដោយលោកិយចិត្ត និងសត្ត-វិញ្ញាណធាតុ ថាជាមនាយតនៈ កំណត់ធម៌ទាំងឡាយ មានផស្សៈជាដើម ដែលសម្បយុត្តនឹងវិញ្ញាណធាតុនោះ និងរូបដ៏សេស ថាជាធម្មាយតនៈ ។

ក្នុងអាយតនៈ ១២ នេះ អាយតនៈ ១០ កន្លះជារូប អាយតនៈ ១ កន្លះ ជានាមដូច្នេះ ។

ព្រះយោគាវចរអង្គខ្លះ កំណត់នាមរូបតាមអាយតនៈ ១២ ដោយន័យដូចពោលមកដូច្នេះ ។

## កំណត់នាមរូបដោយខន្ធ ៥

ព្រះយោគាវចរអង្គខ្លះ កំណត់បង្រួញចុះថា ទុំខន្ធ ៥ កំណត់ដូចម្តេច ? ភិក្ខុក្នុងសាសនានេះ កំណត់ថា រូប ១៧ ក្នុងសរីរៈនេះ គឺធាតុ ៤ ទាំង ៤ សមុដ្ឋាន ពណ៌ ក្លិន រស ឱជា ដែលអាស្រ័យធាតុ ៤ នោះ បសាទ ៥ មានចក្ខុបសាទជាដើម វត្ថុរូប ភាវៈ ជីវិតិន្ទ្រិយ សំឡេងទាំង ២ សមុដ្ឋាន ទាំងនេះ ជារូបសម្រេចហើយ ជារូបពិត គួរដល់ការស្ទាបអង្អែល ( ពិចារណា ) ។ ចំណែករូប ១០ គឺកាយវិញ្ញត្តិ វចីវិញ្ញត្តិ អាកាសធាតុ ការស្រាលនៃរូប ការទន់នៃរូប ការស្ទាត់ជំនាញនៃរូប ការ

ចម្រើននៃរូប ការបន្តនៃរូប ការទ្រុឌទ្រោមទៅនៃរូប ការមិនទៀងនៃរូប ទាំងនេះ មិនមែនរូបសម្រេច មិនមែនរូបពិត គ្រាន់តែអាការនៃរូប វិការនៃរូប និងគ្រឿងកំណត់កាត់ចន្លោះនៃរូប មិនមែនរូបដែលគួរដល់ការបបោស អង្អែល ( ពិចារណា ) តែក៏ដល់នូវការរាប់ថា ជារូប ដោយត្រឹមតែជាអាការ ជាវិការ ជាគ្រឿងកំណត់ កាត់ចន្លោះនៃរូបទាំងឡាយទាំងពួងនោះ រួមជា ២៧ ជារូបក្ខន្ធ ។ វេទនាដែលកើតឡើងព្រមជាមួយលោកិយចិត្ត ៨១ ជាវេទនាខន្ធ ។ សញ្ញាដែលសម្បយុត្តជាមួយលោកិយចិត្តនោះ ជាសញ្ញាខន្ធ ។ សង្ខារទាំងឡាយ ដែលសម្បយុត្តជាមួយលោកិយចិត្តនោះ ជាសង្ខារក្ខន្ធ ។ វិញ្ញាណដែលសម្បយុត្តជាមួយវេទនា សញ្ញា និងសង្ខារ ជាវិញ្ញាណក្ខន្ធ ។ រូបក្ខន្ធ ជារូប អរូបក្ខន្ធ ៤ ជានាមដូច្នេះឯង ។

ព្រះយោគាវចរកំណត់នាមរូប ដោយខន្ធ ៥ ដូចន័យពោលមក ដូច្នេះ ។

## កំណត់នាមរូបដោយសង្ខេប

ព្រះយោគាវចរអង្គខ្លះ កំណត់យករូបក្នុងអត្តភាពនេះ ដោយបង្រួញតែម្តងថា រូបគ្រប់យ៉ាង រូបទាំងអស់ គឺមហាភូតរូប ៤ និងរូបអាស្រ័យមហាភូតរូប ៤ ( ជារូប ) ដូច្នេះហើយ កំណត់យកមនាយតនៈ និងចំណែកមួយនៃធម្មាយតនៈ ថាជានាម ដោយបង្រួញដូចគ្នាហើយកំណត់នាមរូបដោយសង្ខេបថា នេះនាម នេះ រូប ដូចពោលមក នេះហៅថា នាមរូប ។

## ការកំណត់រូបជាឧបាយឧបការៈដល់ការកំណត់នាម

បើព្រះយោគាវចរនោះកំណត់រូបដោយប្រធាននោះៗ ហើយកំណត់អរូប ( គឺនាម ) ទៅ អរូបមិនទាន់ប្រាកដ ព្រោះជាធម៌ល្អិតសោត លោកក៏កុំបោះបង់ធុរៈចោល គប្បីត្រិះរិះធ្វើក្នុងចិត្ត កំណត់វែកញែកមើលរូបនោះឯងទុកតទៅចុះថា រូបជាវត្ថុដែល

ស្អាតបរិសុទ្ធល្អ មិនមានអ្វីជាមន្ទិលដោយប្រការណាមួយឡើយ អរូបធម៌ទាំងឡាយ ដែលមានរូបនោះជាអារម្មណ៍ ក៏រមែងប្រាកដឡើងឯង ដោយប្រការនោះៗ ដូចជា កាលបុរសក្អែកល្អសម្លឹងមើលស្រមោលក្នុងកញ្ចក់ដែលអ័ព្ទ ស្រមោលមិនប្រាកដ បុរសនោះមិនគិតថា ជាស្រមោលមិនប្រាកដ ហើយបោះកញ្ចក់ចោលក៏ទេ តែបុរស នោះជុសកញ្ចក់ញយៗ កាលកញ្ចក់ថ្លាហើយ ស្រមោលរបស់មុខគេនោះក៏ប្រាកដ ឯង យ៉ាងណា ដូចបុគ្គលត្រូវការប្រេង ចាក់ម្សៅល្ង ( គឺល្ងម៉ដ្ឋ ) ចុះក្នុងភាជនៈ ហើយ ព្រមដោយទឹក ( ត្រជាក់ ) កាលប្រេងមិនទាន់ចេញ ដោយត្រឹមតែសង្កត់ម្ដង ឬពីរដង បុរសនោះ ក៏មិនចោលម្សៅល្ងឡើយ តែបុរសនោះប្រោះវាដោយទឹកក្ដៅ ហើយសង្កត់ទៅរឿយៗ កាលធ្វើយ៉ាងនោះ ប្រេងល្ងដ៏ថ្លា រមែងចេញមក យ៉ាងណា ម្យ៉ាងទៀត ដូចបុគ្គលត្រូវការធ្វើទឹកឲ្យថ្លា កាន់គ្រាប់ល្មៀង លូកដៃចុះ ក្នុងក្អមទឹក កាលទឹកមិនទាន់ថ្លា ដោយត្រឹមតែកូរម្ដង ឬពីរដង បុរសនោះក៏មិនចោលគ្រាប់ ល្មៀងឡើយ តែជុសវារឿយៗ ទៅ កាលធ្វើយ៉ាងនោះទៅក្នុងក្អមរឿយៗ កករ ទឹកតូចៗ រមែងធ្លាក់ចុះ ទៅក្រោមទឹករមែងថ្លាស្អាត យ៉ាងណា ភិក្ខុនោះក៏ដូច្នោះដូចគ្នា មិនគប្បីលះបង់ធុរៈចោល ត្រិះរិះធ្វើក្នុងចិត្ត កំណត់វែកញែករូបនោះឯងរឿយៗ ចុះ ព្រោះថា រូបជាវត្ថុដែលស្អាតបរិសុទ្ធល្អ មិនមានមន្ទិល ដោយប្រការណាមួយឡើយ កិលេសទាំងឡាយ ដែលជាសត្រូវដល់ញាណ កំណត់អរូបធម៌នោះ រមែងទ្រមទៅ ចិត្តរមែងថ្លាដូចទឹកនៅក្នុងពាង ។អរូបធម៌ទាំងឡាយដែលមានរូបធម៌នោះជាអារម្មណ៍ ក៏រមែងនឹងប្រាកដឯងដោយប្រការនោះៗ ។

សេចក្ដីនេះ បណ្ឌិតគប្បីប្រកាសដោយឧបមាដទៃៗ ដូចជាដើមបបុស ចោរ គោ ទឹកដោះជូរ និងត្រីក៏បាន តាមន័យដូចពោលមកនេះ ។

# មហាដីកា

## ពណ៌នាទិដ្ឋិវិសុទ្ធិនិទ្ទេស

### កថាពណ៌នាដោយការកំណត់នាមរូប

ក្នុងសេចក្តីបាលីថា **យា វិសុទ្ធិយោ សម្បាទេតព្វា** វិសុទ្ធិពួកណា ដែលព្រះយោគាវចរគប្បីធ្វើឲ្យដល់ព្រម ។ **ក្នុងធម៌ទាំងឡាយ ដែលជាភូមិ** នៃវិបស្សនា មានខន្ធជាដើម តាមដែលបានពិចារណាទុកហើយ **ទាំងនេះ** ។ ការរៀនគម្ពីរ គឺធ្វើឲ្យរត់មាត់ ឈ្មោះថា **ឧគ្គហ** ការរៀន សេចក្តីប្រាថ្នាដើម្បីដឹងអត្ថដោយជុំវិញ ដោយប្រការទាំងពួង ឈ្មោះថា **បរិបុច្ឆា** ការសាកសួរ បានដល់ វិធីធ្វើមនសិការអត្ថនោះដោយអំណាចការស្តាប់ និងការពិចារណាជាដើម ព្រោះញាណក្នុងធម៌ដែលជាភូមិទាំងនោះ លោករមែងសេពរហូតស្ទាត់ជំនាញល្អហើយ ដោយអំណាចការរៀន និងការសាកសួរទាំង ២ នោះ ដូច្នោះ ទើបលោកអាចារ្យពោលថា **ធ្វើការជំនាញដោយញាណ ដោយអំណាចការរៀន និងការសាកសួរ** ដូច្នេះ អធិប្បាយថា ធ្វើញាណដែលសម្រេចដោយការស្តាប់ឲ្យកើតក្នុងធម៌ទាំងឡាយ មានខន្ធជាដើម ។ អធិប្បាយថា **ខ្ញុំធ្វើឲ្យពិស្តារហើយនោះឯង** ព្រោះហេតុនោះ ព្រះយោគាវចរគប្បីញុំាងសីលវិសុទ្ធិឲ្យដល់ព្រម តាមទំនងន័យដែលខ្ញុំធ្វើឲ្យពិស្តារហើយ ក្នុងសីលនិទ្ទេសនោះ ។ សូម្បីឧបចារសមាធិ ក៏ឈ្មោះថា **ចិត្តវិសុទ្ធិ** ដូចគ្នា ព្រោះជាទីតាំងនៃវិបស្សនា ដូចជាអប្បនាសមាធិដែរ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **ព្រមទាំងឧបចារៈ** ។ ពាក្យថា **គប្បីជ្រាប** គឺបណ្ឌិតគប្បីជ្រាបទាក់ទងដោយការកើតឡើងក្នុងសន្តានរបស់ខ្លួននោះឯង ។ អធិប្បាយថា វិសុទ្ធិទាំង ២ នោះ ឈ្មោះថា **បណ្ឌិតបានជ្រាបហើយ** ដោយប្រចក្សយ៉ាងនេះ ព្រោះហេតុនោះ ទើបគប្បីជ្រាប គឺឲ្យដល់ព្រម ។ម្យ៉ាងទៀត

ពាក្យថា **គប្បីជ្រាប** សេចក្ដីថា គប្បីសោយទាក់ទងនឹងការសម្រេចសុខក្នុងសមាបត្តិ ។ ព្រោះថា ព្រះយោគាវចរដែលឈ្មោះថា **តាំងនៅក្នុងចិត្តវិសុទ្ធិ** មិនមែនដោយហេតុត្រឹមតែការដឹង តែម្យ៉ាងនោះឡើយ និងមិនបានតាំងនៅក្នុងចិត្តវិសុទ្ធិនោះ មិនអាចញុំាងវិសុទ្ធិខ្ពស់ៗ ឡើងទៅឲ្យដល់ព្រមឡើយ ។

ពាក្យថា **ការឃើញនាម និងរូប តាមសេចក្ដីពិត** បានដល់ ការឃើញនាម និងរូបបែកចេញអំពីគ្នាតាមសេចក្ដីពិត ។ បណ្ឌិតគប្បីឃើញថា ក្នុងទីនេះ លោកកាន់យកខន្ធទាំង ៤ ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ មានវេទនាជាដើម ដោយស័ព្ទថា **នាម** មិនមែនវៀរវិញ្ញាណដូចក្នុងពាក្យថា **ព្រោះវិញ្ញាណជាបច្ច័យ ទើបមាននាមរូប** ទាំងមិនមែនរួមជាមួយលោកុត្តរក្ខន្ធ ព្រមទាំងនិព្វាន ដូចក្នុងពាក្យថា **នាម** និង **រូប** នេះៗ

ឈ្មោះថា **យាន** ព្រោះមានអត្ថថា ជាគ្រឿងទៅ គឺដល់ យាន គឺសមថៈ ឈ្មោះថា **សមថយាន** សមថយាននោះ មានដល់យោគាវចរនេះ ហេតុនោះ យោគាវចរនេះឈ្មោះថា **សមថយានិកោ** អ្នកមានយាន គឺសមថៈ ។ ពាក្យថា **សមថយានិក** នេះ ជាឈ្មោះរបស់យោគាវចរ ដែលតាំងនៅក្នុងឈាន ឬក្នុងឧបចារៈនៃឈាន ហើយប្រកបវិបស្សនា ដែលយោគាវចរជាសមថយានិក នោះ ។

ពាក្យថា **វៀរនេវសញ្ញានាសញ្ញាយតនៈ** នេះ លោកអាចារ្យពោលព្រោះភវគ្គធម៌កំណត់បានលំបាក សម្រាប់យោគាវចរដែលជាអាទិកម្មិក អធិប្បាយថា **គប្បីកំណត់កាន់យកដោយលក្ខណៈ និងកិច្ចជាដើម** គឺគប្បីកំណត់ដោយញាណកាន់យកឯវិធីកំណត់កាន់យក ខ្ញុំបានពោលទុកហើយ **ក្នុងខន្ធនិទ្ទេស** នោះឯង ។ ការបង្អោនឆ្ពោះទៅកាន់អារម្មណ៍ គឺវៀរចាកអារម្មណ៍ ក៏មិនប្រព្រឹត្តទៅ ដោយអត្ថ គឺការបង្អោនទៅ ឬដោយអត្ថ គឺការតាំងឈ្មោះទុកនោះ ។ ពិតហើយ អរូបធម៌ទាំងឡាយ មានវេទនាជាដើម លោកហៅថា **នាម** ដោយអត្ថ គឺការតាំងឈ្មោះទុក ព្រោះមានឈ្មោះ

ខាងដើមនោះឯង បានតាំងទុកដោយមិនចាំបាច់ឈ្មោះដទៃ មានសក់ និងធ្មាំងជាដើម ដូចរូបធម៌ទាំងឡាយ មានបឋវីជាដើម ព្រោះមានឈ្មោះថា ផស្សៈជាដើម ក្នុងកាលទាំងពួងផងដែរ ។ ម្យ៉ាងទៀត អរូបធម៌ទាំងឡាយ មានវេទនាជាដើម លោកហៅថា នាម ព្រោះមានការកាន់យកដែលទាក់ទងនឹងឈ្មោះ ព្រោះមិនដល់នូវភាពជាឈ្មោះ គឺការកាន់យកអង្គប្រកបដែលឈ្មោះដទៃ មិនបានចូលទៅសន្សំទុក ដូចជាសម្មស្សដោយការសួរឆ្លើយក៏មិនដល់នូវការសួរឆ្លើយ ដូច្នោះ ចំណែករូបសូម្បីវៀរការស្តាប់ឈ្មោះ ក៏រមែងដល់នូវការកាន់យកបានដោយសភាវៈ គឺការបែកធ្លាយបាននោះឯង ។ ពាក្យថា **គប្បីកំណត់ចុះ** សេចក្តីថា គប្បីតាំងទុកដោយមិនលាយឡំគ្នា អធិប្បាយថា គប្បីតាំងគ្នានឹងគ្នាទុកក្នុងចិត្ត ធ្វើមិនឲ្យប្រទ្បំគ្នាជាមួយរូបផង ។

ដែលឈ្មោះថា ការកំណត់កាន់យកនាម និងរូប ក៏ត្រឹមតែដើម្បីលះបង់នាម និងរូបនោះ ព្រោះហេតុនោះ លោកអាចារ្យកាលនឹងសម្តែងរូបសមគួរដល់នាម និងរូបនោះប៉ុណ្ណោះ ជាឧទាហរណ៍ ទើបពោលពាក្យជាដើមថា **ឧបមាយ៉ាងណា** ។ អត្ថថា ប្រែប្រួល ក្នុងពាក្យថា **ដោយការប្រែប្រួល** នេះ ខ្ញុំបានពោលទុកហើយ ក្នុង **ពណ៌នា នៃខន្ធនិទ្ទេស** ដោយពាក្យជាដើមថា **ការដល់នូវភាពមិនដូចគ្នា ក្នុងកាលវិរោធិប្បច្ច័យ មានត្រជាក់ជាដើមប្រជុំគ្នា** ដូច្នេះឯង ។ លោកអាចារ្យ កាលសម្តែងកំណត់កាន់យកនាម និងការកំណត់កាន់យករូបម្ខាងមួយ ចំណែកនេះហើយ ឥឡូវនេះ មានបំណងនឹងសម្តែងការកំណត់កាន់យកនាម និងរូបរួមគ្នា ទើបពោលពាក្យជាដើមថា **តអំពីនោះ ទើបកំណត់នាមរូប ដោយសង្ខេបថា វត្ថុដែលមានការបង្អោនទៅជាលក្ខណៈ ជានាម** ដូច្នេះ ។

លោកអាចារ្យ កាលសម្តែងការប្រាថ្នាវិបស្សនា ដោយគន្លងអរូប ដូច្នេះហើយ ឥឡូវនេះ កាលសម្តែងសេចក្តីប្រាថ្នាវិបស្សនានោះ ដោយគន្លងរូប ទើបពោលពាក្យ

ជាដើមថា **ចំណែកយោគាវចរដែលជាវិបស្សនាយានិកសុទ្ធៗ** ។ ក្នុងពាក្យនោះ យោគាវចរដែលជាសមថយានិក មានការប្រាថ្នាដោយសមថៈ ចំណែកយោគាវចរដែលជាវិបស្សនាយានិក មិនអាស្រ័យសមថៈ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **យោគាវចរដែលជាវិបស្សនាយានិកសុទ្ធៗ** ដូច្នេះ អធិប្បាយថា មានវិបស្សនាយានដែលមិនលាយឡំដោយសមថភាវនានោះឯង ។ ពីរបទថា **អយមេវ វា សមថយានិកោ** ប្រែថា ឬជាសមថយានិកតាមដែលពោលហើយនេះឯងក៏ដោយ ។ ដោយពាក្យនោះ លោកអាចារ្យរមែងសម្តែងថា សេចក្តីប្រាថ្នា វិបស្សនាដោយផ្លូវរូបរមែងមិនបានសូម្បីដល់យោគាវចរ ដែលជាសមថយានិក មិនបានដោយផ្លូវអរូបតែម្យ៉ាង ។ ពាក្យថា **បណ្តាផ្លូវកំណត់ធាតុនោះ** សេចក្តីថា បណ្តាផ្លូវកំណត់ធាតុ ១៣ ប្រការ ដែលពោលទុកហើយ ទាក់ទងជាមួយមនសិការ ដោយសង្ខេបជាដើម ដោយពាក្យជាដើមថា **របស់ណាមានលក្ខណៈរឹង របស់នោះ ជាបឋវីធាតុ** ដូច្នេះៗ សក់ដែលនៅក្នុងស្បែក ឈ្មោះថា មានកម្មជាសមុដ្ឋាន ។ បទថា **តត្ថេវ** ប៉ុនគ្នានឹង **តស្មឹយេវ យោគ កម្មសមុដ្ឋានេ កេសេ** ប្រែថា ក្នុងសក់ដែលមានកម្មជាសមុដ្ឋាននោះឯង លោកអាចារ្យពោលទុកថា **ព្រោះមានសភាវៈនៅផង** ដូច្នេះ ព្រោះភាវៈជ្រួតជ្រាបទូទៅពេញសរីរៈ ដូចកាយបសាទ ។ បទថា **តត្ថេវ** តទៅ សេចក្តីក៏ប៉ុនគ្នានឹង **តស្មឹយេវ យោគ កេសសញ្ញិតេ រូបសមុទាយេ** ប្រែថា ក្នុងក្រុមរូបដែលមានឈ្មោះថា សក់នោះដូចគ្នា ។ ពាក្យថា **រូបដទៃទៀត** បានដល់ រូប ២០ ដែលមានកម្មជាសមុដ្ឋាន ដែលបានពោលទុកខាងដើមហើយ រូប ២៤ មានអាហារសមុដ្ឋានរូបជាដើមនេះ រួមជារូប ៤៤ នោះឯង គប្បីជ្រាបដោយជាកំពូលនៃសន្តតិរូបដែលបានក្នុងរូបទាំងនោះស្មើគ្នា ពាក្យថា **រូប ៤៤ នេះ** លោកពោលទុកព្រោះសំឡេងជារូបមិនពិតប្រាកដ ។ ព្រោះថា សំឡេងរបស់ខ្លួន នោះឯងជារូបកើតឡើងអំពីឧតុ និងចិត្ត

រមែងកើតឡើងសព្វកាលទាំងពួងមិនបានឡើយ ។ ពាក្យថា ដូច្នោះ សេចក្តីថា ក្នុងសក់ យ៉ាងណា ក្នុងកោដ្ឋាស ២៤ ដែលជាចតុសមុដ្ឋាន មានរោមជាដើមក៏ដូច្នោះ ។ ពាក្យថា **ក្នុងកោដ្ឋាស ២៤** បានដល់ ញែកកោដ្ឋាសទាំង ៨ ដែលនឹងពោលដល់ក្នុងកោដ្ឋាស ៣២ ចេញទៅ ក៏ជាកោដ្ឋាស ២៤ ។ កោដ្ឋាសទាំងនោះ លោកពោលថា **មានឧតុ និងចិត្តជាសមុដ្ឋាន** ព្រោះកោដ្ឋាស មានញើសជាដើមកើតឡើង ដោយកម្តៅ និងការធ្វើទារុណកម្ម និងការប្រែប្រួលនៃចិត្ត ។

កាលរូបដែលនៅក្នុងកោដ្ឋាស ៣២ កើត ប្រាកដហើយ រូបដទៃអំពីកោដ្ឋាស ៣២ ក៏រមែងបានប្រាកដ ព្រោះហេតុនោះ ដើម្បីនឹងសម្តែងរូបទាំងនោះ ទើបលោកអាចារ្យពោលពាក្យជាដើមថា **អាការដទៃទៀត** ដូច្នេះ ។ ក្នុងពាក្យថា **អាការ ១០ ដទៃទៀត** បានដល់ អាការ ១០ ដទៃទៀត គឺតេជោកោដ្ឋាស ៤ វាយោកោដ្ឋាស ៦ ។ បទថា **កម្មជ្ជ** លោកពោលដល់កូតរូប មិនមែនជាពាក្យធ្វើឲ្យផ្សេងចេញទៅ ព្រោះតេជោញុំាងអាហារដែលបរិភោគចូលទៅជាដើមឲ្យរលួយ រមែងកើតអំពីកម្ម ។ លោកអាចារ្យពួកខ្លះពោលថា ឯបទថា **យថា ចិត្តជ្ជ** លោកពោលទុក ព្រោះខ្យល់ដង្ហើមចូល-ចេញ មានចិត្តជាសមុដ្ឋានដោយចំណែកមួយ សេចក្តីនោះ លោកពោលព្រោះខ្យល់ដង្ហើមចូល-ចេញ ប្រព្រឹត្តទៅក្នុងសន្តាន ដែលមិនមែនកើតអំពីចិត្ត មិនជាវត្ថុដែលកើតអំពីឧតុឡើយ ។ ឯខ្យល់ដង្ហើមចូល-ចេញនោះ ដែលតាំងនៅខាងក្នុងប៉ុណ្ណោះ ឈ្មោះថា **កើតអំពីចិត្ត** មិនមែនខ្យល់ដង្ហើមចូល-ចេញ ដែលនៅខាងក្រៅ ព្រោះហេតុនោះ ពាក្យថា **កើតអំពីចិត្ត** នេះ ក្នុងពាក្យនោះ ទើបជាពាក្យធ្វើឲ្យផ្សេងចេញទៅប៉ុណ្ណោះ សេចក្តីនេះ ខ្ញុំបានពោលទុកហើយ ក្នុងអនាបានកថាខាងដើមនោះឯង ។ ពាក្យថា **ក្នុងកោដ្ឋាសដ៏សេស** បានដល់ ក្នុងតេជោកោដ្ឋាស ៣ និងវាយោកោដ្ឋាស ៥ ដែលប្រព្រឹត្តទៅទាក់ទងជាមួយភ្លើងដែលធ្វើឲ្យក្តៅជាដើម

និងដែលទាក់ទងជាមួយខ្យល់ ដែលបក់ឡើងលើជាដើម ។

ក្នុងបណ្តារូបកលាបៈ មានចក្ខុទសកៈជាដើម រូបដែលជាប្រធាន បានដល់ចក្ខុជាដើម ព្រោះហេតុនោះ ទើបលោកអាចារ្យបានលើកកិច្ចបន្ទិចបន្តួច គឺវត្ថុ និងទ្វារដែលបានក្នុងរូប មានចក្ខុទាំងនោះឡើងទុកក្នុងសង្គហៈ ពោលថា **រូបកលាបៈ ៥ មានចក្ខុទសកៈជាដើម ដោយជាវត្ថុ និងទ្វារ** ដូច្នេះ ។ គប្បីប្រកបពាក្យថា ហទយវត្ថុទសកៈដោយជាវត្ថុឯកទេស រមែងអនុលោមតាមពាក្យដែលបានសម្តែងលម្អិតទុក ដោយប្រកបទុកពាក្យមួយដូច្នេះ ។ ពាក្យថា **រូបទាំងពួង** បានដល់ រូបរូបចំនួន ១៤៩៤ ក្នុងការរាប់រូបតាមដែលបានពោលហើយ ។ តែកាលកាន់យកប្រភេទនៃចំណែកបន្តិចបន្តួចរបស់កោដ្ឋាសនិងរូបកលាបៈដែលជាចំណែកបន្តិចបន្តួចរបស់កោដ្ឋាសទាំងនោះ ក៏នឹងមានប្រភេទនៃរូបច្រើនក្រៃលែងជាងនោះ ហួសនឹងប្រៀបបាន តែប្រភេទនោះមិនគួរកាន់យក ព្រោះកំណត់កាន់យកបាន លំបាកដល់យោគាវចរដែលជាអាទិកម្មិកក្នុងទីនេះ ។

លោកអាចារ្យពោលថា **អរូបធម៌ទាំងឡាយ រមែងប្រាកដជាទ្វារ** ដូច្នេះ ព្រោះធ្វើអធិប្បាយថា អរូបធម៌ទាំងឡាយ រមែងប្រាកដដោយជាវត្ថុក៏ពិត សូម្បីយ៉ាងនោះ ការកំណត់កាន់យកដោយជាទ្វារ ក៏មិនលាយឡំគ្នា ។ លោកពោលថា **លោកិយចិត្ត ៨១** ដូច្នេះ ទាក់ទងដោយជាចិត្តដែលរួបរួមទុកទាំងអស់ តែមហគ្គតចិត្ត រមែងប្រាកដល្អដល់ព្រះយោគាវចរដែលបានប៉ុណ្ណោះ ។ ពាក្យថា **ដោយមិនប្លែកគ្នា** គឺដោយទូទៅ ។ មែនពិត ចេតសិក ៧ ដួង មានផស្សៈជាដើម កើតទូទៅដល់ចិត្តុប្បាទគ្រប់ដួង ព្រោះកើតឡើងសូម្បីជាមួយចក្ខុវិញ្ញាណជាដើម ។ ពាក្យថា **ទាំងពួងនោះ** បានដល់ អរូបធម៌ទាំងឡាយនោះ គឺលោកិយចិត្ត ៨១ ចេតសិក មានផស្សៈជាដើមដែលសម្បយុត្តជាមួយលោកិយចិត្តនោះ ។ ក៏កាលកាន់យកប្រភេទ ចិត្តុប្បាទដោយ

វិភាគ មានអារម្មណ៍ជាដើម អត្ថរមែងមានច្រើនយ៉ាងក្រៃលែងនោះឯង តែអត្ថនោះលោកមិនមានបំណងយកក្នុងទីនេះ ។

ក្លាប់សេចក្ដីថា ឯធាតុទាំង ៤ ដែលជាទីអាស្រ័យនៃចក្ខុបសាទនោះ ។ ក្លាប់សេចក្ដីថា សហជាតរូបរបស់ចក្ខុបសាទនោះ ដូច្នេះដូចគ្នា ។ បទថា **តត្ថ** សេចក្ដីប៉ុនគ្នានឹង **តស្មឹយេវ យោគ សសម្ភារចក្ខុបទេសេ** ប្រែថា ក្នុងចំណែកសសម្ភារៈចក្ខុនោះឯង ។ ពាក្យថា **អនុបាទិន្នរូប** លោកពោលទុកព្រោះរូបដែលពោលទុកក្នុងកាលមុនជាឧបាទិន្នរូប សេចក្ដីថា បានដល់ អកម្មជរូប ។ ពាក្យថា **រូបដ៏សេស** បានដល់រូបដ៏សេសអំពីចក្ខុនោះ ព្រោះចក្ខុបានពោលទុកមុនហើយ រួមជាមួយចក្ខុនោះ ក៏ជារូប ៥៤ ។ ពាក្យថា **រូប ៤៣ ដ៏សេស** លោកពោលទុក ព្រោះមិនចាំបាច់កាន់យកសូម្បី ១ ទសកៈ ក្នុងបណ្ដាទសកៈទាំងឡាយ មានចក្ខុទសកៈជាដើម ។ លោកអាចារ្យពោលថា រូប ៤៣ ដូច្នេះ ព្រោះមិនកាន់យកសទ្ទរូបនោះ ព្រោះសទ្ទរូបជាអនិយតហើយសម្ដែងវាទៈរបស់កេចិអាចារ្យតទៅថា រូប ៤៥ ព្រោះកាន់យកសទ្ទរូបទាំង ២ ដែលមានឧតុ និងចិត្តជាសមុដ្ឋាន ។

ពាក្យថា **រូបដ៏សេស** បានដល់ និប្ផន្នរូប ៦ ដ៏សេស វៀររូបធម៌ ១២ ដែលលោកពោលថា **ធាតុ ១០** ។ ក្នុងទីនេះ លោកកំណត់កាន់យករូបរូបប៉ុណ្ណោះ មិនមែនកំណត់កាន់យកបរិច្ឆេទនៃរូប វិការនៃរូប និងលក្ខណៈនៃរូប ។ ចក្ខុវិញ្ញាណទាំង ២ លោកពោលថា ចិត្តនោះឯង ព្រោះជាកុសលវិបាក និងអកុសលវិបាក ដែលដឹងរូបារម្មណ៍ មានចក្ខុជាទីអាស្រ័យស្មើគ្នា និងដោយជាចិត្តស្មើគ្នា ។ ដោយពាក្យថា **យ៉ាងនេះ** នេះ លោកអាចារ្យរមែងសង្គ្រោះយកពាក្យដែលពោលទុក ដោយន័យជាដើមថា **អាស្រ័យចក្ខុ** ដូច្នេះ និងពាក្យជាដើមថា **អាស្រ័យសោតៈ** ដែលមិនបានពោលទុក ។ សូម្បីក្នុងពាក្យថា **មនោវិញ្ញាណធាតុ** នេះ ក៏គប្បីនាំយកបទថា មួយ

មកគួបថា **មនោវិញ្ញាណធាតុ ១** ដូច្នេះ ។ ធាតុ ១១ និងកន្ទះ ឈ្មោះថា **អឌ្ឍេកាទស** ប្រែថា ១០ កន្ទះ ។ ម្យ៉ាងទៀត ជា ១១ ទាំងកន្ទះរបស់ធាតុទាំងនេះ ហេតុនោះ ធាតុទាំងនេះ ឈ្មោះថា **អឌ្ឍេកាទស** ប្រែថា គម្រប់ ១១ ទាំងកន្ទះ គឺ ១០ កន្ទះ ។ សូម្បីក្នុងបទថា **អឌ្ឍដ្ឋមា** ប្រែថា គម្រប់ ៨ ទាំងកន្ទះ គឺធាតុ ៧ កន្ទះ ក៏មានន័យនេះដូចគ្នា ។

ពាក្យថា **តាមន័យដែលពោលទុកក្នុងចក្ខុធាតុនោះឯង** គឺតាមន័យដែលពោលហើយ ដោយពាក្យជាដើមថា ស្អាតដោយកែវភ្នែក ស និងខ្មៅ ដែលអ្នកស្រុកតែងស្គាល់ថា ចក្ខុ ។

ពាក្យថា **ភិក្ខុក្នុងសាសនានេះ កំណត់ថា រូប ១៧ ក្នុងសរីរៈនេះ** លោកពោលទុកដោយអំណាចសម្ដែងសេចក្ដីប្រាថ្នាក្នុងវិបស្សនាខាងក្នុង ដោយហេតុនោះឯង ទើបលោកអាចារ្យពោលថា **រូប ១៧ គួរដល់ការពិចារណា** ដូច្នេះ ព្រោះលោកកាន់យកការៈតែម្យ៉ាងប៉ុណ្ណោះ ។ រូប ១៧ គប្បីអាចដើម្បីពិចារណា រមែងចូលដល់ការពិចារណា ព្រោះហេតុនោះ ទើបឈ្មោះថា **សម្មសនុបគានិ** ប្រែថា ចូលដល់នូវការពិចារណា សេចក្ដីថា គួរដល់ការពិចារណា ។ អាចារ្យទាំងឡាយពោលថា វិញ្ញត្តិទាំង ២ លោកពោលទុកដោយសព្ទថា **អាការ** រូប ៣ មានលហុតារូបជាដើម លោកពោលទុកដោយសព្ទថា **វិការ** អាកាសធាតុ លោកពោលទុកដោយសព្ទថា គ្រឿងកំណត់កាត់ចន្លោះក្រៅអំពីនេះ ។ ម្យ៉ាងទៀត លោកអាចារ្យពោលលក្ខណរូប និងវិញ្ញត្តិរូបទាំង ២ ដោយសព្ទថា **អាការ** ។ ឯលក្ខណរូបនោះ ក៏ត្រឹមតែអាការនៃការកើតឡើងជាដើមរបស់រូបទាំងឡាយ ។ ពាក្យថា **គ្រឿងកំណត់កាត់ចន្លោះ** បានដល់គ្រឿងកំណត់កាត់ដែលជាចន្លោះ ព្រោះជាហេតុ មិនលាយឡំគ្នានៃកលាបៈនោះៗ ។ លោកអាចារ្យពោលពាក្យជាដើមថា **តែ** ដូច្នេះ ដើម្បីចៀសវាងពាក្យសួរថា បើរូប

១០ មិនមែនជារូបគួរដល់ការពិចារណា និងត្រឹមតែជាអាការជាដើម នឹងជារូបបាន ដូចម្ដេច ។

លោកអាចារ្យ កាលញ៉ាំងការកំណត់រូបឲ្យជាក់ច្បាស់ដោយពិស្ដារ ទាក់ទង ដោយកោដ្ឋាស ៤២ ញ៉ាំងការកំណត់នាមឲ្យជាក់ច្បាស់ដោយពិស្ដារដូចគ្នា ដោយទំនង ការកំណត់រូបនោះហើយ តអំពីនោះ សម្ដែងការកំណត់រូប និងអរូបដោយសង្ខេប យ៉ាងបង្រួញជាង និងយ៉ាងសង្ខេបបំផុត ដោយជាធាតុ ១៨ អាយតនៈ ១២ និង ដោយខន្ធ ៥ យ៉ាងនេះហើយ មានបំណងនឹងសម្ដែងរូបនោះ ដោយន័យដែលបង្រួញ ក្រៃលែង ទើបពោលពាក្យជាដើមថា **រូបឯណានីមួយ** ដូច្នេះ បណ្ឌិតគប្បីជ្រាបការ កំណត់រូប និងអរូប ដោយជាឥន្ទ្រិយ សច្ចៈ និងបដិច្ចសមុប្បាទ ដូចដែលកំណត់ដោយ ធាតុជាដើម ។ កំណត់ដូចម្ដេច ? កំណត់ដោយជាឥន្ទ្រិយមុន ឥន្ទ្រិយ ៧ គឺឥន្ទ្រិយ ៥ មានចក្ខុជាដើម និងឥត្ថិន្ទ្រិយ បុរិសិន្ទ្រិយ ចាត់ជារូប ឥន្ទ្រិយ ១១ គឺមនិន្ទ្រិយ ១ ឥន្ទ្រិយ គឺវេទនា ៥ និងឥន្ទ្រិយ ៥ មានសទ្ធាជាដើម ចាត់ជានាម ជីវិតិន្ទ្រិយ ចាត់ ជានាមផង ចាត់ជារូបផង ឥន្ទ្រិយ ៣ ខាងក្រោយ លោកមិនសង្គ្រោះចូលក្នុងទីនេះ ព្រោះជាលោកុត្តរ ។ ទុក្ខសច្ច ចាត់ជានាមផង ចាត់ជារូបផង សមុទយសច្ច ចាត់ ជានាម សច្ចៈក្រៅអំពីនេះ លោកមិនមានបំណងយកក្នុងទីនេះ ព្រោះជាលោកុត្តរ ។ អង្គ ៣ ខាងដើម ក្នុងបច្ចយាការ ចាត់ជានាម អង្គទី ៤ និងទី ៥ ចាត់ជានាមផង ចាត់ ជារូបផង អង្គទី ៦-៧-៨ និងទី ៩ ចាត់ជានាម អង្គទី ១០ ចាត់ជានាមផង ចាត់ជា រូបផង អង្គ ២ ខាងក្រោយ មួយអង្គៗ ចាត់ជានាមផង ចាត់ជារូបផង បណ្ឌិតគប្បី ធ្វើការកំណត់នាម រូប ដោយចាត់ជាឥន្ទ្រិយ សច្ចៈ និងបច្ចយាការតាមទំនងនៃពាក្យ មានន័យ ដូចបានពោលហើយ ក្នុងទីនោះៗ ដោយប្រការដូចពោលមកនេះ ។ ប្រយោជន៍ ក្នុងការពោលដោយវិភាគ នៃការកំណត់នាមរូបយ៉ាងនេះ បានពោលទុកហើយខាង

ដើមនោះឯង ។

បណ្ដាអរូបធម៌ទាំងឡាយ មានវេទនាជាដើម អរូបធម៌ដែលកើតមុនៗ មិនល្អិតដូចជាអរូបធម៌ដែលខ្ពស់ឡើងៗ ទៅឡើយ ក៏ពិត សូម្បីយ៉ាងនោះ អរូបធម៌ទាំងអស់បើប្រៀបធៀបនឹងរូបធម៌ទាំងឡាយ ដែលដល់នូវការប្រែប្រួល ដោយការប៉ះខ្ទប់គ្នា ក៏ជាធម៌ល្អិតនោះឯង ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា អរូបមិនទាន់ប្រាកដ ព្រោះជាធម៌ល្អិត ។ ពាក្យថា **គប្បីពិចារណា** គឺគប្បីស្ទាបស្ទង់ ដោយលក្ខណៈជាដើមយ៉ាងត្រឹមត្រូវនោះឯង ។ ពាក្យថា **គប្បីធ្វើទុកក្នុងចិត្ត** គឺគប្បីតាំងទុកដោយចិត្តយ៉ាងនោះ ។ ពាក្យថា **គប្បីកំណត់កាន់យក** គឺគប្បីកំណត់ដោយបញ្ញាដែលធ្វើការកំណត់ ហើយកាន់យក ។ ពាក្យថា **គប្បីបំបែក** គឺគប្បីកាត់សម្រេចដោយមិនលាយឡំគ្នានឹងគ្នា ។ បទថា **អស្ស យោគ យោគិនោ** ។ បទថា **សុវិក្ខាលិតំ** ប្រែថា ជាវត្ថុដែលបរិសុទ្ធល្អ ។ កាលព្រះយោគាវចរ ដែលជាអាទិកម្មិក កំណត់កម្មដ្ឋានធម៌ទាំងឡាយ មិនទាន់ប្រាកដជាក់ច្បាស់ល្អ ដរាបណាធម៌ទាំងនោះ ក៏មិនទាន់ត្រូវកម្ចាំងគឺសម្មោហៈដែលបិទបាំងធម៌នោះគ្របសង្កត់ រមែងជាធម្មជាតិ ឈ្មោះថា **មិនបរិសុទ្ធ** ក៏នៅជាប់ទាក់ទងគ្នានឹងគ្នា ព្រោះមិនមានការប្រាកដ ដោយការមិនលាយឡំគ្នា ។ តែកាលណាជាក់ច្បាស់ដោយពិធី មានការពិចារណាជាដើម កាលនោះ ធម៌ទាំងនោះបរិសុទ្ធល្អហើយ និងរមែងជាសភាវៈឈ្មោះថា មិនមានអ្វីជាប់ទាក់ទង ។ ដោយហេតុនោះ ទើបលោកអាចារ្យពោលពាក្យជាដើមថា **ព្រោះថា រូបជាវត្ថុដែលស្អាតបរិសុទ្ធ មិនមានអ្វីប្រឡាក់ប្រឡូសដោយប្រការណាមួយ** ដូច្នេះ ។ លោកអាចារ្យពោលថា **អរូបធម៌ទាំងឡាយ ដែលមានរូបធម៌នោះជាអារម្មណ៍** ដូច្នេះ ព្រោះធ្វើអធិប្បាយថា អរូបធម៌ទាំងឡាយ រមែងដល់នូវការកាន់យកដោយអាការប្រព្រឹត្តទៅ ប្រារព្ធរូបធម៌ទាំងឡាយដោយ ច្រើនដល់យោគាវចរ ដែលជាអាទិកម្មិក ។ ដោយហេតុនោះឯង

ក្នុងខាងដើម ទើបលោកអាចារ្យពោលទុកថា **អរូបធម៌ទាំងឡាយ រមែងប្រាកដជាទ្វារដល់យោគាវចរនោះ ដែលមានរូបកំណត់ហើយយ៉ាងនេះ** មិនមែនប្រាកដដោយជាវត្ថុ ។

ឥឡូវនេះ លោកអាចារ្យមានបំណងប្រកាសអត្ថ តាមដែលបានពោលហើយថា ការកំណត់រូបជាឧបាយ និងជាការឧបត្ថម្ភនៃការកំណត់អរូប ដោយឧបមាទាំងឡាយ ទើបពោលពាក្យជាដើមថា ដូចជា **ពងត្រី មានឧបមាយ៉ាងណា** ។ ពាក្យថា **ស្រមោលមុខ** បានដល់ រូបប្រៀបរបស់មុខ ។ ក្នុងពាក្យនោះ មានការប្រៀបធៀបឧបមាដូច្នេះ ។

ព្រះយោគាវចរប្រៀបដូចបុរសភ្នែកល្អ ញាណកំណត់កម្មដ្ឋានរបស់យោគីប្រៀបដូចភ្នែករបស់បុរសនោះ ការកំណត់រូបប្រៀបដូចកញ្ចក់ ការកំណត់អរូបប្រៀបដូចស្រមោល វេលាដែលការកំណត់រូបមិនបរិសុទ្ធ ប្រៀបដូចកញ្ចក់ដែលអ័ព្ទការដែលអរូបទាំងឡាយមិនប្រាកដ ព្រោះការកំណត់រូបមិនទាន់បរិសុទ្ធ ប្រៀបដូចការមិនប្រាកដស្រមោលមុខក្នុងវេលានោះ ការកំណត់រូបឲ្យបរិសុទ្ធរឿយៗ ប្រៀបដូចការជុសខាត់កញ្ចក់រឿយៗ ការប្រាកដដោយល្អនៃអរូបធម៌ទាំងឡាយ ក្នុងកាលកំណត់រូបបរិសុទ្ធល្អ មិនមានអ្វីប្រឡាក់ប្រឡូស ប្រៀបដូចការប្រាកដល្អនៃស្រមោលមុខជាក់ច្បាស់ក្នុងកញ្ចក់ដែលជុសខាត់ល្អហើយ គប្បីជ្រាបការប្រៀបធៀបការឧបមាតាមគួរ សូម្បីពាក្យឧបមាទាំងឡាយ **មានឧបមាដោយបុគ្គលដែលត្រូវការប្រេង**ជាដើម ដោយន័យនេះ ។ ពាក្យថា **ម្សៅល្ង** បានដល់ ល្ងបុក ។ ពាក្យថា **គ្រាប់ល្មៀង** បានដល់ ផ្លែឈើល្មៀង ។ ពាក្យថា **កករទឹកតូចៗ** បានដល់ កករតូចៗ ។

ពាក្យថា **ដែលជាសត្រូវដល់ញាណកំណត់អរូបធម៌** បានដល់ កិលេស មានសម្មោហៈជាដើម ដែលជាបដិបក្ខដោយជាធម្មជាតិរាំងចំពោះញាណ ដែលកំណត់

អរូបធម៌នោះ ។ ក្នុងពាក្យឧបមា **មានអំពៅ** ជាដើម មានពាក្យសម្ដែងល្មមជាគន្ធង ដូចតទៅនេះ បុគ្គលត្រូវការទឹកអំពៅ ដាក់អំពៅចូលទៅក្នុងឃ្នាប កាលទឹកអំពៅ មិនទាន់ចេញ ដោយត្រឹមតែឃ្នាបវិលទៅបានម្ដង ឬពីរដង ក៏មិនបានចោលអំពៅ យ៉ាងណា ម្យ៉ាងទៀត រាជបុរសដែលចាប់ចោរបាន ត្រូវការដឹងកំហុស ដែលពួកចោរធ្វើ កាលចោរមិនទាន់ប្រាប់សេចក្ដីនោះ ដោយត្រឹមតែវាយ ២-៣ ដង ក៏នៅមិនទាន់ដោះ លែងពួកចោរទៅ យ៉ាងណា ម្យ៉ាងទៀត អ្នកហ្វឹកគោ ត្រូវការបង្ហឹកគោ ទើបចាប់ទឹម ក្នុងនឹម កាលគោមិនព្រមដើរទៅតាមផ្លូវម្ដង ពីរដង ក៏មិនទាន់ដោះវា ម្យ៉ាងទៀត បុគ្គល ត្រូវការកូរទឹកដោះជូរ កាន់យកទឹកដោះខាប់ ដាក់ម្សៅនំចុះក្នុងឆ្នាំងទឹកដោះជូរ ត្រឹមតែ កូរម្សៅនំម្ដង ឬពីរដង កាលមិនទាន់កើត ជាទឹកដោះខាប់ ក៏មិនទាន់ចោលទឹកដោះជូរ យ៉ាងណា ម្យ៉ាងទៀត បុគ្គលត្រូវការ អាំងត្រីបរិភោគ ត្រឹមភ្លើងរលត់ម្ដង ពីរដង កាលត្រីមិនទាន់ឆ្អិន ក៏មិនចោលត្រី ទាំងនោះ ដូច្នេះ ។ បណ្ឌិតគប្បីប្រកបអត្ថនៃឧបមា ក្នុងទីគ្រប់កន្លែង ដោយពាក្យជាដើមថា **កាលនោះឯង បុគ្គលរមែងគាបអំពៅនោះ រឿយៗ ក្នុងឃ្នាបនោះ** តាមទំនងនៃពាក្យ មានន័យដូចបានពោលហើយ ក្នុងពាក្យ នេះថា **កាលនោះឯង បុគ្គលរមែងជុសខាត់កញ្ចក់នោះរឿយៗ ទៅ** ដូច្នេះ ។

# វិសុទ្ធិមគ្គ

## អរូបធម៌ប្រាកដដោយអាការ ៣

ឯអរូបធម៌ទាំងឡាយ រមែងប្រាកដដល់ភិក្ខុដែលមានការកំណត់រូប ដែលបរិសុទ្ធិល្អបានយ៉ាងនេះហើយ ដោយអាការ ៣ គឺដោយអំណាចផស្សៈខ្លះ ដោយអំណាចវេទនាខ្លះ ដោយអំណាចវិញ្ញាណខ្លះ ប្រាកដដូចម្តេច ?

## អរូបធម៌ប្រាកដដោយផស្សៈ

លំដាប់ដំបូង កាលព្រះយោគាវចរភិក្ខុអង្គណាមួយ កំណត់ធាតុទាំងឡាយដោយន័យថា **បឋវីធាតុ មានការរឹងជាលក្ខណៈ** ដូច្នេះជាដើម អរូបធម៌ដែលធ្លាក់ចុះមកចំពោះមុខជាដំបូង ឈ្មោះ **ផស្សៈ** រមែងប្រាកដ តអំពីនោះ វេទនាដែលសម្បយុត្តជាមួយផស្សៈនោះ ឈ្មោះថា **វេទនាខន្ធ** ក៏ប្រាកដ សញ្ញាដែលសម្បយុត្តជាមួយផស្សៈនោះ ឈ្មោះ **សញ្ញាខន្ធ** ក៏ប្រាកដ ចេតនារួមជាមួយផស្សៈ ឈ្មោះ **សង្ខារក្ខន្ធ** ក៏ប្រាកដ ចិត្តឈ្មោះ **វិញ្ញាណក្ខន្ធ** ក៏ប្រាកដ ដោយន័យដូចគ្នានោះ កាលព្រះយោគាវចរភិក្ខុកំណត់ធាតុទាំងឡាយ ( យ៉ាងពិស្តារ ) ដោយន័យថា **បឋវីធាតុក្នុងសក់ មានការរឹងជាលក្ខណៈ ។បេ។ បឋវីធាតុក្នុងខ្យល់ ដង្ហើមចូល-ចេញមានការរឹងជាលក្ខណៈ** ដូច្នេះជាដើម អរូបធម៌ដែលធ្លាក់ចុះមកចំពោះមុខដំបូង ឈ្មោះ **ផស្សៈ** រមែងប្រាកដ ( តអំពីនោះ ) វេទនាដែលសម្បយុត្តជាមួយផស្សៈនោះ ឈ្មោះ **វេទនាខន្ធ** ក៏ប្រាកដ ។បេ។ ចិត្ត ឈ្មោះ **វិញ្ញាណក្ខន្ធ** ក៏ប្រាកដ ។

អរូបធម៌ទាំងឡាយ ប្រាកដដោយអំណាចផស្សៈដូចពោលមក ដូច្នេះ ។

## អរូបធម៌ប្រាកដដោយវេទនា

កាលព្រះយោគាវចរភិក្ខុអន្តណានីមួយកំណត់ធាតុទាំងឡាយ ដោយន័យថា **បឋវីធាតុ មានការរឹងជាលក្ខណៈ** ដូច្នេះជាដើម វេទនាដែលសោយរសនៃសភាវៈគឺការរឹងនោះ ឈ្មោះ **វេទនាខន្ធ** ប្រាកដ ( មុនហើយ ) សញ្ញាដែលសម្បយុត្តជាមួយវេទនានោះ ឈ្មោះ **សញ្ញាខន្ធ** ក៏ប្រាកដ ផស្សៈ និងចេតនាដែលសម្បយុត្តជាមួយវេទនានោះ ឈ្មោះ **សង្ខារក្ខន្ធ** ក៏ប្រាកដ ចិត្តដែលសម្បយុត្តជាមួយវេទនានោះ ឈ្មោះ **វិញ្ញាណក្ខន្ធ** ក៏ប្រាកដ ដោយន័យដូច្នោះ កាលយោគាវចរភិក្ខុកំណត់ធាតុទាំងឡាយ ( ដោយពិស្តារ ) ដោយន័យថា **បឋវីធាតុក្នុងសក់ មានការរឹងជាលក្ខណៈ ។បេ។ បឋវីធាតុក្នុងខ្យល់ដង្ហើមចូល-ចេញ មានការរឹងជាលក្ខណៈ** ដូច្នេះជាដើម វេទនាដែលសោយរសនៃសភាវៈ គឺការរឹងនោះ ឈ្មោះ **វេទនាខន្ធ** រមែងប្រាកដ ( មុន ) ។បេ។ ចិត្តដែលសម្បយុត្តជាមួយវេទនានោះ ឈ្មោះ **វិញ្ញាណក្ខន្ធ** ក៏ប្រាកដ ។

អរូបធម៌ទាំងឡាយ ប្រាកដដោយអំណាចវេទនាដូចពោលមក ដូច្នេះ ។

## អរូបធម៌ប្រាកដដោយវិញ្ញាណ

កាលព្រះយោគាវចរភិក្ខុអន្តដទៃទៀត កំណត់ធាតុទាំងឡាយ ដោយន័យថា **បឋវីធាតុ មានការរឹងជាលក្ខណៈ** ដូច្នេះជាដើម វិញ្ញាណដែលដឹងច្បាស់ចំពោះអារម្មណ៍ ឈ្មោះ **វិញ្ញាណក្ខន្ធ** ប្រាកដ (មុនហើយ) វេទនាដែលសម្បយុត្តជាមួយវិញ្ញាណនោះ ឈ្មោះ **វេទនាខន្ធ** ក៏ប្រាកដ សញ្ញាដែលសម្បយុត្តជាមួយ វិញ្ញាណនោះ ឈ្មោះ **សញ្ញាខន្ធ** ក៏ប្រាកដ ផស្សៈ និងចេតនា ឈ្មោះ **សង្ខារក្ខន្ធ** ក៏ប្រាកដ ដោយន័យដូចគ្នានោះ កាលព្រះយោគាវចរភិក្ខុកំណត់ធាតុទាំងឡាយ ដោយន័យថា **បឋវីធាតុ**

ក្នុងសក់ មានការរឹងជាលក្ខណៈ ។បេ។ បឋវីធាតុក្នុងខ្យល់ដង្ហើមចូល-ចេញ មានការរឹងជាលក្ខណៈ ដូច្នេះជាដើម វិញ្ញាណដែលដឹងច្បាស់នូវអារម្មណ៍ ( នោះ ) ឈ្មោះ **វិញ្ញាណក្ខន្ធ** ប្រាកដ ( មុនហើយ ) វេទនាដែលសម្បយុត្តជាមួយវិញ្ញាណនោះ ឈ្មោះ **វេទនាខន្ធ** ក៏ប្រាកដ សញ្ញាដែលសម្បយុត្ត ជាមួយវិញ្ញាណនោះ ឈ្មោះ **សញ្ញាខន្ធ** ក៏ប្រាកដ ផស្សៈ និងចេតនាដែលសម្បយុត្តជាមួយវិញ្ញាណនោះ ឈ្មោះ **សង្ខារក្ខន្ធ** ក៏ប្រាកដ ។

អរូបធម៌ទាំងឡាយ ប្រាកដដោយអំណាចនៃវិញ្ញាណ ដូចពោលមកដូច្នេះ ។

ដោយឧបាយនេះឯង បណ្ឌិតគប្បីធ្វើយោជនា ( ការប្រកបសេចក្តី ) ក្នុងកោដ្ឋាសនៃធាតុ ៤២ ដោយន័យថា **បឋវីធាតុក្នុងសក់ ដែលមានកម្មជាសមុដ្ឋាន មានការរឹងជាលក្ខណៈ** ដូច្នេះជាដើម និងក្នុងធាតុដ៏សេស មានចក្ខុធាតុជាដើម ដោយអំណាចនៃធាតុបួនៗ ( គឺកំណត់ចក្ខុជាដើមតាមលក្ខណៈធាតុទាំង ៤ ជាដើម ) ទៅតាមប្រភេទនៃន័យទាំងពួង ក្នុងមាតិកាការកំណត់រូបចុះ ។

ម្យ៉ាងទៀត ព្រោះហេតុដែលអរូបធម៌ទាំងឡាយ រមែងប្រាកដដោយអាការ ៣ដល់ភិក្ខុដែលមានការកំណត់រូបដែលបរិសុទ្ធយ៉ាងនេះប៉ុណ្ណោះ ហេតុនោះ ព្រះយោគាវចរគប្បីធ្វើយោគដើម្បីកំណត់អរូបធម៌ ដោយការកំណត់រូបដែលបរិសុទ្ធល្អនោះឯង មិនគប្បីធ្វើដោយការកំណត់ដទៃឡើយ ព្រោះបើរូបធម៌ ១ ឬ ២ ប្រភេទ ប្រាកដ ( មិនទាន់បរិសុទ្ធល្អ ) លោកលះរូបចោល ផ្តើមកំណត់អរូបសោត លោកនឹងវិនាសអំពីកម្មដ្ឋានក៏បាន ដូចគោដែលរកស៊ីលើភ្នំ ( មិនស្គាល់ដែនដើរទៅរអិលធ្លាក់ជ្រោះ ) មានប្រការដូចពោលក្នុង ( វគ្គ ) បំពេញក្នុងបឋវីកសិណ តមក កាលលោកធ្វើយោគដើម្បីកំណត់អរូប ដោយការកំណត់រូបដែលបរិសុទ្ធល្អហើយ ទើបកម្មដ្ឋានដល់នូវការចម្រើនលូតលាស់បរិបូណ៌ ។

ព្រះយោគាវចរនោះកំណត់យកអរូបក្ខន្ធ ៤ ដែលប្រាកដដោយអំណាចនៃផស្សៈជាដើម ថាជានាម កំណត់យកមហាភូតរូប ៤ ដែលជាអារម្មណ៍នៃអរូបក្ខន្ធនោះ និងឧបាទាយរូប ថាជារូប ដោយប្រការដូច្នេះ ។

ព្រះយោគាវចររមែងកំណត់ធម៌ទាំងឡាយដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ទាំងអស់ គឺធាតុ ១៨ អាយតនៈ ១២ ខន្ធ ៥ ចែកជា ២ ចំណែក គឺនាម ១ រូប ១ ដូចបុគ្គលបើកស្នូកដោយដាវ និងដូចបុគ្គលពុះកំពឹងត្នោតដោយដាវ ដូច្នោះ លោករមែងដល់នូវការផ្តាច់ចេញពីគ្នាថា *ក្រៅអំពីនាមរូបហើយ វត្ថុដទៃជាសត្តក្តី បុគ្គលក្តី ទេវតាក្តី ព្រហ្មក្តី មិនមាន ។*

# មហាដីកា

## កថាពណ៌នាដោយអាការប្រាកដ

## នៃអរូបធម៌

ធម៌ទាំងឡាយ រមែងរកត់រាយទៅ គឺរមែងប្រឈមមុខដោយសភាវៈទាំងនេះ ហេតុនោះ សភាវៈទាំងនេះ ឈ្មោះថា **អាការ** ប្រែថា ជាគ្រឿងរកត់រាយទូទៅ បានដល់ប្រការ គឺការពាល់ត្រូវ ការសោយ និងការដឹងច្បាស់ ដែលជាគន្លងនៃការប្រាកដរបស់អរូបធម៌ទាំងឡាយ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលពាក្យជាដើមថា **អរូបធម៌ទាំងឡាយ រមែងប្រាកដដោយអាការ ៣ យ៉ាង** ដូច្នេះ ។ សូម្បីមិនទាន់មានចិត្ត និងចេតសិក ដែលប្រព្រឹត្តទៅក្នុងអារម្មណ៍ ផស្សៈដែលមានការពាល់ត្រូវក្នុងអារម្មណ៍ ទាំងក្នុងខាងដើម និងខាងចុងជាលក្ខណៈ រមែងដូចធ្លាក់ចុះចំពោះមុខមុនអរូបធម៌ទាំងឡាយ ក្នុងបណ្ដាចិត្ត និងចេតសិកទាំងនោះ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **ការដែលអរូបធម៌ធ្លាក់ចុះមក ចំពោះមុខដំបូង** ឈ្មោះថា **ផស្សៈ** ។ ព្រោះហេតុនោះ ទើបលោកអាចារ្យសម្ដែងការប្រាកដដោយអាការពាល់ត្រូវរបស់ផស្សៈនោះ ដោយភាវៈដែលជាក់ច្បាស់ល្អ កាលផស្សៈប្រាកដហើយ ផស្សៈនោះ នៅក្នុងអារម្មណ៍ណា វេទនាក៏មានការសោយអារម្មណ៍នោះ ជាលក្ខណៈ សញ្ញាក៏មានការចាំអារម្មណ៍នោះជាលក្ខណៈ ចេតនាមានការប្រមូលមកនូវអារម្មណ៍នោះជាលក្ខណៈ វិញ្ញាណមានការទទួលដឹងអារម្មណ៍នោះ ជាលក្ខណៈ ព្រោះហេតុនោះ ធម៌ទាំងនេះ ក៏ជាធម៌ប្រាកដដូច្នេះ ទើបលោកអាចារ្យពោលពាក្យជាដើមថា **វេទនាដែលសម្បយុត្តជាមួយផស្សៈនោះ** ដូច្នេះ ។ លោកអាចារ្យ កាលសម្ដែងការកំណត់អរូបតាមរយៈផស្សៈ ទាក់ទងនឹងការកំណត់ធាតុ ៤ ដោយសង្ខេបលក្ខណៈរបស់ខ្លួន

យ៉ាងនេះហើយ ឥឡូវនេះ មានបំណងសម្ដែងការកំណត់អរូបនោះ ទាក់ទងនឹងការកំណត់ធាតុ ៤ ដោយពិស្ដារ ទើបពោលពាក្យជាដើមថា **ដោយន័យដូចគ្នានោះ** កាលព្រះយោគាវចរកំណត់ធាតុដោយពិស្ដារថា **បឋវីធាតុក្នុងសក់ មានលក្ខណៈរឹង** ដូច្នេះ ។ ក្នុងពាក្យនោះ ពាក្យថា **បឋវីធាតុក្នុងសក់** បានដល់ បឋវីធាតុក្នុងចំណែកនៃបឋវីដែលហៅថា **សក់** ។សេចក្ដីនេះ ជាពាក្យសម្ដែងការកំណត់ធាតុ ដោយចែកលក្ខណៈរបស់ខ្លួន ។

លោកអាចារ្យ មានបំណងសម្ដែងការកំណត់អរូប តាមបែបវេទនា ទាក់ទងនឹងការកំណត់ធាតុទាំង ២ យ៉ាងតទៅ ទើបពោលពាក្យជាដើមថា **កាលយោគាវចរអង្គណាមួយ** ដូច្នេះ ។ ក្នុងបណ្ដាពាក្យទាំងនោះ ពាក្យថា **វេទនាដែលសោយរសនៃសភាវៈ គឺការរឹងនោះ** បានដល់ វេទនាដែលប្រព្រឹត្តទៅទាក់ទងនឹងការសោយសភាវៈនៃផោដ្ឋព្វៈ ពោល គឺការរឹង ។

សូម្បីក្នុងពាក្យថា **កាលព្រះយោគាវចរអង្គមួយទៀត** នេះ ក៏គប្បីជ្រាបការភ្ជាប់គ្នាតាមន័យដែលពោលហើយនោះឯង ។ ក្នុងពាក្យនោះ ពាក្យថា **ទទួលដឹងអារម្មណ៍** បានដល់ ទទួលដឹងអារម្មណ៍ គឺផោដ្ឋព្វៈ ពោល គឺភាពរឹង ។ លោកអាចារ្យពោលដល់ការធ្លាក់ទៅចំពោះផ្លូវកាយទ្វារ ឬពោលដល់ជវនវិញ្ញាណផ្លូវមនោទ្វារតែម្យ៉ាង ។ ចំណែកជវនវិញ្ញាណផ្លូវមនោទ្វារនោះ រមែងទទួលដឹងថា **បឋវីធាតុមានលក្ខណៈរឹង** ចំណែកការធ្លាក់ចុះទៅចំពោះមុខផ្លូវកាយទ្វារក្រៅអំពីនេះ ត្រឹមតែជាការទទួលដឹងលក្ខណៈរឹងប៉ុណ្ណោះឯង ។

ពាក្យថា **ដោយឧបាយនេះឯង** សេចក្ដីថា លោកអាចារ្យកាលសម្ដែងការកំណត់រូបទាក់ទងជាមួយការកំណត់ធាតុ ៤ ដោយសង្ខេបលក្ខណៈរបស់ខ្លួន ដោយចែកលក្ខណៈរបស់ខ្លួន ហើយបានសម្ដែងឧបាយកំណត់អរូប ដោយគន្លងនៃអរូបធម៌

មានផស្សៈជាដើមដល់ព្រះយោគាវចរ ទើបតាំងនៅក្នុងការកំណត់រូបនោះ ដោយឧបាយនេះឯង ។ ពាក្យថា **ក្នុងសក់ដែលមានកម្មជាសមុដ្ឋាន** គឺក្នុងសក់ ដែលមានកម្មជាសមុដ្ឋាន ដែលបានពង្រីកសេចក្តីអំពីសក់ដែលមានសមុដ្ឋាន ៤ ។ ដោយ **អាទិស័ព្ទ** ក្នុងពាក្យថា **ដោយន័យជាដើមថា បឋវីធាតុមានការរឹងជាលក្ខណៈ** បណ្ឌិតគប្បីឃើញថា ជាធាតុដទៃ ព្រមគ្នានឹងការផ្សេងលក្ខណៈគ្នាជាដើមថា **អាបោធាតុមានការហូរទៅមកជាលក្ខណៈ** ដូច្នេះ តែម្យ៉ាងប៉ុណ្ណោះក៏ទេ ដោយពិត ក៏រួមយកកោដ្ឋាសដទៃ ដែលចែកជាកោដ្ឋាសនៃធាតុ ដែលមានសមុដ្ឋាន ១ ជាដើម ។ ដោយហេតុនោះឯង ទើបលោកអាចារ្យពោលថា **ក្នុងកោដ្ឋាសនៃធាតុ ៤២** ។ ពាក្យថា **ទៅតាមប្រភេទរបស់ន័យទាំងពួង** អធិប្បាយថា ន័យនៃការកំណត់រូបមានបែបផ្សេងៗ ដែលលោកអាចារ្យពោលទុក ទាក់ទងជាមួយការកំណត់ដោយលក្ខណៈ នៃបឋវីធាតុជាដើម ក្នុងបណ្តាកោដ្ឋាសនៃធាតុ ៤២ នេះ បណ្ឌិតគប្បីធ្វើពាក្យប្រកបទាក់ទងដោយការកំណត់អរូប តាមគន្លងនៃការកំណត់រូប មានចក្ខុធាតុជាដើមទៅតាមប្រភេទរបស់ន័យ គឺការផ្សេងគ្នារបស់ន័យទាំងពួងនោះ ។ ការសម្តែងត្រឹមតែគន្លងពាក្យប្រកបក្នុងពាក្យនោះ មានដូច្នេះ

ខាងដើម កាលព្រះយោគាវចរអង្គណាមួយ កំណត់ធាតុទាំងឡាយ ដោយន័យជាដើមថា ចក្ខុធាតុ មានលក្ខណៈថ្លានៃភូតរូប ដែលគួរដល់ការប៉ះខ្ទប់រូបផង មានលក្ខណៈថ្លានៃភូតរូប ដែលមានកម្មជាសមុដ្ឋាន មានការត្រូវការឃើញជាហេតុផង ដូច្នេះ គប្បីប្រកបពាក្យទាំងអស់ថា អរូបធម៌ធ្លាក់ចុះមកចំពោះមុខជាដំបូង ប្រាកដជាឈ្មោះ **ផស្សៈ** តទៅវេទនាដែលសម្បយុត្តជាមួយផស្សៈ ប្រាកដជា ឈ្មោះ **វេទនាខន្ធ** ដូច្នេះ គប្បីប្រកបពាក្យជាដើមថា វេទនាដែលសោយរសនៃចក្ខុធាតុ មានលក្ខណៈតាមដែលពោលហើយ ប្រាកដឈ្មោះថា **វេទនាខន្ធ** ។ ម្យ៉ាងទៀត បណ្ឌិតគប្បីប្រកប

ពាក្យទាំងពួង ដោយន័យជាដើមថា ចក្ខុធាតុមានលក្ខណៈតាមដែលពោលហើយ វិញ្ញាណដែលទទួលដឹងអារម្មណ៍ ចាត់ជាវិញ្ញាណក្ខន្ធ សូម្បីក្នុងគន្ថទាក់ទងដោយការកំណត់រូប ទាក់ទងដោយអាយតនៈជាដើម ក៏មានន័យនេះឯង ។

លោកអាចារ្យ កាលនឹងសម្ដែងថា ឈានជាន់ទាបដែលចម្រើនល្អហើយ ធ្វើឲ្យដល់កាពជាវសីនោះឯង រមែងជាបទដ្ឋានអាក្រក់របស់ឈានជាន់ខ្ពស់ ឈានដែលត្រឹមតែបានមក មិនជាបទដ្ឋាននោះឡើយ យ៉ាងណា ការកំណត់រូបដែលបរិសុទ្ធល្អ មិនមានអ្វីពាក់ព័ន្ធ មិនមានអ្វីបិទបាំង រមែងជាបទដ្ឋានយ៉ាងអាក្រក់នៃការកំណត់អរូប ការកំណត់រូបដែលមិនបរិសុទ្ធល្អ មិនជាបទដ្ឋានឡើយ ដូចគ្នា ដូច្នោះ ព្រោះហេតុនោះ សូម្បីកាលចំណែកមួយរបស់រូប និងអរូបមិនប្រាកដ ការកំណត់រូបនោះ រមែងឈ្មោះថា មិនទាន់បរិសុទ្ធនោះឯង នឹងពោលថ្វីដល់កាល ចំណែកច្រើនមិនប្រាកដ ដូច្នេះ ទើបពោលពាក្យជាដើមថា **ព្រោះបើ ដូច្នេះ** ។ ដូចគោល្ងង់ដែលរកស៊ីលើភ្នំ មិនឈ្លាស មិនស្គាល់ដែន ។ ពាក្យថា **ដោយដាវ** គឺដោយចុងដាវ ។ ពាក្យថា **ប្រអប់ ( សុគ្គ )** បានដល់ ប្រអប់ធំស្រដៀងហិប ។ លោកអាចារ្យពោលការបើកប្រអប់ និងការពុះកំពីងត្នោត ដោយការៈជាគំរូ ដើម្បីសម្ដែងថា នាមរូប សូម្បីប្រាកដ ដូចមិនបានបែងចែកដល់បុគ្គល ដែលមិនបានកំណត់ កម្មដ្ឋានក៏មានសភាវៈបែងចែកនោះឯង និងថា ការបែងចែកនាមរូបនោះ រមែងប្រាកដក្នុងការកំណត់កម្មដ្ឋាន ។ គូនៃកំពីងត្នោត សូម្បីមានស្នាមតដែលបែកគ្នា ក៏ប្រាកដដូចមិនបែកគ្នា រូបធម៌ និងអរូបធម៌ ក៏ដូច្នោះឯង ។ ក្នុងពាក្យថា **ព្រះយោគាវចរ រមែងកំណត់ធម៌ទាំងឡាយ ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ទាំងអស់ ញែកជា ២ ចំណែក គឺនាម ១ រូប ១** នេះ ស័ព្ទថា **ទាំងអស់** ជាពាក្យកំណត់កាន់យកមិនមានចំណែកសេសសល់ ក៏ពិត សូម្បីយ៉ាងនោះ នាម និងរូប បែកគ្នានឹងគ្នា ព្រោះហេតុនោះ នាម និងរូប ទាំង ២ នោះ មិនគប្បីឲ្យសម្រេច

ដោយរួមគ្នា ព្រោះហេតុនោះ ទើបមានសេចក្តីថា រមែងកំណត់ចែកជា ២ ចំណែក យ៉ាងនេះថា ក្នុងនាម និងរូបទាំង ២ នេះ វត្ថុណា មានការបង្អោនទៅជាលក្ខណៈ វត្ថុនោះ ជានាម វត្ថុណា មានការបែកធ្លាយទៅជាលក្ខណៈ វត្ថុនោះ ជារូប ដូច្នេះ ។ ឯយោគាវចរដែលកំណត់ចែកយ៉ាងនេះឯង លោកហៅថា **កំណត់ធម៌ទាំងឡាយដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ទាំងអស់ ចែកជា ២ ចំណែក គឺនាម ១ រូប ១** ព្រោះក្នុងបណ្តាធម៌ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ មិនមានធម៌ណាមួយ ដែលផុតទៅអំពីនាម និងរូបទាំង ២ នោះ ។ កាលនាម និងរូបនោះសម្រេចជា ២ យ៉ាង ដោយពាក្យថា **នាម ១ រូប ១** នោះឯង ពាក្យថា **រមែងកំណត់ចែកចេញជា ២ ចំណែក** នេះ ក៏ដើម្បីសម្តែងការមិនមានធម៌ដទៃ ដែលផុតទៅអំពីនាម និងរូប ។ ដោយហេតុនោះ ទើបលោកអាចារ្យពោលពាក្យជាដើមថា **ក្រៅអំពីនាម និងរូបហើយ** ដូច្នេះ ។ ចំណែកស័ព្ទថា **ធម៌ទាំងឡាយដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ទាំងអស់** ក្នុងទីនេះ លោកពោលទុកព្រោះធម៌ដែលគួរដល់ការពិចារណាជាសភាវៈ ដែលមិនគប្បីឲ្យមានចំណែកសេសសល់ ។ ពិតហើយ ធម្មជាតិនោះ គួរកំណត់ដឹងដោយមិនមានចំណែកសេសសល់ គួរប្រាសចាកតម្រេកដោយចំណែកមួយ ព្រោះហេតុនោះ ចិត្ត ភិក្ខុក៏គួរប្រាសចាកតម្រេករលាស់ចោលទៅ ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

**ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលមិនដឹងក្រៃលែង មិនកំណត់ដឹងក្រៃលែងនូវវត្ថុទាំងពួង មិនប្រាសចាកតម្រេក លះមិនទាន់បាននូវចិត្ត ក្នុងវត្ថុទាំងពួងនោះ នៅជាបុគ្គល មិនគួរដល់ការអស់ទុក្ខ ។ ម្នាលភិក្ខុទាំងឡាយ ចំណែកបុគ្គលដែលដឹងក្រៃលែង កំណត់ដឹងវត្ថុទាំងពួង ប្រាសចាកតម្រេក លះបាននូវចិត្ត ក្នុងវត្ថុទាំងពួងនោះ ជាបុគ្គលគួរដល់ការអស់ទុក្ខ ។**

សួរថា បើធម្មជាតិដែលប្រព្រឹត្តទៅក្នុងភូមិ ៣ លោកកាន់យកដោយមិនមាន

ចំណែកសេសសល់ថា **នាមរូប** ដូច្នេះសោត លទ្ធិណា ដែលពួកបុគ្គលក្រៅសាសនានេះ កំណត់យកដោយភាពជាអត្ថចំពោះបទ ដូច **បកតិ** ជាដើម **ទ្រព្យ** ជាដើម **ជីវៈ** ជាដើម **កាយ** ជាដើម ក្នុងលទ្ធិនោះ គួរបដិបត្តិដូចម្តេច ? សេចក្តីនេះ ឆ្លើយថា ក្នុងលទ្ធិនោះ មិនមែនព្រះសម្មាសម្ពុទ្ធទ្រង់ប្រកាសទុក ដូចជាការស្រមើស្រមៃទៅ ដូចជាមនុស្សឆ្កួតនឹងមានគោលបដិបត្តិអ្វីដទៃ ក្រៅអំពីការព្រងើយ ។ ម្យ៉ាងទៀត លទ្ធិទាំងនោះ គប្បីជ្រាបថា កាត់ផ្តាច់នោះឯង ទាក់ទងជាមួយវត្ថុដែលចាត់ចូលក្នុងនាមរូប និងការមិនកើត ។ សេចក្តីនេះដូចម្តេច ? អត្ថទាំងនេះ គឺ **បកតិ មហត្ត អហង្ការ តម្មត្តា ឥន្ទ្រិយ ភូត បុរស** ឈ្មោះថា អត្ថមាន **បកតិ** ជាដើម ។ ក្នុងបណ្តាអត្ថទាំងនោះ ការរួមគ្នានៃសុខទុក្ខ និងមោហៈ គឺការរួមគ្នានៃបកតិ ដែលហៅថា **សត្វរជ** ដែលប្រព្រឹត្តទៅដោយភាវៈស្មើគ្នា លោកហៅថា **បកតិ** និងថា **បធាន** ។ អាចារ្យពួកខ្លះពោលថា ការសង្គ្រោះដែលប្រកាសត្រឹមតែសត្វ ឈ្មោះថា **មហត្ត** បានដល់ **ពុទ្ធិ**។ ក្នុងបណ្តាគុណ មាន **សត្វ** និង **រជ** ជាដើម **អភិមាន** ឈ្មោះថា **អហង្ការ** អាចារ្យពួកខ្លះ ពោលថា ត្រឹមតែជា **អស្មិ** គឺប្រកាន់ថា អញ ។ សំឡេង ផស្សៈ រូប រស និងក្លិន ឈ្មោះថា **តម្មត្តា** ព្រោះសម្តែងដល់ធាតុទាំងឡាយ មានបឋវីធាតុជាដើម ដែលផ្សេងគ្នានឹងគ្នាបន្ថែមឡើងមួយទៀត ការបន្ថែមឡើងទៀត ជា **តម្មត្តា** ព្រោះហេតុនោះ ការផ្សេងគ្នាដែលមានលក្ខណៈដូចគ្នា លោកចាត់ចូលជាមួយ **តម្មត្តា** ដែលមានលក្ខណៈដូចគ្នានឹងកាំបិតដែលចាក់ទម្លុះ អាចារ្យពួកខ្លះពោលថា ការដែលបន្ថែមឡើងមួយទៀត ក៏ព្រោះ **តម្មត្តា** ទាំងនោះបន្ថែមចូល ដោយភាពជាសុខុមរូប ។ ឥន្ទ្រិយ ៥ មានសោតៈជាដើម ដែលមានការប្រព្រឹត្តទៅ ដោយការបានឮជាដើម ឈ្មោះថា **ពុទ្ធិន្ទ្រិយ** ( ឬ ) **ញាណិន្ទ្រិយ** ( ក៏បាន ) ឥន្ទ្រិយ ៥ មានមាត់ជាដើម ដែលមានកិច្ចនិយាយ ចាប់ ( ដៃ ) ត្រាច់ទៅ ( ជើង ) បន្ទោបង់ឧច្ចារបស្សាវៈ ( ទ្វារធំ ទ្វារតូច )

និងការរីករាយ ( គុយ្ហបទេស ) ឈ្មោះថា **កម្មិន្ទ្រិយ** ។ **មនស្ស** ជា **អន្តករណ** ( ធ្វើខាងក្នុង ) អាយតនៈក្រៅអំពីនេះ ជា **ពាហិរករណ** ។ ដី ទឹក ភ្លើង ខ្យល់ និង អាកាស ដែលផ្តើមដោយក្លិនជាដើម ឈ្មោះថា **ភូត** សការៈ គឺចេតនា ឈ្មោះថា **បុរស** បណ្ឌិតគប្បីជ្រាបលទ្ធិ មាន **បកតិ** ជាដើម សរុបដោយប្រការដូចពោលមក ដូច្នេះ ។

ក្នុងបណ្តាពាក្យទាំងនោះ ខាងដើម **បកតិ** ចាត់ជានាម ព្រោះត្រឹមតែជាសុខ ទុក្ខ និងមោហៈ ត្រូវជាវត្ថុដែលមិនទៀង ជាទុក្ខ និងជាសង្ខតៈ ព្រោះដល់នូវភាព ជាវត្ថុដែលស្មោះស្មើ និងប្រាសចាកការស្មោះស្មើ ។ សូម្បី **មហត្ត** ក៏ចាត់ជានាម ព្រោះពោលទុកថា **មហត្ត ត្រឹមតែជាការផ្សេងរបស់លក្ខណៈ រមែងកើតអំពីវត្ថុ ដែលមិនមានលក្ខណៈនោះ** និងព្រោះព្រមទទួលភាពជាពុទ្ធិ ត្រូវជាវត្ថុមិនទៀង ជា សង្ខតៈដូចគ្នា ។ **អហង្ការ** ចាត់ជានាម ព្រោះធ្វើអធិប្បាយថា ជាអភិមានៈ ដោយ ការព្រមទទួលភាវៈដែលជានិមិត្តនៃការប្រកាន់ថា ជាអញ ដោយពោលទុកក្នុងគម្ពីរ សំស្រ្កឹតថា **លោកចាត់ភាពផ្សេងទុក ៦ ប្រការ អំពីមហត្តនោះ** ក៏ព្រោះហេតុនោះឯង **មហង្ការ** នោះ ទើបសម្រេចការដល់នូវភាពជាវត្ថុមិនទៀង និងជាសង្ខតៈ ។ **តម្មត្ត ៥ ប្រការ** ក្រៅអំពីនេះ ចាត់ជារូប ព្រោះព្រមទទួលភាពជាក្លិន រស រូប ផស្សៈ និងសំឡេង តែពួកលទ្ធិអាចារ្យកបិល ត្រឹមតែប្រកាន់ខុសទៅថា ជាអរូប ។ លទ្ធិ ទាំងនោះ ជាការផ្សេង ១៦ យ៉ាង គឺភូត ៥ ឥន្ទ្រិយ ១១ ការផ្សេងនៃភូត ក៏ដោយ ភូតទាំងឡាយ ព្រោះហេតុនោះ ទើបលោកប្រាថ្នាភូត ពោល គឺដី ទឹក ភ្លើង ខ្យល់ និងអាកាស ដែលជាទីអាស្រ័យរបស់ឥន្ទ្រិយនោះ ជាមួយ **តម្មត្ត** មានក្លិនជាដើម ។ ដោយមានពាក្យថា **ឥន្ទ្រិយទាំងឡាយ មកអំពីភាពផ្សេងគ្នានោះ និងមកអំពីអហង្ការ ដែលមានជាតិផ្សេងៗ** ។ ឥន្ទ្រិយ ទើបមាន ១១ គឺសោតៈ ១ កាយ ១ ចក្ខុ ១ ជិវ្ហា

១ យាន ១ មាត់ ១ ដៃ ១ ជើង ១ ទ្វារធំ-តូច ១ អន្តជាត ១ និងមនស្ស ១ ។

ក្នុងបណ្តាឥន្ទ្រិយទាំងនោះ មនស្ស ចាត់ជានាម ឥន្ទ្រិយក្រៅអំពីនេះទាំងអស់ចាត់ជារូប ចំណែកក្នុងពាក្យថា មាត់ នេះ លោកកាន់យកការរួមអក្ខរៈដែលច្នុះបញ្ចាំងឲ្យភ្លឺច្បាស់ ។ ឯឥន្ទ្រិយទាំងនេះ ព្រោះលោកប្រាថ្នាធម៌ ដែលមានហេតុ មិនមែនមានផលដទៃ ជារបស់មិនទៀង ទើបសម្រេចបានក្នុងចំណែកដែលប្រែប្រួលទៅ សូម្បីក្នុងចំណែកដែលជាក់ច្បាស់ បើការជាក់ច្បាស់ ដោយការកើតញាណឡើង មានលទ្ធិនោះជាអារម្មណ៍ ក៏សម្រេចជាការមិនទៀង បើមុនអំពីនោះ ក៏មានញាណដូចគ្នា ។ ចំណែកលទ្ធិដែលទាក់ទងនឹងការជាក់ច្បាស់ខាងឥន្ទ្រិយ ក៏គប្បីមាន ដែលលោកពោលមកនេះ ត្រឹមតែជាការបន្ទុលក្នុងរឿងនេះ ។ ទ្រព្យ គុណ កម្ម សាមានយ វិសេស សមវាយ ឈ្មោះថា អត្ថចំពោះបទ មានទ្រព្យជាដើម ។ ក្នុងបណ្តាអត្ថចំពោះបទទាំងនោះ អត្ថចំពោះបទ ៩ យ៉ាង គឺ បឋវី អាបោ តេជោ វាយុ អាកាស កាល ទេស អត្តា មនស្ស ឈ្មោះថា ទ្រព្យ ។ អត្ថចំពោះបទ ២៣ នេះ យ៉ាងនេះ គឺ ស័ព្ទ គឺសំឡេង ១ រូប គឺពណ៌ ១ រស ១ គន្ធៈ ១ ផស្សៈ ១ សង្ខ្យា គឺចំនួន ១ បរិមាណ គឺខ្នាត ១ បុថុត្ត គឺភាពផ្សេង ១ សំយោគ គឺការរួម ១ វិយោគ គឺការបែក ១ បរត្ត គឺការជិត ១ អបរត្ត គឺការឆ្ងាយ ១ ពុទ្ធិ គឺការដឹង ១ សុខ ១ ទុក្ខ ១ ឥច្ឆា គឺការប្រាថ្នា ១ ទោសៈ ១ បយត្ត គឺសេចក្តីព្យាយាម ១ គរុត្ត គឺភាពធ្ងន់ ១ ទ្រវត្ត គឺភាពរាវ ១ ស្នេហ ១ វេគ គឺភាពរហ័ស ១ សំសការ គឺការពង្រីកចេញ ១ អទិដ្ឋ គឺរបស់ដែលមើលមិនឃើញ បានដល់ ធម៌ និងអធម៌ ១ ឈ្មោះថា គុណ ។ អត្ថចំពោះ បទ ៥ យ៉ាង គឺ ឧក្ខេបន គឺការរំកិលញ័រទៅខាងលើ ១ អវក្ខេបន គឺការរំកិលញ័រទៅខាងក្រោម ១ អាកុចន គឺការបត់ចូល ១ បសារណ គឺការលាតចេញ ១ គមន គឺការឃ្លាតចាកទី ១ ឈ្មោះថា កម្ម ។ ឈ្មោះដ៏សេស ចុះក្នុងអត្ថចំពោះបទ

ដែលផ្សេងគ្នានឹងគ្នា រមែងជាបច្ច័យ ។ លក្ខណៈនេះ គឺក្នុងបណ្តាទ្រព្យ គុណ និងកម្ម ចំណែកដែលកំណត់រួមគ្នា ចំណែកនោះមាននៅនោះឯង ឈ្មោះថា **មហាសាមានយ** ។ ទ្រព្យជាដើម ដែលជាហេតុនៃការសោយអារម្មណ៍ក្នុងការអនុលោមតាម និងជំទាស់ ក្នុងភូតរូប មានបឋវីជាដើម ឧបមាដូច ជាភាពជាទ្រព្យ-គុណ-កម្ម និងភាពជាថ្នាំង ជាដើមនេះ ឈ្មោះថា **សាមានយវិសេស** ។ ការសម្ពន្ធនៃហេតុ និងផល នៃហេតុ ដែលកំណត់ទុកថា នៅក្នុងនេះ ដូចពាក្យថា សំពត់នៅក្នុងសរសៃអំបោះនេះ ថ្នាំង នៅក្នុងអំបែងនេះ ដែលលោកហៅថា ការរួម ឈ្មោះថា **សមវាយ** អត្ថចំពោះបទ ដូចបានពោលមកនេះ ឈ្មោះថា **អត្ថចំពោះបទ មានទ្រព្យជាដើម** ។

ក្នុងបណ្តាអត្ថចំពោះបទទាំងនោះ ដី ទឹក ភ្លើង ខ្យល់ ចាត់ជាភូតរូប អាកាស ត្រឹមតែជាភាពមិនមានរបស់ដី ទឹក ភ្លើង ខ្យល់ប៉ុណ្ណោះ ឬជាការកំណត់ដំណើរគោចរ នៃព្រះចន្ទ និងព្រះអាទិត្យជាដើម ដែលត្រឹមតែជាបញ្ញត្តិអាស្រ័យការប្រព្រឹត្តទៅនៃធម៌ ឈ្មោះថា **កាល** ។ **ទេស** និង **អាត្ម័ន** ក៏ដូចគ្នា ។ **មនស្ស** ចាត់ជានាម ។ **សំឡេង រូប រស** និង **ក្លិន** ចាត់ជារូបតែម្យ៉ាង ។ **ផស្សៈ** ក៏ចាត់ជារូបដូចគ្នា ព្រោះមាន ភូតរូបទាំង ៣ ជាសភាវៈ ។ **សង្ខ្យា** មាន ១ ជាដើម ក៏ត្រឹមតែជាបញ្ញត្តិ ព្រោះ អាស្រ័យចំនួននោះៗ ។ **បុថុត្ត** ( ភាពផ្សេង ) ក្នុងទេស មានលក្ខណៈផ្សេងគ្នា គឺ ភាពជំរែង ទាក់ទងនឹងការផ្សេងគ្នានៃគុណ ក្នុងចំណែកបន្តិចបន្តួច និងភាពសង្គ្រោះ ឬទាក់ទងភាពផ្សេងនៃសណ្ឋាន ភាពតូចខ្ពី ដោយបរិយាយផ្សេងអំពីនោះ ក៏ចាត់ ត្រឹមតែជាបញ្ញត្តិដូចគ្នា ដូច្នេះ ។ **សំយោគ** (ការរួម) ព្រោះភាពដែលវត្ថុដែលកើត ក្នុងទេសៈផ្សេងគ្នាមករួមគ្នា ក៏ចាត់ត្រឹមតែជាបញ្ញត្តិ ។ **វិយោគ** ( ភាពបំបែក ) ព្រោះការប្រាសទៅរបស់វត្ថុដែលរួមគ្នា ក៏ចាត់ត្រឹមតែជាបញ្ញត្តិ ។ សេចក្តីនេះថា ភាព ជិត-ឆ្ងាយ ទាក់ទងជាមួយចន្លោះនៃមហត្តៈ និងទ្រព្យនៃរូបទាំងឡាយ ដែលនៅក្នុង

ទិស និងទេសៈស្មើគ្នា ក៏ចាត់ត្រឹមតែជាបញ្ញត្តិ ។ **ពុទ្ធិ សុខ ទុក្ខ ឥច្ឆា ទោសៈ** និង **បយត្ត** ចាត់ជានាមតែម្យ៉ាង ។ **គុរុត្វ ទ្រវត្វ ស្នេហ** និង **វេគ** ជាអាការដែលគប្បីកាន់យកដោយភាពផ្សេងនៃការប្រព្រឹត្តទៅរបស់រូបធម៌ទាំងឡាយ ។ **សំសការ** ក្រៅអំពីនេះ ជាភាពផ្សេងគ្នានៃការប្រព្រឹត្តទៅរបស់ញាណ ។ **សូម្បីអទិដ្ឋ** ក៏ចាត់ជានាមតែម្យ៉ាង ព្រោះជាធម៌ និងអធម៌ ។ **ឧក្ខេបន អវក្ខេបន អាកុចន បសារណ** និង **គមន** អត្ថចំពោះដូចពោលនេះ ក៏ត្រឹមតែជាការប្រព្រឹត្តទៅនៃរូបធម៌ទាំងឡាយ ។ ឈ្មោះ **សាមានយវិសេស** នៅក្នុងភាពដូចគ្នា និងមិនដូចគ្នា ឈ្មោះ **សមវាយ** នៅក្នុងការសម្ពន្ធអត្ថដែលមិនគួរ ។ ព្រោះហេតុនោះ បណ្ឌិតគប្បីឃើញភាពដែលអត្ថចំពោះបទមានទ្រព្យជាដើម ជាអត្ថដែលឈោងចុះក្នុងនាម និងរូបបាន ។

អត្ថ ព្រោះបទមានជីវៈ អជីវៈ ពន្ធ បុញ្ញ បាប អាសវៈ សំវរៈ និជ្ជរ និងវិមោក្ខ ឈ្មោះថា អត្ថចំពោះ មាន **ជីវៈ** ជាដើម ។ ក្នុងបណ្តាអត្ថចំពោះបទទាំងនោះ ពាក្យថា **ជីវៈ** បានដល់ អាត្មន ។ ក្នុងបុគ្គល ធម៌ អធម៌ អាកាស និងកាល **លោកតាំងឈ្មោះថា អជីវៈ** ។ ក្នុងបណ្តាអត្ថចំពោះបទទាំងនោះ សំឡេង ផស្សៈ រូប រសក្លិន សណ្ឋាន ពន្ធ ភាពបែក ភាពល្អិត ភាពជិត ភាពឆ្ងាយ ភាពប៉ះខ្ទប់ រស្មីស្រមោល ពន្លឺ និងងងឹត ជាលក្ខណៈរបស់បុគ្គល ព្រោះហេតុនោះ **បុគ្គល** ទើបឈ្មោះថា ជារូប ព្រោះត្រឹមតែជាអាការប្រព្រឹត្តទៅនៃរូបធម៌ទាំងឡាយ ។ **ធម៌ និងអធម៌** មិនមែនធ្វើឲ្យបុគ្គលនោះផ្សេងគ្នាឡើយ ព្រោះត្រឹមតែជាការប្រព្រឹត្តទៅ និងការតាំងនៅរបស់ជីវៈ និងបុគ្គល ។ **អាកាស** និង **កាល** ត្រឹមតែជាបញ្ញត្តិ ។ **ពន្ធ** មិនមែនដទៃទៅអំពីបុគ្គល ធម៌ និងអធម៌ទាំងនោះ ព្រោះលោកពោលទុកថា **ភាពរួមរវាងកម្ម និងបុគ្គល** ។ ពាក្យថា **បុណ្យ** និង **បាប** ជានាមជាក់ច្បាស់ហើយនោះឯង ។ កាលមានបុណ្យ និងបាប ក៏នឹងមានឈ្មោះថា **អាសវៈ** ព្រោះលោកពោលទុកថា

**អាសវៈរបស់កម្ម និងបុគ្គល** ដូច្នេះ ព្រោះហេតុនោះ **អាសវៈ** មិនផ្សេងអំពីបុណ្យ និងបាបនោះ ។ ការរំលត់បុណ្យ និងបាប ដោយជាបដិបក្ខគ្នា ឈ្មោះថា **សំវរៈ** ព្រោះលោកពោលទុកថា **ការរំលត់អាសវៈជាសំវរៈ** ។ និមិត្តនៃការរលត់វិបាក ឈ្មោះថា **និជ្ជរ** ព្រោះលោកពោលទុកថា **ការមិនប្រព្រឹត្តទៅនៃបកតិ** ព្រោះមិនប្រព្រឹត្តទៅនៃផលកម្ម ឈ្មោះថា **និជ្ជរ** ។ សូម្បី **មោក្ខ** ក៏គឺការញែកកម្ម បុគ្គល និងជីវៈ ព្រោះលោកពោលទុកថា **វិមោក្ខ** នៃកម្មទាំងពួង ។ ក្នុងបណ្ដាអត្ថទាំងនោះ **កម្ម និងបុគ្គល** ត្រឹមតែជារូប ព្រោះមានសំឡេងជាដើម លក្ខណៈត្រឹមតែជាអរូប ក៏ព្រោះត្រឹមតែជាបុណ្យ និងបាប ម្យ៉ាងទៀត **ជីវៈ** ត្រឹមតែជាអរូបតែម្យ៉ាង ដែលពោលមកនេះជាទ្រព្យមោក្ខ ( ការផុតអំពីទ្រព្យ ) ។ ចំណែកការមោក្ខ ( ការផុតចាកភាវៈ ) បានដល់ការមិនប្រែប្រួលនៃរាគៈជាដើម នៃជីវៈ អត្ថ មានរាគៈជាដើម ជានាមតែម្យ៉ាង ព្រោះហេតុនោះ អត្ថចំពោះបទ មាន **ជីវៈ** ក៏ឈោងចុះក្នុងនាមរូបនោះឯង ។

**កាយ បវត្តិ គតិ ជាតិ ពន្ធ អបវគ្គ** ឈ្មោះថា អត្ថព្រោះបទ **មានកាយជាដើម** ។ បណ្ដាអត្ថព្រោះបទទាំងនោះ ក្នុងដី ទឹក ភ្លើង ខ្យល់ អាត្ម័ន សុខ និងទុក្ខ លោកតាំងឈ្មោះថា **កាយ** ។ **បវត្តិ គតិ ជាតិ ពន្ធ** និង **អបវគ្គ** មិនផ្សេងអំពីកាយ វត្ថុណាដទៃអំពីកាយ រមែងមិនមាន ព្រោះលោកពោលទុកថា **ពាក្យថា ភាវៈ បានដល់អត្ថ ពាក្យថា កាយ បានដល់ វត្ថុដែលមិនមែនអត្ថដទៃ** ។ អត្ថចំពោះបទ មានបវត្តិជាដើមនោះឯង ដែលប្រព្រឹត្តទៅដោយប្រការ ដែលជាគតិជាដើម ឈ្មោះថា **បវត្តិ** គឺការប្រព្រឹត្តទៅ គឺជាឧបចារៈ ព្រោះលោកពោលទុកថា **កិរិយាការរួម និងការញែកលោកតាំងឈ្មោះថា បវត្តិ** ។ ការចូលដល់ភាពជាទេវតា មនុស្ស ប្រេត តិរច្ឆាន និងនរកដែលមិនមែនដទៃក្រៅអំពីកាយ ឈ្មោះថា **គតិ** ព្រោះលោកពោលទុកថា **ក្នុងកាយនោះ មិនមានអត្ថដទៃ** ។ សូម្បីការកាត់ផ្ដាច់របស់អ្នកកើតក្នុងគតិទាំងឡាយ

ដែលមិនផ្សេងគ្នា ទាំងចាស់ និងមិនមែន ចាស់ទាំងនោះ ក៏ត្រឹមតែជាបវត្តិ ព្រោះហេតុនោះ ឈ្មោះថា **ជាតិ** ក៏គឺខ្មៅ ខៀវ ក្រហម លឿង ស និងសច្បាស់ មិនមែនដទៃអំពីគតិនោះ ។ ជាតិទាំងនោះ ផ្សេងគ្នាក្រៃលែងឡើងៗ ទៅ **សុក្កជាតិ** មានការសម្តែងចេញរបស់ភាពដែលមានមោហៈ គឺអញ្ញាណ រាគៈ ទោសៈ តូច ឈ្មោះថា **សុក្កជាតិ** ក៏ព្រោះមានអត្ថថា មានទីបំផុតផុតហើយ ដោយពិត និងឈោងចុះបានហើយ ។ **ពន្ធ** ដែលមានលក្ខណៈជាអញ្ញាណជាដើម ក៏មិនមែនដទៃទៅអំពីជីវៈ ព្រោះលោកពោលទុកថា **ក្នុងទោសទាំងឡាយ** លោកតាំងឈ្មោះថា **ពន្ធ** ដូច្នេះ ។ ព្រោះទោស មានអញ្ញាណជាដើម ទើបសម្រេចជា **អបវគ្គ** ( **និរវាណ** ) ព្រោះហេតុនោះ សូម្បីអត្ថចំពោះបទ មានកាយជាដើម ក៏ត្រឹមតែជានាមរូបប៉ុណ្ណោះ ។

អត្ថចំពោះបទរបស់អាត្មន ដែលលោកពោលទុក ដោយពាក្យបរិយាយជាដើមថា **បុរស អាត្មន ជីវៈ** ដូច្នេះ ក្នុងទីនោះៗ អត្ថចំពោះបទនោះ លោកបញ្ញត្តទុកអាស្រ័យត្រឹមតែជានាមរូបតាមគួរ ឬត្រឹមតែជានាមរូបប៉ុណ្ណោះ ។ ដោយហេតុនោះទើបពោលថា **អត្ថចំពោះ បទទាំងនោះ កាត់សម្រេចបានទាក់ទងដោយភាពជាអត្ថឈោងចុះខាងក្នុងនាម រូប និងមិនកើតនោះឯង** ។

# វិសុទ្ធិមគ្គ

## អរូបធម៌ប្រាកដដោយវិញ្ញាណ (ត)

*ព្រះយោគាវចរនោះ កាលកំណត់ចែកនាមរូបតាមសេចក្តីពិតបានយ៉ាងនេះហើយ ដើម្បីប្រយោជន៍ដែលនឹងលះបង់នូវលោកសាមញ្ញា គឺឈ្មោះដែលសត្វលោកសន្មតហៅថា* ***សត្វ បុគ្គល*** *ដើម្បីប្រយោជន៍ដែលនឹងឈានកន្លងបង់នូវការវង្វេងថាជាសត្វ ដើម្បីប្រយោជន៍ ដែលនឹងតាំងចិត្តទុកក្នុងអសម្មោហភូមិ ឲ្យល្អក្រៃលែងឡើងទៅ រមែងកំណត់ដោយប្រៀបធៀបថា* ***នេះត្រឹមតែជានាមរូបប៉ុណ្ណោះ សត្វមិនមាន បុគ្គលមិនមាន*** *នេះបានតាមព្រះសូត្រច្រើនសូត្រ ពិតហើយ (ក្នុងវជិរាសូត្រ) ព្រះនាងវជិរាភិក្ខុនីក៏ពោលពាក្យនេះទុកថា*

***ដូចឧបមាថា ព្រោះមានអង្គសម្ភារៈ ( ចំណែកផ្សេងៗ ដែលប្រកបចូលគ្នា ) សំឡេងថា រថ ទើបមាន យ៉ាងណា កាលខន្ធទាំងឡាយមាន ការសន្មតិថា សត្វ ទើបមាន ដូច្នោះ ។***

*សូត្រមួយទៀត ព្រះសារីបុត្រពោលទុកថា ម្នាលអាវុសោ អាកាសអាស្រ័យគ្រឿងឈើផង អាស្រ័យវល្លិ៍ផង អាស្រ័យដីឥដ្ឋផង អាស្រ័យស្មៅផង ហ៊ុមព័ទ្ធរមែងបានឈ្មោះថា ផ្ទះ ប៉ុណ្ណោះឯង យ៉ាងណាក្តី ម្នាលអាវុសោ អាកាសអាស្រ័យឆ្អឹងផង អាស្រ័យសរសៃផង អាស្រ័យសាច់ផង អាស្រ័យស្បែកផងហ៊ុមព័ទ្ធ រមែងបានឈ្មោះថា រូប ប៉ុណ្ណោះឯង ដូច្នោះនោះឯង ។*

*ព្រះនាងវជិរាភិក្ខុនីពោលទុកមួយវគ្គទៀតថា* ***សេចក្តីពិត ទុក្ខនោះឯងកើតទុក្ខនោះឯងតាំងនៅ និងវិនាសទៅ ធម្មជាតិក្រៅអំពីទុក្ខ មិនមានវត្ថុដទៃកើត អ្វីក្រៅអំពីទុក្ខ មិនមានវត្ថុដទៃរលត់ឡើយ ។***

# មហាដីកា

## កថាពណ៌នាដោយការប្រៀបធៀប

## ព្រះសូត្រច្រើនសូត្រ

*បទថា **សោ** សេចក្ដីថា **សោ យោគ វិបស្សនាកម្មិកោ យោគាវចរោ** ប្រែថា យោគាវចរដែលប្រកបកម្ម គឺវិបស្សនានោះ ។ ពាក្យថា **យ៉ាងនេះ** ជាពាក្យប្រារព្ធដល់ប្រការដែលបានពោលហើយ ។ បទថា **យាថាវសរសតោ** ប្រែថា តាមសភាវៈដែលពិត ។ ក្នុងសេចក្ដីបាលីថា **នាមរូបំ វវត្ថបេត្វា ឯតមត្ថំ សំសន្ទេត្វា វវត្ថបេតិ** ប្រែថា កាលកំណត់ចែកនាមរូប រមែងកំណត់ដោយប្រៀបធៀបសេចក្ដីនេះ ។ **ដើម្បីប្រយោជន៍លះបង់នូវលោកសមញ្ញា** អធិប្បាយថា នឹងពោលថ្វីដល់ការប្រកាន់ខុសដ៏មាំ ដែលប្រព្រឹត្តទៅថា **សត្វ ជីវៈ** ។ ការវង្វេងដែលប្រព្រឹត្តទៅថា **សត្វ** ដោយអំណាចការប្រកាន់ថា ជាការដូចគ្នា ដោយជាភាវៈប្រជុំ វៀរចាកការប្រកាន់មាំ ព្រោះមិនបានវិនិច្ឆ័យដោយត្រឹមតែនាម និងរូប និងព្រោះមិនបានធ្វើការចែកឃនៈ មានការបន្តគ្នាជាដើម ឈ្មោះថា **ការវង្វេងថា ជាសត្វ** ។ ការសង្កត់ទុកនូវភាពវង្វេងថា ជាសត្វនោះ ឈ្មោះថា **អសម្មោហភូមិ** ។ ពាក្យថា **ដោយអំណាចព្រះសូត្រច្រើនសូត្រ** សេចក្ដីថា ដោយអំណាចព្រះសូត្រ ច្រើនសូត្រដែលពោលទុកក្នុងទីនេះ ដោយពាក្យជាដើមថា **យថាបិ** និងដែលមិនបានពោលទុកដោយពាក្យជាដើមយ៉ាងនេះថា ម្នាលមហាលិ បើរូបនេះ ចាត់ជាអត្តាសោត រូបនេះ ក៏មិនគប្បីប្រព្រឹត្តទៅដើម្បីអាពាធ។ លោកអាចារ្យពោលថា **សេចក្ដីនេះ** សំដៅយកការដែលលោកពោលទុកដោយពាក្យជាដើមថា ត្រឹមតែជានាមរូបប៉ុណ្ណោះ ។*

ពាក្យថា **ព្រោះមានអង្គសម្ភារៈ** គឺព្រោះមានអង្គសម្ភារៈជាហេតុ ។ ព្រោះអង្គសម្ភារៈនោះ ជានិមិត្ត មិនលះអង្គសម្ភារៈនោះ គឺកាលមានអង្គសម្ភារៈនោះឯង ទើបមានវោហារថា **សត្វ** ។

ពាក្យថា **ឈ្មោះថា ផ្ទះ** មានពាក្យប្រកបថា អាកាសអាស្រ័យវត្ថុ មានឈើជាដើម ចោលឈ្មោះរបស់ឈើជាដើមនោះហើយ បានឈ្មោះ គឺហៅថា **ផ្ទះ** យ៉ាងណា អាកាសអាស្រ័យចំណែករបស់រាងកាយ មានឆ្អឹងជាដើម ចោលឈ្មោះ របស់ឆ្អឹងជាដើមនោះ បានឈ្មោះថា **រូប** ថា **សរីរៈ** នោះឯង ដូច្នោះ ។

ពាក្យថា **ទុក្ខនោះឯងកើត** សេចក្តីថា ទុក្ខ ៣ យ៉ាង ដែលផ្សេងគ្នាដោយ **ទុក្ខទុក្ខតា** ជាដើមនោះឯងកើត គឺកើតឡើងតាមបច្ច័យ ទុក្ខនោះឯងតាំងនៅ ដោយតាំងនៅមួយជួរខណៈ និងតាំងនៅជាប់តគ្នាទៅ និងរលត់ ដោយរលត់ទៅមួយជួរខណៈ និងរលត់ទៅ ដោយអស់អាយុជាដើម ។ ឥឡូវនេះ លោកអាចារ្យមានបំណងនឹងសម្តែងអត្ថដែលលោកបដិសេធទុកដោយ **ឯវ** អក្ខរៈ ថា **ទុក្ខមេវ** ទើបពោលពាក្យជាដើមថា **នាញ្ញត្រ** សេចក្តីរបស់ពាក្យនោះថា វៀរទុក្ខតាមដែលពោលហើយ ធម្មជាតិណាមួយ ដទៃអំពីទុក្ខនោះ រមែងមិនកើត សភាវៈណាដែលគប្បីពោលថា **សត្វ** ក្តី ថា **ជីវៈ** ក្តី ការរលត់នៃសភាវៈនោះ នឹងមានមកអំពីណា ព្រោះមិនមានដោយប្រការទាំងពួង ។

# វិសុទ្ធិមគ្គ

## អរូបធម៌ប្រាកដដោយវិញ្ញាណ (ត)

នាមរូបនោះឯង ដែលព្រះសូត្រច្រើនរយសម្តែងទុកដោយន័យដូចពោលមកនេះ មិនមែនសត្វ មិនមែនបុគ្គល ព្រោះហេតុនោះ កាលអង្គសម្ភារៈ មានភ្លៅ កង់ ទ្រនុងរទេះ និងចន្ទោលជាដើមតាំងនៅរៀបរយដោយល្អ ដោយអាការណាទីមួយហើយ វោហារថា រថ ក៏មានឡើងប៉ុណ្ណោះឯង កាលពិនិត្យមើលអង្គតែមួយចំណែកៗ ដោយបរមត្ថ ឈ្មោះថា រថ ក៏មិនមាន យ៉ាងណា ម្យ៉ាងទៀត កាលគ្រឿងផ្ទះ មានឈើជាដើមហ៊ុមព័ទ្ធអាកាសតាំងនៅដោយអាការឯណាទីមួយហើយ វោហារថា ផ្ទះ ក៏មានឡើងប៉ុណ្ណោះឯង... ដោយបរមត្ថ ឈ្មោះថា ផ្ទះមិនមាន ។ ម្យ៉ាងទៀត កាលម្រាមទាំងឡាយ មានម្រាមមេដៃជាដើមតាំងនៅ ដោយអាការឯណាទីមួយហើយ វោហារថា ប្រអប់ដៃ ក៏មានឡើងប៉ុណ្ណោះឯង... ដោយបរមត្ថ ឈ្មោះថា ប្រអប់ដៃមិនមាន... កាលចំណែករបស់ពិណ មានស្នូកជាដើមតាំងនៅ ដោយអាការឯណាទីមួយហើយ វោហារថា ពិណ ក៏មានឡើងប៉ុណ្ណោះឯង... ដោយបរមត្ថ ឈ្មោះថា ពិណមិនមាន... កាលអង្គនៃកងទ័ព មានពលដំរី និងពលសេះជាដើម តាំងនៅដោយអាការឯណាទីមួយហើយ វោហារថា កងទ័ពក៏មានឡើងប៉ុណ្ណោះឯង... ដោយបរមត្ថ ឈ្មោះថា កងទ័ពមិនមាន... កាលអង្គនៃក្រុង មានកំពែង និងទ្វារជុំវិញជាដើមតាំងនៅដោយអាការឯណាទីមួយហើយ វោហារថា ក្រុង ក៏មានឡើងប៉ុណ្ណោះឯង... ដោយបរមត្ថ ឈ្មោះថា ក្រុងមិនមាន... កាលអវយវៈនៃ ដើមឈើ មានដើម មែក ស្លឹកជាដើម តាំងនៅដោយអាការឯណាទីមួយហើយ វោហារថា ដើមឈើ ក៏មានឡើងប៉ុណ្ណោះឯង តែកាលពិនិត្យមើលអវយវៈ តែមួយចំណែកៗ ទៅដោយបរមត្ថ ឈ្មោះថា ដើមឈើ

មិនមាន យ៉ាងណា កាលឧបាទានក្ខន្ធ ៥ មានវោហារថា **សត្វ** ថា **បុគ្គល** ក៏មានឡើងប៉ុណ្ណោះឯង កាលពិនិត្យមើលធម៌តែមួយចំណែកៗ ទៅដោយបរមត្ថ ឈ្មោះថាសត្វដែលជាវត្ថុនៃការប្រកាន់ថា **យើងជា** ឬថា **ជាយើង** មិនមាន ដោយបរមត្ថហើយ ក៏មានតែ នាម និងរូបប៉ុណ្ណោះឯង ដូច្នោះដូចគ្នា ដូច្នេះ ។

ទស្សនៈនៃព្រះយោគាវចរនោះ ដែលឃើញយ៉ាងនេះឯង ឈ្មោះថា **យថាភូតទស្សនៈ** ។

ចំណែកបុគ្គលណា លះ **យថាភូតទស្សនៈនោះចោល** ប្រកាន់ថា **សត្វមាន** បុគ្គលនោះ ក៏នឹងគប្បីឈ្មោះថា អំណោយដល់ការសាបសូន្យ ឬការមិនសាបសូន្យឲ្យដល់ខ្លួនឯង គឺកាលនាំឲ្យការមិនសាបសូន្យ ក៏នឹងធ្លាក់ទៅក្នុងសស្សតៈ កាលនាំឲ្យការសាបសូន្យក៏ធ្លាក់ទៅក្នុងឧច្ឆេទ ព្រោះហេតុអ្វី ព្រោះមិនមានវត្ថុដទៃ និងជាវត្ថុជាប់តាមទៅ ដូចទឹកដោះជូរជាប់តាមទឹកដោះស្រស់ បុគ្គលនោះ កាលកាន់យកថា **សត្វទៀង** ឈ្មោះថា ថយក្រោយ កាលប្រកាន់ថា **សត្វដាច់សូន្យ** ឈ្មោះថា ជ្រុលហួសទៅ ហេតុនោះ ទើបព្រះសាស្តាត្រាស់ទុកថា ម្នាលភិក្ខុទាំងឡាយ ទេវតា និងមនុស្សទាំងឡាយដែលត្រូវទិដ្ឋិគតៈ ២យ៉ាងចោមរោម ពួកមួយថយក្រោយ ពួកមួយជ្រុលទៅមុខ ចំណែកពួកអ្នកមានចក្ខុទាំងឡាយ រមែងឃើញ ( តាមសេចក្តីពិត)។

ម្នាលភិក្ខុទាំងឡាយ ទេវតា និងមនុស្សពួកមួយថយក្រោយ ដូចម្តេច ? ម្នាលភិក្ខុទាំងឡាយ ទេវតា និងមនុស្ស ( ពួកមួយ ) មានភពជាទីត្រេកអរ ពេញចិត្តក្នុងភព រីករាយក្នុងភព កាលធម៌ដើម្បីការរលត់នៃភព ដែលតថាគតសម្តែងចិត្តរបស់ទេវតា និងមនុស្សពួកនោះ មិនស្ទុះទៅ ( តាមក្រសែធម៌ ) មិនជ្រះថ្លា មិនឈប់មិនបង្អោនចិត្ត ( ជឿ ) យ៉ាងនេះឯងភិក្ខុទាំងឡាយ ទេវតា និងមនុស្ស ពួកមួយថយក្រោយ ។

ម្នាលភិក្ខុទាំងឡាយ ទេវតា និងមនុស្សពួកមួយ ជ្រុលទៅ ដូចម្ដេច ? ឯទេវតា និងមនុស្សពួកមួយ ខ្លាចរអា តក់ស្លុត ស្អប់ខ្ពើមកពនោះឯង ត្រេកអរក្រៃពេកនូវវិភវៈ ( ការដាច់សូន្យ ) ជាហេតុឲ្យពោលថា លោកដ៏ចម្រើនទាំងឡាយ ន័យថា អត្តានេះ បែរមុខអំពីស្លាប់ ព្រោះកាយបែកទៅ រមែងដាច់ រមែងសូន្យ រមែងមិនមានទៀត ខាងមុខអំពីស្លាប់ទៅ ការដាច់សូន្យនោះជាធម្មជាតិល្អិត ការដាច់សូន្យនោះជាធម្មជាតិប្រណីត ការដាច់សូន្យនោះជាធម្មជាតិពិត យ៉ាងនេះឯងភិក្ខុទាំងឡាយ ទេវតា និងមនុស្សពួកមួយ ជ្រុលហួសទៅ ។

ម្នាលភិក្ខុទាំងឡាយ ចំណែកពួកបុគ្គលមានចក្ខុ រមែងឃើញដូចម្ដេច ? ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងធម្មវិន័យនេះ រមែងឃើញភូតគឺបញ្ចក្ខន្ធ ឬនាមរូប ដោយភាពជាភូត គឺមិនឃើញជាសត្វជាបុគ្គល កាលឃើញភូតជាភូតហើយ រមែងជាអ្នកបដិបត្តិដើម្បីនឿយណាយ ដើម្បីមិនត្រេកអរ ដើម្បីរលត់ទៅនៃភូត យ៉ាងនេះឯងភិក្ខុទាំងឡាយ ចំណែកពួកដែលមានចក្ខុ រមែងឃើញដូច្នេះ ។

ព្រោះហេតុនោះ ឈើយន្តជារបស់ទទេ មិនមានជីវៈ មិនមានការត្រិះរិះ តែវាដើរក៏បាន ឈប់ក៏បាន ប្រាកដដូចរបស់មានការត្រិះរិះ មានការព្យាយាម ដោយអំណាចការប្រកបចូលគ្នានៃឈើជាមួយខ្សែ ( ទាញ ) យ៉ាងណា សូម្បីនាមរូបនេះ បណ្ឌិតគប្បីឃើញថា ជារបស់ទទេ មិនមានជីវៈ មិនមានការត្រិះរិះ តែវាដើរក៏បាន ឈប់ក៏បាន ប្រាកដដូចវត្ថុមានការត្រិះរិះ មានសេចក្ដីព្យាយាម ដោយអំណាចការប្រកបគ្នានឹងគ្នា ដូច្នោះ ព្រោះហេតុនោះ ទើបព្រះបុរាណាចារ្យទាំងឡាយពោលទុកថា

នាម និងរូប ( ប៉ុណ្ណោះ ) មាននៅក្នុងលោកនេះ ដោយ ( បរមត្ថ ) សច្ចៈ ឯក្នុងនាម និងរូបនោះ សត្វ និងបុគ្គលមិនមានឡើយ នាម និងរូបនេះ ជារបស់ទទេ ដែលបច្ច័យតាក់តែងឡើងដូចយន្ត វាជាគំនរទុក្ខ ដូចជា ( គំនរ ) ស្មៅ និងឧស ។

ម្យ៉ាងទៀត នាមរូបនោះ គួរឲ្យជាក់ច្បាស់ដោយឧបមាឈើយន្ត ត្រឹមប៉ុណ្ណោះក៏ទេ បណ្ឌិតគួរឲ្យជាក់ច្បាស់ដោយឧបមាដទៃៗ មានកំណាត់បបុស ។ ពិតហើយ កំណាត់បបុស ២ កំណាត់ គេតម្រៀបផ្អែកគ្នាទុក វាតែងទប់គ្នាទុក កាលកំណាត់មួយរលំ កំណាត់មួយទៀតក៏រលំដែរ យ៉ាងណា នាម និងរូបក្នុងបញ្ចវោការភព ក៏អាស្រ័យគ្នានឹងគ្នាប្រព្រឹត្តទៅ តែងឧបការៈគ្នាទុក កាលមួយរលំ ដោយអំណាចមរណៈ មួយទៀតក៏រលំដែរ ដូច្នោះដូចគ្នា ព្រោះហេតុនោះ ទើបបុរាណាចារ្យទាំងឡាយពោលទុកថា

**នាម និងរូប ជាគូគ្នា ទាំងគូរអាស្រ័យគ្នានឹងគ្នា កាលរបស់មួយបែក ក៏បែកទាំងគូតាមបច្ច័យ ។**

ម្យ៉ាងទៀត កាលសំឡេងអាស្រ័យស្គរ ដែលបុគ្គលវាយដោយឈើប្រព្រឹត្តទៅ ស្គរម្យ៉ាង សំឡេងក៏ម្យ៉ាង ស្គរ និងសំឡេងមិនបានលាយគ្នា ស្គរទទេអំពីសំឡេងៗ ក៏ទទេអំពីស្គរ យ៉ាងណា កាលនាមអាស្រ័យរូប ពោល គឺហទយវត្ថុ ទ្វារ និងអារម្មណ៍ ប្រព្រឹត្តទៅ រូបក៏ម្យ៉ាង នាមក៏ម្យ៉ាង នាម និងរូបមិនបានលាយគ្នា នាមទទេអំពីរូប រូបក៏ទទេអំពីនាម ដូច្នោះដូចគ្នា ត្រឹមតែជានាមអាស្រ័យរូបប្រព្រឹត្តទៅ ដូចសំឡេងអាស្រ័យស្គរប្រព្រឹត្តទៅ ដូច្នោះ ហេតុនោះ ទើបបុរាណាចារ្យទាំងឡាយពោលទុកថា

**ធម៌ទាំងឡាយ មានផស្សៈជាគម្រប់ ៥ មិនបានកើតអំពីភ្នែក មិនបានកើតអំពីរូប និងមិនបានកើតក្នុងចន្លោះភ្នែក និងរូបទាំង ២ ជាសង្ខតៈ អាស្រ័យហេតុកើតឡើង ប្រៀបដូចស្គរត្រូវវាយ សំឡេងក៏កើតឡើង ដូច្នោះ ។**

**ធម៌ទាំងឡាយ មានផស្សៈជាគម្រប់ ៥ មិនកើតអំពីត្រចៀក មិនបានកើតអំពីសំឡេង និងមិនបានកើតក្នុងចន្លោះត្រចៀក និងសំឡេងទាំង ២ ។បេ។**

**ធម៌ទាំងឡាយ មានផស្សៈជាគម្រប់ ៥ មិនបានកើតអំពីច្រមុះ មិនបានកើត**

អំពីក្លិន និងមិនបានកើតក្នុងចន្លោះច្រមុះ និងក្លិន ទាំង ២ ។បេ។

ធម៌ទាំងឡាយ មានផស្សៈជាគម្រប់ ៥ មិនបានកើតអំពីអណ្តាត មិនបានកើតអំពីរស និងមិនបានកើតក្នុងចន្លោះអណ្តាត និងរសទាំង ២ ។បេ។

ធម៌ទាំងឡាយ មានផស្សៈជាគម្រប់ ៥ មិនបានកើតអំពីកាយ មិនបានកើតអំពីផស្សៈ និងមិនបានកើតក្នុងចន្លោះកាយ និងផស្សៈទាំង ២ ។បេ។

សង្ខតធម៌ទាំងឡាយ មិនបានកើតអំពីវត្ថុរូប គឺហទយៈ ទាំងមិនបានចេញអំពីធម្មាយតនៈទាំងឡាយ ដោយវាជាសង្ខតៈ អាស្រ័យហេតុកើតឡើង ប្រៀបដូចកាលស្គរត្រូវវាយ សំឡេងក៏កើត ដូច្នោះ ។

មួយទៀតសោត ក្នុងនាម និងរូបនេះ នាមមិនមានតេជៈ មិនអាចប្រព្រឹត្តទៅដោយតេជៈរបស់ខ្លួនបាន ទំពាស៊ីមិនបាន ផឹកមិនបាន និយាយមិនបាន សម្រេចឥរិយាបថមិនបាន សូម្បីរូបក៏មិនមានតេជៈ មិនអាចប្រព្រឹត្តទៅ ដោយតេជៈរបស់ខ្លួនទាំងការប្រាថ្នានឹងទំពាស៊ីរបស់វាក៏មិនមាន ប្រាថ្នានឹងផឹកក៏មិនមាន ប្រាថ្នានឹងនិយាយក៏មិនមាន ប្រាថ្នានឹងសម្រេចឥរិយាបថក៏មិនមាន ។ ដែលពិតនោះ រូបអាស្រ័យនាមប្រព្រឹត្តទៅ នាមក៏អាស្រ័យរូបប្រព្រឹត្តទៅ តែកាលប្រាថ្នានឹងទំពា កាលប្រាថ្នានឹងផឹក កាលប្រាថ្នានឹងនិយាយ កាលប្រាថ្នានឹងសម្រេចឥរិយាបថរបស់នាម មានរូបក៏ទំពាក៏ផឹក ក៏និយាយ ក៏សម្រេចឥរិយាបថ ។

ម្យ៉ាងទៀត អាចារ្យទាំងឡាយនាំឧបមានេះមកអាងទុក ដើម្បីញ៉ាំងសេចក្តីនេះឲ្យជាក់ច្បាស់ ដូច ( មនុស្សពិការ ២ នាក់ ) ម្នាក់ក្អែកខ្វាក់អំពីកំណើត ម្នាក់ជាបុគ្គលខ្វិន ប្រាថ្នានឹងចៀសចេញទៅកាន់ទិស ទើបនាយខ្វាក់អំពីកំណើតនិយាយនឹងនាយខ្វិនដូច្នេះថា នែកណោ ខ្ញុំអាចប្រើជើងបាន តែក្អែកប្រើមើលទីរាបមិនរាបរបស់ខ្ញុំមិនមាន ខាងនាយខ្វិនក៏និយាយនឹងនាយខ្វាក់ដូច្នេះថា អើ កណោ ខ្ញុំនេះអាចប្រើ

ក្អែកបាន តែការឈានទៅមុខ ឬថយក្រោយរបស់ខ្ញុំមិនមាន នាយខ្វាក់នោះសប្បាយចិត្ត ទើបឲ្យនាយខ្វិនឡើងលើស្មា នាយខ្វិននោះអង្គុយលើស្មារបស់នាយខ្វាក់ ( ចាំ ) ប្រាប់ដូច្នេះថា ចៀសឆ្វេង ទៅស្តាំ ចៀសស្តាំ ទៅឆ្វេង ( នាយខ្វាក់ធ្វើតាមនាយខ្វិនប្រាប់នាំគ្នាទៅបាន ) ។ ក្នុង ២ នាក់នោះ ខាងនាយខ្វាក់ក៏មិនមានតេជះ ទន់ខ្សោយទៅដោយតេជះរបស់ខ្លួនមិនបាន ទៅដោយពលៈរបស់ខ្លួនក៏មិនបាន នាយខ្វិនសោត ក៏មិនមានតេជះ ទន់ខ្សោយទៅបានដោយតេជះរបស់ខ្លួនក៏ទេ ទៅបានដោយពលៈរបស់ខ្លួនក៏ទេ តែការអាស្រ័យគ្នានឹងគ្នាទៅ របស់នាយខ្វាក់នាយខ្វិនទាំង ២ នោះ ប្រព្រឹត្តទៅមិនបានក៏ទេ យ៉ាងណា សូម្បីនាមក៏មិនមានតេជះ កើតឡើងដោយតេជះរបស់ខ្លួននោះឡើយ មិនប្រព្រឹត្តទៅក្នុងកិរិយានោះៗ ឡើយ រូបសោត ក៏មិនមានតេជះកើតឡើងដោយតេជះរបស់ខ្លួនឡើយ មិនប្រព្រឹត្តទៅក្នុងកិរិយានោះៗ ឡើយ តែការអាស្រ័យគ្នានឹងគ្នាកើតឡើង ឬប្រព្រឹត្តទៅនៃនាម និងរូបនោះមិនមានក៏ទេ ព្រោះហេតុនោះ ទើបអាចារ្យទាំងឡាយពោលពាក្យប្រព័ន្ធនេះទុកថា

*ធម៌ទាំងឡាយ ជាសន្ធត: ទន់ខ្សោយដោយអំណាចខ្លួន កើតដោយពលៈរបស់ខ្លួនមិនបាន ទាំងតាំងនៅដោយកម្លាំងរបស់ខ្លួនក៏មិនបាន មានប្រក្រតីប្រព្រឹត្តទៅតាមអំណាចរបស់ធម៌ដទៃកើតឡើង ធម៌ទាំងនេះកើតព្រោះមានធម៌ដទៃជាបច្ច័យកើតឡើងព្រម ព្រោះមានធម៌ដទៃជាអារម្មណ៍ ឯអារម្មណ៍ និងបច្ច័យទាំងឡាយដែលធម៌ដទៃឲ្យកើតឡើង ។*

បុគ្គលទាំងឡាយ អាស្រ័យទូកទៅក្នុងសមុទ្របាន យ៉ាងណា នាមកាយក៏អាស្រ័យរូបប្រព្រឹត្តទៅបានដូច្នោះដែរ ទូកអាស្រ័យបុគ្គលមនុស្សទាំងឡាយ ទៅក្នុងសមុទ្របាន យ៉ាងណា រូបកាយ ក៏អាស្រ័យនាមប្រព្រឹត្តទៅបាន ដូច្នោះដូចគ្នា មនុស្សទាំងឡាយ និងទូកទាំង ២ ចំណែកតែងអាស្រ័យគ្នាទៅក្នុងសមុទ្របាន យ៉ាងណា

នាម និងរូបទាំង ២ ក៏ជាធម៌អាស្រ័យគ្នានឹងគ្នា ដូច្នោះ ។

ការឃើញនាមរូបតាមសេចក្តីពិត ដែលគ្របសង្កត់បង់នូវសត្តសញ្ញា តាំងនៅក្នុងអសម្មោហភូមិនៃព្រះយោគាវចរ ដែលកំណត់នាមរូបដោយន័យផ្សេងៗ ដូចពណ៌នាមកដូច្នេះ បណ្ឌិតគប្បីជ្រាបថា ឈ្មោះ **ទិដ្ឋិវិសុទ្ធិ** ពាក្យថា **នាមរូបវវដ្ឋាន** ការកំណត់នាមរូបក្តី ពាក្យថា **សង្ខារបរិច្ឆេទ**-កំណត់សង្ខារក្តី ក៏ជាពាក្យហៅ **នាមរូបយាថាវទស្សនៈ** ( ការឃើញនាមរូបតាមសេចក្តីពិត ) នោះឯង ។

បរិច្ឆេទទី ១៨ ឈ្មោះ ទិដ្ឋិវិសុទ្ធិនិទ្ទេស

ក្នុងអធិការនៃបញ្ញាភាវនា

ក្នុងបករណ៍វិសុទ្ធិមគ្គ

ដែលខ្ញុំព្រះករុណា ធ្វើដើម្បីប្រយោជន៍ដល់បាមោជ្ជនៃសាធុជន

ដូច្នេះ ។

# មហាដីកា

## កថាពណ៌នាដោយការអធិប្បាយ

## នាមរូប ដោយឧបមា

ពាក្យថា **តាំងនៅដោយល្អ ដោយអាការឯណានីមួយ** សេចក្ដីថា កាលអង្គសម្ភារៈ មានភ្លៅជាដើមតាំងនៅដោយល្អ ដោយប្រការណា ឈ្មោះថា **រថ ទើបមាន** កាលអង្គសម្ភារៈតាំងចុះដោយល្អ គឺធ្វើឲ្យជាគំនររួមគ្នាដោយអាការឯណានីមួយនោះ ។ ពាក្យថា **ដូច្នោះដូចគ្នា** សេចក្ដីថា កាលធម៌តែមួយចំណែក និងធម៌ ដែលជាចំណែករួម ដែលផ្សេងដោយការតាំងចុះ ប្រព្រឹត្តទៅដោយអំណាចការបន្តគ្នា រ៉ោហារថា **រថ ផ្ទះ ប្រអប់ដៃ ពិណា កងទ័ព ក្រុង ដើមឈើ** ក៏មានឡើងប៉ុណ្ណោះឯង តែដោយបរមត្ថ រមែងមិនមានអ្វីដែលឈ្មោះថា រថ ជាដើមនោះឡើយ សេចក្ដីនេះ យ៉ាងណា ការឧបមេយ្យ ក៏ដូច្នោះឯង ពាក្យថា **កាលឧបាទានក្ខន្ធ** សេចក្ដីថា ការដឹងតាមសេចក្ដីពិតថា កាលរូបធម៌ និងអរូបធម៌ ដែលសន្មតថា ឧបាទានក្ខន្ធប្រជុំគ្នា គឺប្រព្រឹត្តទៅដោយអំណាចការបន្តគ្នា រ៉ោហារថា **សត្វ ជីវៈ** ក៏មានឡើងប៉ុណ្ណោះឯង តែដោយបរមត្ថ មិនមានសត្វ ឬជីវៈឡើយ ។ **ការឃើញតាមសេចក្ដីពិត** នេះ លោកហៅថា **ទិដ្ឋិវិសុទ្ធិ** ។

បទថា **តស្ស ឃោគ សត្តោតិ គហិតស្ស អត្តនោ** ដល់ខ្លួនដែលប្រកាន់ថា មានសត្វ ។ ពាក្យថា **ការសោះសូន្យ** បានដល់ ការសោះសូន្យរបស់អត្តា ដែលលេត់ទៅ ។ ពាក្យថា **ការមិនសោះសូន្យ** គឺការមិនវិនាសទៅ អធិប្បាយថា ជារបស់ទៀង ។ ឯបុគ្គលដែលជាអត្តវាទីទាំងឡាយតាំងនៅហើយ ដោយអំណាចការឃើញ ២ យ៉ាងនោះឯង គឺឃើញថា អត្តាទៀងខ្លះ ឃើញថា អត្តាដាច់សូន្យខ្លះ សូម្បីវាទៈ

ជាទៀងចំណែកខ្លះ ក៏រួមនៅក្នុងទីនេះដូចគ្នា ។ ពាក្យថា **ឲ្យការមិនសោះសូន្យ** បុគ្គលកាលប្រាថ្នាការសោះសូន្យនៃធម៌ទាំងឡាយ មានពុទ្ធិជាដើម ក៏ឲ្យភាពមិនមានការសោះសូន្យរបស់អត្តាថា **សភាវៈមានធម៌ទៀង តាំងនៅដូចកំពូលភ្នំ** ។ ពាក្យថា **ក្នុងសស្សតៈ** គឺក្នុងការប្រកាន់ថា **ទៀង** ។ អធិប្បាយថា **នឹងធ្លាក់ទៅ** ព្រោះការទាក់ទងជាមួយទោស មានការសោះសូន្យរបស់សង្ខតធម៌ និងការមកចំពោះមុខរបស់អសង្ខតធម៌ ។ បទថា **ឱវទ្ធ យស្ស** ប្រែថា ជាប់តាម ទឹកដោះស្រស់ អធិប្បាយថា ដែលជាផល ។ ពាក្យថា **នឹងជាវត្ថុជាប់តាមទៅ** គឺ **ព្រោះមិនមានអ្វីដទៃ** ជាវត្ថុជាប់តាមអត្តានោះ ។ ពាក្យថា **ឈ្មោះថា ជំអក់នៅ** សេចក្តីថា បុគ្គលជាអ្នកត្រេកអរក្រៃលែងក្នុងភព ដោយប្រកាន់មាំថា **អត្តាទៀង** ក៏នឹងរួញខ្លួនអំពីការរលត់ភព ឈ្មោះថា **ជំអក់នៅ** ក្នុងភពនោះឯង ។ ពាក្យថា **ឈ្មោះថា ស្ទុះទៅ** សេចក្តីថា អាចារ្យទាំងឡាយ រមែងពោលថា អ្នកមានលទ្ធិថា ដាច់សូន្យថា អត្តាក្នុងភពនោះឯង រមែងដាច់សូន្យ ដូច្នេះ ប្រកាន់ថា **អត្តារមែងដាច់សូន្យ** ឈានកន្លងភពដែលមានក្រោយអំពីស្លាប់ទៅថា **មិនមាន** ដូច្នេះ ឈ្មោះថា **ស្ទុះទៅ** ។ ក៏កាលគប្បីប្រាថ្នាការរលត់ភពព្រោះកម្មមិនឲ្យផលក្នុងការរំលត់កិលេស បុគ្គលមិនបានកាន់យកយ៉ាងនោះ ប្រកាន់ថា **ការរលត់ភព រមែងមាន យ៉ាងនេះ គឺអត្តា អាស្រ័យភពវិសេសនោះៗ រមែងដាច់សូន្យ** ដូច្នេះ ឈ្មោះថា **រមែងស្ទុះទៅអំពីភពនោះ** ។

ពាក្យថា **ចោមរោម** គឺគ្របសង្កត់ហើយ ។ ពាក្យថា **បុគ្គលដែលមានចក្ខុ** គឺពួកអ្នកមានចក្ខុដោយញាណចក្ខុ ពោល គឺការឃើញតាមសេចក្តីពិត ។

ភពផ្សេងៗ មានកាមភពជាដើម ជាទី.មកត្រេកអរ ដោយអត្ថថា **គួរមកត្រេកអរ** ដល់ទេវតា និងមនុស្សទាំងនេះ ហេតុនោះ ទេវតា និងមនុស្សទាំងនេះ ឈ្មោះថា **ភវារាមា** មានភពជាទីត្រេកអរ ។ ទេវតា និងមនុស្សពួកណាត្រេកអរហើយ គឺ

ត្រេកអរក្រៃលែងហើយក្នុងភពនោះ ហេតុនោះ ទេវតា និងមនុស្សទាំងនោះ ឈ្មោះថា **ភវារាមា** អ្នកត្រេកអរហើយក្នុងភព ។ ទេវតា និងមនុស្សពួកណា ដល់នូវការត្រេកអរក្នុងភព ហេតុនោះ ទេវតា និងមនុស្សទាំងនោះ ឈ្មោះថា **ភវសម្មុទិតា** ដល់នូវភាពត្រេកអរក្នុងភព ។ ដោយបទទាំង ៣ លោកអាចារ្យ ពោលភាពដែលទេវតា និងមនុស្សជាអ្នកត្រេកត្រអាលដោយសេចក្ដីត្រេកអរ ក្នុងភព ។ ពាក្យថា **ចិត្តមិនស្ទុះទៅ** សេចក្ដីថា ចិត្តមិនចូលទៅតាមក្នុងធម៌ដែលនាំមកនូវការរលត់ភព ព្រោះទេវតា និងមនុស្សជាអ្នកត្រេកត្រអាលដោយភាព ត្រេកអរក្នុងភព ។ ពាក្យថា **មិនជ្រះថ្លា** គឺមិនដាក់ចិត្ត ។ ពាក្យថា **មិនឈប់** គឺមិនតាំងមាំ ។ ពាក្យថា **មិនបង្អោនចិត្ត** គឺមិនសម្រេចចិត្ត ។ ពាក្យថា **ខ្វាចរអា** គឺធ្វើឲ្យជាទុក្ខ ។ ពាក្យថា **ឆ្អើម** គឺខ្ពើមរអើម ។ ពាក្យថា **រង្កៀស** គឺមើលងាយ ។ ពាក្យថា **វិភវ** គឺការដាច់សូន្យ ។ ពាក្យថា **យតោ កិរ ភោ** ជាដើម ជាពាក្យសម្ដែងអាការត្រេកអរពន់ពេក ដែលបានពោលហើយថា **ត្រេកអរក្រៃពេក** ។ ពាក្យថា **ភូត** បានដល់ ខន្ធ ៥ ។ ខន្ធ ៥ នោះ ហៅថា **ភូត** ព្រោះជាវត្ថុដែលកើតដោយបច្ច័យទាំងឡាយ តាមសមគួរដល់ខ្លួន និងព្រោះជាវត្ថុមានដោយបរមត្ថ ។ ពាក្យថា **ដោយភាពជាភូត** បានដល់ ដោយសភាវៈតាមសេចក្ដីពិតដោយលក្ខណៈរបស់ខ្លួន និងដោយសាមញ្ញលក្ខណៈ ។

លោកអាចារ្យ កាលសម្ដែងទោសក្នុងការជំអក់នៅ និងការស្ទុះទៅ ដោយការប្រកាន់ថា ជាសត្វ និងគុណ មានទិដ្ឋិទាជាដើម ព្រោះឃើញតាមសេចក្ដីពិត ដោយអំណាចព្រះសូត្រនោះឯង យ៉ាងនេះហើយ ឥឡូវនេះ បំណងនឹងសម្ដែងការសម្រេចកិច្ចរបស់អត្តា មានការដើរបានជាដើម សូម្បីក្នុងវត្ថុដែលត្រឹមតែជានាម និងរូបប៉ុណ្ណោះ ទើបពោលពាក្យថា **ព្រោះហេតុនោះ** ដូច្នេះជាដើម ។ ក្នុងពាក្យនោះ ពាក្យថា **ព្រោះហេតុនោះ** សេចក្ដីថា ឈ្មោះថា សត្វដែលជាវត្ថុនៃការប្រកាន់ថា **ជាអញ** ឬថា

**អញ្ញជា** មិនមានពោលដោយបរមត្ថ ក៏មានត្រឹមតែនាម និងរូបប៉ុណ្ណោះ ព្រោះហេតុណា ព្រោះហេតុនោះ ។ លោកអាចារ្យពោលពាក្យថា **ឈើ យន្ត** ជាដើម សំដៅដល់ការចោទសួរថា បើដែលបានឈ្មោះថា អត្តាណាមួយមិនមានសោត ក្នុងសភាវៈត្រឹមតែជានាមរូប ក្នុងទីនេះ នឹងមានការសម្រេចកិច្ចរបស់អត្តា មានការដើរជាដើម បានដូចម្តេច ។ ដោយពាក្យថា **ប្រាកដ** នេះ លោកអាចារ្យរមែងសម្តែងថា ក្នុងគ្រឿងយន្តដែលធ្វើដោយឈើ ដែលមិនមានជីវៈ ក៏នៅមានការប្រាកដបាន ដូចរបស់ដែលមានសេចក្តីត្រិះរិះ មានសេចក្តីព្យាយាមដោយអំណាចជីវៈដែលប្រព្រឹត្តទៅខាងក្នុង ព្រោះការផ្សេងគ្នានៃបច្ច័យ យ៉ាងណា ក្នុងសភាវៈត្រឹមតែជានាមរូប មិនមានជីវៈ ក៏មានការសម្រេចកិច្ចនៃអត្តា មានការដើរ បានជាដើម ព្រោះការផ្សេងនៃបច្ច័យ ក៏យ៉ាងនោះ ។

ពាក្យថា **ដោយសច្ចៈ** ប្រែថា ដោយសេចក្តីពិត អធិប្បាយថា ដោយបរមត្ថ ។ ឯបំណងថា នាមរូបដែលត្រូវបច្ច័យតាក់តែងឡើង ក៏ដូចជាគ្រឿងយន្ត ដែលទទេចាកជីវៈ រមែងប្រព្រឹត្តទៅដោយអំណាចនៃបច្ច័យ ។ ឈ្មោះថា **ជាគំនរ ទុក្ខ** ព្រោះនាមរូបរសាប់រសល់ជានិច្ច ឈ្មោះថា **ដូចជាស្មៅ និងឧស** អធិប្បាយថា ព្រោះនាមរូបទទេចាក ( អត្តា ) ។ បទថា **ឯតំ** បានដល់ នាមរូប ។

បទថា **យមកំ** ប្រែថា ទាំងគូ ។ ភាពដែលនាម និងរូប ជារបស់គូគ្នានោះឯង ក៏ដោយភាវៈដែលជាវត្ថុអាស្រ័យគ្នានឹងគ្នា ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **ទាំងគូអាស្រ័យគ្នានឹងគ្នា** ដូច្នេះ ។ ព្រោះហេតុនោះឯង កាលមួយបែកធ្លាយក៏បែកទាំងគូ ។ ក្នុងបញ្ចវោការភព កាលរូបរលត់ អរូបមិនរលត់ ឬកាលអរូបរលត់ រូបមិនរលត់ នឹងមាននៅក្នុងកាលណាមួយមិនមាន ។ ការបែកធ្លាយនេះ **តាមបច្ច័យ** គឺដោយការរលត់បច្ច័យនោះឯង អធិប្បាយថា ការរលត់នៃនាមរូប ។ម្យ៉ាងទៀត បទថា **បច្ចយា** ប្រែថា ជាបច្ច័យ អធិប្បាយថា ទាំងគូជាបច្ច័យនៃគ្នានឹងគ្នា ក៏បែក

ជាយនោះឯង ។

ពាក្យថា **ដែលបុគ្គលវាយដោយឈើ** លោកអាចារ្យរមែងសម្តែងដល់ឈើដោយពាក្យដែលធ្វើឲ្យជាភាពពិសេសឡើង និងសេចក្តីព្យាយាមរបស់បុគ្គលជាបច្ច័យនៃការវាយដោយឈើ ភាពដែលស្គរជាវត្ថុដែលគប្បីធ្វើឲ្យវិសេសឡើង ក៏ព្រោះជាហេតុដែលមិនទូទៅនៃសំឡេង ។ ដោយហេតុនោះឯង ទើបលោកកាន់យកស្គរតែម្យ៉ាងថា **ស្គរ ១** មិនបានកាន់យកវត្ថុ មានឈើជាដើមឡើយ លោកអាចារ្យធ្វើការប្រៀបធៀបឧបមាដោយពាក្យថា **ដូច្នោះដូចគ្នា** ជាដើម ធ្វើសំឡេងឲ្យនៅក្នុងឋានៈជានាម ព្រោះសំឡេងជារូបដែលមើលមិនឃើញ ។

ពាក្យថា **មិនបានកើតអំពីភ្នែក** សេចក្តីថា មិនបានកើតដោយចេញទៅអំពីចក្ខាយតនៈ ។ ពិតណាស់ មុននឹងចូលដល់ភាពជាបច្ច័យដល់ចក្ខាយតនៈ ធម៌ទាំងឡាយដែលមានផស្សៈជាគម្រប់ ៥ មិនបានរកធម៌ទាំងឡាយ ដែលមានទីអាស្រ័យដែលជាហេតុ គប្បីចេញទៅអំពីចក្ខាយតនៈនោះបានឡើយ ។ ដោយហេតុនោះឯង ទើបលោកអាចារ្យពោលថា **គំនរខន្ធមិនមានក្នុងអនាគត** ដូច្នេះ ។ សូម្បីក្នុងពាក្យថា **មិនបានកើតអំពីរូប** នេះ ក៏មានន័យនេះដូចគ្នា ។ ចំណែកពាក្យថា **មិនបានកើតចន្លោះភ្នែក និងរូបទាំង ២** នេះ លោកពោលទុក ព្រោះជាធម៌មិនមានទីអាង ហេតុដែលធម៌ទាំងឡាយ មានផស្សៈជាគម្រប់ ៥ នោះ ជាអរូបធម៌ ។ ការសង្គ្រោះបច្ច័យមានក្នុងខណៈណា ក៏មានត្រឹមតែការកើតឡើងប៉ុណ្ណោះឯង ក្នុងវេលានោះតែម្យ៉ាង ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **ធម៌ជាសង្ខតៈ អាស្រ័យហេតុកើតឡើង** អធិប្បាយថា ធម៌ទាំងឡាយ មានផស្សៈជាដើម ឈ្មោះថា **សង្ខតៈ** ព្រោះធម៌ទាំងនោះប្រជុំគ្នា គឺកើតរួមគ្នាតាក់តែងឡើង អាស្រ័យធម្មជាតិដែលផ្សេងគ្នាដោយចក្ខុ រូប ពន្លឺ និងមនសិការជាដើម គឺបានហេតុដែលជាបច្ច័យ ទើបកើតឡើង ។ លោកអាចារ្យ

កាលសម្តែងការប្រព្រឹត្តទៅនៃរូបធម៌ ដែលប្រាកដដោយការកើតឡើងនៃធម៌ទាំងឡាយនោះ ទើបពោលថា **ប្រៀបដូចស្គរដែលត្រូវវាយ សំឡេងក៏កើតឡើង** ដូច្នោះ ។ ក្នុងទីនេះ លោកកាន់យកធម៌ មានផស្សៈ ជាគម្រប់ ៥ ជាគ្រឿងសម្តែងអរូបធម៌ដែលប្រាកដ ។ សូម្បីក្នុងគាថាដ៏សេស ក៏មានន័យនេះឯង ។

ពាក្យថា **អំពីវត្ថុរូប** គឺអំពីហទយវត្ថុ ។ លោកអាចារ្យពោលពាក្យថា **សង្ខតធម៌ទាំងឡាយ** ដើម្បីសម្តែងអរូបធម៌ទាំងនោះ ដោយសាមញ្ញវោហារ ព្រោះអរូបធម៌ទាំងឡាយ ដែលមានហទយវត្ថុនោះជាទីអាស្រ័យ មានប្រភេទច្រើនពន់ពេក ពាក្យថា **មិនមានតេជះ** សេចក្តីថា សូន្យចាកតេជះ គឺវៀរចាកអានុភាព ។ លោកអាចារ្យពោលពាក្យថា **ទំពាមិនបាន** ជាដើម ដើម្បីសម្តែងប្រការដែលនាមនោះ មិនមានតេជះ ។ ឯនាមបុគ្គលណាម្នាក់ អាចពោលថា **មិនមានតេជះ** ក្នុងអាការទាំងឡាយមានការជឿ និងឧស្សាហភាពជាដើម ដោយប្រការដទៃក៏ទេ ។ ទាំងរូប បុគ្គលណាម្នាក់ អាចពោលថា មិនមានតេជះក្នុងអាការ មានការទ្រទ្រង់ទុក និងការជាប់ស្អិតជាដើមក៏ទេ ។ ដោយហេតុនោះឯង លោកអាចារ្យកាលពោលថា **រូបមិនមានតេជះ** ដូច្នេះហើយ បានពោលពាក្យជាដើមថា **ទាំងការប្រាថ្នានឹងទំពា នៃរូបក៏មិនមាន** ។ លោកអាចារ្យរមែងញ៉ាំងនាម និងរូបជាធម្មជាតិមិនមានតេជះ នោះឯងឲ្យជាក់ច្បាស់ សូម្បីទាក់ទងជាមួយសេចក្តីពិសេស ដោយពាក្យថា **ដែលពិត** ដូច្នេះជាដើម ។ សូម្បីការសម្រេចកិច្ចរបស់អត្តានៃនាម និងរូប ដោយជាទីអាស្រ័យគ្នានឹងគ្នា ជាការញ៉ាំងធម្មជាតិមិនមានសមត្ថភាពរៀងៗ ខ្លួន ឲ្យជាក់ច្បាស់ ពិតយ៉ាងនោះ នាម និងរូបទទេចាកអត្តា ភាពជារបស់មិនមានការត្រិះរិះ និងភាពជារបស់ដែលមិនមានការខ្នះខ្នែងរមែងជារឿងជាក់ច្បាស់ល្អក្រៃលែង ។

លោកអាចារ្យ ពោលពាក្យជាដើមថា **ដើម្បីញ៉ាំងសេចក្តីនេះឲ្យជាក់ច្បាស់**

ដូច្នេះ សំដៅដល់ពាក្យសួរថា ព្រោះភាពដែលសភាវធម៌ដែលមិនមានសមត្ថភាពរៀងៗខ្លួន មករួមចូលគ្នា និងមានសមត្ថភាពបានដូចម្ដេច ? ព្រោះសូម្បីកាលសភាវធម៌ដែលមិនមានហេតុ ក្នុងកាលមិនទាន់សាមគ្គីគ្នា មកសាមគ្គីចូលគ្នា ក៏ត្រូវជាធម៌ដែលមិនមានហេតុ ។ បុគ្គលខ្វាក់ដែលមិនអាចនឹងឃើញបានខ្លួនឯង មករួមគ្នាច្រើនរយនាក់ច្រើនពាន់នាក់ក៏មិនអាចឃើញបាន ។ ព្រះអដ្ឋកថាចារ្យទាំងឡាយ ឈ្មោះថា **រមែងនាំយកពាក្យឧបមានេះមកអះអាង** ព្រោះត្រូវញុំាំងអត្ថដែលមិនសម្រេច ដោយឧបមាឲ្យសម្រេច ។ ដោយហេតុនោះឯង ទើបព្រះសារីបុត្រពោលថា **ខ្ញុំនឹងធ្វើឧបមាឲ្យអ្នកស្ដាប់ ក្នុងលោកនេះ បុរសដែលឈ្លាសពួកខ្លះ រមែងដឹងច្បាស់អត្ថនៃភាសិតបានដោយពាក្យឧបមា** ។ ពាក្យថា **មានចិត្តរីករាយ** សេចក្ដីថា **បុគ្គលខ្វាក់ភ្នែកអំពីកំណើត** ត្រេកអរថា យើងមិនអាចធ្វើកិច្ច ដែលគប្បីធ្វើដោយភ្នែក ដោយពិត សូម្បីយ៉ាងនោះ យើងក៏អាចធ្វើកិច្ចដែលគប្បីធ្វើដោយជើង ហើយលោកក៏អាចធ្វើកិច្ចដែលគប្បីធ្វើបានដោយភ្នែក ព្រោះហេតុនោះ ការផ្លាស់ទីកន្លែងដែលបំណង ក៏នឹងសម្រេចបានដោយអំណាចយើងទាំងពីរ រួមគ្នា **ក្នុងបណ្ដាពាក្យទាំងនោះ** ពាក្យថា **បុគ្គលខ្វាក់អំពីកំណើត** ជាដើម ជាពាក្យប្រៀបធៀបឧបមា និងឧបមេយ្យ ។ ពាក្យថា **កើតឡើងដោយតេជះរបស់ខ្លួនក៏ទេ ប្រព្រឹត្តទៅក្នុងកិរិយានោះៗ ក៏ទេ** លោកអាចារ្យពោលទុកដើម្បីសម្ដែងថា ពាក្យដែលគួរពោលថា ការបានខ្លួនរបស់ធម៌ទាំងឡាយ ទាក់ទងដោយធម៌ដទៃ ដូច្នេះឯង រមែងមិនមាន ព្រោះមុនអំពីនោះ ក៏មិនមាន សូម្បីការបានខ្លួនដែលបានទុកហើយ ក៏មានកិច្ចនៃការត្រូវការដែលទាក់ទងដោយធម៌ដទៃនោះឯង លោកអាចារ្យ កាលបញ្ជាក់អត្ថដែលឲ្យសម្រេចហើយ ដោយឧបមា ដោយបុគ្គលខ្វាក់ភ្នែកអំពីកំណើត និងបុគ្គលខ្វិនថា **តែការអាស្រ័យគ្នានឹងគ្នាកើតឡើង ឬប្រព្រឹត្តទៅនៃនាម និងរូបនោះមិនមានក៏ទេ** ដូច្នេះ ទើបអធិប្បាយហេតុតាមដែលពោលហើយ

ជាហេតុមិនមែនប្រព្រឹត្តទៅដោយចំណែកមួយថា ព្រោះសូម្បីកាលសភាវធម៌ ដែលមិនមានហេតុ ក្នុងកាលមិនទាន់ដល់ព្រមគ្នា មកសាមគ្គីចូលគ្នា ក៏ត្រូវជាធម៌ដែលមិនមានហេតុ ។

ពាក្យថា **នាមរូបមានប្រក្រតីប្រព្រឹត្តទៅតាមអំណាចនៃធម៌ដទៃ** គឺមានប្រក្រតីប្រព្រឹត្តទៅតាមអំណាចរបស់ធម៌ដទៃ គឺបានដល់ ធម៌ ពោល គឺហេតុប្បច្ច័យដទៃផ្សេងអំពីខ្លួន ។ ពាក្យថា **ទន់ខ្សោយដោយទំនើងខ្លួន** សេចក្តីថា ទន់ខ្សោយ គឺមិនមានសមត្ថភាពដោយខ្លួនឯង ។ ពាក្យថា **ព្រោះមានធម៌ដទៃជាបច្ច័យ** សេចក្តីថា ព្រោះធម៌ដទៃជាបច្ច័យ ។ ដោយពាក្យនេះ លោកអាចារ្យពោលដល់បច្ច័យ ដែលធ្វើឲ្យកើត ។ ដោយហេតុនោះឯង ទើបលោកពោលថា **កើត** ។ ពាក្យថា **ព្រោះមានធម៌ដទៃជាអារម្មណ៍** សេចក្តីថា ព្រោះធម៌ដទៃជាអារម្មណ៍ ។ ដោយពាក្យនេះ លោកអាចារ្យពោលដល់ឧបត្ថម្ភកប្បច្ច័យ ។ម្យ៉ាងទៀត ស័ព្ទថា **បច្ច័យ** សំដៅដល់រូប ស័ព្ទថា **អារម្មណ៍** សំដៅដល់នាម ។ ពាក្យថា **ដែលជាធម៌ដទៃ** នេះ ជាវិសេសនៈរបស់អារម្មណ៍ និងបច្ច័យ ។ លោកអាចារ្យរមែងធ្វើអត្ថដែលពោលទុកដោយអត្ថមុនឲ្យប្រាកដ ដោយអត្ថក្រោយ ។ បទថា **បភាវិតា** ប្រែថា ធ្វើឲ្យកើតឡើង ។

លោកអាចារ្យពោលគាថាទាំង ៣ ដោយពាក្យថា **សូម្បីយ៉ាងណា** ជាដើម ដើម្បីអធិប្បាយនាម និងរូប ដែលជាធម្មជាតិមិនប្រព្រឹត្តទៅក្នុងអំណាច សូម្បីដោយពាក្យឧបមា មានទូកជាទីបំផុត ។ ពាក្យថា **អាស្រ័យ** គឺពឹងផ្អែក ។ បទថា **យន្តិ** ប្រែថា ទៅ ។ ពាក្យថា **អាស្រ័យបុគ្គល** សេចក្តីថា ពឹងអាស្រ័យបុគ្គល មានអ្នកនាំផ្លូវ និងអ្នកធ្វើការជាដើម ដែលជាអ្នកនាំទៅ ។ ព្រោះទូក មានការរំកិលល្អ ការធ្វើក្តោង

ឲ្យតាំងល្អ និងការអុំជាដើម របស់បុគ្គលទាំងនោះចេញ នឹងដល់ទីប្រាថ្នាមិនបាន ។ ពាក្យថា **ទាំងពីរចំណែក** សេចក្តីថា ដល់គ្នានឹងគ្នា បានដល់ បុគ្គលអាស្រ័យទូក ទូកក៏អាស្រ័យបុគ្គល ។

ពាក្យថា **ដូច្នោះ** គឺដោយប្រការដែលពោលហើយ ។ ពាក្យថា **ដោយន័យផ្សេងៗ** បានដល់ ដោយន័យ មានការកំណត់នាមរូប ៧៤ ន័យ គឺតាមបែបការកំណត់អរូប ១៤ ប្រការ ទាក់ទងនឹងឈាន ៧ មានបឋមជ្ឈានជាដើម និងឧបចារៈនៃឈាន ៧ ទាំងនោះ គន្លងបែបការកំណត់រូប ២០ ទាក់ទងនឹងធាតុ អាយតនៈ ខន្ធ និងមហាភូតនៃគន្លងបែបការកំណត់ធាតុ ១៣ ប្រការដែលពោលទុកក្នុងចតុធាតុវវត្ថាន ទាក់ទងជាមួយឥន្ទ្រិយ សច្ចៈ បដិច្ចសមុប្បន្នធម៌ ដែលបានពោលទុកក្នុងទីនេះ និងបានពោលទុកក្នុងគន្លងបែបការកំណត់រូប ៦០ នោះ តែម្យ៉ាង គុណនឹង ៣ ទាក់ទងជាមួយអរូបធម៌ទាំង ៣ ដែលប្រាកដដោយការៈ ដែលជួបគ្នាទាំងនេះ គឺ **ផស្សៈ វេទនា ចិត្ត** និងគន្លងបែបការកំណត់អរូប ១៤ ប្រការនោះផងដែរ ដោយន័យនៃការញែកសេចក្តីត្រឹមតែជានាមរូបច្រើនព្រះសូត្រ និងពាក្យឧបមាដោយរថ ទូក ប្រអប់ដៃ ពិណ កងទ័ព ដើមឈើ ឈើយន្ត កំណាត់បបុស ស្គរ មនុស្សខ្វាក់អំពីកំណើត និងមនុស្សខ្វិន ទូក និងមនុស្សផងដែរ ។

ពាក្យថា **ដែលគ្របសង្កត់បង់នូវសត្តសញ្ញា** គឺដែលសង្កត់សង្កិនការប្រកាន់ថា ជាអត្តាក្នុងខន្ធ ៥ ដែលធ្វើឲ្យមានរហូតអស់កាលដែលរកខាងដើមមិនមាន ។ ពាក្យថា **ឃើញនាម និងរូបតាមសេចក្តីពិត** សេចក្តីថា ឃើញការៈត្រឹមតែជាធម៌ ដោយមាតិកា គឺការកំណត់លក្ខណៈរបស់នាម និងរូបទាំងនោះថា **នេះនាម នាមប៉ុណ្ណោះ**

មិនក្រៃលែងជាងនេះ និងថា នេះរូប រូបប៉ុណ្ណោះ មិនក្រៃលែងជាងនេះ ។ គប្បីជ្រាបថា ឈ្មោះថា ទិដ្ឋិវិសុទ្ធិ ព្រោះជម្រះមន្ទិល គឺការយល់ឃើញថា ជាអត្តា ។ បទថា ឯតស្សេវ យោគ នាមរូបស្ស យាថាវទស្សនស្ស នោះឯង ប្រែថា របស់ ការឃើញនាមរូបតាមសេចក្ដីពិតនេះនោះឯង ។

កថាពណ៌នាទិដ្ឋិវិសុទ្ធិនិទ្ទេស ចប់

ពណ៌នាបរិច្ឆេទទី ១៨ ចប់ហើយ

ដោយប្រការ ដូច្នេះ ។

# វិសុទ្ធិមគ្គ

## កង្ខាវិតរណវិសុទ្ធិនិទ្ទេស

ចំណែកញាណដែលឆ្លងសេចក្ដីសង្ស័យក្នុងអទ្ធា ៣ បាន ដោយការកំណត់បច្ច័យរបស់នាមរូបនោះឯង ហើយតាំងនៅ ឈ្មោះថា **កង្ខាវិតរណវិសុទ្ធិ** ។

## ពិចារណាដល់ហេតុ-បច្ច័យរបស់នាមរូប

ភិក្ខុដែលប្រាថ្នាញុំាងកង្ខាវិតរណវិសុទ្ធិនោះឲ្យដល់ព្រម រមែងរំពឹងដល់ការរកហេតុ-បច្ច័យនៃនាមរូបនោះ ប្រៀបដូចគ្រូពេទ្យដ៏ឈ្លាស ឃើញរោគហើយ រមែងរកសមុដ្ឋានរបស់រោគនោះ ។ ឬម្យ៉ាងទៀត ប្រៀបដូចបុរសដែល (មានទឹកចិត្ត) រមែងអាណិតកុមារតូចៗ ដែលនៅដេកផ្ងារ ដេកនៅត្រង់ផ្លូវ ហើយរមែងរំពឹងដល់មាតាបិតារបស់ក្មេងនោះ ដោយគិត ( ក្នុងចិត្ត ) ថា **នេះកូនតូចរបស់នរណាហ្ន៎** ដូច្នោះ ។

ដំបូង ភិក្ខុនោះ រមែងពិចារណាដូច្នេះថា នាមរូបនេះអំពីមុន មិនមែនវត្ថុដែលមិនមានហេតុ ព្រោះវាដល់នូវភាពដូចគ្នាគ្រប់កន្លែង គ្រប់កាល និងគ្រប់គ្រា មិនមែនជាវត្ថុ មានបច្ច័យខាងក្រៅ មានព្រះឥស្សរជាដើមជាហេតុ ព្រោះមិនមានវត្ថុទាំងឡាយមានព្រះឥស្សរជាដើម ក្រៅអំពីនាមរូបទៅ ព្រោះសូម្បីជនពួកណា ពោលត្រឹមតែនាមរូបនោះឯងថា ជាឥស្សរជាដើម នាមរូប ពោល គឺព្រះឥស្សរជាដើមនៃជនទាំងនោះក៏ត្រូវ ( ក្លាយ ) ជាវត្ថុមិនមានហេតុ ព្រោះហេតុនោះ ហេតុប្បច្ច័យទាំងឡាយនៃនាមរូបនោះគួរគប្បីមាន ហេតុប្បច្ច័យទាំងនោះ បានដល់អ្វីហ្ន៎ ។

## កំណត់ហេតុ-បច្ច័យរបស់នាមរូបន័យទី ១

ភិក្ខុនោះ កាលពិចារណាដល់ហេតុ-បច្ច័យទាំងឡាយយ៉ាងនេះហើយ រមែង

កំណត់ហេតុ-បច្ច័យនៃរូបកាយនេះមុនដូច្នេះថា កាយនេះ កាលកើត មិនកើតក្នុងត្របកផ្កា មានឧប្បល បទុម បុណ្ឌរិក គឺឈូក.ស និងសោគន្ធិក គឺឈូកពណ៌ស្វាយជាដើមនោះឡើយ មិនកើតក្នុងរតនជាតិ មានកែវមណី និងកែវមុក្តាជាដើមឡើយ ដែលពិត កើតនៅក្នុងចន្លោះក្រពះអាហារថ្មី និងក្រពះអាហារចាស់ បែរខ្នងមកកាន់ខាងមុខ បែរមុខទៅកាន់ឆ្អឹងខ្នង មានពោះវៀនធំ និងពោះវៀន តូចនៅព័ទ្ធព័ន្ធ សត្វនោះឯងក៏ជារបស់បដិកូល មានក្លិនស្អុយគួរខ្ពើម ស្ថិតនៅក្នុងឱកាសដែលបដិកូល មានក្លិនស្អុយគួរខ្ពើម ជាទីចង្អៀតពន់ពេក ប្រៀបបីដូចដង្កូវ កើតក្នុងត្រីស្អុយ ទំផ្អូម អណ្តូងទឹកស្មោកគ្រោក និងរណ្តៅជ្រាំជាដើម ដូច្នោះ ។ ធម៌ ៥ ប្រការ ជាហេតុ-បច្ច័យរបស់រូបកាយនោះ ដែលកើតយ៉ាងនោះ ធម៌ ៤ នេះ គឺអវិជ្ជា តណ្ហា ឧបាទាន កម្ម ចាត់ជាហេតុ ព្រោះជាគ្រឿងធ្វើឲ្យកើតអាហារ ចាត់ជាបច្ច័យ ព្រោះជាគ្រឿងឧបការៈ ។ ម្យ៉ាងទៀត ក្នុងធម៌ ៥ នោះ ធម៌ ៣ មានអវិជ្ជាជាដើម ជាទីអាស្រ័យ ( កើត ) របស់កាយនេះ ដូចមាតាជាទីអាស្រ័យ ( កើត ) របស់ទារក កម្មជាគ្រឿងញុំាងកាយនេះឲ្យកើត ដូចបិតាញុំាងបុត្រឲ្យកើត អាហារជាគ្រឿងបីព.កាយនេះទុក ដូចនាងកីលៀងបីព.ទារកដូច្នោះ ។ កាលកំណត់បច្ច័យរបស់រូបកាយបានយ៉ាងនេះហើយ រមែងធ្វើការកំណត់បច្ច័យរបស់នាមកាយ តទៅ ដោយន័យថា ចក្ខុវិញ្ញាណ អាស្រ័យចក្ខុ និងរូបកើតឡើង ដូច្នេះ ជាដើម ។

## ការសង្ស័យ ១៦ ប្រការ

ភិក្ខុនោះ ឃើញការប្រព្រឹត្តទៅនៃនាមរូបដោយបច្ច័យយ៉ាងនេះហើយ រមែងសង្កេតឃើញបានថា នាមរូបនេះប្រព្រឹត្តទៅក្នុងកាលឥឡូវនេះ យ៉ាងណា សូម្បីក្នុងកាលអតីត វាក៏ប្រព្រឹត្តទៅហើយដោយបច្ច័យ ក្នុងកាលអនាគត វាក៏នឹងប្រព្រឹត្តទៅ

ដោយបច្ច័យ ដូច្នោះ ។ កាលបើលោកសង្កេតឃើញយ៉ាងនោះ ការសង្ស័យប្រារព្ធចំណែកខាងដើម ៥ ប្រការ ដែលពោលទុកថា

ក្នុងអតីតកាល អញបានមានបានកើតមកហើយឬហ្ន៎

ក្នុងអតីតកាល អញមិនបានមានមិនបានកើតឬហ្ន៎

ក្នុងអតីតកាល អញបានកើតជាអ្វីហ្ន៎

ក្នុងអតីតកាល អញបានកើតដូចម្តេចហ្ន៎

ក្នុងអតីតកាល អញបានកើតជាអ្វី ហើយកើតជាអ្វីហ្ន៎

ដូច្នេះ យ៉ាងណា សូម្បីការសង្ស័យប្រារព្ធចំណែកខាងចុង ៥ ប្រការដែលពោលទុកថា

ក្នុងអនាគតកាល អញនឹងមាននឹងកើតឬហ្ន៎

ក្នុងអនាគតកាល អញនឹងមិនមានមិនកើតឬហ្ន៎

ក្នុងអនាគតកាល អញនឹងកើតជាអ្វីហ្ន៎

ក្នុងអនាគតកាល អញនឹងកើតដូចម្តេចហ្ន៎

ក្នុងអនាគតកាល អញនឹងកើតជាអ្វី ហើយកើតជាអ្វីហ្ន៎

ដូច្នេះ យ៉ាងណា សូម្បីការសង្ស័យប្រារព្ធបច្ចុប្បន្ន ៦ ប្រការដែលពោលក្នុងបាលីថា

ម្យ៉ាងទៀត ឬកាលបុគ្គលជាអ្នកមានសេចក្តីសង្ស័យក្នុងខ្លួនឯង ប្រារព្ធបច្ចុប្បន្នកាលឥឡូវនេះថា

អញមាន អញកើតឬហ្ន៎

អញមិនមាន អញមិនកើតឬហ្ន៎

អញកើតជាអ្វីហ្ន៎

អញកើតដូចម្ដេចហ្ន៎

សត្វនេះមកអំពីណាហ្ន៎

សត្វនោះ នឹងជាអ្នកទៅទីណាហ្ន៎ ។

ដូច្នេះ ការសង្ស័យទាំងឡាយនោះ លោករមែងលះបាន ។

## កំណត់បច្ច័យរបស់នាមរូបន័យទី ២

ភិក្ខុអង្គខ្លះទៀត ឃើញបច្ច័យរបស់នាម ២ ប្រការ ដោយជាសាធារណប្បច្ច័យ និងអសាធារណប្បច្ច័យ ឃើញបច្ច័យរបស់រូប ៤ ប្រការ ដោយជាកម្មប្បច្ច័យជាដើម ។ ពិតហើយ បច្ច័យរបស់នាមមាន ២ ប្រការ គឺសាធារណៈ និងអសាធារណៈ ក្នុងបច្ច័យ ២ នោះ ទ្វារ ៦ មានចក្ខុជាដើម អារម្មណ៍ ៦ មានរូបជាដើម ជាសាធារណប្បច្ច័យរបស់នាម ធម៌មានមនសិការជាដើមដែលប្រព្រឹត្តទៅ (ត) អំពីចក្ខុ និងរូបជាដើមនោះ ជាអសាធារណប្បច្ច័យរបស់នាមគ្រប់ប្រការ ដោយប្រភេទ មាននាមដែលជាកុសលជាដើម ។ ពិតហើយ ធម៌មានយោនិសោមនសិការ និងសទ្ធម្មស្សវនៈជាដើមជារបស់នាមដែលជាកុសលតែម្យ៉ាង ធម៌ដែលផ្ទុយគ្នាក៏ជាបច្ច័យរបស់នាមដែលជាអកុសល ធម៌ មានកម្មជាដើម ជាបច្ច័យរបស់នាមដែលជាវិបាក ធម៌មានភវង្គជាដើមជាបច្ច័យរបស់នាម ដែលជាកិរិយា ដូច្នេះ ចំណែកធម៌ ៤ ប្រការ មានកម្មជាដើមនេះ គឺកម្ម ចិត្ត ឧតុ អាហារ ជាបច្ច័យរបស់រូបក្នុងធម៌ ៤ ប្រការនោះ កម្មដែលជាអតីតប៉ុណ្ណោះជាបច្ច័យរបស់រូប ដែលជាកម្មសមុដ្ឋាន ចិត្តដែលកើតឡើងជាបច្ច័យរបស់រូប ដែលជាចិត្តសមុដ្ឋាន ឧតុ និងអាហារជាបច្ច័យរបស់រូប ដែលជាឧតុសមុដ្ឋាន និងអាហារសមុដ្ឋាន ក្នុងឋិតិក្ខណៈ ដូច្នេះ ។

ភិក្ខុអង្គខ្លះ ធ្វើការកំណត់បច្ច័យរបស់នាមរូប ដោយន័យដូចពោលមកដូច្នេះ ភិក្ខុនោះកាលឃើញការប្រព្រឹត្តទៅនៃនាមរូបដោយបច្ច័យយ៉ាងនេះហើយ រមែងសន្និដ្ឋាន

ឃើញថា នាមរូបនេះប្រព្រឹត្តទៅដោយបច្ច័យក្នុងកាលឥឡូវនេះ យ៉ាងណា សូម្បីក្នុងអតីតកាល ក៏ប្រព្រឹត្តទៅហើយដោយបច្ច័យ ក្នុងអនាគតកាលសោត ក៏ប្រព្រឹត្តទៅដោយបច្ច័យ ដូច្នោះ ។ ការសង្ស័យក្នុងកាលទាំង ៣ លោកសង្កេតឃើញយ៉ាងនោះ ក៏លះបានដោយន័យដែលពោលហើយនោះឯង ។

## កំណត់បច្ច័យរបស់នាមរូបន័យទី ៣

ភិក្ខុអង្គខ្លះ ឃើញការដល់នូវជរានៃសង្ខារទាំងឡាយ ដែលបានដល់នាមរូបទាំងនោះៗ ឯង និងការបែកធ្លាយទៅនៃសង្ខារទាំងឡាយដែលជរាហើយ ធ្វើការកំណត់បច្ច័យរបស់នាមរូប តាមបែបបដិច្ចសមុប្បាទ ដោយបដិលោមយ៉ាងនេះថា ជរា និងមរណៈនៃសង្ខារទាំងឡាយនេះ កាលជាតិមាន ទើបមាន, ជាតិ កាលភពមាន ទើបមាន, ភព កាលឧបាទានមាន ទើបមាន, ឧបាទាន កាលតណ្ហាមាន ទើបមាន, តណ្ហា កាលវេទនាមាន ទើបមាន, វេទនា កាលផស្សៈមាន ទើបមាន, ផស្សៈ កាលសឡាយតនៈមាន ទើបមាន, សឡាយតនៈ កាលនាមរូបមាន ទើបមាន, នាមរូប កាលវិញ្ញាណមាន ទើបមាន, វិញ្ញាណ កាលសង្ខារទាំងឡាយមាន ទើបមាន, សង្ខារទាំងឡាយ កាលអវិជ្ជាមាន ទើបមាន ដូច្នេះហើយ ការសង្ស័យរបស់លោក ក៏លះបានដោយន័យដែលពោលហើយនោះឯង ។

## កំណត់បច្ច័យរបស់នាមរូបន័យទី ៤

ភិក្ខុអង្គខ្លះ កំណត់បច្ច័យរបស់នាមរូបតាមបែបបដិច្ចសមុប្បាទ ដោយអនុលោម ដែលបានសម្តែងឲ្យពិស្តារមកហើយខាងដើមថា ដូច្នេះឯង សង្ខារទាំងឡាយ មានព្រោះបច្ច័យ គឺអវិជ្ជា ដូច្នេះជាដើម ហើយការសង្ស័យក៏នឹងលះបានដោយន័យ ដែលពោលហើយដូចគ្នា ។

## កំណត់បច្ច័យរបស់នាមរូបន័យទី ៥

ភិក្ខុអង្គខ្លះ ធ្វើការកំណត់បច្ច័យរបស់នាមរូបតាមគន្លងកម្មវដ្ដ: និងវិបាកវដ្ដ: យ៉ាងនេះថា ធម៌ ៥ ប្រការ គឺការវង្វេងក្នុងបុរិមកម្មភព ជាអវិជ្ជា ចេតនាដែលប្រមូលទុកក្នុងបុរិមកម្មភព ជាសង្ខារ ការប្រាថ្នាក្នុងបុរិមកម្មភព ជាតណ្ហា ការជាប់ជំពាក់ក្នុងបុរិមកម្មភព ជាឧបាទាន ចេតនាក្នុងបុរិមកម្មភព ជាភព កាលបុរិមកម្មភពមាន រមែងជាបច្ច័យនៃបដិសន្ធិក្នុង ( ឧបបត្តិ ) ភពនេះ ។

ធម៌ ៥ ប្រការ គឺបដិសន្ធិក្នុង ( ឧបបត្តិ ) ភពនេះ ជាវិញ្ញាណ ការឈានចុះ ( ក្នុងគភ៌ ) ក្នុង ( ឧបបត្តិ ) ភពនេះ ជានាមរូប បសាទក្នុង ( ឧបបត្តិ ) ភពនេះ ជាអាយតន: ការ:ដែលប៉ះខ្ទប់ ( អារម្មណ៍ ) ក្នុង ( ឧបបត្តិ ) ភពនេះ ជាផស្ស: ការសោយក្នុង ( ឧបបត្តិ ) ភពនេះ ជាវេទនា កាលឧបបត្តិភពនេះមាន រមែងជាបច្ច័យ ( គឺជាទីអាស្រ័យប្រព្រឹត្តទៅ ) នៃកម្មដែលធ្វើទុកក្នុងកាលមុន ព្រោះអាយតន: ទាំងឡាយចាស់ទុំហើយ ធម៌ ៥ ប្រការនេះ គឺការវង្វេងក្នុងកម្មភពនេះ ជាអវិជ្ជា ។បេ។ ចេតនាក្នុងកម្មភពនេះ ជាភព កាលកម្មភពមាន រមែងជាបច្ច័យ នៃបដិសន្ធិក្នុងភពតទៅ ។

## កម្មវិភាគ

## កម្មឲ្យផលតាមកាល ៤ យ៉ាង

ក្នុងកម្ម និងវិបាកនោះ កម្មមាន ៤ យ៉ាង គឺ **ទិដ្ឋធម្មវេទនីយកម្ម ឧបបជ្ជវេទនីយកម្ម អបរាបរិយវេទនីយកម្ម អហោសិកម្ម** ។ ក្នុងកម្ម ៤ នោះ ជវនចេតនាជួនដំបូងជាកុសល ឬអកុសលក៏ដោយ ក្នុងចិត្ត ៧ ជួន ក្នុងជវនវិថីមួយ ឈ្មោះថា **ទិដ្ឋធម្មវេទនីយកម្ម** ទិដ្ឋធម្មវេទនីយកម្មនោះ រមែងឲ្យវិបាកក្នុងអត្តភាពនេះប៉ុណ្ណោះ

តែបើមិនអាច ( ឲ្យវិបាក ) យ៉ាងនោះ ក៏បានឈ្មោះ ( គឺក្លាយជា ) អហោសិកម្ម ។

អហោសិកម្មរមែងកើតដោយអំណាចតិកៈ ( គឺមិនមានផលទាំង ៣ កាល ដូចក្នុងបាលី ) នេះថា **វិបាករបស់កម្មមិនមានហើយ វិបាករបស់កម្មនឹងមិនមាន វិបាករបស់កម្មកំពុងមិនមាន** ។

ចំណែកជវនចេតនាដួងទី ៧ ដែលញ៉ាំងផលឲ្យសម្រេច បានឈ្មោះថា **ឧបបជ្ជវេទនីយកម្ម** ឧបបជ្ជវេទនីយកម្មនោះ រមែងឲ្យវិបាកក្នុងអត្តភាពបន្ទាប់ទៅ កាលមិនអាច ( ឲ្យវិបាក ) យ៉ាងនោះ ក៏បានឈ្មោះថា **អហោសិកម្ម** ។

ជវនចេតនា ៥ ដួង ក្នុងចន្លោះជវនចេតនា ២ ដួងនោះ ឈ្មោះថា **អបរាបរិយវេទនីយកម្ម** អបរាបរិយវេទនីយកម្មនោះបានឱកាសកាលណា រមែងឲ្យវិបាក កាលនោះក្នុងអនាគត កាលការប្រព្រឹត្តទៅនៃសង្សារនៅមាន អបរាបរិយវេទនីយកម្មនោះ រមែងមិនបានឈ្មោះ **អហោសិកម្ម** ឡើយ ។

## កម្មឲ្យផលតាមលំដាប់ ៤ យ៉ាង

កម្ម ៤ យ៉ាងទៀត គឺកម្មដែលជា **គរុកកម្ម ពហុលកកម្ម អាសន្នកម្ម កដត្តាវាបនកម្ម** ។ កម្ម ៤ នោះ កម្មជាកុសល ឬជាអកុសលក៏ដោយ ក្នុងកម្មធ្ងន់ និងមិនធ្ងន់ កម្មណាធ្ងន់ គឺជា ( អនន្តរិយ ) កម្ម មានមាតុឃាតជាដើមក្តី ជាមហគ្គតកម្មក្តី កម្មដែលធ្ងន់នោះឯង រមែងឲ្យផលមុន ។

សូម្បីក្នុងកម្មច្រើន និងមិនច្រើនក៏យ៉ាងនោះ កម្មណាច្រើន ( គឺធ្វើច្រើន ) ជា ( កុសល ) ដូចជាការមានសីលបរិសុទ្ធ ឬជា ( អកុសល ) ដូចជា ការទ្រុស្តសីល ក៏ដោយ កម្មច្រើននោះឯង រមែងឲ្យផលមុន ។

កម្មដែលបុគ្គលរឭកបានក្នុងវេលាជិតស្លាប់ ឈ្មោះថា **អាសន្នកម្ម** ដែលបុគ្គលជិតស្លាប់ អាចរឭកដល់កម្មឯណាបាន បុគ្គលនោះរមែងកើតដោយកម្មនោះឯង ។

ចំណែកកម្មក្រៅអំពីកម្ម ៣ យ៉ាងនោះ ដែលបានអាសេវនៈរឿយៗ ឈ្មោះថា កដត្តាវាបនកម្ម ក្នុងកាលកម្ម ៣ យ៉ាងនោះមិនមាន វាក៏ទាញទៅកាន់បដិសន្ធិបាន ។

## កម្មឱ្យផលតាមកិច្ច ៤ យ៉ាង

វិភាគកម្ម ៤ យ៉ាង មួយ៉ាងទៀត គឺ **ជនកកម្ម ឧបត្ថម្ភកកម្ម ឧបបីឡកកម្ម ឧបឃាតកកម្ម** ។ ក្នុងកម្ម ៤ យ៉ាងនោះ កម្មដែលឈ្មោះ **ជនកកម្ម** កើតបានទាំងកុសល ទាំងអកុសល ជនកកម្មនោះ រមែងញ៉ាំងវិបាកក្ខន្ធ ទាំងជាកាមាវចរ រូបាវចរ អរូបាវចរឲ្យកើត ទាំងក្នុងបដិសន្ធិកាល ទាំងក្នុងបវត្តិកាល ។ ចំណែកឧបត្ថម្ភកកម្ម មិនអាចញ៉ាំងវិបាកឲ្យកើត កាលបដិសន្ធិដែលកម្មដទៃឲ្យហើយ រមែងចូលទៅឧបការៈសុខ ឬទុក្ខ ដែលកើតឡើងក្នុងវិបាក ( ខន្ធ ) ដែលកម្មដទៃឲ្យកើតហើយ ឲ្យប្រព្រឹត្តទៅយូរ ។ ឧបបីឡកកម្ម កាលបដិសន្ធិដែលកម្មដទៃឲ្យហើយ រមែងបៀតបៀន រមែងរារាំងសុខ ឬទុក្ខដែលកើតឡើងក្នុងវិបាក ( ខន្ធ ) ដែលកម្មដទៃឲ្យកើតហើយ មិនឲ្យ ( សុខ ឬទុក្ខនោះ ) ប្រព្រឹត្តទៅយូរ ។ ចំណែកឧបឃាតកកម្ម ខ្លួនឯងជាកុសលក្តី ជាអកុសលក្តី រមែងកាត់ផ្តាច់កម្មដទៃដែលមានកម្លាំងតិច ហាមឃាត់វិបាករបស់កម្មដទៃនោះ ហើយបើកឱកាសឲ្យដល់វិបាករបស់ខ្លួន ឯកាលកម្មបើកឱកាសឲ្យយ៉ាងនោះ វិបាកនោះក៏ហៅបានថា កើតឡើងហើយ ។

ការផ្សេងគ្នានៃកម្ម និងការផ្សេងគ្នានៃវិបាករបស់កម្ម ១២ យ៉ាង ដូចពោលមកនេះរមែងប្រាកដដោយសភាពយ៉ាងពិតប្រាកដដល់កម្មវិបាកញ្ញាណរបស់ព្រះសម្ពុទ្ធទាំងឡាយប៉ុណ្ណោះ មិនសាធារណៈដល់សាវកទាំងឡាយ ទាំងសភាពផ្សេងៗ នៃកម្ម និងសភាពផ្សេងៗ នៃវិបាក វិបស្សកកិច្ចគប្បីដឹងបានដោយឯកទេស ព្រោះហេតុនោះ ការវិចិត្រផ្សេងៗ នៃកម្មនេះ ដែលរាប់ថា ជាការបានប្រកាសហើយ ដោយការសម្តែងកម្មត្រឹមតែជាមុខ ដោយប្រការដូច្នេះ ។

ភិក្ខុអង្គនុ៎ះ ធ្វើការកំណត់បច្ច័យរបស់នាមរូប តាមគន្លងកម្មវដ្ដៈ និងវិបាកវដ្ដៈ យ៉ាងនេះ ដោយពួកកម្ម ១២ យ៉ាងចូលក្នុងកម្មវដ្ដៈ ដោយប្រការដូច្នេះ ។

ភិក្ខុនោះ ឃើញការប្រព្រឹត្តទៅនៃនាមរូប ដោយបច្ច័យតាមកម្មវដ្ដៈ និងវិបាកវដ្ដៈ ដូចពោលមកនេះហើយ រមែងពិចារណាឃើញថា នាមរូបនេះប្រព្រឹត្តទៅដោយបច្ច័យតាមអំណាចកម្មវដ្ដៈ និងវិបាកវដ្ដៈ ក្នុងកាលឥឡូវនេះ យ៉ាងណា សូម្បីក្នុងអតីតកាល ក៏ប្រព្រឹត្តទៅដោយបច្ច័យតាមអំណាចកម្មវដ្ដៈ និងវិបាកវដ្ដៈមកហើយ ក្នុងកាលអនាគតសោត ក៏នឹងប្រព្រឹត្តទៅដោយបច្ច័យតាមអំណាចកម្មវដ្ដៈ និងវិបាកវដ្ដៈ ដូច្នោះដូចគ្នា ។ កម្ម និងវិបាករបស់កម្មក្ដី កម្មវដ្ដៈ និងវិបាកវដ្ដៈក្ដី កម្មប្បវត្តិ និងវិបាកប្បវត្តិក្ដី កម្មសន្តតិ និងវិបាកសន្តតិក្ដី កិរិយា និងផលនៃកិរិយាក្ដី រមែងប្រព្រឹត្តទៅដោយន័យ ដូច្នេះ ។

**វិបាកទាំងឡាយ រមែងប្រព្រឹត្តទៅព្រោះកម្ម វិបាក មានកម្មជាដែនកើត ភពថ្មី រមែងមានព្រោះកម្ម លោករមែងវិលទៅ ដូច្នេះ ។**

កាលលោកពិចារណាឃើញយ៉ាងនេះ សេចក្ដីសង្ស័យប្រារព្ធចំណែកខាងដើមដែលពោលដោយន័យថា **(ក្នុងអតីតកាល) យើងបានមាន បានកើតមកហើយ ឬហ្ន៎** ជាដើមនោះ ការសង្ស័យទាំងឡាយនោះ លោករមែងលះបង់បានប្រាកដនៅតែនាមរូបដែលប្រព្រឹត្តទៅក្នុងកំណើត គតិ ឋិតិ និងនិវាសទាំងពួង ដោយអំណាចការបន្តគ្នានៃហេតុ និងផលប៉ុណ្ណោះ លោកមិនឃើញអ្នកសាងក្រៅអំពីហេតុ មិនឃើញអ្នកសោយផលក្រៅអំពីការប្រព្រឹត្តទៅនៃវិបាកឡើយ លោកឃើញយ៉ាងល្អដោយបញ្ញាដ៏ប្រពៃថា **កាលហេតុមាន បណ្ឌិតទាំងឡាយ ក៏ពោលដោយពាក្យសន្មតថា អ្នកសាង កាលការប្រព្រឹត្តទៅនៃវិបាកមាន បណ្ឌិតទាំងឡាយ ក៏ពោលដោយត្រឹមតែពាក្យសន្មតថា អ្នកសោយប៉ុណ្ណោះឯង** ព្រោះហេតុនោះ ទើបបុរាណាចារ្យទាំងឡាយពោលទុកថា

អ្នកសាងកម្មមិនមាន អ្នកសោយផលក៏មិនមាន ( ត្រឹមតែ ) ធម៌សុទ្ធៗ រមែងប្រព្រឹត្តទៅ ការឃើញដូច្នេះ ជាការឃើញប្រពៃ ។

កាលកម្ម និងវិបាក ព្រមទាំងហេតុប្រព្រឹត្តទៅយ៉ាងនោះ ខាងដើម ខាងចុង មិនមានបុគ្គលណាដឹងបាន ដូចខាងដើមនៃពូជ និងដើមឈើជាដើម ដែលមិនមានបុគ្គលណាម្នាក់ ដឹងបាន ( ថា ពូជកើតមុនដើម ឬដើមកើតមុនពូជ ) ដូច្នោះ សូម្បីក្នុងអនាគតកាល កាលសង្សារនៅមាន ការមិនប្រព្រឹត្តទៅ ( នៃកម្ម និងវិបាក ) ក៏មិនទាន់មើលឃើញ ។

ពួកតិរ្ថិយ មិនដឹងសេចក្តីនេះ ទើបមិនជា សយំវសី ( គឺមិនមានអំណាចក្នុងខ្លួន តែធ្លាក់នៅក្នុងអំណាចការប្រកាន់ខុស ) ស្រវាយកសត្តសញ្ញា ហើយក៏មានការយល់ឃើញថា ទៀងខ្លះ ថា ដាច់សូន្យខ្លះ ប្រកាន់ទិដ្ឋិ ៦២ ជំទាស់គ្នានឹងគ្នា តិរ្ថិយទាំងឡាយត្រូវគ្រឿងចង គឺទិដ្ឋិចងទុក អណ្តែតត្រសែតទៅ តាមក្រសែទឹក គឺតណ្ហា តិរ្ថិយទាំងឡាយអណ្តែតទៅតាមក្រសែទឹក ទើបមិនផុតអំពីទុក្ខទៅបាន ។

ភិក្ខុដែលជាពុទ្ធសាវក ដឹងដោយបញ្ញាដ៏ក្រៃលែង ដោយសេចក្តីដូចពោលមកដូច្នេះហើយ ទើបចាក់ធ្លុះបច្ច័យ ( របស់នាមរូប ) ដ៏ជ្រាលជ្រៅ ល្អិត និងសោះសូន្យ ទទេបាន ។

កម្មមិនមាននៅក្នុងវិបាក វិបាកសោត ក៏មិនមាននៅក្នុងកម្ម ទាំង ២ សូន្យចាកគ្នានឹងគ្នា តែវៀរកម្មចេញ ផលក៏មិនមាន ប្រៀបដូចភ្លើងមិនមានក្នុងព្រះអាទិត្យ មិនមានក្នុងកែវ ( សូរ្យកាន្ត ) មិនមានក្នុងគោម័យ ( អាចម៍គោស្ងួត ប្រើជាភ្នក់ភ្លើង ) ខាងក្រៅអំពីវត្ថុទាំង ៣ នោះ ភ្លើងក៏មិនមាន តែភ្លើងកើតដោយសម្ភារៈទាំងឡាយ ( គឺវត្ថុ ៣ យ៉ាងនោះរួមគ្នា ) យ៉ាងណា វិបាករមែងមិនមានក្នុងកម្ម សូម្បីខាងក្រៅកម្មក៏មិនមាន កម្មសោត ក៏មិនមានក្នុងវិបាកនោះ កម្មនោះ ទទេចាកផល ផលក៏មិនមាន

ក្នុងកម្ម តែផលក៏អាស្រ័យកម្មនោះឯង កើតឡើង ដូច្នោះ ។

ពិតហើយ ក្នុងសង្សារប្បវត្តិនេះ អ្នកសាងសង្សារ នឹងជាទេវតា ឬព្រហ្មក្តី មិនមាន ( គ្រាន់តែ ) ជាធម៌សុទ្ធៗ រមែងប្រព្រឹត្តទៅ ព្រោះការរួមចូលគ្នានៃហេតុជាបច្ច័យ ដូច្នេះ ។

កាលភិក្ខុនោះ ធ្វើការកំណត់បច្ច័យនៃនាមរូបតាមគន្លងកម្មវដ្ដៈ និងវិបាកវដ្ដៈ រហូតលះសេចក្តីសង្ស័យក្នុងកាលទាំង ៣ យ៉ាងនេះហើយ ធម៌ដែលជាអតីត អនាគត និងបច្ចុប្បន្នទាំងឡាយ លោកក៏រមែងដឹងបានដោយអំណាចចុតិ និងបដិសន្ធិ ការដឹងរបស់លោកនោះ ជាញាតបរិញ្ញា ។

គឺលោកដឹងយ៉ាងនេះថា ខន្ធទាំងឡាយណា មានកម្មជាបច្ច័យ កើតហើយក្នុងអតីត ខន្ធទាំងនោះក៏រលត់ទៅហើយ ក្នុងអតីតនោះឯង ចំណែកខន្ធទាំងឡាយដទៃមានអតីតកម្មជាបច្ច័យកើតឡើងក្នុងភពនេះ ធម៌ ( អ្វីត្រឹមតែ ) វត្ថុមួយ ដែលមកកាន់ភពនេះអំពីអតីតភពមិនមាន សូម្បីខន្ធទាំងឡាយដែលកើត ព្រោះកម្មប្បច្ច័យក្នុងភពនេះសោតក៏នឹងរលត់ខន្ធទាំងឡាយដទៃ នឹងកើតក្នុងភពថ្មី (តទៅ) សូម្បីធម៌ (អ្វីត្រឹមតែ) វត្ថុមួយ ក៏នឹងមិនទៅកាន់ភពថ្មីអំពីភពនេះ តែប្រៀបដូចការស្វាធ្យាយអំពីមាត់របស់អាចារ្យ រមែងមិនចូលទៅកាន់មាត់របស់អន្តេវាសិក តែការស្វាធ្យាយក្នុងមាត់របស់អន្តេវាសិកនឹងប្រព្រឹត្តទៅមិនបាន ព្រោះការស្វាធ្យាយអំពីមាត់របស់អាចារ្យមិនមាន យ៉ាងណា ទឹកមន្ត ( របស់គ្រូពិសេស ) ដែលអ្នកជំនួសខ្លួនផឹក រមែងមិនចូលទៅកាន់ពោះរបស់អ្នកមានរោគ តែរោគរបស់អ្នកឈឺមិនជា ព្រោះការផឹកទឹកមន្តរបស់អ្នកជំនួសខ្លួននោះជាបច្ច័យក៏ទេ យ៉ាងណា ពិធីតុបតែងត្រង់មុខ រមែងមិនទៅកាន់ស្រមោលមុខក្នុងគ្រឿងឆ្លុះមុខទាំងឡាយ មានកញ្ចក់ជាដើម តែវិធីតុបតែងនឹងមិនប្រាកដក្នុងគ្រឿងឆ្លុះមុខទាំងនោះ ព្រោះវិធីតុបតែងនោះជាបច្ច័យក៏ទេ យ៉ាងណា អណ្តាត

ប្រទីបរបស់ប្រទេះឯណាមួយ រមែងមិនចូលទៅប្រទេះដទៃ តែអណ្ដាតប្រទីបនឹងមិនកើតក្នុងប្រទេះដទៃនោះ ព្រោះអណ្ដាតប្រទីបរបស់ប្រទេះដើមនោះជាបច្ច័យក៏ទេ យ៉ាងណា ធម៌ត្រឹមតែវត្ថុ រមែងមិនចូលមកកាន់ភពនេះអំពីអតីតភព ឬមិនចូលទៅកាន់ភពថ្មីអំពីភពនេះ តែខន្ធ អាយតនៈ ធាតុ នឹងមិនកើតក្នុងភពនេះ ព្រោះខន្ធ អាយតនៈ ធាតុ ក្នុងអតីតភពជាបច្ច័យ ឬខន្ធ អាយតនៈ ធាតុ ក្នុងភពថ្មី នឹងមិនកើត ព្រោះខន្ធ អាយតនៈ ធាតុ ក្នុងភពនេះជាបច្ច័យក៏ទេ ដូច្នោះដូចគ្នា ។

# គាថាសរុបរឿងចុតិបដិសន្ធិចិត្ត

ចក្ខុវិញ្ញាណមានក្នុងលំដាប់នៃមនោធាតុ តែចក្ខុវិញ្ញាណមិនបានមកអំពីមនោធាតុ ចក្ខុវិញ្ញាណមិនកើតក្នុងលំដាប់នៃមនោធាតុក៏ទេ យ៉ាងណា សន្តតិនៃចិត្ត រមែងប្រព្រឹត្តទៅក្នុងបដិសន្ធិដូច្នោះដូចគ្នា ចិត្តដួងមុន ( គឺចុតិចិត្ត ) បែកធ្លាយ ចិត្តដួងក្រោយ ( គឺបដិសន្ធិចិត្ត ) ក៏កើត ( ក្នុងលំដាប់ ) តអំពីនោះ វត្ថុរាំងរបស់ចិត្តទាំងពីរនោះមិនមាន ការរំកិលទៅមិនមានដល់ចិត្តទាំងពីរនោះ ចិត្តណាមួយ មិនបានទៅអំពីចុតិចិត្តនេះ តែបដិសន្ធិចិត្តក៏កើតបាន ( តាមបច្ច័យ ) ដូច្នេះ ។

ញាណដែលកំណត់បច្ច័យរបស់នាមរូប នៃយោគាវចរភិក្ខុដែលដឹងធម៌ទាំងឡាយ ដោយអំណាចចុតិ និងបដិសន្ធិយ៉ាងនេះ រមែងជាញាណដល់នូវការមានកម្លាំងដោយអាការទាំងឡាយ សេចក្ដីសង្ស័យ ១៦ ប្រការ លោកក៏បានលះយ៉ាងល្អក្រៃលែង មិនមែនតែសេចក្ដីសង្ស័យ ១៦ ប្រការនោះប៉ុណ្ណោះទេ សូម្បីសេចក្ដីសង្ស័យ ៨ ប្រការដែលប្រព្រឹត្តទៅដោយន័យថា ភិក្ខុរមែងសង្ស័យក្នុងព្រះសាស្ដា ដូច្នេះជាដើម ក៏លះបានហើយដូចគ្នា ទិដ្ឋិ ៦២ យ៉ាង រមែងស្ងប់រម្ងាប់ទៅ ។

ញាណដែលឆ្លងសេចក្ដីសង្ស័យក្នុងអទ្ធា ៣ បាន ដោយការកំណត់បច្ច័យរបស់

នាមរូបដោយន័យផ្សេងៗ ដូចពោលមកនេះហើយ តាំងនៅ គប្បីជ្រាបថា ឈ្មោះ **កង្ខាវិតរណវិសុទ្ធិ** ។ ពាក្យថា **ធម្មដ្ឋិតិញ្ញាណន្តិ** ពាក្យថា **យថាភូតញ្ញាណន្តិ** ពាក្យថា **សម្មាទស្សនន្តិ** ជាវេវចនៈរបស់ពាក្យថា **កង្ខាវិតរណវិសុទ្ធិ** នោះឯង ។ពិតហើយ ពាក្យនេះព្រះសារីបុត្រក៏បានពោលទុកថា អវិជ្ជាជាបច្ច័យ សង្ខារជាបច្ចយសមុប្បន្ន ធម៌ទាំង ២ នោះ ជាបច្ចយសមុប្បន្ន ( ដូចគ្នា ព្រោះអវិជ្ជាក៏មានបច្ច័យដូចគ្នា ) បញ្ញាក្នុងការកំណត់បច្ច័យដោយន័យដូច្នេះជាដើម ឈ្មោះថា **ធម្មដ្ឋិតិញ្ញាណ** ។

សួរថា ភិក្ខុធ្វើមនសិការទៅដោយការមិនទៀង រមែងដឹង រមែងឃើញតាមសេចក្តីពិតនូវធម៌ពួកណា សម្មាទស្សនៈ រមែងមានដូចម្តេច សង្ខារទាំងឡាយ រមែងត្រូវភិក្ខុនោះឃើញយ៉ាងល្អដោយការមិនទៀង ទៅតាមគន្លងការដឹងតាមសេចក្តីពិតនោះយ៉ាងណា សេចក្តីសង្ស័យ រមែងលះបានក្នុងទីណា ភិក្ខុធ្វើមនសិការទៅដោយភាពជាទុក្ខ... ដោយភាពជាអនត្តា រមែងដឹង រមែងឃើញតាមសេចក្តីពិតនូវធម៌ទាំងឡាយណា ។បេ។ សេចក្តីសង្ស័យលោករមែងលះបាន ក្នុងទីណា ?

ឆ្លើយថា ភិក្ខុធ្វើមនសិការទៅដោយការមិនទៀង រមែងដឹង រមែងឃើញនូវនិមិត្ត ( គឺសង្ខារ ) តាមសេចក្តីពិត ព្រោះការដឹង-ឃើញតាមសេចក្តីពិតនោះ ទើបហៅសម្មាទស្សនៈ សង្ខារទាំងឡាយ រមែងត្រូវភិក្ខុឃើញយ៉ាងល្អដោយភាពមិនទៀងទៅតាមគន្លងការដឹង-ឃើញតាមសេចក្តីពិតនោះ យ៉ាងនេះ ការសង្ស័យលោករមែងលះបានក្នុងទីនេះ ( គឺក្នុងធម៌តាមដែលឃើញ ) ភិក្ខុធ្វើមនសិការទៅដោយភាពជាទុក្ខ រមែងដឹង រមែងឃើញតាមសេចក្តីពិតនូវបវត្ត ( ការប្រព្រឹត្តទៅនៃសង្ខារ ) តាមសេចក្តីពិត...ភិក្ខុធ្វើមនសិការទៅដោយភាពជាអនត្តា រមែងដឹង រមែងឃើញទាំងនិមិត្ត ទាំងបវត្តតាមសេចក្តីពិត ព្រោះការដឹង-ឃើញតាមសេចក្តីពិតនោះ ទើបហៅថា **សម្មាទស្សនៈ** ធម៌ទាំងឡាយត្រូវភិក្ខុនោះឃើញយ៉ាងល្អ ដោយភាពជាអនត្តាទៅតាមគន្លងការដឹង

តាមសេចក្តីពិតនោះយ៉ាងនេះ សេចក្តីសង្ស័យលោកលះបានក្នុងទីនេះ ( គឺក្នុងធម៌តាមដែលដឹង ដែលឃើញ )។

សួរថា យថាភូតញ្ញាណឯណាក្តី សម្មាទស្សនៈឯណាក្តី កង្ខាវិតរណៈឯណាក្តី ធម៌ទាំងនេះមានអត្ថផ្សេងគ្នា មានព្យញ្ជនៈផ្សេងគ្នា ឬមានអត្ថដូចគ្នាផ្សេងគ្នាតែព្យញ្ជនៈ ? ឆ្លើយថា យថាភូតញ្ញាណឯណាក្តី សម្មាទស្សនៈឯណាក្តី កង្ខាវិតរណៈឯណាក្តី ធម៌ទាំងនេះ មានអត្ថដូចគ្នាផ្សេងគ្នាតែព្យញ្ជនៈប៉ុណ្ណោះ ដូច្នេះ ។

ឯវិបស្សកភិក្ខុដែលប្រកបដោយញាណនេះហើយ រាប់ថា ជាអ្នកបាននូវការកក់ក្តៅបានទីពឹងក្នុងព្រះពុទ្ធសាសនា មានគតិទៀងទាត់ បានឈ្មោះថា ចូឡសោតាបន្ន ។

ព្រោះហេតុនោះ ភិក្ខុដែលមានសេចក្តីត្រូវការដោយកង្ខាវិតរណវិសុទ្ធិ គប្បីជាបុគ្គលមានសតិកំណត់បច្ច័យទាំងឡាយនៃនាមរូប ដោយប្រការទាំងឡាយគ្រប់កាលហោង ។

បរិច្ឆេទទី ១៩ ឈ្មោះ កង្ខាវិតរណវិសុទ្ធិនិទ្ទេស

ក្នុងអធិការនៃបញ្ញាភាវនា

ក្នុងបករណ៍វិសុទ្ធិមគ្គ

ដែលខ្ញុំធ្វើដើម្បីប្រយោជន៍ដល់បាមោជ្ជនៃសាធុជន

ដូច្នេះ ។

# មហាដីកា

## ពណ៌នាកថ្ងាវិតរណវិសុទ្ធិនិទ្ទេស
## កថាពណ៌នាដោយការកំណត់បច្ច័យ

*លោកអាចារ្យពោលថា* **នាមរូបនោះឯង** *ដូច្នេះ ព្រោះទិដ្ឋិវិសុទ្ធិដែលបាន សម្តែងលម្អិតទុកជាលំដាប់ លោកបានសម្តែងហើយ ដោយភាពជាវិស័យ មិនមែន ព្រោះមិនមាន ធម៌ដទៃក្រៅអំពីនាមរូបនោះឯង ដើម្បីនឹងធ្វើឲ្យផ្សេងអំពីធម៌ដទៃក្រៅ អំពីនាមរូបនោះ ។ ព្រោះថា ការប្រាថ្នាវិបស្សនាខាងក្នុង ឬខាងក្រៅ ចូរលើកទុក តែនាមរូបទាំងអស់ រមែងត្រូវព្រះយោគាវចរកំណត់ហើយ ដោយមិនមានសេសសល់ នោះឯង ដោយលក្ខណៈក្នុងការសម្រេចខាងក្នុង ។*

*បទថា* **បច្ចយបរិគ្គហណេន** *ជាតតិយាវិភត្តិ ចុះក្នុងហេតុ ។ សេចក្តីថា មាន ការឆ្លងសេចក្តីសង្ស័យក្នុងកាលទាំង ៣ រមែងមានដល់យោគាវចរនោះ ព្រោះមានការ កំណត់បច្ច័យជាហេតុ ។ម្យ៉ាងទៀត បទថា* **បច្ចយបរិគ្គហណេន** *នេះ ជាតតិយាវិភត្តិ ចុះក្នុងករណៈ ព្រោះកិរិយា គឺការឆ្លងសេចក្តីសង្ស័យ ក៏ដោយការៈដែលញ៉ាំងការកំណត់ បច្ច័យឲ្យសម្រេចជាទីបំផុត ។ ក្នុងកាលណាការកំណត់បច្ច័យបរិសុទ្ធល្អ មិនមានអ្វី ប្រឡាក់ប្រឡូស មិនទុព្វល រមែងសម្រេចដល់ព្រះយោគីនោះ កាលនោះ យោគីនោះ រមែងកន្លងសេចក្តីសង្ស័យបាន ដូច្នេះ ។ ពាក្យថា* **ឆ្លង** *បានដល់ ឈានកន្លងសេចក្តីថា សន្តិតសន្និទទុកបាន លោកអាចារ្យពោលថា* **ញាណតាំងនៅ** *ដូច្នេះ ព្រោះអធិប្បាយ ថា ញាណនោះ ដែលបានសម្រេចហើយយ៉ាងនោះ រមែងប្រព្រឹត្តទៅ ដោយអំណាច ការបន្តគ្នា ក្នុងសន្តានរបស់យោគី ដូចឈានដែលដល់នូវវសីភាវៈ ។*

ការឆ្លងសេចក្តីសង្ស័យនោះផង ជាភាពបរិសុទ្ធផង ហេតុនោះ ឈ្មោះថា **កង្ខាវិតរណវិសុទ្ធិ** ការឆ្លងសេចក្តីសង្ស័យដ៏បរិសុទ្ធ ។ ក្នុងសេចក្តីបាលីថា **តំ សម្បា-ទេតុកាមោ អាវជ្ជតិ** ប្រែថា ភិក្ខុប្រាថ្នានឹងញ៉ាំងកង្ខាវិតរណវិសុទ្ធិឲ្យដល់ព្រម រមែងរំពឹងដល់ ។ លោកអាចារ្យកាលសម្តែងសេចក្តីនេះថា នាមរូប ដែលព្រះយោគីឃើញហើយតាមសេចក្តីពិត រមែងប្រាកដដូចរោគ ព្រោះប្រកបដោយទុក្ខ ៣ យ៉ាង ចំណែកបច្ច័យទាំងឡាយរបស់នាមរូបនោះ រមែងប្រាកដដូចសមុដ្ឋាននៃរោគ ទើបពោលថា **ប្រៀបដូចបុគ្គលឈ្លាស ឃើញរោគហើយ រមែងរកសមុដ្ឋានរបស់រោគ** ដូច្នេះ ។ សត្តានដែលលិចចុះក្នុងសង្សារទុក្ខ រមែងបានការៈដែលគួរអាណិត ទាក់ទងជាមួយសេចក្តីត្រូវការ នឹងដោះចេញចាកសង្សារទុក្ខនោះ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **ឬឧបមាម្យ៉ាងទៀត ប្រៀបដូចជា** ដូច្នេះជាដើម ដើម្បីសម្តែងអត្ថនោះ ។ កាលតាំងសេចក្តីទុកយ៉ាងនេះនោះឯង អាចារ្យពួកមួយរមែងពោលពាក្យណាទុកថា **ការទន្ទឹងដល់មាតាបិតារបស់កុមារតូចនោះ ក៏ដោយសម្តែងដល់កុមារតូចគួរអាណិតមិនមែនជាឧទាហរណ៍ក្នុងទីនេះ ព្រោះការៈ គឺនាមរូបគួរអាណិត ដោយការៈដែលគប្បីឲ្យរលត់** ដូច្នេះ ពាក្យនោះ រមែងជាពាក្យដែលនាំមកហើយ ។ សេចក្តីនេះ គួរប្រាថ្នាយ៉ាងនេះពិតប្រាកដ កាលកាន់យកអត្ថដោយប្រការដទៃ គប្បីពិចារណាដល់ការប្រព្រឹត្តទៅ នៃព្រះមហាករុណារបស់ព្រះសាស្តា ក្នុងសន្តាននៃវេនេយ្យបុគ្គល ។ ឈ្មោះថា **ទន់ខ្ចី** ព្រោះជាបុគ្គលមានបញ្ញាតិច ។ សូម្បីបុគ្គលដែលធំជាងខ្លះ ក៏ជាបុគ្គលមានបញ្ញាតិច ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **កុមារ** ដើម្បីឲ្យផ្សេងអំពីបុគ្គលដែលធំជាងនោះ ។ បុគ្គលណានីមួយដែលនៅក្នុងបឋមវ័យ បុគ្គលនោះ ហៅថា **កុមារ** ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **តូចៗ** ដើម្បីឲ្យផ្សេងអំពីបុគ្គលដែលនៅក្នុងបឋមវ័យនោះ ។ សូម្បីយ៉ាងនោះ ក្មេងស្របាលគ្នារត់ទៅរត់មកក្បែរៗ

បុគ្គលណា សូម្បីក្មេងស្របាលនោះ ក៏ហៅថា **តូចៗ** ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **នៅដេកផ្ងារ** ដើម្បីបដិសេធចេញអំពីក្មេងស្របាលនោះ ។ ដោយបទទាំង ៤ លោកអាចារ្យរមែងសម្តែងភាពដែលក្មេងជាបុគ្គលគួរករុណា ។ បទថា **អាវជ្ជតិ** សេចក្តីថា រមែងធ្វើ ។

ភិក្ខុនោះ រមែងមានការត្រូវស្វែងរកហេតុប្បច្ច័យដោយប្រការណា ដើម្បីសម្តែងប្រការនោះ ទើបលោកអាចារ្យពោលពាក្យជាដើមថា **ភិក្ខុនោះ** ។ ក្នុងពាក្យនោះ អត្ថដែលបានធ្វើឲ្យយល់ទុក ដោយន័យដែលជាគន្លងព្យតិរេក គឺបដិសេធ ហើយស្របតាម រមែងជាអត្ថដែលធ្វើឲ្យយល់បានដោយត្រឹមត្រូវនោះឯង ព្រោះហេតុនោះ លោកអាចារ្យកាលបដិសេធនាមរូប ជាវត្ថុមិនមានហេតុ មុននឹងពោលថា **នាមរូបនេះ ខាងដើម នាមរូបនេះ ជាវត្ថុដែលមិនមានហេតុក៏ទេ** ហើយពោលហេតុក្នុងពាក្យនោះដោយពាក្យថា **គ្រប់កន្លែង** ដូច្នេះជាដើម ។ កាលធម៌ទាំងពួង មានដោយហេតុដទៃការមិនមាននៃហេតុក៏ដូចគ្នា ព្រោះហេតុនោះ ភាវៈដែលដូចគ្នានៃធម៌ទាំងឡាយ ក៏គប្បីមាន ម្យ៉ាងទៀត កាលបើដូច្នោះ ចក្ខុវិញ្ញាណជាដើម គប្បីមានគ្រប់កន្លែង ព្រោះការមិនមានហេតុនៃចក្ខុវិញ្ញាណជាដើម នៅក្នុងចំណែករបស់សោតៈជាដើម និងក្នុងស្ថានខាងក្រៅគប្បីមានគ្រប់កាល ព្រោះការមិនមានហេតុមុនចក្ខុជាដើមកើតឡើងនិងក្រោយអំពីរលត់ទៅ នឹងគប្បីមានគ្រប់អន្លើ ព្រោះការមិនមានហេតុដល់បុគ្គលខ្វាក់ជាដើមដល់អរូបព្រហ្ម និងដល់អសញ្ញីសត្តព្រហ្ម សេចក្តីនោះ ទើបឈ្មោះថា **មិនមានដោយពិសេស** ព្រោះការមិនមានហេតុ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **ព្រោះចក្ខុវិញ្ញាណដល់នូវភាពដូចគ្នា គ្រប់កន្លែង គ្រប់កាល និងគ្រប់អន្លើ** ដូច្នេះ ។ ប្រការដែលថា **ចក្ខុវិញ្ញាណជាដើម** នេះត្រឹមតែជាគំរូ ។ អធិប្បាយថា ក្នុងលោកមានការផ្សេងគ្នាទាំងឡាយប៉ុន្មាន ការផ្សេងទាំងនោះ ក៏គប្បីមានដល់គ្រប់អន្លើ និងសព្វ

កាលទាំងពួង ។ ម្យ៉ាងទៀត ដោយ **អាទិ-ស័ព្ទ** ការកាន់យកភាពផ្សេងទាំងនោះ បណ្ឌិតគប្បីឃើញថា បានដល់ អ្វីខ្លះនោះឯង ។ ព្រោះហេតុនោះ ការមិនមាននៃភាពដែលនាមរូបផ្សេងគ្នា ព្រោះការនាមរូបមិនមានហេតុនោះឯង ព្រោះហេតុនោះ បណ្ឌិតគប្បីជ្រាបការភ្ជាប់សេចក្តីតែមួយបទចូលគ្នាថា ព្រោះនាមរូបដល់នូវភាពដូចគ្នា គ្រប់កន្លែង ព្រោះនាមរូបដល់នូវភាពដូចគ្នា គ្រប់កាល ព្រោះនាមរូបដល់នូវភាពដូចគ្នា គ្រប់អន្ទើ ។ កាលភាពដែលនាមរូបជាវត្ថុដែលមិនមានហេតុយ៉ាងនេះ សម្រេចចំពោះហើយ ម្ចាស់លទ្ធិដែលឃើញថា មានហេតុមិនស្មើ គប្បីពោលថា **សួរថា នាមរូបនេះជាវត្ថុដែលមិនមានហេតុក៏ទេ នឹងមានហេតុអ្វីបានហ្ន៎ ហើយមានហេតុដោយហេតុអ្វី ? ឆ្លើយថា មានហេតុ ដោយហេតុ មានព្រះឥស្សរជាដើម** ។

ដោយ **អាទិ-ស័ព្ទ** គប្បីជ្រាបការកាន់យក **បទាវេ** ទាំងឡាយ មាន **បកតិ បុរស បជាបតី** និង **កាល** ជាដើម លោកអាចារ្យកាលបដិសេធសេចក្តីនោះ ទើបពោលពាក្យជាដើមថា **នាមរូបមានហេតុខាងក្រៅ មានព្រះឥស្សរជាដើម ក៏ទេ** ។ នាមរូប ឈ្មោះថា **មានហេតុខាងក្រៅ មានព្រះឥស្សរជាដើមក៏ទេ ព្រោះព្រះឥស្សរ និងបកតិជាដើមមិនមាន** ព្រោះថា សភាវៈដទៃក្រៅអំពីនាមរូបមិនមាន ។ បើនាមរូបកើតអំពីហេតុ មានព្រះឥស្សរជាដើម ដែលមិនមានសោត កាលបើយ៉ាងនេះ នឹងត្រូវមានភាពដូចគ្នាគ្រប់កន្លែង គ្រប់កាល គ្រប់អន្ទើនោះឯង ។ បើត្រឹមតែនាមរូបប៉ុណ្ណោះ មានខាងក្រៅ មានព្រះឥស្សរជាដើម ក៏នឹងប្រាកដនាមរូប ដែលមិនមានហើយ មានឡើង និងដែលមានហើយ ក៏វិនាសទៅ ព្រោះហេតុនោះ នឹងត្រូវមានហេតុខាងក្រៅ ដូច្នោះ មានព្រះឥស្សរជាដើម ។ ដោយប្រការនោះ នាមរូបនោះ ប្រកបដោយបច្ច័យជាសន្ធតៈនោះឯង ព្រោះហេតុនោះ ព្រះយោគាវចរគួរធ្វើការកំណត់បច្ច័យរបស់នាមរូបនោះ ។ បើនាមរូបនោះមិនកើតឡើង នាមរូបនោះត្រូវជាវត្ថុមិនមានហេតុ ។

ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា ព្រោះត្រូវជាវត្ថុ ដែលមិនមានហេតុទៅដូច្នេះ ។

ម្យ៉ាងទៀត នាមរូបមិនមានហេតុខាងក្រៅ មានព្រះឥស្សរជាដើមឡើយ ។ ព្រោះអ្វីជាហេតុ ? ព្រោះនាមរូបកើតឡើង ដោយលំដាប់ ។ បើគប្បីមានហេតុ ដែលមិនសម្លឹងដល់កម្ម កិលេស ឥន្ទ្រិយ និងអារម្មណ៍ជាដើម ដែលសន្មតថា ជាព្រះឥស្សរជាទីទៀងយ៉ាងនេះសោត វត្ថុគ្រប់យ៉ាងនោះឯង ក៏គប្បីមានការកើតឡើងព្រមគ្នា មានប៉ុនណា នាមរូបក៏គប្បីកើតឡើងអំពីវត្ថុនោះ ។ ព្រោះហេតុអ្វី ? ព្រោះហេតុរួមគ្នា ។ បើបុគ្គលទាំងឡាយ គប្បីកំណត់ការកើតឡើងនៃនាមរូបនោះ ដោយអំណាចការប្រាថ្នានៃរូបនោះ ក៏មានការជំទាស់អ្វីក្នុងការកើតឡើងរួមគ្នារបស់សេចក្តីប្រាថ្នាទាំងនោះ ។ បើមានអ្នកសួរថា បើមានវត្ថុណាៗ ដទៃ ដែលគប្បីសម្លឹងដល់កម្ម កិលេស ឥន្ទ្រិយ និងអារម្មណ៍ជាដើមសោត ? ឆ្លើយថា នុ៎ះឯង ជាតួហេតុ តួការលេះ នឹងមានប្រយោជន៍អ្វីជាមួយវត្ថុដទៃ ដែលមើលមិនឃើញសមត្ថភាព បានត្រឹមតែគិតស្មានយកទៅវិញ? ឯសមត្ថភាពនៃកម្មជាដើម ជារឿងឃើញបាន សូម្បីក្នុងការសង្គ្រោះបច្ច័យដទៃអំពីនោះ ព្រោះកាលវត្ថុនោះមិនមាន នាមរូបក៏មិនមាន ។ ឧបមាដូចជាក្នុងការដែលរូបពន្លឺ និងមនសិការរួមគ្នា កាលចក្ខុមិនមាន ក៏ឃើញការមិនមាននៃចក្ខុវិញ្ញាណ តែកាលចក្ខុមាន ក៏ឃើញការមានបាន ធ្វើឲ្យដឹងបានថា ចក្ខុ មានភាពជាធម្មជាតិ អាចធ្វើឲ្យចក្ខុវិញ្ញាណកើតឡើង សេចក្តីនេះយ៉ាងណា ។ និងនៅមានឧបមាមួយទៀត បុគ្គលជាកូនភ្លោះដូចគ្នា កាលភាពស្មើគ្នានៃបច្ច័យខាងក្រៅជាដើម មានពុកម៉ែ ទឹកសុក្កៈ និងលោហិត ក៏នៅប្រាកដភាពផ្សេងគ្នា មានភាពជាបុគ្គលថោកទាប និងជាបុគ្គលប្រណីតជាដើមនៃសត្វទាំងឡាយ ឯការផ្សេងគ្នានោះ មានកម្ម និងកិលេសជាហេតុ ព្រោះមិនមានហេតុដទៃ ដូច្នោះ ក្នុងសន្តានចំពោះខ្លួន ព្រោះហេតុនោះ ទើបធ្វើឲ្យយល់

ថា កម្ម និងកិលេសនោះ ជារឿងអាចក្នុងការផ្សេងគ្នានោះ សេក្តីនេះយ៉ាងណា ហេតុខាងក្រៅ មានព្រះឥសូរជាដើម ក៏ដូច្នោះ មិនមាន ។ ក្នុងការមាន និងមិនមាននៃហេតុ គប្បីធ្វើឲ្យយល់ភាពជាហេតុ ជារឿងមានការជាក់ច្បាស់ ដោយការមាន និងការមិនមាននៃផល ។ ឯនាមរូបដែលមិនមាន ដូច្នោះ ក្នុងការរួមគ្នា បុគ្គលណាម្នាក់ បានជួបការមិនកើតឡើងក្នុងទីណាមួយ ព្រោះការដាច់ទៅនៃហេតុខាងក្រៅ មានព្រះឥសូរជាដើម មិនមាន ព្រោះហេតុនោះ ទើបព្រះឥសូរមិនមែនជាធំ ។

បើស្ថានសួគ៌គប្បីពោលបានថា មានព្រះឥសូរជាដើម ជាហេតុយ៉ាងនេះសោតការដូចគ្នានៃស្ថានសួគ៌នោះ ក៏គប្បីកើតឡើងអំពីស្ថានសួគ៌នោះ អស់កាលទាំងពួង ។ ព្រោះការមិនកើតឡើងរបស់ផល ដែលមានហេតុរួមគ្នាត្រឹមត្រូវហើយ មិនមាន ។ ហើយនិច្ចភាវៈមានខាងដើមនៃស្ថានសួគ៌នោះឯង ព្រោះមិនសម្រឹងដល់យ៉ាងដទៃ ទើបមិនគួរ ព្រោះទាក់ទងនឹងការមានរបស់វត្ថុទាំងពួងសព្វកាល ដែលព្រះឥសូរជាដើមជាម្ចាស់ ។ បើបុគ្គលណា គប្បីពោលថា **មានបច្ច័យតាមសមគួរ សូម្បីពួកដទៃនោះឯង សូម្បីព្រះឥសូរជាដើម ក៏ជាម្ចាស់ធ្វើការរួមគ្នារបស់បច្ច័យទាំងនោះ** ។ ពាក្យណា ដែលគប្បីពោលក្នុងទីនេះ ពាក្យនោះ ខ្ញុំបានពោលហើយខាងដើមនោះឯង ។ បើអ្នកដទៃគប្បីពោលថា ក្នុងទីនេះ បានឃើញភាពផ្សេងគ្នានៃការរចនាភាវៈទាំងឡាយ ដែលមានពុទ្ធិជាខាងដើម ឧបមាដូចឆ្នាំង និងផ្ទះជាដើម ។ និងនៅមានភាពផ្សេងគ្នានៃការរចនាសរីរៈ និងផ្កាឈូកជាដើម ដែលជាវត្ថុខាងក្នុង និងខាងក្រៅ ព្រោះហេតុនោះ សូម្បីភាពផ្សេងនៃការរចនានោះ ក៏គប្បីមានពុទ្ធិជាខាងដើម ។ ឯភាវៈណា មានការផ្សេងគ្នានៃការរចនា មានពុទ្ធិជាខាងដើម ភាវៈនោះ មានព្រះឥសូរជាដើម ព្រោះហេតុនោះ ភាវៈនោះ នឹងត្រូវជាម្ចាស់របស់លោក ដែលមានឈ្មោះថា **នាមរូប** ។ សេចក្តីនេះ មិនសម្រេចវត្ថុជាតុ មានសរីរៈ និងផ្កាឈូកជាដើម ត្រូវបានរចនាមក

ហើយ ព្រោះជាវត្ថុដែលកើតហើយក្នុងទីនោះៗ ឯង ដោយប្រការ ដូច្នេះ ។ ឯការផ្តើមតែងតាំង ដោយប្រការនោះៗ ដោយអំណាចការតាំងចុះរបស់វត្ថុដែលកើតឡើង លោកហៅថា **ការរចនា** ។ ឯការផ្សេងគ្នានៃការរចនានេះ មិនមែនប្រព្រឹត្តទៅ ដោយចំណែកមួយ ព្រោះនៅបានជួបសូម្បីភាពផ្សេងនៃការរចនា ដែលមិនមែនមានពុទ្ធិជាខាងដើមក៏មាន ។ ពិតហើយ បានឃើញការផ្សេងនៃការរចនា ដោយការមានចំណែករបស់សរីរៈ មានសរសៃជាដើម មកប្រជុំចូលគ្នាជាមួយភ្លើង ចំណែករបស់សរីរៈមានខ្លាញ់ខាប់ និងស្បែកជាដើម ដែលស្ងួតស្ងាំងទៅ ក៏មានភាពផ្សេងគ្នានៃការរចនាដូចគ្នា ។ បើការផ្សេងគ្នានៃការរចនានេះ មានហេតុខាងក្រៅ មានព្រះឥស្សរជាដើម បុគ្គលក៏គប្បីរចនាការបូជារូបប្រៀបធៀប ក្នុងការវិលវល់របស់ឧច្ចារបស្សាវៈរបស់សត្វ មានគោ សេះ ពពែ និងលាជាដើម ក៏គប្បីជាបុគ្គលរាយមាយទៅ ដូចមនុស្សឆ្កួត ការផ្សេងគ្នានៃការវិចិត្រនេះ កាលទឹងចាត់ចែងលោក ក៏គប្បីរៀបចំប្រយោជន៍ខ្លួន ឬប្រយោជន៍លោកអ្វីទៅ ។

ក្នុងសេចក្តីផ្សេងគ្នានៃការរចនានោះ បើមក្ខៈមុនដំបូង មិនគប្បីធ្វើកិច្ច ព្រោះមានវត្ថុដែលលោកគប្បីឲ្យសម្រេចសោត ។ កាលបើដូច្នោះ មក្ខៈក្រោយ ក៏គប្បីធ្វើកិច្ចបាបដែលនាំមកនូវការគ្មានប្រយោជន៍ និងសេចក្តីទុក្ខដល់លោក រមែងរៀបចំទុគ្គតិមាននរកជាដើម និងរបស់ដែលជាអនិដ្ឋៈ មានជរា និងមរណៈជាដើម ព្រោះហេតុអ្វី ? បើមិនប្រារព្ធដល់មក្ខៈទាំង ២ ប្រការនោះទេ បាបក៏រមែងចាប់ទុក ជារបស់នៃការលេង ។ ធម្មតាថា ការលេង រមែងមានសេចក្តីត្រេកអរជាចំណុចបំណង ។ វៀរចាកការលេងចេញ កាលសត្វទាំងឡាយមិនដឹង និងសេចក្តីត្រេកអរ ហើយលោកដែលជាឥស្សរៈក្នុងសេចក្តីត្រេកអរ ផ្តើមការលេងដែលមានសេចក្តីត្រេកអរជាគោលដៅ ក៏គប្បីជាបុគ្គលមិនមែនព្រះឥស្សរ ។ បើការផ្សេងនៃការរចនាមិនបានសម្ងឹងប្រយោជន៍ ក៏គប្បី

ចាត់ចែងទៅសព្វកាលទាំងពួង ឯសេចក្តីដែលផ្សេងគ្នានៃការវិចិត្រនោះ ជារឿងសមត្ថភាពក្នុងការរៀបចំនេះ និងគប្បីជារឿង ដែលមិនមានហេតុខ្លះ មានហេតុខ្លះ ។ បើជារឿងដែលមិនមានហេតុ ក៏គប្បីមានដល់មនុស្សគ្រប់គ្នា ។ បើជារឿងដែលមានហេតុ ក៏គប្បីមានដល់មនុស្សគ្រប់គ្នា ។ បើជារឿងមានហេតុ ឯហេតុនៃការផ្សេងគ្នារបស់ការរចនានេះ ក៏គប្បីកើតមកអំពីអ្នកដទៃខ្លះ អំពីខ្លួនខ្លះ ។ ក្នុង ២ យ៉ាងនោះ បើកើតមកអំពីអ្នកដទៃ ហេតុនោះ របស់ការផ្សេងគ្នានៃការរចនានោះ ដែលបានហើយឯណា ហេតុនេះ របស់ការផ្សេងគ្នានៃការរចនានោះ ក៏គប្បីដូចជាអ្នកបម្រើ ។ បើហេតុកើតមកអំពីខ្លួនសោត ហេតុនេះ នឹងមកមុនវាកើតឡើង ហើយលោកក៏ហាក់ដូចជាសោះសូន្យ ព្រោះហេតុនោះ ពាក្យទាំងអស់នេះក៏ជារឿងស្មុគស្មាញចាក់ស្រែះសាំញ៉ាំ ដូចជា ផ្លូវដែលហ្វូងគោដើរ និងស្មើគ្នាដោយដុំពពុះទឹក មិនអាចនឹងទម្លាយបាន ជាវត្ថុមិនមានសារៈ ។ ការពាក់ព័ន្ធគ្នាចូរតាំងនៅចុះ ខ្ញុំនឹងពណ៌នា ព្រោះរឿងដែលបានដាក់កិច្ចទុកប៉ុណ្ណោះ ។ ពាក្យថា **ព្រោះហេតុនោះ** សេចក្តីថា នាមរូបនេះ នឹងជារឿងមិនមានហេតុក៏ទេ ទាំងជារឿងមានហេតុមិនស្មើអំពីហេតុខាងក្រៅ មានព្រះឥស្សរជាដើមក៏ទេ ព្រោះហេតុណា ព្រោះហេតុនោះ ។ បទថា **តេ យោគ ហេតុប្បច្ចយា** ប្រែថា ហេតុប្បច្ច័យទាំងនេះ ។

ការកំណត់បច្ច័យនៃរូបធ្វើបានងាយ ព្រោះជាធម្មជាតិគ្រោតគ្រាត និងព្រោះជាក់ច្បាស់ល្អ ព្រោះហេតុនោះ ទើបលោកអាចារ្យផ្តើមពិធីកំណត់បច្ច័យនៃរូបនោះមុនដោយពាក្យជាដើមថា **របស់រូបកាយនេះមុន** ដូច្នេះ ។ ក្នុងពាក្យនោះ ការកំណត់បច្ច័យនៃនាមរូប រមែងសម្រេចដោយការបដិសេធនូវលទ្ធិថា មិនមានហេតុ និងលទ្ធិថា មានហេតុមិនស្មើ ដោយប្រការណា ការកំណត់បច្ច័យនៃរូប ក៏ចាំបាច់ដោយការបដិសេធសេចក្តីត្រេកអរក្នុងរូបនោះ ដោយការៈនាំមកនូវការនឿយណាយ និងប្រាស

ចាកតម្រេកដោយប្រការនោះ ព្រោះហេតុនោះ លោកអាចារ្យកាលសម្តែងរូបនោះ ដោយជាគព្ភសេយ្យកសត្វ ក្នុងបំណងនឹងប្រកាសភាពជាវត្ថុមិនស្អាត ដោយគន្លងនៃការបដិសេធភាពជាវត្ថុស្អាតនៃទីកន្លែងកើតឡើង ទើបពោលពាក្យជាដើមថា **កាយ** នេះ ។ក្នុងពាក្យនោះផ្កាទាំងឡាយ មានផ្កាឧប្បលជាដើម សូម្បីកើតក្នុងទីកន្លែងមិនស្អាត តែឧប្បលនោះឯង ជាវត្ថុដែលសន្មតគ្នាថា ជារបស់ស្អាតនោះឯង ទើបលោកប្រើស័ព្ទថា ខាងក្នុងដើម្បីបង្ហាញថា ជាវត្ថុស្អាតនោះ ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

**ផ្កាបទុម មានក្លិនក្រអូប កើតក្នុងគំនរសំរាម ដែលគេចោលជិតផ្លូវធំនោះ គង់ជាទីរីករាយនៃចិត្ត យ៉ាងណា** ដូច្នេះ ។

ពាក្យថា **កើតឡើង** នេះ លោកពោលកាន់យកដោយភាពស្មើគ្នានៃការកើតឡើងរបស់រូបកាយ ក្នុងបដិសន្ធិកាល និងបវត្តិកាល ក្នុងគភ៌មាតា មិនត្រឹមតែការកើតឡើង ចំពោះគ្រាដំបូងនោះឡើយ ។ ព្រោះធ្វើអធិប្បាយយ៉ាងនេះ រមែងធ្វើឲ្យបានដល់នូវការពោលភាព ដែលអាហារជាឧបត្ថម្ភកបច្ច័យ ការពោលដល់ការបែរខ្នងទៅខាងមុខផ្ទៃពោះជាដើម និងការពោលដល់រូបកាយជាវត្ថុបដិកូល មានក្លិនស្អុយគួរខ្ពើមរអើម ។ ក្នុងរូបកាយដែលតាំងចុះយ៉ាងនេះ ពាក្យណាដែលលោកអាចារ្យពួកខ្លះពោលទុកជាដើមថា ការបែរខ្នង និងបែរមុខ នឹងជាអ្វី ក្នុងបដិសន្ធិកាលនោះ ពាក្យនោះ រមែងជាពាក្យជាក់ច្បាស់ហើយ ។ ពាក្យថា **ព្រោះជាគ្រឿងធ្វើឲ្យកើត** នេះ លោកអាចារ្យរមែងសម្តែងថា ធម៌ទាំងឡាយ មានអវិជ្ជាជាដើម ឈ្មោះថា **ជាហេតុ** ព្រោះជាគ្រឿងមិនទូទៅរបស់រូបកាយ ប្រៀបដូចពូជជាហេតុរបស់ពន្លក ដូច្នោះ ។ ចំណែកពាក្យថា **ព្រោះជាគ្រឿងឧបការៈ** នេះ លោកអាចារ្យ រមែងសម្តែងថា អាហារឈ្មោះថា **ជាបច្ច័យ** ព្រោះជាប្រធានទូទៅ ប្រៀបដូចវត្ថុ មោមរោម គឺដី និងទឹកជាដើម

ជាបច្ច័យនៃពន្លក ដូច្នោះ ។

ពាក្យថា **ធម៌ ៥ ប្រការ ជាហេតុប្បច្ច័យ** សេចក្តីថា ធម៌ ៥ ប្រការ មានអវិជ្ជាជាដើមជាហេតុផង ជាបច្ច័យផង តាមសមគួរ ។ សេចក្តីប្រាថ្នាដែលបិទបាំងទោសដែលមាននៅក្នុងភពទាំងឡាយ ជាហេតុនៃសង្ខារភព ដោយភាវៈជាគ្រឿងប្រកាន់មាំជា **ភវនិកន្តិ** ( ការប្រាថ្នាភព ) ព្រោះមានជនកកម្មជាសម្ភាញ់ ជាគ្រឿងតាក់តែង និងជាទីអាស្រ័យ ព្រោះមានបច្ច័យដែលកើតរួមជាមួយជនកកម្មនោះជាហេតុជិត ព្រោះហេតុនោះ ទើបលោកពោលថា **ដូចមាតាជាទីអាស្រ័យនៃទារក** ដូច្នោះ ។ ការកើតឡើងរបស់បុត្រនៅក្នុងស្មុកដែលបិតាធ្វើឲ្យកើត ព្រោះហេតុនោះ ទើបបិតាឈ្មោះថា **ជនក** ប្រែថា អ្នកធ្វើឲ្យកើត យ៉ាងណា **កម្ម** លោកពោលថា ជា **ជនក** ព្រោះញុំាងសត្វឲ្យកើត ក៏ដូច្នោះ ។ **ភីលៀង** ព.ទារក ដែលកើតហើយ ដោយការទំនុកបម្រុងចិញ្ចឹម យ៉ាងណា **អាហារ** ក៏បីបាច់កាយ ដែលកើតហើយ ដូច្នោះ ព្រោះហេតុនោះទើបលោកពោលថា ជាគ្រឿងបីបាច់ ។

ក្នុងអធិការនេះ ធម៌ទាំងឡាយ មានអវិជ្ជាជាដើមជាបច្ច័យ ដល់នាមកាយដោយពិត លោកអាចារ្យមានបំណងសម្តែងវិធីកំណត់បច្ច័យនៃនាមកាយនោះ ដោយធ្វើប្រការដទៃឲ្យប្រាកដ ទើបពោលពាក្យជាដើមថា **ចក្ខុញ្ច បដិច្ច** ដូច្នេះជាដើម ។ ក្នុងពាក្យនោះ **ច**-ស័ព្ទ ក្នុងពាក្យថា **ចក្ខុញ្ច** ជាសមុច្ចយត្ថៈ ។ ដោយ **ច**-ស័ព្ទ នោះព្រះមានព្រះភាគទ្រង់សង្គ្រោះបច្ច័យទាំងពួង ដែលជាខាងក្នុង មានអាវជ្ជនៈជាដើមរបស់ចក្ខុវិញ្ញាណផងដែរ ។ ដោយ **ច**-ស័ព្ទ ក្នុងពាក្យថា **រូបេ ច** ទ្រង់រមែងសង្គ្រោះបច្ច័យខាងក្រៅដទៃ ដោយប្រការដែលរូបខាងក្រៅចំណែកច្រើន ជាអារម្មណប្បច្ច័យដល់ចក្ខុវិញ្ញាណ ។ បទថា **បដិច្ច** សេចក្តីថា ជាបច្ច័យបានហើយ ។ ដោយបទថា **បដិច្ច** នោះ ព្រះសាស្តាទ្រង់សម្តែងបច្ច័យ ដោយជានិស្សយប្បច្ច័យ បុរេជាតប្បច្ច័យ

ឥន្ទ្រិយប្បច្ច័យ វិប្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ និងអវិគតប្បច្ច័យដល់ចក្ខុ ទ្រង់រមែងសម្តែងបច្ច័យដោយអារម្មណប្បច្ច័យ បុរេជាតប្បច្ច័យ អត្ថិប្បច្ច័យ និងអវិគតប្បច្ច័យដល់រូប និងទ្រង់រមែងសម្តែងបច្ច័យ ដោយជាអនន្តរប្បច្ច័យជាដើម និងជាសហជាតប្បច្ច័យជាដើម ដល់ធម៌ក្រៅអំពីនេះ ដែលសង្គ្រោះចូលគ្នាបាន ។ ចំណែកហេតុក្នុងការផ្សេងគ្នានៃវចនៈ ខ្ញុំបានពោលហើយខាងដើមនោះឯង ។ ដោយ **អាទិ-ស័ព្ទ** បណ្ឌិតគប្បីជ្រាបការសង្គ្រោះយកវិញ្ញាណ មានសោតវិញ្ញាណជាដើម ព្រមជាមួយបច្ច័យទាំងឡាយ ដូចសង្គ្រោះយកធម៌ទាំងឡាយ មានផស្សៈជាដើម ព្រោះលោកសង្គ្រោះយកបាឋៈជាដើមថា **សោតញ្ច បដិច្ច** ដូចសង្គ្រោះបាឋៈ មាន **តិណ្ណំ សង្គតិ ផស្សោ** ជាដើម ដូច្នោះ ។ នាមទាំងអស់ ដែលគួរដល់ការពិចារណា លោករមែងសង្គ្រោះ ព្រមជាមួយបច្ច័យដោយប្រការ ដូច្នេះ ។ ដោយហេតុនោះ ទើបលោកអាចារ្យពោលថា **រមែងធ្វើការកំណត់បច្ច័យនៃនាមកាយ** ដូច្នេះ ។ ពាក្យថា **ឃើញការប្រព្រឹត្តទៅ** គឺឃើញការប្រព្រឹត្តទៅក្នុងកាលឥឡូវនេះ ។ ដោយពាក្យថា **យ៉ាងនេះ** នេះ លោកប្រារព្ធទុកត្រឹមតែជានាមរូបប្រព្រឹត្តទៅជាមួយបច្ច័យប៉ុណ្ណោះ តែម្យ៉ាងក៏ទេ ដោយពិត គប្បីឃើញថា នាមរូប រមែងប្រព្រឹត្តទៅក្នុងកាលឥឡូវនេះ ដោយបច្ច័យទាំងឡាយ យ៉ាងណា លោកក៏បានប្រារព្ធនាមរូបទុក ដូចគ្នានឹងបច្ច័យថា នាមរូបប្រព្រឹត្តទៅហើយក្នុងអតីត ដោយបច្ច័យ មានអវិជ្ជាជាដើមនោះឯង ។

ពាក្យថា **ចំណែកខាងដើម** បានដល់ ចំណែកដែលទាក់ទងនឹងខន្ធដែលជាអតីត ។ ពាក្យថា **ប្រារព្ធ** បានដល់ ចោះចំពោះ ។ ពាក្យថា **អញបានមាន បានកើតមកហើយ ឬហ្ន៎ អញមិនបានមាន មិនបានកើត ឬហ៎** សេចក្តីថា រមែងសង្ស័យភាពដែលខ្លួនមាននៅក្នុងអតីត និងភាពដែលខ្លួនមិនមាននៅក្នុងអតីត ព្រោះអាស្រ័យអាការដែលឃើញថា **ទៀង** និងអាការដែលឃើញថា **កើតឡើងរឿយៗ** ។ ពាក្យថា

**យើងបានកើតជាអ្វីហ្ន៎** សេចក្តីថា រមែងសង្ស័យថា យើងបានកើតជាក្សត្រឬហ្ន៎ យើងបានកើតជាបុគ្គលណាមួយ ក្នុងបណ្តាព្រាហ្មណ៍ជាដើម ក្នុងបណ្តា គ្រហស្ថជាដើម ក្នុងបណ្តាទេវតាជាដើម ព្រោះអាស្រ័យជាតិ ភេទ និងការឧប្បត្តិ ។ ពាក្យថា **អញបានកើតដូចម្តេចហ្ន៎** សេចក្តីថា រមែងសង្ស័យថា យើងបានកើតជាបុគ្គលខ្ពង់ខ្ពស់ ឬហ្ន៎ អញបានកើតយ៉ាងណានីមួយ ក្នុងបណ្តាមនុស្សតឿ មនុស្សស មនុស្សខ្មៅ បុគ្គលត្រូវខ្នាត និងបុគ្គលមិនត្រូវខ្នាតជាដើមឬហ្ន៎ ព្រោះអាស្រ័យអាការ គឺទ្រង់ទ្រាយ ។ អាចារ្យទាំងឡាយ រមែងពោលថា តែងសង្ស័យការកើតឡើងរឿយៗ របស់ខ្លួន ដោយអាការដែលកើតឡើងថា **អញបានកើតដោយប្រការដូចម្តេចហ្ន៎** ដូច្នេះ ព្រោះអាស្រ័យហេតុ មានព្រះឥស្សរនិម្មិតជាដើម ។ ពាក្យថា **អញបានកើតជាអ្វី ហើយកើតជាអ្វីហ្ន៎** សេចក្តីថា អញបានជាក្សត្រហើយ ជាព្រាហ្មណ៍ឬហ្ន៎ ។បេ។ អញបានកើតជាទេវតា ហើយកើតជា មនុស្សឬហ្ន៎ ដូច្នេះ ព្រោះអាស្រ័យជាតិជាដើម ។ បទថា **អទ្ធានំ** គ្រប់កន្លែង ជាឈ្មោះរបស់កាល ។ ពាក្យថា **អញនឹងមាន នឹងកើតឬហ្ន៎** សេចក្តីថា រមែងសង្ស័យភាពដែលខ្លួនមាននៅក្នុងអនាគត និងភាពដែលខ្លួនមិនមាននៅក្នុងអនាគត ព្រោះអាស្រ័យអាការដែលឃើញថា **ទៀង** និងអាការដែលឃើញថា **ដាច់សូន្យ** ។ ពាក្យដ៏សេសក្នុងទីនេះ មានន័យបានពោលហើយនោះឯង ។ ពាក្យថា **ឬបច្ចុប្បន្នកាលឥឡូវនេះ** សេចក្តីថា ឬកាលដែលកំពុងប្រព្រឹត្តទៅទាំងអស់ ឥឡូវនេះ មានបដិសន្ធិកាលជាដើមទៅ មានចុតិកាលជាទីបំផុត ។ ពាក្យថា **បុគ្គលដែលជាអ្នកមានសេចក្តីសង្ស័យខាងក្នុង** គឺមានការសង្ស័យក្នុងខន្ធទាំងឡាយរបស់ខ្លួន ។ ពាក្យថា **អញមាន កើតមានឬហ្ន៎** រមែងសង្ស័យការមានរបស់ខ្លួន ។ សេចក្តីនេះ មិនទាន់ត្រឹមត្រូវឡើយ ។ ក្នុងរឿងនេះ នឹងគិតអ្វីថា ត្រឹមត្រូវ ឬមិនត្រឹមត្រូវ ។ ព្រោះបុថុជ្ជនល្ងង់ខ្លៅ ក៏ដូចជាមនុស្សឆ្កួត ។ ពាក្យថា **អញមិនមាន មិនកើត ឬហ្ន៎** សេចក្តី

ថា រមែងសង្ស័យការមិនមានរបស់ខ្លួន ។ ពាក្យថា **អញកើតជាអ្វីហ្ន៎** សេចក្ដីថា ជាក្សត្រនោះឯង ក៏គង់សង្ស័យភាពជាក្សត្ររបស់ខ្លួន ។ ក្នុងពាក្យដ៏សេសក៏មានន័យនេះឯង ។ ពាក្យថា **អញកើតដូចម្ដេចហ្ន៎** មានន័យដូចបានពោលហើយនោះឯង ។ ក្នុងទីនេះ បុគ្គលប្រកាន់ថា **ឈ្មោះថា ជីវៈ មាននៅខាងក្នុង** ដូច្នេះតែម្យ៉ាង សង្ស័យជីវៈនោះ មានទ្រង់ទ្រាយខ្ពស់ជាដើម គប្បីជ្រាបថា ឈ្មោះថា សង្ស័យថា **អញកើតដូចម្ដេចហ្ន៎** ។ ដែលឈ្មោះថា ដែលមិនដឹងទ្រង់ទ្រាយរបស់ខ្លួន ដែលជាបច្ចុប្បន្ន រមែងមិនមាន ។ ពាក្យថា **សត្វនេះមកអំពីណាហ្ន៎ សត្វនោះនឹងជាអ្នកទៅទីណាហ្ន៎** សេចក្ដីថា រមែងសង្ស័យទីកន្លែងមក និងទីទៅនៃអត្តភាព ។ ពាក្យថា **សេចក្ដីសង្ស័យទាំងឡាយនោះ លោករមែងលះបាន** សេចក្ដីថា ការសង្ស័យទាំង ១៦ យ៉ាង តាមដែលពោលហើយនោះ លោករមែងលះបាន ដោយអំណាចវិក្ខម្ភនប្បហាន ។

បណ្ឌិតគប្បីប្រកបសេចក្ដីថា ជាសាធារណប្បច្ច័យដល់នាមគ្រប់ប្រការ ដោយប្រភេទ មាននាមដែលជាកុសលជាដើម និងគប្បីប្រកបសេចក្ដីថា ធម៌ មានមនសិការជាដើម ដែលឲ្យប្រព្រឹត្តទៅតអំពីចក្ខុ និងរូបជាដើមនោះ ជាអសាធារណប្បច្ច័យដល់នាមគ្រប់ប្រការ ដោយប្រភេទ មាននាមដែលជាកុសលជាដើម ។ ពាក្យថា **ដោយប្រភេទ មាននាមដែលជាកុសលជាដើម** បានដល់ ដោយប្រភេទ នាមដែលជាកុសល នាមដែលជាអកុសល នាមដែលជាវិបាក និងនាមដែលជាកិរិយា ។ **សូម្បីគ្រប់ប្រការ ទាក់ទងជាមួយប្រភេទនាមឯណានីមួយ មាននាមដែលសហគតៈដោយសោមនស្សជាដើមនោះ** ។ នាមណាប្រព្រឹត្តទៅតាមទ្វារ ៦ ដោយចំណែកមួយ នាមនោះ លោកកាន់យកដោយសព្ទថា ទ្វារ ៦ នោះឯង ដូចជាអារម្មណ៍ទី ៦ លោកកាន់យកសព្ទថា អារម្មណ៍ ៦ ព្រោះហេតុនោះ ទើបលោកពោលថា **សូម្បីគ្រប់ប្រការ** ។ បទថា **តតោ ឃោគ ចក្ខុរូបាទិតោ** ប្រែថា អំពីចក្ខុ និងរូបជាដើម ។

ពាក្យថា ធម៌ មានមនសិការជាដើម បានដល់ ធម៌ មានយោនិសោមនសិការ និង អយោនិសោមនសិការជាដើម និងធម៌ មានកម្ម និងកវឌ្គជាដើម ។ ក្នុងសេចក្តីនេះ លោកពោលសាធារណប្បច្ច័យ និងអសាធារណប្បច្ច័យដល់នាមតែម្យ៉ាង ទាក់ទង នឹងធម៌មានទ្វារ ៦ និងយោនិសោមនសិការជាដើម ដោយពិត សូម្បីយ៉ាងនោះ ពាក្យ នោះ លោកពោលទុកទាក់ទងជាមួយភាពដែលមិនផ្សេងគ្នា ។ តែពោលដោយការ ផ្សេងគ្នា កម្មជាសាធារណប្បច្ច័យដល់នាមដែលជាវិបាក និងដល់រូបដែលមានកម្ម ជាសមុដ្ឋានទាំងឡាយ ចិត្តជាសាធារណប្បច្ច័យដល់នាម គឺចេតសិក និងដល់រូប ដែលមានចិត្តជាសមុដ្ឋានទាំងឡាយ និងជាអសាធារណប្បច្ច័យ ដោយសម្ព័ន្ធដល់ នាមរូបដទៃអំពីនោះ ដល់នាម និងដល់រូប តាមដែលពោលហើយនោះឯង ។ ម្យ៉ាងទៀត អាហារដែលជាសភាគគ្នា និងជាសភាគចូលជាមួយឧតុបាន ជាសាធារណប្បច្ច័យ ដល់រូប ដែលមានអាហារនោះជាសមុដ្ឋាន ជាអសាធារណប្បច្ច័យ ដោយសម្ព័ន្ធដល់ រូបដទៃក្រៅអំពីនោះ បណ្ឌិតគប្បីពង្រីកសេចក្តីតាមគួរ នូវសាធារណប្បច្ច័យ និង អសាធារណប្បច្ច័យសូម្បីដល់រូប ដោយប្រការ ដូច្នេះ ។ ធម្មតា ការកំណត់បច្ច័យ ដែលបុគ្គលមិនទាន់បាន សម្រេចអរហត្តគួរធ្វើ ព្រោះហេតុនោះ ទើបលោកពោល ថា **ធម៌ មានយោនិសោមនសិការ និង សទ្ធម្មស្សវនៈ** ជាដើម ជាបច្ច័យដល់នាម ដែលជាកុសលតែម្យ៉ាង ដូច្នេះ ដោយសម្ព័ន្ធយកបុគ្គល ដែលមិនទាន់បានសម្រេច អរហត្តនោះ ដោយ **អាទិ**-ស័ព្ទ គប្បីឃើញការសង្គ្រោះយកសប្បុរិសូបនិស្សយ ឬ សម្បត្តិចក្រ ទាំង ៤ ។ ព្រោះពោលទុកថា **ធម៌ចំណែកដែលផ្ទុយគ្នាជាបច្ច័យដល់នាម ដែលជាអកុសល** ដូច្នេះ ទើបមានសេចក្តីថា ធម៌ចំណែកដែលផ្ទុយគ្នានឹងយោនិ-សោមនសិការជាដើម ជាបច្ច័យដល់នាម ដែលជាអកុសលតែម្យ៉ាង យ៉ាងណា ធម៌ មានយោនិសោមនសិការជាដើម ក៏រមែងជាបច្ច័យដល់នាម ដែលជាកុសលតែម្យ៉ាង

ដូច្នោះដែរ ។ ម្យ៉ាងទៀត សេចក្តីនេះ សម្រេចដោយអត្ថថា នាមណា មានកុសល មានអកុសល ឬមានទាំងកុសល និងអកុសល ក៏បានដល់នាមនោះ ។ ដោយ **អាទិ** ស័ព្ទ ក្នុងពាក្យថា **កម្មាទិកោ** ធម៌ មានកម្មជាដើម គប្បីឃើញថា លោកសង្គ្រោះធម៌ មានគតិ និងកាលជាដើម ដូចជាធម៌ មានអវិជ្ជាជាដើម ។ ពាក្យថា **ធម៌ មានភវង្គជាដើម** បានដល់ ធម៌ មានភវង្គ សន្តីរណៈ កិរិយា ដែលជាកាមាវចរ និងភាពជាព្រះអរហន្តជាដើម ។ ក្នុងបណ្តាធម៌ទាំងនោះ **ភវង្គ** គប្បីជ្រាបថា ជាបច្ច័យដល់នាមដែលជាកិរិយា គឺបញ្ចទ្វារាវជ្ជនៈ និងមនោទ្វារាវជ្ជនៈ **សន្តីរណៈ** គប្បីជ្រាបថា ជាបច្ច័យដល់វោដ្ឋព្វនៈ **កិរិយាដែលជាកាមាវចរ** គប្បីជ្រាបថា ជាបច្ច័យដល់នាមដែលជាកិរិយាចំណែកកាមាវចរ និងចំណែកមហគ្គតៈ តាមសមគួរ **ភាពជាព្រះអរហន្ត** គប្បីជ្រាបថា ជាបច្ច័យដល់នាមដែលជាកិរិយាទាំងពួង ដែលវៀរអាវជ្ជនៈ ។

ចេតនានោះឯង លោកមានបំណងយក **កម្ម** ចេតនានោះឯង ជាកុសល និងអកុសល ។ សេចក្តីនេះ សមដូចព្រះពុទ្ធវចនៈដែលត្រាស់ទុកថា **ចេតនាដែលជាកុសល និងអកុសល ជាបច្ច័យ ដោយជាកម្មប្បច្ច័យដល់វិបាកក្ខន្ធទាំងឡាយ និងដល់កដត្តារូបទាំងឡាយ** ដូច្នេះ ។ មិនមែនបំណងយកធម៌ ព្រមទាំងសម្បយុត្តធម៌ទាំងឡាយ ដូចជាចិត្តនោះឡើយ ។ ព្រោះក្នុងទីនេះ លោកមានបំណងយកចិត្ត ព្រមទាំងសម្បយុត្តធម៌ ដោយព្រះបាលីថា សភាវធម៌ដែលជាហេតុ ជាបច្ច័យ ដោយហេតុប្បច្ច័យដល់ធម៌ទាំងឡាយដែលសម្បយុត្តនឹងហេតុ និងដល់រូបទាំងឡាយ ដែលមានធម៌សម្បយុត្តធម៌ជាមួយហេតុនោះជាសមុដ្ឋាន ។ បទថា **តត្ថ** សេចក្តីប៉ុនគ្នានឹង **តេសុ យោគ កម្មាទីសុ រូបជនកបច្ចយេសុ** ប្រែថា ក្នុងបណ្តាបច្ច័យ ដែលធ្វើរូបឲ្យកើត មានកម្មជាដើមនោះ ។ ផលរមែងកើតឡើងអំពីកម្ម ដែលជាអតីតប៉ុណ្ណោះ មិនកើតអំពីកម្មដែលជាបច្ចុប្បន្នឡើយ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា

កម្មដែលជាអតីតប៉ុណ្ណោះ ជាបច្ច័យដល់រូប ដែលមានកម្មជាសមុដ្ឋាន ដូច្នេះ ។ បើផលគប្បីកើតឡើងអំពីកម្មដែលជាបច្ចុប្បន្នសោត ក្នុងខណៈ ដែលធ្វើកម្មនោះឯង គប្បីមានវត្ថុដែលគប្បីកើតឡើងដោយផល តែក៏មិនបានជួប ឬប្រាថ្នាវត្ថុដែលគប្បីកើតឡើងដោយផលនោះ ។ ព្រោះថា បុគ្គលណាម្នាក់ ក៏មិនបានឃើញកម្មដែលកំពុងធ្វើនោះឯងឲ្យផល ក្នុងកាលណាមួយក្នុងលោក ម្យ៉ាងទៀត គម្ពីរដែលអាស្រ័យអាងបែបនោះ ក៏នៅមាន ។ សួរថា សូម្បីផលដែលកើតឡើង អំពីហេតុដែលវិនាសទៅ ឬមាន់ស្លាប់បេះរង៉ាវនេះ បុគ្គលណាម្នាក់ ក៏មិនបានឃើញ មិនមែនឬ ? ឆ្លើយថា សេចក្ដីនេះពិត បុគ្គលណាម្នាក់ មិនឃើញក្នុងការដាច់តំណគ្នារបស់រូបធម៌ទាំងឡាយ តែសេចក្ដីនេះ ជាអរូបធម៌ សូម្បីជាការបន្តគ្នាក៏មាន ព្រោះហេតុនោះ ទើបពាក្យឧបមាមិនចូលគ្នា ។ ផលរមែងកើតអំពីកម្ម ដែលជាអតីតតែម្យ៉ាង ព្រោះកម្មដែលបានធ្វើទុកហើយ និងបានសន្សំទុកហើយ សេចក្ដីនេះ សមដូចព្រះបាលីដែលត្រាស់ទុកដូច្នេះថា **ចក្ខុវិញ្ញាណជាវិបាកកើតឡើង ព្រោះកាមាវចរកុសលកម្ម ដែលបានធ្វើទុកហើយ និងបានសន្សំទុកហើយ** ដូច្នេះ ជាដើម ។ ព្រោះចិត្តជាធម្មជាតិមានកម្លាំង ក្នុងខណៈកើតឡើង ព្រោះបានបច្ច័យ មានអនន្តរប្បច្ច័យជាដើមនោះឯង ដូច្នោះ ចិត្តនោះ កំពុងកើតឡើងនោះឯង រមែងញុំាងរូបឲ្យកើត ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **ចិត្តំ ចិត្តសមុដ្ឋានស្ស ឧប្បជ្ជមានំ** ដូច្នេះ ។ ក្លាប់សេចក្ដីបាលីថា **រូបស្ស បច្ចយោ ហោតិ** ប្រែថា ចិត្តដែលកំពុងកើតឡើង ជាបច្ច័យដល់រូបដែលមានចិត្តជាសមុដ្ឋាន ។ ម្យ៉ាងទៀត ព្រោះរូបដែលមានកម្លាំងក្នុងខណៈតាំងនៅ ព្រោះការបានបច្ច័យ មានបច្ឆាជាតប្បច្ច័យជាដើម ដូច្នោះ ទើបលោកអាចារ្យពោលថា **ឧតុ និងអាហារ ជាបច្ច័យដល់ឧតុសមុដ្ឋានរូប និងអាហារសមុដ្ឋានរូប** ដូច្នេះ អធិប្បាយថា ឧតុ និងអាហារបាន ឧតុ និងអាហារខាងក្រៅជាបច្ច័យហើយ រមែងញុំាងរូបឲ្យកើត

ក្នុងខណៈដែលខ្លួន តាំងនៅ ។

ពាក្យថា **យ៉ាងនេះ** គឺដោយប្រការពោលហើយ ដោយពាក្យជាដើមថា **ដោយជាសាធារណប្បច្ច័យ និងអសាធារណប្បច្ច័យ** ។

ពាក្យថា **នៃសង្ខារទាំងឡាយ** បានដល់ នៃសង្ខារ គឺសង្ខតធម៌ទាំងឡាយ ។ ពាក្យថា **កាបែកធ្លាយទៅ** បានដល់ សេចក្ដីស្លាប់ ។ ការកំណត់បច្ច័យនៃនាមរូបដោយលំដាប់នៃការសម្ដែងហេតុ តាមលំដាប់នៃការសម្ដែងផលជាដើមថា **ឈ្មោះថាជរា និងមរណៈ កាលជាតិមាន ទើបមាន** ដូច្នេះ លោកសម្ដែងទុក ព្រោះអធិប្បាយថា ជាការធ្វើបានងាយ ។ ក្នុងពាក្យនោះ ពាក្យថា **កាលភពមាន** គឺកាលកម្មភពមាន ។

ពាក្យថា **ដោយអំណាចបដិច្ចសមុប្បាទ ដោយអនុលោម ដែលបានសម្ដែងពិស្ដារមកហើយអំពីមុន** សេចក្ដីថា ដោយអំណាចបដិច្ចសមុប្បាទ ដោយអនុលោមដែលបានសម្ដែងឲ្យពិស្ដារមកហើយ ទាក់ទងតាំងអំពីមាតិកាចុងបំផុតទៅឲ្យដល់មាតិកាខាងដើម ដោយបដិលោមន័យ ។ កាលបានបច្ចយាការ ដែលលោកសម្ដែងទុកដោយអំណាចបដិលោម ដោយពាក្យជាដើមថា **កាលជាតិមិនមាន ក៏មិនមានជរា និងមរណៈ** ដូច្នេះ ការកំណត់បច្ច័យនៃនាមរូប ដោយបដិលោមគ្នា និងដោយអនុលោមតាមគ្នាថា **ព្រោះធម៌ណាមិនមាន ធម៌ណាក៏មិនមាន ធម៌នោះ ក៏ជាបច្ច័យដល់ធម៌នោះ** ក៏ជាការធ្វើបានងាយ ដូច្នេះ ។

ពាក្យថា **ការវង្វេងក្នុងបុរិមកម្មភព** ជាដើម មានអត្ថបានពោលទុកហើយនោះឯង ។ លោកអាចារ្យបន្ថែមយកកិលេសវដ្ដៈទុកក្នុងកម្មវដ្ដៈ ពោលទុកថា **ដោយអំណាចកម្មវដ្ដៈ និងវិបាកវដ្ដៈ** ព្រោះកិលេស មានកម្មជាសម្ពាញ់ ។

អត្ដភាពបច្ចុប្បន្ន ជាអត្ដភាពប្រចក្ស ហៅថា **ទិដ្ឋធម៌** កម្មដែលមានផល គប្បីសោយក្នុងអត្ដភាពបច្ចុប្បន្ននេះ ឈ្មោះថា **ទិដ្ឋធម្មវេទនីយកម្ម** ។ កម្មដែលមានផល

ដែលគប្បីសោយក្នុងលំដាប់តអំពីបច្ចុប្បន្នភពទៅ ឈ្មោះថា **ឧបបជ្ជវេទនីយកម្ម** ។ បទថា **អបរាបរិយាយេ** ( ក្នុងភពតៗ ទៅ ) សេចក្តីថា ក្នុងការផ្លាស់ប្តូរអត្តភាព គឺក្នុងការវិលអត្តភាពទៅជាដទៃ ដោយជាអត្តភាពបច្ចុប្បន្ន អត្តភាពបន្ទាប់អំពីបច្ចុប្បន្ន និងអត្តភាពអនាគត ។ ពាក្យថា **អហោសិកម្ម** គឺកម្មដែលមានហើយនោះឯង វិបាករបស់អហោសិកម្មនោះ មិនមានជាកម្ម ដែលគួរពោលយ៉ាងនេះ **មាន ឬនឹងមាន** ។ ជវនចេតនាដួងដំបូង ដែលដល់នូវភាពជាធម្មជាតិ មានកម្លាំង ព្រោះជាធម្មជាតិត្រូវបដិបក្ខគ្របសង្កត់មិនបាន និងព្រោះជាធម្មជាតិ មានភាពពិសេស ដែលបានហើយដោយការផ្សេងគ្នានៃបច្ច័យ ជាធម្មជាតិពិសេស ប្រព្រឹត្តទៅដោយអំណាចអភិសង្ខារខាងដើម ដូច្នោះ ឲ្យផលក្នុងអត្តភាពនោះឯង ឈ្មោះថា **ទិដ្ឋធម្មវេទនីយា** ប្រែថា ឲ្យផលក្នុងបច្ចុប្បន្ន ។ ឯចេតនានោះ ចាត់ជាជវនចេតនាដួងដំបូង ព្រោះប្រព្រឹត្តទៅដោយអំណាចវិធីនៃឧបចារៈក្នុងសការៈដែលប្រកបដោយគុណវិសេស ក្នុងការបន្តនៃជវនដែលមានកម្លាំង ដោយប្រការដែលពោលហើយ និងព្រោះជាកម្មដែលមានវិបាកតិច ដោយការមិនបានអាសេវនៈ មិនទាន់ចាត់ជាកម្មដែលសម្លឹងដល់សការៈតាមក្រោយសការៈ ដែលមាននៅក្នុងបវត្តិកាល និងដែលសម្លឹងដល់ការបានឱកាសដូចជាជវនចេតនា ២ ដួង ក្រៅអំពីនេះ ព្រោះហេតុនោះ ទើបដូចត្រឹមជាផ្កាក្នុងទីនេះនោះឯង រមែងឲ្យផលត្រឹមជាវិបាក ក្នុងបវត្តិកាល ។ ពាក្យថា **តែកាលមិនអាចយ៉ាងនោះ** សេចក្តីថា ឈ្មោះថា **ការឲ្យវិបាករបស់កម្មរមែងមានបាន** ព្រោះការដល់ព្រមនៃបច្ច័យដទៃ មានឧបធិ និងបយោគជាដើមនោះឯង ព្រោះហេតុនោះ កាលមិនអាចឲ្យវិបាកក្នុងអត្តភាពនោះ ព្រោះមិនមានបច្ច័យដទៃ មានឧបធិ និងវិបាកជាដើមនោះ ។ ពាក្យថា **ដែលញុំាងផលឲ្យសម្រេច** គឺដែលញុំាងផល មានការឲ្យទាននិងមានបាណាតិបាតជាដើមឲ្យសម្រេច ។ លោកអាចារ្យពោលថា **ជវនចេតនាដួងទី**

៧ ដូច្នេះ ដើម្បីឆ្លើយសំណួរថា ចេតនានោះ គឺចេតនាអ្វី ។ ចេតនាដែលឲ្យសម្រេចកិច្ចនោះ ជាធម្មជាតិបាន គុណវិសេសតាមន័យដែលពោលហើយ និងបានអាសេវនៈអំពីជវនចេតនាដួងមុនៗ ឲ្យវិបាកក្នុងអត្តភាពបន្ទាប់ទៅ ឈ្មោះថា **ឧបបជ្ជវេទនីយកម្ម** ។ ដោយពាក្យថា **កាលការប្រព្រឹត្តទៅនៃសង្សារនៅមាន** នេះ លោករមែងសម្តែងថា កាលមិនមានការប្រព្រឹត្តទៅនៃសង្សារ ឧបបជ្ជវេទនីយកម្ម រមែងតាំងនៅក្នុងចំណែកអហោសិកម្ម ព្រោះមិនមានឱកាសឲ្យផល ។

ពាក្យថា **កម្មណាធ្ងន់** សេចក្តីថា កម្មណា ជាអកុសល មានទោសច្រើន ជាកុសល មានអានុភាពច្រើន ។ ពាក្យថា **កម្មណាច្រើន** សេចក្តីថា កម្មជាច្រើន គឺបានធ្វើរឿយៗ សេពរហូតជ្រឹក ។ ពាក្យថា **ដែលរឭកបានក្នុងពេលជិតស្លាប់** សេចក្តីថា ដែលរឭកបានក្នុងកាលជិតចំពោះសេចក្តីស្លាប់ ដោយជាកម្មជាក់ច្បាស់ ។ សេចក្តីនេះ សមជាមួយពាក្យដែលលោកពោលទុកថា ពាក្យដែលគប្បីពោលក្នុងកម្មដែលធ្វើទុកក្នុងពេលជិត ( ស្លាប់ ) រមែងមិនមាន ។ ដោយពាក្យថា **ដែលបានអាសេវនៈរឿយៗ** នេះ លោកអាចារ្យរមែងធ្វើអត្ថឲ្យផ្សេងទៅអំពីកម្ម ដែលពោលទុកថា **កម្មណាច្រើន** ។ រមែងបដិសេធទិដ្ឋធម្មវេទនីយកម្ម ដូចគ្នា ព្រោះរមែងទទួលការទាញមកកាន់បដិសន្ធិបាន ។ លោកពោលកម្ម ៤ យ៉ាង មានគរុកកម្មជាដើម ទាក់ទងដោយជាកម្មឲ្យកើតបដិសន្ធិ ។

ក្នុងបណ្តាកម្ម ៤ យ៉ាងនោះ គរុកកម្ម រមែងឲ្យផលមុនកម្មដទៃទាំងអស់ ។ ពិតហើយ ទើបកម្មនោះលោកពោលថា **គរុកកម្ម** ។ កាលគរុកកម្មមិនមានពហុលកកម្ម រមែងឲ្យផល កាលពហុលកកម្មមិនមាន អាសន្នកម្មរមែងឲ្យផល សូម្បីកាលអាសន្នកម្មនោះមិនមាន កម្មដែលបានធ្វើទុកក្នុងជាតិមុន ដែលហៅថា **កដត្តាវាបនកម្ម** រមែងឲ្យផល ។ បណ្ឌិតគប្បីជ្រាបការមានកម្លាំង និងមិនមានកម្លាំង ក្នុងពហុលកកម្ម

អាសន្នកម្ម និងកម្មដែលធ្វើទុកក្នុងកាលមុន គឺការផ្សេងនៃកម្មអាក្រក់អំពីកម្មអាក្រក់ ចាត់ជាកម្មល្អ ការផ្សេងនៃកម្មល្អអំពីកម្មល្អ ចាត់ជាកម្មអាក្រក់ កម្មដែលធ្វើទុកក្នុងកាលមុនជាដើម អំពីកម្មដែលធ្វើទុកច្រើន និងអំពីកម្មធ្ងន់ ចាត់ជាកម្មតិច ។ កម្មដែលមានកម្លាំងដែលហេតុនោះៗ តាំងទុក រមែងឲ្យផលមុន គឺដោយកម្មដែលផ្តើមវិបាកទុក ព្រោះធម៌ដែលជាបដិបក្ខមិនទាន់គ្រប់ចំនួន ដោយធ្វើឲ្យកើតវិប្បដិសារៈជាដើម ដោយការរឭកដល់ពហុលកកម្ម ឬកម្មដ៏សេស ដែលនឹងឲ្យផលក្នុងភពតៗ ទៅ នៅមានការផ្សេងគ្នានៃការប្រែប្រួលនៃការបន្ត ព្រោះជាកម្មមិនទាន់អស់ទៅ ។ ក្នុងរឿងនេះ មានសេនាបតីរបស់ព្រះបាទវិទេហៈ ឈ្មោះ **អលាត** អ្នកបម្រើឈ្មោះ **ពីជកៈ** និងព្រះរាជកញ្ញា ព្រះនាមថា **រុចា** ក្នុង **មហានារទកស្សបជាតក** ជាគំរូ ។ ពិតហើយ ព្រះមានព្រះភាគបានត្រាស់ទុកថា

ម្នាលអានន្ទ ក្នុងបុគ្គល ៤ ពួកនោះ បុគ្គលដែលជាអ្នកច្រើនទៅដោយបាណាតិបាត ។បេ។ មានការយល់ខុសក្នុងលោកនេះ កាលបុគ្គលនោះស្លាប់ទៅ ហើយចូលដល់អបាយ ទុគ្គតិ វិនិបាត នរក ។ ការដែលបុគ្គលធ្វើកម្មអាក្រក់ ឲ្យផលជាទុក្ខក្នុងកាលមុន ឬក្នុងកាលជាខាងក្រោយ ឬថា ដែលមានមិច្ឆាទិដ្ឋិដែលខ្ជួនប្រកាន់ទុកមាំមួនក្នុងពេលនឹងស្លាប់ ព្រោះដូច្នោះ បុគ្គលនោះស្លាប់ទៅ ទើបចូលដល់អបាយ ទុគ្គតិ វិនិបាត នរក ។ ឯបុគ្គលដែលជាអ្នកច្រើនដោយបាណាតិបាត ។បេ។ មានការយល់ខុសក្នុងលោកនេះ បុគ្គលនោះរមែងសោយវិបាករបស់កម្មក្នុងជាតិនេះ ក្នុងជាតិមុខ ឬក្នុងជាតិតទៅ ។

ម្នាលអានន្ទ ក្នុងបុគ្គល ៤ ពួកនោះ បុគ្គលជាអ្នកច្រើនដោយបាណាតិបាត ។បេ។ មានការយល់ខុសក្នុងលោកនេះ កាលស្លាប់ហើយ ចូលដល់សុគតិសួគ៌ ។ ព្រោះថា បុគ្គលធ្វើកម្មល្អទុកដែលឲ្យផលជាសុខក្នុង **កាលមុនៗ** ឬក្នុង **កាលខាង**

ក្រោយ ឬមានសម្មាទិដ្ឋិដែលខ្លួនប្រកាន់ទុកមាំទាំហើយ ក្នុងវេលាជិតស្លាប់ ព្រោះដូច្នោះ បុគ្គលនោះ កាលស្លាប់ទៅ ទើបចូលដល់សុគតិសួគ៌ ។ ឯបុគ្គលជាអ្នកច្រើនដោយបាណាតិបាត ។បេ។ មានការយល់ខុស ក្នុងលោកនេះ បុគ្គលនោះ រមែងសោយវិបាករបស់កម្មនោះ ក្នុងជាតិនេះ ក្នុងជាតិមុខ ឬក្នុងជាតិតទៅ ។

ម្នាលអានន្ទ ក្នុងបុគ្គល ៤ ពួកនោះ បុគ្គលដែលវៀរចាកបាណាតិបាត ។បេ។ មានសម្មាទិដ្ឋិក្នុងលោកនេះ កាលស្លាប់ទៅហើយ ចូលដល់សុគតិសួគ៌ ។ ព្រោះថាបុគ្គលធ្វើកម្មល្អទុក ដែលឲ្យផលជាសុខក្នុងកាលមុនៗ ឬក្នុងកាលខាងក្រោយ ឬមានសម្មាទិដ្ឋិដែលខ្លួនប្រកាន់ទុកយ៉ាងមាំមួន ក្នុងកាលជិតស្លាប់ ព្រោះដូច្នោះ កាលបុគ្គលនោះស្លាប់ទៅ ទើបចូលដល់សុគតិសួគ៌ ។ ឯបុគ្គលដែលវៀរចាកបាណាតិបាត ។បេ។ មានសម្មាទិដ្ឋិក្នុងលោកនេះ បុគ្គលនោះរមែងសោយវិបាករបស់កម្មនោះ ក្នុងជាតិនេះ ក្នុងជាតិមុខ ឬក្នុងជាតិតទៅ ។

ម្នាលអានន្ទ ក្នុងបុគ្គល ៤ពួកនោះ បុគ្គលដែលវៀរចាកបាណាតិបាត ។បេ។ មានសម្មាទិដ្ឋិ ក្នុងលោកនេះ កាលស្លាប់ទៅហើយ ចូលដល់អបាយ ទុគ្គតិ វិនិបាត នរក ព្រោះថា បុគ្គលធ្វើកម្មអាក្រក់ ដែលឲ្យផលជាទុក្ខក្នុង **កាលមុនៗ ឬ ក្នុងកាលខាងក្រោយ ឬ មានមិច្ឆាទិដ្ឋិ** ដែលប្រកាន់នោះប្រកាន់ទុកយ៉ាងមាំមួន ក្នុងពេលជិតស្លាប់ ។ កាលបុគ្គលនោះ ស្លាប់ទៅ ទើបចូលដល់អបាយ ទុគ្គតិ វិនិបាត នរក ។ ឯបុគ្គលដែលវៀរចាកបាណាតិបាត ។បេ។ មានសម្មាទិដ្ឋិ ក្នុងលោកនេះ បុគ្គលនោះរមែងសោយវិបាករបស់កម្មនោះ ក្នុងជាតិនេះ ក្នុងជាតិមុខ ឬក្នុងជាតិតទៅ ដូច្នេះ។

នឹងនិយាយច្រើនធ្វើអ្វី នេះជាវិស័យរបស់មហាកម្មវិភង្គញាណនៃព្រះតថាគតប៉ុណ្ណោះ ទើបយល់កម្មនោះៗ ឲ្យផលមុនក្រោយគ្នា ដោយហេតុនោះៗ ។

កម្មដែលញ៉ាំងការបន្តនៃវិបាកឲ្យកើតឡើង ដោយអំណាចការឲ្យបដិសន្ធិជា

ដើម ចាត់ជាជនកកម្ម ។ ( ដោយហេតុនោះ ទើបលោកអាចារ្យពោលថា **ជនកកម្មនោះរមែងញ៉ាំងវិបាកក្ខន្ធដែលជារូបាវចរ និងអរូបាវចរ ឲ្យកើត ទាំងក្នុងបដិសន្ធិកាល និងក្នុងបវត្តិកាល** ។ កម្មដែលជាហេតុនៃការបន្តសុខ ឬទុក្ខ ឬនៃការទាក់ទងគ្នានៃនាមរូបឲ្យប្រព្រឹត្តទៅបានយូរក្រៃលែង ជាឧបត្ថម្ភកកម្ម ។ ដោយហេតុនោះ ទើបលោកអាចារ្យពោលថា **ឧបត្ថម្ភកកម្ម រមែងចូលឧបការៈសុខ ឬទុក្ខ ឲ្យប្រព្រឹត្តទៅយូរ** ។ ឧបបីឡកកម្ម កាលការទាក់ទងគ្នានៃសុខ ឬទុក្ខ កំពុងប្រព្រឹត្តទៅ ក៏ធ្វើឲ្យការទាក់ទងគ្នានៃសុខ ឬទុក្ខនោះ បន្ថយៗ ស្រកចុះ ។ ដោយហេតុនោះ ទើបលោកអាចារ្យពោលថា **ឧបបីឡកកម្ម រមែងបៀតបៀនសុខ ឬទុក្ខ មិនឲ្យប្រព្រឹត្តទៅបានយូរ** ។ បទថា **ឃាដេត្វា** ប្រែថា ចូលទៅកាត់ ។ ធម្មតាការចូលទៅផ្តាច់របស់កម្ម ក៏គឺការឃាត់គ្នា វិបាករបស់កម្មដទៃនោះឯង ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **ឃាត់វិបាករបស់កម្មដទៃនោះចេញ** ។ ការឃាត់វិបាករបស់កម្មដទៃនោះ ក៏គឺជាការបើកប្រហោងឲ្យវិបាករបស់ខ្លួនកើតឡើង ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **រមែងបើកចន្លោះឲ្យដល់វិបាករបស់ខ្លួន** ។ កម្មដែលបើកឱកាសឲ្យដើម្បីការឲ្យផល រមែងឈ្មោះថា ឲ្យផលហើយនោះឯង ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **កាលកម្មបើកឱកាសឲ្យយ៉ាងនោះ ហើយវិបាកនោះ ក៏ហៅបានថា កើតហើយ** ។ **ឧបបីឡកកម្ម** រមែងចូលទៅកាត់វិបាករបស់កម្មដទៃ មិនឲ្យវិបាករបស់ខ្លួនឯង ។ ចំណែក **ឧបឃាតកកម្ម** ចូលទៅកាត់កម្មដែលមានកម្លាំងតិចជាង ហើយឲ្យវិបាករបស់ខ្លួនកើតឡើង ឧបបីឡកកម្ម និងឧបឃាតកកម្មនេះ មានសេចក្តីផ្សេងគ្នាដូចពោលមកនេះ ។ **ឧបបីឡកកម្ម** បៀតបៀនវិបាកដោយការចូលទៅញ៉ាំងបច្ច័យមានអាពាធច្រើនជាដើម ឲ្យធ្លាក់ចុះទៅ ។ **ឧបឃាតកកម្ម** ចូលទៅកាត់វិបាកនោះឯងយ៉ាងនោះ ។ កម្ម កាលមានការចូលទៅផ្តាច់ ហើយឲ្យផល ដោយការឲ្យឱកាសដល់

វិបាករបស់ខ្លួន គួរជាជនកកម្ម តែម្យ៉ាង ធម្មតាថា ជនកកម្មជាដើម កាលសំដៅដល់វិបាក ក៏គួរកាន់យកបាន មិនមែនសំដៅដល់កម្ម ព្រោះហេតុនោះ កម្មចូលទៅកាត់វិបាកតែម្យ៉ាង មើលទៅសមគួរហើយ រឿងនេះគួរពិចារណាមើល ។

បទថា **កម្មន្តរំ** ប្រែថា ការផ្សេងគ្នានៃកម្ម គឺការបែកផ្សេងដ៏ខ្លាំងក្លា និងមិនខ្លាំងក្លានៃកម្មទាំងឡាយ ។ បទថា **វិបាកន្តរំ** ប្រែថា ផ្សេងគ្នានៃវិបាក គឺការបែកផ្សេងគ្នាដោយវិបាកនោះ ជាវត្ថុថោកទាប និងប្រណីតជាដើម ។ ន័យម្យ៉ាងទៀត កាលធ្វើកម្មណា រមែងមានការកើតឡើងនៃកដត្តារូប ក្នុងបដិសន្ធិកាល និងក្នុងបវត្តិកាល កម្មនោះ ឈ្មោះថា **ជនកកម្ម** ។ ម្យ៉ាងទៀត កាលធ្វើកម្មណាទុក រមែងមានការបន្តជាប់គ្នាអស់កាលដ៏យូរ នៃការទំនុកបម្រុងតាមគួរដល់អានុភាពនៃជនកកម្ម ដោយការមិនកើតឡើងនៃបច្ច័យដែលបៀតបៀនចូលទៅកាត់ និងដោយការកើតឡើងនៃបច្ច័យដែលឧបត្ថម្ភនៃផលដែលគួរប្រាថ្នា ឬមិនគួរប្រាថ្នា ដែលកម្មដទៃឲ្យកើត កម្មនោះឈ្មោះថា **ឧបត្ថម្ភកកម្ម** ។ ផលនៃកុសលក្តី ផលនៃអកុសលក្តី ដែលជនកកម្មឲ្យកើតឡើងហើយ ត្រូវកម្មណាដែលជាសត្រូវបៀតបៀន ដើម្បីជាហេតុនៃរោគ និងការស្មើគ្នានៃធាតុជាដើម កម្មនោះ ឈ្មោះថា **ឧបបីឡកកម្ម** ។ ម្យ៉ាងទៀត កម្មណារមែងចូលទៅសម្លាប់ គឺចូលទៅកាត់ផល ដែលជាផល សមគួរដែលបន្តទៅបានយូរក្រៃលែងដោយអំណាចនៃជនកកម្ម ដោយការកើតឡើងនៃបច្ច័យដែលចូលទៅកាត់កម្មនោះឈ្មោះថា **ឧបឃាតកកម្ម** ។ ក្នុងបណ្តាកម្មទាំងនោះ អាចារ្យពួកខ្លះ រមែងពណ៌នាកម្មបែបទី ២ ជាកុសល ដោយអំណាចញ៉ាំងភាពជាបុគ្គលមានអាពាធតិច និងជាបុគ្គលមានអាយុវែង ឲ្យប្រព្រឹត្តទៅដល់បុគ្គលដែលមានឈ្មោះយ៉ាងនេះ រមែងពណ៌នាកម្ម ២ យ៉ាងខាងក្រោយ ជាអកុសលដោយអំណាចញ៉ាំងភាពជាបុគ្គលមានអាពាធច្រើន និងជាបុគ្គលមានអាយុខ្លី ឲ្យប្រព្រឹត្តទៅ ។ ចំណែកកម្មដែលឧបការៈ គឺបៀតបៀន

និងចូលទៅកាត់អកុសលវិបាកក្នុងអបាយភូមិ មាននរកជាដើមរបស់ពួកនេរយិកសត្វ មានទេវទត្តជាដើមរបស់អបាយសត្វ មាននាគជាដើម និងរបស់ពួកប្រេត ដែលញុំាងជីវិតនៅ បានដោយទានពួកញាតិ ឬមិត្តអាមាត្យឧទ្ទិសឲ្យអំពីលោកនេះ និងមិនមានក៏ទេ ព្រោះហេតុនោះ កម្មទាំង ៤ ជាអកុសល ទើបមិនខុស ការបែកផ្សេងនៃកម្មជាដើម លោកអាចារ្យពោលថា **មិនសាធារណៈដល់សាវកទាំងឡាយ** ព្រោះជាអារម្មណ៍នៃអសាធារណញ្ញាណនោះឯង ដោយភាពជាអារម្មណ៍របស់ព្រះសម្ពុទ្ធតែមួយចំណែក ។ **គប្បីដឹងបានដោយឯកទេស** គឺមិនអាចដឹងបានដោយមិនមានសេសសល់ ព្រោះមិនមែនជាវិស័យ ។ ការកំណត់បច្ច័យ រមែងមិនគ្រប់ចំនួន ព្រោះការមិនដឹងទាំងអស់នោះឯង ។

កម្មតាមដែលពោលហើយ លោកមានបំណងយកចំពោះនិមិត្ត នៃការបន្តគ្នាជាមួយវិបាក ដែលកំពុងប្រព្រឹត្តទៅ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **បន្ថែមកម្មទាំង ១២ យ៉ាងចូលក្នុងកម្មវដ្ដៈ** ព្រោះជាឯកទេសនៃកម្ម ។ លោកអាចារ្យពោលថា **ដោយអំណាចកម្មវដ្ដៈ និងវិបាកវដ្ដៈ** ដូច្នេះ ព្រោះធ្វើកិលេសវដ្ដៈឲ្យប្រព្រឹត្តទៅក្នុងចំណែកនៃកម្មវដ្ដៈ ព្រោះកិលេស មានកម្មជាសម្ភារ ។ នាមរូបប្រព្រឹត្តទៅក្នុងបច្ចុប្បន្ន ព្រោះបច្ច័យ យ៉ាងណា ក៏ប្រព្រឹត្តទៅក្នុងកាលទាំង ២ ក្រៅអំពីនេះ ព្រោះបច្ច័យ ដូច្នោះ ព្រោះហេតុនោះ លោកអាចារ្យ កាលសម្ដែងឧបមាដែលនឹងនាំការយល់ក្នុងអតីត និងអនាគត ទើបពោលពាក្យជាដើមថា **នាមរូប** នេះ ។ ក្នុងបណ្ដាពាក្យទាំងនោះ គួរនាំយក **ឯវំ**-ស័ព្ទ ដែលលោកពោលទុកក្នុងពាក្យថា **អនាគតេបិ កម្មវដ្ដវិបាកវដ្ដវសេនេវ** នេះ មកពោលទុកក្នុងពាក្យថា **ឯតរហិ អតីតេបិ** នេះ ព្រោះពាក្យសួរ មានការសម្ដែងត្រឹមតែជាកិរិយា និងផលនៃកិរិយាក្នុងកាលទាំង ៣ ជាខាងមុខ ។ ពាក្យថា **ឥតិ កម្មញ្ចេវ** ជាដើមលោកអាចារ្យពោលទុកដោយអំណាច

ជាពាក្យបញ្ជាក់អត្ថដែលពោលហើយនោះឯង ។ ការវិលវល់ទៅមក ឈ្មោះថា **វដ្តៈ** ដោយអត្ថថា វិលវល់ ។ ការប្រព្រឹត្តទៅយ៉ាងនោះ ឈ្មោះថា **បវត្ត** ។ ឈ្មោះថា **សន្តតិ** ព្រោះអត្ថថា សម្ពន្ធគ្នា ដោយហេតុ និងផល បានដល់ ការបន្តជាប់គ្នា ។ ឈ្មោះថា **កិរិយា** ដោយអត្ថថា ធ្វើ ឬព្រោះមានអត្ថថា ត្រូវបច្ច័យទាំងឡាយធ្វើ ។

បទថា **កម្មា** ប្រែថា ព្រោះកម្ម ។ ឈ្មោះថា **សម្ភវោ** ព្រោះអត្ថថា ជាដែនកើត កម្មជាដែនកើតរបស់វិបាកនេះ ហេតុនោះ វិបាកនេះ ឈ្មោះថា **កម្មសម្ភវោ** ប្រែថា មានកម្មជាដែនកើត បានដល់ វិបាក ។

កាលកិរិយាដែលឲ្យសម្រេចហើយ ដោយវត្ថុ មានទានជាដើម ប្រព្រឹត្តទៅ ព្រោះការដល់ព្រមនៃហេតុ ការបញ្ញត្តអ្នកធ្វើ ក៏រមែងមានក្នុងអាការត្រឹមតែជាហេតុប៉ុណ្ណោះ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **លោកមិនឃើញអ្នកសាងក្រៅអំពីហេតុ** ដូច្នេះ ។ ពិតហើយ ឈ្មោះថា **អ្នកសាង** ក៏ដោយអត្ថថា ធ្វើ ។ ភ្ជាប់សេចក្តីថា មិនឃើញអ្នកសោយផល ។ បុគ្គលល្ងង់ខ្លៅទាំងឡាយ កាលពោលថា **អ្នកសាង អ្នកសោយ** ដូច្នេះ រមែងពោលត្រឹមតែបញ្ញត្តិប៉ុណ្ណោះ ដោយអត្ថ ដោយពិតសូម្បីយ៉ាងនោះ បុគ្គលល្ងង់ខ្លៅទាំងនោះ ក៏រមែងនិយាយទៅ ដោយអំណាចការប្រកាន់ខុស ព្រោះហេតុនោះ ពាក្យរបស់បុគ្គលល្ងង់ខ្លៅនោះ មិនជាប្រមាណ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **បុគ្គលឈ្លាសទាំងឡាយ រមែងពោលត្រឹមពាក្យសន្មត** ដូច្នេះ ។

បទថា **ឯវេតំ** ប្រែថា ការឃើញយ៉ាងនោះ បានដល់ **ការឃើញប្រពៃ** អធិប្បាយថា ការឃើញមិនវិបរិត ។ ពាក្យថា **ដូចខាងដើមនៃពូជ និងដើមឈើជាដើម** សេចក្តីថា ខាងដើមនៃការបន្តរបស់ពូជ និងដើមឈើ រមែងមិនមាន ព្រោះប្រព្រឹត្តទៅក្នុងកាលមិនមានខាងដើមថា ដើមឈើកើតមកអំពីពូជ ពូជក៏កើតមកអំពីដើមឈើ

ទៀត ដូច្នេះ យ៉ាងណា ខាងដើម និងខាងចុងនៃការបន្តរបស់កម្ម និងវិបាកក៏មិនប្រាកដ ព្រោះមិនមានកាលដែលជាខាងដើមថា វិបាកមានព្រោះកម្មជាបច្ច័យ កម្មមានព្រោះវិបាកជាបច្ច័យ ក៏ដូចគ្នាដូច្នោះ ។ ដោយ **អាទិ-ស័ព្ទ** លោកអាចារ្យរមែងសង្គ្រោះពាក្យជាដើមយ៉ាងនេះថា **ស៊ុតកើតមកអំពីមាន់ មាន់ក៏មកអំពីស៊ុត សូម្បីស៊ុតក៏កើតមកអំពីមាន់ទៀត** ។ ពាក្យថា **សូម្បីក្នុងអនាគតកាល កាលសង្សារនៅមាន** សេចក្តីថា ក្នុងអតីតកាល យ៉ាងណា សូម្បីក្នុងអនាគតកាលក៏យ៉ាងនោះ កាលសង្សារដែលលោកពោលទុក ដោយពាក្យជាដើមថា **លំដាប់នៃខន្ធទាំងឡាយ** ដូច្នេះ នៅមានការមិនប្រព្រឹត្តទៅនៃកម្ម និងវិបាក ក៏នៅមើលមិនឃើញកិរិយា ដែលមិនប្រព្រឹត្តទៅនៃកម្ម និងវិបាក ក៏នៅមើលមិនឃើញ អធិប្បាយថា នៅប្រព្រឹត្តទៅនោះឯង ។

ពាក្យថា **សេចក្តីនេះ** បានដល់ ការពោលដោយពាក្យជាដើមថា **អ្នកសាងកម្មមិនមាន** ។ បទថា **អសយំវសី** ប្រែថា មិនជាសយំវសី ( មិនមានអំណាចខ្លួនឯង ) អធិប្បាយថា ធ្លាក់នៅក្នុងអំណាចអ្នកដទៃ គឺការប្រកាន់ខុសយ៉ាងមាំ ។ ពាក្យថា **ជំទាស់គ្នានឹងគ្នា** សេចក្តីថា ជំទាស់ទៅខាងក្រៅអំពីនេះ ។ម្យ៉ាងទៀត សេចក្តីថា ការឃើញជាមួយការជំទាស់គ្នា គឺខុសគ្នានឹងគ្នា ។

ឈ្មោះថា **ជ្រៅ** ព្រោះជាអារម្មណ៍របស់ញាណដែលជ្រៅ ។ ឈ្មោះថា **ល្អិត** ក៏ដូចគ្នា ។ ឈ្មោះថា **ទទេ** ព្រោះជាធម្មជាតិសូន្យចាកសត្វ និងព្រោះជាធម្មជាតិទទេចាកសភាវៈរបស់គ្នានឹងគ្នា ។ ពាក្យថា **បច្ច័យ** បានដល់ បច្ច័យនៃនាមរូប និងរមែងជាការចាក់ធ្លុះគ្រប់យ៉ាង ដោយការចាក់ធ្លុះបច្ច័យនៃនាមរូបនោះឯង ។ ពាក្យណាដែលគួរពោល ក្នុងពាក្យជាដើមថា **កម្មមិនមាននៅក្នុងវិបាក** ពាក្យនោះ ខ្ញុំពោលទុកហើយខាងដើមនោះឯង ។

លោកអាចារ្យមានបំណងធ្វើអត្ថ តាមដែលពោលទុកថា ផលទទេអំពីបច្ច័យ

ដូច្នេះ ឲ្យជាក់ច្បាស់ដោយពាក្យឧបមា ទើបពោលពាក្យជាដើមថា **ប្រៀបដូចភ្លើង មិនមាន ក្នុងព្រះអាទិត្យ** ។ បទថា **តេសំ យោគ សូរិយាទីនំ** ប្រែថា នៃវត្ថុ មានសុរិយៈជាដើមនោះ ។ បទថា **សោ យោគ អគ្គិ** ប្រែថា ភ្លើងនោះ ។ ពាក្យថា **សម្ភារៈទាំងឡាយ** គឺដោយហេតុទាំងឡាយ មានកម្ដៅជាដើម ។

លោកអាចារ្យពោលថា **ផលអាស្រ័យកម្មនោះឯង** ដូច្នេះ ដើម្បីឆ្លើយសំណួរ ដែលសួរថា បើហេតុ និងផលវៀរចាកគ្នានឹងគ្នា ផលនឹងកើតឡើងអំពីហេតុដូចម្តេច ដើម្បីសម្តែងថា មិនមែនផលនៃកម្មតែម្យ៉ាងប៉ុណ្ណោះទេ គឺវៀរចាកអ្នកធ្វើ សូម្បីធម្មជាតិទាំងអស់ក៏វៀរចាកអ្នកសាង ដូច្នេះ ទើបលោកអាចារ្យពោលគាថាថា **ន ហេត្ថ ទេវោ** ប្រែថា ក្នុងសង្សារប្បវត្តិនេះ មិនមានទេវតា ឬព្រហ្ម អ្នកសាងសង្សារ ។ ពាក្យថា **ព្រោះការរួមចូលគ្នានៃហេតុ ជាបច្ច័យ** បានដល់ ព្រោះការប្រជុំនៃហេតុជានិមិត្ត ឬព្រោះមានហេតុប្បច្ច័យជានិមិត្ត ។

ពាក្យថា **លោករមែងដឹងបានដោយអំណាចចុតិ និងបដិសន្ធិ** សេចក្តីថា លោកអាចារ្យទាំងឡាយពោលថា ឈ្មោះថា **លោករមែងដឹងបានដោយអំណាចចុតិ និងបដិសន្ធិ** ព្រោះលោកបានធ្វើការកំណត់បច្ច័យ ដោយអំណាចកម្មវដ្ដៈ និងវិបាកវដ្ដៈ ។ ឯធម៌ទាំងឡាយ ដែលទាក់ទងដោយកាលទាំង ៣ ភិក្ខុរមែងលះសេចក្តីសង្ស័យក្នុងកាលទាំង ៣ ដោយការឃើញនាមរូប ព្រមទាំងបច្ច័យ តាមន័យដែលបានពោលហើយ ដឹងបានដោយអំណាចចុតិ និងបដិសន្ធិ ក្នុងអតីតភព បច្ចុប្បន្នភព និងអនាគតភព លោកមិនមែនដឹងបាន ព្រោះមិនបានធ្វើការកំណត់យ៉ាងនោះ ដោយអំណាចធម៌ទៅតាមបទ ។ ពាក្យថា **ការដឹងរបស់លោកនោះ ជាញាតបរិញ្ញា** សេចក្តីថា លោករមែងធ្វើការកំណត់នាមរូប និងកំណត់បច្ច័យរបស់នាមរូបនោះ ដោយការដឹងណា ការដឹងនោះ របស់លោក គឺរបស់យោគី ឈ្មោះថា **ញាតបរិញ្ញា** ព្រោះ

ធ្វើពាក្យអធិប្បាយថា ជាបញ្ញាដែលមានការដឹង ដោយអំណាចការកំណត់ ដោយន័យជាដើមថា **នេះជានាម នាមមានប៉ុណ្ណេះ** និងដោយន័យជាដើមថា **នាមនោះមាន បច្ច័យនេះ មានបច្ច័យប៉ុណ្ណេះ** ដូច្នេះ ។

ឥឡូវនេះ លោកអាចារ្យមានបំណងសម្តែងអាការ ដែលជាហេតុឲ្យភិក្ខុដឹងធម៌ដែលទាក់ទងដោយកាលទាំង ៣ ដោយអំណាចចុតិ និងបដិសន្ធិ ទើបពោលពាក្យជាដើមថា **លោកដឹងយ៉ាងនេះ** ។ ដោយពាក្យនោះ លោកអាចារ្យរមែងសម្តែងថា ឈ្មោះថា **ការឆ្លងទៅកាន់ភពដទៃនៃធម៌ទាំងឡាយ** មិនមានក្នុងកាលណាមួយឡើយ ព្រោះរលត់ទៅក្នុងភពនោះៗ ឯង ។ លោកអាចារ្យមានបំណងញុំាងការមិនមានការឆ្លងទៅ នៃធម៌ទាំងឡាយនោះឯងឲ្យជាក់ច្បាស់ ដោយពាក្យឧបមា ដោយការស្វាធ្យាយ ការផឹកទឹកមន្ត ការរចនាមុខ និងអណ្តាតប្រទីប ទើបពោលពាក្យជាដើមថា **មួយ៉ាងទៀត** ដូច្នេះ ។

ពាក្យថា **ក្នុងលំដាប់នៃមនោធាតុ** សេចក្តីថា ចក្ខុវិញ្ញាណដែលបានក្នុងលំដាប់នៃកិរិយាមនោធាតុ ។ ពាក្យថា **តែចក្ខុវិញ្ញាណមិនបានមក** សេចក្តីថា តែចក្ខុវិញ្ញាណមិនបានមកអំពីកិរិយាមនោធាតុ ព្រោះចក្ខុវិញ្ញាណ មិនមានក្នុងកិរិយាមនោធាតុ ។ ពាក្យថា **ទាំងចក្ខុវិញ្ញាណមិនកើតក្នុងលំដាប់នៃមនោធាតុ ក៏មិនមែន** សេចក្តីថា សូម្បីមិនបានមកអំពីកិរិយាមនោធាតុ ទាំងចក្ខុវិញ្ញាណមិនកើតក្នុងលំដាប់អំពីកិរិយាមនោធាតុនោះ ក៏មិនមែន គឺកើតនោះឯង ព្រោះការដល់ព្រមនៃបច្ច័យ ។ ការប្រព្រឹត្តទៅនៃចិត្តក្នុងបវត្តិកាលនេះ យ៉ាងណា សន្តតិ គឺការបន្តនៃចិត្ត រមែងប្រព្រឹត្តទៅក្នុងបដិសន្ធិកាល ដូច្នោះឯង ។ បដិសន្ធិចិត្ត សូម្បីមិនបាន មកអំពីចុតិចិត្ត ឬថា មិនកើតក្នុងលំដាប់អំពីចុតិនោះ ក៏មិនមែន អធិប្បាយថា កើតនោះឯង ដោយអំណាចការដល់ព្រមនៃបច្ច័យ ។ ដោយស័ព្ទថា **សន្តិ** ក្នុងគាថានេះ លោកអាចារ្យ រមែងញុំាង

ការមិនមានការមកអំពីទីណាៗ ឲ្យជាក់ច្បាស់ ។ ពិតហើយ ការសម្ពន្ធគ្នា ជាហេតុនិងផល ព្រោះហេតុនោះ ទើបការប្រព្រឹត្តទៅនៃសការធម៌ ឈ្មោះថា **សន្តតិ** ។ ដោយហេតុនោះ ទើបលោកអាចារ្យពោលពាក្យជាដើមថា **ចិត្តដួងមុនបែកធ្លាយ** ។ ពាក្យថា **ចិត្តដួងមុន** បានដល់ ចុតិចិត្ត ។ ពាក្យថា **បែក** គឺរលត់ ។ ពាក្យថា **ចិត្តដួងក្រោយ** បានដល់ បដិសន្ធិចិត្ត ។ ពាក្យថា **តអំពីនោះ** គឺកើតក្នុងលំដាប់តអំពីចុតិចិត្តនោះឯង ។ ពិតហើយ បដិសន្ធិចិត្តដែលកើតសូម្បីឆ្ងាយ ក្នុងកាលដទៃអំពីចុតិចិត្តក្នុងកពណា លោកក៏ហៅថា កើតក្នុងលំដាប់នោះឯង ។ វត្ថុទីនៅចន្លោះចិត្តទាំង ២ នោះ ឈ្មោះថា **មិនមាន** ព្រោះមិនមានអ្វីដែលរាំងចុតិចិត្ត និងបដិសន្ធិចិត្តនោះឡើយ ។ ពាក្យថា **ការរំកិល មិនមានដល់ចិត្តទាំងពីរនោះ** ជាវេវចនៈរបស់ពាក្យថា **វត្ថុដែលនៅចន្លោះចិត្តទាំងពីរនោះមិនមាននោះឯង** ។ ពាក្យថា **អំពីចុតិចិត្តនេះ** គឺចិត្តណាមួយ មិនទៅក្នុងលំដាប់បន្ទាប់អំពីចុតិចិត្ត ។ ព្រោះថា ចុតិចិត្តនោះ ព្រមទាំងសម្បយុត្តធម៌រលត់ទៅយ៉ាងនោះៗ ឯង ។ ពាក្យថា **អំពីបដិសន្ធិចិត្ត** សេចក្តីថា អំពីបដិសន្ធិវិញ្ញាណនោះឯង **ក៏កើត គឺ កើតឡើងបាន** តាមបច្ច័យ ព្រោះហេតុនោះ លោកអាចារ្យកាលនឹងញុំាំងភាព មិនមានការជំទាស់ទៀត ឲ្យជាក់ច្បាស់ ទើបញ្ញាក់ការឃើញនាមរូប ព្រមទាំងបច្ច័យ ។

ពាក្យថា **បុគ្គលដឹងធម៌ទាំងពួង** លោកអាចារ្យពោលទុក ព្រោះធម៌ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ដែលលោកមិនបានកាន់យក ដោយស័ព្ទថា **នាមរូប** និងដោយស័ព្ទថា **បច្ចយធម៌នៃនាមរូបនោះ** មិនមាន ។ តែក្នុងពាក្យនេះ យោគាវចរភិក្ខុ មិនបានសម្រេចលោកុត្តរធម៌ ញាណដែលកំណត់បច្ច័យ ឈ្មោះថា **រមែងជាញាណដល់នូវភាពមានកម្លាំង** ព្រោះវិធីកំណត់បច្ច័យនៃខន្ធ ដែលមានអាការមិនមែនតិច ជាវិធីតាំងនៅដោយលំដាប់ ។ ឈ្មោះថា **លោកក៏លះបាន យ៉ាងល្អក្រៃលែង** ព្រោះប្រាសចាក

ការវេង្វេងក្នុងការប្រព្រឹត្តទៅនៃធម៌ ដែលនៅក្នុងកាលទាំង ៣ ។ បទថា **សា ឯវ យោគ សោឡសវិធា កង្ខា** នុ៎ះឯង ប្រែថា ការសង្ស័យ ១៦ នោះ ប៉ុណ្ណោះ ។ ព្រោះក្នុងទីនេះ លោកក៏សំដៅយកធម៌ទាំងឡាយ ចំណែកលោកិយ ដែលជាអារម្មណ៍នៃសេចក្តីសង្ស័យថា **ព្រះពុទ្ធ** ថា **ព្រះធម៌** ថា **ព្រះសង្ឃ** និង **សិក្ខា** ។ ព្រោះកិលេសទាំងឡាយ មិនអាចប្រព្រឹត្តទៅប្រារព្ធលោកុត្តរធម៌ទាំងឡាយបានឡើយ ពាក្យថា **ចំណែកខាងដើម** បានដល់ ១៥ អាយតនៈ និងធាតុចំណែកអតីត ។ ពាក្យថា **ចំណែកខាងចុង** បានដល់ ចំណែកអនាគត ។ ពាក្យថា **ទាំងចំណែកខាងដើម និងចំណែកខាងចុង** បានដល់ ទាំង ២ យ៉ាងនោះ ឬបានដល់បច្ចុប្បន្នកាល ព្រោះបច្ចុប្បន្នកាលប្រកបដោយចំណែកទាំង ២ នោះ ។ អារម្មណ៍នៃការសង្ស័យប្រការទី ៨ លោកកាន់យកដោយស័ព្ទថា **ព្រះពុទ្ធជាដើម** និងដោយស័ព្ទថា **បដិច្ចសមុប្បន្នធម៌** ក៏ត្រឹមតែជានាមរូប ដោយប្រការដូច្នេះ ចំណែកបច្ច័យនៃអារម្មណ៍របស់សេចក្តីសង្ស័យនោះ លោកកាន់យកដោយស័ព្ទថា **ឥទប្បច្ចយតា** ព្រោះហេតុនោះ កាលលះសេចក្តីសង្ស័យដែលមានវត្ថុ ១៦ ប្រការបានហើយ ការសង្ស័យដែលមានវត្ថុ ៨ ប្រការ រមែងជាធម្មជាតិមិនមានទីតាំងមាំនោះឯង ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **មិនមែនត្រឹមតែការសង្ស័យ ១៦ ប្រការនោះប៉ុណ្ណោះទេ សូម្បីការសង្ស័យ ៨ ប្រការ ។បេ។ ក៏លះបានដូចគ្នាផងដែរ** ។

ព្រោះវិចិកិច្ឆាជាធម្មជាតិតាំងនៅដូចគ្នាជាមួយទិដ្ឋិ ទិដ្ឋិកាលត្រូវកាត់ផ្តាច់ រមែងកាត់ផ្តាច់បានព្រមជាមួយវិចិកិច្ឆានោះឯង យ៉ាងណា វិចិកិច្ឆា កាលត្រូវស្ងប់រម្ងាប់ ក៏រមែងស្ងប់រម្ងាប់ទៅព្រមជាមួយទិដ្ឋិនោះឯង ដូច្នោះ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **ទិដ្ឋិ ៦២ រមែងស្ងប់ទៅ** ដូច្នេះ ។ ឯសេចក្តីសង្ស័យ មានវត្ថុ ១៦ ប្រការ ដែលប្រព្រឹត្តទៅដោយន័យជាដើមថា **យើងបានមាន បានកើតមក ហើយឬហ្ន៎** ដូច្នេះ

មានការប្រកាន់មាំអត្តាជាឧបនិស្ស័យ ហើយសេចក្តីសង្ស័យនោះឯង លោកពោល ទុកដោយជាការសង្ស័យជាដើមថា មានខាងដើមជាវត្ថុ ។ ទិដ្ឋិ ៦២ មានការប្រកាន់មាំ អត្តា ជាវត្ថុ និងសេចក្តីសង្ស័យក្នុងព្រះពុទ្ធជាដើម ជាវត្ថុ ក៏មានការតាំងនៅដូចគ្នា នឹងទិដ្ឋិនោះឯង ។ សភាវៈទាំងឡាយ ឈ្មោះថា **ធម៌** ព្រោះមានអត្ថថា **ដែលបច្ច័យ ទាំងឡាយរបស់ខ្លួនទ្រទ្រង់ទុក** ឈ្មោះថា **ឋិតិ** ព្រោះមានអត្ថថា ជាទីតាំងនៃផល ដោយភាវៈដែលមានការប្រព្រឹត្តទៅ ទាក់ទងដោយធម៌នោះ ទីតាំងនៃធម៌ទាំងឡាយ ឈ្មោះថា **ធម្មដ្ឋិតិ** បានដល់ **បច្ចយធម៌** ។ ម្យ៉ាងទៀត ពាក្យថា **ធម៌** បានដល់ **ហេតុ** ដូចក្នុងពាក្យជាដើមថា **ធម្មប្បដិសម្ភិទា** ប្រែថា ការបែកធ្លាយក្នុងហេតុ ទីតាំងនៃធម៌ បានដល់ សភាវៈ និងសភាវៈដទៃក្រៅអំពីធម៌ រមែងមិនមាន ព្រោះហេតុនោះ ទើប បច្ចយធម៌ទាំងឡាយ ជាបច្ច័យ ឈ្មោះថា **ធម្មដ្ឋិតិ** ញាណ គឺការដឹងក្នុងការតាំង នៅនៃធម៌ ឈ្មោះថា **ធម្មដ្ឋិតិញ្ញាណ** ។ ធម្មជាតិណាមួយរបស់សង្ខារទាំងឡាយ ឈ្មោះថា **សេចក្តីពិត** បានដល់ ការមិនទៀងជាដើម ឈ្មោះថា **យថាភូត** ប្រែថា តាមសេចក្តីពិត ញាណ គឺការដឹងក្នុងធម្មជាតិតាមសេចក្តីពិតនោះ ហេតុនោះ ទើប ឈ្មោះថា **យថាភូតញ្ញាណ** ។ ធម្មជាតិណា រមែងឃើញដោយប្រពៃ ហេតុនោះ ធម្មជាតិនោះ ឈ្មោះថា **សម្មាទស្សនៈ** ប្រែថា ឃើញដោយប្រពៃ ។

ពាក្យថា **អវិជ្ជាជាបច្ច័យ** សេចក្តីថា អវិជ្ជាជាបច្ច័យគួរដល់សង្ខារ ដោយ អំណាចជាហេតុប្បច្ច័យជាដើម ។ ព្រោះហេតុនោះឯង **សង្ខារទាំងឡាយ** ទើបឈ្មោះ ថា **បច្ចយុប្បន្ន** ( ផល ) ។ ពាក្យថា **ធម៌ទាំងពីរនេះ** សេចក្តីថា ព្រោះហេតុដែល អវិជ្ជាកើតមកហើយអំពីបច្ច័យ ដោយអំណាចអាសវៈជាដើម ដូច្នោះ ធម៌ទាំងពីរ គឺអវិជ្ជា សង្ខារ ទើបឈ្មោះថា **បច្ចយសមុប្បន្ន** ។ បទថា **ឥតិ** សេចក្តីប៉ុនគ្នានឹង **ឯវំ** ប្រែថា យ៉ាងនេះ ។ ពាក្យថា **បញ្ញាក្នុងការកំណត់បច្ច័យ** សេចក្តីថា បានដល់

បញ្ញាដែលប្រព្រឹត្តទៅដោយអំណាចការកំណត់កាន់យកបច្ច័យទាំងឡាយ ។ ឈ្មោះថា **ធម្មដ្ឋិតិញ្ញាណ** តាមន័យដែលពោលហើយ ។

ពាក្យថា **និមិត្ត** បានដល់ និមិត្តនៃសង្ខារ ដោយអត្ថ បានដល់ ខន្ធ ៥ ។ ពិតហើយ ខន្ធ ៥ នោះ ឈ្មោះថា **ជានិមិត្ត** ព្រោះជាទីតាំងនៃការប្រព្រឹត្តទៅរបស់ **ឃនសញ្ញា** ម្យ៉ាងទៀត ឈ្មោះថា **និមិត្ត** ព្រោះការប្រាកដដោយជាកាយរបស់ខ្លួន ។ ព្រោះអាការដែលមិនវិបរិតនៃសង្ខារទាំងឡាយ ឈ្មោះថា **របស់មិនទៀង** ។ ក្នុងសេចក្តីនោះ ភិក្ខុ **កាលឃើញថាជារបស់មិនទៀង** ព្រោះការមិនមានលេសនៃភាពជារបស់ទៀង ឈ្មោះថា **រមែងដឹងតាមសេចក្តីពិត** ។ ញាណនោះ ឈ្មោះថា **សម្មាទស្សនៈ** ព្រោះភាវៈដែលជាការប្រកាន់យ៉ាងមិនវិបរិត ។ ឯភិក្ខុអ្នកមានសេចក្តីដល់ព្រមដោយសម្មាទស្សនៈនោះ កាលយល់ន័យក្នុងអតីត និងអនាគត ដូចក្នុងបច្ចុប្បន្ន រមែងកំណត់ដឹងដោយល្អនូវខន្ធ ៥ នោះ ។

លោកអាចារ្យ កាលសម្តែងសេចក្តីប្រការនេះថា ដែលឈ្មោះថា ជារបស់មិនទៀង រមែងមានដល់វត្ថុដែលមានការកើតឡើងផង ការកើតឡើង ក៏រមែងមានដោយអំណាចបច្ច័យផង ព្រោះហេតុនោះ របស់មិនទៀង កាលសម្រេចជាគំរូ ដែលសង្ខារទាំងឡាយប្រកបដោយបច្ច័យ រមែងប្រព្រឹត្តទៅដើម្បីលះការសង្ស័យ តាមដែលពោលហើយ ទើបពោលថា **ភិក្ខុធ្វើមនសិការដោយជារបស់មិនទៀង រមែងដឹង រមែងឃើញនិមិត្តតាមសេចក្តីពិត ដោយហេតុនោះ ទើបលោកហៅថា សម្មាទស្សនៈ សង្ខារទាំងឡាយ ភិក្ខុនោះ ឃើញយ៉ាងល្អ ដោយជារបស់មិនទៀង តាមគន្លងការដឹង តាមសេចក្តីពិតនោះ សេចក្តីសង្ស័យ លោករមែងលះបានក្នុងទីនេះ** ដូច្នេះ ។ បណ្តាពាក្យទាំងនោះ ពាក្យថា **តាមគន្លងការដឹង ដែលឃើញតាមសេចក្តីពិតនោះ** បានដល់ ដោយការពិចារណាតាមធម៌ដែលឃើញហើយ ដោយប្រចក្ស ។ ពាក្យថា

ក្នុងទីនេះ បានដល់ ក្នុងធម៌ទាំងឡាយតាមដែលបានឃើញហើយ ។ ក្នុងពាក្យថា **មនសិការទៅ ដោយភាពជាទុក្ខនេះ** ក៏មានន័យនេះ ដូចគ្នា ។ ពាក្យថា **បវត្ត** បានដល់ ការប្រព្រឹត្តទៅនៃខន្ធ ដែលកម្មក្កិលេសតាក់តែង ។ ឯការប្រព្រឹត្តទៅនៃខន្ធ ដែលកម្មក្កិលេសតាក់តែងនោះ រមែងប្រាកដដោយភាពជាទុក្ខយ៉ាងក្រៃលែង ព្រោះត្រូវអភិសង្ខារ គឺកិលេសឲ្យប្រព្រឹត្តទៅហើយ អាចារ្យមួយពួកពោលថា ពាក្យថា **បវត្ត** បានដល់ ការប្រព្រឹត្តទៅនៃសង្ខារ ដោយអំណាចឥរិយាបថ មានការឈរ និងការអង្គុយជាដើម និងដោយអំណាចភាពជាទុក្ខពិតៗ ជាដើម ។ បញ្ញាដូចគ្នានោះឯង ដែលប្រព្រឹត្តទៅតាមសេចក្តីពិត ក្នុងនាមរូប ព្រមទាំងបច្ច័យទាំងឡាយ ដែលហៅថា **និមិត្ត** និង **បវត្ត** ដែលសន្មតថា ជាការបន្តខាងក្នុង និងខាងក្រៅ លោកហៅថា **យថាភូតញ្ញាណ** ខ្លះ ហៅថា **សម្មាទស្សនៈ** ខ្លះ ដោយអំណាចពាក្យបរិយាយ ហៅថា **កង្ខាវិតរណៈ** ខ្លះ ដោយការរម្ងាប់បង់នូវសេចក្តីសង្ស័យ ក្នុងធម៌ទាំងនោះ ។ ដោយប្រការដែលលោកអាចារ្យ កាលសម្តែងសេចក្តីនោះថា **ដើមឈើមានឈ្មោះថា រុក្ខោ បាទបោ តរុ** ទើបពោលពាក្យថា **យថាភូតញ្ញាណ** ឯណាក្តី ដូច្នេះជាដើម ។

ពោលដោយបរមត្ថក្នុងព្រះសាសនា អរិយផល ឈ្មោះថា **ការក្សេមនៃចិត្ត** អរិយមគ្គ ឈ្មោះថា **ទីពឹង** ឯភិក្ខុនេះសូម្បីមិនបានសម្រេចមគ្គផល ក៏ហាក់ដូចជាបានការក្សេមនៃចិត្ត និងដូចបានទីពឹង ព្រោះភាពជាអ្នកតាំងនៅក្នុងការបដិបត្តិឧបាយជាគ្រឿងសម្រេចមគ្គផលនោះ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **បុគ្គលបាននូវភាពក្សេមនៃចិត្ត ដែលបានទីពឹង** ដូច្នេះ ។ ភិក្ខុចម្រើនវិបស្សនា អ្នកមានភាពបរិសុទ្ធដោយការឆ្លងសេចក្តីសង្ស័យ ដែលមិនទាន់លះបាន កាលមិនទាន់ត្រាស់ដឹងក្រៃលែងឡើងទៅ ព្រោះជាអ្នកប្រកបដោយសីល សមាធិ និងបញ្ញា ដែលជា

លោកិយ ក៏ជាបុគ្គលមានសុគតិជាទីទៅខាងមុខ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **មានគតិពិតប្រាកដ** ។ ព្រោះហេតុនោះឯង ទើបឈ្មោះថា **ជាចូឡសោតាបន្ន** ។ ព្រោះថា សោតាបន្ន ជាអ្នកមានអបាយ ទុគ្គតិ វិនិបាតអស់ ហើយដូច្នេះឯង ។

ម្យ៉ាងទៀត ឈ្មោះថា **បាននូវការក្សេមនៃចិត្ត** ដោយការសម្រេចទិដ្ឋិវិសុទ្ធិ ។ ព្រោះថា ភិក្ខុកំណត់ធម៌ទាំងឡាយ មានខន្ធជាដើម ដោយកំណត់នាមរូប ដោយកិច្ចរបស់ខ្លួនតាមសភាវធម៌ រមែងជាបុគ្គលបានការក្សេមនៃចិត្ត ដោយការបានបីតិ និងបាមោជ្ជ អាស្រ័យធម៌ក្នុងព្រះសាសនា ។ ឈ្មោះថា **បានទីពឹង** ក៏ដោយការសម្រេចកង្ខាវិតរណវិសុទ្ធិ ។ ព្រោះភិក្ខុដែលមានបន្ទា គឺទិដ្ឋិ ដែលត្រូវដកហើយ មានវាទៈថា មិនមានហេតុ និងថា មានហេតុប្រាសចាកភាពស្មើ ដែលត្រូវទម្លាយហើយ ដោយការឃើញនាមរូប ព្រមទាំងបច្ច័យ ដឹងត្រឹមតែសភាវធម៌តាមបច្ច័យទាំងឡាយប៉ុណ្ណោះ ដែលសមគួរដល់ខ្លួន មានសទ្ធាតាំងមាំក្នុងសាសនា រមែងជាអ្នកឈ្មោះថា **បានទីពឹង** ។ ភិក្ខុដឹងច្បាស់ហើយនូវទុក្ខសច្ច ដោយការកំណត់នាមរូប នូវសមុទយសច្ច ដោយធម្មដ្ឋិតិញ្ញាណ និងមគ្គសច្ច ដោយវិធីធ្វើមនសិការជារបស់មិនទៀងជាដើម ដោយចំណែកខាងក្រោយធម្មដ្ឋិតិញ្ញាណនោះឯង ឃើញភាពជាទុក្ខនៃបវត្តិ ( ខន្ធ ) ដោយបញ្ញាដ៏ក្រៃលែង រមែងជាបុគ្គលមិនគួរកើតក្នុងអបាយទាំងឡាយ និងជាបុគ្គលគួរកើតក្នុងភូមិនៃព្រះសោតាបន្ន ព្រោះជាអ្នកចាក់ធ្លុះអរិយសច្ច ៤ ដោយញាណដែលជាលោកិយនោះឯង ដោយជាបុគ្គលមានអធ្យាស្រ័យបង្អោនទៅតែម្យ៉ាង ក្នុងនិរោធដែលមិនទាន់ប្រព្រឹត្តទៅ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **មានគតិពិតប្រាកដ** ។ ដោយហេតុនោះ ទើបលោកអាចារ្យពោលថា បានឈ្មោះថា **ជាចូឡសោតាបន្ន** ។

ពាក្យថា **ព្រោះហេតុនោះ** សេចក្ដីថា យថាភូតញ្ញាណនេះ មានអានិសង្សច្រើនយ៉ាងនេះ ។ ពាក្យថា **គ្រប់កាល** គឺសព្វកាលទាំងពួង បានដល់ ទាំងយប់ និងទាំង

ថ្ងៃ ។ បទថា **សព្វសោ** ប្រែថា ដោយប្រការទាំងពួង ដោយអំណាចការកំណត់ហេតុ កើតឡើងជាដើម ។

ពណ៌នាកង្ខាវិតរណវិសុទ្ធិនិទ្ទេស ចប់

ពណ៌នាបរិច្ឆេទទី ១៩ ចប់ហើយ

ដោយប្រការ ដូច្នេះ ។

អាស្រមព្រះគន្ធកុដិ ថ្ងៃ ៨ កើត ខែពិសាខ ព.ស. ២៥៥៥

ផ្សព្វផ្សាយដោយសមាគមធម្មទានអរិយវង្សយន៍សុផាត

# ឈ្មោះសប្បុរសប្រគេនសម្ភារៈ មានកុំព្យូទ័រជាដើម ក្នុងកិច្ចការងារជាធម្មទាន

❋ឧបាសិកា ហម យិម

ឧបាសក អ៊ឹង ប៊ុនហួរ ឧបាសិកា បួ ម៉ាឡា ព្រមទាំងកូនចៅ

ឧបាសក បួ ស៊ីថូ ឧបាសិកា ថៃ ស៊ីវន ព្រមទាំងបុត្រ

ឧបាសិកា បួ ចន្ទា និងស្វាមី ព្រមទាំងបុត្រ

កញ្ញា បួ ដាវី កញ្ញា អ៊ឹង មុយហៀក

❋លោកម្ចាស់ សោម ហួន

លោកគ្រូធម្មាចារ្យ អឿ សៅ ( ទក្ខប្បញ្ញោ )

ឧបាសក ប៊ូ ហោនាង ឧបាសិកា អ៊ឹង រិទ្ធារី ព្រមទាំងបុត្រធីតា

ឧបាសក យឹម សំណាង ឧបាសិកា យឹម ច័ន្ទបូ(LAURA) +បុត្រធីតា

ឧបាសិកា លីប៊ុលីន ស៊ីមប៊ូ កូនក្មួយ ប៊ុន ឡុង,សេង ឈិនដានេត

លោកអាចារ្យ ផាត សារឿយ ឧបាសិកា រ៉ាត់ អម +បុត្រធីតា

ឧបាសក សៅ ហ៊ាន ឧបាសិកា មាស មូនីកា +បុត្រធីតា

ឧបាសក សួស ចាន់ធី ឧបាសិកា ឡុង សេង +បុត្រធីតា

ឧបាសក ម៉ៅ វង្ស ឧបាសិកា ឆាន់ កាន់ជួន +បុត្រធីតា

ឧបាសក ម៉ៅ ផុន+សាបូរ៉ាក់ សុខ( SABOREAK SOK )

ឧបាសក យក់ ស៊ីមូរ៉ា ឧបាសិកា តាន់ រ៉ាណា

ឧបាសក អ៊ឹង រិទ្ធី ឧបាសិកា ជូធារី

ឧបាសក មាស សារ៉េត

ឧបាសក លឹម ស៊ាង

ឧបាសក ឈុន គឹមអេង

❋ឧបាសក ឈុំ គឹម គឹមហោ ឧបាសិកា គួ ប៊ុនគាង

ឧបាសក សោម សាខន ឧបាសិកា ឈុំ គីមហួយ

ឧបាសក សារុន សេងហួរ ឧបាសិកា ឈុំ សុរីណែត

ឧបាសក ឈុំ សុរិណា (ហៅប៊ុន ឃីម) ឧបាសិកា ណៃ គឹមហុង

ឧបាសក ឈុំ សុបូរី ឧបាសិកា កើត កុលាប

❋ឧបាសិកា ច័ន្ទ បុប្ផាណា

ឧបាសក សួន សុធីរ

ឧបាសិកា សួន កល្យាណ

ឧបាសិកា សួន ចរណៃ

ឧបាសិកា សួន កញ្ញារ័ត្ន

❋ឧបាសិកា ម៉ក់ នាង ព្រមទាំងកូនចៅ

ឧបាសក តាំង គឹមឲៃ និងភរិយា ព្រមទាំងកូនចៅ

ឧបាសក តាំង គឹមលន់ និងភរិយា ព្រមទាំងកូនចៅ

ឧបាសិកា តាំង លាងនិម និងស្វាមី ព្រមទាំងកូនចៅ

❋ពុទ្ធសាសនបណ្ឌិត្យ អ្នកគ្រូ ម៉ម សុខហេង+ពុទ្ធបរិស័ទ+សៀមរាប

ឧបាសក រស់ សុខ ឧបាសិកា សោម ផាន

ឧបាសិកា នួង ឈុំ សោភ័ណ រស្មី

ឧបាសក ជោគ ឌី ឧបាសិកា ជុះ ចំណាន

ឧបាសិកា វិញ ពូន

❋ឧបាសក ឡាំ ជៀន ឧបាសិកា ស៊ីន ចន្ថា
ឧបាសក លឹម សេងយូ ឧបាសិកា ឡាំ ចាន់សុភី
ឧបាសក ឡាំ ចាន់ណា ឧបាសិកា ទុច ចាន់សាក់គ្រីយ៉ា
ឧបាសក ឡាំ ដាវណ្ណ ឧបាសិកា ឡាំ ចាន់រ៉ាវី
❋ឧបាសក ជុំ លាង ឧបាសិកា ចៀម អ៊ូន ព្រមទាំងបុត្រ
ញោម ឥន្ទ្ទីនិងជូ ញោម ហាន ញោម រ៉ែន ញោម ភ័ណ្ឌ ញោម
សុមនា ញោម ជោត ញោម មាស សុភា ញោម ឡៃ លី កញ្ញា
នា ញោម ឆាង ញោម ជីង ឡេង ញោម អៀម ញោម កួង
ញោម អុំភា ញោម សុភា ញោម វល័ក្ខ ញោម ធាលី លីណា
ញោម ថាក ញោម ផារិន ញោម ឈឿន ញោម ឡាង ញោម
ស៊ិន ញោម ភាព សារឿន ញោម ហ៊ន ញោម ប៊ូ សៀកលីវ
ញោម យក់ វ៉ាន់ថា ។
❋ឧបាសិកា អ៊ុន ខាត់ណា ឧបាសិកា អ៊ុន ញ៉ាណា ឧបាសក អ៊ុន សេរី
លោក ជែង ស្មី និងអ្នកស្រី ជុង កុយយ៉ា ព្រមទាំងបុត្រ
❋ឧបាសក អ៊ឹង ហ្គេចឡេង ឧបាសិកា តាំង ប៉ោជីង ព្រមទាំងបុត្រ
លោក ឆៃ ហេង អ្នកស្រី អ៊ឹង ស៊ីវគៀង ព្រមទាំងបុត្រ
លោក ភួ ពុយ អ្នកស្រី អ៊ឹង ណាងពិន ព្រមទាំងបុត្រ
លោក អ៊ឹង វណ្ណម៉ៅ អ្នកស្រី ហេង ហ៊ុយទៀង ព្រមទាំងបុត្រ
លោក ប៊ី ទី អ្នកស្រី តាំង ប៉ោគិម ព្រមទាំងបុត្រ
ឧបាសិកា ជា នាង និងស្វាមី ព្រមទាំងបុត្រ
❋ឧបាសិកា ង៉ែត យូអេង ព្រមទាំងបុត្រ

ឧបាសិកា គង់ ង៉ោ និងស្វាមី ព្រមទាំងបុត្រ

ឧបាសិកា ច័ន្ទនី និងស្វាមី ព្រមទាំងបុត្រ

❋ឧបាសិកា សាម៉ុល គឹមធន និងអ្នកម្ដាយ

ឧបាសិកា គី វណ្ណហាក់ ព្រមទាំងបុត្រ

លោក សេង យុវនាថ ឧបាសិកា គុជ ឡាំងអេង

ឧបាសិកា ឈន សុភនី ឧបាសក ជីវ និងភរិយា

ឧបាសក សុខ សំ និងភរិយា ព្រមទាំងបុត្រ

ឧបាសក នុត កុសល និងភរិយា ព្រមទាំងបុត្រ

ឧបាសិកា អឿន ភី + អ៊ុំ សុភាព + ឈិត ស្រស់ + សឹម ឡាយ

ញោម ហ៊ុ ជាង + ជាមុយហាង + គុយ លឹម + សេង មុយនី

ញោម ចៅ ជីវ ស៊ុយលៀប+ប៉ៃ អេង+គឹម ធី+ខៀវ វ៉ៃន+ គឹម

ញោម នឿង+យាយ ធឹង+គួង កាង+សើន គា+សឿង+គឹម អាង

ញោម សេង ឆេង+ផាន់ វ៉ាន់+យាយ រុ+ឡាំម៉ាលី+ជាន សុផាត

យាយ ម៉ៅ + ពៅ + ឈួន+ ក. កាវ៉ាឡែន+ ហ៊ុង+ ប៉ៃ ង៉ា+ រី រុត្ន

ញោមអ្នកគ្រូ វ៉ាន់ + យុវសិស្ស អ៊ុំ រតនា + សាមណោរ អ៊ុំ វីរៈ

ញោមប៉ៃ ង៉ាថ្មគោល+អ្នកស្រី លេង យ៉ុង+តី លី+នាង ឈៀត

ញោម ហ៊ុង+នាង មឿន+អូន ប៉ុច+ ឡាត វ៉ាន់យិន+ ម៉ម សុខហេង

ញោម គឹម ឡេង+ តាំង វេន+ យុន+ យាយ ធុច + យាយ យន

ញោម ហ៊ន សឹម ញោម អឿន ភី+វ៉ាន់ ស៊ុនឡាយ+ផល្លី+សុវ៉ាមី

ញោម ឡុង សាវី+ជា សុខហ៊ាង+គុយ លឹម+សេង ទូច+ស៊ីវ ទី

ញោម ណោ ហ្គេចណៃ+វ៉ាន់ សុផានី+សា វឿន+សំ គី+ចាន់ ណារ៉ា

ញោម ធារ៉ា+យឿត និងស្វាមី+ហួត អេង+អាវ សុវណ្ណី+ណា ស៊ី

ញោម យាយ នៅ+ឈុន គាវ+ យាយ ឌី+ សំ វ៉ាន់នី+ គីម អ៊ី

ញោម អៀប សាន្ទួន+ យាយ ហឿន+យាយ ឡាំ+កេន សេងមុំ

ស ខាន់ថង+ស៊ី ណាត+យឿន+ចាន់ នី+ផន សារ៉ែន+កោ ហុង ។

## នាមពុទ្ធបរិស័ទនៅសហរដ្ឋអាមេរិកមានសទ្ធាជ្រះថ្លា ជួយឧបត្ថម្ភប្រាក់ប្រចាំខែ

លោកម្ចាស់ សោម ហួន

លោកគ្រូធម្មបណ្ឌិត ( ទក្ខប្បញ្ញោ ) អឿ សៅ

| | |
|---|---|
| ឧបាសិកា ធីក ស្រ៊ិន | ព្រមទាំងកូនប្រុស អ៊ឹង រិទ្ធី និងភរិយា |
| ឧបាសក ប៊ូហោ នាង | ឧបាសិកា អ៊ឹង រិទ្ធារី ព្រមទាំងបុត្រធីតា |
| ឧបាសក យេម សំណាង | ឧបាសិកា យេម ឡូវ៉ា ព្រមទាំងបុត្រ |
| ឧបាសក សៅ ហ៊ាន | ឧបាសិកា មាស ម៉ូនីកា ព្រមទាំងបុត្រ |
| ឧបាសក ឈៀងសារឿន | ឧបាសិកា ឈុំ ធដា ព្រមទាំងបុត្រធីតា |
| ឧបាសក ម៉ៅ វង្ស | ឧបាសិកា ឆាន់ កាន់ដួង ព្រមទាំងបុត្រ |
| ឧបាសក និន ហាក់ | ឧបាសិកា លុយ ចាន់ថន ព្រមទាំងបុត្រ |
| ឧបាសិកា មុី ចាន់រ៉ាវី | ព្រមទាំងបុត្រធីតា |
| ឧបាសិកា យ៉ក់ ស៊ីមូរ៉ា | ព្រមទាំងបុត្រ |
| ឧបាសិកា វ៉ាន់ចាន់ | ព្រមទាំងបុត្រធីតា |
| ឧបាសិកា ខៀវ ណាត | ព្រមទាំងបុត្រធីតា |

## នាមពុទ្ធបរិស័ទនៅសហរដ្ឋអាមេរិកមានសទ្ធាជ្រះថ្លា ជួយឧបត្ថម្ភប្រាក់ប្រចាំខែ

ឧបាសក ធាយ អ៊ីវស៊ាង ឧបាសិកា ហុង គឹមសែ កូន+ចៅ
ឧបាសិកា យូ ស៊ាងនទ្ទលី ព្រមទាំងកូនចៅ

## នាមពុទ្ធបរិស័ទនៅអូស្ត្រាលីមានសទ្ធាជ្រះថ្លា ជួយឧបត្ថម្ភប្រាក់ប្រចាំខែ

ឧបាសក ប៊ុន ហេង — ឧបាសិកា ជុំ សុខុម
ឧបាសិកា ហេង ស្រីជា — ឧបាសិកា ហេង ស្រីចន្ទ
ឧបាសិកា ហេង គន្ធា — ឧបាសក ហេង សុកត្រៃ

## នាមពុទ្ធបរិស័ទនៅខេត្តបាត់ដំបងមានសទ្ធាជ្រះថ្លា ជួយឧបត្ថម្ភប្រាក់ប្រចាំខែ

ឧបាសក ឈុំ គឹមហោ ឧបាសិកា គួ ប៊ុនគាង ព្រមទាំងកូនចៅ
ឧបាសក សោម សាខន ឧបាសិកា ឈុំ គីមហួយ ព្រមទាំងកូន
ឧបាសក អ៊ីង ហ្គិចឡេង ឧបាសិកា តាំង ប៉េងជីង ព្រមទាំងកូនចៅ
ឧបាសក វៀម ឈឺន ឧបាសិកា ប៊ូ ម៉ុន ព្រមទាំងកូនចៅ
ឧបាសក ញ៉ែម មឿន ឧបាសិកា វៀម ថុល ព្រមទាំងកូនចៅ
ឧបាសក អ៊ីង ប៊ុនហួរ ឧបាសិកា បួ ម៉ាឡា ព្រមទាំងកូនចៅ
ឧបាសក នាង រ៉ា ឧបាសិកា តែម ធារីម ព្រមទាំងកូនចៅ
ឧបាសក សៅ ស៊ុទ្ធរា ឧបាសិកា ប៊ុន មុំ ព្រមទាំងកូនចៅ

ឧបាសក ណូ ស្វែង ឧបាសិកា សោម គឹមលួន ព្រមទាំងកូនចៅ

ឧបាសិកា ងិន យ៉ុន ឧបាសិកា សួស សុខា ព្រមទាំងកូនចៅ

ឧបាសិកា សោម គឹមលឿម និងស្វាមី ព្រមទាំងកូនចៅ

ឧបាសិកា គឹម ធវី និងស្វាមី ព្រមទាំងកូនចៅ

ឧបាសិកា ទាវ គឹមយក់ ឧបាសិកា អ៊ឹម គឹមជីវ

ឧបាសិកា គី វណ្ណហាក់ ឧបាសិកា ឡាំ ម៉ាលី

ឧបាសិកា ហួត អេង ឧបាសិកា ឡេា សាយហ៊ួច

ឧបាសិកា ង៉ែត យូអេង ព្រមទាំងកូនក្មួយ

ឧបាសិកា ហោ ភាព ព្រមទាំងកូនក្មួយ

ឧបាសិកា អ៊ុក នៅ ព្រមទាំងបុត្រ

ឧបាសិកា សៀង ព្រមទាំងបុត្រ

## នាមពុទ្ធបរិស័ទនៅស្ទឹងមានជ័យភ្នំពេញមានសទ្ធាជ្រះថ្លា ជួយឧបត្ថម្ភប្រាក់ប្រចាំខែ

ឧបាសិកា ឆេង ស៊ីម ព្រមទាំងបុត្រ ធីតា និងចៅ

លោក លី ហុង អ្នកស្រី ជាណារី ព្រមទាំងបុត្រ ធីតា

លោក ផូ ចាន់ថន អ្នកស្រី ជា ណារី ព្រមទាំងបុត្រ ធីតា

លោក លីម ចាន់ឌី អ្នកស្រី ទេព ចិន្តា ព្រមទាំងបុត្រ ធីតា

កញ្ញា ហុង លីដា

លោក ហុង សុវណ្ណតារា អ្នកស្រី លីម ចាន់មុនីរ័ត្ន ព្រមទាំងបុត្រ

ឧបាសក ហុង សុវណ្ណារិទ្ធ

ឧបាសក ហុង សុវណ្ណារ៉េត

លោក ហុង ប៊ុនឡុង

ឧបាសក ហ៊ិន ហេងគង់ ឧបាសិកា ទូច សារុន ព្រមទាំងកូនចៅ

ឧបាសិកា ធុយ ឈីវអួន ព្រមទាំងកូនចៅ

ឧបាសក យ៉ែម យ៉ន ឧបាសិកា យ៉ង់ ទូច ព្រមទាំងកូនចៅ

ឧបាសក មិន ម៉ាង ឧបាសិកា ឈិន គីមហ៊ាន ព្រមទាំងកូនចៅ

ឧបាសិកា ជា សុផល ព្រមទាំងកូនចៅ

ឧបាសិកា មៀច យ៉ន ព្រមទាំងកូនចៅ

ឧបាសិកា មុំ សុន ព្រមទាំងកូនចៅ

លោក លន់ វ៉ាន់ថា អ្នកស្រី មុំ ដាន់ ព្រមទាំងបុត្រ ធីតា

លោក ចាប សោភ័ត អ្នកស្រី មុំ ដា ព្រមទាំងបុត្រ ធីតា

ឧបាសិកា ប៉ោ យេកលៀង ព្រមទាំងបុត្រ ធីតា និងចៅ

លោក រស់ ប៊ុនឡេង អ្នកស្រី ឡេង ស៊ីនី ព្រមទាំងបុត្រ ធីតា

ឧបាសិកា ឈួន សុ ព្រមទាំងកូនចៅ

ឧបាសិកា ថ្វាង តាំងគៀន ព្រមទាំងកូនចៅ

ឧបាសិកា ប៉ែន នាង ព្រមទាំងកូនចៅ

ឧបាសិកា អៀង នីម និងស្វាមី ព្រមទាំងកូនចៅ

ឧបាសិកា ហ៊ិន ដារ៉ុង ព្រមទាំងកូនចៅ

ឧបាសិកា គឹម សេង ព្រមទាំងកូនចៅ

ឧបាសិកា ហួយ ជន ព្រមទាំងកូនចៅ

ឧបាសិកា រ័ត្ន សុផល ព្រមទាំងកូនចៅ

អ្នកស្រី ជុន បូណ៌មី និងស្វាមី ព្រមទាំងបុត្រ

ឧបាសិកា ជា ព្រមទាំងកូនចៅ

ឧបាសិកា គឹម អាន់ ព្រមទាំងកូនចៅ

ឧបាសិកា ជាវ ស៊ីយន ព្រមទាំងកូនចៅ

លោក កេត ចាន់តារា

លោក កេត សំបូរ និងកុមារី សុជាតា

ឧបាសិកា ជា វួចទៀង ព្រមទាំងកូនចៅ

ឧបាសក ជឹ សុខអៀម ឧបាសិកា តាំង ស៊ូអេង ព្រមទាំងកូនចៅ

ឧបាសិកា តាំង ស៊ូហៀង ព្រមទាំងកូនចៅ

ឧបាសិកា ជឹ ញ៉ៅ ព្រមទាំងកូនចៅ

ឧបាសិកា ខៀវ សុធី ហៅ អ៊ំម៉ៅ ព្រមទាំងកូនចៅ

ឧបាសិកា ទូច ព្រមទាំងកូនចៅ

ឧបាសក ឡាយ ឧបាសិកា លន់ ព្រមទាំងកូនចៅ

ឧបាសិកា ជាវ ហ៊ិន ព្រមទាំងកូនចៅ

ឧបាសិកា មិល មម ព្រមទាំងកូនចៅ

ឧបាសក រស់ ស្រេង ឧបាសិកា ឡា ហ៊ុយឡេង ព្រមទាំងកូនចៅ

ឧបាសិកា ឡា ស៊ីវឡេង ព្រមទាំងកូនចៅ

ឧបាសិកា គី ប៊ួយ ព្រមទាំងកូនចៅ

លោក យឹម សារ៉ាវិទ្ធ អ្នកស្រី រស់ ចិន្តា ព្រមទាំងបុត្រ

កុមារា យាន ពិសិដ្ឋ

ឧបាសិកា យន សាក ព្រមទាំងកូនចៅ

ឧបាសិកា ហោ យិចឡាំង ព្រមទាំងកូនចៅ

ឧបាសិកា ហ៊ុន ចាន់ថា ព្រមទាំងកូនចៅ

ឧបាសិកា ជី ជុន ព្រមទាំងកូនចៅ

ឧបាសិកា ស៊ិន ឡាច ព្រមទាំងកូនចៅ

ឧបាសក ប៊ុន បួន ឧបាសិកា ឃុត សួរ ព្រមទាំងកូនចៅ

លោក ផាន សុបិន អ្នកស្រី សំ សុវណ្ណមល្លិកា ព្រមទាំងបុត្រ

បងស្រី ណៅ សុភី និងប្អូនស្រី ណៅ សុផល

ឧបាសិកា ឈឹន សុន ព្រមទាំងកូនចៅ

លោក ម៉ាន់ រិទ្ធី អ្នកស្រី អួន សារ៉េត ព្រមទាំងបុត្រ

លោក ឱម ឡូត អ្នកស្រី ស៊ុំ ស្រីពៅ ព្រមទាំងបុត្រ

លោក ម៉ាន់ សារឿន អ្នកស្រី ម៉ម សុធា ព្រមទាំងបុត្រ

លោក ស៊ឹម សារ៉ាន់ អ្នកស្រី លី សុខរ៉េត ព្រមទាំងបុត្រ

ឧបាសក ទិត្យ លី ឧបាសិកា ហេងវណ្ណា ព្រមទាំងកូនចៅ

ឧបាសិកា ថោង គឹមលន់ ព្រមទាំងកូនចៅ

ឧបាសិកា ប៉ូ ប៉ុក ព្រមទាំងកូនចៅ

ឧបាសិកា ប៉េ សារ៉ា ឧបាសក ម៉ឺ ធារី ឧបាសិកា ម៉ៅ ណារី ព្រមទាំងកូនចៅ

ឧបាសក ប៉ៃ ស៊ីថា ឧបាសិកា ង៉ួន សាលីន ព្រមទាំងកូនចៅ

ឧបាសិកា ប៉ូច សាមុត ព្រមទាំងកូនចៅ

ឧបាសក សៅ ម៉េង ឧបាសិកា ថោង វង្ស ព្រមទាំងកូនចៅ

ឧបាសិកា ថោង រ៉េត ព្រមទាំងកូនចៅ

ឧបាសិកា សេក ម៉ាន ព្រមទាំងកូនចៅ

ឧបាសិកា ច័ន្ទ សោភ័ណ្ឌ

ឧបាសក ជូ បូរិន ឧបាសិកា ហែម យ៉ានី ព្រមទាំងកូនចៅ

ឧបាសក ឃោក ម៉ាន ឧបាសិកា ផូ ឡា ព្រមទាំងកូនចៅ

ឧបាសក ហាន គង់ ឧបាសិកា តេង លីគាង ព្រមទាំងកូនចៅ

ឧបាសិកា ឱម សុផាត ព្រមទាំងកូនចៅ

ឧបាសិកា ម៉ៅ សុផានី ព្រមទាំងកូនចៅ

លោក លឹម លី អ្នកស្រី ជាវ ប៊ួយ ព្រមទាំងបុត្រ

ឧបាសិកា សោម សូត្រ ព្រមទាំងកូនចៅ

ឧបាសិកា អ៊ុយ សុខុន និងកូន ឈុន ពុធធារី ព្រមទាំងកូនចៅ

## នាមពុទ្ធបរិស័ទនៅភ្នំពេញមានសទ្ធាជ្រះថ្លា ជួយឧបត្ថម្ភប្រាក់ប្រចាំខែ

ឧបាសក ហុក តាំងអ៊ន់ ឧបាសិកា ជួន ស៊ីមយន់ ព្រមទាំងកូនចៅ

ឧបាសិកា យិន មួយឡាង ឧបាសិកា យិន មួយហួ ព្រមទាំងកូនចៅ

ឧបាសក អ៊ុក សំណាង ឧបាសិកា ប៉ល់ ធីតា ព្រមទាំងកូនចៅ

ឧបាសិកា កាំង ប៉ោះទៀង និងស្វាមី ព្រមទាំងកូនចៅ

ឧបាសិកា យ៉ា សុខគីម ព្រមទាំងកូនចៅ

ឧបាសិកា តឹក អេងគី ព្រមទាំងកូនចៅ

ឧបាសិកា ទី សុធី +បុត្រ ហែម តុលា

## នាមពុទ្ធបរិស័ទនៅស្រុកថ្មគោលមានសទ្ធាជ្រះថ្លា ជួយឧបត្ថម្ភប្រាក់ប្រចាំខែ

ឧបាសក តាំង ម៉េង ឧបាសិកា លី ហ៊ុយស៊ីម ព្រមទាំងកូនចៅ

ឧបាសក លី ប៊ុនយូរ ឧបាសិកា យ៉ាន ស៊ុ ព្រមទាំងកូនចៅ

លោក លី ប៊ុនហាក់ អ្នកស្រី តាំង ស៊ីវទៀង ព្រមទាំងបុត្រ

## នាមពុទ្ធបរិស័ទរួមមានឧបការៈក្នុងការខារធម្មទាន

| | |
|---|---|
| ១- ឧបាសក ប៉េង តាំងហៃ | ឧបាសិកា ហ៊ួ គីមហៀក |
| ២- ឧបាសក ស្រេង ស្រ៊ាង | ឧបាសិកា គិម ចន្ថា |
| ៣- ឧបាសក ឡាយ សុខុម | ឧបាសិកា គី គីមហាប់ |
| ៤- ឧបាសិកា ប៊ូ ម៉ាឡា | ឧបាសក បញ្ញា |
| ៥- ឧបាសិកា ង៉ែង យូអេង | ឧបាសិកា មាស ម៉ូនីកា |
| ៦- ឧបាសក លឹម ខូង | ឧបាសិកា កែវ អុន |
| ៧- ឧបាសិកា កែវ កល្យាណ | ឧបាសិកា ឡឹក ពេញចិត្ត |
| ៨- ឧបាសិកា សឺន ចន្ថា | លោក ឡាំ ដាវណ្ណ |
| ៩- ឧបាសិកា គួ ប៊ុនគាង | ឧបាសិកា ឈុំ គីមហួយ |
| ១០- ឧបាសិកា នេត្រ នរិទ្ធ | ឧបាសិកា តាំង ប៉ោងជីង ( ហៅ ទន់ ) |
| ១១-ឧបាសិកា ឱម លក្ខណា | ឧបាសិកា ហេង ច័ន្ទបុញ្ញវត្តី |
| ១២-ឧបាសិកា គី យក់បួយ | ឧបាសិកា ឈុន ណាត |
| ១៣-ឧបាសិកា អ៊ុង រិទ្ធារី | ឧបាសិកា សៀក ឆាយគីម |
| ១៤-ឧបាសិកា វៀម ថុល | ឧបាសិកា ម៉ៅ នី |

១៥-ឧបាសិកា សន ឈៀត ឧបាសក ឡាន សុខុម
១៦-ឧបាសិកា គី វណ្ណហាក់ ឧបាសិកា ប៉ុន ណម
១៧-ឧបាសិកា ស្នួន កល្យាណ ឧបាសិកា កួង កក្តី
១៨-ឧបាសក អ៊ឹង វ៉ៃយ៉ា ឧបាសក កុយ សាមន
១៩-ឧបាសក ហុង សុវណ្ណារិទ្ធ ឧបាសក ហុង សុវណ្ណារ៉េត

តម្លៃបោះពុម្ពក្នុង ១ ក្បាល ២$ × ១០០០ ក្បាល = ២០០០ $

ខ្ញុំព្រះករុណា អាត្មាភាព មានបំណងនឹងបោះពុម្ពសៀវភៅព្រះធម៌ជាច្រើនមុខទៀត ដើម្បីចែកជាធម្មទាន បើញាតិញោមពុទ្ធបរិស័ទ មានបំណងចង់ចូលរួមបោះពុម្ពសៀវភៅជាធម្មទាននោះ សូមទំនាក់ទំនងតាមរយៈលេខទូរស័ព្ទនេះ ០៧៧ ៦៦ ៦៦ ៣៨, ០៨៨៨ ៧៧ ៩៩ ៦៦, ០១២ ៣០៥ ៧៦៦ ចំពោះសៀវភៅដែលត្រូវបោះពុម្ពនោះ ដូចមានខាងក្រោមនេះ គឺ

**-ជីវប្រវត្តិពុទ្ធឧបាសិកា** មាន ៤ ភាគ ដែលជាភាគបញ្ចប់ ហើយសព្វថ្ងៃនេះក៏បានធ្វើចប់រួចអស់ហើយដែរ ទាំង ៤ ភាគ នៅតែមានការបោះពុម្ពជាបន្តបន្ទាប់ទៀតតែប៉ុណ្ណោះ ។

**-វចនានុក្រមព្រះអភិធម្ម ៧ គម្ពីរ** សព្វថ្ងៃនេះ បានធ្វើសម្រេចជាស្ថាពរហើយ គឺវាយកុំព្យូទ័ររួចជាស្រេច ដែលមានកម្រាស់ រហូតទៅដល់ ៨៣៣ ទំព័រ ។

**-គម្ពីរអភិធម្មត្ថសង្គហៈ** និង **វិភាវិនីដីកា** សព្វថ្ងៃនេះ បានធ្វើសម្រេចជាស្ថាពរហើយ គឺវាយកុំព្យូទ័ររួចជាស្រេច ដែលមានកម្រាស់ រហូតទៅដល់ ៦៥០ ទំព័រជាង ។

**-អភិធម្មត្ថសង្គហៈ** និង **បរមត្ថទីបនីដីកា** សព្វថ្ងៃនេះ បានធ្វើសម្រេចជាស្ថាពរហើយ គឺវាយកុំព្យូទ័ររួចជាស្រេច ដែលមានកម្រាស់រហូតទៅដល់ ៩៨៩ ទំព័រជាង ។

**-គម្ពីរអភិធម្មាវតា** សព្វថ្ងៃនេះបានធ្វើសម្រេចជាស្ថាពរហើយ គឺវាយកុំព្យូទ័ររួចជាស្រេច ដែលមានកម្រាស់រហូតទៅដល់ ៥៩៧ ទំព័រ ។

**-មិលិន្ទបញ្ហា** សព្វថ្ងៃនេះ បានធ្វើសម្រេចជាស្ថាពរហើយ គឺវាយកុំព្យូទ័ររួចជាស្រេច ដែលមានកម្រាស់រហូតទៅដល់ ៥០០ ទំព័រ ។

**-ខ្ញុំព្រះករុណា អាត្មាភាព** មានបំណងនឹងរាបចំធ្វើ គម្ពីរព្រះត្រៃបិដក និងគម្ពីរព្រះអដ្ឋកថា បញ្ចូលជាមួយគ្នា ដោយដាក់ព្រះត្រៃបិដកហើយ ដាក់ព្រះអដ្ឋកថាពីខាងក្រោមព្រះត្រៃបិដក ក្នុងការបញ្ចូលគម្ពីរព្រះត្រៃបិដក និងគម្ពីរព្រះអដ្ឋកថាជាមួយគ្នានោះព្រះត្រៃបិដកយកតាមបិដកខ្មែរយើង ដែលមាន ១១០ ក្បាល ។

**-ព្រះត្រៃបិដកខ្មែរយើងដែលមាន ១១០ ក្បាល បានវាយ កុំព្យូទ័រចប់ហើយ** ( ០១.០៥.២០១០, ២៧.០៣.២០១១ ) ។

-ការដាក់ព្រះត្រៃបិដក និងអដ្ឋកថាបញ្ចូលជាមួយគ្នានោះ ដែលធ្វើសម្រេចជាស្ថាពរនោះ មានដូចខាងក្រោមនេះ គឺ

**-គម្ពីរវិន័យបិដក បានធ្វើរួចជាស្រេចហើយ មានចំនួន ១៤ ភាគ**

**-គម្ពីរទីឃនិកាយ បានធ្វើរួចជាស្រេចហើយ មានចំនួន ៦ ភាគ**

**-គម្ពីរមជ្ឈិមនិកាយ បានធ្វើរួចជាស្រេចហើយ មានចំនួន ៩ ភាគ**

**-គម្ពីរសំយុត្តនិកាយ បានធ្វើរួចជាស្រេចហើយ មានចំនួន ១១ ភាគ**

**-គម្ពីរអង្គុត្តរនិកាយ បានធ្វើរួចជាស្រេចហើយ មានចំនួន ១៣ ភាគ**

**-គម្ពីរខុទ្ទកនិកាយ ប្រែបាន ៣៧ ភាគហើយ**

សរុបការប្រែព្រះត្រៃបិដក និងអដ្ឋកថាបញ្ចូលជាមួយគ្នានោះ សព្វថ្ងៃនេះបានចំនួន ៩០ ក្បាលជាងហើយ ។

## សៀវភៅដែលប្រមូលរៀបរៀង និងបោះពុម្ពហើយដោយ
## ខ្ញុំព្រះករុណា អាត្មាភាព
## ✍ យង់ សុផាត ✍

-ជីវប្រវត្តិព្រះអសីតិមហាសាវក មាន ៨ ភាគ ពីភាគ ១ ដល់ភាគ ៨

-ជីវប្រវត្តិព្រះអសីតិមហាសាវក **មាន ៤ ភាគ** ពីភាគ ១ ដល់ភាគ ៤

-ជីវប្រវត្តិព្រះពុទ្ធសាវិកា មាន ៤ ភាគ ពីភាគ ១ ដល់ភាគ ៤

-ជីវប្រវត្តិព្រះពុទ្ធសាវិកា **មាន ២ ភាគ** ពីភាគ ១ ដល់ភាគ ២

-ជីវប្រវត្តិព្រះពុទ្ធឧបាសក មាន ៥ ភាគ ពីភាគ ១ ដល់ភាគ ៥

-ជីវប្រវត្តិព្រះពុទ្ធឧបាសក **មាន ២ ភាគ** ពីភាគ ១ ដល់ភាគ ២

-ជីវប្រវត្តិព្រះពុទ្ធឧបាសិកា **មាន ២ ភាគ** ពីភាគ ១ ដល់ភាគ ២

-រឿងរ៉ាវដែលទាកទងនឹងពុទ្ធស្ថាន **មាន ៥ ភាគ** ពីភាគ ១ ដល់ភាគ ៥

-វិសុទ្ធិមគ្គ និង បរមត្ថមញ្ជូសាមហាដីកា សីលនិទ្ទេស មាន ១ ភាគ

-វិសុទ្ធិមគ្គ និង បរមត្ថមញ្ជូសាមហាដីកា សមាធិនិទ្ទេស មាន ៤ ភាគ

-វិសុទ្ធិមគ្គ និង បរមត្ថមញ្ជូសាមហាដីកា បញ្ញានិទ្ទេស មាន ៣ ភាគ

-ជីវប្រវត្តិព្រះពុទ្ធឧបាសិកា ភាគ ១-២

-ធម៌សូធ្យនមស្ការបែបសម័យទំនើប

-គម្ពីរសារត្ថសង្គហៈ ភាគ ១

-គម្ពីរមហាសតិប្បដ្ឋានភាវនា

-ពុទ្ធប្បវត្តិ

សូមអនុមោទនាធម្មទាន !!!

## នាមពុទ្ធបរិស័ទដែលមានសទ្ធាបរិច្ចាគប្រាក់នៅសហរដ្ឋអាមេរិក ជួយបោះពុម្ពសៀវភៅនេះ

| | |
|---|---|
| ឧបាសក ជឹម អេងស្រ៊ិន ឧបាសិកា រ៉ា សុខគីន ព្រមទាំងបុត្រ<br>លោក ជឹម មុនីបុត្រ អ្នកស្រី មាស ច័ន្ទនារី ព្រមទាំងបុត្រ<br>លោក ជឹម កុលវុឌ្ឍ អ្នកស្រី ម៉ាង សូលីដា ព្រមទាំងបុត្រ<br>លោក ជឹម សុភរោ អ្នកស្រី ប៉េង វិចិត្តា ព្រមទាំងបុត្រ<br>អ្នកស្រី ជឹម ពន្ធរក្ខ ព្រមទាំងបុត្រ<br>អ្នកស្រី ជឹម ពុទ្ធារី លោក ឈុន ហ៊ី ព្រមទាំងបុត្រ<br>អ្នកស្រី ជឹម ឧសភា លោក ឡៅ ជួយ ព្រមទាំងបុត្រ<br>លោក តាន់ សុផាណា អ្នកស្រី លី គន្ធា ព្រមទាំងបុត្រ | ... ២១០០ $ |
| ឧបាសក ឡឹក ច័ន្ទជេត ព្រមទាំងបុត្រ<br>ឧបាសិកា ឡឹក ពេញចិត្ត<br>ឧបាសិកា អ៊ាប គីមអ៊ុន ព្រមទាំងបុត្រ<br>ឧបាសក អ៊ាប ហៃសាន និងភរិយា ព្រមទាំងបុត្រ<br>ឧបាសិកា សៀក ឆាយគីម<br>ឧបាសក អ៊ាប គីមស៊ុន ព្រមទាំងបុត្រ | .... ១៥០០ $ |
| ឧបាសិកា ឃី គីមលាង ព្រមទាំងកូនចៅ<br>លោក ធន គីមហួន ព្រមទាំងកូនចៅ | ... ១៥០០ $ |
| ឧបាសិកា គឹម ឡុំ ព្រមទាំងបុត្រ ............................................ | ៥០០ $ |
| ឧបាសិកា គីម ប៉ុម ព្រមទាំងបុត្រ ...................................... | ១០០ $ |
| ឧបាសិកា ព្រាម ណៃទាង ព្រមទាំងបុត្រ ............................ | ១០០ $ |
| ឧបាសិកា រ៉ាយ យ៉ានីន ព្រមទាំងបុត្រវណ្ណ ធន ....................... | ៦០ $ |

*ឧបាសិកា រ៉ា សុខគីន ឧបាសក ជឹម អេងស្រ៊ន ព្រមទាំងបុត្រ .... ៥០ $*

*ឧបាសិកា អួន ញ៉ា ព្រមទាំងបុត្រ ........................................... ៥០ $*

*ឧបាសិកា វង គីមឆេង ព្រមទាំងបុត្រ ...................................... ៥០ $*

*ឧបាសិកា ព្រាម ទាង ព្រមទាំងបុត្រ ........................................ ៥០ $*

*ឧបាសិកា គីម ឡុំ ព្រមទាំងបុត្រ ........................................... ៥០ $*

*ឧបាសិកា អ៊ុំ ច័ន្ទជួង ( អប្សរា ) ព្រមទាំងបុត្រ ......................... ៥០ $*

*ឧបាសិកា ឳន ទូច ព្រមទាំងកូនចៅ ........................................ ៥០ $*

*ឧបាសក មុត សក់ ឧបាសិកា សន្ធា វរីនមាសសុខ+ក្រុមគ្រួសារ . ៥០ $*

*ឧបាសិកា ង៉ូវ មួយឡាយ ព្រមទាំងបុត្រ ................................. ៣០ $*

*ឧបាសិកា សួស កន ព្រមទាំងបុត្រ ......................................... ៣០ $*

*ឧបាសិកា គីម ឡាង ព្រមទាំងបុត្រ ........................................ ៣០ $*

*ឧបាសិកា គីម ម៉ាលីស ព្រមទាំងបុត្រ .................................... ២០ $*

*ឧបាសិកា សា អ៊ុត ព្រមទាំងបុត្រ .......................................... ១០ $*

**បោះពុម្ពជាធម្មទាន ១000 ក្បាល**

**ក្នុងតម្លៃ ១ ក្បាល ២ ដុល្លារ**

**រោងពុម្ព រមណីយ**

TEL : 012597431

ផ្សព្វផ្សាយដោយសមាគមធម្មទានអរិយវង្សយង់សុជាត